ព្រះ
ត្រៃបិដក

ប្រែរួមនឹង
ព្រះអដ្ឋកថា

ភាគ១១

បាលីប្រែ ១៧ - ១៨

ពុទ្ធសកាជ ២៥៥៣

ច្បាប់ពិឯក្យ លើកទី២

ព្រះ
សុត្តន្តបិដក
និង
សុមង្គលវិលាសិនី អដ្ឋកថា
សេចក្តីប្រែជាភាសាខ្មែរ
ទីឃនិកាយ
ចតុត្ថភាគ ~ មហាវគ្គ
បញ្ចមភាគ ~ បាដិកវគ្គ

๑๑
បាលីប្រែ ๑๗~๑๘



ប្រោះពុម្ពលើកទី ๑ ពុទ្ធសករាជ ๒๕๕๓

ក្បាលទី ๑๑

ចតុត្ថភាគ មហាវគ្គ

មហាសុទស្សនសូត្រទី ៦

[๑] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងសាលវន ដែលជាផ្លូវបត់ចូល (ទៅកាន់ក្រុង) របស់ពួកមល្ល-ក្សត្រ នាចន្លោះនៃជើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងកាលទៀបបរិនិព្វាន ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ស៊ប់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ កុំបរិនិព្វាន ក្នុងនគរកុសិនារានេះ ដែលជានគរតូច នគរទួល ជាសាខានគរឡើយ បពិត្រព្រះអង្គដ៏ចម្រើន នគរធំៗ ឯទៀតក៏មាន ដូចយ៉ាងនគរចម្បា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី និងពារាណសី សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វានក្នុងនគរទាំងនុ៎ះវិញ (ព្រោះ) ក្នុងនគរទាំងនុ៎ះ មានខត្តិយមហាសាល ព្រាហ្មណមហាសាល និងគហបតិមហាសាល ជាច្រើននាក់ ដែលជ្រះថ្លាស៊ប់ ក្នុងព្រះតថាគត ពួកជនទាំងនោះ នឹងធ្វើការបូជាព្រះសរីរៈរបស់ព្រះតថាគត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលឋានគរនេះ ជានគរតូច នគរទួល ជាសាខានគរយ៉ាងនេះឡើយ ។

ម្នាលអានន្ទ កាលពីព្រេងនាយមក មានព្រះរាជា ទ្រង់ព្រះនាមមហាសុ-ទស្សនៈ ជាក្សត្រៀបានមុទ្ធាភិសេក (ឥស្សរៈលើផែនដី) មានមហាសមុទ្រទាំង ៤ ជាទីបំផុត ព្រះអង្គជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទ ដល់នូវសេចក្តីមាំមួន ។ ម្នាលអានន្ទ នគរកុសិនារានេះ ជារាជធានីឈ្មោះកុសាវតី របស់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ កុសាវតីរាជធានី បណ្តាយពីបុរត្ថិមទិស ទៅបច្ឆិមទិស ១២ យោជន៍ ទទឹងពីឧត្តរទិស ទៅទក្ខិណទិស ៧ យោជន៍ ជានគរស្តុកស្តម្ភ ធំទូលាយ មានជនច្រើន មានមនុស្សកុះករ ជាស្រុកមានភិក្ខាហារបរិបូណ៌ ។ ម្នាលអានន្ទ រាជធានីឈ្មោះអាលកមន្ទា របស់ពួកទេវតា ជារាជធានីដ៏ស្តុកស្តម្ភ ធំទូលាយ មានជនច្រើន មានទេវតាកុះករ ជាស្រុកមានភិក្ខាហារបរិបូណ៌ យ៉ាងណាមិញ ម្នាលអានន្ទ កុសាវតីរាជធានី ជារាជធានីដ៏ស្តុកស្តម្ភ ធំទូលាយ មានជនច្រើន មានមនុស្សកុះករ ជាស្រុកមានភិក្ខាហារបរិបូណ៌ យ៉ាងនោះដែរ ។ ម្នាលអានន្ទ កុសាវតីរាជ-ធានី ជាក្រុងកងរំពងដោយសូរសព្ទ ១០ យ៉ាង ទាំងថ្ងៃ ទាំងយប់ គឺសូរសព្ទដំរី សូរសេព្ទសេះ សូរសព្ទរថ សូរសព្ទស្មរ សូរសព្ទសង្ខារ សូរសព្ទពិណ សូរសព្ទចម្រៀង សូរសព្ទមហោស្រព សូរសព្ទប្រគំ សូរសព្ទមនុស្សនិយាយគ្នាថា អ្នកទាំងឡាយ ចូរបរិភោគទៅ ចូរផឹកទៅ ចូរស៊ីទៅ រួមជាគម្រប់ ១០ យ៉ាង ។ ម្នាលអានន្ទ កុសាវតីរាជធានី មានកំពែងព័ទ្ធជុំវិញ ៧ ជាន់ គឺកំពែងមាស ១ ជាន់ កំពែងច្រាក់ ១ ជាន់ កំពែងកែវពៃទូរ្យ ១ ជាន់ កំពែងកែវផលិក ១ ជាន់ កំពែងកែវទទឹម ១ ជាន់ កំពែង

កែវមរកត ១ ជាន់ កំពែងកែវគ្រប់យ៉ាង ១ ជាន់ ។ ម្នាលអានន្ទ កុសាវតីរាជធានី មានទ្វារ ៤ បែប គឺទ្វារមាស ១ ទ្វារប្រាក់ ១ ទ្វារកែវពៃទូរ្យ ១ ទ្វារកែវផលិក ១ ។ ក្នុងទ្វារមួយៗ គេជាំសសរគោលប្រាំពីរៗ ដើម ជាសសរមានទំហំ ៣ ជួរបុរស គេជាំចុះទៅក្នុងដីជម្រៅ ៣ ជួរបុរស កម្ពស់ពីដីឡើង ១២ ជួរបុរស ។ គឺសសរមាស ១ ដើម សសរប្រាក់ ១ ដើម សសរកែវពៃទូរ្យ ១ ដើម សសរកែវផលិក ១ ដើម សសរកែវទទឹម ១ ដើម សសរកែវមរកត ១ ដើម សសរកែវគ្រប់យ៉ាង ១ ដើម ។ ម្នាលអានន្ទ កុសាវតីរាជធានី មានជួរដើមត្នោតព័ទ្ធជុំវិញ ៧ ជាន់ គឺជួរដើមត្នោតមាស ១ ជាន់ ដើមត្នោតប្រាក់ ១ ជាន់ ដើមត្នោតកែវពៃទូរ្យ ១ ជាន់ ដើមត្នោតកែវផលិក ១ ជាន់ ដើមត្នោតកែវទទឹម ១ ជាន់ ដើមត្នោតកែវមរកត ១ ជាន់ ដើមត្នោតកែវគ្រប់យ៉ាង ១ ជាន់ ។ ត្នោតមាស ដើមជាមាស ឯស្លឹក និងផ្លែជាប្រាក់ ។ ត្នោតប្រាក់ ដើមជាប្រាក់ ឯស្លឹក និងផ្លែជាមាស ។ ត្នោតកែវពៃទូរ្យ ដើមជាកែវពៃទូរ្យ ឯស្លឹក និងផ្លែជាកែវផលិក ។ ត្នោតកែវផលិក ដើមជាកែវផលិក ឯស្លឹក និងផ្លែជាកែវពៃទូរ្យ ។ ត្នោតកែវទទឹម ដើមជាកែវទទឹម ឯស្លឹក និងផ្លែជាកែវមរកត ។ ត្នោតកែវមរកត ដើមជាកែវមរកត ឯស្លឹក និងផ្លែជាកែវទទឹម ។ ត្នោតកែវគ្រប់យ៉ាង ដើមជាកែវគ្រប់យ៉ាង ឯស្លឹក និងផ្លែជាកែវគ្រប់យ៉ាង ។ ម្នាលអានន្ទ ជួរដើមត្នោតទាំងនោះ ត្រូវខ្យល់បក់មក ក៏មានសូរសព្ទពីរោះ គួរត្រេកអរ គួរផ្ទៀងស្តាប់ គួរជក់ចិត្ត ។ ម្នាលអានន្ទ តូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលពួកអ្នកឈ្វាសវៃ

ផ្សុំ ហើយវាយឲ្យលួមពីរោះល្អ ទើបដេញដំ ប្រគំ ក៏មានសូរសព្ទពីរោះ គួរត្រេកអរ គួរផ្ទៀងស្តាប់ គួរជក់ចិត្ត មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ ឯជួរដើមត្នោតទាំងនោះ កាលត្រូវខ្យល់ បក់មក ក៏មានសូរសព្ទពីរោះ គួរត្រេកអរ គួរផ្ទៀងស្តាប់ គួរជក់ចិត្ត ក៏មានឧបមេយ្យដូច្នោះឯង ។ ម្នាលអានន្ទ សម័យនោះ ក្នុងកុសាវតីរាជធានី មានអ្នកលេងបាស្កា អ្នកលេងស៊ីជីក ពួកអ្នកលេងទាំងនោះ ក៏នាំគ្នារាំវែក លេងតាមសូរសព្ទនៃជួរដើមត្នោតដែលខ្យល់បក់មកត្រូវនោះ ។

[๒] *ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បរិបូណ៌ដោយរតន៍ ៧ ប្រការ និងដោយឫទ្ធិ ៤ យ៉ាង ។ រតន៍ ៧ ប្រការ តើដូចម្តេច ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់កក់ព្រះសិរ្សក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករតន៍ជាទិព្វ មានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ និងដុំ បរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដឡើង លុះព្រះបាទមហាសុទស្សនៈ ទ្រង់ទតឃើញហើយ ទើបត្រិះរិះដូច្នេះថា អើ អាត្មាអញ ក៏ធ្លាប់ឮរឿងនេះមកហើយថា ស្តេចអង្គណាជាក្សត្រាបានមុទ្ធាភិសេកហើយ ទ្រង់កក់ព្រះសិរ្សក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករតន៍ជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ទាំងដុំ បរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដឡើង ព្រះរាជាអង្គនោះ ជាស្តេចចក្រពត្តិ ឱហ្ន៎ អាត្មាអញ បានជាស្តេចចក្រពត្តិហើយតើ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ*

ទ្រង់ក្រោកអំពីអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ទើបយកព្រះហស្តខាងឆ្វេងចាប់ព្រះសុវណ្ណកិង្ការ (កុណ្ឌីមាស) យកព្រះហស្តខាងស្តាំប្រោះព្រំចក្កវត្តន៍ ហើយត្រាស់ថា ចក្កវត្តន៍ដ៏ចម្រើន ចូរអណ្តែងទៅ ចក្កវត្តន៍ដ៏ចម្រើន ចូរមានជ័យជម្នះ ។ ម្នាលអានន្ទ លំដាប់នោះ ចក្កវត្តន៍នោះ ឯង ក៏អណ្តែងទៅខាងបុរត្ថិមទិស ។ ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចទៅតាមក្រោយ ជាមួយនឹងសេនាប្រកបដោយអង្គ ៤ ។ ម្នាលអានន្ទ ចក្កវត្តន៍ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទមហាសុទស្សនៈ ព្រមទាំងចតុរង្គសេនា ក៏ទ្រង់ប្រថាប់ក្នុងប្រទេសនោះ ។ ម្នាលអានន្ទ ពួកស្តេចណាដែលជាសត្រូវ គង់នៅក្នុងបុរត្ថិមទិស ពួកស្តេចនោះ ក៏ស្តេចចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ស្តេចមកចុះ បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ខ្ញុំព្រះអង្គ ជារបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការយ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវលួចរបស់ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវនិយាយពាក្យកុហក មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយ ចូរបរិភោគវត្ថុតាមសមគួរចុះ ។ ម្នាលអានន្ទ មួយទៀត ពួកស្តេចណាដែលជាសត្រូវ នៅក្នុងបុរត្ថិមទិស ពួកស្តេចនោះ ក៏ទៅជាចុះចូលព្រះបាទមហាសុទស្សនៈវិញ ។ ម្នាលអានន្ទ វេលានោះ ចក្កវត្តន៍នោះ ក៏ចុះទៅកាន់សមុទ្រខាងបុរត្ថិមទិស

ហើយឆ្លងទៀង ត្រឡប់វិលទៅខាងទក្ខិណទិស ចុះកាន់សមុទ្រខាងទក្ខិណ-ទិស ហើយឆ្លងទៀងវិលទៅខាងបច្ឆិមទិស ចុះកាន់សមុទ្រខាងបច្ឆិមទិស ហើយឆ្លងទៀង វិលទៅខាងឧត្តរទិសវិញ ។ ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់ស្តេចទៅតាមក្រោយជាមួយនឹងចតុរង្គសេនា ។ ម្នាលអានន្ទ ចក្កវត្តន៍ប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់ប្រថាប់នៅក្នុងប្រទេសនោះ ព្រមទាំងចតុរង្គសេនា ។ ម្នាលអានន្ទ មួយទៀត ពួកស្តេចណា ជាសឹកសត្រូវ នៅក្នុងឧត្តរទិស ពួកស្តេចនោះ ក៏ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចមក បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជ-សម្បត្តិរបស់ខ្ញុំព្រះអង្គ ជាព្រះរាជទ្រព្យរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជ-ឱង្ការយ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវលួចរបស់ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវនិយាយពាក្យកុហក មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយ ចូរបរិភោគវត្ថុតាមសមគួរចុះ ។ ម្នាលអានន្ទ មួយវិញទៀត ពួកស្តេចណា ដែលជាសឹកសត្រូវក្នុងឧត្តរទិស ពួកស្តេចនោះ ក៏ត្រឡប់ជាចុះចូលព្រះបាទមហាសុទស្សនៈវិញ ។ ម្នាលអានន្ទ តពីនោះមក ចក្កវត្តន៍នោះបានបង្រាបផែនដី ដែលមានសមុទ្រជាទីបំផុត រួចហើយ ត្រឡប់មកកាន់កុសាវតីរាជធានីវិញ ហើយឋិតនៅក្នុងរបៀងសាលាសម្រាប់វិនិច្ឆ័យ ទៀបទ្វារព្រះបរមរាជវាំងរបស់ព្រះបាទ

មហាសុទស្សន: នៅនឹងថ្ពល់ ហាក់ដូចជាបាក់ភ្លៅ ហើយបំភ្លឺក្នុងព្រះរាជវាំងរបស់ព្រះបាទមហាសុទស្សន: ។ ម្នាលអានន្ទ ចក្ករតន៍មានសភាពយ៉ាងនេះ កើតប្រាកដឡើងដល់ព្រះបាទមហាសុទស្សន: ។

[៣] ម្នាលអានន្ទ តទៅទៀត ហត្ថិរ័តន៍ (ដំរីកែវ) ជាស្តេចដំរីឈ្មោះឧបោសថ មានសម្បុរសសុទ្ធ មានអវយវ:តូចធំ សមរម្យទាំងអស់ ជាដំរីមានឫទ្ធិ អាចហោះលើអាកាសបាន កើតប្រាកដឡើងដល់ព្រះបាទមហាសុទស្សន: ។ លុះព្រះបាទមហាសុទស្សន: ទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើ យានដំរីល្អណាស់តើហ្នឹ ប្រសិនបើចូលទៅបង្ហាត់បាន (ជាការប្រពៃ) ។ ម្នាលអានន្ទ ឯហត្ថិរ័តន៍នោះ ក៏ដល់នូវការបង្ហាត់បាន ដូចជាដំរីអាជានេយ្យដ៏ល្អ ដែលគេបង្ហាត់បានបទល្អយូរអង្វែងហើយ ។ ម្នាលអានន្ទ ព្រះបាទមាហាសុទស្សន: កាលទ្រង់នឹងល្បងមើលហត្ថិរ័តន៍នោះឯង មុនដំបូងទ្រង់ឡើងគង់ (លើហត្ថិរ័តន៍) ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រានូវផែនដី មានសមុទ្រជាទីបំផុត រួចហើយស្តេចត្រឡប់មកសោយព្រះក្រយាហារ ក្នុងវេលាព្រឹក ឯកុសាវតីរាជធានីវិញទាន់ ។ ម្នាលអានន្ទ ហត្ថិរ័តន៍ មានសភាពយ៉ាងនេះ បានកើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សន: ។

[៤] ម្នាលអានន្ទ តទៅទៀត អស្សរ័តន៍ (សេះកែវ) ជាស្តេចសេះឈ្មោះវលាហក: មានសម្បុរសសុទ្ធ មានសម្បុរត្រង់ក្បាលខ្មៅ (រលើប)

ដូចជាសម្បុរនៃក្អែក មានសក់ (សក្បុស) ដូចបណ្តូលស្មៅយ៉ាប្ញង ជាសេះមានឫទ្ធិអាចហោះទៅលើអាកាសបាន កើតប្រាកដដល់ព្រះបាទមហាសុទស្សនៈ ។ លុះព្រះបាទមហាសុទស្សនៈ ទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើ យានសេះល្អណាស់តើហ្ន៎ ប្រសិនបើចូលទៅបង្ខាត់បាន (ជាការប្រពៃ) ។ ម្នាលអានន្ទ លំដាប់នោះ អស្សរ័តន៍ ក៏ដល់នូវការបង្ខាត់បាន ដូចជាសេះអាជានេយ្យដ៏ល្អ ដែលគេបង្ខាត់បានរបៀបល្អយូរអង្វែងហើយ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់នឹងល្បងមើលអស្សរ័តន៍នោះឯង មុនដំបូង ទ្រង់ឡើងគង់លើអស្សរ័តន៍ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រាផែនដី ដែលមានសមុទ្រជាទីបំផុត រួចហើយស្តេចត្រឡប់មកសោយព្រះស្ងោយក្នុងវេលាព្រឹក ឯកុសាវតីរាជធានីវិញទាន់ ។ ម្នាលអានន្ទ អស្សរ័តន៍ មានសភាពយ៉ាងនេះ កើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។

[๕] ម្នាលអានន្ទ តទៅទៀត មណិរ័តន៍ ជាកែវពៃទូរ្យមានជាតិដ៏ល្អ មានជ្រុង ๘ ដែលជាងថ្នៃល្អហើយ មានពណ៌ថ្លាស្អាតបរិបូណ៌ដោយអាការគ្រប់យ៉ាង បានកើតប្រាកដ ដល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ មណិរ័តន៍នោះឯង មានពន្លឺផ្សាយទៅបានមួយយោជន៍ជុំវិញ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់នឹងល្បងមើលនូវមណិរ័តន៍នោះឯង មុនដំបូង ទ្រង់ប្រជុំអស់ពួកចតុរង្គសេនាមកហើយ ទ្រង់សួយកែវមណីឡើងទៅកាន់ចុងជង្គង់ ហើយទ្រង់គ្រវីទៅក្នុងទីងងឹតអំពូក្នុងរាត្រី ។

ម្នាលអានន្ទ ចំណែកអ្នកស្រុកទាំងឡាយណា ដែលនៅជិតខាង អ្នកស្រុកទាំងអស់នោះ សម្គាល់ថាជាវេលាថ្ងៃ ក៏នាំគ្នាប្រកបការងារដោយសារពន្លឺ (នៃកែវនោះឯង) ម្នាលអានន្ទ កែវមណីមានសភាពយ៉ាងនេះ បានកើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សន: ។

[๖] ម្នាលអានន្ទ តទៅទៀត ឥត្ថីរតន៍ (ស្ត្រីកែវ) មានរូបឆោមល្អ គួរឲ្យអ្នកផងពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក លើសលែងកន្ងងហួសសម្បុរស្ត្រីមនុស្ស តែមិនដល់សម្បុរទិព្វទេ បានកើតប្រាកដ ដល់ព្រះបាទមហាសុទស្សន: ។ ម្នាលអានន្ទ ឥត្ថីរតន៍នោះឯង មានកាយសម្ផស្ស (ទន់ល្បើយ) ដូចជាសម្ញីគ ឬសម្ញីកប្បាស ។ ម្នាលអានន្ទ មួយទៀត ឥត្ថីរតន៍នោះឯង កាលរដូវត្រជាក់មានខ្នងក្តៅ កាលរដូវក្តៅមានខ្នងត្រជាក់ ។ ម្នាលអានន្ទ មិនតែប៉ុណ្ណោះ ឥត្ថីរតន៍នោះឯង មានក្លិនខ្ញីមចន្ទន៍ផ្សាយចេញពីកាយ មានក្លិនផ្កាឧប្បលផ្សាយចេញអំពីមាត់ ។ ម្នាលអានន្ទ ឥត្ថីរតន៍នោះឯង ជាស្ត្រីតែងក្រោកឡើងមុនតែងអង្គុយក្រោយ យកចិត្តទុកជាក់ធ្វើអ្វីៗ ប្រព្រឹត្តត្រូវព្រះហឫទ័យ ពោលតែពាក្យជាទីពេញព្រះហឫទ័យរបស់ព្រះបាទមហាសុទស្សន: ។ ម្នាលអានន្ទ ឥត្ថីរតន៍នោះឯង សូម្បីតែចិត្ត ក៏មិនប្រព្រឹត្តកន្ងងព្រះបាទមហាសុទស្សន:ទៅហើយ ម្តេចឡើយនឹងប្រព្រឹត្តកន្ងងដោយកាយបាន ។ ម្នាលអានន្ទ ឥត្ថីរតន៍មានសភាពយ៉ាងនេះ បានកើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សន: ។

[๗] *ម្នាលអានន្ទ តទៅទៀត គហបតិរ័តន៍ (គហបតីកែវ) បានកើតប្រាកដ ដល់ព្រះបាទមហាសុទស្សនៈ ។ ឯគហបតិរ័តន៍នោះ មានទិព្វចក្ខុ កើតអំពីផលនៃកុសលកម្ម អាចមើលឃើញកំណប់ទ្រព្យ ដែលមានម្ចាស់ និងមិនមានម្ចាស់បាន ។ គហបតីនោះ ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក៏ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំមានសេចក្តីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងចាត់ចែងការដែលគួរធ្វើដោយទ្រព្យថ្វាយ ដោយព្រះរាជទ្រព្យព្រះអង្គ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់នឹងល្បងមើលគហបតិរ័តន៍នោះឯង មុនជំបូងទ្រង់ប្រថាប់លើព្រះទីនាំងនាវា សំដៅទៅកាន់ខ្សែទឹកក្នុងកណ្តាលទន្លេគង្គា ទើបទ្រង់ត្រាស់នឹងគហបតិរ័តន៍យ៉ាងនេះថា ម្នាលគហបតី យើងមានសេចក្តីត្រូវការដោយប្រាក់ និងមាស ។ គហបតីនោះ ក្រាបបង្គំទូលតបថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់អៀបនាវាទៅខាងត្រើយច្រាំងម្ខាង ។ ទ្រង់មានព្រះរាជឱង្ការថា ឱគហបតី យើងមានសេចក្តីត្រូវការតែប្រាក់ និងមាសត្រង់ទីនេះឯង ។ ម្នាលអានន្ទ លំដាប់នោះ គហបតិរ័តន៍នោះឯង យកដៃទាំងពីរលូកចុះទៅក្នុងទឹក លើកយកឆ្នាំង ដែលពេញដោយប្រាក់ និងមាស ហើយក្រាបទូលព្រះបាទមហាសុទស្សនៈថា បពិត្រមហារាជ ល្មមហើយ ប្រាក់ និងមាសប៉ុណ្ណេះ បពិត្រមហារាជ ប្រាក់ និងមាសប៉ុណ្ណេះ ល្មមធ្វើព្រះរាជកិច្ចបានហើយ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ប្រាក់ និងមាសប៉ុណ្ណេះល្មមហើយ ម្នាលគហបតី ប្រាក់ និងមាស*

ប៉ុណ្ណោះ លុមធ្វើកិច្ចបានហើយ ម្នាលគហបតី ប្រាក់ និងមាសទាំងប៉ុណ្ណោះ យើងបូជាអ្នកឯង ។ ម្នាលអានន្ទ គហបតិរតន៍ មានសភាពយ៉ាងនេះ កើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សន: ។

[៨] ម្នាលអានន្ទ តទៅទៀត បរិនាយករតន៍ (បរិនាយកកែវ) ជាបណ្ឌិតវាងវៃ មានប្រាជ្ញា អង់អាច ដើម្បីញុំាងព្រះបាទមហាសុទស្សន:ដែលខ្លួនឲ្យស្តេចចូលទៅ ឲ្យចូលទៅបាន ដើម្បីញុំាងព្រះបាទមហាសុទស្សន: ដែលខ្លួនគួរឲ្យស្តេចចេញឲ្យចេញទៅបាន ដើម្បីញុំាងព្រះបាទមហាសុទស្សន: ឲ្យតាំងធារបុគ្គលដែលគួរតាំង បានកើតប្រាកដដល់ព្រះបាទមហាសុទស្សន:។ បរិនាយករតន៍នោះ ចូលទៅគាល់ព្រះបាទមហាសុទ្សន:ហើយ ទើបក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំមានសេចក្តីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងប្រៀនប្រដៅថ្វាយ ។ ម្នាលអានន្ទ បរិនាយករតន៍ មានសភាពយ៉ាងនេះ កើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សន: ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សន: ទ្រង់ប្រកបដោយរតន៍ ៧ ប្រការនេះឯង ។

[៩] ម្នាលអានន្ទ ព្រះបាទមហាសុទស្សន: ទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាង ។ ឫទ្ធិ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលអានន្ទ ព្រះបាទមហាសុ-ទស្សន: ទ្រង់មានព្រះរូបល្អ គួរឲ្យអ្នកផងពិតមិលរមិលមើល គួរឲ្យជ្រះថ្លា ទ្រង់ប្រកបដោយព្រះឆវីវណ្ណដ៏ល្អក្រៃលែង ជាងមនុស្សទាំងឡាយឯទៀតក្នុងលោកនេះ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សន: ទ្រង់ប្រកបដោយឫទ្ធិនេះជាឫទ្ធិទី ១ ។

[๑๐] *ម្នាលអានន្ទ តទៅទៀត ព្រះបាទមហាសុទស្សនៈ មានព្រះជន្មាយុវែង ទ្រង់ឋិតនៅអស់កាលជាយូរអង្វែងក្រៃលែងជាងមនុស្សទាំងឡាយឯទៀត ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ២ ។*

[๑๑] *ម្នាលអានន្ទ តទៅទៀត ព្រះបាទមហាសុទស្សនៈ ទ្រង់មិនមានអាពាធ មិនមានទុក្ខ ប្រកបដោយភ្លើងធាតុដែលកើតអំពីកម្ម មានវិបាកស្មើគ្នា មិនត្រជាក់ពេក មិនក្តៅពេក លើសជាងមនុស្សដទៃ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ៣ ។*

[๑๒] *ម្នាលអានន្ទ តទៅទៀត ព្រះបាទមហាសុទស្សនៈ ទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្តនៃព្រាហ្មណ៍ និងគហបតីទាំងឡាយ ។ ម្នាលអានន្ទ បិតាជាទីស្រឡាញ់ពេញចិត្តនៃបុត្រទាំងឡាយ យ៉ាងណាមិញ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ជាទីស្រឡាញ់ពេញចិត្តនៃព្រាហ្មណ៍ និងគហបតីទាំងឡាយ យ៉ាងនោះដែរ ។ ម្នាលអានន្ទ ចំណែកខាងព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យ នៃព្រះបាទមហាសុទស្សនៈដែរ ។ ម្នាលអានន្ទ កូនទាំងឡាយជាទីស្រឡាញ់ពេញចិត្តនៃបិតា យ៉ាងណាមិញ ម្នាលអានន្ទ ចំណែកខាងព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យនៃព្រះបាទមហាសុទស្សនៈយ៉ាងនោះដែរ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលមុនដំបូង ទ្រង់ស្តេចទៅកាន់ឧទ្យានដោយចតុរង្គសេនា ។ ម្នាលអានន្ទ លំដាប់នោះ ព្រាហ្មណ៍*

និងគហបតីទាំងឡាយ ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំស្តេចទៅដោយរហ័សរួសរាន់ដូចខ្ញុំព្រះអង្គទាំងឡាយធ្លាប់ឃើញព្រះអង្គមក អស់កាលយូរនោះឡើយ។ ម្នាលអានន្ទ ឯព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់នឹងសារថីថា ម្នាលសារថី អ្នកកុំបររថទៅ ដោយរហ័សរួសរាន់ ដូចយើងធ្លាប់ឃើញព្រាហ្មណ៍ និងគហបតីទាំងឡាយ មកអស់កាលយូរយារនោះឡើយ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ៤ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិទាំង ៤ នេះឯង ។

[១៣] ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញកសាងស្រះបោក្ខរណីទាំង-ឡាយសុទ្ធតែ ១០០ ជួរធ្នូៗ ក្បែរចន្លោះជើមត្នោតទាំងឡាយនេះ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់កសាងស្រះបោក្ខរណីទាំងឡាយ សុទ្ធតែ ១០០ ជួរធ្នូៗ ក្បែរចន្លោះជើមត្នោតទាំងនោះ ។ ម្នាលអានន្ទ ឯស្រះបោក្ខរណីទាំងនោះឯង វិចិត្រដោយឥដ្ឋ ៤ យ៉ាង គឺឥដ្ឋមាសមួយយ៉ាង ឥដ្ឋប្រាក់មួយយ៉ាង ឥដ្ឋកែវពិទូរ្យមួយយ៉ាង ឥដ្ឋកែវផលិកមួយយ៉ាង ។ ម្នាលអានន្ទ ក្នុងស្រះបោក្ខរណីទាំងនោះ មានជណ្តើរ ៤ បែប គឺជណ្តើរមាស ១ បែប ជណ្តើរប្រាក់ ១ បែប ជណ្តើរកែវពិទូរ្យ ១ បែប ជណ្តើរកែវផលិក ១ បែប ។ ជណ្តើរមាស មានមេជាមាស តែកាំ និងក្បាលជណ្តើរជាប្រាក់ ។ ជណ្តើរប្រាក់ មានមេជាប្រាក់ តែកាំ និងក្បាលជណ្តើរជាមាស ។

ជណ្តើរកែវពៃទូរ្យ មានមេជាកែវពៃទូរ្យ តែកាំ និងក្បាលជណ្តើរជាកែវ ផលិក ។ ជណ្តើរកែវផលិក មានមេជាកែវផលិក តែកាំ និងក្បាលជណ្តើរ ជាកែវពៃទូរ្យ ។ ម្នាលអានន្ទ មួយទៀត ស្រះបោក្ខរណីទាំងនោះឯង បិទ ពាំងដោយរបង ២ ជាន់ គឺរបងមាស ១ របងប្រាក់ ១ ។ របងមាសមាន សសរបង្គោលជាមាស តែរបាររបង និងក្បាលបង្គោលរបងប្រាក់ របងប្រាក់ មានសសរបង្គោលជាប្រាក់ តែរបាររបង និងក្បាលបង្គោលរបងជាមាស ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្ក យ៉ាងនេះថា ក្នុងស្រះបោក្ខរណីទាំងនេះ គួរតែអាត្មាអញនឹងដាំដើមផ្កាទាំង នេះ គឺឧប្បល ឈូកក្រហម កុមុទៈ ឈូកស ដែលមានផ្ការីកពាល់រដូវ មិន បានឃាត់ខាំងដល់ជនទាំងពួង ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ ដាំដើមផ្កាទាំងនេះ ក្នុងស្រះបោក្ខរណីទាំងនោះ គឺឧប្បល ឈូកក្រហម កុទុមៈ ឈូកស ដែលមានផ្ការីកពាល់រដូវ មិនបានឃាត់ខាំងដល់ជនទាំងពួង ។ ម្នាល អានន្ទ គ្រានោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា បើ ដូច្នោះ គួរតែអាត្មាអញតាំងនហាបកបុរស (អ្នកផ្គូតទឹក) ទុកទៀបឆ្នេរ ស្រះបោក្ខរណីទាំងនេះ សម្រាប់ផ្គូតទឹកជនដែលមកហើយៗ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់តាំងនូវនហាបកបុរស ទុកទៀបឆ្នេរស្រះ បោក្ខរណីទាំងនោះ សម្រាប់ផ្គូតទឹកជនដែលមកហើយៗ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា បើ ដូច្នោះ គួរតែអាត្មាអញតាំងទានវត្ថុ (ភោងទាន) មានសភាពយ៉ាងនេះ

ក្បែរឆ្នេរស្រះបោក្ខរណីទាំងនេះ គឺបាយសម្រាប់អ្នកត្រូវការបាយ ទឹកសម្រាប់អ្នកត្រូវការទឹក សំពត់សម្រាប់អ្នកត្រូវការសំពត់ យានសម្រាប់អ្នកត្រូវការយាន ទីដេកសម្រាប់អ្នកត្រូវការទីដេក ស្រីសម្រាប់អ្នកត្រូវការស្រី ប្រាក់សម្រាប់អ្នកត្រូវការប្រាក់ មាសសម្រាប់អ្នកត្រូវការមាស ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បានតាំងទានវត្ថុនេះ ក្បែរឆ្នេរស្រះបោក្ខរណីទាំងនោះ គឺបាយសម្រាប់អ្នកត្រូវការបាយ ទឹកសម្រាប់អ្នកត្រូវការទឹក សំពត់សម្រាប់អ្នកត្រូវការសំពត់ យានសម្រាប់អ្នកត្រូវការយាន ទីដេកសម្រាប់អ្នកត្រូវការទីដេក ស្រីសម្រាប់អ្នកត្រូវការស្រី ប្រាក់សម្រាប់អ្នកត្រូវប្រាក់ មាសសម្រាប់អ្នកត្រូវការមាស ។

[๑๔] *ម្នាលអានន្ទ លំដាប់នោះ ព្រាហ្មណ៍ និងគហបតីទាំងឡាយ នាំយកសម្បត្តិដ៏ច្រើន ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សម្បត្តិដ៏ច្រើននេះ យើងខ្ញុំព្រះអង្គនាំមកថ្វាយចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ទទួលសម្បត្តិទាំងនោះ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ណ្ហើយកុំ សម្បត្តិដ៏ច្រើននេះ ដែលអ្នកនាំមកដើម្បីយើង ដោយពលិកម្ម ប្រកបដោយធម៌ហើយ តែទ្រព្យសម្បត្តិទាំងនោះ ចូរនៅជារបស់អ្នកទាំង-ឡាយវិញចុះ ចូរអ្នកទាំងឡាយ នាំយកពីនេះថែមទៅទៀតចុះ ។ ពួកព្រាហ្មណ៍ និងគហបតីទាំងនោះ លុះស្តេចឃាត់យ៉ាងនេះហើយ ក៏ថយចេញទៅនៅក្នុងទីដ៏សមគួរ ហើយគិតព្រមគ្នាយ៉ាងនេះថា ការដែលពួកយើងនាំយកសម្បត្តិ*

ទាំងនេះ ត្រឡប់ទៅទុកផ្ទះរបស់យើងវិញយ៉ាងនេះ មិនសមគួរដល់ពួកយើងឡើយ បើដូច្នេះ ពួកយើងគួរនាំគ្នាសាងនិវេសនដ្ឋាន ថ្វាយព្រះបាទមហាសុទស្សនៈវិញ ។ ពួកព្រាហ្មណ៍ និងគហបតីទាំងនោះ ក៏នាំគ្នាចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គនឹងនាំគ្នាសាងនិវេសន៍ថ្វាយព្រះអង្គ ។ ម្នាលអានន្ទ ឯព្រះបាទមហាសុទស្សនៈ ទ្រង់បានទទួលដោយតុណ្ហីភាព ។

[១៥] ម្នាលអានន្ទ លំដាប់នោះឯង សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ បានជ្រាបបរិវិតក្កក្នុងព្រះហឫទ័យនៃព្រះបាទមហាសុទស្សនៈ ដោយព្រះហឫទ័យនៃព្រះអង្គ ក៏ត្រាស់ហៅវិស្សកម្មទេវបុត្រមកថា ម៉ៃវិស្សកម្មទេវបុត្រជាសម្លាញ់ អ្នកចូរមកនេះ អ្នកចូរទៅនិម្មិតព្រះរាជនិវេសន៍ ឈ្មោះធម្មប្រាសាទ ថ្វាយព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ វិស្សកម្មទេវបុត្រ បានទទួលបង្គាប់របស់សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ ដោយពាក្យថា អំពើយ៉ាងនេះ ជាការចម្រើនដល់ព្រះអង្គហើយ ដូច្នេះហើយ ក៏បាត់អំពីឋានទេវតា ឈ្មោះតាវត្តិង្សមកប្រាកដក្នុងទីចំពោះភក្ត្រនៃព្រះបាទមហាសុទស្សនៈ ដូចបុរសដែលមានកម្លាំងលាដៃដែលខ្ជួនបត់ចូល ឬបត់ចូលនូវដៃដែលខ្ជួនលាចេញ ដូច្នោះឯង ។ ម្នាលអានន្ទ គ្រានោះឯង វិស្សកម្មទេវបុត្រ បានក្រាបបង្គំទូលព្រះបាទមហាសុទស្សនៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងនិម្មិតរាជនិវេសន៍ ឈ្មោះធម្មប្រាសាទថ្វាយព្រះអង្គ ។ ម្នាលអានន្ទ ឯព្រះបាទមហាសុទស្សនៈ ទ្រង់ទទួលដោយតុណ្ហីភាព ។

ម្នាលអានន្ទ វិស្សកម្មទេវបុត្រ ក៏បាននិម្មិតព្រះរាជនិវេសន៍ ឈ្មោះធម្មប្រាសាទ ថ្វាយព្រះបាទមហាសុទស្សន: ។ ម្នាលអានន្ទ ធម្មប្រាសាទបណ្តាយអំពីទិសខាងកើតទៅទិសខាងលិច ១ យោជន៍ ទទឹងអំពីទិសខាងជើង ទៅទិសខាងត្បូងកន្លះយោជន៍ ។ ម្នាលអានន្ទ ធម្មប្រាសាទ មានវត្ថុដែលវិចិត្រដោយឥដ្ឋមានបែប ៤ យ៉ាង ដោយកម្ពស់ ៣ ជួរបុរស គឺឥដ្ឋមាស ១ យ៉ាង ឥដ្ឋប្រាក់ ១ យ៉ាង ឥដ្ឋកែវពៃទូរ្យ ១ យ៉ាង ឥដ្ឋកែវផលិក ១ យ៉ាង ។ ម្នាលអានន្ទ ធម្មប្រាសាទ មានសសរ ៨៤០០០ មានបែប ៤ យ៉ាង គឺសសរមាសមួយយ៉ាង សសរប្រាក់មួយយ៉ាង សសរកែវពៃទូរ្យមួយយ៉ាង សសរកែវផលិកមួយយ៉ាង ។ ម្នាលអានន្ទ ធម្មប្រាសាទ ក្រាលដោយផែនក្តារ មានបែប ៤ យ៉ាង គឺផែនក្តារមាស ១ យ៉ាង ផែនក្តារប្រាក់ ១ យ៉ាង ផែនក្តារពៃទូរ្យ ១ យ៉ាង ផែនក្តារកែវផលិកមួយយ៉ាង ។ ម្នាលអានន្ទ ធម្មប្រាសាទ មានជណ្តើរ ២៤ មានបែប ៤ យ៉ាង គឺជណ្តើមាសមួយយ៉ាង ជណ្តើរប្រាក់មួយយ៉ាង ជណ្តើរកែវពៃទូរ្យមួយយ៉ាង ជណ្តើរកែវផលិកមួយយ៉ាង ។ ជណ្តើរមាស មេជាមាស តែកាំ និងក្បាលជណ្តើរជាប្រាក់ ។ ជណ្តើរប្រាក់ មេជាប្រាក់ តែកាំនឹងក្បាលជណ្តើរ ជាមាស ។ ជណ្តើរកែវពៃទូរ្យ មេជាកែវពៃទូរ្យ តែកាំ និងក្បាលជណ្តើរ ជាកែវផលិក ។ ជណ្តើរកែវផលិក មេជាកែវផលិក តែកាំ និងក្បាលជណ្តើរ ជាកែវពៃទូរ្យ ។ ម្នាលអានន្ទ ធម្មប្រាសាទ មានផ្ទះកំពូល ៨៤០០០ មានបែប ៤ យ៉ាង គឺផ្ទះកំពូលដែលធ្វើដោយមាសមួយយ៉ាង ធ្វើដោយប្រាក់មួយយ៉ាង ធ្វើដោយកែវ

ពែទូរ្យមួយយ៉ាង ធ្វើដោយកែវផលិកមួយយ៉ាង ។ ក្នុងផ្ទះកំពូលដែលធ្វើដោយមាស មានតែងតាំងបល្ល័ង្កប្រាក់ ។ ក្នុងផ្ទះកំពូល ដែលធ្វើដោយប្រាក់ មានតែងតាំងបល្ល័ង្កមាស ។ ក្នុងផ្ទះកំពូលដែលធ្វើដោយកែវពែទូរ្យ មានតែងតាំងបល្ល័ង្កភ្លុក ។ ក្នុងផ្ទះកំពូលដែលធ្វើដោយ កែវផលិក មានតែងតាំងបល្ល័ង្កកែវមរកត ។ មានជើមគ្នោតប្រាក់ បិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយមាស ឯគ្នោតនោះ មានជើមជាប្រាក់ តែស្បឹក និងផ្ទៃជាមាស ។ មានជើមគ្នោតមាស បិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយប្រាក់ ឯគ្នោតនោះ មានជើមជាមាស តែស្បឹក និងផ្ទៃជាប្រាក់ ។ មានជើមគ្នោតកែវផលិក បិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយកែវពែទូរ្យ ឯគ្នោតនោះ មានជើមជាកែវផលិក តែស្បឹក និងផ្ទៃជាកែវពែទូរ្យ ។ មានជើមគ្នោតកែវពែទូរ្យ បិតនៅជិតទ្វារផ្ទះកំពូល ដែលធ្វើដោយកែវផលិក ឯគ្នោតនោះ មានជើមជាកែវពែទូរ្យ តែស្បឹក និងផ្ទៃជាកែវផលិក ។

[១៦] ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈទ្រង់មានបរិវិតក្កយ៉ាងនេះថា បើដូច្នោះ មានតែអាត្មាអញ សាងច្បារគ្នោតមាសសុទ្ធ ជិវទ្វារនៃផ្ទះកំពូលដែលធ្វើដោយប្រាក់ ត្រង់កន្លែងដែលអាត្មាអញនឹងអង្គុយក្នុងវេលាថ្ងៃ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បានសាងច្បារគ្នោតមាសសុទ្ធ ជិតទ្វារនៃផ្ទះកំពូលដែលធ្វើដោយប្រាក់ ត្រង់កន្លែងដែលស្តេចគង់ក្នុងវេលាថ្ងៃ ។ ម្នាលអានន្ទ ធម្មប្រាសាទបិទបាំងដោយរបង ២ ជាន់ គឺរបងមាស ១ ជាន់ របងប្រាក់ ១ ជាន់ ។ របងមាសមានសសរ

បង្គោលជាមាស តែរបាររបង និងក្បាលបង្គោលរបងជាប្រាក់ ។ របងប្រាក់ មានសសរបង្គោលជាប្រាក់ តែរបាររបង និងក្បាលបង្គោលរបងជាមាស ។ ម្នាលអានន្ទ ធម្មប្រាសាទបិទបាំងដោយបណ្តាញនៃកណ្តឹង ២ យ៉ាង គឺ បណ្តាញមាស ១ យ៉ាង បណ្តាញប្រាក់ ១ យ៉ាង ។ បណ្តាញមាស កណ្តឹងជាប្រាក់ ។ បណ្តាញប្រាក់កណ្តឹងជាមាស ។ ម្នាលអានន្ទ បណ្តាញកណ្តឹងទាំងនោះ កាលបើត្រូវខ្យល់បក់មក ក៏មានសំឡេងពីរោះ គួរត្រេកអរ គួរផ្ទៀងត្រចៀកស្តាប់ គួរជក់ចិត្ត ។ ម្នាលអានន្ទ តន្ត្រីប្រកបដោយអង្គ ៥ ដែលមនុស្សអ្នកឈ្វាសវៃផ្សុំហើយ វាយឲ្យលួមពីរោះល្អ ទើបដេញដំប្រគំដ៏មានសំឡេងពីរោះ គួរត្រេកអរ គួរផ្ទៀងត្រចៀកស្តាប់ គួរជក់ចិត្ត មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ បណ្តាញកណ្តឹងទាំងនោះ ដែលខ្យល់បក់មកត្រូវ ក៏មានសំឡេងនោះពីរោះ គួរត្រេកអរ គួរផ្ទៀងត្រចៀកស្តាប់ គួរជក់ចិត្ត ដូច្នោះឯង ។ ម្នាលអានន្ទ ក្នុងសម័យនោះឯង កុសាវតីរាជធានីមានអ្នកលេងល្បែងបាស្តា និងអ្នកលេងស៊ីផឹក ពួកអ្នកលេងទាំងនោះ ក៏នាំគ្នាលេងរាំរែក តាមសំឡេងបណ្តាញកណ្តឹង ដែលខ្យល់បក់មកត្រូវទាំងនោះ ។ ម្នាលអានន្ទ លុះធម្មប្រាសាទសម្រេចហើយ លំបាកនឹងមើលបានអ្នកមើល រមែងពិលភ្នែក ។ ម្នាលអានន្ទ កាលដល់សរទសម័យ ខែខាងចុងនៃវស្សានរដូវ មេឃភ្លឺត្រចះចូលមកស៊ប់ពេញទី អាកាសផាត់ ភ្លៀងស្រឡះហើយ ព្រះអាទិត្យក៏ភ្លឺចាំងច្បាស់ឮដ៏អាកាស លំបាកនឹងមើលបានអ្នកមើលរមែងពិលភ្នែក យ៉ាងណាមិញ ម្នាលអានន្ទ ធម្មប្រាសាទ ដែល

លំបាកនឹងមើលបាន អ្នកមើលតែងពិលភ្នែកក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញសាងស្រះឈ្មោះធម្មបោក្ខរណី ខាងមុខធម្មប្រាសាទ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់សាងស្រះឈ្មោះធម្មបោក្ខរណីខាងមុខធម្មប្រាសាទ ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី បណ្តាយពីខាងកើតទៅខាងលិច ១ យោជន៍ ទទឹងពីខាងជើងទៅខាងត្បូងក៏នុះយោជន៍ ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី វិចិត្រដោយឥដ្ឋមានបែប ៤ យ៉ាង គឺឥដ្ឋមាស ១ យ៉ាង ប្រាក់ ១ យ៉ាង កែវពៃទូរ្យ ១ យ៉ាង កែវផលិក ១ យ៉ាង ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី មានជណ្តើរ ២៤ មានបែប ៤ យ៉ាង គឺជណ្តើរមាស ១ យ៉ាង ប្រាក់ ១ យ៉ាង កែវពៃទូរ្យ ១ យ៉ាង ផលិក ១ យ៉ាង ។ ជណ្តើរមាស មេជាមាស តែកាំ និងក្បាលជណ្តើរជាប្រាក់ ។ ជណ្តើរប្រាក់ មេជាប្រាក់ តែកាំ និងក្បាលជណ្តើរជាមាស ។ ជណ្តើរកែវពៃទូរ្យមេជាកែវពៃទូរ្យ តែកាំ និងក្បាលជណ្តើរជាកែវផលិក ។ ជណ្តើរកែវផលិក មេជាកែវផលិក តែកាំ និងក្បាលជណ្តើរជាកែវពៃទូរ្យ ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី បិទបាំងដោយរបង ២ ជាន់ គឺរបងមាស ១ ជាន់ របងប្រាក់ ១ ជាន់ ។ របងមាស មានសសរបង្គោលជាមាស តែរបាររបង និងក្បាលបង្គោលនៃរបងជាប្រាក់ ។ របងប្រាក់ មានសសរបង្គោលរបងជាប្រាក់ តែរបាររបង និងក្បាលរបងជាមាស ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី បិទបាំងដោយជួរ ដើមត្នោត ៧ ជាន់ ជួរដើមត្នោតមាស ១ ជាន់ ជួរដើមត្នោត

ប្រាក់ ๑ ជាន់ ជួរដើមត្នោតកែវពៃទូរ្យ ๑ ជាន់ ជួរដើមត្នោតកែវផលិក ๑ ជាន់ ជួរដើមត្នោតកែវទទឹម ๑ ជាន់ ជួរដើមត្នោតកែវមរកត ๑ ជាន់ ជួរដើមត្នោតកែវគ្រប់យ៉ាង ๑ ជាន់ ។ ត្នោតមាស ដើមជាមាស តែស្លឹក និងផ្លែជាប្រាក់ ។ ត្នោតប្រាក់ ដើមជាប្រាក់ តែស្លឹក និងផ្លែជាមាស ។ ត្នោតកែវពៃទូរ្យ ដើមជាកែវពៃទូរ្យ តែស្លឹក និងផ្លែជាកែវផលិក ។ ត្នោតកែវផលិក ដើមជាកែវផលិក តែស្លឹក និងផ្លែជាកែវពៃទូរ្យ ។ ត្នោតកែវទទឹម ដើមជាកែវទទឹម តែស្លឹក និងផ្លែជាកែវមរតក ។ ត្នោតកែវមរកត ដើមជាកែវមរកត តែស្លឹក និងផ្លែជាកែវទទឹម ។ ត្នោតកែវគ្រប់យ៉ាង ដើមជាកែវគ្រប់យ៉ាង ឯស្លឹក និងផ្លែជាកែវគ្រប់យ៉ាង ។ ម្នាលអានន្ទ ជួរត្នោតទាំងនោះឯង កាលបើមានខ្យល់បក់មកត្រូវ មានសំឡេងពីរោះ គួរត្រេកអរ គួរផ្អៀងត្រចៀកស្តាប់ គួរជក់ចិត្ត ។ ម្នាលអានន្ទ តន្ត្រីប្រកបដោយអង្គ ៥ ដែលមនុស្សឈ្វាសវៃបានផ្សំហើយ វាយឲ្យលួមពីរោះល្អ ទើបដេញដំប្រគំ មានសំឡេងពីរោះ គួរត្រេកអរ គួរផ្អៀងត្រចៀកស្តាប់ គួរជក់ចិត្ត មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ ជួរត្នោតទាំងនោះឯង កាលបើមានខ្យល់បក់មកត្រូវក៏មានសំឡេងពីរោះ គួរត្រេកអរ គួរផ្អៀងត្រចៀកស្តាប់ គួរជក់ចិត្ត យ៉ាងនោះដែរ ។ ម្នាលអានន្ទ ក្នុងសម័យនោះឯង កុសាវតីរាជធានី មានអ្នកលេងល្បែងបាស្តា និងអ្នកលេងស៊ីផឹក ឯពួកអ្នកលេងទាំងនោះ នាំគ្នារាំរែកតាមសំឡេងនៃជួរដើមត្នោតដែលមានខ្យល់បក់មកត្រូវទាំងនោះ។ ម្នាលអានន្ទ លុះដល់ធម្មប្រាសាទ និងស្រះធម្មបោក្ខរណីសម្រេចហើយ ព្រះបាទមហា-

សុទស្សនៈ ទ្រង់និមន្តពួកសមណព្រាហ្មណ៍ ដែលសន្មតថាជាសមណៈ ថាជាព្រាហ្មណ៍ ក្នុង សម័យនោះឯង ឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយពេញចំណង់ ហើយស្តេចឡើងកាន់ធម្មប្រាសាទ ។

បឋមភាណវារ ។

[๑๗] *ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាផលនៃកម្មរបស់អាត្មាអញ ដូចម្តេចហ្ន៎ ជាវិបាកនៃកម្មរបស់អាត្មាអញ ដូចម្តេចហ្ន៎ បានជាឥឡូវនេះ អាត្មាអញមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា នេះជាផលនៃកម្ម ๓ យ៉ាង ជាវិបាកនៃកម្ម ๓ យ៉ាងរបស់អាត្មាអញ បានជាឥឡូវនេះ អាត្មាអញមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ កម្ម ๓ យ៉ាងនោះ គឺ ទាន (ការឲ្យ) ๑ ទមៈ (ការទូន្មានខ្លួន) ๑ សញ្ញមៈ (ការសង្រួមក្នុងសីល) ๑ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចចូលទៅកាន់កូដាគារដ្ឋាន (ផ្ទះមានកំពូល) ជ្រាក់ លុះស្តេចទៅដល់ហើយ ទ្រង់ប្រថាប់ទៀបទ្វារ នៃកូដាគារដ្ឋានជ្រាក់ ទ្រង់បន្ទឺឧទានវាចាថា នែកាមវិតក្ក ព្យាបាទវិតក្ក និងវិហឹសាវិតក្ក អ្នកចូរឈប់ចុះ នែកាមវិតក្ក ព្យាបាទវិតក្ក និងវិហឹសាវិតក្ក លួមប៉ុណ្ណឹងហើយ ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចចូលទៅកាន់កូដាគារដ្ឋានជ្រាក់ ទ្រង់គង់លើបល្ល័ង្កមាស លុះស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាក

អកុសលធម៌ទាំងឡាយហើយ ទ្រង់ចូរកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក
វិចារ: មានបីតិ និងសុខ ដែលកើតអំពីវិវេក លុះទ្រង់រម្ងាប់វិតក្កវិចារ:ហើយ
ទ្រង់ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតជាក់ច្បាស់ក្នុងខ្លួន ប្រកបដោយសេចក្តី
ជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ:ឡើយ មាន
តែបីតិ និងសុខ ដែលកើតពីសមាធិ ព្រោះប្រាសចាកបីតិផង មានឧបេក្ខា
មានសតិសម្បជញ្ញ:ផង ទទួលសេចក្តីសុខ ដោយនាមកាយផង ទើបទ្រង់
ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយ:ទាំងឡាយពោលទុកថា បុគ្គលអ្នក
មានឧបេក្ខា មានសតិ មានប្រក្រតីនៅជាសុខ ទ្រង់ចូលកាន់ចតុត្ថជ្ឈាន ដែល
មិនមានទុក្ខ មិនមានសុខ មានតែឧបេក្ខា និងសតិដ៏បរិសុទ្ធ ព្រោះកិរិយា
លះបង់នូវទុក្ខ និងសុខ ព្រោះកិរិយាវិនាសទៅនៃសោមនស្ស និងទោសម-
នស្សក្នុងកាលមុន ។

[១៨] ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សន: ទ្រង់
ស្តេចចេញពីកូដាគារដ្ឋានប្រាក់ ហើយស្តេចចូលទៅកាន់កូដាគារដ្ឋានមាស
ទ្រង់គង់លើបល្ល័ង្កប្រាក់ មានព្រះហប្ចទ័យប្រកបដោយមេត្តា ផ្សាយទៅកាន់
ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗ គ្នា ។ ទ្រង់មានព្រះ
ហប្ចទ័យប្រកបដោយមេត្តាធំទូលាយ ជាមហគ្គត: គឺរូបាវចរ និងអរូបាវចរ
ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែល
មានសត្វទាំងអស់ដោយយកខ្លួនឯង ប្រៀបនឹងសត្វទាំងអស់ ក្នុងទិសទាំង
ពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយប្រការ

ដូច្នេះ ។ ទ្រង់មានព្រះហឫទ័យប្រកបដោយករុណា ។ ទ្រង់មានព្រះហឫទ័យ ប្រកបដោយមុទិតា ។ ទ្រង់មានព្រះហឫទ័យ ប្រកបដោយឧបេក្ខា ផ្សាយ ទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗ គ្នា ។ ទ្រង់មាន ព្រះហឫទ័យ ប្រកបដោយឧបេក្ខា ជាធម្មជាតធំទូលាយ ជាមហគ្គតៈ មាន ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែល មានសត្វទាំងអស់ ដោយយកខ្លួនឯង ប្រៀបនឹងសត្វទាំងអស់ ក្នុងទិស ទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយ ប្រការដូច្នេះ ។

[១៩] ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់មាននគរ ៨៤០០០ មានកុសាវតីរាជធានីជាប្រធាន ទ្រង់មានប្រាសាទ ៨៤០០០ មាន ធម្មប្រាសាទជាប្រធាន ទ្រង់មានប្រាសាទកំពូល ៨៤០០០ មានកូដាគារដ្ឋាន ប្រាសាទជាប្រធាន ទ្រង់មានបល្ល័ង្ក ៨៤០០០ សុទ្ធសឹងជាមាស ប្រាក់ ភ្នុក កែវមរកត ដែលក្រាលដោយសំពត់ធ្វើពីរោមសត្វ មានរូបសត្វសាហាវ ក្រាលដោយសំពត់ធ្វើពីរោមសត្វមានពណ៌ស ក្រាលដោយសំពត់ ធ្វើពីរោម សត្វ មានផ្ការចង្កោម ក្រាលដោយកម្រាលស្បែកប្រើសយ៉ាងល្អ មានខ្នើយ ពណ៌ក្រហមទាំងសងខាង ព្រមទាំងមានពិតានក៏ពណ៌ក្រហមទាំងសងខាង ទ្រង់មានជ័រ ៨៤០០០ មានជ័រឈ្មោះឧបោសថនាគរាជជាប្រធាន សឹងមាន គ្រឿងអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស ទ្រង់មាន សេះ ៨៤០០០ មានសេះឈ្មោះវលាហកអស្សរាជជាប្រធាន សឹងមានគ្រឿង

អលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស ទ្រង់មានរថ ๘๔๐๐๐ មានវេជយ័ន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស ទ្រង់មានកែវមណី ๘๔๐๐๐ មានមណិរតន៍ជាប្រធាន ទ្រង់មានស្ត្រី ๘๔๐๐๐ មាននាងសុភទ្ទាទេវីជាប្រធាន ទ្រង់មានគហបតី ๘๔๐๐๐ មានគហបតិរតន៍ជាប្រធាន ទ្រង់មានក្សត្រិយ៍ ๘๔๐๐๐ ជាអ្នកចុះចូល មានបរិនាយករតន៍ជាប្រធាន ទ្រង់មានមេគោ ๘๔๐๐๐ សម្រាប់រឺតបង្ហូរ (យកទឹកដោះ) មានកាជន៍សីទិសម្រាប់ត្រេង ទ្រង់មានសំពត់ ๘๔๐๐๐ កោដិ សុទ្ធតែជាសំពត់ដែលត្បាញដោយសម្បកឈើ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិតសំពត់ធ្វើដោយសូត្រមានសាច់ដ៏ល្អិត សំពត់កម្ពល គឺសំពត់ត្បាញដោយរោមសត្វមានសាច់ដ៏ល្អិត ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់មានកាជន៍ក្រយាស្វាយ ๘๔๐๐๐ ដែលពួកពិសេសនាំយកមកថ្វាយទាំងល្ងាចទាំងព្រឹក ។

[๒๐] *ម្នាលអានន្ទ សម័យនោះឯង ជីរៈ ๘๔๐๐๐ តែងនាំគ្នាទៅកាន់ទីបម្រើព្រះបាទមហាសុទស្សនៈ ទាំងល្ងាច ទាំងព្រឹក ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់បរិវិតក្កយ៉ាងនេះថា ជីរៈទាំង ๘๔๐๐๐ នេះឯង តែងនាំគ្នាមកកាន់ទីបម្រើអញ ទាំងល្ងាច ទាំងព្រឹក បើដូច្នោះ លុះកាលកន្លងទៅបាន ๑๐๐ ឆ្នាំៗ សឹមឲ្យជីរៈ ๔๒๐๐๐ៗ មកកាន់*

ទីបម្រើ (អាត្មាអញ) ម្តងៗ ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់ហៅបរិនាយករតនៈមកថា ម្នាលបរិនាយករតន៍សម្ងាញ់ ជីវិ ៨៤០០០ នេះឯង តែងនាំគ្នាមកកាន់ទីបម្រើយើង ទាំងល្ងាចទាំងព្រឹក ម្នាលបរិនាយករតន៍សម្ងាញ់ បើដូច្នោះ លុះកាលកន្លងទៅបាន ១០០ ឆ្នាំៗ សឹមឲ្យជីវិ ៤២០០០ៗ មកកាន់ទីបម្រើយើងម្តងៗ ចុះ ។ ម្នាលអានន្ទ បរិនាយករតន៍ បានទទួលព្រះរាជឱង្ការនៃព្រះបាទមហាសុទស្សនៈថា ព្រះករុណាថ្លៃវិសេស ។ ម្នាលអានន្ទ សម័យខាងក្រោយមក លុះកាលកន្លងទៅ ១០០ ឆ្នាំៗ ។ ជីវិ ៤២០០០ៗ ក៏នាំគ្នាមកកាន់ទីបម្រើព្រះបាទមហាសុទស្សនៈម្តងៗ ។ ម្នាលអានន្ទ លុះកាលកន្លងទៅច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ព្រះនាងសុភទ្ទាទេវី ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញខានឃើញព្រះបាទមហាសុទស្សនៈ អស់កាលយូរមកហើយ បើដូច្នោះគួរតែអាត្មាអញចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ព្រះនាងត្រាស់ហៅ (ពួក) ស្រីស្នំថា នាងទាំង-ឡាយ ចូរមក ចូរកក់ក្បាល ចូរដណ្តប់សំពត់ពណ៌លឿង យើងខានបានឃើញព្រះបាទមហាសុទស្សនៈ អស់កាលយូរមកហើយ យើងគួរនឹងចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ពួកស្រីស្នំ ក៏បានទទួលព្រះរាជសារនីយ៍នៃព្រះនាងសុភទ្ទាទេវីថា ព្រះនាងម្ចាស់ យ៉ាងនោះមែនហើយ ដូច្នេះហើយ ក៏កក់ក្បាល ដណ្តប់សំពត់ពណ៌លឿង ដើរចូលទៅត្រង់ទីដែលព្រះនាងសុភទ្ទាទេវីគង់នៅ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី

ទ្រង់ត្រាស់ហៅបរិនាយករតន៍មកថា ម្នាលបរិនាយករតន៍សម្ងាញ់ អ្នកចូរ
ទៅរៀបចំចតុរង្គសេនា (ឲ្យយើង) ដ្បិតយើងខានបានជួបព្រះបាទមហា-
សុទស្សនៈ អស់កាលយូរហើយ យើងនឹងចូលទៅគាល់ ដើម្បីនឹងឲ្យបាន
ជួបព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ បរិនាយករតន៍ ទទួលព្រះ
រាជសាវនីយ៍របស់ព្រះនាងសុភទ្ទាទេវីថា បពិត្រព្រះរាជទេវី យ៉ាងនេះហើយ
ក៏រៀបចំចតុរង្គសេនា ហើយក្រាបទូលព្រះនាងសុភទ្ទាទេវីថា បពិត្រព្រះទេវី
ចតុរង្គសេនារបស់ព្រះនាង ខ្ញុំព្រះអង្គរៀបចំស្រេចហើយ ឥឡូវនេះ សូម
ព្រះនាងសម្គាល់នូវកាលដែលគួរនឹងព្រះនាងចុះ ។ ម្នាលអានន្ទ លំដាប់នោះ
ព្រះនាងសុភទ្ទាទេវី មួយអន្ទើដោយចតុរង្គសេនា និង (ពួក) ស្រីស្នំ
ព្រះនាងសំដៅទៅរកធម្មប្រាសាទ លុះព្រះនាងចូលទៅដល់ហើយ ក៏ឡើង
ទៅកាន់ធម្មប្រាសាទ ហើយព្រះនាងចូលសំដៅទៅរកកូដាគារដ្ឋានប្រាក់ លុះ
ចូលទៅដល់ហើយ ក៏ព្រះនាងព្រះសណ្ដិតគោងមេទ្វារនៃកូដាគារដ្ឋានប្រាក់ ។
ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់ឮសូរសព្ទនោះ
ហើយ ទើបទ្រង់ត្រាស់ថា សំឡេងនោះ ដូចជាសំឡេងពួកជនច្រើននាក់ឬហ្ន៎
ហើយទ្រង់ស្តេចចេញពីកូដាគារដ្ឋានប្រាក់ ទ្រង់ទតទៅឃើញព្រះនាងសុភទ្ទា
ទេវី កំពុងតែទ្រង់ព្រះសណ្ដិតគោងមេទ្វារ លុះទតឃើញហើយ ទ្រង់មាន
ព្រះរាជឱង្ការ នឹងព្រះនាងសុភទ្ទាទេវីថា នែនាងទេវី ចូរនាងបង្អង់នៅទីនុ៎ះ
សិន នាងកុំអាលចូលមក ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុ-
ទស្សនៈ ទ្រង់ត្រាស់ហៅបុរសម្នាក់មកថា ម្នាលបុរស អ្នកចូរមកនេះ ចូរទៅ

នាំយកបល្ល័ង្កមាសអំពីកូដាគារដ្ឋានប្រាក់ ទៅតាំងក្នុងតាលវន (ព្រៃត្នោត) សុទ្ធតែមាស ។ ម្នាលអានន្ទ បុរសនោះ បានទទួលព្រះរាជឱង្ការនៃព្រះបាទមហាសុទស្សនៈថា ព្រះករុណាថ្លៃវិសេស ដូច្នេះហើយ ក៏នាំយកបល្ល័ង្កមាស ចេញពីកូដាគារដ្ឋានប្រាក់ ទៅតាំងនៅក្នុងតាលវន សុទ្ធតែមាស ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់សម្រេចសីហសេយ្យាដោយខាងស្តាំ ទ្រង់តម្រួតព្រះបាទលើគ្នា ទ្រង់មានព្រះសតិសម្បជញ្ញៈ ។

[๒๑] ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា ឥន្ទ្រិយរបស់ព្រះបាទមហាសុទស្សនៈ ថ្លាស្អាតណាស់តើ ព្រះឆវីវណ្ណផូរផង់ សូមព្រះបាទមហាសុទស្សនៈ កុំទិវង្គតឡើយ ។ ទើបព្រះនាងសុភទ្ទាទេវី ក្រាបបង្គំទូលសេចក្តីនោះ នឹងព្រះបាទមហាសុទស្សនៈថា បពិត្រព្រះសម្មតិទេព នគរទាំង ៨៤០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានីជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្គើតនូវសេចក្តីស្រឡាញ់ ចំពោះនគរទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ប្រាសាទ ៨៤០០០ របស់ព្រះអង្គនេះ មានធម្មប្រាសាទជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្គើតនូវសេចក្តីស្រឡាញ់ចំពោះប្រាសាទទាំងនោះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព កូដាគារប្រាសាទ ៨៤០០០ របស់ព្រះអង្គ មានប្រាសាទឈ្មោះកូដាគារដ្ឋានប្រាក់ជាប្រធាន បពិត្រព្រះ

สมฺมติเทว สูมព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះកូដាគារដ្ឋានប្រាក់ ទាំងនុ៎ះ សូមព្រះអង្គទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះ សម្មតិទេព បល្ង័ង្ក ៨៤០០០ របស់ព្រះអង្គនេះ ជាបល្ង័ង្កមាស ប្រាក់ ភ្នុក កែវមរកត ដែលក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានរូបសត្វសាហាវ ក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានពណ៌ស ក្រាលដោយសំពត់ធ្វើ ដោយរោមសត្វ មានផ្កាចង្កោម ក្រាលដោយកម្រាលស្បែកប្រើសយ៉ាងល្អ មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងមានពិតាន ក៏ពណ៌ក្រហមដូច គ្នា បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះ បល្ង័ង្កទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិ-ទេព ដំរី ៨៤០០០ របស់ព្រះអង្គនេះ មានដំរីឈ្មោះឧបោសថនាគរាជ ជា ប្រធាន សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះដំរីទាំង នុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព សេះ ៨៤០០០ របស់ព្រះអង្គនេះ មានសេះឈ្មោះវលាហកអស្សរាជជាប្រធាន សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រ ព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ចំពោះសេះទាំងនុ៎ះ សូម ទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព រថ ៨៤០០០ របស់ព្រះអង្គនេះ មានវេជយ្យន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ស្បែកខ្លាំធំ ស្បែកខ្លាំដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មាន

អលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ចំពោះរាជរថទាំងនោះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព កែវមណី ៨៤០០០ របស់ព្រះអង្គទាំងនេះ មានមណិរតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះមណិរតនៈទាំងនោះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ស្ត្រី ៨៤០០០ របស់អង្គនេះ មានឥត្ថីរតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ចំពោះស្ត្រីទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព គហបតី ៨៤០០០ របស់ព្រះអង្គនេះ មានគហបតិរតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ចំពោះគហបតីទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ពួកក្សត្រិយ៍ ៨៤០០០ នេះ សុទ្ធតែជាអ្នកចុះចូលព្រះអង្គ មានបរិនាយករតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ចំពោះពួកក្សត្រិយ៍ទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព មេគោ ៨៤០០០ សម្រាប់រឹតបង្ហូរយកទឹកដោះរបស់ព្រះអង្គនេះ មានកាជន៍សីទ្ធិសម្រាប់ត្រង បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ចំពោះមេគោទាំងនោះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព សំពត់ ៨៤០០០ កោដិ របស់ព្រះអង្គទាំងនេះ ជាសំពត់ដែលត្បាញដោយសម្បកឈើ មាន

សាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់កម្ពល គឺសំពត់ដែលត្បាញដោយរោមសត្វ មានសាច់ដ៏ល្អិត បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ចំពោះសំពត់ទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព កាជន៍ក្រយៅស្វាយ ៨៤០០០ របស់ព្រះអង្គទាំងនេះ ដែលពួកពិសេសនាំយកមកថ្វាយ ទាំងល្ងាច ទាំងព្រឹក បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះកាជន៍ក្រយៅស្វាយទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត ។ ម្នាលអានន្ទ កាលបើព្រះនាងសុភទ្ទាទេវីក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការនឹងព្រះនាងសុភទ្ទាទេវីថា ម្នាលនាងទេវី នាងថ្លែងរៀបរាប់ដោយវត្ថុទាំងឡាយ ជាទីជ្រុះថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ចំពោះយើងអស់រាត្រីយូរហើយ តទៅខាងក្រោយ នាងនឹងថ្លែងរៀបរាប់ដោយវត្ថុទាំង-ឡាយ មិនជាទីជ្រុះថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តចំពោះយើងវិញ ។ ព្រះនាងសុភទ្ទាទេវីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ចុះឲ្យខ្ញុំម្ចាស់រៀបរាប់ចំពោះព្រះអង្គដោយប្រការដូចម្តេចវិញ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់ថា ម្នាលនាងទេវី ចូរនាងថ្លែងរៀបរាប់នឹងយើងយ៉ាងនេះវិញថា សេចក្តីវិនាស សេចក្តីព្រាត់ប្រាស និងសេចក្តីឃ្លៀងឃ្លាតចាកសត្វ និងសង្ខារទាំងពួងដែលជាទីស្រឡាញ់ ជាទីពេញចិត្ត (រមែងមានដល់ព្រះអង្គ) បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំទិវង្គត ប្រកបដោយសេចក្តីអាល័យ

ទ្បើយ (ព្រោះថា) កាលកិរិយារបស់បុគ្គលដែលមានសេចក្តីអាល័យ តែង នាំមកនូវសេចក្តីទុក្ខ មួយទៀត កាលកិរិយារបស់បុគ្គលដែលមានសេចក្តី អាល័យ អ្នកប្រាជ្ញតែងតិះដៀល បពិត្រព្រះសម្មតិទេព ឯនគរ ៨៤០០០ របស់ព្រះអង្គទាំងនេះ មាននគរកុសាវតីរាជធានីជាប្រធាន បពិត្រព្រះ សម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ចំពោះនគរទាំងនុ៎ះចេញ សូម ទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតទ្បើយ បពិត្រព្រះសម្មតិទេព ប្រា- សាទ ៨៤០០០ របស់ព្រះអង្គទាំងនេះ ។បេ។ សូមទ្រង់កុំធ្វើនូវសេចក្តី អាល័យក្នុងព្រះជីវិតទ្បើយ បពិត្រព្រះសម្មតិទេព កូដាគារដ្ឋាន ៨៤០០០ របស់ព្រះអង្គនេះ ។បេ។ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតទ្បើយ បពិត្រព្រះសម្មតិទេព បល្ល័ង្ក ៨៤០០០ របស់ព្រះអង្គនេះ សុទ្ធសឹងតែមាស ប្រាក់ ភ្លុក កែវមរកត ក្រាលដោយសំពត់ធ្វើដោយរោមសត្វសាហាវ ក្រាល ដោយសំពត់ធ្វើដោយរោមសត្វមានពណ៌ស ក្រាលដោយសំពត់ ធ្វើដោយ រោមសត្វ មានផ្ការចង្កោម ក្រាលដោយកម្រាលដ៏ល្អ ដែលធ្វើដោយស្បែក ប្រើស មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងពិតានពណ៌ក្រហម ទាំងសងខាង បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ ចំពោះបល្ល័ង្កទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត ទ្បើយ បពិត្រព្រះសម្មតិទេព ជីរ ៨៤០០០ របស់ព្រះអង្គនេះ មានជីរ ឈ្មោះឧបោសថនាគរាជជាប្រធាន សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវ

សេចក្តីស្រឡាញ់ក្នុងជីវិតទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សេះ ៨៤០០០ របស់ព្រះអង្គនេះ មានសេះឈ្មោះវលាហកអស្សរាជជាប្រធាន សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ចំពោះសេះទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព រាជរថ ៨៤០០០ របស់ព្រះអង្គនេះ មានវេជយ័ន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ដោយស្បែកខ្លាំធំ ដោយស្បែកខ្លាដំបង ដោយសំពត់កម្ពល មានពណ៌លឿង សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ ចំពោះរាជរថទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កែវមណី ៨៤០០០ របស់ព្រះអង្គនេះ មានមណិរតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ ចំពោះកែវមណីទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ស្ត្រី ៨៤០០០ របស់ព្រះអង្គនេះ មានព្រះនាងសុភទ្រាទេវី ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះស្ត្រីទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព គហបតី ៨៤០០០ របស់ព្រះអង្គនេះ មានគហបតិរតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់

ចំពោះគហបតីទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកក្សត្រិយ៍ ៨៤០០០ របស់ព្រះអង្គនេះ មានបរិនាយកវតន៍ជាប្រធាន ជាអ្នកចុះចូល បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះក្សត្រិយ៍ទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព មេគោ ៨៤០០០ របស់ព្រះអង្គនេះ សម្រាប់រឹតបង្ហូរ (យកទឹកដោះ) មានភាជន៍សីរិទ្ធិសម្រាប់ត្រង បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះមេគោទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីនូវអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សំពត់ ៨៤០០០ កោដិ របស់ព្រះអង្គនេះ ជាសំពត់ដែលត្បាញដោយសម្បកឈើ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់កម្ពល គឺសំពត់ត្បាញដោយរោមសត្វ មានសាច់ដ៏ល្អិត បពិត្រព្រះសម្មតិ-ទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះសំពត់ទាំងនោះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ភាជន៍ក្រយៅស្វាយ ៨៤០០០ របស់ព្រះអង្គនេះ ដែលពួកពិសេសតែងនាំយកកត្តមកថ្វាយ ទាំងល្ងាច ទាំងព្រឹក បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះភាជន៍ក្រយៅស្វាយទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ ។ ម្នាលអានន្ទ កាលបើព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការបង្គាប់ឲ្យនាងទេវី រៀបរាប់

យ៉ាងនេះហើយ ព្រះនាងសុភទ្ទាទេវី ក៏ទ្រង់ព្រះកន្សែងសោយសោក ស្រក់ទឹកព្រះនេត្រ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ទ្រង់ជូតទឹកព្រះនេត្រហើយ ក្រាបបង្គំទូលព្រះបាទមហាសុទស្សន:យ៉ាងនេះថា បពិត្រព្រះសម្មតិទេព សេចក្តីវិនាសព្រោត់ប្រាស ឃ្យៀងឃ្មាតចាកសត្វ និងសង្ខារទាំងពួង ដែលជាទីស្រឡាញ់ ជាទីពេញចិត្ត (រមែងមានដល់ព្រះអង្គ) បពិត្រព្រះសម្មតិទេព សូមទ្រង់កុំទិវង្គត ប្រកបដោយសេចក្តីអាល័យឡើយ (ព្រោះថា) កាលកិរិយារបស់បុគ្គល ដែលមានសេចក្តីអាល័យ តែងនាំមកនូវទុក្ខ មួយទៀត កាលកិរិយារបស់បុគ្គល ដែលមានសេចក្តីអាល័យអ្នកប្រាជ្ញតែងតិះដៀល បពិត្រព្រះសម្មតិទេព ឯនគរ ៨៤០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានីជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីអាល័យចំពោះនគរទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ប្រាសាទ ៨៤០០០ របស់ព្រះអង្គនេះ មានធម្មប្រាសាទជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះប្រាសាទទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កូដាគារដ្ឋាន ៨៤០០០ របស់ព្រះអង្គនេះ មានកូដាគារដ្ឋានប្រាក់ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះកូដាគារដ្ឋានទាំងនោះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព បល្ល័ង្ក ៨៤០០០ របស់ព្រះអង្គនេះ សុទ្ធតែមាស ប្រាក់ ភ្ងុក

កែវមរកត ដែលក្រាលដោយសំពត់ ធ្វើដោយរោមសត្វសាហាវ ក្រាលដោយសំពត់ ធ្វើដោយរោមសត្វ មានពណ៌ស ក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានផ្ការចង្កោម ក្រាលដោយកម្រាលដ៏ល្អ ដែលធ្វើដោយស្បែកប្រើស មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងពិតានពណ៌ក្រហមទាំងសងខាង បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះបល្ង័ង្កទាំងនោះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ជ័រី ៨៤០០០ មានឧបោសនាគារាជជាប្រធានរបស់ព្រះអង្គនេះ សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះជ័រីទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សេះ ៨៤០០០ មានសេះឈ្មោះ វលាហកអស្សរាជជាប្រធានរបស់ព្រះអង្គនេះ សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះសេះទាំងនោះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព រថ ៨៤០០០ របស់ព្រះអង្គនេះ មានវេជយន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ដោយស្បែកខ្លាធំ ដោយស្បែកខ្លាដំបង ដោយសំពត់កម្ពលមានពណ៌លឿង មានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះរាជរថទាំងនោះចេញ សូមទ្រង់កុំធ្វើនូវ

សេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កែវមណី ៨៤០០០ មានមណិរតនៈជាប្រធានរបស់ព្រះអង្គនេះ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះកែវមណីទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកស្ត្រី ៨៤០០០ របស់ព្រះអង្គនេះ មានឥត្ថីរតនៈជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះ ស្ត្រីទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកគហបតី ៨៤០០០ របស់ព្រះអង្គនេះ មានគហបតិរតនៈជាប្រធាន បពិត្រព្រះសម្មតិ-ទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះគហបតីទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកកញ្ញត្រៃយ៍ ៨៤០០០ របស់ព្រះអង្គនេះ មានបរិនាយករតនៈជាប្រធាន ជាអ្នកចុះចូលព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះពួកកញ្ញត្រៃយ៍ទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព មេគោ ៨៤០០០ សម្រាប់រឹតបង្ហូរ (យកទឹកដោះ) មានភាជន៍សីទ្ធិសម្រាប់ត្រងរបស់ព្រះអង្គនេះ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះមេគោទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សំពត់ ៨៤០០០ កោដិ របស់ព្រះអង្គនេះ ជាសំពត់ដែលធ្វើដោយសម្បកឈើមានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត

សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់កម្ពលគឺសំពត់ធ្វើដោយរោមសត្វមានសាច់ដ៏ល្អិត បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះសំពត់ទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កាជន៍ក្រយោស្វាយ ៨៤០០០ របស់អង្គនេះ ដែលពួកពិសេសនាំយកកត្តមកថ្វាយ ទាំងល្ងាច ទាំងព្រឹក បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះកាជន៍ក្រយោស្វាយទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ ។

[๒๒] *ម្នាលអានន្ទ គ្រានោះឯង មិនយូរប៉ុន្មាន ព្រះបាទមហាសុទស្សនៈ ស្តេចក៏ទ្រង់ទិវង្គតទៅ ។ ម្នាលអានន្ទ គហបតីក្តី កូនគហបតីក្តី កាលបើបរិភោគភោជន ជាទីពេញចិត្តហើយ រមែងកើតសេចក្តីពុលពាយងងុយដេក យ៉ាងណាមិញ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ព្រះអង្គក៏សោយទុក្ខវេទនា មានមរណៈជាទីបំផុត ប្រហែលប៉ុណ្ណោះឯង ។ ម្នាលអានន្ទ លុះដល់ព្រះបាទមហាសុទស្សនៈ ទ្រង់ទិវង្គតផុតទៅហើយ ទ្រង់បានទៅកើតឯសុគតិព្រហ្មលោក ។ ម្នាលអានន្ទព្រះបាទមហាសុទស្សនៈ ទ្រង់ក្រសាលល្បែង ដោយសភាពជាកុមារអស់ ៨៤០០០ ឆ្នាំ ទ្រង់ទទួលទីជាឧបរាជ អស់ ៨៤០០០ ឆ្នាំ ទ្រង់សោយរាជអស់ ៨៤០០០ ឆ្នាំ ទ្រង់កេទជាឃរាវាស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មប្រាសាទអស់ ៨៤០០០ ឆ្នាំ ។ ព្រះអង្គចម្រើនព្រហ្មវិហារធម៌ទាំង ๔ លុះរំលាងរាងកាយ ខាងមុខអំពីមរណភាព ក៏ទៅកើតក្នុងព្រហ្មលោក ។*

[๒๓] *ម្នាលអានន្ទ បើមានពាក្យឆ្ងើងឆ្ងល់ យ៉ាងនេះថា ក្នុងសម័យនោះ ព្រះបាទមហាសុទស្សនៈ ជាបុគ្គលដទៃ (ក្រៅពីពោធិសត្វ) ឬ ម្នាលអានន្ទ ដំណើរនេះ បុគ្គលមិនគប្បីយល់ឃើញយ៉ាងនោះទេ្បីយ តថាគត បានកើតជាព្រះបាទមហាសុទស្សនៈ ក្នុងសម័យនោះ នគរ ៨៤០០០ មាន កុសាវតីរាជធានីជាប្រធាននោះ ជារបស់តថាគត ប្រាសាទ ៨៤០០០ មាន ធម្មប្រាសាទជាប្រធាននោះជារបស់តថាគត កូដាគារដ្ឋាន ៨៤០០០ មានកូដា-គារដ្ឋានប្រាក់ជាប្រធាននោះ ជារបស់តថាគត បល្ល័ង្ក ៨៤០០០ ដែលជា មាស ប្រាក់ ភ្នុក កែវមរកត ក្រាលដោយសំពត់ ធ្វើដោយរោមសត្វ សាហាវ ក្រាលដោយសំពត់ធ្វើដោយរោមសត្វមានពណ៌ស ក្រាលដោយ សំពត់ធ្វើដោយរោមសត្វមានផ្កាចង្កោម ក្រាលដោយកម្រាលដ៏ល្អ ដែលធ្វើ ដោយស្បែកប្រើស មានខ្នើយពណ៌ក្រហមទាំងសងខាង ទាំងពិតានក៏មាន ពណ៌ក្រហមទាំងសងខាងនោះ ជារបស់តថាគត ដំរី ៨៤០០០ មានដំរី ឈ្មោះឧបោសថនាគរាជជាប្រធាន សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាសនោះ ជារបស់តថាគត សេះ ៨៤០០០ មាន សេះវលាហកអស្សរាជជាប្រធាន សឹងមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាសនោះ ជារបស់តថាគត រាជរថ ៨៤០០០ មាន វេជយ័ន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ដោយស្បែកខ្លាឃ្មុំ ដោយស្បែកខ្លាដំបង ដោយសំពត់កម្ពល មានពណ៌លឿង មានអលង្ការ មាស មានទង់មាស បិទបាំងដោយបណ្តាញមាសនោះ ជារបស់តថាគត*

កែវមណី ๘๔๐๐๐ មានមណិរតន៍ ជាប្រធាននោះ ជារបស់តថាគត ស្ត្រី ๘๔๐๐๐ មាននាងសុភទ្ទាទេវី ជាប្រធាននោះ ជារបស់តថាគត គហបតី ๘๔๐๐๐ មានគហបតិរតន៍ជាប្រធាននោះ ជារបស់តថាគត ពួកក្សត្រិយ៍ ๘๔๐๐๐ មានបរិនាយករតន៍ជាប្រធាន ជាអ្នកចុះចូលនោះ ជារបស់តថាគត មេគោ ๘๔๐๐๐ សម្រាប់រូតបង្ហូរ (យកទឹមដោះ) មានភាជន៍សីទ្ធិ សម្រាប់ត្រង់នោះ ជារបស់តថាគត សំពត់ ๘๔๐๐๐ កោដិ ជាសំពត់ធ្វើដោយសម្បកឈើមានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយរោមសត្វ មានសាច់ដ៏ល្អិតនោះ ជារបស់តថាគត ភាជន៍ក្រយោស្វាយ ๘๔๐๐๐ ដែលពួកពិសេសនាំយកភត្តមកថ្វាយ ទាំងល្ងាច ទាំងព្រឹកនោះ ជារបស់តថាគត ម្នាលអានន្ទ បណ្តានគរទាំង ๘๔๐๐๐ នោះឯង នគរទាំងនោះ ទុកដូចជានគរមួយ សម័យនោះ តថាគតគ្រប់គ្រងកុសាវតីរាជធានី ម្នាលអានន្ទ ប្រាសាទទាំង ๘๔๐๐๐ នោះឯង ប្រាសាទទាំងនោះ ទុកដូចជាប្រាសាទមួយ សម័យនោះ តថាគតគ្រប់គ្រងធម្មប្រាសាទ ម្នាលអានន្ទ បណ្តាកូដាគារដ្ឋានទាំង ๘๔๐๐๐ នោះឯង កូដាគារដ្ឋានទាំងនោះ ទុកដូចជាកូដាគារដ្ឋានមួយ សម័យនោះ តថាគតគ្រប់គ្រងកូដាគារដ្ឋានប្រាក់ ម្នាលអានន្ទ បណ្តាបល្ល័ង្កទាំង ๘๔๐๐๐ នោះឯង បល្ល័ង្កទាំងនោះ ទុកដូចជាបល្ល័ង្កមួយ សម័យនោះ តថាគតគ្រប់គ្រងបល្ល័ង្កមាសផង ប្រាក់ផង ភ្នុកផង កែវមរកតផង ម្នាលអានន្ទ បណ្តាជំរីទាំង ๘๔๐๐๐ នោះឯង ជំរីទាំងនោះ ទុកដូចជាជំរីមួយ

សម័យនោះ តថាគតជិះតែជំរីខុជ្ជាសថនាគរាជ ម្នាលអានន្ទ បណ្តាសេះទាំង ៨៤០០០ នោះឯង សេះទាំងនោះ ទុកជូចជាសេះមួយ សម័យនោះ តថាគតជិះតែសេះវលាហកអស្សរាជ ម្នាលអានន្ទ បណ្តារាជរថទាំង ៨៤០០០ នោះ ឯង រាជរថទាំងនោះ ទុកជូចជារាជរថមួយ សម័យនោះ តថាគតជិះតែ រៃជយ័ន្តរថ ម្នាលអានន្ទ បណ្តាស្ត្រីទាំង ៨៤០០០ នោះឯង ស្ត្រីទាំងនោះ ទុកជូចជាស្ត្រីម្នាក់ សម័យនោះ មានស្ត្រីខត្តិយាយិនី (ស្ត្រីក្សត្រិយ៍) ផង ស្ត្រីវេស្សាយិនី (ស្ត្រីរាស្ត្រ) ផង តែងនៅចាំគាល់បម្រើ ម្នាលអានន្ទ បណ្តាសំពត់ទាំង ៨៤០០០ កោដិនោះឯង គូសំពត់ទាំងនោះ ទុកជូចជា សំពត់មួយគូ សម័យនោះ តថាគតស្ងៀកពាក់តែសំពត់ដែលធ្វើដោយ សម្បកឈើមានសាច់ដ៏ល្អិត ឬសំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត ឬសំពត់ធ្វើដោយរោមសត្ត មាន សាច់ដ៏ល្អិត ម្នាលអានន្ទ ភាជន៍ក្រយាស្ងោយទាំង ៨៤០០០ នោះឯង ភាជន៍ ក្រយាស្ងោយទាំងនោះ ទុកជូចជាភាជន៍មួយ ក្នុងវេលាដែលតថាគតបរិភោគ ន្ទូវបាយ ចំនួនអង្ក្រមួយនាឡិជាយ៉ាងក្រៃលែងផង សម្ងដ៏សមគួរដល់បាយ នោះផង ម្នាលអានន្ទ អ្នកចូរមើលចុះ សង្ខារទាំងពួងនោះ កន្ងងទៅហើយ រលាយរលត់ទៅហើយ ប្រែប្រួលទៅហើយ ម្នាលអានន្ទ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះឯង មិនឋិតថេរយ៉ាងនេះឯង មិនស្ពាប់បង្ពាប់យ៉ាងនេះឯង ម្នាលអានន្ទ សេចក្តីនេះមានដរាបមក គួរដើម្បីនឿយណាយ គួរដើម្បីប្រាស ចាកសេចក្តីត្រេកអរ គួរដើម្បីរួចស្រឡះចាកសង្ខារទាំងពួង ម្នាលអានន្ទ មួយ

ទៀត កាលតថាគតជាស្តេចចក្រពត្តិ ប្រកបដោយធម៌ សោយរាជ្យដោយធម៌ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ๔ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម មានជនបទដ៏មាំមួន ប្រកបដោយរាជ ๗ ប្រការ ដ៏ឆ្ងាស់នូវសីរៈដែលគេកប់ទុកក្នុងប្រទេសនោះជាគម្រប់ ๖ ជង ការជាក់ចុះនូវសីរៈ (របស់តថាគត) ជាគម្រប់ ๗ ជងនេះហើយ ម្នាលអានន្ទ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក៏តថាគតមិនបានឃើញនូវប្រទេស ដែលជាទីជាក់ចុះនូវសីរៈ ជាគម្រប់ ๘ ឡើយ ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ កាលខាងក្រោយមក ព្រះសុគតជាសាស្តាបានត្រាស់ពាក្យនេះទៀតថា

[๒๔] *ឱហ្ន៎ សង្ខារទាំងឡាយ មិនទៀង មានសភាពកើតឡើងហើយ តែងវិនាសទៅវិញជាធម្មតា លុះកើតឡើងហើយ តែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ។*

មហាសុទស្សនសូត្រទី ๔ ចប់

อัฏฐกถา

มหาสุทัสสนสูตร

กุสาวตีราชธานีกถา

[๑] มหาสุทัสสนสูตรมีพากย์เบื้องต้นว่า **เอวมฺเม สุตํ** ดังนี้ ฯ พึงทราบวินิจฉัยตามลำดับบท ในมหาสุทัสสนสูตรนั้น มีดังนี้ ในบทว่า **สพฺพรตนมโย** นั้น เป็นกำแพงล้วนด้วยแก้วมาส กำแพงล้วนด้วยแก้วผลึก กำแพงล้วนด้วยแก้วไพฑูรย์ กำแพงล้วนด้วยแก้วสังข์ กำแพงล้วนด้วยแก้วมุกดา กำแพงล้วนด้วยแก้วทับทิม กำแพงล้วนด้วยแก้วปัทมราคะ กำแพงล้วนด้วยแก้วสารพัดอย่าง ฯ กำแพงนั้น ในภายในกำแพงทั้งหมดนั้น กำหนดประมาณ ๖๐ ศอก ฯ ก็แต่ว่าพระเถระบางพวกกล่าวว่า นครนี้ เมื่อเขาเห็นจากภายนอกเข้ามา ก็ดูเหมือนมีเงาเป็นมูล เพราะฉะนั้น กำแพงที่อยู่ภายในทั้งหมดนั้น กำหนด ๖๐ ศอก กำแพงแก้วผลึกล้วน ปิดด้วยดี ฯ อาจารย์พวกหนึ่งกล่าวว่า นครนี้ เมื่อเขาเห็นจากภายนอกเข้ามา ก็มีเงาเป็นมูล เพราะฉะนั้น กำแพงในที่สุด กำหนด ๖๐ ศอก กำแพงแก้วผลึกล้วน ปิดด้วยดี ฯ อาจารย์พวกหนึ่งกล่าวว่า นครนี้ เมื่อเขาเห็นจากภายในและภายนอก ก็ดูเหมือนมีเงาเป็นมูล เพราะฉะนั้น พระโบราณาจารย์กล่าวกำแพงภายในว่า กำหนด ๖๐ ศอก ฯ กำแพงภายใน ๓ ชั้น และภายนอก ๓ ชั้น ปิดด้วยดี ฯ

บทว่า **ฬกสิกา** คือ ซอกกำแพง ฯ บทว่า **ตาโลวิสงฺขา** ความว่า ๑ ทางยาวบุรุษ ๓ คน รวมกันได้ ๑๕ ศอก ฯ ซอกเหล่านั้นตั้ง

នៅដូចម្តេច ។ ដោយខាងក្រៅព្រះនគរ ជិតបន្ទះទ្វារធំ មួយកន្ទែង មានសសរខឿន ១ ដើម ជិតបន្ទះទ្វារតូច មួយកន្ទែង មានសសរខឿន ១ ដើម ចន្ទោះទ្វារធំ និងទ្វារតូច មួយកន្ទែង ៣ ដើម ។ បណ្តាដើមត្នោតដែលធ្វើ ដោយរតន:ទាំងអស់ ក្នុងជួរត្នោតទាំងឡាយ ត្នោតមួយដើមធ្វើដោយមាសព្រោះដូច្នោះ គប្បីជ្រាបលក្ខណ: ដែលពោលហើយក្នុងកំពែងនោះឯង ។ សូម្បីក្នុងស្ទឹក និងផ្ទែទាំងឡាយ ក៏មានន័យដូចគ្នា ។ ជួរត្នោតទាំងនោះ កម្ពស់ ៨០ ហត្ថ តាំងនៅក្នុងចន្ទោះកំពែង មួយកន្ទែង ១ ជួរ ក្នុងផ្ទៃដីរាបស្មើ ដែលរាយដោយខ្សាច់ ។ បទថា **រត្ត្ធ** ជានដល់ ឈ្ទាសវៃ ។ បទថា **រជនីយោ** ប្រែថា គួរត្រេកអរ ។បទថា **កមនីយោ** ប្រែថា កាលស្តាប់អស់មួយថ្ងៃ ក៏មិននឿយណាយ ។ បទថា **មធនីយោ** ប្រែថា ធ្វើឲ្យកើតជក់ចិត្តដល់បុគ្គល ។ បទថា **បញ្ចន្ទ្ធិកស្ស** សេចក្តីថា ប្រកបដោយអង្គ ៥ ប្រការ គឺអាតដ: វិតដ: អាតដវិតដ: សុសិរ: ឃន: ។ ក្នុងអង្គ ៥ ប្រការនោះ គ្រឿងតូរ្យតន្ត្រី ដែលពាសដោយស្បែកតែម្ខាង ក្នុងបណ្តាស្គរជាដើម ដែលពាសដោយស្បែក ឈ្មោះថា អាតដ: គ្រឿងប្រគំដែលពាសទាំង ២ ខាង ឈ្មោះថា វិតដ: គ្រឿងប្រគំដែលរឹតដោយខ្សែ ឈ្មោះថា អាតដវិតដ: ។ ប៉ី និងស័ង្ខជាដើម ឈ្មោះថា សុសិរ: ។ កណ្តឹង ឈិង ក្រាប់ជាដើមឈ្មោះថា ឃន: ។ បទថា **សុវិនីតស្ស** សេចក្តីថា សន្ធឹងល្អហើយ ដោយធ្វើឲ្យធូរជាដើម ។ បទថា **សុប្បដិតាឡិតស្ស** សេចក្តីថា រាយធៀបល្អហើយ ដើម្បីឲ្យដឹងថា ល្មមហើយ ។ បទថា **កុសលេហិ សមន្នាហតស្ស** សេចក្តីថា ប្រគំដោយអ្នក

ជំនាញ ដែលអាចលេងក្ងេងបាន ។ បទថា **ឆេฏฺโก** *គឺអ្នកលេងក្លាល់ ។ បទថា* **សោณฺโฑ** *សេចក្តីថា អ្នកលេងសុរា ។ អ្នកលេងសុរាទាំងនោះឯង ឈ្មោះថា អ្នកផឹក ដោយអំណាចការផឹករឿយៗ ។ បទថា* **ปริจาเรสุ** *ប្រែថា ទះដៃទន្ទ្រាំជើងរាំលេង ។*

[๒-๘] *បទថា* **สีสนฺหาตสฺส** *ប្រែថា ទ្រង់កក់ដោយទឹកក្នុងក្រអូបសព្វព្រះសិរសោ ។ បទថា* **อุโปสถิกสฺส** *សេចក្តីថា ទ្រង់សមាទានអង្គឧបោសថ ។ បទថា* **อุปริปาสาทวรคตสฺส** *សេចក្តីថា ទ្រង់ឡើងកាន់ប្រាសាទដ៏ប្រសើរ សោយព្រះក្រយាហារហើយ ចូលទៅកាន់បន្ទប់ដ៏មានសិរីខាងលើ គឺលើផ្ទៃមហាប្រាសាទដ៏ប្រសើរ ហើយទ្រង់ព្រួកដល់សីល ។ បានឮថា គ្រានោះ ព្រះរាជាទ្រង់ដោះស្រាយបញ្ហាទាំងសែន តាំងពីព្រឹកព្រលឹមហើយទ្រង់ថ្វាយមហាទាន ទ្រង់ជម្រះព្រះសិរ្សដោយទឹកក្រអូប ១៦ ក្អម សោយព្រះក្រយាហារព្រឹក ទ្រង់ដណ្តប់ស្បែជើងបរិសុទ្ធ ប្រថាប់អង្គុយសមាធិក្នុងបន្ទប់ផ្ទៃលើប្រាសាទដ៏ប្រសើរ ទ្រង់ព្រួកដល់ហេតុនៃបុណ្យ ដែលសម្រេចដោយទាន ទមៈ និងសញ្ញមៈរបស់ព្រះអង្គ ។ នេះជាធម្មតារបស់ស្តេចចក្រពត្តិទាំងពួង ។ កាលស្តេចចក្រពត្តិទាំងនោះ ទ្រង់ព្រួកដល់សីលយ៉ាងនោះ ចក្កវត្តន៍ដែលជាទិព្វ ដូចជាដុំកែវមណីពណ៌ខៀវ ដែលមានសមុដ្ឋានអំពីបុញ្ញកម្ម បច្ចុប្បន្ន និងរដូវដូចពោលហើយ រមែងប្រាកដដូចផ្ទៃទឹកសមុទ្រនាទិសខាងកើតត្រូវរលកបក់ប៉ះ ដូចអាកាសដែលប្រដាប់ហើយ ដូច្នោះ ។ ចក្កវត្តន៍នោះ បានប្រាកដដល់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ដូច្នោះ ។

ចក្កវត្តន៍នេះ លោកពោលថា ជាទិព្វ ព្រោះប្រកបដោយអានុភាពដែលជាទិព្វ ។ ចក្កវត្តន៍មានកាំ ១ ពាន់ ទើបឈ្មោះថា **សហស្សារំ** *។ មានខ្នងកង់ និងដុំ ទើបឈ្មោះថា* **សនេមិកំ សនាភិកំ** *។ បរិបូណ៌ដោយអាការទាំងពួង ទើបឈ្មោះថា* **សព្ពាការបរិបូរំ** *។ ចក្រក្នុងមហាសុទស្សនសូត្រនោះផង ជារតនៈផង ព្រោះអត្ថថា ឲ្យកើតសេចក្តីត្រេកអរ ព្រោះដូច្នោះ ទើបឈ្មោះថា* **ចក្ក-រតន** *។ ចក្កវត្តន៍លោក ពោលថា* **សនាភិកំ** *ដោយដុំណា ដុំនោះធ្វើដោយកែវមណីពណ៌ខៀវ ។ ផ្នែកកណ្តាលនៃដុំ ដែលធ្វើដោយប្រាក់ រុងរោចន៍ដូចរំលេចដោយជួរធ្មេញដ៏សស្អាត ។ ស្រោបដោយផែនប្រាក់ទាំងខាងក្រៅ និងខាងក្នុងទាំងពីរ ដូចមណ្ឌលនៃព្រះចន្ទដែលមានចំណុចក្នុងកណ្តាល ដូច្នោះ ។ ក្បួរក្បាច់ដែលឆ្លាក់ក្នុងទីដ៏សមគួរ ក្នុងផែនស្រោបដុំ និងកាំនោះ ប្រាកដជាចាត់ចែងយ៉ាងល្អ ។ សេចក្តីបរិបូណ៌ ដោយអាការទាំងពួងនៃដុំនៃចក្កវត្តន៍ត្រឹមតែប៉ុណ្ណោះ ។ ចក្កវត្តន៍នោះ លោកពោលថា* **សហស្សារំ** *ដោយកាំពួកណា កាំទាំងនោះ ធ្វើដោយរតនៈ ៧ ប្រការ ដល់ព្រមដោយពន្លឺ ដូចរស្មីនៃព្រះអាទិត្យ ដូច្នោះ ។ អាការមានក្បាច់ក្បួរដោយដុំកែវនៃកាំទាំងនេះ ប្រាកដជាចក្រ បែងចែកយ៉ាងល្អ ។ នេះជាភាពសម្បូរដោយអាការទាំងពួងរបស់កាំនៃចក្កវត្តន៍នោះ ។ ម្យ៉ាងទៀត ចក្កវត្តន៍នោះ លោកពោលថា* **សនេមិកំ** *ដោយខ្នងកង់ណា ខ្នងកង់នោះធ្វើដោយកែវប្រពាលក្រហមចាស់បរិសុទ្ធ ដូចជាចំអកដល់សិរីនៃរស្មីទាំងឡាយរបស់ព្រះអាទិត្យស្រទន់ៗ ដូច្នោះ ។ ក្នុងទីតនៃខ្នងកង់នោះ ក្បាច់ដែលឆ្លាក់មានសិរីជាដុំស ក្រហម បរិសុទ្ធល្អ ដេរដាសដោយ*

មាសជម្ពូនុទ ប្រាកដជាការចាត់ចែកទុកយ៉ាងល្អ ។ នេះគឺភាពបរិបូណ៌ដោយ អាការទាំងពួងនៃខ្នងកង់ចក្កវតេនៈនោះ ។ ក្នុងចន្លោះកាំទាំង ១០ នៃចក្កវត្តិ៍ នោះ ខាងខ្នងនៃបរិវេណកង់ មានដុំកែវប្រពាល ជក់ខ្យល់ ធ្លាក់ជាក្បាល ខាងក្នុងដូចដុំផ្សែង ដូច្នោះ ។ ចក្កវត្តិ៍ណាដែលត្រូវខ្យល់ហើយ មានសំឡេង ពីរោះ ទាក់ទាញចិត្ត គួរឲ្យស្តាប់ ឲ្យរំភើបដូចសំឡេងតន្ត្រីដែលប្រកបដោយ អង្គ ៥ ដែលប្រគុំដោយអ្នកជំនាញល្អហើយ ដូច្នោះ ចក្កវត្តិ៍នោះ ខាងលើ នៃជង្គង់កែវប្រពាល មានឆត្រសទាំងពីរខាង មានជួរក្បាច់ផ្កាមាស រួមគ្នាជា ពីរជួរ ខាងក្នុងដុំ និងកាំទាំងពីរ ស្រោបកង់ដ៏ល្អ ព្រមដោយជង្គង់កែវប្រពាល ១០០ ទ្រទ្រង់ឆត្រស ១០០ មានជួរក្បាច់ផ្កាមាស ដែលរួមប្រជុំ ២០០ យ៉ាង នេះជាបរិវារ មានមុខសីហៈពីរ មានកម្រងកែវមុក្តាប្រមាណប៉ុនដើមត្នោត ២ កម្រងដែលស្អាតល្អ ដូចពន្លឺព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដេរជាសដោយសំពត់ កម្ពលពណ៌ក្រហម ប្រៀបដូចព្រះអាទិត្យមានកម្តៅស្រទន់ និងសភាពល្អល្អះ ដែលផ្សាយទូរទៅយក្នុងអាកាស និងស៊ីងគង្គា ដូច្នោះ បន្តោងរំយោល មាន វង់ចក្ក ៣ ព្រមនឹងចក្កវត្តិ៍ ប្រាកដដូចជាវិលក្នុងអាកាសព្រមគ្នាដូច្នោះ នេះ សេចក្តីបរិសុទ្ធិគ្រប់យ៉ាង ដោយប្រការទាំងពួងនៃចក្កវត្តិ៍នោះ ។ ចក្កវត្តិ៍នេះ បរិបូណ៌ដោយអាការទាំងពួងដូច្នេះ កាលមនុស្សទាំងឡាយ បរិភោគអាហារ ល្ងាចតាមប្រក្រតី អង្គុយលើអាសនៈដែលក្រាលត្រង់ទ្វារផ្ទះរៀងៗ ខ្លួន សន្ទនា គ្នា ក្មេងៗ កំពុងលេងក្នុងផ្លូវបែកជា ៤ ជាដើម ចក្កវត្តិ៍នោះអណ្តែតក្នុង អាកាស មិនខ្ពស់ពេកមិនទាបពេក ប្រមាណស្មើចុងឈើ ញាំងទីនោះៗ ឲ្យភ័

ឮសំឡេងចក្កវត្តន៍នោះ ពីរោះដូចសំឡេងបក្សីត្រង់មែកឈើ រហូតចម្ងាយ ១២ យោជន៍ ធ្វើឲ្យនេត្រាមើលឃើញនូវពណ៌ ដ៏រុងរឿងដោយពន្លឺផ្សេងៗ ដល់មួយយោជន៍ ដូចជាយោសនានូវបុញ្ញានុភាពនៃស្តេចចក្រពត្តិ ត្រឡប់មកកាន់រាជធានី ។ លំដាប់នោះ ដោយការស្តាប់សំឡេងចក្កវត្តន៍នុ៎ះឯង ពួកមនុស្សក្រៃឡែកមើលទិសខាងកើត មានការផ្តោតចិត្តថា នេះជាសំឡេងរបស់អ្នកណា មកអំពីទីណាហ្ន៎ ខ្លះក៏ពោលប្រាប់គ្នាថា លោកជ័ចម្រើនគួរអស្ចារ្យណាស់ ពីកាលមុន ព្រះចន្ទពេញវង់រះត្រឹមតែមួយ តែថ្ងៃនេះ ហេតុអ្វី ទើបរះ ២ នុ៎ះជាព្រះចន្ទពេញវង់មួយគូ ដូចរាជហង្សមួយគូ ប្រជាប់ក្នុងផ្ទៃអាកាស ដូចគ្នានឹងកាលមុន ។ អ្នកខ្លះក៏ពោលនឹងអ្នកនោះថា និយាយអ្វីសម្លាញ់ ឯងធ្លាប់ឃើញព្រះចន្ទ ២ រះឡើងព្រមគ្នាពីកាលណា នុ៎ះជាព្រះអាទិត្យបាំងឆត្រមិនមែនឬ ។ អ្នកខ្លះញញឹម ហើយពោលនឹងបុគ្គលនោះថា ឯងឆ្កួតឬ ព្រះអាទិត្យ ទើបតែលិចអម្បាញ់មិញមិនមែនឬ ព្រះអាទិត្យនុ៎ះនឹងរះតាមព្រះចន្ទពេញវង់នេះបានដូចម្តេច នុ៎ះជាវិមានរបស់អ្នកមានបុណ្យណាមួយ ដែលរុងរឿងដោយពន្លឺរតនៈដោយពិត ។ មនុស្សទាំងអស់នោះ មិនជឿគ្នានឹងគ្នា ក៏ពោលនឹងមនុស្សពួកដទៃយ៉ាងនេះថា អ្នកជ័ចម្រើន និយាយច្រើនធ្វើអ្វី នេះមិនមែនព្រះចន្ទពេញវង់ មិនមែនព្រះអាទិត្យ មិនមែនវិមានរបស់ទេវតា និងមិនមែនសិរីសម្បត្តិរបស់ពួកទេវតា តែជាចក្កវត្តន៍មួយដោយពិត ។ កាលជនទាំងនោះសន្ទនាគ្នាយ៉ាងនេះហើយ ចក្កវត្តន៍នោះ ក៏លះបង់ចេញនូវមណ្ឌលនៃព្រះចន្ទ បែរត្រង់ឆ្ពោះរាជធានី ។ តពីនោះ ប្រសិនបើនិយាយថា ចក្កវត្តន៍

នេះ កើតដល់អ្នកណាហ្ន៎ ក៏នឹងមានអ្នកនិយាយថា ចក្កវត្តន៍នោះ មិនកើតដល់អ្នកណាដទៃទេ តែកើតដល់ព្រះបាទមហាចក្រពត្តិ ដែលមានព្រះបារមីបរិបូណ៌របស់ពួកយើង មិនមែនឬ ។ លំដាប់នោះ មហាជននោះ និងជនដទៃៗ ទាំងអស់ក៏ជាប់តាមចក្កវត្តន៍នោះឯង ។ ចក្កវត្តន៍នោះ ដូចប្រាថ្នានឹងឲ្យដឹងដល់ការៈប្រព្រឹត្តទៅនៃខ្លួន ដើម្បីជាប្រយោជន៍ដល់ស្តេចចក្រពត្តិ វិលក្បែរៗ ព្រះនគរ កម្ពស់ប្រមាណ ៧ ជួរកំពែង កាលធ្វើប្រទក្សិណព្រះនគរបស់ស្តេចចក្រពត្តិ ហើយប្រតិស្ឋាននៅត្រង់សីហបញ្ជរ ផ្នែកទិសខាងជើងខាងក្នុងរាជធានី ប្រាកដដូចឲ្យមហាជនសប្បាយដល់ការបូជា ដោយគ្រឿងក្រអូប និងផ្កាដើមជូថ្នោះ ។ កាលចក្កវត្តន៍នោះ តាំងនៅយ៉ាងនេះហើយ ព្រះរាជាមានបំណងនឹងតមើលចក្កវត្តន៍ដែលមានពន្លឺ ធ្វើឲ្យខាងក្នុងប្រាសាទ ភ្លឺដោយពន្លឺរតនៈចម្រុះពណ៌ ដែលផ្សាយចេញមកតាមចន្លោះប្រហោងផ្សេងៗ ។ សូម្បីប្រជាជនដែលមកជាមួយព្រះរាជានោះ ក៏ប្រាថ្នាដល់ពាក្យគួរស្រឡាញ់នៃចក្កវត្តន៍នោះ ទើបប្រកាសសេចក្តីនោះ ។ លំដាប់នោះ ព្រះរាជាទ្រង់មានព្រះសរីរៈផូរផង់ដោយព្រះបីតិ និងបាមោជ្ជជាកម្លាំង ទ្រង់ឈប់សមាធិ ស្តេចក្រោកឡើងចាកព្រះរាជាសនៈ ស្តេចទៅជិតសីហបញ្ជរ ទ្រង់ឃើញចក្កវត្តន៍នោះ ទ្រង់ព្រះតម្រិះថា ចក្កវត្តន៍នោះ អញបានស្តាប់ហើយជូថ្នេះជាដើម ។ ចក្កវត្តន៍នោះ បានកើតឡើងយ៉ាងនោះ ដល់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ។ ដោយហេតុនោះ ទើបលោកពោលថា **រញ្ញោ មហាសុទสฺสนสฺส ฯเปฯ អสฺสุ ขฺวาหំ ราชา จกฺกวตฺตี ฯ** *ក្នុងបទនោះ មានអត្ថថា ព្រះរាជា*

ព្រះអង្គនោះ ជាស្តេចចក្រពត្តិ ។ សួរថា ជាស្តេចចក្រពត្តិដោយហេតុមានប្រមាណប៉ុនណា ។ កាលចក្ករតន៍ស៊ុះឡើងទៅកាន់អាកាស ត្រឹមតែ ๑ ផ្ទាប់ ๒ ផ្ទាប់ ព្រះមានព្រះភាគទ្រង់សម្តែងកិច្ចដែលគប្បីធ្វើ ដើម្បីញុំាងចក្ករតន៍នោះ ឲ្យប្រព្រឹត្តទៅក្នុងកាលឥឡូវនេះ ទើបត្រាស់ថា **អថខោ អាឯន្តុ** *ជាដើម ។*

ក្នុងបទទាំងនោះ បទថា **ឧដ្ឋាយាសនា** *សេចក្តីថា ស្តេចក្រោកចាកព្រះរាជាសនៈ ដែលប្រថាប់ហើយ ស្តេចមកជិតចក្ករតន៍ ។ បទថា* **សុវណ្ណ-ភិង្គារំ គហេត្វា** *សេចក្តីថា ទ្រង់លើកកុណ្ឌីមាស មានចំពុយដូចប្រមោយជ័រ ។ បទថា* **អទ្ទសេវ រាជា មហាសុទស្សនោ សទ្ធឹ ចតុរង្គិនិយា សេនាយ** *សេចក្តីថា ព្រះបាទមហាសុទស្សនចក្រពត្តិរាជនោះ ទ្រង់ព្រះនាមថា ចក្រពត្តិ មួយរំពេច ទន្ទឹមនឹងចក្ករតន៍ហោះឡើងកាន់វេហាស៍ ដូចស្តេចចក្រពត្តិទាំង-ឡាយ ទ្រង់ប្រោះទឹកហើយត្រាស់ថា ចូរចក្ករតន៍ដ៏ចម្រើនមានជ័យជម្នះ ។ កាលចក្ករតន៍ប្រព្រឹត្តទៅហើយ ស្តេចចក្រពត្តិ ទ្រង់ជាប់តាមចក្ករតន៍នោះ ស្តេចទៅកាន់យានដ៏ប្រសើរ ហើយហោះឡើងកាន់វេហាស៍ ។ លំដាប់នោះ បរិជន និងអន្តោជនរបស់ព្រះរាជានោះ កាន់ឆត្រ និងផ្ចិតជាដើម តពីនោះ ពួកឧបរាជ និងសេនាបតី ព្រមទាំងកងពល ប្រដាប់ដោយអាវក្រោះជាដើម រុងរឿងដោយពន្ធីអាភរណៈផ្សេងៗ តាក់តែងដោយទង់ជ័យលាដែលស្អាតល្អ ហោះឡើងកាន់វេហាស៍ហែហមព្រះរាជា ។ បណ្តាកេរីចរ ក៏ឲ្យវាយគ្រាប់ទៅតាមថ្នល់ក្នុងព្រះនគរ ដើម្បីសង្គ្រោះជនថា នែអ្នកទាំងឡាយ ចក្ករតន៍បានកើតឡើងដល់ព្រះរាជារបស់ពួកយើងហើយ អ្នកទាំងឡាយចូរតាក់តែងប្រដាប់ខ្លួនតាមសមគួរដល់ទ្រព្យរៀងៗ ខ្លួន ហើយមកប្រជុំគ្នា ។ មហាជន លះបង់កិច្ច*

ទាំងពួងតាមប្រក្រតី ដោយសំឡេងចក្កវត្តន៍នោះឯង កាន់គ្រឿងក្រអូប និងផ្កា ជាដើម ប្រជុំគ្នាហើយ ។ មហាជនទាំងអស់នោះ ហោះទៅកាន់វេហាស៍ ហែហមព្រះរាជានោះឯង ។ មហាជនណាមួយ បំណងនឹងទៅជាមួយព្រះរាជា មហាជននោះៗ ក៏ទៅកាន់អាកាស ។ បរិស័ទមានទំហំប្រមាណ ១២ យោជន៍ យ៉ាងនេះ ។ ក្នុងបរិស័ទនោះ សូម្បីតែម្នាក់ និងមានសរីរៈបែកបាក់ ឬសំពត់ ប្រឡាក់មិនមាន ។ ពិតហើយ ស្តេចចក្រពត្តិ ទ្រង់មានរាជបរិវារដ៏ស្អាត ។ ឈ្មោះថា បរិស័ទរបស់ស្តេចចក្រពត្តិហោះបានដូចវិទ្យាធរ ប្រៀបដូចជាកែវមណីពាសពេញ ក្នុងលំហមេឃពណ៌ខៀវ ។ បរិស័ទរបស់ព្រះបាទមហា-សុទស្សនចក្រពត្តិរាជ ក៏ដូច្នោះដែរ ។ ដោយហេតុនោះ ទើបលោកពោលថា

អទ្ទសេវ ខោ រាជា មហាសុទស្សនោ សត្តឹ ចតុរង្គិនិយា សេនាយ ។

ចក្កវត្តន៍នោះ រមែងហោះទៅលើអាកាស លើចុងឈើ ដោយមិនខ្ចប់ពេក មិនទាបពេក បុគ្គលត្រូវការផ្លែផ្កា និងវល្លិនៃដើមឈើ ក៏អាចបេះផ្លែផ្កាទាំងនោះបានដោយងាយ និងដូចបុគ្គលឈរលើផែនដី ក៏អាចនឹងសង្កេតដឹងថា នុ៎ះព្រះរាជា នុ៎ះឧបរាជ នុ៎ះសេនាបតី ។ ក្នុងបណ្តាឥរិយាបថ មានឈរជាដើម បុគ្គលណាត្រូវការឥរិយាបថណា បុគ្គលនោះ ក៏ប្រព្រឹត្តទៅដោយឥរិយាបថនោះបាន ។ ក្នុងទីនេះ បុគ្គលខ្វល់ខ្វាយក្នុងសិល្បៈ មានចិត្រកម្មជាដើម កាលធ្វើកិច្ចរៀងៗ ខ្លួនទៅ កិច្ចទាំងពួងរបស់ជនទាំងនោះ ក៏រមែងសម្រេចក្នុងអាកាសនោះឯង ដូចនៅលើផែនដី ។ ចក្កវត្តន៍នោះ នាំបរិស័ទស្តេចចក្រពត្តិទៅដោយអាការយ៉ាងនេះ និងលះភ្នំព្រះសិនេរុផ្លូវខាងឆ្វេង ទៅកាន់បុព្វវិទេហប្រទេស ប្រមាណ ៨ ពាន់យោជន៍ ក្នុងចំណែកខាង

លើនៃមហាសមុទ្រ ។ ក្នុងទីនោះ ភូមិភាគណា ផ្នែកទទឹងដោយជុំវិញបាន ១២ យោជន៍ គួរដល់ការនៅអាស្រ័យរបស់បរិស័ទ ១៦ យោជន៍ មានអាហារគ្រឿងឧបករណ៍រកបានងាយ សម្បូរដោយម្ហូប និងទឹក មានភាគផែនដីស្មើស្អាត គួរីករាយ ចក្កវត្តន៍នោះ តាំងនៅមិនញាប់ញ័រ ក្នុងចំណែកខាងលើនៃភូមិភាគនោះៗ លំដាប់នោះ ដោយសញ្ញានោះ មហាជនក៏ចុះធ្វើកិច្ចទាំងពួងមានការងូត និងបរិភោគជាដើម តាមសេចក្តីពេញចិត្ត សម្រេចការនៅ ។ ចក្កវត្តន៍ទាំងពួងរមែងមានសភាពយ៉ាងនោះ សូម្បីរបស់ព្រះបាទមហាសុទស្សនចក្រពត្តិក៏ដូច្នោះ ដោយហេតុនោះ ទើបលោកពោលថា ម្នាលអានន្ទ ចក្កវត្តន៍ប្រតិស្ឋាននៅក្នុងប្រទេសណា ព្រះបាទមហាសុទស្សនៈ ក៏ប្រថាប់នៅក្នុងប្រទេសនោះ ព្រមទាំងចតុរង្គសេនា ។

កាលស្តេចចក្រពត្តិគង់នៅយ៉ាងនេះហើយ ព្រះរាជាទាំងឡាយ ក្នុងប្រទេសនោះ សូម្បីបានស្តាប់ហើយថា ចក្រមកហើយ ក៏រមែងមិនប្រជុំកម្លាំងដើម្បីត្រៀមច្បាំង ។ ព្រោះក្នុងចន្លោះឧប្បត្តិកឡើងនៃចក្កវត្តន៍ ធម្មតាសត្វដែលព្យាយាមលើកអាវុធតតាំងចំពោះព្រះរាជានោះ ដោយសម្គាល់ថា ជាសត្រូវមិនមានឡើយ ។ នេះជាអានុភាពនៃចក្កវត្តន៍ ។ ពួកសត្រូវដ៏សេសរបស់ព្រះរាជានោះ រមែងចូលដល់ការទូន្មានដោយអានុភាពនៃចក្រ ។ ធម្មតាការទូន្មានសត្រូវ ជាកិច្ចរបស់ព្រះរាជាដែលជាធំនៃមនុស្ស ដោយហេតុនោះ ទើបលោកពោលដល់ចក្ររបស់ព្រះរាជានោះ ។ ព្រោះដូច្នោះ ព្រះរាជាទាំងអស់នោះ ទ្រង់កាន់បណ្ណាការដ៏សមគួរដល់រាជសិរីសម្បត្តិរៀងៗ ខ្លួន ចូលគាល់ព្រះរាជានោះ ទ្រង់បង្អោនព្រះសិរ្សៈ ធ្វើការបូជាព្រះបាទនៃព្រះរាជានោះ

ដោយអភិសេកនៃរស្មីកែវមណីព្រះមោលីរបស់ខ្លួន ដល់នូវការទទួលព្រះរាជា
នោះ ដោយព្រះវចនៈថា បពិត្រព្រះមហារាជ សូមព្រះអង្គយាងមក ដូច្នេះ
ជាដើម ។ ព្រះរាជាទាំងឡាយក៏បានធ្វើយ៉ាងនោះ ដល់ព្រះបាទមហាសុទស្សន-
ចក្រពត្តិរាជដូចគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា **យេ ខោ បនា-**
ឆន្ទ បុរត្ថិមាយ ទិសាយ ។បេ។ អនុសាស មហារាជ *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ស្វាគតំ** *ប្រែថា ស្តេចមកល្អហើយ ។ លោក*
ពោលថា ក៏កាលព្រះរាជាមួយអង្គយាងមក រាជសត្រូវក៏សោកសៅ កាល
ស្តេចទៅ ក៏ទ្រេវីកពាយ កាលព្រះរាជាអង្គខ្លះយាងមក រាជសត្រូវក៏ទ្រេវីក
រាយ កាលយាងទៅ ក៏ទ្រេងសោកសៅ ស្តេចចកក្រពត្តិក៏ដូច្នោះ កាលទ្រេង
យាងមក ព្រះរាជាទាំងឡាយក៏មកត្រេកអរ កាលទ្រេងយាងទៅ ព្រះរាជា
ទាំងឡាយក៏សោយសោក ព្រោះដូច្នោះ ទើបការយាងមករបស់ព្រះអង្គ ជា
ការយាងមកដោយល្អ ។ កាលពោលយ៉ាងនេះហើយ ព្រះបាទចក្រពត្តិមិន
ត្រាស់ថា អ្នកទាំងឡាយ ចូរនាំពលីដ៏សមគួរ មានប្រមាណប៉ុណ្ណោះឲ្យដល់
យើងខ្លះ នឹងមិនកាត់យកកោគៈរបស់ព្រះរាជាអង្គដទៃ ទ្រង់ព្រះរាជទានដល់
ព្រះរាជាអង្គដទៃខ្លះ តែទ្រង់ផ្តើមពាក្យថា **ចាណាតិចាតា** *ជាដើម ពោល*
ដោយបញ្ញាដែលសមគួរ ដល់ភាពដែលព្រះអង្គជាធម្មរាជា ទ្រង់សម្តែងព្រះ
ធម៌ដោយព្រះវចនៈដែលជាទីស្រឡាញ់ ដែលទន់ភ្លន់ផ្អែមល្ហែម ដោយន័យ
ជាដើមថា នែបាទាំងឡាយ អ្នកចូរមើល ដែលឈ្មោះថា ការសម្លាប់សត្វនោះ
ដែលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បី
នរក ទ្រង់ព្រះរាជទានព្រះឱវាទមានជាដើមថា កុំសម្លាប់សត្វ ដូច្នេះ ។ ព្រះបាទ

មហាសុទស្សនចក្រពត្តិ ក៏ទ្រង់ធ្វើយ៉ាងនេះដូចគ្នា ។ ដោយហេតុនោះ ទើប លោកពោលថា ព្រះបាទមហាសុទស្សនចក្រពត្តិត្រាស់យ៉ាងនេះថា អ្នកកុំ សម្លាប់សត្វ ។បេ។ អ្នកគប្បីបរិភោគ តាមសមគួរ ។

សួរថា ព្រះរាជាទាំងអស់ ទ្រង់កាន់យកឱវាទនេះរបស់ព្រះរាជាឬទេ ឆ្លើយថា ព្រះរាជាទាំងអស់ គង់មិនកាន់យកសូម្បីឱវាទរបស់ព្រះពុទ្ធ តើនឹង កាន់យកឱវាទរបស់ព្រះរាជាបានដូចម្តេច ។ ព្រោះដូច្នោះ ព្រះរាជាពួកណា ទ្រង់ជាបណ្ឌិត ឈ្លាសវៃ មានបញ្ញា ព្រះរាជាទាំងនោះ ក៏ទ្រង់កាន់យក ។ តែព្រះរាជាទាំងអស់ ទ្រង់ចុះចូល ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ ថា **យេ ខោ បនានន្ទ** *ដូច្នេះជាដើម ។*

លំដាប់នោះ ចក្កវត្តន៍នោះ លុះព្រះរាជាឲ្យព្រះឱវាទដល់អ្នកបុព្វវិទេហៈ យ៉ាងនេះហើយ ក៏ស្ទុះទៅកាន់វេហាស៍ ព្រមនឹងកម្លាំងរបស់ចក្រពត្តិ ដែលបានទទួលទានអាហារព្រឹកស្រេចហើយ ក៏យាងចូលកាន់សមុទ្រ ទិស ខាងកើត កន្លងរលកដ៏ធំទូលាយ ដូចនាគរាជបានក្ងិនពស់ហើយ បើកពពារ ដូច្នោះ ហោះហើរលើទឹកមហាសមុទ្រប្រមាណមួយយោជន៍ តាំងនៅខាងក្នុង មហាសមុទ្រប្រៀបដូចជាកែវពិទូរ្យ ដូច្នោះ ។ ក្នុងខណៈនោះ រតនៈច្រើន ប្រភេទដែរជាសក្នុងមហាសមុទ្រ ហាក់ដូចបំណងចង់ឃើញ បុញ្ញសិរីរបស់ ព្រះរាជាអង្គនោះ មកពីទីនោះៗ ពេញប្រទេសនោះៗ លំដាប់នោះ បរិស័ទ នៃព្រះរាជានោះ ឃើញផ្ទៃមហាសមុទ្រ ពោរពេញដោយរតនៈច្រើនប្រភេទ នោះ ក៏កាន់យកដោយកម្សាន់ជាដើមតាមចិត្ត ។ កាលបរិស័ទបានកាន់យក រតនៈតាមពេញចិត្ត ចក្កវត្តន៍នោះក៏ត្រឡប់ ។ កាលចក្កវត្តន៍នោះត្រឡប់

បរិសស័ទមិនបាននៅ ព្រះរាជានៅក្នុងកណ្តាល ចក្កវត្តន៍នៅខាងចុង ។ ចក្កវត្តន៍នោះប៉ះខ្ទប់ជុំវិញខ្នងកង់ ដោយការញែកនោះ ដូចប៉ះខ្ទប់ផ្ទៃទឹកសមុទ្រ និងដូចគ្របសង្កត់ដោយចក្កវត្តនសិរី ចូលទៅមួយជួរនិន្នេរ ។ ស្តេចចក្រពត្តិទ្រង់ឈ្នះបុព្វវិទេហប្រទេស ដែលមានមហាសមុទ្រទិសខាងកើតជាព្រំដែន យ៉ាងនេះហើយ ទ្រង់ប្រាថ្នានឹងឈ្នះជម្ពូទ្វីប ដែលមានសមុទ្រផ្នែកទិសត្បូងខាងជាព្រំដែន ស្តេចបែរចំពោះសមុទ្រផ្នែកទិសខាងត្បូង តាមផ្លូវដែលចក្កវត្តន៍នាំទៅ ។ ព្រះបាទមហាសុទស្សនចក្រពត្តិក៏យាងទៅដូច្នោះដែរ ។ ដោយហេតុនោះ ទើបលោកពោលថា ម្នាលអានន្ទ វេលានោះ ចក្កវត្តន៍នោះ ក៏ចុះទៅកាន់សមុទ្រខាងបុរត្ថិមទិសហើយឆ្លងទៅ ត្រឡប់ទៅខាងទក្ខិណទិស ដូច្នេះ។ កាលចក្កវត្តន៍នោះ ប្រព្រឹត្តទៅយ៉ាងនេះ ពាក្យថា វិធីត្រឡប់ការស្នាក់នៅនៃសេនា ការយោងមកនៃព្រះអរិយជ គឺព្រះរាជាជាសត្រូវ ការព្រះរាជទានអនុសាសនីដល់ពួកព្រះអរិយជនោះ។ ការឆ្លងទៅកាន់សមុទ្រទិសខាងត្បូង ការទៅលើសមុទ្រ ការកាន់យករតនៈច្រើនប្រភេទទាំងអស់ គប្បីជ្រាបដោយន័យមុននោះឯង ។ ទ្រង់ឈ្នះជម្ពូទ្វីប ប្រមាណមួយម៉ឺនយោជន៍នោះហើយ ត្រឡប់អំពីសមុទ្រទិសខាងត្បូង យាងទៅដោយន័យពោលហើយក្នុងបទមុន ដើម្បីឈ្នះអមរគោយាន មាន ៧ ពាន់យោជន៍ជាប្រមាណ ទ្រង់ឈ្នះអមរគោយាននោះ ដែលមានសមុទ្រជាព្រំដែនយ៉ាងនោះ ស្តេចឆ្លងទៅអំពីសមុទ្រទិសខាងលិច យាងទៅយ៉ាងនោះ ដើម្បីឈ្នះឧត្តរកុរុ ដែលមាន ៨ ពាន់យោជន៍ជាប្រមាណ ទ្រង់ឈ្នះឧត្តរកុរុនោះ ដែលមានសមុទ្រជាព្រំដែនដូចគ្នា ហើយស្តេចត្រឡប់អំពីសមុទ្រទិសខាងជើង ។ ស្តេចចក្រពត្តិ ទ្រង់

សម្រេចភាពជាអ្នកធំក្រៃលែងនៃប្រឹថពី ដែលមានមហាសមុទ្រទាំងបួនជាព្រំដែន ដោយប្រការដូច្នេះ ។

ព្រះរាជាព្រះអង្គនោះ ទ្រង់ឈ្នះដ៏វិសេស ដោយការឈ្នះហើយយ៉ាងនេះ មានបរិសទ្យដើម្បីសម្តែងដល់សិរីរាជសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់ងើយមើលផ្ទៃអាកាសខាងលើ ទ្រង់ក្រឡេកមើលមហាទ្វីបបួន ដែលមានកោះតូចៗ ប្រមាណ ៥ រយៗ ជាបរិវារ ដូចស្រះកេរតឡើងឯងទាំងបួន ដែលវិចិត្រដោយគុម្ពបទុម ឧប្បល កុមុទ និងបុណ្ឌរីក ដែលរីកល្អហើយ ដូច្នោះ ស្តេចត្រឡប់ទៅកាន់រាជធានីរបស់ព្រះអង្គតាមលំដាប់ តាមផ្លូវដែលចក្កវត្តន៍បង្ហាញហើយនោះឯង ។ លំដាប់នោះ ចក្កវត្តន៍នោះ ក៏តាំងនៅដូចនៅញ្ជាំងខាងក្នុងទ្វារនៃបុរីឲ្យស្រស់ល្អ ដូច្នោះ ។ កាលចក្កវត្តន៍នោះប្រតិស្ឋានយ៉ាងនេះហើយ កិច្ចដែលនឹងគប្បីធ្វើណាមួយ ដោយគប់ភ្លើង ឬដោយប្រទីបខាងក្នុងរាជបុរីក៏មិនមាន ។ ពន្លឺនៃចក្កវត្តន៍នោះ រមែងកម្ចាត់ភាពងងឹតនៃរាត្រី ។ តែបុគ្គលពួកណា ត្រូវការភាពងងឹត ភាពងងឹតនោះ ក៏រមែងមានដល់បុគ្គលទាំងនោះ ។ ចក្កវត្តន៍ទាំងអស់នោះមានហើយយ៉ាងនេះ ដល់ព្រះបាទមហាសុទស្សនចក្រពត្តិ ។ ដោយហេតុនោះ ទើបលោកពោលថា **ឧក្កិណ្ណាសមុទ្ទំ អជ្ឈោគាហេត្វា ។បេ។ ឯវរូបំ ចក្ករតនំ ចាតុរហោសិ ។**

អមាត្យទាំងឡាយរបស់ស្តេចចក្រពត្តិ ដែលមានចក្កវត្តន៍ប្រាកដយ៉ាងនេះ ក៏ឲ្យធ្វើទីនៅរបស់ដ៏រមណីយ ប្រក្រតីឲ្យជាភូមិភាគស្មើបរិសុទ្ធស្អាត ប្រោះព្រំដោយក្លិនសុរភី មានចន្ទន៍ក្រហមជាដើម តាក់តែងឲ្យស្អាតល្អ ដូចវិមានទេវតា ខាងក្រោមពាសពេញដោយផ្កាសុរភី ផ្កាកុសុម ដែលមានពណ៌វិចិត្រ

ខាងលើមានពិតានប្រដាប់ដោយក្បាច់ផ្កាកុសុម ដែលគួរពេញចិត្ត រួមខាងក្នុងផ្ចាយមាស ហើយទូលថា បពិត្រសម្មតិទេព សូមព្រះអង្គព្រះតម្រិះ ការមកនៃហត្ថិវត័ន៍មានសភាពបែបនេះ ។ ព្រះរាជានោះ ក៏ទ្រង់ថ្វាយមហាទានដោយនយដែលពោលហើយ ក្នុងកាលមុន និងទ្រង់សមាទានសីល ហើយគង់រឭកដល់បុញ្ញសម្បត្តិនោះ ។ លំដាប់នោះ ជំរីប្រសើរដែលអានុភាពនៃបុណ្យរបស់ព្រះរាជានោះជាស់តឿនហើយ ដូចគ្របសង្កត់សក្ការៈពិសេសនោះ មកអំពីត្រកូលឆទ្ទន្ត ឬអំពីត្រកូលឧបោសថ មានសរីរៈពណ៌សសុទ្ធតាក់តែងការដើរ ក និងមាត់ មានពណ៌ក្រហមដូចមណ្ឌលនៃព្រះអាទិត្យស្រទន់ៗ មានទីប្រតិស្ឋាន ៧ ប្រការ[1] មានរូបរាងអវយវៈតូចធំតាំងទុកយ៉ាងល្អ មានជោះ ក្រចក និងចុងប្រមោយក្រហម អាចហោះបាន ដូចយោគីអ្នកមានឫទ្ធិ រូបរាងធំស ដូចបរិវេណដែលជ្រលក់ដោយលម្អិតនៃមនោសិលា មកឈរក្នុងប្រទេសនោះ ។ ជំរីនោះ មកពីត្រកូលជំរីឆទ្ទន្ត គឺតូចជាងជំរីឆទ្ទន្តទាំងអស់ ។ បើមកអំពីត្រកូលជំរីឧបោសថ រមែងធំជាងជំរីឧបោសថទាំងពួង ។ តែក្នុងបាលី មានមកថា នាគរាជ គឺជំរីឈ្មោះឧបោសថ ដូច្នេះ ។ លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ដែលឈ្មោះថា ជំរីនាគរាជ មិនសមគួរដល់បុគ្គលណាមួយ ជាជំរីតូចជាងជំរីទាំងអស់ រមែងមកដូច្នេះ ។ ជំរីនេះរមែងមកដល់ស្តេចចក្រពត្តិ ដែលមានវត្តនៃចក្រពត្តិ ទ្រង់ត្រិះរិះដោយនយដូចពោលហើយនោះឯង ។ ជំរីនាគរាជមកកាន់រោងជំរីមង្គលជាប្រក្រតីខ្លួនឯង មិនកម្ចាត់ជំរីមង្គល ឈរនៅក្នុងទីនោះ ។ ដោយហេតុនោះ ទើបលោក

១- ជំរីនោះ មានជើង ៤ ប្រមោយ ១ កន្ទុយ ១ ផ្ចិត ១ ទល់គ្នានឹងផែនដី រួមជា ៧ ដូច្នេះ ។

ពោលថា **បុន ចបរំ អានន្ទ ។បេ។ នាគរាជ** *ដូច្នេះ ។*

បុគ្គលទាំងឡាយមានអ្នកចិញ្ចឹមជីរាជើម ឃើញហត្ថិរ័តន៍ដែលប្រាកដយ៉ាងនោះហើយ រីករាយសប្បាយចិត្តប្រញាប់ទៅទូលជល់ព្រះរាជា ។ព្រះរាជាប្រញាប់យាងមកមើលហត្ថិរ័តន៍នោះ ទ្រង់មានព្រះរាជហឫទ័យថ្លាផូរផង់ ទ្រង់គិតថា ហត្ថិយានប្រសើរហ្ន៎ សមគួរនាំចូលហ្វឹកហាត់ ដូច្នេះ ។ ទ្រង់លាព្រះហស្ត លំជាប់នោះ ជីរានោះ ដូចជីរមេដោះ រំសាយត្រចៀក សម្តែងសំឡេងស្រែក ចូលទៅគាល់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រោថ្នានឹងស្តេចឡើងប្រថាប់ជីរានោះ ។ លំជាប់នោះ បរិជនរបស់ព្រះរាជានោះដឹងព្រះរាជចំណង ធ្វើទង់មាស គ្រឿងប្រដាប់មាស គ្របដោយសំណាញ់មាស នាំចូលទៅរកហត្ថិរ័តន៍នោះ ។ ព្រះរាជាមិនឲ្យជីរានោះអង្គុយ ស្តេចឡើងជណ្តើរដែលធ្វើដោយរតន: ៧ ប្រការ មានព្រះរាជហឫទ័យបង្អោនទៅក្នុងអាកាស ។ ព្រមដោយចិត្តប្បាទរបស់ព្រះរាជានោះ ហត្ថិនាគរាជនោះ ក៏អណ្តែតឡើងកាន់ផ្ទៃអាកាសដ៏រុងរឿងដោយពន្លឺកែវឥន្ទនិល និងកែវមណី ដូចរាជហង្សដូច្នោះ ។ តពីនោះ បរិស័ទរបស់ព្រះរាជាទាំងអស់ក៏ហោះឡើង ដោយនយដែលពោលហើយក្នុងចក្កចារិកានោះឯង ។ ព្រះរាជាមួយអន្ទៅដោយបរិស័ទ ទតប្រឹថពីទាំងមូល ក៏ត្រឡប់មកកាន់រាជធានី ខាងក្នុងអាហារព្រឹក ដោយប្រការដូច្នេះ ។ ហត្ថិរ័តន៍របស់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ក៏មានសភាពដូច្នោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា **ឥស្សា រញ្ញោ ។បេ។ ចាតុរហោសិ** *ដូច្នេះ ។*

អមាត្យទាំងឡាយ របស់ស្តេចចក្រពត្តិ ដែលមានហត្ថិរ័តន៍ប្រាកដយ៉ាងនេះហើយ ឲ្យធ្វើ និងប្រដាប់រោងសេះមង្គលតាមប្រក្រតី ឲ្យមានផ្ទៃដី

ស្អាត រាបស្មើ ញ្ជាំងព្រះខស្សាហៈឲ្យកើតឡើងដល់ព្រះរាជា ដើម្បីទ្រង់គិតការមកនៃសេះនោះ ដោយន័យមុននោះឯង ។ ព្រះរាជានោះ ទ្រង់មានសក្ការៈបង្អោនក្នុងទាន ដែលទ្រង់ធ្វើហើយដោយន័យមុននោះឯង ទ្រង់សមាទានសីលនិងវត្ត គង់លើផ្ទៃប្រាសាទ ទ្រង់រព្រកដល់បុញ្ញសម្បត្តិ ។ លំដាប់នោះ អស្សរាជ ឈ្មោះថា វលាហក មកពីត្រកូលសេះសិន្ធព ដែលអានុភាពនៃបុណ្យរបស់ព្រះរាជានោះដាស់តឿនហើយ មានសិរីនៃជុំពពកស ក្នុងសរទ-កាលដែលត្រូវផ្ទេកបន្ទោរ មានជើងក្រហម មានក្រចកជើងក្រហម មានរូបរាងរឹងមាំបរិសុទ្ធល្អ ដូចជាជុំរស្មីនៃព្រះចន្ទ មានក្បាលខ្មៅ ព្រោះដល់ព្រមដោយរោមត្រង់មូលល្អិត ពណ៌ស ដូចស្មៅយាប្ទង ដែលសម្រេចដោយល្អតាំងទុកហើយ អាចហោះបាន មកនៅក្នុងរោងនោះ ។ អស្សរាជនោះ មកហើយដល់ព្រះបាទមហាសុទស្សនចក្រពត្តិ ដូចហត្ថិរ័តន៍ដូច្នោះ ។ បទទាំងពួងដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងហត្ថិរ័តន៍ន៉ុះឯង ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ អស្សរ័តន៍នោះ ទើបត្រាស់ថា **បុន ចបរំ** ដូច្នេះជាដើម ។

មណិរ័តន៍មកពីវេបុលបព៌ត ប្រវែង ៤ ហត្ថ មានទ្រង់ទ្រាយល្អ ប្រដាប់ដោយមាស បទុមទាំងពីរ មានត្របកជាកែវមុក្តាដ៏បរិសុទ្ធ មានពន្ធឺ ចេញក្នុងទីបំផុតទាំងពីរខាង មានមណី ៨៤០០០ ជាបរិវារ ហាក់ដូចជាផ្សាយទៅខ្ទប់នឹងសិរីនៃព្រះចន្ទពេញវង់ ដែលពួកផ្តាយហែហមជុំវិញ មកដល់ស្តេចចក្រពត្តិ ដែលមានអស្សរ័តន៍ប្រាកដហើយយ៉ាងនេះ ។ កាលមណិរ័តន៍នោះមកហើយយ៉ាងនេះ ដែលបុគ្គលដាក់ក្នុងសំណាញ់មុក្តា លើកឡើងកាន់

អាកាសប្រមាណ ៦០ ហត្ថ ត្រឹមចុងឫស្សី ពន្លឺក៏ផ្សាយទៅកាន់ឱកាសប្រមាណមួយយោជន៍ដោយជុំវិញ ដែលជាហេតុឲ្យឱកាសទាំងអស់នោះ មានពន្លឺដូចក្នុងវេលាអរុណរះដូច្នោះ ។ បន្ទាប់ពីនោះ អ្នកស្រែក៏ប្រកបកសិកម្ម ឈ្មួញក៏ប្រកបការជួញដូរ អ្នកសិល្បៈនោះៗ ក៏ប្រកបការងារនោះៗ សម្គាល់ថាជាពេលថ្ងៃ ។ មណិរតន៍នោះមានហើយយ៉ាងនោះ ដល់ព្រះបាទមហាសុទស្សនចក្រពត្តិនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បុន ចបរំ អានន្ទ ។បេ។ មណិរតនំ ចាតុរហោសិ** *ដូច្នេះ ។*

ឥត្ថិរតន៍ មានហេតុ គឺអារម្មណ៍ជាសុខពិសេស កើតឡើងដល់ស្តេចចក្រពត្តិ ដែលមានមណិរតន៍ប្រាកដហើយយ៉ាងនេះ ។ ព្រះញាតិទាំងឡាយរមែងនាំឥត្ថិរតន៍នោះ មកអំពីមទ្ទរាជត្រកូល មកជាអគ្គមហេសីរបស់ស្តេចចក្រពត្តិនោះ ឬមកពីឧត្តរកុរុប្រទេស ដោយបុញ្ញានុភាព ។ សម្បត្តិនៃឥត្ថិរតន៍នោះ ដ៏សេសមកហើយក្នុងបាលីនោះឯង ដោយន័យជាដើមថា ម្នាលអានន្ទ ទៅទៀត ឥត្ថិរតន៍ មានរូបឆោមល្អ គួរឲ្យអ្នកផងពិតពិលរមិលមើលប្រាកដហើយដល់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ។ក្នុងបណ្តាសម្បត្តិនោះ ឈ្មោះថា **អភិរូបា** *ព្រោះឥត្ថិរតន៍នោះ មានរូបស្អាត បរិបូណ៌ដោយទ្រង់ទ្រាយ ។ ឈ្មោះថា* **ទស្សនីយា** *ព្រោះកាលមើលក៏ត្រូវភ្នែក ត្រូវបញ្ឈប់ធុរកិច្ចដទៃៗ សម្លឹងមើល ។ ឈ្មោះថា* **ចាសាធិកា** *ព្រោះកាលមើលក៏ញាំងចិត្តឲ្យជ្រះថ្លា ដោយអំណាចសោមនស្ស ។ បទថា* **បរមាយ** *សេចក្តីថា ឧត្តម ព្រោះនាំមកនូវសេចក្តីជ្រះថ្លាយ៉ាងនេះ ។ បទថា* **វណ្ណោកិរតាយ** *សេចក្តីថា ព្រោះពណ៌សម្បុរល្អ ។ បទថា* **សមង្គាគតា** *សេចក្តីថា ចូលដល់*

ហើយ ។ មួយប្រការទៀត ឈ្មោះថា **អភិរូចា** *ព្រោះមិនខ្ពស់ពេក មិនទាបពេក ។ ឈ្មោះថា* **ឧស្សន្នីយា** *ព្រោះមិនស្គមពេក មិនធាត់ពេក ។ ឈ្មោះថា* **ចាសាធិកា** *ព្រោះមិនខ្មៅពេក មិនសពេក ។ ឈ្មោះថា* **បរមាយ វណ្ណ-ចោក្ករតាយ សមន្នាគតា** *ព្រោះឈានកន្ធ៍ពណ៌សម្បុរមនុស្ស តែមិនដល់ពណ៌សម្បុទិព្វ ។ ពិតហើយ ពន្លឺពណ៌សម្បុរបស់ពួកមនុស្ស រមែងមិនភ្លឺចេញមកខាងក្រៅ ។ តែពណ៌សម្បុរបស់ទេវតាទាំងឡាយ រមែងភ្លឺចេញទៅឆ្ងាយ ។ ចំណែកពន្លឺសរីរៈនៃឥត្ថិរតន៍នោះ រមែងញុំាងប្រទេសប្រមាណ ១២ ហត្ថ ឲ្យភ្លឺបាន ។ ក្នុងបណ្តាសម្បត្តិ មានមិនខ្ពស់ពេកជាដើមរបស់ឥត្ថិរតន៍នោះ លោកពោលអារោហសម្បត្តិ ដោយគូទីមួយ ពោលបរិណាហសម្បត្តិ ដោយគូទីពីរ ពោលវណ្ណសម្បត្តិ ដោយគូទីបី ពោលភាពដែលកាយវិបត្តិ ដោយកាយវិបត្តិ ដោយអាការវិបត្តិ ៦ ប្រការនោះ ។ ពោលកាយសម្បត្តិ ដោយបទនេះថា* **អតិក្កន្តា មានុសវណ្ណំ** *។ បទថា* **តូលបិចុនោ វា កប្ប-សបិចុនោ វា** *សេចក្តីថា ដូចសម្ងីគ ឬសម្ងីកប្បាស នៃកាយសម្ផស្ស ដែលយកទៅជាក់លើដុំទឹកដោះថ្លា ហើយចែកចេញជា ៧ ចំណែក ។ បទថា* **សីតេ** *សេចក្តីថា មានសភាពត្រៀក ក្នុងកាលព្រះរាជារងា ។ បទថា* **ឧណ្ហេ** *សេចក្តីថា ត្រជាក់ ក្នុងកាលដែលព្រះរាជាក្តៅ ។ បទថា* **ចន្ទនគន្ធោ** *សេចក្តីថា ក្លិនចន្ទន៍ក្រហមដែលប្រកបដោយគន្ធជាតិ ៤ ប្រភេទនៅថ្មី កិនល្អិតល្អអស់កាលជានិច្ច រមែងផ្សាយចេញអំពីកាយ ។ បទថា* **ឧប្បលគន្ធោ** *សេចក្តីថា ក្លិនក្រអូបក្រៃលែងនៃក្លិនឈូកខៀវ ដែលរីកខណៈនោះ រមែងផ្សាយចេញពីមាត់*

វេលាក្អួក ឬនិយាយ ។ ទ្រង់សម្តែងអាចារៈដែលសមគួរ នៃសរីរសម្បត្តិ ប្រកបដោយសម្ផស្សសម្បត្តិ និងគន្ធសម្បត្តិយ៉ាងនេះ ទើបត្រាស់ថា **តំ ខោ បន** *ជាដើម ។ ក្នុងអាចារៈនោះ ឥត្ថិរតន៍ឃើញព្រះរាជាហើយ ក្រោកឡើងចាកអាសនៈមុន ដូចបុគ្គលត្រូវក្តៅងនេះ ព្រោះដូច្នោះ ទើបឈ្មោះថា* **បុព្ពុដ្ឋាយិនី** *លុះព្រះរាជានោះគង់ហើយឥត្ថិរតន៍ធ្វើកិច្ច មានបក់ដោយផ្ទៃតស្វឹកត្នោតជាដើម ដល់ព្រះរាជានោះ ហើយទើបសម្រាក គឺអង្គុយឯក្រោយ ព្រោះដូច្នោះ ទើបឈ្មោះថា* **បច្ឆានិចាតិនី** ។ *ឥត្ថិរតន៍ រមែងខ្វល់ខ្វាយក្នុងកិច្ចដែលគប្បីធ្វើ ដោយវាចាថា បពិត្រទេវៈ ខ្ញុំម្ចាស់នឹងធ្វើអ្វីដល់ព្រះអង្គ ព្រោះដូច្នោះ ទើបឈ្មោះថា* **កិំការបដិសាវិនី** ។ *ឥត្ថិរតន៍រមែងប្រព្រឹត្ត គឺធ្វើវត្តុដែលពេញព្រះរាជហឫទ័យរបស់ព្រះរាជាប៉ុណ្ណោះ ព្រោះដូច្នោះ ទើបឈ្មោះថា* **មនាបចារិនី** ។ *ឥត្ថិរតន៍ រមែងពោលពាក្យដែលគួរស្រឡាញ់ ដល់ព្រះរាជាប៉ុណ្ណោះ ព្រោះដូច្នោះ ទើបឈ្មោះថា* **បិយវាទិនី** ។ *ឥឡូវនេះ ទើបព្រះមានព្រះភាគត្រាស់ថា* **តំ ខោ បន** *ជាដើម ដើម្បីទ្រង់សម្តែងថា អាចារៈរបស់ឥត្ថិរតន៍នេះបរិសុទ្ធតែម្យ៉ាង ដោយមិនមានសាថេយ្យៈឡើយ ។ បណ្តាបទទាំងនោះ បទថា* **នោ អតិចារី** *សេចក្តីថា មិនប្រព្រឹត្តកន្លង ។ លោកពោលថា ឥត្ថិរតន៍មិនច្រោថ្នាបុរសដទៃ សូម្បីដោយចិត្តក្រៅអំពីព្រះរាជា ។ ក្នុងបទនោះ អាចារៈទាំងឡាយណា របស់ឥត្ថិរតន៍នោះលោកពោលថា* **អភិរូចា** *ជាដើម ក្នុងខាងដើម និងពោលថា* **បុព្ពុដ្ឋាយិនិ** *ក្នុងទីបំផុត អាចារៈទាំងនោះជាគុណដោយប្រក្រតីប៉ុណ្ណោះឯង ។ សម្បត្តិជាដើមថា* **អតិក្កន្តា មានុសវណ្ណំ**

គប្បីជ្រាបថា កើតឡើងហើយដោយអានុភាពកម្មចាស់ តាំងពីចក្កវត្តន៍ប្រាកដឡើង ព្រោះអាស្រ័យបុណ្យរបស់ស្តេចចក្រពត្តិ ។ ឬសម្បត្តិថា **អភិរូបតា** *ជាដើម កើតបរិបូណ៌ដោយអាការទាំងពួង តាំងអំពីចក្កវត្តន៍ប្រាកដហើយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **ឯវរូបំ ឥត្ថិរតនំ ចាតុរោសិ** *ដូច្នេះ ។*

គហបតិវត្តន៍ ដើម្បីឲ្យកិច្ចទាំងឡាយ ដែលគប្បីធ្វើដោយទ្រព្យ ប្រព្រឹត្តទៅដោយសប្បាយ រមែងប្រាកដដល់ស្តេចចក្រពត្តិ ដែលមានឥត្ថិវត្តន៍ប្រាកដហើយយ៉ាងនេះ ។ គហបតីនោះ ដោយប្រក្រតីមានកោគៈច្រើន កើតក្នុងត្រកូលមានកោគៈច្រើន ចម្រើនដោយគំនរទ្រព្យ របស់ព្រះរាជា ជាសេដ្ឋីគហបតី ។ ទិព្វចក្ខុដែលជាហេតុឃើញរណ្តៅទ្រព្យ ខាងក្នុងមួយយោជន៍ សូម្បីខាងក្នុងប្រើថពី ដែលកើតពីផលកម្ម សង្គ្រោះដោយអានុភាពចក្កវត្តន៍ រមែងប្រាកដដល់គហបតិវត្តន៍នោះៗ ឃើញសម្បត្តិនោះហើយ ត្រេកអរ ទៅបាវណាព្រះរាជាដោយទ្រព្យ ទទួលធ្វើកិច្ចទាំងឡាយ ដែលគប្បីធ្វើដោយទ្រព្យទាំងអស់ឲ្យសម្រេច ។ គហបតិវត្តន៍របស់ព្រះបាទមហាសុទស្សនចក្រពត្តិ ក៏ញុំាងកិច្ចដែលគប្បីធ្វើដោយទ្រព្យ ឲ្យសម្រេចយ៉ាងនោះដូចគ្នា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បុន ចបរំ អានន្ទ ។បេ។ ឯវរូបំ គហបតិរតនំ ចាតុរោសិ** *ដូច្នេះ ។*

បរិនាយករត្តន៍ ដែលអាចចាត់ចែងកិច្ចសព្វយ៉ាង រមែងប្រាកដដល់ស្តេចចក្រពត្តិ ដែលមានគហបតិវត្តន៍ប្រាកដហើយយ៉ាងនេះ ។ បរិនាយកវត្តន៍នោះ ជាព្រះរាជឱរសច្ឆរបស់ព្រះរាជានោះឯង ។ ដោយប្រក្រតីបរិនា-

យកវត្តន៍នោះ ជាបណ្ឌិតឈ្វាសវៃ មានបញ្ញាអាស្រ័យបុញ្ញានុភាពរបស់ព្រះរាជា រមែងចូលដល់ញាណ ដឹងចិត្តបុគ្គលដទៃដោយអានុភាពនៃកម្មរបស់ខ្លួន ដែលជាហេតុឲ្យដឹងវារចិត្តនៃបរិស័ទប្រមាណ ១២ យោជន៍ អាចកំណត់ដឹងហិតប្រយោជន៍ និងអហិតប្រយោជន៍ ដល់ព្រះរាជាបាន ។ បរិនាយកវត្តន៍នោះ ឃើញអានុភាពរបស់ខ្លួននោះ ត្រេកអរ បវារណាព្រះរាជាដោយការបរិហារកិច្ចទាំងអស់ ។ បរិនាយកវត្តន៍ បវារណាព្រះបាទមហាសុទស្សន-ចក្រពត្តិយ៉ាងនោះ ដូចគ្នា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បុន ចបរំ អានន្ទ ។បេ។ បរិនាយកវត្តនំ ចាតុរហោសិ** *ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា* **ឋបេតព្វំ ឋបេតុំ** *សេចក្តីថា ដើម្បីឲ្យតាំងនៅក្នុងឋានន្តរនោះៗ ។*

[๑๑] *បទថា* **សមវេថាកិនិយា** *សេចក្តីថា ដែលកើតអំពីផលកម្មដែលស្មើ ។ បទថា* **គហណិយា** *សេចក្តីថា ដោយតេជោធាតុដែលកើតអំពីកម្ម ។ ក្នុងបទនេះ អាហារត្រឹមតែសោយហើយរបស់ព្រះបាទមហាសុទស្សនចក្រពត្តិ រមែងរលួយ ឬរមែងតាំងនៅយ៉ាងនោះ ដូចកត្តដែលសោយដល់ព្រមដោយតេជោធាតុ ដែលកើតអំពីវិបាកដ៏ស្មើទាំងពីរនោះ ។ ការពេញព្រះរាជហឫទ័យក្នុងព្រះក្រយាហារ ក្នុងកាលនៃភត្ត រមែងកើតឡើងដល់ព្រះបាទមហាសុទស្សនចក្រពត្តិណា ព្រះបាទមហាសុទស្សនចក្រពត្តិរាជនោះ ទ្រង់ដល់ព្រមដោយតេជោធាតុដែលកើតអំពីវិបាកដ៏ស្មើ ដូច្នេះ ។*

[๑๓] *បទថា* **មាបេសិ ខោ** *សេចក្តីថា ទ្រង់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ទ្រង់ឲ្យពពួកជនធ្វើការកសាងស្រះបោក្ខរណី ๘๔๐๐๐ កន្លែង*

ក៏ផុសឡើងដំណាលគ្នានឹងចិត្តប្បាទរបស់ព្រះរាជា ។ បទថា **មาเยสิ เ**ខ្ញុំ *នោះ ព្រះមានព្រះភាគត្រាស់សំដៅដល់ស្រះបោក្ខរណីទាំងនោះ ។ បទថា* **ទ្វីហิ เวฬิกาหิ** *សេចក្តីថា ព័ទ្ធដោយឥដ្ឋមួយជុំ ក្នុងទីបំផុតនៃឥដ្ឋទាំងឡាយ ព័ទ្ធដោយឥដ្ឋមួយជុំ ក្នុងទីបំផុតនៃការកំណត់បរិវេណ ។*

បទថា **ฬតฺถเหาสิ** *សេចក្តីថា មានហើយព្រោះអ្វី បានឮថា ក្នុងថ្ងៃមួយ មហាបុរសសម្ញឹងមើលមហាជនទៅងូត និងផឹក គិតថា ជនទាំងនេះរមែងទៅដោយកេទមនុស្សឆ្កួត បើគប្បីមានផ្ការប្រជាប់ក្នុងស្រះនោះ ដល់ជនទាំងនោះ ក៏ជាការល្អ លំដាប់នោះ ព្រះបាទមហាសុទស្សនចក្រពត្តិនោះ មានព្រះរាជតម្រិះ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា* **สญฺโจเตสิ** *សេចក្តីថា ព្រះបាទមហាសុទស្សនចក្រពត្តិទ្រង់តម្រិះថា ធម្មតាផ្កា រមែងរីកក្នុងរដូវតែមួយប៉ុណ្ណោះ អញនឹងធ្វើដោយប្រការដែលផ្ការីកគ្រប់រដូវ ។ បទថា* **เจาเปสิ** *សេចក្តីថា ទ្រង់ឲ្យនាំពូជឧប្បលច្រើនប្រភេទអំពីទីនោះៗ ទ្រង់ឲ្យដាំ ។ ផ្កាទាំងអស់ ក៏សម្រេចព្រមគ្នានឹងការកើតឡើងនៃចិត្តប្បាទរបស់ព្រះបាទមហាសុទស្សនចក្រពត្តិនោះ ។ មនុស្សលោកយល់ថា ផ្កានោះ ព្រះរាជាទ្រង់ឲ្យដាំ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **เจาเปสิ** *ដូច្នេះ ។ តាំងអំពីនោះមក មហាជនបានប្រជាប់ផ្កាដែលកើតអំពីទឹក និងកើតលើគោកច្រើនប្រការ ដូចលេងនក្ខត្តឫក្ស ដូច្នោះ ។*

លំដាប់នោះ ព្រះរាជា ទ្រង់មានព្រះរាជបំណងនឹងធ្វើជនឲ្យដល់ព្រមដោយសេចក្តីសុខក្រៃលែងជាងនោះ ទើបទ្រង់គិតចាត់រកសេចក្តីសុខដល់ជនដោយបទថា **យนฺนូนาหं ฯมาสं เจากฺขรณีนំ តីរេ** *ជាដើម ហើយទ្រង់ធ្វើ*

កិច្ចទាំងពួង ។ ក្នុងបណ្តាបទទាំងនោះ បទថា **ឆ្លាបេសុំ** *សេចក្តីថា អ្នកជនៃជម្រះរាងកាយ អ្នកជនៃប្រកបលម្អិតទាំងឡាយ អ្នកជនៃនាំទឹកមកឲ្យដល់អ្នកឆ្អែតទឹក ត្រង់មាត់ស្រះបោក្ខរណី អ្នកជនៃទទួលសំពត់ និងឲ្យសំពត់ ។ បទថា* **បដ្ឋបេសិ** *សេចក្តីថា ទ្រង់រៀបចំដូចម្តេច ។ ទ្រង់រៀបចំរាជការ ប្រជាប់ដ៏សមគួរដល់ស្ត្រី និងបុរសទាំងឡាយ ទ្រង់រៀបចំត្រឹមតែស្ត្រីប៉ុណ្ណោះ ដោយអំណាចការបម្រើក្នុងទីនោះៗ ទ្រង់រៀបកិច្ចទាំងអស់ដ៏សេស ដោយអំណាចបរិច្ចាគ ទ្រង់ឲ្យវាយស្គរប្រកាសថា ព្រះបាទមហាសុទស្សនចក្រពត្តិទ្រង់ឲ្យទាន អ្នកទាំងឡាយ ចូរបរិភោគទាននោះ ។*

មហាជនមកកាន់មាត់ស្រះបោក្ខរណី ឆ្អែតទឹក ផ្ងាស់សំពត់ លាបស្រឡាបដោយគ្រឿងក្រអូបផ្សេងៗ ប្រជាប់ខ្លួនដ៏វិចិត្រ ទៅរោងទាន បរិភោគ និងផឹកវត្ថុតាមត្រូវការ ក្នុងបណ្តាយាគូ ភត្ត និងខាទនីយៈច្រើនប្រការ មួយអន្ទើដោយទឹកបាន ๘ យ៉ាង ស្បៀកជណ្តប់សំពត់កប្បាសសាច់ម៉ដ្ដដ៏ទន់ មានពណ៌ផ្សេងៗ សោយសម្បត្តិ លះបុគ្គលដែលមានរបស់ដូច្នោះទៅ ។ អ្នកដែលមិនមានរបស់ដូច្នោះ កាន់យកហើយអំពីនោះទៅ ។ បុគ្គលដែលអង្គុយលើជំរី សេះ និងយានជាដើម ត្រាច់ទៅ បន្តិចៗ មិនត្រូវការក៏ចេញទៅ ត្រូវការក៏កាន់យកទៅ ។ បុគ្គលដែលដេកក្នុងទីដេកដ៏ប្រសើរ សោយសម្បត្តិហើយ មិនត្រូវការក៏ចេញទៅ ត្រូវការក៏ទទួល ។ អ្នកសោយសម្បត្តិជាមួយស្ត្រីទាំងឡាយ មិនត្រូវការក៏ចេញទៅ ត្រូវការក៏ទទួល ។ អ្នកប្រជាប់ខ្លួនដោយគ្រឿងរតន: ๗ ប្រការ សោយសម្បត្តិហើយ មិនត្រូវការក៏ចេញទៅ ត្រូវការក៏ទទួលយក ។ ទាននោះ ព្រះបាទមហាសុទស្សនចក្រពត្តិ ទ្រង់ក្រោកឡើងហើយក៏ឲ្យ ។

ការងារជនៃរបស់មនុស្សជម្ពូទ្វីបទាំងឡាយមិនមាន ។ មនុស្សជម្ពូទ្វីប ទៅបរិភោគទានរបស់ព្រះរាជាប៉ុណ្ណោះ ។

[๑๔] *លំដាប់នោះ ព្រាហ្មណ៍គហបតីទាំងឡាយគិតថា ព្រះរាជានេះកាលនឹងឲ្យទានបែបនេះ ក៏ទ្រង់មិនឲ្យនាំអ្វីមកថា អ្នកទាំងឡាយ ចូរឲ្យអង្ករជាដើម ឬឲ្យទឹកដោះជាដើមដល់យើង សេចក្តីនោះមិនសមគួរនឹងនៅស្ងៀមព្រងើយ ព្រោះថា ព្រះរាជារបស់ពួកយើង ទ្រង់មិនឲ្យនាំមក ។ ព្រាហ្មណ៍គហបតីទាំងនោះ ក៏រួបរួមទ្រព្យសម្បត្តិចំនួនច្រើន នាំទៅថ្វាយដល់ព្រះរាជា ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ថា* **អថខោ អានន្ទ ព្រាហ្មណគហបតិកា** *ជូច្នេះជាដើម ។*

បទថា **ឯវំ សមចិន្តេសុំ** *សេចក្តីថា គិតរឿយៗ យ៉ាងនេះ ព្រោះហេតុអ្វី ព្រោះព្រាហ្មណ៍គហបតីទាំងឡាយ គិតរឿយៗ យ៉ាងនេះថា អ្នកខ្លះនាំទ្រព្យសម្បត្តិអំពីផ្ទះតិច អ្នកខ្លះនាំមកច្រើន កាលទ្រព្យសម្បត្តិកំពុងរួបរួមសូម្បីសំឡេងគឹកកង ក៏គប្បីកើតឡើងថា ហេតុដូចម្តេចលោកប៉ុណ្ណោះនាំទ្រព្យសម្បត្តិអំពីផ្ទះល្អ យើងនាំមកពីផ្ទះមិនល្អ ហេតុដូចម្តេច លោកប៉ុណ្ណោះ នាំទ្រព្យសម្បត្តិអំពីផ្ទះច្រើន យើងមិនច្រើន ដូច្នេះ សំឡេងគឹកកងនោះ កុំគប្បីកើតឡើងឡើយ ។*

[๑๕-๑๖] *បទថា* **ឯហិ ភុំ សម្ម** *សេចក្តីថា នែអ្នកមានយស ចូរអ្នកមក ។ បទថា* **ធម្មំ ឆាម ចាសាធំ** *សេចក្តីថា លើកឡើងហើយ ទ្រង់តាំងឈ្មោះប្រាសាទ ។ វិស្សកម្មទេវបុត្តក្រាបទូលថា បពិត្រទេវៈ ប្រាសាទនោះធំប៉ុនណា កាលព្រះឥន្ទ្រត្រាស់ថា ប្រាសាទនោះ បណ្តាយមួយយោជន៍*

ទទឹងកន្លះយោជន៍ សាងដោយរតនៈទាំងពួង វិស្សកម្មទេវបុត្តទទួលព្រះតម្រាស់ថា អំពើយ៉ាងនេះ ជាការចម្រើនដល់ព្រះអង្គហើយ លំដាប់នោះ ទូលឲ្យព្រះធម្មរាជាទ្រង់ទទួលជ្រាបហើយ ក៏ធ្វើឲ្យសម្រេច ។

ក្នុងបទទាំងនោះ បទថា **ឯវំ ភន្តេ តវាតិ ខោ អានន្ទ** *សេចក្តីថា ម្នាលព្រះអានន្ទ (វិស្សកម្មទេវបុត្រទូលទទួលហើយ) ថា អំពើយ៉ាងនេះ ជាការចម្រើនដល់ព្រះអង្គហើយ ។ បទថា* **បដិស្សុណិត្វា** *សេចក្តីថា ទទួលជ្រាបហើយ គឺក្រាបទូលហើយ ។ បទថា* **តុណ្ហីភាវេន** *សេចក្តីថា ព្រះបាទមហាសុទស្សនចក្រពត្តិទ្រង់បំណងថា អញនឹងមានឱកាសធ្វើការបដិបត្តិសមណធម៌ ទ្រង់ទទួលដោយការស្ងៀម ។*

បទថា **សារមយោ** *សេចក្តីថា សម្រេចដោយខ្លឹមចន្ទន៍ ។ ក្នុងបទថា* **ទ្វីហិ វេឌិកាហិ** *នោះ របងមួយមានក្នុងកំពូលឧណ្ហិស្ស របងមួយមានក្នុងទីបំផុតកំណត់ខាងក្រោម[1] ។ បទថា* **ទុទ្ទិក្ខោ អហោសិ** *សេចក្តីថា ឃើញបានលំបាក គឺឃើញបានលំបាក ព្រោះសម្បត្តិនៃពន្លឺ ។ បទថា* **មុសតិ** *គឺនាំទៅឲ្យសម្រេច គឺមិនឲ្យតាំងនៅដោយសភាពជានិច្ច ។ បទថា* **ឧបវិទ្ធេ** *សេចក្តីថា រឹងមាំ គឺនៅធ្ងាយ ព្រោះប្រាសចាកពពក ។ បទថា* **ឧឡារេ** *សេចក្តីថា ក្នុងអាកាស ។ បទថា* **មាបេសិ ខោ** *សេចក្តីថា វិស្សកម្មទេវបុត្រមិនធ្វើយ៉ាងនេះថា អញនឹងសាងស្រះបោក្ខរណីក្នុងទីនេះ អ្នកទាំងឡាយ ចូរវើផ្ទះរបស់*

១- ចារីក្នុងអដ្ឋកថាថា ឯកា វេទិកា បនស្ស ឧណ្ហីសមត្ថកេ អហោសិ , ឯកា ហេដ្ឋា បរិច្ឆេទមត្តកេ ។ ពាក្យថា វេទិកានេះ បិដកខ្មែរ ប្រែថា របង តែក្នុងវចនានុក្រម ប្រែថា ភ្ជាក់ដៃ បង្អាន់ដៃ ក្តារហឹង ជើងម៉ាសម្រាប់អង្គុយ ។

អ្នក ដូច្នេះហើយ សាងទ្បើយ ។ ស្រះបោក្ខរណីបែបនោះ បានផុសទ្បើង ហើយ ដោយអំណាចនៃចិត្តប្បាទរបស់ព្រះបាទមហាសុទស្សនចក្រពត្តិនោះ ។ បទថា **តេ សព្វកាមេហិ** *សេចក្តីថា ទ្រង់ផ្គត់ផ្គង់សមណៈទាំងឡាយ ដោយវត្ថុដែលត្រូវការទាំងពួង គឺដោយសមណបរិក្ខារ ទ្រង់ផ្គត់ផ្គង់ព្រាហ្មណ៍ទាំង-ឡាយ ដោយព្រាហ្មណបរិក្ខារ ។*

បឋមភាណវារកថា ចប់

ឈានសម្បត្តិកថា

[๑๗] *បទថា* **មហិទ្ធិកោ** *សេចក្តីថា ទ្រង់ជល់ព្រមដោយឥទ្ធិច្រើន ពោលគឺ សេចក្តីសម្រេចនៃស្រះបោក្ខរណីចំនួន ๘๔๐๐๐ ដោយអំណាចនៃ ចិត្តប្បាទប៉ុណ្ណោះ ។ បទថា* **មហានុភាវោ** *សេចក្តីថា ជល់ព្រមដោយ អានុភាពធំ ព្រោះកម្មដែលគប្បីសោយទាំងនោះមានច្រើន ។ បទថា* **សេយ្យ-ថីទំ** *ត្រឹមតែជានិបាត ។ អត្ថនៃនិបាតនោះថា កម្ម ๓ ប្រការដូចម្តេច ។ បទ ថា* **ទានសច្ច** *បានជល់ បរិច្ចាគសម្បត្តិ ។ បទថា* **ទមសច្ច** *សេចក្តីថា បញ្ញា មកថា* **ទម** *ក្នុងអាទ្បវកសូត្រ ។ ក្នុងបទនេះ យើងទូន្មានខ្លួនឯង រក្សាឧបោ-សថកម្ម ។ បទថា* **សញ្ញមសច្ច** *បានជល់ សីល ។ គប្បីជ្រាបបុព្វបយោគ របស់ព្រះរាជា ដែលតាំងនៅក្នុងសីលនេះ ដូច្នេះថា*

បានឮថា ក្នុងកាលមុន ព្រះរាជាទ្រង់កើតក្នុងត្រកូលគហបតី ។ សម័យ នោះ ក្នុងសាសនារបស់ព្រះពុទ្ធកស្សប ទ្រង់នៅមានព្រះជន្មនៅទ្បើយ មាន ព្រះថេរៈមួយរូបចាំវស្សាក្នុងព្រៃ ។ ព្រះពោធិសត្វចូលព្រៃ ដោយការងារ

របស់ខ្លួន ឃើញព្រះថេរៈហើយ ចូលទៅថ្វាយបង្គំ បានក្រឡេកមើលទីអង្គុយនិងទីចង្រ្កមជាដើមរបស់ព្រះថេរៈ ទើបសួរថា បពិត្រលោកម្ចាស់ជ័ចម្រើន លោកម្ចាស់នៅក្នុងទីនោះឬ ។ ព្រះថេរៈឆ្លើយថា យ៉ាងនោះឯង ទើបមាណពគិតថា សមគួរដល់ការសាងបណ្ណសាលាប្រគេនលោកម្ចាស់ក្នុងទីនេះ ហើយផ្អាកការងាររបស់ខ្លួន ជញ្ជូនទព្វសម្ភារៈធ្វើបណ្ណសាលា លាបបូកជញ្ជាំងដោយជីស្អិត ភ្ជាប់ទ្វារ ធ្វើភ្នាក់ដៃស្រេចហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង គិតថា ព្រះថេរៈនឹងធ្វើការបរិភោគឬទេហ្ន៎ ។ ព្រះថេរៈមកពីស្រុក ចូលទៅកាន់បណ្ណសាលាហើយ អង្គុយត្រង់ទីបង្អែក ។ ឧបាសកនោះមកហើយថ្វាយបង្គំអង្គុយក្នុងទីជិត សួរថា បពិត្រលោកម្ចាស់ បណ្ណសាលានៅជាសប្បាយទេ ។ ព្រះថេរៈពោលថា សប្បាយសមគួរដល់បព្វជិត ។ ឧបាសកសួរថា លោកម្ចាស់នឹងនៅក្នុងទីនេះឬ ។ ព្រះថេរៈឆ្លើយថា អើឧបាសក ។ ឧបាសកនោះជឿថា ព្រះថេរៈនៅដោយអាការទទួល ក៏ទូលឲ្យព្រះថេរៈជ្រាបថា លោកម្ចាស់ គប្បីទៅកាន់ទ្វារផ្ទះរបស់ខ្ញុំជានិច្ចចុះ ហើយពោលបន្តទៀតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យពរមួយដល់ខ្ញុំចុះ ។ ព្រះថេរៈពោលថា នែឧបាសក បព្វជិតមានពរកន្ទងហើយ ។ ឧបាសកពោលថា បពិត្រលោកម្ចាស់ ខ្ញុំសូមពរដែលគួរ និងមិនមានទោស ។ ព្រះថេរៈពោលថា ចូរប្រាប់មកចុះ ។ ឧបាសកពោលថា បពិត្រលោកម្ចាស់ មនុស្សទាំងឡាយ ក្នុងទីជាទីនៅប្រចាំ រមែងប្រាថ្នាការមកក្នុងមង្គល ឬអមង្គល រមែងក្រោធដល់ព្រះថេរៈដែលមិនមក ព្រោះដូច្នោះ លោកម្ចាស់សូម្បីទៅកាន់ទីនិមន្តដទៃហើយ ចូលទៅកាន់ផ្ទះរបស់ខ្ញុំហើយ គប្បីធ្វើកត្តកិច្ច ។ ព្រះថេរៈ ក៏ទទួលហើយ ។

ព្រះពោធិសត្វនោះ ក្រាលកន្ទេលក្នុងសាលា រៀបចំគ្រែ តាំង ធ្វើបង្អែក រៀប ចំកន្ទែងជួតជើង ជីកស្រះ ធ្វើទីចង្ក្រមចាក់រាយដោយឡាច់ កាលឃើញសត្ូ មកទម្ងាយជញ្ជាំង ធ្វើដីស្អិតឲ្យធ្ងាក់ ក៏ធ្វើរបងដោយបន្ទា ឃើញសត្ូចុះស្រះ ធ្វើទឹកធ្វើឲ្យល្អក់ ក៏ធ្វើជណ្តើរខាងក្នុង ព័ទ្ធរបងបន្ទាខាងក្រៅ ដាំដើមត្នោតជា ជួរខាងក្នុងរបង កាលឃើញសត្ូធ្វើកន្ទែងក្នុងទីមហាចង្ក្រមឲ្យស្មោកគ្រោក ក៏ ធ្វើរបងព័ទ្ធទីចង្ក្រម ដាំដើមត្នោតជាជួរក្នុងរបងខាងក្នុង ញ្ជាំងអាវាសឲ្យ សម្រេចយ៉ាងនេះ ប្រគេនត្រៃចីវរ បិណ្ឌបាត ថ្នាំ ភាជនៈបរិភោគ ក្អមទឹក កន្ត្រៃ កាំបិតកាត់ក្រចក ម្ជុល ឈើច្រត់ ស្បែកជើង ពាងទឹក ឆត្រ គប់ភ្លើង ឈើខ្ទារត្រចៀក បាត្រ ស្ទាកបាត្រ សំពត់តម្រងទឹក ទីត្រងទឹក ឬវត្ថុដែល បពូជិតគួរបរិភោគដទៃ ចំពោះព្រះថេរៈ ឈ្មោះថា បរិក្ខារដែលព្រះពោធិសត្ូ មិនប្រគេនដល់ព្រះថេរៈ មិនមាន ។ ព្រះពោធិសត្ូនោះ រក្សាសីល រក្សា ឧបោសថ ទំនុកបម្រុងព្រះថេរៈ រហូតអស់មួយជីវិត[1] ។ ព្រះថេរៈនៅក្នុង អាវាសនោះឯង សម្រេចអរហត្ត ហើយនិញ្ចាន ។ ចំណែកព្រះពោធិសត្ូ ធ្វើបុណ្យរហូតអស់អាយុ ហើយទៅកើតក្នុងទេវលោក ចុតិអំពីទេវលោកនោះ មកកាន់មនុស្សលោក កើតជាព្រះបាទមហាសុទស្សនចក្រពត្តិ ក្នុងរាជធានី ឈ្មោះថា កុសាវតី ។

១- ក្នុងយដិការបានសម្តែងថា ក្នុងសាសនារបស់ព្រះពុទ្ធកស្សប ព្រះពោធិសត្ូកើតជាជោតិ-បាលមាណព ជាសម្ងាញ់នឹងយដិការឧបាសក បានបួសក្នុងសាសនាព្រះជិនស្រី មិនមែនជាឧបាសក ដូចក្នុងទីនេះឡើយ តែក្នុងអដ្ឋកថា ចរិយាបិដក គ្រាន់តែពោលថា កម្មដែលឲ្យបានជាព្រះបាទ មហាសុទស្សនៈ គឺកម្មកាលពី ៣ ជាតិមុនប៉ុណ្ណោះ មិនបានពោលថា ក្នុងសាសនារបស់ព្រះមាន ព្រះភាគអង្គណានីមួយឡើយ ។

បុណ្យសូម្បីតិចតួច បានធ្វើហើយ ក្នុងសាសនា របស់កុលបុត្រយ៉ាងនេះ តែផលដ៏ធំរមែងកើតឡើង ព្រោះដូច្នោះ បណ្ឌិត គប្បីធ្វើបុណ្យនោះ ។

បទថា **មហាវិយូហំ** *សេចក្តីថា មហាកូដាគារដែលធ្វើដោយប្រាក់ ។ ទ្រង់ព្រះបំណងនឹងប្រថាប់នៅក្នុងកូដាគារនោះ ទើបយាងទៅ ។ បទថា* **ឯត្តាវតា កាមវិតក្កេ** *សេចក្តីថា ព្រះបាទមហាសុទស្សនចក្រពត្តិ ទ្រង់គ្របសង្កត់វិតក្កទាំងបីត្រង់ទ្វារកូដាគារនោះឯង យ៉ាងនេះថា*

ម្នាលកាមវិតក្ក អ្នកគប្បីត្រឡប់ត្រឹមតែប៉ុណ្ណេះ ខាងមុខអំពីនេះទៅ អ្នកមិនមានទីនៅ នេះឈ្មោះថា ឈានាគារ ឈានាគារនេះ មិនមែនទីនៅរួមជាមួយអ្នកឡើយ ។

ក្នុងបទថា **បឋមជ្ឈានំ** *ជាដើម ឈ្មោះថា កសិណបរិកម្មកិច្ច រមែងមិនមានដទៃទៀត កាលត្រូវការនីលកសិណ នីលមណីក៏រមែងមាន កាលត្រូវការដោយបិតកសិណ មាសក៏រមែងមាន កាលត្រូវការដោយលោហិត-កសិណ រត្តមណី គឺកែវក្រហមក៏រមែងមាន កាលត្រូវការដោយឱទាត-កសិណ រជតៈ គឺប្រាក់ក៏រមែងមាន លោកបញ្ញត្តកសិណក្នុងឋានៈដែលក្រឡែកមើលហើយយ៉ាងនេះ ក្នុងបទថា* **មេត្តាសហគតេន** *ជាដើម ពាក្យដែលគប្បីពោលទាំងអស់ បានពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ លោកពោលឈាន ๔ អប្បមញ្ញា ๔ ក្នុងបាលីដោយប្រការដូច្នេះ ។ មហាបុរសញ៉ាំងសមាបត្តិ ๘ អភិញ្ញា ๕ ឲ្យកើតហើយចូលសមាបត្តិ ដោយអាការ ๑๔ ដោយអំណាចអនុលោម គឺចូលតាមលំដាប់បដិលោម គឺចូលបញ្ច្រាស់ជា*

ដើម ឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខក្នុងសមាបត្តិនោះឯង ដូចមេឃ្ចុំចូលសម្បុក រស់នៅដោយមធុរស ដូច្នោះ ។

[១៩] បទថា **កុសាវតីរាជធានី** សេចក្តីថា កុសាវតីរាជធានីជាប្រធាន គឺជាធំជាងព្រះនគរទាំងនោះ ។ បទថា **ភត្តាភិហារោ** សេចក្តីថា ភត្តដែលគប្បីនាំទៅចំពោះ ។

[២០] បទថា **វស្សសតស្ស វស្សសតស្ស** សេចក្តីថា លោកគិតយ៉ាងនេះ ព្រោះហេតុអ្វី ។ ព្រោះរំខានដោយសំឡេងនៃបុគ្គលទាំងនោះ ។ លោកពោលថា សំឡេងរមែងបៀតបៀនអ្នកចូលសមាបត្តិ ព្រោះដូច្នោះ ទើបមហាបុរសរំខានដោយសំឡេង ។ បើដូច្នោះ ហេតុដូចម្តេច ទើបមិនប្រាប់ថាពួកលោកចូរកុំមក ។ ឥឡូវនេះ ព្រះរាជាមិនយើញ ព្រោះដូច្នោះ ទើបមិនពោលថា នឹងមិនបានវត្តជានិច្ច វត្តនោះ របស់ជនទាំងនោះ ចូរកុំដាច់ទៅ ។

បទថា **ឯតទហោសិ** សេចក្តីថា ការគិតនោះ មានហើយ ក្នុងកាលណា ។ ក្នុងថ្ងៃកាលកិរិយារបស់ព្រះរាជា ។ បានព្ចថា ក្នុងកាលនោះ ទេវតាទាំងឡាយគិតថា ព្រះរាជាចូរកុំធ្វើកាលកិរិយាយ៉ាងអនាថា ចូរមានបុត្រធីតាទាំងឡាយ មកយំចោមរោមក្នុងការធ្វើកាលកិរិយាចុះ ។ លំដាប់នោះ ក៏នឹកដល់ព្រះទេវី ញ្ចាំងចិត្តនៃព្រះទេវីឲ្យកើតឡើងយ៉ាងនេះ ។ បទថា **បីតានិ វត្តានិ** សេចក្តីថា បានព្ចថា សំពត់លឿងទាំងនោះជាទីពេញព្រះរាជហឫទ័យរបស់ព្រះរាជាដោយប្រក្រតី ព្រោះដូច្នោះ ទើបព្រះនាងសុភទ្ទាទេវីត្រាស់ថានាងទាំងឡាយចូរដណ្តប់សំពត់លឿង ។ បទថា **ឯត្តេវ ទេវិ តិដ្ឋ** សេចក្តីថា ឈ្មោះថា ឈានាគារនេះ មិនមែនស្ថានទីនៅរួមជាមួយនាងទាំងឡាយ តែឈ្មោះ

ថា ជាស្ថានទីដែលបានសេចក្តីត្រេកអរក្នុងឈាន នាងកុំចូលមកក្នុងទីនេះ ។

[๒๑] *បទថា* **ឯតទហោសិ** *សេចក្តីថា ធម្មតាសត្វទាំងឡាយក្នុងលោក រមែងរុងរឿងក្រៃលែងក្នុងសម័យជិតស្លាប់ ដោយហេតុនោះ ព្រះនាងទេវីនោះ ឃើញសភាពនៃព្រះរាជាទ្រង់មានព្រះឥន្ទ្រិយផូរផង់ ទើបមានព្រះតម្រិះយ៉ាងនោះ ។*

បន្ទាប់ពីនោះ ព្រះនាងទេវីមិនជ្រាបថាកាលកិរិយារបស់ព្រះរាជាថា សូមកាលកិរិយាកុំមានដល់ព្រះរាជា ត្រាស់ដល់គុណសម្បត្តិ របស់ព្រះរាជានោះ ព្រះនាងគិតថា អញនឹងធ្វើអាការឲ្យទ្រង់មានព្រះជន្មនៅ ទើបទូលថា **ឥមានិ តេ ទេវ** *ជាដើម ។ ក្នុងបទទាំងនោះ បទថា* **ឆន្ទំ ជនេហិ** *សេចក្តីថា សូមទ្រង់ញុំាងសេចក្តីស្រឡាញ់ឲ្យកើតឡើង គឺសូមទ្រង់ធ្វើបីតិ ។ បទថា* **ជីវិតេ បន អបេក្ខំ** *សេចក្តីថា សូមព្រះអង្គធ្វើសេចក្តីអាល័យ គឺសេចក្តីប្រាថ្នាក្នុងជីវិត ។ បទថា* **ឃវំ ខោ មំ ភុំ ទេវិ** *សេចក្តីថា កាលព្រះនាងទេវីសម្គាល់ព្រះរាជាថា ព្រះរាជានេះ ជាបព្វជិត ទើបទូលថា បពិត្រទេវៈ ខ្ញុំម្ចាស់ជាស្រីរមែងមិនដឹងនូវពាក្យដែលគួរដល់បព្វជិត បពិត្រមហារាជ ខ្ញុំម្ចាស់នឹងពោលដូចម្តេច ទើបព្រះបាទមហាសុទស្សនចក្រពត្តិត្រាស់ថា* **ឃវំ ខោ មំ ភុំ ទេវិ សមុទាចារ** *ដូច្នេះ ។ បទថា* **គរហិតា** *សេចក្តីថា សាបេក្ខកាលកិរិយា ដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវក និងបព្វជិតពួកដទៃដែលជាពហូសូតតិះដៀលហើយ ។ ព្រោះហេតុអ្វី ។ ព្រោះកាលកិរិយាដែលមានសេចក្តីជាប់ជំពាក់ជាហេតុឲ្យកើតជាយក្ខ ឆ្កែ ពពែ គោ ក្របី កណ្តុរ មាន់ និងសត្វបក្សីជាដើម ក្នុងផ្ទះរបស់ខ្លួនប៉ុណ្ណោះ ។*

[២២] បទថា **អថខោ អានន្ទ** សេចក្តីថា ព្រះនាងទេវី ទៅក្នុងទីដ៏សមគួរម្ខាង ហើយទ្រង់ព្រះកន្សែង ទ្រង់ជូតព្រះអស្សុជល ទើបត្រាស់ដូច្នោះ ។ បទថា **គហបតិស្ស វា** សេចក្តីថា ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ ។ បានញ្ចថា សម្បត្តិដ៏ច្រើន រមែងមានដល់ជនទាំងនោះ ដូចមានដល់បុត្ររបស់សោណសេដ្ឋីជាដើម ដូច្នោះ ។ បានញ្ចថា ថាសនៃភត្តមួយរបស់សោណសេដ្ឋីបុត្រ មានតម្លៃពីរសែន កាលជនទាំងនោះ បរិភោគភត្តដូច្នោះមួយភ្លែត ក៏កើតសេចក្តីស្រវឹងក្នុងភត្ត ធ្វើឲ្យលំបាកព្រោះភត្ត ដោយប្រការដូច្នេះ ។

[២៣] បទថា **យំ តេន សមយេន អជ្ឈាវសាមិ** សេចក្តីថា នគរដែលយើងរស់នៅ មានត្រឹមនគរតែមួយប៉ុណ្ណោះ ។ បុត្រធីតាជាដើម និងទាសមនុស្សទាំងឡាយ នៅក្នុងនគរដ៏សេស ។ សូម្បីក្នុងប្រាសាទ និងកូដាគារទាំងឡាយ ក៏មានន័យដូចគ្នា ។ ក្នុងបល្ល័ង្កជាដើម ក៏ទ្រង់ប្រើបល្ល័ង្កតែមួយប៉ុណ្ណោះ ។ បល្ល័ង្កដ៏សេស ជារបស់ប្រើសម្រាប់បុត្រជាដើម ។ សូម្បីក្នុងស្ត្រីទាំងឡាយ ស្ត្រីតែម្នាក់ប៉ុណ្ណោះ ទំនុកបម្រុង ស្ត្រីដ៏សេសត្រឹមតែជាបរិវារ ។ បទថា **បរិធហាមិ** សេចក្តីថា យើងស្ប៉ៀកសំពត់គូតែមួយប៉ុណ្ណោះ ។ សំពត់គូដ៏សេសមានដល់បុរស ១៦ សែន ៨ ម៉ឺននាក់ ដែលសូមត្រាច់ទៅ ។ បទថា **ភុញ្ជាមិ** សេចក្តីថា យើងបរិភោគបាយត្រឹមតែមួយនាឡិ ដោយបត្ត:[1] ជាប្រមាណ ភត្តដ៏សេស បានដល់ បុរស ៨ សែន ៤ ម៉ឺនដែលសូមត្រាច់ទៅ ។ ពិតហើយ ភត្តមួយសម្រាប់ ល្មមដល់ជន ១០ នាក់ ។ បានញ្ចថា

---

[1] - មួយបត្ត: គឺមួយកម្បង់ ។

ព្រះនគរ ៨៤០០០ កន្លែង ប្រាសាទ ១ ពាន់ខ្នង និងកូដាគារ ១ ពាន់ កើតទ្បើងព្រោះផលបុណ្យ ហូរមកអំពីបណ្ណសាលាមួយខ្នង ។ បល្ល័ង្ក ៨៤០០០ កើតទ្បើងដោយផលបុណ្យហូរមកអំពីត្រែដែលប្រគេន ដើម្បីប្រយោជន៍ដល់ការដេក ។ ដំរី ៨៤០០០ សេះ ១០០០ រថ ១០០០ កើតទ្បើងដោយផលបុណ្យដែលហូរមកអំពីតាំង ដែលប្រគេនដើម្បីប្រយោជន៍ដល់ការអង្គុយ ។ កែវមណី ៨៤០០០ កើតទ្បើងដោយផលបុណ្យ ដែលហូរមកអំពីប្រទីបមួយ ។ ស្រះបោក្ខរណី ៨៤០០០ កើតទ្បើងដោយផលបុណ្យដែលហូរមកអំពីស្រះបោក្ខរណីមួយ ។ ស្ត្រី ៨៤០០០ នាក់ បុត្រ ១០០០ នាក់ គហបតី ១០០០ នាក់ កើតទ្បើងដោយផលបុណ្យ ដែលហូរមកអំពីការប្រគេនបរិភោគភាជនៈ ជាត្រ ស្លាកជាត្រ ជម្មក្រក សំពត់ត្រងទឹក ក្អមទឹក កន្ត្រែ កាំបិតកាត់ក្រចកម្ជុល សោ ឈើខ្វារត្រចៀក សំពត់ជូតជើងស្បែកជើង ឆត្រ និងឈើច្រត់ ។ មេគោទឹកដោះ ៨៤០០០ កើតទ្បើងដោយផលបុណ្យ ដែលហូរមកអំពីគោរសទាន ។ សំពត់ ៨៤០០០ កោជិផាប់ កើតទ្បើងដោយផលបុណ្យ ដែលហូរមកអំពីទានសំពត់ស្បៀក សំពត់ដណ្តប់ ។ ព្រះក្រយាហារ ៨៤០០០ សម្រាប់ គប្បីជ្រាបថា កើតទ្បើងដោយអានិសង្សនៃទានភោជនា ។ ព្រះមានព្រះភាគត្រាស់ដល់សម្បត្តិ របស់ព្រះបាទមហាសុទស្សនចក្រពត្តិ តាំងអំពីដើមដោយពិស្តារ ដូច្នេះហើយ កាលទ្រង់សម្តែងសម្បត្តិទាំងអស់នោះ ដូចសម្តែងខ្ទមលេងធូលីដល់ក្មេងទាំងឡាយ ផ្ទំលើព្រះទែនជាទីរលត់ខន្ធបរិនិព្វាន ហើយត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើលចុះ ... ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **វិបរិណាតា** *សេចក្តីថា ដល់នូវសេចក្តីប្រែប្រួល*

ដូចប្រទីបរលត់ ដោយលះប្រក្រតីទៅ ដូច្នោះ ។ បទថា **ឯវំ អនិច្ចា ខោ អានន្ទ សង្ខារា** សេចក្តីថា ឈ្មោះថា មិនទៀង ព្រោះអត្ថថា មានហើយ ត្រឡប់ជាមិនមានយ៉ាងនេះ ។ បុរសចងបង្អោងក្នុងដើមចម្ប៉ាកម្ពស់ ១០០ ហត្ថ ឡើងហើយកាន់យកផ្ការចម្ប៉ា ស្រាយបង្អោង ចុះមកយ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដែរ ទ្រង់លើកនូវសម្បត្តិរបស់ស្តេចមហាសុទស្សនចក្រពត្តិ ខ្ពស់ដល់សែនកោដិឆ្នាំមិនមែនតិច ដូចចងបង្អោង ទ្រង់កាន់យកអនិច្ច-លក្ខណៈ ដែលតាំងនៅក្នុងទីបំផុតនៃសម្បត្តិ ឈានចុះដូចស្រាយបង្អោង ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ក្នុងកាលមុន ព្រះបាទវសភៈ ទ្រង់ស្តាប់ព្រះសូត្រនេះ ដែលព្រះទីយភាណកត្ថេរ ស្វាធ្យាយក្នុងអម្ពលដ្ឋិកា នាទិសខាងកើតនៃលោហប្រាសាទ ហើយទ្រង់គិតថា លោកម្ចាស់របស់យើង ពោលអ្វីក្នុងទីនេះ លោកម្ចាស់ពោលចំពោះសម្បត្តិក្នុងឋានៈដែលខ្ជួនបានស៊ីបានផឹកប៉ុណ្ណោះ ទ្រង់ដាក់ព្រះហស្តឆ្វេងផ្ទុំដោយព្រះហស្តស្តាំថា លោកមានចក្ខុដោយចក្ខុ ៥ ប្រការ យើញសូត្រនេះហើយពោលយ៉ាងនេះ ក្នុងកាលដែលព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះឯង ។ ទ្រង់មានព្រះហឫទ័យត្រេកអរថា សាធុ សាធុ ទ្រង់ឲ្យសាធុការ ។

បទថា **ឯវំ អធុវា** សេចក្តីថា ប្រាសចាកសេចក្តីពិតប្រាកដ ដូចរលកទឹកជាដើមយ៉ាងនេះ ។ បទថា **ឯវំ អនស្សាសិកា** សេចក្តីថា ប្រាសចាកខ្យល់អស្សាសៈដូចទឹកដែលផឹកហើយ និងដូចស្ទាបព្រះចន្ទ ក្នុងការយល់សប្តិយ៉ាងនេះ ។ បទថា **សរីរំ និក្ខិបេយ្យ** សេចក្តីថា ដាក់ចុះនូវសរីរៈ ។ ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ការដាក់ចុះ ឬការបដិបត្តិសរីរៈដទៃ

រមែងមិនមានដល់តថាគត ។ កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់ហៅ ព្រះថេរៈទៀតថា ធម្មតាអានុភាពនៃស្តេចចក្រពត្តិ រមែងអន្តរធានក្នុងថ្ងៃទី ៧ បន្ទាប់ពីការបួស ។ ចំណែកសម្បត្តិទាំងអស់នេះ គឺកំពែងរតន: ៧ ជាន់ ត្នោតរតន: ស្រះបោក្ខរណី ៨៤០០០ ធម្មប្រាសាទ ធម្មបោក្ខរណី ចក្កវត្តន៍ អន្តរធានហើយក្នុងថ្ងៃទី ៧ ចាប់ពីកាលកិរិយានៃព្រះបាទមហាសុទស្សន-ចក្រពត្តិ ។ ក្នុងជីវិតជាដើម ក៏ធម្មតាយ៉ាងនេះ កាលអស់អាយុក្ខ័យ ក៏ស្លាប់ទៅ ។ បើអាយុនៅសល់ ហត្ថិវត្តន៍ ក៏ទៅកាន់ត្រកូលឧបោសថ អស្សវត្តន៍ ក៏ទៅកាន់ត្រកូលវលាហក: មណិវត្តន៍ ក៏ទៅកាន់វេបុល្លបព្វតប៉ុណ្ណោះឯង ។ អានុភាពនៃឥត្ថិវត្តន៍ រមែងអន្តរធានទៅ ។ ចក្កវបស់គហបតិវត្តន៍ ក៏ត្រឡប់ជាប្រក្រតី ។ ការខ្វល់ខ្វាយរបស់បរិនាយកវត្តន៍ ក៏រមែងវិនាស ។

បទថា **ឥមមវោច ភគវា** *សេចក្តីថា ព្រះមានព្រះភាគបានត្រាស់បទទាំងនេះអស់ដែលមកហើយ និងមិនមានមកហើយក្នុងព្រះបាលី ។ បទដ៏សេស មានអត្ថងាយហើយ ដូច្នេះ ។ អដ្ឋកថាមហាសុទស្សនសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ៗ*

មហាសុទស្សនសូត្រ ចប់

សូត្រទី ៤ ចប់

សុត្តន្តបិដក

ជនវសភសូត្រទី ៥

[២៥] ខ្ញុំបានស្តាប់ហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងលំនៅដែលធ្វើដោយឥដ្ឋ ជិតនាទិកគ្រាម ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជនដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ ក្នុងជនបទទាំងឡាយជុំវិញ គឺកាសីជនបទ ១ កោសលជនបទ ១ វជ្ជីជនបទ ១ មល្លជនបទ ១ ចេតិជនបទ ១ វំសជនបទ ១ កុរុជនបទ ១ បញ្ចាលជនបទ ១ មច្ឆជនបទ ១ សុរសេនជនបទ ១ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាង ៥០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ មានសភាពជាឱបបាតិកសត្វ បរិនិព្វានក្នុងលោកនោះ មានសភាវៈមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈទាំង ៥ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិក-គ្រាមជាង ៩០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណ-កាលកន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ តែនៅមានរាគៈ ទោសៈ មោហៈ ដែលស្រាលស្តើង ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាង ៥០០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល

កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនជ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅ ក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ๓ ។

[๒๖] *ពួកជនជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលនៅក្នុងនាទិកគ្រាម បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជនដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ ក្នុងជនបទទាំង៦ប្រាយជុំវិញ គឺ កាសីជនបទ ๑ កោសលជនបទ ๑ វជ្ជីជនបទ ๑ មល្លជនបទ ๑ចេតិជនបទ ๑ វំសជនបទ ๑ កុរុជនបទ ๑ បញ្ចាលជនបទ ๑ មច្ឆជនបទ ๑ សុរសេនជនបទ ๑ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๕๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ មានសភាពជាឱបបាតិកសត្វ បរិនិព្វានក្នុងលោកនោះ មានសភាវៈមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ๕ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๙๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ๓ តែនៅមានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๕๐๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើ*

มรณกาลกลงទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជន: ๓ ฯ ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានស្តាប់បញ្ហាព្យាករបស់ព្រះមានព្រះភាគហើយ ក៏មានចិត្តក្រអរីករាយ កើតបីតិសោមនស្សទ្បើង ដោយដំណើរនៃអនាគាមិបុគ្គលជាដើមនោះ ฯ

[๒๗] *ព្រះអានន្ទមានអាយុ បានឮថា ព្រះមានព្រះភាគ ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជនដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ ក្នុងជនបទទាំងឡាយជុំវិញ គឺកាសីជនបទ ๑ កោសលជនបទ ๑ វជ្ជីជនបទ ๑ មល្លជនបទ ๑ ចេតិជនបទ ๑ វំសជនបទ ๑ កុរុជនបទ ๑ បញ្ចាលជនបទ ๑ មច្ឆជនបទ ๑ សុរសេនជនបទ ๑ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๕๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ មានសភាពជាឱបបាតិកសត្វ បរិនិព្វានក្នុងលោកនោះ មានសភាវៈមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជន: ๕ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๙๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ*

ព្រោះអស់ទៅនៃសំយោជន: ๓ តែនៅមានរាគ: ទោស: មោហ: ស្រាល ស្តើង ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๕๐๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្ត ទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជន: ๓ ពួកជនអ្នកនៅក្នុងនាទិក-គ្រាម ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានស្តាប់បញ្ហាព្យាករបស់ព្រះមានព្រះភាគហើយ ក៏មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ឡើង ដោយដំណើរនៃអនាគាមិបុគ្គលជាដើមនោះ ។ គ្រានោះ ព្រះអានន្ទ មានអាយុ មានសេចក្តីត្រិះរិះថា ពួកជនអ្នកនៅក្នុងមគធជនបទទាំងនេះ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានចំនួនច្រើននាក់ផង ជាអ្នកដឹងរាត្រីយូរផង ធ្វើមរណកាល កន្លងទៅយូរហើយ ដែនអង្គ: និងដែនមគធ: ហាក់ដូចជាសូន្យចាកមនុស្សអ្នកមគធ:ដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជនទាំងនោះ សុទ្ធតែជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំងធ្វើនូវការបំពេញកិច្ចក្នុងសីល ជនទាំងនោះ ធ្វើមរណកាល កន្លងទៅយូហើយ ព្រះមានព្រះភាគ មិនបានព្យាករឡើយ ប្រសិនបើទ្រង់ព្យាករនូវជនទាំងនោះដោយប្រពៃហើយ ជនច្រើននាក់ គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិ ដោយសេចក្តីជ្រះថ្លានោះ ចំណែកខាងព្រះបាទមាគធសេនិយពិម្ពិសារនេះ ព្រះអង្គជាធម្មិកធម្មរាជ ទ្រង់បានធ្វើប្រយោជន៍ឲ្យដល់ពួកព្រាហ្មណ៍ និងគហបតី អ្នកនៅក្នុងនិគមជនបទ បានឮថា ពួក

มនុស្សនិយាយសរសើរព្រះរាជានោះថា ព្រះរាជានោះ ជាធម្មិកធម្មរាជ ទ្រង់ធ្វើសេចក្តីសុខឲ្យដល់យើងទាំងឡាយយ៉ាងនេះហើយ ទ្រង់ទិវង្គតទៅ យើងទាំងឡាយក៏នៅជាសុខសប្បាយ ក្នុងដែនរបស់ព្រះរាជានោះជាធម្មិកធម្មរាជយ៉ាងនេះ ព្រះរាជានោះ ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទ្រង់ធ្វើនូវការបំពេញកិច្ចក្នុងសីល បានឮថា ពួកមនុស្សនាំគ្នានិយាយយ៉ាងនេះថា ព្រះបាទមាគធសេនិយពិម្ពិសារ ព្រះអង្គតែងមានព្រះរាជឱង្កាសរសើរព្រះមានព្រះភាគជរាបជាល់មរណកាល ហើយទ្រង់ទិវង្គតទៅដូច្នេះ លុះព្រះរាជានោះ ទ្រង់ទិវង្គតកន្លងទៅយូរហើយ ព្រះមានព្រះភាគ មិនទ្រង់ព្យាករសោះ ប្រសិនបើទ្រង់ព្យាករនូវព្រះរាជានោះ ដោយប្រពៃហើយ ជនច្រើននាក់គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិដោយសេចក្តីជ្រះថ្លានោះ សម្ពោធិញ្ញាណរបស់ព្រះមានព្រះភាគ រមែងមាននៅក្នុងពួកជន ដែលនៅក្នុងដែនមគធៈ កាលបើសម្ពោធិញ្ញាណរបស់ព្រះមានព្រះភាគ មាននៅក្នុងពួកជនដែលនៅក្នុងដែនមគធៈណាហើយ ហេតុអ្វី ព្រះមានព្រះភាគ ទ្រង់មិនព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជន អ្នកនៅក្នុងដែនមគធៈនោះ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ បើព្រះមានព្រះភាគទ្រង់មិនព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យចំពោះពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយនោះទេ ពួកជនដែលនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ក៏កើតមានសេចក្តីតូចចិត្ត ដោយហេតុ

នោះពុំខាន ពួកជនដែលនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតមានសេចក្តីតូចចិត្ត ដោយហេតុណា ហេតុអ្វី បានជាព្រះមានព្រះភាគ ទ្រង់មិនព្យាករចំពោះពួកជននោះ ដោយហេតុនោះសោះ ។ ព្រះអានន្ទមានអាយុ ប្រាប្តនូវពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ពិចារណានូវហេតុនេះ ក្នុងទីស្ងាត់តែម្នាក់ឯង លុះក្រោកឡើង ក្នុងបច្ចូសសម័យនៃរាត្រី ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា ព្រះមានព្រះភាគ ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជនជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ក្នុងជនបទទាំងឡាយជុំវិញ គឺកាសីជនបទ ១ កោសលជនបទ ១ វជ្ជីជនបទ ១ មល្លជនបទ ១ ចេតិជនបទ ១ វំសជនបទ ១ កុរុជនបទ ១ បញ្ចាល-ជនបទ ១ មច្ឆជនបទ ១ សុរសេនជនបទ ១ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិក-គ្រាមជាង ៥០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណ-កាល កន្លងទៅយូរហើយ មានសភាពជាឱបបាតិកសត្វ ហើយបរិនិព្វានក្នុងលោកនោះ មានសភាវៈមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៩០

នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាលកន្លងទៅយូរ ហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់ទៅនៃសំយោជន: ๓ តែនៅមានរាគ: ទោស: មោហ:ស្រាលស្តើង ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ๕๐๐ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវ:មិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅនៃសំយោជន: ๓ ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានស្តាប់បញ្ហាព្យាករបស់ព្រះមានព្រះភាគហើយ ក៏មានចិត្តត្រេកអរពេកក្រៃ កើតបីតិសោមនស្សខ្លាំង ដោយដំណើរនៃអនាគាមិបុគ្គលជាដើមនោះ បពិត្រព្រះអង្គដ៏ចម្រើន ពួកជនអ្នកនៅក្នុងមគធជនបទទាំងនេះ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានចំនួនច្រើននាក់ផង ជាអ្នកដឹងរាត្រីយូរផង ធ្វើមរណកាល កន្លងទៅយូរហើយ ដែនអង្គ: និងដែនមគធ: ហាក់ដូចជាសូន្យចាកពួកជនអ្នកដែនមគធ: ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន ពួកជននោះ សុទ្ធតែជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំងធ្វើនូវការបំពេញកិច្ចក្នុងសីល ពួកជននោះធ្វើមរណកាល កន្លងទៅយូរហើយ ព្រះមានព្រះភាគទ្រង់មិនទាន់បានព្យាករសោះ ប្រសិនបើទ្រង់ព្យាករនូវពួកជននោះ ដោយប្រពៃហើយ ជនច្រើននាក់ គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិ ដោយសេចក្តីជ្រះថ្លា

នោះ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកព្រះបាទមាគធសេនិយពិម្ពិសារនេះ ព្រះអង្គជាធម្មិកធម្មរាជ ទ្រង់ធ្វើនូវប្រយោជន៍ឲ្យដល់ពួកព្រាហ្មណ៍ និងគហបតីអ្នកនៅក្នុងនិគម និងជនបទដែរ បានឮថា ពួកមនុស្សនិយាយសរសើរព្រះរាជានោះថា ព្រះរាជានោះជាធម្មិកធម្មរាជ ទ្រង់ធ្វើនូវសេចក្តីសុខឲ្យដល់យើងទាំងឡាយយ៉ាងនេះ ហើយទ្រង់ទិវង្គតទៅ យើងទាំងឡាយក៏នៅជាសុខសប្បាយក្នុងដែនរបស់ព្រះរាជានោះ ជាធម្មិកធម្មរាជយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជនោះក៏ជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទ្រង់ធ្វើនូវការបំពេញកិច្ចក្នុងសីលដែរ បានឮថា មនុស្សទាំងឡាយ នាំគ្នានិយាយយ៉ាងនេះថា ព្រះបាទមាគធសេនិយពិម្ពិសារ តែងមានព្រះរាជឱង្កាសរសើរព្រះមានព្រះភាគជរាបជាល់មរណកាល ហើយទ្រង់ទិវង្គតទៅដូច្នេះ លុះព្រះរាជានោះទ្រង់ទិវង្គតកន្លងទៅយូរហើយ ព្រះមានព្រះភាគ មិនទាន់ទ្រង់ព្យាករឡើយ ប្រសិនបើទ្រង់ព្យាករព្រះរាជានោះដោយប្រពៃហើយ ជនច្រើននាក់គប្បីជ្រះថ្លាគប្បីទៅកាន់សុគតិ ដោយសេចក្តីជ្រះថ្លានោះពុំខាន បពិត្រព្រះអង្គដ៏ចម្រើន សម្ពោធិញ្ញាណរបស់ព្រះមានព្រះភាគ រមែងមាននៅក្នុងពួកជនអ្នកនៅក្នុងដែនមគធៈ បពិត្រព្រះអង្គដ៏ចម្រើន កាលបើសម្ពោធិញ្ញាណរបស់ព្រះមានព្រះភាគ មាននៅក្នុងពួកជនអ្នកនៅក្នុងដែនមគធៈណាហើយ ហេតុអ្វី ក៏ព្រះមានព្រះភាគមិនទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យចំពោះពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយនោះ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះ

ภาค ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជនអ្នក
នៅ ក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល
កន្លងទៅយូរហើយនោះទេ ពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ
ព្រះធម៌ ព្រះសង្ឃ ក៏កើតមានសេចក្តីតូចចិត្ត ដោយហេតុនោះពុំខាន ពួក
ជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតមាន
សេចក្តីតូចចិត្ត ដោយហេតុណា ហេតុអ្វី បានជាព្រះមានព្រះភាគ មិនទ្រង់
ព្យាករចំពោះពួកជននោះ ដោយហេតុនោះ ។ ព្រះអានន្ទមានអាយុ ក្រាបទូ
ពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើនូវ
វាចារៀបរាប់នេះ ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ហើយក្រោកអំពី
អាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

[๒๘] *កាលព្រះអានន្ទមានអាយុ ចេញទៅមិនយូរប៉ុន្មាន លំដាប់*
នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ និងបាត្រចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ទៅ
កាន់នាទិកគ្រាមដើម្បីបិណ្ឌបាត លុះស្តេចទៅបិណ្ឌបាតក្នុងនាទិកគ្រាមហើយ
ទ្រង់ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយនៃភត្ត ទ្រង់លាងព្រះបាទ
ហើយស្តេចចូលទៅកាន់លំនៅ ដែលធ្វើដោយឥដ្ឋ ទ្រង់ក្រាបពួកជនអ្នក
មគធៈ ជាអ្នកបម្រើព្រះពុទ្ធព្រះធម៌ ព្រះសង្ឃ ធ្វើឲ្យជាប្រយោជន៍ ទ្រង់ធ្វើ
ទុកក្នុងព្រះហឫទ័យ ទ្រង់ពិចារណានូវហេតុទាំងអស់ ដោយព្រះហឫទ័យ
ហើយគង់លើអាសនៈ ដែលគេក្រាលថ្វាយ ទ្រង់ព្រះចិន្តាថា ពួកជនដ៏
ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈ (ភពខាងមុខ) យ៉ាង

ណា តថាគតក៏ដឹងនូវញាណគតិ និងអភិសម្បរាយៈ របស់ជនទាំងនោះ យ៉ាងនោះដែរ ។ ពួកជនដ៏ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្ប-រាយៈ យ៉ាងណា ព្រះមានព្រះភាគ ទ្រង់បានឃើញនូវពួកជនអ្នកមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ទ្រង់ចេញអំពីលំនៅដែលធ្វើដោយឥដ្ឋ ទៅគង់លើអាសនៈដែលគេក្រាលថ្វាយ នៅត្រង់មុខបំនៃវិហារ ។

[២៩] *លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ឃើញនូវសេចក្តីស្ងប់រម្ងាប់ សម្បុរព្រះភក្ត្រនៃព្រះមានព្រះភាគ រុងរឿងហួសប្រៀប ឥន្ទ្រិយក៏ជ្រះថ្លាយ៉ាងវិសេស បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃនេះ ប្រហែលជាព្រះមានព្រះភាគ ទ្រង់គង់នៅដោយវិហារធម៌ដ៏ស្ងប់ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកប្រារព្ធពួកជនអ្នកមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើនូវវាចារៀបរាប់ចំពោះមុខតថាគត រួចក្រោកអំពីអាសនៈ ចេញទៅក្នុងកាលណា កាលនោះ តថាគតក៏ត្រាច់ទៅបិណ្ឌបាតក្នុងនាទិកគ្រាម លុះត្រឡប់មកពីបិណ្ឌបាត ក្នុងកាលខាងក្រោយនៃភត្ត លាងបាទាហើយ ចូលទៅកាន់លំនៅដែលធ្វើដោយឥដ្ឋ បានប្រារព្ធពួក*

ជនអ្នកមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ពិចារណានូវហេតុទាំងអស់ដោយចិត្តដែរ ហើយអង្គុយលើអាសនៈដែលគេក្រាល គិតថា ពួកជនជ័ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈយ៉ាងណា តថាគតក៏ដឹងគតិ និងអភិសម្បរាយៈ របស់ជនទាំងនោះយ៉ាងនោះដែរ ម្នាលអានន្ទ ពួកជនជ័ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈយ៉ាងណា តថាគតបានឃើញពួកជនអ្នកមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យ៉ាងនោះដែរ ម្នាលអានន្ទ ស្រាប់តែមានយក្ស មានខ្លួនកំពុងជាត់ មកស្រែកបន្លឺសំឡេងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះជនវសភៈ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ឈ្មោះជនវសភៈ ម្នាលអានន្ទ ក្នុងកាលមុនអំពីកាលនេះ អ្នកធ្លាប់បានឮ ឈ្មោះថា ជនវសភៈ យ៉ាងនេះដែរឬទេ ។ បពិត្រព្រះអង្គជ័ចម្រើន ក្នុងកាលមុនអំពីកាលនេះ ខ្ញុំព្រះអង្គមិនធ្លាប់បានឮឈ្មោះថា ជនវសភៈយ៉ាងនេះទេ បពិត្រព្រះអង្គជ័ចម្រើន រោមរបស់ខ្ញុំព្រះអង្គ ក៏ព្រឺព្រួចឡើង ព្រោះបានឮឈ្មោះថា ជនវសភៈដូច្នេះ បពិត្រព្រះអង្គជ័ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា យក្សនោះ មិនមែនជាយក្សថោកថយឡើយ មានឈ្មោះថា ជនវសភៈ មានសភាពយ៉ាងនេះ ជាឈ្មោះដែលគេបញ្ញត្តហើយដោយល្អ ។ ម្នាលអានន្ទ សូរសព្ទសំឡេងកើតប្រាកដហើយក្នុងចន្លោះ យក្សមានសម្បុរដ៏លើសលុបមកប្រាកដក្នុងទីចំពោះមុខតថាគត ស្រែកបន្លឺនូវសំឡេងជាគម្រប់ពីរដងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះពិម្ពិសារ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ

ឈ្មោះពិម្ពិសារ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវខ្ញុំព្រះអង្គ បាននូវកំណើតជា គម្រប់ ๗ នេះ ជាមួយនឹងមហារាជឈ្មោះវេស្សវណៈ លុះខ្ញុំព្រះអង្គច្យុតអំពី អត្តភាពនេះទៅហើយ ទៅកើតជាស្តេចក្នុងពួកមនុស្ស ។

[๓๐] ខ្ញុំព្រះអង្គច្យុតចាកទេវលោកនេះ ๗ ដង ច្យុតចាកមនុស្សលោកនោះ ๗ ដង អន្ទោលទៅមកត្រូវជា ๑๔ ដង ពីដើមខ្ញុំព្រះអង្គធ្លាប់នៅក្នុងលំនៅណា ខ្ញុំព្រះអង្គក៏ស្គាល់ច្បាស់នូវលំនៅនោះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គលមិនធ្លាក់ចុះ ដឹងច្បាស់នូវជំណើរមិនធ្លាក់ចុះអស់កាលជាអង្វែង ទាំងសេចក្តីប៉ុនប៉ងរបស់ខ្ញុំព្រះអង្គ ដើម្បីសេកទាគាមិមគ្គ ក៏តាំងនៅល្អ ។ ជនវសកយក្សក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គលមិនធ្លាក់ចុះ ដឹងច្បាស់នូវជំណើរមិនធ្លាក់ចុះ អស់កាលជាអង្វែងដូច្នេះក្តី ក្រាបទូលថា សេចក្តីប៉ុនប៉ងរបស់ខ្ញុំព្រះអង្គ ដើម្បីសេកទាគាមិមគ្គ ក៏តាំងនៅល្អដូច្នេះក្តី ជនវសកយក្សមានអាយុ បានឈ្មោះថា ស្គាល់នូវកិរិយាគ្រាស់ដឹងនូវគុណវិសេសដ៏លើសលុបមានសភាពយ៉ាងនេះ ព្រោះហេតុណា ហេតុនេះ ជាអស្ចារ្យរបស់ជនវសក-យក្សមានអាយុ ហេតុនេះ ជាហេតុចម្លែករបស់ជនវសកយក្សមានអាយុ ។ ជនវសកយក្សក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ មិនមែនជាខាងក្រៅសាសនារបស់ព្រះអង្គទេ បពិត្រព្រះសុគត ខ្ញុំព្រះអង្គមិនមែនជាខាងក្រៅសាសនារបស់ព្រះអង្គទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាន

ជ្រះថ្លាចំពោះព្រះមានព្រះភាគដោយពិតជាដំបូងក្នុងថ្ងៃណា បពិត្រព្រះអង្គដ៏ចម្រើន តាំងអំពីថ្ងៃនោះជាដើម ខ្ញុំព្រះអង្គជាបុគ្គលមិនធ្លាក់ចុះ ជីងច្បាស់នូវជំណើរមិនធ្លាក់ចុះអស់កាលជាអង្វែង ទាំងសេចក្តីប៉ុនប៉ងរបស់ខ្ញុំព្រះអង្គដើម្បីសកទាគាមិមគ្គ ក៏តាំងនៅល្អ បពិត្រព្រះអង្គដ៏ចម្រើន វេស្សវណមហារាជប្រើខ្ញុំព្រះអង្គទៅក្នុងសំណាក់វិរូឡ្ហកមហារាជ ដោយកិច្ចនីមួយក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់លំនៅដែលធ្វើដោយឥដ្ឋ ត្រង់ពាក់កណ្តាលផ្លូវ ទ្រង់ប្រោរព្ធពួកជនអ្នកមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងព្រះហឫទ័យ ពិចារណានូវហេតុទាំងអស់ ដោយព្រះហឫទ័យ ហើយទ្រង់គង់នៅ ទ្រង់ព្រះចិន្តាថា អ្នកដ៏ចម្រើនទាំងនោះ មានគតិយ៉ាងណា មានអភិសម្បរាយៈយ៉ាងណា តថាគតក៏ជីងនូវគតិ និងអភិសម្បរាយៈរបស់ជនទាំងនោះ យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យណាដែលខ្ញុំព្រះអង្គបានទទួល គឺបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះវេស្សវណមហារាជ ទ្រង់មានព្រះបន្ទូលក្នុងពួកបរិស័ទនោះថា អ្នកដ៏ចម្រើនទាំងនោះ មានគតិយ៉ាងណា មានអភិ-សម្បរាយៈយ៉ាងណា ដូច្នេះ ពាក្យនេះជាអស្ចារ្យដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញនឹងបានឃើញព្រះមានព្រះភាគ នឹងបានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគផង បពិត្រព្រះអង្គដ៏ចម្រើន ហេតុទាំង ២ នេះឯង ដែលជាហេតុនាំឲ្យខ្ញុំព្រះអង្គបានចូលមកឃើញព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃពីមុនៗ មក ពួកទេវតាទាំងអស់

ដែលឋិតនៅក្នុងឋានតាវត្តិង្ស អង្គុយប្រជុំគ្នាក្នុងរោងសុធម្មា ក្នុងរាត្រីមានព្រះចន្ទពេញវង់ ជាថ្ងៃជិតចូលវស្សា គឺថ្ងៃឧបោសថទី ១៥ ទាំងទេវបរិសទ្យជាច្រើនអង្គុយត្រៀបត្រាជុំវិញមហារាជទាំង ៤ ក៏គង់នៅគ្រប់ទិសទាំង ៤ គឺ មហារាជឈ្មោះធតរដ្ឋ: គង់ក្នុងទិសខាងកើត បែរព្រះភក្ត្រទៅទិសខាងលិច មានពួកទេវតាចោមរោមជាបរិវារ មហារាជឈ្មោះវិរូឡ្ហក: គង់ក្នុងទិសខាងត្បូង បែរព្រះភក្ត្រទៅទិសខាងជើង មានពួកទេវតាចោមរោមជាបរិវារ មហារាជឈ្មោះវិរូបក្ខ:គង់ក្នុងទិសខាងលិច បែរព្រះភក្ត្រទៅទិសខាងកើត មានពួកទេវតាចោមរោមជាបរិវារ មហារាជឈ្មោះវេស្សវ័ណ គង់ក្នុងទិសខាងជើង បែរព្រះភក្ត្រទៅទិសខាងត្បូង មានពួកទេវតាចោមរោមជាបរិវារ បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាដែលនៅក្នុងឋានតាវត្តិង្សទាំងអស់ អង្គុយប្រជុំគ្នាក្នុងរោងសុធម្មា ទាំងទេវបរិសទ្យជាច្រើន ក៏អង្គុយត្រៀបត្រាជុំវិញមហារាជទាំង ៤ ក៏គង់ក្នុងទិសទាំង ៤ នេះជាអាសន:របស់មហារាជទាំង ៤ នោះ ឯអាសន:របស់យើងទាំងឡាយ នៅខាងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណាបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយទៅកើតក្នុងពួកទេវតា ដែលនៅក្នុងឋានតាវត្តិង្សក្នុងកាលឥឡូវនេះ ពួកទេវតានោះ រមែងរុងរឿងជាងពួកទេវតាឯទៀត ដោយសម្បុរផង ដោយយសផង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានញ្ញថា ពួកតាវត្តិង្សទេវតា មានចិត្តត្រេកអររីករាយ កើតបីតិសោមនស្សឡើងថា អើហ្នឹ ពួកទិព្ធកាយនៅបរិបូណ៌ ពួកអសុរកាយសាបសូន្យទៅ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង

ព្រះឥន្ទ្រជាធំជាងទេវតាទាំងឡាយ ជ្រាបនូវសេចក្តីជ្រះថ្លា របស់ពួកតាវត្តិង្ស ទេវតាហើយ ក៏អនុមោទនាដោយគាថាទាំងឡាយនេះថា

[๓๑] អើហ្ន៎ ទេវតាទាំងឡាយ ដែលនៅក្នុងឋាន តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ នមស្ការចំពោះព្រះតថាគតផង ចំពោះធម៌ ជាធម៌ដ៏ល្អផង តែងធ្វើចិត្តឲ្យរីករាយ ។ ពួកតាវត្តិង្សទេវតា បានឃើញពួកទេវតាថ្មីៗ ដែលមានសម្បុរកាយ មានយស មកក្នុងទីនេះបាន ព្រោះប្រព្រឹត្តព្រហ្ម-ចរិយធម៌ក្នុងសំណាក់ព្រះសុគត ។ ពួកទេវតានោះ រុងរឿងជាងពួកទេវតាឯទៀត ដោយសម្បុរកាយ ដោយយស និងអាយុ ពួកសាវ័ករបស់ព្រះពុទ្ធ មានប្រាជ្ញាដូចជាផែនដី ជាសាវ័កវិសេស បានចូលមកហើយក្នុងទីនេះ ។ ពួកតាវត្តិង្សទេវតា ព្រមទាំងព្រះឥន្ទ្រ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង តែងធ្វើចិត្តឲ្យត្រេកអរ ព្រោះឃើញហេតុនេះ ។

[๓๒] បពិត្រព្រះអគ្គដ៏ចម្រើន ព្រោះហេតុនោះ បានឮថា ពួកតាវត្តិង្សទេវតា ក៏រីងរឹតតែមានចិត្តត្រេកអររីករាយ កើតបីតិសោមនស្សឡើងថា អើហ្ន៎ ពួកទិព្វកាយនៅបរិបូណ៌ ពួកអសុរកាយសាបសូន្យទៅ បពិត្រព្រះអគ្គដ៏ចម្រើន គ្រានោះ ពួកតាវត្តិង្សទេវតា អង្គុយប្រជុំគ្នាក្នុងរោងសុធម្មា ដោយប្រយោជន៍ណា ក៏គិតនូវប្រយោជន៍នោះ ប្រឹក្សានូវប្រយោជន៍នោះ

(ជាមួយនឹងមហារាជទាំង ๔) មហារាជទាំង ๔ ដែលពួកតាវត្តិង្សទេវតា បាននិយាយជាសរសើរ ក្នុងប្រយោជន៍នោះផង មហារាជទាំង ๔ ដែលពួកតាវត្តិង្សទេវតាបាននិយាយប្រៀនប្រដៅ ក្នុងប្រយោជន៍នោះផង ក៏បិតនៅលើអាសនៈទាំងឡាយរាល់ៗ ខ្លួន មិនចៀសចេញទៅឡើយ ។

ស្តេចទាំងនោះ ដែលទេវបុត្តទាំងនោះ បាននិយាយជាសរសើរហើយ ក៏មានចិត្តជ្រះថ្លា ទទួលយកនូវពាក្យប្រៀនប្រដៅ ហើយក៏បិតនៅលើអាសនៈរបស់ខ្លួន ។

[๓๓] *បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពន្លឺដ៏ធំទូលាយកើតឡើង ក្នុងទិសខាងជើង រស្មីមានប្រាកដហើយ កន្លងនូវអានុភាពរបស់ពួកទេវតា បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ព្រះឥន្ទជាធំជាងពួកទេវតា គ្រាស់ហៅនូវពួកតាវត្តិង្សទេវតាមកថា ម្នាលគ្នាយើងទាំងឡាយ និមិត្តទាំងឡាយប្រាកដឡើង ពន្លឺកើតព្រម រស្មីមានប្រាកដដោយប្រការណា ព្រហ្មមុខជានឹងមានមកប្រាកដ ដោយប្រការនោះ ព្រោះថា ពន្លឺកើតព្រម រស្មីមានប្រាកដដោយហេតុណា ហេតុនុ៎ះ ជាបុព្វនិមិត្តរបស់ព្រហ្មនាំឲ្យមានប្រាកដ ។*

និមិត្តទាំងឡាយ ប្រាកដឡើង ដោយប្រការណា ព្រហ្មមុខជានឹងមានមកប្រាកដ ដោយប្រការនោះ រស្មីដ៏ធំទូលាយមានប្រាកដ នេះជាបុព្វនិមិត្តរបស់ព្រហ្ម ។

[๓๔] *បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកតាវត្តិង្សទេវតា អង្គុយលើអាសនៈទាំងឡាយរបស់ខ្លួន ហើយគិតថា យើងទាំងឡាយនឹងជីនូវស្មើ*

នេះ ផលនឹងមានដោយហេតុណា យើងទាំងឡាយស្គាល់ច្បាស់នូវហេតុនោះ ហើយសឹមទៅ ។ ឯមហារាជទាំង ៤ ក៏គង់លើអាសនៈទាំងឡាយរបស់ខ្លួន ដោយគិតថា យើងទាំងឡាយ នឹងជឿនូវស្មើនេះ ផលនឹងមានដោយហេតុណា យើងទាំងឡាយ ស្គាល់ច្បាស់នូវហេតុនោះហើយ សឹមទៅ ។ ពួកតាវត្តឹង្សទេវតា បានឮពាក្យនេះហើយ ក៏មូលគំនិតគ្នា នាំគ្នាឈប់ស្ងៀម ដោយគិតថា យើងទាំងឡាយនឹងជឿនូវស្មើនេះ ផលនឹងមានដោយហេតុណា យើងទាំងឡាយ ស្គាល់ច្បាស់នូវហេតុនោះហើយ សឹមទៅ បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មឈ្មោះសនង្កុមារ មានមកប្រាកដដល់ពួកតាវត្តឹង្សទេវតា ក្នុងកាលណា ក៏និម្មិត្តអត្តភាពដ៏លើសលុប មានមកប្រាកដក្នុងកាលនោះ បពិត្រព្រះអង្គដ៏ចម្រើន សម្បុរជាប្រក្រតីណារបស់ព្រហ្ម ដែលពួកទេវតាមិនដែលឃើញសម្បុរជាប្រក្រតីនោះ រមែងប្រាកដមកក្នុងគន្ធងចក្ខុរបស់ពួកតាវត្តឹង្ស-ទេវតា បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មឈ្មោះសនង្កុមារ មានមកប្រាកដដល់ពួកតាវត្តឹង្សទេវតា ក្នុងកាលណា ព្រហ្មនោះរុងរឿងជាងពួកទេវតាជាន់ខ្ពស់ ដោយសម្បុរផង ដោយយសផង ក្នុងកាលនោះ បពិត្រព្រះអង្គដ៏ចម្រើន រូបដែលធ្វើពីមាស រមែងរុងរឿងជាងរាងកាយរបស់មនុស្សធម្មតាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម មានមកប្រាកដដល់ពួកតាវត្តឹង្ស-ទេវតាក្នុងកាលណា ព្រហ្មនោះរុងរឿងជាងពួកទេវតាជាន់ខ្ពស់ ដោយសម្បុរផង ដោយយសផង ក្នុងកាលនោះដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារ-ព្រហ្ម មានមកប្រាកដដល់ពួកតាវត្តឹង្សទេវតា ក្នុងកាលណា ឥតមានទេវតា

ណាមួយ ក្នុងបរិស័ទនោះសំពះ ឬក្រោកទទួល ឬអញ្ជើញដោយអាសនៈ ក្នុងកាលនោះឯង ពួកទេវតាទាំងអស់ស្ងៀមព្រងើយ នាំគ្នាផ្គងអញ្ជលីអង្គុយលើបល្ល័ង្ក សនង្កុមារព្រហ្ម ប្រថ្នាចង់អង្គុយលើបល្ល័ង្កបស់ទេវតាណា ក៏អង្គុយលើបល្ល័ង្កបស់ទេវតានោះភ្លាម បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម អង្គុយលើបល្ល័ង្កបស់ទេវតាណា ទេវតានោះ រមែងបាននូវសេចក្តីត្រេកអរលើសលុប ទេវតានោះ រមែងបាននូវសេចក្តីសោមនស្សដ៏លើសលុប បពិត្រព្រះអង្គដ៏ចម្រើន ក្សត្រជាស្តេចដែលបានមុទ្ធាភិសេកហើយ ទើបនឹងអភិសេកហើយថ្មីៗ ស្តេចនោះ រមែងបាននូវសេចក្តីត្រេកអរដ៏លើសលុបដោយរាជសម្បត្តិ ស្តេចនោះ រមែងបាននូវសេចក្តីសោមនស្សដ៏លើសលុប មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារ-ព្រហ្ម អង្គុយលើបល្ល័ង្កបស់ទេវតាណា ទេវតានោះ រមែងបាននូវសេចក្តីត្រេកអរដ៏លើសលុប ទេវតានោះ រមែងបាននូវសេចក្តីសោមនស្សដ៏លើសលុប មានឧបមេយ្យដូច្នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ សនង្កុមារព្រហ្ម បាននិម្មិតអត្តភាពដ៏លើសលុប ជាកេទនៃកុមារប្រហែលគ្នានឹងបញ្ចសិខទេវបុត្រ មានមកប្រាកដដល់ពួកតាវត្តិង្សទេវតា ព្រហ្មនោះហោះឡើងទៅកាន់អាកាស អង្គុយពែនភ្នែនក្នុងអាកាសវាលធំ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង អង្គុយពែនភ្នែនលើបល្ល័ង្ក ដែលគេក្រាលល្អហើយ ឬលើកូមិកាគដ៏ស្មើ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មហោះទៅកាន់អាកាស អង្គុយពែនភ្នែនក្នុងអាកាស

ภาลเขฆ์ มานอุปเมยฺยปุคฺคโลฺ ហើយជ្រាបនូវសេចក្តីជ្រះថ្លារបស់ពួកតាវត្តឹង្សទេវតា ក៏អនុមោទនាដោយគាថាទាំងឡាយនេះថា

[๓๕] អើហ្ន៎ ពួកតាវត្តឹង្សទេវតា ព្រមទាំងព្រះឥន្ទ្រ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ដ៏ល្អផង ហើយធ្វើចិត្តឲ្យរីករាយ ។ ពួកតាវត្តឹង្សទេវតា បានឃើញពួកទេវតាថ្មីៗ ដែលមានសម្បុរកាយ មានយស មកក្នុងទីនេះបាន ព្រោះប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះសុគត ។ ពួកទេវតាថ្មីទាំងនោះ រមែងរុងរឿងជាងពួកទេវតាឯទៀតដោយសម្បុរកាយ ដោយយស និងអាយុ ពួកទេវតាថ្មីទាំងនោះ ជាសាវ័ករបស់ព្រះសម្ពុទ្ធ មានប្រាជ្ញាដូចផែនដី ជាសាវ័កពិសេស បានចូលមកហើយក្នុងទីនេះ ។ ពួកតាវត្តឹង្សទេវតា ព្រមទាំងព្រះឥន្ទ្រ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង ហើយធ្វើចិត្តឲ្យត្រេកអរ ព្រោះឃើញនូវហេតុនេះ ។

[๓๖] បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មបានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលសនង្កុមារព្រហ្មពោលនូវសេចក្តីនេះ មានសំឡេងប្រកបដោយអង្គ ๘ គឺសំឡេងក្បោះក្បាយ ๑ សំឡេងផ្ងាយយល់ ๑ សំឡេងទន់ពីរោះ ๑ សំឡេងគួរស្តាប់ ๑ សំឡេងគ្រលួច ๑ សំឡេងមិនគ្រាវ ๑ សំឡេងក្រអួន ๑ សំឡេងរំពង ๑ ។

បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម ញុំាងបរិស័ទចំនួនប៉ុន្មានក៏ដោយ ឲ្យដឹងច្បាស់ដោយសំឡេងបាន ឯសំឡេងរបស់ព្រហ្មនោះ មិនលាន់ឮចេញទៅខាងក្រៅបរិសទ្យឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា មានសំឡេងប្រកបដោយអង្គ ៨ យ៉ាងនេះ បុគ្គលនោះ ហៅថា មានសំឡេងដូចសំឡេងព្រហ្ម ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្មនិម្មិតអត្តភាពចំនួន ៣៣ គង់លើបល្ល័ង្កមួយៗ របស់ពួកតាវត្តិង្សទេវតា ហើយហៅពួកតាវត្តិង្សទេវតាមកថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកតាវត្តិង្ស-ទេវតា សម្គាល់ហេតុនោះដូចម្តេច ព្រះមានព្រះភាគអង្គនុ៎ះ ទ្រង់ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន បើពួកជនឯណាមួយដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ធ្វើនូវការបំពេញក្នុងសីលទាំងឡាយ ហើយពួកជននោះ លុះទម្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់និម្មានរតី ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់តុសិត ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់យាមៈ ខ្លះក៏មកកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកា ពួកជនណាញុំាងកាយទេវតាដែលទន់ទាបជាងគេទាំងអស់ឲ្យបរិបូណ៌ ពួកជនទាំងនោះ ក៏ញុំាងពួកគន្ធព្វ

ឲ្យបរិបូណ៌ ។

[៣៧] *បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលសនង្កុមារព្រហ្មពោលនូវសេចក្តីនេះ មានសំឡេងគីកកង ពួកទេវតាសម្គាល់ថា ព្រហ្មណាអង្គុយលើបល្ល័ង្ករបស់អាត្មាអញ ព្រហ្មនោះនិយាយតែម្នាក់ឯង ។*

កាលបើសនង្កុមារព្រហ្ម និយាយតែម្នាក់ឯង ព្រហ្មនិម្មិតទាំងអស់ ក៏និយាយដែរ កាលបើសនង្កុមារព្រហ្ម អង្គុយស្ងៀមតែម្នាក់ឯង ព្រហ្មនិម្មិតទាំងអស់នោះក៏ស្ងៀមដែរ ។ ពួកតាវត្តិង្សទេវតា ព្រមទាំងព្រះឥន្ទ្រ សម្គាល់សេចក្តីនោះថា ព្រហ្មណាអង្គុយលើបល្ល័ង្ករបស់អាត្មាអញ ព្រហ្មនោះនិយាយតែម្នាក់ឯង ។

[៣៨] *បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្ម ប្រមូលនូវខ្លួនដែលច្រើន ឲ្យមកជាខ្លួនតែមួយវិញ លុះប្រមូលនូវខ្លួនដែលច្រើន ឲ្យមកជាខ្លួនតែមួយវិញហើយ ក៏អង្គុយលើបល្ល័ង្ក របស់ព្រះឥន្ទ្រជាធំជាងពួកទេវតា ហើយត្រាស់ហៅពួកតាវត្តិង្សទេវតាមកថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតា សម្គាល់សេចក្តីនោះដូចម្តេច ឥទ្ធិបាទទាំង ៤ នេះ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយដោយល្អ រមែងប្រព្រឹត្តទៅ ដើម្បីធ្វើឫទ្ធិឲ្យច្រើន ដើម្បីធ្វើឫទ្ធិឲ្យវិសេសឡើង ដើម្បីធ្វើឫទ្ធិឲ្យប្លែកៗ ឥទ្ធិបាទ*

ទាំង ๔ នោះ តើដូចម្តេច ម្នាលអ្នកដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ម្នាលអ្នកដ៏ចម្រើន ឥទ្ធិបាទទាំង ๔ នេះឯង ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយ រមែងប្រព្រឹត្តទៅ ដើម្បីធ្វើឫទ្ធិឲ្យច្រើន ដើម្បីធ្វើឫទ្ធិឲ្យវិសេសឡើង ដើម្បីធ្វើឫទ្ធិឲ្យប្លែកៗ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកជនណានីមួយ ទោះបីជាសមណៈ ឬព្រាហ្មណ៍ បានហើយនូវឥទ្ធិវិធៈមានច្រើនប្រការ ក្នុងអតីតកាល ពួកជនទាំងអស់នោះបានហើយ ព្រោះបានចម្រើននូវឥទ្ធិបាទទាំង ๔ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ๔ នេះឯងឲ្យច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកជនណានីមួយ ទោះបីជាសមណៈ ឬព្រាហ្មណ៍ ដែលនឹងបាននូវឥទ្ធិវិធៈមានច្រើនប្រការ ក្នុងអនាគតកាល ពួកជនទាំងអស់នោះ ក៏នឹងបាន ព្រោះបានចម្រើននូវឥទ្ធិបាទទាំង ๔ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ๔ នេះឯងឲ្យច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកជនណានីមួយ ទោះបីជាសណមៈ ឬព្រាហ្មណ៍ រមែងបាននូវឥទ្ធិវិធៈ មានច្រើនប្រការក្នុងបច្ចុប្បន្ននេះ ពួកជនទាំងអស់នោះ ក៏រមែងបាន ព្រោះបានចម្រើននូវឥទ្ធិបាទទាំង ๔ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ๔ នេះឯងឲ្យច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតាឃើញឫទ្ធានុភាពមានសភាព

ដូច្នេះនេះ របស់យើងដែរឬទេ ។ ពួកទេវតាឆ្លើយតបថា បពិត្រមហាព្រហ្ម
អើ ឃើញដែរ ។ សនង្កុមារព្រហ្មនិយាយថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ
ឯខ្លួនខ្ញុំបានជាមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះបាន
ចម្រើននូវឥទ្ធិបាទទាំង ៤ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ៤ នេះឯង
ឲ្យច្រើន ។

[๓๙] *ជនវសភយក្ស ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន*
សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន
លុះសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះហើយ ក៏ពោលនឹងពួកតាវត្តិង្ស-
ទេវតាថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតា សម្គាល់សេចក្តី
នោះដូចម្តេច ត្រង់ដែលថា ការបាននូវឱកាស ៣ យ៉ាង ដើម្បីបាននូវសេចក្តី
សុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាប
ច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។ ការបាននូវឱកាស ៣ យ៉ាង
តើដូចម្តេច ។

[๔๐] *ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ*
ជាប់ជំពាក់ដោយកាមទាំងឡាយ ជាប់ជំពាក់ដោយអកុសលធម៌ទាំងឡាយ ។
សម័យជាខាងក្រោយមក បុគ្គលនោះបានស្តាប់នូវអរិយធម៌ ធ្វើទុកក្នុងចិត្ត
ដោយឧបាយនៃប្រាជ្ញា ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ លុះបុគ្គលនោះ
អាស្រ័យការស្តាប់អរិយធម៌ អាស្រ័យការធ្វើទុកក្នុងចិត្តដោយឧបាយនៃ
ប្រាជ្ញា ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ក៏ជាបុគ្គលលែងជាប់ជំពាក់ដោយ

កាមទាំងឡាយ លែងជាប់ជំពាក់ដោយអកុសលធម៌ទាំងឡាយ ។ ការដែលបុគ្គលនោះ លែងជាប់ជំពាក់ ដោយកាមទាំងឡាយហើយ លែងជាប់ជំពាក់ដោយអកុសលធម៌ទាំងឡាយហើយ សេចក្តីសុខក៏កើតឡើង សោមនស្សក៏កើតឡើងដោយក្រៃលែង ព្រោះសេចក្តីសុខជាបច្ច័យ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្តីរីករាយមានកម្លាំងខ្លាំងកើតឡើង ព្រោះសេចក្តីរីករាយមានកម្លាំងទន់ ដូចម្តេចមិញ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ កាលដែលបុគ្គលលែងជាប់ជំពាក់ ដោយកាមទាំងឡាយហើយ លែងជាប់ចំពាក់ដោយអកុសលធម៌ទាំងឡាយហើយ សេចក្តីសុខក៏កើតឡើង សោមនស្សក៏កើតឡើង ដោយក្រៃលែង ព្រោះសេចក្តីសុខ (ជាបច្ច័យ) ដូច្នេះដែរ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ នេះឯងជាការបាននូវឱកាសជាបឋម ដើម្បីបាននូវសេចក្តីសុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។

[๔๑] ម្នាលអ្នកដ៏ចម្រើនទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មានកាយសង្ខារ ដ៏គ្រោតគ្រាតមិនទាន់ស្ងប់រម្ងាប់ មានវចីសង្ខារដ៏គ្រោតគ្រាត មិនទាន់ស្ងប់រម្ងាប់ មានចិត្តសង្ខារ ដ៏គ្រោតគ្រាត មិនទាន់ស្ងប់រម្ងាប់ ។ សម័យខាងក្រោយមក បុគ្គលនោះ ស្តាប់នូវអរិយធម៌ ធ្វើទុកក្នុងចិត្តដោយឧបាយ ប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ។ លុះបុគ្គលនោះអាស្រ័យការស្តាប់អរិយធម៌ អាស្រ័យការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ប្រតិបត្តិនូវធម៌សមគួរដល់ធម៌ហើយ កាយសង្ខារគ្រោតគ្រាត ក៏

สูบ់រម្ងាប់ទៅ វចីសង្ខារគ្រោតគ្រាត ក៏សូប់រម្ងាប់ទៅ ចិត្តសង្ខារគ្រោតគ្រាត ក៏សូប់រម្ងាប់ទៅ ។ សេចក្តីសុខរមែងកើតឡើងដល់បុគ្គលនោះ ព្រោះការសូប់រម្ងាប់នៃកាយសង្ខារគ្រោតគ្រាត ព្រោះការសូប់រម្ងាប់នៃវចីសង្ខារគ្រោតគ្រាត ព្រោះការសូប់រម្ងាប់នៃចិត្តសង្ខារគ្រោតគ្រាត ឯសោមនស្ស ក៏កើតឡើងដោយក្រៃលែង ព្រោះសេចក្តីសុខ (នោះជាបច្ច័យ) ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្តីរីករាយមានកម្លាំងកើតឡើង ព្រោះសេចក្តីរីករាយមានកម្លាំងទន់ ដូចម្តេចមិញ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្តីសុខរមែងកើតឡើង ព្រោះសូប់រម្ងាប់នៃកាយសង្ខារគ្រោតគ្រាត ព្រោះការសូប់រម្ងាប់នៃវចីសង្ខារគ្រោតគ្រាត ព្រោះការសូប់រម្ងាប់នៃចិត្តសង្ខារគ្រោតគ្រាត ឯសោមនស្ស ក៏កើតឡើងដោយក្រៃលែង ព្រោះសេចក្តីសុខ (នោះជាបច្ច័យ) ក៏ដូច្នោះដែរ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ នេះឯងជាការបាននូវឱកាសជាគម្រប់ពីរ ដើម្បីបាននូវសេចក្តីសុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។

[๔๒] ម្នាលអ្នកដ៏ចម្រើនទាំងឡាយ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មិនដឹងច្បាស់តាមពិតថា នេះជាកុសល មិនដឹងច្បាស់តាមពិតថា នេះជាអកុសល មិនដឹងច្បាស់តាមពិតថា នេះជាអំពើប្រកបដោយទោស មិនដឹងច្បាស់តាមពិតថា នេះជាអំពើមិនមានទោស មិនដឹងច្បាស់តាមពិតថា នេះជាអំពើគួរសេព មិនដឹងច្បាស់តាមពិតថា នេះជាអំពើមិនគួរសេព មិន

ដឹងច្បាស់តាមពិតថា នេះជាអំពើថោកទាប មិនដឹងច្បាស់តាមពិតថា នេះជាអំពើខ្ពង់ខ្ពស់ មិនដឹងច្បាស់តាមពិតថា នេះជាអំពើខ្មៅ ជាអំពើស ជាអំពើមានចំណែកប្រៀបផ្ទឹមគ្នា ។ សម័យជាខាងក្រោយមក បុគ្គលនោះស្តាប់នូវអរិយធម៌ ធ្វើទុកក្នុងចិត្តដោយឧបាយ ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ បុគ្គលលុះអាស្រ័យការស្តាប់អរិយធម៌ អាស្រ័យការធ្វើទុកក្នុងចិត្តដោយឧបាយ ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ក៏ដឹងច្បាស់តាមពិតថា នេះជាកុសល ដឹងច្បាស់តាមពិតថា នេះជាអកុសល ដឹងច្បាស់តាមពិតថា នេះជាអំពើប្រកបដោយទោស ដឹងច្បាស់តាមពិតថា នេះជាអំពើមិនមានទោស ដឹងច្បាស់តាមពិតថា នេះជាអំពើគួរសេព ដឹងច្បាស់តាមពិតថា នេះជាអំពើមិនគួរសេព ដឹងច្បាស់តាមពិតថា នេះជាអំពើថោកទាប ដឹងច្បាស់តាមពិតថា នេះជាអំពើខ្ពង់ខ្ពស់ ដឹងច្បាស់តាមពិតថា នេះជាអំពើខ្មៅ ជាអំពើស ជាអំពើមានចំណែកប្រៀបផ្ទឹមគ្នា ។ កាលដែលបុគ្គលនោះ ដឹងច្បាស់យ៉ាងនេះ ឃើញច្បាស់យ៉ាងនេះហើយ អវិជ្ជាក៏សាបសូន្យទៅ វិជ្ជាក៏កើតឡើង ។ សេចក្តីសុខរមែងកើតឡើងដល់បុគ្គលនោះ ព្រោះការសាបសូន្យទៅនៃអវិជ្ជា ព្រោះការកើតឡើងនៃវិជ្ជា ឯសោមនស្ស ក៏កើតឡើងដោយក្រៃលែង ព្រោះសេចក្តីសុខ (នោះជាបច្ចុយ) ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្តីរីករាយមានកម្លាំងខ្លាំង រមែងកើតឡើង ព្រោះសេចក្តីរីករាយមានកម្លាំងទន់ដូចម្តេចមិញ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្តីសុខ រមែងកើតឡើង ព្រោះការសាបសូន្យទៅនៃអវិជ្ជា ព្រោះការកើតឡើងនៃអវិជ្ជា ឯសោមនស្ស

ក៏រមែងកើតឡើងដោយក្រៃលែង ព្រោះសេចក្តីសុខ (នោះជាបច្ច័យ) ដូច្នោះដែរ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ នេះឯងជាការបាននូវឱកាសជាគម្រប់ ៣ ដើម្បីបាននូវសេចក្តីសុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្ត-សម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ការបាននូវឱកាស ដើម្បីបាននូវសេចក្តីសុខ ៣ ប្រការនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។

[๔๓] បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មបានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះហើយ ទើបពោលនឹងពួកតាវត្តិង្សទេវតាថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតា សម្គាល់សេចក្តីនោះដូចម្តេច ត្រង់ដែលថា សតិប្បដ្ឋានទាំង ๔ នេះ ដើម្បីបាននូវកុសល ដែលព្រះមានព្រះភាគអង្គនោះ ជាអរ-ហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយដោយល្អ ។ សតិប្បដ្ឋានទាំង ๔ តើដូចម្តេច ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោសមនស្សក្នុងលោក ភិក្ខុកាលពិចារណាឃើញរឿយៗ នូវកាយជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងកាយជាខាងក្នុងនោះ ។ ភិក្ខុនោះលុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ

ជ្រះថ្លាដោយប្រពៃ ក្នុងកាយជាខាងក្នុងនោះហើយ រមែងញុំាងញាណទស្សនៈ (ការដឹង និងការឃើញ) ឲ្យកើតក្នុងកាយរបស់បុគ្គលដទៃ ជាខាងក្រៅបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនា ក្នុងវេទនាទាំងឡាយជាខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោសមនស្សក្នុងលោក ភិក្ខុកាលពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងវេទនាជាខាងក្នុងនោះ ។ ភិក្ខុនោះលុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងវេទនាជាខាងក្នុងនោះហើយ រមែងញុំាងញាណទស្សនៈ ឲ្យកើតក្នុងវេទនាទាំងឡាយ របស់បុគ្គលដទៃជាខាងក្រៅបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោសមនស្សក្នុងលោក ភិក្ខុកាលពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងចិត្តជាខាងក្នុងនោះ ។ ភិក្ខុនោះ លុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃក្នុងចិត្តជាខាងក្នុងនោះហើយ រមែងញុំាងញាណទស្សនៈ ឲ្យកើតក្នុងចិត្តរបស់បុគ្គលដទៃជាខាងក្រៅបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ ក្នុងធម៌ទាំងឡាយជាខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោសមនស្សក្នុងលោក ភិក្ខុកាលពិចារណាឃើញរឿយៗ នូវធម៌

ក្នុងធម៌ទាំងឡាយជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងធម៌ជាខាងក្នុងនោះ ។ ភិក្ខុនោះ លុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងធម៌ជាខាងក្នុងនោះហើយ ក៏រមែងញុំាងញាណទស្សនៈ ឲ្យកើតក្នុងធម៌ទាំងឡាយរបស់បុគ្គលដទៃជាខាងក្រៅបាន ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សតិប្បដ្ឋានទាំង ៤ នេះឯង ដើម្បីបាននូវកុសល ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយ ។

[៤៤] បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះសនង្កុមារព្រហ្ម ពោលសេចក្តីនេះហើយ ទើបពោលនឹងពួកតាវត្តិង្សទេវតាថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតាសម្គាល់សេចក្តីនោះដូចម្តេច ត្រង់ដែលថាធម៌ជាបរិវារនៃសមាធិ ៧ យ៉ាងនេះ ដើម្បីចម្រើននៃសម្មាសមាធិ ដើម្បីបរិបូណ៌ិនៃសម្មាសមាធិ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយដោយល្អ ។ ធម៌ជាបរិវារនៃសមាធិ ៧ យ៉ាងតើដូចម្តេច ។ សម្មាទិដ្ឋិ(សេចក្តីយល់ត្រូវ) ១ សម្មាសង្កប្ប (សេចក្តីត្រិះរិះត្រូវ) ១ សម្មាវាចា (សម្តីត្រូវ) ១ សម្មាកម្មន្តៈ (ការងារត្រូវ) ១ សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ១ សម្មាវាយាមៈ (សេចក្តីព្យាយាមត្រូវ) ១ សម្មាសតិ (សេចក្តីរឭកត្រូវ) ១ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សភាវៈនៃចិត្ត មានអារម្មណ៍មូលតែមួយណា ដែល

អង្គទាំង ៧ នេះចោមរោមហើយ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សភាវៈនៃចិត្ត មានអារម្មណ៍តែមួយនេះ លោកហៅថា សម្មាសមាធិដ៏ប្រសើរ ប្រកបដោយឧបនិស្សយផង ថាប្រកបដោយធម៌ជាបរិវារផង ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សម្មាសង្កប្បរមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាទិដ្ឋិ សម្មាវាចារមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាសង្កប្ប សម្មាកម្មន្តៈ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាវាចា សម្មាអាជីវៈ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាកម្មន្តៈ សម្មាវាយាមៈ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាអាជីវៈ សម្មាសតិ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាវាយាមៈ សម្មាសមាធិ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាសតិ សម្មាញាណ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាសមាធិ វិមុត្តិ រមែងមានដល់បុគ្គលដែលឋិតនៅក្នុងសម្មាញាណ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលកាលបើពោលដោយប្រពៃ គប្បីពោលនូវពាក្យថា ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ព្រះនពលោកុត្តរធម៌ដែលព្រះអរិយបុគ្គលទាំងពួង ដ៏ងពិត ឃើញពិត ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ទ្វារនៃព្រះនិព្វាននោះរបើកហើយ ។ បុគ្គលកាលពោលដោយប្រពៃ គប្បីពោលនូវពាក្យដែលប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រចំពោះព្រះសម្មាសម្ពុទ្ធថា មែនពិត ព្រះបរិយត្តិធម៌ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែង

ហើយដោយល្អ ព្រះនពលោកុត្តរធម៌ ដែលព្រះអរិយបុគ្គលទាំងពួង ដ៏ឆពិត ឃើញពិត ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន ទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ទ្វារនៃព្រះនិព្វាននោះរបើក ហើយ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ព្រោះថា ជនទាំងឡាយណាមួយ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រចំពោះព្រះពុទ្ធ ប្រកបដោយសេចក្តី ជ្រះថ្លា មិនញាប់ញ័រចំពោះព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ ញ័រចំពោះព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់ របស់ព្រះ អរិយៈ មួយទៀត ជនទាំងឡាយណា ជាឱបបាតិក ជាជនទៀង ក្នុងធម៌ ខ្ញុំខ្ចាចអំពើមុសាវាទ មិនអាចនឹងរាប់ជនទាំងអម្បាលនោះ ដូច្នេះថា ពួកជន នៅក្នុងដែនមគធៈ ច្រើនជាង ២ លាន ៤ សែន ជាអ្នកបម្រើព្រះពុទ្ធ ព្រះ ធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្ត ទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ។ ពួកសកទាគាមិបុគ្គល ក៏មានក្នុងទីនោះដែរ ឯពួកសត្វក្រៅពីនេះ ជាអ្នកមានចំណែកបុណ្យ (ក៏ មានច្រើនដែរ) ។

[៤៥] *បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវ សេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះហើយ វេស្សវណមហារាជ កើតសេចក្តីត្រិះរិះក្នុងចិត្ត*

យ៉ាងនេះថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចម្លែកពេកណាស់ ព្រះសាស្តា ដ៏ប្រសើរ មានសភាពយ៉ាងនេះ មុខជានឹងមានតទៅមិនខាន ការសម្តែង នូវធម៌ដ៏ថ្លៃថ្លា មានសភាពយ៉ាងនេះ នឹងប្រាកដជាឡើង ការត្រាស់ដឹងនូវគុណ វិសេសដ៏លើសលុប មានសភាពយ៉ាងនេះ ក៏នឹងប្រាកដជាឡើង ។ បពិត្រ ព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្ម ដឹងសេចក្តីត្រិះរិះក្នុងចិត្ត របស់ វេស្សវណមហារាជ ដោយចិត្ត (របស់ខ្លួន) ហើយ ទើបពោលពាក្យនេះ នឹងវេស្សវណមហារាជថា វេស្សវណមហារាជដ៏ចម្រើន សម្គាល់សេចក្តី នោះដូចម្តេច ព្រះសាស្តាដ៏ប្រសើរ មានសភាពយ៉ាងនេះ ក៏មានមកហើយ ការសម្តែងនូវធម៌ដ៏ថ្លៃថ្លា មានសភាពយ៉ាងនេះ ក៏ប្រាកដហើយ ការត្រាស់ ដឹងនូវគុណវិសេសដ៏លើសលុប មានសភាពយ៉ាងនេះ ក៏ប្រាកដហើយក្នុង អតីតកាល ព្រះសាស្តាដ៏ប្រសើរ មានសភាពយ៉ាងនេះ មុខជានឹងមានតទៅ ការសម្តែងនូវធម៌ដ៏ថ្លៃថ្លា មានសភាពយ៉ាងនេះ នឹងប្រាកដជាឡើង ការត្រាស់ ដឹងនូវគុណវិសេសដ៏លើសលុប មានសភាពយ៉ាងនេះ ក៏នឹងប្រាកដជាឡើង ក្នុងអនាគតកាល ។

[៤៦] បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវ សេចក្តីនេះ នឹងពួកតាវត្តិង្សទេវតាហើយ ។ កាលសនង្កុមារព្រហ្ម ពោល សេចក្តីនេះនឹងតាវត្តិង្សទេវតា វេស្សវណមហារាជ បានប្រាប់សេចក្តីនេះ ដែលខ្លួនបានឮហើយ ក្នុងទីចំពោះមុខ ដែលខ្លួនបានទទួលហើយក្នុងទីចំពោះ មុខ ក្នុងបរិស័ទរបស់ខ្លួន ។ កាលវេស្សវណមហារាជពោលសេចក្តីនេះ ក្នុង

បរិស័ទរបស់ខ្លួន ជនវសកយក្ស ក៏ក្រាបទូលសេចក្តីដែលខ្លួនបានឮហើយ ក្នុងទីចំពោះមុខ ដែលខ្លួនបានទទួលហើយ ក្នុងទីចំពោះមុខ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានទ្រង់ព្រះសណ្តាប់សេចក្តីនេះ ទទួលសេចក្តីនេះ ក្នុងទីចំពោះមុខនៃជនវសកយក្ស ជ្រាបច្បាស់ដោយព្រះអង្គឯងហើយ ទើបត្រាស់ប្រាប់ដល់ព្រះអានន្ទមានអាយុ ។ លុះព្រះអានន្ទមានអាយុ បានឮ បានទទួលក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគហើយ ទើបប្រាប់សេចក្តីនេះដល់ពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ។ សាសនព្រហ្មចរិយធម៌នេះមាំមួន ដល់នូវសេចក្តីចម្រើន ផ្សាយទៅសព្វទិស អ្នកផងបានដឹងច្រើនគ្នាហើយ កើតមានក្រាស់ក្រែល ត្រាតែពួកទេវតា និងមនុស្សចេះសម្តែងដោយស្រួលបាន ។

ជនវសកសូត្រទី ៥ ចប់

អដ្ឋកថា

ជនវសភសូត្រ

[๒๕] ជនវសភសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្តាប់មកយ៉ាងនេះ ដូច្នេះ ។ ពណ៌នាបទដែលជ្រាលជ្រៅក្នុងជនវសភសូត្រមានដូច្នេះ បទថា **បរិនោ បរិនោ ជនបទេសុ** សេចក្តីថា ក្នុងជនបទជិតខាង ។ បទថា **បរិចារកេ** សេចក្តីថា អ្នកទំនុកបម្រុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា **ឧប្បត្តីសុ** សេចក្តីថា ក្នុងការឧប្បត្តិនៃញាណគតិ និងបុណ្យ ។ បទថា **កាសីកោសលេសុ** សេចក្តីថា ក្នុងដែនកាសី និងកោសល អធិប្បាយថា ក្នុងកាសីរដ្ឋ និងកោសលរដ្ឋ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នា ។ តែទ្រង់មិនព្យាករក្នុងរដ្ឋទាំង ៦ គឺអង្គៈ មគធៈ យោនកៈ កម្ពោជៈ អស្សកៈ និងអវន្តី ។ ទ្រង់ព្យាករក្នុងជនបទ ១០ មុន នៃមហាជនបទ ១៦ នេះ ។

[๒๖-๒๗] បទថា **ឆាឌិកិយា** សេចក្តីថា អ្នកស្រុកនាទិកៈ ។ បទថា **តេន ច** សេចក្តីថា ដោយភាពជាព្រះអនាគាមីជាដើមនោះ ។ បទថា **សុត្វា** សេចក្តីថា បានស្តាប់បញ្ហាព្យាករណ៍របស់ព្រះមានព្រះភាគ ទ្រង់កំណត់ដោយព្រះសព្វញ្ញុតញ្ញាណ ព្យាករហើយ ក៏ទ័ងជល់ទីបំផុត ក្នុងភាពជាព្រះអនាគាមីជាដើមរបស់ជនទាំងនោះ ក៏ទ័ងមានចិត្តជារបស់ខ្លួន ដោយភាពជាព្រះអនាគាមីជាដើមនោះ ។ តែក្នុងអដ្ឋកថាពោលថា បទថា **តេន** គឺអ្នកស្រុកនាទិកៈទាំងនោះ ។ ពិតហើយ **ន** អក្ខរៈ ក្នុងអត្ថនោះ ត្រឹមតែជានិបាត ។

បទថា **ភគវន្តំ កិត្តយមានរូបោ** សេចក្តីថា ព្រះបាទពិម្ពិសារ ទ្រង់បរិកម្មយ៉ាងនេះថា ឱហ្ន៎ព្រះពុទ្ធ ឱហ្ន៎ព្រះធម៌ ឱហ្ន៎ព្រះសង្ឃ ឱព្រះធម៌ដែល

ត្រាស់ល្អ ហើយក៏សោយទិវង្គតសុគត ។ បទថា **ពហុជនោ បសីទេយ្យ** *សេចក្តីថា ជនច្រើន ដល់នូវការជ្រះថ្លាយ៉ាងនេះថា បិតា មាតា បងប្រុស បងស្រី បុត្រ ធីតា សម្លាញ់ របស់ពួកយើង ពួកយើងជាប់បរិភោគរួម ដេករួមនឹងលោក ពួកយើងនឹងធ្វើវត្តុដែលគួរពេញចិត្តយ៉ាងនេះ និងយ៉ាងនេះដល់លោកនោះ បានឮថា លោកនោះ ជាអនាគាមី សកទាគាមី សោតាបន្ន ឱហ្ន៎ជាការប្រសើរ ឱហ្ន៎ជាការប្រពៃ ។ បទថា* **គតិ** *គឺញាណគតិ ។*

[๒๘] *បទថា* **អភិសម្បរាយំ** *សេចក្តីថា មានញាណប្រព្រឹត្តទៅខាងមុខ ។ បទថា* **អទ្ទសា ខោ** *សេចក្តីថា បានឃើញជន ប្រមាណប៉ុនណា ។ ប្រមាណ ๒ លាន ๔ សែននាក់ ។*

[๒๙] *បទថា* **ឧបសន្តបតិស្សោ** *សេចក្តីថា ទ្រង់មានទស្សនៈស្ងប់ហើយ ។ បទថា* **ភាតិរវ** *សេចក្តីថា ស្រស់បស់ក្រៃលែង គឺរុងរឿងពេក ។ បទថា* **ឥន្ទ្រិយានំ** *សេចក្តីថា ព្រះឥន្ទ្រិយដែលមានព្រះហឫទ័យជាគម្រប់ ๖ ។ បទថា* **អទ្ទសំ ខោ អហំ អានន្ទ** *សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា តថាគតបានឃើញអ្នកបម្រើក្នុងដែនមគធៈ មិនមែនចំនួន ๑๐ ចំនួន ๒๐ ចំនួន ๑๐๐ ចំនួន ๑๐๐๐ តែចំនួនមិនគិច ជាង ๒ លាន ๔ សែននាក់ តែជនមានប្រមាណប៉ុណ្ណោះ ឃើញតថាគតហើយ អាស្រ័យតថាគតផុតចាកទុក្ខហើយ សោមនស្សមានកម្លាំងកើតឡើងហើយ ចិត្តជ្រះថ្លា ព្រោះចិត្តជ្រះថ្លា លោហិតដែលមានចិត្តជាសមុដ្ឋានក៏ថ្លាផូរផង់ ព្រោះលោហិតផូរផង់ ឥន្ទ្រិយទាំងឡាយដែលមានមនៈជាគម្រប់ ๖ ក៏ផូរផង់ កាលត្រាស់ដូច្នេះហើយ*

ទើបត្រាស់ថា **អថខោ អានន្ទ** *ជាដើម ។ ព្រះបាទពិម្ពិសារអង្គនោះ ទ្រង់ស្តាប់ព្រះធម្មកថារបស់ព្រះមានព្រះភាគក្នុងទីនោះជាធំនៃជន ๑ សែន និង ๑ ម៉ឺន សម្រេចជាព្រះសោតាបន្ន ព្រោះដូច្នោះ ទើបព្រះអង្គ មានព្រះនាមថា ជនវសភៈ ។*

[๓๐] *បទថា* **ឥតោ សត្ត** *សេចក្តីថា ចុតិចាកទេវលោកនេះ ๗ ជង ។ បទថា* **តតោ សត** *សេចក្តីថា ចុតិអំពីមនុស្សលោកនោះ ๗ ជង ។ បទថា* **សំសរាមិ ចតុទ្ទស** *សេចក្តីថា តាមលំដាប់ខន្ធទាំងអស់ ๑๔ ជង ។ បទថា* **និវាសមភិជានាមិ** *សេចក្តីថា ខ្ញុំព្រះអង្គដឹងនិវាស គឺលំនៅដោយអំណាចនៃជាតិ ។ បទថា* **យត្ត មេ វុសិតំ បុរេ** *សេចក្តីថា ខ្ញុំព្រះអង្គចូលដល់ភាពជាសម្ងាញ់នៃវេស្សវណៈក្នុងទេវលោក និងជាស្តេចក្នុងមនុស្សលោកហើយ ក្នុងកាលមុនអំពីអត្តភាពនេះ និងព្រោះបាននៅយ៉ាងនេះហើយ ឥឡូវនេះ បានជាសោតាបន្ន ធ្វើបុណ្យច្រើនក្នុងវត្តទាំង ๓ សូម្បីអាចកើតក្នុងទីខ្ពស់ ដោយអានុភាពនៃបុណ្យនោះ ទើបបានកើតហើយក្នុងទីនេះឯង ព្រោះកម្លាំងនៃសេចក្តីជ្រាបច្បាស់ ក្នុងលំនៅរហូតអស់កាលយូរ ។*

ដោយបទថា **អាសា ច បន មេ សន្និដ្ឋតិ** *នេះ លោកសម្តែងថា ខ្ញុំព្រះអង្គ មិនប្រមាទថា ខ្ញុំព្រះអង្គជាសោតាបន្ន ញុំាងកាលឲ្យកន្លងហើយ ខ្ញុំព្រះអង្គបានចម្រើនវិបស្សនា ដើម្បីប្រយោជន៍ដល់សកទាគាមី ហើយមានសេចក្តីសង្ឃឹមថា ខ្ញុំព្រះអង្គនឹងសម្រេចក្នុងថ្ងៃនេះៗ ។ បទថា* **យឧត្តេ** *សេចក្តីថា លោកពោលបំណងដល់ថ្ងៃសម្រេចជាព្រះសោតាបន្ន ក្នុងបឋមទស្សនៈ ត្រង់ឱទ្យានលដ្ឋិវន ។ បទថា* **តឧត្តេ អហំ ភន្តេ ឱឃរត្តំ អវិនិ-**

ចាតោ អវិឆិន្នាតំ សញ្ញានាមិ *សេចក្តីថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានធ្វើថ្ងៃនោះជាដើមហេតុ មិនធ្លាក់ចុះអស់កាលយូរវាប់បាន ๑๔ អត្តភាពមុន បានចាំធម៌ដែលមិនញាំងខ្លួនឲ្យធ្លាក់ចុះ ដែលសម្រេចហើយដោយអំណាចសោតាបត្តិមគ្គ នៅត្រង់សួនលដ្ឋិវន ។ បទថា* **អនច្ឆរិយំ** *សេចក្តីថា អស្ចារ្យរឿយៗ ។ កាលខ្ញុំព្រះអង្គទៅដោយកណីយកិច្ចឯណានីមួយ បានឃើញព្រះមានព្រះភាគក្នុងចន្លោះផ្លូវ ជាការអស្ចារ្យដែលគិតជល់រឿយៗ និងធម៌ដែលខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រៈរបស់ព្រះមានព្រះភាគ ត្រាស់ក្នុងបរិស័ទរបស់មហាភជវេស្សវណានោះ សេចក្តីនេះក៏ជាការអស្ចារ្យ ។ បទថា* **ទ្វេ បច្ចយា** *សេចក្តីថា ការឃើញក្នុងចន្លោះផ្លូវ និងការប្រាថ្នាប្រាប់ធម៌ដែលបានស្តាប់ចំពោះមុខវេស្សវណមហាភជ ។ បទថា* **សន្និបតិតា** *សេចក្តីថា ប្រជុំព្រោះហេតុអ្វី ។ បានឮថា ទេវតាទាំងនោះ ប្រជុំដោយហេតុ ๔ ប្រការ គឺដើម្បីសង្គ្រោះថ្ងៃវស្សូបនាយិកា ដើម្បីសង្គ្រោះថ្ងៃបវារណា ដើម្បីស្តាប់ធម៌ ដើម្បីលេងចារិច្ឆត្តកីឡា ។ ក្នុងហេតុការណ៍ទាំងនោះ ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ពួកទេវតាក្នុងទេវលោកទាំងពីរប្រជុំក្នុងទេវសភា ឈ្មោះសុធម្មាថា ស្អែកនេះជាថ្ងៃវស្សូបនាយិកា ហើយប្រឹក្សាគ្នាថា ក្នុងវិហារឯណោះ មានភិក្ខុចូលវស្សាមួយរូប ក្នុងវិហារឯណោះ មានភិក្ខុចូលវស្សា ๒ រូប ๓ រូប ๔ រូប ๕ រូប ๑๐ រូប ๒๐ រូប ๓๐ រូប ๔๐ រូប ๕๐ រូប ๑๐๐ រូប ๑๐๐๐ រូប អ្នកទាំងឡាយ ចូរធ្វើការរក្សាអារាមក្នុងទីនោះៗ ឲ្យល្អ ។ ការសង្គ្រោះវស្សូបនាយិកា ពួកទេវតាបានធ្វើហើយ ដូច្នេះ ។ សូម្បីក្នុងកាលនោះ ពួកទេវតាបានប្រជុំហើយ ដោយហេតុនោះឯង ។ បទថា* **ឥធ តេសំ ហោតិ អាសនស្មឹ**

សេចក្តីថា អាសនៈនេះ ជារបស់មហារាជទាំង ៤ នោះ ។ កាលមហារាជ
ទាំងនោះ បានអង្គុយយ៉ាងនេះហើយ តមកខាងក្រោយ ទើបអាសនៈ មាន
ដល់ខ្ញុំព្រះអង្គ ។

[៣២] បទថា **យេនត្តេន** សេចក្តីថា ដោយប្រយោជន៍នៃវស្សូ-
បនាយិកាណា ។ បទថា **តំ អត្តំ ចិន្តយិត្វា** សេចក្តីថា គិតការរក្សាព្រះភិក្ខុ
សង្ឆដែលនៅព្រៃនោះ ហើយប្រឹក្សានឹងមហារាជទាំង ៤ ថា អ្នកទាំងឡាយ
ចូរចាត់ចែងរក្សាភិក្ខុសង្ឆដែលនៅក្នុងព្រៃនោះៗ ។ បទថា **វុត្តវចនាបិ តំ**
សេចក្តីថា ទេវបុត្រ ៣៣ អង្គ រមែងពោលចេញឈ្មោះថា មហារាជ ។
ទេវបុត្រ ៣៣ អង្គ រមែងហៅយ៉ាងនោះ ។ មហារាជក្រៅពីនេះ ក៏ប្រារព្ធ
ឈ្មោះបន្តបន្ទាប់ចុះមក ។ បទថា **តំ** ក្នុងបទទាំងពីរត្រឹមតែជានិបាតប៉ុណ្ណោះ ។
បទថា **អបក្ពន្ធា** សេចក្តីថា មិនចៀសចេញទៅ ។

[៣៣] បទថា **ទុជ្ឆារោ** គឺធំទូលំទូលាយ ។ បទថា **ជេវានុភាវំ**
សេចក្តីថា ពន្ធឺនៃសំពត់ គ្រឿងប្រដាប់ វិមាន និងសរីរៈរបស់ទេវតាទាំងពួង
រមែងផ្សាយទៅចម្ងាយ ១២ យោជន៍ ចំណែកពន្ធឺនៃសរីរៈរបស់ទេវតា អ្នក
មានបុណ្យច្រើន ផ្សាយទៅចម្ងាយ ១០០ យោជន៍ ឈានកន្ធងនូវទេវានុភាព
នោះ ។ បទថា **ព្រហ្មុនោ ហោតំ បុព្វនិមិត្តំ** សេចក្តីថា លោកសម្តែងថា ពន្ធឺ
អរុណជាបុព្វន្តមៈ ជាបុព្វនិមិត្តនៃព្រះអាទិត្យរះយ៉ាងណា នុ៉ះជាបុព្វនិមិត្ត
នៃព្រហ្ម ដូច្នោះដែរ ។

[៣៤] បទថា **អនភិសម្ភវនិយោ** សេចក្តីថា មិនគប្បីដល់ ។ សេចក្តី
ថា ពួកទេវតាជាន់តាវត្តិង្ស រមែងមិនឃើញព្រហ្មនោះ ។ បទថា **ចក្ខុបថស្មឹ**

សេចក្តីថា ក្នុងបសាទចក្ខុ ឬគន្ធងចក្ខុ ។ ពណ៌នោះ មិនគប្បីឃើញ ឬមិន គប្បីដល់ក្នុងគន្ធងចក្ខុរបស់ទេវតាទាំងឡាយ ។ បទថា **ធាភិភវតិ** សេចក្តីថា បានពោលហើយ ។ ពិតហើយ ទេវតាជាន់ទាប រមែងអាចឃើញអត្តភាព ដែលសាងយ៉ាងបរិបូណ៌របស់ទេវតាជាន់ខ្ពស់ៗ ។ បទថា **ឥធប្បដិលាភំ** សេចក្តីថា ត្រឡប់បានសេចក្តីត្រេកអរ ។ បទថា **អធុធាភិសិត្តោ រជ្ជេន** សេចក្តីថា ទ្រង់អភិសេកដោយសម្បត្តិ ។ ក៏អត្ថនេះ គប្បីសម្តែងរឿងទុដ្ឋ-គាមណីអភ័យ ។

បានញ្ចថា ព្រះបាទទុដ្ឋគាមណីអភ័យនោះ ទ្រង់ឈ្នះក្សត្រិយ៍ទមិឡដល់ ៣២ ព្រះអង្ត ទ្រង់អភិសេកក្នុងក្រុងអនុរាធបុរី ដោយព្រះហប្ចទ័យសោមនស្ស ត្រេកអរ តែមិនបានដេកលក់ ត្រាស់ប្រាប់ភិក្ខុសង្ឆថា បពិត្រលោកម្ចាស់ តាំងពីនោះមក ខ្ញុំមិនបានដេកលក់ឡើយ ។ ភិក្ខុសង្ឆទូលថា បពិត្រមហារាជ បើដូច្នោះ សូមព្រះអង្គទ្រង់អធិដ្ឋានឧបោសថសីលក្នុងថ្ងៃនេះ ព្រះអង្គក៏ទ្រង់ អធិដ្ឋានឧបោសថសីលហើយ ។ ព្រះសង្ឆបញ្ជូនភិក្ខុ ដែលរៀនព្រះអភិធម្ម ៨ រូបថា សូមលោកស្វាធ្យាយចិត្តយមក: ។ ភិក្ខុទាំងនោះទៅហើយ ទូលថា បពិត្រមហារាជ សូមទ្រង់ផ្ទំចុះ ហើយផ្តើមស្វាធ្យាយ ។ ព្រះរាជាទ្រង់ស្តាប់ ការស្វាធ្យាយ ក៏ទ្រង់ផ្ទំលក់ទៅ ។ ព្រះថេរ:ទាំងឡាយគិតថា កុំដាស់ព្រះរាជា ហើយចៀសទៅ ក្នុងថ្ងៃទីពីរ ព្រះរាជាទ្រង់តើនឡើង ពេលព្រះអាទិត្យឧទ័យ កាលទ្រង់មិនឃើញព្រះថេរ: ទើបត្រាស់សួរថា លោកម្ចាស់ទៅណា ។ ទ្រង់ បានទទួលពាក្យក្រាបទូលថា ព្រះថេរ:ដឹងថា ទ្រង់ផ្ទំលក់ហើយ ក៏និមន្តទៅ ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ រមែងដឹងភេសជ្ជ: គឺការដេកលក់ដរាបណា

ឈ្មោះថា កេសជ្ជៈ គឺសេចក្តីមិនជឿរបស់ក្មេងទាំងឡាយ រមែងមិនមានដល់លោកម្ចាស់របស់យើងដរាបនោះ ។

បទថា **បញ្ចសិខោ** *សេចក្តីថា ដូចគ្នានឹងបញ្ចសិខគន្ធព្វ ។ បានឮថា ពួកទេវបុត្រទាំងអស់ បាននិម្មិតអត្តភាពរបស់បញ្ចសិខគន្ធព្វទេវបុត្រ ព្រោះហេតុនោះ សូម្បីព្រហ្មក៏បាននិម្មិតអត្តភាពដូច្នោះ ឲ្យប្រាកដហើយដូចគ្នា ។ បទថា* **បល្លង្កេន និសីទិ** *សេចក្តីថា អង្គុយពត់ភ្នែន ។*

[๓๖] *បទថា* **វិសដ្ឋោ** *សេចក្តីថា ល្អិតទន់ល្អ គឺមិនរឹង ។ បទថា* **វិញ្ញេយ្យោ** *សេចក្តីថា ឲ្យដឹងប្រយោជន៍ ។ បទថា* **មញ្ជុ** *គឺផ្អែមល្ហែម ។ បទថា* **សវនីយោ** *គឺគួរស្តាប់ បានដល់ ពីរោះ ។ បទថា* **ពិន្ទុ** *សេចក្តីថា គ្រលួច ។ បទថា* **អវិសារី** *សេចក្តីថា ល្អស្អាតមិនគ្រាវ ។ បទថា* **គម្ភីរោ** *សេចក្តីថា ជ្រៅ កើតតាំងផ្ទិត មិនបានកើតប៉ះខ្ទប់ត្រឹមតែអណ្តាត ធ្មេញ បបូរមាត់ ឬពិតានឡើយ ព្រោះថា សំឡេងដែលកើតត្រឹមនេះ នឹងមិនទន់ភ្លន់ និងមិនឮទៅឆ្ងាយ ។ បទថា* **និដ្ឋានី** *សេចក្តីថា គឺកងជូចសំឡេងគំរាមរបស់មហាមេឃ និងសំឡេងសម្ភារ ។ មួយទៀត បទក្រោយៗ ក្នុងទីនេះ គប្បីជ្រាបថា ជាប្រយោជន៍នៃបទមុនៗ ។ បទថា* **យថាបរិសំ** *សេចក្តីថា ឲ្យបរិស័ទដឹងទូទៅ ។ សំឡេងនៃព្រហ្មនោះ រមែងតាំងនៅខាងក្នុងបរិស័ទប៉ុណ្ណោះ រមែងមិនឮចេញទៅខាងក្រៅ ។*

បទថា **យេ ហិ កេចិ** *ជាដើម សម្តែងបដិបទាដើម្បីប្រយោជន៍ដល់ជនច្រើន ។ បទថា* **សរណំ គតា** *សេចក្តីថា លោកមិនពោលសំដៅអ្នកដល់សរណៈតាមមានតាមបាន តែពោលសំដៅដល់សរណៈដែលមិនខុស ។ បទ*

ថា **គន្ធព្វកាយំ បរិបូរេតិ** សេចក្តីថា បន្ថែមគណៈនៃគន្ធព្វទេវតាឲ្យបរិបូណ៌ ។ លោកពោលថា ទេវលោក ៦ ជាន់ ចាប់ផ្តើមតាំងពីកាលដែលព្រះសាស្តារបស់ពួកយើង បានកើតឡើងក្នុងលោកហើយ ទេវតាកើតឡើងមិនមានចន្ទោះ ដូចនាឡិដែលពេញដោយម្សៅ និងដូចព្រៃកក់ ព្រៃបបុស ទើបឈ្មោះថា **មារិសា** ។

[៣៨] បទថា **យាវ សុប្បញ្ញត្តាបិ មេ តេន ភគវតា** សេចក្តីថា ព្រះមានព្រះភាគជាសាស្តានៃយើង ទ្រង់បញ្ញត្តល្អហើយ គឺត្រាស់ល្អហើយ ។ ក្នុងបទថា **ឥទ្ធិចាធា** នោះ គប្បីជ្រាបថា **ឥទ្ធិ** ដោយអត្ថថា សម្រេច គប្បីជ្រាបថា **ចាធ** ដោយអត្ថថា ជាទីតាំង ។ បទថា **ឥទ្ធិពហុលីកតាយ** សេចក្តីថា ព្រោះឥទ្ធិមានគ្រប់គ្រាន់ ។ បទថា **ឥទ្ធិវិសេវិតាយ** សេចក្តីថា ព្រោះមានឥទ្ធិជាពិសេស លោកពោលថា **ចិណ្ណវសិតាយ** ដោយអំណាចសេពរឿយៗ ។ បទថា **ឥទ្ធិវិកុព្វនតាយ** សេចក្តីថា ព្រោះការចម្រើនឥទ្ធិរឿយៗ ដើម្បីប្រយោជន៍ដែលនឹងសម្តែងធ្វើ ដោយប្រការផ្សេងៗ ។ ក្នុងបទថា **ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ** ជាដើម មានអត្ថដូច្នេះថា សមាធិដែលមានឆន្ទៈជាហេតុ ឬមានឆន្ទៈជាគោល ឈ្មោះថា ឆន្ទសមាធិ ។ បទថា **ឆន្ទសមាធិ** នោះ ជាឈ្មោះនៃសមាធិដែលបានមកព្រោះធ្វើឆន្ទៈ ដែលមានសេចក្តីប្រាថ្នានឹងធ្វើជាធំ ។ សង្ខារដែលជាបធាន ឈ្មោះថា បធានសង្ខារ ។ បទថា **បធានសង្ខារ** នោះ ជាឈ្មោះរបស់សម្មប្បធាន វីរិយៈដែលញ្ចុាំងកិច្ច ៤ ប្រការឲ្យសម្រេច ។ បទថា **សមន្នាគតំ** សេចក្តីថា ចូលដល់ហើយដោយឆន្ទសមាធិ និងបធានសង្ខារ ។ បទថា **ឥទ្ធិចាធំ** សេចក្តីថា កងនៃចិត្តដ៏សេស

សេស ឬចេតសិកជាបាទ ដោយអត្ថថា តាំងមាំនៃធនុសមាធិ និងបធាន-សង្ខារ ដែលប្រកបព្រមដោយអភិញ្ញាចិត្ត ដែលដល់នូវការរាប់ថា ឥទ្ធិ ដោយបរិយាយថា សម្រេច ឬដោយបរិយាយនេះថា ជាហេតុឲ្យសត្វទាំង-ឡាយសម្រេច ដោយអត្ថថា សម្រេច គឺជាអ្នកសម្រេចហើយ បរិបូណ៌ហើយ ដល់ទីបំផុតហើយ ។ ព្រោះបទថា **ឥជ្ឌិចាធ** លោកពោលថា វេទនា ខន្ធនៃសេចក្តីពិតណា ។បេ។ វិញ្ញាណក្ខន្ធ ។ គប្បីជ្រាបអត្ថក្នុងបទដ៏សេស ដោយន័យនេះ ។ ព្រោះសមាធិដែលធ្វើធនុ:ជាធំ ទើបបានមក លោកហៅថា ធនុសមាធិ យ៉ាងណា សមាធិដែលធ្វើវិរិយ: ចិត្ត វិមំសា ជាធំបានមក ហៅថា **វិមំសាសមាធិ** ដូច្នោះ ។

មួយទៀត គប្បីជ្រាបអត្ថក្នុងបទនេះថា **ចាធ** ក្នុងចំណែកខាងដើមថា ឧបចារជ្ឈានជាបាទ បឋមជ្ឈានជាឥទ្ធិ បឋមជ្ឈានជាបាទ ទុតិយជ្ឈានជាឥទ្ធិ ជាឥទ្ធិក្នុងចំណែកចុង ។ ឥទ្ធិបាទកថា លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ និងក្នុងវិភង្គអដ្ឋកថា ដោយពិស្តារ តែកេចិអាចារ្យពោលថា ឥទ្ធិដែលសម្រេចហើយ ជាឥទ្ធិដែលមិនទាន់សម្រេច ។ ដើម្បីប្រយោជន៍នៃការនិយាយដល់វាទ:នៃកេចិអាចារ្យពួកនោះ ឈ្មោះថា **ឧត្តរចូឡិកវារ** មកហើយក្នុងអភិ-ធម្មថា ឥទ្ធិបាទ ៤ គឺធនុិទ្ធិបាទ វិរិយិទ្ធិបាទ ចិត្តិទ្ធិបាទ វិមំសិទ្ធិបាទ ក្នុងឥទ្ធិបាទទាំង ៤ នោះ ធនុិទ្ធិបាទដូចម្តេច ភិក្ខុក្នុងសាសនានេះ ក្នុងសម័យណា ចម្រើនលោកុត្តរជ្ឈាន ដែលជាគ្រឿងចេញចាកទុក្ខ ដែលជាអបចយគាមី ដើម្បីលះទិដ្ឋិ ដើម្បីសម្រេចបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលដល់បឋមជ្ឈាន ដែលជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ធម្មធនុ:ណា

ឈ្មោះថា ឆន្ទៈ ព្រោះបានធ្វើឆន្ទៈហើយ ឈ្មោះថា កុសល ព្រោះប្រាថ្នានឹងធ្វើ នេះហៅថា ឆន្ទិទ្ធិបាទ ធម៌ដ៏សេសសម្បយុត្តដោយឆន្ទិទ្ធិបាទ ។ ធម៌ទាំងនេះ មកហើយដោយអំណាចនៃលោកុត្តរ ។

ក្នុងទីនេះ ព្រះរដ្ឋបាលត្រេរធ្វើឆន្ទៈឲ្យជាធុរៈ ញុំាងលោកុត្តរធម៌ឲ្យកើតឡើង ព្រះសោណត្ថេរធ្វើវិរិយៈឲ្យជាធុរៈ ព្រះសម្ភូតត្ថេរធ្វើចិត្តឲ្យជាធុរៈ ព្រះមោឃរាជដ៏មានអាយុធ្វើវិមំសាឲ្យជាធុរៈ ញុំាងលោកុត្តរធម៌ឲ្យកើតឡើង ។ ក្នុងសេចក្តីនេះ ឧបមាដូចបុត្រអមាត្យទាំង ៤ នាក់ ប្រាថ្នាឋានន្តរ ចូលទៅអាស្រ័យព្រះរាជា ម្នាក់កើតសេចក្តីពេញចិត្តក្នុងការទំនុកបម្រុងដ៏ងអធ្យាស្រ័យនិងសេចក្តីពេញព្រះទ័យរបស់ព្រះរាជា ចាំបម្រើទាំងពេលថ្ងៃ និងពេលយប់ ញុំាងព្រះរាជាឲ្យពេញព្រះរាជហឫទ័យ ហើយបានឋានន្តរ យ៉ាងណា គប្បីជ្រាបភិក្ខុដែលញុំាងលោកុត្តរធម៌ឲ្យកើតឡើង ដោយឆន្ទធុរៈ ដូច្នោះ ។ ចំណែកម្នាក់ទៀត គិតថា នរណានឹងអាច ដើម្បីទំនុកបម្រុងរាល់ៗ ថ្ងៃបាន កាលកិច្ចកើតឡើង អញនឹងញុំាងព្រះរាជាឲ្យពេញព្រះទ័យ ដោយសេចក្តីព្យាយាម កាលបច្ចន្តជនបទកើតចលាចល ត្រូវព្រះរាជាបញ្ជូនទៅបង្ក្រាបសត្រូវដោយសេចក្តីព្យាយាម បានឋានន្តរ យ៉ាងណា ភិក្ខុនោះ ឲ្យលោកុត្តរធម៌កើតឡើងដោយវិរិយធុរៈ គប្បីជ្រាបដូច្នោះ ។ ម្នាក់ទៀតគិតថា សូម្បីការទំនុកបម្រុងរាល់ៗ ថ្ងៃ ជាការៈធ្ងន់ ដូចកូនសរមុតត្រូវទ្រូង អញនឹងញុំាងព្រះរាជាឲ្យពេញព្រះទ័យ ដោយអំណាចមន្ត ទើបញុំាងព្រះរាជាឲ្យពេញព្រះហឫទ័យដោយការរាយមន្ត ព្រោះវិជ្ជាភូមិសាស្ត្របានសិក្សាមកហើយ ក៏ដល់ឋានន្តរ យ៉ាងណា ភិក្ខុនោះ ដែលញុំាងលោកុត្តរធម៌ឲ្យកើតឡើងដោយចិត្តធុរៈ គប្បី

ជ្រាប ដូច្នោះ ។ បុត្រអមាត្យម្នាក់ទៀតគិតថា ឈ្មោះថា ព្រះរាជា រមែង ព្រះរាជទានឋានន្តរ ដល់បុគ្គលដែលដល់ព្រមដោយជាតិ ដោយការទំនុក បម្រុងទាំងនេះជាដើម កាលទ្រង់ព្រះរាជទានដល់បុគ្គលបែបនោះ ទ្រង់នឹង ព្រះរាជទានដល់អញ អាស្រ័យជាតិសម្បទាតែម្យ៉ាង ក៏ដល់នូវឋានន្តរ យ៉ាង ណា ភិក្ខុនោះ អាស្រ័យវិមំសាដ៏បរិសុទ្ធ ញុំាងលោកុត្តរធម៌កើតឡើង ដោយ វិមំសាធុរៈ គប្បីជ្រាបដូច្នោះ ។ បទថា **អនេកវិហិតំ** *សេចក្តីថា វិធីមិន មែនមួយ ។ បទថា* **ឥទ្ធិំ** *សេចក្តីថា ចំណែករបស់ឥទ្ធិ ។*

[๓๙] *បទថា* **សុខសฺปาธิคมาย** *សេចក្តីថា ដើម្បីសម្រេច ដល់ឈានសុខ មគ្គសុខ និងផលសុខ ។*

[๔๐] *បទថា* **สំสเฏ្ឋา** *សេចក្តីថា ចិត្តសម្បយុត្ត ។ បទថា* **อริยธมฺมំ** *សេចក្តីថា ធម៌ដែលព្រះអរិយៈ ព្រះមានព្រះភាគ គឺព្រះពុទ្ធ ទ្រង់សម្តែងហើយ ។ បទថា* **สุฌาតิ** *សេចក្តីថា ធម៌ដែលភិក្ខុ និងភិក្ខុនី ជាដើម សម្តែងចំពោះព្រះភក្ត្រព្រះសាស្តា ឈ្មោះថា ស្តាប់ហើយ ។ បទថា* **โยนิโสมนสิกโรតิ** *សេចក្តីថា ធ្វើទុកក្នុងចិត្តដោយឧបាយ ដោយគន្ធង ដោយហេតុការណ៍ ដោយអំណាចមិនទៀងជាដើម ។ អធិប្បាយថា ភិក្ខុប្រា-រព្ធកម្ម ដោយការធ្វើទុកក្នុងចិត្តដោយប្រពៃ ដែលលោកពោលយ៉ាងនេះថា ឈ្មោះថា យោនិសោមនសិការ គឺការធ្វើទុកក្នុងចិត្តដោយឧបាយ ការធ្វើទុក ក្នុងចិត្តដោយគន្ធង ឬការរព្រឹក ការចង ការរួបរួមព្រមនៃចិត្ត ការធ្វើទុកក្នុង ចិត្តដោយអនុលោមសច្ចៈ ក្នុងសភាពមិនទៀង ថាមិនទៀង ក្នុងសភាពមិន ស្អាត ថាមិនស្អាត ក្នុងទុក្ខ ថាទុក្ខ ក្នុងភាពជាអនត្តា ថាជាអនត្តា នេះហៅថា*

យោនិសោមនសិការ ។ បទថា **អសំសដ្ឋោ** *សេចក្តីថា មិនច្រឡូកច្រឡំមួយ នឹងវត្ថុកាមខ្លះ កិលេសកាមខ្លះ ។ បទថា* **ឧបជ្ឈតិ សុខំ** *សេចក្តីថា បឋមជ្ឈាន សុខ រមែងកើតឡើង ។ បទថា* **សុខា ភិយ្យោ សោមនស្សំ** *សេចក្តីថា សោមនស្សដទៃៗ ព្រោះឈានសុខជាបច្ចយ រមែងកើតឡើងដល់អ្នកចេញចាកសមាបត្តិ ។ បទថា* **បមុទា** *គឺបីតិដែលមានកម្លាំងតិចជាងអាការរបស់តុដ្ឋី ។ បទថា* **ចាមោដ្ឋំ** *គឺបីតិ និងសោមនស្សដែលមានកម្លាំង ។ បទថា* **បឋមោ ឱកាសាធិគមោ** *សេចក្តីថា បឋមជ្ឈានគ្របសង្កត់នីវរណៈ ៥ កាន់យកឱកាសរបស់ខ្លួនហើយ តាំងនៅ ព្រោះដូច្នោះ ទើបលោកពោលថា* **បឋមោ ឱកាសាធិគមោ** *ប្រែថា ការបាននូវឱកាសជាបឋម ។*

[๔๑] *ក្នុងបទថា* **ឱឡារិកា** *នោះ កាយសង្ខារ និងវចីសង្ខារនៅគ្រោតគ្រោត សួរថា ចិត្តសង្ខារគ្រោតគ្រោតដូចម្តេច ឆ្លើយថា ព្រោះចិត្តសង្ខារមិនទាន់លះ ។ កាយសង្ខារ រមែងលះដោយចតុត្ថជ្ឈាន ។ វចីសង្ខារលះដោយទុតិយជ្ឈាន ។ ចិត្តសង្ខារលះដោយនិរោធសមាបត្តិ ។ កាលកាយ-សង្ខារ និងវចីសង្ខារលះហើយ ចិត្តសង្ខារទាំងឡាយនោះ ក៏តាំងនៅដោយប្រការដូច្នេះ ទើបជាឱឡារិកៈ ព្រោះលះមិនទាន់បាន ដោយប្រការនៃកាយ-សង្ខារ វចីសង្ខារ ដែលលះបានហើយ ។ បទថា* **សុខំ** *សេចក្តីថា ផលសមាបត្តិសុខ ដែលកើតពីចតុត្ថជ្ឈាន ដែលកើតដល់អ្នកចេញចាកនិរោធ ។ បទថា* **សុខា ភិយ្យោ សោមនស្សំ** *សេចក្តីថា សោមនស្សដទៃៗ មានដល់អ្នកចេញហើយអំពីផលសមាបត្តិ ។ បទថា* **ទុតិយោ ឱកាសាធិគមោ** *សេចក្តីថា ចតុត្ថជ្ឈានគ្របសង្កត់សុខទុក្ខ កាន់យកឱកាសខ្លួន ហើយតាំងនៅ*

ព្រោះដូច្នោះ ទើបលោកពោលថា **ឧតិយោ ឧកាសាធិគមោ ។** ចំណែកទុតិ-
យជ្ឈាន និងតតិយជ្ឈាន លោកកាន់យកហើយក្នុងចតុត្ថជ្ឈាននោះ ព្រោះ
ដូច្នោះ ទើបលោកមិនពោលឲ្យផ្សេងទៀត ។

[៤២] ក្នុងបទថា **ឥធំ កុសលំ** ជាដើម មានអធិប្បាយដូច្នេះថា
កុសលកម្មបថ ១០ ឈ្មោះថា កុសល ។ បទថា **អកុសលំ** បានដល់
អកុសលកម្មបថ ១០ ។ គ្រប់សាវជ្ជៈជាដើម គប្បីជ្រាបដោយអំណាចនៃ
អកុសលកម្មបថទាំង ១០ នោះឯង ។ កម្មទាំងអស់នោះឯង ជាកណ្ហៈ សុក្ក:
និងសប្បដិភាគ ទើបឈ្មោះថា **កណ្ហសុក្ពសប្បដិភាគំ ។** និញ្ចានប៉ុណ្ណោះ
ជាអប្បដិភាគ ។ បទថា **អវិជ្ជា បហិយតិ** សេចក្តីថា អវិជ្ជាដែលបិទបាំងវដ្ត:
រមែងលះបាន ។ បទថា **វិជ្ជា ឧប្បជ្ជតិ** សេចក្តីថា អរហត្តមគ្គវិជ្ជា រមែង
កើតឡើង ។ បទថា **សុខំ** គឺសុខដែលកើតពីអរហត្តមគ្គ និងផល ។ បទថា
សុខា ភិយ្យោ សោមនស្សំ សេចក្តីថា សោមនស្សដទៃៗ របស់បុគ្គល
ចេញចាកអំពីផលសមាបត្តិហើយ ។ បទថា **តតិយោ ឧកាសាធិគមោ**
សេចក្តីថា អរហត្តមគ្គគ្របសង្កត់កិលេសទាំងអស់ កាន់យកឱកាសខ្ជួនហើយ
តាំងនៅ ព្រោះដូច្នោះ ទើបលោកពោលថា **តតិយោ ឧកាសាធិគមោ ។**
ចំណែកមគ្គដ៏សេស កាលអរហត្តមគ្គកាន់យកហើយ ក៏ប្រមូលចូលគ្នាបាន
ទើបមិនពោលឲ្យផ្សេងគ្នា ។ ចំណែកឱកាសាធិគម: ៣ ប្រការនេះ គប្បី
ពោលយ៉ាងពិស្តារដោយអំណាចអារម្មណ៍ ៣៨ ប្រការ ។ សេចក្តីនេះដូចម្តេច ។
លោកកំណត់អារម្មណ៍ទាំងអស់ដោយអំណាចឧបចារ: និងអប្បនាដោយន័យ
ដែលពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ពោលដល់បឋមជ្ឈានក្នុងឋាន: ២៤

ប្រការថា **បឋមោ ឝិកាសាធិគមោ ។** លោកកំណត់ទុតិយជ្ឈាន និងតតិយជ្ឈានក្នុងហាន: ១៣ ប្រការ និងចតុត្ថជ្ឈានក្នុងហាន: ១៥ ប្រការ ឲ្យដល់និរោធសមាបត្តិពោលថា **ឧុតិយោ ឝិកាសាធិគមោ ។** ចំណែកឧបចារជ្ឈាន ១០ ប្រការ ជាបទដ្ឋាននៃមគ្គ រួមចូលនឹងឝិកាសាធិគមទី ៣ ។ ម្យ៉ាងទៀត គប្បីពោលដោយអំណាចសិក្ខាយ៉ាងនេះ ក្នុងសិក្ខា ៣ ប្រការ អធិសីលសិក្ខា រួមចូលជាមួយបឋមឝិកាសាធិគម: អធិចិត្តសិក្ខា រួមចូលជាមួយទុតិយឝិកាសាធិគម: អធិប្បញ្ញាសិក្ខា រួមចូលជាមួយតតិយឝិកាសាធិគម: ។ ក្នុងសាមញ្ញផល លោកពោលដោយអំណាចនៃសាមញ្ញផលសូត្រយ៉ាងនេះថា តាំងពីចូឡសីល ដរាបដល់បឋមជ្ឈាន ជាឝិកាសាធិគម:ទី ១ តាំងពីទុតិយជ្ឈាន ដរាបដល់នេវសញ្ញានាសញ្ញាយតន: ជាឝិកាសាធិគម:ទី ២ តាំងពីវិបស្សនា ដរាបដល់អរហត្ត ជាឝិកាសាធិគម:ទី ៣ ។ ចំណែកក្នុងបិដក ៣ ប្រការ គប្បីពោលដោយអំណាចបិដកយ៉ាងនេះថា វិនយបិដក សង្គ្រោះចូលជាមួយបឋមឝិកាសាធិគម: សុត្តន្តបិដកសង្គ្រោះចូលជាមួយទុតិយឝិកាសាធិគម: អភិធម្មបិដក សង្គ្រោះចូលជាមួយតតិយឝិកាសាធិគម: ។

បានឮថា ព្រះមហាថេរ:ក្នុងកាលមុន រមែងតាំងព្រះសូត្រនេះប៉ុណ្ណោះ ក្នុងថ្ងៃវិស្សូបនាយិកា ។ ព្រោះហេតុអ្វី ។ ព្រោះពួកយើងនឹងចែកបិដក ៣ ហើយពោល ។ ព្រោះកាលរួមព្រះត្រៃបិដក ហើយពោល ព្រះសូត្រក៏ពោលបានលំបាក ព្រោះដូច្នោះ បុគ្គលណាមួយ ក៏មិនអាចពោលបាន ។ សូត្រនេះដែលចែកព្រះត្រៃបិដក ហើយពោលក៏នឹងពោលបានងាយ ។

[๔๓] បទថា **កុសលស្សាធិគមាយ** សេចក្តីថា ដើម្បីប្រយោជន៍សម្រេចមគ្គកុសល និងផលកុសល ។ ពិតហើយ ទាំងពីរយ៉ាងនោះ ឈ្មោះ

ថា ជាកុសល ដោយអត្ថថា មិនមានទោស ឬដោយអត្ថថា ក្សេម ។ បទថា **តត្ត សម្មា សមាធិយតិ** *សេចក្តីថា ភិក្ខុតាំងមាំដោយប្រពៃក្នុងកាយខាងក្នុងនោះ ក៏នឹងជាឯកគ្គតាចិត្ត ។ បទថា* **ពហិទ្ធា បរកាយេ ញាណទស្សនំ អភិនិព្ភត្តេតិ** *សេចក្តីថា បញ្ឆេញញាណចំពោះកាយបុគ្គលដទៃ ក្រៅអំពីកាយខ្លួន ។ ក្នុងបទទាំងពួងក៏មាននយនេះ ។ គប្បីជ្រាបសតិ ដែលកំណត់កាយជាដើម ដោយបទថា* **សតិមា** *ក្នុងបទទាំងពួង ។ គប្បីជ្រាបកាយជាដើមដែលកំណត់ហើយ ដោយបទថា* **លោកេ** *សតិប្បដ្ឋាន ៤ នោះ គប្បីជ្រាបថា លោកពោលលាយដោយលោកិយ និងលោកុត្តរ ។*

[๔๔-๔๖] *បរិក្ខារ ក្នុងបទថា* **សមាធិបរិក្ខារា** *មានអត្ថ ៣ យ៉ាង គឺគ្រឿងប្រដាប់ ១ បរិវារ ១ សម្ភារៈ ១ បរិក្ខារមកក្នុងអត្ថថា គ្រឿងប្រដាប់ ដូចក្នុងប្រយោគជាដើមថា* **រថោ សីលបរិក្ខារោ ឈានក្ខោ ចក្កវីរិយោ** *រថគឺអរិយមគ្គ (នោះ) មានសីលជាគ្រឿងពាស មានឈានជាក្ប៉ៅ មានវីរិយៈជាកង់ ។ មកក្នុងអត្ថថា បរិវារ ដូចក្នុងប្រយោគជាដើមថា* **សត្តហិ ឆគរ-បរិក្ខារេហិ សុបរិក្ខតំ ហោតិ** *នគរនៃស្តេច ជាទីបំផុតនៃដែនដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាង ។ មកក្នុងអត្ថថា សម្ភារៈ ដូចក្នុងប្រយោគជាដើមថា* **តិលាឆប្បច្ចុយជីវិតបរិក្ខារោ** *គ្រឿងបរិក្ខារជាទីរក្សាទុកជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺណា ។ ក្នុងទីនេះ លោកពោលថា សមាធិ-បរិក្ខារ ៧ ប្រការ ដោយអំណាចបរិវារ និងបរិក្ខារ ។* **បរិវារិក** *ឈ្មោះថា បរិក្ខារ ។ បទថា* **អយំ វុច្ចតិ ភោ អរិយោ សម្មាសមាធិ** *សេចក្តីថា នេះហៅថា សម្មាសមាធិដ៏ប្រសើរ ដែលចោមរោមដោយអង្គ ៧ ដូចចក្រពត្តិ ចោម*

ភេមដោយវគ្គនេះ ๗ ប្រការ ដូច្នោះ ។ បទថា **សឧបនិសោ ឥតិបិ** *សេចក្តីថា លោកហៅថា សឧបនិសស្រ័យ ដោយប្រការនេះ ។ បទថា* **សបរិវារោ យេវ** *បាននោលហើយ ។ បទថា* **សម្មាទិដ្ឋិស្ស** *សេចក្តីថា បុគ្គលតាំងនៅក្នុងសម្មាទិដ្ឋិ ។ បទថា* **សម្មាសង្កប្បោ បហោតិ** *សេចក្តីថា សម្មាសង្កប្បរមែងប្រព្រឹត្តទៅ ។ ក្នុងបទទាំងពួងក៏មានន័យដូចគ្នា ។ អត្ថនេះគប្បីជ្រាបដោយអំណាចមគ្គខ្លះ ដោយអំណាចផលខ្លះ ។ ជ្រាបដូចម្តេច ។ មគ្គសម្មាសង្កប្ប រមែងមានដល់កិក្ខុដែលតាំងនៅក្នុងមគ្គសម្មាទិដ្ឋិ ។បេ។ និងមគ្គវិមុត្តិ រមែងមានដល់កិក្ខុដែលតាំងនៅក្នុងមគ្គញ្ញាណ ម៉្យាងទៀត ផលសម្មាសង្កប្ប រមែងមានដល់កិក្ខុដែលតាំងនៅក្នុងផលសម្មាទិដ្ឋិ ។បេ។ និងផលវិមុត្តិ រមែងមានដល់កិក្ខុដែលតាំងនៅក្នុងផលសម្មាញ្ញាណ ។ បទថា* **ស្វាក្ខាតោ** *ជាដើម លោកពណ៌នាហើយ ក្នុងវិសុទ្ធិមគ្គ ។ បទថា* **អចារុតា** *សេចក្តីថា បើកហើយ ។ បទថា* **អមតស្ស** *សេចក្តីថា និព្វាន ។ បទថា* **ទ្វារា** *សេចក្តីថា ផ្លូវចូល ។ បទថា* **អវេច្ចប្បសាទេន** *សេចក្តីថា សេចក្តីជ្រះថ្លាមិនកម្រើក ។ បទថា* **ធម្មេ វិនីតា** *សេចក្តីថា ពិតប្រាកដហើយដោយធម្មនិយាម ។ បទថា* **អថាយំ ឥតរា បជា** *សេចក្តីថា លោកពោលសំដៅដល់ព្រះអនាគាមី ។ បទថា* **អនាគាមិនោ អត្តិ** *លោកពោលហើយ ។ បទថា* **បុញ្ញភាគា** *សេចក្តីថា កើតហើយដោយចំណែកនៃបុណ្យ ។ បទថា* **ខិត្តប្បំ** *សេចក្តីថា មានចិត្តខ្វាច ។ បើដូច្នោះ មុសា គប្បីមានក្នុងកាលណា ព្រោះដូច្នោះ ខ្ញុំមិនអាចរាប់ដោយមុសាវាទភ័យបាន តែមិនបានសម្តែងថា កម្ចាំងរាប់របស់ខ្ញុំមិនមាន ។ សន្តិមារព្រហ្ម សាកសួរវេស្សវណ ដោយបទនេះថា* **តំ កិំ**

មញ្ញតិ ភវំ ។ តែសនង្កុមារព្រហ្មនោះ មិនមានលទ្ធិថា ព្រះសាស្តាដូចនោះ មិនមានហើយ ឬនឹងមិនមាន ។ ពិតហើយ ក្នុងអភិសម័យរបស់ព្រះពុទ្ធ ទាំងឡាយ មិនមានពិសេស ។

បទថា **សាយំ បរិសាយំ** សេចក្តីថា ក្នុងបរិស័ទរបស់ខ្ជូន ។ បទថា **តយិធំ ព្រហ្មចរិយំ** សេចក្តីថា ត្រៃសិក្ខាទាំងអស់នេះ គឺព្រហ្មចារ្យ ។ បទ ដ៏សេសមានអត្ថងាយយល់ហើយ ។ ចំណែកបទទាំងនេះ ដែលព្រះធម្ម-សង្គាហកត្ថេរទាំងឡាយ បានតាំងហើយ ដូច្នេះ ។ អដ្ឋកថា ជនវសភសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ។

ជនវសភសូត្រ ចប់

សូត្រធី ៥ ចប់

สุตฺตนฺตปิฎก

มหาគោវិន្ទសូត្រទី ๖

[๔๗] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង បញ្ចសិខគន្ធព្វបុត្រ កាលរាត្រីកន្លងទៅហើយ (កន្លងបឋមយាម) បញ្ចេញរស្មីភ្លឺច្រាល ញុំាងភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺស្វាងហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះបញ្ចសិខគន្ធព្វបុត្រ ឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលព្រះមានព្រះភាគ នូវសេចក្តីដែលខ្ញុំព្រះអង្គ បានស្តាប់ក្នុងទីចំពោះមុខ បានទទួលក្នុងទីចំពោះមុខ នៃពួកទេវតាជាន់តាវត្តិង្ស ។ ព្រះមានព្រះភាគបានត្រាស់ថា ម្នាលបញ្ចសិខៈ អ្នកចូរប្រាប់តថាគតចុះ ។ បញ្ចសិខគន្ធព្វបុត្រ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃមុនៗ ក្នុងតិថីទី ១៥ ដែលជាថ្ងៃឧបោសថ ត្រូវនឹងថ្ងៃបវារណា ក្នុងរាត្រីមានព្រះចន្ទពេញវង់ ពួកទេវតាជាន់តាវត្តិង្សទាំងអស់ កំពុងអង្គុយប្រជុំក្នុងទេវសភាឈ្មោះសុធម្មា ទាំងទេព-បរិសទ្យជាច្រើន ក៏អង្គុយនៅជុំវិញ ឯមហារាជទាំង ៤ អង្គ ក៏គង់ក្នុងទិសទាំង ៤ គឺធតរដ្ឋមហារាជ គង់ក្នុងទិសខាងកើត បែរព្រះភក្ត្រទៅទិសខាងលិច មានពួកទេវតាចោមរោមត្រៀបត្រា វិរូឡ្ហកមហារាជ គង់ក្នុងទិសខាងត្បូង បែរព្រះភក្ត្រទៅទិសខាងជើង មានពួកទេវតាចោមរោមត្រៀបត្រា វិរូបក្ខមហារាជ

គង់ក្នុងទិសខាងលិច បែរព្រះកក្ត្រទៅទិសខាងកើត មានពួកទេវតាចោមរោមត្រៀបត្រា វេស្សវណមហារាជ គង់ក្នុងទិសខាងជើង បែរព្រះកក្ត្រទៅទិសខាងត្បូង មានពួកទេវតាចោមរោមត្រៀបត្រា បពិត្រព្រះអង្គដ៏ចម្រើន កាលណាពួកទេវតា ជាន់តាវត្តិង្សទាំងអស់គ្នា អង្គុយប្រជុំក្នុងទេវសភា ឈ្មោះសុធម្មា ទាំងទេវបរិស័ទជាច្រើនអង្គុយនៅជុំវិញ ឯមហារាជទាំង ៤ ក៏គង់ក្នុងទិសទាំង ៤ នេះ ជាអាសនៈរបស់មហារាជទាំង ៤ នោះ ក្នុងកាលនោះ អាសនៈរបស់ពួកយើងខ្ញុំនៅខាងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណា បានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយមកកើតឋានក្នុងជាន់តាវត្តិង្ស ពួកទេវតាទាំងនោះ ក៏រុងរឿង កន្ទងនូវពួកទេវតាឯទៀត ដោយសម្បុរផង ដោយយសផង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជាពួកទេវតាជាន់តាវត្តិង្ស មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សថា អើហ្ន៎ ពួកកាយទិព្វនៅពេញត្រៀបត្រា ពួកអសុរកាយបាត់ទៅអស់ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង សក្ករាជជាធំជាងពួកទេវតាជ្រាបនូវសេចក្តីជ្រះថ្លា របស់ពួកទេវតាជាន់តាវត្តិង្សហើយ ក៏បានអនុមោទនា ដោយគាថាទាំងឡាយនេះថា

[๔๘] អើហ្ន៎ ពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ រីករាយ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ជាធម៌ដ៏ល្អផង ។ ពួកទេវតាជាន់តាវត្តិង្ស ក៏បានឃើញពួកទេវតាថ្មីៗ មានសម្បុរ មានយស ដែលបានប្រព្រឹត្តព្រហ្ម-

ចរិយធម៌ ក្នុងសំណាក់នៃព្រះសុគត ហើយមកកើតក្នុងទេវលោកនេះ ។ ពួកទេវតាទាំងនោះ រុងរឿងកន្ទឹងនូវពួកទេវតាឯទៀត ដោយសម្បុរ ដោយយស និងអាយុ ពួកសាវ័ករបស់ព្រះសម្ពុទ្ធ ព្រះអង្គមានព្រះប្រាជ្ញាដូចជាផែនដី ជាសាវ័កដល់នូវសេចក្តីវិសេស ក្នុងទេវលោកនេះ ។ ពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ លុះឃើញហេតុនេះហើយ ក៏ត្រេកអរ បាននមស្ការចំពោះព្រះតថាគតផង ចំពោះធម៌ដែលជាធម៌ដ៏ល្អផង ។

[๔๙] *បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជាពួកទេវតាជាន់តាវត្តិង្ស មានចិត្តត្រេកអររីករាយ កើតបីតិសោមនស្ស ដោយក្រៃលែង លើសប្រមាណថា អើហ្ន៎ ពួកកាយទិព្វ នៅពេញត្រៀបត្រា ពួកអសុរកាយបាត់ទៅអស់ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា ជ្រាបនូវសេចក្តីជ្រះថ្លា របស់ពួកទេវតាជាន់តាវត្តិង្សហើយ ទើបមានព្រះបន្ទូលនឹងពួកទេវតាជាន់តាវត្តិង្សថា ម្នាលគ្នាយើង អ្នកទាំងឡាយចង់ស្តាប់គុណជារបស់ពិត ๘ ប្រការរបស់ព្រះមានព្រះភាគនោះដែរឬ ។ ពួកទេវតាក្រាបទូលថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ យើងខ្ញុំចង់ស្តាប់គុណ ជារបស់ពិត ๘ ប្រការ របស់ព្រះមានព្រះភាគនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា បានសម្តែងគុណជារបស់ពិត ๘ ប្រការ របស់ព្រះមានព្រះភាគ ដល់ពួកទេវតាជាន់តាវត្តិង្សថា ម្នាលអ្នកដ៏*

ចម្រើនទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស សម្គាល់ហេតុនោះដូចម្តេច ព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំង-ឡាយរហូតមក ។ យើងពិចារណាឃើញនូវគ្រូដែលជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយយ៉ាងនេះ ជាអ្នកប្រកបដោយគុណានេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ១) ។ ធម៌ដែលព្រះមានព្រះភាគអង្គនោះ ត្រាស់សម្តែងហើយដោយល្អ ជាធម៌ដែលអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌ដែលអរិយបុគ្គល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងចិត្តបាន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ។ យើងពិចារណាឃើញនូវគ្រូដែលជាអ្នកសម្តែងនូវធម៌ គួរបង្អោនចូលមកទុកក្នុងចិត្តបានយ៉ាងនេះ ជាអ្នកប្រកបដោយគុណានេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ២) ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្ត

ដោយប្រពៃហើយថា នេះជាកុសល ទ្រង់បញ្ញត្តហើយដោយប្រពៃថា នេះជាអកុសល ។ នេះប្រកបដោយទោស ។ នេះមិនប្រកបដោយទោស ។ នេះគួរសេព ។ នេះមិនគួរសេព ។ នេះជាអំពើថោកទាប ។ នេះជាអំពើថ្លៃថ្នូ ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តដោយប្រពៃហើយថា នេះធម៌ខ្មៅ ធម៌ស និងធម៌ជាសប្បដិភាគ (លាយខ្មៅលាយស) ។ យើងពិចារណារកមើលនូវគ្រូ ដែលជាអ្នកបញ្ញត្តនូវធម៌ទាំងឡាយ ដែលជាកុសល ជាអកុសល ប្រកបដោយទោស មិនប្រកបដោយទោស គួរសេព និងមិនគួរសេព ថោកទាប និងថ្លៃថ្នូ ធម៌ខ្មៅ ធម៌ស និងសប្បដិភាគយ៉ាងនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ៣) ។ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះទ្រង់បញ្ញត្តល្អហើយ ដល់សាវ័កទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា ក៏ប្រៀបធៀបគ្នាបាន ។ ទឹកក្នុងទន្លេគង្គា ប្រៀបស្មើនឹងទឹកក្នុងទន្លេយមុនា ដូចម្តេចមិញ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះទ្រង់បញ្ញត្តល្អហើយ ដល់សាវ័កទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា ក៏ប្រៀបធៀបគ្នាបានដូច្នោះដែរ ។ យើងពិចារណារកមើលនូវគ្រូ ជាអ្នកបញ្ញត្តនូវបដិបទា ជាទីទៅកាន់ព្រះនិព្វានយ៉ាងនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះ ចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី

๔) ฯ ព្រះមានព្រះភាគអង្គនោះ ទ្រង់បានពួកសេក្ខបុគ្គល ដែលឋិតនៅក្នុង បដិបទាហើយ និងពួកព្រះខីណាស្រព ដែលមានព្រហ្មចរិយធម៌អប់រំស្រេច ហើយជាគ្នីគ្នា តែព្រះមានព្រះភាគ ទ្រង់មិនជាប់ព្រះទ័យនឹងគ្នីគ្នានោះទេ ទ្រង់ ប្រកបនូវសេចក្តីត្រេកអរតែមួយព្រះអង្គឯង ฯ យើងពិចារណារកមើលនូវ គ្រូ ជាអ្នកប្រកបនូវសេចក្តីត្រេកអរ តែម្នាក់ឯងយ៉ាងនេះ ដែលជាអ្នកប្រកប ដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ ក៏មិនឃើញមាន ក្នុង កាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមាន ដែរ (នេះជាគុណទី ๕) ฯ លាភសម្រេចហើយ សេចក្តីសរសើរក៏ សម្រេចហើយដល់ព្រះមានព្រះភាគអង្គនោះ ទាំងពួកក្សត្រិយ៍ក៏មានសភាព ជាអ្នកស្រឡាញ់ រាប់រក (ព្រះអង្គ) ប៉ុន្តែព្រះមានព្រះភាគអង្គនោះ ប្រាស ចាកសេចក្តីស្រេវឹង (ក្នុងលាភជាដើមនោះ) ហើយរមែងសោយនូវអាហារ (តាមធម្មតា) ฯ យើងពិចារណារកមើលនូវគ្រូ ជាអ្នកប្រាសចាកសេចក្តី ស្រេវឹង បរិភោគនូវអាហារយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែក កាលដែលកន្លងទៅហើយ ក៏មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះ មានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ๖) ฯ ព្រះមានព្រះភាគនោះទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាង ណា ទ្រង់ត្រាស់យ៉ាងនោះ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើ យ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ដោយប្រការយ៉ាងនេះ ឯង ฯ យើងពិចារណារកមើលនូវគ្រូ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់

ធម៌យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅ ហើយ ក៏មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះ ចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ៧) ។ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ឆ្ងល់ផុតសេចក្តីសង្ស័យអស់ហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ទ្រង់មានព្រះតម្រិះដល់ទីបំផុតហើយ ដោយព្រហ្មចរិយធម៌ ខាងដើម ជានិស្ស័យដ៏ឧត្តម ។ យើងពិចារណារកមើលនូវគ្រូ ជាអ្នកឆ្ងល់ផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ មានតម្រិះដល់ទីបំផុត ដោយព្រហ្មចរិយធម៌ខាងដើម ជានិស្ស័យដ៏ឧត្តមយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយក៏មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ៨) ។ បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជ ជាធំជាងពួកទេវតា បានសម្តែងគុណជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគនេះឯង ដល់ពួកទេវតាជាន់តាវត្តិង្ស ។

[៥០] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជាពួកទេវតាជាន់តាវត្តិង្ស ជាអ្នកមានចិត្តត្រេកអរ មានចិត្តទន់ កើតបីតិសោមនស្សដ៏ក្រៃលែងលើសប្រមាណ ព្រោះបានស្តាប់គុណ ជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាទេវតាទាំងនោះ ទេវតាពួកខ្លះ នាំគ្នាពោលយ៉ាងនេះថា ម្នាលគ្នាយើង ធ្វើម្តេចហ្ន៎ បានព្រះសម្មាសម្ពុទ្ធ ๔ ព្រះអង្គគ្រាស់ឡើងក្នុងលោក សម្តែងធម៌ឲ្យជួបព្រះមានព្រះ

ภาค ការសម្តែងធម៌នោះសមជាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំង-ឡាយ ។ ទេវតាពួកខ្លះ នាំគ្នាពោលយ៉ាងនេះថា នែពួកយើង ព្រះសម្មា-សម្ពុទ្ធ ๔ ព្រះអង្គលើកទុកសិនចុះ នែពួកយើង ធ្វើម្តេចហ្ន៎ ឲ្យតែព្រះសម្មាសម្ពុទ្ធ ๓ ព្រះអង្គត្រាស់ឡើងក្នុងលោក សម្តែងធម៌ឲ្យដូចព្រះមានព្រះភាគ ការណ៍នោះសមជាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ទេវតាពួកខ្លះ នាំគ្នាពោលយ៉ាងនេះថា នែគ្នាយើង ព្រះសម្មាសម្ពុទ្ធ ๓ ព្រះអង្គលើកទុកសិនចុះ នែគ្នាយើង ធ្វើម្តេចហ្ន៎ ឲ្យតែព្រះសម្មាសម្ពុទ្ធ ๒ ព្រះអង្គត្រាស់ឡើងក្នុងលោក សម្តែងធម៌ឲ្យដូចព្រះមានព្រះភាគ ការណ៍នោះសមជាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលពួកទេវតាពោលយ៉ាងនេះហើយ សក្កទេវរាជជាធំជាងពួកទេវតា បានពោលពាក្យនេះ នឹងពួកទេវតាជាន់តាវត្តិង្សថា ម្នាលគ្នាយើង ដំណើរនេះមិនមែនជាហេតុ មិនមែនជាឱកាសឡើយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ๒ ព្រះអង្គ បានត្រាស់ក្នុងលោកធាតុតែមួយ ដំណាលគ្នាដោយ

ហេតុណា ហេតុនោះមិនដែលមានទេ ម្នាលគ្នាយើង សូមឲ្យតែព្រះមានព្រះ ភាគអង្គនោះ កុំឲ្យមានអាពាធ កុំឲ្យមានទុក្ខ គង់នៅអស់កាលដ៏យូរអង្វែង ការណ៍នោះ គង់តែប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយដែរ ហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ពួកទេវតាជាន់តាវត្តិង្ស អង្គុយប្រជុំគ្នាក្នុងទេវសភា ឈ្មោះសុធម្មា ដោយប្រយោជន៍ណា មហារាជទាំង ៤ អង្គនោះ ក៏គិតនូវប្រយោជន៍នោះ ប្រឹក្សានូវប្រយោជន៍នោះ ហើយតាំងនៅក្នុងប្រយោជន៍នោះ តាមពាក្យដែលតាវត្តិង្សទេវតាប្រាប់ហើយផង មហារាជទាំង ៤ អង្គនោះ តម្កល់នៅក្នុងប្រយោជន៍នោះ តាមពាក្យដែលតាវត្តិង្សទេវតា ប្រៀនប្រដៅហើយផង ឋិតនៅលើអាសនៈរបស់ខ្លួនៗ មិនចៀសចេញទៅឡើយ ។

[៥១] *ព្រះរាជាទាំងនោះ ទទួលពាក្យប្រៀនប្រដៅ តាមពាក្យដែលតាវត្តិង្សទេវតា ប្រាប់ហើយ ក៏មានចិត្តជ្រះថ្លា មានចិត្តស្ងប់រម្ងាប់ ឋិតនៅ លើអាសនៈរបស់ខ្លួន ។*

[៥២] *បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ពន្លឺដ៏លើសលុបក៏កើតឡើង រស្មីដ៏រុងរឿងលើសលែងនូវទេវានុភាពរបស់ពួកទេវតា ក៏កើតប្រាកដឡើងក្នុងទិសទាំងពួង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សក្កទេវរាជជាធំជាងពួកទេវតា មានព្រះបន្ទូលនឹងពួកទេវតាជាន់តាវត្តិង្សថា ម្នាលពួក*

យើង និមិត្តទាំងឡាយប្រាកដឡើង ពន្លឺកើតឡើង រស្មីដ៏រុងរឿងកើតប្រាកដ ក្នុងកាលណា ព្រហ្មនឹងមានប្រាកដក្នុងកាលនោះ នេះជាបុព្វនិមិត្ត ដែលព្រហ្មមានប្រាកដ បានជាពន្លឺកើតឡើង រស្មីកើតឡើងជាក់ស្តែង ។

[៥៣] *និមិត្តទាំងឡាយប្រាកដឡើង ក្នុងកាលណា ព្រហ្មគង់មានប្រាកដ (ក្នុងកាលនោះ) រស្មីដ៏រុងរឿង ធំទូលាយ នេះឯង ជាបុព្វនិមិត្តរបស់ព្រហ្ម ។*

[៥៤] *បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកទេវតាជាន់តាវត្តិង្ស អង្គុយលើអាសនៈទាំងឡាយតាមសមគួរដល់ខ្លួន ហើយគិតគ្នាថា វិបាកនឹងមានប្រាកដ ព្រោះអាស្រ័យនូវពន្លឺណា យើងទាំងឡាយ ចាំដឹងនូវពន្លឺនុ៎ះ ចាំធ្វើឲ្យច្បាស់នូវពន្លឺនោះសិនហើយសឹមទៅ ។ ចំណែកមហារាជទាំង ៤ អង្គ គង់លើអាសនៈទាំងឡាយតាមសមគួរដល់ខ្លួន គិតគ្នាថា វិបាកនឹងមានប្រាកដ ព្រោះអាស្រ័យពន្លឺណា យើងទាំងឡាយ ចាំដឹងនូវពន្លឺនោះ ចាំធ្វើឲ្យច្បាស់នូវពន្លឺនោះសិនហើយសឹមទៅ ។ ពួកទេវតាជាន់តាវត្តិង្ស លុះឮពាក្យនេះហើយ ក៏មានចិត្តមូលតែមួយ ប្រជុំគ្នាគិតថា វិបាកនឹងមានប្រាកដ ព្រោះអាស្រ័យពន្លឺណា យើងទាំងឡាយចាំដឹងនូវពន្លឺនោះ ចាំធ្វើឲ្យច្បាស់នូវពន្លឺនោះសិនហើយសឹមទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលណា សនង្កុមារ-ព្រហ្ម មានប្រាកដដល់ពួកទេវតាជាន់តាវត្តិង្សហើយ និមិត្តអត្តភាព ដ៏លើសលុបឲ្យកើតប្រាកដ ។ បពិត្រព្រះអង្គដ៏ចម្រើន សម្បុរជាប្រក្រតី របស់ព្រហ្មណា ដែលពួកទេវតាមិនទាន់ឃើញ សម្បុរជាប្រក្រតីនោះ (ក៏ប្រាកដ)*

ក្នុងគន្ធង់ចក្ខុរបស់ពួកទេវតាជាន់តាវត្តិង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន កាលណាសនង្កុមារព្រហ្មមានប្រាកដ ដល់ពួកទេវតាជាន់តាវត្តិង្ស ព្រហ្មនោះ ក៏រុងរឿងកន្ធង់នូវពួកទេវតាឯទៀត ដោយសម្បុរផង ដោយយសផង ។ បពិត្រព្រះអង្គដ៏ចម្រើន រូបដែលធ្វើដោយមាស រមែងរុងរឿងកន្ធង់នូវរាងកាយរបស់មនុស្សដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន កាលណា សនង្កុមារ-ព្រហ្មមានប្រាកដ ដល់ពួកទេវតាជាន់តាវត្តិង្ស ព្រហ្មនោះ ក៏រុងរឿងកន្ធង់នូវពួកទេវតាឯទៀត ដោយសម្បុរផង ដោយយសផង ដូច្នោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលណា សនង្កុមារព្រហ្ម មានប្រាកដដល់ពួកទេវតាជាន់តាវត្តិង្ស មិនមានទេវតាណាមួយក្នុងបរិសទ្យនោះសំពះ ឬក្រោកទទួល ឬក៏អញ្ជើញដោយអាសនៈទេ ។ ពួកទេវតាទាំងអស់ស្ងៀម ព្រងើយ នាំគ្នាអង្គុយផ្គងអញ្ជលីលើបល្ល័ង្ក គិតគ្នាថា ឥទ្ធរនេះ សនង្កុមារព្រហ្ម ប្រថ្នាន៏ងគង់លើបល្ល័ង្ករបស់ទេវតាណា ក៏គង់លើបល្ល័ង្ករបស់ទេវតានោះចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មគង់លើបល្ល័ង្ករបស់ទេវតាណា ទេវតានោះ ក៏បាននូវសេចក្តីត្រេកអរដ៏លើសលុប ទេវតានោះ ក៏បាននូវសេចក្តីរីករាយចិត្តដ៏លើសលុប ។ បពិត្រព្រះអង្គដ៏ចម្រើន ក្សត្រជាស្តេចដែលបានមុទ្ធា-អភិសេកហើយ អភិសេកហើយថ្មីៗ ដោយរាជសម្បត្តិ ព្រះរាជានោះតែង បាននូវសេចក្តីត្រេកអរដ៏លើសលុប ព្រះរាជានោះតែងបាននូវសេចក្តីរីករាយព្រះទ័យដ៏លើសលុប ដោយរាជសម្បត្តិ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម គង់លើបល្ល័ង្ករបស់ទេវតាណា ទេវតានោះ

ក៏បាននូវសេចក្តីត្រេកអរដ៏លើសលុប ទេវតានោះ ក៏បាននូវសេចក្តីរីករាយចិត្តដ៏លើសលុប មានឧបមេយ្យដូច្នោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលនោះ សនង្កុមារព្រហ្មដ៏ចំនូវសេចក្តីជ្រះថ្លា របស់ពួកទេវតាជាន់តាវត្តិង្ស ហើយ ក៏អនុមោទនាដោយគាថាទាំងនេះ ហើយក៏បាត់ទៅ ។

[៥៥] អើហ្ន៎ ពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ រមែងរីករាយ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង ។ ពួកទេវតាជាន់តាវត្តិង្ស បានឃើញពួកទេវតាថ្មីៗ មានសម្បុរ មានយស ដែលបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះសុគត ហើយមកកើតក្នុងទេវលោកនេះ ។ ពួកទេវតាទាំងនោះ រុងរឿងកន្ទ្រឹងនូវពួកទេវតាឯទៀត ដោយសម្បុរ ដោយយស និងអាយុ ពួកសាវ័ករបស់ព្រះសម្ពុទ្ធ ព្រះអង្គមានព្រះបាជ្ញាដូចផែនដី សាវ័កដល់នូវសេចក្តីវិសេសក្នុងទេវលោកនេះ ។ លុះពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ឃើញហេតុនេះហើយ ទើបរីករាយ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ជាធម៌ដ៏ល្អផង ។

[៥៦] បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលសនង្កុមារព្រហ្មពោលនូវសេចក្តីនេះ ក៏មានសំឡេងប្រកបដោយអង្គ ៨ គឺសំឡេងក្បោះក្បាយ ๑

ងាយយល់ ๑ ទន់ពីរោះ ๑ គួរស្តាប់ ๑ មូល ๑ មិនគ្រាវ ๑ ក្រអួន ๑ លាន់រំពង ๑ ។ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មញ្ជាំងបរិសទ្យទាំង អស់ឲ្យដឹងច្បាស់ដោយសំឡេងផង សំឡេងក្រាងក្រអៅរបស់ព្រហ្មនោះ មិន បានផ្សាយចេញទៅខាងក្រៅបរិសទ្យផង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គល ណា មានសំឡេងប្រកបដោយអង្គ ៨ យ៉ាងនេះ បុគ្គលនោះគេហៅថា អ្នក មានសំឡេងដូចសំឡេងព្រហ្ម ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួក ទេវតាជាន់តាវត្តិង្ស បានពោលពាក្យនេះនឹងសនង្កុមារព្រហ្មថា បពិត្រមហា-ព្រហ្ម ប្រពៃហើយ ពួកយើងក៏រីករាយ ព្រោះបានដឹងសេចក្តីនោះឯង មួយ ទៀត សក្កទេវរាជជាធំជាងពួកទេវតា បានសម្តែងគុណ ជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគនោះហើយដែរ ពួកយើងក៏រីករាយ ព្រោះបាន ដឹងនូវគុណទាំងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង សនង្កុមារព្រហ្ម បានពោលសេចក្តីនេះនឹងសក្កទេវរាជ ជាធំជាងពួកទេវតាថា បពិត្រទេវានមិន្ទៈ ប្រពៃហើយ ពួកយើងគួរស្តាប់នូវគុណ ជារបស់ពិតទាំង ៨ ប្រការ របស់ ព្រះមានព្រះភាគនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជ ជាធំជាងពួក ទេវតា ទទួលតបពាក្យរបស់សនង្កុមារព្រហ្មថា បពិត្រមហាព្រហ្ម យ៉ាងហ្នឹង ហើយ ទើបថ្លែងនូវគុណជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគ ថា មហាព្រហ្មដ៏ចម្រើន សម្គាល់នូវហេតុនោះដូចម្តេច ព្រះមានព្រះភាគនោះ ទ្រង់ប្រតិបត្តិដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បី

សេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយរហូតមក ។ យើងពិចារណា រកមើល នូវសាស្តាជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បី សេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តី ចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញ ហើយ ក៏មិនឃើញមានឡើយ ។ ធម៌ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ ត្រាស់សម្តែងហើយដោយល្អ ជាធម៌ដែលអរិយបុគ្គល គប្បីឃើញច្បាស់ ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលអរិយបុគ្គល គួរហៅ បុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលអរិយបុគ្គល គួរបង្អោនចូលមក ទុកក្នុងចិត្តបាន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ ខ្លួន ។ យើងពិចារណារកមើលនូវគ្រូ ជាអ្នកសម្តែងធម៌ ដែលគួរបង្អោន ចូលមកទុកក្នុងចិត្តបានយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែក កាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពី ព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមាន ព្រះភាគអង្គនោះ ទ្រង់បញ្ញត្តហើយថា នេះជាកុសល ទ្រង់បញ្ញត្តប្រពៃ ហើយថា នេះជាអកុសល ។ នេះប្រកបដោយទោស ។ នេះមិនប្រកប ដោយទោស ។ នេះគួរសេព ។ នេះមិនគួរសេព ។ នេះជាអំពើថោកទាប ។ នេះជាអំពើថ្លៃថ្លា ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តប្រពៃហើយថា នេះធម៌ខ្មៅ

ធម៌ស និងជាសប្បដិភាគ ។ យើងពិចារណារកមើលនូវសាស្តា ជាអ្នកបញ្ញត្តនូវធម៌ទាំងឡាយ ដែលជាកុសល ជាអកុសល ប្រកបដោយទោស មិនប្រកបដោយទោស គួរសេព មិនគួរសេព ថោកទាប និងថ្លៃថ្លា ធម៌ខ្មៅ ធម៌ស និងជាសប្បដិភាគយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តល្អហើយដល់សាវកទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា រមែងប្រៀបធៀបគ្នាបាន ។ ទឹកក្នុងទន្លេគង្គាប្រៀបស្មើនឹងទឹកក្នុងទន្លេយមុនា ដូចម្តេចមិញ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះបញ្ញត្តល្អហើយដល់សាវកទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា រមែងប្រៀបធៀបស្មើគ្នាបាន ដូច្នោះដែរ ។ យើងពិចារណារកមើលនូវសាស្តា ជាអ្នកបញ្ញត្តនូវបដិបទា ជាទីទៅកាន់ព្រះនិព្វានយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមានព្រះភាគទ្រង់បានពួកសេក្ខបុគ្គល ដែលឋិតនៅក្នុងបដិបទា ហើយនឹងព្រះខីណាស្រពដែលមានព្រហ្មចរិយធម៌អប់រំស្រេចហើយជាគ្នីគ្នា តែព្រះមានព្រះភាគ ទ្រង់មិនជាប់ព្រះទ័យនឹងគ្នីគ្នានោះទេ ទ្រង់ប្រកបសេចក្តីត្រេកអរតែមួយអង្គឯង ។ យើងពិចារណារកមើលនូវសាស្តា ជាអ្នកប្រកបនូវសេចក្តីត្រេកអរតែម្នាក់ឯង

*យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅ
ហើយ មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះ
ចេញហើយ ក៏មិនឃើញមានឡើយ ។ លាភសម្រេចហើយ សេចក្តីសរសើរ
ក៏សម្រេចហើយ ដល់ព្រះមានព្រះភាគអង្គនោះ ទាំងពួកក្សត្រក៏មានសកាព
ជាអ្នកស្រឡាញ់រាប់រកព្រះអង្គ ព្រះមានព្រះភាគអង្គនោះ ជ្រាសចាកសេចក្តី
ស្រេវឹងហើយ រមែងសោយនូវអាហារ (តាមធម្មតា) ។ យើងពិចារណា
រកមើលនូវសាស្តា ជាអ្នកជ្រាសចាកសេចក្តីស្រេវឹង ហើយបរិភោគនូវអាហារ
យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ
មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញ
ហើយ ក៏មិនឃើញមានឡើយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់យ៉ាង
ណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ព្រះមានព្រះ
ភាគទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់
យ៉ាងនោះ ដោយប្រការយ៉ាងនេះ ។ យើងពិចារណារកមើលនូវសាស្តាជាអ្នក
ប្រតិបត្តិនូវធម៌ដ៏សមគួរធម៌ដល់យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុង
ចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅ
អំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមាន
ព្រះភាគអង្គនោះ ព្រះអង្គឆ្ងល់ផុតសេចក្តីសង្ស័យអស់ហើយ ព្រះអង្គជ្រាស
ចាកសេចក្តីងឿងឆ្ងល់អស់ហើយ ទ្រង់មានព្រះតម្រិះដល់ទីបំផុតហើយ ដោយ
ព្រហ្មចរិយធម៌ខាងដើម ជានិស្សយដ៏ឧត្តម ។ យើងពិចារណារកមើលនូវ*

សាស្តា ជាអ្នកឆ្ងាយផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ មានតម្រិះដល់នូវទីបំផុត ដោយព្រហ្មចរិយធម៌ខាងដើម ជានិស្ស័យដ៏ឧត្តមយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជ ជាធំជាងពួកទេវតា បានសម្តែងគុណជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគនេះឯង ដល់សនង្កុមារព្រហ្ម ។

[៥៧] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជាសនង្កុមារ-ព្រហ្ម មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ព្រោះបានស្តាប់គុណជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្ម និម្មិតអត្តភាពដ៏លើសលុប ដូចជាកេទុមារ មានផ្នង ៥ ប្រាកដហើយ ដល់ពួកទេវតាជាន់តាវត្តិង្ស ។ ព្រហ្មនោះក៏ហោះទៅងឿងទៅកាន់អាកាស អង្គុយពែនភ្នែនលើផ្ទៃអាកាសវាលធង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំងអង្គុយពែនភ្នែនលើបល្ល័ង្កដែលគេក្រាលល្អហើយ ឬលើភូមិភាគដ៏រាបស្មើ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម ហោះទៅងឿងទៅកាន់អាកាស អង្គុយពែនភ្នែនលើផ្ទៃអាកាសវាលធង ក៏មានឧបមេយ្យដូច្នោះដែរ ហើយនិយាយនឹងពួកទេវតាជាន់តាវត្តិង្សថា នែអ្នកដ៏ចម្រើនទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស សម្គាល់សេចក្តីនោះដូចម្តេច ព្រះមានព្រះភាគអង្គនោះ ជាបុគ្គលមានបញ្ញា

ច្រើន អស់កាលអង្វែងមកហើយ ฯ ម្នាលអ្នកដ៏ចម្រើន រឿងធ្លាប់មានមក ហើយថា មានស្តេចមួយព្រះអង្គ ទ្រង់ព្រះនាមទិសម្បតិ ฯ មានព្រាហ្មណ៍ ឈ្មោះគោវិន្ទៈ ជាបុរោហិតរបស់ព្រះបាទទិសម្បតិ ฯ ព្រះបាទទិសម្បតិ មាន ព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាមវេណុកុមារ ฯ គោវិន្ទព្រាហ្មណ៍មាន កូនប្រុសម្នាក់ឈ្មោះជោតិបាលមាណព ฯ ជនទាំង ៨ នាក់នេះ គឺវេណុរាជ-បុត្រ ๑ ជោតិបាលមាណព ๑ និងក្សត្រ ๖ អង្គទៀត សុទ្ធតែជាសម្លាញ់ នឹងគ្នា ฯ ម្នាលអ្នកដ៏ចម្រើន លុះថ្ងៃ និងយប់កន្លងទៅហើយ គោវិន្ទ-ព្រាហ្មណ៍ ក៏ធ្វើមរណកាលទៅ ฯ ម្នាលអ្នកដ៏ចម្រើន កាលដែលគោវិន្ទ-ព្រាហ្មណ៍ ធ្វើមរណកាលទៅហើយ ព្រះបាទទិសម្បតិ ទ្រង់ព្រះកន្សែង សោកស្តាយថា ឱហ្ន៎ ក្នុងសម័យណា យើងបានប្រគល់រាជកិច្ចទាំងពួង ដោយស្រួលបួល ដល់គោវិន្ទព្រាហ្មណ៍ហើយ កំពុងតែស្គប់ស្គល់ មូលមិត្ត ផ្គេកផ្គិតដោយកាមគុណទាំង ๕ សម័យនោះឯង គោវិន្ទព្រាហ្មណ៍ ក៏ធ្វើ មរណកាលទៅ ฯ ម្នាលអ្នកដ៏ចម្រើន កាលព្រះបាទទិសម្បតិ ទ្រង់ព្រះ កន្សែងសោយស្តាយយ៉ាងនោះហើយ វេណុរាជបុត្រក៏ក្រាបបង្គំទូលព្រះបាទ ទិសម្បតិយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំទ្រង់ព្រះកន្សែង នឹងគោវិន្ទព្រាហ្មណ៍ ដែលធ្វើមរណកាលនោះខ្លាំងពេកឡើយ បពិត្រព្រះ សម្មតិទេព គោវិន្ទព្រាហ្មណ៍ មានកូនប្រុសម្នាក់ ឈ្មោះជោតិបាលមាណព ជាបណ្ឌិតវិសេសជាងបិតាផង ជាអ្នកមោះមុត អាចកាត់សេចក្តីបានជាងបិតា ផង បិតារបស់ជោតិបាលមាណពនោះ ប្រៀនប្រដៅនូវសេចក្តីទាំងឡាយណា

សេចក្តីទាំងឡាយនោះ សុទ្ធតែជាពាក្យប្រៀនប្រដៅ របស់ជោតិបាល-មាណព ។ ព្រះបាទទិសម្បតិ មានព្រះរាជឱង្ការថា ម្នាលកុមារយ៉ាងហ្នឹងមែនឬ ។ ព្រះរេណុរាជកុមារក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព យ៉ាងហ្នឹងមែន ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះ ព្រះបាទទិសម្បតិ មានព្រះរាជ-ឱង្ការឲ្យហៅបុរសម្នាក់ថា នែបុរសដ៏ចម្រើន ឯងចូរមកនេះ ឯងចូរចូលទៅរកជោតិបាលមាណព លុះចូលទៅដល់ហើយ ចូរនិយាយនឹងជោតិបាល-មាណពយ៉ាងនេះថា សូមសេចក្តីចម្រើនមានដល់ជោតិបាលមាណពដ៏ចម្រើនចុះ ព្រះបាទទិសម្បតិមានព្រះរាជឱង្ការ ឲ្យហៅជោតិបាលមាណពដ៏ចម្រើន ព្រះបាទទិសម្បតិ ចង់ជួបនឹងជោតិបាលមាណពដ៏ចម្រើន ។ ម្នាលអ្នកដ៏ចម្រើន រាជកុមារនោះទទួលព្រះរាជឱង្ការព្រះបាទទិសម្បតិថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចចូលទៅរកជោតិបាលមាណព លុះចូលទៅដល់ហើយ បានថ្លែងព្រះឱង្ការនេះនឹងជោតិបាលមាណពថា សូមសេចក្តីចម្រើនមានដល់ជោតិបាលមាណពដ៏ចម្រើនចុះ ព្រះបាទទិសម្បតិ មានព្រះឱង្ការឲ្យហៅជោតិបាលមាណពដ៏ចម្រើន ព្រះបាទទិសម្បតិចង់ជួបនឹងជោតិ-បាលមាណពដ៏ចម្រើន ។ ម្នាលអ្នកដ៏ចម្រើន ជោតិបាលមាណព ទទួលតបពាក្យរាជបុរសនោះថា អើអ្នកដ៏ចម្រើនយ៉ាងនេះហើយ ទើបចូលទៅគាល់ព្រះបាទទិសម្បតិ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាកទាក់ជាមួយនឹងព្រះបាទទិសម្បតិ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរឮរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអ្នកដ៏ចម្រើន លុះជោតិបាលមាណព

អគ្គ័យក្នុងទីដ៏សមគួរហើយ ទើបព្រះបាទទិសម្បតិ មានព្រះបន្ទូលយ៉ាងនេះ ថា ជោតិបាលមាណពដ៏ចម្រើន ចូរអ្នកប្រៀនប្រដៅយើងចុះ ជោតិបាល-មាណពដ៏ចម្រើន កុំលះបង់យើងអំពីការប្រៀនប្រដៅឡើយ យើងនឹងតាំងអ្នកក្នុងតំណែងងារជាដំណែលបិតាអ្នក យើងនឹងស្រោចទឹកអ្នកក្នុងទីជារបស់គោវិន្ទព្រាហ្មណ៍ ។ ជោតិបាលមាណព ទទួលព្រះបន្ទូលព្រះបាទទិសម្បតិថា ព្រះករុណាវិសេស ។ ម្នាលអ្នកដ៏ចម្រើន ទើបព្រះបាទទិសម្បតិ ទ្រង់ស្រោចទឹកជោតិបាលមាណព ក្នុងតំណែងងារគោវិន្ទព្រាហ្មណ៍ ទ្រង់តាំងជោតិបាល-មាណព ក្នុងតំណែងងារជាដំណែលបិតា ។ ជោតិបាលមាណព ដែលព្រះរាជាទ្រង់ស្រោចទឹក ក្នុងទីជារបស់គោវិន្ទព្រាហ្មណ៍ ទ្រង់តាំងងារជាដំណែលបិតាហើយ តែងប្រៀនប្រដៅនូវសេចក្តីទាំងឡាយ ដែលបិតាបានប្រៀនប្រដៅហើយ ដល់ព្រះរាជានោះផង មិនបានប្រៀនប្រដៅនូវសេចក្តីទាំង-ឡាយ ដែលបិតាមិនបានប្រដៅដល់ព្រះរាជានោះផង បានចាត់ចែងការងារទាំងឡាយ ដែលបិតាបានចាត់ចែងហើយ ដល់ព្រះរាជានោះផង មិនបានចាត់ចែងនូវការងារទាំងឡាយ ដែលបិតាមិនបានចាត់ចែងហើយ ដល់ព្រះរាជានោះផង ។ មនុស្សទាំងឡាយ ក៏នាំគ្នានិយាយពីដំណើរនោះថា អើហ្ន៎ មើលចុះគោវិន្ទព្រាហ្មណ៍ អើហ្ន៎ មើលចុះមហាគោវិន្ទព្រាហ្មណ៍ ។ ម្នាលអ្នកដ៏ចម្រើន ជោតិបាលមាណព ក៏បានឈ្មោះថា មហាគោវិន្ទព្រាហ្មណ៍ ដោយបរិយាយនេះយ៉ាងនេះឯង ។

[๕๘] *ម្នាលអ្នកដ៏ចម្រើន គ្រានោះ មហាគោវិន្ទព្រាហ្មណ៍ ចូលទៅ*

គាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលក្សត្រ ទាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គម្ចាស់ជ័ចម្រើន ព្រះបាទទិ-សម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម ក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គម្ចាស់ជ័ចម្រើន នរណាហ្ន៎ នឹងជឹងនូវជីវិតបាន កាលបើព្រះបាទទិសម្បតិទ្រង់ទិវង្គតទៅ ពួកអ្នករាជការ គប្បីអភិសេករណោរាជបុត្រ ក្នុងរាជសម្បត្តិ ហេតុនេះរមែងមាន សូមព្រះ អង្គម្ចាស់ទាំងឡាយជ័ចម្រើនស្តេចមក សូមព្រះអង្គម្ចាស់ទាំងឡាយទៅគាល់ ព្រះរណោរាជបុត្រ លុះចូលទៅដល់ហើយ ត្រូវថ្លែងសេចក្តីចំពោះព្រះរណោ-រាជបុត្រយ៉ាងនេះថា ពួកយើងជាសម្ងាញ់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីខ្ពើមរអើមនៃព្រះរណោរាជបុត្រជ័ចម្រើនឡើយ ព្រះអង្គជ័ចម្រើនមាន សុខយ៉ាងណា ពួកយើងមានសុខយ៉ាងនោះ ព្រះអង្គជ័ចម្រើនមានទុក្ខយ៉ាង ណា ពួកយើងមានទុក្ខយ៉ាងនោះ បពិត្រព្រះអង្គម្ចាស់ជ័ចម្រើន ព្រះបាទទិ-សម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម ក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គម្ចាស់ជ័ចម្រើន នរណាហ្ន៎ នឹងជឹងជីវិតបាន កាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ពួកអ្នក រាជការ គប្បីអភិសេកព្រះរណោរាជបុត្រជ័ចម្រើនក្នុងរាជសម្បតិ ហេតុនេះ រមែងមាន បើព្រះរណោរាជបុត្រជ័ចម្រើន ត្រូវបានរាជសម្បត្តិ សូមព្រះអង្គ ចែករាជសម្បត្តិដល់យើងខ្ញុំទាំងឡាយផង ។ ក្សត្រទាំង ៦ អង្គនោះ ទទួល ពាក្យរបស់មហាគោវិន្ទព្រាហ្មណ៍ថា ម្នាលអ្នកជ័ចម្រើន មែនហើយ ទើបចូល

ទៅគាល់រណុរាជបុត្រ លុះចូលទៅដល់ហើយ ក្រាបទូលរណុរាជបុត្រ យ៉ាងនេះថា យើងទាំងឡាយ ជាសម្ងាញ់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីខ្ពើមរអើមនៃព្រះរណុរាជកុមារដ៏ចម្រើនទេឬយ ព្រះអង្គដ៏ចម្រើន មានសុខយ៉ាងណា ពួកយើងមានសុខយ៉ាងនោះ ព្រះអង្គដ៏ចម្រើន មានទុក្ខយ៉ាងណា ពួកយើងមានទុក្ខយ៉ាងនោះ បពិត្រព្រះអង្គម្ចាស់ដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្មក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គម្ចាស់ដ៏ចម្រើន នរណាហ្ន៎ នឹងដឹងនូវជីវិតបាន កាលបើព្រះបាទទិសម្បតិទ្រង់ទិវង្គតទៅហើយ ពួកអ្នករាជការ គប្បីអភិសេកព្រះរណុរាជបុត្រដ៏ចម្រើន ក្នុងរាជសម្បត្តិ ហេតុនេះវ៉ែមងមាន បើព្រះរណុរាជបុត្រដ៏ចម្រើន ត្រូវបានរាជសម្បត្តិហើយ សូមព្រះអង្គចែករាជសម្បត្តិដល់យើងខ្ញុំទាំងឡាយផង ។ រណុរាជបុត្រ ទ្រង់តបថា ម្នាលអ្នកដ៏ចម្រើន បើក្រៅអំពីអ្នកដ៏ចម្រើនទាំងឡាយហើយ អ្នកដទៃណា នឹងផ្តល់សេចក្តីសុខឲ្យកើតឡើង ក្នុងដែនរបស់យើងបាន ម្នាលអ្នកដ៏ចម្រើន បើយើងនឹងបានរាជសម្បត្តិ យើងនឹងចែករាជសម្បត្តិដល់អ្នកទាំងឡាយផងដែរ ។ ម្នាលអ្នកដ៏ចម្រើន លុះថ្ងៃ និងយប់ទាំងឡាយកន្លងទៅហើយ ព្រះបាទទិសម្បតិ ក៏ទ្រង់ទិវង្គតទៅ ។ កាលបើព្រះបាទទិសម្បតិទ្រង់ទិវង្គតទៅហើយ ពួកអ្នករាជការ ក៏បានអភិសេកព្រះរណុរាជបុត្រក្នុងរាជសម្បត្តិ ។ លុះព្រះរណុរាជបុត្របានអភិសេកដោយរាជសម្បត្តិហើយ ទ្រង់ស្កប់ស្កល់មូលមិត្តផ្គេកផ្គិតដោយកាមគុណទាំង ៥ ។ ម្នាលអ្នកដ៏ចម្រើន

គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅដល់ហើយ ទើបក្រាបទូលក្សត្រទាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គម្ចាស់ដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ព្រះបាទវេណុដែលបានអភិសេក ដោយរាជសម្បត្តិហើយ ព្រះអង្គក៏ស្កប់ស្កល់មូលមិត្តផ្តេកផ្តិត ដោយកាមគុណទាំង ៥ បពិត្រព្រះអង្គម្ចាស់ដ៏ចម្រើន នរណាហ្ន៎នឹងដឹង (រឿងនេះបាន ព្រោះ) កាមារម្មណ៍ទាំងឡាយ សុទ្ធតែជាសភាវៈនាំឲ្យស្រើង សូមឲ្យព្រះអង្គម្ចាស់ដ៏ចម្រើនទាំងឡាយ ស្តេចមកនឹងចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់ហើយ ចូរក្រាបទូលព្រះបាទវេណុយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតហើយ ព្រះបាទវេណុដ៏ចម្រើន បានទទួលអភិសេកដោយរាជសម្បត្តិហើយ ព្រះអង្គដ៏ចម្រើនរឭកឃើញពាក្យនោះដែរឬ ។ ពួកក្សត្រទាំង ៦ អង្គនោះ ទទួលពាក្យមហាគោវិន្ទព្រាហ្មណ៍ថា ម្នាលអ្នកដ៏ចម្រើន មែនហើយ រួចក៏ចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទវេណុយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតហើយ ព្រះបាទវេណុដ៏ចម្រើន បានទទួលអភិសេកដោយរាជសម្បត្តិហើយ តើព្រះអង្គដ៏ចម្រើន រឭកឃើញពាក្យនោះដែរឬ ។ ព្រះបាទវេណុមានព្រះរាជឱង្ការថា ម្នាលអ្នកដ៏ចម្រើន យើងរឭកឃើញពាក្យនោះដែរ ។ ពួកក្សត្រទាំង ៦ អង្គក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ លុមនឹងចែកមហាប្រឹថពីនេះ ដែលមានបណ្តាយទៅខាងទិសឧត្តរ មានមុខដូចជាមុខរនេះ

ទៅខាងទិសទក្សិណ ឲ្យមានចំណែកស្មើគ្នា ជា ៧ ភាគបាន ។ ព្រះបាទ
រេណុមានព្រះរាជឱង្ការថា ម្នាលអ្នកជ៏ចម្រើន រៀរតែមហាគោវិន្ទព្រាហ្មណ៍
ចេញ អ្នកដទៃណាហ្នឹ ល្មមនឹងចែកបាន ។ ម្នាលអ្នកជ៏ចម្រើន គ្រានោះឯង
ព្រះបាទរេណុ មានព្រះរាជឱង្ការហៅបុរសម្នាក់មកថា ម្នាលអ្នកជ៏ចម្រើន
ឯងចូរមកនេះ ឯងចូរទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ
ចូរជម្រាបមហាគោវិន្ទព្រាហ្មណ៍យ៉ាងនេះថា បពិត្រលោកជ៏ចម្រើន ព្រះបាទ
រេណុមានព្រះរាជឱង្ការឲ្យហៅលោក ។ ម្នាលអ្នកជ៏ចម្រើន បុរសនោះទទួល
ព្រះរាជឱង្ការនៃព្រះបាទរេណុថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស
ហើយចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ បានជម្រាប
មហាគោវិន្ទព្រាហ្មណ៍យ៉ាងនេះថា បពិត្រលោកជ៏ចម្រើន ព្រះបាទរេណុមាន
ព្រះរាជឱង្ការឲ្យហៅលោក ។ ម្នាលអ្នកជ៏ចម្រើន មហាគោវិន្ទព្រាហ្មណ៍
ទទួលពាក្យរបស់បុរសនោះថា អើ អ្នកជ៏ចម្រើន ហើយចូលទៅគាល់ព្រះ
បាទរេណុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល
ទៅរកព្រះបាទរេណុ លុះបញ្ចប់ពាក្យដែលគួរីករាយ និងពាក្យដែលគួររឲ្យក
ហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអ្នកជ៏ចម្រើន លុះមហាគោវិន្ទ-
ព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ព្រះបាទរេណុមានព្រះរាជឱង្ការយ៉ាងនេះ
ថា គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ចូរអញ្ជើញមកចែកមហាប្រឹថពីនេះ ដែលមាន
បណ្តាយទៅខាងទិសឧត្តរ មានមុខដូចជាមុខរទេះ ទៅខាងទិសទក្សិណ ឲ្យ
មានចំណែកស្មើគ្នាជា ៧ ភាគ ។ ម្នាលអ្នកជ៏ចម្រើន មាហាគោវិន្ទព្រាហ្មណ៍

ទទួលព្រះបន្ទូលព្រះបាទវេណុថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចែកមហាប្រឹថពីនេះ ដែលមានបណ្តោទៅខាងទិសឧត្តរ មានមុខដូចមុខជារនេះ ទៅខាងទិសទក្សិណ ឲ្យមានចំណែកស្មើគ្នាជា ៧ ភាគ ហើយតម្កល់ទុកនូវដែនទាំងអស់ ឲ្យមានមុខដូចជាមុខរនេះ ។ មានសេចក្តីតំណាលក្នុងរឿងនោះថា ជនបទរបស់ព្រះបាទវេណុ នៅត្រង់កណ្តាល ។

[៥៩] គោវិន្ទព្រាហ្មណ៍ បានសាងទីក្រុងទាំង ៧ នេះ គឺ ក្រុងទន្តបូរៈ សម្រាប់អ្នកដែនកាលិង្គៈ ១ ក្រុងបោតនៈ សម្រាប់ពួកអ្នកដែនអស្សកៈ ១ ក្រុងមាហិស្សតិ សម្រាប់ពួកអ្នកដែនអវន្តិ ១ ក្រុងរោរុកៈ សម្រាប់ពួកអ្នកដែនសោចិរៈ ១ ក្រុងមិថិលា សម្រាប់ពួកអ្នកដែនវិទេហៈ ១ ក្រុងចម្ប៉ា ដែលកសាងក្នុងដែនឈ្មោះអង្គៈ ១ ក្រុងពារាណសី សម្រាប់ពួកអ្នកដែនកាសី ១ ។

[៦០] ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ក្សត្រទាំង ៦ អង្គនោះ ទ្រង់សព្វព្រះទ័យ មានសេចក្តីប្រាថ្នាពេញបរិបូណ៌ហើយ ដោយលាភគួរដល់ព្រះអង្គថា ឱហ្ន៎ របស់ណាដែលពួកយើងប្រាថ្នាហើយ របស់ណាដែលពួកយើងប៉ុនប៉ងសំដៅយកហើយ របស់ណាដែលពួកយើងកត់សម្គាល់ទុកហើយ របស់នោះៗ ក៏ពួកយើងបានអស់ហើយ ។

[៦១] ព្រះបាទសត្តភូ អង្គ ១ ព្រះបាទព្រហ្មទត្ត អង្គ ១ ព្រះបាទវេស្សភូ អង្គ ១ ព្រមទាំងព្រះបាទករតៈ អង្គ

๑ ព្រះបាទវេណុ អង្គ ๑ ព្រះបាទជតរដ្ឋៈ ๒ ព្រះអង្គ ទៀត រួមបានជាស្តេចគ្រប់គ្រងផែនដី មាន ๗ ព្រះអង្គ ក្នុងគ្រានោះ ។

បឋមភាណវារ ចប់

[๖๒] ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ក្សត្រទាំង ๖ អង្គនោះ ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏មានព្រះរាជឱង្ការទៅនឹងមហាគោវិន្ទព្រាហ្មណ៍យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ជាសម្ងាញ់ ជាទីស្រឡាញ់ពេញព្រះទ័យ មិនជាទីខ្ពើមរអើមនៃព្រះបាទវេណុ យ៉ាងណាមិញ គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ក៏ជាសម្ងាញ់ ជាទីស្រឡាញ់ពេញចិត្ត មិនជាទីខ្ពើមនៃពួកយើងយ៉ាងនោះដែរ គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ចូរប្រៀនប្រដៅពួកយើង គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន កុំលះបង់ពួកយើងអំពីការប្រៀនប្រដៅឡើយ ។ ម្នាលអ្នកដ៏ចម្រើន មហាគោវិន្ទព្រាហ្មណ៍ទទួលស្តាប់ព្រះឱង្ការនៃក្សត្រទាំង ๖ អង្គនោះ ដែលបានមុទ្ធាភិសេកហើយថា ព្រះករុណាថ្លៃវិសេស ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ក៏ប្រៀនប្រដៅពួកក្សត្រទាំង ๗ ព្រះអង្គ ដែលបានមុទ្ធាភិសេកដោយរាជសម្បត្តិ ដោយអនុសាសនីផង បានបង្រៀនមន្តដល់ព្រាហ្មណមហាសាល ๗ នាក់ផង និងខ្ញាន់ព្រះកេស ๗๐๐ នាក់ផង ។ ម្នាលអ្នកដ៏ចម្រើន កាលជាខាងក្រោយមក កិត្តិសព្ទដ៏ពីរោះ របស់មហាគោវិន្ទ-

ព្រាហ្មណ៍ ល្បីឮខ្ចរខ្ចាយថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយ ផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជា មួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហា-គោវិន្ទព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា កិត្តិសព្ទដ៏ពីរោះ របស់អាត្មា អញ ល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្ម ដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍អាចសាកសួរ និយាយ ឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន តែអាត្មាអញមិនបានឃើញព្រហ្ម សោះ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹង ព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ប៉ុន្តែ អាត្មាអញធ្លាប់ឮពាក្យនេះ របស់ព្រាហ្មណ៍ចាស់ៗ មានអាយុច្រើន ជាអាចារ្យ ប្រធានលើអាចារ្យ និយាយគ្នាថា បុគ្គលណាសម្លាំនៅក្នុងរដូវភ្លៀងអស់ ៤ ខែហើយ ពិចារណា នូវកុណាឈាន បុគ្គលនោះ នឹងឃើញព្រហ្ម នឹងសាកសួរ និយាយឆ្លើយ ឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន បើដូច្នោះ គួរតែអាត្មាអញសម្លាំនៅក្នុងរដូវ ភ្លៀងអស់ ៤ ខែ ពិចារណានូវកុណាឈាន ។ គ្រានោះឯង មហាគោវិន្ទ-ព្រាហ្មណ៍ ចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់ហើយ បានក្រាប ទូលព្រះបាទវេណុយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់ ខ្ញុំព្រះអង្គ ល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះថា មាហាគោវិន្ទព្រាហ្មណ៍ អាចឃើញ ព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន បពិត្រព្រះអង្គដ៏ចម្រើន តែខ្ញុំព្រះ

អង្គមិនបានឃើញព្រហ្មសោះទេ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាន
និយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ប៉ុន្តែ ខ្ញុំ
ព្រះអង្គ ធ្លាប់បានឮពាក្យព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យ
ប្រធានលើអាចារ្យ និយាយគ្នាថា បុគ្គលណា សម្ងំនៅក្នុងរដូវភ្លៀងអស់ ៤
ខែ ពិចារណានូវកុណាឈាន បុគ្គលនោះនឹងឃើញព្រហ្មបាន សាកសួរ
និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះ
អង្គប្រាថ្នាដើម្បីនឹងសម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ដើម្បីពិចារណានូវ
កុណាឈាន មិនត្រូវឲ្យអ្នកណាមួយចូលទៅរកខ្ញុំព្រះអង្គឡើយ លៀរលែង
តែបុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ព្រះបាទវេណុ មានព្រះរាជឱង្ការថា
គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ គ្រា
នោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះ
ចូលទៅដល់ហើយ បានក្រាបទូលក្សត្រទាំង ៦ អង្គនោះយ៉ាងនេះថា បពិត្រ
ព្រះអង្គដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំព្រះអង្គ ល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះ
ថា មាហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទ-
ព្រាហ្មណ៍អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយ
ផ្ទាល់ខ្លួនបាន បពិត្រព្រះអង្គដ៏ចម្រើន តែខ្ញុំព្រះអង្គមិនបានឃើញព្រហ្មសោះ
មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយ ឆ្លើយឆ្លងជាមួយនឹងព្រហ្ម
មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្ញុំព្រះអង្គគ្រាន់តែឮសេចក្តីតំណាលនេះ
របស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ

*និយាយថា បុគ្គលណា សម្ងំនៅក្នុងរដូវក្តៀងអស់ ៤ ខែ ពិចារណានូវ
កុណាឈាន បុគ្គលនោះនឹងឃើញនូវព្រហ្មបាន សាកសួរ និយាយឆ្លើយ
ឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នា
ដើម្បីនឹងសម្ងំនៅក្នុងរដូវក្តៀងអស់ ៤ ខែ ពិចារណានូវកុណាឈាន មិន
ត្រូវឲ្យអ្នកណាមួយ ចូលទៅរកខ្ញុំព្រះអង្គឡើយ លៀរលែងតែបុគ្គលម្នាក់ ជា
អ្នកនាំអាហារទៅឲ្យ ។ ក្សត្រទាំង ៦ អង្គ មានព្រះរាជឱង្ការថា គោវិន្ទ-
ព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏
ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ចូលទៅរកព្រាហ្មណមហាសាល
ទាំង ៧ នាក់ និងខ្នាន់ព្រះកេសទាំង ៧០០ នាក់ លុះចូលទៅដល់ហើយ
បាននិយាយទៅនឹងព្រាហ្មណមហាសាលទាំង ៧ នាក់ និងខ្នាន់ព្រះកេសទាំង
៧០០ នាក់យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំ ល្បីឮ
ខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់
ខ្លួន អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់
ខ្លួនបាន ម្នាលអ្នកដ៏ចម្រើន តែខ្ញុំមិនបានឃើញព្រហ្មសោះ មិនបានសាក
សួរជាមួយនឹងព្រហ្ម មិនបាននិយាយ ឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបាន
ប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្ញុំគ្រាន់តែឮនូវសេចក្តីតំណាលនេះ របស់ពួក
ព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយ
ថា បុគ្គលណា សម្ងំនៅក្នុងរដូវក្តៀងអស់ ៤ ខែ ពិចារណានូវកុណាឈាន
បុគ្គលនោះ នឹងឃើញព្រហ្មបាន នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សា*

ជាមួយនឹងព្រហ្មបាន ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយស្វាធ្យាយ នូវមន្តទាំងឡាយតាមដែលបានស្តាប់មកហើយ បានរៀនមកហើយ ដោយពិស្តារចុះ ចូរច្រាប់មន្តទាំងឡាយ ដល់គ្នានិងគ្នាផងចុះ ម្នាលអ្នកដ៏ចម្រើន ខ្ញុំប្រាថ្នាដើម្បីនឹងសម្ងំនៅក្នុងរដូវក្តៀងអស់ ៤ ខែ ដើម្បីនឹងពិចារណានូវកុណាឈាន មិនត្រូវឲ្យអ្នកណាមួយចូលទៅរកខ្ញុំឡើយ លៀរលែងតែបុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ព្រាហ្មណមហាសាល និងខ្មាន់ព្រះកេសទាំងនោះ និយាយតបថា គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកប្រពន្ធទាំង ៤០ នាក់ ដែលមានត្រកូល និងជាតិស្មើគ្នា លុះចូលទៅដល់ហើយ បាននិយាយទៅនឹងប្រពន្ធទាំង ៤០ នាក់ ដែលមានត្រកូល និងជាតិស្មើគ្នាយ៉ាងនេះថា នែនាងដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់អញល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ដោយខ្លួន មហាគោវិន្ទព្រាហ្មណ៍ អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន នែនាងដ៏ចម្រើន តែខ្លួនអញមិនបានឃើញព្រហ្មសោះ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្លួនអញគ្រាន់តែឮនូវសេចក្តីតំណាលនេះ របស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យនិយាយថា បុគ្គលណា សម្ងំនៅក្នុងរដូវក្តៀងអស់ ៤ ខែ ពិចារណានូវកុណាឈាន បុគ្គលនោះ នឹងឃើញ

នូវព្រហ្ម នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន នែ នាងដ៏ចម្រើន ឥឡូវអញប្រាថ្នាដើម្បីសម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ដើម្បីនឹងពិចារណានូវកុណាឈាន មិនត្រូវឲ្យអ្នកណាមួយចូលទៅរកអញឡើយ វៀរលែងតែបុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ប្រពន្ធទាំង ៤០ នាក់ ទទួលតបថា គោវិន្ទដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រហ្មណ៍ ឲ្យសាងអាស្រមថ្មី នាទិសខាងកើតព្រះនគរ ហើយសម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ពិចារណានូវកុណាឈាន ។ មិនមានអ្នកណាចូលទៅរកគាត់ឡើយ វៀរលែងតែបុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង កាលកន្លងទៅ ៤ ខែហើយ មហាគោវិន្ទព្រហ្មណ៍ កើតសេចក្តីអផ្សុកអន្ទះអន្ទែងថា អាត្មាអញ ធ្លាប់ឮសេចក្តីតំណាលនេះរបស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យនិយាយថា បុគ្គលណា សម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ពិចារណានូវកុណាឈាន បុគ្គលនោះ នឹងឃើញព្រហ្ម នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបានតែ (ឥឡូវនេះ) អាត្មាអញ មិនបានឃើញព្រហ្មសោះ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្ម ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង សនង្កុមារព្រហ្ម បានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់មហាគោវិន្ទព្រាហ្មណ៍ ដោយចិត្តរបស់ខ្លួនហើយ ក៏ស្រាប់តែបាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខ មហា-

គោវិន្ទព្រាហ្មណ៍ ប្រៀបដូចជាបុរសមានកម្លាំងលាដៃ ដែលខ្ជួនបត់ចូល ឬបត់ដៃដែលខ្ជួនលាចេញ ។ ម្នាលអ្នកដ៏ចម្រើន លំដាប់នោះឯង សេចក្តីភ័យ សេចក្តីតក់ស្លុត និងការព្រឺរោម ក៏កើតឡើងដល់មហាគោវិន្ទព្រាហ្មណ៍ ព្រោះបានឃើញរូបដែលខ្ជួនមិនធ្លាប់ឃើញសោះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះ ឯង មហាគោវិន្ទព្រាហ្មណ៍និយាយទៅនឹងសនង្កុមារព្រហ្មទាំងកិតភ័យ កត់ស្លុត ព្រឺរោម ដោយគាថាថា

[๖๓] *បពិត្រលោកនិទ្ទុក្ខ លោកជាអ្វីហ្ន៎ ទើបមានសម្បុរ មានយស មានសិរី (យ៉ាងនេះ) យើងមិនស្គាល់ បានជាសូមសួរលោក ធ្វើដូចម្តេចហ្ន៎ យើងនឹងស្គាល់លោក ។*

សនង្កុមារព្រហ្មឆ្លើយថា ពួកជនតែងស្គាល់ខ្ញុំថា ជាកុមារក្នុងព្រហ្មលោក មកអស់កាលយូរហើយ ពួកទេវតាទាំងពួងសោត ក៏ស្គាល់ខ្ញុំដែរ ម្នាលគោវិន្ទ អ្នកចូរដឹងយ៉ាងនេះចុះ ។

មហាគោវិន្ទព្រាហ្មណ៍និយាយថា អាសនៈ ទឹក ប្រេងសម្រាប់លាបជើង និងទឹកឃ្មុំ តែងមានដល់ព្រហ្ម យើងសូមទទួលលោកដ៏ចម្រើន ដោយគ្រឿងទទួលក្បៀវ សូមលោកដ៏ចម្រើន ទទួលគ្រឿងទទួលក្បៀវរបស់យើងចុះ ។

សនង្កុមារព្រហ្មឆ្លើយថា ម្នាលគោវិន្ទ អ្នកពោលចំពោះ

គ្រឿងទទួលភ្ញៀវណា យើងព្រមទទួលគ្រឿងទទួលភ្ញៀវ នោះរបស់អ្នក យើងបើកឱកាសឲ្យអ្នកសួរហើយ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងបរលោកផង អ្នកប្រាថ្នាប្រយោជន៍ណាមួយ ចូរសួរប្រយោជន៍នោះចុះ ។

[๖๔] *ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា សនង្កុមារព្រហ្ម បានបើកឱកាសដល់អញហើយ អាត្មាអញគួរសួរអ្វីនឹងសនង្កុមារព្រហ្មហ្ន៎ គួរសួរប្រយោជន៍ក្នុងបច្ចុប្បន្ន ឬប្រយោជន៍ក្នុងបរលោក ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះ មាហាគោវិន្ទ-ព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញជាមនុស្សឈ្វាសវៃចំពោះប្រយោជន៍ក្នុងបច្ចុប្បន្នស្រាប់ហើយ ទាំងពួកជនដទៃ ក៏តែងសួរពីប្រយោជន៍ក្នុងបច្ចុប្បន្ននឹងអាត្មាអញដែរ បើដូច្នោះ គួរតែអាត្មាអញ សួរសនង្កុមារព្រហ្ម ចំពោះប្រយោជន៍ក្នុងបរលោកតែមួយយ៉ាងប៉ុណ្ណោះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ បាននិយាយនឹងសនង្កុមារព្រហ្ម ដោយគាថាថា*

[๖๕] *ខ្ញុំមានសេចក្តីសង្ស័យ សូមសួរសនង្កុមារព្រហ្ម ដែលជាអ្នកមិនមានសេចក្តីសង្ស័យ ក្នុងប្រស្នាទាំងឡាយ ដែលបុគ្គលដទៃគួរដឹងថា សត្វឋិតនៅក្នុងធម៌អ្វី សិក្សាក្នុងធម៌អ្វី ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ។*

សនង្កុមារព្រហ្មតបថា ម្នាលព្រាហ្មណ៍ សត្វលះបង់នូវសេចក្តីប្រកាន់ ថារបស់អញ ក្នុងពួកក្សត្រចេញ ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង មានចិត្តឱនទៅរកកុណាឈាន ប្រាសចាកកិនពុល គឺកិលេស រៀរចាកមេថុនធម្ម ឋិតនៅក្នុងធម៌ទាំងនេះ លុះសិក្សាក្នុងធម៌ទាំងនេះហើយ ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ។

[๖๖] *គោវិន្ទព្រាហ្មណ៍ និយាយតបថា (ត្រង់ពាក្យ) របស់លោកដ៏ចម្រើនថា លះបង់នូវសេចក្តីប្រកាន់ថារបស់អញចេញដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់នូវគំនរទ្រព្យតិចក្តី លះបង់នូវគំនរទ្រព្យច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី ហើយកោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស (ត្រង់ពាក្យ) របស់លោកដ៏ចម្រើនថា លះបង់នូវសេចក្តីប្រកាន់ ថារបស់អញចេញដូច្នេះ ខ្លួនខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ (ត្រង់ពាក្យ) របស់លោកដ៏ចម្រើនថា ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេនាសនៈស្ងាត់ ចៀសគេចទៅនៅតាមព្រៃម្លប់ឈើ ភ្នំ ជ្រោះ រអាងភ្នំ ទីស្មសាន ព្រៃស្រោង ទីវាល គំនរស្មៅឈើ (ត្រង់ពាក្យ) របស់លោកដ៏ចម្រើនថា ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯងដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ (ត្រង់ពាក្យ) របស់លោកដ៏*

ចម្រើនថា មានចិត្តឱនទៅរកនូវកុណាឈាន ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ๑ ទិសទី ๒ ក៏ដូចគ្នា ទិសទី ๓ ក៏ដូចគ្នា ទិសទី ๔ ក៏ដូចគ្នា មានចិត្តប្រកបដោយករុណាដ៏ធំទូលាយ ដល់នូវភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វទាំងអស់ដោយយកខ្លួនឯង ទៅប្រៀបនឹងសត្វទាំងពួង គ្រប់ទិស គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ក៏ដូច្នោះដែរ (ត្រង់ពាក្យ) របស់លោកដ៏ចម្រើនថា មានចិត្តឱនទៅរកករុណាឈាន ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ តែថា ខ្ញុំមិនយល់សោះនូវពាក្យរបស់លោកដ៏ចម្រើន ដែលនិយាយចំពោះពួកក្ងិនពុល (នោះ) ។

[๖๗] បពិត្រព្រហ្ម អ្វីជាពួកក្ងិនពុលក្នុងពួកសត្វ ខ្ញុំមិនស្គាល់នូវក្ងិនពុលទាំងនុ៎ះទេ្បីយ បពិត្រលោក ជាអ្នកប្រាជ្ញ សូមលោកមេត្តាប្រាប់ឲ្យទាន ក្នុងទីនេះ កិលេសដូចម្តេច ដែលរួបរឹតបក់បោកពួកសត្វ ឲ្យមានក្ងិនអាក្រក់ នាំចូលទៅកាន់អបាយ បិទបាំងផ្លូវទៅកាន់ព្រហ្មលោក ។ សនង្កុមារព្រហ្មឆ្លើយតបថា សេចក្តីក្រោធ ๑ ការនិយាយកុហក ๑ ការបញ្ឆោតបន្លំ ๑ ការទ្រុស្តមិត្ត ๑ សេចក្តីកំណាញ់ស្វិតស្វាយ ๑ សេចក្តីមើលងាយគេ ๑ សេចក្តីប្រកែន ๑ សេចក្តីប្រាថ្នា ๑ សេចក្តីសង្ស័យ ๑ ការ

បៀតបៀនអ្នកដទៃ ๑ លោភ ๑ ទោស ๑ សេចក្តីស្រេវឆ ๑ សេចក្តីវង្វេង ๑ ពួកសត្វដែលប្រកបដោយកិលេសទាំង ๑๔ នេះ ឈ្មោះថា ជាអ្នកមានក្តិនពុលមិនទាន់អស់ រមែងទៅកាន់អបាយ ដែលបិទបាំងផ្លូវទៅកាន់ព្រហ្មលោក ។

[๖๘] *មហាគោវិន្ទព្រហ្មណ៍ និយាយថា ខ្ញុំយល់ច្បាស់ហើយនូវក្តិនពុលទាំងឡាយ ដែលលោកជ័ចម្រើននិយាយ តែក្តិនពុលទាំងនោះ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រលោកជ័ចម្រើន ខ្ញុំនឹងចេញចាកផ្ទះទៅបួស ។ សនង្កុមារព្រហ្មនិយាយតបថា គោវិន្ទព្រាហ្មណ៍ជ័ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកជ័ចម្រើនគ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ព្រះបាទវេណុ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទវេណុយ៉ាងនេះថា ឥឡូវនេះ សូមព្រះអង្គជ័ចម្រើនស្វែងរកបុរោហិតឯទៀត សម្រាប់នឹងប្រឹក្សាការរាជការ របស់ព្រះអង្គជ័ចម្រើនចុះ បពិត្រព្រះអង្គជ័ចម្រើន ខ្ញុំព្រះអង្គប្រាថ្នាដើម្បីនឹងចេញចាកផ្ទះទៅបួស ដ្បិតខ្ញុំព្រះអង្គឮព្រហ្មនិយាយអំពីក្តិនពុលទាំងឡាយហើយ តែក្តិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានទេ បពិត្រព្រះអង្គជ័ចម្រើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។*

[๖๙] *មហាគោវិន្ទព្រហ្មណ៍ក្រាបទូលថា ខ្ញុំព្រះអង្គសូមក្រាបទូលព្រះបាទវេណុជាម្ចាស់ផែនដី សូមព្រះអង្គទ្រង់*

ជ្រាបដោយកិច្ចរាជការចុះ ខ្ញុំព្រះអង្គលែងត្រេកអរ ក្នុងតំណែងបុរោហិតហើយ ។

ព្រះបាទរេណុត្រាស់ថា បើអ្នកខ្វះខាតដោយវត្ថុទាំងឡាយដែលត្រូវការ យើងនឹងបំពេញឲ្យអ្នក បើបុគ្គលណាបៀតបៀនអ្នក យើងជាម្ចាស់នៃសេនាលើផែនដី នឹងហាមប្រាមបុគ្គលនោះ អ្នកទុកដូចជាបិតា យើងទុកដូចជាបុត្រ ម្នាលគោវិន្ទ សូមអ្នកកុំលះបង់យើងឡើយ ។

មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា ការខ្វះខាត់ដោយវត្ថុទាំងឡាយ ដែលត្រូវការ (នៃខ្ញុំព្រះអង្គ) មិនមានទេ បុគ្គលអ្នកបៀតបៀនខ្ញុំព្រះអង្គ ក៏មិនមានដែរ ប៉ុន្តែ ខ្ញុំព្រះអង្គបានស្តាប់ពាក្យរបស់អមនុស្សហើយ ហេតុនោះ បានជាខ្ញុំព្រះអង្គមិនត្រេកអរក្នុងផ្ទះទេ ។

ព្រះបាទរេណុ ទ្រង់ត្រាស់ថា អមនុស្សមានភេទដូចម្តេច បាននិយាយសេចក្តីដូចម្តេចនឹងអ្នក ដែលអ្នកបានស្តាប់ហើយ នឹងលះបង់នូវផ្ទះទាំងឡាយរបស់យើងផង នូវយើងផង នូវជនទាំងអស់ផង ។

មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា កាលពីដើម ខ្ញុំព្រះអង្គចូលទៅពួនសម្ងំនៅតែម្នាក់ឯង កាលដែលខ្ញុំព្រះអង្គប្រាថ្នាដើម្បីបូជាយញ្ញ ខ្ញុំព្រះអង្គក៏ប្រមូលស្បូវ និងស្វ៊ីកឈើមក

គរ បង្គាត់ភ្លើងឲ្យឆេះឡើង ។ លំដាប់នោះ ស្រាប់តែសនង្កុមារព្រហ្មណ៍ មកអំពីព្រហ្មលោក ប្រាកដ (នៅមុខ) នៃខ្ញុំព្រះអង្គ ព្រហ្មនោះបានដោះស្រាយប្រស្នានឹងខ្ញុំព្រះអង្គ ឯខ្ញុំព្រះអង្គ ក៏បានស្តាប់សេចក្តីនូវសេចក្តីនោះហើយ ទើបលែងត្រេកអរក្នុងផ្ទះ ។

ព្រះបាទវេណុ មានព្រះរាជឱង្ការថា ម្នាលគោវិន្ទ អ្នកនិយាយពាក្យណា យើងក៏ជឿពាក្យនោះ របស់អ្នកដ៏ចម្រើន អ្នកបានស្តាប់ពាក្យអមនុស្សហើយ នឹងប្រព្រឹត្តទៅដោយខ្លែកដូចម្តេច យើងនោះនឹងប្រព្រឹត្តតាមអ្នកដែរ ម្នាលគោវិន្ទ (ព្រោះថា) អ្នកដ៏ចម្រើន ជាគ្រូរបស់យើងស្រាប់ហើយ ។ អ្នកប្រៀបដូចកែវមណី និងកែវពៃទូរ្យ មិនមានប្រែធា ថ្លាស្អាត យើងបានឮយ៉ាងនេះហើយ នឹងប្រព្រឹត្តតាមពាក្យប្រដៅរបស់អ្នកគោវិន្ទ ។

[៧០] *ព្រះបាទវេណុ មានព្រះរាជឱង្ការថា ប្រសិនបើគោវិន្ទ-ព្រាហ្មណ៍ដ៏ចម្រើន នឹងចេញចាកកផ្ទះ ហើយចូលទៅកាន់ផ្នួស យើងនឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នកយ៉ាងណា គតិរបស់យើងនឹងទៅជាយ៉ាងនោះដែរ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅដល់ហើយ បានក្រាបទូលក្សត្រទាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គ ឥឡូវនេះ សូមព្រះអង្គ*

ទាំងឡាយដ៏ចម្រើន សូមឯកបុរោហិតដទៃទៀត សម្រាប់នឹងប្រឹក្សាកិច្ចការ រដ្ឋ របស់ព្រះអង្គទាំងឡាយដ៏ចម្រើនចុះ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គប្រាថ្នា ដើម្បីនឹងចេញចាកផ្ទះទៅបួស ដ្បិតខ្ញុំព្រះអង្គបានឮព្រហ្មនិយាយ អំពីកិន ពុលទាំងឡាយហើយ កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយ នឹងលះបង់បានឡើយ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ពួកក្សត្រទាំង ៦ អង្គនោះ ចៀសចេញទៅ ក្នុងទីដ៏សមគួរ ហើយគិតព្រមគ្នាថា ធម្មតាពួកព្រាហ្មណ៍ទាំងនេះ ជាបុគ្គល ល្មោភនឹងទ្រព្យ បើដូច្នោះ គួរយើងល្បួងមហាគោវិន្ទព្រាហ្មណ៍ដោយទ្រព្យ ។ ក្សត្រទាំង ៦ អង្គនោះ ក៏ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ ហើយថ្លែង សេចក្តីយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សម្បត្តិក្នុងរាជ្យទាំង ៧ នេះ មាន ច្រើន ព្រោះហេតុនោះ អ្នកដ៏ចម្រើនត្រូវការដោយសម្បត្តិប៉ុន្មាន ចូរយក សម្បត្តិប៉ុណ្ណោះចុះ ។ មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា កុំឡើយព្រះអង្គ សម្បត្តិរបស់ខ្ញុំព្រះអង្គនេះបរិបូណ៌ហើយ ជាសម្បត្តិដែលព្រះអង្គដ៏ចម្រើន ទាំងឡាយប្រទានឲ្យ ខ្ញុំព្រះអង្គលះចោលសម្បត្តិទាំងអស់ ហើយនឹងចេញ ចាកផ្ទះទៅបួស តាមពាក្យដែលខ្ញុំព្រះអង្គបានឮព្រហ្មនិយាយ អំពីកិនពុល ទាំងឡាយហើយ កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះ បង់បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ក្សត្រទាំង ៦ អង្គនោះ ចៀសចេញទៅក្នុង ទីដ៏សមគួរ ហើយគិតព្រមគ្នាយ៉ាងនេះថា ធម្មតាពួកព្រាហ្មណ៍ទាំងនេះ ជា

បុគ្គលល្មោកនឹងស្ត្រី បើដូច្នោះ គួរតែយើងលួងលោមមហាគោវិន្ទព្រាហ្មណ៍ ដោយពួកស្ត្រី ។ កូរ្តត្រទាំង ៦ អង្គនោះ ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ ហើយថ្លែងសេចក្តីយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ពួកស្ត្រីក្នុងរាជ្យទាំង ៧ នេះមានច្រើន ព្រោះហេតុនោះ អ្នកដ៏ចម្រើនត្រូវការដោយពួកស្ត្រីប៉ុន្មាននាក់ ចូរនាំយកពួកស្ត្រីប៉ុណ្ណោះចុះ ។ មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា កុំឡើយ ព្រះអង្គ អម្បាលដូចជាភរិយាទាំង ៤០ នាក់របស់ខ្ញុំព្រះអង្គនេះ សុទ្ធតែមានជាតិ និងត្រកូលស្មើគ្នា (ម្តេចក៏) ខ្ញុំព្រះអង្គនឹងលះចោលភរិយាទាំងអស់នោះ ហើយចេញចាកផ្ទះទៅបួស តាមដែលខ្ញុំព្រះអង្គបានឮព្រហ្មនិយាយអំពីកិនពុលទាំងឡាយហើយ តែថា កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានទេ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។ កូរ្តត្រទាំង ៦ អង្គត្រាស់ថា បើគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន នឹងចេញចាកផ្ទះ ទៅបួស ពួកយើងក៏ចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នកយ៉ាងណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។

[៧១] *មហាគោវិន្ទព្រាហ្មណ៍ទូលថា បុថុជ្ជនតែងជាប់នៅក្នុងកាមទាំងឡាយណា បើព្រះអង្គទាំងឡាយ នឹងលះបង់នូវកាមទាំងឡាយនោះចេញ សូមព្រះអង្គប្រារព្ធនូវការព្យាយាមឲ្យមាំ ប្រកបដោយកម្លាំងនៃខន្តិធម៌ (ផង) ។ នេះជាផ្លូវត្រង់ នេះជាផ្លូវប្រសើរ ដែលពួកសប្បុរស តែងរក្សាព្រះសទ្ធម្ម ដើម្បីទៅកើតក្នុងព្រហ្មលោក ។*

[๗๒] *ក្សត្រទាំង ៦ អង្គគ្រាស់ថា បើដូច្នោះ សូមមហាគោវិន្ទដ៏ចម្រើន រង់ចាំអស់ ៧ ឆ្នាំ (សិន) លុះកន្លង ៧ ឆ្នាំហើយ ពួកយើងនឹងចេញចាកផ្ទះ ទៅបួស បើគតិរបស់អ្នកយ៉ាងណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។ មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ៧ ឆ្នាំយូរណាស់ ខ្ញុំព្រះអង្គមិនអាចនឹងរង់ចាំព្រះអង្គដល់ ៧ ឆ្នាំបានទេ បពិត្រព្រះអង្គដ៏ចម្រើន នរណាឡើយ នឹងអាចដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរលោក បុគ្គលត្រូវយល់ដោយប្រាជ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតមកហើយ ឈ្មោះថា មិនស្ថាប់គ្មានទេ តាមដែលខ្ញុំព្រះអង្គបានឮព្រាហ្មនិយាយអំពីកិនពុលទាំងឡាយហើយ កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ក្សត្រទាំង ៦ អង្គ មានព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំអស់ ៦ ឆ្នាំសិន ។បេ។ រង់ចាំអស់ ៥ ឆ្នាំសិន ។ រង់ចាំអស់ ៤ ឆ្នាំសិន ។ រង់ចាំអស់ ៣ ឆ្នាំសិន ។ រង់ចាំអស់ ២ ឆ្នាំសិន ។ រង់ចាំអស់ ១ ឆ្នាំសិន លុះដល់កន្លងមួយឆ្នាំហើយ ពួកយើងនឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នកយ៉ាងណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។ មាហាគោវិន្ទ-ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ១ ឆ្នាំយូរណាស់ ខ្ញុំព្រះអង្គមិនអាចនឹងរង់ចាំព្រះអង្គអស់ ១ ឆ្នាំបានទេ បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ អាចដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរលោក បុគ្គលត្រូវ*

យល់ដោយប្រាជ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតហើយ ឈ្មោះថា មិនស្លាប់គ្មានទេ ព្រោះខ្ញុំព្រះអង្គ បានឮព្រហ្មនិយាយអំពីក្ងិនពុលទាំង៦ប្រាយហើយ ក្ងិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះ ទៅបួស ។ ក្សត្រទាំង ៦ អង្គ មានព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំអស់ ៧ ខែសិន លុះកន្លង ៧ ខែហើយ ពួកយើងនឹងចេញចាកផ្ទះ ទៅបួស គតិរបស់អ្នកយ៉ាងណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។ មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ៧ ខែយូរណាស់ ខ្ញុំព្រះអង្គមិនអាចនឹងចាំព្រះអង្គអស់ ៧ ខែបានទេ បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ អាចដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរលោក បុគ្គលត្រូវយល់ដោយប្រាជ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតហើយ ឈ្មោះថា មិនស្លាប់គ្មានទេ ព្រោះខ្ញុំព្រះអង្គបានឮព្រហ្ម និយាយអំពីក្ងិនពុលទាំង៦ប្រាយហើយ ក្ងិនពុលទាំងនោះបុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះ ទៅបួស ។ ក្សត្រទាំង ៦ អង្គមានព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំអស់ ៦ ខែសិន ។ រង់ចាំអស់ ៥ ខែសិន ។ រង់ចាំអស់ ៤ ខែសិន ។ រង់ចាំអស់ ៣ ខែសិន រង់ចាំអស់ ២ ខែសិន ។ រង់ចាំអស់ ១ ខែសិន ។ រង់ចាំអស់កន្លះខែសិន លុះកន្លងកន្លះខែទៅហើយ ពួកយើងនឹងចេញចាកផ្ទះ ទៅបួស គតិ

របស់អ្នកយ៉ាងណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។ មហាគោវិន្ទ-
ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កន្ទុះខែយូរណាស់ ខ្ញុំព្រះ
អង្គមិនអាចនឹងរង់ចាំព្រះអង្គកន្ទុះខែបានទេ បពិត្រព្រះអង្គដ៏ចម្រើន នរណា
ហ្ន៎ អាចដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរលោក បុគ្គលត្រូវ
យល់ដោយប្រជ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែល
កើតមកហើយ ឈ្មោះថា មិនស្លាប់គ្មានទេ ព្រោះខ្ញុំព្រះអង្គ បានឮព្រហ្ម
និយាយអំពីក្ងិនពុលទាំង៦ប្រាយហើយ ក្ងិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រង
ផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹង
ចេញចាកផ្ទះទៅបួស ។ ក្សត្រទាំង ៦ អង្គ មានព្រះរាជឱង្ការថា បើដូច្នោះ
សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំអស់ ៧ ថ្ងៃសិន ទម្រាំពួកយើងប្រៀន
ប្រដៅកូន និងបងប្អូនរបស់ខ្លួនក្នុងរាជសម្បត្តិ លុះកន្លង ៧ ថ្ងៃហើយ ពួក
យើងនឹងចេញចាកផ្ទះទៅបួស គតិរបស់អ្នកយ៉ាងណា គតិរបស់ពួកយើងក៏
យ៉ាងនោះដែរ ។ មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន
៧ ថ្ងៃមិនយូរប៉ុន្មានទេ ខ្ញុំព្រះអង្គនឹងរង់ចាំព្រះអង្គអស់ ៧ ថ្ងៃបាន ។ ម្នាល
អ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកព្រាហ្មណ-
មហាសាលទាំង ៧ នាក់ និងនាយខ្នាន់ព្រះកេស ៧០០ នាក់ លុះចូលទៅ
ដល់ហើយ ក៏និយាយនឹងព្រាហ្មណមហាសាលទាំង ៧ នាក់ និងនាយខ្នាន់
ព្រះកេសទាំង ៧០០ នាក់យ៉ាងនេះថា ឥឡូវនេះ សូមអ្នកដ៏ចម្រើនទាំង-
ឡាយ រកអាចារ្យឯទៀត ឲ្យបង្រៀនមន្តដល់អ្នកទាំងឡាយដ៏ចម្រើនចុះ ម្នាល

អ្នកជ័ចម្រើន យើងប្រាថ្នានឹងចេញចាកផ្ទះ ទៅបួស តាមដែលខ្ញុំបានឮព្រហ្ម
និយាយអំពីកិនពុលទាំងឡាយហើយ កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រង
ផ្ទះ មិនងាយនឹងលះបង់បានឡើយ ម្នាលអ្នកជ័ចម្រើន ខ្ញុំនឹងចេញចាកផ្ទះ
ទៅបួស ។ ព្រហ្មណមហាសាល និងនាយខ្នាន់ព្រះកេសនិយាយតបថា សូម
គោវិន្ទព្រាហ្មណ៍ជ័ចម្រើន កុំអាលចេញចាកផ្ទះទៅបួសឡើយ បពិត្រអ្នកជ័
ចម្រើន ធម្មតាបព្វជ្ជា មានសក្តិតូច មានលាភតិច ឯភាពជាព្រហ្ម មាន
សក្តិធំ មានលាភច្រើន ។ មហាគោវិន្ទព្រាហ្មណ៍តបថា អ្នកជ័ចម្រើនទាំង-
ឡាយ កុំនិយាយយ៉ាងនេះឡើយ អ្នកជ័ចម្រើនទាំងឡាយ កុំនិយាយយ៉ាង
នេះថា បព្វជ្ជាមានសក្តិតូច មានលាភតិច ឯភាពជាព្រហ្មមានសក្តិធំ មាន
លាភច្រើន ម្នាលអ្នកជ័ចម្រើនទាំងឡាយ បុគ្គលណាហ្ន៎ វៀរលែងតែខ្ញុំចេញ
ដែលមានសក្តិធំ មានលាភច្រើនជាង ម្នាលអ្នកជ័ចម្រើន ឥឡូវនេះ ខ្ញុំដូច
ជាស្តេចរបស់ស្តេចទាំងឡាយ ឬដូចជាព្រហ្មរបស់ព្រាហ្មណ៍ទាំងឡាយ ដូច
ជាទេវតារបស់គហបតីទាំងឡាយ ខ្ញុំនឹងលះបង់នូវភាវៈជាធំនោះទាំងអស់
ហើយចេញចាកផ្ទះ ទៅបួស តាមដែលខ្ញុំបានឮព្រហ្មនិយាយអំពីកិនពុល
ទាំងឡាយហើយ កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹង
លះបង់បានឡើយ ម្នាលអ្នកជ័ចម្រើន ខ្ញុំនឹងចេញចាកផ្ទះ ទៅបួស ។ ពួក
ព្រាហ្មណមហាសាលទាំងនោះឆ្លើយតបថា បើគោវិន្ទព្រាហ្មណ៍ចេញចាកផ្ទះ
ទៅបួស យើងទាំងឡាយនឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នកយ៉ាង
ណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។ ម្នាលអ្នកជ័ចម្រើន គ្រានោះ

មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកភរិយាទាំង ៤០ នាក់ ដែលមានជាតិ និងត្រកូលស្មើគ្នា លុះចូលទៅដល់ហើយ បាននិយាយនឹងភរិយាទាំង ៤០ នាក់ ដែលមានជាតិ និងត្រកូលស្មើគ្នាយ៉ាងនេះថា ម្នាលនាងដ៏ចម្រើន នាងណាចង់ទៅ នាងនោះចូរទៅកាន់ត្រកូលញាតិទាំងឡាយនៃខ្លួនចុះ ឬចូររកកស្តាជនៃទៀតចុះ នែនាងដ៏ចម្រើន អញប្រាថ្នានឹងចេញចាកផ្ទះទៅបួស ព្រោះអញបានឮព្រហ្មនិយាយអំពីកិនពុលទាំងឡាយហើយ កិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ ម្នាលនាងដ៏ចម្រើន អញនឹងចេញចាកផ្ទះទៅបួស ។ ពួកភរិយាជម្រាបថា ខ្លួនលោកស្រាប់ហើយ ជាញាតិរបស់ពួកយើងដែលជាអ្នកប្រាថ្នានូវញាតិ មួយទៀត ខ្លួនលោកស្រាប់ហើយជាកស្តារបស់ពួកយើង ដែលជាអ្នកប្រាថ្នានូវកស្តា បើលោកគោវិន្ទដ៏ចម្រើននឹងចេញចាកផ្ទះ ទៅបួស ពួកយើងនឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់លោកយ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។ ម្នាលអ្នកដ៏ចម្រើន ចុះកន្លង ៧ ថ្ងៃទៅហើយ មហាគោវិន្ទព្រាហ្មណ៍ បានកោរសក់ និងពុកមាត់ ហើយស្លៀកពាក់សំពត់កាសាយៈរួចចេញចាកផ្ទះទៅបួស ជាបុគ្គលគ្មានប្រយោជន៍ដោយកិច្ចក្នុងផ្ទះ ។ ក្សត្រទាំង ៧ អង្គ ដែលបានមុទ្ធាភិសេកហើយផង ព្រាហ្មណមហាសាលទាំង ៧ នាក់ផង នាយខ្នាន់ព្រះកេសទាំង ៧០០ នាក់ផង ភរិយាទាំង ៤០ នាក់ ដែលមានជាតិ និងត្រកូលស្មើគ្នាផង ពួកក្សត្រច្រើនពាន់ផង ពួកព្រាហ្មណ៍ច្រើនពាន់ផង ពួកគហបតីច្រើនពាន់ផង ពួកស្រីស្នំជាច្រើនផង ស្ត្រីអ្នកស្រុកទាំង-

ឡាយជាច្រើនផង (បានឃើញ) មហាគោវិន្ទព្រាហ្មណ៍បួស រួចហើយ ក៏កោរសក់ និងពុកមាត់ ស្បៃកពាក់សំពត់កាសាយៈ រួចចេញចាកផ្ទះ ទៅបួសតាមមហាគោវិន្ទព្រាហ្មណ៍ ដែលបួសជាបុគ្គលគ្មានប្រយោជន៍ដោយផ្ទះហើយដែរ ។ ម្នាលអ្នកដ៏ចម្រើន សេចក្តីតំណាលថា មហាគោវិន្ទព្រាហ្មណ៍មានបរិស័ទនោះហែហមចោមរោមត្រាច់ទៅកាន់ចារិក ក្នុងស្រុក និគម និង រាជធានីទាំងឡាយ ។ ម្នាលអ្នកដ៏ចម្រើន សម័យនោះ មហាគោវិន្ទព្រាហ្មណ៍ចូលកាន់ទៅកាន់ស្រុកណា ឬនិគមណា ដូចជាស្តេចរបស់ស្តេចទាំងឡាយ ដូចជាព្រហ្មរបស់ព្រាហ្មណ៍ទាំងឡាយ ដូចជាទេវតារបស់គហបតីទាំងឡាយ ក្នុងស្រុកនោះ ឬនិគមនោះ ។ ម្នាលអ្នកដ៏ចម្រើន ក៏សម័យនោះ ពួកមនុស្សណាកណ្តាស់ ឬរអិលក្លាត់ ពួកមនុស្សនោះ ក៏លាន់មាត់យ៉ាងនេះថា សូមនមស្ការចំពោះមហាគោវិន្ទព្រាហ្មណ៍ សូមនមស្ការចំពោះបុរោហិតទាំង ៧ ។ មហាគោវិន្ទព្រាហ្មណ៍ មានចិត្តប្រកបដោយមេត្តា មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ ដល់នូវភាវៈជាធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វទាំងអស់ ដោយយកខ្លួនឯង ទៅប្រៀបនឹងសត្វទាំងអស់ គ្រប់ទិស គឺទិសខាងលើ ទិសខាងក្រោយ និងទិសទទឹង គឺទិសតូចៗ ក៏ដូច្នោះដែរ មានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ។បេ។ មានចិត្តប្រកបដោយឧបេក្ខា ។បេ។ មិនតែប៉ុណ្ណោះ បានទាំងជ្រាប់ផ្លូវ

ដើម្បីឲ្យកើតជាមួយនឹងព្រហ្ម ក្នុងព្រហ្មលោកដល់សាវ័កទាំងឡាយ ។ ម្នាលអ្នកដ៏ចម្រើន សម័យនោះឯង ពួកសាវ័កណា របស់មហាគោវិន្ទព្រាហ្មណ៍ ជីងចាស់នូវពាក្យប្រៀនប្រដៅសព្វគ្រប់ហើយ ពួកសាវ័កនោះ លុះរំលាងខន្ធ បន្ទាប់អំពីមរណភាពទៅ ក៏បានទៅកើតក្នុងសុគតិព្រហ្មលោក ។ ពួកសាវ័កណា មិនជីងចាស់នូវពាក្យប្រៀនប្រដៅសព្វគ្រប់ទេ ពួកសាវ័កនោះ លុះរំលាងខន្ធ បន្ទាប់អំពីមរណភាពទៅ ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់បរនិម្មិតវសវត្តី ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់និម្មានរតី ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់តុសិត ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់យាមៈ ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់តាវត្តិង្ស ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់ចាតុម្មហារាជិកៈ ។ ពួកជនណាបំពេញវត្តដ៏ថោកទាប ជាងគេទាំងអស់ ពួកជនទាំងនោះទៅកើតក្នុងពួកគន្ធព្វ ។ ឯបព្វជ្ជារបស់កុលបុត្រទាំងអស់នោះ មិនសោះសូន្យ មិនប្រកបដោយទោសទេ ប្រកបតែដោយផល ប្រកបតែដោយសេចក្តីចម្រើន (អាចកើតក្នុងព្រហ្មលោកបាន) ដោយប្រការដូច្នេះឯង ។ បញ្ចសិខគន្ធព្វបុត្រក្រាបទូលថា ព្រះមានព្រះភាគ ទ្រង់រឭកឃើញជំណើរនោះដែរឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបញ្ចសិខៈ តថាគតនឹកឃើញដែរថា សម័យនោះ តថាគតបានកើតជាមហាគោវិន្ទ-ព្រាហ្មណ៍ តថាគតសម្តែងប្រាប់ផ្លូវដើម្បីឲ្យកើតជាព្រហ្ម នាព្រហ្មលោកនោះដល់ពួកសាវ័កទាំងឡាយ ម្នាលបញ្ចសិខៈ ឯព្រហ្មចរិយធម៌នោះឯង មិនមែនប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងាប់ (កិលេស)

ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានបានទេ (គ្រាន់តែឲ្យបានទៅ) កើតក្នុងព្រហ្មលោកប៉ុណ្ណោះ ម្នាលបញ្ចសិខ: ព្រហ្ម-ចរិយធម៌របស់តថាគតនេះឯង ទើបប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកវាគ: ដើម្បីរម្ងាត់ (កិលេស) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែមួយយ៉ាង ។ ម្នាលបញ្ចសិខ: ព្រហ្ម-ចរិយធម៌នោះ តើដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកវាគ: ដើម្បីរម្ងាត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែមួយយ៉ាង ។ គឺផ្លូវដ៏ប្រសើរប្រកដោយអង្គ ៨ នេះឯង ឯ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នោះ គឺសេចក្តីយល់ត្រូវ ๑ សេចក្តីត្រិះរិះ ត្រូវ ๑ សម្តីត្រូវ ๑ ការងារត្រូវ ๑ ការចិញ្ចឹមជីវិតត្រូវ ๑ ការព្យាយាម ត្រូវ ๑ ការរឭកត្រូវ ๑ ការតម្កល់ចិត្ត ๑ ម្នាលបញ្ចសិខ: នេះឯងជា ព្រហ្មចរិយធម៌ប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាកវាគ: ដើម្បី រម្ងាត់ (កិលេស) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បី ព្រះនិព្វានតែមួយយ៉ាង ។ ម្នាលបញ្ចសិខ: ចំណែកពួកសាវ័កណារបស់ តថាគត ដឹងនូវពាក្យប្រៀនប្រដៅសព្វគ្រប់ ពួកសាវ័កនោះអស់អាសវ: ហើយ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្ត បញ្ញាវិមុត្តិ ដែលមិនមានអាសវ: ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថ ។ ពួកសាវ័កណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅដោយសព្វគ្រប់ ពួកសាវ័ក នោះ គ្រាន់តែក្សយពួកសំយោជន: ជាចំណែកខាងក្រោយ ๕ គង់ទៅកើត

ជាឱបបាតិកកំណើត តែងបរិព្វានក្នុងភពនោះ មិនត្រឡប់ចាកលោកនោះមក វិញជាធម្មតា ។ ពួកសាវ័កណា មិនជឿងច្បាស់នូវពាក្យប្រៀនប្រដៅ ដោយ សព្វគ្រប់ ពួកខ្លះគ្រាន់តែកន្ល័យសំយោជនៈទាំង ៣ និងស្រាលស្តើងរាគៈ ទោសៈ មោហៈ ជាសកទាគាមិបុគ្គល ត្រូវត្រឡប់មកកាន់កាមលោកនេះ ម្តងទៀត ទើបធ្វើនូវទីបំផុតទុក្ខបាន ។ ពួកសាវ័កណា មិនជឿងច្បាស់នូវ ពាក្យប្រៀនប្រដៅ ដោយសព្វគ្រប់ ពួកខ្លះគ្រាន់តែកន្ល័យសំយោជនៈទាំង ៣ ជាសោតាបន្នបុគ្គល មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងតែនឹង បានត្រាស់ដឹងនូវធម៌តទៅមុខ ។ ម្នាលបញ្ចសិខៈ បព្វជ្ជារបស់កុលបុត្រ ទាំងអស់គ្នានេះ មិនសោះសូន្យ មិនប្រកបដោយទោសទេ ប្រកបតែដោយ ផល ប្រកបតែដោយសេចក្តីចម្រើន ដោយប្រការដូច្នេះឯង ។ ព្រះមាន ព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះសូត្រនេះចប់ហើយ ។ បញ្ចសិខៈគន្ធព្វបុត្រ ក៏ពេញចិត្ត ត្រេកអរ អនុមោទនា ចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយថ្វាយបង្គំលាព្រះមានព្រះភាគ ដើរប្រទក្សិណ ក៏ចាត់អំពីទីនោះទៅ ។

មហាគោវិន្ទសូត្រទី ៦ ចប់

អដ្ឋកថា

មហាគោវិន្ទសូត្រ

[៤៧] មហាគោវិន្ទសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ជូច្នេះ ។ តទៅនេះជាពាក្យពណ៌នាបទ ដែលជ្រាលជ្រៅក្នុងមហាគោវិន្ទសូត្រនោះ ។ បទថា **បញ្ចសិខ** សេចក្តីថា មានជុក ៥ គឺមានសក់ ៥ កញ្ចុំ ។ បានញ្ចថា បញ្ចសិខគន្ធព្វបុត្រនោះ ក្នុងវេលាធ្វើបុញ្ញកម្ម ក្នុងអត្តភាពជាមនុស្ស នៅជាកុមារនៅឡើយ ។ ក្នុងកាលនៅក្មេងទុកជុក ៥ កញ្ចុំ ជាប្រធាននៃក្មេងឃ្វាលគោទាំងឡាយ នាំពួកក្មេងៗ ដទៃធ្វើសាលា ក្នុងទីដែលមានផ្ទូវបែកជា ៤ ជីកស្រះឈូក ធ្វើស្ពាន ពង្រាបផ្ទូវដែលមិនរាបស្មើ ជញ្ជូនឈើមកធ្វើភ្ជៅនិងឈើស៊ីកភ្ជៅរបស់យានទាំងឡាយ តែងតែធ្វើបុណ្យបែបនេះ ជូចដែលពោលមកហើយ ក៏ស្លាប់ទាំងនៅក្មេង ។ រាងកាយរបស់កុមារនោះ ជារាងកាយដែលគួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត ។ កាលកុមារនោះស្លាប់ហើយ ក៏ទៅកើតក្នុងទេវលោកជាន់ចាតុម្មហារាជិកា មានអាយុ ៩ លានឆ្នាំ ។ រាងកាយរបស់ទេវបុត្រនោះជូចជាជុំមាស មានទំហំ ៣ គាវុត ។ ទេវបុត្រនោះប្រដាប់អលង្ការប្រមាណ ៦០ រទេះ ប្រោះព្រំគ្រឿងក្រអូបប្រមាណ ៩ ក្អម ស្លៀកដណ្តប់សម្ពត់ទិព្វពណ៌ក្រហម ស្រៀតផ្ការកណិការមាស មាន ៥ កន្ទេង បន្តោងនៅខាងក្រោយ ត្រាច់ទៅទំនងដូចក្មេងមានជុក ៥ នោះឯង ។ ទើបពួកទេវតាស្គាល់ទូទៅថា បញ្ចសិខ: ជូច្នេះ ។ បទថា **អភិក្ពន្ទាយ រត្តិយា** គឺរាត្រីឈានកន្ទងទៅហើយ គឺអស់ទៅហើយ ។ សេចក្តីថា កន្ទងទៅហើយមួយចំណែក ។ បទថា **អភិក្ពន្ទវណ្ណោ** គឺមានរស្មីគួរស្រឡាញ់ គួរ

ប្រាថ្នា គួរពេញចិត្តយ៉ាងក្រៃលែង ។ ដោយប្រក្រតី ទេវបុត្រនោះ ក៏មានវស្មី (ពណ៌សម្បុរ) គួរប្រាថ្នាហើយ តែកាលបើតាក់តែងហើយ ក៏រឹងរឹតតែល្អជាងបុគ្គលមានពណ៌សម្បុរល្អនោះទៅទៀត ។ បទថា **កេវលកប្បំ** *គឺដោយជុំវិញមិនមានសេសសល់ ។* **កេវល** *សព្ទ ក្នុងទីនេះ ប្រែថា មិនមានសល់ ដូចក្នុងពាក្យនេះថា បរិបូណ៌ដោយឥតសេសសល់ ។* **កប្ប** *សព្ទ ប្រែថា ដោយជុំវិញ ដូចក្នុងប្រយោគថា* **កេវលកប្បំ ជេតវនំ** *ញាំងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាង ដោយឥតសេសសល់ ។ បទថា* **ឯកាសេត្វា** *គឺផ្សាយទៅដោយពន្លឺ សេចក្តីថា ធ្វើឲ្យជាពន្លឺតែម្យ៉ាង ឲ្យជាប្រទីបតែមួយ ដូចព្រះចន្ទ និងព្រះអាទិត្យ ។*

បទថា **សុធម្មាយំ សភាយំ** *គឺត្រង់សភាដែលកើត ព្រោះផលនៃដើមកណិការ ដែលប្រៀបដូចកែវរបស់ស្រីឈ្មោះសុធម្មា ។ បានឮមកថា ផ្ទៃរបស់សុធម្មាសភានោះ សម្រេចដោយកែវផលិក រនុកសម្រេចដោយកែវមណី សសរសម្រេចដោយមាស ក្បាលសសរសម្រេចដោយប្រាក់ រូបសត្វសាហាវសម្រេចដោយកែវប្រពាល បង្គន់ពិតាន និងស៊ុមបង្អួចសម្រេចដោយកែវ ๗ ប្រការ ក្បឿងសម្រេចដោយឥដ្ឋពណ៌កែវឥន្ទនិល ដំបូលសម្រេចដោយមាស កំពូលប្រាសាទសម្រេចដោយប្រាក់ ផ្នែកបណ្តោយ និងផ្នែកទទឹងម្ខាង ๓๐๐ យោជន៍ ទំហំ ๙๐๐ យោជន៍ដោយជុំវិញ កម្ពស់ ๕๐๐ យោជន៍ ។ សុធម្មាសភា មានសភាពបែបនេះ ។*

ក្នុងបទថា **ធតរដ្ឋោ** *ជាដើម គប្បីជ្រាបថា ស្តេចធតរដ្ឋ ជារាជានៃគន្ធព្វ ដែលពួកទេវតាអ្នករបាំ ๑ សែនកោដិហែហមហើយ ឲ្យកាន់យកបន្ទះ*

ក្តារធំ ដែលធ្វើដោយមាស ១ សែនកោដិ និងលំពែងមាស ហើយបែរព្រះកក្តែទៅទិសខាងលិច យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់គង់ក្នុងទិសខាងកើត ។

ស្តេចវិរូឡ្ហក ជាស្តេចនៃកុម្ភណ្ឌ ដែលមានពួកកុម្ភណ្ឌ ១ សែនកោដិ ហែហមហើយ ឲ្យកាន់យកបន្ទះក្តារធំ ដែលធ្វើដោយប្រាក់ ១ សែនកោដិ និងលំពែងមាស ហើយបែរព្រះភក្តែទៅទិសខាងជើង យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់គង់ក្នុងទិសខាងត្បូង ។

ស្តេចវិរូបក្ខ ជាស្តេចនៃនាគ មានពួកនាគ ១ សែនកោដិហែហម ឲ្យកាន់យកបន្ទះក្តារធំ សម្រេចដោយកែវមណី ១ សែនកោដិ និងលំពែងមាស ហើយបែរព្រះភក្តែទៅទិសខាងកើត យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់គង់ក្នុងទិសខាងលិច ។

ស្តេចវេស្សវ័ណ ជាស្តេចនៃយក្ខ មានពួកយក្ខ ១ សែនកោដិហែហម ឲ្យកាន់យកបន្ទះក្តារធំ ដែលធ្វើដោយកែវប្រពាល ១ សែនកោដិ និងលំពែងមាស បែរព្រះភក្តែទៅទិសខាងត្បូង យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់គង់ក្នុងទិសខាងជើង ។

បទថា **អថ បច្ឆា អម្ហាកំ អាសនំ ហោតិ** *គឺឱកាសសម្រាប់អង្គុយរបស់ពួកយើង រមែងដល់ផ្នែកខាងក្រោយរបស់លោកទាំង ៤ អង្គនោះ តពីនោះ ពួកយើងនឹងចូលក៏មិនបាន ឬនឹងមើលក៏មិនបាន ។*

ក្នុងករណីនេះ លោកពោលហេតុនៃការប្រជុំគ្នា ៤ យ៉ាងជាមុន ។ ក្នុងហេតុទាំង ៤ យ៉ាងនោះ ការប្រមូលចុះក្នុងថ្ងៃចូលវស្សា លោកអធិប្បាយឲ្យ

ធំទូលាយហើយ ។ ពិតហើយ ហេតុក្នុងថ្ងៃចូលវស្សា យ៉ាងណា ភិក្ខុទាំង-ឡាយ ប្រជុំគ្នាក្នុងថ្ងៃ ១៥ កើត ក្នុងថ្ងៃមហាបវារណា ប្រឹក្សាគ្នាថា ថ្ងៃនេះ ពួកយើងនឹងទៅណា ហើយបវារណាក្នុងសម្នាក់អ្នកណា ដូច្នោះ ។ ក្នុងទីប្រជុំ នោះ សក្កទេវរាជជាធំលើពួកទេវតាដោយច្រើន ទ្រង់នឹងបវារណាក្នុងចិយង្គ ទីបមហាវិហារនុ៎ះឯង ។ ពួកទេវតាដ៏សេស ក៏កាន់យកផ្កាទិព្វ ដូចជាផ្កា បារិច្ឆត្តកជាដើម និងលម្អតចន្ទន៍ទិព្វ ហើយទៅកាន់ទីដែលពេញចិត្តរៀងៗ ខ្លួន ហើយបវារណាគ្នា ។ បៃបនេះឈ្មោះថា រមែងប្រជុំគ្នា ដើម្បីប្រយោជន៍ ដល់ការសង្គ្រោះបវារណា ។

ក្នុងទេវលោក មានវល្លិឈ្មោះអាសាវតី ។ ពួកទេវតាគិតថា វល្លិនោះ នឹងចេញផ្កា ទើបទៅកាន់ទីនោះ រក្សាអស់ ១ ពាន់ឆ្នាំ កាលដើមបារិច្ឆត្តក កំពុងចេញផ្កា ពួកទេវតាទៅកាន់ទីនោះ រក្សារហូតដល់អស់ ១ ឆ្នាំ ។ ទេវតា ទាំងនោះ នាំគ្នាត្រេកអរ តាំងពីដើមឈើនោះមានស្លឹកលឿងជាដើមទៅ ។ ដូចដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម័យណា ដើម រលួសផ្កងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស មានស្លឹកទុំជ្រុះ ហើយ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្ត ត្រេកអរថា ឥឡូវនេះ ដើមរលួសផ្កងជាបារិច្ឆត្តកព្រឹក្ស មានស្លឹកទុំជ្រុះហើយ មិនយូរប៉ុន្មាន មុខជានឹងមានស្លឹក ៧ ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងសម័យណា ដើមរលួសផ្កងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតា ជាន់តាវត្តិង្សមានស្លឹក ៧ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់ តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្កង ជាបារិច្ឆត្តកព្រឹក្ស

របស់ពួកទេវតាជាន់តាវត្តិង្សមានស្លឹក ๗ ហើយ មិនយូរប៉ុន្មាន មុខជានឹងមានកញ្ចុំនៃស្លឹក និងផ្កា ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដែលរលួសផ្នងជាបាវិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានកញ្ចុំនៃស្លឹក និងផ្កា ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្នងជាបាវិច្ឆត្តកព្រឹក្ស មានកញ្ចុំនៃស្លឹក និងផ្កាកើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានកញ្ចុំនៃស្លឹក និងផ្កា តាំងខ្ចីងផ្សេងៗ គ្នា ក្នុងកាលឥឡូវនេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ដើមរលួសផ្នង ជាបាវិច្ឆត្តកព្រឹក្ស មានផ្ការីកស្គុះស្គាយ ដោយអាការទាំងពួង មានពន្លឺផ្សាយចេញទៅ ៥០ យោជន៍ដោយជុំវិញ ក្លិនផ្សាយទៅបណ្តាយខ្យល់ ១០០ យោជន៍ នេះជាអានុភាពនៃដើមរលួសផ្នង ជាបាវិច្ឆត្តកព្រឹក្ស ។

កាលដើមបាវិច្ឆត្តការីកហើយ កិច្ចដោយការដាក់បង្អោង កិច្ចដោយការយកតម្កល់ថ្កល់យកមក ឬកិច្ចដោយការយកប្រអប់ទៅទទួល ដើម្បីនាំយកផ្កាមកមិនមាន ។ ខ្យល់ដែលធ្វើនាទីផ្កាច់ តាំងខ្ចីងហើយ ក៏ជាច់ផ្កាអំពីទង ខ្យល់ដែលធ្វើនាទីទទួលក៏ទទួលទុក ខ្យល់ដែលធ្វើនាទីត្រង់បញ្ជូន ក៏បញ្ជូនចូលទៅកាន់សុធម្មាទេវសភា ។ ខ្យល់ដែលធ្វើនាទីបោស ក៏បោសយកផ្កាចាស់ចោល ។ ខ្យល់ដែលធ្វើនាទីក្រាល ក៏ចាត់ចែងក្រាលត្របកផ្កា និងកេសរ ។ ទីត្រង់កណ្តាល មានធម្មាសនៈ មានបល្ល័ង្កកែវកម្ពស់ ๑ យោជន៍ មានសេតច្ឆត្រកម្ពស់ ๓ យោជន៍ ជាំងអំពីខាងលើ ។ បន្ទាប់អំពីបល្ល័ង្កនោះ ក៏ក្រាលអាសនៈសក្កទេវរាជ ។ បន្ទាប់ពីនោះមក ក៏ជាអាសនៈរបស់ទេវបុត្រ ๓๓ អង្គទៀត ។ បន្ទាប់ពីនោះមក ក៏ជាអាសនៈរបស់ទេវបុត្រ អ្នកមានសក្តិ

ធំៗ ពួកដទៃ ។ សម្រាប់ពួកទេវតាដទៃ ក៏ប្រើត្របកផ្ការឈើជាអាសនៈ ។ ពួកទេវតាចូលកាន់ទេវសភាហើយអង្គុយ ។ លម្អងផ្ការហុយទៅទល់នឹងពិតានខាងលើ ហើយធ្លាក់មក ធ្វើឲ្យអត្តភាពប្រមាណ ៣ គាវុតរបស់ទេវតាទាំងឡាយ ដូចលាបខ្ជួនដោយទឹកលក្ត ។ ពួកទេវតាទាំងនោះ លេងកីឡានោះ ៤ ខែ ទើបចប់ ។ ពួកទេវតា រមែងប្រជុំគ្នាដើម្បីប្រយោជន៍ដល់ការសោយបារិច្ចត្តកកីឡា ដោយប្រការដូច្នេះ ។

ក្នុងទេវលោក ទេវតាយោសនាការស្តាប់ធម៌ធំ ១ ខែ ៨ ថ្ងៃ ។ ក្នុងថ្ងៃទាំង ៨ នោះ សនង្កុមារមហាព្រហ្ម សក្កទេវរាជ ភិក្ខុជាធម្មកថិក ឬមិនដូច្នោះ ទេវបុត្រធម្មកថិកអង្គណាមួយ ពោលធម្មកថា ក្នុងសុធម្មាទេវសភា ។ ក្នុងថ្ងៃ ៨ នៃបក្ខ ពួកអមាត្យរបស់មហារាជទាំង ៤ អង្ត ក្នុងថ្ងៃ ១៤ ឧរសទាំងឡាយក្នុងថ្ងៃ ១៥ មហារាជទាំង ៤ អង្ត ស្តេចចេញទៅ ទ្រង់កាន់ដំបារមាស និងជាតិហិង្គុលកៈ ត្រាច់ទៅតាមគាមនិគម និងរាជធានីទាំងឡាយ ។ ព្រះអង្គទ្រង់កត់ត្រាទុក ដោយជាតិហិង្គុលកៈ លើដំបារមាសថា ស្ត្រី ឬបុរសឈ្មោះឯណោះ ដល់ព្រះពុទ្ធជាសរណៈ ដល់ព្រះធម៌ជាសរណៈ ដល់ព្រះសង្ឃជាសរណៈ ។ រក្សាសីល ៥ ធ្វើឧបោសថ ៨ ដង ក្នុង ១ ខែ ធ្វើការទំនុកបម្រុងមាតាបិតា ធ្វើការបូជាដោយផ្ការឧប្បល ១០០ ក្តាប់ បូជាដោយដោយថូផ្ការក្នុងទីនោះ តាំងប្រទីប ១០០០ ដួង ធ្វើការស្តាប់ធម៌ពុំជូកាលសាងធត្រវេទី មុទ្ធិវេទី កុច្ចិវេទី បល្ល័ង្កសីហៈ ជណ្តើរសីហៈ បំពេញសុចរិត ៣ ប្រការ ប្រព្រឹត្តមុតមាំក្នុងកុសលកម្មបថ ១០ ប្រការ ហើយនាំមកប្រគល់ឲ្យដល់ដៃរបស់បញ្ចសិខៈ ។ បញ្ចសិខៈ ក៏ឲ្យដល់ដៃរបស់មាតលី ។ សារថី-

មាតលីក៏ថ្វាយចំពោះសក្កទេវរាជ ។ កាលមនុស្សធ្វើបុណ្យមានតិច ក្រាំងបញ្ជីក៏ស្តើង ។ ពេលពួកទេវតាបានឃើញបញ្ជីនោះប៉ុណ្ណោះ ក៏ទោមនស្សថាសម្ចាញ់អើយ មហាជនប្រមាទពិតហ្នឹ អបាយ ៤ នឹងពេញ ទេវលោក ៦ ជាន់នឹងសោះសូន្យ ។ តែបើបញ្ជីក្រាស់ កាលពួកទេវតាបានឃើញប៉ុណ្ណោះ ក៏នាំគ្នាត្រេកអរថា ឱសម្ចាញ់អើយ មហាជនមិនបានប្រមាទ អបាយ ៤ នឹងទទេ ទេវលោក ៦ ជាន់នឹងពេញ ពួកយើងនឹងបានចោមរោមអ្នកមានបុណ្យធំ ដែលបានធ្វើបុណ្យទុកក្នុងព្រះពុទ្ធសាសនា ហើយមកលេងនក្ខត្តឬក្សជាមួយគ្នា ។ សក្កទេវរាជ ទ្រង់កាន់បញ្ជីនោះហើយ ក៏ទ្រង់ប្រៀនប្រដៅ ។ ជាប្រក្រតី កាលសក្កទេវរាជនោះកំពុងត្រាស់ ព្រះសូរសៀងបានញ្ជទៅចម្ងាយ ១២ យោជន៍ ។ កាលត្រាស់ដោយព្រះសូរសៀងខ្ចាំង ព្រះសូរសៀង ក៏គ្របដណ្តប់ទេវនគរអស់ទាំង ១ ម៉ឺនយោជន៍តាំងនៅ ។ ដូចពោលមកនេះ ទេវតាទាំងឡាយ រមែងប្រជុំគ្នាដើម្បីប្រយោជន៍ស្តាប់ធម៌ ។ ក្នុងទីនេះ គប្បីជ្រាបថា ពួកទេវតាប្រជុំគ្នាដើម្បីប្រយោជន៍បវារណាសង្គហៈ ។

[៤៨] បទថា **តថាគតំ នមស្សន្តា** សេចក្តីថា នមស្ការព្រះតថាគតដោយហេតុ ៩ យ៉ាង ។ សេចក្តីរបស់បាទគាថាថា ព្រះធម៌ដែលជាធម៌ល្អគឺភាវៈនៃព្រះធម៌ មាន **ស្វាក្ខាតោ** ជាដើម ជាធម៌ដែលល្អ និងជាបដិបទាល្អ មាន **ឧជុបដិបន្នោ** របស់ព្រះសង្ឆជាដើម ។

[៤៩] បទថា **យថាភុជ្ជ** គឺតាមពិត តាមភាវៈរបស់ខ្ជូន ។ បទថា **វណ្ណោ** សំដៅយកព្រះគុណ ។ បទថា **បយិរុទាហាសិ** សេចក្តីថា ពោលហើយ ។ បទថា **ពហុជនហិតាយ បដិបន្នោ** គឺបដិបត្តិដូចម្តេច បដិបត្តិយ៉ាង

នេះគឺ

កាលទ្រង់សមោធានធម៌ ៨ ប្រការ ទៀបបាទមូលរបស់ព្រះពុទ្ធទីបង្ករ ហើយបំពេញព្រះអភិនីហារ ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ។ កាលទ្រង់បំពេញព្រះបារមីទាំង ១០ នេះ គឺ ទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី អស់កាល ៤ អសង្ខ្យេយ្យ និង ១ សែនកប្ប ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ។ ក្នុងកាលជាតាបសកាន់យកមាំក្នុងខន្តី (ខន្តិវាទី) ក្នុងកាលជាចូឡធម្មបាលកុមារ ក្នុងកាលជាស្តេចជីរឆទ្ទន្ត ក្នុងកាលជាស្តេចនាគ ឈ្មោះ ភូរិទត្ត ចម្បេយ្យៈ និងសង្ខបាល និងក្នុងកាលជាមហាកបិ ទ្រង់ធ្វើការងារដែលធ្វើបានលំបាកជួច្នោះ ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ។ កាលទ្រង់មានអត្តភាពជាព្រះវេស្សន្តរ ទ្រង់ឲ្យសត្តសតកមហាទាន ធ្វើឲ្យផែនដីកម្រើកក្នុងទី ៧ ស្ថាន ហើយទ្រង់កាន់យកកំពូលនៃបារមី ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ។ ក្នុងអត្តភាពបន្ទាប់អំពីព្រះវេស្សន្តរនោះ ទ្រង់តាំងនៅក្នុងតុសិតបុរីរហូតដល់អស់ព្រះជន្មាយុ ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ។ ព្រះអង្គទ្រង់យើញបុព្វនិមិត្ត ៥ ក្នុងតុសិតបុរីនោះ ដែលពួកទេវតាក្នុង ១ ម៉ឺនចក្រវាលអាវជនាហើយ ទ្រង់ត្រួតមើលមហាវិលោកនៈ ៥ ប្រការ ហើយប្រទាន ប្តេជ្ញាដើម្បីប្រយោជន៍ដល់ការសង្គ្រោះពួកទេវតា ហើយទ្រង់ចុតិចាកតុសិតបុរី ទ្រង់បដិសន្ធិក្នុងព្រះគភ៌មាតា ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ។ ទ្រង់នៅ

ក្នុងព្រះគភ៌ព្រះមាតាជរាបអស់ ១០ ខែ ហើយប្រសូតចាកគភ៌ព្រះមាតា ត្រង់ពៃលុម្ពិនីក្តី ទ្រង់គ្រប់គ្រងផ្ទះអស់ ២៩ វស្សា ទ្រង់ចេញមហាភិនេស្ក្រមណ៍ ទ្រង់សាងព្រះផ្នួសនៅត្រង់ឆ្នេរស្ទឹងអនោមាក្តី ទ្រង់ធ្វើព្រះកាយឲ្យលំបាក ដោយមហាបធានអស់ ៦ ឆ្នាំ ហើយទ្រង់ឡើងកាន់ពោធិបល្ល័ង្ក ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណក្តី ទ្រង់ញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅត្រង់មណ្ឌលពោធិព្រឹក្សអស់ ៧ សប្តាហ៍ក្តី ទ្រង់អាស្រ័យពៃឥសិបតនៈ ហើយបង្វិលនូវធម្មចក្រដ៏ប្រសើរក្តី ទ្រង់ធ្វើយមកប្បាដិហារ្យក្តី ទ្រង់ចុះអំពីទេវលោកក្តី ទ្រង់ជាព្រះពុទ្ធហើយ តាំងនៅអស់ ៤៥ វស្សាក្តី ទ្រង់ជាក់ព្រះជន្មាយុសង្ខារក្តី ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ចន្លោះមហាសាលព្រឹក្សទាំងគូក្តី ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ។ គប្បីជ្រាបថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន អស់កាលដែលព្រះធាតុរបស់ព្រះអង្គតាំងនៅ សូម្បីប៉ុនគ្រាប់ស្ពៃ ។ បទដ៏សេស ក៏ជាពាក្យប្រើជំនួសបទថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើនទាំងអស់ ។ ក្នុងបទទាំងនោះ បទក្រោយជាបទលម្អិតសេចក្តីរបស់បទមុន ។

ច្រើនបទថា **នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ** សេចក្តីថា សូម្បីក្នុងអតីតយើងក៏សម្ងំមើលមិនឃើញ ក្នុងអនាគតក៏សម្ងំមើលមិនឃើញបុគ្គលដទៃក្រៅពីព្រះពុទ្ធ ទោះបីក្នុងឥឡូវនេះ ក៏មើលមិនឃើញ ព្រោះមិនមានសាស្តាដទៃឡើយ ក្រៅពីព្រះដ៏មានព្រះភាគអង្គនោះ ។ សូម្បីក្នុងអដ្ឋកថាក៏ពិចារណាថា ព្រះពុទ្ធទាំងឡាយដែលបរិនិព្វានទៅហើយក្តី ដែលមិនទាន់កើតឡើងក្តី ក៏ដូចព្រះសាស្តារបស់ពួកយើងនោះឯង ហើយសក្ក-

ទេវរាជត្រាស់ធ្វើអ្វី ហើយពោលថា ក្នុងឥទ្ធរនេះ ព្រះសាស្តាទ្រង់បដិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ក្រៅអំពីព្រះសាស្តារបស់ពួកយើងហើយ ក៏ មិនមានអ្នកណាដទៃ ព្រោះដូច្នោះ ទើបសក្កទេវរាជត្រាស់ថា យើងសម្លឹង មើលមិនឃើញ ។ ក្នុងបទនេះមានសេចក្តីយ៉ាងណា សូម្បីក្នុងបទដទៃក្រៅពី នេះ ក៏គប្បីជ្រាបថា មានន័យតែមួយដូចគ្នានោះឯង ។

បទទាំងឡាយមានបទថា **ស្វាក្ខាតោ** *ជាដើម និងបទថា* **កុសលំ** *ជាដើមមានអត្ថដូចបានពោលហើយនោះឯង ។*

ពីរបទថា **តង្ខោទកំ យមុនោទកេន** *សេចក្តីថា ទឹកក្នុងប្រសព្វមុខ នៃស្ទឹងគង្គា និងស្ទឹងយមុនា រមែងចូលគ្នា លាយគ្នាបាន ទាំងដោយពណ៌ ដោយ ក្លិន ដោយរស គឺរមែងដូចគ្នានុ៎ះឯង ដូចមាសដែលបាក់ត្រង់កណ្តាល មិន មែនផ្សេងគ្នា ដូចវេលាដែលលាយចូលគ្នានឹងទឹក របស់មហាសមុទ្រនោះ ឡើយ ។ បដិបទាដើម្បីនិព្វានដែលបរិសុទ្ធ ទើបបរិសុទ្ធ ។ ពិតហើយ បុគ្គល ធ្វើការងារ មានវេជ្ជកម្មជាដើម ក្នុងវេលាជាកំលោះ ត្រាច់ទៅក្នុងអគោចរ ក៏មិនអាចឃើញនិព្វានក្នុងកាលជាមនុស្សចាស់បានឡើយ ។ បដិបទាដែល ឲ្យដល់ព្រះនិព្វាន គប្បីជាការបដិបទាដែលបរិសុទ្ធពិតៗ ប្រៀបដូចអាកាស ។ ពិតហើយ បដិបទារបស់កិកូដែលឆ្ពោះទៅកាន់ព្រះនិព្វាន គួរនឹងប្រៀបផ្ទឹម ដោយអាកាស មិនជាប់ទាក់ក្នុងត្រកូល ឬក្នុងពួកគណៈ ដូចផ្លូវដែលជាទី ប្រាថ្នាក្នុងអាកាសរបស់ព្រះចន្ទ និងព្រះអាទិត្យ ដែលកំពុងចរក្នុងអាកាសដ៏ បរិសុទ្ធ មិនមានអ្វីទើសទាក់ដូច្នោះ ។ ឯបដិបទានេះ ក៏ដូច្នោះឯង ព្រះមាន ព្រះភាគ ទ្រង់បញ្ញត្ត ត្រាស់ គឺទ្រង់សម្តែងហើយ ព្រោះហេតុនោះ ទើបសក្ក-*

ទេវរាជត្រាស់ថា ព្រះនិព្វានក្តី បដិបទាក្តី រមែងចូលគ្នាបាន ដូច្នេះ ។

បទថា **បដិបន្នានំ** *គឺរបស់បុគ្គលដែលតាំងនៅក្នុងបដិបទា ។ បទថា* **វុសិតវតំ** *គឺ បុគ្គលដែលមានការនៅ នៅស្រេចហើយ ។ បទថា* **លទ្ធ-សហាយោ** *សេចក្តីថា ឈ្មោះថា គ្នីគ្នា ព្រោះទៅជាមួយគ្នានឹងបុគ្គលទាំងនេះ ក្នុងទីនោះៗ ។ បទថា* **អទុតិយោ អសហាយោ អប្បដិសមោ** *នេះ សក្តទេវរាជត្រាស់ដោយអត្តថា មិនមានអ្នកណា ដូចព្រះមានព្រះភាគអង្គនោះ ។ បទថា* **អបនុជ្ជ** *សេចក្តីថា ក្នុងកណ្តាលបុគ្គលទាំងនេះ ក៏ទ្រង់នៅដោយផលសមាបត្តិ គឺដោយព្រះហឫទ័យ ហើយទ្រង់មិនជាប់ក្នុងបុគ្គលទាំងនោះ ទ្រង់តាមប្រកបក្នុងភាពជាបុគ្គលតែម្នាក់ឯង ជាទីមកត្រេកអរហើយ ។*

ច្រើនបទថា **អភិនិបួន្នោ ខោ បន តស្ស ភគវតោ លាភោ** *គឺលាភដែលធំក្រៃលែងកើតឡើងហើយ ដល់ព្រះមានព្រះភាគអង្គនោះ ។ សួរថា កើតឡើងហើយតាំងអំពីកាលណា ឆ្លើយថា កើតឡើងហើយដល់ព្រះអង្គតាំងអំពីទ្រង់សម្រេចអភិសម្ពោធិហើយ ទ្រង់កន្លង ៧ សប្តាហ៍ ទ្រង់បង្វិលនូវធម្មចក្រ ត្រង់ឥសិបតនៈ ទ្រង់ធ្វើការទូន្មានទេវតា និងមនុស្សដោយលំដាប់ ទ្រង់ឲ្យជដិល ៣ នាក់បួស ទ្រង់យាងដល់ក្រុងរាជគ្រឹះ ទូន្មានព្រះបាទពិម្ពិសារ ដូចលោកពោលថា សម័យនោះឯង ព្រះមានព្រះភាគ មានមនុស្ស និងទេវតាធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ព្រះអង្គបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ លាភសក្ការៈកើតឡើងមក ដូចអន្ទង់ទឹកធំ ជោរជន់ហើយ ព្រោះផលបុណ្យដ៏ច្រើន ក្នុង ៤ អសង្ខ្យេយ្យ និង ១ សែនកប្ប ។*

បានឮមកថា ក្នុងក្រុងរាជគ្រឹះ ក្រុងសាវត្ថី ក្រុងសាកេត ក្រុងកោសម្ពី ក្រុងពារាណសី ឈ្មោះថា បដិបាដិកត្ត គឺកត្តដែលឲ្យតាមលំដាប់ កើតឡើង ហើយដល់ព្រះមានព្រះភាគ ។ ក្នុងក្រុងទាំងនោះ ម្នាក់ៗ ចុះក្នុងបញ្ជីថា ខ្ញុំនឹងលះបង់ទ្រព្យ ១០០ ថ្វាយទាន ហើយក៏បិទទុកត្រង់ទ្វារវិហារ អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ២០០ អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ៥០០ អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ១ ពាន់ អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ២ ពាន់ អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ៥ ពាន់ អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ១ ម៉ឺន អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ២ ម៉ឺន អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ៥ ម៉ឺន អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ១ សែន អ្នកខ្លះពោលថា ខ្ញុំលះបង់ទ្រព្យ ២ សែនថ្វាយទាន សរសេរដួចេ្នះហើយ ក៏បិទត្រង់ទ្វារវិហារ ។ មហាជនគិតថា បានឱកាស ខ្ញុំនឹងថ្វាយ ហើយក៏ផ្ទុកពេញរទេះ ដឹកតាមកិក្ខុដែលកំពុងត្រាច់ ទៅកាន់ជនបទនោះឯង ។ ដូចដែលលោកពោលថា សម័យនោះឯង ពួកមនុស្សអ្នកជនបទ បានផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ក្នុងរទេះទាំងឡាយ ហើយក៏បរទៅតាមក្រោយៗ កិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ពួកមនុស្សអ្នកស៊ីដែលប្រមាណ ៥០០ នាក់ក៏គិតគ្នាថា បើពួកយើងបានលំដាប់វេននៃកត្តក្នុងកាលណា នឹងធ្វើកត្តក្នុងកាលនោះ ។ រឿងដទៃៗ ជាច្រើនក្នុងខន្ធកៈក្តី ក្នុងព្រះវិនយក្តី ដូចដែលពោលមកនេះ ក៏គប្បីជ្រាប ។ ឯលោកនោះដល់កំពូលហើយ ក្នុងអសទិសទាន ។

បានឮមកថា សម័យមួយ កាលព្រះមានព្រះភាគ ស្តេចត្រាច់ចារិកតាមជនបទ ហើយទ្រង់មកដល់វត្តជេតពន ព្រះរាជាទ្រង់និមន្តថ្វាយទាន ។ ក្នុង

ថ្ងៃទី ២ ពួកអ្នកក្រុងថ្វាយ ។ ព្រះរាជាទ្រង់ថ្វាយក្រៃលែងជាងទានរបស់ពួកអ្នកក្រុងទាំងនោះទៀត ពួកអ្នកនគរក៏ថ្វាយក្រៃលែងជាងទានរបស់ព្រះអង្គដូច្នេះ កាលកន្លងទៅច្រើនថ្ងៃ ព្រះរាជាទ្រង់ព្រះតម្រិះថា ពួកអ្នកនគរទាំងនេះនាំគ្នាធ្វើក្រៃលែងឡើងៗ រាល់ៗ ថ្ងៃ នឹងមានពាក្យរិះគន់ថា អើ ពួកអ្នកនគរឈ្នះព្រះរាជាដែលជាធំក្នុងផែនដីបាន ។ ពេលនោះ ព្រះនាងមល្លិកាបានក្រាបទូលឧបាយដល់ព្រះរាជា ។

ព្រះរាជាត្រាស់បង្គាប់ឲ្យយកការសាលព្រឹក្សប្រភេទល្អ មកសាងបារំ ហើយឲ្យយកផ្ការបួលខៀវមកប្រក់ ត្រាស់បង្គាប់ឲ្យក្រាលទីអង្គុយ ៥០០ ផ្នែកខាងក្រោយទីអង្គុយ មានជីវិឈរ ៥០០ ក្នុងជីវិមួយៗ ជាំងស្វេតច្ឆត្រ ដល់កិកូមួយរូប ។ ចន្លោះទីអង្គុយពីមួយទៅមួយ មានខត្តិយធីតាមួយអង្គៗ តាក់តែងកាយដោយគ្រឿងស្អិតស្អាង កិនគ្រឿងក្រអូប ដែលកើតពីឈើ ៤ ប្រភេទ ។ ខត្តិយធីតាអង្គជទៃ ក៏ជាក់គ្រឿងក្រអូប ដែលកិនស្រេចហើយក្នុងស្នូកសម្រាប់ជាក់របស់ក្រអូប ក្នុងទីត្រង់កណ្តាល ។ ខត្តិយធីតាមួយអង្គទៀត ក៏កាន់ឧបួលខៀវ និងគ្រឿងក្រអូបនោះ ដោយប្រការដូច្នេះ កិកូមួយអង្គៗ មានខត្តិយធីតា ៣ អង្គៗ ជាបរិវារ ។ ស្ត្រីម្នាក់ទៀត ដែលតែងគ្រឿងស្អិតស្អាងសព្វគ្រប់ កាន់ផ្ទៃតស្វីកស្នោត ស្ត្រីជទៃយកតម្រងទឹក ស្ត្រីជទៃនាំយកទឹកអំពីជាត្រ ។ ចំណែកព្រះមានព្រះភាគ មានរបស់ ៤ យ៉ាង កាត់ថ្លៃមិនបាន ។ របស់ ៤ យ៉ាង ដែលកាត់ថ្លៃមិនបានទាំងនេះ គឺទីជូតព្រះបាទទ្រនៃក្តារបង្អែក មណីជើងត្រ ។ ទេយ្យធម៌សម្រាប់សង្ឃនាវកៈ មានតម្លៃ ១ សែន ។ ឯក្នុងការថ្វាយទាននោះ ព្រះអង្គលិមាលត្ថេរ បានជាកិកូប្តីក្នុង

សង្ឃ ។ ជិតទីអង្គុយរបស់លោក ជ័រដែលនាំមកហើយ មិនអាចចូលជិតលោកបាន ។ លំដាប់នោះ អ្នកចាត់ចែងការងារក្រាបទូលព្រះរាជា។ ត្រាស់ថា ចូរពួកលោកនាំយកជ័រដទៃមក ។ ជ័រដែលនាំមកហើយនាំមកទៀត ក៏មិនអាចឡើយ ។ ព្រះរាជាត្រាស់ថា មិនមានជ័រដទៃទេឬ ។ អ្នកចាត់ចែងការងារក្រាបទូលថា នៅមានជ័រកាច តែនាំមកមិនបាន ។ ព្រះរាជាទូលសួរព្រះមានព្រះភាគថា កិកុអង្គណាជាកិកុថ្មីក្នុងសង្ឃ ព្រះមានព្រះភាគត្រាស់ថា អង្គុលិមាល ព្រោះដូច្នោះ សូមឲ្យអ្នកចាត់ចែងការងារនាំយកជ័រកាចមកតាំងទុកចុះ ពួកអ្នកចាត់ចែងការងារតាក់តែងជ័រកាច ហើយក៏នាំមក ។ ដោយតេជៈរបស់ព្រះថេរៈ ជ័រនោះ សូម្បីត្រឹមតែធ្វើខ្យល់ឲ្យផុតចុងច្រមុះ ក៏ធ្វើមិនបាន ។ ព្រះរាជាទ្រង់បានថ្វាយទានជាប់តគ្នាប្រាំពីរថ្ងៃ ដោយប្រការដូច្នេះ ។ ក្នុងថ្ងៃទី ៧ ព្រះរាជាទ្រង់ថ្វាយបង្គំ ហើយក្រាបទូលព្រះទសពលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គមេត្តាសម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។

ឯក្នុងបរិស័ទនោះ មានអមាត្យ ២ នាក់ គឺកាឡៈ និងជុណ្ហៈ ។ កាឡៈគិតថា សម្បត្តិរបស់រាជត្រកូលនឹងវិនាស ពួកបុគ្គលមានប្រមាណប៉ុណ្ណេះនឹងធ្វើអ្វី ស៊ីហើយទៅវត្ត ហើយក៏នឹងដេកប៉ុណ្ណោះឯង តែរាជបុរសម្នាក់បានវត្ថុនេះ នឹងមិនធ្វើឬ ឱ សម្បត្តិរបស់ព្រះរាជានឹងវិនាស ។ ជុណ្ហៈគិតថា ដែលឈ្មោះថា ភាពជាព្រះរាជានេះ ធំក្រៃលែង បុគ្គលដទៃណាហ្ន៎ នឹងធ្វើវត្ថុនេះបាន ដែលឈ្មោះថា ព្រះរាជា គឺអ្នកដែលតាំងនៅក្នុងភាពជាព្រះរាជា ហើយទ្រង់ឲ្យទានបែបនោះ មិនបានឬ កាលព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់បរិស័ទ ក៏ទ្រង់ជ្រាបអធ្យាស្រ័យរបស់អ្នកទាំងពីរនោះ ទើប

ទ្រង់ព្រះតម្រិះថា ប្រសិនបើតថាគតនឹងសម្តែងធម៌តាមអធ្យាស្រ័យរបស់ជុណ្ហៈក្នុងថ្ងៃនេះ ក្បាលរបស់កាឡៈ នឹងបែកជា ៧ ភាគ តថាគតបំពេញបារមីក៏ដោយសេចក្តីអាណិតសត្វ សូម្បីក្នុងថ្ងៃដទៃ កាលតថាគតសម្តែងធម៌ ជុណ្ហៈក៏គង់នឹងសម្រេចមគ្គផល គ្រានេះ តថាគតឃើញដល់កាឡៈ ហើយបានត្រាស់គាថា ៤ បាទប៉ុណ្ណោះ ដល់ព្រះរាជាថា

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ
ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នក
ប្រាជ្ញតែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបាន
សេចក្តីសុខ ក្នុងលោកខាងមុខ ។

ព្រះរាជា ទ្រង់មិនពេញព្រះរាជហឫទ័យថាអញថ្វាយទានយ៉ាងធំសម្បើមតែព្រះសាស្តា ទ្រង់សម្តែងធម៌ដល់អញតែបន្តិចបន្តួច អញមិនអាចយកព្រះហឫទ័យរបស់ព្រះទសពលបានទេដឹង កាលសោយព្រះក្រយាហារព្រឹកស្រេចហើយ ព្រះរាជាក៏យាងទៅកាន់វត្ត ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ទូលសួរថា ខ្ញុំព្រះអង្គថ្វាយមហាទាន តែព្រះអង្គទ្រង់ធ្វើអនុមោទនាដល់ខ្ញុំព្រះអង្គមិនច្រើន ខ្ញុំព្រះអង្គមានកំហុសអ្វីឬ ។ ព្រះសាស្តាត្រាស់ថា ទ្រង់គ្មានកំហុសអ្វីឡើយ តែបរិស័ទមិនស្អាត ព្រោះដូច្នោះ ទើបតថាគតមិនសម្តែងធម៌ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុដូចម្តេច ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថាបរិស័ទមិនស្អាត ។ ព្រះសាស្តាត្រាស់ប្រាប់បរិវិតក្កបស់អមាត្យ ។ ព្រះរាជាត្រាស់សួរកាឡៈថា យ៉ាងនោះឬ បាកាឡៈ ។ កាឡអមាត្យទូលថា យ៉ាងនោះមែនមហារាជ ។ ព្រះរាជាត្រាស់ថា កាលយើងឲ្យទ្រព្យរបស់យើង អ្នក

នឹងក្តៅក្រហាយដូចម្តេច យើងមិនអាចមើលអ្នកបាន ពួកអ្នកចូរបណ្តេញអមាត្យនេះ ចេញពីដែនរបស់យើង ។ បន្ទាប់ពីនោះ ត្រាស់ហៅជុណ្ហៈមកសួរថា បានឮថា បាគិតយ៉ាងនោះឬ ។ ជុណ្ហអមាត្យទូលថា យ៉ាងនោះឯង ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ចូរធ្វើតាមចិត្តអ្នកចុះ ចូរអ្នកនិមន្តភិក្ខុ ៥០០ អង្គមកអង្គុយលើទីអង្គុយ ដែលក្រាលទុកក្នុងបារំទុំឯង ហើយឲ្យខត្តិយធីតាទាំងនោះឯង ហែហមយកទ្រព្យពីព្រះរាជវាំងមកថ្វាយទានប្រាំពីរថ្ងៃ ដូចដែលយើងថ្វាយចុះ ជុណ្ហអមាត្យបានធ្វើយ៉ាងនោះហើយ ។ លុះថ្វាយសម្រេចហើយ ក្នុងថ្ងៃទី ៧ ក៏ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាទានទាំងពីរ ឲ្យដូចគ្នាតែមួយ ដូចទ្រង់ធ្វើស្ទឹងធំពីរខ្សែ ឲ្យពេញដោយជំនន់ទឹកតែមួយ ទ្រង់សម្តែងមហាធម្មទេសនា ។ កាលចប់ទេសនា ជុណ្ហៈក៏បានជាព្រះសោតាបន្ន ។ ព្រះរាជាទ្រង់ជ្រះថ្លា ទ្រង់ថ្វាយសំពត់ ឈ្មោះបាវាយចំពោះព្រះទសពល ។ គប្បីជ្រាបថា លាភសម្រេចក្រៃលែងចំពោះព្រះមានព្រះភាគអង្គនោះ ដោយអាការយ៉ាងនេះ ។

បទថា **អភិបូជ្ជោ សិលោកោ** *គឺការសរសើរដល់ព្រះកិត្តិគុណ ។ ព្រះកិត្តិសព្ទនោះ ក៏សម្រេចយ៉ាងក្រៃលែងចំពោះព្រះមានព្រះភាគ តាំងពីទ្រង់បង្វិលធម្មចក្រឲ្យប្រព្រឹត្តទៅ ។ ពិតហើយ តាំងអំពីនោះមក ពួកក្សត្រក៏និយាយដល់ព្រះកិត្តិសព្ទរបស់ព្រះមានព្រះភាគ ដល់ពួកព្រាហ្មណ៍ ពួកគហបតី ពួកនាគ ពួកគ្រុឌ ពួកគន្ធព្វ ពួកទេវតា ពួកព្រហ្ម ក៏ពោលដល់ព្រះកិត្តិសព្ទ ហើយសរសើរដោយពាក្យថា* **ឥតិបិ សោ ភគវា** *សូម្បីពួកតិរ្ថិយឲ្យទ្រព្យ ១*

ពាន់ដល់វារវោជ: ហើយបញ្ជូនទៅថា ចូរអ្នកពោលទោសព្រះសមណគោតម ។ បុរសនោះទទួលទ្រព្យ ๑ ពាន់ហើយ ក៏ពិចារណាមើលព្រះទសពល តាំងពីផ្ទៃព្រះបាទទល់នឹងចុងព្រះកេសា ទោសត្រឹមតែ ๑ លិក្ខា[๑] ក៏មិនឃើញមាន ទើបគិតថា អ្នកដែលបែរត្រឡប់មាត់និយាយដល់ទោសក្នុងអត្តភាព ដែលរកទោសមិនបាន ដែលពោរពេញទៅដោយមហាបុរិសលក្ខណៈ ๓๒ ប្រការ ប្រដាប់ដោយអនុព្យញ្ជន: ๘๐ ហែហមទៅដោយរស្មីមួយព្យាម ដូចបាវិច្ឆត្តក: ដែលរីក ដូចផ្ទៃមេឃដែលរុងរឿងដោយពួកផ្កាយ និងនន្ទវន ដែលស្រស់ល្អទៅដោយផ្កាដ៏វិចិត្រ ដូច្នេះ ក្បាលត្រូវបែកជា ๗ ភាគ ឧបាយដែលនឹងពោលតិះដៀល ក៏មិនមាន អញនឹងពោលសរសើរប៉ុណ្ណោះ ដូច្នេះហើយ ក៏ពោលសរសើរតែម្យ៉ាង តាំងពីផ្ទៃព្រះបាទរហូតដល់ចុងព្រះកេសា ដោយពាក្យជាង ๑ ពាន់បទ ។ ឈ្មោះថា កិត្តិសព្ទនោះដល់កំពូល ក្នុងរឿងយមកប្បាដិហារ្យ ព្រះកិត្តិសព្ទសម្រេចយ៉ាងក្រៃលែង ដូចពោលមក ដោយប្រការដូច្នេះ ។ បទថា **យាវ មញ្ញេ ខត្តិយា** *សេចក្តីថា ពួកមនុស្សទាំងអស់ គឺព្រាហ្មណ៍ វេស្សៈ សូទ្រៈ នាគ គ្រុឌ អសុរ ទេវតា ព្រហ្ម សុទ្ធតែជាអ្នកស្រឡាញ់ រីករាយពេញចិត្តទាំងអស់គ្នា ។*

បទថា **កតមេនោ เอวา បน** *គឺទ្រង់មិនមែនជាបុគ្គលស្រវឹង ប្រមាទថា ពួកជនមានប្រមាណប៉ុណ្ណោះ ជាអ្នកស្រឡាញ់តថាគត ហើយសោយព្រះក្រយាហារ ដោយការលេងជាដើម ការពិត ព្រះមានព្រះភាគអង្គនោះទ្រង់ប្រាសចាកសេចក្តីស្រវឹង សោយព្រះក្រយាហារ ។ បទថា* **យថាฯลฯ**

๑- ๑ លិក្ខា គឺប្រវែង ๑ ពង់ចៃ ។

សេចក្តីថា ត្រាស់ពាក្យណាដោយព្រះវាចា ករណីយកិច្ចតាមផ្លូវកាយរបស់ព្រះអង្គ ក៏ស្របតាមព្រះវាចានោះពិតៗ និងករណីយកិច្ច ដែលទ្រង់ធ្វើដោយព្រះកាយ ករណីយកិច្ចផ្លូវព្រះវាចារបស់ព្រះអង្គ ក៏ស្របតាមព្រះកាយដោយពិត ព្រះកាយមិនឈានកន្លងព្រះវាចា ឬព្រះវាចា ក៏មិនឈានកន្លងព្រះកាយ ព្រះវាចាសមនឹងព្រះកាយ ព្រះកាយក៏សមនឹងព្រះវាចា ។ ដូចសេចក្តីថា

ខាងឆ្វេងជាជ្រូក ខាងស្តាំជាពពែ ដោយសំឡេង ជាចៀម ដោយស្នែងជាគោចាស់ ដូច្នេះ ។

សូករយក្ខនេះ កាលឃើញហ្វូងជ្រូក ក៏បង្ហាញផ្នែកខាងឆ្វេងដូចជ្រូក ហើយក៏ចាប់ជ្រូកទាំងនោះបរិភោគ កាលឃើញហ្វូងពពែ ក៏បង្ហាញផ្នែកខាងស្តាំដូចពពែនោះ ហើយក៏ចាប់ពពែទាំងនោះបរិភោគ កាលឃើញហ្វូងកូនចៀម ក៏ស្រែកជាសំឡេងរបស់កូនចៀម ហើយក៏ចាប់កូនចៀមទាំងនោះបរិភោគ ពេលឃើញហ្វូងគោ ក៏និម្មិតស្នែងឲ្យដូចស្នែងរបស់គោទាំងនោះ មើលពីចម្ងាយ ក៏ឃើញដូចគោ ដោយប្រការដូច្នេះ ក៏ចាប់គោទាំងនោះដែលចូលមកជិត បរិភោគយ៉ាងណា និងដូចក្អែក ក្នុងធម្មទ្ធជជាតក ទ្រទ្រង់ធម៌ដែលពួកបក្សីសួរ ក៏ច្រាប់ថា ខ្ញុំជាក្អែកហាមាត់ស៊ីខ្យល់ ឈរដោយជើងតែម្ខាងប៉ុណ្ណោះ ព្រោះខ្លាចជាន់សត្វស្លាប់ ព្រោះដូច្នោះ សូម្បីពួកអ្នក ក៏ចូរប្រព្រឹត្តធម៌ ហើយពោលនូវគាថាថា

ម្នាលញាតិទាំងឡាយ អ្នកទាំងឡាយ ចូរប្រព្រឹត្តធម៌ អ្នកទាំងឡាយ ចូរប្រព្រឹត្តធម៌ សេចក្តីចម្រើន (នឹងមាន) ដល់អ្នកទាំងឡាយ អ្នកប្រព្រឹត្តធម៌រមែងដេកជាសុខ ក្នុងលោក

នេះ និងលោកខាងមុខ ។

បក្សីទាំងឡាយ សរសើរក្អែកថា

សត្វស្វាបមានកំណើតពីរនេះ ប្រសើរណាស់តើ ជាអ្នក
ប្រកបដោយពណ៌ដ៏ក្រៃលែង ឈរតែជើងម្ខាង ប្រឿន
ប្រដៅតែធម៌ ។

កាលធ្វើឲ្យពួកបក្សីទុកចិត្តហើយ បន្ទាប់អំពីនោះ ក៏បរិភោគស៊ុត និងកូនបក្សី ដែលធ្វេសប្រហែសហើយ ។ វាចារបស់សូករយក្ខ និងក្អែកនោះ មិនសមនឹងកាយ ឯកាយ មិនសមនឹងវាចាយ៉ាងណា របស់ព្រះមានព្រះភាគ មិនដូច្នោះទេ្បីយ លោកសម្តែងថា ព្រោះព្រះវាចារបស់ព្រះមានព្រះភាគ សមនឹងព្រះកាយ ឯព្រះកាយក៏សមនឹងព្រះវាចា ដោយពិត ដូច្នេះ ។

ឈ្មោះថា **តិណ្ណាវិចិកិច្ឆោ** *ព្រោះព្រះអង្គទ្រង់កន្ទង គឺទ្រង់ឆ្លងសេចក្តីសង្ស័យបានហើយ ។ ឈ្មោះថា* **វិគតកថំកថោ** *ព្រោះព្រះអង្គប្រាសចាកការសួរឿងរ៉ាវផ្សេងៗ ដូច្នេះថា នេះជាអ្វី នេះជាអ្វី ។ ពិតហើយ ព្រះសាស្តាមិនដូចមនុស្សចំនួនច្រើន ដែលនៅមានសេចក្តីសង្ស័យថា ដើមឈើនេះ ឈ្មោះដើមអ្វី តំបន់នេះឈ្មោះតំបន់អ្វី ស្រុកនេះឈ្មោះស្រុកអ្វី ដែននេះឈ្មោះដែនអ្វី ហេតុដូចម្តេច ទើបដើមឈើនេះ មានដើមត្រង់ ដើមឈើនេះមានដើមវៀច ដើមឈើនេះមានបន្ទា ដើមឈើនេះខ្លះត្រង់ ខ្លះវៀច ខ្លះផ្តាក្រអូប ខ្លះផ្តាស្អុយ ខ្លះផ្លែផ្អែម ខ្លះផ្លែមិនផ្អែម ។ ពិតហើយ ព្រះសាស្តាទ្រង់ជ្រាបថា ព្រោះធាតុទាំងនេះច្រើន ទើបវត្ថុនេះយ៉ាងនេះ ទើបទ្រង់ជាអ្នកប្រាសចាកការសួរឿងរ៉ាវផ្សេងៗដោយពិត ។ ម្យ៉ាងទៀត ចំពោះព្រះពុទ្ធ ទ្រង់ក៏មិនដូចអ្នកដែលបាន*

ឈានទី ๑ ជាដើម មានសេចក្តីសង្ស័យក្នុងឈានទី ២ ជាដើម និងសូម្បីព្រះបច្ចេកពុទ្ធ ក៏នៅមានសេចក្តីសង្ស័យ ដោយអំណាចវោហារដោយពិត ព្រោះមិនទាន់មានការដល់ព្រមតាមសេចក្តីជាពិតដោយសព្វញ្ញុតញ្ញាណ ទើបសក្កទេវរាជសម្តែងថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ប្រាសចាកការសួរថា នេះជាអ្វី នេះជាអ្វី ក្នុងវត្តុគ្រប់យ៉ាងដូច្នេះ ។

បទថា **បរិយោសិតសង្កប្បោ** *គឺព្រះសាស្តានៃយើង មិនដូចមនុស្សពួកខ្លះ ដែលចប់ការគិត គឺពេញមនោរថត្រឹមតែសីល ខ្លះត្រឹមតែវិបស្សនា ខ្លះត្រឹមតែបឋមជ្ឈាន ។បេ។ ខ្លះត្រឹមតែនេវសញ្ញានាសញ្ញាសមាបត្តិ ខ្លះត្រឹមតែភាពជាសោតាបន្ន ខ្លះត្រឹមតែអរហត្តមគ្គ ខ្លះត្រឹមតែសាវកបារមីញ្ញាណ ខ្លះត្រឹមតែបច្ចេកពោធិញ្ញាណ ។ សក្កទេវរាជ ទ្រង់បញ្ជាក់ថា ចំណែកព្រះសាស្តានៃយើង មានតម្រិះដល់ទីបំផុត ដោយសព្វញ្ញុតញ្ញាណ ។ បទថា* **អជ្ឈាសយំ អាទិព្រហ្មចរិយំ** *ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា ទ្រង់ឆ្លងសេចក្តីសង្ស័យបាន ទ្រង់ប្រាសចាកការសួរថា នេះអ្វី នេះអ្វី ទ្រង់ដល់ទីបំផុតហើយនៃសេចក្តីត្រិះរិះ ដោយបដិបទាដែលជាខាងដើមនៃព្រហ្មចរិយៈ ដែលជាទីអាស្រ័យយ៉ាងក្រៃលែង គឺជាទីអាស្រ័យដ៏ឧត្តម និងដោយអរិយមគ្គ ដែលជាបុព្វណាព្រហ្មចរិយៈ ។ ភាពដែលព្រះមានព្រះភាគ ទ្រង់បញ្ចប់សេចក្តីត្រិះរិះហើយ ឈ្មោះថា សម្រេចហើយដោយអរិយមគ្គនុ៎ះឯង ព្រោះព្រះបាលីថា ត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងវត្តុដែលទ្រង់មិនបានស្តាប់មកអំពីមុន និងទ្រង់សម្រេចភាពជាអ្នកត្រាស់ដឹងគ្រប់យ៉ាង ក្នុងវត្តុទាំងនោះ និងទ្រង់សម្រេចភាពជាអ្នកស្ទាត់ជំនាញក្នុងធម៌*

ដែលជាកម្ចាំងទាំងឡាយ ។

[៥០] *បទថា* **យថិវេ ភគវា** *គឺព្រះមានព្រះភាគទុំ៎ះឯង យ៉ាងណា ។ បុគ្គលទាំងឡាយទន្ទឹងថា ឱហ្ន៎ ព្រះជិនស្រី ៤ ព្រះអង្គ គប្បីត្រាច់ចារិកសម្តែងធម៌ក្នុងទិសទាំង ៤ លើផ្ទៃជម្ពូទ្វីបតែមួយ ។ តមកបុគ្គលពួកដទៃប្រាថ្នាការយាងទៅជាមួយគ្នាក្នុង ៣ មណ្ឌល ក៏ពោលថា ព្រះសម្មាសម្ពុទ្ធ ៣ ព្រះអង្គ ។ បុគ្គលមួយពួកទៀតគិតថា ការបំពេញបារមី ដរាបដល់គ្រប់ ១០ ហើយត្រាស់ជាព្រះពុទ្ធ ៤ ឬ ៣ ព្រះអង្គ លំបាកនឹងរកបាន តែបើព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ គប្បីគង់ប្រចាំសម្តែងធម៌ ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គស្តេចយាងទៅ សូម្បីដូច្នេះ ជម្ពូទ្វីបក៏នឹងគប្បីស្រស់ល្អ នឹងគប្បីសម្រេចហិតសុខដ៏ច្រើនដោយពិត ទើបពោលថា ឱហ្ន៎ លោកអ្នកនិទ្ទុក្ខទាំងឡាយ ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា* **អដ្ឋានមេតំ អនវកាសោ** *ដូច្នេះ ពាក្យទាំង ២ នេះ គឺហាន ១ អវកាស ១ ជាឈ្មោះរបស់ហេតុទុំ៎ះឯង ។ ពិតហើយ ហេតុ ឈ្មោះថា ហាន ព្រោះផលរមែងតាំងនៅក្នុងទីនោះ ព្រោះផលជារបស់ប្រព្រឹត្តទៅជាប់ទាក់ទងជាមួយហេតុនោះ ឯហេតុនោះ ក៏ដូចគ្នានឹងឱកាស ទើបឈ្មោះថា អវកាស ព្រោះភាពដែលផលនោះរៀវឱកាសនោះចេញហើយមិនមានក្នុងទីដទៃទៀត ។ បទថា* **យំ** *ជាបឋមាវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ មានពាក្យដែលសក្តទេវរាជទ្រង់អធិប្បាយដូច្នេះថា ក្នុងលោកធាតុមួយ ព្រះពុទ្ធ ២ ព្រះអង្គ ទ្រង់គប្បីកើតឡើង ព្រមគ្នាដោយហេតុណា ហេតុនោះមិនមាន ។ ម្យ៉ាងទៀត ចក្រវាលមួយប៉ុណ្ណោះ ឈ្មោះថា លោកធាតុ មួយ ក្នុងគាថានេះថា*

ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺបានត្រឹមណា លោក គឺចក្រវាលទាំងមួយពាន់ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅ បានតែត្រឹមចក្រវាលមួយពាន់នុ៎ះ ។

ចក្រវាល ១ ពាន់ ឈ្មោះថា លោកធាតុ ក្នុងអាគតដ្ឋានថា លោកធាតុ ១ ពាន់ បានញាប់ញ័រហើយ ។ តិសហស្សីមហាសហស្សីចក្រវាល ឈ្មោះថា មួយលោកធាតុ ក្នុងអាគតដ្ឋានថា ម្នាលអានន្ទ កាលបើតថាគតប្រាថ្នាដើម្បីញ៉ាំងតិសហស្សីមហាសហស្សីលោកធាតុ[1] ឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថា គប្បីប្រាថ្នាដល់ត្រឹមណាក៏បាន ។ ចក្រវាល ១ ម៉ឺន ឈ្មោះថា លោកធាតុ ដូចក្នុងអគតដ្ឋានថា លោកធាតុ មួយទៀតលោកធាតុទាំង ១ ម៉ឺននេះ ។ ព្រះមានព្រះភាគនោះ ទ្រង់សំដៅដល់លោកធាតុ ១ ម៉ឺននោះ ទើបត្រាស់ថា ក្នុងលោកធាតុ ១ ដូច្នេះ ។ លោកធាតុ ១ ម៉ឺននេះ ឈ្មោះថា ជាតិក្ខេត្ត ។ សូម្បីក្នុងជាតិក្ខេត្តនោះ វៀរមជ្ឈិមប្រទេសនៃជម្ពូទ្វីប ក្នុងចក្រវាលនេះហើយ ក្នុងប្រទេសជនៃ ព្រះពុទ្ធទាំងឡាយទ្រង់មិនបានកើតឡើងឡើយ ផុតពីជាតិក្ខេត្តទៅ មិនប្រាកដជា មានការកើតឡើងនៃព្រះពុទ្ធទាំងឡាយឡើយ ។

๑- ព្រះអាទិត្យ ព្រះចន្ទ ភ្លឺត្រឹមណា ត្រឹមនោះ ជាលោកធាតុ ១ ឬចក្រវាល ១ ។ ចក្រវាលនោះ ១ ពាន់ហៅថា សហស្សីចូឡនិកាលោកធាតុ ។ សហស្សីចូឡនិកាលោកធាតុនោះ ១ ពាន់ដង ហៅថា ទ្វិសហស្សីមជ្ឈិមិកាលោកធាតុ ។ ទ្វិសហស្សីមជ្ឈិមិកាលោកធាតុនោះ ១ ពាន់ដង ហៅថា តិសហស្សីមហាសហស្សីលោកធាតុ ។

បទថា **យេនត្ថេន** *គឺដោយប្រយោជន៍នៃបវារណាសង្គហៈណា ។*

[๕๔] *បទថា* **វណ្ណេន เจว យสสา จ** *សេចក្តីថា ដោយគ្រឿងតែងខ្លួន និងបរិវារ និងដោយបុញ្ញសិរី ។*

[๕๖] **สาธุ** *សព្ទ ប្រព្រឹត្តទៅក្នុងសេចក្តីជ្រះថ្លា ក្នុងបទនេះថា សាធុ មហាព្រហ្ម ។ បទថា* **สงฺฆาย โมทามห** *គឺដឹងហើយ ទើបត្រេកអរ ។ បុគ្គលណាម្នាក់មិនអាចកំណត់ថា ប៉ុណ្ណេះ ហើយពោលបានថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានព្រះបញ្ញាដ៏ធំក្រៃលែងមកយូរ ពីត្រឹមណាមក ការពិត ព្រះមានព្រះភាគនៃយើងអង្គនោះ ទ្រង់មានព្រះបញ្ញាដ៏ធំក្រៃលែងមកអស់កាលដ៏យូរ គឺយូរណាស់មកហើយ ព្រោះដូច្នោះ ពួកលោកនឹងសម្គាល់យ៉ាងណា ពេលនោះ សនង្កុមារព្រហ្មមានបំណងនឹងដោះស្រាយបញ្ហានោះដោយខ្លួនឯង ទើបពោលថា អ្នកនិទ្ទុក្ខទាំងឡាយ មិនគួរអស្ចារ្យឡើយដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមី ទម្លាយកំពូលមារទាំង ៣ ត្រង់ពោធិបល្ល័ង្ក ទ្រង់មានព្រះញាណមិនទូទៅ ដែលទ្រង់ត្រាស់ដឹងហើយ គប្បីក្លាយជាអ្នកមានព្រះបញ្ញាធំក្រៃលែង ក្នុងកាលឥឡូវនេះ តើនឹងអស្ចារ្យអ្វី ។ នែសម្លាញ់ ខ្ញុំនឹងប្រាប់ពួកអ្នក ដល់ភាពដែលព្រះអង្គតាំងនៅក្នុងបទេ-សញ្ញាណ នៃព្រះពោធិញ្ញាណ ដែលមិនទាន់ចាស់ក្លា ទ្រង់មានបញ្ញាធំក្រៃលែងពិតៗ សូម្បីក្នុងវេលាដែលទ្រង់នៅមានរាគៈជាដើម កាលសនង្កុមារព្រហ្មនាំយកហេតុការណ៍ ដែលត្រូវកពបិទបាំងមកសម្តែង ទើបពោលពាក្យជាដើមថា* **ภูตปุพฺพํ เภา** *ដូច្នេះ ។*

[๕๗] បទថា **បុរោហិតោ** គឺទីប្រឹក្សាសម្រាប់ទូន្មានកិច្ចគ្រប់យ៉ាង ។ បទថា **គោវិន្ទោ** គឺបានទទួលអភិសេក ដោយការអភិសេកឲ្យជាធំក្នុងផែនដី ។ ដោយប្រក្រតី បុរោហិតនោះមានឈ្មោះដទៃៗ ដោយពិត លុះបានទទួលអភិសេកហើយ ក៏ដល់នូវការរាប់ថា ជាគោវិន្ទ ។ បទថា **ជោតិបាលោ** គឺឈ្មោះថា ជោតិបាល ព្រោះមានពន្លឺ និងព្រោះរក្សា ។

បានឮថា ក្នុងថ្ងៃដែលជោតិបាលកើតនោះ អាវុធគ្រប់ប្រភេទ ក៏ភ្លឺសន្ធោសន្ធៅ ។ ព្រះរាជា កាលទ្រង់ឃើញពន្លឺមង្គលាវុធរបស់ព្រះអង្គភ្លឺសន្ធោសន្ធៅ ក្នុងវេលាជិតភ្លឺ ក៏ទ្រង់តក់ស្លុត ហើយប្រថាប់ឈរ ។ គោវិន្ទទៅគាល់ព្រះរាជាអំពីព្រលឹម ក្រាបទូលសួរការផ្ទំជាសុខ ។ ព្រះរាជាត្រាស់ឆ្លើយថា លោកអាចារ្យ ខ្ញុំដេកជាសុខបានអំពីណា ហើយទ្រង់ក៏ប្រាប់ហេតុនោះ ។ គោវិន្ទព្រាហ្មណ៍ទូលថា បពិត្រមហារាជ សូមទ្រង់កុំខ្វាចឡើយ កូនប្រុសទូលបង្គំកើតហើយ ដោយអានុភាពរបស់ទារកនោះ អាវុធទាំងឡាយក៏ភ្លឺពេញព្រះនគរ ។ ព្រះរាជាទ្រង់គិតថា កុមារនេះ នឹងគប្បីជាសត្រូវដល់អញឬហ្ន៎ ហើយក៏រីងរឹតតែខ្លាច ។ កាលទ្រង់ត្រូវទូលសួរថា បពិត្រមហារាជ ព្រះអង្គទ្រង់គិតអ្វី ក៏ត្រាស់ប្រាប់សេចក្តីនោះ ។ ពេលនោះ គោវិន្ទបានក្រាបទូលព្រះរាជាថា បពិម្រហារាជ សូមទ្រង់កុំខ្វាចឡើយ កុមារនេះ មិនប្រទូស្តព្រះអង្គឡើយ តែក្នុងជម្ពូទ្វីបទាំងមូលមិនមានបុគ្គលណាមួយ មានបញ្ញាស្មើទារកនោះឡើយ សេចក្តីសង្ស័យរបស់មហាជន នឹងអស់ទៅ ព្រោះពាក្យរបស់កូនប្រុសទូលបង្គំ ទារកនោះនឹងទូន្មានកិច្ចគ្រប់យ៉ាងជូនព្រះអង្គ ហើយក៏លួងលោមព្រះរាជា ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ត្រាស់ថា ចូរឲ្យតម្លៃ

ទឹកដោះដល់កុមារ ហើយព្រះរាជទានទ្រព្យមួយពាន់ ត្រាស់ថា ចូរបង្ហាញកុមារនោះដល់យើង ក្នុងវេលាដែលកុមារនោះធំ ។ កុមារដល់នូវការធំលូតលាស់ ដោយលំដាប់ ។ ព្រោះភាពដែលកុមារនោះ ជាអ្នកនាំមកនូវពន្ធឺ និង ជាអ្នកអាចក្នុងការរក្សា ទើបឪពុកម្តាយដាក់ឈ្មោះថា ជោតិបាល ។ ព្រោះ ហេតុនោះ ទើបលោកពោលថា ជោតិបាល ព្រោះមានពន្ធឺ និងព្រោះការ រក្សា ដូច្នេះ ។

បទថា **សម្មោសដ្ឋិភ្វា** *គឺលះបង់បានដោយប្រពៃ ។ ឬបទថា* **សម្ម-ោសដ្ឋិភ្វា** *ជាបាឋៈ ។ បទថា* **អលមត្តទសតរោ** *គឺព្រោះជាអ្នកអាច អាច ហ៊ាន ជាអ្នកឃើញសេចក្តី ទើបឈ្មោះថា ជាអ្នកអាចឃើញសេចក្តី ឈ្មោះថា ជាអ្នកអាចឃើញ និងពិចារណាសេចក្តី ព្រោះរមែងពិចារណាសេចក្តីនោះ ។ ដោយបទថា* **ជោតិចាលស្សេវ មាណវស្ស អនុសាសនិយា** *លោកសម្តែងថា សូម្បីព្រះរាជានោះ ក៏ទ្រង់សួរជោតិបាលនុ៎ះឯងហើយ ទើបទ្រង់គ្រប់គ្រង ។ បទថា* **ភវមត្តុ ភវន្តំ ជោតិចាលំ** *សេចក្តីថា ភាពនៃសេចក្តីចម្រើន ការ សម្រេចគុណវិសេស សេចក្តីល្អ និងមហាមង្គលទាំងអស់ ចូរមានដល់ ជោតិបាលដ៏ចម្រើន ។*

បទថា **សម្មោទនីយកថំ** *គឺចប់ពាក្យបដិសណ្ឋារៈ ដែលជាគ្រឿងបន្ទោ បង់នូវសោក សម្បយុត្តដោយសេចក្តីស្ងប់ ដោយនយជាដើមថា កុំឡើយ មហារាជទ្រង់កុំគិតឡើយ នេះជារបស់ពិតសម្រាប់សព្វសត្វ ។ បទថា* **មាន ណោ ភវំ ជោតិចាលោ មាណវោ អនុសាសនិយា បច្ចព្យាហាសិ** *សេចក្តីថា កុំឲ្យវិនាសចាកពាក្យទូន្មាន អធិប្បាយថា កាលត្រូវសូមអង្វរថា ចូរទូន្មាន*

ក៏កុំបោះបង់ចោលពួកយើងពីពាក្យទូន្មាន ដោយនិយាយថា ខ្ញុំនឹងមិនទូន្មាន ។ បទថា **អភិសម្ភោសិ** *គឺចាត់ចែងតែងតាំង ។*

បទថា **មនុស្សា ឱរមាហំសុ** *សេចក្តីថា កាលពួកមនុស្សយើញជោតិ-បាលនោះមានបញ្ញាច្រើនជាងឪពុក ទូន្មានកិច្ចគ្រប់ប្រភេទ ចាត់ចែងការងារគ្រប់យ៉ាង ក៏មានចិត្តត្រេកអរ ពោលយ៉ាងនេះថា អើហ្ន៎ មើលចុះគោវិន្ទ-ព្រាហ្មណ៍ អើហ្ន៎ មើលចុះមហាគោវិន្ទព្រាហ្មណ៍ មានពាក្យដែលលោកអធិប្បាយយ៉ាងនេះថា លោកដ៏ចម្រើន គោវិន្ទព្រាហ្មណ៍ជាបិតារបស់បុរសនេះ ចំណែកបុរសនេះ ជាមហាគោវិន្ទព្រាហ្មណ៍ ។*

[๕๘] *បទថា* **យេន តេ ឆ ខត្តិយា** *គឺក្សត្រ ៦ អង្គ ដែលលោកពោលថា ជាសម្ចាញ់ ។ បានឮថា ក្សត្រទាំងនោះ រួមព្រះបិតានឹងព្រះបាទវេណុ ទ្រង់ជាបួន ព្រោះដូច្នោះ ទើបមហាគោវិន្ទ គិតថា ព្រះបាទវេណុនេះ ទ្រង់បានទទួលអភិសេកហើយ នឹងបែងចែក ឬមិនបែងចែករាជសម្បត្តិដល់ក្សត្រទាំង ៦ អង្គនោះ បើដូច្នោះ អញត្រូវបញ្ជូនក្សត្រទាំងនោះ ទៅកាន់សម្នាក់របស់ព្រះបាទវេណុដោយប្រញាប់ ហើយធ្វើឲ្យព្រះបាទវេណុ ទ្រង់ទទួលពាក្យប្តេជ្ញាឲ្យបាន ទើបចូលគាល់ក្សត្រទាំង ៦ អង្គនោះដល់ទីប្រថាប់ ។ បទថា* **រាជកត្តារោ** *បានដល់ ពួកអ្នករាជការ គឺពួកអមាត្យ ។ បទថា* **មទនីយាកាមា** *សេចក្តីថា កាមទាំងឡាយ ធ្វើឲ្យស្រវឹង ធ្វើឲ្យប្រមាទ អធិប្បាយថា កាលបើវេលាកន្លងទៅៗ ព្រះបាទវេណុនេះ មិនអាចដើម្បីតាមរឭកដល់ ។ ព្រោះដូច្នោះ លោកដ៏ចម្រើនទាំងឡាយចូរមក គឺចូរធ្វើដំណើរមក ។ បទថា* **សរាមហំ ភោ** *គឺបានឮថា ភ្លោនោះ ជាវេលាដែលពួកអ្នកត្រូវ*

និយាយការពិតជល់គ្នានិងគ្នា ព្រោះដូច្នោះ ទើបព្រះបាទវេណុ មិនត្រាស់ពាក្យមិនពិតថា យើងនិយាយក្នុងកាលណា នរណាបានឃើញ នរណាបានឮ (តែ) ត្រាស់ថា ម្នាលអ្នកដ៏ចម្រើន យើងនៅចាំបាន ។

បទថា **សម្ពោធនីយំ ករំ** *គឺពាក្យទទួលបែបនេះថា មហារាជ កាលព្រះរាជាស្តេចសុគតហើយ ព្រះអង្គទ្រង់កុំគិតអ្វី នេះជាវត្តពិតរបស់សព្វសត្វសង្ខារទាំងឡាយមានសភាពយ៉ាងនេះ ។ បទថា* **សព្ពានិ សកជមុខានិ បដ្ឋបេសិ** *គឺតម្កល់ទុកនូវដែនទាំង ៦ ជាផ្លូវរទេះ ។ ព្រះរាជាមួយអង្គ មានរាជសម្បត្តិ ៣០០ យោជន៍ ប្រទេសដែលជាទីរួមនៃរាជសម្បត្តិរបស់ព្រះបាទវេណុ ១០ គាវុត ។ រាជសម្បត្តិរបស់ព្រះបាទវេណុ នៅត្រង់កណ្តាលដូចជាពិតាន ។ សួរថា ហេតុអ្វី ទើបតាំងទុកយ៉ាងនេះ ឆ្លើយថា ព្រោះក្សត្រទាំង-ឡាយ កាលមកគាល់ព្រះរាជាម្តងម្កាល នឹងមិនបៀតបៀនរាជសម្បត្តិរបស់ក្សត្រអង្គដទៃ ទ្រង់មក និងទៅដោយប្រទេសរៀងៗ ខ្លួនប៉ុណ្ណោះ ព្រោះកាលទ្រង់ធ្លាក់ចុះកាន់រាជសម្បត្តិរបស់អង្គដទៃ ហើយត្រាស់ថា ពួកលោកចូរឲ្យអាហារ ចូរឲ្យគោ ពួកមនុស្សក៏នឹងលើកទោស ព្រះរាជាទាំងនេះមិនយាងទៅផ្លូវព្រំដែនរបស់ខ្លួន ទ្រង់រមែងធ្វើការបៀតបៀនពួកយើង ។ តែកាលស្តេចទៅផ្លូវព្រំដែនរបស់ខ្លួន ពួកមនុស្សក៏រមែងមិនសម្គាល់ការបៀតបៀនថា ព្រះរាជាអង្គនេះ នឹងត្រូវបានវត្តនេះ និងវត្តនេះ ពីសម្នាក់របស់ពួកយើងនោះឯង ។ មហាគោវិន្ទព្រហ្មជល់សេចក្តីនេះ ទើបចែកយ៉ាងនេះថា កាលពួកព្រះរាជាទ្រង់រីករាយព្រមព្រៀងគ្នា ចូរគ្រប់គ្រងរាជសម្បត្តិ ឲ្យយឺនយូរចុះ ដូច្នេះ ។ នគរ ៧ កន្លែងនេះ គឺ*

[๕๙] ក្រុងទន្តបុរៈសម្រាប់ពួកអ្នកដែនកលិង្គៈ ๑ ក្រុងបោតនៈសម្រាប់ពួកអ្នកដែនអស្សកៈ ๑ ក្រុងមហិស្សតិសម្រាប់ពួកអ្នកដែនអវន្តិ ๑ ក្រុងរោរុកៈសម្រាប់ពួកអ្នកដែនសោចិរៈ ๑ ក្រុងមិថិលាសម្រាប់ពួកអ្នកដែនវិទេហៈ ๑ ក្រុងចម្បាដែលកសាងក្នុងដែនឈ្មោះអង្គៈ ๑ ក្រុងពារាណសីសម្រាប់ពួកអ្នកដែនកាសី ๑ នគរទាំងនេះគោវិន្ទបានសាងហើយ ។

មហាគោវិន្ទនុ៎ះឯង សាងទ្បើងដើម្បីប្រយោជន៍ ដល់ព្រះរាជា ព្រះនាមទាំងនេះ គឺ

[๖๑] ព្រះបាទសត្តភូ ๑ អង្គ ព្រះបាទព្រហ្មទត្ត ๑ អង្គ ព្រះបាទវេស្សភូ ๑ អង្គ ព្រមទាំងព្រះបាទភរតៈ ๑ អង្គ ព្រះបាទរេណុ ๑ អង្គ ព្រះបាទធតរដ្ឋ ๒ អង្គទៀត រួមបានជាស្តេចគ្រប់គ្រងផែនដី មាន ๗ អង្គ ក្នុងគ្រានោះ ។

នេះជាព្រះនាមនៃព្រះរាជាទាំង ๗ ព្រះអង្គនោះ ។ ពិតហើយ ទាំង ๗ ព្រះអង្គនោះ បានដល់អង្គទាំងនេះ គឺសត្តភូ ๑ ព្រហ្មទត្ត ๑ វេស្សភូ ๑ ព្រមនឹងវេស្សភូនោះឯង គឺភរតៈ ๑ រេណុ ๑ ចំណែកធតរដ្ឋមាន ๒ ព្រះអង្គ ព្រះរាជាទាំង ๗ អង្គ ទ្រង់មានការៈ គឺទ្រង់ជាអ្នកមានព្រះការៈ បានដល់ទ្រង់ជាមហារាជក្នុងផ្ទៃជម្ពូទ្វីប ។

បឋមភាណវារកថា ចប់

កិត្តិសព្ទរបស់មហាគោវិន្ទព្រាហ្មណ៍

[៦២] បទថា **ឧបសង្កមឹសុ** គឺព្រះរាជាទាំង ៧ ព្រះអង្គ ទ្រង់ព្រះតម្រិះថា ឥស្សរិយសម្បត្តិនេះ សម្រេចហើយដល់ពួកយើង មិនមែនដោយអានុភាពនៃអ្នកដទៃ តែដោយអានុភាពរបស់មហាគោវិន្ទ មហាគោវិន្ទបានធ្វើឲ្យពួកយើងទាំង ៧ អង្គ ព្រមព្រៀងគ្នា តែងតាំងពួកយើងក្នុងផែ្នជម្ពូទ្វីប ឯពួកយើងមិនងាយនឹងធ្វើការគបសង្កត់ដល់មហាគោវិន្ទដែលជាបុព្វការី មហាគោវិន្ទនេះឯង ចូរប្រៀនប្រដៅពួកយើងទាំង ៧ អង្គ ពួកយើងនឹងឲ្យមហាគោវិន្ទនេះឯងជាមេទ័ព និងជាទីប្រឹក្សា កាលបើដូច្នេះ ពួកយើងគង់នឹងមានសេចក្តីចម្រើនពិត ហើយក៏ចូលទៅរក ។ ចំណែកមហាគោវិន្ទក៏គិតថា អញបានធ្វើព្រះរាជាទាំងនេះឲ្យសាមគ្គីនឹងគ្នាហើយ ។ ប្រសិនបើព្រះរាជាទាំងនេះនឹងមានអ្នកដទៃជាមេទ័ព និងជាទីប្រឹក្សា បន្ទាប់អំពីនោះ ព្រះរាជាទាំងនេះទ្រង់ក៏នឹងកាន់យកពាក្យរបស់មេទ័ព និងទីប្រឹក្សារៀងៗ ខ្លួន ហើយបែកគ្នា អញនឹងព្រមទទួលទាំងតំណែងមេទ័ព និងតំណែងទីប្រឹក្សារបស់ព្រះរាជាទាំងនេះ ហើយទូលថា យ៉ាងនោះហើយព្រះអង្គ ។

បទថា **សត្ត ច ព្រាហ្មណមហាសាលេ** គឺមហាគោវិន្ទគិតថា អញគប្បីនៅចំពោះព្រះភក្ត្រក្តី មិននៅក្តី ក្នុងទីគ្រប់កន្លែង ព្រះរាជាទាំងនេះ ទ្រង់នឹងបដិបត្តិកិច្ច ដោយប្រការដែលអញនឹងមិននៅចំពោះព្រះភក្ត្របាន ហើយក៏តែងតាំងទីប្រឹក្សាបន្ទាប់ទុក ៧ នាក់ លោកសំដៅយកទីប្រឹក្សា ៧ នាក់នោះ ទើបពោលពាក្យនេះថា ព្រាហ្មណមហាសាល ៧ នាក់ផង ដូច្នេះ ។ ឈ្មោះថា **ឆហាតកា** ប្រែថា ខ្នាន់ព្រះកេស ឬអ្នកផ្ងូតទឹក ព្រោះផ្ងូតទឹកមួយថ្ងៃ ៣ ដង ឬផ្ងូតទឹកក្នុងពេលល្ងាច និងពេលព្រឹកវាល់ថ្ងៃ ឬឈ្មោះថា ងូតហើយ ព្រោះ

ចប់ការប្រព្រឹត្តវត្ត ។ ឈ្មោះថា អ្នកផ្ងូត ព្រោះតាំងអំពីនោះ ពួកព្រាហ្មណ៍ មិនបរិភោគ មិនផឹករួមនឹងពួកព្រាហ្មណ៍ផងគ្នា ។

បទថា **អព្ភុគ្គច្ឆិ** *គឺល្បីឡើងទៅខ្ពស់ក្រៃលែង បានឮមកថា គ្រានោះ ពាក្យនេះឯង ប្រព្រឹត្តទៅហើយដល់មនុស្សទាំងឡាយ ក្នុងទីដែលអង្គុយ ហើយថា មនុស្សយើង កាលបានប្រឹក្សាជាមួយព្រហ្មហើយ ក៏នឹងទូន្មានបាន អស់ទាំងជម្ពូទ្វីប ។ បទថា* **ន ខោ បនាហំ** *សេចក្តីថា បានឮថា មហាបុរស គិតថា គុណដែលមិនមានពិតនេះ កើតដល់អញហើយ ឯការកើតគុណឡើង មិនមែនរបស់ធ្ងន់អ្វី តែការរក្សាគុណ ដែលកើតឡើងហើយនុ៎ះឯង ជារបស់ ធ្ងន់ ។ ម៉្យាងទៀត ទាំងដែលអញមិនបានគិត មិនបានប្រឹក្សា ធ្វើគុណនេះ ក៏កើតឡើងហើយ កាលអញគិតហើយ ប្រឹក្សាហើយ ទើបធ្វើ គុណក៏នឹង ធំទូលាយក្រៃលែងពិត ហើយក៏ស្វែងរកឧបាយ ក្នុងការឃើញព្រហ្ម កាល បានឃើញព្រហ្មនោះហើយ ក៏ត្រិះរិះដល់សេចក្តីនេះជាដើមថា ប៉ុន្តែ អាត្មា អញធ្លាប់ឮពាក្យនេះ ដូច្នេះ ។ បទថា* **យេន រេណុ រាជា តេនុបសង្កមិ** *សេចក្តីថា មហាគោវិន្ទគិតថា សេចក្តីត្រូវការដើម្បីនឹងគាល់ ឬសេចក្តីត្រូវការ ដើម្បីនឹងសន្ទនាគ្នាក្នុងរវាងនោះមិនមានឡើយ ព្រោះអាត្មាកាត់សេចក្តីកង្វល់ បានហើយ និងនៅជាសប្បាយ ដូច្នេះ ទើបចូលគាល់ដើម្បីកាត់សេចក្តី កង្វល់ឲ្យអស់ ។ គ្រប់កន្លែងក៏នយនេះ ។ បទថា* **សាធិសិយោ** *គឺស្ត្រីមាន វណ្ណៈស្មើគ្នា មានជាតិស្មើគ្នា ។*

បទថា **សណ្ឋាគារំ** *គឺឲ្យសាងលំនៅយ៉ាងវិចិត្រ យកដើមបបុសមក ព័ទ្ធខាងក្រៅ មានទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ និងទីចង្រ្កមបរិបូណ៌

សមគួរសម្រាប់នៅក្នុងរដូវក្តៅ ๔ ខែ ។ បទថា **ករុណាំ ឈានំ ឈាយិ** *គឺសម្ងីតតិយចជ្ឈាន និងចតុត្ថជ្ឈាននៃករុណា ។ ឯក្នុងបទថា* **ករុណាំ ឈានំ ឈាយិ** *នេះលោកពោលករុណាជាប្រធាន តែព្រហ្មវិហារ ๓ ដ៏សេស ឈ្មោះថា លោកកាន់យកហើយនោះឯង ។ បទថា* **ឧកណ្ឌនា បរិតស្សនា** *សេចក្តីថា កាលនៅក្នុងភូមិជ្ឈាន សេចក្តីអផ្សុក ព្រោះសេចក្តីមិនត្រេកអរក្តី សេចក្តីអន្ទះអន្ទែងព្រោះសេចក្តីខ្ជាចក្តី រមែងមិនមាន តែសេចក្តីត្រូវការឲ្យព្រហ្មមក សេចក្តីប្រាថ្នាឲ្យព្រហ្មមក មាន ។ សេចក្តីភ័យខ្លាច ព្រោះចិត្តតក់ស្លុតនុ៎ះឯង ហៅថា* **ភយំ ។**

[๖๓] *បទថា* **អជានន្តា** *គឺមិនជ្រាប ។ បទថា* **កថំ ជានេមុ តំ មយំ** *សេចក្តីថា ពួកយើងនឹងស្គាល់លោកដូចម្តេច អធិប្បាយថា ពួកយើងនឹងចាំលោកដោយអាការដូចម្តេច ក្នុងអាការជាដើមថា បុគ្គលនេះនៅទីណា ឈ្មោះអ្វី គោត្រអ្វី ។ បទថា* **មំ វេ កុមារំ ជានន្តិ** *សេចក្តីថា ជនទាំងឡាយស្គាល់ខ្ញុំនុ៎ះឯងថា ជាកុមារ ថាជាប្រុសកំលោះ ។ បទថា* **ព្រហ្មលោកេ** *គឺក្នុងលោកដ៏ប្រសើរ ។ បទថា* **សនន្តនំ** *គឺជារបស់យូរលង់ ជារបស់យូរអង្វែង ។ ព្រហ្មរមែងសម្តែងថា ខ្ញុំនោះជាបុរាណកុមារ ឈ្មោះសនង្កុមារព្រហ្ម ។ បទថា* **ឃរំ គោវិន្ទ ជានាមិ** *សេចក្តីថា គោវិន្ទបណ្ឌិត លោកចូរដឹងខ្ញុំយ៉ាងនេះ គឺចូរចាំនូវខ្ញុំយ៉ាងនេះ ។*

របស់ដែលគប្បីបង្អោនទៅដើម្បីក្តៅ ហៅថា របស់ទទួលក្តៅ ក្នុងគាថានេះថា

អាសនៈ ទីក យើងសូមទទួលលោកដ៏ចម្រើន ដោយគ្រឿងទទួលក្បៀវ សូមលោកដ៏ចម្រើន ទទួលគ្រឿងទទួលក្បៀវរបស់យើងចុះ ។

មានពាក្យដែលលោកអធិប្បាយទុក ដោយបទថា របស់ទទួលក្បៀវនុ៎ះឯងថា នេះទឹអង្គុយដែលក្រាលទុកហើយ សូមអញ្ជើញអង្គុយលើទីអង្គុយនេះ នេះទឹកបរិសុទ្ធ អញ្ជើញផឹកទឹក អញ្ជើញលាងជើងពីទឹកនេះ នេះប្រេងលាបជើង ដែលយកប្រេងមកផ្សំដើម្បីប្រយោជន៍ដល់ជើង អញ្ជើញលាបជើងដោយប្រេងនេះ ។ បទថា **មធុសាកំ**[1] *គឺពហ្មចរិយៈរបស់ព្រះពោធិសត្វ មិនដូចគ្នានឹងព្រហ្មចរិយៈរបស់ពួកអ្នកដទៃឡើយ ព្រះពោធិសត្វនោះ មិនធ្វើការសន្សំដោយគិតថា នេះសម្រាប់ថ្ងៃស្អែក នេះសម្រាប់ថ្ងៃខានស្អែក បន្ទែស្ងោរលាយដោយទឹក មានរសផ្អែម មិនប្រៃ មិនក្តៅ មិនជូរមាន ព្រះពោធិសត្វនោះទ្រង់សំដៅយកបន្ទែស្ងោរនោះ ទើបពោលថា អញ្ជើញយកបន្ទែស្ងោរទៅបរិភោគចុះ ទើបពោលពាក្យជាដើមថា សូមលោកដ៏ចម្រើន ទទួលគ្រឿងទទួលក្បៀវរបស់យើងចុះ ។ របស់ទទួលក្បៀវទាំងអស់នេះ មានសម្រាប់ព្រហ្ម ខ្ញុំសូមសួរបស់ទទួលក្បៀវទាំងនោះនឹងលោកដ៏ចម្រើន លោកដ៏ចម្រើនចូរធ្វើរបស់ទទួលក្បៀវរបស់ខ្ញុំ គឺលោកដ៏ចម្រើន ចូរទទួលរបស់ទទួលក្បៀវនេះ របស់ខ្ញុំ ដែលជាអ្នកសួរហើយយ៉ាងនេះ ។*

សួរថា មហាគោវិន្ទនេះ មិនដឹងឬថា ព្រហ្មមិនបរិភោគ សូម្បីតែវត្ថុណាមួយអំពីវត្ថុនេះ ឆ្លើយថា មិនមែនមិនដឹងទេ តែទោះដឹង ក៏សួរដោយ

๑- បិដកខ្មែរ ប្រែថា ទឹកឃ្មុំ ។

ប្រាថ្នាវត្ថុជាសំខាន់ថា ឈ្មោះថា ក្តៀវ ដែលមកកាន់សម្ផាក់របស់ខ្លួន ជាអ្នក ដែលត្រូវសួរ ។ ពេលនោះ ព្រហ្មក៏ពិចារណាមើលថា បណ្ឌិតដឹងថា អញ មិនមានការបរិភោគហើយ ទើបសួរឬហ្ន៎ ឬថា តាំងនៅក្នុងសេចក្តីប្រាកបញ្ចោតហើយ ទើបសួរ ដឹងថា តាំងនៅក្នុងវត្ថុជាសំខាន់ ទើបសួរ ទើបគិតថា ឥឡូវនេះ អញគួរទទួល ទើបពោលថា ម្នាលគោវិន្ទ អ្នកពោលចំពោះគ្រឿងទទួលក្តៀវណា យើងព្រមទទួលគ្រឿងទទួលក្តៀវនោះរបស់អ្នក ។ អធិប្បាយថា នែគោវិន្ទ ពាក្យដែលអ្នកពោលជាដើមថា នេះទីអង្គុយបានក្រាលហើយ សូមអញ្ជើញអង្គុយ លើទីអង្គុយនេះ ក្នុងវត្ថុទាំងនេះ យើងនោះឯងឈ្មោះថា ជាអ្នកអង្គុយហើយ លើទីអង្គុយ ឈ្មោះថា ជាអ្នកផឹកទឹកហើយ សូម្បីជើងយើង ក៏ឈ្មោះថា លាងហើយ ឈ្មោះថា លាបប្រេងហើយ ឈ្មោះថា បរិភោគបន្ទៃស្ងោរហើយ តាំងពីវេលាដែលយើងទទួលរបស់ដែលអ្នកឲ្យ អ្នកនិយាយដល់វត្ថុណា វត្ថុនោះ យើងបានទទួលស្រេចហើយ ព្រោះហេតុនោះ ទើបលោកពោលថា យើងព្រមទទួលគ្រឿងទទួលក្តៀវនោះរបស់អ្នក ។ កាលទទួលរបស់ទទួលក្តៀវហើយ កាលនឹងធ្វើឱកាសនៃបញ្ហា ទើបមហាព្រហ្មពោលពាក្យជាដើមថា ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដូច្នេះ ។

[๖๕] *បទថា* **กงฺขี อกงฺขี ปรเวธิเยสุ** *សេចក្តីថា ខ្ញុំនៅមានសេចក្តីសង្ស័យ សូមសួរលោកដ៏ចម្រើន ដែលមិនមានសេចក្តីសង្ស័យក្នុងបញ្ហាដែលគប្បីធ្វើឲ្យអ្នកដទៃយល់ ដែលប្រាកដដល់អ្នកដទៃ ព្រោះភាពដែលត្រូវអ្នកដទៃសាងទ្បើងមកឯង ។ បទថា* **ฮิกฺกา มมตฺตํ** *គឺលះតណ្ហាដែលជាគ្រឿងឲ្យប្រកាន់ថា នេះរបស់អញ នេះរបស់អញ ។ បទថា* **มนุเชสุ** *គឺក្នុងពួក*

សត្ត អធិប្បាយថា បុគ្គលលះនូវភាពជារបស់អញហើយ ។ បទថា **ឯកោ-ធិភ្ភូតោ** គឺតែម្នាក់ឯង សេចក្តីថា ឈរម្នាក់ឯង អង្គុយម្នាក់ឯង ។ ក្នុងសេចក្តីនេះ អត្ថថា ដែលឈ្មោះថា **ឯកោ** ព្រោះជាបុគ្គលតែឯង លេចឡើង គឺប្រព្រឹត្តទៅ ។ ដែលឈ្មោះថា បុគ្គលម្នាក់ឯង ព្រោះជាបុគ្គលដូច្នោះ ។ បទថា **ការុណោធិមុត្តោ** គឺបង្អោនទៅក្នុងឈាន ដែលប្រកបដោយសេចក្តីអាណិត សេចក្តីថា ធ្វើឲ្យឈាននោះកើតឡើង ។ បទថា **មិរាមតន្ទោ** គឺប្រាសចាកក្ងិនពុល ។ បទថា **ឯត្ថឋិតោ** គឺតាំងនៅក្នុងធម៌ទាំងនេះ ។ បទថា **ឯត្ថ ច សិក្ខមានោ** គឺកំពុងសិក្សាក្នុងធម៌ទាំងនេះ ។ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែកសេចក្តីពិស្តារ មហាគោវិន្ទ និងព្រហ្ម បានពោលហើយខាងលើ ។

[៦៧] បណ្តាបទទាំងនោះ បទថា **ឯតេ អវិជ្ជា** សេចក្តីថា ខ្ញុំមិនដឹងមិនស្គាល់ក្ងិនពុលទាំងនេះ ។ បទថា **ឥធ ព្រូហិ ធីរ** សូមលោកពោលក្នុងទីនេះ សេចក្តីថា **ធីរ** គឺអ្នកប្រាជ្ញ ព្រោះហេតុនោះ សូមលោកពោល គឺសូមប្រាប់ខ្ញុំក្នុងទីនេះ ។ បទថា **កេនាវជា វាតិ បជា ការូ** សេចក្តីថា សត្វត្រូវគ្រឿងរារាំង គឺកិលេសដូចម្តេចរួបរឹត ទើបក្ងិនស្អុយផ្សាយទៅ ។ បទថា **អាចា-យិកា** បានដល់ សត្វដែលចូលដល់អបាយ ។ បទថា **និវុតព្រហ្មលោកា** គឺឈ្មោះថា បិទព្រហ្មលោកហើយ ព្រោះព្រហ្មលោករបស់បុគ្គលនោះ ត្រូវបានគ្រប គឺត្រូវបិទហើយ ។ មហាគោវិន្ទសួរថា ពួកសត្វត្រូវកិលេសអ្វីរួបរឹត គឺបិទ បានដល់ បិទបាំងផ្លូវព្រហ្មលោកហ្នឹ មហាព្រហ្មឆ្លើយថា សេចក្តីក្រោធ

ការនិយាយកុហក ការបញ្ឆោតបន្ទំ ការទ្រុស្តមិត្តជាដើម សេចក្តីក្រោធ មានការឆេវឆាវជាលក្ខណៈ ការពោលកុហក មានការពោលឲ្យឃ្លាតជាមួយអ្នកដទៃជាលក្ខណៈ ការបញ្ឆោតបន្ទំ មានការសម្តែងវត្ថុដែលដូចគ្នា ហើយបញ្ឆោតយកជាលក្ខណៈ និងការទ្រុស្តមិត្ត មានការទម្លាយមិត្តជាលក្ខណៈ ។ បទថា **កឆវិយតា អតិមានោ ឧស្សុយ្យ** *សេចក្តីថា សេចក្តីកំណាញ់ មានសេចក្តីរីង និងការជាប់ស្អិតជាលក្ខណៈ ការមើលងាយ មានការជាន់ឈ្លី ហើយមើលងាយមើលថោកជាលក្ខណៈ សេចក្តីច្រណែន មានការអស់ទៅនៃសម្បត្តិអ្នកដទៃជាលក្ខណៈ ។ បទថា* **ឥច្ឆា វិវិច្ឆា**[1] **បរហេឋនា** *សេចក្តីថា ឥច្ឆា មានការចង់បាន ជាលក្ខណៈ វិវិច្ឆា មានសេចក្តីកំណាញ់ ជាលក្ខណៈ បរហេឋនា មានការធ្វើឲ្យអ្នកដទៃលំបាក ជាលក្ខណៈ ។ បទថា* **លោភោ ច ទោសោ ច មទោ ច មោហោ** *គឺលោភៈ មានការចង់បានជាលក្ខណៈ ទោសៈ មានការកាចជាលក្ខណៈ មទៈ មានការស្រវឹងជាលក្ខណៈ មោហៈ មានការវង្វេងជាលក្ខណៈ ។ បទថា* **ឯតេសុ យុត្តា អនិរាមគន្ធ** *សេចក្តីថា ពួកសត្វដែលប្រកបក្នុងកិលេសទាំង ១៤ ប្រការនេះ មិនមែនជាអ្នកមិនមានក្លិនពុល ។ មហាព្រហ្មពោលថា ជាអ្នកមានក្លិនពុល មានក្លិនសាកសព មានក្លិនស្អុយពិតៗ ។ បទថា* **អាចាយិកា ឯវុត-ព្រហ្មលោកា** *មហាព្រហ្ម រមែងសម្តែងថា ពួកសត្វនេះ ជាសត្វអបាយ និងជាអ្នកបិទផ្លូវព្រហ្មលោក ។ អ្នកពោលសូត្រនេះ គប្បីពោលឲ្យជាក់ច្បាស់បានដោយអាមគន្ធសូត្រ សូម្បីអាមគន្ធសូត្រ ក៏គប្បីពោលឲ្យជាក់ច្បាស់បាន*

๑- បិដកខ្មែរថា វិចិកិច្ឆា ប្រហែលជាលោកច្រឡំជាលីទេដឹង ។

ដោយសូត្រនេះ ។

[៦៨-៦៩] បទថា **តេ ន សុនិម្មទយា** សេចក្តីថា ក្ងិនពុលទាំងនោះ មិនមែនជាវត្ថុដែលគប្បីញាំញីចេញបានដោយងាយ គឺមិនមែនជាវត្ថុ ដែលគប្បីញាំញីចេញបានស្រួល គឺមិនមែនជាវត្ថុដែលគប្បីលះបង់បានងាយៗ ។ សេចក្តីថា លះបានដោយកម្រ គឺលំបាកលះ ។ បទថា **យស្សទានិ ភវំ គោវិន្ទោ កាលំ មញ្ញតិ** សេចក្តីថា គោវិន្ទដ៏ចម្រើន រមែងសម្គាល់វេលាដើម្បីការបួសណា ការបួសនេះឯងចូរសម្រេច ។ កាលបើដូច្នោះ ការមកក្នុងសម្នាក់របស់អ្នក សូម្បីយើងក៏ជាការមកដោយល្អ ។ ពាក្យក្នុងផ្ទូវធម៌ដែលពោលហើយ ក៏ជាការពោលល្អហើយ គោវិន្ទអ្នកជាបុរសដ៏កំពូលក្នុងជម្ពូទ្វីបទាំងមូល ជាមនុស្សក្មេង នៅក្នុងបឋមវ័យ ឈ្មោះថា ការលះភាពជាសិរីនៃសម្បត្តិដ៏ធំយ៉ាងនេះ ហើយបួសរបស់អ្នកនេះ ជាការធំក្រៃលែង ដូចគ្នានឹងជំរីបានក្ងិនក្រអូប គឺក្ងិនជំរីញី ហើយកាត់ចំណងដែកទៅបានដូច្នោះ ។ កាលធ្វើការងារ គឺភាពមុតមាំដល់មហាបុរសថា ការបួសនេះ ឈ្មោះថា ជាព្រះពុទ្ធភាវ: ដូច្នេះហើយ សនង្កុមារព្រហ្មក៏ទៅកាន់ព្រហ្មលោកវិញ ។ មហាបុរសគិតថា ការដែលអញចេញចាកទីនេះឯងបួស មិនសមគួរ អញនឹងប្រៀនប្រដៅអត្ថដល់រាជត្រកូល ព្រោះដូច្នោះ អញនឹងក្រាបទូលដល់ព្រះរាជាបើព្រះអង្គទ្រង់ចេញបួសដែរ ក៏ជាការល្អពិត បើទ្រង់មិនបួសទេ អញនឹងវៀរលែងពីតំណែងទីប្រឹក្សាស្រេចហើយ សឹមបួស ដូច្នេះហើយ ទើបចូលគាល់ព្រះរាជា ។ ព្រោះហេតុនោះ ទើបលោកពោលថា ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ។បេ។ ខ្ញុំព្រះអង្គលែងត្រេកអរក្នុងតំណែង

បុរោហិតហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ត្វំ បជានស្មុ រជ្ជេន** សេចក្តីថា សូមព្រះអង្គ នោះឯង ទ្រង់ជ្រាបចំពោះរាជសម្បត្តិរបស់ព្រះអង្គ ។ បទថា **នាហំ បុរោ ហិច្ចេ មេ** សេចក្តីថា ទូលបង្គំមិនត្រេកអរក្នុងភាពជាទីប្រឹក្សាទេ ទូលបង្គំ នៀយណាយហើយ សូមព្រះអង្គទ្រង់ជ្រាបបុរោហិត អ្នកទូន្មានដទៃចុះ ទូល បង្គំមិនត្រេកអរក្នុងភាពជាទីប្រឹក្សា ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ភោគៈក្នុងផ្ទះរបស់ព្រាហ្មណ៍អ្នកពួនសម្ងំបួនខែ គង់នឹងតិចពិត ទើបទ្រង់ អញ្ជើញដោយទ្រព្យថា បើលោកនៅខ្វះដោយកាមទាំងឡាយ យើងនឹងថែម ឲ្យលោកដរាបពេញ ហើយទ្រង់ព្រះតម្រិះទៀតថា កាលព្រាហ្មណ៍នេះ នៅ ម្នាក់ឯង ត្រូវបុគ្គលណាម្នាក់បៀតបៀនឬហ្នឹ ទើបត្រាស់សួរថា

> បើបុគ្គលណាបៀតបៀនអ្នក យើងជាម្ចាស់នៃសេនាលើ
> ផែនដី នឹងហាមប្រាមបុគ្គលនោះ អ្នកទុកដូចជាបិតា យើង
> ទុកដូចជាបុត្រ ម្នាលគោវិន្ទ សូមអ្នកកុំលះបង់យើងឡើយ ។

សេចក្តីនៃគាថានេះថា យើងនឹងការពារអ្នកដែលបៀតបៀនលោក សូមតែម្យ៉ាង ត្រឹមតែឲ្យលោកប្រាប់ថា បុគ្គលនោះ យើងនឹងដឹងវត្ថុដែលគួរ ធ្វើក្នុងករណីនោះ ។ បទថា **ភូមិសេនាបតី អហំ** សេចក្តីថា ម្យ៉ាងទៀត យើងជាម្ចាស់ផែនដី យើងនឹងធ្វើឲ្យអ្នកប៉ុណ្ណោះ គ្រប់គ្រងរាជសម្បត្តិនេះ ។ បទថា **ត្វុវំ បិតា អហំ បុត្តោ** សេចក្តីថា លោកតាំងនៅក្នុងតំណែងជាឪពុក យើងតាំងនៅក្នុងតំណែងកូន ចិត្តរបស់យើងត្រូវលោកនាំយកទៅហើយ នែ គោវិន្ទ សូមលោកកុំលះបង់យើងចោល បាឬៈថា លោកចូរឲ្យប្រព្រឹត្តទៅតាម

ដែលលោកត្រូវការចុះ ចំណែកខ្ញុំព្រមតាមចិត្តរបស់លោកតែម្យ៉ាង នឹងបរិ-ភោគអាហារដែលលោកឲ្យ មានដៃកាន់ដាវ និងខែលបម្រើលោក ឬបររថ ឲ្យលោកក៏បាន នែគោវិន្ទ លោកកុំលះបង់យើងឡើយ ដូច្នេះក៏មាន ។ អត្ថនៃ ពាក្យនោះថា លោកចូរតាំងនៅក្នុងតំណែងជាឪពុក យើងនឹងតាំងនៅក្នុង តំណែងជាកូន នែគោវិន្ទ លោកកុំបោះបង់ គឺកុំលះបង់យើងទៅឡើយ ។

គ្រានោះ កាលមហាបុរសសម្តែងវត្ថុដែលព្រះរាជាទ្រង់គិត មិនមាន ក្នុងខ្លួន ទើបពោលថា

> ការខ្វះខាត ដោយវត្ថុទាំងឡាយ ដែលត្រូវការ មិនមានទេ
> បុគ្គលអ្នកបៀតបៀនទូលបង្គំ ក៏មិនមានដែរ ប៉ុន្តែទូលបង្គំ
> បានស្តាប់ពាក្យរបស់អមនុស្សហើយ ហេតុនោះ បានជា
> ទូលបង្គំ មិនត្រេកអរក្នុងផ្ទះទេ ។

ក្នុងបទទាំងនោះ បទថា **ន មត្ថិ** សេចក្តីថា មិនមាន ដល់ខ្ញុំ ។ បទថា **គហេ** គឺត្រង់ផ្ទះ ។

លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់សួរមហាគោវិន្ទនោះថា

> អមនុស្សមានភេទដូចម្តេច បាននិយាយសេចក្តីដូចម្តេចនឹង
> អ្នក ដែលអ្នកបានស្តាប់ហើយ នឹងលះបង់នូវផ្ទះទាំងឡាយ
> របស់យើងផង នូវយើងផង នូវជនទាំងអស់ផង ។

បណ្តាបទទាំងនោះ បទថា **ជហាសិ ឆោ គេហេ អម្ហេ ច ភោវលី** សេចក្តីថា ព្រះរាជា កាលទ្រង់ធ្វើព្រះរាជវាំងរបស់ព្រះអង្គ ដោយអំណាច រួមយកទាំងស្រុកព្រាហ្មណ៍ ដែលបរិបូណ៌ដោយសម្បត្តិ ទើបត្រាស់ថា ដែល

លោកបានស្តាប់ហើយ ក៏ចោលផ្ទះរបស់ពួកយើង និងអ្នកជម្ពូទ្វីប ទាំងអស់ គឺមិនមានសល់ហើយទៅ ។

លំដាប់នោះ កាលមហាបុរសក្រាបទូលចំពោះព្រះរាជាអង្គនោះ ទើបពោលថា **ឧបវុត្តស្ស មេ បុព្ពេ** *ជួច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឧបវុត្តស្ស** *សេចក្តីថា ចូលទៅដល់ភាពជាបុគ្គលតែម្នាក់ឯងហើយ ។ បទថា* **យិដ្ឋកាមស្ស មេ សតោ** *សេចក្តីថា ខ្ញុំជាអ្នកប្រាថ្នាដើម្បីនឹងបូជាយញ្ញ ។ បទថា* **អគ្គិ បជ្ជលិតោ អាសិ កុស-បត្តបរិត្តតោ** *គឺសេចក្តីក្នុងប្រការនេះថា ខ្ញុំឈរគិតយ៉ាងនេះថា ភ្លើងដែលយកស្បូវមកថែម ហើយជាក់ទឹកដោះថ្លា ទឹកដោះជូរ និងទឹកឃ្មុំជាដើមចូលទៅ កាន់តែឆេះសន្ធោសន្ធៅ ហើយកាលបង្អាត់ភ្លើងឲ្យឆេះសន្ធោសន្ធៅយ៉ាងនោះស្រេចហើយ ខ្ញុំនឹងឲ្យទានដល់មហាជន ។ បទថា* **សឆន្ទោ** *បានដល់សន្ទុំមារព្រហ្ម ។ បន្ទាប់អំពីនោះ សូម្បីព្រះរាជាអង្គនោះឯង ទ្រង់ជាអ្នកប្រាថ្នានឹងបួស ទើបត្រាស់ថា* **សទ្ធហាមិ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **កថំ វត្តេថ អញ្ញេ** *សេចក្តីថា លោកនឹងប្រព្រឹត្តដោយប្រការដទៃបានដូចម្តេច ។ បទថា* **តេតំ អនុវត្តិស្សាម** *សេចក្តីថា ពួកយើងទាំងនោះនឹងប្រព្រឹត្តតាម គឺនឹងបួសតាមលោកនោះឯង ។ បទថា* **អនុវជិស្សាម** *ដូច្នេះក៏មាន អត្ថនៃបាលីនោះថា នឹងប្រព្រឹត្តតាម ។ បទថា* **អកាចោ** *គឺមិនប្រែ មិនគ្រោតគ្រាត ។ បទថា* **គោវិន្ទស្សានុសាសនេ** *គឺក្នុងពាក្យទូន្មានរបស់គោវិន្ទ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើគោវិន្ទជ័ចម្រើននោះឯង ឲ្យជាគ្រូ ហើយប្រព្រឹត្តតាម ។*

[๗๐] បទថា **ឆ ខត្តិយា តេនុបសង្កមិ** សេចក្តីថា គោវិន្ទគាំទ្រ ព្រះបាទវេណុថា សាធុមហារាជ ទ្រង់ធ្វើល្អហើយ កិច្ចដ៏ធំក្រៃលែង ដែល មហារាជ ទ្រង់ប្រាថ្នាដើម្បីនឹងទ្រង់ព្រះផ្នួស ទ្រង់លះបង់រាជសិរី ដ៏ធំក្រៃលែង យ៉ាងនេះ ក្នុងកាលដែលពួកសត្វសម្ងាប់ឪពុកខ្លះ ម្តាយខ្លះ បងប្អូនប្រុសខ្លះ បងប្អូនស្រីជាដើមខ្លះ ដើម្បីរាជសម្បត្តិ ធ្វើឧស្សាហៈរបស់ព្រះរាជា ឲ្យមាំទាំ ហើយ ទើបចូលគាល់ ។ បទថា **ឃវំ សមចិន្តេសុំ** សេចក្តីថា ក្សត្រ ៦ ព្រះ អង្គ ទ្រង់សម្គាល់ថា ពេលខ្លះ កោគៈទាំងឡាយរបស់ព្រាហ្មណ៍សាបសូន្យ ហើយក៏បាន ទើបទ្រង់គិតព្រមគ្នា ដោយនយដែលព្រះរាជាទ្រង់គិតនុ៎ះឯង ។ បទថា **ធនេន សិក្ខេយ្យាម** សេចក្តីថា ពួកយើងគប្បី ជួយស្រោចស្រង់ គឺគប្បីសង្គ្រោះ ។ បទថា **តាវតកំ អាហារិយតំ** សេចក្តីថា គប្បីឲ្យនាំមក គឺគប្បីឲ្យកាន់យកប៉ុណ្ណោះ ។ មានពាក្យដែលលោកពោលថា លោកគប្បី កាន់យកតាមចំនួនដែលលោកត្រូវការ ។ បទថា **ភវន្តានំយេវ អាយាសា** សេចក្តីថា សម្បត្តិជារបស់កើតគ្រប់គ្រាន់ហើយ ព្រោះទ្រង់ទាំងឡាយធ្វើទ្រង់ ទាំងឡាយឲ្យជាបច្ចយ ឲ្យហើយនោះឯង ។

[๗๑] បទថា **សចេ បជហាថ កាមានិ** សេចក្តីថា បើទ្រង់ទាំងឡាយ លះវត្ថុកាម និងកិលេសកាមបាន ។ បទថា **យត្ត សតោ បុថុជ្ជនោ** គឺជាប់ ជំពាក់ហើយ ក្នុងកាមទាំងឡាយណា ។ បទថា **អារម្ភថ្លោ ធង្ហា បុថុជ្ជនោ** គឺកាលបើដូច្នេះ សូមទ្រង់ទាំងឡាយប្រារព្ធសេចក្តីព្យាយាម អធិដ្ឋានវិរិយៈ ដែលទន់ខ្សោយ ឲ្យជាបុគ្គលរឹងមាំ ។ បទថា **ខត្តិពលសមាហិតា** គឺការអត់ ធន់ គោវិន្ទញុំាងឧស្សាហៈឲ្យកើតដល់ព្រះរាជាទាំងឡាយថា សូមទ្រង់ទាំង-

ទ្បាយ ជាអ្នកដល់ព្រមដោយកម្លាំង គឺសេចក្តីអត់ធន់ ។ បទថា **ឯស មគ្គោ ឧជុមគ្គោ** *សេចក្តីថា ផ្លូវនៃឈានដែលប្រកបដោយកុណានោះ ឈ្មោះថា ជាផ្លូវត្រង់ ។ បទថា* **ឯស មគ្គោ អនុត្តរោ** *សេចក្តីថា នុ៎ះឯង ឈ្មោះថា ជាផ្លូវដ៏ប្រសើរ មិនមានផ្លូវដទៃដូច ដើម្បីការចូលដល់ព្រហ្មលោក ។ បទថា* **សទ្ធម្មោ សព្ភិ រក្ខិតោ** *សេចក្តីថា ព្រះធម៌នោះឯង ឈ្មោះថា ជាធម៌ដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ជាសប្បុរសរក្សាហើយ ។ គោវិន្ទរមែងធ្វើពាក្យឲ្យជាកម្មវឹងមាំពិតៗ ដើម្បីប្រយោជន៍ការមិនត្រឡប់នៃព្រះរាជាទាំងនោះ ដោយពណ៌នាឈានដែលប្រកបដោយកុណា ដោយប្រការដូច្នេះ ។*

បទថា **កោ នុ ខោ បន កោ ជានាតិ ជីវិតានំ** *សេចក្តីថា បពិត្រព្រះអង្គ ឈ្មោះថា ជីវិត ក៏ដូចគ្នានឹងពពុះទឹក ដូចតំណក់ទឹកសន្សើម នៅចុងស្មៅ មានការបែកធ្លាយក្នុងកាលឆាប់ជាធម្មតា នរណានឹងដឹងគតិរបស់ជីវិតនោះបានថា តើជីវិតនឹងបែកធ្លាយក្នុងខណៈណា ។ បទថា* **គមនីយោ សម្ប-រាយោ** *សេចក្តីថា លោកខាងមុខជារបស់ដែលត្រូវទៅ ពិតប្រាកដនោះឯង ព្រោះដូច្នោះ កុលបុត្រដែលជាបណ្ឌិតគប្បីដឹងដោយបញ្ញា ក្នុងរឿងនោះ អធិប្បាយថា បញ្ញា លោកហៅថា សេចក្តីដឹង ត្រូវប្រឹក្សា ត្រូវយល់ ត្រូវពិនិត្យពិចារណា ដោយបញ្ញានោះ ។ បទថា* **មន្តាយ** *នោះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ បទថា* **មន្តាយំ ពោទ្ធព្ពំ** *សេចក្តីថា ត្រូវដឹងដោយសេចក្តីដឹង អធិប្បាយថា ត្រូវយល់ដោយសេចក្តីដឹង ។ ត្រូវដឹងអ្វី ត្រូវដឹងនូវជីវិតដែលដឹងបានលំបាក និងលោកខាងមុខជាទីត្រូវទៅពិតប្រាកដ ។ កាលដឹងហើយ ក៏ត្រូវកាត់សេចក្តីវល់គ្រប់យ៉ាង ហើយធ្វើកុសល ត្រូវប្រព្រឹត្ត*

ព្រហ្មចរិយធម៌។ ព្រោះអ្វី ព្រោះសត្វដែលកើតហើយមិនស្លាប់ រមែងមិនមាន។ បទថា **អប្បេវសក្ខា ច អប្បលាភា ច** *គឺថា លោកដ៏ចម្រើន ដែលឈ្មោះថា ការបួស រមែងមានយសតូច ព្រោះអ្នកបៀតបៀនហើយបៀតបៀនទៀតដល់អ្នកដែលលះបង់រាជសម្បត្តិ ហើយបួស តាំងពីវេលាដែលបួសហើយ រមែងនិយាយធ្វើឲ្យទន់ខ្សោយ និងគ្មានទីពឹង និងឈ្មោះថា មានលាភតិច ព្រោះសូម្បីដើរទៅរហូតទូទាំងស្រុក ក៏រកអាហារលេបបានលំបាកនុ៎ះឯង ចំណែកភាពជាព្រាហ្មណ៍នេះ ឈ្មោះថា មានសក្តិធំ ព្រោះជាអ្នកមានយសធំ មានលាភធំ ព្រោះភាពជាអ្នកបរិបូណ៌ដោយលាភ និងសក្ការៈធំ។ ក្នុងឥឡូវនេះ លោកដ៏ចម្រើន ដែលជាទីប្រឹក្សាថ្នាក់ខ្ពស់ ទូទាំងជម្ពូទ្វីប គ្រប់ទីកន្លែង រមែងបានទីអង្គុយដ៏ប្រសើរ ទឹកដ៏ប្រសើរ អាហារដ៏ប្រសើរ ភិនដ៏ប្រសើរ កម្រងផ្កាដ៏ប្រសើរ។ បទថា* **រាជារ រញ្ញំ** *សេចក្តីថា ខ្ញុំនោះឯង ឥឡូវនេះ ដូចជាស្តេចចក្រពត្តិ ក្នុងចំណោមពួកព្រះរាជា។ បទថា* **ព្រហ្មារ ព្រាហ្មណានំ** *សេចក្តីថា ដូចជាមហាព្រហ្ម ក្នុងចំណោមនៃព្រាហ្មណ៍ប្រក្រតីទាំងឡាយ។ បទថា* **ទេវតារ គហបតិកានំ** *សេចក្តីថា ឯខ្ញុំប្រៀបដូចជាសក្កទេវរាជ ក្នុងចំណោមពួកគហបតីទាំងឡាយដ៏សេស។ បទថា* **ចត្តារីសា ភរិយា សាធិសិយោ** *សេចក្តីថា ពួកភរិយាដែលមានជាតិ និងវណ្ណៈដូចគ្នា ៤០ នាក់ប៉ុណ្ណោះ តែពួកស្ត្រីរបាំដទៃ ក្នុងវិយទាំងបីរបស់គោវិន្ទ មានច្រើននោះឯង។ បទថា* **ចារិកំ ចរតិ** *សេចក្តីថា គោវិន្ទ ត្រាច់ទៅតាមគាមនិគម និងគ្រប់ៗ ស្ថានទីដែលគេទៅ ក៏មានកោលាហល ដូចកោលាហលរបស់ព្រះសម្ពុទ្ធដូច្នោះ។ ពួកមនុស្សបានឮថា មហាគោវិន្ទបណ្ឌិតកំពុងនឹងមក ក៏ឲ្យសាងបារាំទុកជា*

មុន តាក់តែងលម្អផ្លូវថ្នល់ ហើយក្រោកឡើងទទួល នាំមក ។ លាភ និង សក្ការៈ កើតឡើងដូចជំនន់ទឹកធំ ហូរជោរជន់ ។ បទថា **សត្ត ខត្តិយាភិសេកា** *គឺអំពីទីប្រឹក្សារបស់ព្រះរាជា ៧ ព្រះអង្គ ។ ក្នុងគ្រានោះ ពួកមនុស្សរមែងពោលថា សូមនមស្ការដល់មហាគោវិន្ទព្រាហ្មណ៍ សូមនមស្ការដល់ទីប្រឹក្សារបស់ព្រះរាជាទាំង ៧ ដូចក្នុងឥឡូវនេះ កាលទុក្ខណាមួយ កើតក្នុងឋានៈបែបនេះ រមែងពោលថា សូមនមស្ការចំពោះព្រះពុទ្ធ ដូច្នោះ ដោយប្រការដូច្នេះ ។*

ព្រហ្មវិហារមកហើយក្នុងបាលី ដោយន័យជាដើមថា ទៅដោយសេចក្តីស្រឡាញ់ ។ ឯមហាបុរស ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ ។ បទថា **សាវកានញ្ច ព្រហ្មលោកេ សហព្យតាយ មគ្គំ ឧបទិសិ** *សេចក្តីថា ប្រាប់ផ្លូវដែលត្រូវនៅរួមគ្នាជាមួយនឹងព្រហ្ម ក្នុងព្រហ្មលោក ។ បទថា* **សព្ពេន សព្ពំ** *សេចក្តីថា សាវកទាំងឡាយណា ធ្វើសមាបត្តិ ៨ និង អភិញ្ញា ៥ ឲ្យកើតឡើងហើយ ។ សាវកពួកណា មិនជ្រាបទូទៅដល់សាសនាទាំងអស់ ។ សាវកពួកណា មិនជីឯ មិនអាចឲ្យសូម្បីតែសមាបត្តិមួយ ក្នុងសមាបត្តិ ៨ កើតឡើង ។ បទថា* **អមោឃា** *គឺមានផល ។ បទថា* **អវញ្ឈា** *គឺមិនសោះសូន្យ ។ បាលីថា* **សព្ពធិហីនំ** *ដូច្នេះក៏មាន អធិប្បាយថា បាននូវកាយគន្ធព្វ ។ បទថា* **សជលា** *គឺប្រព្រឹត្តទៅព្រមដោយផល ប្រព្រឹត្តទៅជាមួយប្រយោជន៍ដើម្បីការចូលដល់ទេវលោកដ៏សេស ។ បទថា* **សឧទ្រយ** *បានដល់ ប្រព្រឹត្តទៅជាមួយសេចក្តីចម្រើន ដើម្បីចូលដល់ព្រហ្មលោក ។*

បទថា **សរាមហំ** *សេចក្តីថា ម្នាលបញ្ចសិខៈ តថាគតនឹកឃើញដែរ ។ បានឮមកថា ព្រោះបទនេះ ព្រះសូត្រនេះ ទើបក្លាយជាពុទ្ធភាសិត ។ បទថា* **ឆ**

និព្វិទាយ *គឺមិនមែនដើម្បីប្រយោជន៍ដល់សេចក្តីនឿយណាយក្នុងវដ្ត: ។ បទថា* **ន វិរាគាយ** *គឺមិនមែនដើម្បីប្រយោជន៍ដល់ការប្រាសចាកតម្រេកក្នុងវដ្ត: ។ បទថា* **ន និរោធាយ** *គឺមិនមែនដើម្បីប្រយោជន៍ដល់ការរលត់វដ្ត: ។ បទថា* **ន ឧបសមាយ** *គឺមិនមែនដើម្បីដល់ការចូលទៅស្ងប់រម្ងាប់វដ្ត: ។ បទថា* **ន អភិញ្ញាយ** *គឺមិនមែនដើម្បីប្រយោជន៍ដល់ការដឹងវដ្ត:យ៉ាងក្រៃលែង ។ បទថា* **ន សម្ពោធាយ** *គឺមិនមែនដើម្បីប្រយោជន៍ដល់ការភ្ញាក់ចាកវដ្ត: ដោយប្រាសចាកការនិទ្រាក្នុងកិលេស ។ បទថា* **ន និព្វានាយ** *គឺមិនមែនដើម្បីប្រយោជន៍ដល់អមតមហានិព្វាន ។ បទថា* **ឯកន្តនិព្វិទាយ** *គឺដើម្បីប្រយោជន៍ដល់សេចក្តីនឿយណាយក្នុងវដ្ត:ដោយចំណែកមួយប៉ុណ្ណោះ ។ ចំពោះក្នុងទីនេះ បទថា* **និព្វិទាយ** *បានដល់ វិបស្សនា ។ បទថា* **វិរាគាយ** *បានដល់មគ្គ ។ បទថា* **និរោធាយ ឧបសមាយ** *បានដល់ ព្រះនិព្វាន ។ បទថា* **អភិញ្ញាយ សម្ពោធាយ** *សំដៅយកមគ្គ ។ បទថា* **និព្វានាយ** *ក៏គឺព្រះនិព្វានន៎ុះឯង ដោយប្រការដូច្នេះ ក៏គប្បីជ្រាបពាក្យដែលប្រាសចាកវដ្ត:យ៉ាងនេះថា លោកពោលវិបស្សនា ១ កន្លែង ពោលមគ្គ ៣ កន្លែង ពោលនិព្វាន ៣ កន្លែង ពាក្យប្រើជំនួសមគ្គក្តី ពាក្យប្រើជំនួសនិព្វានក្តី ទាំងអស់នេះ រមែងមានដោយទំនងនេះឯង ។ ពាក្យដែលនឹងគប្បីពោលក្នុងបទជាដើមថា សម្មាទិដ្ឋិ ក៏បានពោលហើយ ក្នុងសច្ចវណ្ណនា ក្នុងវិសុទ្ធិមគ្គ ។*

បទថា **យេន សព្វេន សព្វំ** *សេចក្តីថា ពួកកុលបុត្រណា មិនជ្រាបដើម្បីនឹងបំពេញអរិយមគ្គទាំង ៤ ឬធ្វើឲ្យអរិយមគ្គ ៣-២ ឬ ១ កើតឡើង ។ បទថា* **សព្វេសំយេវ តេសំ កុលបុត្តានំ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់

ញុំាងធម៌ទេសនាឲ្យចប់ស្រេចដល់កំពូល គឺអរហត្ត បព្វជ្ជារបស់ពួកកុលបុត្រ ដែលប្រព្រឹត្តព្រហ្មចរិយៈរឿយៗ មិនជារបស់ទទេ មានផលដូច្នេះ ។ បទថា **ភគវន្តំ អភិវាเទត្វา បទក្ខិណំ กตฺวา** *សេចក្តីថា បញ្ចសិខទេវបុត្រកាយ ទទួលព្រះធម៌ទេសនា របស់ព្រះមានព្រះភាគហើយដោយចិត្ត អនុមោទនា សរសើរហើយដោយវាចា ផ្គងនូវមហាអញ្ជលីដាក់លើសិរ្ស ចូលទៅក្នុង បណ្តាឆព្វណ្ណរង្សីរបស់ព្រះទសពល ដូចមុជចូលក្នុងទឹកល័ក្តដ៏ថ្លា ថ្វាយបង្គំ ក្នុងទី ៤ កន្លែង ហើយធ្វើប្រទក្សិណបីជុំ សរសើរព្រះមានព្រះភាគបណ្តើរ ក៏អន្តរធានអំពីព្រះភក្ត្រព្រះសាស្តា បានមកកាន់ទេវលោករបស់ខ្លួនហើយ ដោយប្រការដូច្នេះឯង ។ អដ្ឋកថាមហាគោវិន្ទសូត្រ ក្នុងទីឃនិកាយឈ្មោះ សុមង្គលវិលាសិនី ចប់ ៗ*

មហាគោវិន្ទសូត្រ ចប់

សូត្រទី ៦ ចប់

សុត្តន្តបិដក

មហាសមយសូត្រទី ៧

[๗๓] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងមហាវន ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើនចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។ ទេវតាទាំង-ឡាយក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ គ្រានោះឯង ទេវតាទាំងឡាយ ដែលនៅក្នុងជាន់សុទ្ធាវាស ๔ អង្គ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគនេះ ព្រះអង្គគង់នៅក្នុងមហាវន ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។ ទេវតាទាំងឡាយក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគ និងភិក្ខុសង្ឃ បើដូច្នេះ គួរយើងទាំងអស់គ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ គប្បីពោលនូវគាថាមួយម្នាក់ៗ ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លំដាប់នោះ ទេវតាទាំងនោះឯង ក៏បាត់អំពីសុទ្ធាវាសព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ (ដោយឆាប់រហ័ស) គួរនាដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ គ្រានោះ ពួកទេវតានោះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាទាំងនោះឋិតនៅក្នុងទីដ៏សមគួរ ហើយទើបទេវតាមួយអង្គ ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

[๗๔] *ថ្ងៃនេះជាថ្ងៃប្រជុំធំក្នុងជនបទ ពួកទេវតាក៏មកប្រជុំគ្នាហើយ យើងទាំងឡាយ (លុះឃើញពួកទេវតាប្រជុំគ្នាយ៉ាងនេះហើយ) ក៏នាំគ្នាមកកាន់ទីប្រជុំប្រកបដោយធម៌នេះ ដើម្បីឃើញនូវអបរាជិតសង្ឃ គឺសង្ឃដែលមារផ្តាញ់មិនបាន ។*

[๗๕] *លំដាប់នោះ ទេវតាមួយអង្គទៀត ក៏ពោលនូវគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា*

> *ពួកភិក្ខុក្នុងទីប្រជុំនោះ ប្រកបដោយសមាធិ ធ្វើចិត្តរបស់ខ្លួន (ដែលវៀចកោង) ឲ្យជាចិត្តស្ងួតត្រង់ ភិក្ខុជាបណ្ឌិតទាំងឡាយ តែងរក្សានូវឥន្ទ្រិយ (ដោយល្អ) ដូចជានាយសារថី ដែលកាន់ទប់នូវខ្សែបរទុកដូច្នោះឯង ។*

[๗๖] *លំដាប់នោះ ទេវតាមួយអង្គទៀត ក៏ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា*

> *ពួកភិក្ខុទាំងនោះ កាត់បង់នូវដែកគោល (រាគៈ ទោសៈ មោហៈ) កាត់បង់នូវទ្រនុកទ្វារ (រាគៈ ទោសៈ មោហៈ) គាស់រម្ងើងនូវសសរគោល (រាគៈ ទោសៈ មោហៈ) ជាអ្នកមិនមានតណ្ហា ជាគ្រឿងញាប់ញ័រ ជាអ្នកបរិសុទ្ធស្អាត ជ្រាសចាកមន្ទិល ជានាគកំលោះ ដែលព្រះពុទ្ធជាម្ចាស់ប្រកបដោយចក្ខុ ๕ ទ្រង់ទូន្មានល្អហើយ តែងត្រាច់ទៅបានក្នុងទិសទាំង ๔ មិនមានទើសទាល់ ។*

[๗๗] *លំដាប់នោះ ទេវតាមួយអង្គទៀត ក៏ពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា*

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹង ទីរឭកហើយ
ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិទៀយ លុះ
លះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញ
ពពួកនៃទេវតាមិនខាន ។

[๗๘] *លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនអង្គ ក្នុងលោកធាតុទាំង ១០ មកប្រជុំគ្នា ដើម្បីឃើញនូវតថាគត និងភិក្ខុសង្ឃ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹងហើយក្នុងអតីតកាល ពួកទេវតាមានប្រមាណប៉ុណ្ណោះដូចគ្នា មកប្រជុំគ្នាដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចជាពួកទេវតាដែលមកប្រជុំគ្នា ដើម្បីឃើញតថាគត ក្នុងកាលឥឡូវនេះដែរ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងបានត្រាស់ដឹងក្នុងអនាគតកាល ពួកទេវតាមានប្រមាណប៉ុណ្ណោះដូចគ្នា នឹងមកប្រជុំគ្នាដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចពួកទេវតាដែលមកប្រជុំគ្នា ដើម្បីឃើញតថាគតក្នុងកាលឥឡូវនេះដែរ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់នូវនាម និងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងពោលនូវនាម និងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹង*

សម្តែងនូវនាម និងគោត្រវបស់ពួកទេវតាទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់រឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងនូវភាសិតនេះថា

[๗๙] *តថាគតនឹងធ្វើនូវស្មោក ភូមទេវតា (ឋិតនៅ) ក្នុងទីណា ពួកភិក្ខុក៏អាស្រ័យនៅទីនោះ ពួកភិក្ខុណា ដែលនៅអាស្រ័យនឹងផ្ទៃភ្នំ បញ្ជូនចិត្តទៅកាន់អារម្មណ៍ល្អ មានចិត្តតម្កល់នឹង (តថាគតនឹងសម្តែងគុណនៃភិក្ខុទាំងនោះ) ។ ពួកភិក្ខុច្រើនរូបសម្លឹងនៅក្នុងកម្មដ្ឋានគ្របសង្កត់នូវការព្រឺរោម ព្រឺស្បែក (ឥតមានភ័យខ្លាច) ដូចសត្វសីហៈ មានចិត្តផូរផង់ បរិសុទ្ធ ជ្រះថ្លា ឥតមានល្អក់ឡើយ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបនូវពួកព្រះអរហន្តជាង ៥០០ រូប នៅក្នុងដងព្រៃជិតក្រុងកបិលវត្ថុ ទើបទ្រង់ត្រាស់នឹងពួកភិក្ខុជាសាវក ដែលត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកនៃទេវតាមានពន្លឺរស្មីជុំវិញរឿង (មកហើយ) អ្នករាល់គ្នា ចូរស្គាល់នូវពួកទេវតាទាំងនោះ (ដោយទិព្វចក្ខុញ្ញាណ) ចុះឯពួកភិក្ខុទាំងនោះ បានស្តាប់នូវពាក្យប្រដៅនៃព្រះពុទ្ធជាម្ចាស់ហើយក៏ធ្វើនូវការព្យាយាម (ដើម្បីទិព្វចក្ខុញ្ញាណនោះ) ។*

ទិព្វចក្ខុញ្ញាណ សម្រាប់មើលឃើញ នូវពួកអមនុស្ស (ទេវតា) ក៏កើតមានប្រាកដដល់ពួកភិក្ខុទាំងនោះ ពួកភិក្ខុខ្លះ បានឃើញនូវអមនុស្ស ១០០ ខ្លះបានឃើញនូវអមនុស្ស ១០០០ ខ្លះបានឃើញនូវអមនុស្ស ៧០ ពាន់ ។ ពួកភិក្ខុខ្លះបានឃើញនូវអមនុស្ស ១ សែន (១០០០០០) ខ្លះបានឃើញនូវអមនុស្សច្រើន (មិនមានកំណត់) អមនុស្សទាំងនោះ ក៏ផ្សាយនៅពាសពេញ ក្នុងទិសទាំងពួង ។ លំដាប់នោះ ព្រះសាស្តាប្រកបដោយចក្ខុ ៥ ទ្រង់ពិចារណាហើយ ជ្រាបនូវហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់នឹងពួកភិក្ខុជាសាវក អ្នកត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាមានពន្លឺរស្មីរុងរឿង (មកហើយ) អ្នកវាល់គ្នា ចូរស្គាល់នូវពួកទេវតាទាំងនោះចុះ តថាគតនឹងប្រាប់ (នូវទេវតាទាំងនោះ) ដល់អ្នកវាល់គ្នាដោយពាក្យតាមលំដាប់ហូរហែ ។ យក្សទាំង ៧០០០ ជាភូម្មទេវតា អាស្រ័យនៅនាក្រុងកបិលវត្ថុ មានឫទ្ធិ មានអានុភាព មាសម្បុរកាយ មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកយក្ស ៦០០០ ដែលកើតនៅនាភ្នំហិមវន្ត មានសម្បុរផ្សេងៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស

មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកយក្ស ៣០០០ ដែលនៅអាស្រ័យនឹងភ្នំសាតាគីរី មានសម្បុរផ្សេងៗគ្នា មានឫទ្ធិ មានអានុភាព មានវស្ម៌ មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកយក្ស ១៦ ពាន់នេះ មានសម្បុរផ្សេងៗ គ្នា មានឫទ្ធិ មានអានុភាព មានវស្ម៌ មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ ពួកយក្ស ដែលកើតនៅនាវេស្សាមិត្តបពិត មានសម្បុរផ្សេងៗគ្នា មានឫទ្ធិ មានអានុភាព មានវស្ម៌ មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ កុម្ភីរយក្សដែលកើតនៅនានគរាជគ្រឹះ ឯភ្នំឈ្មោះវេបុល្លជាទីនៅរបស់កុម្ភីរយក្សនោះ មានយក្សជាង ១ សែននាក់ តែងចូលទៅសេពគប់នឹងកុម្ភីរយក្សនោះ កុម្ភីរយក្ស ដែលកើតក្នុងនគរាជគ្រឹះនោះ (ព្រមទាំងបរិវារ) ក៏មកកាន់មហាវនជាទីប្រជុំ (នៃភិក្ខុទាំង-ឡាយដែរ) ។

[៨០] ព្រះបាទធតរដ្ឋៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងកើត ទ្រង់ជាធំលើគន្ធព្វទាំងឡាយ ព្រះអង្គជាមហារាជ

មានយសធំ ។ ព្រះរាជបុត្រទាំង៦ឡាយ របស់ព្រះបាទ ធតរដ្ឋៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំង ច្រើន មានឫទ្ធិ មានអានុភាព មានវស្ដី មានយស មាន ចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃកិក្ខុទាំង-ឡាយ ។ ព្រះបាទវិរូឡ្ហៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាង ត្បូង ជាធំលើពួកកុម្ភណ្ឌ ព្រះអង្គជាមហារាជ មានយស ធំ ។ ព្រះរាជបុត្រទាំង៦ឡាយ របស់ព្រះបាទវិរូឡ្ហៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានវស្ដី មានយស មានចិត្តរីករាយ នាំគ្នា មកកាន់មហាវន ជាទីប្រជុំនៃកិក្ខុទាំង៦ឡាយ ។ ព្រះបាទ វិរូបក្ខៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងលិច ទ្រង់ជាធំលើ ពួកនាគ ព្រះអង្គជាមហារាជ មានយសធំ ។ ព្រះរាជ-បុត្រទាំង៦ឡាយ របស់ព្រះបាទវិរូបក្ខៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុ-ភាព មានវស្ដី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ មហាវន ជាទីប្រជុំនៃកិក្ខុទាំង៦ឡាយ ។ ព្រះបាទកុវេរៈ ទ្រង់ ប្រៀនប្រដៅក្នុងទិសខាងជើងនោះ ទ្រង់ជាធំលើពួកយក្ស ព្រះអង្គជាមហារាជ មានយសធំ ។ ព្រះរាជបុត្រទាំង-ឡាយ របស់ព្រះបាទកុវេរៈនោះ មានច្រើនរូប មាននាម

ថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ព្រះបាទធតរដ្ឋៈ ជាធំក្នុងទិសខាងកើត ព្រះបាទវិរូឡ្ហៈ ជាធំក្នុងទិសខាងត្បូង ព្រះបាទវិរូបក្ខៈ ជាធំក្នុងទិសខាងលិច ព្រះបាទកុវេរៈ ជាធំក្នុងទិសខាងជើង មហារាជទាំង ៤ ព្រះអង្គនោះ បានញុំាងទិសទាំង ៤ ដោយជុំវិញឲ្យភ្លឺព្រោងព្រាត (ដោយរស្មីរបស់ខ្លួន) ឋិតនៅក្នុងមហាវន ជិតក្រុងកបិលវត្ថុ ។

[៨១] ពួកទាសៈនៃមហារាជទាំង ៤ ព្រះអង្គនោះ គឺ កុដេណ្ឌុ ១ វេដេណ្ឌុ ១ វិដូ ១ វិដូដៈ ១ ចន្ទនៈ ១ កាមសេដ្ឋៈ ១ កិន្នុយណ្ឌុ ១ និយណ្ឌុ ១ សុទ្ធតែជាអ្នកមានមាយា ជាអ្នកល្បួងបញ្ឆោត ជាអ្នកអួតអាង តែងធ្វើនូវមាយាមកជាមួយគ្នាដែរ ។ ទាំងទេវរាជអម្បាលនេះ គឺ បនាទៈ ១ ឱបមញ្ញៈ ១ ទេវសូត ១ មាតលី ១ ចិត្តគន្ធព្វ ១ សេនគន្ធព្វ ១ នឡ្បាវជៈ ១ ជនោសភៈ ១ បញ្ចសិខៈ ១ តិម្ពរុ ១ នាងសុរិយវច្ឆសា (ជាធីតារបស់តិម្ពរុនោះ) ១ ក៏នាំគ្នាមកដែរ ។ គន្ធព្វរាជទាំងឡាយនេះផង ពួកជនៃផង ព្រមទាំងទេវរាជទាំងឡាយ មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុ

ទាំងឡាយ ។ មួយទៀត នាគទាំងឡាយនៅក្នុងស្រះ ឈ្មោះនាភស: និងនាគនៅក្នុងក្រុងវេសាលី ក៏នាំគ្នាមក ជាមួយនឹងនាគបរិសទ្យ ឈ្មោះតច្ចកកម្ពលនាគ និង អស្សតរនាគ (ដែលនៅនាជើងភ្នំសិនេរុ) ក៏នាំគ្នាមក នាគទាំងឡាយនៅក្នុងកំពង់បយាគ: ព្រមដោយពពួកញាតិ ក៏បាននាំគ្នាមកដែរ ពួកនាគដែលនៅក្នុងទន្ទេយមុនាក្តី នាគ ដែលកើតក្នុងត្រកូលស្តេចធតរដ្ឋ: មានបរិវារដ៏ច្រើនក្តី ក៏ បាននាំគ្នាមក សូម្បីតែឯរាវណទេវបុត្រជាជំរីធំនោះសោត ក៏បានមកកាន់មហាវន ជាទីប្រជុំ (នៃភិក្ខុទាំងឡាយដែរ) ។

[៨២] ពួកគ្រុឌណា ជាសត្វស្ទាបមានកំណើតពីរដង មានអានុភាពជាទិព្វ មានភ្នែកដ៏បរិសុទ្ធ (អាចមើល ឃើញពួកនាគអំពីចម្ងាយ ចំនួន ១០០ យោជន៍ ១០០០ យោជន៍) តែងចាប់យកនូវស្តេចនាគ ទៅដោយឆាប់ រហ័ស គ្រុឌទាំងនោះ ក៏ហើរមកតាមអាកាស បានមក ដល់ពាក់កណ្តាលនៃមហាវន គ្រុឌទាំងនោះមានឈ្មោះថា ចិត្រសុបណ្ណ: ដូច្នេះ គ្រានោះ ស្តេចនាគទាំងឡាយ ក៏ មិនមានសេចក្តីភ័យខ្ទាចឡើយ ព្រះសម្ពុទ្ធជាម្ចាស់ ក៏បាន ធ្វើ (ស្តេចនាគ) ឲ្យក្សេមក្សាន្តអំពីគ្រុឌ នាគ និងគ្រុឌ ទាំងឡាយ ក៏ត្រឡប់និយាយរកគ្នា ដោយសម្តីដ៏ពីរោះ

(ហាក់ដូចជាមិត្តសម្លាញ់នឹងគ្នា) បានធ្វើនូវព្រះពុទ្ធឲ្យ ជាទីពឹង ទីរឭក ។ ពួកអសុរ (ណា) ដែលព្រះឥន្ទ្រ ឈ្នះហើយ អាស្រ័យនៅក្នុងសមុទ្រ ពួកអសុរទាំងនោះ ជាបង់ប្អូន (ជាប់ពន្ធ) នឹងព្រះឥន្ទ្រ ជាអ្នកមានឫទ្ធិ មានយស ។ កាលកញ្ញអសុរទាំងឡាយ មានកាយធំ សម្បើមក្តី ទានវេយសអសុរទាំងឡាយក្តី វេបចិត្តិអសុរក្តី សុចិត្តិអសុរក្តី បហារាទអសុរក្តី នមុចិទេវបុត្តមារក្តី ក៏មកជាមួយគ្នាដែរ ។ កូនរបស់ពលិអសុរទាំង ១០០ នាក់ មានឈ្មោះថា វេរោចៈទាំងអស់ ចង់សៀតនូវគ្រឿងពលិសេនា ចូលមកគាល់រាហុអសុរិន្ទដ៏ចម្រើន ដោយពាក្យថា ឥឡូវនេះជាសម័យគួរនឹងប្រជុំគ្នា សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ដូច្នេះហើយ ទេវតាទាំងនោះ ក៏នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

[៨៣] អាបោទេវតាក្តី បថវីទេវតាក្តី តេជោទេវតាក្តី វាយោទេវតាក្តី វរុណាទេវតាក្តី វាវុណាទេវតាក្តី សោម-ទេវតា ព្រមទាំងយសទេវតាក្តី ក៏បាននាំគ្នាមកក្នុងកាលនោះ ។ ទេវតាទាំងឡាយ ដែលកើតដោយអំណាចមេត្តាឈាន និងករុណាឈាន ជាអ្នកមានយស ក៏បាននាំគ្នាមក ទេវតាទាំង ១០ ពួកនេះ ឋិតនៅដោយចំណែក ១០ សុទ្ធ

តែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានវស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំ នៃភិក្ខុទាំងឡាយ ។ ពួកទេវតាឈ្មោះវេណ្ហុក្តី ឈ្មោះសហលីក្តី ឈ្មោះអសមាក្តី និងឈ្មោះយមៈទាំងពីរពួកក្តី ពួកទេវតាដែលអាស្រ័យនូវព្រះចន្ទក្តី បានបៃហាមព្រះចន្ទ ក៏មកដែរ ។ ពួកទេវតាដែលអាស្រ័យនូវព្រះអាទិត្យ បានបៃហាមព្រះអាទិត្យមក ពួកទេវតាដែលអាស្រ័យនូវផ្កាយ ក៏បៃហាមផ្កាយមក ទាំងមនុវលាហកទេវតាទាំងឡាយ ក៏មក សូម្បីសក្កទេវរាជទ្រង់ព្រះនាមវាសវបុរិន្ទទៈដ៏ប្រសើរជាងពួកទេវតា ក៏មកដែរ ។ ទេវតាទាំង ១០ ពួកនេះ ឋិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានវស្មី មានយស មានចិត្តរីករាយ ក៏នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ មួយទៀត ទេវតាទាំងឡាយឈ្មោះសហភូដ៏រុងរឿង បីដូចជាអណ្តាតភ្លើងក៏បានមក ពួកទេវតាឈ្មោះអរិដ្ឋកៈក្តី រោជៈក្តី ឧម្មាបុប្ផនិភាសីក្តី វរុណៈក្តី សហធម្មៈក្តី អច្ចុតៈក្តី អានេជកៈក្តី សុលេយ្យៈក្តី រុចិរៈក្តី ក៏បានមក ទាំងពួកទេវតាឈ្មោះវាសវានេសីក៏បានមក ។ ទេវតាទាំង ១០ ពួកនេះ ឋិតនៅ

ដោយចំណែក ๑๐ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំង អស់ មានឫទ្ធិ មានអានុភាព មានវស្មី មានយស មាន ចិត្តរីករាយ ក៏នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំង-ឡាយ ។ ទេវតាទាំងឡាយ ឈ្មោះសមាន:ក្តី មហា-សមាន:ក្តី មានុស:ក្តី មានុសុត្តម:ក្តី ខិឌ្ឌាបទូសិក:ក្តី ក៏ បានមក ពួកទេវតាឈ្មោះមនោបទូសិក:ក៏បានមក ទាំង ពួកទេវតាឈ្មោះហរិក្តី ឈ្មោះលោហិតវាសីក្តី ក៏បានមក ទេវតាទាំងឡាយ ឈ្មោះបារគ:ក្តី ឈ្មោះមហាបារគ:ក្តី ជាអ្នកមានយសក៏បានមក ។ ទេវតាទាំង ๑๐ ពួកនេះ បិតនៅដោយចំណែក ๑๐ សុទ្ធតែមានសម្បុរផ្សេងៗ គ្នា ទាំងអស់ មានឫទ្ធិ មានអានុភាព មានវស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃ ភិក្ខុទាំងឡាយ ។ ទេវតាទាំងឡាយ ឈ្មោះសុក្ក:ក្តី កកុម្ភ:ក្តី អរុណ:ក្តី ក៏បានមកជាមួយនឹងវេយនទេវតា ។ ពួក ទេវតាឈ្មោះឱទាតគយ្ហ:ជាប្រធានក្តី ឈ្មោះវិចក្ខណ:ក្តី ក៏ បានមក ពួកទេវតាឈ្មោះសទាមត្ត:ក្តី ឈ្មោះហារគជ:ក្តី ឈ្មោះមិស្សក:ក្តី សុទ្ធតែជាអ្នកមានយស (ក៏បានមក) បជុន្នទេវរាជ ដែលញុំាងមេឃឲ្យគ្រហឹមកមូរ ហើយបង្អុរ ភ្លៀងឲ្យធ្លាក់ចុះគ្រប់ទិស ក៏បានមក ។ ទេវតាទាំង ๑๐

ពួកនេះ ឋិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរ ផ្សេងៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានវស្ដី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកវេមិយទេវតា ដែលឋិត នៅក្នុងតុសិតបុរីក្ដី ឋិតនៅក្នុងយាមទេវលោកក្ដី ពួក កដ្ឋកទេវតាដែលមានយសក្ដី ពួកលម្ពិតកទេវតាក្ដី ពួក លាមសេដ្ឋទេវតាក្ដី ពួកទេវតាឈ្មោះជោតិក្ដី ឈ្មោះ អាសវៈក្ដី ពួកនិម្មានរតីទេវតាក្ដី ក៏បានមក ទាំងពួកបរ-និម្មិតទេវតាក៏បានមក ។ ទេវតាទាំង ១០ ពួកនេះ ឋិត នៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំង អស់ មានឫទ្ធិ មានអានុភាព មានវស្ដី មានយស មាន ចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុ ទាំងឡាយ ។ ពួកទេវតាទាំង ៦០ មានអាបោទេវតា ជាដើមនេះ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មក ហើយដោយចំណែកនាម សូម្បីពួកទេវតាណាក្រៅពីនោះ ដែលមានវស្ដីប្រហែលគ្នា ក៏មកព្រមគ្នាដោយគិតថា យើង ទាំងឡាយនឹងទៅមើលព្រះអរិយសង្ឃ ដែលប្រាសចាក ជាតិ ឥតមានកិលេស ដូចជាដែកគោល លោកឆ្ងងចាក អន្លង់ទាំង ៤ ហើយ មិនមានកិលេសជាគ្រឿងត្រាំ រួច

ស្រឡះចាកឱឃៈទាំង ๔ ហើយ លោកមិនបានធ្វើនូវបាប មួយទៀត យើងនឹងបានឃើញនូវព្រះទសពល ដែលរុងរឿងដោយសិរី ដូចព្រះចន្ទឆ្វេងផុតអំពីពពក ។

[๘๔] *អរិយព្រហ្មទាំងឡាយ គឺសុព្រហ្ម និងបរមត្ត-ព្រហ្ម ជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់មានឫទ្ធិ ក៏មកជាមួយគ្នាសន្ធឹមារមហាព្រហ្មក្តី តិស្សមហាព្រហ្មក្តី ក៏នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ មហាព្រហ្មទាំង ๑๐๐๐ ក៏មកហើយ មហាព្រហ្មមួយអង្គ គ្របសង្កត់នូវព្រហ្មឯទៀតបាន មហាព្រហ្មនោះ កើតក្នុងព្រហ្ម-លោក មានអានុភាព មានកាយសម្បីម មានយស ក៏មកដែរ ។ មហាព្រហ្មទាំង ๑๐ ជាឥស្សរៈលើព្រហ្មទាំង ๑๐๐๐ នេះ តែងផ្សាយអំណាចផ្សេងៗ ក៏បានមកហាវិតមហាព្រហ្ម (ដែលមានព្រហ្មទាំង ๑ សែន) ហៃហាមក្នុងកណ្តាល នៃពួកព្រហ្មទាំងនោះ ក៏បានមក ។ សេនារបស់មារបានឃើញនូវពួកទេវតា ព្រមទាំងព្រះឥន្ទ ព្រមទាំងព្រះព្រហ្មទាំងអស់នោះ មកជួបប្រុះហើយ ក៏បានមក ហើយពោលថា អ្នកទាំងឡាយ ចូរមើលនូវសេចក្តីល្ងង់នៃមារ ។ (ឯសេនារបស់មារក៏ពោលថា) អ្នកទាំង-ឡាយចូរមក ចូរចាប់ចងពួកទេវតាទាំងនេះទុក ការចង*

*ដោយរាគៈ ចូរមានដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរ ព័ទ្ធឲ្យជុំវិញ បណ្តាអ្នកទាំងអស់គ្នា អ្នកណាមួយ ក៏កុំ បណ្តោយឲ្យទៅតាមួយអង្គ រួចទៅបានឡើយ ។ មារជា សេនាធំក្នុងទីប្រជុំធំនោះ ក៏ទះនូវផ្ទៃនៃផែនដីដោយបាតដៃ ធ្វើនូវសំឡេងគំរាមមុខគួរខ្លាច ជូចជាមហាមេឃ គ្រហឹម បង្អុរភ្លៀងមានទាំងផ្គរបន្ទោរ ក្នុងកាលនោះ មារនោះមិន អាចនឹងធ្វើ (ទេវតាណាមួយ) ឲ្យប្រព្រឹត្តទៅក្នុង អំណាចខ្លួនបាន ក៏ក្រេវក្រោធថយចេញបាត់ទៅ ។ លំដាប់ នោះ ព្រះសាស្តាទ្រង់មានចក្ខុពិចារណាហើយ ជ្រាបហេតុ នោះទាំងអស់ ទើបទ្រង់ ត្រាស់នឹងភិក្ខុជាសាវ័កទាំងឡាយ ដែលត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ មារ-សេនាមកដល់ហើយ អ្នកទាំងឡាយចូរស្គាល់នូវមារសេនា ទាំងនោះចុះ ឯពួកភិក្ខុទាំងនោះ លុះបានស្តាប់ពាក្យប្រដៅ ព្រះពុទ្ធជាម្ចាស់ហើយ ក៏ធ្វើព្យាយាម (ដើម្បីចូលកាន់ ផលសមាបត្តិ) ។ មារ ព្រមទាំងពួកសេនារបស់មារ ក៏ ចៀសចេញឆ្ងាយទៅ អំពីពួកអរិយសាវ័កដែលប្រាសចាក រាគៈ សូម្បីតែរោមរបស់ព្រះអរិយៈទាំងនោះ ក៏មិនបាន ព្រឺព្រួចឡើយ (ទើបមារពោលសរសើរភិក្ខុសង្ឃថា) ពួកសាវ័កទាំងនោះ លោកឈ្នះសឹកសង្គ្រាមហើយ កន្ទង

បង់នូវសេចក្តីភ័យខ្លាចបានហើយ មានយស ល្បីទូរទ័រទៅ
ក្នុងប្រជុំជន តែងរីករាយជាមួយនឹងព្រះអរិយៈដែលកើត
ហើយ (ក្នុងសាសនាព្រះទសពល) ។

មហាសមយសូត្រទី ៧ ចប់

อัฏฐกถา

มหาสมยสูตร

[๗๓] มหาสมยสูตรมีอาทิว่า **เอวมฺเม สุตํ** ดังนี้ ฯ

ตั้งแต่นี้ ชื่อว่าวินิจฉัยตามลำดับบทในมหาสมยสูตรนั้น ฯ บทว่า **สกฺเกสุ** *ความว่า ชนบทหนึ่ง ชื่อว่าสักกะ เป็นที่อยู่ของพระราชกุมารทั้งหลาย ที่ได้พระนามว่า สักกะ เพราะอาศัยพระราชดำรัสว่า เอหิ ตาต กุมารา เป็นต้น ก็ในที่นี้ ท่านประสงค์เอาชนบทนั่นแหละ ที่ตรัสเรียกว่า สักกะ ในอัมพัฏฐสูตร ฯ* บทว่า **กปิลวตฺถุสฺมึ** *ความว่า ในกรุงกบิลพัสดุ์ ฯ* บทว่า **มหาวเน** *ความว่า ในป่าใหญ่ที่ยังไม่ได้ตัดต้นไม้ ตั้งแต่กรุงกบิลพัสดุ์ถึงหิมวันต์ ฯ* บทว่า **สพฺเพหิว อรหนฺเตหิ** *ความว่า ในวันที่ตรัสพระสูตรนี้ พระอรหันต์ทั้งหมดก็ประชุมกันแล้ว ฯ ตั้งแต่นี้ชื่อว่าวินิจฉัยบทแห่งพากย์ ฯ*

ได้ยินมาว่า พวกสักกะและโกลิยะ ได้ทำสัญญากันไว้ว่า ที่ฝั่งแม่น้ำโรหิณีในกรุงกบิลพัสดุ์ และในนครโกลิยะ ต่างคนต่างทำนาด้วยน้ำคนละครั้งเดียวเท่านั้น ฯ ในเดือนเชฏฐมูลมาถึง ข้าวกล้าในนาทั้งสองฝั่งแม่น้ำก็แก่จัด ฯ ครั้งนั้น ชาวนาทั้งหลายของนครทั้งสองนั้นประชุมกัน ฯ ในที่ประชุมนั้น ชาวนาของนครโกลิยะกล่าวว่า น้ำนี้ควรนำมาใช้ทั้งสองครั้ง ฯ ชาวนาของนครโกลิยะแม้เหล่านั้นก็ไม่ยินยอม ชาวนาของนครสักกะแม้เหล่านั้นก็ไม่ยินยอม ต่างก็ยืนยันว่าน้ำควรนำมาใช้ครั้งเดียวเท่านั้น ขอชาวนาของนครโกลิยะจงให้น้ำแก่ชาวนาของนครสักกะเถิด ฯ ชาวนาของนครสักกะกล่าวว่า เมื่อข้าวกล้าของพวกท่านแห้งเหี่ยวแล้ว ข้าวกล้าของพวกเราก็จักสุกงอม ฯ

ខ្ញុំនឹងយកស្ពាន់ កែវមណី និងកហាបណៈ មានដៃកាន់កញ្ជើ និងទៃជាដើម ដើរទៅជិតទ្វារផ្ទះរបស់ពួកអ្នកក៏មិនបាន សូម្បីសំណាបរបស់ពួកខ្ញុំក៏សម្រេច ដោយទឹកត្រឹមតែម្តងដូចគ្នា សូមពួកអ្នកឲ្យទឹកនេះដល់ពួកខ្ញុំចុះ ពួកខ្ញុំឲ្យមិនបាន ។ ឯពួកខ្ញុំក៏ឲ្យមិនបាន ។ កាលឈ្លោះគ្នា ដៀមជាមយ៉ាងនេះហើយ ម្នាក់ក៏ក្រោកទៅវាយម្នាក់ សូម្បីអ្នកនោះក៏វាយអ្នកដទៃ គ្រប់គ្នាក៏វាយតបគ្នា និងគ្នាយ៉ាងនេះ ហើយក៏ឈ្លោះគ្នា រាលដាលជាបក្ខជាប់ទាក់ទងទៅដល់ជាតិ របស់ពួករាជត្រកូល ដោយប្រការដូច្នេះ ។

កម្មករខាងកោលិយៈនិយាយថា ពួកឯងចូរនាំយកពួកអ្នកកបិលវត្ថុ ដែលរួមសង្វាសនឹងបងប្អូនស្រីរបស់ខ្លួន ដូចគ្នានឹងពួកឆ្កែ និងចចកជាដើម ទៅ ទោះបីពួកកបិលពស្តុយកជីរី សេះ ខែល និងអាវុធរបស់ពួកគេមក ក៏ធ្វើអ្វីពួកអញមិនបាន ។ ពួកកម្មករខាងសក្យៈ ក៏ពោលដែរថា ពួកឯងក៏ចូរ នាំយកក្មេងគម្ងំ ដែលជាពួកអនាថា មិនមានគតិ នៅក្រោមដើមក្រៅ ដូចពួកតិរច្ឆានទៅឥឡូវនេះចុះ ទោះបីពួកកោលិយៈនាំយកជីរី សេះ ខែល និងអាវុធរបស់ពួកគេនោះមក ក៏ធ្វើអ្វីពួកអញមិនបាន ។ កាលជនទាំងនោះ ត្រឡប់ទៅហើយ ក៏បានប្រាប់ដល់ពួកអមាត្យ ដែលជាប់ទាក់ទងនឹងការងារ នោះ ។ ពួកអមាត្យ ក៏ក្រាបទូលដល់ពួករាជត្រកូលនោះ តពីនោះពួកស្តេច សក្យៈក៏ពោលថា ពួកយើងនឹងសម្តែងភាពក្លៀវក្លា និងកម្លាំងរបស់ពួកអ្នក រួមសង្វាសនឹងបងប្អូនស្រី ហើយក៏ត្រៀមលើកទ័ពទៅ ។ ចំណែកពួកស្តេច កោលិយៈ ក៏ពោលថា ពួកយើងនឹងសម្តែងភាពក្លៀវក្លា និងកម្លាំងរបស់ពួក

អ្នកនៅក្រោមដើមក្រៅ ហើយក៏ត្រៀមលើកទ័ពទៅ ។

ចំណែកព្រះមានព្រះភាគ កាលវេលាជិតភ្លឺនោះឯង ស្តេចចេញចាកមហាកុណាសមាបត្តិ កាលទ្រង់ពិចារណានូវលោក ទ្រង់បានឃើញជនទាំងនោះ កំពុងត្រៀមលើកទ័ពទៅយ៉ាងនេះ លុះទ្រង់ឃើញហើយ ទ្រង់ក៏ពិចារណាថា កាលតថាគតទៅ ជម្ងោះនេះនឹងស្ងប់ឬទេហ្ន៎ ទ្រង់បានជ្រាបថា កាលតថាគតទៅទីនោះហើយ នឹងសម្តែងជាតក ៣ រឿង ដើម្បីរម្ងាប់ការឈ្លោះគ្នា បន្ទាប់ពីនោះជម្ងោះក៏នឹងស្ងប់ និងដើម្បីប្រយោជន៍ដល់ការឆ្លុះបញ្ចាំងដល់ការព្រមព្រៀងគ្នា តថាគតនឹងសម្តែងជាតកពីរទៀត ហើយសម្តែងអត្តទណ្ឌសូត្រ កាលអ្នកនគរទាំងពីរបានស្តាប់ទេសនាហើយ នឹងឲ្យទារកម្នាង ២៥០ នាក់ តថាគតនឹងឲ្យទារកទាំងនោះបួស ពេលនោះ ការប្រជុំធំក៏នឹងមាន ព្រោះហេតុនោះ ខណៈដែលពួកជនទាំងនេះ កំពុងត្រៀមលើកទ័ពចេញទៅ ទ្រង់មិនសំដៅយកបុគ្គលណាមួយ ទ្រង់កាន់ជាត្រ ចីវរ យាងទៅ គង់ពត់ព្រះភ្នែនផ្សាយព្រះរស្មីមានពណ៌ ៦ ត្រង់ចន្លោះកងទ័ពទាំងពីរចំណែក ។

លុះអ្នកនគរកបិលវត្ថុ បានឃើញព្រះមានព្រះភាគយាងដល់ប៉ុណ្ណោះ ក៏គិតថា ព្រះសាស្តាព្រះញាតិដ៏ប្រសើររបស់ពួកយើងយាងមកហើយ ទ្រង់ជ្រាបការដែលពួកយើងឈ្លោះគ្នាឬហ្ន៎ ហើយគិតថា កាលព្រះមានព្រះភាគយាងមកហើយ ពួកយើងនឹងញ៉ាំងសស្ត្រាឲ្យពាល់ត្រូវសរីរៈអ្នកដទៃ មិនបានជាច់ខាត ហើយក៏ដាក់អាវុធចុះ អង្គុយសំពះព្រះមានព្រះភាគ ។ សូម្បីពួកអ្នកនគរកោលិយៈ ក៏គិតដូចគ្នាយ៉ាងនោះឯង នាំគ្នាដាក់អាវុធចុះ អង្គុយសំពះ

ព្រះមានព្រះភាគ ។ កាលទ្រង់ជ្រាបហើយ ព្រះមានព្រះភាគ ក៏ត្រាស់សួរថា មហាបពិត្រ ពួកព្រះអង្គយាងមកធ្វើអ្វី ពួកក្សត្រទាំងនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គមកទីនេះ មិនមែនដើម្បីលេងកំពង់ទឹក មិនមែនដើម្បីលេងក្តុំ មិនមែនដើម្បីលេងស្ងួង មិនមែនដើម្បីសរសើរគ្នា តែមកច្បាំងគ្នា ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រោះអាស្រ័យអ្វី ទើបទ្រង់ឈ្លោះគ្នា ព្រះរាជាទាំងនោះក្រាបទូលថា បពិត្រព្រះអង្គព្រោះ អាស្រ័យទឹក ។ ព្រះសាស្តាត្រាស់ថា ទឹកមានតម្លៃប៉ុន្មាន ព្រះរាជាទាំងឡាយទូលថា មានតម្លៃតិច ។ ព្រះសាស្តាត្រាស់ថា ឈ្លោះថា ផែនដីមានតម្លៃប៉ុន្មាន ព្រះរាជាទាំងឡាយទូលថា កាត់ថ្លៃមិនបានទេ្បីយ ។ ព្រះសាស្តាត្រាស់ថា ឈ្លោះថា ពួកក្សត្រ មានតម្លៃប៉ុន្មាន ព្រះរាជាទាំងនោះទូលថា ឈ្លោះថា ពួកក្សត្រកាត់ថ្លៃមិនបាន ។ ព្រះមានព្រះភាគត្រាស់ថា ពួកទ្រង់អាស្រ័យទឹកដែលមានតម្លៃតិចហើយមកធ្វើឲ្យពួកក្សត្រ ដែលកាត់ថ្លៃមិនបានឲ្យវិនាសដើម្បីអ្វី ហើយត្រាស់ថា ក្នុងការឈ្លោះគ្នា មិនមានសេចក្តីរីករាយ មហាបពិត្រទាំងឡាយ ដោយអំណាចការឈ្លោះគ្នា ការឈឺចាប់ផ្លូវចិត្ត ដែលរុក្ខទេវតាមួយអង្គ ធ្វើពៀរក្នុងទីដែលមិនគួរប្រព្រឹត្តទៅបាន ហើយចងទុកជាមួយខ្លាឃ្មុំ បានជាប់តាមទៅ រហូតដល់អស់ ១ កប្ប ហើយត្រាស់ផនួនជាតក ។ បន្ទាប់ពីនោះ ត្រាស់ទៀតថា មហាបពិត្រទាំងឡាយ មិនគប្បីជាអ្នកក្ងាក់ផ្អើល ព្រោះហ្វូងសត្វជើង ៤ ក្នុងព្រៃហិមពាន្ត ដែលមានទទឹងរហូត ៣ ពាន់យោជន៍ ក្ងាក់ផ្អើល ព្រោះពាក្យនិយាយរបស់ទន្សាយមួយ បាននាំគ្នារត់ទៅរហូតដល់សមុទ្រ

ព្រោះដូច្នោះ មិនគប្បីជាអ្នកក្ងាក់ផ្អើល ហើយត្រាស់ទុទ្ទុកាយជាតក បន្ទាប់ពីនោះត្រាស់ថា មហាបពិត្រទាំងឡាយពេលខ្លះ សូម្បីតែបុគ្គលដែលទន់ខ្សោយ ក៏ឃើញចំណុចខ្សោយរបស់អ្នកមានកម្លាំងច្រើនបាន ពេលខ្លះ បុគ្គលមានកម្លាំងច្រើន ក៏ឃើញកំហុសរបស់អ្នកខ្សោយបាន ពិតហើយ សូម្បីតែចាបចៀបកប្បាស ក៏អាចសម្លាប់ដំរីបាន ហើយត្រាស់លដុកិកជាតក[1] ។ កាលត្រាស់ជាតកទាំងបីរឿង ដើម្បីរម្ងាប់ការឈ្លោះគ្នាយ៉ាងនេះហើយ ដើម្បីឆ្លុះបញ្ចាំងដល់កាព្រមព្រៀងគ្នា ទើបបានត្រាស់ជាតកពីររឿងទៀត ។ សួរថា ទ្រង់ត្រាស់ដូចម្តេច ឆ្លើយត្រាស់ថា មហាបពិត្រទាំងឡាយ សត្រូវមិនអាចនឹងបានឱកាសក្នុងពួកបុគ្គលដែលព្រមព្រៀងគ្នា ហើយត្រាស់រុក្ខធម្មជាតក ។ បន្ទាប់ពីនោះ ទ្រង់តាស់ថា មហាបពិត្រទាំងឡាយ សត្រូវមិនអាចឃើញឱកាសរបស់ពួកបុគ្គលដែលព្រមព្រៀងគ្នាឡើយ តែកាលពួកសត្វធ្វើវិវាទដល់គ្នានិងគ្នា កាលនោះ កូនព្រានក៏សម្លាប់សត្វទាំងនោះកាន់យកទៅ ដែលឈ្មោះថា ការត្រេកអរ រមែងមិនមានក្នុងការឈ្លោះគ្នាឡើយ ហើយត្រាស់សម្មោទមានជាតក កាលត្រាស់ជាតកទាំង ៥ រឿងនេះស្រេចហើយ ចុងបញ្ចប់ ទ្រង់ត្រាស់អត្តទណ្ឌសូត្រ ។

ព្រះរាជាទាំងឡាយទ្រង់ជ្រះថ្លា ត្រាស់ថា បើព្រះសាស្តាស្តេចមិនបានយាងមក ពួកយើងក៏នឹងសម្លាប់គ្នាឯងដោយដៃរបស់ខ្លួនហើយធ្វើឲ្យស្ទឹងឈាម

๑- សព្ទថា លដុកិក នេះ ក្នុងជាតកនេះ ប្រែថា ចាបចៀបកប្បាស តែក្នុងលដុកិកូបមសូត្រ ប្រែថា សត្វប្រចៀចទៅវិញ ។

ឲ្យហូរទៅ ពួកយើងនឹងមិនគប្បីឃើញកូន និងបងប្អូនរបស់យើង ត្រង់ទ្វារផ្ទះ ពួកយើងនឹងមិនមានសូម្បីតែអ្នកនាំសារឆ្លើយឆ្លងគ្នា ពួកយើងបានជីវិតព្រោះអាស្រ័យព្រះសាស្តា បើព្រះសាស្តានឹងទ្រង់គ្រប់គ្រងផ្ទះ រាជសម្បត្តិក្នុងទ្វីបធំ ៤ ដែលមានទ្វីបតូច ២ ពាន់ជាបរិវារ ក៏គង់នឹងបាននៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះអង្គ កូនៗ របស់ពួកយើងទាំងពាន់នាក់ជាងក៏មាន និងតពីនោះ ព្រះអង្គក៏នឹងមានក្សត្រជាបរិវារត្រាច់ទៅ តែទ្រង់លះបង់សម្បត្តិនោះហើយទ្រង់ចេញទៅ សម្រេចព្រះសម្មាធិញ្ញាណហើយ ឥឡូវនេះ ក៏សូមឲ្យទ្រង់មានក្សត្រជាបរិវារត្រាច់ទៅ ដូច្នេះ ។ ក្សត្រទាំង ២ នគរ ក៏បានថ្វាយព្រះរាជកុមារ ម្នាង ២៥០ អង្គ ។ ព្រះមានព្រះភាគ ទ្រង់ឲ្យព្រះរាជកុមារទាំងនោះបួសហើយ ក៏យាងទៅកាន់មហាវ័ន ព្រោះភាពដែលភិក្ខុទាំងនោះគោរពយ៉ាងធ្ងន់ ទើបការអផ្សុកកើតឡើងដល់ភិក្ខុទាំងនោះ ដែលមិនបានបួសតាមសេចក្តីពេញចិត្តរបស់ខ្លួន ។ សូម្បីពួកបុរាណទុតិយិការបស់ភិក្ខុទាំងនោះ ក៏ពោលពាក្យជាដើមថា សូមព្រះអយ្យបុត្តទាំងឡាយសឹកចុះ ការគ្រប់គ្រងផ្ទះទ្រង់នៅមិនបានឬ ហើយក៏បញ្ជូនសំបុត្រ ។ ភិក្ខុទាំងនោះក៏រីងរឹតតែអផ្សុកថែមទៀត ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាហើយ ក៏ទ្រង់ជ្រាបការមិនត្រេកអររបស់ពួកភិក្ខុទាំងនោះ ទ្រង់គិតថា ពួកភិក្ខុទាំងនេះ នៅរួមគ្នានឹងព្រះពុទ្ធដូចតថាគត តើនឹងអផ្សុកដូចម្តេច តថាគតនឹងពោលសរសើរស្រះតារៀជាមុនពួកភិក្ខុទាំងនេះ ហើយក៏ទ្រង់នាំទៅកាន់ទីនោះ ទ្រង់ព្រះចិន្តាថា តថាគតនឹងបន្ទោបង់ការអផ្សុក ទើបទ្រង់ពោលគុណរបស់ស្រះតារៀ ។ ពួកភិក្ខុទាំង

នោះ ក៏ជាអ្នកចង់ឃើញស្រះនោះ ។ ព្រះមានព្រះភាគ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចង់ឃើញស្រះតាវៅឬ ។ ពួកភិក្ខុក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ មក ពួកយើងទៅ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គនឹងទៅកាន់ទីដែលទៅរបស់ពួកលោកអ្នកមានឫទ្ធិបានដូចម្តេច ។ ព្រះសាស្តាត្រាស់ថា ពួកអ្នកប្រាថ្នាចង់ទៅស្រះនោះ តថាគតនឹងនាំទៅដោយអានុភាពរបស់តថាគត ។ ភិក្ខុទាំងឡាយក្រាបទូលថា សាធុ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុ ៥០០ អង្គ ហោះទៅក្នុងអាកាស ចុះត្រង់ទីជិតស្រះតាវៅ និងត្រាស់ចំពោះភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ស្រះតាវៅនេះ អ្នកណាមិនស្គាល់ឈ្មោះពួកត្រី ចូរសួរតថាគត ។ ភិក្ខុទាំងនោះទូលសួរហើយ ។ ព្រះមានព្រះភាគ ក៏ត្រាស់ប្រាប់វត្ថុដែលភិក្ខុសួរហើយសួរទៀត ។ និងមិនមែនតែឈ្មោះពួកត្រីប៉ុណ្ណោះ ទ្រង់ឲ្យសួរដល់ឈ្មោះរបស់ដើមឈើទាំងឡាយ ក្នុងជង្ហែព្រៃនោះផង របស់សត្វជើង ២ ជើង ៤ និងបក្សីត្រង់ជើងក្នុងផង ហើយទ្រង់ប្រាប់ ។

គ្រានោះ ស្តេចតាវៅ ទំត្រង់កំណាត់ឈើដែលតាវៅ ២ ពាំកំណាត់ឈើនោះសង្ខាង មានពួកតាវៅចោមរោមពីមុខ ពីក្រោយ និងសង្ខាងកំពុងមក ។ កាលភិក្ខុបានឃើញបក្សីនោះ ក៏ទូលសួរថា បពិត្រព្រះអង្គ ទុំះប្រហែលជាស្តេចរបស់បក្សីទាំងនោះ ខ្ញុំព្រះអង្គទាំងឡាយយល់ថា ពួកបក្សីទាំងនោះ ជាបរិវាររបស់ស្តេចបក្សីនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ យ៉ាងនោះឯង នេះជាវង្សរបស់តថាគត ជាបវេណីរបស់តថាគត ។ ពួកភិក្ខុពោលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមើលសត្វទាំងនោះត្រឹមតែម្តង ក៏ពួកខ្ញុំព្រះអង្គចង់ស្តាប់ប្រការដែលព្រះមានព្រះភាគត្រាស់ថា នេះក៏ជាវង្សរបស់តថាគត ជាបវេណីរបស់តថាគត ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកចង់ស្តាប់ឬ ។ ភិក្ខុទាំងឡាយពោលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា បើដូច្នោះ ចូរស្តាប់ ហើយក៏ត្រាស់កុណាលជាតក ប្រជាប់ដោយគាថា ៣០០ ទ្រង់បន្ទោបង់សេចក្តីអផ្សុក កាលចប់ទេសនា ភិក្ខុទាំងនោះ ក៏តាំងនៅក្នុងសោតាបត្តិផលគ្រប់អង្គ សូម្បីតែឫទ្ធិរបស់ភិក្ខុទាំងនោះ ក៏មកព្រមគ្នានឹងមគ្គនុ៎ះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រែះរិះថា សម្រាប់ភិក្ខុទាំងនេះត្រឹមតែប៉ុណ្ណោះសិនចុះ ហើយទ្រង់ក៏ហោះទៅក្នុងអាកាស យាងទៅកាន់មហាវនុ៎ះឯង ។ ភិក្ខុទាំងនោះកាលទៅ ក៏ទៅដោយអំណាចរបស់ព្រះទសពល តែកាលមកចោមរោមព្រះមានព្រះភាគ ក្នុងព្រៃមហាវន ក៏មកដោយខ្លួនឯង ។

ព្រះមានព្រះភាគ ប្រថាប់លើទីអង្គុយដែលក្រាលទុកហើយ ត្រាស់ហៅភិក្ខុទាំងនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរមក តថាគតនឹងប្រាប់កម្មដ្ឋាន ដើម្បីឲ្យពួកអ្នកលះកិលេស ដែលត្រូវលះដោយមគ្គ ៣ ខាងលើ ហើយក៏ទ្រង់ប្រាប់កម្មដ្ឋាន ។ ពួកភិក្ខុនាំគ្នាគិតថា ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ពួកយើងអផ្សុក ទើបទ្រង់នាំទៅស្រះតារៅ ទ្រង់បន្ទោបង់សេចក្តីអផ្សុកឥឡូវនេះ ទ្រង់បានប្រទានកម្មដ្ឋានសម្រាប់មគ្គទាំង ៣ ក្នុងទីនេះដល់ពួកយើង

ដែលសម្រេចសោតាបត្តិផលក្នុងទីនោះហើយ ឯពួកយើងមិនគួរឲ្យវេលាកន្លងហួស ដោយគិតថា ពួកយើងជាព្រះសោតាបន្នហើយ ពួកយើងគួរជាឧត្តមបុរស ទើបភិក្ខុទាំងនោះថ្វាយបង្គំបាទារបស់ព្រះទសពល ហើយក្រោកឡើងរលាស់អាសនៈ បែកគ្នាទៅអង្គុយត្រង់ញែកកន្លែង និងគល់ឈើ ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះ ដោយប្រក្រតី ក៏មិនលះបង់ការងារសម្រាប់ភិក្ខុដែលបានឧបាយ មិនមានហេតុនៃការនឿយហត់ កាលទៅតាំងវិបស្សនាហើយ ក៏បានសម្រេចអរហត្ត ហើយនាំគ្នាមកកាន់សម្នាក់តថាគត ដោយគិតថា ពួកយើងនឹងក្រាបទូលគុណវិសេស ដែលយើងម្នាក់ៗ បានចំពោះហើយ កាលពួកភិក្ខុទាំងនោះមក ពួកទេវតាក្នុងចក្រវាល ១ ម៉ឺន នឹងប្រជុំគ្នាក្នុងចក្រវាលមួយ មហាសម័យ គឺការប្រជុំធំនឹងមាន តថាគតគួរអង្គុយក្នុងទីស្ងាត់ ។ លំដាប់នោះ ក៏ត្រាស់បង្គាប់ឲ្យក្រាលពុទ្ធាសនៈក្នុងទីដែលស្ងាត់ ហើយប្រថាប់គង់ ។

ព្រះថេរៈដែលទទួលកម្មដ្ឋានមុនគេ សម្រេចអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយហើយ ។ បន្ទាប់មកភិក្ខុមួយរូបទៀត បន្ទាប់មកភិក្ខុមួយរូបទៀត ដូច្នេះ ភិក្ខុទាំង ៥០០ អង្គ រីកដូចផ្កាឈូកដែលរីកក្នុងស្រះឈូកដូច្នោះ ។ ភិក្ខុដែលសម្រេចអរហត្តមុនគេបង្អស់ គិតថា យើងនឹងក្រាបទូលដល់ព្រះមានព្រះភាគ ទើបក្រោកចាកទីអង្គុយបែរមុខទៅរកព្រះទសពល ។ មួយរូបទៀតក៏យ៉ាងនោះ មួយរូបទៀតក៏យ៉ាងនោះ ដូច្នេះ ភិក្ខុទាំង ៥០០ រូបមកតាមលំដាប់ ដូចចូលកាន់រោងធាន ដូច្នោះ ។ ភិក្ខុដែលមកមុនគេ ថ្វាយ

បង្គំ និងក្រាលទីអង្គុយ ហើយអង្គុយក្នុងទីដ៏សមគួរមួយ ជាអ្នកប្រាថ្នានឹងក្រាបទូលនូវគុណវិសេស ដែលបានដោយចំពោះ គិតថា អ្នកដទៃណាមានឬមិនមានហ្ន៎ បែរសម្លឹងមើលផ្លូវមក បានឃើញភិក្ខុមួយអង្គហើយ មួយអង្គទៀត ។ ដោយប្រការដូច្នេះ ឈ្មោះថា លោកទាំងអស់នោះ ក៏មកអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ហើយក៏គិតថា ភិក្ខុរូបនេះកំពុងខ្វាស ទើបមិនប្រាប់ដល់អង្គនេះ អង្គនេះក៏កំពុងខ្វាស ទើបមិនប្រាប់ដល់អង្គនេះ បានឮថា សម្រាប់បុគ្គលអស់អាសវៈហើយ រមែងមានអាការពីរយ៉ាង គឺកើតសេចក្តីគិតថា មនុស្សលោក ព្រមទាំងទេវតា គប្បីចាក់ផ្តុំនូវគុណវិសេស ដែលអញបានចំពោះហើយ ដោយឆាប់រួសរាន់ ๑ មិនប្រាថ្នានឹងប្រាប់គុណដែលខ្លួនបានហើយដល់អ្នកដទៃ ដូចអ្នកដែលបានកំណប់ទ្រព្យដូច្នោះ ๑ ។ កាលអរិយមណ្ឌលទាំងនោះឈមចុះហើយ ព្រះចន្ទពេញវង់ដែលផុតពីភាពសៅហ្មង គឺអព្ភ ទឹកសន្សើម ផ្សែង ធូលី រាហូ ចាកផុតព្រំដែនភ្នំយុគន្ធរនាទិសខាងកើត ប្រកបដោយសិរីនៃកងប្រាក់ ដែលកំពុងវិលទៅ ហាក់បីដូចជារង្វង់កញ្ចក់ដ៏ធំ ដែលសម្រេចដោយប្រាក់ ដែលលើកឡើងក្នុងទិសខាងកើត ដើម្បីមើលទីគួរវែកវាយរបស់លោក ដែលប្រដាប់ដោយពុទ្ធប្បាទ អណ្តែតទៅតាមផ្លូវខ្យល់ ។ ព្រះមានព្រះភាគប្រថាប់ នៅត្រង់ព្រៃមហាវន ជិតក្រុងកបិលវត្ថុ ក្នុងដែននៃពួកអ្នកសក្កៈ ជាមួយពួកភិក្ខុចំនួនច្រើន គឺភិក្ខុមានចំនួន ๕๐๐ អង្គ គ្រប់រូបសុទ្ធតែជាព្រះអរហន្តក្នុងខណៈ គឺលយៈ បានដល់ ក្នុងវេលាមួយភ្លែតបែបនេះ ដោយប្រការដូច្នេះ ។

ក្នុងទីប្រជុំនោះ ព្រះមានព្រះភាគ ទ្រង់កើតក្នុងវង្សព្រះបាទមហាសម្មត ពួកភិក្ខុទាំង ៥០០ អង្គនោះ ក៏កើតក្នុងត្រកូលព្រះបាទមហាសម្មត ព្រះមានព្រះភាគ ទ្រង់កើតក្នុងព្រះគភ៌ក្សត្រ ភិក្ខុទាំងនោះ ក៏កើតក្នុងគភ៌ក្សត្រ ព្រះមានព្រះភាគ ទ្រង់ជាអ្នកបួស ភិក្ខុទាំងនោះ ក៏ជាអ្នកបួស ព្រះមានព្រះភាគ ទ្រង់លះបង់ស្វេតច្ឆត្រ ទ្រង់លះបង់រាជសម្បត្តិជាស្តេចចក្រពត្តិដែលនៅក្នុងព្រះហស្ត ទ្រង់ព្រះផ្នួស ភិក្ខុទាំងនោះក៏លះបង់ស្វេតច្ឆត្រ លះរាជសម្បត្តិដែលនៅក្នុងដៃ ហើយបួស ។ សេចក្តីដូចពោលមកនេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់បរិសុទ្ធ ទ្រង់មានបរិវារដែលបរិសុទ្ធ ក្នុងឱកាសដែលបរិសុទ្ធ ក្នុងចំណែកវត្តីដ៏បរិសុទ្ធ ទ្រង់ប្រាសចាករាគៈ ទ្រង់មានបរិវារដែលប្រាសចាករាគៈ ទ្រង់ប្រាសចាកទោសៈ ទ្រង់មានបរិវារដែលប្រាសចាកទោសៈ ទ្រង់ប្រាសចាកមោហៈ ទ្រង់មានបរិវារដែលប្រាសចាកមោហៈ ទ្រង់មិនមានតណ្ហា ទ្រង់មានបរិវារដែលមិនមានតណ្ហា ទ្រង់មិនមានកិលេស ទ្រង់មានបរិវារដែលមិនមានកិលេស ទ្រង់ស្ងប់ ទ្រង់មានបរិវារដែលស្ងប់ ទ្រង់ទូន្មានហើយ ទ្រង់មានបរិវារដែលទូន្មានហើយ ទ្រង់រួចផុតហើយ ទ្រង់មានបរិវារដែលរួចផុតហើយ ទ្រង់រុងរឿងគ្មានអ្វីប្រៀបផ្ទឹម ដោយប្រការដូច្នេះ ។ នេះឈ្មោះថា ជាប្រភេទវណ្ណៈអាចនិយាយបានប៉ុនណា ក៏គប្បីនិយាយប៉ុណ្ណោះ ។ សេចក្តីដូចពោលមកនេះ ព្រះអានន្ទសំដៅយកភិក្ខុទាំងនេះ ទើបពោលថា ភិក្ខុមានចំនួន ៥០០ អង្គ សុទ្ធតែជាព្រះអរហន្ត ដូច្នេះ ។

បទថា **យេភុយ្យេន** *គឺច្រើនជាង ប្រជុំគ្នាហើយ ដែលតិចរៀរលែងតែ*

ទេវតាមិនមានសញ្ញា ទេវតាជាន់អរូបាវចរ និងទេវតាដែលចូលសមាបត្តិ មិនបានចូលប្រជុំ។ តទៅនេះ ជាលំដាប់ការចូលប្រជុំក្នុងមហាសមយសូត្រនោះ។

បានឮថា ពួកទេវតាដោយជុំវិញព្រៃមហាវន រំជើបរំជួលហើយ ធ្វើសំឡេងខ្ទាំងៗថា មកចុះអ្នកដ៏ចម្រើនទាំងឡាយ ឈ្មោះថា ការឃើញព្រះពុទ្ធមានឧបការៈច្រើន ការស្តាប់ព្រះធម៌មានឧបការៈច្រើន ការឃើញពួកភិក្ខុមានឧបការៈច្រើន មកចុះពួកយើង ហើយក៏នាំគ្នាមកនមស្ការព្រះមានព្រះភាគ និងពួកព្រះខីណាស្រព ដែលសម្រេចអរហត្តក្នុងវេលាមួយរំពេចនោះហើយ ឈរក្នុងទីដ៏សមគួរក្នុងចំណែកម្ខាង។ ដោយឧបាយនេះនោះឯង គប្បីជ្រាបថា ពួកទេវតាទាំងឡាយក្នុង ១ សែនចក្រវាលមកប្រជុំគ្នា ព្រោះស្តាប់សំឡេងទេវតាទាំងនោះ ដោយលំដាប់ គឺទេវតាដែលនៅក្នុងចក្រវាលទាំងអស់ ដែលនៅក្នុងសកលជម្ពូទ្វីប បុព្វវិទេហទ្វីប អមរគោយានទ្វីប ឧត្តរ-កុរុទ្វីប ក្នុងទ្វីបតូច ២ ពាន់ គឺពួកទេវតាដែលអាស្រ័យនៅក្នុងព្រៃហិមពន្ត ដែលមានទំហំប្រមាណ ៣ ពាន់យោជន៍ ដោយស្តាប់សំឡេងទេវតា ដែលអាស្រ័យនៅក្នុងទីកន្ទុះគាវុត មួយគាវុត កន្ទុះយោជន៍ មួយយោជន៍ ដោយលំដាប់តគ្នា ទេវតាក្នុងនគរ ១៨៤០០០ នគរ ទេវតានៅត្រង់ទោណមុខ ៨៤០០០០០ កន្លែង ទេវតានៅត្រង់បជនៈ ៨៦ សែនកោដិ និងអាស្រ័យនៅត្រង់សមុទ្រ ៥៦ កន្លែង មកប្រជុំគ្នាហើយ បន្តអំពីនោះ ក៏ទេវតាក្នុងចក្រវាលទី ២-៣ ជាដើម មកប្រជុំគ្នាដោយប្រការដូច្នេះ។ ចក្រវាល ១ ម៉ឺនលោកសំដៅយកថា ១០ លោកធាតុក្នុងទីនេះ។ ហេតុនោះ ទើបលោកពោល

ថា ទេវតាមកពី ១០ លោកធាតុ ដោយច្រើន ប្រជុំគ្នាហើយ ។

ផ្ទៃចក្រវាលទាំងមូល រហូតដល់ព្រហ្មលោក ពោរពេញទៅដោយពួកទេវតាដែលមកប្រជុំយ៉ាងនោះ ដូចបំពង់ម្ទុលដែលពេញទៅដោយម្ទុល ដាក់ជរាបរកទីដាក់មិនបាន ។ ក្នុងផ្ទៃចក្រវាលទាំងមូលនោះ គប្បីជ្រាបថា ដែលខ្ពស់ជាងគេ បានដល់ ផ្ទៃចក្រវាលរបស់ព្រហ្មលោក ។ បានឮថា បុគ្គលឈរក្នុងព្រហ្មលោក យកដុំថ្មប៉ុនផ្ទះកំពូល ៧ ជាន់ ក្នុងលោហប្រាសាទទម្លាក់ចុះមកអស់រយៈពេល ៤ ខែ ទើបដល់ផែនដី ។ ក្នុងឱកាសធំបែបនោះ មានទេវតាជរាបរកទីដាក់មិនបាន ដូចផ្លាឈើដែលអ្នកឈរខាងក្រោមបោះទៅឬដូចផែ្សងមិនមានផ្លូវដើម្បីហុយទៅឆ្ងាយទៅខាងលើ ឬដូចគ្រាប់ស្ពៃដែលអ្នកឈរខាងលើ រោយទៅ មិនមានប្រយោជន៍ដើម្បីធ្លាក់ចុះក្រោម ដូច្នោះ ។ ការប្រថាប់គង់របស់ព្រះមានព្រះភាគ មិនចង្អៀតដល់ពួកទេវតា និងពួកព្រហ្មដែលមានសក្តិធំ ដែលមកហើយនោះ រមែងបានឱកាសគ្រប់អង្គ ដូចទីប្រថាប់របស់ស្តេចចក្រពត្តិ រមែងមិនចង្អៀតដល់ពួកក្សត្រជាអ្នកធំ ដែលយោងមកហើយនោះ ទ្រង់ក៏បានឱកាសទំនេរនុ៎ះឯង ដូច្នោះ ។ បានឮមកថា ប្រទេសសូម្បីទំហំប៉ុនចុងរោមទ្រាយ តាមន័យដែលពោលហើយ ក្នុងមហាបរិនិព្វាន-សូត្រ ក្នុងទីជិតព្រះមានព្រះភាគនុ៎ះឯង ក៏នៅមានទេវតា ១០ អង្គខ្វះ ២០ អង្គខ្វះ និម្មិតរាងកាយតូចល្អិតឈរ ។ ខាងមុខទាំងអស់មានទេវតា ៦០ អង្គៗ ឈរហើយ ។

បទថា **សុទ្ធាវាសកាយิกานំ** *គឺព្រហ្មសុទ្ធាវាស ។ ព្រហ្មលោក ៥*

ជាន់ ដែលជាលំនៅរបស់ព្រះអនាគាមី និងព្រះខីណាស្រពដែលបរិសុទ្ធ ឈ្មោះថា **សុទ្ធាវាស** ។ *បទថា* **ឯតទហោសិ** *គឺហេតុអ្វីទើបមាន ។ បានឮថា ក្នុងគ្រានោះ ពួកព្រហ្មទាំងនោះ ចូលសមាបត្តិហើយ ចេញតាមកំណត់ កាលសម្លឹងមើលលំនៅរបស់ព្រហ្ម ក៏បានឃើញទេ ដូចរោងធាន់ក្នុងវេលាក្រោយភត្ត បន្ទាប់ពីនោះ ពិចារណាថា ពួកព្រហ្មទៅណាអស់ហ្ន៎ ជ្រាបថា ទៅកាន់ទីប្រជុំធំ គិតថា សមាគមនេះធំ ចំណែកពួកយើងវេលាតែបង្អែបង្អង់ សម្រាប់ពួកអ្នកបង្អែបង្អង់នឹងរកឱកាសបានលំបាក ព្រោះដូច្នោះ កាលនឹងទៅ ពួកយើងកុំមានដៃទេ ក៏ចងគាថាមួយអង្គមួយបទ ហើយសឹមទៅ ពួកយើងនឹងឲ្យព្រះមានព្រះភាគទ្រង់ជ្រាបថា ខ្ញុំនមក្នុងសមាគមដូចគ្នា ដោយគាថានោះ ហើយនឹងពោលព្រះកិត្តិគុណ របស់ព្រះទសពលផង ។ ទើបសេចក្តីត្រិះរិះយ៉ាងនេះមាន ព្រោះភាពដែលព្រហ្មទាំងនោះចេញចាកសមាបត្តិហើយ ពិចារណា ដោយប្រការដូច្នេះ ។ បទថា* **ភគវតោ បុរតោ ចាតុរហោសុំ** *សេចក្តីថា លោកធ្វើព្រហ្មទាំងនោះ ឲ្យដូចធ្លាក់ចុះក្នុងទីចំពោះព្រះភក្ត្រ ជិតព្រះមានព្រះភាគនុ៎ះឯង ពោលហើយក្នុងបាលី តែក្នុងទីនេះ មិនគប្បីយល់សេចក្តីយ៉ាងនេះឡើយ ។*

ព្រហ្មទាំងនោះ ឋិតនៅក្នុងព្រហ្មលោក តែងគាថាស្រេចហើយ មួយអង្គចុះត្រង់កណ្តាប់ចក្រវាលខាងកើត មួយអង្គចុះត្រង់កណ្តាប់ចក្រវាលខាងត្បូង មួយអង្គចុះត្រង់កណ្តាប់ចក្រវាលលិច មួយអង្គចុះត្រង់កណ្តាប់ចក្រវាលខាងជើង ។ បន្ទាប់អំពីនោះ ព្រហ្មដែលចុះត្រង់កណ្តាប់ចក្រវាលខាងកើត ក៏

ចូលនីលកសិណ បញ្ចេញនូវស្មីពណ៌ខៀវ ប៉ីដូចជាដណ្តប់ស្បែកកែវមណី ហើយឲ្យទេវតាក្នុង ๑ ម៉ឺនចក្រវាលដឹងថា ខ្ញុំនមកហើយ ធម្មតាវិថីរបស់ព្រះពុទ្ធ មិនមានបុគ្គលណាអាចនឹងកន្ទងទៅបាន ព្រោះដូច្នោះ ទើបមកដោយវិថីរបស់ព្រះពុទ្ធ ដែលប៉ះខ្ចប់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ឈរនៅក្នុងទីដ៏សមគួរនាចំណែកម្ខាង ហើយពោលនូវគាថាដែលខ្ញុំនបានចង ។ ព្រហ្មដែលចុះត្រង់កណ្តាប់ចក្រវាលផ្នែកខាងត្បូង ក៏ចូលបីតកសិណ បញ្ចេញរស្មីមានពន្លឺដូចមាស ដូចជាដណ្តប់សំពត់មាស ប្រកាសឲ្យទេវតាក្នុង ๑ ម៉ឺនចក្រវាលដឹងថា ខ្ញុំនមក ហើយឈរក្នុងទីនោះឯង ។ ព្រហ្មដែលចុះត្រង់កណ្តាប់ចក្រវាលខាងលិច ចូលលោហិតកសិណ បញ្ចេញរស្មីក្រហម ដូចជណ្តប់សំពត់រោមសត្វដ៏ល្អមានពណ៌ក្រហម ប្រកាសឲ្យទេវតាក្នុង ๑ ម៉ឺនចក្រវាលដឹងថា ខ្ញុំនមក ហើយឈរយ៉ាងនោះដូចគ្នា ។ ព្រហ្មដែលចុះត្រង់កណ្តាប់ចក្រវាលផ្នែកខាងជើង ចូលឱទាតកសិណបញ្ចេញរស្មីពណ៌ស ដូចជណ្តប់សំពត់ផ្កាម្ទិះ ប្រកាសឲ្យទេវតាក្នុង ๑ ម៉ឺនចក្រវាល ដឹងថា ខ្ញុំនមក ហើយ បានឈរយ៉ាងនោះដូចគ្នា ។ តែក្នុងបាលីពោលថា ព្រហ្មទាំងឡាយនោះ ប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគថា គ្រានោះ ទេវតាទាំងនោះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ នាចំណែកម្ខាងដូច្នេះ ហើយបានពោលភាពប្រាកដខាងមុខ និងការអភិវាទ ហើយឈរក្នុងទីដ៏សមគួរនាចំណែកម្ខាងដូចគ្នា ក្នុងខណៈតែមួយ ដូច្នោះ ។ ការប្រាកដ និងការឈរមានតាមលំដាប់នេះ តែលោកធ្វើឲ្យព្រមគ្នា សម្តែងហើយ ។ ឯការ

ពោលគាថាក្នុងបាលី លោកពោលចែកជាផ្នែកៗ នោះឯង ។

[๗๔] *ក្នុងបទទាំងនោះ បទថា* **មហាសមយោ** *ប្រែថា ការប្រជុំធំ ។ ព្រៃក្រាស់ហៅថា ព្រៃធំ ព្រះមានព្រះភាគត្រាស់ថា មហាសម័យ គឺការចូលប្រជុំធំមានក្នុងថ្ងៃនេះ ត្រង់ព្រៃជ្រៅនេះ ដោយបទទាំងពីរ ។ បន្ទាប់អំពីនោះ ដើម្បីសម្តែងពួកដែលចូលប្រជុំនោះ ទើបព្រះមានព្រះភាគត្រាស់ថា ពួកទេវតាក៏មកប្រជុំគ្នាហើយ ។ ក្នុងបទថា* **ទេវកាយា** *នោះ គឺពួកទេវតា ។ បទថា* **អាគតម្ហ ឥមំ ធម្មសមយំ** *គឺកាលបានឃើញពួកទេវតាមកប្រជុំគ្នាយ៉ាងនេះ សូម្បីពួកយើង ក៏មកកាន់ធម្មសម័យនេះ ។ ព្រោះហេតុអ្វី ព្រោះដើម្បីឃើញពួកបុគ្គលដែលមិនមានបុគ្គលណាឈ្នះបាន អធិប្បាយថា ពួកយើងមកដើម្បីសរសើរពួកបុគ្គលដែលមិនមានអ្នកណាឈ្នះបាននេះ បុគ្គលឈ្មោះថា ពិជិត-សង្គ្រាម ព្រោះជាបុគ្គលដែលមិនមានអ្នកណាផ្ចាលផ្ចាញ់បាន ហើយញាំញីមារទាំង ៣ ប្រកេទបានក្នុងថ្ងៃនេះឯង ។ ព្រហ្មនោះ កាលពោលគាថានេះហើយ ក៏អភិវាទព្រះមានព្រះភាគ បានឈរត្រង់កណ្តាប់ចក្រវាលខាងកើត ។ បន្ទាប់មកព្រហ្មទី ២ ក៏មកពោលតាមន័យដែលពោលហើយនុ៎ះឯង ។*

[๗๕] *ក្នុងបទថា* **តត្រ ភិក្ខវោ** *នោះ បានដល់ ពួកភិក្ខុដែលនៅក្នុងទីប្រជុំនោះ ។ បទថា* **សមាធយាំសុ** *គឺប្រកបដោយសមាធិ ។ បានគាថាថា* **ចិត្ត មត្តនោ ឧជុកំ អកំសុ** *បានដល់ បាននាំការវៀច និងការកោងចេញអស់ហើយ ធ្វើចិត្តរបស់ខ្លួនឲ្យត្រង់ ។ បានគាថាថា* **សារថិវ ឧត្តានិ គហេត្វា** *សេចក្តីថា កាលពួកសេះសិន្ធពទៅយ៉ាងរៀបរយ សារថីដាក់ជន្លួញចុះ ហើយ*

ចាប់ខ្សែទាំងអស់ទុក មិនជាស់តឿន មិនបញ្ឈប់ តាំងនៅយ៉ាងណា ភិក្ខុទាំង ៥០០ នេះ ដល់ព្រមដោយឆន្ទរាគៈបក្ខា ឃុំគ្រងទ្វារបានហើយ បណ្ឌិតរក្សា ឥន្ទ្រិយទាំងឡាយទុកដូច្នោះ ព្រហ្មពោលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំ ព្រះអង្គ ជាអ្នកមកទីនេះ ដើម្បីសរសើរភិក្ខុទាំងនេះ ។ ហើយព្រហ្មទាំងនោះ ក៏ទៅឈរតាមតំណែងរៀងខ្លួន ។ បន្ទាប់មក ព្រហ្មទី ៣ ក៏មកពោលតាម នយដែលពោលហើយនុ៎ះឯង ។

[๗๖] *ក្នុងបទទាំងនោះ បទថា* **ឆេត្វា ឱឃំ** *គឺកាត់ដែកគោល បានដល់ រាគៈ ទោសៈ និងមោហៈ ។ បទថា* **បលិឃំ** *បានដល់ រនុក គឺរាគៈ ទោសៈ និងមោហៈនុ៎ះឯង ។ បទថា* **ឥន្ទ្រឱឃំ** *បានដល់ សសរគោល គឺរាគៈ ទោសៈ និងមោហៈនុ៎ះឯង ។ បទថា* **ឧហាច្ចមនេជា** *គឺពួកភិក្ខុឈ្មោះថា មិន ញាប់ញ័រ ព្រោះមិនមានការញាប់ញ័រ គឺតណ្ហា ដកហើយ គឺគាស់រម្ងើម សសរគោលបានហើយ ។ បទថា* **តេ ចរន្តិ** *គឺត្រាច់ទៅដោយការមិនទើស ទាក់នឹងបុគ្គលណាម្នាក់ក្នុងទិសទាំង ៤ ។ បទថា* **សុទ្ធា** *គឺមិនមានអ្វីដែលចូល មកធ្វើឲ្យចិត្តសៅហ្មង ។ បទថា* **វិមលា** *គឺមិនមានមន្ទិល ។ បទថា* **វិមលា** *នេះ ជាវេវចនៈនឹងបទថា* **សុទ្ធា** *នុ៎ះឯង ។ បទថា* **ចក្ខុមតា** *គឺមានភ្នែក ដោយចក្ខុ ៥ ។ បទថា* **សុឧត្តា** *គឺទូន្មានភ្នែក ត្រេចៀក ច្រមុះ អណ្តាត ផ្លូវ កាយហើយ ផ្លូវចិត្តក៏ទូន្មានហើយ ។ បទថា* **សុសុទាគា** *គឺនាគក្មេងៗ ។ ព្រហ្មអធិប្បាយថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គជាអ្នកមកហើយ ដើម្បី*

សរសៅរនោគជំទង់ដែលទូន្មានហើយ ដោយសេចក្តីព្យាយាមជាគ្រឿងប្រកបដ៏កំពូលបែបនេះ ។ សូម្បីព្រហ្មអង្គនោះ ក៏បានទៅឈរតាមតំណែងនុ៎ះឯង ។ បន្ទាប់មកព្រហ្មទី ៤ ក៏បានមកពោលតាមន័យដែលពោលហើយនុ៎ះឯង ។

[๗๗] *បណ្តាបទទាំងនោះបទថា* **គតាសេ** *គឺដល់ហើយ ដោយការដល់សរណៈដែលមិនមានសេចក្តីសង្ស័យ ។ សូម្បីព្រហ្មអង្គនោះ ក៏បានទៅឈរតាមតំណែងនុ៎ះឯង ។*

[๗๘] *លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់បានត្រួតមើលតាំងពីផ្ទៃផែនដី ដរាបទល់នឹងកំណត់កណ្តាប់ចក្រវាល ពីកណ្តាប់ចក្រវាលទល់ព្រហ្មលោក ទតឃើញការប្រជុំរបស់ទេវតាហើយ ទើបទ្រង់ព្រះតម្រិះថា សមាគមទេវតានេះធំ ចំណែកពួកភិក្ខុមិនជ្រាបថា សមាគមទេវតានេះ ធំយ៉ាងនេះ ណ្ហើយចុះ តថាគតនឹងប្រាប់ពួកភិក្ខុទាំងនេះ កាលទ្រង់ត្រិះរិះយ៉ាងនោះស្រេចហើយ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុ ដោយប្រការដូច្នេះ ។ គប្បីពង្រីកសេចក្តីឲ្យទូលាយទាំងអស់ ។*

បណ្តាបទទាំងនោះ បទថា **ឯតបរមោ** *គឺឈ្មោះថា មានត្រឹមប៉ុណ្ណេះយ៉ាងក្រៃលែង ព្រោះប៉ុណ្ណេះជាប្រមាណយ៉ាងក្រៃលែង របស់ព្រះពុទ្ធទាំងនោះ ។ ព្រោះកាលឥឡូវនេះ មិនមានព្រះពុទ្ធទាំងឡាយ ទើបមិនត្រាស់ជាលើកទី ៣ ថា ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធទាំងឡាយណា ក្នុងកាលឥឡូវនេះ ។ បទថា* **អាចិក្ខិស្សាមិ ភិក្ខវេ** *សេចក្តីថា សួរថា ហេតុដូចម្តេច ទើបត្រាស់ឡើយថា ដើម្បីឲ្យជ្រាបការដល់ព្រមនៃចិត្តរបស់ពួកទេវតា បានឮថា*

ពួកទេវតានាំគ្នាគិតថា ព្រះមានព្រះភាគទ្រង់នឹងពោលឈ្មោះ និងគោត្រ តែ ពួកទេវតាថ្នាក់ធំប៉ុណ្ណោះ ឯពួកទេវតាថ្នាក់តូច ទ្រង់នឹងប្រាប់នៅក្នុងសមាគម ធំនេះធ្វើអ្វី ។ ភ្លាមនោះ ព្រះមានព្រះភាគ ទ្រង់ពិចារណាថា ទេវតាទាំងនេះ គិតដូចម្តេច ទ្រង់ជ្រាបវារចិត្តនោះ របស់ទេវតាទាំងនោះ ដូចស៊ីកដៃចូល មាត់ ហើយស្ទាបអង្អែលហទយៈ និងដូចចាប់ចោរបានទាំងភស្តុតាង ទើប ទ្រង់ត្រិះរិះថា តថាគតនឹងពោលដល់ឈ្មោះ និងគោត្រ របស់ពួកទេវតាទាំង អស់ ទាំងថ្នាក់តូច និងថ្នាក់ធំ ដែលនាំគ្នាមកអំពី ១ ម៉ឺនចក្រវាល ។

ធម្មតាថា ព្រះពុទ្ធទាំងឡាយទ្រង់ជាមហន្តបុគ្គល ព្រះពុទ្ធទាំងនោះ ទ្រង់ ជាសត្វពិសេស ទ្រង់ជ្រាបវត្ថុដែលមនុស្សលោក ព្រមទាំងទេវលោកបានឃើញ បានឲ្ព បានជ្រាប បានដឹងច្បាស់ បានដល់ បានស្វែងរក បានប្រើចិត្ត អន្ទោលទៅតាម មិនថា វត្ថុណាមួយ ក្នុងទីណាមួយ ទោះជារូបារម្មណ៍ក្នុង រូបារម្មណ៍ ដែលចែកដោយអំណាចរូប មានរូបពណ៌ខៀវជាដើម ឬអារម្មណ៍ មានសំឡេងជាដើម ដែលចែកជាផ្នែកៗ ក្នុងសទ្ទារម្មណ៍ជាដើម ដែលចែក ដោយអំណាចសំឡេងស្គរជាដើម ដែលមកកាន់គន្ធងចំពោះព្រះញាណរបស់ ព្រះពុទ្ធទាំងនោះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក ។បេ។ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឲ ពាល់ត្រូវ បានដឹងច្បាស់ បានដល់ បាន ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ឯ អារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះ មិនស្ថិតនៅក្នុង

តថាគតទេ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះញាណមិនមានអ្វីមកវារាំងបាន គ្រប់គ្រា គ្រប់ទីកន្លែងយ៉ាងនេះ ទ្រង់បានធ្វើពួកទេវតាទាំងអស់នោះ ឲ្យជា ២ ពួក ដោយអំណាចកពូសត្វ និងអកពូសត្វ គឺពួកដែលជាអកពូសត្វ ពោលដោយន័យជាដើមថា សត្វពួកណាជាប់ព្រមដោយទំនប់ គឺកម្ម សត្វពួកនោះ ទោះនៅរួមវិហារគ្នា ព្រះពុទ្ធទាំងឡាយ ក៏ទ្រង់មិនសម្លឹងមើល ឯពួកកពូសត្វ ដែលផុយគ្នានឹងពួកអកពូសត្វនោះ សូម្បីនៅឆ្ងាយ ក៏ទ្រង់យាងទៅជ្រោស ។ ព្រោះដូច្នោះ ក្នុងការប្រជុំរបស់ទេវតានោះ ព្រះមានព្រះភាគ ទ្រង់លះពួកដែលអកពូ ហើយរួបរួមយកតែពួកកពូសត្វ កាលរួបរួមស្រេចហើយ ទ្រង់ក៏ចាត់ជា ៦ ពួក តាមអំណាចចរិតនុ៎ះឯងថា ពួករាគចរិតប៉ុណ្ណេះ ពួកទោស-ចរិតប៉ុណ្ណេះជាដើម ។

បន្ទាប់មក ទ្រង់ពិចារណាធម៌ទេសនា ដែលជាទីសប្បាយដល់ពួកចរិតទាំងនោះ ទ្រង់កំណត់ទេសនាថា ពួកទេវតារាគចរិត តថាគតនឹងសម្តែងសម្មាបរិព្វាជនីយសូត្រ (សូត្រពោលអំពីរឿងដែលគប្បីវៀរដោយប្រពៃ) និងសម្តែងកលហវិវាទសូត្រ (សូត្រដែលសម្បយុត្តដោយវិវាទ) ដល់ពួកទេវតាទោសចរិត និងសម្តែងមហាព្យូហសូត្រ (សូត្រពោលអំពីពួកធំ) ដល់ពួកមោហចរិត និងសម្តែងចូឡព្យូហសូត្រ (សូត្រពោលអំពីពួកតូច) ដល់ពួកវិតក្កចរិត និងសម្តែងតុវដ្តកបដិបទា (បដិបទារបស់សត្វក្រួច) ដល់ពួកសទ្ធាចរិត និងសម្តែងបុរាភេទសូត្រ (សូត្រពោលអំពីរឿងបែកក្នុងអនាគត) ដល់ពួកពុទ្ធិចរិត ហើយក៏ទ្រង់ជាក់ព្រះទ័យដល់បរិស័ទនោះទៀត

ថា បរិសទ្ទគប្បីដឹងដោយអធ្យាស្រ័យរបស់ខ្លួន ដោយអធ្យាស្រ័យរបស់អ្នកដទៃ ដោយអត្ថុប្បត្តិហេតុ ឬដោយអំណាចការសួរហ្ន៎ បន្ទាប់អំពីនោះ ទ្រង់ជ្រាបថា បរិសទ្ទគប្បីដឹងដោយអំណាចការសួរ ហើយទ្រង់ព្រះតម្រិះថា នឹងមានអ្នកណា ឬមិនមានហ្ន៎ ដែលជាអ្នកកាន់យកអធ្យាស្រ័យរបស់ពួកទេវតា ហើយអាចសួរបញ្ហាដោយអំណាចចរិតបាន ទ្រង់ឃើញថា ក្នុងពួកកិកូទាំង ៥០០ នោះ តែមួយអង្គក៏មិនអាច ។ បន្ទាប់អំពីនោះ ទ្រង់រួមយកព្រះមហាសាវក ៨០ អង្គ និងអគ្គសាវក ២ អង្គ ទ្រង់ឃើញថា កិកូទាំងនោះក៏មិនអាច ហើយទ្រង់រំពឹងថា បើគប្បីមានព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធនឹងអាចឬទេហ្ន៎ ទ្រង់ជ្រាបថា ព្រះបច្ចេកពុទ្ធក៏មិនអាច ទ្រង់សរុបថា ក្នុងបណ្តាសក្តទេវរាជ និងស្តេចសុយាម:ជាដើម បុគ្គលណាម្នាក់ដែលអាចឆ្លើយឆ្លងជាមួយតថាគត មិនមាន ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ព្រះពុទ្ធដូចតថាគតប៉ុណ្ណោះ ទើបអាច តើមានព្រះពុទ្ធអង្គដទៃក្នុងទីណាខ្លះទេ ហើយក៏ទ្រង់ផ្សាយព្រះញាណដែលមិនមានទីបំផុត ទៅក្នុងលោកធាតុ ដែលមិនមានទីបំផុត ទ្រង់ពិចារណា ទ្រង់មិនបានឃើញព្រះពុទ្ធអង្គដទៃ ។ ប្រការដែលទ្រង់មិនឃើញអ្នកណាស្មើព្រះអង្គក្នុងឥឡូវនេះ នុ៎ះមិនគួរអស្ចារ្យឡើយ សូម្បីក្នុងថ្ងៃប្រសូត កាលទ្រង់មិនឃើញអ្នកណាស្មើព្រះអង្គ តាមន័យដែលពោលហើយក្នុងអដ្ឋកថាព្រហ្មជាលសូត្រ ព្រះអង្គក៏បានបន្ទឺសីហនាទ ដែលមិនមានបុគ្គលណាម្នាក់ឲ្យប្រព្រឹត្តទៅបានថា យើងជាកំពូលនៃលោក ដូច្នេះ ។

កាលទ្រង់មិនឃើញអ្នកជនៃស្មើនឹងព្រះអង្គយ៉ាងនេះហើយ ទ្រង់គិតថា បើតថាគតគប្បីសួរ ហើយឆ្លើយដោយខ្លួនឯង សូម្បីយ៉ាងនេះ ទេវតាទាំងនេះក៏នឹងមិនអាចចាក់ផ្ទុះបាន ប៉ុន្តែបើព្រះពុទ្ធអង្គដទៃនុ៎ះឯងទ្រង់សួរ ហើយតថាគតឆ្លើយ ទើបជាវត្តុគួរអស្ចារ្យ ពួកទេវតាក៏អាចចាក់ផ្ទុះបាន ដូច្នោះ តថាគតនឹងនិម្មិតព្រះពុទ្ធនិម្មិត ។ ហើយទ្រង់ចូលឈានដែលមានអភិញ្ញាជាបាទ កាលទ្រង់ចេញហើយ ទ្រង់បរិកម្មដោយកាមាវចរចិត្តទាំងឡាយថា សូមឲ្យការកាន់បាត្រ និងចីវរ ការមើលទៅមុខ និងមើលមកក្រោយ និងការបត់ចូល និងលាចេញ ចូរដូចតថាគតនោះឯង ហើយក៏ទ្រង់អធិដ្ឋានដោយរូបាវចរចិត្ត ដូចទម្ងាយព្រះចន្ទ ដែលកំពុងអណ្តែតត្រង់ឃុគន្ធរបណ្ណល នាទិសខាងកើត ឲ្យចេញទៅ ដូច្នោះ ។

កាលពួកទេវតាបានឃើញពុទ្ធនិម្មិតនោះ ក៏និយាយថា ម្នាលគ្នាយើងព្រះចន្ទដួងដទៃទៀតហើយឬហ្ន៎ ។ កាលព្រះពុទ្ធនិម្មិត ទ្រង់អណ្តែតចូលមកជិត ក៏និយាយថា មិនមែនព្រះចន្ទ តែជាព្រះអាទិត្យរះឡើងទេ កាលចូលជិតមកទៀត ក៏និយាយថា មិនមែនព្រះអាទិត្យ នុ៎ះជាវិមានទេវតា ។ កាលចូលជិតមកទៀត ក៏និយាយថា មិនមែនវិមានទេវតា នុ៎ះជាទេវបុត្រ ។ កាលចូលជិតមកទៀត ក៏និយាយថា មិនមែនទេវបុត្រ នុ៎ះជាមហាព្រហ្ម កាលចូលជិតមកទៀត ក៏និយាយថា មិនមែនជាមហាព្រហ្ម តែជាព្រះពុទ្ធមួយអង្គទៀតយាងមក ដូច្នេះ ។ ក្នុងទីនោះ ពួកទេវតាបុថុជ្ជន ក៏នាំគ្នាគិតថា ព្រះពុទ្ធតែមួយអង្គ ទីប្រជុំទេវតាក៏ធំយ៉ាងនេះហើយ ពីរព្រះអង្គនឹងធំយ៉ាងណា (ឯ)

ទេវតាអរិយៈ ក៏នាំគ្នាគិតថា ក្នុងលោកធាតុតែមួយ មិនមានព្រះពុទ្ធពីរព្រះអង្គ ព្រះមានព្រះភាគនោះឯង ទ្រង់និម្មិតព្រះពុទ្ធអង្គជទៃមួយព្រះអង្គទៀត ដែលដូចនឹងព្រះអង្គដោយពិត ។

ខណៈដែលពួកទេវតាកំពុងឃើញព្រះពុទ្ធនិម្មិតនុ៎ះឯង ព្រះពុទ្ធនិម្មិតក៏យាងមកជល់ ទ្រង់មិនសំពះព្រះទសពលឡើយ ទ្រង់ធ្វើស្មើៗ ក្នុងទីចំពោះព្រះភក្ត្រ ហើយក៏ប្រថាប់គង់លើសេនាសនៈដែលនិម្មិត ។ មហាបុរិស-លក្ខណៈ ៣២ ប្រការរបស់ព្រះមានព្រះភាគយ៉ាងណា មហាបុរិសលក្ខណៈរបស់ពុទ្ធនិម្មិតក៏មាន ៣២ ប្រការដូចគ្នា ។ ព្រះរស្មី ៦ ពណ៌ ចេញអំពីព្រះសរីរៈរបស់ព្រះមានព្រះភាគយ៉ាងណា របស់ពុទ្ធនិម្មិតក៏ដូចគ្នា ។ ព្រះរស្មីចេញអំពីព្រះសរីរៈរបស់ព្រះមានព្រះភាគ ប៉ះខ្ទប់ព្រះកាយរបស់ពុទ្ធនិម្មិត រស្មីចេញព្រះសរីរៈរបស់ពុទ្ធនិម្មិត ក៏ប៉ះខ្ទប់ព្រះកាយព្រះមានព្រះភាគ ។ រស្មីទាំងនោះ ផ្សាយចេញអំពីសរីរៈរបស់ព្រះពុទ្ធទាំងពីរអង្គ ទល់គ្នានឹងអកនិដ្ឋព្រហ្មត្រឡប់អំពីនោះ ក៏ចូលក្នុងទីបំផុត គ្រប់សិរ្សរបស់ពួកទេវតា ហើយតាំងនៅត្រង់កណ្តាប់ចក្រវាល ។ ផ្ទៃចក្រវាលទាំងមូលរុងរឿង ដូចខឿនចេតិយដែលមានជហ្វាសម្រេចដោយប្រាក់ ដូច្នោះ ។ ទេវតាក្នុង ១ ម៉ឺនចក្រវាល រួមជាក្រុមក្នុងចក្រវាលតែមួយ ចូលទៅតាំងនៅក្នុងចន្លោះព្រះរស្មី របស់ព្រះពុទ្ធទាំងពីរព្រះអង្គ ។ កាលព្រះពុទ្ធនិម្មិតកំពុងប្រថាប់គង់នោះឯង សារសើរការលះកិលេសត្រង់ពោធិបល្ល័ង្ករបស់ព្រះភគវា ទើបត្រាស់គាថាថា

ខ្ញុំសូមសួរនូវព្រះមុនី ដែលមានប្រាជ្ញាច្រើន បានឆ្លងចាក

ឱឃៈ(ដល់នូវត្រើយគឺព្រះនិព្វាន)បានរម្ងាប់ហើយ មាន ព្រះហឫទ័យតាំងនៅមាំ កិក្ខុបន្ទោបង់នូវកាមទាំងឡាយ ហើយចេញចាកផ្ទះ កិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក តើដោយប្រការ ដូចម្តេច ។

ព្រះសាស្តា កាលទ្រង់គិតថា តថាគតនឹងពោលដល់ឈ្មោះ និងគោត្រ របស់ទេវតាដែលមកហើយៗ ដើម្បីឲ្យពួកទេវតាកើតភាពជាអ្នកមានចិត្តព្រមព្រៀងគ្នាមុន ទើបត្រាស់ពាក្យជាដើមថា ម្នាលកិក្ខុទាំងឡាយ តថាគតនឹងសម្តែង ដូច្នេះ ។

[๗๙] *បណ្តាបទទាំងនោះ បទថា* **សិលោកមនុកស្សាមិ** *គឺពាក្យដែលចងជាឆន្ទ គឺនឹងឲ្យពួកពាក្យដែលនិយមហើយដោយបទអក្ខរៈប្រព្រឹត្តទៅ ។ បទថា* **យត្ត ភុម្មា តទស្សិតា** *សេចក្តីថា ពួកទេវតាដែលនៅតាមផែនដីក្នុងទីណាមួយ ក៏អាស្រ័យទីនោះៗហើយ ។ ព្រះមានព្រះភាគត្រាស់ប្រាប់ប្រកេទពណ៌សម្បុរដល់កិក្ខុទាំងនោះ ដោយបទជាដើមថា ពួកកិក្ខុណាដែលនៅអាស្រ័យនឹងផ្នែកភ្នំ អធិប្បាយថា កិក្ខុពួកណាអាស្រ័យខ្នងភ្នំ ។ បទថា* **បហិតត្តា** *គឺមានចិត្តដែលបញ្ជូនទៅហើយ ។ បទថា* **សមាហិតា** *គឺមិនរវើរវាយ ។ បទថា* **ឃុឃុ** *គឺជនច្រើន ។ បទថា* **សិហាវ សល្លីន** *គឺចូលដល់ភាពជាអ្នកមានចិត្តតែមួយ ដូចសីហៈលាក់ខ្លួន ។ បទថា* **លោមហំសាភិ-សម្ភុនោ** *គឺគ្របសង្កត់រោមដែលបះឡើង ហើយតាំងនៅ ។ មានពាក្យអធិប្បាយថា មិនមានភ័យ ។ បទថា* **ឱឃាតមនសា សុទ្ធា** *គឺជាអ្នកមានចិត្ត*

ស្អាតបរិសុទ្ធ ។ បទថា **វិប្បសន្នមនាវិលា** គឺថ្លាស្អាតមិនល្អក់ ។ បទថា **ភិយ្យោ បញ្ចសតេ ញត្វា** គឺទ្រង់ជ្រាបលើសពី ៥០០ អង្គ ព្រោះរាប់ទាំងព្រះសម្មាសម្ពុទ្ធផង ។ បទថា **វនេ កាបិលវត្ថនេ** គឺក្នុងជងព្រៃ ដែលកើតឯងជិតក្រុងកបិលវត្ថុ ។ បទថា **តតោ អាមន្ថយិ សត្ថា** គឺត្រាស់ហៅក្នុងគ្រានោះ ។ បទថា **សាវកេ សាសនេ រតេ** គឺឈ្មោះថា សាវក ព្រោះកើតក្នុងទីបំផុតនៃការស្តាប់ព្រះធម្មទេសនារបស់ព្រះអង្គ ឈ្មោះថា អ្នកត្រេកអរក្នុងសាសនា ព្រោះត្រេកអរក្នុងសាសនា គឺសិក្ខា ៣ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើពាក្យទាំងអស់នេះ ឲ្យដូចអ្នកដទៃពោល ត្រាស់ដោយព្រះតម្រាស់ថា តថាគតនឹងធ្វើពាក្យស្មោក ។ បទថា **ទេវកាយា អភិក្ពន្ថា តេ វិជានាថ ភិក្ខវោ** សេចក្តីថា ព្រះមានព្រះភាគ ត្រាស់ដើម្បីប្រយោជន៍ដល់អភិនីហារនៃទិព្វចក្ខុញ្ញាណរបស់ភិក្ខុទាំងនោះថា ពួកអ្នកចូរស្គាល់ពួកទេវតាទាំងនោះ ដោយទិព្វចក្ខុ ដូច្នេះ ។

បទថា **តេ អាតប្បមករុំ សុត្វា ពុទ្ធស្ស សាសនំ** សេចក្តីថា ភិក្ខុទាំងនោះ ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគហើយ ភ្លាមនោះឯងក៏បានធ្វើសេចក្តីព្យាយាមដើម្បីប្រយោជន៍ដល់ទិព្វចក្ខុនោះ ។ ញាណក៏បានប្រាកដដល់ភិក្ខុទាំងនោះ ដែលគ្រាន់តែបានប្រារព្ធធ្វើសេចក្តីព្យាយាមនុ៉ះឯងយ៉ាងនោះ ។ សេចក្តីនេះដូចម្តេច គឺទិព្វចក្ខុញ្ញាណ ដែលជាគ្រឿងឃើញពួកអមនុស្សកើតឡើងហើយ ។ ទិព្វចក្ខុញ្ញាណនោះ មិនមែនថា ពួកលោកទាំងនោះធ្វើបរិកម្មហើយ ឲ្យកើតឡើងក្នុងខណៈនោះ តែទិព្វចក្ខុញ្ញាណនោះ

សម្រេចដោយមគ្គនោះឯង ។ ឯហេតុត្រឹមតែអភិនីហារនៃទិព្វចក្ខុញ្ញាណ ដើម្បីឃើញអមនុស្សនោះប៉ុណ្ណោះ បានធ្វើហើយ ។ សូម្បីព្រះសាស្តា ទ្រង់សំដៅយកប្រការនេះឯងថា ពួកអ្នកមានញ្ញាណ បើដូច្នោះ ចូរពួកអ្នកបង្អោនញ្ញាណ ទៅដើម្បីដឹង ហើយទើបត្រាស់ថា អ្នករាល់គ្នាចូរស្គាល់នូវពួកទេវតាទាំងនោះ ។ បទថា **អប្បេកេ សតមទ្ធក្ខុំ** សេចក្តីថា ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកខ្លះបានឃើញពួកអមនុស្ស ១០០ ។ បទថា **សហស្សំ អថ សត្តរឹ** សេចក្តីថា ពួកខ្លះឃើញអមនុស្ស ១០០០ ពួកខ្លះឃើញអមនុស្ស ៧ ម៉ឺន ។ បទថា **សតំ ឯកេ សហស្សានំ** សេចក្តីថា ភិក្ខុពួកខ្លះឃើញអមនុស្ស ១ សែន ។ បទថា **អប្បេកេនន្តមទ្ធក្ខុំ** សេចក្តីថា បានឃើញយ៉ាងធំ អធិប្បាយថា បានឃើញអមនុស្សសូម្បីនឹងកំណត់ដោយអំណាចចំនួន ១០០ និងដោយអំណាចចំនួន ១០០០ ក៏មិនបាន ព្រោះហេតុអ្វី ព្រោះអមនុស្សបានផ្សាយពាសពេញក្នុងទិសទាំងពួង គឺមានពាសពេញទីកន្លែង ។

បទថា **តញ្ច សព្វំ អភិញ្ញាយ** គឺក្នុងភិក្ខុទាំងនោះ វត្ថុណា ដែលភិក្ខុមួយរូបបានឃើញ ក៏ដឹងវត្ថុទាំងអស់នោះដែរ ។ បទថា **វវក្ខិត្វាន ចក្ខុមា** គឺព្រះសាស្តាទ្រង់មានចក្ខុ ដោយចក្ខុទាំង ៥ យ៉ាង ទ្រង់ពិចារណាដោយប្រចក្ស ដូចអ្នកពិចារណាមើលក្រឡាបាតដៃ ដូច្នោះ ទើបត្រាស់ព្រះគាថា ដែលពោលមកកាលមុនថា តអំពីនោះ ទើបត្រាស់ហៅ ដើម្បីប្រារព្ធដល់ឈ្មោះ និងគោត្រ ។ ក្នុងបទនេះ មានសេចក្តីជាប់ទាក់ទងយ៉ាងនេះថា ពួកអ្នកចូរដឹង គឺចូរមើល បានដល់ ចូរសម្ញឹងមើលពួកអមនុស្ស ដែលតថាគតនឹងប្រាប់ដល់

ពួកអ្នក ។ បទថា **តិរាហិ** គឺដោយពាក្យទាំងឡាយ ។ បទថា **អនិបុព្វសោ** គឺតាមលំដាប់ ។

បទថា **សត្តសហស្សា វ យក្ខា ភុម្មា កាបិលវត្ថវា** គឺព្រះមានព្រះភាគត្រាស់ថា ពួកយក្ខ គឺពួកទេវតានៅតាមផែនដី អាស្រ័យក្រុងកបិល-វត្ថុ កើតក្នុងក្រុងកបិលវត្ថុនោះ ។ បទថា **ឥទ្ធិមន្តោ** គឺប្រកបដោយទិព្វឫទ្ធិ ។ បទថា **ជុតិមន្តោ** គឺដល់ព្រមដោយអានុភាព ។ បទថា **វណ្ណាវន្តោ** គឺបរិបូណ៌ដោយពណ៌សម្បុរនៃរាងកាយ ។ បទថា **យសស្សិនោ** គឺបរិបូណ៌ដោយបរិវារ ។ បទថា **មោឧមានា អភិក្ពាមុំ** គឺមានចិត្តត្រេកអរមក ។ បទថា **ភិក្ខូនំ សមិតឹ វនំ** គឺមកដើម្បីមើលព្រៃធំនេះ គឺសម្នាក់របស់ពួកភិក្ខុនេះ បានដល់ ដើម្បីមើលភិក្ខុទាំងឡាយ ។ ម្យ៉ាងទៀត បទថា **សមតិ** ហៅថា ប្រជុំ អធិប្បាយថា មកដើម្បីមើលពួកភិក្ខុ ដូច្នេះក៏បាន ។ បទថា **ឆសហស្សា ហោមវតា យក្ខា នានត្តវណ្ណិនោ** គឺពួកយក្ខដែលកើតត្រង់ភ្នំហោមវត: ៦ ពាន់ ពួកយក្ខ ទាំងអស់នោះ មានសម្បុរផ្សេងៗ គ្នា ដោយអំណាចពណ៌ខៀវជាដើម ។ បទថា **សាតាគិរា តិសហស្សា** គឺពួកយក្ខដែលកើតត្រង់ភ្នំសាតាគិរី ៣០០០ ។ បទថា **ឥច្ចេតេ សោឡសសហស្សា** គឺយក្ខ ទាំងអស់នេះ រួមគ្នាជា ១៦០០០។ បទថា **វស្សាមិត្តា បញ្ចសតា** គឺពួកយក្ខដែលកើតលើភ្នំវេស្សាមិត្ត ៥០០ ។ បទថា **កុម្ភីរោ រាជគហិកោ** គឺយក្ខឈ្មោះកុម្ភីរ កើតក្នុងក្រុងរាជគ្រឹះ ។ បទថា **វេបុល្ជស្ស និវេសនំ** អធិប្បាយថា ភ្នំវេបុល្ជានិវេសន៍ គឺទីលំនៅរបស់

របស់យក្ខនោះ ។ បទថា **ភយ្យោ នំ សតសហស្សំ យក្ខានំ បយิรุបาสติ** *គឺយក្សច្រើនជាង ๑ សែន ចូលគាល់យក្សឈ្មោះកុម្ភីរនោះ ។ បទថា* **กุมฺภีโร ราชคหิโก เสาวาค สมิติ วนំ** *គឺសូម្បីយក្ខឈ្មោះកុម្ភីរនោះ ព្រមទាំងបរិវារ ក៏មកកាន់ព្រៃនេះ ដើម្បីមើលការប្រជុំរបស់ភិក្ខុទាំងឡាយ ។*

[๘๐] *បទថា* **ปุริมญฺ จิสំ ราชา ธตរฏฺโ បสาสติ** *គឺទ្រង់គ្រប់គ្រងទិសខាងកើត ។ បទថា* **คนฺธพฺพานំ อธิปติ** *គឺទ្រង់ជាប្រធានរបស់ពួកគន្ធព្វ (ទេវតាតន្ត្រី) គន្ធព្វទាំងអស់នោះ ប្រព្រឹត្តទៅក្នុងអំណាចរបស់ស្តេចធត-រដ្ឋ:នោះ ។ បទថា* **มหาราชา យสสฺวี เสา** *គឺមហារាជអង្គនោះ ទ្រង់មានបរិវារច្រើន ។ បទថា* **បុตฺตาปิ ตสฺส พหโว ส ฆนามา มหาพลา** *គឺបុត្ររបស់ព្រះបាទធតរដ្ឋ:នោះ មានច្រើន មានកម្លាំងច្រើន បុត្រទាំងឡាយនោះទ្រង់នូវឈ្មោះដូចសក្ក: ដែលជាស្តេចនៃទេវតា ។ បទថា* **วิรูเฬฺห តំ បสา-สติ** *គឺទិសនោះ ព្រះបាទវិរុឡ្ហ: ទ្រង់ប្រៀនប្រដៅ ។ បទថា* **បุตฺตาปิ ตสฺส** *គឺបុត្ររបស់ព្រះបាទវិរុឡ្ហ:នោះក៏ដូចគ្នា ។ ឯក្នុងបាលីវចនាទុកថា* **มหาพลา** *គឺមានកម្លាំងច្រើន ។ ក្នុងវារ:ទាំងអស់ក្នុងអដ្ឋកថា ចាប:ជា* **มหาពលา** *។ ឯគាថា ព្រះមានព្រះភាគត្រាស់ដោយអំណាចរួមយកទាំងអស់យ៉ាងនេះថា*

ព្រះបាទធតរដ្ឋ: ជាធំក្នុងទិសខាងកើត ព្រះបាទវិរូឡ្ហ: ជា
ធំក្នុងទិសខាងត្បូង ព្រះបាទវិរូបក្ខ: ជាធំក្នុងទិសខាងលិច
ព្រះបាទកុវេរ: ជាធំក្នុងទិសខាងជើង មហារាជទាំង ๔ ព្រះ

អង្គនោះ បានញុំាងទិសទាំង ๔ ដោយជុំវិញ ឲ្យភ្ញីព្រោង ព្រាត (ដោយរស្មីរបស់ខ្លួន) ស្ថិតនៅក្នុងមហាវន ជិតក្រុងកបិលវត្ថុ ។

ក្នុងគាថានោះ មានអត្ថដូច្នេះថា ក្នុង ๑ ម៉ឺនចក្រវាលជនៃទៀត ក៏មានពួកមហារាជ ព្រះនាមថាធតរដ្ឋៈ ។ មហារាជទាំងអស់នោះ ទ្រង់ក៏មានគន្ធព្វ ๑ សែនកោដិជាបរិវារ ឈរពេញផ្ទៃចក្រវាល តាំងអំពីព្រៃមហាវន ជិតក្រុងកបិលវត្ថុនាទិសខាងកើត ។ ស្តេចវិរុឡ្ហៈក្នុងទិសខាងត្បូងជាដើមក៏យ៉ាងនេះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ទ្រង់ញុំាងទិសទាំង ๔ ដោយជុំវិញឲ្យរុងរឿង ហើយប្រថាប់នៅ ។ ឯពាក្យអធិប្បាយមានយ៉ាងនេះថា មកពីចក្រវាលដោយជុំវិញ ញុំាងទិសទាំង ๔ ឲ្យរុងរឿងយ៉ាងល្អ ប្រថាប់នៅដូចគំនរភ្លើង លើកំពូលភ្នំ ។ លោកទាំងនោះ ទ្រង់សំដៅយកព្រៃជិតក្រុងកបិលវត្ថុប៉ុណ្ណោះឯង ទើបមក ព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ដល់ពួកលោកថា ជាអ្នកញុំាងចក្រវាលឲ្យពេញស្មើៗគ្នា ហើយប្រថាប់ត្រង់ព្រៃ ជិតក្រុងកបិលវត្ថុ ដូច្នេះ ។

បទថា **តេសំ មាយាវិនោ ទាសា អាគុំ វញ្ចនិកា សឋា** *សេចក្តីថា មហារាជទាំងនោះ ទ្រង់មានទាសៈដែលប្រព្រឹត្តកោង ប្រកបដោយមាយា មានការបិទបាំងនូវអំពើអាក្រក់ដែលធ្វើហើយជាលក្ខណៈ ជាពួកដែលហៅថា អ្នកល្បួងបញ្ឆោតបន្ទំលោក ដោយការបញ្ឆោតបន្ទំទាំងចំពោះមុខ និងកំបាំងមុខ និងពួកដែលហៅថា ជាអ្នកអួតអាង ព្រោះប្រកបដោយភាពក្អេងក្អាង និងអួត*

អាង ពួកទេវតាទាំងនោះក៏មក ។ បទថា **មាយា កុដេណ្ឌុ វេដេណ្ឌុ វិដូ ច**
វិដុដោ សហ គឺទាស:ទាំងអស់នោះ សុទ្ធតែជាអ្នកធ្វើមាយាទាំងអស់ ក្នុងពួក
ធ្វើមាយានេះ ដោយឈ្មោះក៏មាន កុដេណ្ឌុ ១ វិដេណ្ឌុ ១ ។ ឯក្នុងបាលី
រចនាទុកថា វេដេណ្ឌុ ១ វិដុ ១ វិដុដ: ១ ។ បទថា **សហ** គឺវិដុដ:នោះ ក៏មក
ជាមួយពួកទេវតាទាំងនោះដូចគ្នា ។ (បន្ទាប់មកក៏មាន) ចន្ទន: ១ កាមសេដ្ឋ:
១ កិន្នុយណ្ឌុ ១ និយណ្ឌុ ១ កិន្នុយណ្ឌ: ១ ។ តែក្នុងបាលីរចនាថា កិន្នុយណ្ឌុ ។
ឈ្មោះនិយណ្ឌុដទៃ ក៏ឈ្មោះនិយណ្ឌុផងដែរ ។ (និយណ្ឌុមានពីរអង្ត) ពួក
អ្នកបម្រើមាន ១០ អង្គប៉ុណ្ណោះ ។ ចំណែកទេវតាពួកដទៃក្រៅពីនេះ បានដល់
ទេវរាជទាំងនេះ គឺ

> បនាទ: ១ ឧបមញ្ញ: ១ ទេវសូត ១ មាតលី ១ ចិត្តសេន:
> ១ គន្ធព្ព: ១ នឡោរាជ: ១ ជនោសក: ១ បញ្ចសិខ: ១
> តិម្ពរូ ១ សុរិយវច្ចសា ១ ក៏នាំគ្នាមកដែរ ។

[៨០] បណ្តាបទទាំងនោះ បទថា **ទេវសូត** គឺទេវសារថី ។ បទថា
ចិត្តសេន គឺចែកជាទេវរាជបាន ៣ អង្ត ចិត្ត: ១ សេន: ១ ចិត្តសេន: ១ ។
បទថា **គន្ធព្ព** បានដល់ ចិត្តសេន: ដែលជាពួកគន្ធព្ពនេះ ។ មិនមែនតែ
ចិត្តសេន:នេះប៉ុណ្ណោះ សូម្បីបនាទ:ជាដើម ក៏ជាគន្ធព្ពទាំងអស់នោះឯង ។
បទថា **នឡោរាជ** បានដល់ ទេវតាមួយអង្គឈ្មោះនឡការទេវបុត្រ ។ បទថា
ជនោសក គឺទេវបុត្រឈ្មោះជនវសក: ។ បទថា **អាគុំ បញ្ចសិខោ ចេវ** គឺ
បញ្ចសិខទេវបុត្រនោះឯងក៏មក ។ បទថា **តិម្ពរូ** គឺគន្ធព្ពទេវរាជ ។ បទថា

សុរិយវច្ឆសា បានដល់ ជាធីតារបស់ស្តេចតិម្ពរូន៉ុះឯង ។ បទថា **ឯតេ ចញ្ញេ ច រាជានោ គន្ធព្វា សហ អភិក្ការ រាជុភិ** គឺទេវតាទាំងនេះ ពួកស្តេចគន្ធព្វ ដែលពោលដោយអំណាចព្រះនាម និងគន្ធព្វចំនួនច្រើនពួកដទៃ ព្រមទាំងព្រះ រាជាទាំងនោះ ។ បទថា **មោឧមានា អភិក្ការមុំ ភិក្ខូនំ សមិតឹ វនំ** សេចក្តីថា មានចិត្តត្រេកអរមកហើយកាន់ព្រៃនេះ ដែលជាទីប្រជុំរបស់ភិក្ខុទាំងឡាយ ។

បទថា **អថាគុំ នាភសា នាគា វេសាលា សហ តច្ឆកា** គឺនាគ ទាំងឡាយនៅក្នុងស្រះនភស: និងនាគនៅក្នុងក្រុងវេសាលី ក៏មកព្រមទាំង បរិស័ទរបស់តច្ឆកនាគរាជ ។ បទថា **កម្ពលអស្សតរា** គឺកម្ពល ១ អស្សតរ ១ ។ បានញ្ចថា នាគទាំងនេះ នៅត្រង់ជើងភ្នំសិនេរុ ជានាគមានសក្តិធំ សូម្បី ពួកគ្រុឌ ក៏គប្បីធក់យកទៅ គឺចាប់មិនបាន ។ បទថា **ទាយាគា សហ ញ្ញាតិភិ** និងពួកនាគដែលអាស្រ័យនៅត្រង់កំពង់បយាគ: ក៏មកជាមួយពួក ញ្ញាតិ ។ បទថា **យមុនា ធតរដ្ឋា ច** គឺពួកនាគដែលនៅក្នុងស្ទឹងយមុនា និង ពួកនាគដែលកើតក្នុងត្រកូលធតរដ្ឋ: ។ បទថា **ឯរាវណ្ណោ មហានាគោ** គឺ ឯរាវណជាទេវបុត្រ មិនមែនជាដំរីដោយកំណើត តែទេវបុត្រនោះ ត្រូវហៅថា ដំរី ។ បទថា **សោទាគ** គឺសូម្បីឯរាវណទេវបុត្រនោះ ក៏មក ។

[៨២] បទថា **យេ នាគរាជេ សហសា ហរន្តិ** គឺពួកគ្រុឌណា មាន សេចក្តីលោភគ្របសង្កត់ ហើយនាំ គឺចាប់យកពួកនាគមានប្រការដូចដែល ពោលហើយនេះ ទៅបានយ៉ាងរហ័ស ។ បទថា **ឧព្ភា ឧជា បក្ខិ វិសុទ្ធិចក្ខុ** គឺឈ្មោះថា ជាទិព្ធ ព្រោះមានអានុភាពទិព្ធ ឈ្មោះថា កើតពីរដង ព្រោះកើត

ហើយពីរដង គឺអំពីផ្នែមេម្តង និងញាស់អំពីស៊ុតម្តង ឈ្មោះថា មានស្លាប ព្រោះប្រកបដោយស្លាប ឈ្មោះថា មានភ្នែកបរិសុទ្ធ ព្រោះប្រកបដោយភ្នែក ដែលអាចឃើញពួកនាគក្នុងចន្លោះ ១០០ យោជន៍ខ្លះ ១០០០ យោជន៍ខ្លះ ។ បទថា **វេហាយសា តេ វនមជ្ឈបត្តា** *គឺពួកគ្រុឌទាំងនោះមកដល់ព្រៃមហាវននេះតាមអាកាសនោះឯង ។ បទថា* **ចិត្រា សុបណ្ណា ឥតិ តេស ឆាម** *គឺគ្រុឌទាំងនោះ ឈ្មោះចិត្រៈ និងសុបណ្ណៈ ។ បទថា* **អភយំ តទា នាគរាជា-ឆមាសិ សុបណ្ណតោ ខេមមកាសិ ពុទ្ធោ** *គឺ (ព្រោះហេតុណា) ព្រោះហេតុនោះ ពួកនាគ និងគ្រុឌទាំងអស់នោះ ក៏ត្រឡប់និយាយដោយសម្តីដ៏ពីរោះរីករាយរកគ្នា ដូចសម្លាញ់ និងដូចញាតិ ឱបក្រសោបគ្នា ចាប់ដៃគ្នា ជាក់ដៃលើចង្កឹយស្មាគ្នា មានចិត្តត្រេកអរ ។ បទថា* **នាគា សុបណ្ណា សរណមកំសុ ពុទ្ធំ** *គឺពួកគេទាំងនោះ ដល់ព្រះពុទ្ធ ជាទីពឹង ទីរឭក ។*

ពួកដែលនៅក្នុងសមុទ្រ គឺពួកអសុរ ដែលអាស្រ័យសមុទ្រ ដែលត្រូវព្រះឥន្ទ្រជាស្តេចនៃទេវតា មានព្រះនាមថា ស្តេចវជិរហត្ថ (មានវជិរាវុធក្នុងដៃ) ប្រោបប្រាមហើយក្នុងកាលមុន ព្រោះហេតុនាងសុជាតាធីតារបស់អសុរ សូម្បីពួកណា សូម្បីពួកអសុរទាំងអស់នោះ ជាបងប្អូនរបស់ស្តេចវាសវៈ (ព្រះឥន្ទ្រ) ជាអ្នកមានឫទ្ធិ មានយស ។ បទថា **កាលកញ្ញោ មហាភិស្មា** *គឺពួកអសុរកាលកញ្ញានិម្មិតរាងកាយធំ គួរស្បើមហើយក៏មក ។ បទថា* **អសុរា ឆានវេយ្យសា** *បានដល់ ពួកអសុរកាន់ធ្នូពួកជទៃ ឈ្មោះទានវេយសៈ ។ បទថា* **វេបចិត្តិ សចិត្តិ ច មហារាឆោ ឆមុចី សហា** *បានដល់ និងពួកអសុរទាំង*

នេះ គឺអសុរឈ្មោះវេបចិត្តិ ๑ អសុរឈ្មោះសុចិត្តិ ๑ ។ បទថា **ឧមុចី សហា** *បានដល់ មារឈ្មោះនមុចិដែលជាទេវបុត្រ ក៏មកជាមួយអសុរទាំងនោះឯង ។ អសុរទាំងនេះនៅក្នុងសមុទ្រ តែនមុចិនេះ នៅក្នុងទេវលោកជាន់បរនិម្មិត ហេតុអ្វី ទើបមកជាមួយអសុរទាំងនោះ ព្រោះជាពួកមិនពេញចិត្ត ជាពួកអកព្វ ។ ចំណែកនមុចិនេះ ក៏ដូចគ្នានុ៎ះឯង ជាតុត្រូវគ្នា ព្រោះដូច្នោះ ទើបមក ។ បទថា* **សតញ្ច ពលិបុត្តានំ** *គឺកូន ๑๐๐ នាក់ របស់ពលី ជាអសុរធំ ។ បទថា* **សព្ពេ វេរោចនាមកា** *គឺទ្រទ្រង់នូវឈ្មោះថា រាហូ ដូចឈ្មោះរបស់អ៊ំនុ៎ះឯង ។ បទថា* **សន្នយ្ហិត្វា ពលឺ សេនំ** *គឺចងសៀតគ្រឿងសេនា ដែលមានកម្លាំងរៀងៗខ្លួន ដូចអ្នកចម្បាំងរៀបចំខ្លួន ចូលសមរភូមិស្រេចហើយ ។ បទថា* **រាហុភទ្ទមុចាគមុំ** *គឺចូលទៅរកស្តេចអសុរឈ្មោះរាហូ ។ បទថា* **សមយោ-ធានិ ភទ្ទន្តេ** *គឺសេចក្តីចម្រើនចូរមានដល់លោក ឥឡូវនេះ ជាវេលាប្រជុំ ។ អធិប្បាយថា សូមលោកចូលទៅកាន់ព្រៃជាទីប្រជុំនៃភិក្ខុទាំងឡាយ ដើម្បីមើលពួកភិក្ខុ ។*

[๘๓] *បទថា* **អាចោ ច ឥរា បថវី ច តេជោ វាយោ តទាគមុំ** *គឺពួកទេវតាដែលមានឈ្មោះជាដើមថា ទឹក ព្រោះធ្វើបរិកម្មក្នុងអាបោកសិណជាដើម ទើបកើតឡើង ក៏មកក្នុងគ្រានោះ ។ បទថា* **វរុណា វារុណា ឥរា សោមោ ច យសសា សហ** *សេចក្តីថា ពួកទេវតាដែលមានឈ្មោះយ៉ាងនេះ គឺវរុណាទេព វារុណាទេព សោមទេព ក៏មកជាមួយគ្នានឹងយសទេព ។ បទថា* **មេត្តាករុណាកាយិកា** *គឺពួកទេវតាដែលធ្វើបរិកម្មក្នុងឈាន ប្រកបដោយ*

មេត្តា និងប្រកបដោយករុណាហើយ ទើបកើតឡើង ។ បទថា **អាគុំ ឧបា យសស្សិនោ** *គឺសូម្បីពួកទេវតាទាំងនេះ ជាអ្នកមានយសធំ ក៏បាននាំគ្នាមកហើយ ។ បទថា* **ឧសេតេ ឧសធា កាយា សព្ពេ ឆានត្តវណ្ណិនោ** *សេចក្តីថា ពួកទេវតាទាំង ១០ ពួកនោះ តាំងនៅដោយចំណែក ១០ ទាំងអស់មានពណ៌សម្បុរផ្សេងៗគ្នា ដោយអំណាចនៃពណ៌ខៀវជាដើមក៏បាននាំគ្នាមកហើយ ។*

បទថា **វេណ្ហូ ច ឧបា** *គឺវេណ្ហុទេព ១ ។ បទថា* **សហលិ ច** *គឺទេវតាឈ្មោះសហលី ១ ។ បទថា* **ឧសមា ច ទុវេ យមា** *គឺអសមទេព និងសមទេព ២ ទៀត ។ បទថា* **ចន្ទសុបនិសា ឧបា ចន្ទមាគុំ បុរក្ខតា** *គឺពួកទេវតាដែលអាស្រ័យព្រះចន្ទ ធ្វើព្រះចន្ទទុកខាងមុខ ហើយក៏មក ឯពួកទេវតាដែលអាស្រ័យព្រះអាទិត្យ ក៏ធ្វើព្រះអាទិត្យទុកខាងមុខ ហើយក៏មកជួបគ្នា ។ បទថា* **ឆក្ខត្តានិ បុរក្ខតា** *គឺទេវតាទាំងឡាយ ដែលអាស្រ័យផ្កាយ ធ្វើពួកផ្កាយទុកខាងមុខ ហើយក៏មក ។ បទថា* **អាគុំ មន្ទវលាហកា** *សេចក្តីថា ពួកវាតវលាហក: ពួកអព្ភវលាហក: ពួកឧណ្ហវលាហក: ពួកវលាហកទេវតាទាំងអស់នេះ ហៅឈ្មោះថា មន្ទវលាហក: ពួកមន្ទវលាហក:នោះ ក៏មក ។ បទថា* **វស្សំ វាសវោ សេដ្ឋោ សក្កោ ថាគា បុរិន្ទទោ** *គឺវាសវ:អង្គណាដែលហៅថា សក្ក: និងបុរិន្ទទ: ជាបុគ្គលដ៏ប្រសើរជាងវសុទេពទាំងឡាយស្តេចវាសវ:នោះ ក៏យាងមក ។ បទថា* **ឧសេតេ ឧសធា កាយា** *គឺពួកទេវតាទាំង ១០ នេះ មកហើយដោយចំណែក ១០ ។ បទថា* **សព្ពេ ឆានត្ត-**

វណ្ណិនោ គឺមានពណិសម្ឃុរផ្សេងៗ គ្នា ដោយអំណាចពណិខៀវជាដើម ។

បទថា **អថាគុំ សហភូ ទេវ** គឺលំដាប់តមក ពួកទេវតា ឈ្មោះសហភូ ក៏មក ។ បទថា **ជលមគ្គិសិខាវិវ** គឺរុងរឿងបីដូចអណ្តាតភ្លើង ។ លោកពោលថា បទថា **ជលមគ្គិ** នេះ ជាឈ្មោះរបស់ទេវតាទាំងនោះ ដូច្នេះក៏មាន ។ បទថា **អវិដ្ឋកា ច រោជា ច** គឺពួកអវិដ្ឋកទេវតា និងពួករោជទេវតា ។ បទថា **ឧម្មាបុបួនិភាសិនោ** គឺពួកទេវតាទាំងនោះ ឈ្មោះថា ពួកទេវតាផ្តាត្រកៀត[1] ។ ព្រោះថា រស្មីខ្ជួនទេវតាទាំងនោះ ដូចគ្នានឹងផ្តាត្រកៀត ដូច្នោះ ទើបហៅថា **ឧម្មាបុបួនិភាសី** គឺមានរស្មីដូចផ្តាត្រកៀត ។ បទថា **វរុណា សហធម្មា ច** គឺពួកទេវតាទាំងពីរអង្គនេះផង ។ បទថា **អច្ចុតា ច អនេជកា** គឺពួកអច្ចុតទេវតា និងពួកអនេជកទេវតា ។ បទថា **សូលេយ្យរុចិរា អាគុំ** គឺពួកទេវតាឈ្មោះសុលេយ្យ: និងពួកទេវតាឈ្មោះរុចិរ: ក៏មក ។ បទថា **អាគុំ វាសវនេសិនោ** គឺពួកទេវតាវាសវនេសី ក៏មក ។ បទថា **ទសេតេ ទសធា កាយា** គឺពួកទេវតាទាំង ១០ ពួកនេះ មកហើយដោយចំណែក ១០ នុ៉ះឯង ។

បទថា **សមានា មហាសមានា** គឺពួកទេវតាឈ្មោះសមាន: និងពួកទេវតាឈ្មោះមហាសមាន: ។ បទថា **មានុសា មានុសុត្តមា** គឺពួកទេវតាឈ្មោះមានុស: និងពួកទេវតាឈ្មោះមានុសុត្តម: ។ បទថា **ទិឌ្ឌាបទូសិកា អាគុំ អាគុំ មនោបទូសិកា** គឺពួកទេវតាដែលមានការលេងប្រទូស្ត និងពួកទេវតា

---

[1] - បិដកខ្មែរ ប្រែថា ផ្តាកឃ្យាស ។

ដែលមានចិត្តប្រទូស្ត[1] *ក៏មក ។ បទថា* **អថាគុំ ហារយោ ទេវា** *គឺពួកដែលឈ្មោះហរិទេពក៏មក ។ បទថា* **យេ ច លោហិតវាសិនោ** *គឺពួកទេវតា-លោហិតវាសី ក៏មក ។ បទថា* **ចារគា មហាចារគា** *សេចក្តីថា ពួកទេវតាទាំងពីរនេះ គឺពួកទេវតាឈ្មោះចារគៈ និងពួកទេវតាឈ្មោះមហាចារគៈក៏មក ។ បទថា* **ឧសេតេ ឧសធា កាយា** *គឺពួកទេវតាទាំង ១០ នេះ មកហើយដោយចំណែក ១០ នោះឯង ។*

បទថា **សុក្កា ករុម្ហា អរុណា អាគុំ វេយនសា សហ** *គឺពួកទេវតាទាំង ៣ មានពួកសុក្កៈជាដើម និងពួកវេយនសទេវតា ក៏មកព្រមជាមួយទេវតាទាំងនោះ ។ បទថា* **ឱទាតគយ្ហា ចាមោក្កា** *គឺពួកទេវតាជាប្រធានឈ្មោះឱទាតគយ្ហៈ ក៏មក ។ បទថា* **អាគុំ ទេវា វិចក្ខណា** *គឺពួកទេវតា ឈ្មោះវិចក្ខណៈក៏មក ។ បទថា* **សទាមត្តា ហារគជា** *គឺពួកទេវតាឈ្មោះសទាមត្តៈ និងពួកទេវតាឈ្មោះហារគជៈ ។ បទថា* **មិស្សកា ច យសស្សិនោ** *គឺពួកទេវតាឈ្មោះមិស្សកៈ ដល់ព្រមដោយយស ។ បទថា* **ឋនយំ អាគា បជ្ជុន្នោ** *គឺទេវរាជឈ្មោះបជ្ជុនៈ ក៏មក ។ បទថា* **យោ ឥសា អភិវស្សតិ** *គឺទេវតានេះ ទៅកាន់ទិសណាៗ ភ្លៀងក៏ធ្លាក់ក្នុងទិសនោះៗ ។ បទថា* **ឧសេតេ ឧសធា កាយា** *គឺពួកទេវតាទាំង ១០ នេះ មកហើយដោយចំណែក ១០ នុ៎ះឯង ។*

បទថា **ទេមិយា តុសិតា យាមា** *បានដល់ ពួកទេវតាដែលមានសេចក្តី*

๑- ពួកទេវតា ដែលចុតិព្រោះតែការលេងក្លេចបរិភោគ និងពួកទេវតាដែលចុតិព្រោះក្រោធ ។

ក្សេម នៅតុសិតបុរី និងពួកទេវតា ដែលនៅក្នុងយាមាទេវលោក ។ បទថា **កថកា ច យសស្ឃិនោ** បានដល់ ពួកទេវតាឈ្មោះកថក: ដែលបរិបូណិ ដោយយសផង ។ ឯក្នុងបាលីរចនាថា **កដ្ឋក ។** បទថា **លម្ពិតកា លាម-សេដ្ឋោ** បានដល់ ពួកទេវតាឈ្មោះលម្ពិតក: និងពួកទេវតាឈ្មោះលាម-សេដ្ឋ: ។ បទថា **ជោតិនាមា ច អាសវា** សេចក្តីថា មានពួកទេវតាឈ្មោះ ជោតិទេព រុងរឿងដូចគំនរភ្លើងបបុស លើកំពូលភ្នំ និងពួកអាសាទេវតា ក៏ មក ។ តែក្នុងបាលីរចនាថា ជោតិនាម និងហៅអាសាទេវតាថា អាសវ: ដោយអំណាចធនូ ។ ទេវតាជាន់និម្មានរតី ក៏មក បន្ទាប់មកទេវតាជាន់ បរនិម្មិតា ក៏មក ។ បទថា **ឧសេតេ ឧសធា កាយា** បានដល់ ពួកទេវតាទាំង ១០ នេះ មកហើយ ដោយចំណែក ១០ នុ៉ះឯង ។

បទថា **សដ្ឋេតេ ទេវនិកាយា** បានដល់ ទេវតា ១០ ពួក ៦ ជង រាប់ ពីអាបោទេវតាជាដើមទៅ ជាទេវតា ៦០ ពួក ។ ទេវតាទាំងអស់ មាន ពណិសម្ឃុរផ្សេងគ្នា ដោយអំណាចពណិខៀវជាដើម ។ បទថា **នាមនូយេន អាគញ្ជុំ** បានដល់ មកហើយដោយភាគនៃឈ្មោះ គឺដោយចំណែកនៃឈ្មោះ នុ៉ះឯង ។ បទថា **យេ ចញ្ញេ សធិសា សហ** បានដល់ សូម្បីទេវតាក្នុង ចក្រវាលដ៏សេសពួកដទៃណា ដែលមានសភាពដូចគ្នានឹងទេវតាទាំងនេះ គឺ ដូចគ្នាដោយពណិសម្ឃុរផង ដោយឈ្មោះផង ទេវតាទាំងនោះមកហើយដូច្នេះ ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់សម្តែងទេវតាទាំងអស់ ដូចប្រមូលចងជា ក្រុមៗ ដោយបទមួយប៉ុណ្ណោះ ។ កាលទ្រង់សម្តែងពួកទេវតាក្នុង ១ ម៉ឺន

លោកធាតុយ៉ាងនេះស្រេចហើយ ឥឡូវនេះ កាលទ្រង់សម្តែងសេចក្តីត្រូវការ ដែលទេវតាទាំងនោះមក ទើបត្រាស់គាថាជាដើមថា **បរិត្តជាតិ** *ដូច្នេះ ។*

គប្បីជ្រាបអត្ថនៃគាថានោះដូច្នេះថា ព្រះអរិយសង្ឃ ឈ្មោះថា មានជាតិដែលនៅចប់ហើយ ព្រោះជាតិរបស់លោកទៅប្រាសហើយ ។ លោកមានជាតិដែលទៅប្រាសហើយនោះឯង ។ ពួកយើងនឹងមើល គឺនឹងឃើញព្រះអរិយ-សង្ឃ ដែលឈ្មោះថា **អក្កិលំ** *ព្រោះដែកគោល គឺរាគៈ ទោសៈ និងមោហៈ មិនមាន ឈ្មោះថា* **ឱឃតិណ្ណំ** *ព្រោះឆ្លងអន្ទង់ទាំង ៤ បាន ហើយតាំងនៅ ឈ្មោះថា* **អនាសវំ** *ព្រោះមិនមានអាសវៈទាំង ៤ ។ ឈ្មោះថា* **ឱឃតរំ** *ព្រោះឆ្លងឱឃៈទាំងនោះឯង បានហើយ ឈ្មោះថា* **នាគំ** *ព្រោះមិនធ្វើបាប ។ បទថា* **អសិតាតិតំ** *គឺពួកយើងគប្បីមើល គឺគប្បីឃើញព្រះទសពល ដែលទ្រង់រុងរឿងហើយដោយសិរី ដូចព្រះចន្ទចេញចាកពពកខ្មៅ ដូច្នោះ ។ ទេវតាទាំងនោះ និងពួកទេវតាដទៃណា ដែលមានសភាពដូចគ្នានឹងទេវតាទាំងនោះ មកហើយ ដោយការប្រារព្ធឈ្មោះដើម្បីប្រយោជន៍នោះ ដោយប្រការដូច្នេះ ។*

[๘๔] ឥឡូវនេះ កាលនឹងទ្រង់សម្តែងដល់ពួកព្រហ្ម ទើបត្រាស់ថា សុព្រហ្ម និងបរមត្តព្រហ្ម ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សុព្រហ្មា** *បានដល់ ព្រហ្មប្រសើរមួយអង្គ និងព្រហ្មឈ្មោះបរមត្តៈ (បរមាត្មន) ។ បទថា* **បុត្តា ឥទ្ធិមតោ សហា** *បានដល់ អរិយព្រហ្មទាំងនេះ ជាបុត្ររបស់ព្រះមានព្រះភាគ ទ្រង់មានឫទ្ធិច្រើន*

ក៏មកជាមួយគ្នា ។ បទថា **សនង្កុមារោ តិស្សោ ច** បានដល់ សនង្កុមារព្រហ្ម ១ អង្គ តិស្សមហាព្រហ្ម ១ អង្គ ។ បទថា **សោចាគា** បានដល់ តិស្សមហាព្រហ្មនោះ ក៏មក ។ មានព្រះតម្រាស់ក្នុងរឿងព្រហ្មនេះថា

មហាព្រហ្ម ចូលដល់ព្រហ្មលោក មានសេចក្តីរុងរឿង មាន
វង្កាយធំ មានយស គ្រប់គ្រងព្រហ្មលោកមួយពាន់ ។

បទថា **សហស្សព្រហ្មលោកានំ** បានដល់ ព្រហ្មធំ ១០០០ អង្គមក ហើយ ព្រហ្មទាំងនេះអាចធ្វើពន្លឺក្នុង ១០០០ ក្រាលឲ្យភ្លឺ ដោយម្រាមដៃតែមួយ ក្នុង ១ ម៉ឺនចក្រាលដោយម្រាមដៃទាំង ១០ ។ បទថា **មហាព្រហ្មាភិតិដ្ឋតិ** បានដល់ មហាព្រហ្មតែមួយអង្គ គ្របសង្កត់ព្រហ្មពួកដទៃ ហើយតាំងនៅក្នុងទីណា ។ បទថា **ឧបបន្នោ** បានដល់ កើតក្នុងព្រហ្មលោក ។ បទថា **ផុតិមន្តោ** បានដល់ បរិបូណ៌ដោយអានុភាព ។ បទថា **អិស្សាកាយោ** បានដល់ មានវង្កាយធំ មានទំហំវង្កាយស្មើនឹង ២-៣ គាមក្ខេត្តរបស់ពួកអ្នកស្រុកដែនមគធៈ ។ បទថា **យសស្សិ សោ** បានដល់ ប្រកបព្រមដោយយស ពោល គឺសិរីនៃអត្តភាព ។ បទថា **ឧសេត្ត ឥស្សរោ អាគុំ បច្ចេកវសវត្តិនោ** បានដល់ មហាព្រហ្មជាឥស្សរៈ ១០ អង្គ ដែលមានសភាពបែបនោះ ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយចំពោះ ក៏មក ។ បទថា **តេសញ្ច មជ្ឈតោ អាគ ហារិតោ បរិវារិតោ** សេចក្តីថា មហាព្រហ្មឈ្មោះហារិតៈ មានព្រហ្ម ១ សែនអង្គជាបរិវារ ក៏មកក្នុងកណ្តាលព្រហ្មទាំងនោះ ។ បទថា

តេ ច សព្វេ អភិក្ពន្តេ សឥន្ទេ ទេវេ សព្រហ្មកេ សេចក្តីថា ពួកទេវតាទាំងអស់នោះ ធ្វើសក្កទេវរាជឲ្យជាប្រធានហើយមក និងពួកព្រហ្ម ក៏ធ្វើហារិត-មហាព្រហ្ម ឲ្យជាប្រធានហើយមក ។ បទថា **មារសេនា អភិក្ពាមិ** សេចក្តីថា កងទ័ពមារ ក៏ចូលមក ។ បទថា **បស្ស កណ្ហស្ស មន្ទិយំ** សេចក្តីថា អ្នកទាំងឡាយ ចូរមើលភាពល្ងង់ខ្លៅរបស់មារមានចិត្តបាប ។ បទថា **ឯថ តណ្ហថ ពន្ធថ** សេចក្តីថា ស្តេចមារ ប្រាប់បរិស័ទរបស់ខ្លួនយ៉ាងនេះថា ពួកអ្នកចូរចាប់ចងពួកទេវតាទាំងនេះ ។ បទថា **រាគេន ពន្ធមត្ថុ វោ** សេចក្តីថា ទេវមណ្ឌលរបស់លោកទាំងអស់នេះ ចូរជាការចងហើយដោយរាគៈ ។ បទថា **សមន្តា បរិវារេថ មា វោ មុញ្ចិត្ថ កោចិ នំ** សេចក្តីថា បណ្តាពួកអ្នក សូម្បីតែម្នាក់កុំបណ្តោយឲ្យរួចខ្លួន សូម្បីតែម្នាក់ក្នុងពួកទេវតាទាំងនេះ បាឯៈថា **មា វោ មុញ្ចិត្ថ** ពួកអ្នកកុំលែង ឯសេចក្តីក៏ដូចគ្នា ។ បទថា **ឥតិ តត្ថ មហាសេនោ កណ្ហោសេនំ អបេសយិ** សេចក្តីថា មារដែលជាមេទ័ពធំ បញ្ជាកងទ័ពមារក្នុងទីប្រជុំនោះយ៉ាងនេះ ។ បទថា **ចាណិនា តលមាហច្ច** សេចក្តីថា ទះផែនដីដោយបាតដៃ ។ បទថា **សរំ កត្វាន ភេរវំ** សេចក្តីថា និងធ្វើសំឡេងដែលគួរខ្លាច ដើម្បីសម្តែងសំឡេងដែលគួរខ្លាចរបស់មារ ។ បទថា **យថា ចាវុស្ស្មកោ មេឃោថនយន្តោ សវិជ្ជុកោ** សេចក្តីថា ដូចមហាមេឃបង្អុរទឹកភ្លៀង ប្រព្រឹត្តទៅព្រមដោយផ្លកបន្ទោរ ផ្គរគ្រហឹមយ៉ាងខ្លាំង ។ បទថា **តទា សោ បច្ចុ-ទាវត្តិ** សេចក្តីថា សម័យនោះ កាលសម្តែងវត្ថុដែលគួរខ្លាចនោះស្រេចហើយ

มารនោះក៏ត្រឡប់ទៅ ។ បទថា **សង្ឃដ្ដោ អសយំ វសេ** *សេចក្តីថា កាលមិនអាចនឹងឲ្យបុគ្គលណាមួយ ប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន ក៏ក្រេវក្រោធប្រទ្បាតនឹងអ្នកដែលមិននៅក្នុងអំណាចខ្លួន អស់ចំណង់ដោយអំណាចរបស់ខ្លួនហើយ ក៏ថយចេញបាត់ទៅ ។*

បានឮថា ព្រះមានព្រះភាគ ទ្រង់បានជ្រាបថា មារនេះឃើញសមាគមនេះធំ គិតថា នឹងធ្វើអន្តរាយដល់ការសម្រេចមគ្គផលក្នុងទីប្រជុំដ៏សំខាន់ ទើបបញ្ជូនកងទ័ពមារទៅសម្តែងវត្ថុដែលគួរខ្លាចប្លែកៗ ឯប្រក្រតីរបស់ព្រះមានព្រះភាគ គឺក្នុងទីណានឹងមិនមានការសម្រេចមគ្គផល ក្នុងទីនោះ ព្រះអង្គទ្រង់មិនហាមមារ ដែលសម្តែងវត្ថុដែលគួរខ្លាចរបស់មារ តែក្នុងទីណា មានការសម្រេចមគ្គផល ក្នុងទីនោះព្រះអង្គ ទ្រង់អធិដ្ឋានមិនឲ្យបរិស័ទឃើញរូប មិនឲ្យឮសំឡេងមារ ព្រោះក្នុងសម័យនេះ នឹងមានការត្រាស់ដឹងមគ្គផលធំ ដូច្នោះ ទើបទ្រង់អធិដ្ឋានដោយប្រការ ដែលពួកទេវតាមិនឃើញ និងមិនឮសំឡេងរបស់មារនោះឡើយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា កាលនោះ មារនោះ ក្រេវក្រោធជាមួយអ្នកដែលមិនប្រព្រឹត្តទៅក្នុងអំណាចខ្លួន បានគេចចេញបាត់ទៅ ។

បទថា **តញ្ច សព្វំ អភិញ្ញាយ វាត្តិត្វាន ចក្ខុមា** *សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាប និងទ្រង់ពិចារណាហេតុទាំងអស់នោះហើយ ។ បទថា* **មារសេនា អភិក្កន្តា តេ វិជានាថ ភិក្ខវោ** *សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កងទ័ពមារចូលមកហើយ ពួកអ្នកចូរស្គាល់*

ពួកមារតាមសមគួរដល់ខ្លួន ចូរពួកអ្នកចូលផលសមាបត្តិ ។ បទថា **អាតប្ប-មការុំ** *សេចក្តីថា ភិក្ខុទាំងនោះប្រារព្ធសេចក្តីព្យាយាម ដើម្បីប្រយោជន៍ចូលផលសមាបត្តិ ។ បទថា* **វិតរាគេហិ បក្ការុំ** *សេចក្តីថា មារ និងអ្នកត្រាច់ទៅតាមមារ បានចៀសចេញទៅយ៉ាងឆ្ងាយពីពួកព្រះអរិយៈ ដែលប្រាសចាករាគៈហើយនោះឯង ។ បទថា* **នេសំ លោមម្បិ ឝញ្ញយុំ** *សេចក្តីថា សូម្បីតែរោមរបស់លោកអ្នកប្រាសចាករាគៈទាំងនោះ ក៏មិនញាប់ញ័រ ។ គ្រានោះ មារប្រារព្ធពួកភិក្ខុហើយ បានពោលគាថានេះថា*

> *ពួកសាវកទាំងនោះ លោកឈ្នះសឹកសង្គ្រាមហើយ កន្ទងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយស ល្បីទូទៅក្នុងប្រជុំជន តែងរីករាយជាមួយនឹងព្រះអរិយៈ ដែលកើតហើយ (ក្នុងសាសនាព្រះទសពល) ។*

បណ្តាបទទាំងនោះ បទថា **មោឌន្តិ សហ ភូតេហិ** *សេចក្តីថា រីករាយ គឺរីករាយទូទៅជាមួយនឹងពួកព្រះអរិយៈ ដែលកើតហើយ គឺកើតព្រមហើយក្នុងសាសនារបស់ព្រះទសពល ។ បទថា* **ជិនេ សុគាតិ** *សេចក្តីថា ប្រាកដដោយវិសេស គឺដឹងច្បាស់ បានដល់ ដែលពួកជនស្គាល់ជាក់ជាយ៉ាងក្រៃលែង ។ ក៏ព្រោះមហាសមយសូត្រនេះ ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ពួកទេវតា ដូច្នោះ ក្នុងស្ថានទីថ្មោងថ្មី កាលនឹងពោលមង្គល ក៏គប្បីពោលតែមហាសមយសូត្រនេះឯង ។*

បានឮថា ពួកទេវតានាំគ្នាគិតថា ពួកយើងនឹងស្តាប់ព្រះសូត្រនេះ ហើយ

ក៏ផ្ទៀងត្រចៀកស្តាប់ ។ កាលព្រះមានព្រះភាគ ទ្រង់សម្តែងចប់ ទេវតាចំនួន ๑ សែនកោដិ បានសម្រេចអរហត្តហើយ ទេវតាដែលជាព្រះសោតាបន្នជាដើម មិនមានការរាប់ ។ រឿងនេះ គប្បីមានព្រោះភាពដែលជាទីស្រឡាញ់ពេញចិត្តរបស់ពួកទេវតា ។

មានរឿងតំណាលថា ត្រង់វត្តកោដិបពិត មានទេពធីតាមួយអង្គអាស្រ័យនៅត្រង់ដើមខ្លឹង ជិតទ្វារល្អាងគុហាដែលមានដើមខ្លឹង ។ ភិក្ខុកំលោះមួយរូបស្វាធ្យាយសូត្រនេះ ក្នុងខាងក្នុងវិហារ ។ ទេពធីតាបានស្តាប់ ក្នុងវេលាចប់ព្រះសូត្រ ក៏បានឲ្យសាធុការដោយសំឡេងខ្លាំង ។

ភិក្ខុកំលោះសួរថា នុ៎ះអ្នកណា ។ ទេពធីតា ឆ្លើយថា ខ្ញុំជាទេពធីតា ។ ភិក្ខុកំលោះសួរថា ហេតុអ្វី ទើបបានឲ្យសាធុការ ។ ទេពធីតា ឆ្លើយថា លោកម្ចាស់ ខ្ញុំបានស្តាប់ព្រះសូត្រនេះ ក្នុងថ្ងៃដែលព្រះទសពលប្រថាប់គង់សម្តែងត្រង់ព្រៃមហាវន ថ្ងៃនេះបានស្តាប់ម្តងទៀត ធម្មបទនេះ លោកកាន់យកល្អហើយ ព្រោះមិនធ្វើឲ្យអក្ខរៈសូម្បីតែមួយតួ ដែលព្រះមានព្រះភាគទ្រង់សម្តែងឲ្យបាត់ទៅ ។ ភិក្ខុកំលោះសួរថា កាលព្រះទសពលកំពុងសម្តែងនាងបានស្តាប់ឬ ទេពធីតាឆ្លើយថា ពិតហើយ លោកម្ចាស់ ។ ភិក្ខុសួរថា បានឮថា ទេវតាមកប្រជុំគ្នាច្រើន ហើយនាងឈរស្តាប់ទីណា ទេពធីតាឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំជាទេវតាក្នុងព្រៃមហាវន កាលពួកទេវតាអ្នកមានសក្តិធំកំពុងនាំគ្នាមក ខ្ញុំមិនមានកន្លែងនៅក្នុងជម្ពូទ្វីបឡើយ បានទៅកាន់តម្ពបណ្ណិទ្វីបនេះ ឈរនៅមាត់ច្រាំងត្រង់កំពង់ជម្ពូកោលៈ សូម្បីថយដល់កំពង់

នោះក៏ដោយ កាលពួកទេវតាអ្នកមានសក្តិធំកំពុងនាំគ្នាមកក៏ថយៗ ទៅដោយលំដាប់ ត្រាំទឹកសមុទ្រជ្រៅត្រឹមក ខាងក្រោយស្រុកធំក្នុងរោហណជនបទ ហើយក៏ឈរស្តាប់ក្នុងទីនោះ ។ ភិក្ខុសួរថា ពីទីដែលនាងឈរនោះ ឆ្ងាយណាស់ នាងឃើញព្រះសាស្តាឬ ។ ទេពធីតាពោលថា លោកម្ចាស់និយាយអ្វី ខ្ញុំយល់ថា ព្រះសាស្តាទ្រង់សម្តែងធម៌ នៅត្រង់ព្រៃមហាវ័ន ទ្រង់ក្រេឡកមើលខ្ញុំម្ចាស់រឿយៗ ខ្ញុំខ្ជាច ខ្ញុំខ្មាស ។ ភិក្ខុសួរថា បានឮមកថា ថ្ងៃនោះ មានទេវតា ១ សែនកោដិសម្រេចអរហត្តហើយ ឯនាងសោត ពេលនោះ សម្រេចអរហត្តឬ ទេពធីតាពោលថា មិនសម្រេចទេ លោកម្ចាស់ ។ ភិក្ខុសួរថា នាងសម្រេចអនាគាមិផលឬ ទេពធីតាពោលថា មិនមែនទេ លោកម្ចាស់ ។ ភិក្ខុសួរថា នាងប្រហែលជាសម្រេចសកទាគាមិផលឬ ទេពធីតាឆ្លើយថា មិនមែនទេ លោកម្ចាស់ ។ ភិក្ខុសួរថា បានឮថា ពួកទេវតាដែលសម្រេចមគ្គ ៣ ភាប់មិនបាន នាងប្រហែលជាសម្រេចសោតាទេដឹង ។

ក្នុងថ្ងៃនោះ ទេពធីតាសម្រេចសោតាបត្តិផល មានការខ្មាស ទើបនិយាយថា លោកម្ចាស់សួរវត្ថុមិនគួរសួរ ។ លំដាប់នោះ ទើបភិក្ខុនោះ ពោលថា ទេវតា នាងនឹងសម្តែងកាយឲ្យអាត្មាឃើញបានដែរឬទេ ទេវតាពោលថា បពិត្រលោកម្ចាស់ ឃើញទាំងអស់មិនបានទេ ខ្ញុំនឹងឲ្យលោកម្ចាស់ឃើញតែម្រាមដៃមួយ ពោលហើយ ក៏យកម្រាមដៃស៊ីកចូលខាងក្នុងល្អាង តាមរន្ធសោ ។ ម្រាមដៃ ក៏ដូចជាវេលាព្រះចន្ទ ព្រះអាទិត្យរះឡើងជា ១ ពាន់ដួង ។

ទេពធីតាពោលថា សូមលោកម្ចាស់កុំប្រមាទ ហើយថ្វាយបង្គំភិក្ខុត្រឡប់ទៅ ។ សូត្រនេះ ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយយ៉ាងនេះ ទេវតាទាំងឡាយ រមែងសម្គាល់ថា ព្រះសូត្រនោះជារបស់យើង ដោយប្រការដូច្នេះ ។ អដ្ឋកថាមហាសមយសូត្រ ក្នុងទីឃនិកាយឈ្មោះសុមង្គលវិលាសិនីចប់ ៗ

មហាសមយសូត្រ ចប់

សូត្រទី ៧ ចប់

សុត្តន្តបិដក

សក្កប្បញ្ហាសូត្រទី ៨

[៨៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយក: (តាំងនៅ) ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌ:ក្នុងដែនមគធ: ។ ក៏សម័យនោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា មានសេចក្តីខ្វល់ខ្វាយកើតឡើង ដើម្បីនឹងទៅគាល់ព្រះមានព្រះភាគ ។ វេលានោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់បរិវិតក្កដូច្នេះថា ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងទីណាហ្ន៎ ។ សក្កទេវរាជាធំជាងពួកទេវតា បានទតឃើញព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយក: ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌ: ក្នុងដែនមគធ: លុះឃើញហើយ ក៏ត្រាស់ហៅពួកទេវតា ដែលនៅក្នុងហានតាវត្តិង្ស មកប្រាប់ថា ម្នាលគ្នាយើងទាំងឡាយ ឥឡូវនេះ ព្រះមានព្រះភាគ ជាម្ចាស់អង្គនេះ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយក: ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌ: ក្នុងដែនមគធ: ម្នាលគ្នាយើងទាំងឡាយ បើដូច្នោះ គួរយើងទាំងអស់គ្នា ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ពួកទេវតាដែលឋិតនៅក្នុងហានតាវត្តិង្ស ក៏ទទួលព្រះរាជឱង្ការនៃសក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ។ លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ត្រាស់ហៅបញ្ចសិខគន្ធព្វបុត្តថា ម្នាល

អ្នកបញ្ចសិខៈ ឥឡូវនេះ ព្រះមានព្រះភាគអង្គនេះ ទ្រង់គង់នៅក្នុងឥន្ទ-សាលគុហា ជិតភ្នំវេទិយកៈ ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ម្នាលអ្នកបញ្ចសិខៈ បើដូច្នោះ គួរយើងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ បញ្ចសិខគន្ធព្វបុត្ត ក៏ទទួលព្រះរាជឱង្ការនៃសក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ហើយក៏កាន់ពិណមានសម្បុរលឿងដូចផ្លែញៅទុំ ដើរតាមក្រោយនៃសក្កទេវរាជ ជាធំជាងពួកទេវតា ។ ក្នុងខណៈនោះឯង សក្កទេវរាជជាធំជាងពួកទេវតា មានពួកទេវតាដែលបឋមនៅក្នុងជាន់តាវត្តិង្ស ចោមរោម សរសើរ មានបញ្ចសិខ-គន្ធព្វបុត្តជាអ្នកនាំមុខ ក៏បាត់អំពីពពួកទេវតា ដែលបឋមនៅក្នុងឋានតាវត្តិង្ស មកប្រតិស្ឋាននៅលើភ្នំវេទិយកៈ ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ (ដោយឆាប់រហ័ស) ប្រៀបដូចបុរសមានកម្លាំង លាដៃដែលខ្ជួនបត់ចូល ឬបត់ចូលនូវដៃដែលលាចេញចូច្នោះឯង ។ ក្នុងសម័យនោះឯង ភ្នំវេទិយកៈ និងព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក៏មានពន្លឺព្រោងព្រាត ដោយទេវានុភាពនៃពួកទេវតា ។ បានឮថា ពួកមនុស្សក្នុងស្រុកជិតខាងនិយាយគ្នាយ៉ាងនេះថា ថ្ងៃនេះ ភ្នំវេទិយកៈរុងរឿង ថ្ងៃនេះ ភ្លើងឆេះភ្នំវេទិយកៈ ថ្ងៃនេះ ភ្នំវេទិយកៈភ្លឺច្រាលរន្ទាល ភ្នំវេទិយកៈ និងព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ហេតុអ្វីបានជាមានពន្លឺភ្លឺក្រៃពេកក្នុងថ្ងៃនេះ ។ ពួកមនុស្សទាំងនោះ ក៏មានសេចក្តីកត់សុត

ព្រឹកភេម ។ គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ត្រាស់ហៅបញ្ចសិខគន្ធព្វបុត្តមកថា នែអ្នកបញ្ចសិខៈ ព្រះតថាគតទាំងឡាយ ព្រះអង្គមានឈាន ត្រេកអរក្នុងឈាន ព្រះអង្គសម្ងំនៅដោយកម្មដ្ឋានបានភ្លាមៗ (ព្រោះហេតុនោះ) បុគ្គលដូចយ៉ាងយើងដែលជាអ្នកមានរាគៈ ទោសៈ មោហៈ នឹងចូលទៅគាល់បានដោយលំបាក នែអ្នកបញ្ចសិខៈ បើដូច្នោះ គួរធ្វើឲ្យព្រះមានព្រះភាគពេញព្រះហឫទ័យ (បើកឱកាសឲ្យ) ជាមុនសិន ម្នាលអ្នក បើអ្នកបានធ្វើឲ្យព្រះអង្គពេញព្រះហឫទ័យជាមុនហើយ សឹមយើងទាំងឡាយចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ក្នុងកាលជាខាងក្រោយ ។ បញ្ចសិខគន្ធព្វបុត្ត ទទួលព្រះរាជឱង្ការរបស់សក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ហើយក៏កាន់នូវពិណមានសម្បុរលឿងដូចផ្លែឈើទុំ ចូលសំដៅទៅត្រង់ឥន្ទសាលគុហា លុះចូលទៅដល់ហើយ ក៏ឋិតនៅក្នុងទីសមគួរ ដោយគិតថា ទីត្រឹមប៉ុណ្ណោះ ព្រះមានព្រះភាគគង់នៅ មិនឆ្ងាយពេក មិនជិតពេកអំពីអញ ទាំងព្រះអង្គក៏ទ្រង់ឮសំឡេងអញបានផង ។ លុះបញ្ចសិខគន្ធព្វបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ចាប់ដេញពិណមានសម្បុរលឿងដូចជាផ្លែឈើទុំ ហើយច្រៀងនូវគាថាទាំងនេះ ដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត ព្រមទាំងប្រកបដោយកាមថា

[๘๖] *ម្នាលនាងសុរិយវច្ឆសាដ៏ចម្រើន បងសូមថ្វាយបង្គំនូវទេវរាជ ព្រះនាមតិម្ពរុ ជាបិតារបស់នាង ដោយ*

ហេតុដែលនាងកើតមកហើយ មានលម្អជាទីញុំាងសេចក្តី ត្រេកអរឲ្យកើតដល់បង ។ ដូចខ្សល់ជាទីត្រេកអរ របស់ បុគ្គលអ្នកមានញើស ពុំនោះសោត ដូចទឹកសម្រាប់ផឹក ជាទីត្រេកអរ របស់បុគ្គលអ្នកស្រេកទឹក នាងមានពន្លឺរស្មី នៃអវយវៈ ជាទីស្រឡាញ់ពេញចិត្តនៃបង ដូចនវលោ- កុត្តរធម៌ ជាទីស្រឡាញ់ របស់ពួកព្រះអរហន្តដូច្នោះ ។ ម្នាលនាងដ៏ចម្រើន ចូរនាងជួយលត់ (សេចក្តីក្រហល់ ក្រហាយរបស់បង) ចេញ ដូចគេដាក់ថ្នាំដល់អ្នកជំងឺ ពុំនោះសោត ដូចគេឲ្យកោជនដល់អ្នកកំពុងឃ្លាន ពុំនោះ សោត ដូចគេលត់ភ្លើងកំពុងឆេះដោយទឹក ។ សូមឲ្យបង បានអែបនែបត្រង់ចន្លោះស្តន និងខនរបស់នាង ដូចជាដីរ មានសេចក្តីក្រហល់ក្រហាយ ក្នុងរដូវក្រុំង បានចុះកាន់ ស្រះឈូកមានទឹកដ៏ត្រជាក់ ប្រកបដោយលម្អងនៃកេសរ ផ្កាឈូក ដូច្នោះឯង ។ បងងោងងប់ព្រោះក្លៀវរបស់នាង ដែលបរិបូណ៌ដោយលក្ខណៈ ក៏លែងស្គាល់ហេតុ (ដែល នាំឲ្យប្រាសចាកវាគៈ) ដូចជាដីរ (ចុះប្រេង) ហួស វិស័យកង្វេរ គិតថា អញឈ្នះផ្លែកង្វេរ និងលំពែង ។ បង មានចិត្តស្ទុះចុះហើយក្នុងនាង បងមិនអាចនឹងទាញចិត្ត ដែលងប់ស៊ប់ហើយ ឲ្យត្រឡប់វិញបានឡើយ ដូចជាត្រី

លេបសន្ថូច ។ ម្នាលនាងមានភ្លៅដូចបណ្តូលចេកដ៏ចម្រើន ចូរនាងឱបបង ម្នាលនាងមានភ្នែកស្រទន់ ចូរនាងមកកៀកបង ម្នាលនាងមានរូបឆោមដ៏ល្អ ចូរនាងមកឱបរឹតបង ការឱបរឹតនេះ បងត្រូវការណាស់ ។ កាមរបស់បងមានតិចដែរទេ តែព្រោះនាងមានសក់ត្រសាយងឡឹងសេចក្តីប្រាថ្នានៃបង ក៏កើតមានជាអនេក ដូចទក្ខិណាទានដែលគេថ្វាយចំពោះព្រះអរហន្ត ។ ម្នាលនាង មានលម្អសព្វសព្វាង្គ បុណ្យណាដែលបងបានធ្វើហើយ ចំពោះព្រះអរហន្តទាំងឡាយ ជាអ្នកនឹងធឹង បុណ្យរបស់បងនោះ សូមជួយបងឲ្យបានកប់ប្រសព្វនឹងនាង ។ ម្នាលនាងមានលម្អអស់អង្គ បុណ្យណាដែលបងបានធ្វើហើយ ក្នុងមណ្ឌលនៃប្រឹថពីនេះ បុណ្យរបស់បងនោះ សូមជួយបងឲ្យបានកប់ប្រសព្វនឹងនាង ។ ព្រះមុនីជាសក្យបុត្រ ទ្រង់ប្រកបដោយឈាន គង់នៅតែមួយព្រះអង្គឯង មានព្រះប្រាជ្ញាស្មារតី ព្រះអង្គខំស្វែងរកព្រះនិព្វាន យ៉ាងណា ម្នាលនាងសុរិយវច្ឆសា បងក៏ខំស្វែងរកនាង យ៉ាងនោះដែរ ។ មួយទៀត សម្តេចព្រះមុនី ព្រះអង្គបានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ ទ្រង់រីករាយព្រះហឫទ័យយ៉ាងណាមិញ ម្នាលនាងកល្យាណី ខ្លួនបងបើបានមូល

មិត្រនឹងនាងហើយ ក៏នឹងវីកវាយក្នុងចិត្តយ៉ាងនោះដែរ ។ ម្នាលនាងដ៏ចម្រើន បើសក្កទេវរាជ ជាធំជាងពួកទេវតាក្នុងជាន់តាវត្តិង្ស ទ្រង់ប្រទានពរដល់បង បងគប្បីប្រាថ្នានាង សេចក្តីប្រាថ្នាដែលមាំមួន (ក្នុងចិត្ត) របស់បងយ៉ាងនេះ ។ ម្នាលនាងទេវធីតា មានប្រាជ្ញាឈ្លាសវៃនាងមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា បងសូមថ្វាយបង្គំចំពោះអ្នកនោះ ជាបិតារបស់នាង ដូចឈើដែលទើបនឹងមានផ្កា ។

[๘๗] *កាលបើបញ្ចសិខគន្ធព្វបុត្ត ច្រៀងគាថាទាំងនោះយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរបញ្ចសិខគន្ធព្វបុត្តយ៉ាងនេះថា ម្នាលបញ្ចសិខៈ សំឡេងខ្សែពិណរបស់អ្នក សមល្មមគ្នានឹងសំឡេងច្រៀង ទាំងសំឡេងច្រៀងក៏សមល្មមគ្នានឹងសំឡេងខ្សែពិណ ម្នាលបញ្ចសិខៈ មួយទៀត សំឡេងខ្សែពិណរបស់អ្នកមិនប្រព្រឹត្តកន្លងសំឡេងច្រៀង ទាំងសំឡេងច្រៀងក៏មិនប្រព្រឹត្តកន្លងសំឡេងខ្សែពិណដែរ ម្នាលបញ្ចសិខៈ គាថាទាំងនេះដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត ទាំងប្រកបដោយកាម តើអ្នកចងក្រងទុកតាំងពីកាលណាមក ។ បញ្ចសិខគន្ធព្វបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានចងក្រងទុកមក តាំងអំពីសម័យដែលព្រះមានព្រះភាគទ្រង់បានត្រាស់ដឹងជាដំបូង ហើយទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស*

ឯណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះ ខ្ញុំព្រះអង្គប្រាថ្នាចង់បាន នូវនាង*សុរិយវច្ឆសា*ដ៏ល្អ ដែលជាធីតានៃព្រះបាទ*តិម្ពរុគន្ធព្វរាជ* ។ បពិត្រព្រះអង្គដ៏ចម្រើន តែនាងនោះឯងមានសេចក្តីស្រឡាញ់ចំពោះបុរសដទៃវិញ គឺចង់បានសិទ្ធិទេវបុត្រ ជាបុត្តរបស់មាតលីសង្គហកទេវបុត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលដែលខ្ញុំព្រះអង្គមិនបាននាងនោះ ដោយបរិយាយណាមួយហើយ ទើបខ្ញុំព្រះអង្គកាន់ពិណ មានសម្បុរលឿងដូចផ្ទៃព្នៅទុំ ចូលសំដៅទៅត្រង់លំនៅរបស់ព្រះបាទ*តិម្ពរុគន្ធព្វរាជ* លុះចូលទៅដល់ហើយ ក៏ដេញពិណមានសម្បុរលឿងដូចផ្ទៃព្នៅទុំ ហើយច្រៀងនូវគាថាទាំងនេះ ដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត ទាំងប្រកបដោយកាមថា

> *ម្នាលនាងទេវធីតា ឈ្មោះ*សុរិយវច្ឆសា*ដ៏ចម្រើន នាងកើតមកហើយ មានរូបល្អ បងសូមថ្វាយបង្គំនូវទេវរាជ ព្រះនាម*តិម្ពរុ*ជាបិតារបស់នាង ដោយហេតុដែលនាងកើតមកហើយ មានលម្អ ជាទីញុំាងសេចក្តីត្រេកអរឲ្យកើតដល់បង ។បេ។ ម្នាលនាងទេវធីតា មានប្រជ្រាឈ្វាសវៃ នាងមានរូបប្រាកដ ដូច្នេះ ជាធីតារបស់អ្នកណា បងសូមថ្វាយបង្គំចំពោះអ្នកនោះ ជាបិតារបស់នាង ដូចឈើដែលទើបនឹងមានផ្លា ។

[๘๘] បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គច្រៀងគាថាយ៉ាងនេះហើយ នាង*សុរិយវច្ឆសា*ដ៏ចម្រើន បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា

ម្នាលអ្នកនិទ្ទុក្ខ ខ្ញុំមិនដែលបានឃើញព្រះមានព្រះភាគអង្គនោះ ក្នុងទីចំពោះព្រះភក្ត្រសោះឡើយ ប៉ុន្តែកាលខ្ញុំចូលទៅរាំក្នុងវេន ឈ្មោះ សុធម្មារបស់ទេវតាទាំងឡាយ នៅក្នុងឋានតាវត្តិង្ស ក៏បានឮកិត្តិគុណ របស់ព្រះមានព្រះភាគនោះ ម្នាលអ្នកនិទ្ទុក្ខ កាលណាបើអ្នកនិយាយសរសើរព្រះមានព្រះភាគអង្គនោះ កាលជួបគ្នាក្នុងថ្ងៃនេះ ចូរមានដល់យើងទាំង ២ នាក់ ។ បពិត្រព្រះអង្គដ៏ចម្រើន ការស្មគ្រែសមាគមជាមួយនឹងនាងនោះ ក៏មានដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គក៏លែងច្រៀង (ទំនុកនេះ) តាំងពីក្រោយនោះមក ។ លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ត្រិះរិះយ៉ាងនេះថា បញ្ចសិខ-គន្ធព្វបុត្តសាទរជាមួយនឹងព្រះមានព្រះភាគ ទាំងព្រះមានព្រះភាគ ក៏ទ្រង់សាទរជាមួយនឹងបញ្ចសិខគន្ធព្វបុត្ត ។ ទើបសក្កទេវរាជ ជាធំជាងពួកទេវតា ត្រាស់ហៅបញ្ចសិខគន្ធព្វបុត្តមកថា នែអ្នកបញ្ចសិខៈ អ្នកចូរទៅថ្វាយបង្គំព្រះមានព្រះភាគ តាមពាក្យរបស់យើងថា បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមបរិសទ្យ សូមក្រាបថ្វាយបង្គំនូវព្រះបាទទាំងគូ របស់ព្រះមានព្រះភាគដោយត្បូង ។ បញ្ចសិខគន្ធព្វបុត្ត ក៏ទទួលព្រះបន្ទូលសក្កទេវរាជ ជាធំជាងពួកទេវតាដោយពាក្យថា ព្រះករុណាថ្ងៃវិសេស សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ហើយថ្វាយបង្គំព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិសទ្យ សូមក្រាបថ្វាយបង្គំនូវព្រះបាទទាំងគូ របស់ព្រះមានព្រះភាគដោយត្បូង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបញ្ចសិខៈ

សូមឲ្យសក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិសទ្យ បានសេចក្តីសុខ តាមសេចក្តីប្រាថ្នាចុះ ព្រោះពួកទេវតា និងមនុស្ស អសុរ នាគ គន្ធព្វ និងសត្វដទៃៗ ជាច្រើនពួក តែងប្រាថ្នាសេចក្តីសុខ ។

[๘๙] *ធម្មតាព្រះតថាគតរាល់ព្រះអង្គ តែងមានព្រះបន្ទូលដោយស្មោះ ចំពោះទៅរកពួកយក្សដែលមានសក្តិធំ មានសរីរាង្គយ៉ាងនេះ ដូច្នេះឯង ។ ឯសក្កទេវរាជជាធំជាងពួកទេវតា លុះព្រះមានព្រះភាគ មានព្រះបន្ទូលដោយស្មោះចំពោះហើយ ក៏ចូលទៅកាន់ឥន្ទសាលគុហា ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ទាំងពួកទេវតានៅក្នុងជាន់តាវត្តិង្ស ក៏ចូលទៅកាន់ឥន្ទសាលគុហា ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ឯបញ្ចសិខគន្ធព្វបុត្ត ក៏ចូលទៅកាន់ឥន្ទសាលគុហា ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ក្នុងសម័យនោះឯង ឥន្ទសាលគុហា ដែលមានផ្ទៃមិនរាបស្មើ ក៏ប្រែជាមានផ្ទៃរាបស្មើវិញ មានទីចង្អៀត ក៏ប្រែជាមានទីធំទូលាយវិញ ទាំងងងឹតក្នុងគុហាក៏បាត់ទៅ មានពន្លឺភ្លឺព្រោងព្រាតឡើង ដោយទេវានុភាពរបស់ពួកទេវតានោះឯង ។*

[๙๐] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងសក្កទេវរាជ ជាធំជាងពួកទេវតាដូច្នេះថា នេះជាហេតុគួរអស្ចារ្យ របស់កោសិយៈមានអាយុ នេះជាហេតុមិនធ្លាប់កើតមានរបស់កោសិយៈមានអាយុ នេះជាដំណើរស្តេចមកក្នុងទីនេះ របស់ទេវរាជដែលមានកិច្ចច្រើន មានការងារច្រើន ។ សក្ក-ទេវរាជក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានបំណងនឹង*

ចូលមកគាល់ព្រះមានព្រះភាគ ជាយូរណាស់ហើយ តែខ្ញុំព្រះអង្គមានសេចក្តីខ្វល់ខ្វាយដោយកិច្ចការងារនីមួយ របស់ពួកទេវតានៅក្នុងជាន់តាវត្តិង្ស ព្រោះហេតុនោះ ខ្ញុំព្រះអង្គក៏មិនអាចនឹងចូលមកគាល់ព្រះមានព្រះភាគបាន ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសលឡ-គន្ធកុដិ ជិតក្រុងសាវត្ថី ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះឯង ខ្ញុំព្រះអង្គបានមកកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន តែជួនជាវេលានោះ ព្រះមានព្រះភាគកំពុងគង់សម្ងំដោយសមាធិណាមួយ ។ ឯនាងទេវធីតាឈ្មោះកុជគី ជាបរិចារិការបស់វេស្សវណមហារាជ កំពុងតែឈរប្រណម្យអញ្ជលីមនស្ការ គោរពព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ខ្ញុំព្រះអង្គផ្តាំផ្ញើនឹងនាងទេវធីតាឈ្មោះកុជគីដូច្នេះថា ម្នាលប្អូនស្រី នាងចូរថ្វាយបង្គំព្រះមានព្រះភាគ តាមពាក្យយើងថា បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិសទ្យ សូមថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគដោយត្បូង ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គផ្តាំផ្ញើយ៉ាងនេះហើយ នាងទេវធីតាឈ្មោះកុជគីនោះ ឆ្លើយបតមកនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ វេលានេះជាកាលមិនគួរនឹងចូលទៅគាល់ព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគកំពុងសម្ងំនៅដោយព្រះកម្មដ្ឋាន ។ ខ្ញុំព្រះអង្គបាននិយាយថា បើដូច្នោះ កាលណាបើព្រះមានព្រះភាគ ទ្រង់ចេញចាកសមាធិនោះហើយ ចូរនាងថ្វាយបង្គំព្រះមានព្រះភាគ តាមពាក្យរបស់យើងថា បពិត្រព្រះអង្គដ៏

ចម្រើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិសទ្យ សូមថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគដោយត្ឈូង ។ បពិត្រព្រះអង្គដ៏ចម្រើន នាងនោះបានថ្វាយបង្គំព្រះមានព្រះភាគ តាមពាក្យខ្ញុំព្រះអង្គដែរឬ ព្រះមានព្រះភាគទ្រង់រឲកឃើញពាក្យនាងនោះដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បពិត្រទេវានមិនូ នាងនោះ បានថ្វាយបង្គំតថាគតហើយ តថាគតក៏រឲកឃើញពាក្យនោះបាន តែតថាគតចេញចាកសមាធិនោះព្រោះសូរនៃខ្នងកង់ (រាជរថ) របស់ទេវរាជមានអាយុ ។ សក្កទេវរាជក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណា បានទៅកើតក្នុងពពួកទេវតា នៅក្នុងជាន់តាវត្តិង្ស មុនជាងខ្ញុំព្រះអង្គៗ បានឲ្ចចំពោះមុខ បានទទួល (ជំណឹងនោះ) ចំពោះមុខ នៃទេវតាទាំងនោះថា កាលណា ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើងក្នុងលោក កាលនោះ ពួកទេវតាក៏កុះករ ពួកអសុរក៏សាបសូន្យទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះឯង ខ្ញុំព្រះអង្គបានឃើញជាក់ហើយ តាំងពីដួចព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធកើតឡើងហើយក្នុងលោក ពួកទេវតាក៏កុះករ ពួកអសុរក៏សាបសូន្យទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងកបិលវត្ថុនេះឯង មានសក្យធីតាម្នាក់ ឈ្មោះគោបិកា ជាស្ត្រីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ តែងធ្វើនូវការបំពេញកិច្ចក្នុងសីលទាំងឡាយ នាងនឿយណាយចិត្ត ក្នុងភេទនៃខ្លួនជាស្ត្រីកើតសេចក្តីពេញចិត្ត ក្នុងភេទនៃខ្លួនជាបុរស លុះដល់បែកទម្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ ក៏បានទៅកើតក្នុង

សុគតិសួគ៌ទេវលោក ជាមួយនឹងទេវតាដែលឋិតនៅក្នុងជាន់តាវត្តិង្ស បានមក ជាឱរសរបស់ខ្ញុំព្រះអង្គ ពួកទេវតាដែលនៅក្នុងជាន់តាវត្តិង្សនោះ ស្គាល់ទេវ-បុត្តនោះយ៉ាងនេះថា គោបកទេវបុត្រ គោបកទេវបុត្ត ដូច្នោះ ។ បពិត្រព្រះអង្គដ៏ចម្រើន មានកិក្ខុ ៣ រូបដទៃទៀត ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ (លុះទម្លាយរាងកាយ) ក៏ទៅកើតក្នុងពួកគន្ធព្វដ៏ថោកទាប គន្ធព្វទាំង ៣ រូបនោះ ឲ្យគេបម្រើ ឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ តែងមកកាន់ទីបម្រើរបស់ខ្ញុំព្រះអង្គ មកកាន់ទីគោរពប្រតិបត្តិខ្ញុំព្រះអង្គ លុះគន្ធព្វទាំង ៣ នោះ មកកាន់ទីបម្រើរបស់ខ្ញុំព្រះអង្គ មកកាន់ទីគោរព ប្រតិបត្តិខ្ញុំព្រះអង្គ គោបកទេវបុត្រ ក៏និយាយជាសំតៀនរំឭកថា ម្នាលអ្នក និទ្ទុក្ខទាំងឡាយ អ្នកទាំងឡាយយកមុខទៅទុកក្នុងទីណា បានជាឃ្វាងនឹងធម៌របស់ព្រះមានព្រះភាគអង្គនោះ អម្បាលយ៉ាងខ្ញុនខ្ញុំជាស្ត្រីសោះទេ ម្តេចគង់ជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានធ្វើនូវការបំពេញកិច្ច ក្នុងសីលទាំងឡាយទៅកើត (មិនតែប៉ុណ្ណោះ) ក៏នឿយណាយចិត្តក្នុងភេទនៃស្ត្រី កើតសេចក្តីពេញចិត្តក្នុងភេទនៃបុរស លុះដល់បែកទម្លាយរាងកាយ ខាងមុនអំពីសេចក្តីស្លាប់ ក៏មកកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយនឹងទេវតាដែលឋិតនៅក្នុងជាន់តាវត្តិង្ស បានមកជាបុត្ររបស់សក្កទេវរាជ ជាធំជាងពួកទេវតា ឯពួកទេវតាដែលនៅក្នុងជាន់តាវត្តិង្សនេះ នាំគ្នាហៅខ្ញុំយ៉ាងនេះថា គោបកទេវបុត្ត គោបកទេវបុត្តដូច្នេះ ម្នាលអ្នកនិទ្ទុក្ខទាំងឡាយ ចំណែកអ្នកទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមាន

ព្រះភាគ តែបែរជាមកកើតក្នុងពួកគន្ធព្វដ៏ថោកទាបវិញ ឱហ្ន៎ យើងទាំង-ទ្បាយណា បានឃើញពួកសហធម្មិក ដែលកើតក្នុងគន្ធព្វដ៏ថោកទាប យើងទាំងទ្បាយនោះ ឈ្មោះថា បានឃើញរូបដែលមិនគួរឃើញ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាទេវតាទាំង ៣ អង្គដែលគោបកទេវបុត្ត និយាយរំពឹកជាស់តឿននោះ ទេវតា ២ អង្គ ក៏ត្រឡប់បានស្មារតី ប្រកបដោយឈានក្នុងបច្ចុប្បន្ន (លុះច្យុតចាកអត្តភាពនោះហើយ) ក៏បានទូវកាយជាព្រហ្ម-បុរោហិត ។ ឯទេវតាមួយអង្គទៀត អាស្រ័យនៅក្នុងកាមភព ។

[៩១] ខ្ញុំបានជាឧបាសិកា របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់មានចក្ខុ ឯឈ្មោះរបស់ខ្ញុំប្រាកដជា គោបិកា ជាស្ត្រីមានចិត្តជ្រះថ្លាស៊ប់ ក្នុងព្រះពុទ្ធ និងព្រះធម៌ លុះមានចិត្តជ្រះថ្លាហើយ បានទាំងបម្រើព្រះសង្ឃផង ។ ដោយអំណាចនៃព្រះពុទ្ធជាម្ចាស់នោះ និងព្រះធម៌ដ៏ប្រពៃ ខ្ញុំក៏បានមកកើតក្នុងបុរីនៃទេវតា បានជាបុត្ររបស់សក្កទេវរាជ ជាអ្នកមានអានុភាពច្រើន មានពន្លឺច្រើន ពួកទេវតាដែលនៅក្នុងទេវលោកនេះ តែងស្គាល់ខ្ញុំថា គោបកទេវបុត្តដូច្នេះ ។ ខ្ញុំបានឃើញ នូវពួកភិក្ខុដែលធ្លាប់ឃើញហើយមកកើតក្នុងពួកគន្ធព្វ នៅក្នុងពួកគន្ធព្វនោះ ឯភិក្ខុទាំងនោះសុទ្ធតែជាសាវ័ករបស់ព្រះគោតម មួយទៀត យើងទាំង-ទ្បាយណា បានកើតជាមនុស្សក្នុងកាលមុន យើងទាំង-

ឡាយនោះ បានចាត់ចែងកិច្ច គឺ លាងលាបបាទាហើយ បានទំនុកបម្រុងដោយម្ហូបចំណី និងទឹកក្នុងលំនៅរបស់ខ្លួន អ្នកទាំងឡាយដ៏ចម្រើន យកមុខទៅទុកក្នុងទីណា បានជាមិនទទួលយកព្រះធម៌របស់ព្រះពុទ្ធជាម្ចាស់ ។ ឯធម៌ដែលវិញ្ញូជនគប្បីត្រាស់ដឹងដោយខ្លួនឯង ក៏ព្រះសម្មាសម្ពុទ្ធមានចក្ខុ ទ្រង់ត្រាស់ដឹងហើយ សម្តែងដោយប្រពៃហើយ ឯខ្ញុំបានចូលទៅអង្គុយស្តាប់សុភាសិត របស់ព្រះអរិយៈទាំងឡាយ ដូចអ្នកទាំងឡាយដែរ ។ ខ្ញុំបានមកកើតក្នុងបុរីនៃទេវតា បានជាបុត្ររបស់សក្កទេវរាជ ជាអ្នកមានអានុភាពច្រើន មានពន្ធឺច្រើន ឯអ្នកទាំងឡាយ បានចូលទៅអង្គុយជិតព្រះពុទ្ធដ៏ប្រសើរ ទាំងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងព្រះពុទ្ធសាសនាដ៏ប្រសើរ ។ អ្នកទាំងឡាយដ៏ចម្រើន បានមកកើតក្នុងពួកគន្ធព្វ ជាអ្នកថោកទាប ការកើតរបស់អ្នកទាំងឡាយដ៏ចម្រើន (នេះ) មិនសមគួរសោះឡើយ យើងបានឃើញនូវពួកសហធម្មិក ដែលមកកើតក្នុងពួកគន្ធព្វ អ្នកថោកទាប (នេះ) ឱហ្ន៎ ឈ្មោះថាបានឃើញរូបដែលមិនគួរឃើញ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយកើតក្នុងពួកគន្ធព្វ មកកាន់ទីបម្រើនៃទេវតាទាំងឡាយ ចូរមើលនូវគុណវិសេសនេះ របស់ខ្ញុំដែលនៅ

ក្នុងផ្ទះ ។ ពីដើមខ្ញុំជាស្ត្រី ឥឡូវនេះ ខ្ញុំបានជាទេវបុត្រ
បរិបូណិដោយកាមជាទិព្វទាំងឡាយ ឯទេវបុត្តទាំងនោះ
លុះគោបកទេវបុត្ត ជាសាវ័ករបស់ព្រះគោតមបានរំព្ចក
ជាស់តឿនហើយ ក៏ដល់នូវសេចក្តីសង្វេគថា យើងទាំង-
ឡាយ បានមកជួបនឹងគោបកទេវបុត្រ បើដូច្នោះ យើងចូរ
នាំគ្នាខំប្រឹងប្រែងព្យាយាមទៅ កុំឲ្យបានមកជាអ្នកបម្រើ
គេទៀតឡើយ បណ្តាទេវបុត្រទាំង ៣ រូបនោះ ទេវបុទ្រ
២ រូប បានរព្ចកនូវសាសនានៃព្រះគោតមហើយ ប្រារព្ធ
នូវសេចក្តីព្យាយាមជានិច្ច ធ្វើចិត្តឲ្យនឿយណាយ ក្នុង
ទេវលោកនេះ បានឃើញទោសក្នុងកាមហើយ ទេវបុត្រ
ទាំងពីររូបនោះ បានកាត់នូវកាមសំយោជនៈ នឹងកាម-
ពន្ធនៈ ជាចំណងរបស់មារ ដែលសត្វប្រព្រឹត្តកន្ធងបាន
ដោយកម្រ ។ ទេវបុត្រទាំង ២ អង្គនោះ បានកាត់នូវ
ចំណងដ៏ល្អិត ដូចជំរី (ផ្តាច់ទន្ទីង) ហើយប្រព្រឹត្តកន្ធង
នូវពួកទេវតា ដែលនៅក្នុងជាន់តាវត្តិង្ស ពួកទេវតាទាំង
អស់ ព្រមទាំងព្រះឥន្ទ្រាធិរាជ និងបជាបតិទេវរាជ បាន
ចូលទៅក្នុងរោងឈ្មោះសុធម្មា ។ ទេវតាទាំងនោះ លុះប្រជុំ
គ្នាហើយ ក៏មិនប្រព្រឹត្តកន្ធងនូវទេវបុត្រទាំង ២ រូបនោះ
បានឡើយ ទេវបុត្រទាំង ២ រូបនោះ ជាអ្នកក្លៀវក្លា ប្រាស

ចាកភាគៈ ធ្វើនូវអនាគាមិមគ្គដែលជ្រាសចាកធូលី ភាសវ-ទេវរាជ ជាធំជាងពួកទេវតា បានឃើញនូវទេវបុត្រទាំង ២ រូបនោះហើយ ក៏ធ្វើនូវសេចក្តីសង្វេគ ក្នុងកណ្តាលនៃពួកទេវតាថា ។ ទេវបុត្រទាំងនេះ គឺទេវបុត្រដែលកើតក្នុងពួកគន្ធព្វ ជាអ្នកថោកទាបនោះឯង ប្រព្រឹត្តកន្ទងនូវពួកទេវតា ដែលនៅក្នុងជាន់តាវត្តិង្ស ឯគោបកទេវបុត្រ លុះបានស្តាប់នូវព្រះបន្ទូលនៃភាសវទេវរាជ ដែលទ្រង់កើតសេចក្តីសង្វេគហើយ ក៏ក្រាបទូលភាសវទេវរាជថា ។ បពិត្រព្រះអង្គជាធំជាងជន ព្រះពុទ្ធទ្រង់កើតក្នុងមនុស្សលោក ទ្រង់គ្របសង្កត់នូវកាមបាន អ្នកផងតែងស្គាល់ព្រះនាមថា សក្យមុនី ទេវបុត្រទាំង ២ រូបនោះ ជាបុត្ររបស់ព្រះអង្គ សាបសូន្យចាកឈានសតិ លុះខ្ញុំព្រះអង្គរំឭកជាស់តឿនហើយ ទេវបុត្រទាំងពីររូបនោះ ក៏ត្រឡប់បាននូវឈានសតិវិញ ។ បណ្តាជនទាំង ៣ នាក់នោះ ជនម្នាក់អាស្រ័យនៅក្នុងពួកដ៏ថោកទាបនេះ បានចូលទៅរួមក្នុងពួកគន្ធព្វ នៅក្នុងពួកគន្ធព្វនោះ ជន ២ នាក់ទៀត រឭកឃើញនូវផ្លូវនៃសម្មោធិញ្ញាណ គឺអនាគាមិមគ្គ ក៏ធុញទ្រាន់នឹងទេវលោក ព្រោះខ្លួនមានចិត្តប្រកបដោយសមាធិ ។ កិរិយាប្រកាសនូវធម៌ ក្នុងសាសនានេះ មានសភាពដូច្នេះ

បណ្តាសាវ័កទាំងនោះ សូម្បីសាវ័កណាមួយ ក៏មិនសង្ស័យ នឹងអ្វីឡើយ យើងទាំងឡាយសូមនមស្ការនូវព្រះពុទ្ធ ព្រះអង្គឈ្នះមារ ព្រះអង្គជាធំជាងជន ទ្រង់ឆ្លងនូវឱឃៈបានហើយ កាត់បង់នូវសេចក្តីសង្ស័យបានហើយ ។ ទេវបុត្រទាំងនោះ បានដឹងច្បាស់នូវធម៌ណា របស់ព្រះអង្គ ក្នុងសាសនានេះហើយ បាននូវគុណវិសេស បណ្តាគន្ធព្វទាំង ៣ នាក់នោះ គន្ធព្វ ២ នាក់បាននូវកាយជាព្រហ្មបុរោហិត បានដល់នូវគុណវិសេស គឺមគ្គ និងផល ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ យើងខ្ញុំព្រះអង្គនាំគ្នាមក ដើម្បីដល់នូវធម៌នោះ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ បើព្រះមានព្រះភាគ ទ្រង់បើកឱកាសហើយ យើងខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរនូវប្រស្នា ។

[๙๒] *លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា សក្កទេវរាជនេះ ទ្រង់មានព្រះទ័យដ៏បរិសុទ្ធស្អាត មកអស់កាលយូរហើយ នឹងសួរនូវប្រស្នាណាមួយចំពោះតថាគត ក៏សួរតែប្រស្នាដែលមានប្រយោជន៍ទាំងអស់ មិនមែនសួរនូវប្រស្នាដែលមិនមានប្រយោជន៍ឡើយ មួយទៀត សក្កទេវរាជ បានសួរតថាគតៗ នឹងដោះស្រាយចំពោះប្រស្នាណា សក្កទេវរាជ ក៏នឹងយល់ច្បាស់នូវប្រស្នានោះ ធាប់រហ័សបាន ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងសក្កទេវរាជ ជាធំជាងទេវតា ដោយបទគាថាថា*

បពិត្រវាសវៈ មហារាជមានព្រះហឫទ័យ ប្រាថ្នានឹងសួរនូវ ប្រស្នាណា ចូរសួរនូវប្រស្នានោះចំពោះតថាគតចុះ តថាគត នឹងធ្វើនូវទីបំផុតនៃប្រស្នាទាំងនោះៗ ថ្វាយមហាបពិត្របាន ។

បឋមភាណវារ ចប់

[๙๓] *លុះព្រះមានព្រះភាគ ទ្រង់ប្រទានឱកាសហើយ សក្កទេវរាជ ជាធំជាងពួកទេវតា ក្រាបបង្គំទូលសួរប្រស្នាជាដំបូងនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ពួកទេវតា មនុស្ស អសុរ នាគ និងគន្ធព្វ ទាំងពួកជនច្រើនដទៃៗ មានធម៌អ្វីជាគ្រឿងចងរួបរឹតទុក បានជាពួកសត្វទាំងនោះ សូម្បីប្រាថ្នាថា សូមឲ្យយើងទាំងឡាយ ជាអ្នកមិនមានពៀរ មិនមានអាជ្ញា មិនមានសត្រូវ មិនមានព្យាបាទ នៅដោយមិនមានពៀរនឹងគ្នា ពួកសត្វទាំងនោះ តែងមានសេចក្តីប្រាថ្នាយ៉ាងនេះឯង ទោះបីមានសេចក្តីប្រាថ្នាដូច្នោះ ក៏គង់សត្វទាំងនោះ នៅតែជាអ្នកមានពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទ នៅដោយមានពៀរនឹងគ្នាដដែល ។ សក្កទេវរាជ ជាធំជាងពួកទេវតា បានទូលសួរប្រស្នាចំពោះព្រះមានព្រះភាគហើយ ដោយប្រការដូច្នេះ ។ លុះសក្កទេវរាជនោះ បានទូលសួរប្រស្នាហើយ ព្រះមានព្រះភាគ ក៏ទ្រង់ព្យាករថា បពិត្រទេវានមិន្ទ ពួកទេវតា មនុស្ស អសុរ នាគ និងគន្ធព្វ ទាំងពួកជនច្រើនដទៃៗ មានឥស្សា (សេចក្តីច្រណែន) និងមច្ឆរិយៈ (សេចក្តីកំណាញ់) ជាគ្រឿងចងរួបរឹតទុក បានជាពួកសត្វទាំងនោះ សូម្បីប្រាថ្នាថា សូមឲ្យយើងទាំងឡាយ ជាអ្នកមិនមានពៀរ មិនមានអាជ្ញា មិន*

មានសត្រូវ មិនមានព្យាបាទ នៅដោយមិនមានពៀរនឹងគ្នា ពួកសត្វទាំងនោះ តែងមានសេចក្តីប្រាថ្នាដូច្នេះឯង ទោះបីមានសេចក្តីប្រាថ្នាដូច្នោះ ក៏គង់សត្វទាំងនោះ នៅតែជាអ្នកមានពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទ នៅដោយមានពៀរនឹងគ្នាជដែល ។ លុះព្រះមានព្រះភាគ ទ្រង់ព្យាករនូវប្រស្នាដែលសក្កទេវរាជជាធំជាងពួកទេវតា ក្រាបទូលសួរដោយប្រការដូច្នេះហើយ ។ សក្កទេវរាជ ជាធំជាងពួកទេវតា ក៏មានព្រះហឫទ័យត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ដំណើរនោះ យ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនោះ យ៉ាងហ្នឹងហើយ សេចក្តីសង្ស័យក្នុងប្រស្នានុ៎ះ ខ្ញុំព្រះអង្គបានឆ្លងផុតហើយ សេចក្តីងឿងឆ្ងល់ក៏អស់ហើយ ព្រោះបានស្តាប់នូវបញ្ហាវេយ្យាករណ៍ របស់ព្រះមានព្រះភាគ ។

[๙๔] លុះសក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគដូច្នេះហើយ ទើបសួរនូវប្រស្នាចំពោះព្រះមានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ សេចក្តីច្រណែន និងសេចក្តីកំណាញ់ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើតមានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ ទើបសេចក្តីច្រណែន និងសេចក្តីកំណាញ់កើតមាន កាលបើអ្វីមិនមានហើយ ទើបសេចក្តីច្រណែន និងសេចក្តីកំណាញ់ក៏មិនមានដែរ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា បពិត្រទេវានមិន្ទ សេចក្តីច្រណែន និងសេចក្តីកំណាញ់ មានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ជាដើមហេតុ មានសេចក្តីស្រឡាញ់ និងសេចក្តី

ស្អប់នាំឲ្យកើត មានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ជាកំណើត មានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់បណ្តាលឲ្យកើត កាលបើសេចក្តីស្រឡាញ់ និងសេចក្តីស្អប់មានហើយ ទើបសេចក្តីច្រណែន និងសេចក្តីកំណាញ់ក៏មានដែរ កាលបើសេចក្តីស្រឡាញ់ និងសេចក្តីស្អប់មិនមានហើយ សេចក្តីច្រណែន និងសេចក្តីកំណាញ់ ក៏មិនមានដែរ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះសេចក្តីស្រឡាញ់ និងសេចក្តីស្អប់មានអ្វីជាដើមហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ ទើបសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ក៏មានដែរ កាលបើអ្វីមិនមានហើយ សេចក្តីស្រឡាញ់ និងសេចក្តីស្អប់ក៏មិនមានដែរ ។ បពិត្រទេវានមិន្ទ សេចក្តីស្រឡាញ់ និងសេចក្តីស្អប់ មានឆន្ទៈ (សេចក្តីពេញចិត្ត) ជាដើមហេតុ មានឆន្ទៈនាំឲ្យកើត មានឆន្ទៈជាកំណើត មានឆន្ទៈបណ្តាលឲ្យកើត កាលបើឆន្ទៈមានហើយ សេចក្តីស្រឡាញ់ និងសេចក្តីស្អប់ក៏មានដែរ កាលបើឆន្ទៈមិនមានហើយ សេចក្តីស្រឡាញ់ និងសេចក្តីស្អប់ក៏មិនមានដែរ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះឆន្ទៈមានអ្វីជាដើមហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ ឆន្ទៈក៏មានដែរ កាលបើអ្វីមិនមានហើយ ឆន្ទៈក៏មិនមានដែរ ។ បពិត្រទេវានមិន្ទ ឆន្ទៈ មានវិតក្ក (សេចក្តីត្រិះរិះ) ជាដើមហេតុ មានវិតក្កនាំឲ្យកើត មានវិតក្កជាកំណើត មានវិតក្កបណ្តាលឲ្យកើត កាលបើវិតក្កមានហើយ ឆន្ទៈក៏មានដែរ កាលបើវិតក្កមិនមានហើយ ឆន្ទៈក៏មិនមានដែរ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះវិតក្ក មានអ្វីជាដើមហេតុ មានអ្វី

នាំឲ្យកើត មានអ្វីជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ វិតក្កក៏មានដែរ កាលបើអ្វីមិនមានហើយ វិតក្កក៏មិនមានដែរ ។ បពិត្រទេវានមិន្ទ វិតក្ក មានចំណែកនៃបបញ្ចសញ្ញា (សេចក្តីសម្គាល់ប្រកបដោយធម៌ជាគ្រឿងឲ្យយឺតយូរ) ជាដើមហេតុ មានចំណែកនៃបបញ្ចសញ្ញា នាំឲ្យកើត មានចំណែកនៃបបញ្ចសញ្ញាជាកំណើត មានចំណែកនៃបបញ្ចសញ្ញាបណ្តាលឲ្យកើត កាលបើ ចំណែកនៃបបញ្ចសញ្ញាមានហើយ វិតក្កក៏មានដែរ កាលបើចំណែកនៃបបញ្ចសញ្ញា មិនមានហើយ វិតក្កក៏មិនមានដែរ ។

[๙๕] បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះភិក្ខុប្រតិបត្តិយ៉ាងណា ទើបឈ្មោះថា ជាអ្នកប្រតិបត្តិនូវបដិបទា ជាដំណើរដ៏សមគួរដល់សេចក្តីរម្ងាប់នូវចំណែកនៃបបញ្ចសញ្ញា ។ បពិត្រទេវានមិន្ទ តថាគតសម្តែងថា សោមនស្សមាន ២ យ៉ាង គឺសោមនស្សគួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន បពិត្រទេវានមិន្ទ តថាគតសម្តែងថា ទោសមនស្សមាន ២ យ៉ាង គឺទោសមនស្សគួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន បពិត្រទេវានមិន្ទ តថាគតសម្តែងថា ឧបេក្ខាមាន ២ យ៉ាង ឧបេក្ខាគួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា សោមនស្សមាន ២ យ៉ាង គឺសោមនស្សគួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមកយ៉ាងនោះ តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាសោមនស្សទាំង ២ ប្រការនោះ ភិក្ខុដឹងច្បាស់នូវសោមនស្សណាថា កាលបើអាត្មាអញសេពគប់នូវសោមនស្ស

នេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំង-ឡាយ តែងសាបសូន្យទៅដូច្នេះ សោមនស្សបែបនេះ កិកូមិនគួរសេពគប់ ។ បណ្តាសោមនស្សទាំង ២ ប្រការនោះ កិកូដឹងច្បាស់នូវសោមនស្សណាថា កាលបើអាត្មាអញ សេពគប់នូវសោមនស្សនេះហើយ អកុសលធម៌ទាំង-ឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងដូច្នេះ សោមនស្សបែបនេះ កិកូគួរសេពគប់ ។ ក្នុងសោមនស្សគួរសេពគប់នោះ សោមនស្សដែលមានវិតក្ក វិចារៈក៏មាន សោមនស្សដែលមិនមានវិតក្ក មិនមានវិចារៈក៏មាន សោមនស្សណា ដែលមិនមានវិតក្ក មិនមានវិចារៈ សោម-នស្សនោះប្រសើរជាង ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា សោមនស្សមាន ២ យ៉ាង គឺសោមនស្សគួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា ទោមនស្សមាន ២ យ៉ាង គឺទោមនស្សគួរសេពក៏មាន មិនគួរសេពគប់ក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមកយ៉ាងនោះ តើព្រោះអាស័យហេតុអ្វី ។ ព្រោះថា បណ្តាទោមនស្សទាំងពីរនោះ កិកូដឹងច្បាស់នូវទោមនស្សណាថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ ទោមនស្សបែបនេះ កិកូមិនគួរសេព ។ បណ្តាទោមនស្សទាំង ២ ប្រការនោះ កិកូដឹង

ច្បាស់នូវទោមនស្សណាថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុ-
សលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើន
ដុះដាលឡើងដូច្នេះ ទោមនស្សបែបនេះ ភិក្ខុគួរសេព ។ ក្នុងទោមនស្ស
ដែលគួរសេពនោះ ទោមនស្សដែលមានវិតក្កវិចារៈក៏មាន ទោមនស្សដែល
មិនមានវិតក្កវិចារៈក៏មាន ទោមនស្សណា ដែលមិមានវិតក្កវិចារៈ ទោម-
នស្សនោះប្រសើរជាង ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែង
ថា ទោមនស្សមាន ២ យ៉ាង គឺទោមនស្សគួរសេពក៏មាន មិនគួរសេពក៏
មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោល
ហើយ ព្រោះអាស័យហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ
តថាគតសម្តែងថា ឧបេក្ខាមាន ២ យ៉ាង គឺឧបេក្ខាគួរសេពក៏មាន មិនគួរ
សេពក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោល
មកយ៉ាងនោះ តើព្រោះអាស័យហេតុអ្វី ព្រោះថា បណ្តាឧបេក្ខាទាំង ២
ប្រការនោះ ភិក្ខុជឿងច្បាស់នូវឧបេក្ខាណាថា កាលបើអាត្មាអញ សេពនូវ
ឧបេក្ខានេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌
ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ ឧបេក្ខាបែបនេះ ភិក្ខុមិនគួរសេព ។
បណ្តាឧបេក្ខាទាំង ២ ប្រការនោះ ភិក្ខុជឿងច្បាស់នូវឧបេក្ខាណាថា កាលបើ
អាត្មាអញសេពនូវឧបេក្ខានេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ
កុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង ដូច្នេះ ឧបេក្ខាបែបនេះ ភិក្ខុ
គួរសេព ។ ក្នុងឧបេក្ខាដែលគួរសេពនោះ ឧបេក្ខាដែលមានវិតក្កវិចារៈក៏មាន

ឧបេក្ខាដែលមិនមានវិតក្កវិចារៈក៏មាន ឧបេក្ខាណា ដែលមិនមានវិតក្កវិចារៈ ឧបេក្ខានោះប្រសើរជាង ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា ឧបេក្ខាមាន ២ យ៉ាង គឺឧបេក្ខាគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ បពិត្រទេវានមិន្ទ ភិក្ខុលុះតែប្រតិបត្តិយ៉ាងនេះឯង ទើបឈ្មោះថា ជាអ្នកប្រតិបត្តិនូវបដិបទា ជាដំណើរដ៏សមគួរ ដល់សេចក្តីរម្ងាប់នូវចំណែកនៃបបញ្ចសញ្ញា ។ ព្រះមានព្រះភាគ ទ្រង់ព្យាករនូវប្រស្នាដែលសក្កទេវរាជ ជាធំជាងពួកទេវតា ទូលសួរហើយ ដោយប្រការដូច្នេះ ។ សក្កទេវរាជ ជាធំជាងពួកទេវតា ក៏ពេញព្រះរាជហឫទ័យ ត្រេកអរវីរកាយនូវភាសិតរបស់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ដំណើរនោះ យ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនោះ យ៉ាងហ្នឹងហើយ សេចក្តីសង្ស័យក្នុងប្រស្នានោះ ខ្ញុំព្រះអង្គបានឆ្លងផុតហើយ សេចក្តីងឿងឆ្ងល់ក៏អស់ហើយ ព្រោះបានស្តាប់នូវបញ្ហាព្យាករណ៍របស់ព្រះមានព្រះភាគ ។

[๙๖] *លុះសក្កទេវរាជ ជាធំជាងពួកទេវតា ត្រេកអរវីរកាយ នឹងភាសិតរបស់ព្រះមានព្រះភាគដូច្នេះហើយ ទើបក្រាបទូលសួរនូវប្រស្នាតទៅទៀត ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះភិក្ខុប្រតិបត្តិដូចម្តេច ឈ្មោះថា អ្នកប្រតិបត្តិដើម្បីសង្រ្គមក្នុងជាតិមោក្ខ ។ បពិត្រទេវានមិន្ទ តថាគតសម្តែងថា កាយសមាចារ (មារយោទផ្លូវកាយ) មាន ២ យ៉ាង គឺ កាយសមាចារគួរសេពក៏មាន មិនគួរសេពក៏មាន បពិត្រទេវានមិន្ទ តថាគត*

សម្តែងថា វចីសមាចារ (មាវយោទផ្លូវវាចា) មាន ២ យ៉ាង គឺវចីសមាចារ ដែលគួរសេពក៏មាន មិនគួរសេពក៏មាន បពិត្រទេវានមិនូ តថាគតសម្តែងថា បរិយេសនា (ការស្វែងរក) មាន ២ យ៉ាង គឺបរិយេសនាគួរសេពក៏មាន មិនគួរសេពក៏មាន ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិនូ តថាគតសម្តែងថា កាយសមាចារមាន ២ យ៉ាង គឺកាយសមាចារគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមកយ៉ាងនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាកាយសមាចារទាំង ២ ប្រការនោះ ភិក្ខុដឹងច្បាស់នូវកាយសមាចារណាថា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ដូច្នេះ កាយសមាចារបែបនេះ ភិក្ខុមិនគួរសេព ។ បណ្តាកាយសមាចារទាំង ២ ប្រការនោះ ភិក្ខុដឹងច្បាស់នូវកាយសមាចារណាថា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនដុះដាលឡើងដូច្នេះ កាយសមាចារបែបនេះ ភិក្ខុគួរសេព ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិនូ តថាគតសម្តែងថា កាយសមាចារ មាន ២ យ៉ាង គឺកាយសមាចារគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិនូ តថាគតសម្តែងថា វចីសមាចារ មាន ២ យ៉ាង គឺវចីសមាចារដែលគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះនេះ តថាគត

បានពោលហើយ ពាក្យដែលតថាគតពោលមកយ៉ាងនុ៎ះ តើព្រោះអាស្រ័យ
ហេតុអ្វី ។ ព្រោះថា បណ្តាវចីសមាចារទាំង ២ ប្រការនោះ កិក្ខុដឹងច្បាស់នូវ
វចីសមាចារណាថា កាលបើអាត្មាអញសេពនូវវចីសមាចារនេះ អកុសលធម៌
ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ
ទៅដូច្នេះ វចីសមាចារបែបនេះ កិក្ខុមិនគួរសេព ។ បណ្តាវចីសមាចារទាំង
២ ប្រការនោះ កិក្ខុដឹងច្បាស់នូវវចីសមាចារណាថា កាលបើអាត្មាអញសេព
នូវវចីសមាចារនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌
ទាំងឡាយ តែងចម្រើនដុះដាលឡើងដូច្នេះ វចីសមាចារបែបនេះ កិក្ខុគួរ
សេព ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា វចីសមាចារ
មាន ២ យ៉ាង គឺវចីសមាចារគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះនេះ
តថាគតពោលហើយ ពាក្យនោះដែលតថាគតពោលហើយ ព្រោះអាស្រ័យ
ហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា
បរិយេសនាមាន ២ យ៉ាង គឺបរិយេសនាគួរសេពក៏មាន មិនគួរសេពក៏មាន
ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមកយ៉ាងនុ៎ះ
តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាបរិយេសនាទាំង ២ ប្រការ
នោះ កិក្ខុដឹងច្បាស់នូវបរិយេសនាណាថា កាលបើអាត្មាអញសេពនូវបរិ-
យេសនានេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌
ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ បរិយេសនាបែបនេះ កិក្ខុមិនគួរសេព ។
បណ្តាបរិយេសនាទាំង ២ ប្រការនោះ កិក្ខុដឹងច្បាស់នូវបរិយេសនាណាថា

កាលបើអាត្មាអញសេពនូវបរិយេសនានេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនជុះជាលឡើង ដូច្នេះ បរិ-យេសនាបែបនេះ ភិក្ខុគួរសេព ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិនូ តថាគតសម្តែងថា បរិយេសនាមាន ២ យ៉ាង គឺបរិយេសនាគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ បពិត្រទេវានមិនូ ភិក្ខុអ្នកប្រតិបត្តិយ៉ាងនេះ ទើបឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីសេចក្តីសង្រួមក្នុងបាតិមោក្ខ ។

[៩៧] បពិត្រព្រះអង្គទ្រង់និទ៌ុក្ខ ចុះភិក្ខុប្រតិបត្តិដូចម្តេច ទើបឈ្មោះថា ជាអ្នកប្រតិបត្តិ ដើម្បីសេចក្តីសង្រួមក្នុងឥន្ទ្រិយ ។ បពិត្រទេវានមិនូ តថាគតសម្តែងថា រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកមាន ២ យ៉ាង គឺ រូបារម្មណ៍ដែលគួរសេពក៏មាន មិនគួរសេពក៏មាន ។ បពិត្រទេវានមិនូ តថា-គតសម្តែងថា សទ្ទារម្មណ៍ដែលគួរដឹងច្បាស់ដោយត្រចៀកមាន ២ យ៉ាង គឺ សទ្ទារម្មណ៍ដែលគួរសេពក៏មាន មិនគួរសេពក៏មាន ។ បពិត្រទេវានមិនូ តថាគតសម្តែងថា គន្ធារម្មណ៍ដែលគួរដឹងច្បាស់ដោយច្រមុះមាន ២ យ៉ាង គឺ គន្ធារម្មណ៍ដែលគួរសេពក៏មាន មិនគួរសេពក៏មាន ។ បពិទ្រទេវានមិនូ តថាគតសម្តែថា រសារម្មណ៍ដែលគួរដឹងច្បាស់ដោយអណ្តាត ។បេ។ បពិត្រទេវានមិនូ តថាគតសម្តែងថា ផោដ្ឋព្វារម្មណ៍ដែលគួរដឹងច្បាស់ដោយកាយ ។បេ។ បពិត្រទេវានមិនូ តថាគតសម្តែងថា ធម្មារម្មណ៍ ដែលគួរដឹងច្បាស់

ដោយចិត្តមាន ๒ យ៉ាង គឺធម្មារម្មណ៍ដែលគួរសេពក៏មាន មិនគួរសេពក៏មាន ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សក្កទេវរាជ ជាធំជាងពួកទេវតា បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គអាចដឹងសេចក្តីច្បាស់ដោយពិស្តារយ៉ាងនេះបាន បពិត្រព្រះអង្គដ៏ចម្រើន កាលបើភិក្ខុសេពនូវរូបារម្មណ៍ ដែលគួរដឹងច្បាស់ដោយភ្នែកបែបណា អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកបែបនេះ ភិក្ខុមិនគួរសេពទេ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាលបើភិក្ខុសេពនូវរូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកបែបណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកបែបនេះ ភិក្ខុគួរសេព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាលបើភិក្ខុសេពនូវសទ្ទារម្មណ៍ ដែលគួរដឹងច្បាស់ដោយត្រចៀកបែបណា ។បេ។ កាលបើភិក្ខុសេពនូវគន្ធារម្មណ៍ ដែលគួរដឹងច្បាស់ដោយច្រមុះ ។បេ។ កាលបើភិក្ខុសេពនូវរសារម្មណ៍ ដែលគួរដឹងច្បាស់ដោយអណ្តាត ។បេ។ កាលបើភិក្ខុសេពនូវផោដ្ឋព្វារម្មណ៍ ដែលគួរដឹងច្បាស់ដោយកាយ ។បេ។ កាលបើភិក្ខុសេពនូវធម្មារម្មណ៍ដែលគួរដឹងច្បាស់ដោយចិត្ត អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ធម្មារម្មណ៍ដែលគួរដឹងច្បាស់ដោយចិត្តបែបនេះ ភិក្ខុមិនគួរសេពទេ ។ បពិត្រព្រះ

អគ្គដ៏ចម្រើន មួយវិញទៀត កាលបើភិក្ខុសេពនូវធម្មារម្មណ៍ ដែលគួរដឹងច្បាស់ដោយចិត្តបែបណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង ធម្មារម្មណ៍ដែលគួរដឹងច្បាស់ដោយចិត្តបែបនេះ ភិក្ខុគួរសេព ។ បពិត្រព្រះអគ្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គអាចដឹងសេចក្តីច្បាស់ដោយពិស្តារយ៉ាងនេះបាន សេចក្តីសង្ស័យក្នុងប្រស្នានុ៎ះ ខ្ញុំព្រះអង្គបានឆ្លងផុតហើយ សេចក្តីងឿងឆ្ងល់ក៏អស់ហើយ ព្រោះបានស្តាប់នូវបញ្ហាវេយ្យាករណ៍របស់ព្រះមានព្រះភាគ ។

[๙๘] *លុះសក្កទេវរាជ ជាធំជាងពួកទេវតា ត្រេកអរវីរភាយ នឹងភាសិតរបស់ព្រះមានព្រះភាគយ៉ាងនេះហើយ ក៏ក្រាបបង្គំទូលសួរនូវប្រស្នាតទៅចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះពួកសមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែជាអ្នកមានវាទៈដូចគ្នា មានមារយាទដូចគ្នា មានឆន្ទៈ គឺលទ្ធិដូចគ្នា មានសេចក្តីចូលចិត្តដូចគ្នាឬ ។ បពិត្រទេវានមិន្ទ ពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនមានវាទៈដូចគ្នាទេ មិនមែនមានមារយាទដូចគ្នា មិនមែនមានឆន្ទៈ គឺលទ្ធិដូចគ្នាទេ មិនមែនមានសេចក្តីចូលចិត្តដូចគ្នាទេ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះហេតុអ្វី បានជាពួកសមណព្រាហ្មណ៍ទាំងអស់មានវាទៈមិនដូចគ្នា មានមារយាទមិនដូចគ្នា មានឆន្ទៈ គឺលទ្ធិមិនដូចគ្នា មានសេចក្តីចូលចិត្តមិនដូចគ្នា ។ បពិត្រទេវានមិន្ទ លោក គឺពពួកសត្វមានធាតុ គឺអធ្យាស្រ័យច្រើនពន់ពេក មានធាតុផ្សេងៗ គ្នាក្នុងលោក ដែលមានធាតុ*

ច្រើន មានជាតុផ្សេងគ្នានោះ សត្វទាំងឡាយ ប្រកាន់មាំនូវជាតុ គឺអជ្ឈា-ស្រ័យណាៗ ក៏ប្រកាន់មាំនូវជាតុ គឺអជ្ឈាស្រ័យនោះៗ ដោយកម្លាំងចិត្ត និងការសាបអង្អែល តែងពោលនូវពាក្យនេះថាជាពាក្យពិត ពាក្យជនៃជាមោយៈ ឥតប្រយោជន៍ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ទាំងអស់មានវាទៈមិនដូចគ្នា មានមារយោទមិនដូចគ្នា មានឆន្ទៈ គឺលទ្ធិមិនដូចគ្នា មានសេចក្តីចូលចិត្តមិនដូចគ្នា ។បេ។

[๙๙] *បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះពួកសមណព្រាហ្មណ៍ទាំងអស់សុទ្ធតែមានសេចក្តីសម្រេច គឺព្រះនិព្វានទៀងប្រាកដ មានធម៌ជាគ្រឿងអស់ទៅនៃយោគៈពិតប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀងប្រាកដ ជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដឬ ។ បពិត្រទេវានមិនូ សមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែមានសេចក្តីសម្រេច គឺព្រះនិព្វានទៀងប្រាកដទេ មិនមែនមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដទេ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀងប្រាកដទេ មិនមែនជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដទេ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀងប្រាកដ មិនមែនជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀងប្រាកដ មិនមែនជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដទាំងអស់គ្នា តើព្រោះហេតុអ្វី ។ បពិត្រទេវានមិនូ ភិក្ខុទាំងឡាយណា ដែលមានចិត្តចុះស៊ប់ក្នុងព្រះនិព្វាន ជា*

ទីអស់ទៅនៃតណ្ហាហើយ ភិក្ខុទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀងប្រាកដ ជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀងប្រាកដ ជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដ ព្រោះហេតុនោះឯង បានជាថា ពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀងប្រាកដ មិនមែនជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរទៀងប្រាកដ មិនមែនជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដទាំងអស់គ្នាឡើយ ។ ព្រះមានព្រះភាគទ្រង់ព្យាករនូវប្រស្នា ដែលសក្កទេវរាជ ជាធំជាងពួកទេវតាទូលសួរហើយដោយប្រការដូច្នេះ ។ សក្កទេវរាជ ជាធំជាងពួកទេវតា ក៏ពេញព្រះហឫទ័យត្រេកអរវីរភាយនឹងភាសិតរបស់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគដំណើរនុ៎ះ យ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនោះ យ៉ាងហ្នឹងហើយ សេចក្តីសង្ស័យក្នុងប្រស្នានោះ ខ្ញុំព្រះអង្គបានឆ្លងផុតហើយ សេចក្តីងឿងឆ្ងល់ក៏អស់ហើយ ព្រោះបានស្តាប់នូវបញ្ហាព្យាករណ៍របស់ព្រះមានព្រះភាគ ។

[๑๐๐] សក្កទេវរាជ ជាធំជាងពួកទេវតា លុះត្រេកអរវីរភាយនឹងភាសិតរបស់ព្រះមានព្រះភាគដូច្នេះហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីញាប់ញ័រ គឺតណ្ហា ទុកដូចជារោគ សេចក្តីញាប់ញ័រ គឺតណ្ហា ទុកដូចជាបូស សេចក្តីញាប់ញ័រ គឺតណ្ហា ទុកដូចជាកូនសរ សេចក្តីញាប់ញ័រ គឺតណ្ហា តែងជីកទាញនូវបុរសនេះ ឲ្យកើត

ក្នុងភពនោះៗ ព្រោះហេតុនោះឯង បុរសនេះរមែងដល់នូវសភាពខ្ជិលច្រអូសទាប ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបាននូវឱកាសកម្មនៃប្រស្នាណា អំពីសមណព្រាហ្មណ៍ដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះ ប្រស្នានោះ ព្រះមានព្រះភាគ ជាអ្នកឃើញនូវកាលដ៏វែង បានព្យាករដល់ខ្ញុំព្រះអង្គហើយ មួយទៀត ព្រះមានព្រះភាគបានទាំងជកនូវសរ គឺសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ អំពីខ្ញុំព្រះអង្គចេញបានហើយ ។ បពិត្រទេវានមិនូ មហាបពិត្រធ្លាប់យកប្រស្នានេះទៅសួរចំពោះពួកសមណព្រាហ្មណ៍ដទៃដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់នាំយកប្រស្នានេះ ទៅសួរចំពោះសមណ-ព្រាហ្មណ៍ដទៃដែរ បពិត្រទេវានមិនូ ចុះសមណព្រាហ្មណ៍ទាំងនោះ បានព្យាករថ្វាយមហាបពិត្រដូចម្តេចខ្លះ បើមហាបពិត្រ មិនទើសទាល់ព្រះទ័យទេ សូមមហាបពិត្រមានព្រះបន្ទូលទៅមើល ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគក្តី បុគ្គលដែលមានរូបប្រហែលព្រះមានព្រះភាគក្តី អង្គុយក្នុងទីណា ទីនោះ មិនទើសទាល់ចិត្តនៃខ្ញុំព្រះអង្គឡើយ ។ បពិត្រទេវានមិនូ បើដូច្នោះ សូមមហាបពិត្រ មានព្រះបន្ទូលទៅមើល ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសម្គាល់ក្នុងពួកសមណព្រាហ្មណ៍ណាថា សមណព្រាហ្មណ៍ទាំង-ទ្បាយ ជាអ្នកនៅក្នុងអរញ្ញប្រទេស មានសេនាសនៈដ៏ស្ងាត់ដូច្នេះ ខ្ញុំព្រះអង្គក៏ចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរនូវប្រស្នាទាំងនេះ ពួកសមណព្រាហ្មណ៍នោះ លុះខ្ញុំព្រះអង្គសួរហើយ ក៏មិនអាចនឹងដោះស្រាយបាន កាលមិនអាចនឹងដោះស្រាយហើយ ក៏ត្រឡប់សួរមកខ្ញុំព្រះអង្គវិញថា

អ្នកមានអាយុឈ្មោះអ្វី លុះពួកសមណព្រាហ្មណ៍នោះ សួរខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គបានប្រាប់ថា បពិត្រអ្នកនិទ្ទុក្ខ ខ្ញុំឯងជាសក្កទេវរាជ ជាធំជាងពួកទេវតា ពួកសមណព្រាហ្មណ៍នោះ ក៏ត្រឡប់សួរមកខ្ញុំព្រះអង្គតទៅទៀតថា បពិត្រទេវានមិនូមានអាយុ ចុះព្រះអង្គសាងនូវអំពើដូចម្តេច បានជាដល់នូវឋានៈនេះដូច្នេះ ខ្ញុំព្រះអង្គក៏សម្តែងធម៌ប្រាប់ដល់ពួកសមណព្រាហ្មណ៍នោះ តាមដែលបានស្តាប់មក បានរៀនមក ពួកសមណព្រាហ្មណ៍នោះ ក៏មានសេចក្តីត្រេកអរ ដោយធម៌មានប្រមាណប៉ុណ្ណោះថា សក្កទេវរាជ ជាធំជាងពួកទេវតា គឺយើងទាំងឡាយបានឃើញហើយផង យើងទាំងឡាយបានសួរនូវប្រស្នាណា លោកក៏បានដោះស្រាយនូវប្រស្នានោះ ដល់យើងទាំងឡាយផង ពួកសមណព្រាហ្មណ៍នោះ ក៏ត្រឡប់ទៅជាសាវ័ករបស់ខ្ញុំព្រះអង្គវិញ ឯខ្ញុំព្រះអង្គមិនមែនជាសាវ័ករបស់ពួកសមណព្រាហ្មណ៍នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គជាសាវ័ករបស់ព្រះមានព្រះភាគ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានប្រាជ្ញាជាគ្រឿងត្រាស់ដឹងប្រពៃត្តទៅក្នុងខាងមុខ ។ បពិត្រទេវានមិនូ ក្នុងកាលពីមុនអំពីកាលនេះ មហាបពិត្រធ្លាប់ទទួលការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សបែបនេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុនអំពីកាលនេះ ខ្ញុំព្រះអង្គធ្លាប់ទទួលការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សបែបនេះដែរ ។ បពិត្រទេវានមិនូ ចុះក្នុងកាលមុនអំពីកាលនេះ មហាបពិត្រធ្លាប់ទទួលការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សបែបនេះ តើដូច

ម្តេច ។

[๑๐๑] *បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ សង្គ្រាមនៃពួកទេវតា និងអសុរបានតទល់គ្នាហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងសង្គ្រាមនោះ ពួកទេវតាឈ្នះ ឯពួកអសុរចាញ់ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គឈ្នះសង្គ្រាមនោះហើយ បានឈ្មោះថា មានសង្គ្រាមឈ្នះស្រេចហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកទេវតាទាំង-ទ្វាយ នឹងបរិភោគនូវឱជារសទាំងពីរ គឺឱជារសរបស់ទេវតា និងឱជារសរបស់អសុរ ក្នុងទេវលោកនេះ បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវសេចក្តីត្រេកអរ និងការបាននូវសេចក្តីសោមនស្សរបស់ខ្ញុំព្រះអង្គនោះ សឹងប្រកបដោយគ្រឿងវាយដំ ប្រកបដោយគ្រឿងកាប់ចាក់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីការប្រាសចាកវាគៈ ដើម្បីការរម្ងាប់ទុក្ខ ដើម្បីការស្ងប់រម្ងាប់ ដើម្បីការដឹងចំពោះ ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សណារបស់ខ្ញុំព្រះអង្គ ព្រោះស្តាប់ធម៌របស់ព្រះមានព្រះភាគ ការបាននោះ មិនប្រកបដោយគ្រឿងវាយដំ មិនប្រកបដោយគ្រឿងកាប់ចាក់ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដើម្បីការប្រាសចាកវាគៈ ដើម្បីការរម្ងាប់ទុក្ខ ដើម្បីការស្ងប់រម្ងាប់ ដើម្បីការដឹងចំពោះ ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វានតែមួយយ៉ាង ។ បពិត្រទេវានមិន្ទ ចុះមហាបពិត្រ ទ្រង់ឃើញនូវអំណាចនៃប្រយោជន៍ដូចម្តេច ទើបសម្តែងនូវការបាននូវសេចក្តីត្រេកអរ*

និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយើញនូវអំណាចនៃប្រយោជន៍ ៦ យ៉ាង ទើបសម្តែងនូវការបាន នូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

[១០២] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយើញនូវអំណាចនៃ ប្រយោជន៍ជាដំបូងនេះថា

> កាលអាត្មាអញកើតជាទេវតា ឋិតនៅក្នុងឧកាសនេះ
> អាត្មាអញ បានអាយុថ្មីទៀត ម្នាលគ្នាយើង អ្នកចូរដឹង
> យ៉ាងនេះចុះ ដូច្នេះហើយ ទើបសម្តែងនូវការបាននូវសេចក្តី
> ត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

[១០៣] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយើញនូវអំណាចនៃ ប្រយោជន៍ ជាគម្រប់ ២ នេះថា

> ចិត្តរបស់ខ្ញុំព្រះអង្គ ត្រេកអរក្នុងត្រកូលណា ខ្ញុំព្រះអង្គ
> ច្យុតចាកកាយជារបស់ទេវតា លះបង់នូវអាយុ មិនមែនជា
> របស់មនុស្ស ហើយជាអ្នកមិនវង្វេង ចូលទៅកាន់គភ៌ក្នុង
> ត្រកូលនោះ ដូច្នេះហើយ ទើបសម្តែងនូវការបាននូវសេចក្តី
> ត្រេកអរ និងការបាននូវសោមនស្សមានសភាពយ៉ាងនេះ ។

[១០៤] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយើញនូវអំណាចនៃ ប្រយោជន៍ ជាគម្រប់ ៣ នេះថា

> ខ្ញុំព្រះអង្គជាអ្នកត្រេកអរក្នុងសាសនា របស់ព្រះពុទ្ធជាម្ចាស់

ដែលទ្រង់មានប្រស្នាមិនកាន់ច្រឡំ ហើយជាអ្នកមាន សេចក្តីជឿខ្លួន មានស្មារតីតម្កល់ខ្ជាប់ នៅដោយសេចក្តីជឿខុសត្រូវ ដូច្នេះហើយ ទើបសម្តែងនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

[๑๐๕] *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ ๔ នេះថា*

បើសម្ពោធិញ្ញាណ នឹងមានដល់ខ្ញុំព្រះអង្គ ក្នុងខាងមុខ ដោយសេចក្តីជឿខុសត្រូវ ខ្ញុំព្រះអង្គជាអ្នកប្រាថ្នាដើម្បីជឿខុសត្រូវ សេចក្តីជឿខុសត្រូវនោះឯង ជាការសំខាន់របស់ខ្ញុំព្រះអង្គ (ក្នុងមនុស្សលោក) ដូច្នេះហើយ ទើបសម្តែងនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

[๑๐๖] *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ ๕ នេះថា*

ខ្ញុំព្រះអង្គ មុខជានឹងច្យុតចាកកាយ ជារបស់នៃមនុស្ស លះបង់នូវអាយុ ជារបស់នៃមនុស្ស ហើយបានទៅកើតជាទេវតាដ៏ឧត្តម ក្នុងទេវលោកវិញ ដូច្នេះហើយ ទើបសម្តែងនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោម-

នស្ស មានសភាពយ៉ាងនេះ ។

[๑๐๗] *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ ๖ នេះថា*

ពួកទេវតានោះ ឧត្តមជាងទេវតាទាំងពួង ជាអ្នកមិនថោកថយ ជាអ្នកមានយស ឋិតនៅក្នុងលំនៅណា លំនៅនោះមុខជានឹងមានដល់ខ្ញុំព្រះអង្គក្នុងភពជាទីបំផុតមិនខាន ដូច្នេះហើយ សម្តែងនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សមានសភាពយ៉ាងនេះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញនូវអំណាចនៃប្រយោជន៍ទាំង ๖ ប្រការហ្នឹងឯង ទើបសម្តែងនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សមានសភាពយ៉ាងនេះ ។

[๑๐๘] *ខ្ញុំព្រះអង្គមានសេចក្តីជ្រាបថ្នា មិនទាន់សម្រេចនៅមានសេចក្តីសង្ស័យងឿងឆ្ងល់ តែងត្រាច់ស្វះស្វែងរកព្រះតថាគតអស់កាលជាយូរអង្វែងមកហើយ ។ ខ្ញុំព្រះអង្គសម្គាល់នូវពួកសមណៈណា ដែលជាអ្នកនៅក្នុងទីស្ងាត់ ក៏ទីកស្មានថាជាព្រះពុទ្ធ ដូច្នេះហើយ ចូលទៅអង្គុយជិតពួកសមណៈនោះ ។ ពួកសមណៈនោះ លុះខ្ញុំព្រះអង្គសួរថា សេចក្តីជ្រះថ្លា តើដូចម្តេច សេចក្តីមិនជ្រះថ្លាតើដូចម្តេច ដូច្នេះហើយ មិនអាចនឹងដោះស្រាយក្នុងមគ្គ និង*

បដិបទាទាំងឡាយបានឡើយ ។ កាលណា ដែលពួក
សមណៈទាំងនោះ ស្គាល់ខ្ញុំព្រះអង្គថាជាសក្កទេវរាជ មក
ពីឋានទេវតា ពួកសមណៈទាំងនោះ បានសួរខ្ញុំព្រះអង្គថា
ទេវរាជបានសាងកុសលដូចម្តេច ទើបបានន្ទូវសម្បត្តិនេះ ។
ខ្ញុំព្រះអង្គក៏សម្តែងធម៌តាមដែលបានស្តាប់មក ប្រាប់ដល់
សមណៈទាំងនោះ ឲ្យប្រាកដក្នុងទីប្រជុំជន ពួកសមណៈ
ទាំងនោះ នាំគ្នាពេញចិត្ត ដោយហេតុនោះថា យើងទាំង-
ឡាយបានឃើញវាសវទេវរាជហើយ ។ មួយវិញទៀត
កាលណា ដែលខ្ញុំព្រះអង្គ បានឃើញនូវព្រះសម្ពុទ្ធ ទ្រង់
ឆ្ងងផុតចាកសេចក្តីសង្ស័យហើយក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជា
អ្នករួចចាកភ័យហើយ បានចូលមកអង្គុយជិតព្រះសម្ពុទ្ធ ។
ខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ ទ្រង់ដកចោលនូវសរ
គឺតណ្ហាចេញបានហើយ រកបុគ្គលប្រៀបផ្ទឹមគ្មាន ទ្រង់
មានព្យាយាមច្រើន ទ្រង់ត្រាស់ដឹង (នូវចតុរារិយសច្ច)
ព្រះអង្គជាពូជពង្សនៃអាទិច្ចគោត្រ ។ បពិត្រព្រះអង្គ ទ្រង់
និទ្ទិក្ខ (ក្នុងកាលមុន) ខ្ញុំព្រះអង្គ ព្រមទាំងទេវតា បាន
ធ្វើនូវការនមស្ការណា ចំពោះព្រហ្ម ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គ
សូមថ្វាយនមស្ការនោះចំពោះព្រះអង្គវិញ ខ្ញុំព្រះអង្គសូម
ធ្វើនូវការថ្វាយបង្គំចំពោះព្រះអង្គដោយខ្លួនឯង ។ ព្រះអង្គ

ជាព្រះសម្ពុទ្ធពិតមែន ព្រះអង្គជាសាស្តាប្រសើរ ក្នុងលោក នេះ ព្រមទាំងទេវលោក នឹងរកបុគ្គលណាមួយមកប្រៀប ផ្ទឹមនឹងព្រះអង្គគ្មានឡើយ ។

[๑๐๙] *លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ត្រាស់ហៅនូវបញ្ចសិខគន្ធព្វបុត្តថា នែអ្នកបញ្ចសិខៈ អ្នកជាបុគ្គលមានឧបការៈច្រើនដល់យើងពិត ដោយហេតុអ្នកបានធ្វើព្រះមានព្រះភាគ ឲ្យប្រោសប្រាណជាមុន ម្នាលអ្នក លុះអ្នកបានធ្វើព្រះមានព្រះភាគឲ្យប្រោសប្រាណជាមុនហើយ ទើបយើងបានចូលមកគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ក្នុងកាលជាខាងក្រោយ យើងនឹងតាំងអ្នកទុកក្នុងទីដូចជាបិតា អ្នកនឹងបានជាស្តេចនៃពួកគន្ធព្វ មួយវិញទៀត យើងនឹងឲ្យនាងកទ្ទាសុរិយវច្ឆសាដល់អ្នក ព្រោះថា នាងកទ្ទាសុរិយវច្ឆសានោះ អ្នកក៏ចង់បានមកជាយូរហើយ ។ គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់យកព្រះហស្តទះផែនដី ហើយបន្លឺនូវឧទានអស់វារៈ ๓ ដងថា*

សូមនមស្ការ ថ្វាយបង្គំចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ សូមនមស្ការ ថ្វាយបង្គំចំពោះព្រះមានព្រះភាគ ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ សូមនមស្ការ ថ្វាយបង្គំចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

[๑๑๐] *ក៏កាលដែលព្រះមានព្រះភាគ កំពុងសម្តែងនូវវេយ្យាករណ៍នេះ ធម្មចក្ខុ (សោតាបត្តិមគ្គ) ដ៏ប្រាសចាកធូលី គឺរាគាទិក្កិលេសប្រាសចាកមន្ទិល គឺទិដ្ឋិ និងវិចិកិច្ឆា ក៏បានកើតដល់សក្កទេវរាជ ជាធំជាង*

ពួកទេវតាផង ដល់ពួកទេវតាទាំង ๘ ហ្នឹងឯទៀតផងថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ។ ប្រស្នាណា ដែលសក្កទេវរាជ ជាធំជាងពួកទេវតា បានអារាធនា បានទូលសួរហើយ ប្រស្នានោះ ព្រះមានព្រះភាគទ្រង់បានព្យាករណ៍ហើយ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ពាក្យថា សក្កប្បញ្ហដូច្នេះ ជាឈ្មោះនៃវេយ្យាករណ៍នេះឯង ។

សក្កប្បញ្ហសូត្រទី ๘ ចប់

អដ្ឋកថា

សក្កបញ្ហសូត្រ

[៨៥] សក្កបញ្ហសូត្រមានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ តទៅនេះ ជាអធិប្បាយសេចក្ដីចំពោះបទដែលមិនជាក់ច្បាស់ ក្នុងសក្កបញ្ហសូត្រនោះ ។ បទថា **អម្ពសណ្ឌា នាម ព្រាហ្មណគ្គាមោ** គឺបានឮមកថា ស្រុកនោះ នៅមិនឆ្ងាយពីព្រៃស្វាយ ដូច្នោះ ទើបហៅថា **អម្ពសណ្ឌ** ។ បទថា **វេទិយកេ បព្វតេ** បានឮថា ភ្នំនោះមានព្រៃពណ៌ខៀវ ដូចវេទិកាកែវមណី ដែលកើតត្រង់ជុំវិញជើងភ្នំ ដូច្នោះ ទើបហៅថា **ភ្នំវេទិយក** ។ បទថា **ឥន្ទសាលគុហាយំ** គឺពីមុនមក គុហានោះ នៅចន្លោះកូនភ្នំពីរ និងក្បែរទ្វារគុហានោះ មានដើមពោនស្វា ដូច្នោះ ទើបហៅថា គុហាពោនស្វា តមកពួកមនុស្សក៏រាំងជញ្ជាំងគុហានោះ បិទទ្វារមុខ ធ្វើទីពួនសម្ងំ ដែលវិចិត្រដោយភ្ជីផ្កា ភ្ជីវល្លិ បូកបាយអ រួចស្រេចរៀបរយហើយ ក៏ថ្វាយចំពោះព្រះមានព្រះភាគ ។ តែមនុស្សទាំងឡាយ ក៏នៅស្គាល់គុហានោះថា គុហាពោនស្វា តាមឈ្មោះដើមនោះឯង ។ ព្រះអានន្ទសំដៅយកគុហានោះ ទើបពោលថា **ឥន្ទសាលគុហាយំ** ។

បទថា **ឧស្សុក្កំ ឧទបាទិ** គឺកើតសេចក្ដីឧស្សាហៈដែលប្រកបដោយធម៌ ។ សួរថា សក្កទេវរាជនោះ ទ្រង់គាល់ព្រះមានព្រះភាគមករឿយៗ មិនមែនឬ មានទេវតាប្រជុំគ្នានៅទីណានោះ ក៏មិនមែនថា សក្កទេវរាជនេះ មិនធ្លាប់យាងមក ដែលឈ្មោះថា ទេវបុត្តដូចសក្កទេវរាជនៅដោយប្រមាទ មិនមាន

កាលបើដូច្នោះ ហេតុអ្វី ទើបសក្កទេវរាជនោះ ទ្រង់កើតសេចក្តីឧស្សាហ៍ ដូច បុគ្គលមិនធ្លាប់មកគាល់ព្រះពុទ្ធ ឆ្ងើយថា ព្រោះត្រូវសេចក្តីខ្លាចស្ទាប់គំរាម ។ បានឮថា សម័យនោះ ព្រះជន្មាយុរបស់សក្កទេវរាជអស់ហើយ ។ សក្កទេវរាជ ទ្រង់បានឃើញបុព្វនិមិត្ត ៥ ប្រការ ទ្រង់ជ្រាបថា ឥឡូវនេះ អញអស់អាយុ ហើយ គ្រឿងសម្គាល់សេចក្តីស្ទាប់ ច្រាកដដល់ទេវបុត្តពួកណា ក្នុងទេវបុត្ត ទាំងនោះ ពួកណាកើតក្នុងទេវលោកដោយបុញ្ញកម្មបន្តិចបន្តួច ពួកនោះ ក៏ រមែងដល់ការភ័យតក់ស្លុត ព្រោះសេចក្តីខ្លាចថា ពេលនេះអញនឹងកើតទីណា ហ្ន៎ ទេវតាណាបានត្រៀមការពារភ័យ ដែលគួរខ្លាចដ៏ពន្លឹក ធ្វើបុណ្យទុកច្រើន បានកើតហើយ ពួកនោះគិតថា អញអាស្រ័យទានដែលខ្លួនបានឲ្យ សីលដែល រក្សាមក និងភាវនាដែលបានអប់រំហើយ នឹងសោយសម្បត្តិក្នុងទេវលោក ជាន់ខ្ពស់ រមែងមិនខ្លាច ។ ចំណែកសក្កទេវរាជ កាលទ្រង់បានឃើញបុព្វ-និមិត្ត ទ្រង់សម្លឹងមើលសម្បត្តិទាំងអស់យ៉ាងនេះថា ទេវនគរ ១ ម៉ឺនយោជន៍ វេជយ័ន្តប្រាសាទ កម្ពស់ ១០០០ យោជន៍ សុធម្មាទេវសភា ៣០០ យោជន៍ ដើមមហាបារិច្ឆត្តកៈ កម្ពស់ ១០០ យោជន៍ ថ្នបណ្តុកម្ពស់ ៦០ យោជន៍ ទេពអប្សរ ២ កោដិកន្លះ ទេវបរិស័ទក្នុងទេវលោកទាំងពីរ នន្ទនឧទ្យាន ចិត្ត-លតាឧទ្យាន មិស្សកឧទ្យាន បារុសកឧទ្យាន ទ្រង់ត្រូវសេចក្តីភ័យខ្លាចគ្រប សង្កត់ថា នែលោក សម្បត្តិរបស់យើងនេះ នឹងវិនាសហ្ន៎ តទៅក៏ទ្រង់ សម្លឹងមើលថា មាននរណាខ្លះហ្ន៎ មិនថាជាសមណៈ ជាព្រាហ្មណ៍ ឬមហា-ព្រហ្មដែលជាព្រះបិតារបស់លោក ដែលគប្បីដកនូវសរ គឺសេចក្តីសោកដែល

អាស្រ័យហាទយៈយើង ហើយធ្វើឲ្យសម្បត្តិនេះតាំងមាំបាន កាលទ្រង់សម្លឹងមើលបុគ្គលណាមួយក៏មិនឃើញ ទ្រង់ឃើញថា មានតែព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ដែលទ្រង់អាចដកសេចក្តីសោក ដែលកើតដល់ទេវតាទាំងឡាយដូចយើងសូម្បីទាំងសែនបាន ។ តមក ដោយសម័យនោះឯង សេចក្តីខ្វល់ខ្វាយ ដើម្បីនឹងគាល់ព្រះមានព្រះភាគ ក៏បានកើតឡើងដល់សក្កទេវរាជដែលជាធំលើទេវតា ដែលទ្រង់ត្រិះរិះយ៉ាងនេះ ។

បទថា **កហំ នុ ខោ ភគវា ឯតរហិ វិហរតិ** *គឺសក្កទេវរាជ ទ្រង់គិតថា ព្រះមានព្រះភាគប្រថាប់នៅត្រង់ជនបទណា ទ្រង់ចូលទៅអាស្រ័យនគរណា កំពុងសោយបច្ច័យរបស់អ្នកណា ទ្រង់កំពុងសម្តែងអមតធម៌ដល់អ្នកណា ។ បទថា* **អទฺทสาខោ** *សេចក្តីថា ទ្រង់បានឃើញ គឺទ្រង់ចាក់ជ្រុះហើយ ។ បទថា* **មาริสา** *នេះ ជាពាក្យដែលគួរស្រឡាញ់ ជាសំនួនពាក្យរបស់ពួកទេវតាដោយចំពោះ អធិប្បាយថា អ្នកនិទុ៌ក្ខក៏បាន ។ ហេតុដូចម្តេច ទើបសក្កទេវរាជនេះ ទ្រង់ហៅពួកទេវតា ដើម្បីជាសម្ងាញ់ ។ ក្នុងកាលមុន បានឮមកថា សក្កទេវរាជនេះ កាលព្រះមានព្រះភាគ កំពុងប្រថាប់នៅក្នុងកុដិជិតដើមស្រល់ បានយាងទៅគាល់ដោយទំនើងខ្លួនឯងម្តងហើយ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ញាណរបស់សក្កទេវរាជនេះ មិនទាន់ចាស់ក្លា តែបើវាំងចាំបន្តិចទៀត ខណៈដែលតថាគតនៅត្រង់គុហាពោនស្វា សក្កទេវរាជនឹងឃើញបុព្វនិមិត្ត ៥ យ៉ាង ទ្រង់ខ្លាចចំពោះមរណភ័យ នឹងចូលមករកព្រមជាមួយពួកទេវតាទាំងពីរទេវលោក ទ្រង់សួរបញ្ហា ១៤ ប្រការ កាលដោះស្រាយចប់*

បញ្ហាជាប់ទាក់ទងនឹងឧបេក្ខាហើយ ទ្រង់តាំងនៅក្នុងសោតាបត្តិផល មួយអន្ទើ ដោយទេវតា ៨ ម៉ឺនអង្ត ដូច្នេះ ទើបមិនប្រទានព្រះឌិកាស ។ សក្កទេវរាជ នោះ ទ្រង់ព្រះតម្រិះថា ព្រះសាស្តាមិនប្រទានព្រះឌិកាស ព្រោះកាលមុន អញទៅតែម្នាក់ឯង អញមិនទាន់មានឧបនិស្សយនៃមគ្គផលដោយពិត កាល អញតែម្នាក់មានឧបនិស្សយ ព្រះមានព្រះភាគ ទ្រង់នឹងសម្តែងធម៌ជល់បរិស័ទ សូម្បីដរាបដល់ទីបំផុតចក្រវាល ជាការពិតណាស់ ក្នុងទេវលោកទាំងពីរជាន់ បុគ្គលណាមួយគង់នឹងមានឧបនិស្សយពិតប្រាកដ ព្រះសាស្តា គង់នឹងទ្រង់ សំដៅយកអ្នកនោះ ហើយទ្រង់សម្តែងធម៌ជល់អញ កាលបានស្តាប់ធម៌នោះ ហើយ ក៏គង់នឹងរលត់សេចក្តីទោមនស្សរបស់ខ្ញួនបាន ដូច្នេះហើយ ទើប ត្រាស់ហៅ ដើម្បីបានជាសម្ងាញ់ ។

បទថា **ឯវំ ភទ្ទន្តវាតិ ទោ ទេវា តាវត្តឹសា សក្ពស្ស ទេវានមិន្ទ** សេចក្តីថា សូមជាយ៉ាងនោះចុះមហារាជ ពួកយើងនឹងទៅគាល់ព្រះមានព្រះភាគ ការកើតទ្បើងរបស់ព្រះពុទ្ធ មានសភាពដែលរកបានដោយក្រ សូមសេចក្តី ចម្រើនមានចំពោះព្រះអង្ត តែមិនពោលថា សូមឲ្យយើងទាំងឡាយទៅលេង តាមភ្នំ ទៅលេងតាមស្ទឹង ហើយទ្រង់ប្រកបពួកខ្ញុំក្នុងឋានៈបែបនេះ ។ បទថា **បច្ចស្សោសុំ** គឺទទួលព្រះរាជឌិន្ទាររបស់ស្តេចដោយសិរសា ។ បទថា **បញ្ចសិខំ គន្ធព្ធបុត្តំ អាមន្តេសិ** គឺ (សួរថា) កាលត្រាស់ហៅពួកទេវតា ទាំងនោះហើយ ហេតុអ្វី ទើបត្រាស់ហៅបញ្ចសិខគន្ធព្ធទេវបុត្តនេះទៀត ឆ្ងើយ ថា ដើម្បីឲ្យបញ្ចសិខៈជួយសូមឌិកាស ។ បានញ្ចមកថា សក្កទេវរាជនោះទ្រង់

ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ការនឹងនាំយកពួកទេវតា ក្នុងទេវលោកទាំងពីរ ចូលទៅគាល់ព្រះសាស្តាព្រមគ្នា មិនសមគួរ ឯបញ្ចសិខៈនេះ ជាឧបដ្ឋាកអ្នក បម្រើដែលព្រះទសពលប្រោសប្រាណ ទៅទូលសួរបញ្ហាហើយ ស្តាប់ធម៌ បានគ្រប់ខណៈដែលត្រូវការ ពួកយើងបញ្ជូនបញ្ចសិខៈនេះទៅជាមុន ឲ្យសូម ប្រទានព្រះឱកាសហើយ ទើបចូលគាល់ទូលសួរបញ្ហាក្នុងវេលាដែលបញ្ច-សិខៈនេះ សូមប្រទានព្រះឱកាសស្រេចហើយ ទើបត្រាស់ហៅ ដើម្បីឲ្យសូម ប្រទានឱកាស ។

បទថា **ឯវំ ភទ្ទំ តវា** សេចក្តីថា សូម្បីបញ្ចសិខៈនោះ ក៏គាំទ្រយ៉ាង ម៉ឺងម៉ាត់ថា ព្រះករុណាថ្ងៃវិសេស សូមសេចក្តីចម្រើនមានដល់ព្រះអង្ត ដែល ព្រះអង្តមិនត្រាស់ចំពោះខ្ញុំថា អ្នកនិទ្ទ៊ិក្ខមកចុះ ពួកយើងនឹងត្រាច់ទៅលេង កីឡា ឯឧទ្យានជាដើម ឬទៅលេងមហោស្រពរបស់អ្នករបាំជាដើម (តែ) ត្រាស់ថា ពួកយើងនឹងទៅគាល់ព្រះពុទ្ធ នឹងស្តាប់ធម៌ ហើយក៏ទទួលព្រះ តម្រាស់របស់សក្កទេវរាជ ជាធំជាងពួកទេវតា ហើយក៏រួមជំណើរទៅជាមួយ គ្នា ។ ក្នុងបទទាំងនោះ បទថា **រេឌ្ឍវបណ្ឌុវីណំ** គឺពិណពណ៌លឿងដូចផ្ទែ ញ្ចៅទុំ ។ បានព្ចមកថា ប្រហោងពិណនោះ ធ្វើដោយមាស ដងធ្វើដោយកែវ ឥន្ទនិល ខ្សែធ្វើដោយប្រាក់ ស្នូកធ្វើដោយកែវប្រពាល ។ ស្នូកពិណ ១ គាវុត ខ្ទង់ ១ គាវុត ដងកំណាត់លើ ១ គាវុត ដូច្នេះ ទើបពិណមានប្រវែង ៣ គាវុត ។ បញ្ចសិខៈនោះ កាន់ពិណនោះ ដូចដែលពោលមកនេះហើយ ក៏បញ្ចេញការ ប្រគំយ៉ាងជំនាញ ប្រើចុងក្រចកដេញបន្ទរសំឡេងយ៉ាងពីរោះ ឲ្យពួកទេវតា

ដ៏សេសជ្រាបវេលាការទៅរបស់សក្កទេវរាជ ហើយឈរក្នុងទីដ៏សមគួរ នាចំណែកម្ខាង ។ ក្នុងខណៈនោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា ។បេ។ មកប្រតិស្ឋាននៅលើភ្នំវេទិយកៈ ។

បទថា **អតិរិវ ឱភាសជាតោ** គឺក្នុងថ្ងៃដទៃៗ ក៏កើតពន្លឺភ្លឺ ដោយពន្លឺរបស់ទេវតា មារ ឬព្រហ្ម ត្រឹមតែម្នាក់ប៉ុណ្ណោះ តែថ្ងៃនោះ កើតមានពន្លឺភ្លឺស្វាងដូចគ្នា រុងរឿងទៅជាប់តគ្នាតែមួយ ដូចវេលាព្រះចន្ទ និងព្រះអាទិត្យរះឡើង ១ ពាន់ដួង ព្រោះពន្លឺនៃពួកទេវតា ក្នុងទេវលោកទាំងពីរជាន់ ។ បទថា **បរិតោ គមេសុ មនុស្សា** គឺពួកអ្នកនៅក្នុងស្រុកជិតខាង ។ បានព្ឋមកថា ក្នុងវេលាអាហារល្ងាចជាប្រក្រតីនោះឯង កាលពួកក្មេងៗ កំពុងនាំគ្នាលេងត្រង់កណ្តាលភូមិស្រុក សក្កទេវរាជក៏បានយាងទៅភ្នំវេទិយកៈនោះ ព្រោះដូច្នោះ ពួកមនុស្សកាលបានឃើញ ទើបនាំគ្នាពោលយ៉ាងនោះ ។ ពួកទេវតាចូលមកគាល់ព្រះមានព្រះភាគ ក្នុងមជ្ឈិមយាម មិនមែនឬ ហេតុដូចម្តេចទើបសក្កទេវរាជនេះបានយាងមក ក្នុងបឋមយាមទៅវិញ ។ ព្រោះទ្រង់ត្រូវមរណភ័យគំរាមនុ៉ះឯង ។ បទថា **កឹ សុ ឆាម** សេចក្តីថា ពួកមនុស្សនិយាយគ្នាថា ហេតុអ្វីថ្ងៃនេះទេវតា ឬព្រហ្ម ដែលមានសក្តិធំអង្គណាហ្នឹ ចូលគាល់ព្រះមានព្រះភាគ ដើម្បីនឹងទូលសួរបញ្ហា ដើម្បីនឹងស្តាប់ធម៌ ហើយព្រះមានព្រះភាគនឹងទ្រង់ដោះស្រាយបញ្ហា នឹងទ្រង់សម្តែងធម៌យ៉ាងណា លាភរបស់ពួកយើង ពួកយើងដែលមានព្រះសាស្តា ទ្រង់បន្ទោបង់សេចក្តីសង្ស័យរបស់ពួកទេវតា ទ្រង់ប្រថាប់នៅក្នុងវត្តជិតៗ ដែលពួកយើងបានថ្វាយភិក្ខា

មួយថាសខ្លះ កិក្ខាមួយវែកខ្លះ ហើយក៏តក់ស្លុត ព្រឺរោម ព្រឺស្បែក ផ្តង អញ្ជលីដ៏រុងរឿង ដោយទសនខសមោធាន ជាក់លើសិរសា ឈរនមស្ការ ។

បទថា **ឧរុបសង្ខម** *គឺគប្បីចូលទៅអង្គុយជិតបានលំបាក ។ យើង នៅមានរាគៈ ទោសៈ មោហៈ (តែ) ព្រះសាស្តាមិនមានរាគៈ ទោសៈ មោហៈ ព្រោះដូច្នោះ ព្រះតថាគតទាំងឡាយ ដែលបុគ្គលដូចជាយើង គប្បីចូលទៅ អង្គុយជិតបានលំបាក ។ បទថា* **ឈាយី** *គឺទ្រង់មានឈាន ដោយលក្ខណៈ-បឋមជ្ឈាន និងអារម្មណូបចារជ្ឈាន ។ ឈ្មោះថា* **ឈានរតោ** *ព្រោះទ្រង់ត្រេកអរ ក្នុងឈាននោះឯង ។ បទថា* **តទនន្តរំ បដិសល្លីន** *គឺក្នុងលំដាប់ដែលទ្រង់ពួន សម្ងំនោះ ឬពេលដែលទ្រង់ពួនសម្ងំ ព្រោះដូច្នោះ ទើបមិនមែនចូលគាល់ លំបាក ព្រោះទ្រង់មានឈាន ទ្រង់ត្រេកអរក្នុងឈានប៉ុណ្ណោះ តែចូលគាល់ លំបាក ព្រោះទ្រង់ទើបតែពួនសម្ងំអម្បាញ់មិញនេះឯង ។ បទថា* **បសាទេយ្យាសិ** *គឺគប្បីឲ្យទ្រង់ពេញព្រះហឫទ័យ ។ សក្កទេវរាជត្រាស់ថា អ្នកគប្បីធ្វើឲ្យទ្រង់ប្រទានព្រះឱកាសដល់យើង ។ សួរថា ក្រែងបញ្ចសិខៈកាន់ពិណដែលមានពណ៌លឿងដូចផ្ទៃព្នៅស្រាប់ហើយ មិនមែនឬ ឆ្លើយថា កាន់ហើយ តែពិណនោះស្ងាយនៅត្រង់ចង្កួយស្មា ដោយអំណាចការធ្វើដំណើរ ឥឡូវនេះ បញ្ចសិខៈយកពិណនោះមកកាន់ត្រង់ដៃឆ្វេង ធ្វើការត្រៀមនឹងដេញ ដូច្នោះ ទើប ពោលថា កាន់ហើយ ។ បទថា* **អស្សាវេសិ** *គឺឲ្យទ្រង់ស្តាប់ ។ បទថា* **ពុទ្ធូបសញ្ហិតា** *គឺប្រារព្ធព្រះពុទ្ធ អធិប្បាយថា ធ្វើព្រះពុទ្ធឲ្យជាទីអាស្រ័យ។ សូម្បីក្នុងបទដ៏សេស ក៏នយនេះឯង ។*

[៨៦-៨៧] គប្បីជ្រាបវិនិច្ឆ័យក្នុងបទ **វន្ទេ តេ បតរំ ភន្ទេ តិម្ពរុំ សុរិយវច្ឆសេ** ដូច្នេះ បទថា **សុរិយវច្ឆសា** គឺមានរូបរាងស្មើគ្នានឹងព្រះអាទិត្យ ។ បានញ្ជមកថា រស្មីតាំងឡើងត្រង់ចុងជើងរបស់ទេវធីតានោះ ហើយផ្សាយឡើងទៅរហូតដល់នឹងចុងសក់ ដូច្នោះ ទើបប្រាកដដូចពន្លឺព្រះអាទិត្យដ៏ស្រទន់ៗ ដោយប្រការដូច្នេះ ទើបទេវតាទាំងឡាយស្គាល់នាងថា សុរិយវច្ឆសា ។ បញ្ចសិខៈបំណងយកសេចក្តីនោះ ទើបពោលថា ម្នាលនាងសុរិយវច្ឆសា ដូច្នេះ ។ បញ្ចសិខៈពោលថា បងសូមថ្វាយបង្គំនូវទេវរាជព្រះនាមតិម្ពរុ ជាបិតារបស់នាង ។ បទថា **យេន ជាតាសិ កល្យាណី** គឺព្រោះអាស្រ័យតិម្ពរុទេវរាជណា នាងស្រស់ល្អ គឺស្អាតគ្រប់ចំណែក ទើបបានកើតមក ។ បទថា **អានន្ទជនន៊ី មម** គឺធ្វើឲ្យបីតិ និងសោមនស្សចម្រើនដល់បង ។

បទថា **វាតោវ សេទតំ កន្ពោ** អធិប្បាយថា ឲ្យល់ជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដែលបែកញើស ដើម្បីឲ្យញើសស្ងួតអស់ យ៉ាងណា បញ្ចសិខៈក៏ដូច្នោះ ។ បទថា **ចានីយំវ បិចាសតោ** គឺទឹកជាទីប្រាថ្នារបស់អ្នកដែលត្រូវសេចក្តីស្រេកគ្របសង្កត់ហើយ ប្រាថ្នានឹងផឹក ។ បទថា **អង្គីរំសី បិយា មេសិ** គឺរស្មីចាកកាយរបស់នាងមាន ហេតុនោះ ទើបនាងឈ្មោះថា **អង្គីរំសី** ។ បញ្ចសិខៈពោលប្រារព្ធដល់នាងសុរិយវច្ឆសានោះឯង ។ បទថា **ធម្មោ អរ-ហតំ ឥវ** គឺដូចលោកុត្តរធម៌ ៩ យ៉ាង របស់ព្រះអរហន្តទាំងឡាយ ។

បទថា **ជិឃច្ឆតោ** គឺរបស់អ្នកដែលត្រូវសេចក្តីឃ្លានគ្របសង្កត់ ប្រាថ្នា

និងបរិភោគ ។ បទថា **ជលន្តមិវ រាវិនា** គឺបញ្ចសិខៈពោលថា បុគ្គលគប្បីយកទឹករម្ងត់ភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ យ៉ាងណា នាងចូវរម្ងត់ការក្តៅក្រហាយ ព្រោះរាគៈរបស់បង ដែលកើតឡើងហើយ ព្រោះនាងជាហេតុដូច្នោះ ។ បទថា **យុត្តំ កិញ្ជក្ខរេណុនា** គឺប្រកបដោយកេសរ និងលម្អងផ្តាឈូក បទថា **ឃម្មាភិតត្តោវ** គឺដូចជំរីដែលត្រូវកម្តៅថ្ងៃដុតរោលក្នុងរដូវក្តៅ ។ បទថា **ទ្វិតាហេ តេ ថនូទរំ** គឺបញ្ចសិខៈពោលថា កាលណាហ្នឹ បងនឹងបានចុះកាន់ដោះ និងខទរ ដែលបានដល់នែបនិត្យត្រង់ចន្ងោះស្តន និងខទររបស់នាង ហើយបានទទួលសេចក្តីសុខ និងសេចក្តីរីករាយ ដូចជំរីចុះកាន់ស្រះឈូក ផឹក ហើយត្រាំខ្លួន ដើបឡើងតែចុងប្រមោយប៉ុណ្ណោះឲ្យប្រាកដបានទទួលសេចក្តីសុខ និងសេចក្តីរីករាយ ដូច្នោះ ។ ដែកកោង ដែលប្រើកាប់ត្រង់គុម្ពត្រចៀក ហៅថា កង្វេរ ដោយគាថានេះថា

> បងដោងងប់ព្រោះភ្លៅរបស់នាង ដែលបរិបូណិដោយ
> លក្ខណៈ ក៏លែងស្គាល់ហេតុ (ដែលនាំឲ្យប្រាសចាក
> រាគៈ) ដូចជាជំរី (ចុះប្រេង) ហួសវិស័យកង្វេរ គិតថា
> អញឈ្នះផ្ទែកង្វេរ និងលំពែង ដូច្នោះ ។

ដែលហៅថា លំពែង បានដល់ លំពែងអាជ្ញាប្រើចាក់ជើងជាដើម ។ ដែលហៅថា កង្វេរ បានដល់ ដែកស្រួចកោងប្រើកាប់ក្បាលជំរី ។ ជំរីដែលចុះប្រេងពេញទី ជាជំរីដែលហួសវិស័យកង្វេរ ចចេសនឹងកង្វេរ ទោះជាឲ្យយកកង្វេរកាប់ទាញ ក៏មិននៅ ជំរីយល់ថា អញយកឈ្នះកង្វេរ និងលំពែងបាន

ហើយ ព្រោះសូម្បីតែកង្វេរក៏នៅទាក់អញមិនបាន មិនព្រមទទួលជីងហេតុការណ៍ផ្សេងៗ ព្រោះកម្ចាំងនៃការស្រេវឹង ។ បញ្ចសិខៈពោលថា សូម្បីខ្លួនបង ក៏វង្វេង ស្រេវឹង ឆ្គួតក្នុងនាង ដែលមានក្លៀល្អ ព្រោះមានក្លៀដល់ព្រមដោយលក្ខណៈ ទើបមិនជីងច្បាស់ហេតុការណ៍អ្វីណាមួយ ដូចជីរចុះប្រេងនោះ យល់ថា អញយកឈ្នះកង្វេរ និងលំពែងបានហើយ ក៏មិនជីងច្បាស់ហេតុការណ៍អ្វីៗ ដូច្នោះ ។ ម្យ៉ាងទៀត ខ្លួនបងដូចជាជីរដែលចចេសនឹងកង្វេរ វង្វេងក្នុងនាងដែលមានក្លៀល្អ ដូច្នោះ ទើបមិនជីងច្បាស់ ហេតុនៃការប្រាសចាកតម្រេកត្រឹមតែបន្តិចបាន ។ ព្រោះហេតុអ្វី ព្រោះឲ្យនរណាៗ មកពោល បង ក៏មិនកាន់យកពាក្យ ដូចជីរដែលគិតថា អញឈ្នះកង្វេរ និងលំពែងបានហើយ ដូច្នោះ ។

បទថា **តយិ គធិតចិត្តោស្មិ** *សេចក្តីថា នាងជាទីស្រឡាញ់ បងនេះជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងនាងដែលមានក្លៀល្អ ។ បទថា* **គធិតចិត្តោ** *បានដល់ មានចិត្តសម្ងឹងផ្តោតដោយសេចក្តីស្រឡាញ់ ។ បទថា* **ចិត្តំ វិបរិណាមិតំ** *គឺចិត្តលះបង់ប្រក្រតីតាំងនៅ ។ បទថា* **បដិគ្គន្តុំ ឧសក្កោមិ** *គឺបងឲ្យត្រឡប់មិនបាន ។ បទថា* **វង្គយត្តោវ អម្ពុជោ** *គឺជូចត្រីដែលលេបសន្ទូចហើយជាប់នៅ ជាបៈថា* **ឃស** *ក៏មាន ។ អត្តក៏ជូចគ្នា ។ បទថា* **វាមូរូ** *គឺមានក្លៀដែលតាំងមាំដោយល្អ ឬអធិប្បាយថា មានក្លៀជូចដើមចេក ។ បទថា* **សជ** *គឺសូមឱបបង ។ បទថា* **មន្ទលោចនេ** *គឺពួកស្រី រមែងមិនផ្តោតមើលចំ តែរមែងជៀងភ្នែកមើល ដូច្នោះ ទើបហៅថា អ្នកមានភ្នែកស្រេទន់ ។ បទថា*

បលិស្សជ គឺចូរឧបបងគ្រប់ចំណែក ។ បទថា **ឯតំ មេ អភិបដ្ឋិតំ** គឺបងត្រូវ
ការយ៉ាងនេះជានិច្ច ។ បទថា **អប្បកោ វត មេ សន្តោ** គឺមានសេចក្តី
ស្រឡាញ់តិច ដោយប្រក្រតីនោះឯង ។ បទថា **វេលិ្ចតកេសិយា** គឺឈ្មោះថា
មានសក់ត្រសាយងឡើង ព្រោះសក់របស់ស្រីនោះក្នុងវេលាដែលរំសាយ ហើយ
ជ្ជាក់ទៅខាងក្រោយ លូនទៅដូចពស់ ។ ដែលមានសក់ដូចទឹករលកនោះ ។
បទថា **អនេកភាវោ សមុទាធិ** គឺកើតឡើងមិនមែនតែម្តង ជាឯះថា **អនេក-
ភាតោតិបិ** ក៏មាន ។ បទថា **អរហន្តេវធក្ខិណា** គឺផ្សាយចេញទៅដោយ
ប្រការផ្សេងៗ ដូចទានដែលថ្វាយក្នុងព្រះអរហន្ត (រមែងមានផលច្រើន
ដូច្នោះ) ។ បទថា **យំ មេ អត្ថិ កតំ បុញ្ញំ** គឺបុណ្យឯណា ដែលបងជានធ្វើទុក
មាន ។ បទថា **អរហន្តេសុ ធាធិសុ** គឺក្នុងពួកព្រះអរហន្ត ដែលដល់លក្ខណៈ
នៃបុគ្គលនឹងធឹង ។ បទថា **តយោ សជ្ជឺ វិបច្ចតំ** គឺបុណ្យទាំងអស់ ចូរផ្តល់
ផលឲ្យបង និងនាងនុ៉ះឯង ។ បទថា **ឯកោធិ** គឺដល់ភាពតែម្នាក់ឯង ។ បទថា
និបកោ សតោ ជានដល់ ឈ្មោះថា បញ្ញាជាគ្រឿងយុំគ្រងខ្ជួន ព្រោះប្រកប
ដោយបញ្ញាដែលហៅថា ជាគ្រឿងរក្សាខ្ជួននោះ ព្រោះប្រកបដោយសតិ ទើប
ឈ្មោះថា មានស្មារតី ។ បទថា **អបតំ មុនិ ជិតឺសានោ** គឺអង្គព្រះពុទ្ធមុនីនោះ
ទ្រង់ស្វែងរក គឺស្វែងរកអមតៈ ជានដល់ ព្រះនិញ្ចាន យ៉ាងណា នៃនាងសុរិយ-
វច្ចសា បងក៏ដូច្នោះ រមែងស្វែងរក គឺស្វះស្វែងរកនាង ។ ម្យ៉ាងទៀត
អធិប្បាយថា ព្រះពុទ្ធមុនីអង្គនោះ ទ្រង់ត្រាច់ស្វែងរកអមតៈធម៌ យ៉ាងណា បង

ក៏ត្រាច់ស្វែងរកនាងដូច្នោះដែរ ។

បទថា **យថាបិ មុនិ ឧត្តេយ្យបត្ថា សម្ពោធិមុត្តមំ** *សេចក្តីថា ព្រះពុទ្ធ-មុនីទ្រង់ប្រថាប់គង់ត្រង់ពោធិបល្ល័ង្ក ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ គប្បីទ្រង់រីករាយ គឺគប្បីទ្រង់ត្រេកអរ យ៉ាងណា ។ បទថា* **ឯវំ ឧត្តេយ្យ** *សេចក្តីថា បញ្ចសិខៈពោលថា បើបង់បានកៀកកើយនឹងនាងហើយ ក៏គប្បីត្រេកអរ គឺគប្បីជាអ្នកកើតបីតិ និងសោមនស្សដូច្នោះ ដូចគ្នា ។*

បទថា **អហោ** *ក្នុងបាទគាថាថា* **តាហំ ភទ្ទេ វរេយ្យាហោ** *ជាពាក្យសម្រាប់ហៅ អធិប្បាយថា នេះនែ៎នាងសុរិយវច្ឆសា បើសក្កទេវរាជ ជាធំជាងពួកទេវតា ប្រទានពរយ៉ាងនេះថា អ្នកនឹងយកទេវរាជក្នុងទេវលោកទាំងពីរជាន់ ឬយកនាងសុរិយវច្ឆសា បងនឹងក្រាបទូលថា ខ្ញុំសូមលះបង់ទេវរាជ្យ ហើយយកនាងសុរិយវច្ឆសា បងត្រូវជ្រើសរើស គឺត្រូវការ បានជល់ ត្រូវយកនាង ដោយប្រការដូច្នេះ ។*

បទថា **សាលំវ ន ចិរំ ផុល្លំ** *សេចក្តីថា ជិតទ្វារនគរ របស់បិតានាង មានដើមសាលព្រឹក្សទើបតែនឹងរីកដើមសាលព្រឹក្សនោះ គួរត្រេកអរពន់ពេក ។ ដូចដើមសាលព្រឹក្សដែលទើបតែនឹងរីកនោះ ។ បទថា* **បិតរំ តេ សុមេធសេ** *សេចក្តីថា កាលបើបង់ថ្វាយបង្គំ ក៏សូមថ្វាយបង្គំ គឺនមស្ការបិតារបស់នាងដែលទ្រទ្រង់សិរីគ្មានអ្វីប្រៀប ។ បទថា* **យស្សា សេតាធិសី បជា** *សេចក្តីថា នាងដែលមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា ។ សួរថា ហេតុដូចម្តេចទើបព្រះមានព្រះភាគត្រាស់សរសើរសំឡេងជេញ និងសំឡេងពិណថា សម*

ល្មមគ្នា តម្រេកខ្ចាំងក្នុងសំឡេងនោះ របស់ព្រះមានព្រះភាគនៅមានឬ ឆ្លើយ ថា មិនមាន ។ ព្រះមានព្រះភាគ ទ្រង់ជាអ្នកព្រងើយដោយឆឡង្គុប្បេក្ខា ក្នុង ហាន:ដូច្នេះ ទ្រង់ជ្រាបអារម្មណ៍ដែលគួរពេញចិត្ត និងមិនគួរពេញចិត្តគ្រប់ យ៉ាង ទ្រង់មិនជាប់ក្នុងអារម្មណ៍នោះ ។ សមដូចពាក្យដែលលោកពោល យ៉ាងនេះថា នែអាវុសោ ព្រះចក្ខុរបស់ព្រះមានព្រះភាគក៏មាន ព្រះមានព្រះ ភាគ ទ្រង់ទតមើលរូបដោយព្រះចក្ខុដែរ តែឆន្ទរាគ:របស់ព្រះមានព្រះភាគ មិន មានទេ ព្រោះព្រះមានព្រះភាគ ព្រះអង្គមានព្រះហឫទ័យផុតស្រឡះហើយ នែអាវុសោ ព្រះសោតរបស់ព្រះមានព្រះភាគក៏មាន ។បេ។ ដូច្នេះជាដើម ។ ព្រះមានព្រះភាគត្រាស់សរសើរ ព្រោះទ្រង់ជ្រាបថា បើតថាគតមិនពោល សរសើរ បញ្ចសិខ:ក៏ដឹងមិនបានថា តថាគតបានឲ្យឱកាសហើយ ពេលនោះ សក្កទេវរាជក៏នឹងទ្រង់នាំពួកទេវតា ត្រឡប់ទៅអំពីទីនោះ ព្រោះទ្រង់យល់ក្នុង ព្រះទ័យថា ព្រះមានព្រះភាគមិនប្រទានព្រះឱកាសដល់បញ្ចសិខ: បន្ទាប់ អំពីនោះ ក៏នឹងគប្បីវិនាសធំ កាលត្រាស់សរសើរ ដូច្នោះ បន្ទាប់អំពីនោះ សក្កទេវរាជទ្រង់ក៏នឹងយល់ក្នុងព្រះហឫទ័យថា ព្រះមានព្រះភាគ បានប្រទាន ឱកាសដល់បញ្ចសិខ:ហើយ ទ្រង់នឹងចូលមកគាល់ មួយអន្ទើដោយពួកទេវតា ទ្រង់សួរបញ្ហា កាលដោះស្រាយបញ្ហាស្រេច សក្កទេវរាជ និងពួកទេវតា ៨ ម៉ឺន ក៏នឹងតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងបទទាំងនោះ បទថា **កថา សំយុត្តោ** *សេចក្តីថា (គាថាទាំងនេះអ្នក) ចង គឺរួបរួមអំពីពេលណា ។*

បទថា **តេន ខោ បនាហំ ភន្តេ សមយេន** *សេចក្តីថា ដោយសម័យ*

នោះ គឺក្នុងសប្តាហ៍ទី ๘ បន្ទាប់ពីព្រះអង្គសម្រេចសម្មោធិញ្ញាណនោះ ។ បទថា **ភទ្ទា ឆាម សុរិយវច្ឆសា** *គឺដោយឈ្មោះ ឈ្មោះភទ្ទា ព្រោះដល់ព្រមដោយសណ្ឋានដែលស្អាតល្អ ទើបឈ្មោះថា* **សុរិយវច្ឆសា ។** *បទថា* **ភគិនី** *នេះ ជាពាក្យសំនួនហៅ ។ សេចក្តីថា នែទេវធីតា ។ បទថា* **បរកាមិនី** *គឺស្រឡាញ់បានដល់ ប្រាថ្នាអ្នកដទៃ ។*

[๘๘] *បទថា* **ឧបនច្ចន្តិយា** *បានដល់ កំពុងរាំ ។ បានឮថា សម័យមួយ នាងទៅដើម្បីមើលរបាំរបស់សក្កទេវរាជ ជាមួយពួកទេវតាជាន់ចាតុម្មហារាជិកា ។ ក្នុងកាលនោះ សក្កទេវរាជ ទ្រង់បានពោលសរសើរព្រះគុណតាមសេចក្តីពិត ๘ ប្រការ របស់ព្រះតថាគត ។ ដោយប្រការដូច្នេះ ឈ្មោះថា ក្នុងថ្ងៃនោះ នាងក៏បានទៅមើលការរាំក្នុងរោង[๑] ។*

បទថា **បដិសម្មោទតិ** *សេចក្តីថា កាលព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា សំឡេងខ្សែពិណរបស់អ្នក សមល្មមគ្នានឹងសំឡេងច្រៀង ឈ្មោះថា ទ្រង់ត្រេកអរ បញ្ចសិខៈក៏ឈ្មោះថា ត្រេកអរតប កាលបញ្ចសិខៈកំពុងពោលគាថា ក៏ឈ្មោះថា ត្រេកអរ ព្រះមានព្រះភាគ ក៏ឈ្មោះថា ទ្រង់ត្រេកអរតប ។ បទថា* **អាមន្តេសិ** *គឺទ្រង់បញ្ជាក់ឲ្យដឹង ។ បានឮមកថា សក្កទេវរាជនោះ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា អញបញ្ជូនបញ្ចសិខៈនេះទៅ ដោយការងាររបស់អញ បញ្ចសិខៈក៏ទៅធ្វើការងាររបស់ខ្លួនឯង បញ្ចសិខៈឈរក្នុងសម្នាក់ព្រះសាស្តាបែបនោះ ហើយទៅជាពោលពាក្យដែលប្រកបដោយកាម-*

๑- *បិដកខ្មែរថា ចូលទៅរាំក្នុងរោង ។*

គុណ ដែលជាពាក្យមិនសមគួរ ឈ្មោះថា ពួកអ្នករបាំ ជាពួកគ្មានអៀនខ្មាស បញ្ចសិខៈកាលកំពុងពោល គប្បីសម្តែងអាការដែលខុសឆ្គងក៏បាន ណ្ហើយចុះ អញនឹងជាសំតឿន ឲ្យគេដឹងការងាររបស់អញ កាលទ្រង់គិតដូច្នេះហើយ ក៏ត្រាស់ហៅមក ។

[๘๙] *បទថា* **ฯลฯ បន តថាគតោ** *ដូច្នេះ ដែលពួកព្រះថេរៈ អ្នកចងក្រងធម៌វចនាហើយ ។ បទថា* **អភិវន្ទិ** *គឺពោលដោយការទទួលការថ្វាយបង្គំ បានដល់ ដោយពាក្យដែលបន្តែមឡើង ។ បទថា* **អភិវន្ទិតោ** *គឺការពោលដោយពាក្យដែលបន្តែមឡើង ។ បទថា* **ឧរុឡ្ហា សមថាធិ** *គឺក្លាយជាបើកធំទូលាយ ។ បទថា* **អាលោកោ ឧទបាធិ** *គឺភាពងងឹតដោយប្រក្រតីរបស់គុហានោះ បានបាត់ទៅ កើតពន្លឺភ្លឺជំនួស ។ ទាំងអស់នេះ ជាពាក្យរបស់ធម្មសង្គាហកាចារ្យ ។*

[๙๐] *បទថា* **ចិរបដិកាហំភន្តេ** *សេចក្តីថា ខ្ញុំព្រះអង្គប្រាថ្នានឹងចូលគាល់ជាយូរមកហើយ អធិប្បាយថា ខ្ញុំព្រះអង្គប្រាថ្នានឹងគាល់តាំងពីយូរមកហើយ ។ បទថា* **កេហិចិ កិច្ចករណីយេហិ** *សេចក្តីថា ពួកកូនស្រី និងកូនប្រុស រមែងកើតលើភ្លៅរបស់ពួកទេវតា ពួកស្ត្រីដែលជាបាទបរិចារិកា រមែងកើតលើទីដេក ពួកទេវតាដែលជាអ្នកធ្វើគ្រឿងប្រដាប់តាក់តែងរបស់ទេវតាទាំងនោះ រមែងកើតជុំវិញទីដេក ពួកទេវតាជាអ្នកបម្រើការងារ រមែងកើតខាងក្នុងវិមាន ។ ការកាត់ក្តី ដើម្បីប្រយោជន៍ដល់ទេវតាទាំងនេះមិនមាន តែពួកទេវតាដែលកើតចន្លោះព្រំប្រទល់នោះ កាលមិនអាចកាត់ក្តីថា របស់លោក*

របស់ខ្ញុំ ដូច្នេះ ក៏កើតក្តីនឹងគ្នា រមែងទូលសួរសក្កទេវរាជដែលជាស្តេចទេវតា ព្រះអង្គក៏ត្រាស់ថា ជិតវិមានអ្នកណាជាង ជារបស់អ្នកនោះ បើមានចម្ងាយស្មើគ្នារវាងវិមានទាំងពីរ ព្រះអង្គក៏ត្រាស់ថា ទេវតាដែលទើបតែកើតសម្ងឹងវិមានរបស់បុគ្គលណាមុន ជារបស់បុគ្គលនោះ បើមិនសម្ងឹងមើលវិមានមួយណាទេ ដើម្បីកាត់ការឈ្លោះទាំងពីរចំណែក ក៏ទ្រង់យកដោយខ្លួនឯង ញ៉ាំងកិច្ច មានការលេងកីឡាជាដើម ក៏ចាំបាច់ទ្រង់ត្រូវចាត់ការទាំងអស់ សក្ក-ទេវរាជទ្រង់សំដៅយកករណីទាំងនោះ មានសភាពបែបនេះហើយ ទើបត្រាស់ថា ដោយការងារនីមួយ ដូច្នេះ ។

បទថា **សលឋាគារកេ** *បានដល់ ព្រះគន្ធកុដិដែលសាងដោយដើមស្រល់ ។ បទថា* **អញ្ញតរេន សមាធិនា** *គឺមានរឿងតំណាលថា គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ញាណរបស់សក្កទេវរាជនុ៎ះ មិនទាន់ចាស់ក្លា ទើបទ្រង់មិនប្រទានព្រះឱកាសឡើយ ប្រថាប់គង់ដោយធម៌ជាគ្រឿងសម្រាកគឺផលសមាបត្តិ សក្កទេវរាជទ្រង់មិនជ្រាបដល់សេចក្តីនោះ ទើបត្រាស់ថា ដោយសមាធិឯណាមួយ ដូច្នេះ ។ បទថា* **កុជគី ជាម** *គឺទេពធីតានោះ ឈ្មោះថា កុជគី ។ បទថា* **បរិចារិកា** *គឺទេពធីតាដែលជាបាទបរិចារិកា ។ មានរឿងតំណាលមកថា នាងសម្រេចផលពីរយ៉ាង ហេតុនោះ ទើបនាងមិនមានសេចក្តីត្រេកអរក្នុងទេវលោកឡើយ នាងមកកាន់ទីបម្រើព្រះមានព្រះភាគជានិច្ច ឈរប្រណម្យដៃ ដាក់លើសិរសា ថ្វាយបង្គំព្រះមានព្រះភាគ ។*

ក្នុងពាក្យថា ចេញចាកសមាធិនោះ ព្រោះសូរនៃខ្នងកង់ (រាជរថ)

របស់ទេវរាជនេះ ។ មិនត្រូវយល់ថា ទ្រង់ចូលសមាបត្តិហើយ ទ្រង់បានឮសំឡេង ។ សួរថា ព្រះមានព្រះភាគ ក៏នៅតែត្រាស់នឹងសក្កទេវរាជ ជាធំជាងពួកទេវតាថា មួយប្រការទៀត តថាគតចេញចាកសមាធិនោះ ព្រោះសំឡេងកង់ និងដុំនៃរថរបស់មហាបពិត្រ មិនមែនឬ ។ ឆ្លើយថា សំឡេងដុំនៃរថលើកទុកចុះ ធម្មតាអ្នកចូលសមាបត្តិ ខាងក្នុងសមាបត្តិ ទោះជាឲ្យអ្នកណាយកគូសង្ខ័មកផ្ចុំជាក់ជិតៗ គុម្ពត្រចៀកក្តី រន្ទះបាញ់ក្តី ក៏រមែងមិនបានឮសំឡេង ។ ចំណែកព្រះមានព្រះភាគ ទ្រង់កំណត់ថា អស់កាលប៉ុណ្ណេះ តថាគតនឹងមិនទាន់ឲ្យឱកាសដល់សក្កទេវរាជ ទើបទ្រង់ចូលផលសមាបត្តិ ដោយអំណាចវេលា ។ សក្កទេវរាជទ្រង់គិតថា ឥឡូវនេះ ព្រះសាស្តាមិនទាន់ប្រទានឱកាសដល់អញ ទើបទ្រង់ធ្វើប្រទក្សិណព្រះគន្ធកុដិ ហើយឲ្យត្រឡប់រថបែរព្រះភក្ត្រ ទៅកាន់ទេវលោក ។ បរិវេណព្រះគន្ធកុដិ ក៏មានការលាន់រំពង ព្រោះសំឡេងរថជួចតន្ត្រី មានអង្គ ៥ ។ កាលព្រះមានព្រះភាគ ទ្រង់ចេញចាកសមាបត្តិ តាមអំណាចវេលាដែលទ្រង់បានកំណត់ហើយ ចិត្តដែលធ្វើកិច្ចពិចារណាអារម្មណ៍ជួងដំបូងក៏កើតឡើង ដូច្នោះ ទើបព្រះអង្គត្រាស់យ៉ាងនោះ ។

បទថា **សីលេសុ បរិបូរីការិនី** *គឺជាអ្នកមានប្រក្រតី ធ្វើឲ្យបរិបូណ៌ក្នុងសីល ៥ ប្រការ ។ បទថា* **ឥត្តីចិត្តំ វិភាវេត្វា** *គឺមកគិតថា លុបហើយសម្រាប់ភាពជាស្ត្រី ព្រោះថា តាំងនៅក្នុងភាពជាស្ត្រី ហើយនឹងសោយសិរីរបស់ស្តេចចក្រពត្តិក៏មិនបាន សោយសិរីរបស់ព្រះឥន្ទ្រ មារ និងព្រហ្មក៏មិនបាន នឹងសម្រេចបច្ចេកពោធិញ្ញាណក៏មិនបាន នឹងសម្រេចសម្មាសម្ពោ-*

ជិញ្ញាណក៏មិនបាន យ៉ាងនេះហើយ ឈ្មោះថា រមែងប្រាសចាកសេចក្តីប្រាថ្នា ក្នុងភាពជាស្ត្រី ចំណែកអ្នកដែលគិតថា ធម្មតាភាពជាបុរសនេះ ធំក្រៃលែង ប្រសើរបំផុត ព្រោះបុគ្គលដែលតាំងនៅក្នុងភាពជាបុរសនេះ អាចដល់ព្រមនូវសម្បត្តិទាំងនេះយ៉ាងនេះហើយ ឈ្មោះថា រមែងធ្វើភាពជាបុរសឲ្យមាន សូម្បីនាងក៏បានធ្វើយ៉ាងនោះ ព្រោះដូច្នោះ ទើបពោលថា នឿយណាយចិត្ត ក្នុងភេទនៃខ្លួនជាស្ត្រី កើតសេចក្តីពេញចិត្ត ក្នុងភេទនៃខ្លួនជាបុរស ដូច្នេះ ។ បទថា **ហីនំ គន្ធព្វកាយំ** *ពួកគន្ធព្វថោកទាប គឺលាមក ។ សួរថា ពួកភិក្ខុទាំងនោះ សុទ្ធតែមានសីលបរិសុទ្ធ ហេតុដូចម្តេច ទើបកើតឡើងក្នុងទេវលោកនោះ ឆ្លើយថា ព្រោះសេចក្តីពេញចិត្តមកពីមុន ។ បានឮថា កាលពីមុនមក ទីនុ៎ះឯង ជាទីដែលធ្លាប់នៅមកហើយរបស់ភិក្ខុទាំងនោះ ព្រោះដូច្នោះ ទើបកើតឡើងក្នុងទីនោះ ដោយអំណាចនៃសេចក្តីពេញចិត្ត ។ បទថា* **ឧបដ្ឋានំ** *បានដល់ ភោគសម្រាប់បម្រើ ។ បទថា* **ចារិចរិយំ** *បានដល់ ការបម្រើ ។ គន្ធព្វទាំងនោះរមែងមក ដោយគិតថា ពួកយើងនឹងបម្រើដោយការប្រគំ និងការច្រៀង ។ បទថា* **បដិចោទេសិ** *គឺឲ្យនូវស្មារតី ។ បានឮថា កាលគោបក-ទេវបុត្តឃើញគន្ធព្វទាំងនោះ ទើបពិចារណាថា ទេវបុត្តទាំងនេះ មានរស្មីហួសប្រមាណ បានធ្វើកម្មអ្វីហ្ន៎ បានឃើញថា ជាពួកភិក្ខុ បន្ទាប់ពីនោះក៏ពិចារណាទៀតថា ពួកភិក្ខុទាំងនេះមានប្រក្រតីធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយឬហ្ន៎ បានឃើញថា មានប្រក្រតីធ្វើឲ្យបរិបូណ៌ ពិចារណាតទៅថា មានប្រក្រតីធ្វើឲ្យបរិបូណ៌ ចុះគុណពិសេសយ៉ាងដទៃមាន ឬមិនមាន បានឃើញថា ជាពួក*

មានប្រក្រតីបានឈាន ពិចារណាតទៅទៀតថា សូម្បីមានប្រក្រតីបានឈាន ចុះជាអ្នកណា បានឃើញថា ជាអ្នកមកទទួលបាត្រប្រចាំត្រកូលរបស់យើងន៉ុះឯង ទើបគិតថា ធម្មតាអ្នកមានសីលបរិសុទ្ធ រមែងកើតក្នុងទេវលោក ៦ ជាន់ ក្នុងជាន់ដែលត្រូវការ តែពួកភិក្ខុទាំងនេះ មិនកើតក្នុងទេវលោកជាន់ខ្ពស់ ធម្មតាអ្នកបានឈាន រមែងកើតក្នុងព្រហ្មលោក តែភិក្ខុទាំងនេះមិនកើតក្នុងព្រហ្មលោក ចំណែកខ្ជូនអញតាំងនៅក្នុងឧវាទរបស់ភិក្ខុទាំងនេះ កើតជាបុត្រត្រង់បល្ជ័ង្ក្ររបស់សក្កទេវរាជ ដែលជាម្ចាស់នៃទេវលោក ភិក្ខុទាំងនេះកើតក្នុងពួកគន្ធព្វថោកទាប ដែលឈ្មោះថា ពួកគន្ធព្វនោះ ជាពួកបុគ្គលដែលយកធ្មឹងមកចោះពាក់ត្រង់ក រាំរែកទៅ រាំរែកមកប៉ុណ្ណោះឯង ទើបជាស់តឿនដោយពាក្យជាដើមថា យកមុខទៅទុកទីណា ។ ក្នុងបទទាំងនោះ បទថា **ក្រុតោមុខា** សេចក្តីថា កាលព្រះមានព្រះភាគ ទ្រង់បែរព្រះភក្ត្រមកសម្តែងធម៌ ពួកលោករវល់តែយកមុខទៅទុកក្នុងទីណា ឬរវល់តែបញ្ជូនចិត្តទៅទីដទៃមើលនោះមើលនេះ ឬរវល់តែដេកលក់ ។ បទថា **ឧុឧ្ធិជ្ជូរបំ** គឺមិនសមគួរនឹងឃើញ សភាពដែលមិនគួរមើល ។ បទថា **សហធម្មិកេ** គឺអ្នកប្រព្រឹត្តធម៌បានដល់ ធ្វើបុណ្យក្នុងសាសនារបស់ព្រះសាស្តាជាមួយគ្នា ។ បទថា **តេសំ ភន្តេ** សេចក្តីថា បណ្តាទេវបុត្រទាំងនោះ ត្រូវគោបកទេវបុត្រពោលយ៉ាងនោះហើយ ជាស់តឿនទៀត ដោយពាក្យជាដើមថា ឧ ពួកលោក ហេតុអ្វីមិនមានលជ្ជី ហេតុអ្វីមិនមានហិរិ ទេវតាទាំងពីរអង្គក៏ត្រឡប់បានស្មារតីក្នុងពេលភ្ជាមនោះឯង ។ បទថា **ការយំ ព្រហ្មបុរោហិតំ** គឺបានព្ចថា ទេវបុត្រទាំង

នោះ នាំគ្នាគិតថា ដែលឈ្មោះថា ពួកអ្នករបាំ ដែលរាំច្រៀង លេងភ្លេងតន្ត្រី មកហើយ ក៏ត្រូវបានតម្លៃជារង្វាន់ ចំណែកគោបកទេវបុត្រនេះ តាំងពីពេល ដែលអញឃើញ គិតតែផ្ទុះប្រែះៗ ដូចយកអំបិលជាក់ក្នុងជើងក្រាន នេះតើ មានរឿងអ្វីហ្ន៎ កាលពិចារណាតទៅ ក៏ឃើញថា ខ្លួនជាសមណៈ មានសីល បរិសុទ្ធ បានឈាន និងជាអ្នកទទួលបាត្រប្រចាំត្រកូលរបស់គោបកទេវបុត្រ នោះផង ហើយបានដឹងថា ធម្មតាអ្នកមានសីលបរិសុទ្ធ រមែងជ្រើសរើស កើតក្នុងទេវលោកទាំង ៦ ជាន់បាន អ្នកបានឈាន រមែងកើតក្នុងព្រហ្មលោក (តែ) ពួកយើង ទាំងក្នុងទេវលោកជាន់ខ្ពស់ ទាំងក្នុងព្រហ្ម មិនបានកើតទេ គោបកទេវបុត្រនេះ ធ្លាប់ជាស្ត្រី តាំងនៅក្នុងឱវាទរបស់ពួកយើងគង់ក្នុងទី ខ្ពស់បាន ពួកយើងជាភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសម្នាក់ព្រះមានព្រះភាគ កើតក្នុងពួកគន្ធព្វដែលថោកទាប ហេតុនោះ ទើបគោបកទេវបុត្រនេះ សង្កត់ សង្កិនពួកយើងយ៉ាងនេះបាន ទើបបានព្រមស្តាប់ពាក្យរបស់គោបកទេវបុត្រ នោះ។ ក្នុងទេវតាទាំង ៣ អង្គនោះ ពីរអង្គ ត្រឡប់បានស្មារតីដល់ឈានទី ១ យកឈានជាបាទ ហើយក៏ពិចារណាសង្ខារ តាំងនៅក្នុងអនាគាមិផលទុំៗឯង។ ពេលនោះ អត្តភាពដែលត្រាច់អន្ទោលក្នុងកាម ដែលមានសភាពបន្តិចបន្តួច របស់ពួកលោកទាំងនោះ តាំងនៅមិនញាប់ញ័រ មួយរំពេចនោះឯង លោកក៏ ឃ្លាតទៅកើតក្នុងជាន់ព្រហ្មបុរោហិត និងកាយរបស់ពួកគន្ធព្វទាំងនោះ ដែល នៅក្នុងជាន់ព្រហ្មបុរោហិតនោះ ក៏កើតហើយ ព្រោះហេតុនោះ ទើបសក្កទេវរាជ ត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន បណ្តាទេវតាទាំង ៣ នាក់ ដែលគោបក-

ទេវបុត្រ និយាយរម្ងឹកជាសំតៀននោះ ទេវតាពីរនាក់ ក៏ត្រឡប់បានស្មារតី ប្រកបដោយឈាន ក្នុងបច្ចុប្បន្ន (លុះច្យុតចាកអត្តភាពនោះហើយ) ក៏បានន្ទូវកាយជាព្រហ្មបុរោហិត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឯដ្ឋេ វ ឆម្ភេ** *គឺត្រឡប់បានស្មារតីក្នុងអត្តភាពនោះឯង គប្បីឃើញអធិប្បាយក្នុងបទនោះយ៉ាងនេះថា នៅក្នុងទីនោះៗ ឯង ។ ចុតិហើយ ត្រឡប់បានកាយជាព្រហ្មបុរោហិត គឺសរីរៈជាព្រហ្មបុរោហិត ។ បទថា* **ឃកោ បន ឧរោ** *គឺទេវបុត្រម្នាក់ ទម្ងាយភាពជាប់ចិត្តមិនទាន់បាន ក៏នៅគ្រប់គ្រងកាម គឺនៅប្រចាំ គឺអាស្រ័យនៅក្នុងកាមាវចរភពទុំ៎ះឯង ។*

[๙๑] *បទថា* **សង្ឃញ្ចុបដ្ឋាសឺ** *គឺបានទំនុកបម្រុងសង្ឃផង ។ បទថា* **សុធម្មតាយ** *គឺដោយភាពដែលព្រះធម៌ជាធម៌ល្អ ។ បទថា* **តិទិវូបបន្នោ** *គឺកើតក្នុងត្រៃត្រឹង្ស បានដល់ តាវត្តិង្សបុរី ។ បទថា* **គន្ធព្វកាយូបគតេ វសិនេ** *គឺជាអ្នកចូលទៅនៅអាស្រ័យក្នុងពួកគន្ធព្វ ។ បទថា* **យេ ច មយំ បុព្វេ មនុស្សភូតា** *គឺកាលមុននេះ ពួកយើងជាមនុស្ស ។ គប្បីប្រកបនឹងពាក្យនេះថា ខ្ញុំទំនុកបម្រុង ដោយបាយទឹកហើយជ្រាបអត្ត ។ បទថា* **ចាតុបសង្គយ្ហ** *គឺចូលទៅជិតជើងហើយផង បូជាដោយការលាងជើងផង ការលាបជើងផង ថ្វាយបង្គំទៀបជើងផង ។ បទថា* **សកេ ឯវេសនេ** *គឺក្នុងផ្ទះរបស់ខ្លួន ។ ចំពោះបទនេះ ក៏ត្រូវយកទៅភ្ជាប់នឹងបទថា* **ឧបដ្ឋហិម្ហា** *នេះដូចគ្នា ។ បទថា* **បច្ចត្តំ វេទិតព្ពោ** *គឺគប្បីដឹងបានដោយខ្លួនឯង ។ បទថា* **អរិយានំ សុភាសិតានិ** *គឺ*

សុភាសិតទាំងឡាយរបស់ព្រះមានព្រះភាគ ដែលពួកលោកបានពោល ។ បទ
ថា **តុម្ហេ បន សេដ្ឋមុចាសមានា** *គឺអង្គុយនៅជិតព្រះមានព្រះភាគ ជាបុគ្គល*
ដ៏ឧត្តម ។ បទថា **អនុត្តរេ** *គឺឬក្នុងព្រះពុទ្ធសាសនា ។ បទថា* **ព្រហ្មចរិយំ**
បានដល់ ការប្រព្រឹត្តដ៏ប្រសើរបំផុត ។ បទថា **ភវត្ថូបបត្តិ** *បានដល់ការចូល*
ដល់របស់ពួកលោក ។ បទថា **អាគារេ វសតោ មយ្ហំ** *បានដល់ កាលខ្ញុំនៅ*
ក្នុងផ្ទះ ។ បទថា **ស្វាជ្ជ** *កាត់បទជា* **សោ អជ្ជ** *ប្រែថា គោបកទេវបុត្រនោះ*
ក្នុងថ្ងៃនេះ ។

លោកហៅគោបកៈថា សាវ័កព្រះគោតម ក្នុងទីនេះថា ជាសាវ័កព្រះ
គោតម ។ បទថា **សមេច** *គឺប្រជុំគ្នាហើយ ។ បទថា* **ហន្ទ វិគាឡាម**
វិឡាឡមាម *គឺណ្ហើយចុះ ពួកយើងមកខ្នះខ្នែង ព្យាយាមចុះ ។ បទថា* **នោ**
ក្នុងបទថា **មា នោ មយំ បរបេស្សា អហុម្ហា** *នេះ ត្រឹមតែជាពាក្យជ្រែកចូល*
មកប៉ុណ្ណោះ ។ ឯអត្ថ គឺពួកយើងកុំមកជាអ្នកបម្រើរបស់អ្នកដទៃឡើយ ។
ក្នុងបទថា **គោតមសាសនានិ** *នេះ ដោយប្រក្រតី លោកហៅបឋមជ្ឈាន*
ដែលបានន៎ុះឯងថា ពាក្យប្រៀនប្រដៅរបស់ព្រះគោតម សេចក្តីថា អនុ-
សរណៈ គឺតាមរឭកដល់បឋមជ្ឈាននោះ ។ បទថា **ចិត្តានិ វិរាជយិត្វា** *គឺ*
ប្រាសចាកពួកចិត្តដែលប្រកបដោយកាមគុណ ៥ យ៉ាង ។ បទថា **កាមេសុ**
អាទីនវំ *គឺបានឃើញទោសក្នុងកាមទាំងឡាយ ដោយបឋមជ្ឈាន ព្រោះ*
ដោយអំណាចវិក្ខម្ភណៈ និងដោយអំណាចសមុច្ឆេទ លោកទាំងនោះ បាន

ឃើញទាំងគ្រឿងប្រកប គឺកាម និងគ្រឿងចង គឺកាម ដែលឈ្មោះថា កាម-សញ្ញោជនៈ ដោយមគ្គទី ៣ ។ បទថា **ចាបិមតោ យោគាធិ** *សេចក្តីថា ជាគ្រឿងប្រកប ជាគ្រឿងចងរបស់បុគ្គលមានបាប គឺរបស់មារ ។ បទថា* **ទុរុជ្ឈ-យានិ** *គឺលំបាកនឹងឈានកន្លងទៅបាន ។ បទថា* **សឥន្ទាទេវា សបជាបតីកា** *សេចក្តីថា អ្នកដែលធ្វើព្រះឥន្ទ្រឲ្យជាប្រធាន ហើយចូលទៅ ឈ្មោះថា រួមទាំងព្រះឥន្ទ្រ អ្នកដែលធ្វើបជាបតិទេវរាជឲ្យជាប្រធាន ហើយចូលទៅ ឈ្មោះថា ព្រមទាំងបជាធិបតី ។ បទថា* **សភាយុបវិដ្ឋា** *សេចក្តីថា ចូលទៅអង្គុយក្នុងទីប្រជុំ ។ បទថា* **វីរា** *គឺអ្នកក្លាហាន ។ បទថា* **វិរាគា** *គឺប្រាសចាកតម្រេក ។ បទថា* **វេរដំ ករោន្តា** *គឺធ្វើ បានដល់ ធ្វើអនាគាមិមគ្គដែលមិនមានមន្ទិលឲ្យកើតឡើង ។ បទថា* **ឆាគោវ សព្ពានិ គុណានិ** *កាត់គ្រឿងប្រកប គឺកាម និងគ្រឿងចងបានហើយ ក៏ឈានកន្លងពួកទេវតាជាន់តាវត្តិង្សទៅ ។*

បទថា **សំវេគជាតស្ស** *គឺដល់សក្កទេវរាជ ទ្រង់កើតសេចក្តីសង្វេគ ។ បទថា* **កាមាភិភូ** *គឺដែលទ្រង់គ្របសង្កត់កាមទាំងពីរយ៉ាង ។ បទថា* **សតិយា វេហីនា** *គឺអ្នកវៀរចាកសេចក្តីរឭកដល់ឈាន ។ បទថា* **តិណ្ណំ តេសំ** *គឺក្នុង ៣ នាក់នោះ ។ បទថា* **អាសិនេត្ត ឯកោ** *គឺដែលជាអ្នកកើតនៅក្នុងពួកជាន់ថោកទាបនោះ មានត្រឹមតែម្នាក់ប៉ុណ្ណោះ ។ បទថា* **សម្ពោធិបថានុសារិនោ** *គឺមានប្រក្រតីតាមរឭកដល់អនាគាមិមគ្គ ។ បទថា* **ទេវេបិ ហីឡេន្តិ** *គឺមើលងាយបានដល់ ធ្វើទេវលោកទាំងពីរជាន់ឲ្យធ្លាក់ទាបចុះ ព្រោះភាពដែលខ្លួនតាំងមាំ*

ដោយឧបចារសមាធិ និងអប្បនាសមាធិ ទើបយកធូលី ដែលជាប់ត្រង់ជើងរបស់ខ្ជូន មករោយជាក់ក្បាលពួកទេវតា ដែលហោះទៅក្នុងអាកាស ។ បទថា **ឯតាធិសី ធម្មបកាសនេត្ត** គឺពួកសាវក ជាអ្នកប្រកបព្រមដោយគុណ-សម្បត្តិទាំងនេះ ដែលជាគុណសម្បត្តិរបស់អ្នក ដែលប្រកាសធម៌មានសភាពដូច្នេះ ក្នុងសាសនានេះ ។ បទថា **ន តត្ត កឺ កឌ្ឍតិ កោចិ សាវកោ** គឺក្នុងសាវកទាំងនោះ បុគ្គលណាម្នាក់ សូម្បីសាវកតែមួយអង្គ ក៏មិនសង្ស័យក្នុងព្រះពុទ្ធជាដើម ឬក្នុងភាពជាអ្នកនៅក្នុងទិសទាំង ៤ ជាអ្នកមិនទើសទាក់ មិនប្រកាន់មាំក្នុងទិសទាំងអស់ ។ ឥឡូវនេះ កាលទ្រង់សរសើរព្រះគុណរបស់ព្រះមានព្រះភាគ ទើបត្រាស់ថា សូមនមស្ការព្រះពុទ្ធ ដែលទ្រង់ឆ្ងងអន្ងង់បានហើយ កាត់សេចក្តីសង្ស័យបានហើយ ព្រះអង្គទ្រង់ឈ្នះ ព្រះអង្គជាធំជាងជនដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិចិកិច្ចធិន្ទំ** គឺកាត់សេចក្តីសង្ស័យបានហើយ ។ បទថា **ជនិន្ទំ** គឺទ្រង់ឧត្តមក្នុងលោកទាំងអស់ ។ បទថា **យំ តេ ធម្មំ** គឺធម៌របស់ព្រះអង្គណា ។ បទថា **អជ្ឈតមំសុំតេ** គឺទេវបុត្រទាំងនោះបានសម្រេចហើយ ។ បទថា **កាយំ ព្រហ្មបុរោហិតំ** គឺកាលពួកខ្ញុំព្រះអង្គកំពុងមើលនោះ សរីរៈក្ងាយជាព្រហ្មបុរោហិត ។ មានពាក្យដែលសក្កទេវរាជទ្រង់អធិប្បាយដូច្នេះថា ទេវតាទាំងនោះជ្រាបធម៌របស់ព្រះអង្គណាហើយ ក្នុងទេវបុត្រទាំង ៣ នោះ ទេវបុត្រទាំង ២ អង្គ បានដល់គុណវិសេស ខណៈដែលពួកខ្ញុំព្រះអង្គឃើញទាំងអស់គ្នានោះ ក៏សម្រេចកាយជាព្រហ្មបុរោហិត ហើយបាន

សម្រេចគុណវិសេស គឺ មគ្គផល ម្នាលអ្នកនិទ្ទុក្ខ សូម្បីពួកខ្ញុំព្រះអង្គក៏មក ដើម្បីសម្រេចធម៌នោះ ។ បទថា **អាគតម្ហាបិ** គឺដល់ព្រមហើយ ។ បទថា **ឥតាវកាសា ភគវតា បញ្ហំ បុច្ឆេមុ មារិសា** សេចក្តីថា ប្រសិនបើព្រះមានព្រះភាគ ប្រទានព្រះឱកាសហើយ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ពួកខ្ញុំព្រះអង្គដែលព្រះមានព្រះភាគបានប្រទានព្រះឱកាសហើយ នឹងគប្បីទូលសួរបញ្ហា ។

[៩២] បទថា **ឧីយរត្តំ វិសុទ្ធោ ទោ អយំ សក្ពោ** គឺជាអ្នកបរិសុទ្ធ ល្អចាប់ផ្តើមតាំងពីកាលយូរមកហើយ ។ សួរថា ក្នុងកាលយូរប៉ុនណា ឆ្លើយថា យូរ ចាប់ផ្តើមពីកាលជាមយមាណពជាអ្នកស្រុកមចល: ដែនមគធ: មុនពុទ្ធកាលមកម្ញេះ ។

បានញ្ចថា គ្រានោះ ថ្ងៃមួយ មយមាណពនោះ ក្រោកឡើងពីព្រឹកព្រលឹមហើយ ទៅកាន់កន្ទែងធ្វើការងារប្រចាំក្នុងស្រុក ជាមួយពួកអ្នកស្រុក យកចុងជើងនុ៉ះឯង ក៉ៀរគំនរដី និងសំរាមលាមកចេញទៅ ធ្វើកន្ទែងដែលខ្ជូនឈរឲ្យគួររីករាយ ។ អ្នកដទៃក៏មកឈរក្នុងទីនោះ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះឯង មយមាណពក៏ត្រឡប់បានសេចក្តីរព្រក ទើបកាប់ធ្តារកន្ទែងជារង្វង់ ត្រង់ធ្លាកណ្តាលស្រុក ហើយក៏ជញ្ជូនខ្សាច់មករោយ ជញ្ជូនយកឧសមកបង្កាត់ភ្លើងក្នុងវេលាត្រជាក់ ។ ទាំងកំលោះក្រមុំ និងមនុស្សចាស់ ក៏នាំគ្នាមកអង្គុយក្នុងទីនោះ ។ ថ្ងៃមួយ មាណពកើតគំនិតថា កាលយើងទៅព្រះនគរ ក៏យើញព្រះរាជា និងអ្នករាជការជាអ្នកធំជាដើម អ្នកទាំងឡាយនោះក៏ពោលថា ក្នុងព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ក៏មានទេវបុត្រឈ្មោះចន្ទ ទេវបុត្រ

ឈ្មោះសុរិយៈ ពួកអ្នកទាំងនោះធ្វើអ្វីហ្ន៎ ទើបបានសម្បត្តិទាំងនេះ ។ តមក ទើបគិតបានថា វត្តជនៃណាមិនមាន ត្រូវធ្វើបុណ្យប៉ុណ្ណោះ ហើយគិតថា សូម្បីអញ ក៏ត្រូវធ្វើបុណ្យដែលឲ្យសម្បត្តិយ៉ាងនេះដូចគ្នា ។ ទើបមាណព ក្រោកឡើងអំពីព្រលឹម បរិភោគបបរហើយ ក៏កាន់យកកាំបិត ពូថៅ ចបជីក និងអង្រែទៅត្រង់ផ្លូវធំបែកជា ៤ យកអង្រែគាស់ជុំថ្នឲ្យរបើក ហើយប្រមៀលចេញទៅ យកឈើមកធ្វើជាភ្លៅយាន ពង្រាបទីរាបស្មើ ហើយសាងសាលាត្រង់ផ្លូវធំដែលមានមុំ ៤ ជីកស្រះឈូក ចងស្ពានធ្វើការងារយ៉ាងនេះអស់ ១ ថ្ងៃ រហូតដល់ថ្ងៃលិច ទើបត្រឡប់មកផ្ទះ ។ មានអ្នកជនៃសួរមាណពថា នែ មយៈសម្លាញ់ អ្នកចេញទៅតាំងអំពីព្រឹក ល្ងាចទើបមកពីព្រៃ អ្នកធ្វើការអ្វី មយៈមាណពពោលថា ខ្ញុំធ្វើបុណ្យ សាងផ្លូវទៅសួគ៌ ។ អ្នកស្រុកសួរថា នែសម្លាញ់ឈ្មោះថាបុណ្យនេះ គឺអ្វី មយមាណពឆ្លើយថា លោកមិនដឹងទេឬ អ្នកស្រុកឆ្លើយថា អើខ្ញុំមិនដឹងទេ ។ មយមាណពពោលថា កាលទៅព្រះនគរ ពួកអ្នកធ្លាប់ឃើញពួកព្រះរាជា និងអ្នករាជការ ជាអ្នកធំជាដើមឬទេ អ្នកស្រុក ឆ្លើយថា ធ្លាប់ឃើញ ។ មាណពពោលថា ជនទាំងនោះធ្វើបុណ្យហើយ ទើប បានតំណែងនោះ ខ្ញុំក៏នឹងធ្វើការងារដែលឲ្យសម្បត្តិយ៉ាងនោះខ្លះ អ្នកធ្លាប់ឮ ទេថា ទេវបុត្រឈ្មោះចន្ទ ទេវបុត្រឈ្មោះសុរិយៈ អ្នកស្រុកឆ្លើយថា អើ ខ្ញុំ ធ្លាប់ឮ មយមាណពប្រាប់ថា ខ្ញុំក៏ធ្វើផ្លូវទៅសួគ៌នោះ ។ អ្នកស្រុកពោលថា អើ បុញ្ញកម្មនេះ សមគួរសម្រាប់លោកប៉ុណ្ណោះ ឬសម្រាប់អ្នកជនៃក៏សមគួរ ដែរ មយមាណពឆ្លើយថា បុណ្យនោះ មិនជំទាស់ដល់បុគ្គលទេ អ្នកស្រុក

ពោលថា បើដូច្នោះ ស្អែកនេះ ពេលទៅព្រៃ អ្នកហៅខ្ញុំផង ។ ថ្ងៃស្អែកឡើង មាណពក៏នាំជនទាំងនោះទៅ ។ ដោយប្រការដូច្នេះ ទើបក្នុងពួកអ្នកស្រុកនោះ មានអ្នកនៅក្នុងវ័យក្មេង រួម ៣៣ នាក់ គ្រប់គ្នាសុទ្ធតែប្រព្រឹត្តទៅតាមមមាយ-មាណពទាំងអស់ ។ ពួកជនទាំងនោះ ធ្វើបុណ្យដោយមានឆន្ទៈតែមួយ កាលពង្រាបផ្លូវឲ្យរាបស្មើ ក៏ពង្រាបមួយថ្ងៃប៉ុណ្ណោះ កាលជីកស្រះឈូកក្តី សាងសាលាក្តី សាងស្ពានក្តី ក៏សម្រេចក្នុងមួយថ្ងៃប៉ុណ្ណោះ ។ បន្ទាប់មក មេស្រុករបស់ពួកជនទាំងនោះ គិតថា ពីមុន កាលជនទាំងនេះនៅផឹកស្រា និងនៅសម្លាប់សត្វជាដើម អញ្ជើរមែងបានទ្រព្យដោយអំណាចកហាបណៈបន្តិចបន្តួចជាដើមខ្លះ ដោយអំណាចកាសុខ្លះ ឥឡូវនេះ តាំងពីជនទាំងនេះធ្វើបុណ្យ ចំណូលទាំងនោះក៏អស់ទៅ ណ្ហើយចុះ អញនឹងបំផ្លាញជនទាំងនេះក្នុងរាជត្រកូល ទើបចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ ទូលបង្គំជួបក្រុមចោរ ព្រះរាជាត្រាស់ថា នែបា ជួបឯណា មេស្រុកពោលថា បពិត្រព្រះអង្គ ក្នុងស្រុកខ្ញុំ ។ ព្រះរាជាត្រាស់ថា នែបា ចោរប្រភេទណា មេស្រុកឆ្លើយថា បពិត្រព្រះអង្គ ប្រភេទធ្វើខុសចំពោះព្រះរាជា ។ ព្រះរាជាត្រាស់ថា ចោរទាំងនោះមានជាតិអ្វី មេស្រុកឆ្លើយថា បពិត្រព្រះអង្គ មានជាតិជាអ្នកស្រុក ។ ព្រះរាជាត្រាស់ថា អ្នកស្រុកនឹងធ្វើអ្វីបាន កាលបើអ្នកដឹងដូច្នោះ ហេតុអ្វី ទើបមិនប្រាប់យើង មេស្រុកឆ្លើយថា បពិត្រមហារាជ ដែលមិនបានក្រាបទូល ព្រោះខ្លាចព្រះអាជ្ញា ឥឡូវនេះ សូមព្រះអង្គកុំគប្បីដាក់ព្រះអាជ្ញាដល់ទូលបង្គំ ។ គ្រានោះ ព្រះរាជាទ្រង់គិតថា មេស្រុកនេះបន្ទឺសំឡេងខ្លាំងៗ ទើបទ្រង់ជឿ ហើយ

ត្រាស់ថា បើដូច្នោះ ចូរអ្នកទៅនាំពួកចោរទាំងនោះមក ហើយក៏ប្រទានកម្ចាំង បញ្ជូនទៅ ។ មេស្រុកនោះក៏ទៅព័ទ្ធចាប់ពួកជនទាំងនោះ ខណៈដែលកំពុងធ្វើការងារប្រចាំថ្ងៃក្នុងព្រៃស្រេចហើយ អង្គុយទទួលទានអាហារល្ងាច ត្រង់កណ្តាលស្រុក ដែលកំពុងប្រឹក្សាគ្នាថា ស្អែកនេះ ពួកយើងនឹងធ្វើការងារអ្វី នឹងពង្រាបផ្លូវឲ្យស្មើ នឹងជីកស្រះ ឬនឹងចងស្ពាន ហើយស្រែកសន្ធាប់ទៅថា កុំកម្រើក នេះជារាជបញ្ជា ហើយចងបណ្តើរទៅ ។ លំដាប់នោះ ពួកស្ត្រីជាប្រពន្ធរបស់អ្នកទាំងនោះ បានឮថា ស្វាមីរបស់ពួកខ្លួនជាចោរក្បត់ចំពោះព្រះរាជា ដែលមេស្រុកចោទថាជាចោរ ហើយចងបណ្តើរទៅ ទើបពោលថា ជនទាំងនេះ ប្រព្រឹត្តអាក្រក់មកយូរហើយ មួយថ្ងៃៗ មានតែនិយាយថា ធ្វើបុណ្យៗ ហើយក៏ទៅព្រៃតែម្យ៉ាង ការងារគ្រប់យ៉ាងក៏វិនាសអស់ ក្នុងផ្ទះនឹងរកអ្វីតែបន្តិចក៏គ្មាន ចូរចងឲ្យល្អ នាំទៅឲ្យល្អ ។ មេស្រុកក៏នាំពួកជនទាំងនោះ ទៅបង្ហាញដល់ព្រះរាជា ។ ព្រះរាជាទ្រង់មិនទាន់បានសាកសួរ ក៏ត្រាស់ថា ចូរឲ្យដីរព្រេច ។ កាលពួកជនទាំងនោះត្រូវនាំទៅ មឃៈនិយាយនឹងអ្នកដទៃថា នែសម្លាញ់ ពួកអ្នកនឹងធ្វើតាមពាក្យរបស់ខ្ញុំបានទេ អ្នកស្រុកឆ្លើយថា កាលធ្វើតាមពាក្យរបស់អ្នកនុ៎ះឯង ទើបពួកយើងដល់នូវភ័យ ដូច្នោះ ណ្ហើយចុះ យើងក៏នៅធ្វើតាមពាក្យរបស់អ្នក តើអ្នកឲ្យពួកខ្ញុំធ្វើអ្វី ។ មឃមាណពោលថា នែសម្លាញ់មកចុះ នេះជាទោសរបស់វដ្តៈ តើពួកអ្នកជាចោរឬ ។ អ្នកស្រុកឆ្លើយថា ពួកយើងមិនមែនជាចោរទេ ។ មឃមាណពន្យល់ថា ឈ្មោះថា សច្ចកិរិយាជាទីពឹងរបស់សត្វលោក ដូច្នោះ បើពួកយើងទាំងអស់

ជាចោរ សូមឲ្យដីរព្រេចចុះ បើមិនមែនជាចោរ ចូរកុំព្រេចឡើយ ចូរពួកអ្នកធ្វើសច្ចកិរិយា ដូច្នេះ ។ ពួកជនទាំងនោះ ក៏បានធ្វើយ៉ាងនោះ ។

ដីរសូម្បីតែចូលជិតក៏មិនបាន ស្រែកបណ្តើរ រត់គេចបណ្តើរ សូម្បីនឹងយកដែកស្រួច លំពែង និងកង្វេរចាក់យ៉ាងណា ក៏បញ្ឈប់មិននៅ ។ ទើបពួកហ្មដីរ ទៅក្រាបទូលព្រះរាជាថា ពួកទូលបង្គំដេញដីរ ចូលទៅជិតមិនបាន ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរយកកន្ទេលផែងគ្របបិទបាំងខាងលើពួកវា ហើយឲ្យជាន់ពួកវា ។ កាលគ្របកន្ទេលផែងខាងលើហើយ ដីរក៏ស្រែកយ៉ាងខ្លាំងជាលើកទីពីរ ហើយក៏រត់គេចចេញទៅ ។ ព្រះរាជាទ្រង់ស្តាប់ហើយ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកញុះញង់មក ហើយត្រាស់ថា នែបា ដីរវាមិនព្រមជាន់ ។ មេស្រុកទូលថា បពិត្រព្រះអង្គ មាណពដែលជាប្រធានចេះមន្តន៎ុះជាអានុភាពរបស់មន្តដោយពិត ។ ព្រះរាជា ទ្រង់ត្រាស់បង្គាប់ឲ្យមាយ-មាណពនោះចូលគាល់ ហើយត្រាស់សួរថា បានឮថា ឯងមានមន្តឬ មាយ-មាណពពោលថា ទូលបង្គំមិនមានមន្តឡើយ តែពួកទូលបង្គំបានធ្វើសច្ច-កិរិយាថា បើពួកខ្ញុំជាចោររបស់ព្រះរាជា សូមឲ្យដីរព្រេចចុះ បើមិនមែនជាចោរ ដីរកុំព្រេចឡើយ នេះជាអំណាចរបស់សច្ចកិរិយារបស់ពួកទូលបង្គំ ។ ព្រះរាជាត្រាស់ថា ចុះពួកអ្នកធ្វើការងារអ្វី មាយមាណពទូលថា ទូលបង្គំពង្រាបផ្លូវដែលរដិបរដុបឲ្យរាបស្មើ សាងសាលាក្នុងផ្លូវធំដែលមានមុំ ៤ ជីកស្រះឈូក ចង់ស្តាន សូមទ្រង់មេត្តាជ្រាប ពួកខ្ញុំព្រះអង្គ ត្រាច់សាងបុញ្ញកម្មបែបនេះ ។ ព្រះរាជាត្រាស់ថា មេស្រុកមួលបង្កាច់ពួកអ្នកដើម្បីអ្វី ។ មាយ-

មាណពទូលថា កាលពួកទូលបង្គំប្រមាទ មេស្រុកវមែងបានវត្តនេះ និងវត្តនេះ ពេលមិនប្រមាទ វត្តនោះក៏មិនមាន ដោយហេតុនេះ ទើបញុះញង់ ។ ព្រះរាជាត្រាស់ថា នែបា ជីវនេះជាសត្វតិរច្ឆាន ក៏គង់ជីងគុណរបស់ពួកអ្នក តែទុំជាមនុស្សក៏មិនជីង ទុំសូមលើកលែងស្រុកដែលជាទីនៅរបស់ពួកអ្នកជា ស្រុករួចផុតពន្ធដល់ពួកអ្នក ជីវនេះ ក៏ចូរជារបស់ពួកអ្នក ដូចគ្នាចំណែកអ្នក មួលបង្កាច់ សូមប្រគល់ឲ្យជាទាស:របស់ពួកអ្នកចុះ តាំងពីនេះទៅ ចូរពួកអ្នកធ្វើបុណ្យដើម្បីទុំខ្ញុះ ត្រាស់ហើយ ក៏ព្រះរាជទានទ្រព្យឲ្យ ហើយក៏ដោះលែងទៅ ។ ពួកជនទាំងនោះទទួលទ្រព្យហើយ ក៏ផ្ញាស់វេនគ្នាឡើងជីវទៅបណ្តើរ ប្រឹក្សាគ្នាថា នែសម្លាញ់ ធម្មតាបុញ្ញកម្ម ជារបស់ដែលត្រូវធ្វើ ដើម្បីប្រយោជន៍នៃភពក្នុងអនាគត ព្រោះបុណ្យនោះ របស់ពួកយើងឲ្យផលក្នុងអត្តភាពនេះឯង ដូចឧប្បលខៀវដែលចេញផ្កា ចេញផ្លែខាងក្នុងទឹក ឥឡូវនេះពួកយើងនឹងធ្វើបុណ្យឲ្យក្រៃលែង ។ អ្នកស្រុកសួរថា ពួកយើងនឹងធ្វើអ្វី មឃមាណពពោលថា យើងធ្វើថាវវត្តុ ក្នុងផ្លូវធំមានមុំ ๔ ហើយសាងសាលាសម្នាក់របស់មហាជន ។ តែពួកស្ត្រីមិនត្រូវឲ្យមានចំណែក ព្រោះកាលពួកយើងត្រូវមេស្រុកចោទថាជាចោរចាប់នាំទៅ ពួកស្ត្រីសូម្បីតែម្នាក់ ក៏មិនធ្វើសូម្បីតែមានចិត្តឈឺឆ្អាល មានតែពោលផ្តាលថា ចងឲ្យល្អ ចាប់ឲ្យល្អ ព្រោះដួច្នោះ ពួកយើងមិនចាំបាច់ឲ្យស្ត្រីទាំងនោះ មានចំណែកឡើយ ។ ពួកជនទាំងនោះ ក៏នាំគ្នាទៅផ្ទះរៀងៗ ខ្លួន ឲ្យបាយ ๓๓ ដុំ ឲ្យស្មៅ ๓๓ បាច់ដល់ជីវ ។ ទាំងអស់នោះក៏ពេញពោះជីវ ។ ពួកជនទាំងនោះចូលព្រៃកាត់ឈើ ។ ជីវក៏

អូសយកឈើដែលកាត់ហើយ មកជាក់ត្រង់ផ្លូវនេះ ។ ពួកជនទាំងនោះ ក៏នាំគ្នាចាំងឈើ ផ្តើមសាងសាលា ។

មឃមាណព មានភរិយានៅក្នុងផ្ទះ ៤ នាក់ គឺនាងសុជាតា នាងសុធម្មា នាងសុចិត្រា នាងសុនន្ទា ។ នាងសុធម្មា សួរជាងឈើថា បពិត្រលោកឪពុក ពួកសម្ងាញ់ទាំងនេះ ព្រឹកក៏ទៅ ល្ងាចទើបមក ពួកគេធ្វើការងារអ្វី ។ ជាងឈើពោលថា ពួកគេធ្វើសាលា ។ នាងសុធម្មាពោលថា បពិត្រលោកឪពុក សូមលោកជួយធ្វើឲ្យខ្ញុំមានចំណែកក្នុងសាលាផងចុះ ។ មេជាងពោលថា ពួកសម្ងាញ់ទាំងនោះពោលថា ពួកយើង នឹងមិនព្រមឲ្យពួកមនុស្សស្រីមានចំណែក ។ នាងបានឲ្យប្រាក់ជាងឈើ ៨ កហាបណៈ ដោយនិយាយថា បពិត្រលោកឪពុក សូមលោកយកប្រាក់នេះ ហើយជួយរកឧបាយឯណានីមួយ ធ្វើឲ្យខ្ញុំមានចំណែកផងចុះ ។ មេជាងពោលថា សាធុ ហើយក៏កាន់យកកាំបិត និងយកពូថៅយ៉ាងរហ័ស ទៅឈរកណ្តាលស្រុក ស្រែកសំឡេងខ្លាំងៗ ថា នែអ្នកទាំងឡាយ ថ្ងៃនេះ វេលាថ្មើរនេះហើយ មិនទាន់ចេញទៅទៀតឬ ដឹងថា ទ្បើងកាន់ផ្លូវអស់ហើយ ទើបពោលថា សូមពួកអ្នកដើរទៅមុន ខ្ញុំមានការចាំបាច់ត្រូវពន្យា ហើយក៏ឲ្យអ្នកទាំងនោះទៅមុន ហើយដើរទៅផ្លូវដទៃ កាប់ឈើសម្រាប់ ប្រើជារោងជាង ចាំងស្រេចហើយ ជញ្ជូនមកទុកត្រង់ផ្ទះនាងសុធម្មា ប្រាប់នាងថា នាងគប្បីឲ្យជញ្ជូនចេញទៅបាន ក្នុងថ្ងៃដែលខ្ញុំប្រាប់ថា ចូរឲ្យចុះ ។

បន្ទាប់មក កាលសម្រេចការងារដែលទាក់ទងនឹងគ្រឿងធ្វើសាលា និង

កាលធ្វើគ្រឿងចងត្រង់ទីតោង ការលើកសរសរ ការប្រកបធ្នឹម និងទីភ្ជាប់ ហោជាង តាំងពីពង្រាបផែដីស្រេចហើយ ជាងឈើនោះ ក៏អង្គុយក្នុងទី សម្រាប់ជាក់ហោជាង ឲ្យលើកបង្គន់ទាំង ៤ ទិស ពោលថា ឱ ក្លែចរបស់ មួយទៅហើយ ។ ពួកជនទាំងនោះសួរថា តើអ្នកមានក្លែចអ្វីខ្លះទេ មេជាង ឆ្លើយថា ក្លែចទាំងអស់នោះឯង ។ ពួកជនទាំងនោះសួរថា យកបង្គន់ទាំងនេះ ទៅជាក់ត្រង់ណា មេជាងពោលថា ទាល់តែមានហោជាងសិន ។ ជនទាំងនោះ សួរថា នែអ្នក ឥឡូវនេះ យើងអាចបានអំពីទីណា មេជាងពោលថា អាច បានក្នុងផ្ទះនៃត្រកូលទាំងឡាយ សាកដើរសួរមើលចុះ ។ ពួកជនទាំងនោះ ក៏ ចូលទៅសួរក្នុងស្រុក ហើយមកឈរត្រង់ទ្វារផ្ទះនាងសុធម្មា សួរថា ក្នុងផ្ទះ នេះមានហោជាងដែរឬទេ នាងសុធម្មាពោលថា មាន ។ ជនទាំងនោះពោល ថា សូមទទួលតម្លៃចុះ នាងពោលថា ខ្ញុំមិនទទួលទេ បើពួកលោកព្រមឲ្យ ខ្ញុំមានចំណែកផង ខ្ញុំនឹងឲ្យ ។ ពួកជនទាំងនោះពោលថា ពួកយើងមិនព្រម ឲ្យ មនុស្សស្រីមានចំណែកឡើយ ពួកយើងនឹងទៅព្រៃ ហើយកាត់ឈើ ថា ហើយ ក៏នាំគ្នាចេញទៅ ។ តពីនោះ ពួកជនទាំងនោះ កាលត្រូវជាងឈើ សួរថា យ៉ាងម៉េចទៅហើយ បានហោជាងឬទេ ជនទាំងនោះក៏ប្រាប់សេចក្តី នោះ ។ ជាងឈើអង្គុយនៅត្រង់ទីជាក់ហោជាងដូចមុន ងើយសម្លឹងមើល អាកាស ហើយនិយាយថា អ្នកដ៏ចម្រើន ថ្ងៃនេះ ឫក្សល្អ បើហួសឫក្សនេះ ហើយ ឆ្នាំក្រោយទើបមានឫក្សល្អទៀត ឯពួកអ្នក បើកាប់ឈើយកមក ឈើទាំងនោះ ត្រូវយកមកគរទុកអស់ ១ ឆ្នាំនឹងពុកផុយក្នុងទីនេះឯង ណ្ហើយ

ចុះ កើតក្នុងទេវលោក ក៏ចូរព្រមឲ្យសាលាមួយជ្រុងដល់នាងចុះ ចូរយកហោជាងនោះមក ។ នាងសុធម្មានោះ រៀលាដែលពួកជនទាំងនោះមិនទាន់មកម្តងទៀត បានប្រាប់ឲ្យឆ្លាក់អក្សរថា សាលាមួយខ្នងនេះ ឈ្មោះសុធម្មា ទុកត្រង់ផ្ទៃក្រោមហោជាង ហើយយកសំពត់ថ្មីមកវុំទុក ។ កាលជនទាំងនោះមកហើយ ពោលថា ជួយនាំយកហោជាងមកចុះ នាងនឹងបានចំណែកជួមជាមួយពួកយើង ។ នាងក៏នាំចេញមកប្រាប់ថា អ្នកទាំងឡាយ កុំយកសំពត់នេះចេញ ដរាបដល់ជាងមិនទាន់ដាក់បង្គងបាន ៨ ឬ ១៦ កំណាត់មុន ហើយក៏ឲ្យទៅ ។ ជនទាំងនោះក៏ទទួលថា សាធុ កាលលើកបង្គងឡើងស្រេចហើយ ក៏យកសំពត់ចេញ ។ សម្ងាញ់ម្នាក់ ងើយមុខឡើងខាងលើ ឃើញអក្សរទើបនិយាយថា នេះជាអ្វី ហើយឲ្យទៅតាមអ្នកដែលចេះអានអក្សរមកឲ្យអាន ។ ជននោះក៏អានថា សាលាមួយខ្នងនេះឈ្មោះសុធម្មា ។ ពួកជនទាំងនោះក៏ស្រែកឡើងថា យកចេញ តាំងពីដើមមក កាលសាងសាលា ពួកយើងមិនបានសូម្បីតែឈ្មោះ នាងនេះគ្រាន់តែយកឈើហោជាងត្រឹមតែមួយហត្ថមកជាក់ ហើយធ្វើសាលាឲ្យជាឈ្មោះរបស់ខ្លួន ។ កាលពួកជនទាំងនោះកំពុងស្រែកនោះឯង ជាងឈើក៏ស៊កបង្គង់ ហើយជំគន្ធីះ ដែលជាការសម្រេចក្នុងការសាងសាលា ។ ជនទាំងនោះបែងចែកសាលាជា ៣ ចំណែក គឺ ១ ចំណែក ធ្វើជាទីសម្រាកពួកមនុស្សចាស់ៗ ១ ចំណែក សម្រាប់ពួកអ្នកក្រលំបាក ១ ចំណែកទៀត សម្រាប់អ្នកជំងឺ ។ ៣៣ នាក់ ក្រាលក្តា ៣៣ ផ្ទាំង ហើយឲ្យសញ្ញាដំរីថា អាគន្តុកៈមកអង្គុយលើក្តារបស់អ្នកណា ចូរនាំអ្នកនោះ

ឯង ទៅកាន់ត្រង់ផ្ទះ របស់ម្ចាស់ក្តារនោះចុះ ឲ្យការច្រចាប់ជើង ឲ្យការគក់ខ្នង របស់ទំពាបស់ស៊ី និងទីដេក ទាំងអស់ដល់អាគន្តុកៈនោះ នឹងជាការៈរបស់ ម្ចាស់នៃសន្ទឹកក្តារនោះឯង ។ ជីវកក៏នាំក្មៀវ ដែលមកហើយ នាំទៅកាន់ផ្ទះ របស់ម្ចាស់ក្តារនោះឯង ។ ថ្ងៃនោះ ម្ចាស់របស់ក្តារនោះ ក៏រៀបចំវត្ថុដែលគប្បី ធ្វើដល់ក្មៀវនោះ ។

ក្នុងទីមិនឆ្ងាយសាលា មយមាណពដាំដើមរលួសផ្អុង ។ ត្រង់គល់ ឈើនោះក្រាលផ្ទាំងថ្ម ។ សូម្បីកវិយារបស់មាណព ដែលឈ្មោះសុនន្ទា ក៏ឲ្យ ជីកស្រះឈូកក្នុងទីជិតសាលានោះ ។ នាងសុចិត្រា ដាំឈើដែលមានផ្កា ។ ចំណែកប្រពន្ធដើមយកតែកញ្ចក់ទ្រនំ តាក់តែងរាងកាយប៉ុណ្ណោះ ។ មយ-មាណពពោលនឹងនាងថា នែនាង នាងសុធម្មា មានចំណែកនៃសាលា នាង សុនន្ទា ជីកស្រះឈូក ឯនាងសុចិត្រា ដាំឈើដែលមានផ្កា ចំណែកនាងមិន ទាន់មានបុញ្ញកម្ម ចូរនាងធ្វើបុណ្យឯណាមួយចុះ ។ នាងឆ្លើយថា អ្នកធ្វើព្រោះ ហេតុអ្នកណា អ្នកធ្វើក៏ដើម្បីខ្ញុំដូចគ្នាមិនមែនឬ ។ ហើយក៏ជំពាក់ចិត្តនឹងការ តាក់តែងខ្លួនតែម្យ៉ាង ។

កាលមយមាណព រស់នៅដរាបដល់អស់អាយុហើយ ក៏ចុតិចាកមនុស្ស លោកនោះ ទៅកើតជាសក្កទេវរាជក្នុងឋានតាវត្តិង្ស ។ ឯសម្ភាញ់ទាំង ៣៣ នាក់ ស្លាប់ហើយ ក៏កើតជាទេវបុត្រ ៣៣ អង្គ ក្នុងសម្នាក់របស់សក្កទេវរាជ នោះឯង ។ ប្រាសាទឈ្មោះវេជយ័ន្តរបស់សក្កទេវរាជ ផុសឡើងមានកម្ពស់

๗๐๐ យោជន៍ ទង់ផ្ទុសទ្បើងកម្ពស់ ๓๐๐ យោជន៍[๑] ។ ដោយផលរបស់ដើមរលួសផ្អុង ក៏កើតជាដើមបារិច្ឆត្តកៈ មានបរិមណ្ឌលដោយជុំវិញ ๓๐๐ យោជន៍ ទទឹង ๑๕ យោជន៍ ។ ដោយផលនៃផ្ទាំងថ្ម កើតជាថ្មដូចសំពត់រោមសត្វពណ៌លឿង ๖๐ យោជន៍ ត្រង់គល់បារិច្ឆត្តកៈ ។ ដោយផលនៃហោជាងរបស់នាងសុធម្មា ទេវសភាក៏កើតទ្បើង កម្ពស់ ๓๐๐ យោជន៍ ។ ដោយផលនៃស្រះឈូករបស់នាងសុនន្ទា ស្រះឈូកឈ្មោះនន្ទាក៏កើតទ្បើងទំហំ ๕๐ យោជន៍ ។ ដោយផលនៃសួនផ្ការបស់នាងសុចិត្រា ឧទ្យានឈ្មោះចិត្តលតាវ័នក៏កើតទ្បើងទំហំ ๖๐ យោជន៍ ។

សក្កទេវរាជ ជាស្តេចនៃទេវតា ប្រថាប់លើបល្ល័ង្កមាស ๑ យោជន៍ ក្នុងសុធម្មាទេវសភា ក្រោមស្វេតច្ឆត្រ ๓ យោជន៍ ចោមរោមទៅដោយទេវបុត្រទាំងនោះ ដោយទេពធីតាទាំងនោះ ដោយអ្នករបាំ ๒ កោដិកន្លះ និងដោយពួកទេវតាក្នុងទេវលោកពីរជាន់ កាលត្រួតមើលមហាសម្បត្តិ ទ្រង់ឃើញស្ត្រីទាំង ๓ នាក់នោះ ទ្រង់ឃើញថា ស្រី ๓ នាក់នេះប្រាកដ តើនាងសុជាតានៅទីណា ទ្រង់ឃើញថា នាងទៅកើតជាកុកញី ត្រង់ញកក្នុ ព្រោះមិនព្រមធ្វើតាមពាក្យអញ ហើយទ្រង់ចុះចាកទេវលោក យាងទៅកាន់សម្នាក់កុកញីនោះ ។ ពេលកុកនោះឃើញប៉ុណ្ណោះឯង ក៏ចាំបាន ហើយឱនមុខ ។ ទើបសក្កទេវរាជត្រាស់ថា នែស្រីល្ងង់ ឥឡូវនេះ ម្តេចក៏មិនងើបមុខទ្បើង នាងមិនធ្វើតាមពាក្យរបស់អញ គិតតែតែងខ្ជិនឲ្យពេលវេលាកន្លងទៅ សម្បត្តិដ៏ធំ

๑- រួមកម្ពស់ប្រាសាទ និងទង់ត្រូវជា ๑๐๐๐ យោជន៍ ។

កើតហើយដល់នាងសុធម្មា នាងសុនន្ទា និងនាងសុចិត្រា មកនាង ចូរមើលសម្បត្តិរបស់ពួកយើងចុះ ហើយទ្រង់ក៏នាំទៅកាន់ទេវលោក ទ្រង់លែងក្នុងស្រះឈូកឈ្មោះនន្ទា ហើយទ្រង់គង់លើបល្ល័ង្ក ។ ពួកស្រីរបាំក្រាបទូលសួរថា បពិត្រមហារាជ ទ្រង់យាងទៅណា ព្រះឥន្ទ្រទោះបីមិនចង់ប្រាប់ កាលត្រូវទេពអប្សរទាំងនោះបៀតបៀនហើយ ក៏ត្រាស់ថា យើងទៅកាន់សម្នាក់នាងសុជាតា ។ ស្រីរបាំសួរថា បពិត្រមហារាជ នាងកើតក្នុងទីណា សក្កទេវរាជត្រាស់ថា ត្រង់ញាកភ្នំ ។ ស្រីរបាំសួរថា ឥឡូវនេះនៅទីណា ព្រះឥន្ទ្រឆ្លើយថា យើងលែងត្រង់ស្រះឈូក ឈ្មោះនន្ទា ។ ស្រីរបាំពោលថា មកអ្នកជ័ចម្រើនពួកយើងទៅមើលម្ចាស់របស់ពួកយើង ហើយក៏នាំគ្នាទៅក្នុងទីនោះ ។ នាងសុជាតានោះ អំពីមុនមក ប្រកាន់ខ្លួនថា ជាធំជាងគេទាំងអស់ ។ ឥឡូវនេះ ត្រឹមតែពួកស្រីរបាំ កាលឃើញកុកនោះ ក៏នាំគ្នានិយាយចំអកឡកឋថា មើលចុះគ្នាយើង មាត់ម្ចាស់ពួកយើងដូចជាច្បុកចាក់ក្តាម ។ កុកញីកើតសេចក្តីតូចចិត្តហួសប្រមាណ ទើបទូលសក្កទេវរាជថា បពិត្រមហារាជ វិមានមាស វិមានប្រាក់ ឬនន្ទាបោក្ខរណីទាំងនេះ នឹងធ្វើអ្វីដល់ខ្ញុំ បពិត្រមហារាជ កូមិកំណើតប៉ុណ្ណោះឯង ដែលជាសុខរបស់ពួកសត្វ សូមទ្រង់លែងខ្ញុំ ត្រង់ជើងភ្នំនោះវិញចុះ ។ សក្កទេវរាជទ្រង់លែងនាងត្រង់ទីនោះ ហើយត្រាស់ថា នាងធ្វើតាមពាក្យរបស់យើងទេ ។ កុកញីពោលថា ខ្ញុំនឹងធ្វើតាម ។ ទើបសក្កទេវរាជ ត្រាស់ថា ចូរនាងទទួលសីល ៥ រក្សាកុំឲ្យជាប់ មិនប៉ុន្មានថ្ងៃ យើងនឹងធ្វើនាងឲ្យធំជាងស្រីទាំងនោះ ។ កុកញីក៏បានធ្វើយ៉ាងនោះ ។ កន្ទងទៅបាន

๒-๓ ថ្ងៃ សក្កទេវរាជគិតថា កុកញ្ជីរក្សាសីលបានឬទេហ្ន៎ ទើបកាឡាខ្លួនជា
ត្រីផ្ងារពោះ អណ្តែតលើទឹកខាងមុខកុកញ្ជី ។ កុកញ្ជីគិតថា នេះជាត្រីងាប់
ទើបចឹកត្រង់ក្បាល ។ ត្រីកម្រើកកន្ទុយ ។ កុកញ្ជីគិតថា ប្រហែលជាត្រីនៅ
រស់ហើយក៏លែងក្នុងទឹកទៅ ។ សក្កទេវរាជឈរត្រង់អាកាសត្រាស់ថា សាធុ
សាធុ នាងរក្សាសិក្ខាបទបាន យើងនឹងធ្វើនាងដែលរក្សាបានយ៉ាងនេះ ឲ្យជា
ប្រធានរបស់ពួកស្រីរបាំ ដោយមិនយូរឡើយ ។ កុកញ្ជីមានអាយុ ៥០០ ឆ្នាំ ។
សូម្បីតែមួយថ្ងៃ ក៏មិនបានអាហារពេញគែ សូម្បីនឹងស្ងួតហួតហែងក្រៀម
ក្រោះអស់កម្លាំងក៏ដោយ ក៏មិនធ្វើឲ្យសីលដាច់ កាលស្លាប់ហើយ ក៏កើតក្នុង
ផ្ទះស្នូនឆ្នាំង ក្នុងក្រុងពារាណសី ។ សក្កទេវរាជកាលទ្រង់ប្រមើលមើលថា
កុកញ្ជីកើតក្នុងទីណាហ្ន៎ ទ្រង់ក៏ឃើញហើយ គិតថា អញនឹងនាំនាងមកទីនេះ
ពីទីនោះមិនបាន អញនឹងឲ្យការប្រព្រឹត្តទៅនៃជីវិតដល់នាង ទើបទ្រង់យក
ល្អៀមាសដាក់ក្នុងយានតូចដរាបពេញ ហើយដំណែងខ្លួនជាមនុស្សចាស់
អង្គុយត្រង់កណ្តាលភូមិ ស្រែកថា អ្នកទាំងឡាយចូរមកយកល្អៀ ។ ពួកអ្នក
ភូមិដោយជុំវិញមក ពោលថា លោកឪពុកចូរឲ្យមក ។ មនុស្សចាស់និយាយ
ថា ខ្ញុំនឹងឲ្យដល់អ្នករក្សាសីល ពួកអ្នករក្សាសីលដៃឬទេ ។ ពួកមនុស្ស
ទាំងនោះពោលថា បពិត្រលោកឪពុក ពួកខ្ញុំមិនស្គាល់ថា សីលនោះដូចម្តេច
ឡើយ សូមលក់ឲ្យខ្ញុំចុះ ។ តាចាស់និយាយថា ខ្ញុំនឹងឲ្យដល់អ្នករក្សាសីល
ប៉ុណ្ណោះ ។ ពួកមនុស្សពោលថា ម្នាលគ្នាយើង តាចាស់លក់ល្អៀនេះជា
នរណា ហើយនាំគ្នាត្រឡប់ ។ ទារិកានោះសួរពួកអ្នកស្រុកថា អ្នកម៉ែ ទៅ

ដើម្បីត្រូវការល្អៅ ហេតុដូចម្តេច ទើបត្រឡប់មកដៃទទេ ។ ពួកស្រីទាំង
នោះឆ្លើយថា នែនាង តាចាស់លក់ល្អៅជាអ្នកណា គាត់និយាយថា ខ្ញុំនឹង
ឲ្យដល់អ្នករក្សាសីល សូម្បីក្មេងស្រីរក្សាសីល រមែងបានល្អៅនេះដោយពិត
ពួកយើងមិនស្គាល់សីលឡើយ ។ ទាវិកាគិតថា បុរសនេះគង់នឹងនាំមកដើម្បី
អញពិត ទើបទៅ ហើយនិយាយថា បពិត្រលោកឪពុក សូមឲ្យល្អៅមកខ្ញុំ
ព្រះឥន្ទ្រពោលថា នាងរក្សាសីលឬទេ ទាវិការឆ្លើយថា បពិត្រលោកឪពុក ខ្ញុំ
រក្សាសីល ។ ព្រះឥន្ទ្រពោលថា ខ្ញុំនាំយកល្អៅនេះមកដើម្បីនាងប៉ុណ្ណោះ ហើយ
ក៏ទុកល្អៅនឹងយានតូចត្រង់ទ្វារផ្ទះ ហើយចៀសចេញទៅ ។ នាងក៏រក្សាសីល
រហូតអស់ជីវិត ចុតិហើយ កើតជាធីតារបស់វេបចិត្តិអសុរ ។ ព្រោះផល
របស់សីល ទើបនាងជាអ្នកដែលគួរជ្រះថ្លា ។ ព្រះបាទវេបចិត្តិគិតថា អញនឹង
ធ្វើវិវាហមង្គលដល់កូនស្រី ទើបឲ្យពួកអសុរប្រជុំគ្នា ។

សក្កទេវរាជប្រមើលមើលថា នាងសុជាតាកើតក្នុងទីណា ទ្រង់ឃើញ
ថា កើតក្នុងពិភពអសុរ ថ្ងៃនេះ នឹងធ្វើវិវាហមង្គលដល់នាង ទ្រង់គិតថា
ឥឡូវនេះ អញគួរធ្វើឧបាយណាមួយ ដើម្បីនាំនាងមក ទើបទ្រង់និម្មិតភេទជា
អសុរ ឈរក្នុងចន្លោះពួកអសុរ ។ ស្តេចអសុរត្រាស់ថា ឪពុកអនុញ្ញាតឲ្យកូន
ជ្រើសរើសស្វាមី ហើយក៏ប្រទានកម្រងផ្កាដល់ដៃរបស់នាង ប្រាប់ថា កូនត្រូវ
ការអ្នកណា ក៏បូរបោះផ្កាលើអ្នកនោះ ។ កាលនាងពិនិត្យមើល ក៏ឃើញ
សក្កទេវរាជ កើតសេចក្តីស្រឡាញ់ ព្រោះធ្លាប់នៅរួមគ្នាមកពីកាលមុន
កំណត់ថា នេះជាស្វាមីរបស់អញ ហើយក៏បោះកម្រងផ្កាទៅលើអសុរនោះ ។

สกฺกទេវរាជនោះ ក៏ទ្រង់ចាប់ដើមដៃអសុរកញ្ញាហោះទៅលើអាកាស ។ គ្រានោះ ពួកអសុរក៏ចាំបាន ពួកអសុរទាំងនោះ ស្រែកថា ចាប់ ចាប់សក្កៈកញ្ចាស់ជាសត្រូវពួកយើង ពួកយើងមិនព្រមឲ្យកូនស្រីដល់សក្កៈនោះទេ ហើយក៏នាំគ្នាដេញតាម ។ ស្តេចវេបចិត្តិត្រាស់សួរថា អ្នកណានាំទៅ ពួកអាសុរទូលថា បពិត្រមហារាជ សក្កៈកញ្ចាស់នាំទៅ ។ ព្រះបាទវេបចិត្តិត្រាស់ថា ក្នុងបណ្តាទេវតាដ៏សេស សក្កៈនេះប៉ុណ្ណោះ ប្រសើរបំផុត ចូរអ្នកចេញទៅ ។ កាលសក្កទេវរាជនាំនាងទៅហើយ ក៏ទ្រង់តាំងទុកក្នុងតំណែងជាធំលើស្រីរបាំ ២ កោដិកន្ទះ ។ នាងទូលសូមពរចំពោះសក្កទេវរាជថា បពិត្រមហារាជ ក្នុងទេវលោកនេះ ខ្ញុំមិនមានមាតា បិតា ឬបងប្អូនប្រុសស្រី ព្រះអង្គយាងទៅទីណាៗ សូមនាំខ្ញុំទៅក្នុងទីនោះផង ។ សក្កទេវរាជប្រទានប្តេជ្ញាថា សាធុ ។ ព្រះមានព្រះភាគ កាលទ្រង់ឃើញភាពដែលសក្កទេវរាជនោះ ជាអ្នកបរិសុទ្ធតាំងពីកាលនៅជាមឃមាណព ក្នុងស្រុកមចលៈ ដូចដែលពោលមកនេះ ទើបត្រាស់ថា សក្កៈនេះ ជាអ្នកបរិសុទ្ធអស់កាលយូរហើយ ។ បទថា **អត្ត-សញ្ញិតំ** *គឺអាស្រ័យផល អាស្រ័យហេតុ ។*

បឋមភាណវារ ចប់

អធិប្បាយ បញ្ហាព្យាការណ៍

[๙๓] *បទថា* **កីសញ្ញោជនា** *គឺមានអ្វីជាគ្រឿងចង ជាប់ដល់ជាបុគ្គលត្រូវចំណងអ្វីចង ។ បទថា* **ឃុដ្ឋកាយា** *គឺពួកជនច្រើន ។ បទថា*

អវេរា គឺមិនមានការប៉ះទង្គិច ។ បទថា **អឧណ្ហា** គឺផុតពីអាជ្ញា គឺអាវុធ និងអាជ្ញា គឺធ្នូ ។ បទថា **អសបត្តា** គឺមិនមានសត្រូវ ។ បទថា **អព្យាបជ្ជា** បានដល់ ប្រាសចាកទោមនស្ស ។ បទថា **ទិមាវេមុ អវេរិនោ** គឺរមែងឲ្យទាន រមែងធ្វើការបូជាហើយប្រាថ្នាថា ឧហ្នុ៎ សូមឲ្យពួកយើងជាអ្នកមិនមានពៀរនឹងអ្នកណាម្នាក់ចុះ សូមឲ្យពួកយើងមិនបង្ករការកម្រើកឲ្យកើតក្នុងអ្នកណាម្នាក់ឡើយហើយប្រើប្រាស់របស់ដែលកាន់យកដោយម្រាមដៃ ព្រមនឹងមនុស្ស ១០០០ នាក់ចុះ ។ បទថា **ឥតិ ច ឯសំ ហោតិ** គឺសេចក្តីប្រាថ្នានេះ រមែងមានដល់ពួកជនទាំងនោះ ដោយប្រការដូច្នេះ ។ បទថា **អថ ច បន** គឺកាលសេចក្តីប្រាថ្នាយ៉ាងនាះមាន ។ បទថា **ឥស្សាមច្ឆរិយសញ្ញោជនា** គឺសេចក្តីច្រណែន មានការអស់ទៅនៃសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ និងសេចក្តីកំណាញ់ មានការទ្រាំមិនបានចំពោះសម្បត្តិរបស់ខ្លួន ជាសាធារណៈដល់ជនដទៃជាលក្ខណៈ ។ ឈ្មោះថា អ្នកមានសេចក្តីច្រណែន និងសេចក្តីកំណាញ់ ជាគ្រឿងចងរួបរឹតព្រោះសេចក្តីប្រណែន និងសេចក្តីកំណាញ់ ជាគ្រឿងប្រកបទុករបស់ពួកជនទាំងនោះ ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។ ចំណែកសេចក្តីច្រណែន និងសេចក្តីកំណាញ់យ៉ាងពិស្តារ បានពោលហើយក្នុងអភិធម្ម ។ ចំណែកក្នុងរឿងសេចក្តីកំណាញ់នេះ ព្រោះសេចក្តីកំណាញ់លំនៅ សត្ត មិនថាជាយក្ខក្តី ជាប្រេតក្តី ម្នាក់ៗ ក៏ដើរទូលសំរាមនៃទីលំនៅនោះឯង ។ ព្រោះសេចក្តីកំណាញ់ត្រកូល កាលបុគ្គលឃើញអ្នកដែលកំពុងធ្វើទានជាដើមដល់អ្នកដទៃក្នុងត្រកូលនោះ ក៏គិតថា ត្រកូលរបស់អញនេះ បែកហើយហ្នុ៎ នឹងដល់ការក្អួតឈាមខ្លះ

ជ្ជាយពោះខ្ជះ ពោះវៀនដាច់ជាកំណាត់តូចធំជ្ជាក់ចេញមកខ្ជះ ។ ព្រោះសេចក្តីកំណាញ់លាភ អ្នកមានសេចក្តីកំណាញ់ក្នុងលាភរបស់សង្ឆ ឬរបស់គណៈ បរិភោគដូចបរិភោគចំណែករបស់បុគ្គល កើតជាយក្ខខ្ជះ ប្រេតខ្ជះ ពោះថ្ជាន់ធំខ្ជះ ។ ព្រោះសេចក្តីកំណាញ់វណ្ណៈនៃសរីរៈ និងវណ្ណៈនៃគុណ និងព្រោះសេចក្តីកំណាញ់ការសិក្សាវៀនសូត្រ បុគ្គលនឹងពោលសរសើរតែគុណរបស់ខ្ជួនឯងប៉ុណ្ណោះ មិនពោលសរសើរគុណរបស់បុគ្គលពួកដទៃទេ ពោលតែទោសនោះឯងថា បុគ្គលនេះ មានស្អីល្អ និងមិនឲ្យការសិក្សាវៀនសូត្រណាមួយ ដល់បុគ្គលណាម្នាក់ ពោលតែទោសថា អ្នកនេះអាក្រក់ និងឆ្ពួតភ្ជីភ្ជី ។ ម្យ៉ាងទៀត ដោយការកំណាញ់លំនៅ បុគ្គលនោះមែងធេះក្នុងខ្ជះលោហៈ ។ ដោយការកំណាញ់ត្រកូល បុគ្គលនោះរមែងជាអ្នកមានលាភតិច ។ ដោយការកំណាញ់លាភ បុគ្គលនោះរមែងកើតក្នុងគូថនរក ។ ដោយការកំណាញ់វណ្ណៈ កាលកើតក្នុងភព នឹងមិនមានវណ្ណៈ ។ ដោយការកំណាញ់ធម៌ បុគ្គលនោះរមែងកើតក្នុងនរកផេះក្តៅ ។ ឯសេចក្តីច្រណែន និងសេចក្តីកំណាញ់ដែលជាគ្រឿងប្រកប (សត្វទុកក្នុងភព) នេះ នឹងលះបានដោយសោតាបត្តិមគ្គ ។ រហូតដល់អស់កាលដែលមិនទាន់លះវាបាន ទេវតា និងមនុស្ស សូម្បីប្រាថ្នាភាពជាអ្នកមិនមានពៀរជាដើមក៏ដោយ ក៏មិនអាចរួចផុតចាកពៀរជាដើមទ្បើយ ។ បទថា **តិណ្ណា មេត្ត កជ្ជា** សេចក្តីថា សក្កទេវរាជត្រាស់ថា ក្នុងបញ្ហានេះ ព្រោះស្តាប់ព្រះតម្រាស់របស់ព្រះអង្គ ទើបខ្ញុំព្រះអង្គឆ្ជងសេចក្តីសង្ស័យបាន ។ សក្កទេវរាជ ទ្រង់មិនបានសម្តែងសេចក្តីសង្ស័យ ដែលទ្រង់ឆ្ជង

បានដោយអំណាចមគ្គ ។ បទថា **វិគតា កថំកថា** គឺសេចក្តីសង្សយយ៉ាងនេះថា នេះអ្វី នេះអ្វី ប្រាសចាកទៅហើយ ។

[៩៤] បទថា **និធានា** ជាដើម មានសេចក្តីដូចបានពោលស្រេចហើយ ។ បទថា **បិយាបិយនិធានំ** គឺសេចក្តីកំណាញ់ មានសត្ត និងសង្ខារដែលជាទីស្រឡាញ់ជាដើមហេតុ ឥស្សា មានសត្ត និងសង្ខារដែលមិនជាទីស្រឡាញ់ជាដើមហេតុ ឬទាំងពីរ ក៏មានទាំងពីរជាដើមហេតុ ។ ចំពោះអ្នកបួស ថាកូនសិស្សជាដើម សម្រាប់អ្នកស្រុក កូនជាដើម ឬសត្ត មានជំរីសេះជាដើម រមែងជាទីស្រឡាញ់ ជាទីប្រលែងលេង ជាទីប្រកាន់ថា របស់អញ ។ កាលមិនឃើញជនទាំងនោះ សូម្បីត្រឹមតែមួយភ្លែត ក៏ទ្រាំមិនបាន ។ កាលបុគ្គលនោះ បានឃើញអ្នកដទៃ ដែលបានសត្ត្ជាទីស្រឡាញ់យ៉ាងនោះ ក៏កើតសេចក្តីច្រណែន ត្រូវអ្នកដទៃសូមសត្ត្នោះឯងថា ពួកយើងមានការងារខ្ជះដោយសត្ត្នេះ សូមឲ្យខ្ចីត្រឹមតែមួយពេលចុះ ក៏មិនបានឲ្យ ពោលថា រ៉ានឹងនឿយហត់ ឬវានឹងកើតទុក្ខ ហើយក៏កើតសេចក្តីកំណាញ់ ។ ដោយប្រការដូច្នេះ ក៏ឈ្មោះថា សេចក្តីច្រណែន និងសេចក្តីកំណាញ់ សូម្បីទាំងពីរ មានសត្ត្ដែលជាទីស្រឡាញ់ជាដើមហេតុ ។ សម្រាប់ភិក្ខុ មានបរិក្ខារ មានបាត្រ និងចីវរជាដើម សម្រាប់អ្នកស្រុក ឧបករណ៍ មានគ្រឿងប្រដាប់ជាដើម រមែងជាទីស្រឡាញ់ជាទីពេញចិត្ត ។ កាលបុគ្គលនោះឃើញវត្ថុប្រភេទនោះ កំពុងកើតដល់អ្នកដទៃ ក៏កើតសេចក្តីច្រណែនថា ឧហ្នឹ សូមវត្ថុបែបនេះ កុំគប្បីមានដល់បុគ្គលនោះ បើមានគេសូម ក៏កើតសេចក្តីកំណាញ់ថា ពួកយើងកំពុង

ស្រឡាញ់ នៅប្រើប្រាស់វត្ថុនេះ ឲ្យមិនបានទេ ។ ដោយប្រការដូច្នេះ ឈ្មោះថា សេចក្តីច្រណែន និងសេចក្តីកំណាញ់ទាំងពីរ រមែងមានសង្ខារដែលជាទីស្រឡាញ់ជាដើមហេតុ ។ តែកាលបានសត្វ និងសង្ខារ ដូចប្រការដែលពោលមកហើយនោះ ជាប្រភេទដែលមិនគួរស្រឡាញ់ បើសត្វ និងសង្ខារទាំងនោះ មិនជាទីស្រឡាញ់ សូម្បីយ៉ាងនោះក៏ដោយ ដើម្បីឲ្យពួកកិលេសដែលផ្ទុយគ្នាប្រព្រឹត្តទៅបាន ក៏ធ្វើសេចក្តីច្រណែនថា វៀរខ្ញុំចេញហើយ អ្នកដទៃណា ជាអ្នកបានសត្វ និងសង្ខារបែបនេះ ឬត្រូវសូមខ្វីក៏មិនឲ្យ រមែងធ្វើសេចក្តីហួងហែង ។ ដោយប្រការដូច្នេះ ឈ្មោះថា សេចក្តីច្រណែន និងសេចក្តីកំណាញ់សូម្បីទាំងពីរ រមែងមានសត្វ និងសង្ខារ ដែលមិនជាទីស្រឡាញ់ជាដើមហេតុ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឆន្ទ ឯធានំ** *នេះ ដូច្នេះថា ឆន្ទៈមាន ៥ យ៉ាង* **បរិយេសនឆន្ទ** *គឺសេចក្តីពេញចិត្តក្នុងការស្វែងរក ១* **បដិលាភឆន្ទ** *គឺសេចក្តីពេញចិត្តក្នុងការបានចំពោះ ១* **បរិភោគឆន្ទ** *គឺសេចក្តីពេញចិត្តក្នុងការប្រើប្រាស់ ១* **សន្និធិឆន្ទ** *គឺសេចក្តីពេញចិត្តក្នុងការសន្សំ ១* **វិស្សជ្ជនឆន្ទ** *គឺសេចក្តីពេញចិត្តក្នុងការលះបង់ ១ ។* **បរិយេសនឆន្ទ** *តើដូចម្តេច គឺបុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងស្វែងរក រូប សំឡេង ក្លិន រស រមែងស្វែងរកវត្ថុដែលគប្បីពាល់ត្រូវ រមែងស្វែងរកទ្រព្យ នេះឈ្មោះថា* **បរិយេសនឆន្ទ** *។* **បដិលាភឆន្ទ** *តើដូចម្តេច គឺបុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងបានចំពោះរូប សំឡេង ក្លិន រស រមែងបាន*

ចំពោះវត្ថុដែលគប្បីពាល់ត្រូវ រមែងបានចំពោះនូវទ្រព្យ នេះឈ្មោះថា **បដិ-លាភធនំ ។ បរិភោគធនំ** *តើដូចម្តេច គឺបុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងប្រើប្រាស់រូប សំឡេង ក្លិន រស រមែងប្រើប្រាស់វត្ថុដែលគប្បីពាល់ត្រូវ រមែងប្រើប្រាស់ទ្រព្យ នេះឈ្មោះថា* **បរិភោគធនំ ។ សន្និធិធនំ** *តើដូចម្តេច គឺបុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងធ្វើការសន្សំទ្រព្យ ដោយគិតថា នឹងមានក្នុងគ្រាវិបត្តិ នេះឈ្មោះថា* **សន្និធិធនំ ។ វិស្សជ្ជនធនំ** *តើដូចម្តេច គឺបុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងចាយវាយទ្រព្យដល់ពលជំរី ពលសេះ ពលរថ ខ្មាន់ធ្នូ ដោយគិតថា អ្នកទាំងនេះនឹងរក្សា នឹងឃុំគ្រង នឹងស្រឡាញ់ នឹងចោមរោម នេះឈ្មោះថា* **វិស្សជ្ជនធនំ ។** *ធនៈទាំង ៥ យ៉ាងនេះ ក្នុងទីនេះត្រឹមតែជាតណ្ហាប៉ុណ្ណោះឯង ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកសេចក្តីពេញចិត្តនោះ ទើបត្រាស់ពាក្យនេះ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វិតក្កិតោ** *នេះ ដូច្នេះថា វិតក្កដែលកើតពីការវិនិច្ឆ័យ ដែលត្រាស់យ៉ាងនេះថា វិនិច្ឆ័យ គឺសេចក្តីត្រិះរិះកើតមានព្រោះអាស្រ័យលាភ ឈ្មោះថា* **វិតក្ក ។** *បទថា* **វិនិច្ឆយោ** *វិនិច្ឆ័យមាន ២ យ៉ាង គឺ* **តណ្ហាវិនិច្ឆយោ** *វិនិច្ឆ័យ គឺតណ្ហា ១* **ទិដ្ឋិវិនិច្ឆយោ** *វិនិច្ឆ័យ គឺទិដ្ឋិ ១ ។ តណ្ហាវិបរិត ១០៨ ឈ្មោះថា* **តណ្ហាវិនិច្ឆយោ** *ទិដ្ឋិ ៦២ ឈ្មោះថា* **ទិដ្ឋិវិនិច្ឆយោ** *ដោយប្រការដូច្នេះ ទើបមិនមានការចង្អុលបង្ហាញថា គួរជ្រាប់ជ្រា

មិនគួរប្រាថ្នា និងគួរស្រឡាញ់ មិនគួរស្រឡាញ់ ដោយអំណាច **តណ្ហា-វិនិច្ឆយ** *ដែលពោលមកហើយយ៉ាងនោះ ។ ព្រោះវត្ថុនោះឯង ជារបស់គួរប្រាថ្នាសម្រាប់បុគ្គលខ្លះ មិនគួរប្រាថ្នាសម្រាប់បុគ្គលខ្លះ ដូចវិនិច្ឆយក្នុងជន្ទេម្រីគ និងសាច់ជាដើម របស់បច្ចន្តបទេសរាជ និងមជ្ឈិមបទេសរាជ កាលវត្ថុដែលបានទទួលមកនោះ ត្រូវវិនិច្ឆយដោយតណ្ហាវិនិច្ឆយហើយ ទើបនឹងមានវិនិច្ឆយសម្រេច វិតក្កវិនិច្ឆយថា ជារបស់រូបប៉ុណ្ណេះ ជារបស់សំឡេងប៉ុណ្ណេះ ជារបស់ក្លិនប៉ុណ្ណេះ ជារបស់រសប៉ុណ្ណេះ ជាវត្ថុដែលគប្បីពាល់ត្រូវប៉ុណ្ណេះ ជារបស់យើងប៉ុណ្ណេះ ជារបស់គេប៉ុណ្ណេះ នឹងរក្សាទុកប៉ុណ្ណេះ នឹងឲ្យប៉ុណ្ណេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បពិត្រទេវានមិន្ទ ធន្ទៈ មានវិតក្កជាដើមហេតុ ដូច្នេះ ។*

បទថា **បបញ្ចសញ្ញាសង្ខានិទានោ** *សេចក្តីថា បបញ្ចធម៌មាន ៣ យ៉ាង គឺ* **តណ្ហាបបញ្ច** *ធម៌ជាគ្រឿងយឺតយូរ គឺតណ្ហា១* **មានបបញ្ច** *ធម៌ជាគ្រឿងយឺតយូរ គឺមានៈ ១* **ទិដ្ឋិបបញ្ច** *ធម៌ជាគ្រឿងយឺតយូរ គឺទិដ្ឋិ ១ ។ ក្នុង ៣ យ៉ាងនោះ តណ្ហាវិបរិត ១០៨ ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ គឺតណ្ហា មានៈ ៩ យ៉ាង ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ គឺមានៈ ទិដ្ឋិ ៦២ ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ គឺទិដ្ឋិ ។ ក្នុងធម៌ជាគ្រឿងយឺតយូរទាំងនោះ ក្នុងទីនេះ លោកសំដៅយកធម៌ជាគ្រឿងយឺតយូរ គឺតណ្ហា ។ ដែលហៅថា ធម៌ជាគ្រឿងយឺតយូរ ព្រោះអត្ថដូចម្តេច ដែលហៅថា ធម៌ជាគ្រឿងយឺតយូរ ព្រោះអត្ថថាឲ្យដល់អាការរបស់អ្នកស្រេវឹងប្រមាទ ។ ការសម្គាល់ ដែលប្រកបដោយធម៌*

ជាគ្រឿងយឺតយូរនោះ ឈ្មោះថា **បបញ្ចសញ្ញា** *(ការសម្គាល់ដែលលាយ ឡំទៅដោយធម៌ជាគ្រឿងយឺតយូរ) ។ ឯហៅថា* **សង្ខារ** *ដូចក្នុងប្រយោគ ជាដើមថា ធម៌ជាចំណែកនៃសេចក្តីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ។ ដោយប្រការដូច្នេះ ពាក្យថា មានបបញ្ចសញ្ញាជាដើមហេតុ ទើបសំដៅ សេចក្តីថា វិតក្ក មានបញ្ចសញ្ញាជាដើមហេតុ ។*

[๙๕] *បទថា* **បបញ្ចសញ្ញាសង្ខានិរោធសារុប្បគាមិនឹ** *សេចក្តីថា ការរលត់ដោយមិនមានសល់ បានដល់ ការស្ងប់រម្ងាប់ឯណា នៃបបញ្ច-សញ្ញានេះ សក្កទេវរាជ រមែងទូលសួរផ្លូវ ព្រមទាំងវិបស្សនា គឺភាពសមរម្យ នៃការរលត់ដោយមិនមានសល់នោះ និងបដិបទាឲ្យដល់និរោធ ដោយមិនមាន សល់នោះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ផ្តើមវេទនា ๓ យ៉ាង ដល់ សក្កទេវរាជនោះថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា សោមនស្ស ... ។ សួរថា ព្រះមានព្រះភាគត្រាស់តែបទដែលទូលសួរ ឬត្រាស់បទដែលមិនទូល សួរដែរ ត្រាស់តែបទដែលប្រកបដោយអនុសន្ធិ ឬត្រាស់បទដែលមិនប្រកប ដោយអនុសន្ធិដែរ ឆ្លើយថា ត្រាស់តែបទដែលទូលសួរប៉ុណ្ណោះ មិនត្រាស់ បទដែលមិនទូលសួរ ត្រាស់បទដែលប្រកបដោយអនុសន្ធិប៉ុណ្ណោះ មិនត្រាស់ បទដែលមិនប្រកបដោយអនុសន្ធិឡើយ ។ ពិតហើយ ចំពោះទេវតាទាំង-ឡាយ អរូបប្រាកដជាងរូប សូម្បីក្នុងអរូប វេទនាក៏ប្រាកដជាង ។ ព្រោះ ហេតុអ្វី ព្រោះកវជកាយរបស់ពួកទេវតាជារបស់សុខុម កម្មជរូបជារបស់មាន កម្មាំង ព្រោះកវជកាយជារបស់សុខុម និងព្រោះកម្មជរូបជារបស់មានកម្មាំង*

បើឈានកន្ធង់អាហារតែមួយពេលហើយ ពួកទេវតាក៏តាំងនៅមិនបាន រមែងវិនាសទៅ ដូចសប្បិជាក់លើផ្ទាំងថ្មដែលក្តៅ ។ គប្បីជ្រាបពាក្យទាំងអស់តាមន័យដែលពោលហើយ ក្នុងព្រហ្មជាលសូត្រនោះឯង ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ផ្តើមវេទនាទាំង ៣ យ៉ាង ដល់សក្កទេវរាជ ។

ឯកម្មដ្ឋានមាន ២ យ៉ាង គឺរូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន ។ នីងហៅកម្មដ្ឋាននោះឯងថា ការកំណត់រូប និងការកំណត់អរូបក៏បាន ។ ក្នុងកម្មដ្ឋាន ២ យ៉ាងនោះ រូបប្រាកដដល់បុគ្គលណា ព្រះមានព្រះភាគ កាលទ្រង់ធ្វើការកំណត់ធាតុ ៤ ឲ្យពិស្តារដល់បុគ្គលនោះ ដោយអំណាចធ្វើទុកក្នុងចិត្តដោយសង្ខេប ឬដោយអំណាចធ្វើទុកក្នុងចិត្តដោយពិស្តារ ក៏ត្រាស់រូបកម្មដ្ឋាន អរូបប្រាកដដល់បុគ្គលណា ក៏ត្រាស់អរូបកម្មដ្ឋានដល់បុគ្គលនោះ កាលត្រាស់អរូប ទ្រង់ក៏សម្តែងរូបកម្មដ្ឋាន ដែលជាទីតាំងរបស់អរូបនោះ ទើបត្រាស់ ។ តែសម្រាប់ពួកទេវតា ទ្រង់ជ្រាបថា អរូបប្រាកដ ទើបទ្រង់ផ្តើមវេទនាដោយអំណាចអរូបកម្មដ្ឋាន ។

សេចក្តីតាំងមាំក្នុងអរូបកម្មដ្ឋានមាន ៣ យ៉ាង គឺដោយអំណាចផស្សៈ ដោយអំណាចវេទនា ដោយអំណាចចិត្ត ។ សេចក្តីនេះដូចម្តេច គឺចំពោះបុគ្គលខ្លះ កាលទទួលយករូបកម្មដ្ឋានដោយសង្ខេបក្តី ដោយពិស្តារក្តី រមែងមានការធ្លាក់ទៅយ៉ាងក្រៃលែង ក្នុងគ្រាដំបូងរបស់ចិត្ត និងចេតសិកទាំងឡាយក្នុងអារម្មណ៍នោះ ផស្សៈកើតពាល់ត្រូវអារម្មណ៍នោះ រមែងជារបស់ប្រាកដ ។ ចំពោះបុគ្គលខ្លះ វេទនាកើត តាមសោយអារម្មណ៍នោះ រមែងជារបស់ប្រាកដ ។

ចំពោះបុគ្គលខ្ទះ វិញ្ញាណដែលកើតឡើង ដឹងច្បាស់អារម្មណ៍នោះ រមែងជារបស់ប្រាកដ ។

ក្នុងការតាំងមាំទាំង ៣ យ៉ាងនោះ បុគ្គលណាមានផស្សៈប្រាកដច្បាស់ បុគ្គលនោះ មិនមែនកើតឡើងតែផស្សៈតែម្យ៉ាងប៉ុណ្ណោះទេ ព្រមគ្នានឹងផស្សៈនោះ សូម្បីវេទនាដែលតាមសោយអារម្មណ៍នោះឯង ក៏រមែងកើតឡើងផងដែរ សូម្បីសញ្ញាដែលចាំអារម្មណ៍នោះ សូម្បីចេតនាដែលគិតអារម្មណ៍នោះ សូម្បីវិញ្ញាណដែលដឹងច្បាស់អារម្មណ៍នោះ ក៏រមែងកើតឡើងដែរ ទើបឈ្មោះថា រមែងប្រមូលកាន់យកពួកចេតសិកធម៌ ដែលមានផស្សៈជាគម្រប់ ៥ ដូចគ្នាដោយប្រការដូច្នេះ ។ បុគ្គលណា មានវេទនាប្រាកដច្បាស់ បុគ្គលនោះ ក៏រមែងឈ្មោះថា ប្រមូលកាន់យកពួកចេតសិកធម៌ ដែលមានផស្សៈជាគម្រប់ ៥ ដូចគ្នា ព្រោះមិនមែនវេទនាតែម្យ៉ាងប៉ុណ្ណោះទេ ដែលកើតឡើងព្រមគ្នានឹងវេទនានោះ នៅមានផស្សៈកើតឡើង ប៉ះខ្ទប់អារម្មណ៍នោះឯង នៅមានសញ្ញាដែលចាំអារម្មណ៍ នៅមានចេតនាដែលគិតអារម្មណ៍ នៅមានវិញ្ញាណដែលដឹងច្បាស់អារម្មណ៍នោះ កើតឡើងផងដែរ ។ ចំពោះបុគ្គលដែលមានវិញ្ញាណប្រាកដច្បាស់ ក៏រមែងឈ្មោះថា ប្រមូលកាន់យកពួកចេតសិកធម៌ ដែលមានផស្សៈជាគម្រប់ ៥ ដូចគ្នានុ៉ះឯង ព្រោះមិនមែនកើតឡើងចំពោះវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះទេ ព្រមនឹងវិញ្ញាណនោះ ក៏នៅមានផស្សៈដែលកើតឡើង ប៉ះខ្ទប់អារម្មណ៍នោះឯង នៅមានវេទនាដែលតាមសោយអារម្មណ៍ នៅមានសញ្ញាដែលចាំអារម្មណ៍ នៅមានចេតនាដែលគិតអារម្មណ៍កើតឡើងផង ។

กาลปุคฺคลนោះពិចារណាថា ធម៌ពួកដែលមានផស្សៈជាគម្រប់ ๕ នេះ អាស្រ័យអ្វី ក៏រមែងដឹងច្បាស់ថា អាស្រ័យទីតាំង ។ ឈ្មោះថា ទីតាំង ក៏គឺ រាងកាយ (ករជកាយ) ដែលលោកសំដៅយកពោលថា ឯវិញ្ញាណ របស់អញនេះ អាស្រ័យនៅក្នុងរាងកាយនេះ ជាប់ទាក់ទងក្នុងរាងកាយនេះ ។ ដោយអត្ត គឺបុគ្គលនោះមែងដឹងច្បាស់ទាំងកូតរូប និងឧបាទាយរូប ។ កាល ដឹងច្បាស់ថា ទីតាំងក្នុងរាងកាយនេះ ជារូប ពួកធម៌ដែលមានផស្សៈជាគម្រប់ ๕ ជានាម យ៉ាងនេះក៏ឈ្មោះថា រមែងឃើញត្រឹមតែជានាមរូបប៉ុណ្ណោះ ។ ហើយនាមរូបក៏ត្រឹមតែជាខន្ធ ๕ គឺរូបក្នុងទីនេះ ជារូបក្ខន្ធ ឯនាម ក៏ជាខន្ធ ដែលមិនមែនរូបទាំង ๔ ។ ខន្ធ ๕ ដែលផ្សេងអំពីនាមរូប ឬនាមរូបដែល ផ្សេងអំពីខន្ធ ๕ មិនមានទេ ។ កាលបុគ្គលត្រិះរិះថា ខន្ធទាំង ๕ នេះ មានអ្វី ជាហេតុ ក៏រមែងឃើញថា មានអវិជ្ជាជាដើមជាហេតុ តពីនោះ កាលត្រិះរិះ ដល់បច្ចយ និងវត្ថុ ដែលកើតព្រោះបច្ចយ ក៏ដឹងថា ក្រៅពីបច្ចយ និងវត្ថុ ដែលកើតពីបច្ចយនោះហើយ មិនមានសត្វ ឬបុគ្គលដទៃ មានតែគំនរសង្ខារ សុទ្ធៗ ប៉ុណ្ណោះឯង ហើយក៏លើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនាម រូបព្រមនឹងបច្ចយ និងពិចារណាថា មិនទៀង ទ្រាំមិនបាន មិនមានអ្វីជាតួខ្លួន តាមលំដាប់នៃវិបស្សនា ។ បុគ្គលទន្ទឹងការចាក់ធ្លុះថា ថ្ងៃនេះ ថ្ងៃនេះ ក្នុងថ្ងៃ បែបនោះ កាលបានឧតុជាទីសប្បាយ បុគ្គលជាទីសប្បាយ អាហារជាទី សប្បាយ ឬការស្តាប់ធម៌ជាទីសប្បាយហើយ ក៏អង្គុយដោយភ្នែនមួយ ប៉ុណ្ណោះ ញ៉ាំងវិបស្សនាឲ្យដល់កំពូល ក៏រមែងតាំងនៅក្នុងអរហត្តផល ។

គោបកទេវបុត្រ ប្រាប់កម្មដ្ឋានដរាបដល់អរហត្ត ដល់លោកទាំង ๓ នេះ យ៉ាងនេះឯង ។

តែក្នុងទីនេះ កាលព្រះមានព្រះភាគ ទ្រង់សម្តែងអរូបកម្មដ្ឋាន ក៏ទ្រង់សម្តែងដោយវេទនាជាប្រធាន ។ កាលព្រះអង្គសម្តែងដោយអំណាចផស្សៈ ឬដោយអំណាចវិញ្ញាណ នឹងមិនមានភាពជាក់ច្បាស់ដល់សក្កទេវរាជនេះ តែនឹងប្រាកដដូចភាពងងឹត ។ តែដោយអំណាចវេទនា ទើបជាក់ច្បាស់ ។ ព្រោះហេតុអ្វី ព្រោះការកើតវេទនាឡើង ជារបស់ជាក់ច្បាស់ហើយ ។ ពិតហើយ ការកើតសេចក្តីសុខ និងទុក្ខវេទនាឡើង ជាវត្ថុប្រាកដច្បាស់ហើយ ។ កាលសេចក្តីសុខកើតឡើង សរីរៈទាំងមូល ក៏រំកើបរំជួល ផ្សព្វផ្សាយ ជ្រួតជ្រាប ដូចឲ្យផឹកសប្បិ ដែលជម្រះ ๑๐๐ ដង ដូចកំពុងលាបប្រេង ដែលចម្រាញ់ ๑๐๐ ដង ដូចកំពុងយកទឹក ๑ ពាន់ក្អម មកអម្ងត់សេចក្តីក្តៅក្រហាយ បន្ទឺវាចាថា សុខហ្ន៎ សុខហ្ន៎នោះឯង ។ កាលកើតសេចក្តីទុក្ខឡើង សរីរៈទាំងមូលញាប់ញ័រ រញ្ជួយ ផ្សព្វផ្សាយ ជ្រួតជ្រាប ដូចបុគ្គលធ្លាក់ក្នុងខ្លះក្តៅ ដូចយកទឹកទង់ដែងមកស្រោច ដូចបុគ្គលត្រូវគប់ភ្លើងក្នុងព្រៃ ដែលមានស្មៅ និងឈើធំៗ និងឈើស្ងួតធំៗ កន្ទក់កន្ទេញថា ទុក្ខហ្ន៎ ទុក្ខហ្ន៎ នោះឯង ។ សុខ និងទុក្ខវេទនា កើតឡើងប្រាកដដូចពោលមកនេះ ។ ចំណែកអទុក្ខមសុខវេទនា ចង្អុលបង្ហាញលំបាក ដូចត្រូវសេចក្តីងងឹតគ្របសង្កត់ ។ អទុក្ខមសុខវេទនានោះ ព្រោះវៀរសុខ និងទុក្ខ ទើបមានអាការជាកណ្តាល ដោយអំណាចជាបដិបក្ខចំពោះសុខ និងទុក្ខ ដូច្នេះ កាលកាន់យកដោយនិយ ទើបនឹងជាក់

ច្បាស់ ។ សេចក្តីនេះដូចម្តេច ដូចព្រានម្រឹគ ដើរទៅតាមស្នាមជើងម្រឹគ ដែលទ្បើងដុំថ្មក្នុងរវាងផ្លូវហើយគេចទៅ បានឃើញស្នាមជើងខាងដើមខ្លះ ខាងចុងខ្លះ ត្រង់ដុំថ្មមិនឃើញ ក៏រមែងដឹងបានដោយនយ័ថា ម្រឹគគង់នឹងទ្បើងផ្លូវនេះ ហើយចុះផ្លូវនេះ ទៅតាមប្រទេសនេះ ត្រង់កណ្តាលលើផ្ទាំងថ្ម យ៉ាងណា ក៏ការកើតសុខវេទនាទ្បើង រមែងជាវត្តុជាក់ច្បាស់ ដូចស្នាមជើងត្រង់ទីដែលម្រឹគទ្បើង ការកើតទ្បើងនៃទុក្ខវេទនា ក៏ជាវត្តុជាក់ច្បាស់ ដូចស្នាមជើងត្រង់ទីម្រឹគចុះ កាលកាន់យកដោយនយ័ថា ព្រោះវៀរសុខ និងទុក្ខ ទើបអទុក្ខមសុខវេទនានោះ មានអាការជាកណ្តាល ដោយអំណាចជាបដិបក្ខចំពោះទាំងសុខ និងទុក្ខ រមែងជារបស់ជាក់ច្បាស់ ដូចការកាន់យកដោយនយ័ថា ម្រឹគទ្បើងត្រង់នេះ ចុះត្រង់នេះ ហើយទៅយ៉ាងនេះ ដូច្នោះ ។

កាលត្រាស់រូបកម្មដ្ឋានជាមុនយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏ទ្រង់បែរត្រឡប់សម្តែងអរូបកម្មដ្ឋាន ដោយអំណាចវេទនាក្នុងកាលជាក្រោយ ។ មិនមែនទ្រង់សម្តែងយ៉ាងនេះតែម្យ៉ាង ក្នុងទីនេះប៉ុណ្ណោះទ្បើយ សូម្បីរូបកម្មដ្ឋានក្នុងសូត្រមិនមែនតិច ដូចជាមហាសតិប្បដ្ឋានសូត្រ ចូឡតណ្ហាសង្ខយសូត្រ មហាតណ្ហាសង្ខយសូត្រ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រ រដ្ឋបាលសូត្រ មាគន្ទិយសូត្រ ធាតុវិភង្គសូត្រ អានេញ្ជសប្បាយសូត្រ និងក្នុងវេទនាសំយុត្តទាំងអស់ ក៏ទ្រង់សម្តែងហើយ ទើបទ្រង់ត្រឡប់សម្តែងអរូបកម្មដ្ឋាន ដោយអំណាចវេទនាខាងក្រោយ ។ ក្នុងព្រះសូត្រទាំងនោះ យ៉ាងណា សូម្បីក្នុងសក្កបញ្ហសូត្រនេះក៏ដូច្នោះ ដំបូងទ្រង់សម្តែងរូបកម្មដ្ឋាន ហើយខាងក្រោយ

ទើបទ្រង់ត្រឡប់សម្តែងអរូបកម្មដ្ឋាន ដោយអំណាចវេទនា ។ ចំណែកក្នុងសក្កប្បញ្ហសូត្រនេះ រូបកម្មដ្ឋានព្រះមានព្រះភាគ ទ្រង់សង្ខេបត្រឹមតែជាអារម្មណ៍របស់វេទនាប៉ុណ្ណោះ ដូច្នោះ ទើបក្នុងបាលីមិនលើកឡើង ។ ដើម្បីទ្រង់សម្តែងប្រការដែលជាគោលសម្រាប់តាំងមាំ ដោយអំណាចនៃវេទនាដែលជាក់ច្បាស់ដល់សក្កទេវរាជនោះឯង ក្នុងអរូបកម្មដ្ឋាន ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា បពិត្រទេវានមិន្ទ តថាគតសម្តែងថា សោមនស្ស ... ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទ្វិធេន** *គឺពីរប្រភេទ សេចក្តីថា ដោយចំណែកពីរ ។ បទថា* **ឯវរូបំ សោមនស្សំ ន សេវិតព្វំ** *គឺមិនគប្បីសេពគេហសិតសោមនស្ស គឺសោមនស្សដែលអាស្រ័យផ្ទះបែបនេះ ។ ឈ្មោះថាគេហសិតសោមនស្ស បានដល់ សោមនស្សដែលអាស្រ័យកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារ ៦ គឺវេទនាទាំងនោះ បណ្តាគេហសិតសោមនស្ស ៦ យ៉ាង តើដូចម្តេច បុគ្គលកាលបានកាលឃើញច្បាស់ នូវការបានរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោភាមិស គឺតណ្ហាក្តី កាលរឭកឃើញ (នូវរូប) ដែលខ្ជួនធ្លាប់បានហើយក្នុងកាលមុន ដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតសេចក្តីសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា គេហសិតសោមនស្ស ដូច្នេះជាដើម ។ បទថា* **ឯវរូបំ សោមនស្សំ សេវិតព្វំ** *គឺគប្បីសេពនេក្ខម្មសិតសោមនស្ស គឺ*

សោមនស្សដែលអាស្រ័យការចេញចាកផ្ទះបែបនេះ ។ ឈ្មោះថា នេក្ខម្ម-សិតសោមនស្ស បានដល់ សោមនស្សដែលកើតឡើងដល់បុគ្គលដែលកើតសោមនស្សថា អញបានខ្ងល់ខ្ងាយក្នុងវិបស្សនាហើយ ជាអ្នកអាចហាត់ពត់ចិត្តឲ្យខ្ងល់ខ្ងាយ ផ្តើមវិបស្សនាដោយអំណាចត្រៃលក្ខណ៍ មានមិនទៀងជាដើម ក្នុងអារម្មណ៍ដែលគួរស្រឡាញ់ ដែលមកកាន់គន្ធងក្នុងទ្វារទាំង ៦ យ៉ាងនេះជាដើមថា ក្នុងវេទនាទាំងនោះ នេក្ខម្មសិតសោមនស្ស ៦ តើដូចម្តេច បុគ្គលកាលដឹងច្បាស់ថា រូបមានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ហើយឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតសោមនស្ស ។ បទថា **សេវិតព្វំ** *គឺសោមនស្សដែលកើតឡើងដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ ដោយអំណាចបឋមជ្ឈានជាដើម នេះឈ្មោះថា គប្បីសេព ។*

ក្នុងបទទាំងនោះ បទថា **តត្ត យញ្ចេ សេវិតញ្ចំ សវិចារំ** *គឺក្នុងសោមនស្សដែលអាស្រ័យការចេញចាកផ្ទះនោះ ក៏ត្រូវដឹងថា សោមនស្សដែលកើតឡើងដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ និងដោយអំណាចនៃបឋមជ្ឈាននោះ ជាសោមនស្សដែលនៅមានវិតក្ក នៅមានវិចារៈ ។ បទថា* **តត្ត យញ្ចេ អវិតញ្ចំ អវិចារំ** *គឺចំណែក*

សោមនស្សដែលកើតដោយអំណាចទុតិយជ្ឈាន និងតតិយជ្ឈាន ក៏ត្រូវជីងថា ជាសោមនស្សដែលមិនមានវិតក្ក មិនមានវិចារៈ ។ បទថា **យេ អវិតក្កេ អវិចារេ តេ បណីតតរេ** *សេចក្តីថា សូម្បីក្នុងសោមនស្សទាំងពីរនេះ សោម-នស្សដែលមិនមានវិតក្ក មិនមានវិចារៈនោះប្រណីតជាង ។ ឈ្មោះថា លោក ពោលដល់អ្វី លោកពោលដល់អរហត្តផលរបស់គន្ធព្វពីរនាក់ ។ សេចក្តីនេះ ដូចម្តេច ពិតហើយ ភិក្ខុមួយរូប កាលផ្តើមវិបស្សនាក្នុងសោមនស្ស ដែលនៅ មានវិតក្ក នៅមានវិចារៈ ហើយក៏មកពិចារណាថា សោមនស្សនេះអាស្រ័យ អ្វី ក៏ជ្រាបច្បាស់ថា អាស្រ័យទីតាំង ហើយក៏តាំងនៅក្នុងអរហត្តផលដោយ លំដាប់ តាមន័យដែលពោលហើយក្នុងពួកធម៌ ដែលមានផស្សៈជាគម្រប់ ៥ នុ៎ះឯង ។ ១ រូប ផ្តើមវិបស្សនាក្នុងសោមនស្ស ដែលមិនមានវិតក្ក មិនមាន វិចារៈ ហើយក៏តាំងនៅក្នុងអរហត្តផល តាមន័យដែលពោលហើយដូចគ្នា ។*

សូម្បីក្នុងសោមនស្សដែលតាំងមាំទាំងនោះ សោមនស្សដែលមិនមាន វិតក្ក និងមិនមានវិចារៈប្រណីតជាង ដែលនៅមានវិតក្ក និងនៅមានវិចារៈ សោមនស្សវិបស្សនា ដែលមិនមានវិតក្ក និងមិនមានវិចារៈប្រណីតជាង សូម្បីសោមនស្សវិបស្សនាដែលមានវិតក្ក និងមានវិចារៈ សោមនស្សផល-សមាបត្តិដែលមិនមានវិតក្ក និងមិនមានវិចារៈប៉ុណ្ណោះ ដែលប្រណីតជាង សោមនស្សផលសមាបត្តិ ដែលនៅមានវិតក្ក និងនៅមានវិចារៈ ព្រោះហេតុ នោះ ទើបព្រះមានព្រះភាគត្រាស់ថា សោមនស្សណា ដែលមិនមានវិតក្ក មិនមានវិចារៈ សោមនស្សនោះ ប្រសើរជាង ដូច្នេះ ។

បទថា **ឯវរូបំ ឧោមនស្សំ ន សេវិតព្វំ** សេចក្តីថា មិនគប្បីសេព គេហសិតទោមនស្ស គឺទោមនស្សដែលអាស្រ័យផ្ទះបែបនេះ ។ ដែលឈ្មោះថា គេហសិតទោមនស្ស បានដល់ ទោមនស្សដែលអាស្រ័យកាមគុណដែលកើតដល់អ្នកត្រិះរិះថា អញមិនតាមសោយហើយ នឹងមិនតាមសោយ រមែងមិនតាមសោយនូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៦ យ៉ាងនេះថា បណ្តាវេទនាទាំងនោះ គេហសិតទោមនស្ស ៦ តើដូចម្តេច បុគ្គលកាលមិនបានឃើញច្បាស់នូវការមិនបានរូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសក្តី កាលរញកឃើញនូវរូបដែលខ្ជួនមិនធ្លាប់បាន ក្នុងកាលមុនក្តី ដែលកន្ជងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតទោមនស្សឡើង ទោមនស្សណា មានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា គេហសិតទោមនស្ស ដូច្នេះជាដើម ។ បទថា **ឯវរូបំ ឧោមនស្សំ សេវិតព្វំ** គឺគប្បីសេពនេក្ខម្មសិតទោម-នស្ស គឺទោមនស្សដែលអាស្រ័យការចេញចាកផ្ទះបែបនេះ ។ ដែលឈ្មោះថា នេក្ខម្មសិតទោមនស្ស បានដល់ ទោមនស្សដែលកើតដល់បុគ្គល ដែលមិនអាចហាត់ពត់ចិត្ត ឲ្យខ្ងល់ខ្ងាយ ចូលទៅតាំងសេចក្តីប្រាថ្នាក្នុងធម៌ គឺអរិយផលពោល គឺសេចក្តីរួចផុតដ៏កំពូល ហើយផ្តើមវិបស្សនា ដោយអំណាចត្រៃលក្ខណ៍ មានអនិច្ចំជាដើម ដើម្បីសម្រេចអរិយផលនោះ បុគ្គលតាមក្តៅក្រហាយចិត្តថា អញមិនអាចនឹងហាត់ពត់ចិត្ត ឲ្យខ្ងល់ខ្ងាយក្នុងវិបស្សនាអស់បក្ខនេះ អស់ខែនេះ អស់ឆ្នាំនេះ ហើយសម្រេចអរិយភូមិបាន ក្នុងអារម្មណ៍

ដែលគួរស្រឡាញ់ ដែលមកកាន់គន្ធង៍ក្នុងទ្វារទាំង ៦ យ៉ាងនេះថា ក្នុង វេទនាទាំងនោះ នេក្ខម្មសិតទោមនស្ស ៦ តើដូចម្តេច បុគ្គលដឹង៍ច្បាស់ថា រូបមានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញ ច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះដូច្នេះថា រូបក្នុងកាលមុនក្តី ក្នុង កាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តី ប្រែប្រួលជាធម្មតា ហើយក៏ញុំាងសេចក្តីស្រឡាញ់ឲ្យតាំងខ្ជឹង៍ក្នុង៍អនុត្តរ-វិមោក្ខ គឺព្រះអរហត្តថា កាលណាហ្ន៎ អាត្មាអញ នឹង៍បានដល់នូវអាយតនៈ គឺអរហត្តជាអាយតនៈ ដែលព្រះអរិយៈទាំងឡាយ តែង៍បានដល់ក្នុង៍កាល ឥឡូវនេះ កាលញុំាងសេចក្តីស្រឡាញ់ឲ្យតាំង៍ខ្ជឹង៍ ក្នុង៍អនុត្តរវិមោក្ខដូច្នេះ ហើយ ក៏កើតទោមនស្សខ្ជឹង៍ ព្រោះតែសេចក្តីស្រឡាញ់ជាបច្ច័យ ទោម-នស្សណាមានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតទោម-នស្ស ដូច្នេះជាដើម ។ បទថា **សេវិតព្វំ** *គឺទោមនស្សដែលកើតខ្ជឹង៍ ដោយ អំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរព្រឹក ដល់ ដោយអំណាចបឋមជ្ឈានជាដើមនេះ ឈ្មោះថា ជាទោមនស្សគប្បីសេព ។*

ក្នុង៍បទទាំងនោះ បទថា **យញ្ហេ សវិតក្កំ សវិចារំ** *គឺក្នុង៍ទោមនស្ស ទាំង៍ពីរយ៉ាង៍នោះ គេហសិតទោមនស្សប៉ុណ្ណោះ ដែលឈ្មោះថា នៅមានវិតក្ក នៅមានវិចារៈ ។ ចំណែកទោមនស្សដែលកើតខ្ជឹង៍ ដោយអំណាចការចេញ ចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរព្រឹកដល់ ដោយ អំណាចបឋមជ្ឈាន និង៍ទុតិយជ្ឈាន គប្បីជ្រាបថា ជាទោមនស្ស ដែលនៅ*

មានវិតក្ក និងនៅមានវិចារៈ ។ ចំណែកពោលដោយត្រង់ ដែលឈ្មោះថា ទោមនស្សមិនមានវិតក្ក និងមិនមានវិចារៈ មិនមាន ។ សម្រាប់ទោម-នស្សិន្ទ្រិយ ជាអកុសលតែម្យ៉ាងប៉ុណ្ណោះ និងនៅមានវិតក្ក នៅមានវិចារៈផង ដែរ ។ តែដោយអំណាចការយល់របស់ភិក្ខុនោះ ទើបលោកពោលថា ទោម-នស្សិន្ទ្រិយ នៅមានវិតក្ក និងនៅមានវិចារៈ ហើយពោលថា ដែលមិនមាន វិតក្ក និងមិនមានវិចារៈ ដូច្នេះ ។

តទៅនេះ ជានយក្នុងរឿងទោមនស្សនោះ គឺក្នុងករណីនេះ ភិក្ខុកាន់យក ធម៌ដែលនៅមានវិតក្ក និងនៅមានវិចារៈ និងធម៌ដែលមិនមានវិតក្ក និងមិន មានវិចារៈ ជាធម៌ដែលមានទោមនស្សជាបច្ច័យ និងធម៌ គឺមគ្គ និងផលដែល កើតឡើង មានទោមនស្សជាបច្ច័យនុ៎ះឯង ថាជាទោមនស្ស ព្រោះអំណាច ឃើញបដិបទារបស់ភិក្ខុពួកដទៃ ហើយក៏គិតថា កាលណាហ្ន៎ ទើបអញផ្តើម វិបស្សនាក្នុងទោមនស្សដែលនៅមានវិតក្ក និងនៅមានវិចារៈបាន កាលណា ទើបអញផ្តើមវិបស្សនាក្នុងទោមនស្សដែលមិនមានវិតក្ក និងមិនមានវិចារៈ បាន រួចគិតទៀតថា កាលណាហ្ន៎ ទើបអញឲ្យផលសមាបត្តិក្នុងទោមនស្ស ដែលនៅមានវិតក្ក និងនៅមានវិចារៈកើតបាន កាលណា ទើបអញញុំង ផលសមាបត្តិក្នុងទោមនស្ស ដែលមិនមានវិតក្ក និងមិនមានវិចារៈឲ្យកើតបាន ហើយក៏កាន់យកបដិបទាអស់ ៣ ខែក្តី ៦ ខែក្តី ឬ ៩ ខែក្តី កាលកាន់យក បដិបទាអស់ ៣ ខែ ក្នុងខែដំបូង ដើរចង្រ្កមក្នុបបឋមយាម និងមជ្ឈិមយាម ធ្វើឱកាសដល់ការដេកលក់ ក្នុងខែកណ្តាល ដើរចង្រ្កមអស់យាម ២ធ្វើឱកាស

ដល់ការដេកលក់ ๑ យាម ក្នុងខែចុងក្រោយ ឲ្យរាងកាយប្រព្រឹត្តទៅ ដោយការដើរចង្រ្កម និងការអង្គុយប៉ុណ្ណោះឯង បើបែបនេះ សម្រេចព្រះអរហត្តនោះក៏ជាការល្អ ។ បើមិនសម្រេច លោកក៏កាន់យកបដិបទា ប្រកេទ ៦ ខែ ឲ្យវិសេសថែមទៀត ក្នុងបដិបទា ៦ ខែនោះ គ្រប់ ២ ខែៗ បដិបត្តិតាមន័យដែលពោលហើយ កាលមិនអាចសម្រេចអរហត្តបាន ក៏កាន់យកបដិបទា ៩ ខែឲ្យវិសេសថែមទៀត ក្នុងបដិបទា ៩ ខែនោះ គ្រប់ ៣ ខែៗ ក៏បដិបត្តិយ៉ាងនោះឯង កាលមិនអាចសម្រេចភាពជាព្រះអរហន្តបាន (និង) កាលពិចារណាថា អញមិនបានបវារណា បែបវិសុទ្ធិបវារណាព្រមជាមួយពួកសព្រហ្មចារីហ្នឹងទាមនស្សក៏រមែងកើតឡើង ។ ទឹកភ្នែកក៏ហូរ ដូចទឹកភ្នែករបស់ព្រះមហាសិវត្ថេរ ដែលនៅត្រង់ញកក្នុំ ខាងចុងស្រុកដូច្នោះ ។

បានឮមកថា ព្រះថេរៈបង្រៀនមហាគណៈ ១៨ គណៈ ពួកភិក្ខុ ៣ ម៉ឺនរូប តាំងនៅក្នុងឱវាទរបស់លោកសម្រេចអរហត្តហើយ ។ តមក មានភិក្ខុមួយរូប ពិចារណាថា ខាងក្នុងខ្លួនអញ មានគុណប្រមាណមិនបាន គុណរបស់អាចារ្យអញ មានដូចម្តេចហ្ន៎ កំពុងពិចារណា ក៏ឃើញភាពជាបុថុជ្ជនទើបគិតថា អាចារ្យពួកយើងជាទីពឹងរបស់ពួកអ្នកដទៃ តែមិនអាចជាទីពឹងរបស់ខ្លួនបានឡើយ អញនឹងឲ្យឱវាទដល់លោក ហើយក៏ហោះមកចុះក្បែរវត្តចូលទៅរកអាចារ្យ អង្គុយក្នុងទីសម្រាកពេលថ្ងៃ ធ្វើវត្តហើយ ក៏អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះថេរៈពោលថា អាវុសោអ្នកកាន់បិណ្ឌបាតជាវត្ត លោកមកព្រោះហេតុអ្វី ភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំ

ជាអ្នកមកហើយ ដោយគិតថា នឹងសួរនូវអនុមោទនាត្រឹមតែមួយបទ ។ ព្រះថេរៈពោលថា ប្រហែលជាមិនមានឱកាសទេ កិកូនោះពោលថា លោកម្ចាស់ខ្ញុំនឹងសួរក្នុងវេលាឈរ ត្រង់រោងត្រែរិះ ព្រះថេរៈពោលថា ក្នុងទីនោះ ពួកអ្នកជនៃក៏នឹងសួរ ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងផ្លូវដែលត្រាច់បិណ្ឌបាត ព្រះថេរៈពោលថា សូម្បីក្នុងផ្លូវនោះ ពួកអ្នកជនៃក៏នឹងសួរ ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងទីស្មៀកសំពត់ពីរជាន់ ក្នុងទីជណ្តប់សង្ឃាដិ ក្នុងទីនាំយកបាត្រចេញ ក្នុងវេលាត្រាច់ទៅក្នុងស្រុក ហើយឆាន់បបរក្នុងរោងឆាន់ ព្រះថេរៈពោលថា ក្នុងទីទាំងនោះ មានពួកព្រះថេរៈខាងអដ្ឋកថា បន្ទោបង់សេចក្តីសង្ស័យរបស់ខ្លួន ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងវេលាចេញអំពីក្នុងស្រុក ព្រះថេរៈពោលថា ក្នុងទីនោះ ក៏មានពួកអ្នកជនៃសួរ ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងរវាងផ្លូវ ក្នុងវេលាសម្រេចការឆាន់ ក្នុងរោងអាហារ ក្នុងវេលាលាងជើង ក្នុងវេលាលុបមុខ ក្នុងទីសម្រាកពេលថ្ងៃ ព្រះថេរៈពោលថា តាំងពីពេលនោះទៅដរាបដល់ភ្លឺ ក៏មានពួកជនជនៃទៀតសាកសួរ ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងវេលាយកឈើសូនំ ហើយទៅកាន់ទីលុបមុខ ព្រះថេរៈពោលថា ពេលនោះ ពួកជនជនៃក៏នឹងសួរ ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងវេលាលុបមុខស្រេចហើយ ព្រះថេរៈពោលថា ក្នុងពេលនោះ ពួកជនជនៃក៏សួរ ។ កិកូនោះពោលថា ខ្ញុំនឹងសួរក្នុងវេលាចូលសេនាសនៈ ហើយអង្គុយ ព្រះថេរៈពោលថា ក្នុងពេលនោះពួកជនជនៃក៏សួរ ។ កិកូនោះពោលថា លោកម្ចាស់ គួរជាឱកាស និងពេលវេលារបស់ពួកជនដែលលុបមុខ

ស្រេចហើយ ចូលកាន់សេនាសនៈ ឲ្យកាពកក់ក្តៅ ដោយការពត់ក្អែន ๓-๔ ស្របក់ ហើយធ្វើការងារដោយការយកចិត្តទុកជាក់យ៉ាងមានហេតុផល មិនមែនឬ បពិត្រលោកម្ចាស់ លោកម្ចាស់មិនមានសូម្បីតែខណៈនៃការស្ងាប់សូមលោកម្ចាស់ ដូចជាបន្ទុះក្តារចុះ[๑] លោកម្ចាស់ ជាទីពឹងរបស់អ្នកដទៃចុះ លោកម្ចាស់មិនអាចជាទីពឹងរបស់ខ្លួន ខ្ញុំមិនមានសេចក្តីត្រូវការដោយការអនុមោទនារបស់លោកម្ចាស់ ពោលហើយ ក៏ហោះទៅលើអាកាស ។

ព្រះថេរៈជ្រាបថា ការងារដែលជាប់ទាក់ទងនឹងការសិក្សារៀនសូត្ររបស់ភិក្ខុរូបនេះមិនមាន លោកមកដោយគិតថា នឹងប្រៀនប្រដៅអញ ហើយគិតថា ឥឡូវនេះ នឹងមិនមានឱកាស វេលាជិតភ្លឺអញនឹងទៅ ហើយក៏រក្សាបាត្រ ចីវរទុកជិតៗ ទូន្មានធម៌អស់បឋមយាម និងមជ្ឈិមយាម ខណៈដែលព្រះថេរៈមួយរូបរៀនខន្ធសៈ ហើយចេញទៅក្នុងបច្ឆិមយាម ក៏កាន់បាត្រ ចីវរ ចេញទៅជាមួយគ្នានឹងព្រះថេរៈនោះឯង ពួកសិស្សដែលអង្គុយ យល់ថា អាចារ្យចេញទៅដោយធុរៈណាមួយអស់កាយយូរ ។ ព្រះថេរៈដែលចេញទៅ ក៏ធ្វើការយល់ថា ជាភិក្ខុដែលរួមអាចារ្យគ្នារូបខ្លះនុ៎ះឯង ។ បានឮថា ព្រះថេរៈគិតថា ឈ្មោះថា កាពជាព្រះអរហន្ត សម្រាប់បុគ្គលដូចអញ នឹងមានអ្វីធ្ងន់ហ្នឹ៎ តែមតែ ๒-๓ ថ្ងៃប៉ុណ្ណោះឯង ក៏នឹងសម្រេច ហើយសឹមត្រឡប់មក ដូច្នេះ ទើបមិនប្រាប់ពួកកូនសិស្សឡើយ ក្នុងថ្ងៃ ๑๓ កើត ๒ ខែ អាសាឍ ទៅកាន់ព្រំភ្នំខាងបូងស្រុក កាលឡើងកាន់ទីចង្រ្កមហើយ យកចិត្តទុកជាក់ក្នុងកម្មដ្ឋាន

๑- បន្ទុះក្តារដែលគេជាន់ដើរឆ្លង ។

ក្នុងថ្ងៃនោះក៏កាន់យកអរហត្តផលមិនបាន ។ កាលដល់ថ្ងៃខុបោសថ ក៏គិតថា អញមកដោយគិតថា ២-៣ ថ្ងៃ អញនឹងយកអរហត្តផលឲ្យបាន ក៏នៅតែមិនបាន ៣ ខែក៏ជូចបីថ្ងៃទុំ៎ះឯង រង់ចាំដល់ថ្ងៃមហាបវារណានឹងជឹង ដល់ចូលវស្សាហើយ ក៏នៅតែកាន់យកមិនបាន ។ ក្នុងថ្ងៃបវារណា លោកគិតថា អញមកហើយដោយគិតថា ដោយ ២-៣ ថ្ងៃ អញនឹងកាន់យកអរហត្តផលឲ្យបាន នេះ ៣ ខែហើយ ក៏មិនអាចនឹងយកបាន ចំណែកពួកសព្រហ្មចារីនឹងបវារណាដោយវិសុទ្ធិបវារណា កាលលោកគិតដូច្នោះ ទឹកភ្នែកក៏ហូរ ។ បន្ទាប់ពីនោះ លោកគិតថា មគ្គផលនឹងមិនកើតទៀង ព្រោះឥរិយាបថ ៤ របស់អញនៅលើគ្រែ បើឥឡូវនេះ មិនទាន់សម្រេចអរហត្តផល អញនឹងមិនព្រមទម្រេតខ្នងលើគ្រែជាដាច់ខាត និងមិនព្រម លាងជើង ហើយក៏ឲ្យលើកយកគ្រែទៅរក្សាទុក រដូវវស្សាក៏មកដល់ទៀត ។ លោកក៏កាន់យកអរហត្តផលមិនបាន ទឹកភ្នែកក៏ហូរ ក្នុងថ្ងៃបវារណា ២៩ ដង ។ ពួកក្មេងក្នុងស្រុក នាំគ្នាយកបន្ទាមកជូសត្រង់ទីដែលបែក ក្នុងជើងទាំងពីរខាងរបស់ព្រះថេរៈ ។ សូម្បីកាលនឹងនាំគ្នាលេង ក៏និយាយលេងថា សូមឲ្យជើងទាំងពីរ ដូចជើងរបស់លោកម្ចាស់មហាសិវត្ថេរចុះ ។

ក្នុងថ្ងៃមហាបវារណាឆ្នាំទី ៣០ ព្រះថេរៈឈរគោងបន្ទុះក្តារ សម្រាប់ផ្អែក គិតថា កាលអញធ្វើសមណធម៌មកអស់ ៣០ ឆ្នាំហើយ អញក៏មិនអាចសម្រេចអរហត្តផលបាន ក្នុងអត្តភាពរបស់អញនេះ មគ្គ ឬផល រមែងមិនមានដល់អញពិត អញមិនបានបវារណាដោយវិសុទ្ធិបវារណាជាមួយនឹង

សព្រហ្មចារី ។ កាលលោកគិតយ៉ាងនោះ ក៏កើតទោមនស្សឡើង ទឹកភ្នែកក៏ហូរ ។ ខណៈនោះ ក្នុងទីជិតៗ មានទេពធីតាអង្គមួយ កំពុងឈរយំ ។ ព្រះថេរៈសួរថា អ្នកណាយំទីនេះ ទេពធីតាពោលថា ខ្ញុំទេពធីតា ។ ព្រះថេរៈពោលថា យំធ្វើអ្វី ទេពធីតាពោលថា កាលមគ្គផលកំពុងកើត ព្រោះការយំ ខ្ញុំគិតថា សូម្បីអញក៏នឹងឲ្យកើតមគ្គផលមួយ ឬពីរ ទើបយំ ។

តពីនោះព្រះថេរៈក៏គិតថា នែ មហាសិវៈ សូម្បីតែទេពធីតា ក៏នៅមកចំអកអ្នកដែរ នេះគួរដល់អ្នកឬ ហើយក៏ចម្រើនវិបស្សនា បានកាន់យកភាពជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទាទាំងឡាយហើយ ។

លោកគិតថា ឥឡូវនេះ អញនឹងដេក ហើយក៏រៀបចំសេនាសនៈក្រាលគ្រែ តាំង ទឹកក្នុងទីមានទឹក គិតថា អញនឹងលាងជើងទាំងពីរ ហើយអង្គុយចុះត្រង់កាំជណ្តើរ ។ ពួកសិស្សរបស់លោក ក៏នាំគ្នាគិតថា កាលអាចារ្យរបស់យើងទៅធ្វើសមណធម៌រហូត ៣០ ឆ្នាំ លោកអាចធ្វើគុណវិសេសឲ្យកើត ឬមិនអាចហ្នឹ យើញថា លោកសម្រេចអរហត្ត ហើយអង្គុយចុះ ដើម្បីលាងជើង ទើបគិតថា អាចារ្យពួកយើង កាលពួកសិស្សដូចយើងនៅមាន គិតថា នឹងលាងជើង ដោយខ្ជួនឯងនេះ មិនមែនជាឋានៈយើងនឹងលាង យើងនឹងលាង ទាំង ៣០០០០ អង្គ ក៏ហោះមកថ្វាយបង្គំ ហើយពោលថា ខ្ញុំនឹងលាងជើងប្រគេន ព្រះថេរៈយាត់ថា ខ្ញុំខានលាងជើងអស់ ៣០ ឆ្នាំហើយ ពួកលោកមិនចាំបាច់ទេ ខ្ញុំនឹងលាងឯង ។

សក្កទេវរាជក៏ទ្រង់ពិចារណាថា លោកម្ចាស់មហាសិវត្ថេររបស់អញ

សម្រេចអរហត្តហើយ កាលពួកសិស្ស ๓ ម៉ឺនអង្គមកហើយ ដោយគិតថា ពួកយើងនឹងលាងជើងប្រគេន ក៏មិនឲ្យលាង កាលឧបដ្ឋាក ដូចអញ្ញទៅមាន លោកម្ចាស់គិតថា នឹងលាងជើងខ្លួនឯង នេះប្រពៃត្តទៅមិនបាន ហើយទ្រង់សម្រេចព្រះហឫទ័យថា អញនឹងលាងជើងប្រគេន ក៏មកជ្រាកដក្នុងសម្នាក់របស់ពួកភិក្ខុ មួយអន្ទើដោយសុជាតាទេវី ។ ទ្រង់បញ្ជូនាងសុជាតា ដែលជាអសុរកញ្ញាឲ្យដើរទៅមុន ឲ្យបើកឱកាសថា បពិត្រលោកម្ចាស់ លោកម្ចាស់សូមពួកលោកចៀសចេញទៅ សូមឲ្យឱកាសដល់មាតុគ្រាម ហើយទ្រង់ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយច្រហោងចំពោះមុខគ្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងលាងជើងប្រគេន ព្រះថេរៈឆ្លើយថា កោសី អាត្មាភាពមិនបានលាងជើងមកអស់ ๓๐ ឆ្នាំហើយ ដោយប្រក្រតីឈ្មោះថា ភិនខ្លួនមនុស្សជារបស់គួរខ្ពើមសម្រាប់ពួកទេវតា សូម្បីនៅឆ្ងាយរាប់រយយោជន៍ ដូចយកសាកសពមកព្យួរត្រង់ក អាត្មាភាពនឹងលាងឯង ។ សក្កទេវរាជត្រាស់ថា បពិត្រលោកម្ចាស់ ឈ្មោះថា ភិនយ៉ាងនេះមិនជ្រាកដ ព្រោះថា ភិនសីលរបស់លោកម្ចាស់ រំលងទេវលោក ๖ ជាន់ រហូតដល់ភវគ្គព្រហ្មខាងលើ មិនមានភិនដទៃក្រៃលែងជាងភិនសីល បពិត្រលោកម្ចាស់ ខ្ញុំមកព្រោះភិនសីលរបស់លោកម្ចាស់ ហើយក៏ទ្រង់យកព្រះហស្តឆ្វេងចាប់ត្រង់កជើង យកព្រះហស្តស្តាំអង្អែលបាតជើង ។ ជើងរបស់លោក ក៏ដូចគ្នានឹងជើងរបស់ទារកមួយរំពេច ។ កាលសក្កទេវរាជ ទ្រង់លាងជើងប្រគេនស្រេចហើយ ទ្រង់ថ្វាយបង្គំ ហើយឃាងទៅកាន់ទេវលោកវិញ ។

គប្បីជ្រាបថា លោកហៅអារម្មណ៍របស់វិបស្សនាក្តី វិបស្សនាក្តី មគ្គក្តី ផលក្តី ថាទោមនស្សដែលនៅមានវិតក្ក នៅមានវិចារៈ និងថា ទោមនស្ស ដែលមិនមានវិតក្ក មិនមានវិចារៈ ដោយអំណាចការយល់របស់កិក្ខុដែល អាស្រ័យទោមនស្ស ដែលកើតឡើងហើយ ពិចារណាថា អញមិនបានបរា-រណាដោយវិសុទ្ធិបរាណាជាមួយសព្រហ្មចារីទាំងឡាយដូចពោលមកនេះ ។

ក្នុងរឿងទោមនស្សនេះ មានកិក្ខុមួយរូបផ្តើមវិបស្សនាក្នុងទោមនស្ស ដែលនៅមានវិតក្ក នៅមានវិចារៈ មកពិចារណាថា ទោមនស្សនេះអាស្រ័យអ្វី ក៏ដឹងច្បាស់ថា អាស្រ័យវត្ថុ ទើបតាំងនៅក្នុងព្រះអរហត្តផលដោយលំដាប់ ដោយន័យដែលពោលហើយក្នុងពួកធម៌ដែលមានផស្សៈជាគម្រប់ ៥ នុ៎ះឯង ។ មួយរូបទៀត ផ្តើមវិបស្សនាក្នុងទោមនស្ស ដែលមិនមានវិតក្ក មិនមានវិចារៈ ក៏តាំងនៅក្នុងអរហត្តផល តាមន័យដែលពោលហើយដូចគ្នា ។

ក្នុងទោមនស្សដែលតាំងមាំហើយទាំងនោះ ទោមនស្សដែលមិនមានវិតក្ក មិនមានវិចារៈប្រណីតជាង ដែលមានវិតក្ក និងវិចារៈ វិបស្សនាក្នុងទោម-នស្ស ដែលមិនមានវិតក្ក មិនមានវិចារៈក៏ប្រណីតជាងវិបស្សនាក្នុងទោម-នស្សដែលមានវិតក្ក មានវិចារៈផងដែរ ផលសមាបត្តិក្នុងទោមនស្ស ដែល មិនមានវិតក្ក មិនមានវិចារៈ ក៏ប្រណីតជាងផលសមាបត្តិក្នុងទោមនស្ស ដែលនៅមានវិតក្ក នៅមានវិចារៈនោះឯង ។ ព្រោះហេតុនោះ ទើបព្រះមាន ព្រះភាគត្រាស់ថា ទោមនស្សណា ដែលមិនមានវិតក្ក មិនមានវិចារៈ ប្រសើរ ជាង ដូច្នេះ ។

បទថា **ឯវ្ហ្ហ ឧបេក្ខា ន សេវិតព្ហ** សេចក្តីថា មិនគប្បីសេព គេហសិតឧបេក្ខា គឺឧបេក្ខាដែលអាស្រ័យផ្ទះបែបនោះ ។ ដែលឈ្មោះថា គេហសិតឧបេក្ខា បានដល់ ឧបេក្ខាដែលអាស្រ័យកាមគុណដែលជាប់ ដែលជំពាក់ កើតឡើងក្នុងកាមគុណនោះឯង ប្រព្រឹត្តទៅកន្ងងរូបជាដើមមិនបាន ដូចរុយចោមរោមជុំស្ពរអំពៅ ក្នុងអារម្មណ៍ដែលគួរស្រឡាញ់ ដែលមកកាន់គន្ងង ក្នុងទ្វារទាំង ៦ យ៉ាងនេះ គឺក្នុងវេទនាទាំងនោះ គេហសិតឧបេក្ខា ៦ យ៉ាង តើដូចម្តេច បុថុជ្ជន ជាបុគ្គលល្ងង់ វង្វេង ឬបុថុជ្ជន ដែលមិនទាន់ផ្ចាញ់កិលេសបាន មិនទាន់ផ្ចាញ់វិបាកបាន ជាអ្នកឃើញថា មិនមានទោស ជាអ្នកមិនចេះដឹងពុទ្ធវចន: ឃើញរូបដោយភ្នែកហើយ ក៏កើតឧបេក្ខាឡើង ឧបេក្ខាណាមានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្ងងនូវរូបឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា គេហសិតឧបេក្ខា ដូច្នេះជាដើម ។ បទថា **ឯវ្ហ្ហ ឧបេក្ខា សេវិតព្ហ** គឺគប្បីសេពនេក្ខម្មសិតឧបេក្ខា គឺឧបេក្ខាដែលអាស្រ័យការចេញចាកផ្ទះបែបនេះ ។ ដែលឈ្មោះថា នេក្ខម្មសិតឧបេក្ខា បានដល់ ឧបេក្ខាដែលប្រកបព្រមដោយវិបស្សនាញាណ ដែលកើតដល់បុគ្គលអ្នកមិនត្រេកអរក្នុងអារម្មណ៍ដែលគួរស្រឡាញ់ មិនប្រទូសក្នុងអារម្មណ៍ដែលមិនជាទីស្រឡាញ់ មិនវង្វេង ព្រោះមិនមានការសម្ងឹងពិចារណាក្នុងអារម្មណ៍ មានអារម្មណ៍ដែលគួរស្រឡាញ់ជាដើម ដែលមកកាន់គន្ងង ក្នុងទ្វារទាំង ៦ យ៉ាងនេះ គឺក្នុងវេទនាទាំងនោះ នេក្ខម្មសិតឧបេក្ខា ៦ តើដូចម្តេច បុគ្គលកាលដឹងច្បាស់ថា រូបមានការមិនទៀង មានការប្រែប្រួល មានការវិនាស

មានការរលត់ យើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដូច្នេះថា រូប ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណា មានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្ងងនូវរូបឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា នេក្ខម្មសិតឧបេក្ខា ដូច្នេះជាដើម ។ ម្យ៉ាងទៀត ឧបេក្ខាដែលជាកណ្តាលក្នុងអារម្មណ៍ទាំងនោះ មានចំណែកស្មើគ្នានឹងវេទនា ក៏ចាត់ជាឧបេក្ខាក្នុងទីនេះបានដូចគ្នា ។ បទថា **សេវិតព្វា** សេចក្តីថា គប្បីសេព ឧបេក្ខាដែលកើតដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរព្ចកដល់ ដោយអំណាចឈានទី ១-២-៣ និងទី ៤ នេះ ។

ក្នុងបទទាំងនោះ បទថា **យញ្ចោ សវិតក្ពំ សវិចារំ** គឺក្នុងឧបេក្ខា ដែលអាស្រ័យការចេញចាកផ្ទះនោះ ក៏គប្បីជ្រាបថា ឧបេក្ខានៅមានការត្រិះរិះ នៅមានការពិចារណា ដែលកើតឡើងដោយអំណាចការចេញចាកផ្ទះ ដោយ អំណាចវិបស្សនា ដោយអំណាចការតាមព្ចកដល់ និងដោយអំណាច បឋមជ្ឈានណា ។ បទថា **យញ្ចោ អវិតក្ពា អវិចារំ** គឺគប្បីជ្រាបថា ឧបេក្ខា ដែលមិនមានវិតក្ក មិនមានវិចារ: ដែលកើតឡើងដោយអំណាចទុតិយជ្ឈាន និងតតិជ្ឈានជាដើមណា ។ បទថា **យេ អវិតក្ពេ អវិចារេ បណីតតរេ** សេចក្តីថា ក្នុងឧបេក្ខាទាំង ២ នេះ ឧបេក្ខាដែលមិនមានវិតក្ក មិនមានវិចារ: នោះ ប្រណីតជាង ។ ដោយពាក្យនេះ ឈ្មោះថា លោកពោលដល់អ្វី ពោល

ដល់អរហត្តផលរបស់គន្ធព្វពីររូប ។ ពិតហើយ ភិក្ខុមួយរូប កាលផ្តើមវិបស្សនាក្នុងឧបេក្ខាដែលនៅមានវិតក្ក នៅមានវិចារៈ ហើយក៏វិលមកពិចារណាថា ឧបេក្ខានេះ អាស្រ័យអ្វី ក៏ជ្រាបច្បាស់ថា អាស្រ័យត្រង់វត្ត ហើយក៏តាំងនៅក្នុងអរហត្តផលដោយលំដាប់ តាមន័យដែលពោលហើយក្នុងពួកដែលមានផស្សៈជាគម្រប់ ៥ នុ៎ះឯង ។ មួយរូប ផ្តើមវិបស្សនា ក្នុងឧបេក្ខាដែលមិនមានវិតក្ក មិនមានវិចារៈ ហើយក៏តាំងនៅក្នុងអរហត្តផល តាមន័យដូចពោលហើយដូចគ្នា ។

ក្នុងឧបេក្ខាដែលតាំងមាំទាំងនោះ ឧបេក្ខាដែលមិនមានវិតក្ក មិនមានវិចារៈ ប្រណីតជាងឧបេក្ខាដែលនៅមានវិតក្ក នៅមានវិចារៈ ឧបេក្ខាវិបស្សនាដែលមិនមានវិតក្ក មិនមានវិចារៈ ប្រណីតជាងឧបេក្ខាវិបស្សនាដែលមានវិតក្ក មានវិចារៈ ឧបេក្ខាផលសមាបត្តិ ដែលមិនមានវិតក្ក មិនមានវិចារៈ ប៉ុណ្ណោះ ប្រណីតជាងឧបេក្ខាផលសមាបត្តិដែលនៅមានវិតក្ក នៅមានវិចារៈ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ឧបេក្ខាណា ដែលមិនមានវិតក្កវិចារៈ ឧបេក្ខានោះ ប្រសើរជាង ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់ថា បពិត្រទេវានមិន្ទ ភិក្ខុលុះតែប្រតិបត្តិយ៉ាងនោះឯង ទើបឈ្មោះថា ជាអ្នកប្រតិបត្តិនូវបដិបទា ជាដំណើរដ៏សមគួរដល់សេចក្តីរម្ងាប់ ដូចចំណែកនៃបបញ្ចសញ្ញា ហើយទ្រង់ក៏បញ្ចប់ទេសនាដោយកំពូល គឺអរហត្តផល ។ ចំណែកសក្កទេវរាជ ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ ។

ធម្មតាព្រះអធ្យាស្រ័យរបស់ព្រះពុទ្ធមិនមានអាក្រក់ មានតែថ្នាក់កំពូលប៉ុណ្ណោះ ។ កាលទ្រង់សម្តែងធម៌ដល់បុគ្គលម្នាក់ក្តី ដល់បុគ្គលច្រើននាក់ក្តី សុទ្ធតែទ្រង់កាន់យកកំពូល ដោយអរហត្តផលប៉ុណ្ណោះ ។ តែពួកសត្វតាំងនៅក្នុងឧបនិស្សយដែលសមគួរដល់ខ្លួន ។ ពួកខ្លះក៏ជាសោតាបន្ន ពួកខ្លះក៏ជាសកទាគាមី ពួកខ្លះក៏ជាអនាគាមី ពួកខ្លះក៏ជាអរហន្ត ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ដូចព្រះរាជា ពួកវេនេយ្យសត្វ ដូចពួកព្រះរាជកុមារ ។ ដូចឧបមាថា ក្នុងវេលាសោយព្រះក្រយាហារ ព្រះរាជាទ្រង់ពូតជុំបាយតាមខ្នាតព្រះអង្គ ហើយទ្រង់បញ្ជូកពួកព្រះរាជកុមារ ។ ពួកព្រះរាជកុមារទាំងនោះ ក៏ទ្រង់ធ្វើជុំបាយតាមខ្នាត ព្រះឱស្ឋរបស់ព្រះអង្គអំពីជុំបាយនោះ យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះ ទ្រង់កាន់យកកំពូលដោយអរហត្តផល ដោយទេសនាដែលសមគួរដល់ព្រះអធ្យាស្រ័យរបស់ព្រះអង្គប៉ុណ្ណោះ វេនេយ្យសត្វទាំង-ឡាយ ក៏រមែងទទួលយកសោតាបត្តិផល សកទាគាមិផល អនាគាមិផល ឬអរហត្តផលនុ៎ះឯង អំពីព្រះធម៌ទេសនានោះ តាមប្រមាណនៃឧបនិស្សយរបស់ខ្លួន ។

ឯសក្កទេវរាជ កាលទ្រង់ជាព្រះសោតាបន្នហើយ ក៏ទ្រង់ចុតិចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគនុ៎ះឯង ហើយក៏ទ្រង់កើតក្លាយជាសក្កទេវរាជកំលោះ ។ ធម្មតាទីទៅ និងទីមកនៃអត្តភាពរបស់ពួកទេវតាដែលចុតិ រមែងមិនប្រាកដ ។ រមែងដូចជាការប្រាសទៅនៃអណ្តាតប្រទីប ដូច្នោះ ទើបពួកទេវតាដ៏សេសមិនដឹង ។ ឯអ្នកដែលដឹង មានតែពីរអង្គប៉ុណ្ណោះ គឺសក្កទេវរាជ

ព្រោះទ្រង់ចុតិខ្ជួនឯង ១ ព្រះមានព្រះភាគ ព្រោះទ្រង់មានព្រះញាណដែលមិន
មានអ្វីរារាំងបាន ១ ។ លំដាប់នោះ សក្កទេវរាជទ្រង់គិតថា ព្រះមានព្រះភាគ
ទ្រង់សម្តែងផលរបស់បុគ្គលដែលកើតក្នុងទី ៣ ស្ថានប៉ុណ្ណោះដល់អញ ឯមគ្គ
ឬផលនេះ មិនមានបុគ្គលណាហោះទៅយកបានដូចបក្សី ព្រោះការកាន់យក
មគ្គ ឬផលនោះ គប្បីកើតបានដោយការមកនៃបុព្វភាគបដិបទានៃមគ្គ ឬផល
ណ្ហើយចុះ អញនឹងទូលសួរបដិបទាដែលជាចំណែកខាងដើមរបស់ព្រះខីណា-
ស្រពក្នុងខាងលើឲ្យបាន ។ បន្ទាប់អំពីនោះ កាលនឹងទូលសួរបដិបទានោះ
ទើបត្រាស់ពាក្យថា បពិត្រព្រះអង្គទ្រង់និទ៊ុក្ខ ចុះភិក្ខុប្រតិបត្តិដូចម្តេចជាដើម ។

[៩៦] បណ្តាបទទាំងនោះ បទថា **ចាតិមោក្ខសំវរាយ** គឺដោយ
ការសង្រួមក្នុងសីលដែលខ្ពស់បំផុត និងចម្រើនបំផុត ។ បទជាដើមថា **ការយ-
សមាចារំ** ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្តែងដល់ការសង្រួមក្នុងបាតិ-
មោក្ខ ដោយអំណាចមារយាទផ្ទូវកាយ ដែលគប្បីសេព ។ ឯឈ្មោះថា ពាក្យ
ដែលជាប់ទាក់ទងនឹងសីលនេះ រមែងជាការពោលដោយអំណាចកម្មបថ ឬ
ដោយអំណាចបញ្ញត្តិក៏បាន ។ ក្នុងកម្មបថ និងបញ្ញត្តិនោះ ដែលបុគ្គលនឹង
ពោលដោយអំណាចកម្មបថ ត្រូវពោលដល់មារយាទផ្ទូវកាយជាមុន ដែល
មិនគប្បីសេព ដោយការសម្ងាប់សត្ត ការលួចទ្រព្យ និងការប្រព្រឹត្តខុសក្នុង
កាមទាំងឡាយ កាលនឹងពោលដោយអំណាចបញ្ញត្តិ ត្រូវពោលដោយអំណាច
បញ្ញត្តិសិក្ខាបទ និងការល្មើសតាមផ្ទូវកាយ ។ ត្រូវពោលដល់មារយាទផ្ទូវ
កាយ ដែលគប្បីសេពដោយចេតនា ជាគ្រឿងវៀរចាកការសម្ងាប់សត្វជាដើម

និងដោយបញ្ញត្តិសិក្ខាបទ និងការមិនល្មើសក្នុងកាយទ្វារ ។ ត្រូវពោលដល់មារយោទតាមផ្លូវវាចា ដែលមិនគប្បីសេព ដោយការប្រព្រឹត្តអាក្រក់តាមវាចា មានការនិយាយកុហកជាដើម និងដោយបញ្ញត្តិសិក្ខាបទ និងការល្មើសក្នុងវចីទ្វារ ត្រូវពោលដល់មារយោទតាមផ្លូវវាចា ដែលគប្បីសេពដោយចេតនាជាគ្រឿងវៀរចាកអំពីការពោលកុហកជាដើម និងដោយបញ្ញត្តិសិក្ខាបទ និងការមិនល្មើសក្នុងវចីទ្វារ ។

ចំណែកការស្វែងរក បានដល់ ការស្វែងរកដោយកាយ និងវាចានុ៎ះឯង ។ ការស្វែងរកនោះ ក៏ជាការកាន់យកហើយដោយសព្ទ គឺមារយោទតាមផ្លូវកាយ និងវាចា ព្រោះធម្មតាសីលដែលមានអាជីវៈជាគម្រប់ ៨ រមែងកើតឡើងតែក្នុង ២ ទ្វារនេះប៉ុណ្ណោះ មិនមែនក្នុងអាកាស ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ការស្វែងរកនោះមួយផ្នែកជាទៃផ្សេង ដើម្បីទ្រង់សម្តែងដល់សីលដែលមានអាជីវៈជាគម្រប់ ៨ ។ ក្នុងការស្វែងរកនោះ មិនគប្បីពោលដល់ការស្វែងរកដែលគប្បីសេព ដោយការស្វែងរកដែលមិនប្រសើរ គប្បីពោលដល់ការស្វែងរកដែលគប្បីសេព ដោយការស្វែងរកដ៏ប្រសើរ ។

សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ការស្វែងរកនេះមាន ២ ប្រការ គឺការស្វែងរកមិនប្រសើរ ១ ការស្វែងរកប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមិនប្រសើរ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ស្វែងរកបរស់មានជាតិជាធម្មតាថែមទៀត ខ្លួនឯងមានជរាជាធម្មតា

ស្វែងរកបស់មានជរាជាធម្មតាថែមទៀត ខ្ញុំនឯងមានព្យាធិជាធម្មតា ស្វែងរកបស់មានព្យាធិជាធម្មតាថែមទៀត ខ្ញុំនឯងមានមរណៈជាធម្មតា ស្វែងរកបស់មានមរណៈជាធម្មតាថែមទៀត ខ្ញុំនឯងមានសេចក្តីសោកជាធម្មតា ស្វែងរកបស់មានសេចក្តីសោកជាធម្មតាថែមទៀត ខ្ញុំនឯងមានសេចក្តីសៅហ្មងជាធម្មតា ស្វែងរកបស់មានសេចក្តីសៅហ្មងជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ថាអ្វី ដែលមានជាតិជាធម្មតា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថា បុត្រភរិយា មានជាតិជាធម្មតា ទាសី ទាសៈ មានជាតិជាធម្មតា ពពែ ចៀម មានជាតិជាធម្មតា មាន់ ជ្រូក មានជាតិជាធម្មតា ដំរី គោ សេះ លាឈ្មោល និងញី មានជាតិជាធម្មតា មាស ប្រាក់ មានជាតិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជាតិធម៌ទាំងនោះឯង ជាឧបធិ (កិលេស) បុគ្គលនេះ មានចិត្តងោកជ្រប់ លង់ស៊ប់ក្នុងឧបធិទាំងនុ៎ះ ឈ្មោះថា ខ្ញុំនឯងមានជាតិជាធម្មតា ស្វែងរកបស់មានជាតិជាធម្មតាថែមទៀត ។បេ។ ស្វែងរកបស់មានជរាជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វី ដែលមានព្យាធិជាធម្មតា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថា បុត្រភរិយាមានព្យាធិជាធម្មតា ។បេ។ ស្វែងរកបស់មានព្យាធិជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វី ដែលមានមរណៈជាធម្មតា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថា បុត្រភរិយាមានមរណៈជាធម្មតា ។បេ។ ស្វែងរកបស់មានមរណៈជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយថាអ្វី មានសោកជាធម្មតា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថា

បុត្រកវិយោមានសោកជាធម្មតា ฯបេฯ ស្វែងរកវបស់មានសេចក្តីសោកជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វី មានសេចក្តីសៅហ្មងជាធម្មតា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថា បុត្រកវិយោមានសេចក្តីសៅហ្មងជាធម្មតា ฯបេฯ ស្វែងរកវបស់មានសេចក្តីសៅហ្មងជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកមិនប្រសើរ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ការស្វែងរកដែលមិនប្រសើរមាន ៥ យ៉ាង ដោយអំណាចកុហនាជាដើម មាន ៦ យ៉ាង ដោយអំណាចអគោចរជាដើម មាន ២១ យ៉ាង ដោយអំណាចវេជ្ជកម្មជាដើម ។ ការស្វែងរកដែលមិនសមគួរទាំងអស់ ដែលប្រព្រឹត្តទៅយ៉ាងនេះ គប្បីជ្រាបថា ជាការស្វែងរកដែលមិនប្រសើរ ដោយពិត ។

ម្នាលភិក្ខុទាំងឡាយ ឯការស្វែងរកដ៏ប្រសើរ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានជាតិ ឥតមានគុណជាតិដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា ដឹងច្បាស់នូវទោសក្នុងជរាធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានជរា ឥតមានគុណជាតិដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា ដឹងច្បាស់នូវទោសក្នុងព្យាធិធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានព្យាធិ ឥតមានគុណជាតិដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានមរណៈជាធម្មតា ដឹងច្បាស់នូវទោសក្នុងមរណធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមាន

មរណ: ឥតមានគុណជាតិដទៃស្មើ ជាទីក្សេមចាកយោគ: ខ្លួនឯងមានសោក ជាធម្មតា ដឹងច្បាស់នូវទោស ក្នុងសោកធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានសេចក្តីសោក ឥតមានគុណជាតិដទៃស្មើ ជាទីក្សេមចាកយោគ: ខ្លួនឯង មានសេចក្តីសៅហ្មងជាធម្មតា ដឹងច្បាស់នូវទោស ក្នុងសង្កិលេសធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានសង្កិលេសធម៌ ឥតមានគុណជាតិ ដទៃស្មើ ជាទីក្សេមចាកយោគ: ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែង រកដ៏ប្រសើរ ។ ម្យ៉ាងទៀត ការវៀរនូវកុហនា ៥ យ៉ាង មានការគៃបន្ទំជាដើម អគោចរ ៦ កន្ទែង និងអនេសនា ២១ យ៉ាង ហើយស្វែងរកដោយការត្រាច់ បិណ្ឌបាតដោយធម៌ស្មើ ក៏គប្បីជ្រាបថា ជាការស្វែងរកដ៏ប្រសើរនោះឯង ។

ចំពោះក្នុងរឿងមារយាទរបស់កាយនេះ មារយាទណាមួយ ដែលព្រះ មានព្រះភាគត្រាស់ថា មិនគប្បីសេពមារយាទទាំងនោះ ត្រូវកុំសេពតាំងពី ពេលដែលធ្វើគ្រឿងឧបករណ៍នៃការស្វែងរក ការធ្វើសេចក្តីព្យាយាម និង ការទៅក្នុងចំណែកខាងដើម នៃការសម្ចាប់សត្វជាដើមនោះឯង ។ ក្រៅអំពី នេះ គប្បីសេពតាំងពីដើម ។ បុគ្គលដែលមិនអាចក៏គប្បីធ្វើ សូម្បីត្រឹមតែ ចិត្តឲ្យកើតឡើង (គិតក៏បាន) ។ ម្យ៉ាងទៀត មិនត្រូវសេពមារយាទផ្ទូវ កាយ ដូចភិក្ខុទេវទត្តជាដើម ដែលព្យាយាមដើម្បីបំបែកសង្ឆជាដើម ។ ត្រូវ សេពមារយាទផ្ទូវកាយ ដូចព្រះធម្មសេនាបតី និងព្រះមហាមោគ្គល្លានជាដើម ដែលប្រព្រឹត្តទៅដោយអំណាចការទៅកាន់ទីបម្រើព្រះរតនត្រ័យមួយថ្ងៃ ២-៣ ដង ។ មារយាទផ្ទូវវាចា ដែលមិនគប្បីសេព ក៏ដូចវាចាភិក្ខុទេវទត្តជាដើម

ដែលបន្ទឹវាចាដោយអំណាចការបញ្ជូនខ្ទាន់ធ្នូជាដើម ។ គប្បីសេពមារយាទផ្ទូវ
វាចា ដែលដូចវាចាព្រះធម្មសេនាបតី និងព្រះមហាមោគ្គល្លានជាដើម ដែល
ប្រព្រឹត្តទៅដោយអំណាចការប្រកាសព្រះគុណព្រះត្រៃរតនៈ ។ មិនត្រូវសេព
ការស្វែងរកដូចភិក្ខុទេវទត្តជាដើម ដែលស្វែងរកក្នុងការស្វែងរកមិនប្រសើរ ។
ត្រូវសេពការស្វែងរកដូចព្រះធម្មសេនាបតី និងព្រះមហាមោគ្គល្លានជាដើម
ដែលស្វែងរកតែការស្វែងរកដ៏ប្រសើរប៉ុណ្ណោះ ។ បទថា **ឯវំ បដិបន្នោ ទោ**
សេចក្តីថា បពិត្រទេវានមិន្ទ ភិក្ខុដែលលះមារយាទផ្ទូវកាយ និងវាចា និងការ
ស្វែងរកដែលមិនគប្បីសេព បដិបត្តិដើម្បីសេចក្តីពេញបរិបូណ៌នៃមារយាទ
ផ្ទូវកាយ និងវាចា និងការស្វែងរកដែលគប្បីសេព ដូចពោលមកនេះហើយ
ក៏រមែងឈ្មោះថា ជាអ្នកបដិបត្តិដើម្បីសង្រួមក្នុងសីលដែលខ្ពស់បំផុត និង
ចម្រើនបំផុត ព្រះមានព្រះភាគត្រាស់បដិបទាដែលជាបុព្វភាគ ដែលនឹងត្រូវ
មករបស់បុគ្គលដែលអស់អាសវៈហើយ ដោយប្រការដូច្នេះ ។

[៩៧] ក្នុងទុតិយបុច្ឆាបទថា **ឥន្ទ្រិយសំវរាយ** បានដល់ ដើម្បីបិទនូវ
ឥន្ទ្រិយទាំងឡាយ គឺដើម្បីរក្សាទ្វារបាន ដោយអត្ថថា ដើម្បីសេចក្តីសង្រួម
នូវទ្វារទាំងឡាយ ។ ក្នុងការធ្វើយដល់សក្កទេវរាជនោះ ព្រះមានព្រះភាគ
បានត្រាស់ពាក្យជាដើមថា រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែក ដើម្បីទ្រង់
សម្តែងដល់ការសង្រួមឥន្ទ្រិយ ដោយអំណាចរូបដែលគប្បីសេពជាដើម ។ បទ
ថា **ឯវំ វុត្តេ** សេចក្តីថា កាលព្រះមានព្រះភាគបានត្រាស់យ៉ាងនេះ សក្កទេវរាជ
ក៏ទ្រង់កើតសេចក្តីញ័ររន្ធត់ថា ធម៌នេះក៏ត្រូវកើតដោយលក្ខណៈដូចគ្នានោះឯង

ព្រោះទ្រង់ដោះស្រាយបញ្ហា ក្នុងរឿងសោមនស្សជាដើម ជារឿងដែលទ្រង់បានស្តាប់មកហើយអំពីខាងដើម ទើបទ្រង់ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះ គឺបានត្រាស់ពាក្យជាដើមនេះថា ខ្ញុំព្រះអង្គអាចដឹងសេចក្តីច្បាស់ដោយពិស្តារយ៉ាងនេះបាន ។ សូម្បីព្រះមានព្រះភាគ ក៏ប្រទានឱកាសដល់សក្កៈ ទើបទ្រង់ស្ងៀម ។ សេចក្តីពិតថា បុគ្គលដែលមិនអាចធ្វើឲ្យសម្រេចប្រយោជន៍បាននោះ ជាអ្នកពេញចិត្តនិយាយ ឬបុគ្គលដែលអាចធ្វើឲ្យសម្រេចប្រយោជន៍បាននោះ មិនជាអ្នកពេញចិត្តនិយាយ បុគ្គលបែបនោះ ព្រះមានព្រះភាគមិនប្រទានឱកាសឲ្យ ។ ចំណែកសក្កទេវរាជនេះ ព្រោះទ្រង់ជាអ្នកចូលចិត្តនិយាយផង ទ្រង់អាចធ្វើប្រយោជន៍ឲ្យសម្រេចបានផង ដូច្នោះ ទើបព្រះមានព្រះភាគ ប្រទានឱកាសដល់ទ្រង់ ។

ក្នុងរឿងនៃការសង្រួមឥន្ទ្រិយនោះ នេះជាសេចក្តីសង្ខេប ក្នុងបទជាដើមថា មិនគប្បីសេពបែបនោះ ។ កាលមើលរូបណា សេចក្តីស្រឡាញ់ជាដើម រមែងកើតឡើង មិនគប្បីសេព មិនគប្បីសម្លឹងមើលរូបនោះ តែកាលមើលរូបណា សេចក្តីសម្គាល់ថា មិនស្អាតរមែងតាំងមាំ សេចក្តីជ្រះថ្លារមែងកើតឡើង ឬការត្រឡប់បាននូវសេចក្តីសម្គាល់ថា មិនទៀង រមែងមានគប្បីសេពរូបនោះ ។ កាលស្តាប់សំឡេង ដែលមានអក្ខរៈវិចិត្រក្តី មានព្យញ្ជនៈវិចិត្រក្តី រមែងកើតសេចក្តីស្រឡាញ់ជាដើម សំឡេងបែបនោះមិនគប្បីសេព ។ តែកាលស្តាប់សំឡេងណា សូម្បីតែចម្រៀងរបស់កុម្ភទាសី ដែលអាស្រ័យអត្ថ អាស្រ័យធម៌ រមែងកើតសេចក្តីជ្រះថ្លាឡើង ឬសេចក្តីនឿយណាយរមែង

តាំងមាំ សំឡេងបែបនោះគប្បីសេព ។ កាលហិតកិនណា រមែងកើតតម្រេកជាដើម កិនខ្លះមិនគប្បីសេព ។ តែកាលហិតកិនណា រមែងត្រឡប់បានសេចក្តីយល់ថា មិនស្អាតជាដើម កិនយ៉ាងនោះ គប្បីសេព កាលលិទ្ធរសណា រមែងកើតតម្រេកជាដើម រសយ៉ាងនោះ មិនគប្បីសេព ។ តែកាលលិទ្ធរសណា រមែងកើតសេចក្តីយល់ថា ជារបស់បដិកូលក្នុងអាហារ និងរមែងអាស្រ័យកម្លាំងកាយ ព្រោះរសដែលបានលិទ្ធជាបច្ច័យហើយ អាចឈានចុះកាន់អរិយភូមិបាន ដូចសាមណេរសិវៈ ក្នុយព្រះមហាសិវត្ថេរ ឬកាលបរិភោគ ក៏រមែងមានការអស់កិលេសទៅ រសបែបនោះគប្បីសេព ។ កាលពាល់ត្រូវផោដ្ឋព្វៈណា រមែងកើតរាគៈជាដើម មិនគប្បីសេពផោដ្ឋព្វៈបែបនោះ ។ តែកាលពាល់ត្រូវវត្តុណា រមែងមានការអស់កិលេស ជាគ្រឿងត្រាំបាន ដូចរបស់ព្រះសារីបុត្រជាដើម ទាំងសេចក្តីព្យាយាម ក៏បានទទួលការផ្គងទុកយ៉ាងល្អ និងទាំងប្រជុំជនខាងក្រោយ ក៏រមែងបានទទួលការអនុគ្រោះដោយការដើរតាម គំរូដូចដែលបានឃើញផោដ្ឋព្វៈបែបនោះ គប្បីសេពចុះ ។

បានឮមកថា ព្រះសារីបុត្តត្ថេរ មិនធ្លាប់ទម្រេតខ្នងលើគ្រែ អស់ ៣០ ឆ្នាំ ព្រះមហាមោគ្គល្លានត្ថេរក៏ដូចគ្នា ។ ព្រះមហាកស្សបត្ថេរ មិនធ្លាប់ទម្រេតខ្នងលើគ្រែ ១២០ ឆ្នាំ ។ ព្រះអនុរុទ្ធត្ថេរ ៥៥ ឆ្នាំ ព្រះកទិយត្ថេរ ៣០ ឆ្នាំ ព្រះសោណត្ថេរ ១៨ ឆ្នាំ ព្រះរដ្ឋបាលត្ថេរ ១២ ឆ្នាំ ព្រះអានន្ទត្ថេរ ១៥ ឆ្នាំ ព្រះរាហុលត្ថេរ ១២ ឆ្នាំ ព្រះពាកុលត្ថេរ ៨០ ឆ្នាំ ព្រះនាឡកត្ថេរមិនធ្លាប់ទម្រេតខ្នងលើគ្រែដរាបបរិនិព្វាន ។

កាលពិចារណាធម៌ដែលគប្បីជ័ងច្បាស់បាន ដោយចិត្តពួកណា រមែងកើតរាគៈជាដើម ឬការសម្ញ័ងវៃចង់បាន ដោយនយ័ជាដើមថា ឱហ្ន៎ សូមឲ្យគ្រឿងឧបករណ៍ គឺសម្បត្តិដែលជាទីត្រេកអររបស់អ្នកដទៃនោះ មកជារបស់អញចុះ មកកាន់គន្ធង មិនគប្បីសេព ។ តែធម៌ទាំងឡាយរបស់ព្រះថេរៈ ៣ រូប ដោយអំណាចមេត្តាជាដើមយ៉ាងនេះថា សូមឲ្យពួកសត្វទាំងអស់ ជាអ្នកមិនមានពៀរនឹងគ្នាចុះ ធម៌បែបនេះ គប្បីសេព ។

បានឮថា ព្រះថេរៈ ៣ រូប ក្នុងថ្ងៃបូលវសព្ទ បានធ្វើកតិកាថា អកុសលវិតក្ក មានកាមវិតក្កជាដើម ពួកយើងមិនគប្បីត្រិះរិះ ។ លុះក្នុងថ្ងៃបវារណា ព្រះសង្ឃត្តេរសួរភិក្ខុពីរូបថា លោកម្ចាស់ ក្នុង ៣ ខែនេះ លោកឲ្យចិត្តសុះទៅប៉ុន្មានកន្លែង ។ ព្រះថេរៈអង្គទី ១ ឆ្លើយប្រាប់ថា លោកម្ចាស់ ខ្ញុំមិនបានឲ្យរត់ចេញក្រៅបរិវេណឡើយ ។ ទើបព្រះសង្ឃត្តេរ សួរអង្គទី ២ ថា របស់លោកប៉ុន្មានកន្លែង ។ អង្គទី ២ នោះឆ្លើយថា លោកម្ចាស់ ខ្ញុំមិនបានឲ្យរត់ទៅក្រៅលំនៅ ។ កាលសួរហើយ ព្រះថេរៈទាំង ២ រូប ក៏នាំគ្នាសួរព្រះថេរៈថា ចុះលោកម្ចាស់វិញ ។ ព្រះថេរៈឆ្លើយថា ខ្ញុំមិនបានឲ្យសុះចេញពីខន្ធ ៥ ដែលតម្កល់មាំក្នុងកាយខាងក្នុងឡើយ ។ ទើបលោកទាំង ២ អង្គ ឆ្លើយប្រាប់ថា លោកម្ចាស់ លោកបានធ្វើវត្តដែលធ្វើបានលំបាកហើយ ។ គប្បីសេពធម៌ដែលត្រូវជ័ងច្បាស់បាន ដោយចិត្តបែបនេះចុះ ។

[๙๘] បទថា **ឯកន្តវាទា** *គឺដែលឈ្មោះថា អ្នកមានពាក្យដែលមានទីបំផុតតែម្យ៉ាង ព្រោះទីបំផុតនៃពាក្យរបស់ជនទាំងនេះតែមួយប៉ុណ្ណោះ មិន*

មែន ២ ពាក្យ ។ សក្កទេវរាជទ្រង់សួរថា រមែងពោលតែម្យ៉ាងប៉ុណ្ណោះ ។ បទថា **ឯកន្តសីលា** គឺមានមារយាទតែមួយ ។ បទថា **ឯកន្តជន្ធា** គឺមានលទ្ធិតែមួយ ។ បទថា **ឯកន្តអជ្ឈោសានា** គឺមានការបញ្ចប់ មានទីបំផុតតែមួយ ។ បទថា **អនេកធាតុ នានាធាតុ ទោ ទេវានមិន្ទ លោកោ** សេចក្តីថា បពិត្រទេវានមិន្ទ លោកនេះ មានអធ្យាស្រ័យមិនមែនតែមួយ មានអធ្យាស្រ័យផ្សងៗ គ្នា កាលម្នាក់ចង់ដើរ ម្នាក់ចង់ឈរ កាលទៀតម្នាក់ចង់ឈរ ម្នាក់ចង់ដេក សត្វទាំង ២ ឈ្មោះថា មានអធ្យាស្រ័យដូចគ្នា រកបានដោយក្រ ។

ក្នុងលោកដែលមានធាតុច្រើន និងមានធាតុផ្សងៗ គ្នានោះ ពួកសត្វ រមែងប្រកាន់មាំ រមែងកាន់យកធាតុណាមួយ អធ្យាស្រ័យណាមួយ ក៏រមែងប្រកាន់មាំ រមែងកាន់យកធាតុនោះៗ ឯង ដោយកម្ចាំង ដោយការស្ទាបអង្អែល ព្រោះដូច្នោះ ទើបលោកសម្តែង គឺប្រារព្ធថា រមែងចាប់យកច្រើនជាង រមែងកាន់យកមកពោលយ៉ាងល្អ ដោយកម្ចាំង និងដោយការស្ទាបអង្អែល ។ បទថា **ឯទមេវ សច្ចំ មោឃមញ្ញំ** គឺពាក្យរបស់ពួកយើងប៉ុណ្ណោះ ឯងពិត ពាក្យរបស់អ្នកដទៃសោះសូន្យ គឺទទេ បានដល់ មិនមានប្រយោជន៍ ។

[៩៩] សេចក្តីវិនាស ដែលហៅថា **អន្ត** គឺទីបំផុត ក្នុងបទថា **អច្ចន្តនិដ្ឋា** ឈ្មោះថា អ្នកមានការរលត់កន្ធងចំណែក ព្រោះការរលត់របស់បុគ្គលទាំងនោះ កន្ធងទីបំផុតហើយ ។ ការរលត់របស់ជនណា សេចក្តីប្រាថ្នាយ៉ាងក្រៃលែង គឺព្រះនិព្វានណា នុ៉ះលោកហៅថា វត្ថុមានទីបំផុតកន្ធងចំណែក ឈានកន្ធងសេចក្តីវិនាសរបស់ពួកជនទាំងអស់ ។ បទថា **យោគក្ខេមោ** ជា

ឈ្មោះរបស់ព្រះនិព្វានទុំ៎ះឯង ។ ឈ្មោះថា **អច្ចន្តយោគក្ខេមី** *ព្រោះក្សេមចាក កិលេស ជាគ្រឿងប្រកបសត្វក្នុងទុក្ខរបស់ជនទាំងនេះមាន ។ ឈ្មោះថា* **ព្រហ្មចារី** *ព្រោះបុគ្គលនោះរមែងប្រព្រឹត្តផ្លូវដែលធ្វើយចាកសឹកសត្រូវ ដែលឈ្មោះថា ប្រសើរ ព្រោះអត្ថថា ប្រសើរបំផុត ។ ឈ្មោះថា* **អច្ចន្តព្រហ្មចារី** *ព្រោះជាការប្រព្រឹត្តកន្លងចំណែក ឈ្មោះថា អ្នកប្រព្រឹត្តប្រសើរកន្លងចំណែក ។ បទថា* **បរិយោសានំ** *ជាឈ្មោះរបស់ព្រះនិព្វានទុំ៎ះឯង ។ ឈ្មោះថា* **អច្ចន្ត-បរិយោសានា** *ព្រោះបុគ្គលនោះ មានទីបញ្ចប់ដែលកន្លងចំណែក ។ បទថា* **តណ្ហាសង្ខយវិមុត្តោ** *ក្នុងបទថា* **តណ្ហាសង្ខយវិមុត្តោ** *នេះ ជាមគ្គក៏បាន ជាព្រះនិព្វានក៏បាន មគ្គឈ្មោះថា ជាទីអស់ទៅព្រមនៃតណ្ហា ព្រោះធ្វើតណ្ហាឲ្យអស់ទៅព្រម គឺឲ្យវិនាសទៅ ព្រះនិព្វាន ឈ្មោះថា ជាទីអស់ទៅព្រមនៃតណ្ហា ព្រោះតណ្ហា កាលមកដល់ព្រះនិព្វាននោះហើយ ក៏រមែងអស់ទៅព្រម គឺរមែងវិនាសទៅ ឈ្មោះថា បុគ្គលរួចផុតហើយ ព្រោះការអស់ទៅព្រមនៃតណ្ហា ព្រោះរួចផុតហើយដោយមគ្គ ដែលជាគ្រឿងអស់ទៅនៃតណ្ហាប្បរួចផុត គឺរួចផុតយ៉ាងក្រៃលែង ព្រោះព្រះនិព្វានដែលជាទីអស់ទៅព្រមនៃតណ្ហា ។ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់ព្យាករបញ្ហាគ្រប់ទាំង ១៤ ប្រការហើយ ។ ឈ្មោះបញ្ហា ១៤ ប្រការ គឺ ឥសិ្សា និងមច្ឆរិយៈ គឺសេចក្តីច្រណែន និងសេចក្តីកំណាញ់ ១ បិយាបិយៈ គឺការស្រឡាញ់ និងការស្អប់ ១ ឆន្ទៈ គឺការពេញចិត្ត ១ វិតក្ក គឺសេចក្តីត្រិះរិះ ១ បបញ្ចធម៌ជាគ្រឿងយឺតយូរ ១ សោមនស្ស ១ ទោមនស្ស ១*

ឧបេក្ខា ๑ កាយសមាចារ គឺការប្រព្រឹត្តតាមផ្លូវកាយ ๑ វចីសមាចារ គឺការប្រព្រឹត្តតាមផ្លូវវាចា ๑ បរិយេសនា គឺការស្វែងរក ๑ ឥន្ទ្រិយសំវរៈ គឺការសង្រួមឥន្ទ្រិយ ๑ អនេកធាតុ គឺធាតុមិនតែមួយ ๑ អច្ចន្តនិដ្ឋា គឺការរម្ងាប់កន្ទួចចំណែក ๑ ។

[๑๐๐] *តណ្ហា លោកហៅថា* **ឱជា** *គឺការញាប់ញ័រ ព្រោះអត្ថថា ញាប់ញ័រ ។ សេចក្តីញាប់ញ័រនោះ ហៅថា រោគ ព្រោះអត្ថថា បៀតបៀន ហៅថា បូស ព្រោះអត្ថថា ប្រទូស្តខាងក្នុង ហៅថា សរ ព្រោះអត្ថថា តាមចាក់ដោត ។ បទថា* **តស្មា អយំ បុរិសោ** *គឺសេចក្តីញាប់ញ័រ រមែងអូសទាញបុរស ដើម្បីប្រយោជន៍ដល់ការកើតក្រៃលែងឡើងក្នុងភពទាំងនោះ តាមសមគួរដល់កម្ម ដែលខ្លួនបានធ្វើ ព្រោះហេតុណា ព្រោះហេតុនោះ ទើបបុរសនេះ រមែងជល់នូវភាពខ្ពង់ខ្ពស់ និងថោកទាប ដោយអំណាចកពទាំងនោះ ។ ខ្ពស់ក្នុងព្រហ្មលោក ទាបក្នុងទេវលោក ខ្ពស់ក្នុងទេវលោក ទាបក្នុងមនុស្សលោក ខ្ពស់ក្នុងមនុស្សលោក ទាបក្នុងអបាយ ។ បទថា* **យេសាហំ ភន្តេ** *កាត់បទជា* **យេសំ អហំ ភន្តេ ។** *ព្រោះបទថា* **យេសាហំ** *ក្នុងទីនេះ កើតដោយអំណាចសន្ធិ ។ បទថា* **យថាសុតំ យថាបរិយត្តំ** *គឺខ្ញុំព្រះអង្គបានស្តាប់មក និងបានរៀនមកយ៉ាងណា ។ បទថា* **ធម្មំ ទេសេមិ** *គឺរមែងសម្តែងធម៌ គឺវត្តបទ ៧ ប្រការ ។ បទថា* **ន ចាហំ តេសំ** *គឺចំណែកខ្ញុំព្រះអង្គមិនជាសាវ័ករបស់សមណព្រាហ្មណ៍ទាំងនោះទេ ។ សក្កទេវរាជ ទ្រង់បង្ហាញឲ្យព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តី ដែលព្រះអង្គទ្រង់ជាព្រះសោតាបន្ន*

ដោយព្រះតម្រាស់ជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គ ... ដូច្នេះ ឯង ។ បទថា **វេធប្បដិលาភំ** *គឺការបានចំពោះនូវសេចក្តីត្រេកអរ ។*

[๑๐๑] *បទថា* **เทวาสุรสงฺคโม** *បានដល់ សង្គ្រាមរបស់ពួកទេវតា និងពួកអសុរ ។ បទថា* **สมุปพฺยูฬฺหา** *បានដល់ ប្រឈមមុខគ្នា បានដល់ លក្ខណៈដែលយកថ្ងាសចូលទៅប៉ះទង្គិចគ្នា ។ បានឮថា ពេលខ្លះ ជនទាំងនោះ ច្បាំងគ្នាលើផ្ទៃមហាសមុទ្រក៏មាន ។ តែក្នុងទីនោះ មិនមានការសម្ងាប់គ្នានិងគ្នាដោយការកាប់ ការចាក់ជាដើម ។ គ្រាន់តែយកឈ្នះ និងចាញ់ ដូចការច្បាំងគ្នារវាងឈើ និងពពែប៉ុណ្ណោះឯង ។ ជួនកាលពួកទេវតាក៏ឈ្នះ ជួនកាលក៏ពួកអសុរឈ្នះ ។ ក្នុងការច្បាំងគ្នានោះ ពួកទេវតាឈ្នះពួកអសុរ ដោយការមិនត្រឡប់មកទៀត ក្នុងសង្គ្រាមណា សក្កទេវរាជទ្រង់សំដៅយកសង្គ្រាមនោះ ទើបត្រាស់ពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសង្គ្រាមនោះ ដូច្នេះជាដើម ។ បទថា* **อุภยเมตฺถ** *បានដល់ ពួកទេវតាប៉ុណ្ណោះ រមែងបរិភោគឱជារសទាំងពីរ គឺពីរយ៉ាងនេះ ក្នុងទេវលោកនេះ ព្រោះដូច្នោះ កាលសក្កទេវរាជនោះ ទ្រង់ពិចារណា សេចក្តីត្រេកអរ និងសោមនស្សដ៏មានកម្លាំង ទើបកើតឡើង ។ បទថា* **สฆณฺหาวโร** *បានដល់ បុគ្គលដែលត្រាច់ជាប្រចាំព្រមដោយអាជ្ញា ។ លោកសម្តែងថា បានជាអ្នកត្រាច់ទៅព្រមដោយការកាន់ដំបង និងការកាន់សស្ត្រា មិនមែនជាក់អាជ្ញា និងអាវុធចុះទេ ។ បទថា* **ฬกนฺตนิฏฺฐาย** *បានដល់ ដើម្បីសេចក្តីនឿយណាយក្នុងការវិលវល់ ស្ងាប់កើត ដោយទីបំផុតតែម្យ៉ាងប៉ុណ្ណោះ ។ នយគ្រប់យ៉ាងបានពោលក្នុងមហា-*

គោរិន្ទសូត្រចប់ហើយ ។ ពាក្យថា **បវេទេសិ** *បានដល់ ពោល គឺសម្តែង ។*

[๑๐๒] *បទថា* **ឯតេ** *គឺក្នុងឱកាសនេះឯង ។ បទថា* **ទេវភូតស្ស មេ សតោ** *គឺខ្ញុំព្រះអង្គជាទេវតា ។ បទថា* **បុនេវាយុ វ មេ លទ្ធោ** *សេចក្តីថា ខ្ញុំព្រះអង្គបាននូវជីវិតដោយផលកម្មជនែទៀត ។ ដោយបទនេះ សក្កទេវរាជ ទ្រង់បើកបង្ហាញដល់ចុតិ និងបដិសន្ធិរបស់ព្រះអង្គ ។*

[๑๐๓] *បទថា* **ឯវិយា កាយា** *គឺអត្តភាពជាទិព្វ ។ បទថា* **អាយុំ ហិត្វា អមានុសំ** *គឺលះបង់អាយុទិព្វ ។ បទថា* **អម្ហេឡោ គព្ភមេស្សាមិ** *គឺជាអ្នកមិនវង្វេង ព្រោះមានគតិទៀង នឹងចូលដល់គភ៌ក្នុងត្រកូលក្សត្រជាដើម ដែលចិត្តរបស់ខ្ញុំព្រះអង្គត្រេកអរប៉ុណ្ណោះ ។ សក្កទេវរាជ ទ្រង់សម្តែងសេចក្តីនេះថា ក្នុងទេវតា និងក្នុងមនុស្ស ๗ ជង ។*

[๑๐๔] *បទថា* **ញាយេន វិហរិស្សាមិ** *សេចក្តីថា ខ្ញុំព្រះអង្គ កើតក្នុងពួកមនុស្ស នឹងនៅដោយសេចក្តីដឹងយ៉ាងត្រឹមត្រូវ គឺតាមហេតុផលដោយស្មើ ព្រោះភាពជាអ្នកមិនគួរដល់ការផ្តាច់ជីវិតមាតាជាដើម ។*

[๑๐๕] *សក្កទេវរាជ ទ្រង់ត្រាស់សំដៅដល់សកទាគាមិមគ្គនេះថា* **សម្ពោធិ ចេ ភវិស្សតិ** *ទ្រង់សម្តែងថា បើខ្ញុំព្រះអង្គនឹងជាសកទាគាមី ។ បទថា* **អញ្ញាតា វិហរិស្សាមិ** *គឺខ្ញុំព្រះអង្គនឹងជាអ្នកដឹងទូទៅ គឺនឹងជាអ្នកប្រាជ្ញាដឹងទូទៅ ។ បទថា* **ស្វេ អន្តោ ភវិស្សតិ** *គឺទីបំផុតក្នុងមនុស្សលោកនោះឯង នឹងមាន ។*

[๑๐๖] *สกฺกទេវរាជត្រាស់ថា* **បុន ទេវោ ភវិស្សាមិ ទេវលោកស្មិ-មុត្តមោ** *ដោយពាក្យនេះថា ខ្ញុំព្រះអង្គនឹងជាទេវតាដ៏ឧត្តមក្នុងទេវលោកទៀត ។*

[๑๐๗] *បទថា* **អត្តិមេ វត្តមានម្ហិ** *គឺក្នុងភពដែល មានក្នុងទីបំផុត ដែលកំពុងប្រព្រឹត្តទៅ ។ បទថា* **សោ ឯវាសោ ភវិស្សតិ** *គឺពួកទេវតាទាំងនោះណា ដែលមិនតិចជាងអ្នកណា ទាំងដោយអាយុ ទាំងដោយបញ្ញា ជាអ្នកចម្រើនបំផុត ប្រណីតជាងពួកទេវតាទាំងអស់ ក្នុងទីបំផុតភពនោះ នឹងជាលំនៅរបស់ខ្ញុំព្រះអង្គ ។ បានឮមកថា សក្កទេវរាជនេះ ចុតិចាកអត្តភាពនៃសក្កៈនោះហើយ នឹងជាអ្នកមានក្រសែខ្ពស់ទៅជរាបដល់ជាន់អកនិដ្ឋ ព្រោះទ្រង់នឹងបានជាអនាគាមិមគ្គ ក្នុងអត្តភាពនោះ កាលទ្រង់កើតក្នុងជាន់អវិហាជាដើម ចុងក្រោយនឹងជាអកនិដ្ឋគាមីព្រហ្ម ។ សក្កទេវរាជសំដៅដល់សេចក្តីនោះ ទើបត្រាស់យ៉ាងនោះ ។*

បានឮថា សក្កទេវរាជនេះ នឹងទ្រង់នៅក្នុងជាន់អវិហា ๑ ពាន់កប្ប ក្នុងជាន់អតប្បា ๒ ពាន់កប្ប ក្នុងជាន់សុទស្សា ๔ ពាន់កប្ប ក្នុងជាន់សុទស្សី ๘ ពាន់កប្ប ក្នុងជាន់អកនិដ្ឋ ๑๖ ពាន់កប្ប ដូចពោលមកនេះ សក្កទេវរាជនឹងសោយអាយុព្រហ្ម ๓ ម៉ឺន ๑ ពាន់កប្ប ។ ពិតហើយ ឈ្មោះថា សត្វត្រេកអរយ៉ាងក្រៃលែង ក្នុងការវិលស្ទាប់វិលកើត មានប្រមាណអាយុដូចគ្នាពិត ទាំង ๓ នាក់នេះ បានដល់ សក្កទេវរាជជាស្តេចរបស់ទេវតា អនាថ-បិណ្ឌិកគហបតី នាងវិសាខាមហឧបាសិកា ។ ធម្មតាអ្នកមានចំណែកសេចក្តីសុខស្មើនឹងអ្នកទាំងនេះ មិនមាន ។

[๑๐๘] *បទថា* **អបរិយោសិតសង្កប្បោ** *គឺមានមនោរថនៅមិនទាន់ដល់ទីបំផុត ។ បទថា* **យស្សុ មញ្ញាមិ សមណោ** *គឺខ្ញុំព្រះអង្គ រមែងសម្គាល់

ថា សមណៈពួកណាជាអ្នកមានប្រក្រតីនៅស្ងប់ស្ងៀម ។ បទថា **អារាធនា** *ប្រែថា សេចក្តីសម្រេច ។ បទថា* **វិរាធនា** *ប្រែថា សេចក្តីមិនសម្រេច[1] ។ បទថា* **ន សម្ភោន្តិ** *គឺមិនអាចនិយាយឲ្យសម្រេចបាន ។ បទថា* **អាទិច្ចពន្ធុំ** *គឺព្រះអាទិត្យ ក៏ជាគោតមគោត្រផងដែរ ។ ព្រះមានព្រះភាគ ទ្រង់ជាគោតម-គោត្រ ដូច្នោះ ទើបសក្កទេវរាជត្រាស់យ៉ាងនោះ ។ បទថា* **យំ កវោមសេ** *គឺពីមុនមក ពួកខ្ញុំព្រះអង្គបានធ្វើនមស្ការណាដល់ព្រហ្ម ។ បទថា* **សមំ ឧវេហិ** *គឺព្រមទាំងពួកទេវតា ។ សក្កទេវរាជទ្រង់សម្តែងថា ឥឡូវនេះ តាំងពីនេះទៅ ពួកខ្ញុំព្រះអង្គមិនមានការធ្វើការនមស្ការដល់ព្រហ្ម ពួកខ្ញុំព្រះអង្គលែងថ្វាយបង្គំព្រហ្ម ។ បទថា* **សាមំ កវោម** *គឺពួកខ្ញុំព្រះអង្គសូមធ្វើនូវការនមស្ការ ។*

[๑๐๙-๑๑๐] *បទថា* **បរាមសិត្វា** *សេចក្តីថា សក្កទេវរាជមានព្រះហឫទ័យត្រេកអរ ទ្រង់ទះផែនដី ទ្រង់ទះដើម្បីបំណងឲ្យជាសាក្សី ដូចអ្នកយកដៃស្ទាបដៃសម្ងាញ់ ត្រាស់ថា យើងក៏ដូចលោកដែលមិនញាប់ញ័រ ។ បទថា* **អដ្ឋិប្បញ្ហោ** *គឺបញ្ហាដែលបានទូលអារាធនា សេចក្តីថា បញ្ហាដែលត្រូវទូលសួរ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។*

អដ្ឋកថាសក្កប្បញ្ហសូត្រ ក្នុងទីឃនិកាយឈ្មោះសុមង្គលវិលាសិនី ចប់ ៗ

សក្កប្បញ្ហសូត្រ ចប់

សូត្រទី ៨ ចប់

๑- បិដកខ្មែរ អារាធនា ប្រែថា សេចក្តីជ្រះថ្លា វិរាធនា ប្រែថា សេចក្តីមិនជ្រះថ្លា ។

សុត្តន្តបិដក

មហាសតិប្បដ្ឋានសូត្រ ទី ៩

[១១១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងកម្មាសទម្មនិគម របស់អ្នកកុរុ ក្នុងដែនកុរុ ។ កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសទម្មនិគមនោះឯង បានត្រាស់ហៅភិក្ខុទាំងឡាយ ថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមួលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរម្ងាប់បង់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិប្បដ្ឋានទាំង ៤ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ចាត់កិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ១ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ចាត់កិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ១ ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្ចាត់នូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿង

กំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ๑ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោសមន្ទក្នុងលោកចេញ ๑ ฯ

ខន្ធសារកថា ចប់

[๑๑๒] *ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ តើដោយវិធីដូចម្តេច ฯ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តាំងសតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ฯ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើញចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើញចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី (ភិក្ខុ) សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញញ្ញនឹងរម្ងាប់កាយសង្ខារ (អស្សាសបស្សាសៈ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹង*

រម្ងាប់កាយសង្ខារ ដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹងក្តី កូនសិស្សនៃជាងក្រឡឹងក្តី ដែលបុិនប្រសប់ កាលទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងវែង ឬកាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងខ្លី មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី (ភិក្ខុ) សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយ-សង្ខារ ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង (កាយរបស់ខ្លួន) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅ (កាយរបស់បុគ្គលដទៃ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង និងកាយខាងក្រៅ (កាយរបស់ខ្លួន និងកាយរបស់បុគ្គលដទៃ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំ

កើតឡើងក្នុងកាយ គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយគ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ ទាំងធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ๔ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ដង់ឡើងចំពោះថាកាយមានមែន (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ๔ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

អានាបានបព្វៈ ចប់

[๑๑๓] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុកាលដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ។ មួយទៀត ភិក្ខុនោះបានតាំងនូវកាយដោយអាការយ៉ាងណាៗ ក៏ដឹងច្បាស់នូវកាយនោះ ដោយអាការយ៉ាងនោះៗ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង យ៉ាងនេះ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅ គ្រប់*

ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុង និង ខាងក្រៅ គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំ កើតឡើង ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណា ឃើញនូវធម៌ ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅ ក្នុង កាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ។ មួយទៀត ស្មារតីរបស់កិក្ខុ នោះ ក៏ផ្ដង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យ ចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ កិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ๔ ផង មិនប្រកៀកប្រកាន់អ្វី តិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ កិក្ខុពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

ឥរិយាបថបព្វៈ ចប់

[๑๑๔] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខ នៅមានទៀត កិក្ខុធ្វើ នូវសម្បជញ្ញៈ គឺសេចក្ដីដឹងខ្លួន ក្នុងការដើរទៅមុខ ឬថយក្រោយ ធ្វើនូវ សេចក្ដីដឹងខ្លួន ក្នុងកាលក្រឡេកមើលទៅមុខ ឬប្រឡេកមើលទៅទិសផ្សេងៗ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលបត់ដៃជើង ឬលាដៃជើង ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលទ្រទ្រង់នូវសង្ឃាដិ ចីវរ និងបាត្រ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាល បរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយៈ ជញ្ជាប់ (នូវភេសជ្ជៈ មាន*

សប្បិជាដើម) ធ្វើនូវសេចក្តីជឹងខ្លួន ក្នុងកាលបន្ទោបង់នូវឧច្ចារបស្សាវៈ ធ្វើនូវសេចក្តីជឹងខ្លួន ក្នុងកាលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ស្ងៀម ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង និងខាងក្រៅ គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើត ទាំងធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ងង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ๔ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

សម្បជញ្ញបព្វៈ ចប់

[๑๑๕] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើ តាំងអំពីបាតជើងឡើងទៅ ខាង*

ក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយ វត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម ភាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់ភាវ ទឹកមាត់ ទឹកសម្បារ ទឹករំអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ទៃដែលមានមាត់ទាំង ២ ខាង ពេញដោយធញ្ញជាតិ មានប្រការផ្សេងៗ ធញ្ញជាតិទាំងនោះ គឺស្រូវឱ្យាយស ស្រូវឱ្យាយក្រហម សណ្តែកបាយ សណ្តែកវាជមាស ល្ង អង្ករ បុរសដែលមានចក្ខុគប្បីស្រាយនូវទៃនោះ ហើយពិនិត្យមើលដូច្នេះថា នេះស្រូវឱ្យាយស នេះស្រូវឱ្យាយក្រហម នេះ សណ្តែកបាយ នេះសណ្តែកវាជមាស នេះល្ង នេះអង្ករ មានឧបមាដូចម្តេច មិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាង លើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែល មានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះ ថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម ភាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់ភាវ ទឹកមាត់ ទឹកសម្បារ ទឹករំអិល ទឹកមូត្រ មានឧបមេយ្យដូច្នោះឯង ។ (ភិក្ខុ) ពិចារណាឃើញនូវកាយខាងក្នុងជា

ប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវកាយខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើត ទាំងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ងង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ๔ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

បដិកូលមនសិការបព្វៈ ចប់

[๑๑๖] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថា គ្រាន់តែជាធាតុថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។ ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី*

កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលបុិនប្រសប់ គប្បីពិឃាតគោ ហើយរំលែកជាចំណែកៗ អង្គុយនៅទៀបផ្លូវធំបែកជា ៤ មានឧបមាដូច ម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថា គ្រាន់តែជា ធាតុដូច្នេះថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មាន ឧបមេយ្យដូច្នេះឯង ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុង (ដោយការកំណត់ថាជាធាតុ ៤) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។បេ។

ធាតុមនសិការបព្វៈ ចប់

[๑๑๗] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុឃើញ នូវសរីរៈស្ងាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន ទោះស្ងាប់អស់ ១ ថ្ងៃក្តី ស្ងាប់អស់ ២ ថ្ងៃក្តី អស់ ៣ ថ្ងៃក្តី ដែលកំពុងហើម មានសម្បុរខៀវដោយ ច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្អោន សរីរៈស្ងាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះ ពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុង ជា ប្រក្រតី (ដោយការកំណត់នូវអសុភ មានអសុភកំពុងហើមជាដើម) គ្រប់ ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។បេ។*

[๑๑๘] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្ងាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ត្រដក់គរងទាំងឡាយ កំពុងចឹកស៊ីក្តី ឆ្មាតទាំងឡាយ កំពុងចឹកស៊ីក្តី សត្វស្វានទាំងឡាយ កំពុងកកេរស៊ីក្តី ចចកទាំងឡាយ កំពុងកកេរស៊ីក្តី ជាណកជាតិ (សត្វល្អិតៗ មានរុយជាដើម) ទាំងឡាយផ្សេងៗ កំពុងរួងជញ្ជក់ស៊ីក្តី ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្ហោនសរីរៈស្ងាប់នោះ) មកប្រៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាវៈដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវសភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង ជាប្រក្រតី ដោយការកំណត់នូវអសុក មានអសុកដែលពួកសត្វកំពុងចឹកស៊ីជាដើម គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ងង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមាន

ចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

[១១៩] ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនូវមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្ងាប់ ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែរាងធ្ម៉ឹង ប្រកបដោយសាច់ និងឈាម មានសរសៃជាគ្រឿងចងដូចម្តេចមិញ ។បេ។

[១២០] សីរៈនៅសល់តែរាងធ្ម៉ឹង ឥតមានសាច់ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។បេ។

[១២១] សរីរៈនៅសល់តែរាងធ្ម៉ឹង មិនមានសាច់ និងឈាម មានតែសរសៃជាគ្រឿងចង ។បេ។

[១២២] សរីរៈនូវសល់តែរាងធ្ម៉ឹងទទេ មិនមានសរសៃចងរួបរឹតខ្ចាត់ខ្ចាយរាត់រាយទៅក្នុងទិសតូច និងទិសធំ គឺធ្ម៉ឹងដៃទៅដោយឡែក ធ្ម៉ឹងជើងទៅដោយឡែក ធ្ម៉ឹងស្មងទៅដោយឡែក ធ្ម៉ឹងភ្ជៅទៅដោយឡែក ធ្ម៉ឹងចង្កេះទៅដោយឡែក ធ្ម៉ឹងខ្នងទៅដោយឡែក ធ្ម៉ឹងទ្រនុងខ្នងទៅដោយឡែក ធ្ម៉ឹងជំនីទៅដោយឡែក ធ្ម៉ឹងទ្រូងទៅដោយឡែក ធ្ម៉ឹងស្មាទៅដោយឡែក ធ្ម៉ឹងកំភួនដៃទៅដោយឡែក ធ្ម៉ឹងកទៅដោយឡែក ធ្ម៉ឹងចង្កាទៅដោយឡែក ធ្មេញទៅដោយឡែក លលាដ៍ក្បាលទៅដោយឡែក (ដូចម្តេចមិញ) ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្ងាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាវៈដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ និង

កន្ធ៦នូវការៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវសរីរៈស្ងាប់ដែលសល់តែរាងឆ្អឹងជាដើម) គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ងង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

[๑๒๓] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្ងាប់ដែលគេចោលក្នុងព្រៃស្មាសាន សល់នៅតែឆ្អឹងទេ មានសម្បុរស ដូចជាសម្បុរនៃសង្ខ ។បេ។*

[๑๒๔] *សរីរៈសល់នូវតែឆ្អឹងទេ រោយរាយជាពំនូកៗ កន្លងហួស*

ទៅ ๑ ឆ្នាំហើយ ฯลฯ

[๑๒๕] *សរីរៈសល់នៅតែឆ្អឹងទេ ពុកផុយខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេងៗ (ដូចម្តេចមិញ) ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្ងាប់នោះ) មកប្រៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាវៈដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ងង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។*

នវសីវថิกาបព្វៈ ចប់

กายานุปสฺสนา จบ

[๑๒๖] *ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់តវិយោបថទាំង ๔ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា កាលទទួលសុខវេទនា ប្រកបដោយអាមិស:ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ប្រកបដោយអាមិស: កាលទទួលសុខវេទនាដែលឥតអាមិស:ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ដែលឥតអាមិស: កាលទទួលទុក្ខវេទនាប្រកបដោយអាមិស:ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាប្រកបដោយអាមិស: កាលទទួលទុក្ខវេទនាដែលឥតអាមិស:ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា ដែលឥតអាមិស: កាលទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិស:ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិស: កាលទទួលអទុក្ខមសុខវេទនាដែលឥតអាមិស:ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា ដែលឥតអាមិស: ។ (ភិក្ខុ) ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវវេទនា មានសុខវេទនាជាដើម) យ៉ាងនេះ គ្រប់តវិយោបថទាំង ๔ ផង ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយខាងក្រៅជាប្រក្រតី គ្រប់តវិយោបថទាំង ๔ ផង ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយខាងក្នុង និងខាងក្រៅជា*

ប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ๔ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់នូវវេទនា) របស់ភិក្ខុនោះ ក៏ផ្ដងឡើងចំពោះថា វេទនាទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ (ភិក្ខុ) មានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ๔ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

វេទនានុបស្សនា ចប់

[๑๒๗] *ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ តើដោយវិធីដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ទោះចិត្ត*

ប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ទោះចិត្តដល់នូវការៈជាធំ (គឺរូបាវចរ និងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវការៈជាធំ ទោះចិត្តមិនដល់នូវការៈជាធំ (គឺជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវការៈជាធំ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង (គឺនៅជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង (គឺជារូបាវចរ និងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ទោះចិត្តតាំងនៅមាំ (ជាអប្បនាសមាធិ និងឧបចារសមាធិ) ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ ទោះចិត្តមិនតាំងនៅមាំ (ប្រាសចាកសមាធិទាំង ២) ក៏ដឹងច្បាស់ថា ចិត្តមិនតាំងនៅមាំ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ទោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ (កិកុ) ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុងជាប្រក្រតី គ្រប់តវិយោបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្រៅជាប្រក្រតី គ្រប់តវិយោបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់តវិយោបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើងក្នុងចិត្ត គ្រប់តវិយោបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងចិត្ត គ្រប់តវិយោបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើត ទាំងធម៌ដែលសូន្យទៅក្នុង

จิตฺต คฺรบ់តវិយោបថទាំង ๔ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់នូវចិត្ត) របស់ភិក្ខុនោះ ក៏ផ្ដង់ឡើងចំពោះថា ចិត្តមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនជ្រាជ្រា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ (ភិក្ខុមានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋ) គ្រប់តវិយោបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារ-ណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់តវិយោបថទាំង ៤ យ៉ាងនេះឯង ។

ចិត្តានុបស្សនា ចប់

[๑๒๘] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់តវិយោបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំង-ឡាយជាប្រក្រតី គឺនីវរណៈទាំង ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណធម៌ទាំង ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះកាមច្ឆន្ទៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ក៏រិយាលះបង់នូវកាមច្ឆន្ទៈដែលកើតឡើងហើយ ដោយហេតុ

ណា ក៏ដឹងច្បាស់នូវហេតុនោះផង កាមមច្ឆន្ទៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះព្យាបាទមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះព្យាបាទដែលមិនទាន់កើតឡើងហើយ កើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវព្យាបាទដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ព្យាបាទដែលលះបង់បានហើយ មិនកើតឡើងទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះថីនមិទ្ធមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធមាននៅក្នុងសន្តានចិត្តអាត្មាអញ ទោះថីន-មិទ្ធមិនមានក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា ថីនមិទ្ធមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះថីនមិទ្ធដែលមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវថីនមិទ្ធដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ថីនមិទ្ធដែលលះបង់បានហើយ មិនកើតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ហើយកើត

ទ្បើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវឧទ្ធច្ច-កុក្កុច្ចៈដែលកើតទ្បើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ឧទ្ធច្ចកុក្កុច្ចៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះវិចិកិច្ឆាមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិចិកិច្ឆាមិនទាន់កើតទ្បើង ហើយកើតទ្បើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ក៏រិយាលះបង់នូវវិចិកិច្ឆាដែលកើតទ្បើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង វិចិកិច្ឆាដែលលះបង់បានហើយ មិនកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវនីវរណធម៌ ៥ យ៉ាង) គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតទ្បើង ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើត ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង

๔ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផង់ខ្ពើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

នីវរណបព្វៈ ចប់

[๑๒๙] ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានតទៅទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ (ពិចារណាឃើញដូច្នេះថា) រូបមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាទីកើតឡើងនៃរូប មានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនវិនាសទៅនៃរូប មានប្រមាណប៉ុណ្ណោះ វេទនាមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនកើតឡើងនៃវេទនា មានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនវិនាសទៅនៃវេទនា មានប្រមាណប៉ុណ្ណោះ សញ្ញាមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញា

มានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនវិនាសទៅនៃសញ្ញា មានប្រមាណ ប៉ុណ្ណោះ សង្ខារទាំងឡាយមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនកើតឡើង នៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនវិនាសទៅនៃ សង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណោះ វិញ្ញាណមានប្រមាណប៉ុណ្ណោះ ធម៌ ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែន វិនាសទៅនៃវិញ្ញាណ មានប្រមាណប៉ុណ្ណោះ ។ ភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទី ប្រជុំកើតក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចា-រណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែល សូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយ ទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផង់ឡើងចំពោះថា ធម៌មានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើន ស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទ-

នក្ខន្ធទាំង ๕ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

ខន្ធបព្វៈ ចប់

[๑๓๐] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ๖ ទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ๖ ទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវភ្នែកផង ដឹងនូវរូបទាំងឡាយផង មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនៅភ្នែក និងរូបទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើងហើយកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ភិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បានហើយមិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុដឹងច្បាស់នូវត្រចៀកផង ដឹងច្បាស់នូវសំឡេងទាំងឡាយផង ។ ដឹងច្បាស់នូវច្រមុះផង ដឹងច្បាស់នូវក្លិនទាំងឡាយផង ។ ដឹងច្បាស់នូវអណ្តាតផង ដឹងច្បាស់នូវរសទាំងឡាយផង ។ ដឹងច្បាស់នូវកាយផង ដឹងច្បាស់នូវផោដ្ឋព្វៈទាំងឡាយផង ។ ដឹងច្បាស់នូវចិត្តផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង សញ្ញោជនៈ*

ណាដែលអាស្រ័យនៅចិត្ត និងធម្មារម្មណ៍ទាំង ២ នោះកើតឡើង ក៏ដឹង ច្បាស់នូវសញ្ញោជន:នោះផង សញ្ញោជន:ដែលមិនទាន់កើតឡើងហើយកើត ឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ក៏រិយាលះបង់នូវ សញ្ញោជន:ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ផង សញ្ញោជន:ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុ ណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញ នូវធម៌ក្នុងធម៌ ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចា-រណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុង និងខាងក្រៅជា ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំ កើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចា-រណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយា-បថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផ្ដង់ឡើងចំពោះ ថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុង លោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំង-

ទ្វាយ គឺអាយតនៈ ๖ ខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

អាយតនបព្វៈ ចប់

[๑๓๑] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ๗ ប្រការ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ๗ ប្រការជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះសតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះសតិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះសតិសម្ពោជ្ឈង្គដែលមិនទាន់កើតទ្បើង ហើយកើតទ្បើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ភាវៈយោចម្រើនពេញបរិបូណ៌នៃសតិសម្ពោជ្ឈង្គដែលកើតទ្បើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះធម្មវិចយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ។បេ។ ទោះវីរិយសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។បេ។ ទោះបីតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។បេ។ ទោះបស្សទ្ធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។បេ។ ទោះសមាធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។បេ។*

ទោះឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខា-សម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គមិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូណ៌នៃឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្នុងជាប្រក្រតី គ្រប់តំរិយោបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្រៅជាប្រក្រតី គ្រប់តំរិយោបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់តំរិយោបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់តំរិយោបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងធម៌ទាំងឡាយ គ្រប់តំរិយោបថទាំង ៤ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផ្ដង់ឡើងចំពោះថាធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់តំរិយោបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ

ទាំង ๗ ជាប្រក្រតី គ្រប់តវិយោបថទាំង ๔ យ៉ាងនេះឯង ។

ពោជ្ឈង្គបព្វៈ ចប់

បឋមភាណវារ ចប់

[๑๓๒] *ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណា ឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ๔ គ្រប់តវិយោបថទាំង ๔ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ๔ គ្រប់តវិយោបថទាំង ๔ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសភាវៈរម្ងាប់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសភាវៈរម្ងាប់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ចតើដូចម្តេច ។ ជាតិ គឺកំណើតដែលកើតជាដំបូង ក៏ជាទុក្ខ ជរា គឺសេចក្តីចាស់គ្រាំគ្រា ក៏ជាទុក្ខ មរណៈ គឺសេចក្តីស្លាប់ ក៏ជាទុក្ខ សោក គឺសេចក្តីស្តាយស្រណោះ បរិទេវៈ គឺសេចក្តីខ្សឹកខ្សួល ទុក្ខ គឺសេចក្តីលំបាកកាយ ទោមនស្ស គឺសេចក្តីអាក់អន់តូចចិត្ត ឧបាយាសៈ គឺសេចក្តីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ អបិយេហិសម្បយោគ គឺជំណើរជួបប្រសព្វដោយសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ ក៏ជាទុក្ខ បិយេហិវិប្បយោគ គឺសេចក្តីព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ក៏ជាទុក្ខ យម្បិច្ឆំនល-

ภតិតម្បិ គឺបុគ្គលកាលចង់បាននូវរបស់ណា មិនបាន ឯការមិនបានរបស់នោះ ក៏ជាទុក្ខ បើដោយសេចក្តីបង្រួញឧបាទានក្ខន្ធទាំង ៥ មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ ។

[๑๓๓] *ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាជាតិ ។ កិរិយាកើត ជាដំបូង កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការវិលត្រឡប់មកកើត ការកើតប្រាកដនៃខន្ធ ការបាននូវអាយតនៈណា របស់សត្វនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាជាតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាជរា ។ ជរា គឺសេចក្តីចាស់គ្រាំគ្រា ឬការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយុរយោរ ការរួញថយនៃអាយុ ការទ្រុឌ្រោមឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ជរា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា មរណៈ ។ ការៈនៃចិត្តដែលឃ្លាតចេញ អាការនៃចិត្តដែលឃ្លាតទៅ សេចក្តីបែកធ្លាយទៅ សេចក្តីបាត់បង់ទៅ សេចក្តីវិនាសជីវិត សេចក្តីស្លាប់ កាលកិរិយា សេចក្តីបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិលនូវជីវិតិន្ទ្រិយណា របស់សត្វទាំងឡាយនោះៗ ចាកសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សោក ។ ម្នាលភិក្ខុទាំងឡាយ សោក គឺសេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោកសៅ សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្តណា របស់សត្វដែលប្រកប*

ហើយដោយសេចក្តីវិនាសណាមួយ (ឬ) ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សោក ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈទួញរក (បិយជនមានកូនជាដើម) សភាវៈទួញរៀបរាប់ (សរសើរគុណ) កិរិយាយំអណ្តឹតអណ្តក កិរិយាយំបម្រះនទៀល ភាវៈនៃការយំអណ្តឹតអណ្តក ភាវៈនៃការយំបម្រះនទៀលណា របស់សត្វដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ (ឬ) ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកកាយ សេចក្តីមិនសប្បាយកាយ សេចក្តីលំបាកដែលកើតអំពីកាយសម្ផស្ស ការទទួលវេទនាសេចក្តីមិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទោមនស្ស ។ ម្នាលលភិក្ខុទាំង-ឡាយ សេចក្តីលំបាកក្នុងចិត្ត សេចក្តីមិនសប្បាយក្នុងចិត្ត សេចក្តីលំបាកដែលកើតអំពីមនោសម្ផស្ស ការទទួលអារម្មណ៍មិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទោមនស្ស ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីតានតឹងក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ភាវៈនៃសេចក្តីតានតឹងក្នុងចិត្ត ភាវៈនៃសេចក្តីចង្អៀតចង្អល់ចិត្តណា របស់សត្វដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ (ឬ) ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ

នេះតថាគតហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា អប្បិយេហិសម្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មានដល់បុគ្គលណាក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ប្រាថ្នានូវសេចក្តីមិនចម្រើន ប្រាថ្នានូវអំពើ ឥតប្រ-យោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវអំពើដែលមិនក្សេមចាក យោគៈ ចំពោះបុគ្គលនោះ ក៏វិយោបានជួបគ្នា ក៏វិយោជួបជុំគ្នា ក៏វិយោប្រជុំគ្នា ការនៅច្រឡូកច្រឡំគ្នានឹងអារម្មណ៍ទាំងឡាយនោះៗ នឹងជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អប្បិយេហិសម្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បិយេហិវិប្បយោគទុក្ខ ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានដល់បុគ្គលណាក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ដែលជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសប្បាយ ប្រាថ្នានូវសេចក្តីក្សេមចាកយោគៈ ចំពោះបុគ្គលនោះ ការមិនបានជួបគ្នា មិនបានជួបជុំគ្នា ក៏វិយោមិនបានប្រជុំគ្នា ការមិននៅច្រឡូកច្រឡំ នឹងអារម្មណ៍ទាំងឡាយនោះៗ នឹងជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា បិយេហិវិប្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា យម្បិច្ឆំនលភតិតម្បិទុក្ខ ។ ម្នាល

ភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ឲ្យយើងទាំងឡាយកុំគប្បីមានជាតិជាធម្មតា ពុំនោះសោត ជាតិកុំគប្បីមកដល់យើងទាំងឡាយ សេចក្តីនេះ ពួកសត្វក៏មិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯងឈ្មោះថា យម្បិច្ឆំនលភតិតម្បិទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានសេចក្តីគ្រាំគ្រា ឬប្រែប្រួលជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានសេចក្តីឈឺប្តាត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានសេចក្តីស្លាប់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្វោចផ្សាចិត្តជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ឲ្យយើងទាំងឡាយ កុំប្បីមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្វោចផ្សាចិត្តជាធម្មតា ពុំនោះសោត សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់ចិត្ត សេចក្តីខ្វោចផ្សាចិត្ត កុំគប្បីមកដល់យើងទាំងឡាយឡើយ សេចក្តីនេះ ពួកសត្វ ក៏មិនបានសម្រេចតាមប្រាថ្នា នេះឯងក៏ឈ្មោះថា យម្បិច្ឆំនលភតិតម្បិទុក្ខដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចឧបាទានក្ខន្ធទាំង ៥ ដោយសេចក្តីបង្រួញដែលថាជាទុក្ខ ។ ឧបាទានក្ខន្ធទាំង ៥ នោះ គឺអ្វីខ្លះ គឺរូប ជាឧបាទានក្ខន្ធ ១ វេទនា ជាឧបាទានក្ខន្ធ ១ សញ្ញា ជាឧបាទានក្ខន្ធ ១ សង្ខារ ជាឧបាទានក្ខន្ធ ១ វិញ្ញាណ ជាឧបាទាន-ក្ខន្ធ ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះតថាគតហៅថា ឧបាទានក្ខន្ធទាំងឡាយ

๕ ដោយសេចក្តីបង្រួញថាជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខអរិយសច្ច ។

[๑๓๔] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខសមុទយអរិយ-សច្ច ។ តណ្ហាណា ជាធម្មជាតនាំសត្វឲ្យកើតទៀត ប្រកបដោយតម្រេក រីករាយ ជាធម្មជាតនាំសត្វឲ្យត្រេកត្រអាលនៅក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ តណ្ហានោះ គឺអ្វីខ្លះ គឺកាមតណ្ហា (សេចក្តីប្រាថ្នាក្នុងកាមគុណ) ១ ភវតណ្ហា (សេចក្តីប្រាថ្នាក្នុងរូបភព និងអរូបភព) ១ វិភវតណ្ហា (សេចក្តីប្រាថ្នាក្នុងភពសូន្យ) ១ ។

[๑๓๕] ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា ។ អារម្មណ៍ណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍អ្វីមួយ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុនុ៎ះ ។ សោតៈក្នុងលោក ។ ឃានៈក្នុងលោក ។ ជិវ្ហាក្នុងលោក ។ កាយក្នុងលោក ។ មនោក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅ

ក្នុងមនោនុ៎ះ ។ រូបារម្មណ៍ទាំងឡាយក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយ ក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយក្នុងលោក ។ រសារម្មណ៍ទាំងឡាយក្នុង លោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយក្នុង លោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ ជាប់នៅក្នុងធម្មារម្មណ៍នុ៎ះ ។ ចក្ខុវិញ្ញាណក្នុងលោក ។ សោតវិញ្ញាណក្នុង លោក ។ ឃានវិញ្ញាណក្នុងលោក ។ ជិវ្ហាវិញ្ញាណក្នុងលោក ។ កាយ-វិញ្ញាណក្នុងលោក ។ មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុង មនោវិញ្ញាណនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុ-សម្ផស្សក្នុងលោក ។ សោតសម្ផស្សក្នុងលោក ។ ឃានសម្ផស្សក្នុងលោក ។ ជិវ្ហាសម្ផស្សក្នុងលោក ។ កាយសម្ផស្សក្នុងលោក ។ មនោសម្ផស្សក្នុង លោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោសម្ផស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោសម្ផស្សនុ៎ះ ។ វេទនាកើតអំពីចក្ខុសម្ផស្សក្នុងលោក ។ វេទនាកើតអំពីសោតសម្ផស្សក្នុងលោក ។ វេទនាកើតអំពីឃានសម្ផស្សក្នុង លោក ។ វេទនាកើតអំពីជិវ្ហាសម្ផស្សក្នុងលោក ។ វេទនាកើតអំពីកាយ-សម្ផស្សក្នុងលោក ។ វេទនាកើតអំពីមនោសម្ផស្សក្នុងលោក ដែលមាន សភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង

ក៏កើតឡើងក្នុងវេទនា ដែលកើតអំពីមនោសម្ផស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនុ៎ះ ។ សេចក្តីសម្គាល់នូវរូបាវចរម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើង ក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។ ការគិតសន្សំនូវរូបាវចរម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវគន្ធារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវរសារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងធម្មារម្មណ៍នុ៎ះ ។ សេចក្តីប្រាថ្នានូវរូបាវចរម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវរសារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍

នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ។ សេចក្តីត្រិះរិះនូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវរសារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ ។ ការពិចារណានូវរូបារម្មណ៍ក្នុងលោក ។ ការពិចារណានូវសទ្ទារម្មណ៍ក្នុងលោក ។ ការពិចារណានូវគន្ធារម្មណ៍ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ក្នុងលោក ។ ការពិចារណានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការពិចារណានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅក៏ជាប់នៅក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខសមុទយអរិយសច្ច ។

[๑๓๖] *ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខនិរោធអរិយសច្ច ។ ការអស់ទៅ និងការរលត់ទៅ ដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការផ្រុះចោល ការមិនមានអាល័យ ចំពោះតណ្ហានោះឯង (ហៅថា ទុក្ខនិរោធអរិយសច្ច) ។ ម្នាលភិក្ខុទាំងឡាយ ចុះ*

ចុះតណ្ហានោះឯង កាលដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ។ អារម្មណ៍ណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ តែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលដែលរលត់ទៅ តែងរលត់ទៅក្នុងអារម្មណ៍នុ៎ះ ។ ចុះអារម្មណ៍អ្វីក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុនុ៎ះ ។ សោតៈក្នុងលោក ។ ឃានៈក្នុងលោក ។ ជិវ្ហាក្នុងលោក ។ កាយក្នុងលោក ។ មនោក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាវៈគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោនោះ ។ រូបារម្មណ៍ទាំងឡាយក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយក្នុងលោក ។ រសារម្មណ៍ទាំងឡាយក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងធម្មារម្មណនុ៎ះ ។ ចក្ខុវិញ្ញាណក្នុងលោក ។ សោតវិញ្ញាណក្នុងលោក ។ ឃានវិញ្ញាណក្នុងលោក ។ ជិវ្ហាវិញ្ញាណក្នុងលោក ។ កាយ-វិញ្ញាណក្នុងលោក ។ មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់

មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោវិញ្ញាណនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុសម្ផស្សក្នុងលោក ។ សោតសម្ផស្សក្នុងលោក ។ ឃានសម្ផស្សក្នុងលោក ។ ជិវ្ហាសម្ផស្សក្នុងលោក ។ កាយសម្ផស្សក្នុងលោក ។ មនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផស្សនុ៎ះ ។ វេទនាកើតអំពីចក្ខុសម្ផស្សក្នុងលោក ។ វេទនាកើតអំពីសោតសម្ផស្សក្នុងលោក ។ វេទនាកើតអំពីឃានសម្ផស្សក្នុងលោក ។ វេទនាកើតអំពីជិវ្ហាសម្ផស្សក្នុងលោក ។ វេទនាកើតអំពីកាយសម្ផស្សក្នុងលោក ។ វេទនាកើតអំពីមនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផស្សនុ៎ះ ការដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផស្សនុ៎ះ ។ សេចក្តីសម្គាល់នូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។ ការគិតសន្សំនូវរូបារម្មណ៍

ក្នុងលោក ฯ ការគិតសន្សំនូវសទ្ទារម្មណ៍ក្នុងលោក ฯ ការគិតសន្សំនូវគន្ធារម្មណ៍ក្នុងលោក ฯ ការគិតសន្សំនូវរសារម្មណ៍ក្នុងលោក ฯ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ฯ ការគិតសន្សំនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ ฯ សេចក្តីប្រាថ្នានូវរូបារម្មណ៍ក្នុងលោក ฯ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ក្នុងលោក ฯ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ក្នុងលោក ฯ សេចក្តីប្រាថ្នានូវរសារម្មណ៍ក្នុងលោក ฯ សេចក្តីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ฯ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ฯ សេចក្តីត្រិះនូវរូបារម្មណ៍ក្នុងលោក ฯ សេចក្តីត្រិះនូវសទ្ទារម្មណ៍ក្នុងលោក ฯ សេចក្តីត្រិះនូវគន្ធារម្មណ៍ក្នុងលោក ฯ សេចក្តីត្រិះនូវរសារម្មណ៍ក្នុងលោក ฯ សេចក្តីត្រិះនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ฯ សេចក្តីត្រិះនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីត្រិះនូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីត្រិះនូវធម្មារម្មណ៍នុ៎ះ ฯ ការពិចារណានូវរូបារម្មណ៍ក្នុងលោក ฯ ការពិចារណានូវសទ្ទារម្មណ៍ក្នុងលោក ฯ

កាលពិចារណានូវគន្ធារម្មណ៍ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ក្នុងលោក ។ ការពិចារណានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការពិចារណានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរតណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏លត់ទៅក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធអរិយសច្ច ។

[๑๓๗] *ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ អរិយមគ្គដែលប្រកបដោយអង្គ ๘ ប្រការនេះឯង (ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច) អរិយមគ្គដែលប្រកបដោយអង្គ ๘ ប្រការ តើដូចម្តេច គឺសម្មាទិដ្ឋិ (សេចក្តីយល់ឃើញត្រូវ) ๑ សម្មាសង្កប្ប (សេចក្តីត្រិះរិះត្រូវ) ๑ សម្មាវាចា (ការនិយាយពាក្យត្រូវ) ๑ សម្មាកម្មន្តៈ (ការងារត្រូវ) ๑ សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ๑ សម្មាវាយាមៈ (សេចក្តីព្យាយាមត្រូវ) ๑ សម្មាសតិ (សេចក្តីនឹករឭកត្រូវ) ๑ សម្មាសមាធិ (ការតម្កល់ចិត្តឲ្យនឹងត្រូវ) ๑ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដឹងច្បាស់ក្នុងកងទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងធម៌ដែលជាទីប្រជុំឲ្យកើតទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងធម៌ដែលជាទីរលត់ទៅនៃទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងបដិបទាទៅកាន់ធម៌ជាទីរលត់នៃទុក្ខណា ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាសង្កប្ប ។*

សេចក្តីត្រិះរិះដើម្បីចេញចាកកាម សេចក្តីត្រិះរិះដើម្បីការមិនព្យាបាទ សេចក្តីត្រិះរិះដើម្បីការមិនបៀតបៀន ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា សម្មាសង្កប្ប ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា សម្មាវាចា ។ ចេតនាវៀរចាកកិរិយានិយាយពាក្យមិនពិត ១ ចេតនាវៀរចាកសម្តីញុះញង់ ស៊ីកសៀត ១ ចេតនាវៀរចាកសម្តីទ្រគោះបោះបោក ១ ចេតនាវៀរចាកការពោលពាក្យរោយរាយឥតប្រយោជន៍ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថាសម្មាវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាសម្មាកម្មន្តៈ ។ ចេតនាវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ ចេតនាវៀរចាកកិរិយាកាន់យករបស់ដែលគេមិនបានឲ្យ ១ ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាសម្មាកម្មន្តៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាសម្មាអាជីវៈ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស ហើយរស់នៅដោយការចិញ្ចឹមជីវិតត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មា-អាជីវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវការព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ញ៉ាំង

*ឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលមិនទាន់កើតឡើងហើយ ឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យឋិតថេរ មិនឲ្យវិនាស ឲ្យចម្រើនធំទូលាយ ពេញបរិបូណ៌ ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានការព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។បេ។ ក្នុងចិត្ត ។បេ។ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានការព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាសម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថាសម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកធម៌ទាំងឡាយជាអកុសល ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខៈដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រេចសម្រាន្ត

នៅដោយឥរិយាបថ ๔ លុះភិក្ខុចូលទៅជិតរម្ងាប់នូវវិតក្ក និងវិចារៈរួចហើយ ក៏ចូលកាន់ទុតិយជ្ឈាន ដែលកើតមានក្នុងសន្តាន ជាទីផូរផង់ មានសភាព ជាចិត្តខ្ពស់ឯក គ្មានវិតក្ក និងវិចារៈ មានតែបិតិ និងសុខ ដែលកើតអំពី សមាធិ ฯបេฯ ចូលកាន់តតិយជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថ ๔ ចូលកាន់ចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ឥតទុក្ខ ឥតសុខ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរលត់ ទៅនៃសោមនស្ស និងទោមនស្សអំពីមុនផង ក៏សម្រេចសម្រាន្តនៅដោយ ឥរិយាបថ ๔ ฯ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាសមាធិ ฯ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ฯ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិ-យាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជា ប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ក្នុងទាំងឡាយ ខាងក្នុង និងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញ នូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជា ប្រក្រតី គ្រប់ឥរិយាបថទាំង ๔ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំ កើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយា-បថទាំង ๔ ផង ដោយប្រការដូច្នេះឯង ฯ ម្យ៉ាងទៀត ស្មារតីជាគ្រឿង កំណត់នូវសច្ចៈ ๔ របស់ភិក្ខុនោះ ក៏ផូរផង់ឡើងចំពោះថា ធម៌ទាំងឡាយមាន

មែន តែគ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតី ប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យនៅ ដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ๔ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ๔ យ៉ាងនេះឯង ។

សច្ចបព្វៈ ចប់

ធម្មានុបស្សនា ចប់

[๑๓๘] *ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ๔ នេះ អស់ ๗ ឆ្នាំ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ បណ្តាផលទាំងឡាយ ๒ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្តីជ្រះថ្លាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈ ជាអនាគាមិបុគ្គលពុំខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ๗ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ๔ នេះ អស់ ๖ ឆ្នាំ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ ។ អស់ ๕ ឆ្នាំ ។ អស់ ๔ ឆ្នាំ ។ អស់ ๓ ឆ្នាំ ។ អស់ ๒ ឆ្នាំ ។ អស់ ๑ ឆ្នាំ ។បេ។ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់មួយឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិ-*

ปฏฺฐานทាំង ๔ នេះ អស់ ๗ ខែ តាមលំដាប់នៃវិធីចម្រើន ដែលតថាគត បានពោលមកហើយយ៉ាងនេះ បណ្តាផលទាំងឡាយ ๒ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្តីប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិ-បុគ្គលពុំខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ๗ ខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើននូវសតិបដ្ឋានទាំង ๔ នេះអស់ ๖ ខែ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ ។ អស់ ๕ ខែ ។ អស់ ๔ ខែ ។ អស់ ๓ ខែ ។ អស់ ๒ ខែ ។ អស់ ๑ ខែ ។ អស់កន្លះខែ ។បេ។ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់កន្លះខែឡើយ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិបដ្ឋានទាំង ๔ នេះអស់ ๗ ថ្ងៃ តាមលំដាប់នៃវិធីចម្រើនដែលតថាគតបានពោលមកហើយយ៉ាងនេះ បណ្តាផលទាំងឡាយ ๒ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទាន-ក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គល ពុំខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិបដ្ឋានទាំងឡាយ ๔ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ ដោយវិសេសរបស់សត្វទាំង-ឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលរំជួលចិត្តទាំង-

ទ្ធាយ ដើម្បីរលត់ទៅនៃទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយ-មគ្គជាធម៌សម្រាប់ស្រោចស្រង់ ដើម្បីធ្វើជាក់ច្បាស់នូវព្រះនិព្វាន ។ ពាក្យណាដែលតថាគតបានពោលហើយថា (សាសនារបស់តថាគត ជាគុណសម្រាប់ស្រោចស្រង់សត្វ) ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រសើរ គឺសតិប្បដ្ឋានទាំង ๔ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសតិប្បដ្ឋានសូត្រនេះចប់ហើយ ។ ភិក្ខុទាំងឡាយនោះក៏មានចិត្តរីករាយ ត្រេកអរ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

មហាសតិប្បដ្ឋានសូត្រទី ៩ ចប់

អដ្ឋកថា

មហាសតិប្បដ្ឋានសូត្រ

កំណើតមហាសតិប្បដ្ឋានសូត្រ

[๑๑๑] *មហាសតិប្បដ្ឋានសូត្រ មានពាកផ្តើមថា* **ឯវមេ សុតំ** *ជួច្នេះ ជាដើម ។ ក្នុងមហាសតិប្បដ្ឋានសូត្រនេះ មានពណ៌នាតាមលំដាប់បទដូច្នេះថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះថា ម្នាលភិក្ខុទាំង-ឡាយ ផ្លូវនេះជាផ្លូវមួលតែមួយ ព្រោះជនអ្នកដែនកុរុអាចទទួលទេសនាដ៏ជ្រាលជ្រៅបាន ។*

បានឮថា អ្នកដែនកុរុ ជាភិក្ខុក្តី ភិក្ខុនីក្តី និងឧបាសកក្តី ឧបាសិកាក្តី មានរាងកាយ និងចិត្តបរិបូណ៌ជានិច្ច ដោយសេពបច្ច័យ គឺឧតុជាទីសប្បាយ ព្រោះដែននោះ បរិបូណ៌ដោយសប្បាយ មានឧតុជាទីសប្បាយជាដើម ។ អ្នកកុរុនោះ មានកម្លាំងបញ្ញាដែលរាងកាយ និងចិត្តបរិបូណ៌ឧបត្ថម្ភហើយ ទើបអាចទទួលទេសនាដ៏ជ្រាលជ្រៅនេះបាន ។ ព្រោះដូច្នោះ កាលព្រះមាន ព្រះភាគ ទ្រង់ឃើញភាពជាអ្នកអាចទទួលទេសនា ដ៏ជ្រាលជ្រៅយ៉ាងនេះ ទើបទ្រង់លើកកម្មដ្ឋាន ๒๑ ហាន: ដាក់ចុះក្នុងអរហត្ត ត្រាស់មហាសតិ-ប្បដ្ឋានសូត្រ ដែលមានអត្ថដ៏ជ្រាលជ្រៅនេះដល់អ្នកកុរុទាំងនោះ ។ ប្រៀបដូច បុរសបានប្រអប់មាសហើយ គប្បីដាក់ផ្តាច្រើនប្រភេទ ក្នុងប្រអប់មាសនោះ ឬថា បុរសបានហិបមាស ហើយគប្បីដាក់រតន: ๗ យ៉ាងណា ព្រះមាន ព្រះភាគក៏ដូច្នោះ ទ្រង់បានបរិស័ទអ្នកកុរុហើយ ទើបទ្រង់ដាក់ទេសនា ដ៏ ជ្រាលជ្រៅ ។ ដោយហេតុនោះឯង ក្នុងសេចក្តីនេះ ព្រះមានព្រះភាគទ្រង់បាន សម្តែងព្រះសូត្រដទៃៗទៀត មានអត្ថជ្រាលជ្រៅក្នុងគម្ពីរទីឃនិកាយនេះ គឺ

មហានិទានសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ សតិប្បដ្ឋានសូត្រ សារោបមសូត្រ រុក្ខោបមសូត្រ រដ្ឋបាលសូត្រ មាគណ្ឌិយសូត្រ អានេញ្ជសប្បាយសូត្រ ។

មួយទៀត បរិស័ទ ៤ ក្នុងដែនកុរុនោះ នាំគ្នាប្រកបរឿយៗ ក្នុងការចម្រើនសតិប្បដ្ឋានជាប្រក្រតី ដោយហោច អ្នកបម្រើ និងកម្មករទាំងឡាយ ក៏និយាយគ្នាតែរឿងដែលជាប់ទាក់ទងដោយសតិប្បដ្ឋានទាំងអស់ សូម្បីតែត្រង់កំពង់ទឹក ទីខារអំបោះជាដើម ក៏មិនមានការនិយាយគ្នាដល់រឿង ដែលឥតប្រយោជន៍ឡើយ ។ បើស្ត្រីខ្លះ ត្រូវសួរថា នែនាង តើនាងជាក់ចិត្តក្នុងសតិប្បដ្ឋានមួយណា បើស្រីនោះមិនឆ្លើយ អ្នកកុរុនឹងតិះដៀលគេថា គួរតិះដៀលជីវិតរបស់នាងពិតៗ ទោះនាងរស់នៅ ក៏ដូចស្លាប់ហើយ ហើយក៏នឹងទូន្មានស្ត្រីនោះថា កុំធ្វើយ៉ាងនេះតទៅទៀត ហើយឲ្យស្ត្រីនោះរៀនសតិ-ប្បដ្ឋានប្រការណាមួយ ។ តែស្ត្រីណានិយាយថា ខ្ញុំជាក់ចិត្តក្នុងសតិប្បដ្ឋានប្រការឯណោះ អ្នកកុរុក៏នឹងពោលសរសើរថា សាធុ សាធុ ដល់នាង សរសើរដោយពាក្យផ្សេងៗ ជាដើមថា ជីវិតរបស់នាង ជាជីវិតល្អ សមនឹងនាងកើតមកជាមនុស្ស ព្រះសម្ពុទ្ធទ្រង់ឧប្បត្តិកមកដើម្បីប្រយោជន៍ដល់នាងពិតៗ ។ ក្នុងសេចក្តីនេះ មិនមែនអ្នកកុរុដែលកើតមកជាមនុស្ស ប្រកបដោយការជាក់ចិត្តក្នុងសតិប្បដ្ឋានតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីតែសត្វតិរច្ឆាន ដែលអាស្រ័យអ្នកកុរុ ក៏នៅជាក់ចិត្តចម្រើនសតិប្បដ្ឋានដូចគ្នា ។ ក្នុងសេចក្តីនោះ មានរឿងសាធកៈដូច្នេះ

រឿងកូនសត្វសេក

បានឮថា អ្នករបាំម្នាក់ ចាប់កូនសេកបានមួយ បង្រៀនឲ្យសេកនិយាយភាសាមនុស្ស (ខ្លួនឯងត្រាច់ទៅ សម្តែងរបាំក្នុងទីដទៃៗ) ។ អ្នករបាំនោះ

អាស្រ័យសម្ផាក់របស់កិកូនី វេលាទៅក្នុងទីដទៃៗ ក៏ភ្ញេចកូនសេក ។ ពួកសាមណេរីក៏ចាប់មកចិញ្ចឹម ជាក់ឈ្មោះថា ពុទ្ធរក្ខិត ។ ថ្ងៃមួយ ព្រះមហាថេរីឃើញវាទំនៅក្នុងទីចំពោះមុខ ទើបហៅថា ពុទ្ធរក្ខិត ។ ទើបកូនសេកសួរថា បពិត្រអ្នកនាងម្ចាស់ មានការអ្វី ។ ព្រះមហាថេរីក៏សួរថា ការជាក់ចិត្តក្នុងការនាណាមួយរបស់នាងមានខ្លះទេ ។ សេកឆ្លើយថា មិនមានទេ ។ ព្រះមហាថេរីក៏ទូន្មានថា ដែលឈ្មោះថា អ្នកនៅក្នុងសម្ផាក់របស់ពួកអ្នកបួសនឹងនៅបណ្តែតបណ្តោយខ្លួនមិនសមគួរទេ គួរប្រាថ្នាការជាក់ចិត្តយ៉ាងណាមួយ តែនាងមិនត្រូវសិក្សាដទៃទេ ចូរបរិកម្មថា អដ្ឋិ អដ្ឋិ ក៏សមគួរ ។ កូនសេកនោះ ក៏នៅក្នុងឱវាទរបស់ព្រះថេរី បរិកម្មថា អដ្ឋិ អដ្ឋិ តែម្យ៉ាង ហើយត្រាច់ទៅ ។ ថ្ងៃមួយ ពេលព្រឹក កូនសេកទំត្រង់ចុងទ្វារ អាងថ្ងៃពេលព្រឹក មេស្អាំងមួយក៏ធាបកូនសេកយកទៅដោយក្រញាំ ។ កូនសេកបញ្ចេញសំឡេងកិរិ កិរិ ។ ពួកសាមណេរីក៏ស្រែកថា បពិត្រអ្នកនាងម្ចាស់ ពុទ្ធរក្ខិត ត្រូវស្អាំងធាបទៅ យើងនឹងជួយ ក៏នាំគ្នាកាន់យកដុំដីជាដើមដេញតាម ដរាបស្អាំងលែង ។ ពួកសាមណេរីនាំសេកមកទុកត្រង់ទីចំពោះមុខព្រះមហាថេរី ព្រះមហាថេរីសួរថា ពុទ្ធរក្ខិត ខណៈត្រូវស្អាំងចាប់យកទៅ អ្នកគិតដូចម្តេច កូនសេកឆ្លើយថា បពិត្រអ្នកនាងម្ចាស់ ខ្ញុំមិនបានគិតអ្វីដទៃ គឺគិតតែរឿងគំនរឆ្អឹងប៉ុណ្ណោះថា គំនរឆ្អឹង នាំគំនរឆ្អឹងទៅ នឹងរត់រាយនៅក្នុងទីណាហ្ន៎ ។ ទើបព្រះមហាថេរីឲ្យសាធុការថា សាធុ សាធុ ពុទ្ធរក្ខិត នោះនឹងជាបច្ច័យនៃការអស់កពរបស់នាងក្នុងកាលខាងមុខនោះឯង ។ សូម្បីសត្វតិរច្ឆាន ក្នុងដែនកុរុ

នោះ ក៏ប្រកបរឿយៗ នូវសតិប្បដ្ឋាន ដោយប្រការដូច្នេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបដល់សេចក្តីចម្រើនលូតលាស់នៃសតិប្បដ្ឋាន របស់អ្នកកុរុទាំងនោះ ទើបត្រាស់ព្រះសូត្រនេះ ។

ឧទ្ទេសវារកថា

ក្នុងព្រះសូត្រនោះ បទថា **ឯកាយនោ** *គឺជាផ្លូវតែមួយ ។ ពិតហើយ ផ្លូវមានច្រើនឈ្មោះ គឺ មគ្គ: បន្ថ: បថ: បជ្ជ: អញ្ជស: វដុម: អយន: នាវា ឧត្តរសេតុ កុល្ល: កិសិសង្កម: ។ ផ្លូវនោះ ក្នុងទីនេះ លោកពោលដោយឈ្មោះថា* **អយន** *ព្រោះដូច្នោះ ក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវមូលតែមួយនេះ ទើបគួរយើញយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវតែមួយ មិនមែនផ្លូវបែកជាពីរទេ ។*

នយម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** *ព្រោះអត្ថវិគ្គហ:ថា ជាផ្លូវដែលបុគ្គលគប្បីទៅតែម្នាក់ឯង ។ ពាក្យថា ម្នាក់ឯង គឺអ្នកដែលលះការច្រឡូកច្រឡំដោយពួក ចៀសចេញទៅដោយស្ងប់ស្ងាត់ ។ ពាក្យថា គប្បីទៅ គឺ គប្បីធ្វើដំណើរទៅ ។ នយម្យ៉ាងទៀត ឈ្មោះថា* **អយន** *ព្រោះអត្ថវិគ្គហ:ថា ជាគ្រឿងទៅ អធិប្បាយថា ទៅអំពីសង្សារវដ្តកាន់ព្រះនិព្វាន ។ ផ្លូវទៅរបស់បុគ្គលម្នាក់ ឈ្មោះថា* **ឯកាយន** ***។*** *ពាក្យថា តែមួយ គឺរបស់បុគ្គលដ៏ប្រសើរនៃសព្វសត្វ ។ ព្រះមានព្រះភាគនោះ ទ្រង់ប្រសើរជាងសព្វសត្វ ព្រោះដូច្នោះ ទើបលោកអធិប្បាយថា ផ្លូវរបស់ព្រះមានព្រះភាគ ។ សត្វពួកដទៃ ទោះដើរទៅដោយផ្លូវនោះក៏ពិតមែនហើយ តែផ្លូវនោះ ក៏ជាផ្លូវដើររបស់ព្រះមានព្រះ*

ភាគប៉ុណ្ណោះ ព្រោះជាផ្លូវដែលទ្រង់ធ្វើឲ្យកើតឡើង ។ ដូចត្រាស់ក្នុងគោបក-មោគ្គល្លានសូត្រថា ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ដូច្នេះជាដើម ។ នយម្យ៉ាងទៀត ផ្លូវ រមែងទៅ ហេតុនោះ ទើបឈ្មោះថា **អយន** *អធិប្បាយថា ទៅ គឺប្រព្រឹត្ត ទៅ ។ ផ្លូវទៅក្នុងធម្មវិនយតែមួយ ឈ្មោះថា* **ឯកាយន** *លោកអធិប្បាយថា ផ្លូវប្រព្រឹត្តទៅក្នុងធម៌វិនយនេះប៉ុណ្ណោះ មិនប្រព្រឹត្តទៅក្នុងធម្មវិនយ គឺសាសនា ដទៃឡើយ ។ ដូចទ្រង់ត្រាស់ក្នុងមហាបរិនិព្វានសូត្រថា ម្នាលសុភទ្ទ អរិយមគ្គ ប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិនយនេះឯង ដូច្នេះ ។ មគ្គនោះ ផ្សេងគ្នា ដោយទេសនា តែដោយអត្ថ ក៏ដូចគ្នានុ៎ះឯង ។*

នយម្យ៉ាងទៀត ផ្លូវ រមែងទៅតែម្តង ហេតុនោះ ទើបផ្លូវនោះឈ្មោះថា **ឯកាយន** *លោកអធិប្បាយថា ផ្លូវ សូម្បីប្រព្រឹត្តទៅដោយមុខ គឺការនា មាន នយផ្សេងៗ គ្នា ក្នុងខាងដើម ក្នុងខាងចុង ក៏ទៅកាន់ព្រះនិព្វានតែមួយដូចគ្នា នុ៎ះឯង ។ ដូចលោកពោលក្នុងសំយុត្តនិកាយ មហាវារវគ្គថា សហម្បតីព្រហ្ម ក្រាបទូលព្រះមានព្រះភាគថា*

ឯកាយនំ ជាតិខយន្តទស្សី មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន តរីសុ បុព្ពេ តរិស្សរេ ចេវ តរន្តិ ឱឃំ ។

បុគ្គលឃើញនូវទីបំផុតនៃការអស់នៃជាតិ មានសេចក្តីអនុគ្រោះដោយ ប្រយោជន៍ រមែងជីងច្បាស់នូវផ្លូវមួលតែមួយ ជនទាំងឡាយបានឆ្លងហើយ ក្នុងកាលមុនក្តី នឹងឆ្លង (ក្នុងអនាគត) ក្តី កំពុងឆ្លងក្នុងកាលឥឡូវនេះក្តី នូវឱឃៈបាន ដោយផ្លូវនុ៎ះឯង ។

តែកេចិអាចារ្យពោលតាមន័យនៃគាថា ដែលថា ធម្មតាព្រះអរិយ-បុគ្គល មិនដែលទៅកាន់ត្រើយខាងនាយ គឺព្រះនិព្វានដល់ពីរដងឡើយ ព្រះនិព្វាននេះ មិនគួរបានដោយគុណតែមួយទេ ដូច្នោះ ទើបផ្ទុំវានោះ ឈ្មោះថា **ឯកាយន** *គឺទៅតែម្តង ។ ពាក្យនេះមិនត្រូវ ។ ព្រោះអត្ថនេះ និងគប្បីមានព្យញ្ជនៈយ៉ាងនេះថា* **សកឹ អយនោ** *ទៅតែម្តង ។ ប្រសិនបើប្រកបអត្ថពោលយ៉ាងនេះថា ការទៅតែម្តង គឺប្រព្រឹត្តទៅមួយដងរបស់មគ្គនោះ ប្រព្រឹត្តទៅដូច្នេះ ព្យញ្ជនៈក៏និងត្រឹមត្រូវ តែអត្ថមិនត្រូវទាំងពីរប្រការ ។ ព្រោះហេតុអ្វី ។ ព្រោះក្នុងទីនេះ លោកបំណងយកតែមគ្គដែលជាចំណែកខាងដើម ។ ពិតហើយ ក្នុងទីនេះ លោកបំណងយកតែមគ្គ ដែលមានសតិប្បដ្ឋានជាចំណែកខាងដើម ដែលប្រព្រឹត្តទៅដោយអារម្មណ៍ ៤ មានកាយជាដើម ។ មិនបានបំណងយកមគ្គដែលជាលោកុត្តរ ព្រោះថា មគ្គដែលជាចំណែកខាងដើមនោះ រមែងប្រព្រឹត្តទៅសូម្បីច្រើនដង ទាំងការប្រព្រឹត្តទៅរបស់មគ្គនោះ ក៏មិនមែនមានតែមួយដង ។*

ក្នុងសេចក្តីនេះ ពីមុនព្រះមហាថេរៈទាំងឡាយ ក៏ធ្លាប់បានសន្ទនាគ្នាមកហើយ ។ ព្រះចុល្លនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា សតិប្បដ្ឋានជាមគ្គខាងដើម (បុព្វភាគ) ។ ចំណែកព្រះចុល្លសុមនត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក អាចារ្យរបស់ព្រះចុល្លនាគត្ថេរ ពោលថា ជាមគ្គផ្សំ (មិស្សកៈ) ។ ព្រះថេរៈជាសិស្សពោលថា បពិត្រលោកម្ចាស់ ជាបុព្វភាគ ។ អាចារ្យពោលថា អាវុសោ ជាមិស្សកៈទេ ។ តែកាលអាចារ្យនិយាយរឿយៗ អន្តេវាសិក

ក៏មិនជំទាស់ ហើយនៅស្ងៀម ។ ទាំងសិស្ស ទាំងអាចារ្យសម្រេចបញ្ហាគ្នាមិនបាន ក៏ក្រោកទៅ ។ ខាងក្រោយ ព្រះថេរៈជាអាចារ្យ ដើរទៅរោងស្រង់ទឹក ពិចារណាថា អញពោលថា ជាមិស្សកមគ្គ ចំណែកលោកចុល្លនាគកាន់យកគោល ពោលថា ជាបុព្វភាគមគ្គ សេចក្តីវិនិច្ឆ័យក្នុងសេចក្តីនេះ ដូចម្តេចហ្ន៎ កាលស្វាធ្យាយព្រះសូត្រ (មហាសតិប្បដ្ឋានសូត្រ) តាំងពីដើម ក៏កំណត់បានត្រង់នេះ ដែលថា ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ ទាំងនេះដល់ ៧ ឆ្នាំ ក៏ជឿថា លោកុត្តរមគ្គកើតឡើងហើយ ឈ្មោះថា តាំងនៅដល់ ៧ ឆ្នាំ មិនមាន ដែលអញពោលថា ជាមិស្សកមគ្គ គឺមិនត្រឹមត្រូវ ចំណែកអាវុសោចុល្លនាគឃើញថា ជាបុព្វភាគនៃមគ្គ រមែងត្រឹមត្រូវ កាលជនទាំងឡាយប្រកាសការស្តាប់ធម៌ថ្ងៃ ៨ លោកក៏ទៅ ។

បានឮថា បុរាណត្ថេរ ជាអ្នកស្រឡាញ់ការស្តាប់ធម៌ កាលបានឮសំឡេងប្រកាស ក៏បន្ទឺសំឡេងតែមួយថា ខ្ញុំមុន ខ្ញុំមុន ។ ថ្ងៃនោះ ជាវារៈរបស់ព្រះចុល្លនាគត្ថេរ ។ លោកអង្គុយលើធម្មាសនៈ ចាប់ផ្តើមពោលគាថាខាងដើម ព្រះថេរៈជាអាចារ្យនៅក្រោយអាសនៈ ក៏គិតថា នឹងអង្គុយកំប៉ាំងៗ មិននិយាយចរចា ។ ពិតហើយ បុរាណត្ថេរ មិនច្រណែនគ្នា មិនចាប់យកសេចក្តីពេញចិត្តរបស់ខ្លួនឡើងជាការៈ ដូចជាលីកំណាត់អំពៅ កាន់យកតែហេតុ (ដែលគួរ) ប៉ុណ្ណោះ ដែលមិនមែនក៏លះបង់ទៅ ព្រោះដូច្នោះ ទើបព្រះចុល្លសុមនត្ថេរ ហៅព្រះចុល្លនាគតិចៗ ព្រះចុល្លនាគត្ថេរបានឮដូច

សំឡេងអាចារ្យហៅ ទើបបញ្ឈប់ធម្មកថា សួរថា បពិត្រលោកម្ចាស់ មានការ អ្វី ។ អាចារ្យពោលថា អាវុសោចុល្លនាគ ដែលខ្ញុំពោលថា ជាមិស្សកមគ្គនោះ មិនត្រូវទេ ចំណែកដែលលោកពោលថា សតិប្បដ្ឋាន ជាបុព្វភាគនៃមគ្គត្រូវ ហើយ ។ ព្រះចុល្លនាគត្ថេរគិតថា អាចារ្យរបស់អញទ្រទ្រង់បរិយត្តិធម៌ទុក ទាំងអស់ ជាសុតពុទ្ធ ខាងព្រះត្រៃបិដក កិក្ខុបែបនេះគង់វឹកវរមិនអាចបែង ចែកបញ្ហាបាន អំណឹះតទៅ ព្រះធម្មកថិកទាំងឡាយនឹងវឹកវរក្នុងបញ្ហាប្រភេទ នេះ ព្រោះដូច្នោះ អញនឹងកាន់យកព្រះសូត្រជាគោល ធ្វើបញ្ហាប្រភេទនេះ មិនឲ្យវឹកវរតទៅ ។ សតិប្បដ្ឋានជាបុព្វភាគនៃមគ្គ តែក្នុងគម្ពីរបដិសម្ភិទាមគ្គ ហៅថា ឯកាយនមគ្គ ។ ទើបលោកនាំព្រះសូត្រ ក្នុងធម្មបទ ខុទ្ទកនិកាយ តាំងជាបទខាទូសទ្បើង

មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទ្វិបទានញ្ច ចក្ខុមា។
ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា
ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារសេនប្បមទ្ទនំ
ឯតញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ។

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯងប្រព្រឹត្ត ទៅ ដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។ ព្រោះហេតុនោះ

អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះ ជាផ្លូវញ្ចាំងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ នឹងអាចធ្វើឲ្យផុតទុក្ខបាន ដូច្នេះ ។

ក្នុងបទថា **មគ្គោ** ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថដូចម្តេច ព្រោះអត្ថថា ជាគ្រឿងដើរទៅកាន់ព្រះនិព្វាន ១ ព្រោះអត្ថថា បុគ្គលដែលត្រូវការព្រះនិព្វានគប្បីស្វែងរក ១ ។

បទថា **សត្តានំ វិសុទ្ធិយា** សេចក្តីថា ដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធនៃសត្វទាំងឡាយដែលមានចិត្តសៅហ្មង ព្រោះមន្ទិលទាំងឡាយ មានរាគៈជាដើម និងព្រោះឧបក្កិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈជាដើម ជាការពិត សត្វទាំងនេះ គឺព្រះសម្មាសម្ពុទ្ធទាំងឡាយជាអនេក តាំងពីព្រះពុទ្ធព្រះនាមថា តណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ ដែលបរិនិព្វានក្នុងកប្បតែមួយប៉ុណ្ណោះ ខាងដើមតាំងអំពី ៤ អសង្ខេយ្យ ១ សែនកប្ប អំពីកប្បនេះចុះមក ដរាបដល់ព្រះពុទ្ធព្រះនាមថា សក្យមុនី ជាទីបំផុត ព្រះបច្ចេកពុទ្ធច្រើនរយ ឯព្រះអរិយសាវកទាំងឡាយរាប់មិនបាន បានបណ្តែតមន្ទិលផ្លូវចិត្តទាំងអស់ ដល់សេចក្តីបរិសុទ្ធយ៉ាងក្រៃលែង ដោយផ្លូវនេះប៉ុណ្ណោះ ។ ការបញ្ញត្តិសេចក្តីសៅហ្មង និងផូរផង់ ដោយមន្ទិលដោយរូបតែម្យ៉ាង មិនមាន ។ សមពិត ដូចពាក្យដែលត្រាស់ថា

រូបេន សង្ពឹលិដ្ឋេន	សង្ពឹលិស្សន្តិ មាណវា
រូបេ សុទ្ធេ វិសុជ្ឈន្តិ	អនក្ខាតំ មហោសិនា
ចិត្តេន សង្ពឹលិដ្ឋេន	សង្ពឹលិស្សន្តិ មាណវា

ចិត្តេ សុទ្ធេ វិសុជ្ឈន្តិ ឥតិ វុត្តំ មហេសិនា។

ព្រះពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំក្រៃលែង មិនបានត្រាស់ទូន្មានថា សត្វទាំងឡាយមានរូបសៅហ្មងហើយ ទើបសៅហ្មង មានរូបបរិសុទ្ធហើយ ទើបបរិសុទ្ធ តែព្រះមហេសីទ្រង់ទូន្មានថា សត្វទាំងឡាយមានចិត្តសៅហ្មងហើយ ទើបសៅហ្មង មានចិត្តបរិសុទ្ធហើយ ទើបបរិសុទ្ធ ដូច្នេះ ។

ជួចដែលត្រាស់ក្នុងសំយុត្តនិកាយខន្ធវារវគ្គថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្ត រមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធ ដូច្នេះ ។ សេចក្តីផូរផង់នៃចិត្តនោះ រមែងមានដោយមគ្គ គឺសតិប្បដ្ឋាននេះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។

បទថា **សោកបរិទេវានំ សមតិក្កមាយ** *សេចក្តីថា ដើម្បីឈានកន្ទង គឺលះបង់នូវសោក និងបរិទេវៈ ។ ពិតហើយ មគ្គនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីឈានកន្ទងសោក ដូចសោករបស់សន្តតិ-មហាមាត្យជាដើម ដើម្បីឈានកន្ទងបរិទេវៈ ដូចបរិទេវៈរបស់នាងបដាចារជាដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីឈានកន្ទងសោក និងបរិទេវៈ ។ ពិតហើយ សន្តតិមហាមាត្យស្តាប់គាថា ដូច្នេះថា*

យំ បុព្វេ តំ វិសោចេហិ បច្ឆា តេ មាហុ កិញ្ចនំ

មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។

កិលេសជាតណាកើតឡើង ព្រោះប្រារព្ធសង្ខារជាអតីត អ្នកចូរធ្វើ

កិលេសនោះ ឲ្យវិនស្វូតទៅ កិលេសគ្រឿងកង្វល់ មានរាគៈជាដើម កើតឡើង ព្រោះប្រារព្ធសង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្តាល មានរូបជាដើមដែលជាបច្ចុប្បន្ន អ្នកនឹងទៅជាបុគ្គលស្ងប់ ដូច្នេះហើយ ក៏សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ។

នាងបជាបតីស្តាប់ព្រះគាថានេះ ដូច្នេះថា

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមាន ដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងឡើយ ទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន ។

ហើយក៏តាំងនៅក្នុងសោតាបត្តិផល ព្រោះថា ឈ្មោះថា ការមិនពាល់ត្រូវនូវធម៌ណាមួយ ក្នុងកាយ វេទនា ចិត្ត ធម៌ទាំងឡាយហើយ ការនាមិនមានឡើយ ដូច្នោះ ទើបគួរជ្រាបថា សន្តតិមហាមាត្យ និងនាងបជាបតីនោះ ជាបុគ្គលឈានកន្ទងសោក និងបរិទេវៈ ដោយមគ្គនេះឯង ។

បទថា **ទុក្ខទោមនស្សានំ អត្ថង្គមាយ** *សេចក្តីថា ដើម្បីតាំងនៅមិនបាន គឺរលត់ទាំងពីរនេះ គឺទុក្ខផ្លូវកាយ និងទោមនស្សផ្លូវចិត្ត ។ ព្រោះថា មគ្គនេះ បុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ ដូចទុក្ខរបស់ព្រះតិស្សត្ថេរជាដើម រលត់ទោមនស្ស ដូចទោមនស្សរបស់សក្កទេវរាជជាដើម ។ ក្នុងរឿងទាំងពីរនោះ សម្តែងសេចក្តីរលត់ដូចតទៅនេះ ។*

រឿងឧក្ខរបស់ព្រះតិស្សត្ថេរ

បានញ្ចថា ក្នុងក្រុងសាវត្ថី បុត្ររបស់កុដុម្ពិកៈឈ្មោះតិស្សៈ លះទ្រព្យ ៤០ កោដិ ចេញបួសនៅតែម្នាក់ឯងក្នុងព្រៃ មិនមានផ្ទះ ។ ភរិយារបស់ប្អូនប្រុស បញ្ជូនចោរ ៥០០ ឲ្យទៅសម្ងាប់លោក ។ ពួកចោរទៅព័ទ្ធចាប់លោក ។ ទើបលោកសួរថា ឧបាសក អ្នកនាំគ្នាមកធ្វើអ្វី ពួកចោរធ្វើយថា មកសម្ងាប់លោកម្ចាស់ ។ ព្រះថេរៈក៏សំណូមពរថា ឧបាសកទាំងឡាយ មេត្តាទទួលធានាអាត្មា ឲ្យជីវិតអាត្មាត្រឹមតែមួយយប់ចុះ ពួកចោរពោលថា សមណៈ អ្នកណានឹងធានាលោកក្នុងឋានៈយ៉ាងនេះបាន ។ ព្រះថេរៈក៏ចាប់ថ្មដុំធំ វាយធ្មឹងស្មងជើងទាំងពីរខាង ហើយពោលថា ការធានាប៉ុណ្ណេះគ្រប់គ្រាន់ទេ ។ ពួកចោរទាំងនោះ ក៏មិនទាន់គេចទៅ ត្រឡប់មកបង្កាត់ភ្លើងដេកក្បែរទីចង្ក្រមព្រះថេរៈគ្របសង្កត់វេទនា ពិចារណាសីល អាស្រ័យសីលដែលបរិសុទ្ធ ក៏កើតបីតិ និងបាមោជ្ជ ។ លំដាប់តពីនោះ ក៏ចម្រើនវិបស្សនា ធ្វើសមណធម៌អស់រាត្រីក្នុងយាមទាំង ៣ ពេលអរុណរះ ក៏សម្រេចអរហត្ត បន្ទឺឧទានថា

ឧភោ ចាធានិ ភិន្ទិត្វា សញ្ញមិស្សាមិ រោ អហំ
អដ្ឌិយាមិ ហរាយាមិ សរាគមរណេ អហំ
ឯវាហំ ចិន្តយិត្វាន យថាភូតំ វិបស្សិសំ
សម្សត្ថេ អរុណុគ្គម្ហិ អរហត្តំ អចាបុណឹ ។

ខ្ញុំវាយបំបាក់ជើងទាំងពីរ ធានាដល់ចោរទាំងឡាយ ខ្ញុំខ្ពើមក្នុងការស្ងាប់ទាំងដែលនៅមានរាគៈ ខ្ញុំគិតយ៉ាងនេះហើយ ក៏យើញច្បាស់តាមសេចក្តីពិត ពេលអរុណរះ ខ្ញុំក៏សម្រេចអរហត្ត ដូច្នេះ ។

រឿងទុក្ករបស់ភិក្ខុ ៣០ រូប

ភិក្ខុ ៣០ រូប មួយក្រុមទៀត រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមានព្រះភាគ ហើយចាំវស្សាក្នុងព្រៃ ធ្វើកតិកាគ្នាថា អ្នកមានអាយុ យើងគួរធ្វើសមណធម៌ រហូតអស់រាត្រីក្នុងយាមទាំង ៣ យើងមិនគួរមកកាន់សម្នាក់នៃគ្នានិងគ្នា ហើយក៏ទៅកាន់ទីផ្សេងៗ គ្នា ។ កាលភិក្ខុទាំងនោះធ្វើសមណធម៌ ក្នុងពេលជិតភ្លឺក៏ដេកលក់ ខ្លាមួយក៏មកចាប់ភិក្ខុទៅស៊ី ម្តងមួយអង្គៗ ។ ភិក្ខុណាមួយក៏មិនបានបន្ទឺវាចាថា ខ្លាពាំខ្ញុំហើយ ។ ភិក្ខុត្រូវខ្លាស៊ីអស់ ១៥ អង្គ ដោយអាការយ៉ាងនេះ ដល់ថ្ងៃឧបោសថ ភិក្ខុដ៏សេសក៏សួរថា លោកនៅទីណា ក៏បានដឹងរឿង ហើយពោលថា បើត្រូវខ្លាចាប់ គប្បីប្រាប់ថា ឥឡូវនេះ ខ្ញុំត្រូវខ្លាចាប់ហើយ ក៏នៅបន្តទៅទៀត ។ តមកខ្លាក៏ចាប់ភិក្ខុកំលោះមួយរូប ដោយនយមុននោះឯង ។ ភិក្ខុកំលោះក៏ស្រែកថា ខ្លា លោកម្ចាស់ ។ ភិក្ខុទាំងឡាយក៏កាន់ឈើច្រត់ និងគប់ភ្លើងដេញតាមបំណងថា នឹងឲ្យខ្លាលែង ខ្លាក៏ឡើងទៅកាន់ទីជាប់នៃភ្នំ ដែលភិក្ខុទាំងឡាយទៅមិនបាន ផ្តើមស៊ីភិក្ខុនោះតាំងពីម្រាមជើង ។ ភិក្ខុទាំងឡាយក្រៅនោះ ក៏បានតែពោលថា សប្បុរស ឥឡូវនេះ កិច្ចដែលពួកយើងត្រូវធ្វើមិនមាន ដែលឈ្មោះថា សេចក្តីវិសេសរបស់ភិក្ខុទាំងឡាយរមែងប្រាកដក្នុងឋានៈដូច្នេះ ។ ភិក្ខុកំលោះនោះ ដេកនៅក្នុងមាត់ខ្លា គ្របសង្កត់វេទនាដែលឈឺចុកចាប់ ហើយចម្រើនវិបស្សនា ពេលខ្លាស៊ីដល់កជើង បានជាព្រះសោតាបន្ន ពេលស៊ីទៅដល់ក្បាលជង្គង់ បានជាព្រះសកទាគាមី ពេលខ្លាស៊ីទៅដល់ពោះ បានជាព្រះអនាគាមី ពេលខ្លាស៊ីជិតដល់បេះដូង ក៏សម្រេចអរហត្ត មួយអន្ទឹដោយបដិសម្ភិទា ទើបបន្ទឺឧទានដូច្នេះថា

សីលវាវត្តសម្បន្នោ បញ្ញវា សុសមាហិតោ
មុហុត្តំ បមាទមជ្ឈាយ ព្យគ្ឃោ រុទ្ធមានសោ
បញ្ជរស្មឹ សោ គហេត្វា សិលាយ ឧបរិ កតោ
កាមំ ខាទតុ មំ ព្យគ្ឃោ អដ្ឋិយា ច ឆ្ឆារុស្ស ច
កិលេសេ ខេបយិស្សាមិ ផុសិស្សាមិ វិមុត្តិយំ ។

ខ្ញុំមានសីល ដល់ព្រមដោយវត្ត មានបញ្ញា មានចិត្តតាំងមាំល្អហើយ អាស្រ័យសេចក្តីប្រមាទមួយភ្លែត ទាំងដែលមានចិត្តមិនគិតប្រទូស្តក្នុងខ្លា ខ្លាក៏ចាប់ខ្ញុំទុកក្នុងក្រចក នាំទៅទុកលើផ្ទាំងថ្ម ទោះខ្លាស៊ីខ្ញុំដល់ឆ្អឹង និងសរសៃក៏ដោយ ខ្ញុំនឹងធ្វើកិលេសឲ្យអស់ទៅ នឹងពាល់ត្រូវវិមុត្តិ ដូច្នេះ ។

រឿងទុក្ករបស់ព្រះបិតិមល្លត្ថេរ

កិកុមួយរូបទៀត ឈ្មោះបិតិមល្លត្ថេរ កាលនៅជាគ្រហស្ថ កាន់ទង់មកកោះលង្កា អស់ ៣ វស្សកាល ចូលគាល់ព្រះរាជា ហើយបានទទួលព្រះរាជានុគ្រោះ ថ្ងៃមួយ ធ្វើដំណើរទៅកាន់ទ្វារសាលា ដែលមានទីអង្គុយ ក្រាលដោយកន្ទេលផែង បានស្តាប់នតុម្ហាកវគ្គ ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គថា ម្នាលកិកុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នូវរូបនោះចេញ រូបនោះ បើអ្នកទាំងឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដូច្នេះហើយ ក៏គិតថា មិនមែនតែរូបប៉ុណ្ណោះទេ វេទនាក៏មិនមែនរបស់ខ្លួន ។ បុរសនោះធ្វើព្រះបាលីនោះឲ្យជាប្រធាន ហើយចេញទៅកាន់មហាវិហារ សូមបព្វជ្ជាឧបសម្បទា ហើយធ្វើ

មាតិកាទាំងពីរ ឲ្យស្តាត់ជំនាញ នាំភិក្ខុ ៣០ រូប ទៅកាន់លានក្នុងតំបន់គវបរបាលី ធ្វើសមណធម៌ ។ កាលជើងដើរមិនបាន ក៏លុតជង្គង់ដើរចង្រ្កែម ។ ក្នុងយប់នោះ ព្រានព្រៃម្នាក់សម្គាល់ថា ម្រឹគ ក៏ពួយលំពែងទៅ ។ លំពែងក៏ត្រូវលោកដល់ធ្លុះ លោកក៏ឲ្យព្រានដកលំពែងចេញ យកវមូរស្មៅញាត់មុខរបួស ឲ្យព្រានលើកខ្លួនអង្គុយលើផ្នាំងថ្ម ឲ្យព្រានបើកឱកាស ចម្រើនវិបស្សនា ក៏សម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ព្យាករដល់ភិក្ខុទាំងឡាយដែលនាំគ្នាមក ដោយឲ្យសំឡេងក្អកគ្រហែម បន្ទឹខទានដូច្នេះថា

ភាសិតំ ពុទ្ធសេដ្ឋស្ស សព្វលោកគ្គវាទិនោ
ឯ តុម្ហាកមិទំ រូបំ តំ ជហេយ្យាថ ភិក្ខវោ
អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។

ព្រះពុទ្ធដ៏ប្រសើរ ដែលសត្វលោកពោលសរសើរថា ទ្រង់ជាកំពូលលើសលោកទាំងពួង ទ្រង់ភាសិតថា ម្នាលភិក្ខុទាំងឡាយ រូបនេះ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ គប្បីលះបង់រូបនោះចេញ ។ សង្ខារទាំងឡាយមិនទៀងហ្ន៎ មានការកើត និងវិនាសទៅជាធម្មតា កើតហើយ ក៏រលត់ ការស្ងប់រម្ងាប់នៃសង្ខារទាំងនោះ ជាសុខ ដូច្នេះ ។

មគ្គនេះ រមែងប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ ដូចជាទុក្ខរបស់ព្រះតិស្សត្ថេរជាដើម ត្រឹមតែប៉ុណ្ណេះ ។

រឿងនោមនស្សរបស់សក្កទេវរាជ និងសុព្រហ្មទេវបុត្រ

សក្កទេវរាជ ទ្រង់ឃើញបុព្វនិមិត្ត ៥ ប្រការរបស់ព្រះអង្គ ត្រូវមរណភ័យគ្របសង្កត់ កើតទោមនស្ស ចូលគាល់ព្រះមានព្រះភាគ ទូលសួរបញ្ហា ។ ទ្រង់ក៏តាំងនៅក្នុងសោតាបត្តិផល ព្រមដោយទេវតា ៨ ម៉ឺនអង្គ ដោយអំណាចការវិសជ្ជនាឧបេក្ខាបញ្ហា ។ បដិសន្ធិរបស់សក្កទេវរាជ ក៏មានជាប្រក្រតីវិញ[1] ។

សូម្បីសុព្រហ្មទេវបុត្រ ដែលទេពអប្សរ ១០០០ ចោមរោម ក៏សោយសម្បត្តិ ។ ក្នុងទេពអប្សរ ១០០០ នោះ ទេពអប្សរ ៥០០ រលៀតបេះផ្កាអំពីដើម ក៏ចុតិទៅកើតក្នុងនរក សុព្រហ្មទេវបុត្រពិចារណាថា ហេតុដូចម្តេចទើបទេពអប្សរទាំងនេះយឺតយូរម៉្លេះ ក៏ដឹងថា ពួកនាងទៅកើតក្នុងនរក ទើបបែរមកពិចារណាមើលខ្លួនឯងថា អាយុប៉ុន្មានហើយហ្ន៎ ក៏ដឹងថា ខ្លួននឹងអស់អាយុ នឹងទៅកើតក្នុងនរកនោះដែរ ក៏ភ័យខ្លាច កើតទោមនស្សយ៉ាងក្រៃលែង ឃើញថា ព្រះបរមសាស្តាប៉ុណ្ណោះ នឹងញុំាងទោមនស្សរបស់អញនេះឲ្យវិនាសទៅ មិនមានអ្នកដទៃ ហើយក៏នាំទេពអប្សរ ៥០០ ដ៏សេស ចូលគាល់ព្រះមានព្រះភាគ ទូលសួរបញ្ហាថា

និច្ចមុត្រស្តមិទំ ចិត្តំ និច្ចមុពិគ្គមិទំ មនោ
អនុប្បន្នេសុ កិច្ចេសុ អថោ ឧប្បត្តិតេសុ ច
សចេ អត្ថិ អនុត្រស្តំ តំ មេ អក្ខាហិ បុច្ឆិតោ ។

កាលបើកិច្ច គឺសេចក្តីទុក្ខទាំងឡាយ មិនទាន់កើតឡើងក្តី ឬកើតឡើងហើយក្តី ចិត្តរបស់ខ្ញុំព្រះអង្គនេះតក់ស្លុតជានិច្ច ចិត្តរបស់ខ្ញុំព្រះអង្គ នេះរន្ធត់

๑- មើលអដ្ឋកថា សក្កបញ្ហសូត្រ ។

ជានិច្ច បើចិត្តដែលមិនតក់ស្លុតមាន ខ្ញុំព្រះអង្គសូមសួរឲ្យព្រះអង្គប្រាប់ នូវចិត្តនោះដល់ខ្ញុំព្រះអង្គ ។

លំដាប់នោះ ទើបព្រះមានព្រះភាគ បានត្រាស់ប្រាប់សុព្រហ្មទេវបុត្រក្នុងសំយុត្តនិកាយ សគាថវគ្គដូច្នេះថា

ជាញ្ញត្រ ពោជ្ឈង្គ តបសា ជាញ្ញត្រ ឥន្ទ្រិយសំវរា
ជាញ្ញត្រ សព្វបនិស្សគ្គា សោត្តិ បស្សាមិ ចាណិនំ។

តថាគត មិនឃើញសួស្តីរបស់ពួកសត្វ ក្រៅអំពីពោជ្ឈង្គ និងតបោ-គុណ ក្រៅអំពីការសង្រួមនូវឥន្ទ្រិយទេ ក្រៅអំពីការលះបង់នូវកិលេសទាំងអស់ទេ ដូច្នេះ ។

ក្នុងទីបំផុតទេសនា សុព្រហ្មទេវបុត្រក៏តាំងនៅក្នុងសោតាបត្តិផល មួយអន្ទើដោយទេពអប្សរ ៥០០ ធ្វើសម្បត្តិនោះឲ្យថាវរៈហើយ ត្រឡប់ទៅកាន់ទេវលោក ។

មគ្គនេះ ដែលបុគ្គលចម្រើនហើយ បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅដើម្បីរលត់ទោមនស្ស ដូចទោមនស្សរបស់សក្កទេវរាជជាដើម ដូចពោលមកនេះ ។

មគ្គមានអង្គ ៨ ដែលជាអរិយៈ ហៅថា ញេយ្យធម៌ ក្នុងបទថា **ញាយស្ស អធិគមាយ** *លោកអធិប្បាយថា ដើម្បីសម្រេច គឺដើម្បីដល់ញេយ្យធម៌នោះ ។ ពិតហើយ មគ្គ គឺសតិប្បដ្ឋានដែលជាលោកិយជាខាងដើមនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសម្រេចមគ្គដែល*

ជាលោកុត្តរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីសម្រេចញ្ញយ្យធម៌ ។

បទថា **និព្ពានស្ស សច្ឆិកិរិយាយ** *លោកអធិប្បាយថា ដើម្បីធ្វើឲ្យច្បាស់ គឺដើម្បីប្រចក្សដោយខ្លួនឯង នូវអមតធម៌ ដែលបានឈ្មោះថា និព្វាន ព្រោះរៀរចាកតណ្ហាជាគ្រឿងរួបរឹត ។ ពិតហើយ មគ្គនេះដែលបុគ្គលចម្រើនហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឲ្យសម្រេចទៅតាមលំដាប់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដូច្នេះ ។*

ក្នុងព្រះសូត្រនេះ កាលព្រះមានព្រះភាគត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយហើយ ពាក្យថា ដើម្បីឈានកន្ទងសោក និងបរិទេវៈជាដើម ឈ្មោះថា សម្រេចអត្ថបានក៏ពិត រៀរលែងតែអ្នកឈ្លាស ជ្រាបនូវភាពត្រឹមត្រូវនៃពាក្យប្រៀនប្រដៅចេញហើយ ក៏មិនប្រាកដដល់អ្នកដទៃបាន តែព្រះមានព្រះភាគ ទ្រង់មិនបានធ្វើឲ្យជនអ្នកឈ្លាស ជ្រាបភាពត្រឹមត្រូវរបស់ពាក្យប្រៀនប្រដៅជាមុន ហើយទ្រង់សម្តែងធម៌ក្នុងកាលជាក្រោយឡើយ តែបើទ្រង់ញុំាងជនទាំងឡាយឲ្យជ្រាបអត្ថនោះៗ ដោយសូត្រនោះៗ តែម្តង ព្រោះដូច្នោះ ក្នុងទីនេះ ឯកាយនមគ្គ នឹងញុំាងអត្ថណាមួយឲ្យសម្រេចបាន ក៏ទ្រង់សម្តែងអត្ថនោះៗ ឲ្យប្រាកដ ទើបត្រាស់ថា ដើម្បីឈានកន្ទងសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលជាដើម ។ ឬនយម្យ៉ាងទៀត សេចក្តីបរិសុទ្ធិរបស់សត្វទាំងឡាយ រមែងប្រព្រឹត្តទៅបានដោយឯកាយនមគ្គ សេចក្តីបរិសុទ្ធនោះ តែង

មានដោយការ ឈានកន្ធង់សោក និង៥វិទេវៈ ការឈានកន្ធង់សោក និង៥វិទេវៈ រមែងមានដោយការរលត់ទុក្ខ និងទោមនស្ស ការរលត់ទុក្ខ និងទោមនស្ស រមែងមានដោយការសម្រេចព្រោយ្យធម៌ ការសម្រេចព្រោយ្យធម៌ រមែងមានដោយការធ្វើឲ្យច្បាស់នូវព្រះនិព្វាន ព្រោះដូច្នោះ កាលទ្រង់សម្តែងលំដាប់នយយ៉ាងនេះ ទើបត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ហើយត្រាស់ពាក្យថា ដើម្បីឈានកន្ធង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលជាដើម ។

នយម្យ៉ាងទៀត ពាក្យដែលពោលមកនេះ ជាពណ៌នាគុណរបស់ឯកាយនមគ្គ ។ ប្រៀបដូចព្រះមានព្រះភាគ បានត្រាស់គុណដោយបទទាំង ៨ ដោយឆក្កទេសនា ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក:ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌ ដែលមានចំនួន ៦ ឆក្កៈ ដូច្នេះ យ៉ាងណា និងត្រាស់គុណដោយបទទាំង ៩ ដោយអរិយ-វង្សទេសនា ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ ជីងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្របូកច្របល់ មិនដែលច្របូកច្របល់ មិនរតាត់រតាយ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបានដូច្នេះ យ៉ាងណា ព្រះមានព្រះភាគ ក៏បានត្រាស់គុណរបស់ឯកាយនមគ្គនេះ ដោយបទ

ទាំង ๗ ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយជាដើម ក៏ដូច្នោះ ។ បើសួរ ថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា ដើម្បីឲ្យកើតឧស្សាហៈដល់ភិក្ខុទាំងនោះ ។ ពិតហើយ ភិក្ខុទាំងនោះ ស្តាប់ការត្រាស់គុណ (របស់ឯកាយនមគ្គ) ដ៏ធំ ថា មគ្គនេះនាំចេញទៅនូវឧបទ្ទវ ๔ គឺសោក ដែលជាគ្រឿងជុតចិត្ត បរិទេវៈ ដែលជាការយំរៀបរាប់ ទុក្ខដែលជាការមិនសប្បាយផ្លូវកាយ ទោមនស្ស ដែលជាការមិនសប្បាយផ្លូវចិត្ត នាំមកនូវគុណវិសេស ๓ គឺវិសុទ្ធិ ញេយ្យ-ធម៌ ព្រះនិព្វាន ដូច្នេះហើយ ក៏កើតឧស្សាហៈ សម្គាល់ទេសនានេះថា គួរ ស្វាធ្យាយ គួររៀន គួរទ្រទ្រង់ គួរពោល និងសម្គាល់មគ្គនេះថា គួរចម្រើន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ បានត្រាស់គុណ (របស់ឯកាយនមគ្គ) ដើម្បីឲ្យកើតឧស្សាហៈ ដល់ភិក្ខុទាំងនោះ ដូចឈ្មួញសំពត់កម្ពលជាដើម ឃោសនាគុណភាពរបស់សំពត់កម្ពល ជាដើមដូច្នោះ ។

ឧបមាថា ឈ្មួញអ្នកលក់សំពត់កម្ពល ដែលមានតម្លៃរាប់សែន ឃោសនាថា សូមទិញសំពត់កម្ពល មនុស្សទាំងឡាយក៏មិនទាន់ជ្រាបមុនថា សំពត់កម្ពលធ្វើដោយសក់មនុស្សក៏មាន សំពត់កម្ពលធ្វើដោយរោមសត្វក៏មានជាដើម វាមានក្លិនស្អុយ សម្ផស្សគ្រោតគ្រោត តែក៏ហៅថា សំពត់កម្ពលដូចគ្នា ប៉ុន្តែកាលណា ឈ្មួញនោះឃោសនាថា សំពត់កម្ពលពណ៌ក្រហមធ្វើក្នុងដែនគន្ធារៈ ល្អិតល្អន់ ស្រស់ថ្លា សម្ផស្សទន់ កាលនោះ បើមានប្រាក់គ្រប់ក៏ទិញយក បើមិនគ្រប់ ក៏ចង់មើល យ៉ាងណា កាលព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវមួលតែមួយ ដូច្នេះ ក៏មិនទាន់

ប្រាកដជាមុនថា ផ្លូវណា ព្រោះថា សូម្បីផ្លូវដែលមិននាំសត្វចេញចាកទុក្ខ មានប្រការផ្សេងៗ ក៏ហៅថា ផ្លូវដូចគ្នា តែកាលព្រះមានព្រះភាគត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដូច្នេះជាដើម ភិក្ខុទាំងឡាយក៏ជ្រាបថា ផ្លូវនេះនាំចេញនូវឧបទ្ទវ ៤ នាំមកនូវគុណវិសេស ៣ ហើយក៏កើតឧស្សាហៈ សម្គាល់ទេសនានេះថា គួរស្វាធ្យាយ គួររៀន គួរទ្រទ្រង់ គួរពោល និង សម្គាល់មគ្គនេះថា គួរចម្រើន ព្រោះដូច្នោះ ព្រះមានព្រះភាគកាលត្រាស់គុណ (របស់ឯកាយនមគ្គ) ទើបត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ជាដើម ។

មួយទៀត ការឧបមាពោលដោយឈ្នួញសំពត់កម្ពលពណ៌លឿង ដែលមានតម្លៃមួយសែន នាំមកប្រៀបធៀបយ៉ាងណា ក្នុងសេចក្តីនេះ ក៏គួរនាំការឧបមាពោលដោយឈ្នួញ មាសជម្ពូនុទ កែវមណីដែលធ្វើទឹកឲ្យថ្លា កែវមុក្តាដែលបរិសុទ្ធ សំពត់រោមសត្វ និងកែវប្រពាលជាដើម យកមកប្រៀបធៀបដូច្នោះ ។

ពាក្យថា **យទิทំ** ជានិបាតសព្ទ ។ និបាតសព្ទនោះ មានសេចក្តីដូច្នេះថា **(យេ ឥមេ)** ទាំងនេះ ។ បទថា **ចตฺตาโร** ជាសព្ទកំណត់ចំនួន ។ ដោយចំនួននោះ ព្រះមានព្រះភាគ ទ្រង់សម្តែងការកំណត់ចំនួនសតិបដ្ឋានថា មិនតិចជាងនោះ មិនច្រើនជាងនោះ ។ បទថា **สติปฏฺฐานา** បានដល់ សតិបដ្ឋាន ៣ គឺអារម្មណ៍នៃសតិក៏មាន ភាពដែលព្រះសាស្តាទ្រង់កន្ទងបង់សេចក្តីប្រទូស្ត

*និងត្រេកអរក្នុងសាវ័កទាំងឡាយ អ្នកបដិបត្តិ ៣ យ៉ាងក៏មាន តួសតិក៏មាន ។ អារម្មណ៍នៃសតិ ហៅថា សតិប្បដ្ឋាន ដូចបាលីក្នុងសំយុត្តនិកាយ មហាវារ-វគ្គជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើង និងសូន្យទៅនៃសតិប្បដ្ឋាន ៤ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះចុះ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីកើតឡើងនៃកាយដូចម្តេច សេចក្តីកើតឡើងនៃកាយ ព្រោះកើតឡើងនៃអាហារ ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា សតិប្បដ្ឋាន ដូចបាលីក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គជាដើមថា កាយ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថា សតិទេ សតិឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ។ ពាក្យនោះ មានសេចក្តីដូច្នេះ ។ ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថវិគ្គហៈថា ជាទីតាំងក្នុងទីនេះ ។ សួរថា អ្វីតាំង ឆ្លើយថា សតិ ។ ទីតាំងនៃសតិ ឈ្មោះថា សតិប្បដ្ឋាន ។ នយម្យ៉ាងទៀត ការតាំងជាប្រធាន ហេតុនោះ ទើបឈ្មោះថា បដ្ឋាន ។ ការតាំងនៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** ដូចជាការឈរបស់ជីរ ការឈរបស់សេះជាដើម ។ ភាពដែលព្រះបរមសាស្តា ទ្រង់កន្ទងបង់សេចក្តីទាស់ចិត្ត និងសេចក្តីពេញចិត្តក្នុងសាវ័កទាំងឡាយ អ្នកបដិបត្តិ ៣ យ៉ាង ហៅថា សតិប្បដ្ឋាន ដូចក្នុងបាលីសឡាយតនវិភង្គសូត្រ មជ្ឈិម-និកាយ ឧបរិបណ្ណាសកៈថា ឯសតិប្បដ្ឋាន ៣ ប្រការ ជាធម៌ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរប្រៀនប្រដៅនូវគណៈបាន ដូច្នេះ ។ ពាក្យនោះមានសេចក្តីដូច្នេះ ឈ្មោះថា **បដ្ឋាន** ព្រោះជាធម៌ដែលគប្បីតាំងទុក អធិប្បាយថា គប្បីឲ្យប្រព្រឹត្តទៅ ។ សួរថា ព្រោះ*

ជាធម៌ដែលគប្បីតាំងទុកដោយអ្វី ឆ្លើយថា ដោយសតិ ។ ការតាំងទុកដោយ សតិ ឈ្មោះថា **សតិបฏฺฐาน** *ក៏សតិប៉ុណ្ណោះហៅថា* **សតិបฏฺฐาน** *ដូចក្នុង បាលីសំយុត្តនិកាយ មហាវារវគ្គជាដើមថា សតិបដ្ឋានទាំង ៤ ដែលបុគ្គល បានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញ បរិបូណ៌បាន ដូច្នេះ ។ ពាក្យនោះមានសេចក្តីដូច្នេះ ធម្មជាតណាតាំងនៅ ហើយអធិប្បាយថា ចូលទៅតាំងមាំ គឺប្រព្រឹត្តទៅ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា* **បฏฺฐาน** ។ *សតិនោះឯង ឈ្មោះថា* **សតิបฏฺฐาน** ។ *នយម្យ៉ាងទៀត ដែលឈ្មោះថា* **សតิ** *ព្រោះអត្ថថា រឭកបាន ដែលឈ្មោះថា* **បฏฺฐาน** *ព្រោះ អត្ថថា ចូលទៅតាំងទុក ។ ព្រោះដូច្នោះ សតិនោះផង បដ្ឋានផង ព្រោះ ហេតុនោះ ទើបឈ្មោះថា* **សតิបฏฺฐาน** ។ *ក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់ បំណងយកសតិបដ្ឋាននេះ ។ សួរថា បើដូច្នោះ ហេតុអ្វី ទើបពាក្យថា សតិបដ្ឋានទាំងឡាយជាពហុវចនៈ ឆ្លើយថា ព្រោះត្រូវមានសតិច្រើន សេចក្តី ពិត សតិនោះមានច្រើន ព្រោះផ្សេងគ្នានៃអារម្មណ៍ ។ សួរថា ហេតុអ្វី ទើប ពាក្យថា* **มคฺค** *ជាឯកវចនៈ ឆ្លើយថា ព្រោះជាផ្លូវតែមួយ ដោយអត្ថថា ជា មគ្គ ។ សេចក្តីពិត សតិទាំងនោះសូម្បីមាន ៤ ក៏រាប់ថា ផ្លូវតែមួយ ដោយ អត្ថថា ជាមគ្គ ។ សមពិត ដូចដែលលោកពោលថា សួរថា ក្នុងពាក្យថា មគ្គ ដែលឈ្មោះថា* **มคฺค** *ព្រោះអត្ថដូចម្តេច ឆ្លើយថា ព្រោះអត្ថថា ជាគ្រឿងទៅ កាន់ព្រះនិព្វានផង ព្រោះអត្ថថា អ្នកត្រូវការព្រះនិព្វាននឹងគប្បីស្វែងរកផង ។ សតិទាំង ៤ នោះ ធ្វើកិច្ចឲ្យសម្រេចក្នុងអារម្មណ៍ទាំងឡាយ មានកាយជាដើម*

ទើបដល់ព្រះនិព្វានក្នុងខាងក្រោយ តែអ្នកត្រូវការព្រះនិព្វានទាំងឡាយ ចាំបាច់ដើរទៅតាំងអំពីដើមមក ព្រោះដូច្នោះ ទើបសតិទាំង ៤ ហៅថា ផ្លូវមួលតែមួយ ។ ទេសនា ព្រមដោយអនុសន្ធិ រមែងមានដោយអនុសន្ធិ បទថា **សតិ** *ដូចក្នុងបាលីសំយុត្តនិកាយ មហាវារវគ្គជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវមគ្គ ជាគ្រឿងញ៉ាំញីនូវមារ និងសេនា ដល់អ្នកទាំង-ឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះចុះ ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដែលជាគ្រឿងញ៉ាំញីមារ និងសេនា តើដូចម្តេច គឺពោជ្ឈង្គ ៧ នេះឯង ដូច្នេះ ។ ពាក្យថា* **មគ្គ** *ជាគ្រឿងកម្ចាត់កងទ័ពមារ និងពាក្យថា* **សម្ពោជ្ឈង្គ ៧** *ដោយអត្ថ ក៏តែមួយដូចគ្នា ផ្សេងគ្នាតែព្យញ្ជន:ប៉ុណ្ណោះ យ៉ាងណា ពាក្យថា* **ឯកា-យនមគ្គ** *និងពាក្យថា* **សតិប្បដ្ឋាន ៤** *ដោយអត្ថក៏ដូចគ្នា ផ្សេងគ្នាតែព្យញ្ជន:ប៉ុណ្ណោះ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ជាឯកវចន: ក៏ព្រោះជាផ្លូវតែមួយ ដោយអត្ថថា ជាមគ្គ ជាពហុវចន: ក៏ព្រោះសតិមានច្រើន ដោយការផ្សេងគ្នានៃអារម្មណ៍ ។*

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ត្រាស់សតិប្បដ្ឋានថា មាន ៤ មិនខ្វះមិនលើស ឆ្លើយថា ក៏ព្រោះទ្រង់ធ្វើឲ្យជាប្រយោជន៍ដល់វេនេយ្យសត្វ ។ ពិតហើយ ក្នុងពួកវេនេយ្យសត្វដែលជាតណ្ហាចរិត ទិដ្ឋិចរិត ជាសមថយានិក (អ្នកមានសមថ:ជាយាន) និងវិបស្សនាយានិក ដែលប្រព្រឹត្តទៅដោយចំណែកទាំង ២ គឺបញ្ញាទន់ខ្សោយ និងបញ្ញាចាស់ក្លា កាយា-នុបស្សនាសតិប្បដ្ឋាន មានអារម្មណ៍គ្រោតគ្រោត ជាផ្លូវបរិសុទ្ធសម្រាប់

វេនេយ្យសត្ត ដែលមានតណ្ហាចរិត មានបញ្ញាទន់ខ្សោយ វេទនានុបស្សនា សតិប្បដ្ឋាន មានអារម្មណ៍ល្អិត ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ដែលមានតណ្ហាចរិត មានបញ្ញាចាស់ក្លា ចិត្តានុបស្សនាសតិប្បដ្ឋាន ដែលមានអារម្មណ៍មិនចែកចេញច្រើន ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ដែលមានទិដ្ឋិចរិត មានបញ្ញាទន់ខ្សោយ ធម្មានុបស្សនាសតិប្បដ្ឋាន ដែលមានអារម្មណ៍ចែកចេញច្រើន ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ដែលមានទិដ្ឋិចរិត មានបញ្ញាចាស់ក្លា ។ ម្យ៉ាងទៀត សតិប្បដ្ឋានទី ១ ដែលមាននិមិត្ត នឹងគប្បីសម្រេចបានដោយមិនលំបាក ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ជាសមថ-យានិក មានបញ្ញាទន់ខ្សោយ សតិប្បដ្ឋានទី ២ ព្រោះមិនតាំងនៅក្នុងអារម្មណ៍គ្រោតគ្រាត ទើបជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ជាសមថ-យានិក មានបញ្ញាចាស់ក្លា សតិប្បដ្ឋានទី ៣ មានអារម្មណ៍ដែលចែកចេញមិនច្រើន ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ជាវិបស្សនាយានិក មានបញ្ញាទន់ខ្សោយ សតិប្បដ្ឋានទី ៤ មានអារម្មណ៍ដែលចែកចេញច្រើន ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្ត ជាវិបស្សនាយានិក មានបញ្ញាចាស់ក្លា ។ ព្រោះហេតុដូច្នោះ ទើបពោលថា សតិប្បដ្ឋានមាន ៤ ប៉ុណ្ណោះ មិនលើសមិនខ្ងះ ។ ម្យ៉ាងវិញទៀត ដែលត្រាស់ថា សតិប្បដ្ឋានមាន ៤ ក៏ដើម្បីលះបង់នូវវិបល្លាស សេចក្តីសម្គាល់ខុសថា ស្អាត សុខ ទៀង និងជាតួខ្លួន ។ ពិតហើយ កាយជាអសុភ មិនស្អាត តែសត្ងទាំងឡាយ សម្គាល់ថា ស្អាត ក្នុងកាយនោះ ។ ដោយទ្រង់សម្តែងភាពមិនស្អាតក្នុងកាយនោះ ដល់សត្ងទាំងនោះ

ទើបត្រាស់សតិប្បដ្ឋានទី ១ ដើម្បីលះវិបល្លាសនោះចេញ ។ ក្នុងវេទនាជាដើម ដែលសត្វប្រកាន់ថា សុខ ទៀង ជាតួខ្លួន វេទនាក៏ជាទុក្ខ ចិត្តមិនទៀង ធម៌ទាំងឡាយជាអនត្តា តែសត្វទាំងឡាយ ក៏សម្គាល់ថា សុខ ទៀង ជាតួខ្លួន ក្នុងវេទនា ចិត្ត ធម៌នោះ ដោយទ្រង់សម្តែងភាពជាទុក្ខជាដើម ក្នុងវេទនា ចិត្ត ធម៌នោះ ដល់សត្វទាំងនោះ ទើបត្រាស់សតិប្បដ្ឋាន ៣ ដ៏សេស ដើម្បីលះវិបល្លាសទាំងនោះចេញ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ដែលត្រាស់ថា សតិប្បដ្ឋាន ๔ មិនលើសមិនខ្វះ ក៏ដើម្បីលះសេចក្តីសម្គាល់ខុសថា ស្អាត សុខ ទៀង និងតួខ្លួនចេញ ដូចដែលពោលមកនេះ មិនមែនដើម្បីលះនូវវិបល្លាសតែម៉្យាងប៉ុណ្ណោះទេ បណ្ឌិតគប្បីជ្រាបថា ដែលត្រាស់សតិប្បដ្ឋាន ๔ ក៏ដើម្បីលះឱឃៈ យោគៈ អាសវៈ គន្ថៈ ឧបាទាន និងអគតិ នីមួយៗ ๔ ផង ដើម្បីកំណត់ជីងអាហារ ๔ យ៉ាងផង គប្បីជ្រាបក្នុងទីមកក្នុងបករណ៍ចាលីប៉ុណ្ណោះ ។

ចំណែកក្នុងអដ្ឋកថា ពោលថា **សតិប្បដ្ឋាន** *មានមួយប៉ុណ្ណោះ ដោយការពួក និងដោយជាទីប្រជុំចុះតែមួយ មាន ๔ ដោយអំណាចអារម្មណ៍ ។ ប្រៀបដូចនគរមានទ្វារ ๔ បុគ្គលដែលមកពីទិសខាងកើត នាំវត្ថុដែលនៅទិសខាងកើត មកចូលនគរតាមទ្វារទិសខាងកើត អ្នកដែលមកពីទិសខាងត្បូង ទិសខាងលិចក៏ដូចគ្នា បុគ្គលដែលមកពីទិសខាងជើង ក៏នាំវត្ថុដែលនៅក្នុងទិសខាងជើង ចូលនគរតាមទ្វារទិសខាងជើង យ៉ាងណា ឧបមេយ្យនេះ ក៏ដូច្នោះ ។ ពិតហើយ និព្វាន ប្រៀបដូចនគរ លោកុត្តរមគ្គមានអង្គ ๘ ប្រៀបដូចទ្វារនគរ*

សតិប្បដ្ឋាន មានកាយជាដើម ប្រៀបដូចទិសទាំងឡាយ មានទិសខាងកើត ជាដើម ។ បុគ្គលដែលមកពីទិសខាងកើត នាំវត្ថុដែលនៅទិសខាងកើតមក ចូលនគរ តាមទ្វារទិសខាងកើត យ៉ាងណា អ្នកបដិបត្តិ ដោយយកកាយា-នុបស្សនាជាប្រធាន ចម្រើនកាយានុបស្សនា ១៤ វិធី រមែងឈមចុះកាន់ព្រះនិព្វានតែម្យ៉ាង ដូចគ្នានុ៉ះឯង ដោយអរិយមគ្គ ដែលកើតពីអានុភាពនៃការចម្រើនកាយានុបស្សនា ក៏ដូច្នោះ ។ បុគ្គលដែលមកពីទិសខាងត្បូង នាំវត្ថុដែលនៅទិសខាងត្បូង រមែងចូលមកកាន់នគរតាមទ្វារទិសខាងត្បូង យ៉ាងណា អ្នកបដិបត្តិដោយយកវេទនាជាប្រធាន ចម្រើនវេទនានុបស្សនា ៩ វិធី រមែងឈមចុះកាន់ព្រះនិព្វានដូចគ្នានុ៉ះឯង ដោយអរិយមគ្គ ដែលកើតអំពីអានុភាពនៃការចម្រើនវេទនានុបស្សនា ក៏ដូច្នោះ ។ បុគ្គលដែលមកអំពីទិសខាងលិច នាំវត្ថុដែលនៅទិសខាងលិច រមែងចូលមកកាន់នគរ តាមទ្វារទិសខាងលិច យ៉ាងណា អ្នកបដិបត្តិ ដោយយកចិត្តានុបស្សនាជាប្រធាន ចម្រើនចិត្តានុបស្សនា ១៦ វិធី រមែងឈមចុះកាន់ព្រះនិព្វាន ដូចគ្នានុ៉ះឯង ដោយអរិយមគ្គ ដែលកើតអំពីអានុភាពនៃការចម្រើនចិត្តានុបស្សនា ដូច្នោះ ។ បុគ្គលដែលមកអំពីទិសខាងជើង នាំវត្ថុដែលនៅទិសខាងជើង រមែងចូលមកកាន់នគរតាមទ្វារទិសខាងជើង យ៉ាងណា អ្នកបដិបត្តិ ដោយយកធម្មានុ-បស្សនាជាប្រធាន ចម្រើនធម្មានុបស្សនា ៥ វិធី រមែងឈមចុះកាន់ព្រះនិព្វានតែម្យ៉ាងដូចគ្នានោះឯង ដោយអរិយមគ្គ ដែលកើតអំពីអានុភាពនៃការចម្រើនធម្មានុបស្សនា ក៏ដូច្នោះ ។ បណ្ឌិតគប្បីជ្រាបថា ដែលលោកពោល

ថា សតិប្បដ្ឋានមានតែមួយប៉ុណ្ណោះ ក៏ដោយអំណាចការពួកបាន ๑ ដោយអានុភាពការប្រជុំចុះកាន់ភាពតែមួយដូចគ្នា ๑ ដែលពោលថា មាន ๔ ដោយចាត់តាមអារម្មណ៍ ដូចពោលមក ដូច្នេះ ។

បទថា **កតមេ ចត្តារោ** *ជាពាក្យសួរដោយបំណងនឹងឆ្លើយឯង ។ បទថា* **ឥធ** *គឺក្នុងសាសនានេះ ។ បទថា* **ភិក្ខវេ** *នោះ ជាពាក្យហៅបុគ្គលអ្នកទទួលធម៌ ។ បទថា* **ភិក្ខុ** *នោះ ជាពាក្យសម្តែងដល់បុគ្គល ដែលដល់ព្រមដោយបដិបទា ។ ទេវតា និងមនុស្សពួកជទៃក៏ប្រព្រឹត្តបដិបត្តិឲ្យព្រមដូចគ្នា ។ តែដែលត្រាស់ថា ភិក្ខុ ក៏ព្រោះជាបុគ្គលប្រសើរ ๑ ព្រោះទ្រង់សម្តែងភាវៈនៃភិក្ខុដោយបដិបទា ๑ ។ ពិតហើយ ក្នុងបុគ្គលទាំងឡាយ អ្នកទទួលពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ ភិក្ខុជាអ្នកប្រសើរ ព្រោះដូចជាភាជនៈទទួលពាក្យប្រៀនប្រដៅ មានប្រការផ្សេងៗ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា ភិក្ខុ ព្រោះជាអ្នកប្រសើរ ។ តែកាលទ្រង់កាន់យកភិក្ខុហើយ បុគ្គលទាំង-ឡាយដ៏សេស ក៏ឈ្មោះថា ទ្រង់កាន់យកផងដែរ ដូចក្នុងរាជដំណើរជារដ្ឋមពួករាជបរិវារក្រៅពីនោះ ក៏ឈ្មោះថាលោកសង្គ្រោះទុកដោយសព្វថា* **រាជ ។** *បុគ្គលណាបដិបត្តិបដិបទានេះ បុគ្គលនោះ រមែងឈ្មោះថា ភិក្ខុ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ថា ភិក្ខុ ព្រោះទ្រង់សម្តែងភាវៈរបស់ភិក្ខុដោយបដិបទា ។ ពិតហើយ អ្នកបដិបត្តិ ទោះជាទេវតាក្តី មនុស្សក្តី រមែងរាប់បានថា ជាភិក្ខុទាំងអស់ ។ ដូចដែលត្រាស់ក្នុងធម្មបទ ខុទ្ទកនិកាយថា*

អលង្ករោ ចេបិ សមំ ចរេយ្យ

សន្តោ ឧន្តោ និយតោ ព្រហ្មចារី

សព្វេសុ ភូតេសុ និធាយ ឧណ្ឌំ

សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

បើបុគ្គលណា មានខ្ជួនប្រដាប់ស្អិតស្អាងហើយ ដោយគ្រឿងអម្ពរ តែ ជាអ្នកប្រព្រឹត្តស្មើ ជាអ្នកសូប់រម្ងាប់ទូន្មានឥន្ទ្រិយ ជាបុគ្គលទៀងចំពោះមគ្គផល ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថាព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ដូច្នោះ ។

បទថា **កាយេ** *គឺក្នុងរូបកាយ ។ ពិតហើយ រូបកាយក្នុងទីនេះ លោកប្រាថ្នាយកថា* **កាយ** *ព្រោះអត្ថថា ជាទីរួមនៃអវយវៈតូចធំ និងធម៌ទាំងឡាយ មានសក់ជាដើម ដូចខ្ជួនរបស់ដំរី តួរថជាដើម ។ ដែលឈ្មោះថា* **កាយ** *ព្រោះ អត្ថថា ជាទីរួម យ៉ាងណា ដែលឈ្មោះថា* **កាយ** *ព្រោះអត្ថថា ជាប្រភពនៃ ការមករបស់វត្ថុដែលគួរខ្ពើម ដូច្នោះ ។ ពិតហើយ កាយនោះ ជាទីមកនូវវត្ថុ គួរខ្ពើម គឺគួរខ្ពើមយ៉ាងក្រៃលែង ព្រោះហេតុនោះ ទើបឈ្មោះថា* **កាយ ។** *ពាក្យថា ជាទីមក គឺជាដែនកើត អត្ថរបស់ពាក្យ ក្នុងពាក្យថា ជាទីមកនោះ មានដូច្នេះ ធម្មជាតទាំងឡាយមកអំពីកាយនោះ ហេតុនោះ ទើបកាយនោះ ឈ្មោះថា ជាទីមក ។ សួរថា អ្វីមក ឆ្លើយថា វត្ថុដែលគួរខ្ពើមទាំងឡាយ មានសក់ជាដើមរមែងមក ។ ឈ្មោះថា* **អាយ** *ព្រោះជាទីនាំមកនូវរបស់គួរ ខ្ពើមទាំងឡាយ ដោយប្រការដូច្នេះ ។ បទថា* **កាយានុបស្សី** *សេចក្តីថា មាន*

ប្រក្រតីពិចារណាឃើញក្នុងកាយ ឬពិចារណាឃើញកាយ ។ ព្រះមានព្រះភាគ ទោះត្រាស់ថា **កាយេ** *ហើយ បណ្ឌិតគប្បីជ្រាបថា ទ្រង់ធ្វើសព្ទថា* **កាយ** *លើកទី ២ ថា* **កាយានុបស្សី** *ម្តងទៀត ដើម្បីទ្រង់សម្តែងការកំណត់ និង ការចែកចេញអំពីឃនៈជាដើម ដោយមិនលាយឡំគ្នា ។ មិនមែនកិក្ខុពិចារណា ឃើញវេទនាក្នុងកាយ ឬពិចារណាឃើញចិត្តក្នុងកាយ ឬពិចារណាឃើញធម៌ ក្នុងកាយទេ ដែលពិត ពិចារណាឃើញនូវកាយក្នុងកាយ ព្រោះដូច្នោះ ទើប ទ្រង់សម្តែងការកំណត់មិនលាយគ្នា ដោយទ្រង់សម្តែងអាការ គឺពិចារណា ឃើញកាយ ក្នុងវត្ថុដែលរាប់ថា កាយ ។ មិនមែនពិចារណាឃើញធម៌យ៉ាង ណាមួយ ដែលផុតពីអវយវៈតូចធំក្នុងកាយទេ ទាំងមិនមែនពិចារណាឃើញ ជាស្ត្រី ឬជាបុរស ដែលផុតអំពីសក់ រោមជាដើមឡើយ ។ ពិតហើយ ក្នុង ប្រការនោះ កាយសូម្បីយ៉ាងណា ដែលរាប់ថា ជាទីប្រជុំរួមរបស់ភូតរូប និង ឧបាទាយរូប មានសក់ រោមជាដើម មិនមែនពិចារណាឃើញធម៌យ៉ាងណា មួយ ដែលផុតពីភូតរូប និងឧបាទាយរូបទេ ដែលពិត ពិចារណាឃើញកាយ ជាទីប្រជុំរួមនៃអវយវៈតូចធំ ក្នុងកាយនោះ ដូចជាពិចារណាឃើញចំណែក ប្រកបរបស់រថ ដូច្នោះ ពិចារណាឃើញកាយ ជាទីប្រជុំរួមនៃសក់ រោមជា ដើម ដូចពិចារណាឃើញចំណែកតូចធំនៃព្រះនគរ ពិចារណាឃើញនូវកាយ ជាទីប្រជុំរួមនៃភូតរូប និងឧបាទាយរូប ដូចចែកស្វ៊ីក និងធាងរបស់ដើមចេក និងដូចលាតដៃក្តាប់ដែលទទេ ដូច្នោះ ព្រោះហេតុនោះ ទើបទ្រង់សម្តែងការ ចែកចេញអំពីឃនៈ ដោយទ្រង់សម្តែងវត្ថុដែលរាប់បានថា* **កាយ** *ដែលជា*

ទីប្រជុំរួម ដោយប្រការផ្សេងៗ នោះឯង ។ សេចក្តីពិត កាយ ឬបុរសស្ត្រី ឬធម៌ណាមួយដទៃ ដែលផុតអំពីកាយ ដែលជាទីប្រជុំរួម ដូចពោលហើយ មិនមានប្រាកដក្នុងកាយនោះទេ តែសត្វទាំងឡាយក៏ប្រកាន់ខុស ដោយប្រការនោះៗ ក្នុងកាយ ដែលត្រឹមតែជាទីប្រជុំនៃធម៌ ដូចពោលហើយនុ៎ះឯង ។ ព្រោះដូច្នោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

យំ បស្សតិ ន តំ ទិដ្ឋំ យំ ទិដ្ឋំ តំ ន បស្សតិ

អបស្សំ ពជ្ឈតេ មូឡ្ហោ ពជ្ឈមានោ ន មុច្ចតិ ។

បុគ្គលឃើញវត្ថុណា វត្ថុនោះក៏មិនបានឃើញ វត្ថុណាឃើញហើយ ក៏មិនឃើញវត្ថុនោះ កាលមិនឃើញក៏វង្វេងជាប់ កាលជាប់ក៏មិនរួចផុត ដូច្នេះ ។

លោកពោលពាក្យនេះ ក៏ដើម្បីសម្តែងការចែកចេញពីឃនៈជាដើម ។ ដោយសព្ទថា **អាទិ** *ជាដើម ពាក្យនេះ បណ្ឌិតគប្បីជ្រាបសេចក្តី ដូច្នេះ ។ ភិក្ខុពិចារណាឃើញកាយក្នុងកាយនេះប៉ុណ្ណោះ លោកអធិប្បាយថា មិនមែនពិចារណាឃើញធម៌ឯងដទៃ ។ មនុស្សទាំងឡាយ ក្រឡេកឃើញទឹកក្នុងថ្លែបណ្តើរកូនដែលមិនមានទឹកយ៉ាងណា ភិក្ខុពិចារណាឃើញកាយនេះថាជារបស់មិនទៀង ជាទុក្ខ មិនមែនតួខ្លួន មិនស្អាត មិនមែនឃើញថាជារបស់ទៀង ជាសុខ ជាតួខ្លួន និងស្អាត ដូច្នោះ ដែលពិត ពិចារណាឃើញកាយ លោកអធិប្បាយថា ពិចារណាឃើញកាយ ជាទីប្រជុំរបស់អាការ គឺមិនទៀង ជាទុក្ខ មិនមែនតួខ្លួន និងមិនស្អាត ។*

ម្យ៉ាងទៀត កាយនេះ ដែលលោកពោលខាងមុខថា មានខ្យល់

อสฺสาสปสฺสาสะ:ជាខាងដើម មានឆ្អឹងដែលពុកផុយខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំជាទីបំផុត តាមន័យព្រះបាលីជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ฯបេฯ មានសតិ ដកដង្ហើមចូល ដូច្នេះ និងកាយឯណា ដែលលោកពោលក្នុងបដិសម្ភិទាមគ្គថា បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវពួកដី ថាមិនទៀង ฯបេฯ ពិចារណាឃើញនូវពួកទឹក ពួកភ្លើង ពួកខ្យល់ ពួកសក់ ពួករោម ពួកសម្បុរថ្លៃ ពួកស្បែក ពួកសាច់ ពួកសរសៃ ពួកឆ្អឹង ពួកខួរក្នុងឆ្អឹង ថាមិនទៀង ... ដូច្នេះ ฯ បណ្ឌិតគប្បីជ្រាបអត្តនៃកាយទាំងអស់ យ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ ដោយពិចារណាឃើញក្នុងកាយយ៉ាងនេះប៉ុណ្ណោះ ฯ

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីយ៉ាងនេះថា ពិចារណាឃើញកាយ ដែលរាប់ថា ជាទីប្រជុំនៃធម៌ មានសក់ជាដើមក្នុងកាយ ដោយមិនពិចារណាឃើញចំណែកណាមួយដែលគប្បីប្រកាន់ថា ជាអញ ជារបស់អញ ក្នុងកាយ តែពិចារណាឃើញកាយទាំងនោះប៉ុណ្ណោះ ជាទីប្រជុំនៃធម៌ផ្សេងៗ មានសក់ រោមជាដើម ฯ

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីយ៉ាងនេះថា ពិចារណាឃើញកាយក្នុងកាយ ដោយពិចារណាឃើញកាយដែលរាប់ថា ជាទីប្រជុំនៃអាការ មានលក្ខណៈមិនទៀងជាដើមទាំងអស់នោះឯង ដែលមានន័យមកក្នុងបដិសម្ភិទាមគ្គ តាមលំដាប់បាលីជាដើមថា ពិចារណាឃើញក្នុងកាយនេះថា មិនទៀង មិនមែនថាទៀងទេ ដូច្នេះ ฯ ពិតហើយ ភិក្ខុដែលបដិបត្តិបដិបទា គឺពិចារណា

ឃើញកាយក្នុងរូបកាយនេះ រមែងពិចារណាឃើញកាយយ៉ាងនេះ ដោយភាពជារបស់មិនទៀង មិនមែនឃើញដោយភាពជារបស់ទៀង ពិចារណាឃើញដោយភាពជាទុក្ខ មិនមែនឃើញដោយភាពជាសុខ ពិចារណាឃើញថាមិនមែនតួខ្លួន មិនមែនឃើញថាជាតួខ្លួន ដោយអំណាចអនុបស្សនា ๗ ប្រការ មានការពិចារណាឃើញការមិនទៀងជាដើម រមែងនឿយណាយ មិនមែនត្រេកអរ រមែងប្រាសចាកតម្រេក មិនមែនមានតម្រេក រមែងរម្ងាប់ទុក្ខ មិនមែនញុំាងទុក្ខឲ្យកើត រមែងលះបង់ មិនមែនប្រកាន់មាំ ។ ភិក្ខុនោះ កាលពិចារណាឃើញកាយយ៉ាងនេះ ដោយភាពជារបស់មិនទៀង រមែងលះបង់និច្ចសញ្ញា គឺសេចក្តីសម្គាល់ថា ទៀងចេញបាន កាលពិចារណាឃើញដោយភាពជាទុក្ខ រមែងលះនូវសុខសញ្ញា គឺការសម្គាល់ថាជាសុខចេញបាន កាលពិចារណាឃើញដោយសភាពមិនមែនតួខ្លួន រមែងកម្ចាត់អត្តសញ្ញា គឺការសម្គាល់ថា ជាតួខ្លួនចេញបាន កាលនឿយណាយ រមែងលះសេចក្តីត្រេកអរចេញបាន កាលប្រាសចាកតម្រេក រមែងលះរាគៈចេញបាន កាលរម្ងាប់ទុក្ខ រមែងលះទុក្ខសមុទយចេញបាន កាលលះ រមែងលះនូវសេចក្តីប្រកាន់ចេញបាន ដូច្នេះ គប្បីជ្រាបដូចពោលមកនេះ ។

បទថា **วิหรติ** *គឺប្រព្រឹត្តទៅ ។ បទថា* **อาตาปี** *មានអត្ថថា សភាវៈណារមែងដុតកិលេសទាំងឡាយក្នុងភពទាំង ๓ ហេតុនោះ សភាវៈនោះ ឈ្មោះថា* **อาตาป** *គឺដុតកម្ចាកិលេស ពាក្យនេះ ជាឈ្មោះនៃសេចក្តីព្យាយាម ។ សេចក្តីព្យាយាមរបស់បុគ្គលនោះមាន ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា*

អាតាបី គឺអ្នកមានសេចក្តីព្យាយាម ។ បទថា **សម្បជានោ** គឺបុគ្គលប្រកបដោយសេចក្តីដឹង ដែលរាប់ថាជាសម្បជញ្ញៈ ។ បទថា **សតិមា** គឺប្រកបដោយសតិពិចារណាកាយ ។ ភិក្ខុរូបនេះ កំណត់អារម្មណ៍ដោយសតិ ពិចារ-ណាឃើញដោយបញ្ញា ធម្មតាបញ្ញាពិចារណាឃើញរបស់បុគ្គលដែលច្រាសចាកសតិមិនមាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្ត-និកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ព្រោះដូច្នោះ ទើបក្នុងទីនេះទ្រង់ត្រាស់ថា ពិចា-រណាឃើញនូវកាយក្នុងកាយជាប្រក្រតី ដូច្នេះ ។ កាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា ទ្រង់បានអធិប្បាយដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត សេចក្តីរួញរាខាងក្នុង រមែងធ្វើអន្តរាយដល់បុគ្គលដែលមិនមានសេចក្តីព្យាយាម បុគ្គលមិនមានសម្បជញ្ញៈ រមែងវង្វេងក្នុងការកំណត់ឧបាយ ក្នុងការវៀរចាកវត្ថុដែលមិនមែនឧបាយ បុគ្គលមិនមានស្មារតីហើយ រមែងមិនអាចក្នុងការកំណត់ឧបាយ និងក្នុងការលះបង់វត្ថុដែលមិនមែនឧបាយ ដោយហេតុនោះ កម្មដ្ឋាននោះរបស់ភិក្ខុនោះ រមែងមិនសម្រេច ព្រោះដូច្នោះ កម្មដ្ឋាននោះ តែងសម្រេចដោយអានុភាពនៃធម៌ពួកណា ដើម្បីទ្រង់សម្តែងធម៌ពួកនោះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា មានព្យាយាម មានសម្បជញ្ញៈ មានសតិ ។ ទ្រង់សម្តែងកាយានុបស្សនាសតិប្បដ្ឋាន និងអង្គនៃសម្បយោគ ឥឡូវនេះ ដើម្បីទ្រង់សម្តែងអង្គនៃការលះ ទើបត្រាស់ថា បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

បណ្តាបទទាំងនោះ បទថា **วิเนยฺย** *សេចក្តីថា បណ្តេញបង់ដោយតទង្គៈ ឬបណ្តេញបង់ដោយវិក្ខម្ភនៈ ។ បទថា* **โลเกៈ** *គឺក្នុងកាយនោះឯង ។ ពិតហើយ កាយក្នុងទីនេះ ទ្រង់សំដៅដល់លោក ព្រោះអត្ថថា វិនាស ។ អភិជ្ឈា និងទោមនស្ស មិនមែនព្រះយោគាវចរនោះ លះបង់បានក្នុងអារម្មណ៍ត្រឹមតែកាយប៉ុណ្ណោះទេ សូម្បីក្នុងវេទនាជាដើម ក៏លះបានដែរ ព្រោះដូច្នោះ ទើបលោកពោលនៅក្នុងសតិបដ្ឋានវិភង្គថា ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា* **លោក** ។ *ពាក្យនោះ លោកពោលតាមអត្ថនៃការពង្រីកសេចក្តី ព្រោះធម៌ទាំងនោះរាប់បានថា ជាលោក ។ តែលោកពោលពាក្យណាថា* **លោក** *តើដូចម្តេច* **លោក** *គឺកាយនោះឯង សេចក្តីក្នុងពាក្យនោះ មានដូច្នេះ ។ គប្បីឃើញការភ្ជាប់សេចក្តីដូច្នេះថា បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកនោះ ។ ព្រោះក្នុងទីនេះ កាមច្ឆន្ទៈ សង្គ្រោះចូលនឹងសព្ទថា* **អភិជ្ឈា** *ព្យាបាទ សង្គ្រោះចូលនឹងសព្ទថា* **โทมนสฺส** *ដូច្នោះ ទើបគួរជ្រាបថា ទ្រង់អធិប្បាយការលះនីវរណៈ ដោយទ្រង់សម្តែងធម៌ដែលជាគូ ដែលមានកម្លាំងជាប់ទាក់ទងក្នុងនីវរណៈ ។ តែដោយពិសេស ក្នុងទីនេះ ត្រាស់ការលះសេចក្តីត្រេកអរ ដែលមានកាយសម្បត្តិជាមូល ដោយការកម្ចាត់អភិជ្ឈា ត្រាស់ការលះសេចក្តីប្រទូស្ត ដែលមានកាយវិបត្តិជាមូល ដោយការកម្ចាត់ទោមនស្ស ត្រាស់ការលះសេចក្តីត្រេកអរក្រៃលែងក្នុងកាយ ដោយការកម្ចាត់អភិជ្ឈា ត្រាស់ការលះសេចក្តីមិនត្រេកអរក្រៃលែង ក្នុងការចម្រើនកាយានុបស្សនា ដោយការកម្ចាត់ទោមនស្ស ត្រាស់ការលះកាយរបស់អ្នក*

ជាក់នូវភាវៈថា ស្អាត ជាសុខ ជាដើម ដែលមិនមានពិតក្នុងកាយ ដោយការកម្ចាត់អកិរិយា និងត្រាស់ការលះដល់ការយកចេញទៅនូវភាវៈដែលមិនស្អាតជាទុក្ខជាដើម ដែលមានពិតក្នុងកាយ ដោយការកម្ចាត់ទោមនស្ស ។ ដោយព្រះតម្រាស់នោះ ឈ្មោះថា ទ្រង់សម្តែងអានុភាពនៃសេចក្តីព្យាយាម និងភាពជាអ្នកអាចក្នុងការប្រកបសេចក្តីព្យាយាមរបស់ព្រះយោគាវចរ ។ ពិតហើយ អានុភាពរបស់សេចក្តីព្យាយាមនោះ គឺជាបុគ្គលរួចផុតចាកសេចក្តីត្រេកអរមិនត្រេកអរ គ្របសង្កត់សេចក្តីមិនត្រេកអរ និងសេចក្តីត្រេកអរ និងវៀរចាកក្នុងវត្ថុដែលមិនមានពិត និងនាំចេញនូវវត្ថុដែលមានពិត ។ ព្រះយោគាវចរនោះ ជាអ្នករួចផុតចាកសេចក្តីត្រេកអរ មិនត្រេកអរ ជាអ្នកគ្របសង្កត់សេចក្តីមិនត្រេកអរ និងសេចក្តីត្រេកអរ មិនជាក់វត្ថុដែលមិនមានពិត មិននាំចេញនូវវត្ថុដែលមានពិត ទើបឈ្មោះថា ជាអ្នកអាចក្នុងការប្រកបសេចក្តីព្យាយាមដោយប្រការដូច្នេះ ។

ន័យម្យ៉ាងទៀត ទ្រង់ត្រាស់កម្មដ្ឋានដោយអនុបស្សនា ក្នុងពាក្យដែលថា **កាយេ កាយានុបស្សី** ។ *ត្រាស់ការបរិហារកាយ របស់ព្រះយោគាវចរបំពេញកម្មដ្ឋាន ដោយវិហារធម៌ដែលពោលហើយ ក្នុងពាក្យនេះថា* **វិហរតិ** ។ *ក្នុងបទថា* **អាតាបី** *ជាដើម គប្បីជ្រាបថា ទ្រង់ត្រាស់សេចក្តីព្យាយាមប្រពៃដោយ* **អាតាប** *ត្រាស់កម្មដ្ឋានដែលឲ្យសម្រេចប្រយោជន៍ទូទៅ ឬឧបាយជាគ្រឿងបរិហារកម្មដ្ឋាន ដោយសតិសម្បជញ្ញៈ ឬត្រាស់សមថៈ ដែលបានមកដោយអំណាចកាយានុបស្សនា ត្រាស់វិបស្សនាដោយសម្បជញ្ញៈ ត្រាស់*

ផលនៃការនាដោយការកម្ចាត់នូវអកិរិយា និងទោមនស្ស ដូច្នេះ ។

ចំណែកក្នុងបាលីវិភង្គ ពោលសេចក្តីរបស់បទទាំងនោះយ៉ាងនេះ បទថា **អនុបស្សី** *សេចក្តីថា អនុបស្សនាក្នុងពាក្យនោះ តើដូចម្តេច ការដឹងជុំវិញ ការដឹងទូទៅ ។បេ។ សម្មាទិដ្ឋិ នេះហៅថា* **អនុបស្សនា** *បុគ្គលបានប្រកបហើយ ប្រកបព្រមហើយ ចូលទៅហើយ ចូលទៅព្រមហើយ ចូលដល់ហើយ ចូលដល់ព្រមហើយ មកព្រមហើយ ដោយអនុបស្សនានេះ ហេតុនោះទើបបុគ្គលនោះឆ្លើយប្រាប់ថា* **អនុបស្សី** ។ *បទថា* **វិហរតិ** *ប្រែថា នៅ ប្រព្រឹត្តទៅ រក្សាជំណើរទៅ ឲ្យអត្តភាពជំណើរទៅ ត្រាច់ទៅ ហេតុនោះទើបហៅថា* **វិហរតិ** ។ *បទថា* **អាតាបី** *អ្នកមានសេចក្តីព្យាយាម សេចក្តីថា* **អាតាប** *សេចក្តីព្យាយាមក្នុងពាក្យនោះ តើដូចម្តេច ការប្រារព្ធសេចក្តីព្យាយាមប្រព្រឹត្តទៅតាមផ្លូវចិត្ត ។បេ។ សម្មាវាយាម:ណានេះហៅថា* **អាតាប** *បុគ្គលដែលប្រកបដោយ* **អាតាប** *នេះ ហេតុនោះ ទើបបុគ្គលនោះ ហៅថា* **អាតាបី** ។ *បទថា* **សម្បជានោ** *សេចក្តីថា សម្បជញ្ញៈ ក្នុងពាក្យនោះ តើដូចម្តេច ការដឹងជុំវិញ ការដឹងទូទៅ ។បេ។ សម្មាទិដ្ឋិ នេះហៅថា* **សម្បជញ្ញ** *បុគ្គលណាប្រកបហើយ ។បេ។ មកតាមព្រមហើយ ដោយសម្បជញ្ញៈនេះ ហេតុនោះ ទើបបុគ្គលនោះ ហៅថា* **សម្បជានោ** ។ *បទថា* **សតិមា** *សេចក្តីថា សតិ ក្នុងពាក្យនោះ តើដូចម្តេច ការរឭកបាន ការរឭកដល់ ។បេ។ ការរឭកប្រពៃ នេះហៅថា* **សតិ** *បុគ្គលណាប្រកបហើយ ។បេ។ មកតាមព្រម*

ហើយដោយសតិនេះ ហេតុនោះ ទើបបុគ្គលនោះ ហៅថា **សតិមា** *។ បទ ថា* **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** *សេចក្តីថា លោក ក្នុងពាក្យនោះ តើដូចម្តេច កាយនោះឯង ឈ្មោះថា* **លោក** *ឧបាទានក្ខន្ធទាំង ៥ ក៏ឈ្មោះថា លោក នេះហៅថា* **លោក** *។ អភិជ្ឈា ក្នុងពាក្យនោះ តើដូចម្តេច តម្រេក តម្រេកខ្លាំង សេចក្តីសប្បាយចិត្ត សេចក្តីត្រេកអរ នន្ទិ នន្ទិរាគៈ តម្រេកខ្លាំង នៃចិត្ត នេះហៅថា* **អភិជ្ឈា** *។ ទោមនស្ស ក្នុងពាក្យនោះ តើដូចម្តេច សេចក្តីមិនសប្បាយផ្លូវចិត្ត ទុក្ខផ្លូវចិត្ត ។បេ។ ទុក្ខវេទនា ដែលកើតអំពីចិត្ត-សម្ផស្ស នេះហៅថា* **ទោមនស្ស** *។ អភិជ្ឈា និងទោមនស្សនេះ ឈ្មោះថា ព្រះយោគាវចរកម្ចាត់ចេញហើយ នាំចេញទៅហើយ ស្ងប់ហើយ ឲ្យស្ងប់ហើយ ឲ្យរម្ងាប់ហើយ ឲ្យដល់ការតាំងនៅមិនបានហើយ ឲ្យដល់សេចក្តីសាបសូន្យហើយ ឲ្យដល់ការមិនមានហើយ ឲ្យដល់ការសង្ខេបខ្វីហើយ ឲ្យស្ងួតហួតហែងហើយ ឲ្យស្ងួតព្រមហើយ ធ្វើឲ្យដល់ទីបំផុតហើយ ហេតុនោះ ទើបត្រាស់ថា* **វិនេយ្យ លោកេ អភិជ្ឈា ទោមនស្សំ** *ដូច្នេះ ។ នយដែលមកក្នុងអដ្ឋកថានេះ និងបាលីវិភង្គនោះ បណ្ឌិតគប្បីជ្រាបបានដោយការប្រៀបធៀបគ្នា ។*

ពណ៌នាសេចក្តីនៃឧទ្ទេស ដែលពោលដោយកាយានុបស្សនាសតិប្បដ្ឋាន មានត្រឹមតែប៉ុណ្ណេះ ។

ឧទ្ទេសវារកថា នៃកាយានុបស្សនា មានប្រមាណប៉ុណ្ណេះ

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងពាក្យថា កិកុពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ចិត្តក្នុងចិត្ត ធម៌ក្នុងធម៌ទាំងឡាយ ។បេ។ បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ដូច្នេះ ប្រយោជន៍ក្នុងការពោលត្រួតវេទនាជាដើម ក្នុងពាក្យថា **វេទនាសុ វេទនានុបស្សី** *ជាដើម គប្បីជ្រាបដោយនយដែលពោលមកហើយក្នុងកាយានុបស្សនានុ៎ះឯង ។ ម្យ៉ាងទៀត ក្នុងពាក្យថា ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ពិចារណាឃើញចិត្តក្នុងចិត្ត ពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយនេះ មានវិនិច្ឆ័យដូច្នេះថា វេទនា បានដល់ វេទនា ៣ ឯវេទនា ៣ នោះ ជាលោកិយតែម្យ៉ាង សូម្បីចិត្តក៏ជាលោកិយ ធម៌ទាំងឡាយ ក៏ជាលោកិយដូចគ្នា ។ ការចែកវេទនា ចិត្ត ធម៌នោះ នឹងប្រាកដក្នុងនិទ្ទេសវារៈ ។ ចំណែកក្នុងខន្ទេសវារៈនេះ កិកុដែលពិចារណាវេទនា ៣ នោះ ដោយប្រការដែលខ្លួនគប្បីពិចារណាឃើញ ក៏គប្បីជ្រាបថាជាអ្នកពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត និងធម៌ ក៏នយនេះដូចគ្នា ។*

សួរថា គប្បីពិចារណាឃើញវេទនាដូចម្តេច ឆ្លើយថា គប្បីពិចារណាឃើញសុខវេទនា ដោយភាពជាទុក្ខ ឃើញទុក្ខវេទនា ដូចជាកូនសរ ឃើញអទុក្ខមសុខវេទនា ដោយភាពជារបស់មិនទៀង ។ ដូចព្រះតម្រាស់ថា

យោ សុខំ ទុក្ខតោ អទ្ទ ទុក្ខមទុក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ អនិច្ចតោ ។
សចេ សម្មទ្ទសោ ភិក្ខុ បរិជានាតិ វេទនា

សោ វេទនា បរិញ្ញាយ ឥដ្ឋេ ធម្មេ អនាសវោ

កាយស្ស ភេទា ធម្មដ្ឋោ សំខ្យំ ន្ទូបេតិ វេទគូ ។

អ្នកឯណា បានឃើញសុខវេទនា ថាជាទុក្ខវេទនាវិញ បានឃើញទុក្ខ-វេទនា ថាជាកូនសរ បានឃើញអទុក្ខមសុខវេទនានោះ ថាជាសភាវៈមិនទៀងទៅវិញ បើភិក្ខុបានឃើញដោយប្រពៃ កំណត់ដឹងនូវវេទនាទាំង៣យ៉ាយ ភិក្ខុនោះ លុះកំណត់ដឹងនូវវេទនាទាំង៣យ៉ាយ ក្នុងបច្ចុប្បន្ននេះហើយ ជាអ្នកមិនមានអាសវៈ ស្ថិតនៅក្នុងធម៌ ជាអ្នកដល់នូវវេធ លុះទម្លាយរាងកាយទៅ មិនគួរពោលថា (ជាអ្នកមានភពទៀតទៅឡើយ) ។

ម៉្យាងទៀត ព្រះយោគាវចរគប្បីពិចារណាឃើញវេទនាទាំងអស់ទុំៈឯង ដោយភាពជាទុក្ខផង ។ សមដូចព្រះតម្រាស់ថា តថាគតពោលថា អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះជាទុក្ខ ។ គប្បីពិចារណាឃើញវេទនា ដោយភាពជាសុខ ជាទុក្ខ ផ្ទាស់ប្តូរគ្នា ដូចព្រះតម្រាស់ថា សុខវេទនា មានកិរិយាស្ថិតនៅជដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ដូច្នេះ ពាក្យទាំងអស់អ្នកសិក្សា គប្បីយល់ឲ្យទូលំទូលាយ ។

ម៉្យាងទៀត ព្រះយោគាវចរ គប្បីពិចារណាឃើញ ដោយអំណាចអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ។ ពាក្យគួរពោលដ៏សេសនេះ នឹងប្រាកដក្នុងនិទ្ទេសវារៈនោះឯង ។

បណ្តាចិត្ត និងធម៌ ចិត្តដែលព្រះយោគាវចរគប្បីពិចារណាឃើញ ដោយអំណាចប្រភេទនៃចិត្តដែលផ្សេងៗ គ្នា មានអារម្មណចិត្ត អធិបតិចិត្ត

สหชาตจิตฺต ภูมิจิตฺต กมฺมจิตฺต วิปากจิตฺต និងកិរិយាចិត្តជាដើម និងដោយ អំណាចប្រភេទនៃចិត្ត មានចិត្តប្រកបដោយរាគៈជាដើម ដែលមកក្នុងនិទ្ទេសវារៈ នៃអនុបស្សនា មានអនិច្চានុបស្សនាជាដើម ។ ធម៌ដែលព្រះយោគាវចរ គប្បី ពិចារណាឃើញដោយអំណាចនៃលក្ខណៈចំពោះខ្លួន និងលក្ខណៈទូទៅ និង នៃធម៌ដែលជាសកាពទេ និងដោយអំណាចប្រភេទនៃធម៌ មានធម៌ដែលស្ងប់ ជាដើម ដែលមកក្នុងនិទ្ទេសវារៈនៃអនុបស្សនា ๗ មានអនិច្চានុបស្សនាជា ដើម ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

អភិជ្ឈា និងទោមនស្ស ក្នុងលោក គឺកាយ ដែលព្រះយោគាវចរណា លះបានហើយ ក្នុងកាយានុបស្សនាសតិបដ្ឋាននេះ សូម្បីអភិជ្ឈា និងទោម- នស្សក្នុងលោក គឺវេទនាជាដើម ក៏ឈ្មោះថា ព្រះយោគាវចរនោះ លះបាន ហើយដូចគ្នាក៏ពិត សូម្បីដូច្នោះ ព្រះមានព្រះភាគ ក៏នៅត្រាស់ការលះអភិជ្ឈា និងទោមនស្ស ក្នុងសតិបដ្ឋានគ្រប់ប្រការ ដោយអំណាចនៃបុគ្គលផ្សេងៗ គ្នា និងដោយអំណាចនៃសតិបដ្ឋានភាវនា ដែលប្រព្រឹត្តទៅក្នុងខណៈចិត្តផ្សេង គ្នា ។ ន័យម្យ៉ាងទៀត ព្រោះអភិជ្ឈា និងទោមនស្ស ដែលលះបានក្នុងសតិ- បដ្ឋានទីមួយ សូម្បីក្នុងសតិបដ្ឋានដ៏សេសទាំង ๓ ប្រការ ក៏ឈ្មោះថា លះ បានដូចគ្នា ។ ព្រោះដូច្នោះ ទើបគួរជ្រាបថា ការលះបង់អភិជ្ឈា និងទោម- នស្សនេះ ទ្រង់ត្រាស់ដើម្បីសម្តែងការលះក្នុងសតិបដ្ឋានទាំងនោះ របស់កិកូ នោះ ដូច្នេះ ។

ឧទ្ទេសវារកថា ចប់

និទ្ទេសវារកថា

កាយានុបស្សនាសតិប្បដ្ឋាន

អានាចានបព្វ:

[១១២] ជាងត្បាញផែងដែលឈ្លាស ប្រាថ្នានឹងធ្វើគ្រឿងប្រើប្រាស់ ដូចជាកន្ទេលរឹង កន្ទេលទន់ តៀប កម្បោម៍ និងសាជីជាដើម បានប្ញស្សីមួយ ដើមធំ កាត់ជា ៤ កំណាត់ហើយ គប្បីយកកំណាត់មួយៗ ពុះជា ៤ នោះ មកពុះចេញធ្វើជាគ្រឿងប្រើនោះៗ យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដូចគ្នា ឥឡូវនេះ ទ្រង់ប្រាថ្នានឹងធ្វើសត្វទាំងឡាយឲ្យសម្រេចគុណវិសេសផ្សេងៗ ដោយទ្រង់សម្តែងសតិប្បដ្ឋាន ចែកសម្មាសតិតែម្យ៉ាងប៉ុណ្ណោះ ចេញជា ៤ ចំណែក ដោយអំណាចនៃអារម្មណ៍ ដោយន័យជាដើមថា សតិប្បដ្ឋាន ៤ តើ ដូចម្តេច ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយក្នុងកាយ ដូច្នេះ ទ្រង់ កាន់យកសតិប្បដ្ឋានតែ ១ យ៉ាង អំពី ៤ យ៉ាងនោះ កាលទ្រង់ចែកកាយ ទើបទ្រង់ផ្តើមត្រាស់និទ្ទេសវារ: ដោយន័យថា **កថញ្ច ភិក្ខវេ** ជាដើម ។

ក្នុងនិទ្ទេសវារ:នោះ បទថា **កថញ្ច** ជាដើម ជាពាក្យសួរដោយពន្រីក ឲ្យធំទូលាយ ។ ឯសេចក្តីសង្ខេបក្នុងបុច្ឆវារ:នេះមានដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុពិចារណាឃើញកាយក្នុងកាយ ដោយប្រការដូចម្តេច ។ ក្នុង បុច្ឆវារ:គ្រប់ប្រការក៏ន័យនេះ ។ បទថា **ឥធ ភិក្ខវេ** គឺភិក្ខុក្នុងសាសនានេះ ។ **ឥធ** សព្ទ ក្នុងពាក្យនេះ ជាគ្រឿងសម្តែងសាសនា ដែលជាទីអាស្រ័យយ៉ាង ល្អ របស់បុគ្គលអ្នកបំពេញកាយានុបស្សនាសតិប្បដ្ឋានគ្រប់ប្រការ ឲ្យកើត

ទ្បើងហើយ និងជាគ្រឿងបដិសេធ សេចក្តីមិនមានពិតរបស់សាសនាដទៃ ។ សមដូចព្រះតម្រាស់ក្នុងចូឡសីហនាទសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសក: ថា ម្នាលភិក្ខុទាំងឡាយ សមណ:ទី ១ គឺសោតាបន្នមានតែក្នុងសាសនានេះ សមណ:ទី ២ គឺសកទាគាមី ក៏មានតែក្នុងសាសនានេះ សមណ:ទី ៣ គឺអនាគាមីក៏មានតែក្នុងសាសនានេះ សមណ:ទី ៤ គឺអរហន្ត ក៏មានតែក្នុងសាសនានេះ វាទ:របស់សាសនាដទៃ សូន្យចាកសមណ:ទាំងឡាយ ព្រោះដូច្នោះ ទើបត្រាស់ថា **ឥធ ភិក្ខវេ** *ដូច្នេះ ។*

បទថា **អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា** *នេះជាគ្រឿងសម្តែងការកំណត់យកសេនាសន:ដែលសមគួរ ដល់ការចម្រើនសតិបដ្ឋានរបស់ភិក្ខុនោះ ។ ព្រោះចិត្តរបស់ភិក្ខុត្រាច់ទៅក្នុងអារម្មណ៍ទាំង-ឡាយ មានរូបជាដើមអស់កាលជ័យូរ រមែងមិនប្រាថ្នានឹងចុះកាន់វីថីនៃកម្មដ្ឋានធ្លាប់តែត្រាច់ចេញក្រៅផ្លូវ ដូចរនេះដែលទឹមដោយគោកៀច ដូច្នោះ ។ ព្រោះដូច្នោះ ភិក្ខុនឹងចម្រើនសតិបដ្ឋាននេះ ប្រាថ្នានឹងទូន្មានចិត្តដែលកាច ដែលចម្រើនមកដោយការផឹកវស មានរូបារម្មណ៍ជាដើមអស់កាលយូរ គប្បីប្រាសចេញពីអារម្មណ៍ ដូចរូបារម្មណ៍ជាដើម ហើយចូលទៅព្រៃក៏បាន គល់ឈើក៏បាន ផ្ទះស្ងាត់ក៏បាន ហើយយកខ្សែ គឺសតិចងត្រង់បង្គោល គឺអារម្មណ៍របស់សតិបដ្ឋាននោះ ចិត្តរបស់ភិក្ខុនោះទោះបម្រុះនៀលទៅផ្លូវនេះ ផ្លូវនោះ កាលមិនបានអារម្មណ៍ដែលធ្លាប់ស្និទ្ធស្នាលមកអំពីមុន មិនអាចកាត់ខ្សែ គឺសតិឲ្យដាច់ ហើយគេចចៀសចេញបាន ក៏នឹងអែបជិតស្និទ្ធ ចំពោះអារម្មណ៍នោះ*

តែម្យ៉ាង ដោយអំណាចនៃឧបចារកាវនា និងអប្បនាកាវនា ដូចជាអ្នកចិញ្ចឹមគោ ដើម្បីនឹងទូន្មានកូនគោកៀច ដែលជ្រៅជោះមេគោកៀច ជារបធំធាត់ គប្បីពង្រាត់វាចេញអំពីមេគោ ហើយបោះបង្គោលធំមួយ យកខ្សែចងត្រង់បង្គោលនោះ គ្រានោះ កូនគោរបស់បុរសនោះ ក៏នឹងដើរទៅផ្លូវនេះ ផ្លូវនោះ កាលមិនអាចគេចចេញទៅបាន ក៏ក្រាប ឬដេក ជិតបង្គោលនោះឯង ដូច្នោះ ។ ហេតុនោះ ទើបព្រះបុរាណាចារ្យពោលថា

យថា ថម្ភេ និពន្ធេយ្យ វច្ឆំ ឧមំ ឆរោ ឥធ

ពន្ធេយ្យុំ សកំ ចិត្តំ សតិយារម្មណេ ឧត្តមំ ។

នរជនក្នុងសាសនានេះ គប្បីចងចិត្តរបស់ខ្លួនក្នុងអារម្មណ៍ឲ្យមាំដោយសតិ ដូចអ្នកចិញ្ចឹមគោ កាលនឹងទូន្មានកូនគោ គប្បីចងកូនគោ ត្រង់បង្គោលដូច្នោះ ។

សេនាសនៈនេះ រមែងសមគួរដល់ការចម្រើនសតិប្បដ្ឋានរបស់ភិក្ខុអ្នកចម្រើនសតិប្បដ្ឋាននោះ ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ទើបខ្ញុំពោលថា ពាក្យនេះ ជាគ្រឿងសម្តែងការកំណត់សេនាសនៈដែលសមគួរដល់ការចម្រើនសតិប្បដ្ឋានរបស់ភិក្ខុនោះ ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះព្រះយោគាវចរមិនលះចន្លោះស្រុក ដែលអ៊ូអរដោយសំឡេងស្រី ប្រុស ដំរី សេះជាដើម បំពេញអានាបានសតិកម្មដ្ឋាន ដែលជាកំពូលក្នុងកាយានុបស្សនា ជាបទដ្ឋាននៃការសម្រេចគុណវិសេស និងជាសុខវិហារធម៌ក្នុងបច្ចុប្បន្ន របស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកទាំងពួងនេះ

ឲ្យសម្រេច មិនមែនធ្វើបានងាយៗ ទ្បើយ ព្រោះឈាន មានសំឡេងជាសត្រូវ តែព្រះយោគាវចរកំណត់កម្មដ្ឋាននេះហើយ ឲ្យចតុត្ថជ្ឈាន មានអានាបាន: ជាអារម្មណ៍ កើតទ្បើង ធ្វើឈាននោះឯងឲ្យជាបាទ ពិចារណាសង្ខារទាំងទ្បាយ ហើយសម្រេចអរហត្តដែលជាអគ្គផលធ្វើបានងាយតែនៅក្នុងព្រៃដែលមិនមានស្រុក ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសន: ដ៏សមគួរដល់យោគាវចរភិក្ខុនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** *ជាដើម ។*

ព្រះមានព្រះភាគ ប្រៀបដូចអាចារ្យអ្នកដឹងជ័យភូមិ ។ អាចារ្យអ្នកដឹងជ័យភូមិ ឃើញជីដែលគួរសាងនគរហើយ ពិចារណាសព្វគ្រប់ហើយ ក៏ប្រាប់ថា អ្នកទាំងទ្បាយចូរសាងនគរត្រង់នេះ កាលជនទាំងទ្បាយសាងនគរសម្រេចដោយសួស្តីហើយ រមែងបានទទួលលាភសក្ការ:យ៉ាងធំពីរាជត្រកូលយ៉ាងណា ព្រះមានព្រះភាគនោះ ក៏ដូច្នោះ ទ្រង់ពិចារណាដល់សេនាសន: ដែលសមគួរដល់ព្រះយោគាវចរហើយ ទ្រង់ចង្អុលថា សេនាសន:ត្រង់នេះ ព្រះយោគាវចរគួរប្រកបកម្មដ្ឋានរឿយៗ បន្ទាប់អំពីនោះ ព្រះយោគីចម្រើនកម្មដ្ឋានរឿយៗ ក្នុងសេនាសន:នោះ បានសម្រេចអរហត្តតាមលំដាប់ ទ្រង់រមែងបានទទួលមហាសក្ការ:ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងឯងដោយប្រពៃពិតហ្ន៎ ។

ភិក្ខុនេះ លោកពោលថា ដូចគ្នានឹងខ្លាធំ ។ ដូចជាស្តេចខ្លាធំ អាស្រ័យស្មៅក្រាស់ ព្រៃក្រាស់ ឬជួរភ្នំក្នុងព្រៃ លាក់ខ្លួនចាំចាប់ពួកម្រឹគ មានក្របីព្រៃរមាំង ជ្រូកព្រៃជាដើម យ៉ាងណា ភិក្ខុនេះ ជាអ្នកមានព្យាយាមប្រកបរឿយៗ

នូវកម្មដ្ឋានក្នុងព្រៃជាដើម រមែងកាន់យកអរិយមគ្គ ๔ និងអរិយផល ๔ បាន តាមលំដាប់ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលថា

យថាបិ ធីបិកោ ឆាម និលីយិត្វា គណ្ហាតិ មិគេ
តថេវ យំ ពុទ្ធបុត្តោ យុត្តយោគោ វិបស្សកោ
អរញ្ញំ បវិសិត្វាន គណ្ហាតិ ផលមុត្តមំ ។

ខ្វាធំ លាក់ខ្លួនចាំចាប់ពួកម្រឹគ យ៉ាងណា ភិក្ខុដែលជាពុទ្ធបុត្រនេះ ក៏ដូច្នោះដូចគ្នា ចូលទៅកាន់ព្រៃ ហើយប្រកបសេចក្តីព្យាយាម ជាអ្នកមានបញ្ញាឃើញច្បាស់ រមែងកាន់យកបាននូវផលដ៏ឧត្តម ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈព្រៃ ដែលជាភូមិដ៏សមគួរដល់អ្នកមានបញ្ញារហ័ស ដែលជាគ្រឿងព្យាយាមរបស់ព្រះយោគាវចរនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** *ជាដើម ។*

តពីនេះទៅ ពាក្យដែលគួរពោលក្នុងអានាបានបព្វៈនេះ លោកពោលក្នុងគម្ពីរវិសុទ្ធិមគ្គទាំងអស់ហើយ ។

បទថា **សេយ្យថាបិ ភិក្ខវេ ឧក្កោ ភមកាភោ វា** *នេះ ត្រឹមតែជាពាក្យឧបមាប៉ុណ្ណោះ ។ បទថា* **ឥតិ អជ្ឈត្តំ វា កាយេ** *នេះ កើតត្រឹមតែអប្បនាប៉ុណ្ណោះ ។ តែអប្បនានោះ ក៏រមែងមិនមកក្នុងពាក្យនោះ ។ មកតែឧបចារៈកម្មដ្ឋានដ៏សេស ។ តែក៏នៅមកមិនដល់បទថា* **ឧក្កោ** *សំដៅដល់អ្នកឈ្ងាស ។ បទថា* **ធីឃំ វា អញ្ឆន្តោ** *សេចក្តីថា លាដៃ លាជើង ទាញខ្សែវែង ក្នុងវេលាក្រឡឹងស្គរ ប្រហោងពិណជាដើមដែលជារបស់ធំ ។ បទថា* **រស្សំ វា អញ្ឆន្តោ**

សេចក្តីថា ទាញខ្សែខ្ទីៗ ក្នុងវេលាក្រឡឹងរបស់តូចតាច ដូចជាភ្ជុក និងស្នៀត គន្ធឹះជាដើម ។ បទថា **ឯវមេវ ខោ** សេចក្តីថា សូម្បីភិក្ខុនេះក៏ដូច្នោះ កាលដកដង្ហើមចូលវែងដោយខ្យល់អស្សាសៈ និងបស្សាសៈ ដែលប្រព្រឹត្តទៅដោយរយៈវែង និងរយៈខ្ទី ក៏ដឹងច្បាស់ថា អញដកដង្ហើមចូលវែង ។បេ។ ដឹងច្បាស់ថា អញដកដង្ហើមចេញវែង ដូច្នេះ ។ កាលលោកសិក្សាយ៉ាងនេះ ចតុត្ថជ្ឈាន រមែងកើតក្នុងនិមិត្តនៃខ្យល់អស្សាសបស្សាសៈ ។ លោកចេញចាកឈានហើយ នឹងកំណត់ខ្យល់អស្សាសបស្សាសៈ ឬអង្គឈានបាន ។

ក្នុងការកំណត់ខ្យល់អស្សាសបស្សាសៈនោះ ភិក្ខុប្រកបកម្មដ្ឋានក្នុងខ្យល់អស្សាសបស្សាសៈ រមែងកំណត់រូបយ៉ាងនេះថា ខ្យល់អស្សាស-បស្សាសៈទាំងនេះអាស្រ័យអ្វី អាស្រ័យវត្ថុ ករជកាយ ឈ្មោះថា វត្ថុ មហាភូតរូប ៤ និងឧបាទាយរូប ឈ្មោះថា ករជកាយ បន្ទាប់អំពីនោះ ទើបកំណត់ក្នុងនាមធម៌ ដែលមានផស្សៈជាគម្រប់ ៥ (វេទនា ១ សញ្ញា ១ ចេតនា ១ វិញ្ញាណ ១ ផស្សៈ ១) មានរូបនោះជាអារម្មណ៍ ។ កាលកំណត់នាមរូបនោះយ៉ាងនេះ ដោយប្រការដូច្នេះហើយ ស្វែងរកបច្ចយនៃនាមរូបនោះ ឃើញបដិច្ចសមុប្បាទ មានអវិជ្ជាជាដើមហើយ ឆ្ងងផុតសេចក្តីសង្ស័យបានថា នេះត្រឹមតែជាបច្ចយ និងបច្ចយុប្បន្នធម៌ប៉ុណ្ណោះ មិនមែនសត្ត ឬបុគ្គល ទើបលើកឡើងនូវនាមរូប ព្រមទាំងបច្ចយ កាន់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា រមែងសម្រេចអរហត្តដោយលំដាប់ ។ នេះជាផ្លូវបដិបត្តិចេញចាកទុក្ខដរាបដល់អរហត្តរបស់ភិក្ខុមួយរូប ។

ភិក្ខុដែលចម្រើនឈានកម្មដ្ឋាន កំណត់នាមរូបថា អង្គឈានទាំងនេះ អាស្រ័យអ្វី អាស្រ័យវត្ថុរូប កវជកាយ ឈ្មោះថា វត្ថុរូប អង្គឈាន ចាត់ជានាម កវជកាយចាត់ជារូប កាលនឹងស្វែងរកបច្ច័យនៃនាមរូបនោះ ទើបឃើញបច្ចយាការ មានអវិជ្ជាជាដើម ទើបឆ្លងសេចក្តីសង្ស័យបានថា នេះត្រឹមតែជាបច្ច័យ បច្ចុប្បន្ន មិនមែនសត្វ ឬបុគ្គល ទើបលើកឡើងនូវនាមរូបព្រមទាំងបច្ច័យកាន់ត្រៃលក្ខណ៍ចម្រើនវិបស្សនា សម្រេចអរហត្តដោយលំដាប់ ។ នេះជាបដិបទាចេញចាកទុក្ខ ដរាបដល់អរហត្ត របស់ភិក្ខុមួយរូប ។

បទថា **ឥតិ អជ្ឈត្តំ វា** *ក្នុងកាយខាងក្នុងក្តី សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ គឺខ្យល់អស្សាសបស្សាស:របស់ខ្លួនយ៉ាងនេះ ។ បទថា* **ពហិទ្ធា វា** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ គឺខ្យល់អស្សាស-បស្សាស:របស់អ្នកដទៃក្តី ។ បទថា* **អជ្ឈត្តពហិទ្ធា វា** *សេចក្តីថា ក្នុងកាយ គឺខ្យល់អស្សាសបស្សាស:របស់ខ្លួនតាមកាលក្តី របស់អ្នកដទៃ តាមកាលក្តី ដោយពាក្យនេះ ព្រះមានព្រះភាគ ត្រាស់កាលដែលភិក្ខុនោះ មិនបញ្ឈប់កម្មដ្ឋានដែលស្អាត់ជំនាញ ឲ្យកាយ គឺខ្យល់អស្សាសបស្សាស:សព្វរទៅមកឯកិច្ចទាំងពីរនេះ រមែងមិនបានក្នុងវេលាតែមួយជាមួយគ្នា ។*

បទថា **សមុទយធម្មានុបស្សី វា** *សេចក្តីថា ខ្យល់អាស្រ័យស្នប់របស់ជាងមាស ១ ជង្ងស្នប់ ១ សេចក្តីព្យាយាមដែលកើតអំពីជង្ងស្នប់នោះ ១ ទើបនឹងសព្វរទៅមកបាន យ៉ាងណា កាយ គឺខ្យល់អស្សាសបស្សាស: ក៏អាស្រ័យកវជកាយ ១ រន្ធច្រមុះ ១ ចិត្ត ១ របស់ភិក្ខុ ទើបសព្វរទៅមកបាន*

ដូច្នោះ ។ ភិក្ខុឃើញធម៌ មានកាយជាដើម ដែលមានការកើតជាធម្មតា លោកហៅថា ពិចារណាឃើញធម៌ គឺការកើតក្នុងកាយ ។ បទថា **វយ-ធម្មានុបស្សី វា** *សេចក្តីថា កាលស្នប់ត្រូវនាំចេញទៅហើយ កាលដងស្នប់ជាក់ហើយ កាលសេចក្តីព្យាយាមដែលកើតអំពីដងស្នប់នោះមិនមាន ខ្យល់នោះ រមែងប្រព្រឹត្តទៅមិនបាន យ៉ាងណា កាលកាយបែកធ្លាយហើយ កាលវន្ទច្រមុះត្រូវកម្ចាត់ហើយ និងកាលចិត្តរលត់ហើយ ឈ្មោះថា កាយ គឺខ្យល់អស្សាសបស្សាសៈ ក៏រមែងប្រព្រឹត្តទៅមិនបានដូច្នោះដែរ ។ ភិក្ខុកាលឃើញយ៉ាងនេះថា ខ្យល់អស្សាសបស្សាសៈរលត់ ព្រោះកាយជាដើមរលត់ ដូច្នេះ លោកហៅថា ពិចារណាឃើញធម៌ គឺការវិនាសទៅក្នុងកាយ ។ បទថា* **សមុទយវយធម្មានុបស្សី វា** *សេចក្តីថា ពិចារណាឃើញការកើតតាមកាល ការវិនាសទៅតាមកាល ។*

បទថា **អត្ថិ កាយោតិ វាបនស្ស** *សេចក្តីថា ស្មារតីរបស់ភិក្ខុនោះ ចូលទៅតាំងចំពោះយ៉ាងនេះថា កាយនេះមាន តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនអញ មិនមែនរបស់អញ មិនមែនអ្នកណា មិនមែនរបស់អ្នកណា ។ បទថា* **យាវទេវ** *នេះ ជាគ្រឿងកំណត់ដែននៃប្រយោជន៍ ។ លោកអធិប្បាយថា សតិដែលចូលទៅតាំងនោះ មិនមែនដើម្បីប្រយោជន៍យ៉ាងដទៃទេ ដែលពិត ក៏ត្រឹមតែដើម្បីប្រយោជន៍ គឺសេចក្តីដឹង គឺប្រមាណនៃសេចក្តីដឹងក្រៃលែងឡើងៗ និងប្រមាណនៃសតិប៉ុណ្ណោះ អធិប្បាយថា ដើម្បីសេចក្តីចម្រើននៃសតិសម្បជញ្ញៈ ។ បទថា*

អនិស្សិតោ ច វិហរតិ សេចក្តីថា មិនត្រូវកិលេសអាស្រ័យដោយអំណាចនៃកិលេសជាទីអាស្រ័យ គឺតណ្ហា និងទិដ្ឋិ ។ បទថា **ន ច កិញ្ចិ លោកេ ឧចាធិយតិ** សេចក្តីថា មិនប្រកាន់វត្ថុណាមួយក្នុងលោក គឺរូប ។បេ។ ឬវិញ្ញាណថា នេះជាខ្លួនរបស់អញ នេះមានក្នុងខ្លួនរបស់អញ ។ **ឯ** អក្ខរ: ក្នុងបទថា **ឯវំឯ** ចុះក្នុងអត្ត គឺអាស្រ័យសេចក្តីខាងមុខប្រមូលមក ។ ព្រះមានព្រះភាគទ្រង់ប្រគល់ទេសនា គឺអានាបានបព្វ: សម្តែងហើយដោយបទនេះ ។

ក្នុងអានាបានបព្វ:នោះ សតិដែលកំណត់ខ្យល់អស្សាសបស្សាស: ជាអារម្មណ៍ ជាទុក្ខសច្ច តណ្ហាមានក្នុងកាលមុន ដែលញ្ចុាំងទុក្ខសច្ចនោះឲ្យតាំងឡើង ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃសច្ច:ទាំងពីរ ជានិរោធសច្ច អរិយមគ្គដែលកំណត់ដឹងទុក្ខសច្ច លះសមុទយសច្ច មាននិរោធសច្ចជាអារម្មណ៍ ជាមគ្គសច្ច ។ យោគាវចរភិក្ខុ ខ្ងល់ខ្ងាយដោយអំណាចសច្ច: ៤ យ៉ាងនេះ រមែងសម្រេចការរម្ងត់ទុក្ខបាន ដូច្នេះ ។

នេះជាបដិបទានាំចេញចាកទុក្ខ ដរាបសម្រេចអរហត្តនៃភិក្ខុ ដែលតាំងមាំហើយ ដោយអំណាចនៃខ្យល់អស្សាសបស្សាស:មួយរូប ដូច្នេះឯង ។

អានាចានបព្វ: ចប់

ឥរយាបថបព្វ:

[១១៣] ព្រះមានព្រះភាគ កាលទ្រង់ចែកកាយានុបស្សនា ដោយផ្លូវនៃខ្យល់អស្សសបស្សាស:យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយ

ឥរិយាបថ ទើបត្រាស់ថា **បុន จปรំ** *ជាដើម ។ ក្នុងឥរិយាបថនោះ គប្បីជ្រាបសេចក្តីថា សូម្បីសត្វតិរច្ឆាន ដូចជាឆ្កែស្រុក ឆ្កែចចកជាដើម កាលដើរទៅ ក៏ដឹងថា ខ្លួនដើរក៏ពិត តែក្នុងឥរិយាបថនោះ មិនបានត្រាស់សំដៅយកការដឹងបែបនោះ ។ ព្រោះការដឹងនោះ លះការយើញថាសត្វមិនបាន ដកសេចក្តីសម្គាល់ថាសត្វមិនបាន ។ មិនជាកម្មដ្ឋាន ឬសតិប្បដ្ឋានភាវនាឡើយ ។ ចំណែកការដឹងរបស់ភិក្ខុ (អ្នកចម្រើនកាយានុបស្សនា) នេះ រមែងលះការយល់ឃើញថា សត្វ ដកការសម្គាល់ថា សត្វបាន ។ ទាំងជាកម្មដ្ឋាន និងជាសតិប្បដ្ឋានភាវនា ។ ម្យ៉ាងទៀត ពាក្យដែលត្រាស់សំដៅដល់សេចក្តីដឹងច្បាស់យ៉ាងនេះថា នរណាដើរ ការដើររបស់នរណា ដើរបានព្រោះអ្វី ។ សូម្បីក្នុងឥរិយាបថដទៃ មានការឈរជាដើម ក៏នយនេះដូចគ្នា ។*

វិនិច្ឆ័យក្នុងបញ្ហាទាំងនោះ ពាក្យថា អ្នកណាដើរ សេចក្តីថា មិនមែនសត្វ ឬបុគ្គលណាមួយដើរ ។ ពាក្យថា ការដើររបស់អ្នកណា សេចក្តីថា មិនមែនការដើររបស់សត្វ ឬបុគ្គលណាមួយឡើយ ។ ពាក្យថា ដើរបានព្រោះអ្វី សេចក្តីថា ដើរបានព្រោះការផ្សាយទៅរបស់វាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ។ ព្រោះដូច្នោះ ភិក្ខុនោះ រមែងដឹងច្បាស់យ៉ាងនេះ គឺចិត្តកើតឡើងថា អញនឹងដើរ ចិត្តនោះក៏ធ្វើឲ្យកើតវាយោធាតុៗ ក៏ធ្វើឲ្យកើតវិញ្ញត្តិការកម្រើក ការនាំសកលកាយ ឲ្យឈានទៅខាងមុខ ដោយការកម្រើកនៃវាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ហៅថា ដើរ ។ ក្នុងឥរិយាបថដទៃមានឈរជាដើម ក៏នយនេះដូចគ្នា ។ ក្នុងឥរិយាបថឈរជាដើមនោះ ចិត្តកើត

ទ្បើងថា អញនឹងឈរ ចិត្តនោះធ្វើឲ្យកើតវាយោធាតុៗ ធ្វើឲ្យកើតកាយវិញ្ញត្តិ គឺការកម្រើក ការទ្រទ្រង់សកលកាយ តាំងទ្បើងអំពីបាតជើងជាទីបំផុត ដោយការកម្រើកនៃវាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ហៅថា ឈរ ។ ចិត្តកើតទ្បើងថា អញនឹងអង្គុយ ចិត្តនោះក៏ធ្វើឲ្យកើតវាយោធាតុៗ ក៏ធ្វើឲ្យកើតវិញ្ញត្តិ ការបត់កាយខាងក្រោម ទ្រទ្រង់កាយខាងលើតាំងទ្បើង ដោយការកម្រើកនៃវាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ហៅថា អង្គុយ ។ ចិត្តកើតទ្បើងថា អញនឹងដេក ចិត្តនោះក៏ធ្វើឲ្យកើតវាយោធាតុៗ ធ្វើឲ្យកើតវិញ្ញត្តិ ការសណ្ឋកកាយទាំងអស់ឲ្យជារបស់វែង ដោយការកម្រើកនៃវាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ហៅថា ដេក ។ កាលកិកូនោះដឹងច្បាស់យ៉ាងនេះ រមែងមានការគិតយើញយ៉ាងនេះថា បានឮថា សត្វដើរ សត្វឈរ តែដោយអត្តហើយ សត្វណាមួយ ដែលដើរ ដែលឈរមិនមាន ដូចពាក្យដែលគេពោលថា រនេះទៅ រនេះឈប់ តែធម្មតាថា រនេះណាមួយ ដែលទៅបាន ឈប់បានខ្លួនឯង មិនមានទេ លុះតែនាយសារថីអ្នកឈ្វាស ទឹមគោ ៤ ក្បាល ហើយដេញទៅ ទើបរនេះទៅ ទើបឈប់ ព្រោះដូច្នោះ ទើបពាក្យនោះមានត្រឹមតែបញ្ញត្តិសន្មតិហៅ យ៉ាងណា កាយប្រៀបដូចរនេះ ព្រោះអត្តថាមិនដឹង ខ្យល់ដែលកើតអំពីចិត្ត ប្រៀបដូចគោ ចិត្តប្រៀបដូចសារថី កាលចិត្តកើតទ្បើងថា អញនឹងដើរ អញនឹងឈរ វាយោធាតុដែលធ្វើឲ្យកើតការកម្រើកក៏កើតទ្បើង ឥរិយាបថ មានដើរជាដើម រមែងប្រព្រឹត្តទៅ ព្រោះការកម្រើកនៃវាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត បន្ទាប់អំពីនោះ សត្វក៏ដើរ សត្វ

ก็ឈរ អញ្ជើរ អញ្ឈរ ព្រោះហេតុនោះ ទើបពាក្យនោះ មានត្រឹមតែ បញ្ញត្តិសន្ទតិហៅគ្នាដូច្នោះដូចគ្នា ។ ព្រោះហេតុនោះ ទើបបុរាណាចារ្យ ពោលថា

នាវា មាលុតវេគេន ឯយាវេគេន តេជនំ
យថា យាតិ តថា កាយោ យាតិ វាតាហតោ អយំ
យន្តំ សុត្តវសេនេវ ចិត្តសុត្តវសេនិធំ
បយុត្តំ កាយយន្តម្បិ យាតិ ឋាតិ និសីទតិ
កោ ឆាម ឯត្ថ សោ សត្តោ យោ វិនា ហេតុបច្ចយេ
អត្តនោ អានុភាវេន តិដ្ឋេ វា យទិ វា វជេ ។

នាវាសូរទៅបានដោយកម្លាំងខ្យល់ កូនធ្នូសូរទៅដោយកម្លាំងខ្សែធ្នូ យ៉ាងណា កាយនេះដែលខ្យល់នាំទៅ ទើបដើរទៅបាន ដូច្នោះ សូម្បីយន្ត គឺកាយនេះ ដែលបច្ច័យប្រកបហើយ ដើរ ដេក ឈរ និងអង្គុយ បាន ដោយអំណាចខ្សែទាញ គឺចិត្ត ដូចគ្រឿងយន្ត វិលទៅបានដោយអំណាច ខ្សែទាញ ដូច្នោះឯង ក្នុងលោកនេះ សត្វណាវៀរហេតុបច្ច័យចេញហើយ ឈរបាន ដើរបាន ដោយអានុភាពរបស់ខ្លួនឯង សត្វនោះឈ្មោះថា និង មានដូចម្តេច ដូច្នេះ ។

*ព្រោះដូច្នោះ គប្បីជ្រាបថា ភិក្ខុនេះ កំណត់ឥរិយាបថ មានដើរជាដើម ដែលប្រព្រឹត្តទៅបានដោយអំណាចហេតុបច្ច័យប៉ុណ្ណោះ យ៉ាងនេះ កាលដើរក៏ ដឹងថា អញ្ជើរ កាលឈរ ក៏ដឹងថា អញ្ឈរ កាលអង្គុយក៏ដឹងថា អញ

អង្គុយ កាលដេកក៏ដឹងថា អញដេក ដូច្នេះ ។

បទថា **យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា តថា នំ បជ្ជានាតិ** *នេះ ជាពាក្យពោលរួមឥរិយាបថទាំងពួង ។ មានពាក្យអធិប្បាយថា ឬកាយរបស់លោកតាំងនៅដោយអាការណាមួយ ក៏ដឹងច្បាស់កាយនោះ ដោយអាការនោះៗ គឺកាយនោះ តាំងនៅដោយអាការដើរ ក៏ដឹងច្បាស់ថា អញដើរ កាយតាំងនៅដោយអាការឈរ អង្គុយ ដេក ក៏ដឹងច្បាស់ថា អញឈរ អញអង្គុយ អញដេក ។*

បទថា **ឥតិ អជ្ឈត្តំ វា** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ๔ របស់ខ្លួនឯងយ៉ាងនេះ ។ បទថា* **ពហិទ្ធា វា** *សេចក្តីថា ដោយការកំណត់ឥរិយាបថ ๔ របស់អ្នកដទៃ ។ បទថា* **អជ្ឈត្ត ពហិទ្ធា វា** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ๔ របស់ខ្លួនឯងតាមកាល របស់អ្នកដទៃតាមកាល ។ ក្នុងពាក្យបាលីជាដើមថា* **សមុទយធម្មានុបស្សី វា** *គឺគប្បីនាំការកើត និងការវិនាសនៃរូបក្ខន្ធ សម្តែងដោយអាការទាំង ๕ តាមនយបាលីជាដើមថា រូបកើតព្រោះអវិជ្ជាកើត ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកការកើត និងការវិនាសនោះឯង ត្រាស់ថា ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើង ដូច្នេះជាដើម ក្នុងទីនេះ ។*

ពាក្យបាលីជាដើមថា **អត្ថិ កាយោតិ វា បនស្ស** *ដូច្នេះ ក៏មានសេចក្តីដូចគ្នាដែលពោលមកហើយនុ៎ះឯង ។*

ក្នុងឥរិយាបថបព្វៈនេះ សតិដែលកំណត់ឥរិយាបថ ๔ ជាអារម្មណ៍ ជាទុក្ខសច្ច តណ្ហាដែលមានក្នុងកាលមុន ដែលញុំាងសតិដែលកំណត់ឥរិយាបថ ๔ នោះឲ្យតាំងឡើង ជាសមុទយសច្ច ការបញ្ឈប់ទុក្ខសច្ច និងសមុទយសច្ចទាំង ๒ ជានិរោធសច្ច អរិយមគ្គដែលកំណត់ដឹងទុក្ខ លះសមុទយៈ មាននិរោធជាអារម្មណ៍ ជាមគ្គសច្ច ភិក្ខុជាយោគាវចរខ្ងល់ខ្ងាយដោយផ្លូវសច្ចៈ ๔ យ៉ាងនេះ រមែងសម្រេចព្រះនិព្វានរលត់ទុក្ខ ។

នេះជាបដិបទានាំចេញចាកទុក្ខ ដរាបដល់អរហត្ត របស់ភិក្ខុដែលកំណត់ឥរិយាបថ ๔ មួយរូប ដូច្នេះឯង ។

ឥរិយាបថបព្វៈ ចប់

សម្បជញ្ញបព្វៈ

[๑๑๔] *ព្រះមានព្រះភាគ លុះទ្រង់ចែកកាយានុបស្សនាដោយឥរិយាបថ ๔ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយសម្បជញ្ញៈ ๔ ទើបត្រាស់ថា* **បុន จปรំ** *ជាដើម ។ ក្នុងសម្បជញ្ញបព្វៈនោះ បទថា* **អភิกฺกนฺเต** *ជាដើម ទ្រង់ពណ៌នាហើយក្នុងសាមញ្ញផលសូត្រ ។ បទថា* **ឥติ อชฺฌตฺตំ วา** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់បុគ្គលដទៃ ឬក្នុងកាយរបស់ខ្លួនតាមកាល របស់បុគ្គលដទៃតាមកាលដោយកំណត់សម្បជញ្ញៈ ๔ យ៉ាងនេះ ។ ការកើត និងការវិនាសនៃរូបក្ខន្ធនោះឯង គប្បីនាំមកសម្តែង ក្នុងពាក្យថា ពិចារណាឃើញនូវធម៌ដែលប្រជុំ*

កើតជាដើម ក្នុងសម្បជញ្ញបព្វៈនេះ ។ ពាក្យក្រៅពីនេះ ក៏ដូចគ្នានឹងពោលមកហើយន៉ុះឯង ។

ក្នុងសម្បជញ្ញបព្វៈនេះ សតិកំណត់សម្បជញ្ញៈ ៤ ជាទុក្ខសច្ច តណ្ហាដែលមានក្នុងកាលមុន ដែលញ្ចាំងសតិកំណត់សម្បជញ្ញៈ ៤ នោះឲ្យតាំងឡើង ជាសុមទយសច្ច ការបញ្ឈប់ទុក្ខសច្ច និងសមុទយសច្ចទាំង ២ ជានិរោធសច្ច អរិយមគ្គមានប្រការដូចពោលមកហើយ ជាមគ្គសច្ច យោគាវចរភិក្ខុ ខ្ងល់ខ្ងាយដោយផ្ទូវសច្ចៈ ៤ យ៉ាងនេះ រមែងសម្រេចនិព្វាន រម្ងត់ទុក្ខបាន ដូច្នេះ ។

នេះជាបដិបទានាំទុក្ខចេញ ដរាបដល់អរហត្ត របស់ភិក្ខុដែលកំណត់សម្បជញ្ញៈ ៤ មួយរូប ដូច្នេះ ។

សម្បជញ្ញបព្វៈ ចប់

បដិកូលមនសិការបព្វៈ

[១១៥] ព្រះមានព្រះភាគ កាលទ្រង់ចែកកាយានុបស្សនាដោយផ្ទូវសម្បជញ្ញៈ ៤ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកបដិកូលមនសិការ ទើបត្រាស់ថា **បុន ចបរំ** ជាដើម ។ ក្នុងបដិកូលមនសិការបព្វៈនោះ ពាក្យណាដែលគួរពោលក្នុងបាលីជាដើមថា **ឥមមេវ កាយំ** ពាក្យទាំងអស់នោះ លោកពោលហើយក្នុងកាយគតាសតិកម្មដ្ឋាន ក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្តារដោយអាការទាំងពួង ។ បទថា **ឧភតោមុខា** សេចក្តីថា ប្រកបដោយមាត់

ទាំងសងខាង ទាំងខាងក្រោម និងលើ ។ បទថា **នានាวิหิตสฺส** *គឺមានប្រភេទផ្សេងៗ ។ ក្នុងសេចក្តីនោះ មានពាក្យប្រៀបធៀបឧបមាដូច្នេះ កាយដែលប្រកបដោយមហាភូតរូប ៤ គប្បីជ្រាបថា ប្រៀបដូចទៃមានមាត់សងខាង អាការ ៣២ មានសក់ជាដើម ប្រៀបដូចធញ្ញជាតិប្រភេទផ្សេងៗ ដែលគេលាយគ្នាជាក់ចូលទៅក្នុងទៃនោះ ព្រះយោគាវចរ ប្រៀបដូចបុរសមានចក្ខុ អាការច្រាកដច្បាស់នៃអាការ ៣២ របស់ព្រះយោគាវចរ គប្បីជ្រាបដូចអាការដែលធញ្ញជាតិប្រភេទផ្សេងៗ ច្រាកដដល់បុរសអ្នកស្រាយទៃនោះចេញ ហើយពិចារណាមើល ។*

បទថា **สติ อฏฺฐตฺถุ วา** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួនក្តី ក្នុងកាយរបស់បុគ្គលដទៃក្តី ឬក្នុងកាយរបស់ខ្លួនតាមកាល របស់បុគ្គលដទៃតាមកាលក្តី ដោយការកំណត់អាការ ៣២ មានសក់ជាដើម យ៉ាងនេះ ។ សេចក្តីតពីនេះទៅ ក៏មានន័យដូចពោលមកហើយ ។ ក្នុងបដិកូល-មនសិការបព្វៈនេះ ផ្សេងគ្នាតែម្យ៉ាង គឺគួរប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់អាការ ៣២ ជាអារម្មណ៍ ជាទុក្ខសច្ច ហើយគប្បីជ្រាបថា ជាបដិបទានាំចេញចាកទុក្ខ ដរាបដល់អរហត្ត របស់ភិក្ខុដែលកំណត់អាការ ៣២ មួយរូប ។ ពាក្យក្រៅពីនេះ ដូចគ្នាតាមដែលពោលមកហើយនោះឯង ។*

បដิกูลมนสิการបព្វៈ จบ

ធាតុមនសិការបព្វៈ

[๑๑๖] ព្រះមានព្រះភាគ កាលទ្រង់ចែកកាយានុបស្សនា ដោយបដិកូលមនសិការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកធាតុមនសិការបព្វៈ ទើបត្រាស់ធាតុមនសិការបព្វៈថា **បុន ចបរំ** ជាដើម ។ ក្នុងធាតុមនសិការបព្វៈនោះ មានពណ៌នាអត្ថ ព្រមដោយសេចក្តីប្រៀបធៀបនៃឧបមាដូច្នេះថា នាយគោឃាតកៈក្តី កូនសិស្សរបស់នាយគោឃាតកៈក្តី ដែលគាត់ចិញ្ចឹមដោយអាហារ និងតម្លៃឈ្នួល សម្លាប់គោហើយ ពន្លះជាចំណែកៗ ហើយអង្គុយក្នុងផ្លូវធំដែលមានមុំ ๔ គឺទីប្រជុំផ្លូវត្រង់កណ្តាលផ្លូវធំ ដែលទៅបានទាំង ๔ ទិស យ៉ាងណា ភិក្ខុ (អ្នកបំពេញធាតុកម្មដ្ឋាន) ក៏ដូច្នោះឯង រមែងពិចារណាកាយ ដែលឈ្មោះថា តាមដែលតាំងនៅហើយ ព្រោះតាំងនៅដោយអាការយ៉ាងណាមួយនៃឥរិយាបថទាំង ๔ និងដែលឈ្មោះថា តាមដែលតម្កល់នៅ ព្រោះតាមដែលតាំងនៅយ៉ាងនេះថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា កាលអ្នកសម្លាប់គោចិញ្ចឹមគោក្តី នាំគោទៅកាន់ទីសម្លាប់ក្តី នាំមកចងត្រង់ទីសម្លាប់ក្តី កំពុងសម្លាប់ក្តី សម្លឹងមើលគោដែលសម្លាប់ហើយក្តី ការសម្គាល់ថា គោមិនទាន់បាត់ទៅជារាបដែលគេមិនទាន់បានពន្លះគោនោះចេញជាចំណែកៗ កាលគេពន្លះ បែងចែកចេញហើយ ការសម្គាល់ថា គោក៏បាត់ទៅ ត្រឡប់សម្គាល់ថា សាច់គោ បុរសនោះមិនបានគិតថា អញលក់គោ ជនទាំងនេះទិញគោទៅ ដែលពិតបុរសនោះគិតថា អញលក់សាច់គោ ជនទាំងនេះទិញសាច់គោទៅ យ៉ាងណា

សូម្បីភិក្ខុនេះ ក៏ដូច្នោះដូចគ្នា កាលនៅជាបុថុជ្ជនល្ងង់ខ្លៅ ជាគ្រហស្ថក្តី បព្វជិតក្តី ការសម្គាល់ថា សត្វ ឬបុគ្គលមិនទាន់បាត់ទៅដរាបណា ដែលនៅមិនទាន់ពិចារណាឃើញកាយនេះឯង តាមដែលតាំងនៅ តាមដែលតម្កល់នៅ ចែកចេញជាដុំ ដោយភាពជាធាតុ កាលលោកពិចារណាឃើញដោយភាពជាធាតុ ទើបការសម្គាល់ថា សត្វបាត់ទៅ ចិត្តក៏តាំងនៅដោយល្អ ដោយភាពជាធាតុតែម្យ៉ាង ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលស្ថិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថា គ្រាន់តែជាធាតុថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលបំបែនប្រសប់ ។បេ។ គ្រាន់តែជាវាយោធាតុ ដូច្នេះ ។ ព្រះយោគាវចរ ប្រៀបដូចអ្នកសម្លាប់គោ សេចក្តីសម្គាល់ថា សត្វ ប្រៀបដូចសេចក្តីសម្គាល់ថា គោ ឥរិយាបថទាំង ๔ ប្រៀបដូចផ្ទះធំដែលមានមុំ ๔ ការពិចារណាឃើញថា ជាធាតុ ប្រៀបដូចអ្នកសម្លាប់គោអង្គុយរម្លែកជាចំណែកៗ នេះជាពណ៌នាបាលីក្នុងធាតុមនសិការបព្វៈនេះ ។ ចំណែកកថាពោលដោយកម្មដ្ឋាន លោកពណ៌នាពិស្តារក្នុងគម្ពីរវិសុទ្ធិមគ្គហើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** *សេចក្តីថា ពិចារណាឃើញខាងក្នុងកាយរបស់ខ្លួនក្តី ក្នុងកាយរបស់បុគ្គលដទៃក្តី ក្នុងកាយរបស់ខ្លួនតាមកាលក្តី របស់អ្នកដទៃតាមកាលក្តី ដោយការកំណត់ធាតុ ๔ ដោយអាការយ៉ាងនេះ ។ សេចក្តីតទៅពីនេះ មានន័យដូចពោលមកហើយនោះឯង ។ តែក្នុងទីនេះ មាន*

សេចក្តីផ្សេងគ្នាតែម៉្យាង គឺគប្បីប្រកបអត្តយ៉ាងនេះថា សតិកំណត់ធាតុ ๔ ជាអារម្មណ៍ ជាទុក្ខសច្ចជាដើម ។ ហើយគប្បីជ្រាបថា នេះជាបដិបទានាំចេញចាកទុក្ខរបស់កិកូ ដែលកំណត់ធាតុ ๔ ដូច្នេះ ។ ចំណែកពាក្យដ៏សេសដូចដែលពោលមកហើយក្នុងកាលមុននុ៎ះឯង ។

ធាតុមនសិការបព្វៈ ចប់

ឆវសីវថិកាបព្វៈ

[๑๑๗] *ព្រះមានព្រះភាគ កាលទ្រង់ចែកកាយានុបស្សនា ដោយធាតុមនសិការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយនវសីវថិកាបព្វៈ ទើបត្រាស់ថា* **បុន ចបរំ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **សេយ្យថាបិ បស្សេយ្យ** *គឺឃើញ ។ បទថា* **សរីរំ** *គឺសរីរៈរបស់អ្នកស្លាប់ ។ បទថា* **សីវថិកាយ ឆឌ្ឌិតំ** *គឺដែលគេចោលក្នុងព្រៃស្មសាន ។ សាកសពដែលឈ្មោះថា* **ឯកាហមតំ** *ព្រោះជាសាកសពដែលស្លាប់ហើយបាន ๑ ថ្ងៃ ។ ដែលឈ្មោះថា* **ទ្វិហមតំ** *ព្រោះជាសាកសពដែលស្លាប់ហើយបាន ๒ ថ្ងៃ ។ ដែលឈ្មោះថា* **តីហមតំ** *ព្រោះសាកសពដែលស្លាប់ហើយបាន ๓ ថ្ងៃ ។ ដែលឈ្មោះថា* **ឧទ្ធុមាតកំ** *ព្រោះជាសាកសពដែលហើមប៉ោង ព្រោះជាសាកសពដែលហើមប៉ោងតាមលំដាប់ តាំងពីអស់ជីវិតមក ដូចស្នប់ជាងមាស ដែលប៉ោងឡើងដោយខ្យល់ ។ សាកសពដែលប៉ោងឡើងនុ៎ះឯង ឈ្មោះថា* **ឧទ្ធុមាតក** *។ នយម្យ៉ាងទៀត សាកសពដែលប៉ោងឡើងគួរខ្ពើម ព្រោះជារបស់*

បដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **ឧទ្ទុមាតក** ។ សាកសពដែល មានពណ៌ផ្សេងៗ លាយដោយពណ៌ខៀវ ហៅថា **វិនីលកំ** ។ សាកសពដែល មានពណ៌ខៀវលាយន្ទុ៉ះឯង ឈ្មោះថា **វិនីលក** ។ នយម្យ៉ាងទៀត សាកសព ដែលមានពណ៌ខៀវគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះហេតុនោះ ទើប ឈ្មោះថា **វិនីលក** ។ បទថា **វិនីលក** នេះ ជាឈ្មោះរបស់សាកសព មាន ពណ៌ក្រហម ក្នុងកន្ទែងសាច់ប៉ោងឡើងក្រាស់ មានពណ៌ស ក្នុងទីដែលខ្ទុះ ច្រើន ដោយច្រើនមានពណ៌ខៀវ ក្នុងទីគួរខៀវ ដូចសំពត់ដណ្តប់ពណ៌ខៀវ ។ សាកសពដែលមានខ្ទុះហូរចេញចាកទីជុំវិញនៃទ្វារទាំង ៩ ខ្ទះ ឈ្មោះថា **វិបុព្វកជាតំ** ។ សាកសពមានខ្ទុះហូរន្ទុ៉ះឯង ឈ្មោះថា **វិបុព្វក** ។ នយម្យ៉ាង ទៀត សាកសព មានខ្ទុះហូរគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **វិបុព្វក** ។ សាកសពដែលជាវិបុព្វកៈកើតហើយ គឺដល់ភាព ជាសាកសព មានខ្ទុះហូរយ៉ាងនោះ ព្រោះហេតុនោះ ឈ្មោះថា **វិបុព្វកជាត** ។ បទថា **សោ ឥមមេវ កាយំ** សេចក្តីថា ភិក្ខុនោះ ប្រើញាណន្ទុ៉ះឯង បង្អោន នាំកាយរបស់ខ្លួននេះទៅ ប្រៀបនឹងកាយនោះ ។ សួរថា ប្រៀបធៀបដូចម្តេច ឆ្ទើយថា ប្រៀបធៀបថា កាយនេះឯង មានសភាពយ៉ាងនោះជាធម្មតា ត្រូវ តែមានសភាពយ៉ាងនោះ មិនកន្ទងផុតពីសភាពយ៉ាងនោះទៅបានឡើយ ។

លោកអធិប្បាយថា កាយនេះ ដែលនៅឈរ ដើរ ជាដើមបាន ក៏ព្រោះ មានធម៌ ៣ យ៉ាងនេះ គឺអាយុ ភ្ទើងធាតុ និងវិញ្ញាណ តែព្រោះធម៌ ៣ យ៉ាង នេះ ប្រាសចាកពីគ្នា ទើបកាយនេះ ត្រូវមានយ៉ាងនោះជាធម្មតា គឺមានសភាព

ស្មុយរលួយយ៉ាងនោះដូចគ្នា ត្រូវមានសភាពយ៉ាងនោះ គឺនឹងជាប្រភេទសាកសពហើមប៉ោងជាដើមយ៉ាងនោះដូចគ្នា មិនកន្ទុងផុតសភាពយ៉ាងនោះទៅបាន គឺមិនកន្ទុងផុតសភាពជាសាកសពហើមប៉ោង ជាដើមយ៉ាងនោះទៅបានឡើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួនក្តី ក្នុងកាយរបស់អ្នកដទៃក្តី ក្នុងកាយរបស់ខ្លួនតាមកាលក្តី របស់អ្នកដទៃតាមកាលក្តី ដោយការកំណត់សាកសពដែលហើមប៉ោងជាដើមយ៉ាងនេះ ។*

[๑๑๘-๑๒๕] *បទថា* **ខជ្ជមានំ** *បានដល់ សាកសពដែលមានសត្វត្មាត ក្អែកជាដើម ទំត្រង់អវយវៈ ដូចជាពោះជាដើម ហើយទាញសាច់ពោះសាច់មាត់ ប្រឡង់ក្អែកជាដើមចឹកស៊ី ។ បទថា* **សមំសលោហិតំ** *គឺសាកសពដែលមានសាច់ និងឈាមនៅសល់ ។ បទថា* **ឯម្ចំសលោហិតមក្ខិតំ** *គឺកាលសាច់អស់ទៅហើយ តែឈាមមិនទាន់ស្ងួត ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកសាកសពប្រភេទនោះ ទើបត្រាស់ថា* **ឯម្ចំសលោហិតមក្ខិតំ ។** *បទថា* **អញ្ញេន** *គឺសាកសពដែលរាត់រាយក្នុងទិសផ្សេងៗ ។ បទថា* **ហត្ថដ្ឋិកំ** *សេចក្តីថា ឆ្អឹងដៃមាន ៦៤ កំណាត់ ខ្ចាត់ខ្ចាយបែកគ្នាទៅ ។ សូម្បីឆ្អឹងជើងជាដើម ក៏ន័យនេះដូចគ្នា ។ បទថា* **តេរោវស្សិកានិ** *គឺកន្ទុងមួយឆ្នាំទៅហើយ ។ បទថា* **ឫតីនិ** *សេចក្តីថា ឆ្អឹងដែលតាំងនៅកណ្តាលវាល រមែងពុកផុយព្រោះត្រូវខ្យល់ កម្តៅថ្ងៃ និងភ្លៀង ចំណែកឆ្អឹងដែលនៅក្នុងផែនដី រមែងតាំង*

នៅបានយូរជាង ។ បទថា **ចุณฺณกชาตานิ** *គឺបែកជាលម្អិតតូចធំខ្ចាត់ខ្ចាយ ទៅ ។ គប្បីប្រកបសេចក្តីចូលក្នុងបទទាំងពួង ដោយបទថា* **อฏฺฐิมานิ** *ជាដើម ដោយនយដែលពោលមកហើយថា ភិក្ខុក៏បង្អោនកាយនេះឯង ចូលទៅប្រៀបធៀបនឹងសាកសពជាដើម ។*

បទថា **สกิ อฏฺฐึ วา** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួនក្តី ក្នុងកាយរបស់អ្នកដទៃក្តី ក្នុងកាយរបស់ខ្លួនតាមកាលក្តី និងរបស់អ្នកដទៃតាមកាលក្តី ដោយការកំណត់សាកសព ដែលសត្វកកេរស៊ីជាដើម រហូតដល់ឆ្អឹង ដែលបែកជាកម្ទេចតូចធំយ៉ាងនេះ ។*

ព្រៃជាទីចោលសាកសព ៩ ប្រការ ក្នុងនវសីវថិកាបព្វៈនេះ បណ្ឌិតគប្បីប្រមូលមកដូច្នេះ គឺបទដែលត្រាស់ដោយនយថា សាកសពស្លាប់អស់ ១ ថ្ងៃក្តីជាដើម ទាំងអស់នេះ ជា ១ បព្វៈ បទដែលត្រាស់ថា សាកសពដែលត្រូវហ្វូងក្អែកចឹកស៊ីជាដើម ជា ១ បព្វៈ បទដែលត្រាស់ថា សល់តែពាងឆ្អឹង នៅមានសាច់ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ជា ១ បព្វៈ បទដែលត្រាស់ថា ប្រាសចាកសាច់ នៅប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចងជាដើម ជា ១ បព្វៈ បទដែលត្រាស់ថា ប្រាសចាកសាច់ និងឈាម នៅមានសរសៃជាគ្រឿងចង ជា ១ បព្វៈ បទដែលត្រាស់ថា ឆ្អឹងទាំងឡាយដែលប្រាសចាកសរសៃជាគ្រឿងចងជាដើម ជា ១ បព្វៈ បទដែលត្រាស់ថា ឆ្អឹងទាំងឡាយមានពណ៌ស ដូចជាសម្បុរនៃសង្ខ ជា ១ បព្វៈ ។ បទដែលត្រាស់ថា ឆ្អឹងដែលរាត់រាយ មានឆ្នាំមួយកន្លងហើយ ជា ១ បព្វៈ ។ បទដែល

ត្រាស់ថា ឆ្អឹងទាំងឡាយដែលពុកផុយ ជាកម្ទេចតូចធំផ្សេងៗ ជា ១ បព្វៈ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រៃ ជាទីចោលសាកសពទាំង ៩ ហើយកាលទ្រង់បញ្ចប់កាយានុបស្សនា ទើបត្រាស់ពាក្យនេះថា **ឯវំ ខោ ភិក្ខវេ** *ជាដើម ។*

ក្នុងនវសីវថិកាបព្វៈនោះ សតិដែលកំណត់ព្រៃជាទីចោលសាកសពទាំង ៩ ប្រការ ជាទុក្ខសច្ច តណ្ហាដែលមានក្នុងកាលមុន ដែលញុំាងសតិនោះឲ្យកើតឡើង ជាសមុទយសច្ច ការបញ្ឈប់ទុក្ខសច្ច និងសមុទយសច្ចទាំងពីរ ជានិរោធសច្ច អរិយមគ្គដែលកំណត់ទុក្ខ លះសមុទយ មាននិរោធជាអារម្មណ៍ ជាមគ្គសច្ច ។ យោគាវចរភិក្ខុ ខ្វល់ខ្វាយដោយអំណាចសច្ចៈយ៉ាងនេះ រមែងសម្រេចព្រះនិព្វាន រម្ងាប់ទុក្ខបាន ដូច្នេះ ។

នេះជាបដិបទានាំចេញចាកទុក្ខ ដរាបដល់អរហត្ត របស់ពួកភិក្ខុដែលកំណត់ព្រៃជាទីចោលសាកសពទាំង ៩ ប្រការ យ៉ាងនេះឯង ។

នវសីវថិកាបព្វៈ ចប់

កាយានុបស្សនា ១៤ បព្វៈ គឺអានាបាន ១ បព្វៈ ឥរិយាបថ ១ បព្វៈ ចតុសម្បជញ្ញៈ ១ បព្វៈ បដិកូលមនសិការ ១ បព្វៈ ធាតុមនសិការ ១ បព្វៈ នវសីវថិកា ១ បព្វៈ ចប់ហើយ ដោយពាក្យពណ៌នា មានប្រមាណប៉ុណ្ណេះ ។

*ក្នុង ១៤ បព្វៈនោះ អានាបានបព្វៈ និងបដិកូលមនសិការបព្វៈ ២ បព្វៈនេះប៉ុណ្ណេះ ជាអប្បនាកម្មដ្ឋាន ចំណែក ១២ បព្វៈដ៏សេស ជាឧបចារកម្មដ្ឋានតែម្យ៉ាង ព្រោះត្រាស់ទុកដោយការពិចារណាឃើញទោសនៃកាយដែលជាប់

ទាក់ទងដោយព្រៃជាទីចោលសាកសព ដូច្នេះឯង ។

កាយានុបស្សនាសតិបដ្ឋាន ចប់

វេទនានុបស្សនាសតិបដ្ឋាន

[๑๒๖] *ព្រះមានព្រះភាគ កាលត្រាស់កាយានុបស្សនាសតិបដ្ឋាន ๑๔ វិធី យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រាស់វេទនានុបស្សនា ๙ វិធី ទើបត្រាស់ថា* **កថញ្ច ភិក្ខវេ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **សុខំ វេទនំ** *សេចក្តីថា ភិក្ខុកំពុងសោយវេទនាដែលជាសុខផ្លូវកាយក្តី ផ្លូវចិត្តក្តី ក៏ដឹងច្បាស់ថា អញសោយសុខ-វេទនា ។ វិនិច្ឆ័យក្នុងពាក្យនោះ សូម្បីទារកដែលនៅដេកផ្ងារ កាលសោយសុខក្នុងគ្រាបៅទឹកដោះជាដើម ក៏ដឹងច្បាស់ថា អញសោយសុខវេទនាក៏ពិត ។ តែពាក្យថា សុខវេទនាជាដើមនេះ មិនបានត្រាស់សំដៅដល់សេចក្តីដឹងច្បាស់យ៉ាងនោះ ព្រោះការដឹងដូច្នោះ មិនលះការយើញថាសត្វ មិនដកការសម្គាល់ថាជាសត្វ មិនជាកម្មដ្ឋាន ឬសតិបដ្ឋានភាវនាឡើយ ។ ចំណែកសេចក្តីដឹងរបស់ភិក្ខុនេះ លះការយើញថាសត្វ ដកការសម្គាល់ថាជាសត្វបានផង ជាកម្មដ្ឋានផង ជាសតិបដ្ឋានភាវនាផង ។ ពាក្យនេះ ត្រាស់សំដៅដល់ការសោយសុខវេទនា ព្រមទាំងការដឹងខ្លួនយ៉ាងនេះថា អ្នកណាសោយ ការសោយរបស់អ្នកណា សោយព្រោះហេតុអ្វី ។*

វិនិច្ឆ័យក្នុងបញ្ហាទាំងនោះ សួរថា អ្នកណាសោយ ឆ្លើយថា មិនមែនសត្វ

ឬបុគ្គលណាមួយសោយ ។ សួរថា ការសោយរបស់អ្នកណា ឆ្លើយថា មិនមែនការសោយរបស់សត្វ ឬបុគ្គលណាមួយឡើយ ។ សួរថា សោយព្រោះហេតុអ្វី ឆ្លើយថា វេទនារបស់ភិក្ខុនោះ មានវត្ថុជាអារម្មណ៍តែម្យ៉ាង ហេតុនោះទើបលោកជីងយ៉ាងនេះថា សត្វទាំងឡាយសោយវេទនា ព្រោះធ្វើវត្ថុជាទីតាំងនៃវេទនា មានសុខវេទនាជាដើមនោះ។ ឲ្យជាអារម្មណ៍ ពាក្យថា អាត្មាអញសោយវេទនា ត្រឹមតែជាសន្ទត ព្រោះចាប់យកការប្រព្រឹត្តទៅនៃវេទនានោះ ។ ភិក្ខុកំណត់ថា សត្វទាំងឡាយសោយវេទនា ព្រោះធ្វើវត្ថុឲ្យជាអារម្មណ៍យ៉ាងនេះ គប្បីជ្រាបថា ភិក្ខុរមែងជីងច្បាស់ថា អញសោយសុខវេទនា ដូចព្រះថេរៈមួយរូប ដែលនៅត្រង់ចិត្តលបពិតដូច្នោះ ។

រឿងព្រះថេរៈសោយទុក្ខវេទនា

បានឮថា ព្រះថេរៈបម្រុងនៀល ដោយវេទនាខ្លាំងក្លា ក្នុងកាលមានអាពាធ ។ ភិក្ខុកំលោះមួយរូបសួរថា លោកម្ចាស់ឈឺត្រង់ណា ព្រះថេរៈឆ្លើយថា ប្រាប់កន្លែងឈឺមិនបានទេ ខ្ញុំធ្វើវត្ថុជាអារម្មណ៍សោយវេទនា ។ ភិក្ខុកំលោះសួរថា តាំងពីវេលាជីងច្បាស់យ៉ាងនោះ លោកម្ចាស់អត់សង្កត់មិនគួរឬ ព្រះថេរៈឆ្លើយថា អើខ្ញុំនឹងអត់សង្កត់ ។ ភិក្ខុកំលោះពោលថា អត់សង្កត់បានជាការល្អ ។ ព្រះថេរៈក៏អត់សង្កត់នូវទុក្ខវេទនា ។ រោគខ្យល់ ក៏ចាក់ដោតរហូតដល់បេះដូង ពោះវៀនរបស់ព្រះថេរៈក៏ចេញមកគរលើគ្រែ ។ ព្រះថេរៈបង្ហាញឲ្យភិក្ខុកំលោះមើល ហើយសួរថា អត់សង្កត់ប៉ុណ្ណេះល្មមទេ ។ភិក្ខុកំលោះក៏ស្ងៀម ។ ព្រះថេរៈក៏ប្រកបសេចក្តីព្យាយាមស្មើ សម្រេចអរហត្ត មួយអន្ទឹ

ដោយបដិសម្ភិទាទាំងឡាយ ជាព្រះអរហន្តសមសីសីបរិនិព្វានហើយ ។

មួយទៀត ភិក្ខុចម្រើនវេទនានុបស្សនាសតិប្បដ្ឋាននោះ សោយទុក្ខវេទនា ។បេ។ អទុក្ខមសុខវេទនាប្រាសចាកអាមិស ក៏ដឹងច្បាស់ថា អញសោយទុក្ខ វេទនា ។បេ។ អទុក្ខមសុខវេទនាប្រាសចាកអាមិស ដូចកាលលោកសោយ សុខវេទនានោះឯង ។

ព្រះមានព្រះភាគ កាលត្រាស់រូបកម្មដ្ឋាន ដោយប្រការដូច្នេះហើយ កាលត្រាស់អរូបកម្មដ្ឋាន តែព្រោះត្រាស់ដោយអំណាចផស្ស: ឬដោយអំណាច ចិត្ត កម្មដ្ឋានមិនប្រាកដច្បាស់ ប្រាកដដូចងងឹត ចំណែកការកើតឡើងនៃវេទនា ទាំងឡាយ ប្រាកដច្បាស់ កម្មដ្ឋានប្រាកដច្បាស់ ដោយអំណាចវេទនា ដូច្នោះ ទើបត្រាស់អរូបកម្មដ្ឋានដោយអំណាចវេទនា ក្នុងព្រះសូត្រនេះ ដូចក្នុងសក្ក-ប្បញ្ហសូត្រ ។ កថាមគ្គក្នុងព្រះសូត្រនេះ គប្បីជ្រាបដោយន័យដែលត្រាស់ ក្នុងសក្កប្បញ្ហសូត្រហើយនុ៉ះឯងថា ក៏កម្មដ្ឋានមាន ២ យ៉ាង គឺរូបកម្មដ្ឋាន និង អរូបកម្មដ្ឋាន ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវេទនានុបស្សនាសតិប្បដ្ឋាននោះ ក្នុងពាក្យថា សុខវេទនាដូច្នេះជាដើម មានបរិយាយនៃសេចក្តីដឹងច្បាស់ម្យ៉ាងទៀតដូច្នេះ បទថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** សេចក្តីថា កាលសោយសុខ-វេទនា ព្រោះខណៈសោយសុខវេទនា មិនមានទុក្ខវេទនា ក៏ដឹងច្បាស់ថា អញសោយសុខវេទនា ដូច្នេះ ។ ព្រោះដូច្នោះ ដែលឈ្មោះថា វេទនាមិនទៀង មិនស្ថិតស្ថេរ មានការប្រែប្រួលជាធម្មតា ព្រោះក្នុងខណៈដែលមិនមានទុក្ខ-

វេទនា ដែលជាប់មានមកពីមុន និងព្រោះមុននេះ ក៏មិនមានសុខវេទនានេះ ។ ភិក្ខុដឹងខ្លួនក្នុងសុខវេទនានោះយ៉ាងនេះ ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងទីឃនខសូត្រ មូលបណ្ណាសក: មជ្ឈិមនិកាយ ដូច្នេះថា ម្នាលអគ្គិវេស្សន: សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ ទទួលចំពោះតែសុខវេទនា ។ ម្នាលអគ្គិវេស្សន: សម័យណាបុគ្គលទទួលទុក្ខវេទនា ។បេ។ ទទួលអទុក្ខមសុខ-វេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ ទទួលចំពោះតែអទុក្ខមសុខវេទនា ។ ម្នាលអគ្គិវេស្សន: សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្ងាយទៅ ទាំងមានកិរិយារលត់ទៅវិញជាធម្មតា ។ ម្នាលអគ្គិវេស្សន: ទុក្ខវេទនា ក៏ជារបស់មិនទៀង ។បេ។ ម្នាលអគ្គិវេស្សន: សូម្បីអទុក្ខមសុខវេទនា ក៏ជារបស់មិនទៀង ។បេ។ មានកិរិយារលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សន: អរិយសាវ័កអ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខវេទនាផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេស កាលចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះ មិនមានឡើយ។

วินิจฺฉัยกฺนฺ̊ตฺงบทថា **สามิสํ วา สุขំ** *ជាដើម សោមនสฺสเวทนา อาស្រัยអាមิส គឺកามคุณ ๕ อาស្រัยផ្ទះ ๖ ឈ្មោះថา สามิสสุข-เวทนา សោមនสฺสเวทนาអាស្រัยនេក្ខម្មៈ ๖ ឈ្មោះថา นิรามิสสุขเวทนา โทมนสฺสเวทนาអាស្រัยផ្ទះ ๖ ឈ្មោះថา สามิสทุกฺขเวทนา โทมนสฺส-เวทนาអាស្រัยនេក្ខម្មៈ ๖ ឈ្មោះថา นิรามิสทุกฺขเวทนา อุเปกฺขาเวทนา អាស្រัยផ្ទះ ๖ ឈ្មោះថา สามิสอทุกฺขมสุขเวทนา อุเปกฺขาដែលអាស្រัย នេក្ខម្មៈ ๖ ឈ្មោះថา นิรามิสอทุกฺขมสุขเวทนา ฯ ម្យ៉ាងទៀត การចែก เวทนาទាំងនេះ លោកពោលក្នុងสกฺกปญฺหสูตรហើយនោះឯង ฯ*

บทថา **สติ อฏฺฐงฺคเม วา** *សេចក្តីថา พิจารณาเห็นเวทนา ក្នុងเวทนา ទាំងឡាយរបស់ខ្លួនក្តី ក្នុងเวทนาទាំងឡាយរបស់អ្នកដទៃក្តី ក្នុងเวทนาទាំង-ឡាយរបស់ខ្លួនតามกาล របស់អ្នកដទៃតามกาลក្តី ដោយการกำណត់สุข-เวทนាជាដើមយ៉ាងនេះ ฯ ចំណែកក្នុងบทថา* **สมุทยธมฺมานุปสฺสี วา** *នេះ มានวินิจฉัยថา ภิกฺขุกาลเห็นการเกิด និងการสูญទៅនៃเวทนาទាំងឡាย ដោយអาการមួយ ទីមួយ ๕ យ៉ាងថา ព្រោះអวิชฺชาเกิด ទើបเวทนาเกิดដូច្នេះ ជាដើម គប្បីជ្រាបថา ภิกฺขุพิจารณาเห็นธรรม គឺการเกิดក្នុងเวทนาទាំងឡาย พิจารณาเห็นธรรม គឺการสูญទៅក្នុងเวทนาទាំងឡาย ឬพิจารณาเห็นธรรม គឺการเกิดក្នុងเวทนาទាំងឡายตามกาล พิจารณาเห็นธรรม គឺการสูญទៅក្នុងเวทนาទាំងឡายตามกาล ฯ ប្រการតអំពីនេះទៅ ก็มานัย ដូចដែលពោលមកហើយក្នុងกายานุปสฺสนានុ៎ះឯង ฯ*

ក្នុងវេទនានុបស្សនានេះ មានសេចក្តីផ្សេងគ្នាតែម៉្យាង គឺគប្បីប្រកបសេចក្តីយ៉ាងនេះថា សតិដែលកំណត់វេទនាជាអារម្មណ៍ ជាទុក្ខសច្ចជាដើម ហើយគប្បីជ្រាបថា ជាបដិបទានាំចេញចាកទុក្ខរបស់កិក្ខុដែលកំណត់វេទនាជាអារម្មណ៍ ។ ពាក្យដ៏សេសក៏មានសេចក្តីដូច្នោះដូចគ្នា ។

វេទនានុបស្សនាសតិប្បដ្ឋាន ចប់

ចិត្តានុបស្សនាសតិប្បដ្ឋាន

[๑๒๗] *ព្រះមានព្រះភាគ កាលត្រាស់វេទនានុបស្សនាសតិប្បដ្ឋាន ๙ វិធី យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រាស់ចិត្តានុបស្សនា ๑๖ វិធី ទើបត្រាស់ថា* **កថញ្ច ភិក្ខវេ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **សរាគំ** *គឺចិត្តដែលសហគតៈដោយលោភៈ ๘ ។ បទថា* **វីតរាគំ** *គឺចិត្តដែលជាកុសល និងអព្យាកតផ្នែកលោកិយ ។ តែប្រការនេះ ជាការពិចារណា មិនមែនជាការប្រជុំធម៌ ព្រោះដូច្នោះ ក្នុងពាក្យថា* **សរាគំ** *នេះ ទើបមិនមែនជាលោកុត្តរចិត្ត សូម្បីតែមួយបទ ។ អកុសលចិត្ត ๘ ដួងដ៏សេស ទើបមិនចូលនឹងបទដើម មិនចូលនឹងបទក្រោយ ។ បទថា* **សទោសំ** *បានដល់ ចិត្ត ๒ ដួង ដែលសហគតៈដោយទោមនស្ស ។ បទថា* **វីតទោសំ** *បានដល់ ចិត្តដែលជាកុសល និងអព្យាកតផ្នែកលោកិយ ។ អកុសលចិត្ត ๑๐ ដួងដ៏សេស មិនចូលបទដើម មិនចូលបទក្រោយ ។ បទថា*

สเหตุกำ បានដល់ ចិត្ត ២ ដួង គឺចិត្តដែលសហគត:ដោយវិចិកិច្ឆា ១ ដែលសហគត:ដោយឧទ្ធច្ចៈ ១ ។ តែព្រោះមោហៈ រមែងកើតបានក្នុងអកុ-សលចិត្តទាំងអស់ ដូច្នោះ សូម្បីអកុសលចិត្តដ៏សេស ក៏គួរបានក្នុងបទថា **សเหตุกำ** នេះដោយពិត ។ ពិតហើយ អកុសលចិត្ត ១២ សង្គ្រោះក្នុងទុក: នេះប៉ុណ្ណោះ ។ បទថា **วิตเหตุกำ** បានដល់ ចិត្តដែលជាកុសល និងអព្យាកត ផ្នែកលោកិយ ។ បទថា **สวิจฺจำ** បានដល់ ចិត្តដែលធ្លាក់ទៅក្នុងបីនមិទ្ធៈ ។ ចិត្តដែលធ្លាក់ទៅក្នុងបីនមិទ្ធៈនោះ ឈ្មោះថា **สวิจฺจำ** ។ បទថា **วิกิณฺณำ** បានដល់ ចិត្តដែលកើតព្រមដោយឧទ្ធច្ចៈ ។ ចិត្តដែលកើតព្រមដោយឧទ្ធច្ចៈនោះ ឈ្មោះ ថា **วิกิณฺณำ** ។ បទថា **มหคฺคตำ** បានដល់ ចិត្តដែលជារូបាវចរ និងអរូបាវចរ ។ បទថា **อมหคฺคตำ** បានដល់ ចិត្តដែលជាកាមាវចរ ។ បទថា **สอุตฺตรำ** បាន ដល់ ចិត្តដែលជាកាមាវចរ ។ បទថា **อนุตฺตรำ** បានដល់ ចិត្តដែលជារូបាវចរ និងអរូបាវចរ ។ សូម្បីក្នុងចិត្តទាំងនោះ ចិត្តដែលឈ្មោះថា សឧត្តរ បានដល់ ចិត្តជារូបាវចរ ចិត្តឈ្មោះថា អនុត្តរ បានដល់ ចិត្តដែលជាអរូបាវចរ ។ បទថា **สมาหิตำ** បានដល់ អប្បនាសមាធិ ឬឧបចារសមាធិ ។ បទថា **อสมาหิตำ** បានដល់ ចិត្តដែលវៀរចាកសមាធិទាំងពីរ ។ បទថា **วิมุตฺตำ** បានដល់ ចិត្តរួចផុតដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ។ បទថា **อวิมุตฺตำ** បាន ដល់ ចិត្តដែលវៀរចាកវិមុត្តិទាំងពីរ ។ ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិ វិមុត្តិ និងនិស្សរណវិមុត្តិ មិនមានឱកាស ក្នុងបទនេះឡើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** *សេចក្តីថា យោគាវចរភិក្ខុកំណត់ចិត្ត ដែលប្រព្រឹត្តទៅក្នុងសម័យណាមួយ ដោយការកំណត់ចិត្ត មានរាគៈជាដើម យ៉ាងនេះឈ្មោះថា ពិចារណាឃើញចិត្តក្នុងចិត្តរបស់ខ្លួនក្តី ក្នុងចិត្តរបស់អ្នកដទៃក្តី ក្នុងចិត្តរបស់ខ្លួនតាមកាលក្តី ក្នុងចិត្តរបស់អ្នកដទៃតាមកាលក្តី ។ ក្នុងបទថា* **សមុទយធម្មានុបស្សី** *គប្បីនាំការកើត និងការសូន្យទៅនៃវិញ្ញាណ មកប្រៀបធៀបដោយអាការនីមួយ ៥ យ៉ាងថា ព្រោះអវិជ្ជាកើត ទើបវិញ្ញាណកើតដូច្នេះជាដើម ។ បទបន្ទាប់អំពីនេះទៅ មានន័យដូចនោះឯង ។*

តែក្នុងចិត្តានុបស្សនាសតិប្បដ្ឋាននេះ មានសេចក្តីផ្សេងគ្នាតែម្យ៉ាង គឺគប្បីប្រកបសេចក្តីថា សតិដែលកំណត់ចិត្តជាអារម្មណ៍ ជាទុក្ខសច្ចដូច្នេះជាដើម ហើយគប្បីជ្រាបថា ជាបជិបទានាំចេញចាកទុក្ខ របស់ភិក្ខុដែលកំណត់ចិត្តជាអារម្មណ៍ ។ ពាក្យដ៏សេសក៏ដូចគ្នានុ៎ះឯង ។

ចិត្តានុបស្សនាសតិប្បដ្ឋាន ចប់

ធម្មានុបស្សនាសតិប្បដ្ឋាន

[๑๒๘] *ព្រះមានព្រះភាគ កាលត្រាស់ចិត្តានុបស្សនាសតិប្បដ្ឋាន ១៦ វិធី យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រាស់ធម្មានុបស្សនា ៥ វិធី ទើបត្រាស់ថា* **កថញ្ច ភិក្ខវេ** *ជាដើម ។*

ម្យ៉ាងទៀត ព្រះមានព្រះភាគ ត្រាស់ការកំណត់រូបកម្មដ្ឋានសុទ្ធ ដោយកាយានុបស្សនា ត្រាស់ការកំណត់អរូបកម្មដ្ឋានសុទ្ធៗ ដោយវេទានុបស្សនា

និងចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីត្រាស់ការកំណត់រូបកម្មដ្ឋាន និង អរូបកម្មដ្ឋានលាយគ្នា ទើបត្រាស់ថា **កថញ្ច ភិក្ខវេ** *ជាដើម ។*

ម្យ៉ាងទៀត ព្រះសាស្តា ត្រាស់ការកំណត់រូបក្ខន្ធដោយកាយានុបស្សនា ត្រាស់ការកំណត់វេទនាខន្ធដោយវេទនានុបស្សនា ត្រាស់ការកំណត់វិញ្ញាណក្ខន្ធ ដោយចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីត្រាស់ការកំណត់សញ្ញាខន្ធ និង សង្ខារក្ខន្ធ ទើបត្រាស់ថា **កថញ្ច ភិក្ខវេ** *ជាដើម ។*

នីវរណាបញ្ហៈ

បណ្តាបទទាំងនោះ បទថា **សន្តំ** *គឺនៅព្រមដោយអំណាចផ្សាយទៅឯរឿយៗ ។ បទថា* **អសន្តំ** *គឺមិនមានព្រម ព្រោះមិនផ្សាយទៅឯ ឬព្រោះលះបានហើយ ។ បទថា* **យថា ច** *សេចក្តីថា កាមច្ឆន្ទៈ កើតទៅឯព្រោះហេតុណា ។ បទថា* **តញ្ច បជានាតិ** *គឺដឹងច្បាស់ហេតុនោះ ។ គ្រប់ៗ បទ គប្បីជ្រាបអត្ថដោយនយនេះឯង ។*

ក្នុងនិមិត្តទាំងពីរនោះ កាមច្ឆន្ទៈ រមែងកើតទៅឯ ព្រោះអយោនិសោ-មនសិការក្នុងសុភនិមិត្ត ។ វត្ថុដែលស្អាតក្តី អារម្មណ៍ដែលល្អក្តី ឈ្មោះថា សុភនិមិត្ត ។ ការធ្វើទុកក្នុងចិត្តដោយអយោនិសោមនសិការ ការធ្វើទុកក្នុង ចិត្តក្នុងវត្ថុដែលមិនទៀង ថាទៀង ក្នុងវត្ថុដែលជាទុក្ខ ថាសុខ ក្នុងវត្ថុដែល មិនមែនខ្លួន ថាខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាស្អាត ឈ្មោះថា អយោ-និសោមនសិការ ។ កាលភិក្ខុធ្វើអយោនិសោមនសិការនោះ ឲ្យប្រព្រឹត្តទៅ

ច្រើនៗ ក្នុងសុភនិមិត្តនោះ កាមច្ឆន្ទៈ រមែងកើតឡើង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តរមែងមានក្នុងការធ្វើទុកក្នុងចិត្តខុសទំនង និងធ្វើឲ្យក្រាស់ក្រែលក្នុងសុភនិមិត្តនោះ នុ៎ះជាអាហារដែលញុំាងកាមឆន្ទៈមិនទាន់កើតឡើង ឲ្យកើតឡើង ឬញុំាងកាមឆន្ទៈ ដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ដូច្នេះ ។

ចំណែកកាមច្ឆន្ទៈនោះ នីវរណៈបាន ក៏ដោយយោនិសោមនសិការក្នុងអសុភនិមិត្ត ។ វត្ថុដែលមិនស្អាតក្តី អារម្មណ៍ដែលមិនល្អក្តី ឈ្មោះថាអសុភនិមិត្ត ។ ការធ្វើទុកក្នុងចិត្តដោយខុសប្បាយ ការធ្វើទុកក្នុងចិត្តត្រូវផ្លូវ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាមិនទៀង ក្នុងវត្ថុដែលជាទុក្ខ ថាទុក្ខ ក្នុងវត្ថុដែលមិនមែនខ្លួន ថាមិនមែនខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាមិនស្អាត ឈ្មោះថា យោនិសោមនសិការ ។ កាលភិក្ខុធ្វើយោនិសោមនសិការនោះ ឲ្យប្រព្រឹត្តទៅច្រើនៗ ក្នុងអសុភនិមិត្តនោះ រមែងលះកាមច្ឆន្ទៈចេញបាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ មានតែអសុភនិមិត្ត និងការធ្វើទុកយោនិសោមនសិការឲ្យច្រើនក្នុងអសុភនិមិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់កាមច្ឆន្ទៈ ដែលកើតហើយ ឲ្យរីងរឹតតែចម្រើនឡើង ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺកាន់យកអសុភនិមិត្តជាអារម្មណ៍ ១ ប្រកបរឿយៗ នូវអសុភភាវនា ១ រក្សាទ្វារ

ក្នុងឥន្ទ្រិយទាំង៦ប្រាយ ១ ស្គាល់ប្រមាណក្នុងភោជន ១ សេពគប់កល្យាណមិត្ត ១ សប្បាយកថា ១ ។ ពិតហើយ កាលភិក្ខុកំណត់អសុភនិមិត្ត ១០ ក៏លះកាមច្ឆន្ទៈបាន ។ កាលចម្រើនអសុភ ១០ ក្តី កាលបិទទ្វារក្នុងឥន្ទ្រិយទាំង-៦ប្រាយក្តី ស្គាល់ប្រមាណក្នុងភោជន ព្រោះកាលមានឱកាសនឹងបរិភោគ ៤-៥ ដុំទៀត ក៏ផឹកទឹក ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅ រមែងលះកាមច្ឆន្ទៈបាន ព្រោះហេតុនោះ ទើបព្រះសារីបុត្រពោលទុកក្នុងទុកនិកាយ ថេរគាថាថា

ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ

អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ ។

ភិក្ខុឈប់បរិភោគ ៤-៥ ពុំនូត ក្នុងកាលជិតឆ្អែត ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុះទៅរកព្រះនិព្វាន ។

សូម្បីភិក្ខុដែលសេពកល្យាណមិត្ត ដែលជាអ្នកត្រេកអរក្នុងការចម្រើនអសុភ ដូចព្រះតិស្សត្ថេរ អ្នកចម្រើនអសុភកម្មដ្ឋាន រមែងលះកាមច្ឆន្ទៈបាន ។ សូម្បីដោយការចរចាប្រារព្ធរឿងជាទីសប្បាយ ដែលអាស្រ័យអសុភ ១០ ក្នុងឥរិយាបថឈរ និងអង្គុយជាដើម រមែងលះកាមច្ឆន្ទៈបាន ព្រោះហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា កាមច្ឆន្ទៈដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ រមែងមិនកើតតទៅទៀត ដោយអរហត្តមគ្គ ។

ចំណែកព្យាបាទ រមែងកើតព្រោះអយោនិសោមនសិការក្នុងបដិឃ-និមិត្ត ។ បដិឃៈក្តី អារម្មណ៍ដែលឲ្យកើតបដិឃៈក្តី ឈ្មោះថា បដិឃនិមិត្ត

ក្នុងពាក្យថា បដិយនិមិត្តជាដើមនោះ ។ អយោនិសោមនសិការមានលក្ខណៈតែម្យ៉ាងដូចគ្នាក្នុងធម៌ទាំងពួង ។ កាលភិក្ខុធ្វើអយោនិសោមនសិការនោះឲ្យប្រព្រឹត្តទៅច្រើនៗ ក្នុង (បដិយៈ) និមិត្តនោះ ព្យាបាទរមែងកើត ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា

> *ម្នាលភិក្ខុទាំងឡាយ បដិយនិមិត្តរមែងមានការធ្វើទុកក្នុងចិត្ត ខុសទំនង និងធ្វើឲ្យក្រាស់ក្រែលក្នុងបដិយនិមិត្តនោះ នេះជាអាហារ ដែលញុំាងព្យាបាទមិនទាន់កើតឡើង ឲ្យកើតឡើង ឬញុំាងព្យាបាទដែលកើតឡើងហើយ ឲ្យរីងរឹតតែកើតធំទូលាយទៅ ដូច្នេះ ។*

តែព្យាបាទនោះ នឹងលះបានដោយយោនិសោមនសិការក្នុងមេត្តាចេតោវិមុត្តិ ។ ក្នុងពាក្យថា មេត្តាចេតោវិមុត្តិនោះ កាលពោលដល់មេត្តារមែងគួរទាំងអប្បនា ទាំងឧបចារៈ ។ ពាក្យថា មេត្តាចេតោវិមុត្តិ បានដល់អប្បនាយោនិសោមនសិការ មានលក្ខណៈដូចពោលហើយ ។ កាលភិក្ខុធ្វើយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើនៗ ក្នុងមេត្តាចេតោវិមុត្តិនោះ រមែងលះព្យាបាទបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា

> *ម្នាលភិក្ខុទាំងឡាយ មានតែមេត្តាចេតោវិមុត្តិ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងមេត្តាចេតោវិមុត្តិនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ព្យាបាទ ដែលមិនទាន់*

កើត ឲ្យកើតឡើងបាន ឬរបស់ព្យាបាទដែលកើតហើយ ឲ្យរីងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺកំណត់និមិត្តក្នុងមេត្តាជាអារម្មណ៍ ១ ប្រកបរឿយៗ នូវមេត្តាភាវនា ១ ពិចារណាដល់សត្វមានកម្មជារបស់ខ្លួន ១ ធ្វើឲ្យច្រើននូវការពិចារណា ១ សេពគប់កល្យាណមិត្ត ១ សប្បាយកថា ១ ។

ពិតហើយ កាលកិក្ខុកំណត់មេត្តាកម្មដ្ឋាន ដោយការផ្សាយមេត្តាសព្វទិស ដោយចំពោះ ឬមិនចំពោះយ៉ាងណាមួយ រមែងលះព្យាបាទបាន ។ កាលកិក្ខុចម្រើនមេត្តា ដោយផ្សាយទូទៅសព្វទិស ដោយចំពោះក្តី មិនចំពោះក្តី កាលពិចារណាដល់ភាពនៃខ្លួន និងអ្នកដទៃ មានកម្មជារបស់ខ្លួនយ៉ាងនេះថា ឯងក្រោធបុគ្គលនោះ នឹងធ្វើអ្វីបុគ្គលនោះបាន ឯងអាចកម្ចាត់សីលជាដើមរបស់បុគ្គលឲ្យវិនាសបានឬ ឯងមកហើយដោយកម្មរបស់ខ្លួន នឹងទៅដោយកម្មរបស់ខ្លួនទុំៈឯង ដែលឈ្មោះថា ការក្រោធនឹងអ្នកដទៃ ក៏ដូចគ្នានឹងបុគ្គលប្រាថ្នាចាប់រងើកភ្លើងដ៏ច្រាលឆ្អៅ ដុំដែកដ៏ក្តៅ និងចាប់ឧច្ចារៈជាដើម យកទៅប្រហារអ្នកដទៃដូច្នោះ ឬបើបុគ្គលនោះក្រោធនឹងឯង តើនឹងធ្វើអ្វីបានបុគ្គលនោះអាចធ្វើសីលជាដើមរបស់ឯងឲ្យវិនាសបានឬ បុគ្គលនោះមកដោយកម្មរបស់ខ្លួន ក៏នឹងទៅតាមកម្មរបស់ខ្លួនទុំៈឯង សេចក្តីក្រោធនោះ នឹងជាក់លើអំបែងក្បាលរបស់បុគ្គលទុំៈឯង ដូចប្រហារអ្នកមិនប្រហារតប និងដូចនាំធូលីបាចទៅក្នុងទីច្រាសខ្យល់ដូច្នោះ យ៉ាងនេះក្តី កាលពិចារណាកម្មស្សកតាទាំង

ពីរ បញ្ឈប់ក្នុងការពិចារណាក្តី សេពគប់កល្យាណមិត្ត អ្នកត្រេកអរក្នុងការចម្រើនមេត្តា ដូចព្រះអស្សគុត្តត្ថេរក្តី រមែងលះព្យាបាទបាន ។ ដោយការចរចារឿងដែលជាទីសប្បាយដែលអាស្រ័យមេត្តា ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះព្យាបាទបាន ។ ព្រោះហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះព្យាបាទ ដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ព្យាបាទដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ រមែងមិនកើតតទៅដោយអនាគាមិមគ្គ ។

ថីនមិទ្ធៈ រមែងកើតដោយអយោនិសោមនសិការក្នុងធម៌ទាំងឡាយ មានអរតិជាដើម ។ សេចក្តីមិនត្រេកអរនឹងបុគ្គលណាមួយ ឈ្មោះថា **អរតិ** *។ សេចក្តីខ្ជិលច្រអូសផ្លូវកាយ ឈ្មោះថា* **តន្ទិ** *។ ការមើតពត់កាយ ឈ្មោះថា* **វិជម្ភិកា** *។ សេចក្តីស្រេវឹងព្រោះអាហារ សេចក្តីក្រវល់ក្រវាយព្រោះអាហារ ឈ្មោះថា* **ភត្តសម្មទៈ** *។ អាការ គឺការរួញរានៃចិត្ត ឈ្មោះថា* **ចេតសោ លីនត្តំ** *។ កាលភិក្ខុធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើនក្នុងអរតិជាដើមនេះ ថីនមិទ្ធៈ រមែងកើត ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ទុកក្នុង សំយុត្តនិកាយ មហាវារវគ្គថា*

> *ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនត្រេកអរ ខ្ជិល មើតពត់កាយ ពុលបាយ រួញរាចិត្ត និងការធ្វើនូវអយោនិសោមនសិការឲ្យច្រើន ក្នុងសេចក្តីមិនត្រេកអរជាដើមនោះ នេះធម៌ជាអាហាររបស់ ថីនមិទ្ធៈ ដែលមិនទាន់កើត ឲ្យកើត*

ទ្បើងបាន ឬរបស់ចីនមិទ្ធៈ ដែលកើតហើយ ឲ្យរីងរឹតតែកើតច្រើនទ្បើង ដូច្នេះ ។

ចីនមិទ្ធៈ នីឝលះបានដោយយោនិសោមនសិការក្នុងធម៌ទាំងឡាយ មានអារព្ភធាតុជាដើម ។ ការផ្ដួចផ្ដើម ឈ្មោះថា **អារព្ភធាតុ** *។ ការខ្នះខ្នែងដែលមានកម្លាំងជាងអារព្ភធាតុនោះ ព្រោះចេញទៅផុតពីសេចក្ដីខ្ជិលច្រអូសហើយ ឈ្មោះថា* **និក្កមធាតុ** *។ ការប្រឹងប្រែងដែលមានកម្លាំងក្រៃលែងជាងនិក្កមធាតុនោះ ព្រោះកន្ទងហាន:ដទៃៗ ឈ្មោះថា* **បរក្កមធាតុ** *។ កាលភិក្ខុធ្វើយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន ក្នុងសេចក្ដីព្យាយាម ៣ ប្រភេទនេះ រមែងលះចីនមិទ្ធៈបាន ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា*

ម្នាលភិក្ខុទាំងឡាយ មានតែការតាំងផ្ដើម ការខ្នះខ្នែង ការប្រឹងប្រែង និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងការតាំងផ្ដើមជាដើមនោះ នេះធម៌ មិនមែនជាអាហាររបស់ចីនមិទ្ធៈ ដែលមិនទាន់កើត ឲ្យកើតទ្បើងបាន ឬរបស់ចីនមិទ្ធៈ ដែលកើតហើយ ឲ្យរីងរឹតតែកើតច្រើនទ្បើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះចីនមិទ្ធៈ គឺកំណត់និមិត្តក្នុងភោជនដែលលើសប្រមាណ ១ ផ្ទាស់ប្ដូរឥរិយាបថ ១ ធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា ១ នៅក្នុងទីស្រឡះ ១ សេពគប់កល្យាណមិត្ត ១ សប្បាយកថា ១ ។

ព្រោះថា កាលភិក្ខុបរិភោគភោជន ដូចព្រាហ្មណ៍ ដែលឈ្មោះអាហារ-ហត្ថក: ដែលឈ្មោះតត្រវដ្ដក: ដែលឈ្មោះអលំសាដក: ដែលឈ្មោះកាក-មាសក: និងដែលឈ្មោះកុត្តវមិតក: អគ្គិយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ឋីនមិទ្ធ:រមែងមកគ្របសង្កត់ បានដូចដីរដ៏ធំតែឋីនមិទ្ធ:នោះ នឹងមិនមានដល់ភិក្ខុដែលវៀរឱកាសបរិភោគ ๔-๕ ដុំហើយផឹកទឹក ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតី ព្រោះហេតុនោះ កាលភិក្ខុកំណត់និមិត្ត ក្នុងភោជនដែលលើសយ៉ាងនេះ រមែងលះឋីនមិទ្ធ:បាន កាលភិក្ខុកើតឋីនមិទ្ធ:ក្នុងឥរិយាបថណា ផ្ទាស់ប្ដូរឥរិយាបថដទៃអំពីឥរិយាបថនោះ ក៏លះឋីនមិទ្ធ:បាន ។ កាលភិក្ខុជាក់ចិត្តក្នុងពន្លឺព្រះចន្ទ ពន្លឺប្រទីប ពន្លឺគប់ភ្លើងក្នុងវេលារាត្រី ពន្លឺព្រះអាទិត្យវេលាពេលថ្ងៃក្ដី នៅក្នុងទីស្រឡះក្ដី សេពកល្យាណមិត្តអ្នកលះឋីនមិទ្ធ:បាន ដូចព្រះមហាកស្សបត្ថេរក្ដី រមែងលះឋីន-មិទ្ធ:បាន ។ សូម្បីដោយការចរចាតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យធុតង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរ អគ្គិយជាដើម ក៏លះឋីនមិទ្ធ:បាន ។ ព្រោះដូច្នោះ ទើបលោកពោលថា ធម៌ ๖ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីលះឋីនមិទ្ធ: ។ ភិក្ខុរមែងជីងច្បាស់ថា ឋីនមិទ្ធ:ដែលលះបានដោយធម៌ ๖ ប្រការ និងមិនកើតតទៅដោយអរហត្តមគ្គ ដូច្នេះ ។

*ឧទ្ធច្ចកុក្កុច្ច: រមែងកើតដោយអយោនិសោមនសិការ ក្នុងការមិនស្ងប់នៃចិត្ត ។ អាការដែលមិនស្ងប់ ឈ្មោះថា **អវូបសម** ។ ពាក្យនេះ ដោយអត្ត គឺឧទ្ធច្ចកុក្កុច្ច:នុ៎ះឯង ។ កាលភិក្ខុធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន*

ក្នុងសេចក្តីមិនស្ងប់នៃចិត្តនោះ ឧទ្ធច្ចកុក្កុច្ចៈរមែងកើត ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា

ម្នាលភិក្ខុទាំងឡាយ មានតែការមិនស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវអយោនិសោមនសិការឲ្យច្រើន ក្នុងការមិនស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

តែឧទ្ធច្ចកុក្កុច្ចៈនេះ នឹងលះបាន ដោយយោនិសោមនសិការក្នុងសេចក្តីស្ងប់នៃចិត្ត ពោល គឺសមាធិ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា

ម្នាលភិក្ខុទាំងឡាយ មានតែការស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងការស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈ ដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ ភាពជាពហុសូត ១ ភាពជាអ្នកសាកសួរដោយជុំវិញ ១ ជំនាញក្នុងវិន័យ ១ សេពគប់រកបុគ្គលដែលចម្រើន ១ មានកល្យាណមិត្ត ១ សប្បាយកថា ១ ។

ពិតហើយ កាលភិក្ខុសិក្សារៀនសូត្រទាំងបាលី ទាំងអដ្ឋកថាក្នុង ១ និកាយ

១ ក្តី ២ និកាយក្តី ៣ និកាយក្តី ៤ និកាយក្តី ៥ និកាយក្តី រមែងលះ ខន្ធចក្កុក្កុច:បាន ដោយភាពជាពហូសូតយ៉ាងនេះ ។ កិក្ខុដែលច្រើនដោយ ការសាកសួរវត្ថុដែលគួរ និងមិនគួរក្តី ដែលជំនាញ ព្រោះមានភាពជំនាញ ដែលសន្សំទុកក្នុងវិនយប្បញ្ញត្តិក្តី ដែលចូលទៅរកព្រះថេរ:ក្តី អ្នកចម្រើន ដោយវ័យក្តី សេពគប់កល្យាណមិត្តអ្នកទ្រទ្រង់វិនយ ដូចព្រះឧបាលិត្ថេរក្តី រមែងលះខន្ធចក្កុក្កុច:បាន ។ ដោយការចរចាតែរឿងដែលជាទីសប្បាយ ដែល អាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយ ជាដើម ក៏លះខន្ធចក្កុក្កុច:បាន ។ ព្រោះដូច្នោះ ទើបលោកពោលថា ធម៌ ៦ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីលះខន្ធចក្កុក្កុច: ។ កិក្ខុរមែងជឿងច្បាស់ថា កាលខន្ធចក្កុក្កុច:លះបានហើយដោយធម៌ ៦ ប្រការនេះ ខន្ធច:នឹងមិនកើត តទៅ ដោយអរហត្តមគ្គ កុក្កុច:មិនកើតតទៅ ដោយអនាគាមិមគ្គ ។

វិចិកិច្ឆា រមែងកើតបានដោយអយោនិសោមនសិការក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃវិចិកិច្ឆា ។ សេចក្តីងឿងឆ្ងល់ ព្រោះជាហេតុនៃសេចក្តីសង្ស័យ រឿយៗ ឈ្មោះថា **វិចិកិច្ឆដ្ឋានីយាធម្មា** *គឺធម៌ដែលជាទីតាំងនៃវិចិកិច្ឆា ។ កាលកិក្ខុធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន វិចិកិច្ឆដ្ឋានីយធម៌នោះ វិចិកិច្ឆារមែងកើត ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុង សំយុត្តនិកាយ មហាវារវគ្គថា*

*ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយ ដែលបណ្តាលឲ្យកើតវិចិកិច្ឆា និងការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហារ

របស់វិចិកិច្ឆា ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរីងរីតតែកើតច្រើនឡើង ដូច្នេះ ។

វិចិកិច្ឆានេះ លះបានដោយយោនិសោមនសិការក្នុងធម៌ មានកុសលជាដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុងសំយុត្តនិកាយ មហាវារវគ្គថា

ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសល និងអកុសល ពួកធម៌ដែលប្រកបដោយទោស និងឥតទោស ពួកធម៌ដែលថោកទាប និងថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅ និងស និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់វិចិកិច្ឆា ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរីងរីតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺភាពជាពហូសូត ១ ភាពជាអ្នកសាកសួរដោយជុំវិញ ១ ភាពជាអ្នកជំនាញក្នុងវិនយ ១ ច្រើនដោយអធិមោក្ខ គឺការបង្អោនចិត្តជឿ ១ មានកល្យាណមិត្ត ១ សប្បាយកថា ១ ។

ពិតហើយ កាលភិក្ខុសិក្សារៀនសូត្រទាំងបាលី ទាំងអដ្ឋកថា ក្នុង ១ និកាយក្តី ២ និកាយក្តី ៣ និកាយក្តី ៤ និកាយក្តី ៥ និកាយក្តី រមែងលះវិចិកិច្ឆាបានដោយភាពជាពហូសូត ។ កាលភិក្ខុច្រើនដោយការប្រារព្ធព្រះរតន-ត្រ័យ សាកសួរដោយជុំវិញក្តី មានភាពជំនាញដែលសន្សំទុកក្នុងវិនយក្តីច្រើន

ទៅដោយអធិមោក្ខ គឺសទ្ធាដែលនៅកម្រើកក្នុងព្រះរតនត្រ័យក្តី សេពគប់
កល្យាណមិត្ត ដូចព្រះវក្កលិអ្នកបង្អោនចិត្តទៅក្នុងសទ្ធាក្តី រមែងលះវិចិកិច្ចា
បាន ។ សូម្បីដោយការចរចាតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យគុណ
របស់ព្រះរតនត្រ័យ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះ
វិចិកិច្ចាបាន ព្រោះហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែង
ប្រព្រឹត្តទៅដើម្បីលះវិចិកិច្ចា ។ ភិក្ខុរមែងដឹងច្បាស់ថា វិចិកិច្ចាដែលលះបាន
ដោយធម៌ទាំងនេះ រមែងមិនកើតតទៅ ដោយសោតាបត្តិមគ្ត ដូច្នេះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំង-
ឡាយរបស់ខ្លួនផង ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃផង ក្នុងធម៌ទាំងឡាយ
របស់ខ្លួនតាមកាល និងរបស់អ្នកដទៃតាមកាលផង ដោយការកំណត់នីវរណៈ
៥ យ៉ាងនេះ ។ ការកើត និងការសូន្យទៅ ក្នុងបទថា ពិចារណាឃើញនូវ
ធម៌ដែលជាទីប្រជុំកើត ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតីនេះ
ដែលពោលហើយ ក្នុងនីវរណៈ ៥ ដោយអំណាចអយោនិសោមនសិការ និង
យោនិសោមនសិការក្នុងសុភនិមិត្ត និងអសុភនិមិត្តជាដើម បណ្ឌិតគប្បីនាំមក
ប្រៀបធៀបចុះ ។ បទតទៅ ក៏មានន័យដូចពោលមកហើយនោះឯង ។

ក្នុងនីវរណបញ្ចៈនេះ មានការផ្សេងគ្នាតែម្យ៉ាង គឺគប្បីប្រកបសេចក្តីថា
សតិដែលកំណត់នីវរណៈជាអារម្មណ៍ ជាទុក្ខសច្ច គប្បីជ្រាបថា ជាបដិបទា
នាំចេញចាកទុក្ខរបស់ភិក្ខុដែលកំណត់នីវរណៈជាអារម្មណ៍ ។ ពាក្យដ៏សេស
ក៏មានន័យដូចគ្នា ។

នីវរណបញ្ចៈ ចប់

ខន្ធបញ្ចៈ

[๑๒๙] ព្រះសាស្តា កាលទ្រង់ចែកធម្មានុបស្សនា ដោយនីវរណៈ ๕ នេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយខន្ធ ๕ ទើបត្រាស់ថា **បុន ចបរំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បញ្ចសុ ឧបាទានក្ខន្ធេសុ** គឺកងឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ អធិប្បាយថា ក្រុមធម៌ គឺកងធម៌ដែលជាបច្ច័យនៃឧបាទាន ។ សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ចំណែកសេចក្តីពិស្តារ លោកបានពោលហើយ ក្នុងកថាពោលអំពីខន្ធ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **ឥតិ រូបំ** សេចក្តីថា នេះរូប រូបមានប្រមាណប៉ុណ្ណេះ ។ ភិក្ខុរមែងដឹងច្បាស់រូបដោយសភាពថា រូបដទៃក្រៅពីនេះមិនមាន ដូច្នេះ ។ សូម្បីក្នុងវេទនាជាដើម ក៏នយនេះដូចគ្នា ។ សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។ ចំណែករូបជាដើម លោកពោលទុកហើយក្នុងកថាពោលអំពីខន្ធក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្តារ ។ បទថា **ឥតិ រូបស្ស សមុទយោ** សេចក្តីថា ការកើតឡើងនៃរូបដោយអាការ ๕ ដោយការកើតនៃអវិជ្ជាជាដើម រមែងមានដោយអាការយ៉ាងនេះ ។ បទថា **ឥតិ រូបស្ស អត្ថង្គមោ** សេចក្តីថា ការរលត់នៃរូបដោយអាការ ๕ ដោយការរលត់នូវអវិជ្ជាជាដើម រមែងមានដោយអាការយ៉ាងនេះ ។ ក្នុងវេទនាជាដើម ក៏នយនេះដូចគ្នា ។ សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ លោកបានពោលហើយក្នុងឧទយព្វយញ្ញាណកថា ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ពិចារណាឃើញធម៌ ក្នុងធម៌ទាំង-ឡាយរបស់ខ្លួនក្តី ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃក្តី ក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល និងរបស់អ្នកដទៃតាមកាលក្តី ដោយការកំណត់ខន្ធ ៥ យ៉ាងនេះ ។ ការកើត និងការរលត់ ក្នុងពាក្យថា ពិចារណាឃើញធម៌ គឺការកើត និងការរលត់ បណ្ឌិតគប្បីនាំមកប្រៀបធៀបដោយលក្ខណៈ ៥០ ដែលពោលក្នុងខន្ធ ៥ ថា ព្រោះអវិជ្ជាកើត ទើបរូបកើតដូច្នេះជាដើម ។ ពាក្យដ៏សេសអំពីនេះ មានន័យដូចពោលហើយនោះឯង ។

ក្នុងទីនេះ មានប្រការផ្សេងគ្នាតែម្យ៉ាង គឺគប្បីប្រកបសេចក្តីយ៉ាងនេះ ថា សតិកំណត់ខន្ធជាអារម្មណ៍ ជាទុក្ខសច្ច ដូច្នេះហើយ គប្បីជ្រាបថា ជាបដិបទានាំចេញចាកទុក្ខរបស់ភិក្ខុ ដែលកំណត់ខន្ធជាអារម្មណ៍ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ទន្ទបញ្ចៈ ចប់

អាយតនបញ្ចៈ

[១៣០] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយអំណាចខន្ធ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយអាយតនៈ ទើបត្រាស់ថា **បុន ចបរំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ** សេចក្តីថា ក្នុងអាយតនៈខាងក្នុងទាំង ៦ នេះ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត

កាយ ចិត្ត ។ ក្នុងអាយតនៈខាងក្រៅទាំង ៦ នេះ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។ បទថា **ចក្ខុញ្ច បជានាតិ** *សេចក្តីថា រមែងដឹងច្បាស់នូវចក្ខុបសាទ ដោយលក្ខណៈ និងកិច្ចតាមសេចក្តីពិត ។ បទថា* **រូបេ ច បជានាតិ** *សេចក្តីថា រមែងដឹងច្បាស់រូបដែលកើតអំពីសមុដ្ឋាន ៤ គឺកម្ម ចិត្ត ឧតុ អាហារ ខាងក្រៅដោយលក្ខណៈ និងកិច្ចតាមសេចក្តីពិត ។ បទថា* **យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ** *សេចក្តីថា សញ្ញោជនៈ ១០ យ៉ាង គឺ កាមរាគៈ បដិឃៈ មានៈ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគៈ ឥស្សា មច្ឆរិយៈ និងអវិជ្ជា សញ្ញោជនៈកើតឡើង ព្រោះអាស្រ័យអាយតនៈទាំង ២ គឺចក្ខុ និងរូប ។ ម្យ៉ាងទៀត រមែងដឹងច្បាស់សញ្ញោជនៈ ១០ នោះ ដោយលក្ខណៈ ព្រមដោយកិច្ចតាមការពិត ។*

សួរថា សញ្ញោជនៈកើតបានដូចម្តេច ។ ឆ្លើយថា កើតបានយ៉ាងនេះ នឹងពោលក្នុងចក្ខុទ្វារមុន កាលបុគ្គលត្រេកអរ ភ្លើតភ្លើនក្នុងឥដ្ឋារម្មណ៍ ដែលមកប្រាកដតាមចក្ខុទ្វារ ដោយសេចក្តីត្រេកអរក្នុងកាម សញ្ញោជនៈ គឺកាមរាគៈ ក៏កើត ។ កាលបុគ្គលអាក់អន់ចិត្តក្នុងអនិដ្ឋារម្មណ៍ សញ្ញោជនៈ គឺបដិឃៈ ក៏កើត ។ កាលសម្គាល់ថា វៀរលែងតែអញចេញអ្នកជនៃណា ដែលអាចសោយអារម្មណ៍នោះ មិនមាន ដូច្នេះ សញ្ញោជនៈ គឺមានះក៏កើត ។ កាលប្រកាន់រូបារម្មណ៍នោះថា ទៀង ស្ថិតស្ថេរ សញ្ញោជនៈ គឺទិដ្ឋិក៏កើត ។ កាលសង្ស័យរូបារម្មណ៍នោះថា សត្វឬហ្ន៎ របស់សត្វឬហ្ន៎ សញ្ញោជនៈ គឺវិចិកិច្ឆាក៏កើត ។ កាលប្រាថ្នាភពថា អារម្មណ៍នេះ អញបានដោយងាយ ក្នុងសម្បត្តិ-

កពពិត សញ្ញោជន: គឺកវរាគ:ក៏កើត ។ កាលប្រកាន់មាំនូវសីល និងវត្តថា អញប្រកាន់មាំសីល និងវត្ត អាចបានអារម្មណ៍បែបនេះតទៅទៀត សញ្ញោជន: គឺសីលព្វតបរាមាសក៏កើត ។ កាលប្រណែនថា អ្នកដទៃមិនគប្បីបានរូបា-រម្មណ៍បែបនេះឡើយ សញ្ញោជន: គឺឥស្សាក៏កើត ។ កាលហួងហែងរូបារម្មណ៍ ដែលខ្លួនបានហើយចំពោះអ្នកដទៃ សញ្ញោជន: គឺមច្ឆរិយ:ក៏កើត ។ កាលមិនដឹងច្បាស់ ដោយអំណាចការមិនដឹងវត្ថុដែលកើតព្រមនឹងចក្ខុ និងរូបទាំងមូល សញ្ញោជន: គឺអវិជ្ជាក៏កើត ។

បទថា **យថា ច អនុប្បន្នស្ស** *សេចក្តីថា សញ្ញោជន: ១០ យ៉ាងនោះ ដែលនៅមិនកើត ដោយការមិនផ្សាយឡើង រមែងកើតព្រោះហេតុណា រមែងដឹងច្បាស់ហេតុនោះផង ។ បទថា* **យថា ច ឧប្បន្នស្ស** *សេចក្តីថា សញ្ញោជន: ១០ យ៉ាងនោះ ដែលកើតហើយ ព្រោះអត្ថថា នៅលះមិនទាន់បាន ឬព្រោះផ្សាយឡើង រមែងលះបាន ព្រោះហេតុណា រមែងដឹងច្បាស់ហេតុនោះផង ។ បទថា* **យថា ច បហីនស្ស** *សេចក្តីថា សញ្ញោជន: ១០ យ៉ាងនោះ ដែលលះបានហើយ ដោយតទង្គប្បហាន និងវិក្ខម្ភនប្បហាន រមែងមិនកើតតទៅ ព្រោះហេតុណា រមែងដឹងច្បាស់ហេតុនោះផង ។ សួរថា សញ្ញោជន: ១០ នោះមិនកើតតទៅ ព្រោះហេតុដូចម្តេច ឆ្លើយថា សញ្ញោជន: ៥ គឺទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា និងមច្ឆរិយ: មិនកើតតទៅ ដោយសោតាបត្តិមគ្គ ។ សញ្ញោជន: ២ គឺកាមរាគ: ដែលគ្រោតគ្រាត និងបដិឃ: ដែលគ្រោតគ្រាត មិនកើតតទៅ ដោយសកទាគាមិមគ្គ ។ កាមរាគ:ដែលល្អិត និងបដិឃ:ដែល*

ល្អិត មិនកើតតទៅ ដោយអនាគាមិមគ្គ ។ សំយោជន: ៣ គឺមាន: ភវាគ: និងអវិជ្ជា មិនកើតតទៅ ដោយអរហត្តមគ្គ ។ ក្នុងបទថា **សោតញ្ច បជានាតិ សទ្ទេ ច** ជាដើម ក៏មានន័យដូចគ្នា ។ ម្យ៉ាងទៀត អាយតន:កថាក្នុងទីនេះ គប្បីជ្រាបដោយពិស្តារ តាមន័យដែលលោកពោលហើយ ក្នុងអាយតន-និទ្ទេស នៃគម្ពីរវិសុទ្ធិមគ្គ ។

បទថា **สតิ อชฺฌตฺตំ วา** សេចក្តីថា ពិចារណាឃើញធម៌ ក្នុងធម៌ទាំង-ទ្បាយរបស់ខ្លួន ដោយការកំណត់អាយតន:ខាងក្នុងផង ក្នុងធម៌ទាំងទ្បាយរបស់អ្នកដទៃ ដោយការកំណត់អាយតន:ខាងក្រៅផង ក្នុងធម៌ទាំងទ្បាយរបស់ខ្លួនតាមកាល និងរបស់អ្នកដទៃតាមកាលយ៉ាងនេះផង ។ ការកើត និងការសូន្យទៅក្នុងអាយតនបព្វ:នេះ គប្បីនាំមកប្រៀបធៀប រូបាយតន:សង្គ្រោះក្នុងរូបខន្ធ អរូបាយតន: គឺមនាយតន:ទាំងទ្បាយ សង្គ្រោះចូលក្នុងវិញ្ញាណក្ខន្ធ ធម្មាយតន:សង្គ្រោះចូលក្នុងខន្ធដ៏សេស មិនគប្បីកាន់យកលោកុត្តរធម៌ ។ សេចក្តីបន្ទាប់អំពីនេះ មានន័យដូចពោលមកហើយនុ៎ះឯង ។

ក្នុងបព្វ:នេះ មានប្រការផ្សេងគ្នាតែម្យ៉ាង គឺគប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់អាយតន:ជាអារម្មណ៍ ជាទុក្ខសច្ចដូច្នេះជាដើម ហើយគប្បីជ្រាបថា ជាបជិបទានាំចេញចាកទុក្ខ របស់ភិក្ខុដែលកំណត់អាយតន:ជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏មានន័យដូចគ្នានោះឯង ។

អាយតនបព្វ: ចប់

ពោជ្ឈង្គបព្វៈ

[๑๓๑] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនា ដោយអាយតនៈខាងក្នុង ខាងក្រៅ នីមួយៗ ๖ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយពោជ្ឈង្គ ទើបត្រាស់ថា **បុន ចបរំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ពោជ្ឈង្គេសុ** គឺក្នុងអង្គរបស់សត្វដែលត្រាស់ដឹង ។ បទថា **សន្តំ** គឺមានព្រមដោយការបានមក ។ បទថា **សតិ-សម្ពោជ្ឈង្គំ** បានដល់ សម្ពោជ្ឈង្គ ពោល គឺសតិ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សម្ពោជ្ឈង្គេ** នេះ ដូច្នេះថា ព្រះយោគាវចរត្រាស់ដឹង ចាប់តាំងអំពីផ្តើមវិបស្សនាក្តី ព្រះយោគាវចរនោះក្រាក់ទ្បើងពីកិលេសនិទ្រាក្តី ចាក់ជ្រុះសច្ចៈទាំងទ្បាយក្តី ដោយធម្មសាមគ្គី ๗ មានសតិជាដើមឯណា ធម្មសាមគ្គីនោះឈ្មោះថា **សម្ពោធិ** អង្គរបស់អ្នកក្រាក់នោះ ឬធម្មសាមគ្គីជាគ្រឿងជាស់ឲ្យក្រាក់នោះ ហេតុនោះ ទើបឈ្មោះថា **សម្ពោជ្ឈង្គេ** ។ ព្រោះដូច្នោះ ទើបលោកពោលថា សម្ពោជ្ឈង្គពោល គឺសតិ ។ ក្នុងសម្ពោជ្ឈង្គដ៏សេស គប្បីជ្រាបអត្ថនៃពាក្យតាមន័យនេះឯង ។ បទថា **អសន្តំ** គឺមិនមាន ព្រោះមិនបានមក ។

វិនិច្ឆ័យក្នុងបទថា **យថា ច អនុប្បន្នស្ស** ជាដើមថា សតិ-សម្ពោជ្ឈង្គ រមែងកើតតាមន័យដែលមកក្នុងបាលីសំយុត្តនិកាយ មហាវារវគ្គ យ៉ាងនេះថា

ម្នាលភិក្ខុទាំងទ្បាយ មានធម៌ទាំងទ្បាយ ដែលនាំឲ្យកើតសតិ-សម្ពោជ្ឈង្គ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះ

ធម៌ជាអាហារបស់សតិសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬ របស់សតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ឲ្យចម្រើនបរិបូណ៌ ។ ក្នុងធម៌ ទាំងនោះ សតិនោះឯងឈ្មោះថា ធម៌ជាទីតាំងនៃសតិសម្ពោជ្ឈង្គ ។ យោនិ-សោមនសិការមានលក្ខណៈដូចពោលមកហើយនុ៎ះឯង ។ កាលភិក្ខុធ្វើយោនិ-សោមនសិការនោះ ឲ្យប្រព្រឹត្តទៅច្រើនក្នុងអារម្មណ៍នេះហើយ សតិសម្ពោជ្ឈង្គ ក៏កើត ។

ម្យ៉ាងទៀត ធម៌ ៤ ប្រការ ជាផ្លូវកើតនៃសតិសម្ពោជ្ឈង្គ គឺសតិ-សម្បជញ្ញៈ ១ វៀរបុគ្គលដែលមិនមានស្មារតី ១ សេពគប់បុគ្គលដែលមាន ស្មារតីមាំទាំ ១ បង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គនោះ ១ ។

សតិសម្ពោជ្ឈង្គ រមែងកើតដោយសតិសម្បជញ្ញៈក្នុងឋាន:ទាំង ៧ មាន ឈានទៅមុខជាដើម ដោយការវៀរចាកបុគ្គលអ្នកមិនមានសតិ ដូចគ្នានឹងការ រក្សាអាហារ ដោយការគប់រកបុគ្គល អ្នកមានសតិមាំទាំ ដូចគ្នានឹងព្រះ តិស្សទត្តត្ថេរ និងព្រះអភយត្ថេរជាដើម និងដោយភាពជាអ្នកមានចិត្តបង្អោន ទៅដើម្បីតាំងសតិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ។ ភិក្ខុ រមែងដឹងច្បាស់ថា សតិសម្ពោជ្ឈង្គនោះ ដែលកើតឡើងដោយហេតុ ៤ ប្រការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

ធម្មវិចយសម្ពោជ្ឈង្គ រមែងកើតតាមន័យដែលមកក្នុងបាលីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសល ឬអកុសល ពួកធម៌ប្រកបដោយ ទោស ឬឥតទោស ពួកធម៌ថោកទាប ឬថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅ ឬស

និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌ជាអាហារ របស់ធម្មវិចយសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្ម-វិចយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើង នៃធម្ម-វិចយសម្ពោជ្ឈង្គ គឺការសាកសួរដោយជុំវិញ ១ ធ្វើវត្ថុឲ្យស្អាតរៀបរយ ១ ធ្វើឥន្ទ្រិយឲ្យស្មើគ្នា ១ វៀរបុគ្គលមានបញ្ញាទន់ថោកថយ ១ សេពគប់បុគ្គល អ្នកមានបញ្ញា ១ ពិចារណានូវញាណចរិយាដ៏ជ្រាលជ្រៅ ១ ការបង្អោនចិត្ត ទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ១ ។

បណ្តាធម៌ ៧ ប្រការនោះ ភាពជាអ្នកច្រើនទៅដោយការសាកសួរ ដោយជុំវិញ ដែលអាស្រ័យអត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពល ពោជ្ឈង្គ អង្គមគ្គ អង្គឈាន សមថៈ និងវិបស្សនា ឈ្មោះថា ការសាកសួរ ។

ការធ្វើវត្ថុខាងក្នុង និងខាងក្រៅឲ្យស្អាតរៀបរយ ឈ្មោះថា ការធ្វើវត្ថុ ឲ្យស្អាតរៀបរយ ។ វេលាណា ភិក្ខុមានសក់ ក្រចក និងរោមវែងពេកក្តី រាងកាយស្មោកគ្រោកប្រឡាក់ប្រឡូសដោយញើស និងក្អែលក្តី វេលានោះ វត្ថុខាងក្នុង គឺរាងកាយ មិនស្រឡះ មិនស្អាត ។ តែក្នុងវេលាណា ចីវរ ចាស់គ្រាំគ្រា ស្មោកគ្រោក ស្អុយឆ្អេះឆ្អាប ឬសេនាសនៈស៊ុបទ្រុប ក្នុងវេលា នោះ វត្ថុខាងក្រៅមិនស្រឡះ មិនស្អាត ។ ព្រោះដូច្នោះ ទើបគួរធ្វើវត្ថុខាងក្នុង ឲ្យស្អាតរៀបរយ ដោយកិច្ច មានការកោរសក់ជាដើម ដោយការធ្វើរាងកាយ ឲ្យស្រាលសប្បាយ ដោយកិច្ច មានការបន្ទោបង់ជម្រះមន្ទិលឲ្យទូទៅទាំងខាង

លើ ខាងក្រោមជាដើម និងដោយការដុសក្អែលងូតទឹកបន្ទោបង់ក្លិនស្អុយ ។ គប្បីធ្វើវត្ថុខាងក្រៅឲ្យស្អាត រៀបរយដោយកិច្ច មានការដេរ ជ្រលក់ ហោកចីវរ និងធ្វើការដុតបាត្រជាដើម ។ ព្រោះកាលវត្ថុខាងក្នុង និងខាងក្រៅនោះមិនស្អាតរៀបរយ កាលចិត្ត និងចេតសិកកើតឡើង សូម្បីបញ្ញា ក៏មិនផូរផង់ ដូចពន្លឺរបស់ប្រទីបដែលកើតឡើង ព្រោះអាស្រ័យចង្កៀង ប្រឆេះ និងប្រេង ដែលមិនស្អាតបរិសុទ្ធដូច្នោះ តែកាលវត្ថុខាងក្នុង និងខាងក្រៅស្អាតរៀបរយ កាលចិត្ត និងចេតសិកកើតឡើង សូម្បីបញ្ញាក៏ផូរផង់ ដូចពន្លឺរបស់ប្រទីប ដែលកើតឡើង ព្រោះអាស្រ័យចង្កៀង ប្រឆេះ និងប្រេង ដែលស្អាតបរិសុទ្ធ ដូច្នោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ការធ្វើវត្ថុឲ្យស្អាតរៀបរយ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ ដូច្នេះ ។

ការធ្វើឥន្ទ្រិយមានសទ្ធាជាដើម ឲ្យស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រិយ ឲ្យស្មើ ។ ព្រោះថា បើឥន្ទ្រិយ គឺសទ្ធារបស់ភិក្ខុមានកម្លាំងខ្លាំងក្លា ឥន្ទ្រិយក្រៅពីនេះខ្សោយ តពីនោះ ឥន្ទ្រិយ គឺវីរិយៈ ក៏មិនអាចធ្វើកិច្ច គឺការផ្គងចិត្តបាន ឥន្ទ្រិយ គឺសតិក៏មិនអាចធ្វើកិច្ច គឺការប្រាកដ ឥន្ទ្រិយ គឺសមាធិក៏មិនអាចធ្វើកិច្ច គឺការមិនរាយមាយ ឥន្ទ្រិយ គឺបញ្ញាក៏មិនអាចធ្វើកិច្ច គឺការឃើញបាន ព្រោះដូច្នោះ កាលមនសិការដល់ឥន្ទ្រិយ គឺសទ្ធានោះ ដោយការពិចារណាសភាវធម៌ ឬដោយប្រការណា ឥន្ទ្រិយ គឺសទ្ធាមានកម្លាំងខ្លាំងក្លា គប្បីថយចុះដោយការមិនមនសិការដោយប្រការនោះ ។ ក្នុងប្រការនេះ មានរឿងព្រះវក្កលិត្ថេរ ជាឧទាហរណ៍ ។ បើឥន្ទ្រិយ គឺវីរិយៈមានកម្លាំងខ្លាំងក្លា កាល

ដូច្នោះ ឥន្ទ្រិយ គឺសទ្ធាក៏មិនអាចធ្វើកិច្ច គឺការបង្អោនចិត្តជឿបាន ឥន្ទ្រិយក្រៅពីនេះ ក៏មិនអាចធ្វើកិច្ច គឺនាទីផ្សេងៗ របស់ខ្លួនបាន ព្រោះដូច្នោះ ទើបគួរបន្ថយឥន្ទ្រិយ គឺវិរិយៈនោះ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គជាដើម ។ ក្នុងសេចក្តីនោះ គប្បីសម្តែងរឿងព្រះសោណត្ថេរជាឧទាហរណ៍ ។ ក្នុងឥន្ទ្រិយដ៏សេសក៏ដូចគ្នា កាលឥន្ទ្រិយណាមួយមានកម្លាំងខ្លាំងក្លា គប្បីជ្រាបថា ឥន្ទ្រិយក្រៅពីនេះក៏មិនអាចធ្វើកិច្ច គឺនាទីរបស់ខ្លួនបាន ។ តែដោយចំពោះយ៉ាងក្រៃលែង ក្នុងរឿងឥន្ទ្រិយនេះ លោកសរសើរសទ្ធា និងបញ្ញា សមាធិ និងវិរិយៈ ត្រូវស្មើគ្នា ។ ព្រោះអ្នកមានសទ្ធាខ្លាំងក្លា តែមានបញ្ញាទន់ខ្សោយ សេចក្តីជ្រះថ្លាមានកម្លាំង រមែងជ្រះថ្លាក្រៅការ ។ មានបញ្ញាខ្លាំងក្លា តែមានសទ្ធាខ្សោយ រមែងនិយមចូលចិត្តទៅខាងខិលខូច ដូចរោគកើតព្រោះប្រតិកម្មថ្នាំ កែមិនបាន ដូច្នោះ ។ អ្នកមានបញ្ញាខ្លាំងក្លា សុះលោតឆ្លៀវទៅថា កុសលមានដោយចិត្តប្បាទមួយខណៈប៉ុណ្ណោះ ដូច្នេះហើយ ក៏មិនធ្វើបុណ្យមានទានជាដើម រមែងកើតក្នុងនរក ។ ព្រោះឥន្ទ្រិយ គឺសទ្ធា និងបញ្ញាទាំងពីរស្មើគ្នា ទើបជ្រះថ្លាក្នុងវត្ថុ គឺព្រះរតនត្រ័យតែម្យ៉ាង ។ តែសមាធិខ្លាំងក្លា វិរិយៈខ្សោយ កោសជ្ជៈ សេចក្តីខ្ជិលច្រអូស រមែងគ្របសង្កត់បាន ព្រោះសមាធិជាសភាគៈនឹងកោសជ្ជៈ ។ វិរិយៈខ្លាំងក្លា សមាធិខ្សោយ ឧទ្ធច្ចៈរមែងគ្របសង្កត់បាន ព្រោះវិរិយៈជាសភាគៈនឹងឧទ្ធច្ចៈ ។ តែសមាធិដែលវិរិយៈចូលប្រកប រមែងមិនធ្លាក់ទៅក្នុងកោសជ្ជៈ វិរិយៈដែលសមាធិចូលប្រកប ក៏មិនធ្លាក់ទៅក្នុងឧទ្ធច្ចៈ ។ ព្រោះដូច្នោះ ទើបគួរធ្វើឥន្ទ្រិយពីរគូនោះឲ្យស្មើគ្នា ។

ព្រោះថា អប្បនានឹងមាន ក៏ព្រោះឥន្ទ្រិយពីរគូស្មើគ្នា ។ ម្យ៉ាងទៀត សទ្ធា សូម្បីមានកម្លាំងខ្លាំងក្លា ក៏គួរដល់អ្នកចម្រើនសមាធិ ។ ព្រោះអ្នកចម្រើនសមាធិ ជឿមាំយ៉ាងនេះ នឹងសម្រេចអប្បនាបាន ចំណែកក្នុងសមាធិ និងបញ្ញា ឯកគ្គតា ភាពនៃចិត្តមានអារម្មណ៍តែមួយ មានកម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកចម្រើនសមាធិ ។ ព្រោះថា អ្នកចម្រើនសមាធិនោះ រមែងសម្រេចអប្បនាបានដោយឯកគ្គតាយ៉ាងនេះ ។ បញ្ញាមានកម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកចម្រើនវិបស្សនា ។ ព្រោះថា អ្នកចម្រើនវិបស្សនានោះ រមែងដល់ការចាក់ជ្រុះត្រៃលក្ខណ៍ ដោយបញ្ញាយ៉ាងនេះ ។ តែអប្បនានឹងមាន ក៏ព្រោះសទ្ធា និងបញ្ញាទាំងពីរស្មើគ្នា ដោយពិត ។ ចំណែកសតិមានកម្លាំងហើយ រមែងគួរក្នុងទីទាំងពួង ។ ព្រោះថា សតិ រមែងរក្សាចិត្តមិនឲ្យធ្លាក់ទៅក្នុងឧទ្ធច្ចៈ ដោយអំណាចសទ្ធា វីរិយៈ បញ្ញា ដែលជាសភាគៈនឹងឧទ្ធច្ចៈ មិនឲ្យធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះសមាធិជាសភាគៈនៃកោសជ្ជៈ ។ ព្រោះដូច្នោះ ទើបសតិនោះ ចាំបាច់ក្នុងទីទាំងពួង ដូចការផ្សំរសដោយអំបិល ចាំបាច់ក្នុងការផ្សំអាហារគ្រប់យ៉ាង និងដូចអមាត្យដែលជំនាញក្នុងរាជកិច្ចគ្រប់យ៉ាង ចាំបាច់ក្នុងរាជកិច្ចគ្រប់យ៉ាង ដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សតិ ចាំបាច់ក្នុងទីទាំងពួង ព្រោះហេតុអ្វី ព្រោះចិត្តមានសតិជាទីអាស្រ័យ និងសតិមានការរក្សាជាអាការប្រាកដ រឿសតិចេញហើយនឹងផ្តង ឬសង្កត់ចិត្ត[1] មិនបាន ។

๑- ផ្តងដោយធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ ក្នុងខណៈដែលចិត្តរញ្ជួរ ព្រោះមានសេចក្តីព្យាយាមធូរថយ ។ សង្កត់ដោយបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យដែលចិត្តរាយមាយ ព្រោះព្យាយាមខ្លាំងពេក ។

ការវៀរឲ្យឆ្ងាយនូវបុគ្គលដែលមានបញ្ញាថោកថយ មិនមានបញ្ញាឈមចុះក្នុងប្រភេទនៃធម៌ មានខន្ធជាដើម ឈ្មោះថា ការវៀរចាកបុគ្គលមានបញ្ញាថោកថយ ។ ការសេពគប់បុគ្គលដែលប្រកបដោយបញ្ញាដោយជុំវិញ ដឹងការកើត និងការរលត់នៃសភាវធម៌ ដែលកំណត់ដោយលក្ខណៈ ៥០ ឈ្មោះថា សេពគប់បុគ្គលដែលមានបញ្ញា ។ ការពិចារណាប្រភេទនៃបញ្ញាដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅក្នុងសភាវធម៌ទាំងឡាយ មានខន្ធជាដើមដ៏ជ្រាលជ្រៅ ឈ្មោះថា ការពិចារណានូវញាណចរិយាដោយបញ្ញាដ៏ជ្រាលជ្រៅ ។ ភាពជាអ្នកមានចិត្តដែលបង្អោនទៅ ដើម្បីតម្កល់ក្នុងធម្មវិចយសម្ពោជ្ឈង្គ ក្នុងឥរិយាបថទាំង-ឡាយ មានឈរ អង្គុយជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយ-សម្ពោជ្ឈង្គនោះ ។ កិក្ខុរមែងដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គនោះ ដែលកើតដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

វីរិយសម្ពោជ្ឈង្គ រមែងកើតតាមនយដែលមកហើយនៅក្នុងបាលីសំយុត្តនិកាយ មហាវារវគ្គយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតាំងផ្តើមការខ្នះខ្នែង ការប្រឹងប្រែង និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងសេចក្តីតាំងផ្តើមជាដើមនោះ នេះធម៌ជាអាហាររបស់វីរិយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វីរិយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតនៃវីរិយ-សម្ពោជ្ឈង្គ គឺការពិចារណាឃើញភ័យក្នុងអបាយ ១ ការឃើញអានិសង្សនៃ

សេចក្តីព្យាយាម ๑ ការពិចារណាឃើញផ្លូវសម្រាប់ដើរទៅរបស់ព្រះពុទ្ធជាដើម ๑ ការគោរពក្នុងបិណ្ឌបាត ๑ ការពិចារណាភាពជាធំនៃការទទួលទ្រព្យមត៌ក ๑ ការពិចារណាភាពដែលមានព្រះសាស្តាជាធំ ๑ ការពិចារណាការមានជាតិជាធំ ๑ ការពិចារណាការមានសព្រហ្មចារីជាធំ ๑ ការវៀរចាកបុគ្គលខ្វិលច្រអូស ๑ ការសេពគប់បុគ្គលដែលប្រារព្ធសេចក្តីព្យាយាម ๑ ការបង្អោនចិត្តទៅក្នុងវិរិយសម្ពោជ្ឈង្គនោះ ๑ ។

សេចក្តីអធិប្បាយ

បណ្តាធម៌ ๑๑ ប្រការនោះ កាលភិក្ខុចម្រើនវិរិយសម្ពោជ្ឈង្គ ពិចារណាឃើញភ័យក្នុងអបាយយ៉ាងនេះថា បុគ្គលណាមួយ មិនអាចញុំាងវិរិយសម្ពោជ្ឈង្គឲ្យកើតបាន ក្នុងវេលាដែលសោយមហាទុក្ខ ចាប់ផ្តើមពីត្រូវដាក់ទោសដោយចំណង ๕ ប្រការ ក្នុងនរកក្តី ក្នុងវេលាកើតជាសត្វតិរច្ឆាន ដែលត្រូវគេចាប់ដោយគ្រឿងនេសាទ មានអន្ទាក់ សំណាញ់ អួនជាដើម ក្នុងវេលាបរ ឬកៀង ចាក់ដោយគ្រឿងប្រហារ មានជន្លួញជាដើម ឲ្យអួសរនេះជាដើមក្តី ក្នុងវេលាដែលរងទុក្ខក្នុងបេតវិសយ ដោយការស្រេកឃ្លាន មួយពាន់ឆ្នាំ ឬមួយពុទ្ធន្តរក្តី ក្នុងវេលាដែលកើតក្នុងកាលកញ្ចិកាសុរ ដែលមានសរីរៈប្រមាណ ๖๐ ហត្ថ ឬ ๘๐ ហត្ថនៅសល់តែ ស្បែកជណ្តប់ឆ្អឹងក្តី នៃភិក្ខុវេលានេះប៉ុណ្ណោះ ជាពេលប្រារព្ធសេចក្តីព្យាយាមរបស់អ្នក ដូច្នេះ វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។

កាលឃើញអានិសង្សយ៉ាងនេះថា អ្នកខ្ជិលច្រអូស មិនអាចបាន លោកុត្តរធម៌ ៩ អ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ទើបអាច នេះជាអានិសង្សរបស់សេចក្តីព្យាយាម ដូច្នេះ វីរិយសម្ពោជ្ឈង្គ ក៏រមែងកើតបាន ។

កាលពិចារណាឃើញវិថី គឺផ្លូវយ៉ាងនេះថា គួរដើរតាមផ្លូវ ដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ មហាសាវកគ្រប់អង្គ ដើរទៅហើយ ផ្លូវនោះ បុគ្គលអ្នកខ្ជិលច្រអូសមិនអាចដើរទៅបាន ដូច្នេះ វីរិយសម្ពោជ្ឈង្គ ក៏រមែងកើតបាន ។

កាលពិចារណាដល់ការគោរពកោតក្រែង ចំពោះបិណ្ឌបាតយ៉ាងនេះថា មនុស្សពួកណាទំនុកបម្រុងអ្នកដោយបច្ច័យ មានបិណ្ឌបាតជាដើម មនុស្សទាំងនោះ មិនមែនញាតិ មិនមែនទាសៈ និងមិនមែនកម្មករបស់អ្នកឡើយ មនុស្សទាំងនោះ ក៏មិនមែនឲ្យបច្ច័យ មានចីវរជាដើម ដែលប្រណីត ដល់អ្នកដោយគិតថា នឹងអាស្រ័យអ្នកចិញ្ចឹមជីវិត ដោយពិត គេទន្ទឹងឧបការៈដែលគេធ្វើហើយមានផលច្រើនទើបឲ្យ សូម្បីព្រះសាស្តា ក៏មិនបានពិចារណាឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ នឹងមានរាងកាយរឹងមាំច្រើននៅជាសុខ ដូច្នេះ ហើយទ្រង់អនុញ្ញាតបច្ច័យដល់អ្នក ដែលពិត ទ្រង់ពិចារណាឃើញថា ភិក្ខុបរិភោគបច្ច័យទាំងនេះ បំពេញសមណធម៌ នឹងផុតចាកទុក្ខក្នុងវដ្តៈបាន ដូច្នេះ ទើបទ្រង់អនុញ្ញាតបច្ច័យ ឥឡូវនេះ អ្នកខ្ជិលច្រអូស មិនគោរពកោតក្រែងក្នុងបិណ្ឌបាតនោះ ដែលឈ្មោះថា ការគោរពកោតក្រែងចំពោះបិណ្ឌបាត រមែងមានដល់អ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ដូច្នេះ វីរិយសម្ពោជ្ឈង្គក៏កើតបាន ដូចវីរិយសម្ពោជ្ឈង្គ កើតដល់ព្រះមហាមិត្តៈ

ដូច្នោះ ។

រឿងព្រះមហាមិត្តត្ថេរ

បានឮមកថា ព្រះថេរៈអាស្រ័យនៅក្នុងគុហាឈ្មោះកស្សកៈ ។ មហាឧបាសិកាម្នាក់ក្នុងស្រុក ជាទីគោចរបស់លោកទំនុកបម្រុងព្រះថេរៈ ដូចកូន ។ ថ្ងៃមួយ ឧបាសិកានោះទៅព្រៃទើបផ្តាំកូនស្រីថា នែហង អង្ករចាស់នៅឯណោះ សប្បិ ខីរៈ ទឹកអំពៅនៅឯណោះ ពេលដែលលោកម្ចាស់មិត្តៈ បងប្រុសរបស់នាងមកហើយ ចូរផ្សំអាហារប្រគេន មួយអន្ទើដោយសប្បិ ខីរៈ និងទឹកអំពៅផងចុះ ។ កូនស្រីសួរថា ម៉ែទទួលទានដែរឬទេ មហាឧបាសិកាឆ្លើយថា ម៉ែបរិភោគអាហារសល់ពីម្សិលមិញ ដែលទុករម្ងៀរត្រី ជាមួយនឹងទឹកជ្រក់ហើយ ។ កូនស្រីសួរថា ម៉ែពិសាពេលថ្ងៃដែរឬទេ មហាឧបាសិកាប្រាប់ថា ចូរនាងដាក់បន្លែជ្រក់ ហើយយកចុងអង្ករបបរ ធ្វើឲ្យមានរសជូរទុកឲ្យម៉ែចុះ ។ ព្រះថេរៈគ្រងចីវរហើយ កំពុងនាំបាត្រចេញអំពីស្ងោក បានឮសំឡេងនោះហើយ ក៏ទូន្មានខ្លួនឯងថា បានឮថា មហាឧបាសិកា បរិភោគតែអាហារដែលសល់ពីម្សិល និងទឹកជ្រក់ ពេលថ្ងៃ ក៏បរិភោគបបរជូរជាមួយបន្លែជ្រក់ ឧបាសិកានេះ ប្រាប់អាហារមានអង្ករចាស់ជាដើម ដើម្បីប្រយោជន៍ដល់អ្នក មហាឧបាសិកានោះ មិនបានប្រាថ្នាទីស្រែ ទីចម្ការ អាហារ និងសំពត់ ព្រោះអាស្រ័យអ្នកឡើយ តែប្រាថ្នាសម្បត្តិ ៣ ប្រការ ទើបឲ្យ ឯងអាចឲ្យសម្បត្តិទាំងនោះ ដល់ឧបាសិកានោះបានឬទេ ដូច្នេះ លោកគិតថា

បិណ្ឌបាតនេះឯង អញនៅមានរាគៈ ទោសៈ មោហៈ នៅមិនអាចទទួលបានដូច្នេះហើយ ក៏ទុកបាត្រក្នុងស្មោក ដោះក្តុំចីវរ ត្រឡប់ទៅកាន់គុហាកស្សបៈ ទុកបាត្រក្រោមត្រែ ពាក់ចីវរទុកត្រង់ស្មាចីវរ អង្គុយអធិដ្ឋានសេចក្តីព្យាយាមថា បើអញមិនសម្រេចអរហត្ត នឹងមិនចេញទៅអំពីគុហាដូច្នេះ ។ កិកូដែលមិនប្រមាទមកអស់កាលជាយូរ ចម្រើនវិបស្សនា ក៏សម្រេចអរហត្ត មុនវេលាអាហារព្រឹក ជាព្រះមហាខីណាស្រពអស់អាសវៈហើយ អង្គុយញញឹមដូចផ្កាឈូក ដែលកំពុងរីកដូច្នោះ ។ ទេវតាដែលអាស្រ័យត្រង់ដើមឈើក្បែរគុហា បន្លឺឧទានថា

ឧមោ តេ បុរិសាជញ្ញ ឧមោ តេ បុរិសុត្តម

យស្ស តេ អាសវា ខីណា ឧក្កិណោយ្យាសិ មានិស ។

បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការ បពិត្រឧត្តមបុរស ខ្ញុំសូមនមស្ការ ខ្ញុំសូមនមស្ការលោកអ្នកមានអាសវៈអស់ហើយ លោកអ្នកនិទ្ទុក្ខ លោកជាអ្នកគួរដល់ទក្ខិណាទាន ដូច្នេះ ។ ហើយពោលថា បពិត្រលោកម្ចាស់ ពួកស្រីចាស់ប្រគេនអាហារដល់ព្រះអរហន្តទាំងឡាយ ដូចលោកម្ចាស់ ដែលចូលទៅបិណ្ឌបាត នឹងផុតទុក្ខបាន ដូច្នេះ ។

ព្រះថេរៈក្រោកឡើង បើកទ្វារមើលវេលា ដឹងថា នៅព្រឹក ទើបកាន់បាត្រ និងចីវរចូលកាន់ស្រុក ចំណែកទាវិកាត្រៀមអាហារស្រេចហើយ អង្គុយចាំមើលនៅត្រង់ទ្វារ ដោយគិតថា មួយភ្លែតទៀតបងប្រុសអញនឹងមក មួយភ្លែតទៀតបងប្រុសអញនឹងមក ។ កាលព្រះថេរៈមកដល់ទ្វារផ្ទះហើយ ទាវិកា

នោះ ក៏ទទួលបាត្រដាក់ពេញដោយអាហារលាយទឹកដោះ ដែលផ្សំដោយ សប្បិ និងទឹកអំពៅហើយ ដាក់លើដៃរបស់ព្រះថេរៈ ។ ព្រះថេរៈធ្វើអនុ-មោទនាថា ចូរបានសុខចុះ ហើយក៏ចៀសចេញទៅ ។ ទារិកានោះ ឃើញ សម្ងំមើលលោកហើយ ។ សេចក្តីពិត ក្នុងគ្រានោះ ពណ៌សម្បុរបស់ព្រះ ថេរៈ បរិសុទ្ធក្រៃលែង ឥន្ទ្រិយថ្លាផូរផង់ មុខរបស់លោកស្រស់បស់ក្រៃលែង ដូចផ្ទៃខ្នោតទុំជ្រុះចាកទង ដូច្នោះ ។ មហាឧបាសិកាត្រឡប់មកអំពីព្រៃសួរថា បងប្រុសរបស់នាងមកហើយឬ ទារិកានោះក៏ប្រាប់ រឿងទាំងអស់ឲ្យមាតា ស្តាប់ ។ មហាឧបាសិកាក៏ជឿថា ថ្ងៃនេះ បព្វជិតកិច្ចនៃកូនរបស់អញដល់ ទីបំផុតហើយ ទើបពោលថា បងប្រុសរបស់នាង ត្រេកអរក្រៃលែង ក្នុងព្រះ ពុទ្ធសាសនា មិនអផ្សុក គឺចង់សឹកឡើយ ដូច្នេះ ។

កាលពិចារណា ការមានមត៌កជាធំយ៉ាងនេះថា មត៌ករបស់ព្រះសាស្តា មានច្រើន គឺអរិយទ្រព្យ ៧ ប្រការ មត៌កនោះ អ្នកឱ្ងិលច្រអូសមិនអាច ទទួលបាន ដូចជាមាតាបិតា រមែងកាត់កាល់បុត្រដែលប្រព្រឹត្តខុស ធ្វើឲ្យជា អ្នកខាងក្រៅថា អ្នកនេះមិនមែនជាកូនរបស់អញ កាលមាតាបិតាស្លាប់ទៅ បុគ្គលនោះក៏មិនបានទទួលមត៌កយ៉ាងណា សូម្បីបុគ្គលដែលឱ្ងិលច្រអូស ក៏ ដូច្នោះ រមែងមិនបានមត៌ក គឺអរិយទ្រព្យនេះ បុគ្គលប្រារព្ធព្យាយាមប៉ុណ្ណោះ រមែងបានទទួល ដូច្នេះ វីរិយសម្ពោជ្ឈង្គ រមែងកើតបាន ។

កាលពិចារណា ការមានព្រះសាស្តាជាធំយ៉ាងនេះថា ព្រះសាស្តារបស់ អញជាធំ ព្រោះក្នុងវេលាដែលព្រះសាស្តារបស់អញ ទ្រង់បដិសន្ធិក្នុងគភ៌

របស់ព្រះមាតាក្តី វេលាស្តេចចេញមហាភិនេស្ក្រមណ៍ក្តី វេលាត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណក្តី វេលាប្រកាសធម្មចក្រ សម្តែងយមកប្បាដិហារ្យ ស្តេចចុះចាកពីទេវលោក និងទ្រង់ជាក់អាយុសង្ខារក្តី វេលាស្តេចរលត់ខន្ធបរិនិព្វានក្តី លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រហើយ អ្នកបួសក្នុងសាសនារបស់សាស្តាដែលមានសភាពបែបនេះ ហើយជាអ្នកខ្វិលច្រអូស គួរឬ ដូច្នេះ វិរិយសម្ពោជ្ឈង្គ រមែងកើតបាន ។

កាលពិចារណា ការមានជាតិជាធំយ៉ាងនេះថា ដោយជាតិ ឥឡូវនេះ អ្នកមិនមែនបុគ្គលមានជាតិថោកថយទ្បើយ អ្នកឈ្មោះថា កើតហើយក្នុងវង្ស របស់ព្រះបាទឱក្កាកវាជ ដែលបន្តវង្សគ្នាមកដោយមហាសម្មតបវេណី មិនលាយជាមួយនឹងជាតិដទៃ ជាចៅរបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាព្រះអនុជរបស់ព្រះរាហុល ពុទ្ធជិនោរស ដែលឈ្មោះថា អ្នកជាពុទ្ធជិនបុត្រ មានសភាពបែបនេះ ហើយនៅជាបុគ្គលខ្វិលច្រអូសមិនសមគួរ ដូច្នេះ វិរិយសម្ពោជ្ឈង្គ រមែងកើតបាន ។

កាលពិចារណា ការមានសព្រហ្មចារីជាធំ យ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះមហាសាវ័ក ៨០ អង្គ លោកត្រាស់ដឹងលោកុត្តរធម៌ ដោយសេចក្តីព្យាយាមទាំងអស់ អ្នកនឹងដើរតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ឬមិនដើរតាមទេ ដូច្នេះ វិរិយសម្ពោជ្ឈង្គ រមែងកើតបាន ។

កាលវៀរបុគ្គលដែលខ្វិលច្រអូស បុគ្គលដែលលះសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ដូចជាពោះថ្ងាន់ស៊ីពេញពោះហើយ ក៏ឈប់មួយកន្លែងក្តី

សេពគប់បុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម អ្នកឧទ្ទិសខ្ជួនប្រាថ្នាបដិបត្តិធម៌ក្តី មានចិត្តបង្អោនទៅ ដើម្បីឲ្យសេចក្តីព្យាយាមកើតឡើង ក្នុងឥរិយាបថទាំង-ទ្បាយ មានឈរ អង្គុយជាដើមក្តី វិរិយសម្ពោជ្ឈង្គ រមែងកើតបាន ។ ភិក្ខុ រមែងដឹងច្បាស់ថា វិរិយសម្ពោជ្ឈង្គនោះ ដែលកើតហើយ ដោយអាការយ៉ាង នេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។

បីតិសម្ពោជ្ឈង្គ រមែងកើតដោយនយដែលមកហើយក្នុងបាលីសំយុត្ត-និកាយ មហាវារវគ្គយ៉ាងនេះថា ម្នាលភិក្ខុទាំងទ្បាយ មានធម៌ទាំងទ្បាយ ដែលនាំឲ្យកើតបីតិសម្ពោជ្ឈង្គ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុង ធម៌ទាំងនោះ នេះធម៌ជាអាហាររបស់បីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យ កើតឡើងបាន ឬរបស់បីតិសម្ពោជ្ឈង្គ ដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ដូច្នេះ ។ បីតិនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គក្នុងបាលីនោះ ។ មនសិការដែលញុំាងបីតិនោះឲ្យកើត ឈ្មោះថា យោនិសោមនសិការ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងជាផ្លូវកើត បីតិសម្ពោជ្ឈង្គ គឺពុទ្ធា-នុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ឧបសមានុស្សតិ ១ វៀរបុគ្គលដែលសៅហ្មង ១ សេព គប់បុគ្គលដែលបរិសុទ្ធ ១ ការពិចារណាសេចក្តីក្នុងព្រះសូត្រដែលជាទីតាំងនៃ សេចក្តីជ្រះថ្លា ១ ការបង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ១ ។

ពិតហើយ បុគ្គលចម្រើនបីតិសម្ពោជ្ឈង្គ កាលរឭកដល់ពុទ្ធគុណ បីតិ-សម្ពោជ្ឈង្គផ្សាយពេញសរីរៈ ជារបដល់ឧបចារសមាធិ រមែងកើតឡើង ។

កាលឮកដល់គុណព្រះធម៌ និងព្រះសង្ឃក្តី ពិចារណាចតុប្បារិសុទ្ធិសីលដែលខ្លួនរក្សា មិនជាច់ធ្លុះធ្លាយ អស់កាលយូរក្តី សូម្បីជាគ្រហស្ថ ពិចារណាសីល ១០ សីល ៥ ក្តី ពិចារណាចាគៈ បរិច្ចាគថា ក្នុងវេលាជួបទុព្ភិក្ខភ័យជាដើម អញប្រគេនកោជន ដែលប្រណីតដល់សព្រហ្មចារីទាំងឡាយ ហើយប្រគេនកោជនឈ្មោះយ៉ាងនេះ ដូច្នេះក្តី សូម្បីជាគ្រហស្ថ ពិចារណាដល់ទាន ដែលឲ្យដល់លោកអ្នកមានសីល ក្នុងវេលាបែបនោះក្តី ពិចារណាដល់គុណ ដូចដែលទេវតាប្រកបហើយដល់ភាពជាទេវតាថា មាននៅក្នុងខ្លួនក្តី ពិចារណាឃើញថា កិលេសដែលគ្របសង្កត់បានហើយ សូម្បីដោយសមាបត្តិរហូតអស់ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ មិនមានការកម្រើកដូច្នេះក្តី វៀរបុគ្គលសៅហ្មង ដែលមានចិត្តកករល្អក់ដែលសន្សំ ព្រោះមិនធ្វើដោយគោរពក្នុងវេលាឃើញព្រះចេតិយ ឃើញពោធិព្រឹក្ស និងឃើញព្រះថេរៈ ដូចជាល្អងធូលីលើខ្នងលា ព្រោះមិនមានសេចក្តីជ្រះថ្លា គោរព ស្រឡាញ់ក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមក្តី សេពគប់បុគ្គលដែលបរិសុទ្ធ ដែលច្រើនដោយសេចក្តីជ្រះថ្លា មានចិត្តទន់ភ្លន់ចុះក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមក្តី ពិចារណាសេចក្តីក្នុងព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ដែលសម្តែងគុណរបស់ព្រះរតនត្រ័យក្តី មានចិត្តបង្អោនទៅដើម្បីឲ្យកើតបីតិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើមក្តី បីតិសម្ពោជ្ឈង្គ រមែងកើតបាន ។ កិក្ខុរមែងដឹងច្បាស់ថា បីតិ-សម្ពោជ្ឈង្គនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតដោយនយដែលមកហើយ ក្នុងបាលីសំយុត្តនិកាយ មហាវារវគ្គយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ការស្ងប់ស្ងាត់កាយ ការស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងការស្ងប់ស្ងាត់នោះ នេះធម៌ជាអាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឲ្យកើតឡើងបាន ឬរបស់បស្សទ្ធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងជាផ្លូវកើតបស្សទ្ធិសម្ពោជ្ឈង្គ គឺសេពកោជនដែលប្រណីត ๑ សេពរដូវជាទីសប្បាយ ๑ សេពឥរិយាបថជាទីសប្បាយ ๑ ប្រកបភាពជាកណ្តាល ๑ វៀរបុគ្គលអ្នកមិនស្ងប់កាយ ๑ សេពគប់បុគ្គលអ្នកស្ងប់កាយ ๑ បង្អោនចិត្តទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ๑ ។

ពិតហើយ បុគ្គលចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ កាលបរិភោគកោជនជាទីសប្បាយដែលប្រណីតបរិសុទ្ធក្តី សេពរដូវជាទីសប្បាយ ទោះជារដូវរងា រដូវក្តៅក្តី សេពឥរិយាបថជាទីសប្បាយ ទោះជាឥរិយាបថឈរជាដើមក្តី រមែងកើតសេចក្តីស្ងប់បាន ។ តែពាក្យនោះ លោកមិនបានពោលសំដៅដល់បុគ្គលដែលជាមហាបុរស ដែលអត់ធន់ចំពោះរដូវ និងឥរិយាបថជាទីសប្បាយ ។ កាលបុគ្គលមានរដូវ និងឥរិយាបថដែលត្រូវគ្នា និងមិនត្រូវគ្នា វៀររដូវ និងឥរិយាបថដែលមិនត្រូវគ្នាចេញហើយ សេពរដូវ និងឥរិយាបថដែលត្រូវគ្នា បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតបាន ។ ការពិចារណាដល់ភាពដែលខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួន ហៅថា ប្រកបភាពជាកណ្តាល បស្សទ្ធិ-

សម្ពោជ្ឈង្គ រមែងកើតបានដោយប្រកបភាពជាកណ្តាលយ៉ាងនេះ ។ កាលវៀរបុគ្គលដែលមានកាយមិនស្ងប់ ដូចជាបុគ្គលដែលត្រាច់បៀតបៀនសត្វដទៃដោយគ្រឿងប្រហារ មានដុំដី និងកំណាត់ឈើជាដើមក្តី សេពគប់បុគ្គលអ្នកមានកាយស្ងប់ សង្រួមដៃជើងក្តី មានចិត្តបង្អោនទោរទន់ទៅដើម្បីឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គ ក្នុងឥរិយាបថ មានឈរ អង្គុយជាដើមក្តី បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតបាន ។ កិកូរមែងជីងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។

សមាធិសម្ពោជ្ឈង្គ រមែងកើតបាន ដោយន័យមកហើយ ក្នុងបាលីសំយុត្តនិកាយ មហាវារវគ្គយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មានតែសមាធិនិមិត្ត អព្យគ្គនិមិត្ត និងការធ្វើនូវយោនិសោមនសិការ ឲ្យច្រើនក្នុងនិមិត្តទាំងនោះ នេះធម៌ជាអាហាររបស់សមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់សមាធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ដូច្នេះ ។

ក្នុងនិមិត្តទាំងនេះ សមថៈនុ៎ះឯង ឈ្មោះថា សមថនិមិត្ត និងអព្យគ្គនិមិត្ត ព្រោះអត្ថថា មិនរាយមាយ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងជាផ្លូវកើតសមាធិសម្ពោជ្ឈង្គ គឺធ្វើវត្តុឲ្យស្អាតរៀបរយ ១ ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ១ ឈ្លាសក្នុងនិមិត្ត ១ ផ្គងចិត្តក្នុងសម័យដែលគួរផ្គង ១ សង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់ ១ ធ្វើចិត្តឲ្យត្រេកអរក្នុងសម័យដែលគួរឲ្យត្រេកអរ ១ ព្រងើយក្នុងសម័យដែលគួរ

ព្រងើយ ๑ វៀរបុគ្គលដែលមានចិត្តមិនជាសមាធិ ๑ សេពគប់បុគ្គលដែលមានចិត្តជាសមាធិ ๑ ពិចារណាឈាន និងវិមោក្ខ ๑ បង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គនោះ ๑ ។

សេចក្តីអធិប្បាយ

ក្នុងធម៌ ๑๑ ប្រការនោះ ចំពោះការធ្វើវត្តុឲ្យស្អាតរៀបរយ និងការធ្វើឥន្ទ្រិយឲ្យស្មើ គប្បីជ្រាបតាមន័យដែលពោលមកហើយនុ៎ះឯង ។

ការឈ្វាសក្នុងការកំណត់កសិណនិមិត្តជាអារម្មណ៍ ឈ្មោះថា ឈ្វាសក្នុងនិមិត្ត ។ ការផ្គងចិត្តទុក ដោយការតាំងធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ ក្នុងសម័យដែលចិត្តរួញរា ព្រោះមានសេចក្តីព្យាយាមធូរថយពេកជាដើម ឈ្មោះថា ផ្គងចិត្តក្នុងសម័យដែលគួរផ្គង ។

ការគ្រប សង្កត់ចិត្តទុក ដោយការតាំងបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យដែលចិត្តរាយមាយ ព្រោះប្រារព្ធសេចក្តីព្យាយាមខ្លាំងហួសពេកជាដើមឈ្មោះថា សង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់ ។

ពាក្យថា ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយ អធិប្បាយថា សម័យណាចិត្តមិនស្រស់ថ្លា ព្រោះមានបញ្ញា និងសេចក្តីព្យាយាមខ្សោយ ឬព្រោះមិនបានសម្រេចសុខដែលកើតពីសេចក្តីស្ងប់ សម័យនោះ ក៏ធ្វើចិត្តឲ្យសង្វេគ ដោយពិចារណាសំវេគវត្តុ ๘ ប្រការ ។ សង្វេគវត្តុ ๘ ប្រការ គឺ ជាតិ ๑ ជរា ๑ ព្យាធិ ๑ មរណៈ ๑ ទុក្ខក្នុងអបាយ ๑ អតីតវដ្តមូលកទុក្ខ ๑

អនាគតវដ្តមូលកទុក្ខ ๑ ទុក្ខក្នុងបច្ចុប្បន្នមានការស្វែងរកអាហារជាមូល ๑ ។ ម្យ៉ាងទៀត ការធ្វើសេចក្តីជ្រះថ្លាឲ្យកើត ដោយមកពឹកដល់គុណព្រះរតន-ត្រ័យ នេះក៏ហៅថា ការធ្វើចិត្តឲ្យត្រេកអរក្នុងសម័យដែលគួរឲ្យត្រេកអរ ។

ឈ្មោះថា ព្រងើយក្នុងសម័យដែលគួរព្រងើយ អធិប្បាយថា សម័យណា ចិត្តអាស្រ័យនូវបដិបត្តិប្រពៃ មិនរួញរា មិនរាយមាយ ស្រស់ថ្លា ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ ដំណើរក្នុងសមថវិថី សម័យនោះ មិនចាំបាច់ខ្វល់ខ្វាយក្នុងការផ្គង គ្របសង្កត់ ហើយធ្វើចិត្តឲ្យរីករាយ ដូចសារថី មិនចាំបាច់ខ្វល់ខ្វាយ ក្នុងកាលសេះរត់ស្មើល្អដូច្នោះ នេះហៅថា ព្រងើយក្នុងសម័យដែលគួរព្រងើយ ។

ការវៀរឲ្យឆ្ងាយពីបុគ្គលដែលមានចិត្តរាយមាយ មិនសម្រេចឧបចារៈ ឬអប្បនា ឈ្មោះថា វៀរបុគ្គលដែលមានចិត្តមិនជាសមាធិ ។ ការគប់រកចូលទៅអង្គុយជិតបុគ្គល ដែលមានចិត្តជាសមាធិ ដោយឧបចារភាវនា ឬអប្បនាភាវនា ឈ្មោះថា គប់រកបុគ្គលដែលមានចិត្តជាសមាធិ ។

ភាពជាអ្នកមានចិត្តបង្អោនទោរទន់ទៅ ដើម្បីឲ្យកើតសមាធិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ឈ្មោះថា បង្អោនចិត្តទៅក្នុងសមាធិ-សម្ពោជ្ឈង្គ ។

ព្រោះថា កាលបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គនោះ រមែងកើតបាន ។ កាលភិក្ខុដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

ឧបេក្ខាសម្ពោជ្ឈង្គ រមែងកើតបាន តាមន័យដែលមកហើយក្នុងបាលីសំយុត្តនិកាយ មហាវារវគ្គយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ដែលនាំឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឲ្យកើតឡើងបាន ឬរបស់ឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ដូច្នេះ ។ ក្នុងធម៌ទាំងនោះ ឧបេក្ខានុ៎ះឯង ឈ្មោះថា ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

ម្យ៉ាងទៀត ធម៌ ៥ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ គឺជាក់ខ្លួនជាកណ្តាលក្នុងសត្វ ១ ជាក់ខ្លួនជាកណ្តាលក្នុងសង្ខារ ១ វៀរបុគ្គលអ្នកប្រកាន់សត្វ និងសង្ខារ ១ សេពគប់បុគ្គលអ្នកជាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ១ បង្អោនចិត្តទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ១ ។

សេចក្តីអធិប្បាយ

ក្នុងធម៌ ៥ ប្រការនោះ បុគ្គលចម្រើនឧបេក្ខាសម្ពោជ្ឈង្គ រមែងផ្តើមការជាក់ខ្លួនជាកណ្តាលក្នុងសត្វ ដោយអាការ ២ យ៉ាង គឺដោយការពិចារណាដល់ភាពដែលខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួនយ៉ាងនេះថា អ្នកមកដោយកម្មរបស់ខ្លួន ក៏នឹងទៅដោយកម្មរបស់ខ្លួន ឯបុគ្គលនោះក៏មកដោយកម្មរបស់ខ្លួន នឹងទៅដោយកម្មរបស់ខ្លួនដូចគ្នា អ្នកនឹងប្រកាន់អ្វី ដូច្នេះ និងដោយការពិចារណាដល់ការមិនមានសត្វយ៉ាងនេះថា កាលពោលដោយបរមត្ថ ដែលថា សត្វៗ គឺមិនមាន អ្នកនឹងប្រកាន់អ្វី ដូច្នេះ ។

ផ្តើមការជាក់ខ្លួនជាកណ្តាលក្នុងសង្ឃារ ដោយអាការ ២ យ៉ាង គឺដោយការពិចារណាដោយភាពជារបស់មិនមានម្ចាស់ យ៉ាងនេះថា ចីវរនេះ នឹងចូលដល់ការប្រែប្រួលពណ៌ និងការចាស់គ្រាំគ្រា ជាសំពត់ជួតជើង ត្រូវឆ្អែះចោលដោយចុងឈើច្រត់ បើចីវរនោះ គប្បីមានម្ចាស់សោត គេក៏មិនគប្បីឲ្យវាវិនាសយ៉ាងនេះ ដូច្នេះ និងពិចារណាដោយភាពជារបស់មួយជួរខណៈ យ៉ាងនេះថា ចីវរនេះនៅមិនបានយូរ ជារបស់មួយជួរខណៈ ដូច្នេះ ។ សូម្បីក្នុងបរិក្ខារ មានបាត្រជាដើម ក៏គប្បីប្រកបសេចក្តីដូចក្នុងចីវរនេះ ។

ក្នុងពាក្យថា រឿរបុគ្គលដែលប្រកាន់ក្នុងសត្វ និងសង្ខារ មានវិនិច្ឆ័យដូច្នេះថា បុគ្គលណាជាគ្រហស្ថ ក៏ប្រកាន់បិយជន មានកូនប្រុសកូនស្រីជាដើមរបស់ខ្លួន ឬជាបព្វជិត ក៏ប្រកាន់បព្វជិត មានអន្តេវាសិក និងអ្នករួមឧបជ្ឈាយ៍គ្នាជាដើមរបស់ខ្លួន រវល់តែធ្វើកិច្ចកម្ម មានកោរសក់ ដេរចីវរ ជ្រលក់ចីវរជុតបាត្រជាដើមរបស់ជនទាំងនោះ ដោយដៃរបស់ខ្លួននោះឯង កាលមិនឃើញត្រឹមតែមួយភ្លែត ក៏នឹកក្អកថា សាមណេររូបនោះទៅណា ភិក្ខុរូបកំណែរូបនោះទៅណា រកមើលឆ្វេងស្តាំ ដូចម្តើគស្មាន់កិតភ័យ ដូច្នោះ សូម្បីអ្នកដទៃសូមថា មេត្តាបញ្ជូនសាមណេរឈ្មោះឯណោះ ទៅជួយកោរសក់ជាដើម ត្រឹមតែមួយភ្លែតចុះ ដូច្នេះ ក៏មិនព្រមឲ្យ ដោយនិយាយថា ពួកខ្ញុំមិនធ្វើកិច្ចកម្មរបស់ខ្លួនខ្លះទេឬ ពួកលោកនាំសាមណេរ និងភិក្ខុនេះទៅ នឹងលំបាកដូច្នេះ បុគ្គលនេះ ឈ្មោះថា ប្រកាន់សត្វ ។

ចំណែកបុគ្គលណា ប្រកាន់បរិក្ខារ មានចីវរ បាត្រ ស្មៅកបាត្រ ឈើ

ច្រត់ជាដើម សូម្បីអ្នកជនៃនឹងយកដៃចាប់ក៏មិនឲ្យចាប់ ទោះសូមខ្ចី ក៏ឆ្លើយជំទាស់ថា ខ្ញុំត្រូវការប្រើទ្រព្យក៏មិនហ៊ានប្រើ នឹងឲ្យពួកលោកបានដូចម្តេចដូច្នេះ បុគ្គលនេះឈ្មោះថា ប្រកាន់សង្ខារ ។ ចំណែកបុគ្គលណា ជាក់ខ្លួនជាកណ្តាល ទៀងត្រង់ក្នុងវត្ថុទាំងពីរនោះ បុគ្គលនេះឈ្មោះថា ជាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ។

កាលវៀរឆ្ងាយបុគ្គលដែលប្រកាន់សត្វ និងសង្ខារមានសភាពបែបនេះក្តី គប់រកបុគ្គលអ្នកជាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារក្តី មានចិត្តបង្អោនទៅ ដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរអង្គុយជាដើមក្តី ឧបេក្ខាសម្ពោជ្ឈង្គនេះ រមែងកើតបាន ដោយប្រការដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គនោះ ដែលកើតហើយ ដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។

បទថា **สติ อฏฺฐงฺคตฺถํ วา** *សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំង-ឡាយ ព្រោះកំណត់សម្ពោជ្ឈង្គ ៧ របស់ខ្លួនក្តី របស់អ្នកជនៃក្តី កំណត់សម្ពោជ្ឈង្គ ៧ របស់ខ្លួនតាមកាល និងរបស់អ្នកជនៃតាមកាលក្តី ។ ការកើត និងការសូន្យទៅ នៃឧបេក្ខាសម្ពោជ្ឈង្គគប្បីជ្រាបដោយអំណាចការកើត និងការរលត់នៃសម្ពោជ្ឈង្គទាំងឡាយ ក្នុងពោជ្ឈង្គបព្វៈនេះ ។ សេចក្តីតអំពីនេះក៏មានន័យដូចពោលមកហើយ ។*

ក្នុងពោជ្ឈង្គបព្វៈនេះ មានសេចក្តីផ្សេងគ្នាតែម៉្យាង គឺគប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់ពោជ្ឈង្គជាអារម្មណ៍ ជាទុក្ខសច្ចជាដើម ហើយគប្បី

ជ្រាបថា ជាបដិបទានាំចេញចាកទុក្ខរបស់ភិក្ខុ ដែលកំណត់ពោជ្ឈង្គ ជាអារម្មណ៍ ។ ពាក្យដ៏សេសក៏ដូច្នោះដូចគ្នា ។

ពោជ្ឈង្គបព្វៈ ចប់

សច្ចបព្វៈ

[๑๓๒] *ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនា ដោយពោជ្ឈង្គ ៧ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកសច្ចៈ ៤ ប្រការ ទើបត្រាស់ថា* **បុន จបរំ** *ជាដូច្នេះជាដើម ។*

ក្នុងបទទាំងនោះ បទថា **ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ** *សេចក្តីថា ដឹងច្បាស់តាមសេចក្តីពិត នូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ๓ វៀរតណ្ហាថា នេះទុក្ខ ដឹងច្បាស់តាមសេចក្តីពិតនូវតណ្ហា ដែលមានអំពីមុន ដែលធ្វើទុក្ខនោះឯងឲ្យកើត ឲ្យប្រាកដឡើង នេះទុក្ខសមុទយៈ ដឹងច្បាស់តាមសេចក្តីពិតនូវសេចក្តីរលត់ គឺបញ្ឈប់នូវទុក្ខ និងទុក្ខសមុទយៈទាំងពីរថា នេះទុក្ខនិរោធ ដឹងច្បាស់តាមសេចក្តីពិតនូវអរិយមគ្គ ដែលជាហេតុកំណត់ដឹងទុក្ខ ជាហេតុលះសមុទយៈ ជាហេតុធ្វើឲ្យច្បាស់នូវនិរោធថា នេះទុក្ខនិរោធគាមិនីបដិបទា ។ សច្ចកថាដ៏សេស វៀរកថាពោលដោយបទភាជនៈ មានជាតិជាដើម លោកពោលពិស្តារក្នុងគម្ពីរវិសុទ្ធិមគ្គហើយនោះឯង ។*

អធិប្បាយបទភាជនៈ

[๑๓๓] *ចំណែកក្នុងបទភាជនៈ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា* **กตมา**

ฉ ภิกฺขเว ชาติ *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ជាតិដូចម្តេច ដែលតថាគត ពោលយ៉ាងនេះថា ជាតិក៏ជាទុក្ខ ជាតិនោះ តើដូចម្តេច ។ គប្បីជ្រាបអត្តក្នុង បុច្ឆាទាំងពួងយ៉ាងនេះ ។ បទថា* **យา តេសំ តេសំ សត្តានំ** *ជាពាក្យ សង្គ្រោះសត្វទុកទាំងអស់ដោយមិនមានកំណត់ថា របស់ពួកសត្វឈ្មោះនេះ ។ សូម្បីបទថា* **តម្ហิ តម្ហิ สตฺตนิกายេ** *នេះ ជាពាក្យសង្គ្រោះពួកសត្វទុកទាំង អស់ ។ ការកើត ឈ្មោះថា* **ជាតិ ។** *ពាក្យថា ជាតិនេះ ជាឈ្មោះរបស់ខន្ធ ដែលកើតក្នុងគ្រាដំបូង ព្រមដោយការប្រែប្រួល ។ បទថា* **สญฺชาติ** *នេះ ជា វេវចន:របស់ជាតិនោះឯង តែប្រកបដោយឧបសគ្គ ។ ការកើតនុ៎ះឯង ឈ្មោះ ថា* **ขนฺธานญฺจ** *ដោយអត្តថា ចុះចាប់ផ្តៃដោយអាការដែលចូលទៅតាមលំដាប់ ។ ឈ្មោះថា* **អภินิพฺพตฺติ** *ដោយអត្តថា កើតកើតច្រាកដ ពោល គឺកើត ។ ទាំង ៤ យ៉ាងនេះ ឈ្មោះថា ពោលដោយសន្ទត ។ ចំណែកបាលីថា* **ขนฺธานำ จาตุ-ภูมโก** *នេះ ពោលដោយបរមត្ថ ។ ការច្រាកដនៃខន្ធទាំងឡាយនុ៎ះឯង ដែល ចែកជាខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ក្នុងបណ្តាពួកសត្វដែលមានខន្ធ ១ ជាដើម នុ៎ះឯង មិនមែនការច្រាកដនៃបុគ្គល ។ តែកាលការច្រាកដនៃខន្ធនោះមាន ក៏ សន្ទតហៅថា បុគ្គលច្រាកដដូច្នេះ ។ បទថា* **អายตนานำ បฏิลาภោ** *សេចក្តី ថា អាយតន:ទាំងឡាយច្រាកដនុ៎ះឯង ឈ្មោះថា បដិលាភនោះ គឺការបានមក ដែលពោលបានថា ការច្រាកដនៃអាយតន:ទាំងនោះ ។*

បទថា **ชรา** *ជាសព្ទសម្តែងជល់សភាពខ្លួនឯង ។ បទថា* **ជีรณตา**

សម្តែងដល់ការៈ គឺអាការ ។ បទថា **ឧណ្ហិច្ចំ** *ជាដើម គឺសម្តែងដល់ការៈផ្ងាស់ប្តូរ ពិតហើយ វេលាជាកំលោះក្រមុំ ធ្មេញក៏ស ភបស្មើ ។ កាលចាស់គ្រាំគ្រា ធ្មេញទាំងនោះ ក៏ផ្ងាស់ពណ៌ទៅដោយលំដាប់ រន្ធោះបាក់ធ្លាក់ទៅក្នុងទីនោះៗ ។ ម្យ៉ាងទៀត ធ្មេញបាក់ សំដៅដល់ធ្មេញដែលបាក់ផង ធ្មេញដែលនៅសល់ផង ឈ្មោះថា* **ឧណ្ហិតា** *។ ការៈនៃធ្មេញដែលបាក់ ហៅថា* **ឧណ្ហិច្ចំ** *។ សក់ និងរោម គ្រាំគ្រាទៅដោយលំដាប់ ឈ្មោះថា សក់ស្កូវ ។ សក់ស្កូវកើតព្រមហើយ ដល់បុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា មានសក់ស្កូវ ។ ការៈនៃបុគ្គលអ្នកមានសក់ស្កូវ ឈ្មោះថា* **ចាលិច្ចំ** *។ សភាពជ្រីវជ្រួញត្រង់ស្បែករបស់បុគ្គលនោះមាន ព្រោះមានសាច់ និងឈាមស្ងួតទៅ ដោយត្រូវខ្យល់ គឺជរាប្រហារ ហេតុនោះ បុគ្គលនោះ ឈ្មោះថា មានស្បែកជ្រីវជ្រួញ ។ ការៈនៃបុគ្គលមានស្បែកជ្រីវជ្រួញនោះ ឈ្មោះថា* **វលិតចតា** *។ ដោយពាក្យមានប្រមាណត្រឹមប៉ុណ្ណេះ ដែលព្រះមានព្រះភាគ ទ្រង់សម្តែង* **ចាកជជរា** *គឺជរាដែលប្រាកដ ដោយសម្តែងការប្រែប្រួលក្នុងធ្មេញ សក់ រោម ស្បែក ។ ផ្លូវទៅរបស់ខ្យល់ ឬភ្លើង នឹងប្រាកដបាន ក៏ព្រោះខ្យល់បក់ត្រូវស្មៅ ឬដើមឈើជាដើម បាក់បែករន្ធោះរន្ធើ ឬភ្លើងឆេះ តែផ្លូវទៅរបស់ខ្យល់ និងភ្លើងនោះ ក៏មិនប្រាកដ យ៉ាងណា ផ្លូវទៅនៃជរាក៏ដូច្នោះដែរ នឹងប្រាកដបាន ក៏ដោយការៈ មានធ្មេញបាក់ជាដើមនៃអាការ ៣២ មានធ្មេញជាដើម សូម្បីបុគ្គលបើកភ្នែកមើលក៏ចាប់មិនបាន ការគ្រាំគ្រានៃអាការ មានធ្មេញបាក់ជាដើម មិនមែនតួជរាទេ ព្រោះជរាជីងតាមចក្ខុមិនបាន ។ តែព្រោះកាលដល់ជរា អាយុ

សាបសូន្យទៅ ដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ដោយផលជិតថា ការរួញ ថយនៃអាយុ ហៅថា **ជរា** *។ ម្យ៉ាងទៀត ព្រោះកាលនៅ កំលោះក្រមុំ ឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើម ស្រស់ថ្លាល្អ អាចទទួលអារម្មណ៍របស់ខ្លួនសូម្បីដែលល្អិតតូចបានដោយងាយ កាលជល់ជរា ក៏ជល់ភាពទុំជោរ កករ ល្អក់ មិនថ្លាផូរផង់ មិនអាចទទួលអារម្មណ៍របស់ខ្លួន សូម្បីគ្រោតគ្រាតបាន ដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ដោយផលជិតថា ការទ្រុឌទ្រោមឥន្ទ្រិយ ទាំងឡាយ ហៅថា* **ជរា** *ដូច្នេះ ។*

ក្នុងមរណនិទ្ទេស មានវិនិច្ឆ័យដូចតទៅនេះ បទថា **យំ** *សំដៅដល់ មរណៈ ជាសព្ទសម្តែងនបុំសកលិង្គ ។ ក្នុងបទថា* **យំ** *នោះ គប្បីប្រកបសេចក្តីដូច្នេះថា មរណៈ លោកហៅថា* **ចុតិ** *និងហៅថា* **ចវនតា** *។ ក្នុងសព្ទទាំងនោះ បទថា* **ចុតិ** *សម្តែងដល់ការនិទ្ទេស ។ សព្ទថា* **ចវនតា** *សម្តែងដល់អាការការនិទ្ទេស ។ កាលបុគ្គលដល់មរណៈហើយ ខន្ធទាំងឡាយរមែងបែកផង អន្តរធានផង លែងបានឃើញ ព្រោះដូច្នោះ ទើបមរណៈនោះ ហៅថា ការបែកធ្លាយ ការអន្តរធាន ។ បទថា* **មចฺจุ มรณำ** *គឺ មចฺจุមรณៈ មិនមែនខណិកមរណៈ ។ ការធ្វើកាលៈ គឺស្លាប់ ឈ្មោះថា* **กาลกิริยา** *។ សូម្បីទាំងអស់នេះ ពោលដោយសម្មតិនោះឯង ។ ចំណែកបាលីថា* **ขนฺธานំ เภเทา** *នេះ ជាការពោលដោយបរមត្ថ ។ ការបែកធ្លាយនៃខន្ធទាំងឡាយ ដែលចែកជាខន្ធ ๑ ខន្ធ ๔ និងខន្ធ ๕ ក្នុងបណ្តាពួកសត្វ ដែលមានខន្ធ ๑ ជាដើម*

នុ៎ះឯង មិនមែនការបែកធ្លាយនៃបុគ្គល ។ តែកាល ការប្រជុំព្រមនៃខន្ធ មាន ក៏សន្មតថា បុគ្គលស្លាប់ ។ ការដាក់ចុះនូវអត្តភាព ឈ្មោះថា ការដាក់ចុះនូវសាកសព ។ ពិតហើយ កាលបុគ្គលដល់សេចក្តីស្លាប់ អត្តភាពក៏ធ្លាក់ចុះដូចជាអង្គត់ឧសរកប្រយោជន៍គ្មានដូច្នោះ ព្រោះហេតុនោះ ទើបមរណៈនោះ លោកហៅថា ការដាក់ចុះនូវសាកសព ។ ចំណែកការដាច់នៃជីវិតិន្ទ្រិយ កាលពោលដោយបរមត្ថ ដោយអាការទាំងពួង ក៏គឺមរណៈ ។ មរណៈនោះឯង ហៅថា សម្មតិមរណៈ ។ សត្វលោកកាន់យកការដាច់នៃជីវិតិន្ទ្រិយប៉ុណ្ណោះ ទើបនិយាយថា តិស្សៈស្លាប់ ផុស្សៈស្លាប់ ដូច្នេះ ។

បទថា **ព្យសនេន** *សេចក្តីថា ដោយវិបត្តិណានីមួយ បណ្តាវិបត្តិទាំង-ទ្បាយ មានវិនាសញ្ញាតិជាដើម ។ បទថា* **ទុក្ខធម្មេន** *សេចក្តីថា ដែលហេតុនៃទុក្ខ មានការសម្លាប់ និងការឃុំឃាំងជាដើម ។ បទថា* **ដុដ្ឋស្ស** *បានដល់ លិចលង់គ្របសង្កត់ហើយ ។ បទថា* **សោកោ** *បានដល់ សេចក្តីសោកដែលមានការរីងស្ងួតនៃចិត្តជាលក្ខណៈ រមែងកើតដល់បុគ្គលក្នុងកាលត្រូវវិបត្តិមានការវិនាសចាកញ្ញាតិជាដើម ឬហេតុនៃសេចក្តីទុក្ខ មានការសម្លាប់ ការចងជាដើមណាមួយ គ្របសង្កត់ហើយ ។ ភាពជាអ្នកសោក បានដល់ សេចក្តីសោក ។ សេចក្តីសោកនោះ កើតឡើងធ្វើខាងក្នុងឲ្យរីងស្ងួត ឲ្យក្រៀមស្វិត ព្រោះដូច្នោះ ទើបហៅថា សេចក្តីរីងស្ងួតចិត្ត សេចក្តីក្រៀមក្រំចិត្ត ដូច្នេះ ។*

ជនទាំងឡាយ ប្រកាន់យ៉ាងនេះថា កូនស្រីរបស់អញ កូនប្រុសរបស់អញ ដូច្នេះ រមែងកន្ទក់កន្ទេញ ដោយសេចក្តីប្រកាន់នោះ ហេតុនោះ ទើប

សេចក្តីប្រកាន់នោះ ឈ្មោះថា **អាឧេវោ** ។ *ជនទាំងឡាយ យំរៀបរាប់លើកនូវគុណទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា* **បរិឧេវោ** ។ *សព្ទទាំង ២ ក្រៅអំពី* **អាឧេវនា បរិឧេវនា** *នោះ ជាសព្ទសម្តែងការៈនៃសេចក្តីទួញយំរៀបរាប់នោះឯង ។*

សេចក្តីទុក្ខ ដែលមានកាយបសាទជាទីតាំង ព្រោះអត្តថា ទ្រាំបានដោយក្រ ឈ្មោះថា **ទុក្ខំ** ។ *បទថា* **អសាតំ** *គឺមិនសប្បាយ ។ បទថា* **កាយសម្ផស្សជំ ទុក្ខំ** *គឺទុក្ខដែលកើតពីកាយសម្ផស្ស ។ បទថា* **អសាតំ វេទយិតំ** *គឺវេទនាដែលមិនគួរពេញចិត្ត ។ ទោមនស្សដែលសម្បយុត្តនឹងចិត្ត ឈ្មោះថា* **ចេតសិកំ** *បានដល់ ទោមនស្សតាមផ្លូវចិត្ត ។ បទដ៏សេស មានន័យដូចពោលមកហើយ ក្នុង* **ទុក្ខ** *សព្ទនុ៎ះឯង ។*

បទថា **អាយាសោ** *បានដល់ សេចក្តីលំបាកផ្លូវចិត្ត ដែលដល់អាការគឺតានតឹងចិត្ត ។ សេចក្តីចង្អៀតចិត្តដោយការៈមានកម្លាំង ឈ្មោះថា* **ឧបាយាសោ** ។ *សព្ទទាំងពីរក្រៅអំពី* **អាយាស** *និង* **ឧបាយាស** *នោះ គឺ* **អាយាសិតត្តំ ឧបាយាសិតត្តំ** *ជាធម៌ទាក់ទងក្នុងខ្លួន បំភ្លឺការៈ ចង្អុលការៈ ។*

បទថា **ជាតិធម្មានំ** *គឺមានការកើតជាសភាវៈ ។ ពីរបទថា* **ឥច្ចា ឧប្បជ្ជតិ** *គឺតណ្ហា រមែងកើត ។ បទថា* **អហោ វត** *បានដល់ សេចក្តីប្រាថ្នា ។ បទថា* **ន ខោ បនេតំ ឥច្ចាយ** *សេចក្តីថា សេចក្តីនោះ គឺការមិនត្រូវមកកើតរៀរមគ្គភាវនាចេញ បុគ្គលមិនគប្បីសម្រេចបានតាមប្រាថ្នា ។ បទថា* **ឥធម្បិ**

គឺសូម្បីយ៉ាងនេះ ។ **ឯ** *អក្ខរៈ ក្នុងបទថា* **ឥធម្បិ** *សំដៅដល់បទដ៏សេសខាងមុខ ។ បទថា* **យម្បិច្ចំ** *សេចក្តីថា បុគ្គលប្រាថ្នា វត្ថុដែលមិនគប្បីបាន រមែងមិនបាន ព្រោះធម៌ណា សេចក្តីប្រាថ្នាក្នុងវត្ថុ ដែលមិនគប្បីបាននោះ ក៏ជាទុក្ខ ។ គ្រប់ៗបទ ក៏នយនេះដូចគ្នា ។ ក្នុងខន្ធនិទ្ទេសមានវិនិច្ឆ័យដូច្នេះ រូបនោះផង ឧបាទានក្ខន្ធផង ព្រោះហេតុនោះ ទើបឈ្មោះថា* **រូបូបាទានក្ខន្ធោ។** *គ្រប់ខន្ធទាំងអស់ ក៏គប្បីជ្រាបយ៉ាងនេះ ។*

[๑๓๔-๑๓๕] *បទថា* **យាយំ តណ្ហា** *កាត់ជា* **យា អយំ តណ្ហា** *ប្រែថា តណ្ហានេះ ។ បទថា* **ទោនោព្ភវិកា** *មានវិគ្គហៈថា ការធ្វើកពថ្មី ឈ្មោះថា កពថ្មី កពថ្មីនោះ ជាប្រក្រតីនៃតណ្ហានោះ ហេតុនោះ ទើបតណ្ហានោះ ឈ្មោះថា* **ទោនោព្ភវិកា ។** *បទថា* **ឧទ្ធិរាគសហគតា** *បានដល់ តណ្ហាដែលកើតរួមដោយតម្រេក ដោយអំណាចសេចក្តីត្រេកអរខ្លាំង ។ លោកអធិប្បាយថា ដោយអត្ថ តណ្ហានោះ ក៏ដូចគ្នានឹងនន្ទិរាគៈនុ៎ះឯង ។ ក្នុងបទទាំងនោះ បទថា* **តត្រតត្រាភិនន្ទិនី** *សេចក្តីថា អត្តភាពកើតចំពោះក្នុងទីណាមួយ តណ្ហាក៏ត្រេកត្រអាលក្នុងទីទាំងនោះ ។ នយម្យ៉ាងទៀត តណ្ហាតែងតែត្រេកត្រអាលក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ឈ្មោះថា ក្នុងទីទាំងឡាយ ។ អធិប្បាយថា ត្រេកត្រអាលក្នុងរូប ត្រេកត្រអាលក្នុងសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។ សព្ទថា* **សេយ្យថីទំ** *ជានិបាតសព្ទ ។ សព្ទថា* **សេយ្យថីទំ** *នោះ មានសេចក្តីថា បើមានពាក្យសួរថា តណ្ហានោះ តើដូចម្តេច*

ចំណង់ក្នុងកាម ឈ្មោះថា **កាមតណ្ហា** ។ ពាក្យថា កាមតណ្ហានោះ ជាឈ្មោះនៃតម្រេកជាប់ដោយកាមគុណ ៥ ។ ចំណង់ក្នុងភព ឈ្មោះថា **ភវតណ្ហា** ។ ពាក្យថា ភវតណ្ហានេះ ជាឈ្មោះរបស់តម្រេកក្នុងរូបភព និងអរូបភព ដែលកើតព្រមដោយសស្សតទិដ្ឋិ ដែលកើតដោយសេចក្តីប្រាថ្នាភព និងសេចក្តីត្រេកអរក្នុងឈាន ។ ចំណង់ក្នុងវិភវ: ឈ្មោះថា **វិភវតណ្ហា** ។ ពាក្យថា វិភវតណ្ហានេះ ជាឈ្មោះរបស់តម្រេក ដែលកើតព្រមដោយឧច្ឆេទ-ទិដ្ឋិ ។ ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងវត្ថុជាទីតាំង ដែលកើតនៃតណ្ហានោះដោយពិស្តារ ទើបត្រាស់ថា **សា ទោ បនេសា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧប្បជ្ជតិ** ប្រែថា កើត ។ បទថា **និវិសតិ** បានដល់ តាំងនៅដោយការប្រព្រឹត្តទៅរឿយៗ ។ បទថា **យំ លោកេ បិយរូបំ សាតរូបំ** សេចក្តីថា សភាវ:ជាទីស្រឡាញ់ និងសភាវ:ដែលពេញចិត្តក្នុងលោក ។ ក្នុងបទថា **ចក្ខុំ លោកេ** ជាដើម មានអធិប្បាយដូច្នេះថា ពិតហើយសត្វទាំងឡាយ ប្រកាន់មាំក្នុងចក្ខុជាដើម ក្នុងលោកដោយភាពជារបស់អញ តាំងមាំនៅក្នុងសម្បត្តិ រមែងសម្គាល់ចក្ខុរបស់ខ្លួន ដែលមានបសាទទាំង ៥ ស្រស់ថ្លា ដូចបង្អួចនៃកែវមណី ដែលបើកហើយក្នុងវិមានមាស ដោយទំនងកាន់យកនិមិត្តក្នុងកញ្ចក់ជាដើម រមែងសម្គាល់សោត: ដូចបំពង់ប្រាក់ និងដូចអំបោះដោតសង្ខារ រមែងសម្គាល់ឃាន: ដែលបានវោហារហៅថា តុង្គនាសា (ច្រមុះស្រួច) ដូចទងហរិតាល ដែលគេពូត តាំងទុក រមែងសម្គាល់ជិវ្ហា ដែលទន់ស្អាតចាំទទួលរសច្ចាញ់ ដូចផ្ទាំងសំពត់កម្ពលក្រហម រមែងសម្គាល់

កាយ ដូចដើមសាលព្រឹក្សជំទង់ និងដូចសសរមាស រមែងសម្គាល់មនៈ ដ៏ឧឡារ មិនដូចគ្នានឹងចិត្តរបស់អ្នកដទៃ រមែងសម្គាល់រូប ដូចជាពណ៌ផ្កាកណិការមាសជាដើម រមែងសម្គាល់សំឡេង ដូចជាសំឡេងករវិក និងតាវៅដែលគួរស្តាប់ និងសំឡេងរំពងរបស់ប៊ីកែវដែលផ្ទុំឡើង រមែងសម្គាល់អារម្មណ៍ មានគន្ធារម្មណ៍ជាដើម ដែលមានសមុដ្ឋាន ៤ ដែលខ្ជួនបានហើយថា អារម្មណ៍បែបនេះរបស់អ្នកដទៃណាហ្នឹ និងមាន ។ កាលបើសត្វទាំងនោះ សម្គាល់យ៉ាងនេះ ចក្ខុទាំងនោះជាដើម ក៏រមែងជាទីស្រឡាញ់ ជាទីរីករាយ ។ កាលបើដូច្នោះ តណ្ហារបស់សត្វទាំងនោះ ដែលមិនទាន់កើត ក៏រមែងកើតក្នុងចក្ខុជាដើមនោះ និងតណ្ហាដែលកើតហើយ ក៏រមែងតាំងនៅដោយការប្រព្រឹត្តទៅរឿយៗ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ចក្ខុក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុន៉ុះ ដូច្នេះជាដើម ។

បទថា **តត្ត ឧប្បជ្ជមានា ឧប្បជ្ជតិ** សេចក្តីថា តណ្ហានោះ កាលកើតក្នុងកាលណា ក៏រមែងកើតត្រង់ចក្ខុនេះ ក្នុងកាលនោះ ។ គ្រប់បទទាំងអស់ក៏នយនេះ ។

[១៣៦] បទទាំងពួង មានបទថា **អសេសវិរាគនិរោធោ** ទាំងអស់នេះជាដើម ជាវេវចនៈរបស់ព្រះនិព្វានន៉ុះឯង ។ ពិតហើយ តណ្ហាមកដល់ព្រះនិព្វាន រមែងកម្ចាត់ រលត់មិនសល់ ព្រោះដូច្នោះ ទើបព្រះនិព្វាននោះ ត្រាស់ហៅថា ការរលត់ដោយកម្ចាត់មិនសល់ នៃតណ្ហានោះឯង ។ ម្យ៉ាងទៀត

តណ្ហាមកជល់ព្រះនិព្វាន រមែងលះ លះបង់ បន្សាត់ មិនជាប់ ព្រោះដូច្នោះ ទើបព្រះនិព្វានត្រាស់ហៅថា ជាទីលះ លះបង់ បន្សាត់ មិនជាប់ ។ ពិតហើយ ព្រះនិព្វាន ក៏មានតែម្យ៉ាងប៉ុណ្ណោះ ។ តែឈ្មោះរបស់ព្រះនិព្វាននោះមានច្រើន ដោយបដិបក្ខចំពោះឈ្មោះរបស់សង្ខតធម៌ទាំងអស់ ។ ឈ្មោះទាំងនោះដូចម្តេច គឺធម៌ជាទីខ្ជាក់ចោលមិនសេសសល់ ជាទីរលត់មិនសេសសល់ ជាទីលះ ជាទីលះបង់ ជាទីផុត ជាទីមិនជាប់ ជាទីអស់រាគៈ ជាទីអស់ទោសៈ ជាទីអស់មោហៈ ជាទីអស់តណ្ហា ជាទីមិនកើត ជាទីឈប់ មិនមាននិមិត្ត មិនមានទីតាំង មិនមានទីអាស្រ័យ មិនមានបដិសន្ធិ មិនប្រព្រឹត្តទៅ មិនទៅ មិនកើត មិនចាស់ មិនឈឺ មិនស្លាប់ មិនសោក មិនបរិទេវៈ មិនចង្អៀតចង្អល់ មិនសៅហ្មង ដូច្នេះជាដើម ។ ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងការមិនមាននូវតណ្ហាទាំងពួង ដែលមគ្គលះបានហើយ ជល់នូវការឈប់ គឺមិនប្រព្រឹត្តទៅ ព្រោះមកជល់ព្រះនិព្វាន ក្នុងវត្ថុដែលទ្រង់សម្តែងថា តណ្ហាកើតនុ៎ះឯង ទើបត្រាស់ថា **សา เอา ปเนสา** *ដូច្នេះជាដើម ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះដូច្នេះ ឧបមាថា បុរសជួបវល្ល៊ិនោងព្រៃ ដែលកើតក្នុងស្រែហើយ ចាប់ស្រាវពីចុង ស្វែងរកគល់ ជួបហើយ ដកចេញ វល្ល៊ិនោះក៏សូតទៅដោយលំដាប់ ជល់នូវការមិនជ្រាកដ ពេលនោះ គេក៏ហៅថា វល្លនោងព្រៃក្នុងស្រែនោះ រលត់ហើយ លះហើយ តណ្ហាក្នុងចក្ខុជាដើម ប្រៀបដូចវល្លនោងព្រៃក្នុងស្រែ តណ្ហានោះ កាត់ឫសបានដោយអរហត្តមគ្គ ជល់នូវការឈប់ដុះ ព្រោះមកជល់ព្រះនិព្វាន ម្យ៉ាងទៀត តណ្ហា

ដែលដល់ការឈប់យ៉ាងនោះ ហើយរមែងមិនប្រាកដក្នុងវត្តទាំងនោះ ដូចវល្ិ នទោងព្រៃមិនប្រាកដក្នុងស្រែ ដូច្នោះ ។ ម្យ៉ាងទៀត ប្រៀបដូចពួកមនុស្សនាំ ចោរមកពីព្រៃ គប្បីសម្ងាប់ត្រង់ទ្វារទិសខាងត្បូងនៃព្រះនគរ បន្ទាប់អំពីនោះ មនុស្សទាំងឡាយ នឹងគប្បីនិយាយគ្នាថា ពួកចោរក្នុងព្រៃស្ងាប់ហើយ ឬត្រូវ សម្ងាប់ហើយ ដូច្នេះ យ៉ាងណា ក៏ដូច្នោះដូចគ្នា តណ្ហាក្នុងចក្ខុជាដើម ប្រៀប ដូចចោរក្នុងព្រៃ តណ្ហានោះ ឈ្មោះថា រលត់ទៅក្នុងព្រះនិព្វានទុ៎ះឯង ព្រោះ មកដល់ព្រះនិព្វានហើយ ទើបរលត់ទៅ ដូចចោរត្រូវសម្ងាប់ត្រង់ទ្វារទិសខាង ត្បូង ដូច្នោះ ម្យ៉ាងទៀត តណ្ហាដែលរលត់ហើយយ៉ាងនោះ រមែងមិនប្រាកដ ក្នុងវត្តទាំងនោះ ដូចចោរមិនប្រាកដក្នុងព្រៃដូច្នោះ ។ ព្រោះដូច្នោះ ព្រះមាន ព្រះភាគ កាលទ្រង់សម្តែងការរលត់នៃតណ្ហានោះ ក្នុងចក្ខុជាដើមនោះ ទើប ត្រាស់ថា ចក្ខុក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរ ត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុនុ៎ះ ដូច្នេះ ជាដើម ។

[๑๓๗] *បទថា* **អយមេវ** *ជាពាក្យកំណត់ពិត ដើម្បីបដិសេធមគ្គ ដទៃ ។ បទថា* **អរិយោ** *សេចក្តីថា មគ្គ ឈ្មោះថា* **អរិយ** *ព្រោះឆ្ងាយចាក កិលេសទាំងឡាយ ដែលមគ្គទាំងនោះគប្បីសម្ងាប់ និងព្រោះធ្វើភាពជាព្រះ អរិយៈ ។ ទ្រង់សម្តែងកម្មដ្ឋានពោលដោយសច្ចៈ ๔ ដោយពាក្យថា ជីងក្នុង ទុក្ខជាដើម ។ ក្នុងសច្ចៈ ๔ នោះ សច្ចៈ ๒ ខាងដើម ជាវដ្តសច្ច សច្ចៈ ๒ ខាងចុង ជាវិវដ្តសច្ច ។ ក្នុងវដ្តសច្ច និងវិវដ្តសច្ចទាំងនោះ ការតាំងមាំនៃ*

กมฺมฏฺฐานรបស់ភិក្ខុ រមែងមានក្នុងវដ្តសច្ច មិនមានក្នុងវិវដ្តសច្ច ។ ព្រះ យោគាវចរកំណត់សច្ច: ២ ខាងដើម ក្នុងសម្នាក់អាចារ្យដោយសង្ខេប យ៉ាង នេះថា បញ្ចក្ខន្ធជាទុក្ខ តណ្ហាជាសមុទយ: និងពិស្តារដោយនយជាដើមថា បញ្ចក្ខន្ធដូចម្តេច គឺរូបក្ខន្ធ ដូច្នេះហើយ ស្វាធ្យាយ ឈ្មោះថា ធ្វើកម្មក្នុងសច្ច: ទាំង ២ នោះ ។ ចំណែកក្នុងសច្ច: ២ ក្រៅពីនេះ ព្រះយោគាវចររមែងធ្វើកម្ម ដោយការស្តាប់តែម្យ៉ាង យ៉ាងនេះថា និរោធសច្ច គួរស្រឡាញ់ គួរពេញចិត្ត មគ្គសច្ច គួរស្រឡាញ់ គួរពេញចិត្ត ។ ព្រះយោគាវចរនោះ កាលធ្វើយ៉ាងនេះ រមែងចាក់ធ្លុះសច្ច:ទាំង ៤ ដោយបដិវេធញ្ញាណតែម្យ៉ាង រមែងត្រាស់ដឹង ដោយអភិសមយញ្ញាណតែម្យ៉ាង គឺចាក់ធ្លុះទុក្ខសច្ចដោយបដិវេធ គឺបរិញ្ញាកិច្ច ចាក់ធ្លុះសមុទយ: ដោយបហានកិច្ច ចាក់ធ្លុះនិរោធសច្ច ដោយសច្ឆិកិរិយាកិច្ច ចាក់ធ្លុះមគ្គសច្ចដោយភាវនាកិច្ច ។ រមែងត្រាស់ដឹងទុក្ខសច្ច ដោយអភិសម-យញ្ញាណ គឺបរិញ្ញាកិច្ច ត្រាស់ដឹងសមុទយសច្ច ដោយបហានកិច្ច ត្រាស់ដឹងនិរោធសច្ច ដោយសច្ឆិកិរិយាកិច្ច ត្រាស់ដឹងមគ្គសច្ច ដោយភាវនាកិច្ច ។ ក្នុងខាងដើម ព្រះយោគាវចរនោះ មានបដិវេធញ្ញាណក្នុងសច្ច: ២ ខាងដើម ដោយការកំណត់ ការសាកសួរ ការស្តាប់ ការទ្រទ្រង់ចាំ និងការពិចារណា ចំណែកក្នុងសច្ច: ២ ខាងចុង ព្រះយោគាវចរមានបដិវេធញ្ញាណ ដោយ អំណាចការស្តាប់តែម្យ៉ាងក្នុងខាងក្រោយ ទើបមានបដិវេធញ្ញាណក្នុងសច្ច: ៣ ដោយកិច្ច មានបដិវេធញ្ញាណ ក្នុងនិរោធសច្ចដោយអារម្មណ៍ ។ ចំណែក បច្ចវេក្ខណញ្ញាណ មានដល់ព្រះយោគាវចរ ដែលសម្រេចសច្ច:ហើយ ។ ព្រះ

យោគាវចរនេះ ជាអ្នកផ្តើមបំពេញសេចក្តីព្យាយាម ព្រោះដូច្នោះ ទើបមិនត្រាស់បច្ចវេក្ខណញ្ញាណនោះទុកក្នុងទីនេះ ។ ម្យ៉ាងទៀត កាលកិក្ខុនេះកំណត់ដឹងក្នុងខាងដើម សេចក្តីរំពឹង រួបរួមចិត្ត ធ្វើទុកក្នុងចិត្ត និងពិចារណាថា អញកំណត់ដឹងទុក្ខ អញលះសមុទយៈ អញធ្វើឲ្យច្បាស់និរោធ អញចម្រើនមគ្គដូច្នេះ មិនទាន់មាន នឹងមាន តាំងពីការកំណត់ទៅ ។ ចំណែកក្នុងវេលាខាងក្រោយ ទុក្ខ ឈ្មោះថា កំណត់ដឹងហើយ សមុទយៈឈ្មោះថាលះចេញហើយ និរោធ ឈ្មោះថា ធ្វើឲ្យច្បាស់ហើយ មគ្គ ឈ្មោះថា ធ្វើឲ្យកើតហើយ ។

ក្នុងសច្ចៈទាំងនោះ ២ សច្ចៈខាងដើម ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាក ២ សច្ចៈខាងចុង ឈ្មោះថា ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ។ សេចក្តីពិត ទុក្ខសច្ច ជ្រាកជតាំងពីកើតមក សូម្បីពោលថា ទុក្ខហ្ន៎ ក្នុងវេលាដែលប៉ះជង្គត់ និងបន្ទាមុតជាដើម ។ សូម្បីសមុទយសច្ច ក៏ជ្រាកជតាំងពីកើតមក ដោយអំណាចចង់ទំពា ចង់បរិភោគដើម ។ តែសូម្បីសច្ចៈទាំង ២ នោះ ក៏ឈ្មោះថា ជ្រាលជ្រៅ ដោយលក្ខណៈ និងការចាក់ធ្លុះ ។ ២ សច្ចៈនោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាកដោយប្រការដូច្នេះ ។ ចំណែកសេចក្តីព្យាយាម ដើម្បីឃើញ ២ សច្ចៈក្រៅពីនេះ ក៏ដូចលាដៃចាប់ភវគ្គព្រហ្ម ឈានជើងទៅប៉ះអវីចីនរក និងដូចយកចុងភេមទ្រាយដែលគេច្រៀកជា ៧ ចំណែក ឲ្យចុងនិងចុងទល់គ្នា ។ សច្ចៈខាងចុងទាំង ២ នោះ ឈ្មោះថា ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ថា នេះសេចក្តីដឹងក្នុងទុក្ខ ដូច្នេះជា

ដើមទ្រង់សំដៅដល់ការកើតញាណដែលជាចំណែកខាងដើម ក្នុង ๔ សច្ចៈ ដែលឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាក និងដែលឈ្មោះថា ឃើញបានលំបាកព្រោះជ្រាលជ្រៅ ដោយអំណាចការកំណត់ជាដើម ដោយប្រការដូច្នេះ ។ ចំណែកក្នុងបដិវេធញ្ញាណនោះ ក៏មាន ๑ ប៉ុណ្ណោះ ។

ការត្រិះរិះ មានការត្រិះរិះចេញចាកកាមជាដើម ផ្សេងគ្នាអំពីខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកកាម ព្យាបាទ និងវិហិង្សាផ្សេងគ្នា ។ តែក្នុងមគ្គក្ខណៈ កុសលសង្កប្បតែម្យ៉ាងប៉ុណ្ណោះកើតឡើងឲ្យអង្គមគ្គបរិបូណ៌ ដោយឲ្យសម្រេចការមិនកើតនៃអកុសលសង្កប្ប ដែលកើតហើយក្នុងឋានៈទាំង ๓ នេះ ព្រោះកម្ចាត់ផ្លូវនៃអកុសលវិតក្កនោះបានជាសមុច្ឆេទ នេះឈ្មោះថា **សម្មាសង្កប្ប ។**

សូម្បីកុសលធម៌ មានចេតនាវៀរចាកមុសាវាទជាដើម ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកមុសាវាទជាដើមផ្សេងគ្នា ។ តែក្នុងមគ្គក្ខណៈ កុសលចេតនាតែម្យ៉ាងប៉ុណ្ណោះកើតឡើងឲ្យអង្គមគ្គបរិបូណ៌ ដោយឲ្យសម្រេចការមិនកើតនៃអកុសលចេតនាជាគ្រឿងទ្រុស្តសីល ដែលកើតហើយក្នុងឋានៈទាំង ๔ នេះ ព្រោះកម្ចាត់ផ្លូវនៃអកុសលចេតនាជាគ្រឿងទ្រុស្តសីលនោះបានជាសមុច្ឆេទ នេះឈ្មោះថា **សម្មាវាចា ។**

សូម្បីកុសលធម៌ មានចេតនាវៀរចាកបាណាតិបាតជាដើម ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកបាណាតិបាតជាដើមផ្សេងគ្នា ។ តែក្នុងមគ្គក្ខណៈ កុសលចេតនាដែលវៀរចាកតែ๑ ប៉ុណ្ណោះ កើតឡើងឲ្យអង្គនៃមគ្គ

បរិបូណ៌ ដោយឲ្យសម្រេចការមិនកើតនៃអកុសលចេតនាជាគ្រឿងទ្រុស្តសីល ដែលកើតហើយក្នុងឋាន:ទាំង ៣ នេះ ព្រោះកម្ចាត់ផ្លូវបានដោយសមុច្ឆេទ នេះឈ្មោះថា **សម្មាកម្មន្ត** *។*

បទថា **មិច្ឆាអាជីវំ** *បានដល់ កាយទុច្ចរិត និងវចីទុច្ចរិត ដែលប្រព្រឹត្តទៅដើម្បីរបស់ទំពា របស់បរិភោគជាដើម ។ បទថា* **មហាយ** *គឺរៀរ ។ បទថា* **សម្មាអាជីវេន** *គឺដោយអាជីវ:ដែលព្រះពុទ្ធទ្រង់សរសើរ ។ បទថា* **ជីវិកំ កប្បេតិ** *គឺដំណើរនៃការចិញ្ចឹមជីវិត ។ ដែលឈ្មោះថា សម្មាអាជីវ: ផ្សេងគ្នាខាងដើម ព្រោះសញ្ញាក្នុងការរៀរចាកទុច្ចរិត មានមុសាវាទជាដើមផ្សេងគ្នា ។ តែក្នុងមគ្គក្ខណ: កុសលចេតនាដែលសម្រាប់រៀរតែ ១ ប៉ុណ្ណោះ កើតឡើងឲ្យអង្គនៃមគ្គបរិបូណ៌ ដោយឲ្យសម្រេចការមិនកើតនៃមិច្ឆាជីវចេតនាដែលជាគ្រឿងទ្រុស្តសីល ដែលកើតហើយក្នុងឋាន:ទាំង ៧ (កាយទុច្ចរិត ៣ វចីទុច្ចរិត ៤) នេះឯង ព្រោះកម្ចាត់ផ្លូវបានជាសមុច្ឆេទ នេះឈ្មោះថា* **សម្មាអាជីវ** *។*

បទថា **អនុប្បន្នានំ** *គឺដែលមិនទាន់កើតដល់ខ្លួនក្នុងភពមួយ ឬក្នុងអារម្មណ៍បែបនោះ ។ តែព្រះយោគាវចរឃើញបាប អកុសលធម៌ ដែលកំពុងកើតដល់អ្នកដទៃ រមែងញ៉ាំងឆន្ទ:ឲ្យកើត ប្រារព្ធសេចក្តីព្យាយាម ផ្គងចិត្តទុកដើម្បីមិនឲ្យកើតបាបអកុសលដែលមិនទាន់កើត ដោយគិតយ៉ាងនេះថា ឱហ្ន៎ បាបអកុសលធម៌បែបនោះ មិនគប្បីកើតដល់អញ ដូច្នេះ ។ បទថា* **ឆន្ទំ ជនេតិ** *គឺឲ្យកើតសេចក្តីពេញចិត្តក្នុងសេចក្តីព្យាយាម ដែលឲ្យសម្រេចបដិបទា ដែលមិនឲ្យកើតបាបអកុសលទាំងនោះ ។ បទថា* **វាយមតិ** *គឺធ្វើ*

សេចក្តីព្យាយាម ។ បទថា **วิริยํ อารภติ** *គឺញុំងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅ។បទថា* **จิตฺตํ ปคฺคณฺหาติ** *គឺធ្វើការផ្គងចិត្តដោយសេចក្តីព្យាយាម។ បទថា* **ปธหาติ** *គឺញុំងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅថា នឹងសល់តែស្បែក សរសៃ ឆ្អឹង ក៏ដោយចុះ ដូច្នេះ ។ បទថា* **อุปฺปนฺนานំ** *គឺដែលធ្លាប់កើតហើយដល់ខ្លួន ដោយការកម្រើកឡើង ។ រមែងឲ្យកើតឆន្ទៈ ដើម្បីលះបាបអកុសលទាំងនោះថា ឥឡូវនេះ អញនឹងមិនឲ្យបាបអកុសលដូច្នោះកើតឡើងឡើយ ។ បទថា* **อนุปฺปนฺนานํ กุสลานํ** *គឺកុសលធម៌ មានបឋមជ្ឈានជាដើម ដែលខ្លួនមិនទាន់បាន ។ បទថា* **อุปฺปนฺนานំ** *គឺកុសលទាំងនោះឯង ដែលខ្លួនបានហើយ ។ បទថា* **ឋิติยา** *គឺដើម្បីតាំងនៅដោយការកើតបន្តគ្នារឿយៗ ។ បទថា* **อสมฺโมสาย** *គឺដើម្បីមិនឲ្យសាបសូន្យ ។ បទថា* **ภิยฺโยภาวาย** *គឺដើម្បីចម្រើនជាភយ្យោភាព ។ បទថា* **เวปุลฺลาย** *គឺដើម្បីការទូលាយ ។ បទថា* **ภาวนาย ปาริปูริยา** *គឺដើម្បីភាពបរិបូណ៌ ។ សម្មាវាយាម:នេះផ្សេងគ្នាក្នុងខាងដើម ព្រោះចិត្តដែលគិតមិនឲ្យកើតអកុសល ដែលមិនទាន់កើតជាដើមផ្សេងគ្នា ។ តែក្នុងមគ្គក្ខណៈ កុសលវីរិយៈតែមួយប៉ុណ្ណោះ កើតឡើងឲ្យអង្គនៃមគ្គបរិបូណ៌ ដោយឲ្យសម្រេចកិច្ចក្នុងឋាន:ទាំង ๔ នេះដូចគ្នា នេះឈ្មោះថា* **สมฺมาวายาม ។**

សម្មាសតិ ផ្សេងគ្នាក្នុងខាងដើម ព្រោះចិត្តដែលកំណត់អារម្មណ៍ មានកាយជាដើមផ្សេងគ្នា តែក្នុងនៃមគ្គក្ខណៈ សតិតែម្យ៉ាងប៉ុណ្ណោះកើតឡើងឲ្យអង្គ

នៃមគ្គបរិបូណ៌ ដោយឲ្យសម្រេចកិច្ចក្នុងឋាន: ๔ នេះឈ្មោះថា **សម្មាសតិ** ។

ឈានទាំងទ្បាយផ្សេងគ្នា ទាំងខាងដើម ទាំងក្នុងមគ្គក្ខណៈ ។ ក្នុងខាងដើម ផ្សេងគ្នាដោយសមាបត្តិ ។ ក្នុងមគ្គក្ខណៈ ផ្សេងគ្នាដោយមគ្គ ។ ពិតហើយ មគ្គទី ๑ នៃមគ្គក្ខណៈមួយ មានបឋមជ្ឈានជាបាទ មគ្គទី ๒ ជាដើម មានបឋមជ្ឈានជាបាទខ្លះ មានឈានណាមួយ ក្នុងទុតិយជ្ឈានជាដើមជាបាទខ្លះ ។ មគ្គទី ๑ នៃមគ្គក្ខណៈ សូម្បីតែមួយ មានឈានណាមួយនៃទុតិយជ្ឈានជាដើមជាបាទ សូម្បីមគ្គទី ๒ ជាដើម ក៏មានឈានណាមួយនៃទុតិយជ្ឈានជាដើមជាបាទខ្លះ មានបឋមជ្ឈានជាបាទខ្លះ ។ មគ្គទាំង ๔ ពោលដោយឈាន ដូចគ្នាក៏មាន ផ្សេងគ្នាក៏មាន ដូចគ្នាកន្លែងខ្លះក៏មាន ដោយប្រការដូច្នេះ ។ នេះជាប្លែកគ្នានៃមគ្គនោះ ព្រោះកំណត់ដោយឈានដែលជាបាទ ។ គប្បីជ្រាបអធិប្បាយដោយការកំណត់ដោយឈានជាបាទមុនថា មគ្គដែលកើតដល់ព្រះយោគាវចរដែលបានបឋមជ្ឈាន ចេញចាកបឋមជ្ឈានចម្រើនវិបស្សនា ឈ្មោះថា មានបឋមជ្ឈានជាបាទ ។ អង្គនៃមគ្គ និងពោជ្ឈង្គរមែងបរិបូណ៌ក្នុងបឋមជ្ឈាននេះដោយពិត ។ មគ្គដែលកើតដល់យោគាវចរដែលបានទុតិយជ្ឈាន ចេញចាកទុតិយជ្ឈានហើយ ចម្រើនវិបស្សនា ឈ្មោះថា មានទុតិយជ្ឈានជាបាទ ។ ចំណែកអង្គមគ្គក្នុងទុតិយជ្ឈាននេះ មាន ๗ ប្រការ ។ មគ្គដែលកើតដល់ព្រះយោគាវចរ ដែលចេញចាកតតិយជ្ឈានហើយចម្រើនវិបស្សនា ឈ្មោះថា មានតតិយជ្ឈានជាបាទ ។ ចំណែកអង្គមគ្គក្នុងតតិយជ្ឈាននេះ មាន ๗ តែពោជ្ឈង្គមាន ๖ ប្រការ ។ ចំពោះព្រះយោគា-

វចរដែលចេញចាកចតុត្ថជ្ឈាន ដរាបដល់នេវសញ្ញានាសញ្ញាយតន: ក៏នយ
នេះដូចគ្នា ។ ឈានពួក ៤ និងពួក ៥ រមែងកើតក្នុងអរូប ហើយឈាននោះ
លោកពោលថាជាលោកុត្តរ មិនមែនលោកិយ ។ សួរថា ក្នុងឈាន មាន
បឋមជ្ឈានជាដើមនេះ តើដូចម្តេច ។ ឆ្លើយថា ក្នុងឈាន មានបឋមជ្ឈាន
ជាដើមនេះ ព្រះយោគាវចរនោះ ចេញចាកឈានណាហើយ បានសោតា-
បត្តិមគ្គ ចម្រើនអរូបសមាបត្តិ ហើយកើតក្នុងអរូបភព មគ្គទាំង ៣ មាន
ឈាននោះជាបាទ កើតឡើងដល់ព្រះយោគាវចរនោះ ក្នុងអរូបភពនោះ ។
លោកកំណត់មគ្គ ដែលមានឈានជាបាទតែម្យ៉ាង ដោយប្រការដូច្នេះ ។ តែ
ព្រះថេរ:ពួកខ្លះពោលថា កំណត់ខន្ធជាអារម្មណ៍នៃវិបស្សនា ។ ពួកខ្លះពោល
ថា កំណត់អធ្យាស្រ័យបុគ្គល ។ ពួកខ្លះពោលថា កំណត់វិបស្សនាដែលជា
វុដ្ឋានគាមិនី ។ វិនិច្ឆ័យវាទ:របស់ព្រះថេរ:ទាំងនោះ គប្បីជ្រាបតាមនយ
ដែលលោកពោលក្នុងអធិការពោលអំពីវុដ្ឋានគាមិនីវិបស្សនា ក្នុងគម្ពីរវិសុទ្ធិ-
មគ្គ ។ បទថា **អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ** សេចក្តីថា ធម៌នេះ ខាង
ដើមជាលោកិយ ខាងចុង ហៅថា **លោកុត្តរសម្មាសមាធិ ។**

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំង-
ឡាយ ព្រោះកំណត់សច្ច: ៤ របស់ខ្លួនក្តី របស់អ្នកដទៃក្តី ព្រោះកំណត់សច្ច:
៤ របស់ខ្លួនតាមកាល និងរបស់អ្នកដទៃតាមកាលក្តីយ៉ាងនេះ ។ ចំណែកការ
កើត និងការរលត់ក្នុងសច្ចបព្ធ:នេះ គប្បីជ្រាបដោយការកើត និងការសូន្យ
ទៅនូវសច្ច: ៤ តាមសេចក្តីពិត ។ ពាក្យដទៃក្រៅពីនេះ មានន័យដូចពោល

មកហើយនោះឯង ។

ក្នុងសច្ចបព្វៈនេះ ផ្សេងគ្នាតែម្យ៉ាង គឺគប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់សច្ចៈ ๔ ជាអារម្មណ៍ ជាទុក្ខសច្ចជាដើម ហើយគប្បីជ្រាបថា ជាបដិបទានាំចេញចាកទុក្ខរបស់កិកូ ដែលកំណត់សច្ចៈជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏មានន័យដូចគ្នា ។

សច្ចបព្វៈ ចប់

សរុបសេចក្តី

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ កម្មដ្ឋាន ๒๑ គឺអានាបានបព្វៈ ๑ ចតុឥរិយាបថបព្វៈ ๑ ចតុសម្បជញ្ញបព្វៈ ๑ ទ្វត្តឹសាការ ๑ ចតុធាតុវវត្ថាន: ๑ នវសីវថិកា ๑ វេទនានុបស្សនា ๑ ចិត្តានុបស្សនា ๑ នីវរណបរិគ្គហៈ ๑ ខន្ធបរិគ្គហៈ ๑ អាយតនបរិគ្គហៈ ๑ ពោជ្ឈង្គបរិគ្គហៈ ๑ សច្ចបរិគ្គហៈ ๑ ។

បណ្តាកម្មដ្ឋាន ๒๑ នោះ កម្មដ្ឋាន ๑๑ គឺអានាបាន ๑ ទ្វត្តឹសាការ ๑ នវសីវថិកា ๑ ជាអប្បនាកម្មដ្ឋាន ។ តែព្រះមហាសិវត្ថេរ អ្នករចនាគម្ពីរទីឃនិកាយ ពោលថា ព្រះមានព្រះភាគត្រាស់នវសីវថិកា ដោយអានាបានុបស្សនា ។ ព្រោះដូច្នោះ តាមមតិរបស់លោក អានាបាន និងទ្វត្តឹសាការ ๒ ប៉ុណ្ណេះ ជាអប្បនាកម្មដ្ឋាន ។ កម្មដ្ឋានដ៏សេស ជាឧបចារកម្មដ្ឋាន សួរថា ការតាំងមាំកើតក្នុងកម្មដ្ឋាននោះទាំងអស់ ឬមិនកើត ឆ្លើយថា មិនមែនមិនកើតសេចក្តីតាំងមាំ មិនកើតក្នុងឥរិយាបថសម្បជញ្ញៈ នីវរណៈ និងពោជ្ឈង្គ

កើតក្នុងកម្មដ្ឋានដ៏សេស ។ ចំណែកព្រះមហាសិវៈពោលថា សេចក្តីតាំងមាំ រមែងកើតក្នុងកម្មដ្ឋានទាំងអស់ ព្រោះព្រះយោគាវចរនេះ កំណត់យ៉ាងនេះថា ឥរិយាបថ ៤ មានដល់អញ ឬមិនមានហ្ន៎ សម្បជញ្ញៈ ៤ មានដល់អញ ឬមិនមានហ្ន៎ នីវរណៈ ៥ មានដល់អញ ឬមិនមានហ្ន៎ ពោជ្ឈង្គ ៧ មានដល់អញ ឬមិនមានហ្ន៎ ដូច្នេះ ព្រោះដូច្នោះ សេចក្តីតាំងមាំ តែងកើតក្នុងកម្មដ្ឋានទាំងអស់ ។

អានិសង្ស

[๑๓๘] *បទថា* **យោ ហิ កោចิ ភิក្ខវេ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ។ បទថា* **ឍវំ ភាវេយ្យ** *សេចក្តីថា គប្បីចម្រើនតាមលំដាប់ភាវនា ដែលពោលមកហើយតាំងអំពីដើម ។ បទថា* **ចាជិកង្ខំ** *សេចក្តីថា គប្បីសង្ឃឹមបានគប្បីប្រាថ្នាបានពិតប្រាកដ ។ បទថា* **អញ្ញា** *សំដៅដល់ អរហត្ត ។ បទថា* **សតិ វា ឧបាធិសេសេ** *សេចក្តីថា កាលឧបាទិសេសវិបាកក្ខន្ធ ដែលកិលេសមានតណ្ហាជាដើម ចូលទៅប្រកាន់នៅមាន មិនទាន់អស់ទៅ ។ បទថា* **អនាគាមិតា** *ប្រែថា ភាពជាព្រះអនាគាមី ។ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សម្តែងពាក្យប្រៀនប្រដៅ ជាធម៌នាំអ្នកបដិបត្តិចេញចាកទុក្ខដោយ ๗ ឆ្នាំយ៉ាងនេះហើយ កាលទ្រង់សម្តែងវេលាបដិបត្តិដែលតិចទៅជាងនោះទៀត ទើបត្រាស់ថា* **តិដ្ឋន្តុ ភិក្ខវេ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ ត្រាស់ដោយ*

វេនេយ្យបុគ្គលថ្នាក់កណ្តាល ។ តែដែលត្រាស់ថា បុគ្គលទទួលពាក្យប្រៀនប្រដៅវេលាព្រឹក សម្រេចគុណវិសេស វេលាល្ងាច ទទួលពាក្យប្រៀនប្រដៅវេលាល្ងាច សម្រេចគុណវិសេសវេលាព្រឹក ដូច្នេះ ទ្រង់សំដៅដល់បុគ្គលដែលមានបញ្ញាមុតស្រួច ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងថា ពាក្យប្រៀនប្រដៅរបស់តថាគត នាំអ្នកបដិបត្តិចេញចាកទុក្ខយ៉ាងនេះហើយ កាលទ្រង់ញុំាងទេសនា ដែលទ្រង់សម្តែងដោយធម៌ដ៏កំពូល គឺអរហត្ត ឲ្យចប់ស្រេចក្នុងឋាន: ២១ ប្រការ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីឈានកន្ទងសោក និងបរិទេវៈ ដើម្បីរម្ងាប់ទុក្ខ និងទោមនស្ស ដើម្បីសម្រេចញាយធម៌ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន នេះគឺសតិប្បដ្ឋាន ៤ ដោយប្រការដូច្នេះ ពាក្យណាដែលតថាគតពោលហើយយ៉ាងនេះ ពាក្យនោះ តថាគតអាស្រ័យផ្លូវឯកនេះពោលហើយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

ក្នុងវេលាចប់ទេសនា ភិក្ខុ ៣ ម៉ឺនអង្គ តាំងនៅក្នុងអរហត្ត ។ អដ្ឋកថាមហាសតិប្បដ្ឋានសូត្រ ក្នុងទីឃនិកាយឈ្មោះសុមង្គលវិលាសិនី ចប់ ៗ

មហាសតិប្បដ្ឋានសូត្រ ចប់

សូត្រទី ៩ ចប់

สุตฺตนฺตปิฎก

ชายาสิราชญฺญสุตฺรที ๑๐

[๑๓๙] ขุ้พเจ้าได้สดับมาอย่างนี้ ฯ สมัยหนึ่ง พระกุมารกัสสปผู้มีอายุ เที่ยวจาริกไปในแคว้นโกศล พร้อมด้วยหมู่ภิกษุสงฆ์เป็นอันมาก จำนวน ๕๐๐ รูป ได้ไปถึงเสตัพยนคร ของชาวโกศลทั้งหลาย ฯ ได้ยินว่า พระกุมารกัสสปผู้มีอายุ ประทับอยู่ในป่าใหญ่ ทางทิศเหนือแห่งกรุงเสตัพยะ ใกล้กรุงเสตัพยะนั้น ฯ สมัยนั้นแล พระเจ้าปายาสิราชญัญ ครองเสตัพยนคร ซึ่งเป็นนครอันมั่งคั่งด้วยสัตว์ และมนุษย์ บริบูรณ์ด้วยข้าวและน้ำ บริบูรณ์ด้วยข้าวสาลี เป็นราชธานีของพระเจ้าประเสนทิโกศล ทรงได้รับพระราชทานเป็นบำนาญ เป็นบำนาญอันประเสริฐ ฯ สมัยนั้นแล พระเจ้าปายาสิราชญัญ ได้มีทิฏฐิอันลามกอย่างนี้ว่า โลกอื่นไม่มี สัตว์ผู้เป็นโอปปาติกะไม่มี ผลวิบากของกรรมทั้งหลายที่ทำดีทำชั่วไม่มี ฯ พราหมณ์และคหบดีชาวกรุงเสตัพยะ ได้ยินกิตติศัพท์ดังนี้ว่า ได้ยินว่า พระสมณโคดมผู้เป็นศากยบุตร เสด็จจาริกไปในแคว้นโกศล พร้อมด้วยหมู่ภิกษุสงฆ์เป็นอันมาก จำนวน ๕๐๐ รูป ได้เสด็จมาถึงกรุงเสตัพยะ ประทับอยู่ในป่าใหญ่ ทางทิศเหนือแห่งกรุงเสตัพยะ ใกล้กรุงเสตัพยะนั้น ฯ ก็กิตติศัพท์อันงามของพระสมณโคดมพระองค์นั้น ได้ฟุ้งไปอย่างนี้ว่า แม้เพราะเหตุนี้ ๆ พระผู้มีพระภาคนั้น เป็นพระอรหันต์ ตรัสรู้ชอบเองโดยชอบ ถึงพร้อมด้วยวิชชาและจรณะ เสด็จไปดีแล้ว ทรงรู้แจ้งโลก เป็นสารถีฝึกบุรุษที่ควรฝึกได้ดังนี้ ฯ ครั้นพราหมณ์และคหบดีชาวกรุงเสตัพยะนั้น ได้ฟังกิตติศัพท์ของพระกุมารกัสสปผู้เจริญนั้นแล้ว ได้เกิดความคิดขึ้นอย่างนี้ว่า ได้ยินว่า พระกุมารกัสสปผู้มีอายุ ประทับอยู่ในป่าใหญ่ ทางทิศเหนือแห่งกรุงเสตัพยะ ใกล้กรุงเสตัพยะนี้ ฯ ก็พระเจ้าปายาสิราชญัญ ได้มีทิฏฐิอันลามกอย่างนี้ว่า โลกอื่นไม่มี สัตว์ผู้เป็นโอปปาติกะไม่มี ผลวิบากของกรรมทั้งหลายที่ทำดีทำชั่วไม่มี ฯ

ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ជាពហុស្សូត មានសម្តីដ៏វិចិត្រ មានបដិភាណដ៏ល្អ ជាអ្នកត្រាស់ដឹងផង ជាព្រះអរហន្តផង ក៏កាលដែលបានជួបព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃណាស់ ។ លំដាប់នោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ ចេញពីក្រុងសេតព្យៈទៅ ជាពួក ជាកង មានមុខត្រសងទៅកាន់ទិសខាងជើង ដើរទៅកាន់ព្រៃផ្នង់ ។

[๑๔๐] សម័យនោះឯង ព្រះបាទបាយាសិរាជញ្ញៈ ទ្រង់ស្តេចចូលទៅកាន់ក្រឡាបបន្ទំក្នុងវេលាថ្ងៃខាងលើប្រាសាទ ។ ព្រះបាទបាយាសិរាជញ្ញៈបានទតឃើញពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ កំពុងចេញពីក្រុងសេតព្យៈ ជាពួក ជាកង មានមុខត្រសងទៅកាន់ទិសខាងជើង លុះទតឃើញហើយ ទ្រង់ត្រាស់សួរខត្តាមាត្យថា ម្នាលខត្តៈដ៏ចម្រើន ចុះពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ ចេញទៅពីក្រុងសេតព្យៈ ជាពួក ជាកង មានមុខត្រសងទៅទិសខាងជើង ដើរទៅកាន់ព្រៃផ្នង់ ធ្វើអ្វីហ្ន៎ ។ ខត្តាមាត្យក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ជ្បតមានសមណៈឈ្មោះកុមារកស្សប ជាសាវ័កនៃព្រះសមណគោតម គ្រាចរទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃប្រើនចំនួន ๕๐๐ រូប មកដល់ក្រុងសេតព្យៈដោយលំដាប់ ហើយគង់នៅក្នុងព្រៃផ្នង់ ជាខាងជើងក្រុងសេតព្យៈ ជិតក្រុងសេតព្យៈ កិត្តិសព្ទ សរសើរកុមារកស្សបដ៏ចម្រើននោះ ពីរោះឮខ្ចរខ្ចាយទៅយ៉ាងនេះថា លោកជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ជាពហុស្សូត មានសម្តីដ៏វិចិត្រ មានបដិភាណដ៏ល្អ ជាអ្នកត្រាស់ដឹងផង ជាព្រះអរហន្តផង ឯពួក

ព្រាហ្មណ៍ និងគហបតីទាំងនោះ នឹងចូលទៅរកជួបព្រះកុមារកស្សបដ៏ចម្រើន
នោះ ។ ព្រះបាទបាយាសិរាជញ្ញៈ មានព្រះបន្ទូលថា ម្នាលខត្តៈដ៏ចម្រើន
បើដូច្នោះ ចូរអ្នកចូលទៅរកពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ
លុះចូលទៅដល់ហើយ និយាយនឹងពួកព្រាហ្មណគហបតី អ្នកក្រុងសេតព្យៈ
យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ព្រះបាទបាយាសិរាជញ្ញៈ បានត្រាស់យ៉ាង
នេះថា អ្នកដ៏ចម្រើនទាំងឡាយ ចូររង់ចាំសិន ព្រះបាទបាយាសិរាជញ្ញៈ នឹង
ចូលទៅដើម្បីជួបសមណៈកុមារកស្សបដែរ ហើយត្រាស់ដូច្នេះថា ពីមុនមក
សមណៈកុមារកស្សប តែងញ្ចុាំងពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុង
សេតព្យៈ ដែលល្ងង់ មិនវាងវៃ ឲ្យទាល់តែចូលចិត្តច្បាស់ថា លោកដទៃ
មាន សត្វជាឧបបាតិកៈមាន ផល និងវិបាករបស់កម្មទាំងឡាយដែលពួក
សត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ម្នាលខត្តៈដ៏ចម្រើន តែបើតាម
ពិតនោះ លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់
កម្មទាំងឡាយដែលពួកសត្វ ធ្វើល្អ ធ្វើអាក្រក់មិនមានទេ ។ ខត្តាមាត្យនោះ
ទទួលព្រះឧង្ការរបស់ព្រះបាទបាយាសិរាជញ្ញៈថា ការុណាវិសេស ហើយក៏
ចូលទៅរកពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ លុះចូលទៅដល់
ហើយ បាននិយាយនឹងពួកព្រាហ្មណគហបតី អ្នកក្រុងសេតព្យៈយ៉ាងនេះថា
ម្នាលអ្នកដ៏ចម្រើន ព្រះបាទបាយាសិរាជញ្ញៈត្រាស់យ៉ាងនេះថា ចូរអ្នកដ៏
ចម្រើនទាំងឡាយរង់ចាំសិន ដ្បិតព្រះបាទបាយាសិរាជញ្ញៈ នឹងចូលទៅជួប
សមណៈកុមារកស្សបដែរ ។ លំដាប់នោះ ព្រះបាទបាយាសិរាជញ្ញៈ មានពួក

ព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈហៃហមអមអង្គ ក៏ចូលទៅរកព្រះកុមារកស្សបជ៏មានអាយុ ដែលនៅក្នុងព្រៃធ្នង់ លុះចូលទៅដល់ហើយ ក៏មានបន្ទូលវាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះកុមារកស្សបជ៏មានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យគួរឲ្យរីករហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ចំណែកពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ ពួកខ្លះថ្វាយបង្គំព្រះកុមារកស្សបជ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះនិយាយពាក្យវាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះកុមារកស្សបជ៏មានអាយុ លុះបញ្ចប់ពាក្យវាក់ទាក់ចំណេះសំណាល និងពាក្យគួរឲ្យរីករហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ អង្គុយក្នុងទីសមគួរ ប្រណមអញ្ជលីចំពោះព្រះកុមារ-កស្សបជ៏មានអាយុ ពួកខ្លះ ប្រកាសនាម និងគោត្រ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ អង្គុយស្ងៀមក្នុងទីដ៏សមគួរ ។ លុះព្រះបាទបាយាសិរាជញ្ញៈគង់ក្នុងទីដ៏សមគួរហើយ ទើបមានព្រះឱង្ការនឹងព្រះកុមារកស្សបជ៏មានអាយុយ៉ាងនេះថា បពិត្រព្រះកស្សបជ៏ចម្រើន ខ្ញុំតែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ព្រះកុមារកស្សបថ្វាយព្រះពរថា បពិត្ររាជញ្ញៈ អាត្មាភាពបានឃើញ បានឮបុគ្គលដែលធ្លាប់និយាយយ៉ាងនេះ យល់យ៉ាងនេះហើយ តែមិនសមបើបុគ្គលនោះ និយាយយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមានដូច្នេះសោះ

បពិត្ររាជញ្ញ: បើដូច្នោះ អាត្មាភាពនឹងទូលសួរមហាបពិត្រ ក្នុងដំណើរនេះ ប្រស្នានេះ ពេញព្រះហឫទ័យនៃមហាបពិត្រយ៉ាងណា សូមមហាបពិត្រ ព្យាករប្រស្នានោះយ៉ាងនោះចុះ បពិត្ររាជញ្ញ: ចុះទ្រង់សម្គាល់ដំណើរនោះថា ដូចម្តេច ព្រះចន្ទ និងព្រះអាទិត្យនេះ នៅក្នុងលោកនេះ ឬនៅក្នុងលោកដទៃ ជាទេវតា ឬជាមនុស្ស ។ ព្រះបាទបាយាសិរាជញ្ញ:តបថា បពិត្រព្រះកស្សបដ៏ចម្រើន ព្រះចន្ទ និងព្រះអាទិត្យនេះ នៅក្នុងលោកដទៃ មិនមែននៅក្នុងលោកនេះទេ ជាទេវតា មិនមែនជាមនុស្សទេ ។ ព្រះកុមារកស្សបថ្វាយ ព្រះពរថា ឱរាជញ្ញ: បើតាមបរិយាយនេះ សូមមហាបពិត្របែរព្រះយោបល់ យល់យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឱបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ។

[១៤១] ព្រះបាទបាយាសិរាជញ្ញ:ត្រាស់ថា ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះ ក៏គួរម្យ៉ាងដែរហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ឃើញ ក្នុងហេតុន៉ុះ យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមានទេ ដោយ ហេតុនេះ ។ ថ្វាយព្រះពររាជញ្ញ: ចុះបរិយាយដែលនាំឲ្យមហាបពិត្រ មាន សេចក្តីយល់ឃើញយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិក: មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដូច្នេះ តើមានឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយដែលនាំឲ្យខ្ញុំមាន សេចក្តីយល់ឃើញយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិក:

មិនមាន ផលវិបាកវបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះមានដែរ ។ ថ្វាយព្រះពរព្រាជញ្ញៈ បរិយាយនោះតើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួកមិត្តអាមាត្យ និងញាតិសាលោហិតរបស់ខ្ញុំ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគុំកួន មានសេចក្តីយល់ខុស ពួកមិត្តអាមាត្យជាដើមនោះ លុះសម័យខាងក្រោយមក ជាបុគ្គលមានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ កាលដែលខ្ញុំដឹងថា ពួកមិត្តអាមាត្យទាំងនោះ មុខជានឹងមិនស្បើយចាកអាពាធនេះ ក្នុងកាលឥឡូវនេះទេ ខ្ញុំក៏បានចូលទៅរកពួកមិត្តអាមាត្យទាំងនោះ ហើយនិយាយយ៉ាងនេះថា នែអ្នកដ៏ចម្រើន មានសមណព្រាហ្មណ៍ ពួកមួយនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ពួកជនណាសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគុំកួន មានសេចក្តីយល់ខុស ពួកជននោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ដូច្នេះ ឯអ្នកដ៏ចម្រើនទាំងឡាយ សុទ្ធតែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគុំកួន មានសេចក្តីយល់ខុសហើយ បើជាពាក្យរបស់សមណ-

ព្រាហ្មណ៍ទាំងនោះពិតមែន អ្នកដ៏ចម្រើនទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ មុខជានឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកពុំខាន នែអ្នកដ៏ចម្រើនទាំងឡាយ បើអ្នកទាំងឡាយបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត-វិស័យ អសុរកាយ នរកមែន អ្នកទាំងឡាយត្រូវមកប្រាប់យើងផងថា លោកដទៃមាន ពួកសត្វជាឧបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ព្រោះថា អ្នកទាំងឡាយដ៏ចម្រើនជាបុគ្គលដែលខ្ញុំគួរជឿ ខ្ញុំគួរទទួលស្តាប់ពាក្យបាន ហេតុណាដែលអ្នកដ៏ចម្រើនទាំងឡាយបានឃើញហើយ ហេតុន៉ុះ នឹងទុកដូចជាខ្ញុំបានឃើញចំពោះខ្លួនឯងដែរ ពួកមិត្តអាមាត្យទាំងនោះ ទទួលតបពាក្យរបស់ខ្ញុំថា ព្រះករុណាវិសេស ដូច្នេះហើយ (ស្លាប់ទៅ) តែមិនឃើញមកប្រាប់ ទាំងមិនបញ្ជូនបម្រើមកឡើយ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយល់យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[១៤២] ថ្វាយព្រះរាជញ្ញ: បើដូច្នោះ អាត្មាភាពនឹងត្រឡប់សួរមហាបពិត្រ ក្នុងបរិយាយន៉ុះវិញ ប្រស្នានេះ ពេញព្រះហប្ចទ័យមហាបពិត្រយ៉ាងណា សូមមហាបពិត្រ ព្យាករប្រស្នានោះយ៉ាងនោះចុះ បពិត្ររាជញ្ញ: មហាបពិត្រសម្គាល់នូវហេតុនោះដូចម្តេច ពួកបុរសរបស់មហាបពិត្រក្នុងដែន

នេះ ចាប់បានចោរដែលប្រព្រឹត្តអាក្រក់មកថ្វាយមហាបពិត្រ រួចក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនេះជាចោរ ប្រព្រឹត្តអាក្រក់ទីឯព្រះអង្គ ទ្រង់សព្វព្រះហឫទ័យនឹង (ដាក់) អាជ្ញាណាដល់ចោរនេះ សូមទ្រង់ដាក់អាជ្ញានោះមក ទើបមហាបពិត្រមានបន្ទូលនឹងបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរនាំគ្នាចងបុរសនេះ ឲ្យមានដើមដៃទៅខាងក្រោយ (ចងស្វាបសេក) ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ រួច (ត្រូវទួង) ស្គរជ័យដែលមានសំឡេងឮខ្លាំង នាំបណ្តើរជុំវិញសព្វច្រកសព្វផ្លូវបំបែក រួចនាំចេញទៅតាមទ្វារខាងត្បូង កាត់ក្បាលត្រង់កន្លែងសម្រាប់ពិឃាតជាខាងត្បូងនគរចុះ បុរសទាំងនោះទទួលព្រះឱង្ការរបស់មហាបពិត្រថា ព្រះករុណាវិសេស ហើយក៏នាំគ្នាចងបុរសនោះ ឲ្យមានដើមដៃទៅខាងក្រោយ ឲ្យខ្ជាប់ដោយខ្សែដ៏មាំ កោរក្បាលឲ្យរលីងចេញ (ទួង) ស្គរជ័យដែលមានសំឡេងឮខ្លាំង នាំបណ្តើរជុំវិញសព្វច្រក សព្វផ្លូវបំបែក រួចនាំចេញទៅតាមទ្វារខាងត្បូង ហើយឲ្យចោរនោះអង្គុយត្រង់កន្លែងសម្រាប់ពិឃាតជាខាងត្បូងនៃនគរ ចុះបើចោរនោះ (ទីឯអង្វរ) ពួកពេជ្ឈឃាដថា សូមពួកពេជ្ឈឃាដដ៏ចម្រើនបង្អង់សិន (ព្រោះ) ពួកមិត្តអាមាត្យ និងញាតិសាលោហិត (របស់ខ្ញុំមាន) ក្នុងស្រុក ឬនិគមឯណោះ ចាំខ្ញុំផ្តែផ្តាំដល់ពួកមិត្តអាមាត្យទាំងនោះហើយ សឹមមកវិញ ដូច្នេះតើបានឬទេ ឬក៏ពួកពេជ្ឈឃាដ (ទាំងនោះ) នឹងចេះតែកាត់ក្បាលចោរដែលកំពុងទួញយំដោយឥតយោគយល់ ។ បពិត្រព្រះកស្សបដ៏ចម្រើន ចោរ

នោះ (នឹងអង្វរ) ពួកពេជ្ឈយាជថា សូមពួកពេជ្ឈយាជដ៏ចម្រើន បង្អង់ឲ្យសិន (ព្រោះ) ពួកមិត្តអាមាត្យ និងញាតិសាលោហិត (របស់ខ្ញុំមាន) ក្នុងស្រុក ឬនិគមនឯណោះ ចាំខ្ញុំផ្តែផ្តាំដល់ពួកមិត្តអាមាត្យនោះរួច សឹមមកវិញ ដូច្នេះ មិនបានឡើយ តាមដែលពិតនោះ ពួកពេជ្ឈយាជនឹងចេះតែកាត់ក្បាលចោរ ដែលកំពុងទួញយំនោះ ឲ្យទាន់តែបាន ។ ថ្វាយព្រះពររាជញ្ញៈ អម្បាលយ៉ាងចោរនោះជាមនុស្សជាតិដូចគ្នាត្រឡាំង ម្តេចគង់ (អង្វរ) ពួកពេជ្ឈយាជជាមនុស្សជាតិដូចគ្នាថា សូមពួកនាយពេជ្ឈយាជដ៏ចម្រើន បង្អង់ឲ្យសិន (ព្រោះ) ពួកមិត្តអាមាត្យ និងញាតិសាលោហិត (របស់ខ្ញុំមាន) ក្នុងស្រុក ឬនិគមឯណោះ ចាំខ្ញុំទៅផ្តែផ្តាំដល់ពួកមិត្តអាមាត្យទាំងនោះសិនរួចសឹមមកវិញ ដូច្នេះមិនបានទៅហើយ ចំណង់បើពួកមិត្តអាមាត្យញាតិសា-លោហិតរបស់មហាបពិត្រ សុទ្ធតែជាអ្នកសម្ងាប់សត្ត លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគុំកួន មានសេចក្តីយល់ខុស លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកហើយ ធ្វើម្តេចឡើយ នឹងអង្វរពួកនាយនិរយបាលថា សូមពួកនាយនិរយបាលដ៏ចម្រើន បង្អង់ឲ្យសិន ចាំយើងទាំងឡាយទៅក្រាបទូលដល់ព្រះបាទបាយាសិរាជញ្ញៈថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់មានដោយហេតុនេះ ដូច្នេះបាន ឧរាជញ្ញៈ បើតាមបរិយាយ

នេះឯង សូមមហាបពិត្រ បែរព្រះយោបល់យល់មកយ៉ាងនេះវិញថា លោកជទៃមាន ពួកសត្វជាឱបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ។

[๑๔๓] *ព្រះកស្សបដ៏ចម្រើនពោលយ៉ាងនេះ ក៏គួរដែរហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ឃើញក្នុងហេតុនុ៎ះយ៉ាងនេះថា លោកជទៃមិនមានពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរាជញ្ញៈ ចុះបរិយាយដែលនាំឲ្យមហាបពិត្រមានសេចក្តីយល់ឃើញយ៉ាងនេះថា លោកជទៃមិនមានពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ដូច្នេះ តើនៅមានឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយដែលនាំឲ្យខ្ញុំមានសេចក្តីយល់ឃើញយ៉ាងនេះថា លោកជទៃមិនមាន ពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំង-ឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះនៅមាន ។ ថ្វាយព្រះពរាជញ្ញៈ បរិយាយនោះដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ។ ពួកមិត្តអាមាត្យ និងញាតិសាលោហិតរបស់ខ្ញុំក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ គ្មានអភិជ្ឈា គ្មានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ លុះសម័យខាងក្រោយមក ពួកមិត្តអាមាត្យទាំងនោះ មានអាពាធជល់នូវសេចក្តីទុក្ខ ឈឺចាប់ធ្ងន់ កាលដែលខ្ញុំ*

ជឹងថា ឥឡូវនេះ ពួកមិត្តអាមាត្យទាំងនេះ មុខជានឹងមិនស្បើយចាកអាពាធ
នេះទេ ខ្ញុំក៏ចូលទៅរកពួកមិត្តអាមាត្យទាំងនោះ ហើយនិយាយយ៉ាងនេះថា នែ
អ្នកដ៏ចម្រើន មានសមណព្រាហ្មណ៍មួយពួកនិយាយយ៉ាងនេះ យល់យ៉ាង
នេះថា ពួកជនណា រៀរចាកបាណាតិបាត រៀរចាកអទិន្នាទាន រៀរចាក
កាមេសុមិច្ឆារ រៀរចាកមុសាវាទ រៀរចាកបិសុណាវាចា រៀរចាកផរុសវាចា
រៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យបាទ ជាសម្មាទិដ្ឋិ ពួក
ជននោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ តែងទៅកើតឯ
ឋានសុគតិសួគិទេវលោក (ឥឡូវនេះ)អ្នកដ៏ចម្រើនទាំងឡាយ សុទ្ធតែជា
អ្នករៀរចាកបាណាតិបាត រៀរចាកអទិន្នទាន រៀរចាកកាមេសុមិច្ឆាចារ រៀរ
ចាកមុសាវាទ រៀរចាកបិសុណាវាចា រៀរចាកផរុសវាចា រៀរចាកសម្ផប្ប-
លាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិហើយ បើពាក្យ
សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះពិតមែន អ្នកដ៏ចម្រើនទាំងឡាយ លុះ
បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ មុខជានឹងទៅកើតឯឋាន-
សុគតិសួគិទេវលោកពុំខាន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បើអ្នកទាំងឡាយ
បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ទៅកើតឯឋានសុគតិសួគិ-
ទេវលោកមែន អ្នកទាំងឡាយគប្បីមកប្រាប់យើងផងថា លោកដទៃមាន ពួក
សត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើ
អាក្រក់មាន ដោយហេតុនេះ ព្រោះថា អ្នកទាំងឡាយដ៏ចម្រើន ជាបុគ្គល គឺ
យើងគួរជឿ គួរទទួលស្តាប់ពាក្យបាន ហេតុណា ដែលអ្នកដ៏ចម្រើនទាំង-

ទ្បាយ បានឃើញហើយ ហេតុនុ៎ះ នឹងទុកដូចជាយើងបានឃើញដោយខ្លួនឯងដែរ ពួកមិត្តអាមាត្យទាំងនោះ ទទួលតបពាក្យខ្ញុំថា កុណាវិសេស ហើយមិនឃើញត្រឡប់មកប្រាប់ ទាំងមិនបញ្ជូនបម្រើមកឡើយ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកជនៃមិនមាន ពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[๑๔๔] ថ្វាយព្រះពររាជញ្ជៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ (ជ្បិត) ពួកបុរសខ្លះជាអ្នកចេះដឹង ក្នុងលោកនេះ គង់យល់សេចក្តីនៃភាសិត ដោយពាក្យឧបមាបាន បពិត្ររាជញ្ជៈ ប្រៀបដូចបុរសលិចចុះព្រមទាំងក្បាលទៅក្នុងរណ្តៅលាមក គ្រានោះ មហាបពិត្របានត្រាស់បង្គាប់រាជបុរសទាំងឡាយថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ស្រង់បុរសនោះអំពីរណ្តៅលាមកនោះទៅចុះ រាជបុរសទាំងនោះទទួលព្រះឱង្ការរបស់មហាបពិត្រថា កុណាវិសេស ហើយនាំគ្នាទៅស្រង់បុរសនោះពីរណ្តៅលាមកនោះមក ឯមហាបពិត្រក៏មានព្រះឱង្ការនឹងរាជបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ យកចម្រៀកឫស្សី មកកោសកៀរលាមកអំពីកាយបុរសនោះឲ្យស្អាតចេញ រាជ-បុរសទាំងនោះទទួលព្រះឱង្ការនៃមហាបពិត្រថា កុណាវិសេស ហើយក៏យកចម្រៀកឫស្សីមក កោសកៀរលាមក អំពីកាយបុរសនោះឲ្យស្អាត ទើបមហាបពិត្រមានព្រះបន្ទូលនឹងរាជបុរសទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកដ៏

ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយមកដីស្អិតពណ៌លឿង មកដុសលាងកាយបុរសនោះអស់ ៣ ដង រាជបុរសទាំងនោះទទួលព្រះឧន្ការរបស់មហាបពិត្រថា ការុណាវិសេស ហើយក៏យកដីស្អិតពណ៌លឿងមកដុសលាងកាយបុរសនោះអស់ ៣ ដង មហាបពិត្រមានព្រះបន្ទូល នឹងរាជបុរសទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ អ្នកទាំងឡាយ ចូរយកប្រេងលាបបុរសនោះ ហើយយកគ្រឿងលម្អិតដ៏ម៉ដ្ឌទៅខាត់ឲ្យស្អាតល្អអស់ ៣ ដង រាជបុរសទាំងនោះក៏បានយកប្រេងមកលាបបុរសនោះ ហើយយកគ្រឿងលម្អិតដ៏ម៉ដ្ឌទៅខាត់ឲ្យស្អាតល្អអស់ ៣ ដង មហាបពិត្រត្រាស់ទៅនឹងរាជបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំង-ឡាយ កាត់សក់ និងពុកមាត់របស់បុរសនោះចេញ រាជបុរសទាំងនោះ ក៏បានកាត់សក់ និងពុកមាត់របស់បុរសនោះ មហាបពិត្រត្រាស់យ៉ាងនេះថា បើដូច្នោះ ចូរអ្នកទាំងឡាយ យកផ្ការកម្រងមានថ្ងៃច្រើន គ្រឿងលាបមានថ្ងៃច្រើន និងសំពត់ទាំងឡាយមានថ្ងៃច្រើន ទៅប្រគល់ឲ្យបុរសនោះចុះ រាជ-បុរសទាំងនោះ បានយកផ្ការកម្រងមានថ្ងៃច្រើន គ្រឿងលាបមានថ្ងៃច្រើន និងសំពត់ទាំងឡាយមានថ្ងៃច្រើន ទៅប្រគល់ឲ្យបុរសនោះ មហាបពិត្រត្រាស់ទៅនឹងរាជបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ឲ្យបុរសនោះឡើងទៅលើប្រាសាទ ហើយចាត់ចែងនូវកាមគុណទាំង ៥ ចុះ ឯរាជបុរសទាំងនោះ ក៏ឲ្យបុរសនោះឡើងទៅលើប្រាសាទ ហើយចាត់ចែងនូវកាមគុណទាំង ៥ បពិត្ររាជញ្ញៈ ចុះមហាបពិត្រ

សម្គាល់ហេតុនោះថាដូចម្តេច កាលបើបុរសនោះ ជាន់ងូតទឹកស្អាត ហើយ លាបកាយស្រួលបួល កាត់សក់ កោរពុកមាត់ស្រេចហើយ ពាក់គ្រឿង ប្រដាប់កែវមណី ស្បៃកសំពត់ពណ៌សស្រេចហើយ ឡើងទៅលើប្រាសាទ ដ៏ប្រសើរ ឲ្យគេបម្រើឲ្យឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ ហើយ តើ វានៅតែមានសេចក្តីប្រាថ្នានឹងមុជចុះទៅក្នុងរណ្តៅលាមកនោះទៀតឬ ។ បពិត្រ ព្រះកស្សបដ៏ចម្រើន មិនត្រូវការប្រាថ្នាទៀតទេ ។ ចុះដំណើរនោះ តើព្រោះ ហេតុដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន (ព្រោះ) រណ្តៅលាមកមិន ជាទីពេញចិត្ត ជារបស់មិនស្អាតផង ជាចំណែកនៃរបស់មិនស្អាតផង មាន ក្លិនស្អុយផង ជាចំណែកនៃរបស់មានក្លិនស្អុយផង ជារបស់គួរធុញទ្រាន់ផង ជាចំណែកនៃរបស់គួរធុញទ្រាន់ផង ជារបស់គួរខ្ពើមរអើមផង ជាចំណែកនៃ របស់គួរខ្ពើមរអើមផង ។ ថ្វាយព្រះពរវាជញ្ញៈ មនុស្សទាំងឡាយក៏យ៉ាង នោះដែរ គឺជាបុគ្គលមិនស្អាតផង ជាចំណែកនៃបុគ្គលមិនស្អាតផង មានក្លិន ស្អុយផង ជាចំណែកនៃបុគ្គលមានក្លិនស្អុយផង គួរធុញទ្រាន់ផង ជាចំណែក នៃបុគ្គលគួរធុញទ្រាន់ផង គួរខ្ពើមរអើមផង ជាចំណែកនៃបុគ្គល គួរខ្ពើម រអើមផង នៃវេទតាទាំងឡាយ បពិត្រវាជញ្ញៈ ក្លិនមនុស្សជុំអាក្រក់ ផ្សាយ ឡើងទៅកាន់ឋានទេព្តាចំនួន ១០០ យោជន៍ ពួកមិត្តអាមាត្យ និងញាតិ-សាលោហិតរបស់មហាបពិត្រ ជាអ្នកវៀរចាកបាណាតិបាត វៀរចាក អទិន្នាទាន វៀរចាកកាមេសុមិចច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណា-វាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមាន

จิตฺตญฺจาปาทิ ជាសម្មាទិដ្ឋិ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ បានទៅកើតឯឋានសុគតិសួគ៌ទេវលោកហើយ និងមកប្រាប់ថា លោកជនៃមាន ពួកសត្វជាឱបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះដូចម្តេចបាន ឱរាជញ្ញ: បើតាមបរិយាយនេះឯង សូមមហាបពិត្រ បែរព្រះយោបល់យល់មកយ៉ាងនេះវិញថា លោកជនៃមាន ពួកសត្វជាឱបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ។

[๑๔๕] ព្រះកស្សបដ៏ចម្រើនពោលយ៉ាងនេះ ក៏គួរដែរហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ឃើញក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកជនៃមិនមានពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរាជញ្ញ: ចុះបរិយាយនៅមានទៀតឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមានទៀត ។បេ។ ថ្វាយព្រះពរាជញ្ញ: ចុះបរិយាយនោះ តើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួកមិត្តអាមាត្យ និងញាតិសាលោហិតរបស់ខ្ញុំ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន លុះសម័យខាងក្រោយមក ពួកមិត្តអាមាត្យជាដើម្បីនោះ មានអាពាធ ជល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ កាលបើខ្ញុំដឹងថា ឥឡូវនេះ ពួកមិត្តអាមាត្យទាំងនេះមុខជាមិនសះស្បើយចាកអាពាធនេះទេ ខ្ញុំក៏ចូលទៅរកពួកមិត្តអាមាត្យទាំងនោះ ហើយនិយាយយ៉ាង

នេះថា នែអ្នកដ៏ចម្រើនទាំងឡាយ មានសមណពាហ្មណ៍ពួកមួយនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ពួកជនណាជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរសុរាមេរយមជ្ជប្បមាទដ្ឋាន: លុះពួកជនទាំងនោះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ តែងទៅកើតឯឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស (ឥឡូវនេះ) អ្នកដ៏ចម្រើនទាំងឡាយសោត ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានហើយ បើជាពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះពិតមែន អ្នកដ៏ចម្រើនទាំងឡាយ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ គង់នឹងទៅកើតឯឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្សពុំខាន នែអ្នកដ៏ចម្រើនទាំងឡាយ បើអ្នកទាំងឡាយបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ បានទៅកើតឯឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្សមែន អ្នកទាំងឡាយត្រូវមកប្រាប់យើងផងថា លោកដទៃមាន ពួកសត្វជាឱបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មានដោយហេតុនេះ ព្រោះថា អ្នកទាំងឡាយដ៏ចម្រើន ជាបុគ្គលដែលយើងគួរជឿ គួរទទួលស្តាប់ពាក្យបាន ហេតុណា ដែលអ្នកដ៏ចម្រើនទាំងឡាយបានឃើញហើយ ហេតុនោះ នឹងទុកជួចជាយើងបានឃើញដោយខ្លួនឯងដែរ ពួកមិត្តអាមាត្យទាំងនោះ ទទួលពាក្យរបស់ខ្ញុំថា ការុណាវិសេស ហើយមិនឃើញមកប្រាប់សោះ ទាំងមិនបញ្ជូន

បម្រើមកឡើយ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[១៤៦] ថ្វាយព្រះពរព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងត្រឡប់សួរមហាបពិត្រក្នុងបរិយាយនេះវិញ ប្រស្នានេះ ពេញព្រះហឫទ័យមហាបពិត្រយ៉ាងណា សូមមហាបពិត្រព្យាករប្រស្នានោះយ៉ាងនោះចុះ បពិត្រព្រះរាជញ្ញៈ ១០០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជាមួយខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១ ពាន់ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវត្តិង្ស ពួកមិត្តអាមាត្យ និងញាតិសាលោហិតណា ជាអ្នកបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆារ វៀរចាកមុសាវាទ វៀរសុរាមេរយមជ្ជប្បមាទដ្ឋានហើយ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ បានទៅកើតឯឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ចុះបើពួកមិត្តអាមាត្យទាំងនោះ មានគំនិតយ៉ាងនេះថា ចាំយើងទាំងឡាយឲ្យគេបម្រើឲ្យឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ ជាទិព្វ អស់យប់ និងថ្ងៃ ២ ឬ ៣ សិន រួចសឹមយើងទៅប្រាប់ដល់ព្រះបាទចាយាសិ-រាជញ្ញៈថា លោកដទៃមាន ពួកសត្វជាឱបបាតិក:មាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មានដោយហេតុនេះ ចុះពួកមិត្តអាមាត្យ

ជាដើមនោះ គប្បីមកទូលមហាបពិត្រថា លោកដទៃមាន ពួកសត្វជាឱបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ តើទាន់ឬទេ បពិត្រព្រះកស្សបដ៏ចម្រើន មកជ្រាប់មិនទាន់ទេ បពិត្រព្រះកស្សបដ៏ចម្រើន ចានជាមកជ្រាប់មិនទាន់ ព្រោះថា ខ្ញុំមុខជានឹងស្ងាប់ចាត់ទៅមុនយូរណាស់ហើយ ចុះអ្នកណាមកជ្រាប់ ដំណឹងនេះដល់ព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្សមានអាយុវែងយ៉ាងនេះ យើងមិនទាន់ជឿព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្សមានអាយុវែងយ៉ាងនេះទេ ។ ថ្វាយព្រះពរភញ្ជៈ ប្រៀបដូចជាបុរសខ្វាក់ពីកំណើត មិនដែលឃើញរូបខ្មៅ ឬស មិនដែលឃើញរូបដែលមានសម្បុរខៀវ មិនដែលឃើញរូបមានសម្បុរលឿង មិនដែលឃើញរូបមានសម្បុរក្រហម មិនដែលឃើញរូបមានសម្បុរហង្សបាទ មិនដែលឃើញរបស់ស្មើ និងមិនស្មើ មិនដែលឃើញរូបផ្កាយទាំងឡាយ មិនដែលឃើញព្រះចន្ទ និងព្រះអាទិត្យទេ មនុស្សខ្វាក់នោះមុខជានឹងនិយាយយ៉ាងនេះថា រូបខ្មៅ ឬសគ្មានទេ បុគ្គលអ្នកឃើញរូបខ្មៅ ឬសគ្មានទេ រូបខៀវគ្មានទេ បុគ្គលអ្នកឃើញរូប មានសម្បុរខៀវគ្មានទេ រូបសម្បុរលឿងគ្មានទេ បុគ្គលអ្នកឃើញរូបសម្បុរលឿងគ្មានទេ រូបសម្បុរក្រហមគ្មានទេ បុគ្គលអ្នកឃើញរូបសម្បុរក្រហមគ្មានទេ រូបសម្បុរហង្សបាទគ្មានទេ បុគ្គលអ្នកឃើញរូបសម្បុរហង្សបាទគ្មានទេ របស់ស្មើ និងមិនស្មើគ្មានទេ បុគ្គលអ្នកឃើញរបស់ស្មើ និងមិនស្មើគ្មានទេ រូបផ្កាយគ្មានទេ បុគ្គល

អ្នកឃើញរូបផ្កាយគ្មានទេ ព្រះចន្ទ និងព្រះអាទិត្យគ្មានទេ បុគ្គលអ្នកឃើញនូវព្រះចន្ទ និងព្រះអាទិត្យគ្មានទេ អាត្មាអញមិនស្គាល់របស់នុ៎ះ អាត្មាអញមិនឃើញរបស់នុ៎ះ ហេតុដូច្នោះ របស់នោះគ្មានទេ បពិត្ររាជញ្ញៈដ៏ចម្រើន កាលបើមនុស្សខ្វាក់អំពីកំណើតនិយាយ (យ៉ាងនោះ) ឈ្មោះថា និយាយត្រូវឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន មិនត្រូវទេ (ព្រោះ) រូបខ្មៅ ឬសមាន បុគ្គលអ្នកឃើញរូបខ្មៅ ឬសមាន រូបខៀវមាន បុគ្គលអ្នកឃើញរូបខៀវមាន ។បេ។ របស់ស្មើ និងមិនស្មើមាន បុគ្គលអ្នកឃើញរបស់ស្មើ និងមិនស្មើមាន រូបផ្កាយមាន បុគ្គលអ្នកឃើញរូបផ្កាយមាន ព្រះចន្ទ ព្រះអាទិត្យមាន បុគ្គលអ្នកឃើញព្រះចន្ទ ព្រះអាទិត្យមាន បពិត្រព្រះកស្សបដ៏ចម្រើន កាលបើបុរសខ្វាក់អំពីកំណើតនិយាយថា អាត្មាអញមិនស្គាល់របស់នុ៎ះ អាត្មាអញមិនឃើញរបស់នុ៎ះ ព្រោះហេតុនោះ របស់នោះមិនមានទេ ដូច្នេះឈ្មោះថា និយាយមិនត្រូវសោះឡើយ ។ ថ្វាយព្រះពរព្រះរាជញ្ញៈ យ៉ាងហ្នឹងមែនហើយ អង្គមហាបពិត្រទុកដូចមនុស្សខ្វាក់អំពីកំណើតប្រាកដ (បានជា) មហាបពិត្រត្រាស់យ៉ាងនេះថា ចុះមានអ្នកណាមកប្រាប់ដំណឹងនេះ ដល់ព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្សមានអាយុវែងយ៉ាងនេះ យើងមិនជឿ (ពាក្យរបស់) ព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្សមានអាយុវែងយ៉ាងនេះទេ បពិត្ររាជញ្ញៈ ព្រះអង្គសម្គាល់យកដោយមំសចក្ខុនេះ យ៉ាងណា ឯលោកជនៃ បុគ្គលមិនគប្បីឃើញបានយ៉ាងនោះឡើយ បពិត្រ

រាជញ្ញៈ ពួកសមណព្រាហ្មណ៍ណា អាស្រ័យសេពសេនាសនៈទាំងឡាយ ដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃតូច និងព្រៃធំ ពួកសមណព្រាហ្មណ៍ទាំងនោះ មិនប្រមាទ មានព្យាយាមដុតកម្ដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន ជម្រះនូវទិព្វចក្ខុ នៅក្នុងព្រៃស្ងាត់នោះ ពួកសមណព្រាហ្មណ៍ទាំងនោះឯង ទើបឃើញលោកនេះផង លោកដទៃផង ពួកសត្វជាឱបបាតិកៈផង ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងចក្ខុជារបស់មនុស្សធម្មតា បពិត្ររាជញ្ញៈ ឯបុគ្គលគប្បីឃើញលោកដទៃយ៉ាងនោះឯង មិនមែនដូចជាមហាបពិត្រសម្គាល់ដោយមំសចក្ខុនោះទេ ឱរាជញ្ញៈ បើតាមបរិយាយនេះ សូមមហាបពិត្របែរព្រះយោបល់យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឱបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មានដោយហេតុនេះ ។

[๑๔๗] ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះក៏គួរម្យ៉ាងដែរហើយ ប៉ុន្តែ ខ្ញុំនៅតែមានសេចក្ដីយល់ឃើញក្នុងហេតុនុ៎ះយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមានដោយហេតុនេះ ។ ថ្វាយព្រះពររាជញ្ញៈ ចុះបរិយាយទៀតមាន (ទៀត) ឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន ។បេ។ ថ្វាយព្រះពររាជញ្ញៈ បរិយាយនោះតើដូចម្ដេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ក្នុងលោកនេះ ខ្ញុំឃើញពួកសមណព្រាហ្មណ៍ មានសីល មានធម៌ល្អ ចង់តែរស់ មិនចង់ស្លាប់ ប្រាថ្នាតែសេចក្ដីសុខ ស្អប់ខ្ពើមទុក្ខ បពិត្រព្រះកស្សបដ៏ចម្រើន ខ្លួនខ្ញុំនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើពួក

សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះមានសីល មានធម៌ល្អ គប្បីដឹងយ៉ាងនេះ ថា យើងទាំងឡាយកាលបើស្លាប់ពីលោកនេះទៅ មុខជានឹងបានសេចក្តីសុខប្រសើរ ឥឡូវនេះ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ មានសីល មានធម៌ដ៏ល្អហើយ គួរតែសុំថ្នាំពិសក្តី យកកាំបិតមក (អារកខ្លួន) ឯងក្តី ចងកសម្លាប់ក្តី លោតទម្លាក់ទៅក្នុងជ្រោះក្តី តែពួកសមណព្រាហ្មណ៍ដ៏ចម្រើននេះ មានសីល មានធម៌ល្អហើយ មិនដឹងយ៉ាងនេះថា យើងកាលបើស្លាប់ពីលោកនេះទៅ នឹងបានសេចក្តីសុខប្រសើរដូច្នេះឡើយ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ដ៏ចម្រើននេះ មានសីល មានធម៌ល្អហើយ នៅតែចង់រស់ មិនចង់ស្លាប់ ប្រាថ្នាតែសេចក្តីសុខ ស្អប់ខ្ពើមទុក្ខ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានសេចក្តីចូលចិត្តយ៉ាងនេះ ថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[๑๔๘] ថ្វាយព្រះពរព្រះរាជញ្ញ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ ព្រោះពួកបុរសជាអ្នកចេះដឹងខ្លះ ក្នុងលោកនេះ គង់យល់សេចក្តីនៃភាសិត ដោយពាក្យឧបមាបាន បពិត្រព្រះរាជញ្ញៈ កាលពីព្រេងនាយមក មានព្រាហ្មណ៍ម្នាក់ មានប្រពន្ធ ๒ នាក់ គឺប្រពន្ធម្នាក់មានកូនប្រុស ๑ មានអាយុ ๑๐ ឆ្នាំ ឬ ๑๒ ឆ្នាំ ប្រពន្ធម្នាក់ទៀត កំពុងតែមានគភ៌ ជិតនឹងសម្រាល ក្នុងពេលនោះ ព្រាហ្មណ៍ជា (ស្វាមី) នោះ ក៏ធ្វើមរណកាលទៅ លំដាប់នោះ មាណពជាកូននោះបាននិយាយនឹងម្តាយចុង

យ៉ាងនេះថា នែអ្នកម្តាយដ៏ចម្រើន របស់ណា គឺទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី របស់ទាំងអស់នោះ ជារបស់ខ្ញុំ ឯអ្នកមិនត្រូវបានចំណែកតិចតួច ក្នុងសម្បត្តិនេះទេ នែអ្នកម្តាយដ៏ចម្រើន សូមអ្នកម្តាយប្រគល់ទ្រព្យមត៌ក ជារបស់បិតាឲ្យមកខ្ញុំ ។ កាលមាណពនោះ និយាយយ៉ាងនេះ ព្រាហ្មណីនោះបាននិយាយនឹងមាណពនោះយ៉ាងនេះថា នែកូន ចូរបាបង្អង់សិន ទម្រាំអញសម្រាលកូនរួចសិន បើកូននោះជាកូនប្រុស កូនប្រុសនោះ នឹងត្រូវបានទ្រព្យ បន្តិចបន្តួចដែរ បើកូននោះជាកូនស្រី កូនស្រីនោះ នឹងបានធ្វើជាភរិយារបស់អ្នក ។ មាណពនោះនិយាយនឹងម្តាយចុងជាគម្រប់ ២ ដងយ៉ាងនេះថា នែអ្នកម្តាយ របស់ណា គឺទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី របស់ទាំងអស់នោះ ជារបស់ខ្ញុំ អ្នកមិនត្រូវបានចំណែកតិចតួចក្នុងសម្បត្តិនេះទេ នែអ្នកម្តាយដ៏ចម្រើន ចូរអ្នកប្រគល់ទ្រព្យមត៌កជារបស់បិតាឲ្យមកខ្ញុំ ។ ព្រាហ្មណីនោះនិយាយនឹងមាណពនោះ ជាគម្រប់ ២ ដងទៀតយ៉ាងនេះថា នែបា ចូរអ្នកបង្អង់សិន ទម្រាំអញសម្រាលកូនរួច បើកូននោះជាកូនប្រុស កូនប្រុសនោះនឹងត្រូវបានទ្រព្យបន្តិចបន្តួចដែរ បើកូននោះជាកូនស្រី កូនស្រីនោះ នឹងបានជាភរិយារបស់អ្នក ។ មាណពនោះ និយាយនឹងម្តាយចុងជាគម្រប់ ៣ ដងយ៉ាងនេះថា នែអ្នកម្តាយដ៏ចម្រើន របស់ណា គឺទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី របស់ទាំងអស់នោះជារបស់ខ្ញុំ អ្នកមិនត្រូវបានចំណែកតិចតួច ក្នុងសម្បត្តិនេះទេ នែអ្នកម្តាយ ចូរអ្នកប្រគល់ទ្រព្យមត៌កជារបស់បិតាឲ្យមកខ្ញុំ ។ លំដាប់នោះឯង នាងព្រាហ្មណីនោះ កាន់កាំបិតចូលទៅក្នុងបន្ទប់ ហើយវះ

ពោះខ្ជូនឯង គិតថា បើជាប្រុស ឬស្រី អាត្មាអញគង់ដឹងច្បាស់បាន នាងព្រាហ្មណីនោះ ហេតុតែល្ងង់មិនឈ្លាសវៃ ស្វែករកទ្រព្យមតិកដោយមិនត្រូវទំនង ក៏ដល់នូវសេចក្តីវិនាសទាំងខ្ជូនផង ជីវិតផង កូនក្នុងគភ៌ផង សម្បត្តិផង ដោយពិត បពិត្ររាជញ្ញ: ព្រះអង្គជាបុគ្គលល្ងង់ មិនឆ្លាសវៃ ស្វែករកបរលោកដោយខុសទំនង គង់នឹងដល់នូវសេចក្តីវិនាស ដូចជាព្រាហ្មណីដែលល្ងង់មិនឈ្លាសវៃ ស្វែងរកសម្បត្តិដោយមិនត្រូវទំនង ក៏បានដល់នូវសេចក្តីវិនាសដូច្នោះមិនខាន ។ បពិត្ររាជញ្ញ: សមណព្រាហ្មណ៍ទាំងឡាយមានសីល មានធម៌ល្អ រមែងមិនផ្តាច់បង់នូវអាយុ ដែលមិនទាន់អស់ទេ មួយវិញទៀត អ្នកប្រាជ្ញទាំងឡាយ តែងរង់ចាំកាលឲ្យអាយុដល់កំណត់ ។ បពិត្ររាជញ្ញ: សមណព្រាហ្មណ៍ទាំងឡាយមានសីល មានធម៌ល្អ មានជីវិតវិសេសជាងពួកជនដទៃ បពិត្ររាជញ្ញ: ពួកសមណព្រាហ្មណ៍ មានសីល មានធម៌ល្អ ឋិតនៅអស់កាលយូរអង្វែង ដោយប្រការណា ពួកសមណព្រាហ្មណ៍ទាំងនោះរមែងបាននូវបុណ្យច្រើន និងប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំង-ឡាយ ដោយប្រការដូច្នោះឯង ។ ឧរាជញ្ញ: បើតាមបរិយាយនេះ សូមមហាបពិត្របែរព្រះយោបល់យល់មកយ៉ាងនេះវិញថា លោកដទៃមាន ។បេ។ ផលវិបាកមានដោយហេតុនេះ ។

[១៤៩] ព្រះកស្សបដ៏ចម្រើន និយាយយ៉ាងនេះក៏គួរហើយ ប៉ុន្តែខ្ញុំ

នៅតែមានសេចក្តីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកដទៃមិនមាន ។បេ។ ផលវិបាកមិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរព្រាជញ្ញៈ ចុះបរិយាយមានទៀតឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន ។បេ។ ថ្វាយព្រះពរព្រាជញ្ញៈ ចុះបរិយាយតើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួករាជបុរសក្នុងដែននេះ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ យកមកបង្ហាញខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនេះជាចោរប្រព្រឹត្តអាក្រក់ទីឆ្ងព្រះអង្គ ព្រះអង្គសព្វព្រះហឫទ័យ ដាក់អាជ្ញាណាដល់ចោរនេះ សូមព្រះអង្គដាក់អាជ្ញានោះមក ខ្ញុំក៏និយាយទៅនឹងរាជបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយចាប់បុរសនេះទាំងរស់ ចោះទៅក្នុងខ្ទះ ហើយគ្របមាត់ខ្ទះ យកស្បែកស្រស់ពាសជាស់ រួចយកជីស្អិតសើមមកបូកឲ្យក្រាស់ ហើយលើកដាក់លើចង្ក្រាន រួចដុតភ្លើង ឯរាជបុរសទាំងនោះ ទទួលពាក្យរបស់ខ្ញុំថា ករុណាវិសេស ហើយចាប់បុរសនោះទាំងរស់ចោះទៅក្នុងខ្ទះ គ្របមាត់ខ្ទះយកស្បែកស្រស់មកពាសជាស់ រួចយកជីស្អិតសើមមកបូកឲ្យក្រាស់ រួចដាក់លើចង្ក្រាន ហើយដុតភ្លើង ។ កាលដែលយើងដឹងថា បុរសនោះស្លាប់ហើយ ទើបឲ្យពួករាជបុរស ដាក់ខ្ទះនោះចុះមក គាស់ដីស្អិត បង្ហើបមាត់សន្សឹមៗ ហើយពិនិត្យមើលដោយបំណងថា យើងនឹងចាំមើលជីវៈ (ព្រលឹង) របស់ចោរនោះដែលចេញទៅ តែយើងមិនឃើញជីវៈរបស់ចោរនោះចេញទៅសោះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផល

វិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងត្រឡប់សួរមហាបពិត្រក្នុងបរិយាយនេះវិញ ប្រស្នានេះ ពេញព្រះហឫទ័យនៃមហាបពិត្រយ៉ាងណា សូមមហាបពិត្រព្យាករប្រស្នានោះយ៉ាងនោះ ។ បពិត្រពរាជញ្ញៈ ទ្រង់ធ្លាប់ចូលទៅកាន់ទីព្រះបន្ទំក្នុងវេលាថ្ងៃ បានទ្រង់ព្រះសុបិនឃើញសួនច្បារជាទីសប្បាយ ព្រៃជាទីសប្បាយ (ទេសភាព) ផែនដីជាទីសប្បាយ ស្រះឈូកជាទីសប្បាយ ដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន ខ្ញុំធ្លាប់ចូលទៅកាន់ជំណេកក្នុងវេលាថ្ងៃ ធ្លាប់យល់សប្តិឃើញសួនច្បារជាទីសប្បាយ ព្រៃជាទីសប្បាយ ផែនដីជាទីសប្បាយ ស្រះឈូកជាទីសប្បាយដែរ ។ ចុះក្នុងសម័យនោះ មានពួកស្រីគមខ្លះ ស្រីតឿខ្លះ ក្មេងស្រីកំពុងពេញល្បែងខ្លះ ក្មេងស្រីតូចៗ ខ្លះ ចាំរក្សាព្រះអង្គដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន អើ ក្នុងសម័យនោះ មានពួកស្រីគមខ្លះ ស្រីតឿខ្លះ ក្មេងស្រីកំពុងពេញល្បែងខ្លះ ក្មេងស្រីតូចៗ ខ្លះ ចាំរក្សាខ្ញុំដែរ ។ ចុះពួកស្រីទាំងនោះ ឃើញព្រលឹងរបស់មហាបពិត្រកំពុងចូលមក ឬកំពុងចេញទៅដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន មិនឃើញទេ ។ ឱរាជញ្ញៈ អម្បាលយ៉ាងពួកស្រីទាំងនោះនៅរស់ គង់មិនឃើញព្រលឹងរបស់មហាបពិត្រកំពុងរស់នៅ កាលចូលមក ឬចេញទៅ ចំណង់បើមនុស្សស្លាប់ទៅហើយ មហាបពិត្រនឹងទតឃើញព្រលឹង កាលចូលមក ឬចេញទៅដូចម្តេចបាន ។ ឱរាជញ្ញៈ បើតាមបរិយាយនេះឯង សូមមហាបពិត្រយល់មកយ៉ាងនេះវិញថា លោកជំទៃមាន ពួកសត្វជាឱបបាតិកៈ

មាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់មាន ដោយ ហេតុនេះ ។

[๑๕๐] ព្រះកស្សបដ៏ចម្រើនពោលយ៉ាងនេះ ក៏គួរដែរហើយ ប៉ុន្តែ ខ្ញុំនៅតែមានសេចក្តីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកដទៃមិនមាន ពួក សត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើ អាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរាជញ្ញៈ ចុះបរិយាយនៅ មានទៀតដែរឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន ។បេ។ ថ្វាយព្រះពរាជញ្ញៈ បរិយាយនោះតើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួករាជបុរសក្នុងដែននេះ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ យកមកឲ្យខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនេះជាចោរប្រព្រឹត្តអាក្រក់ទីងព្រះអង្គ។ សព្វព្រះ ហឫទ័យជាក់អាជ្ញាណាជល់ចោរនេះ សូមជាក់អាជ្ញានោះចុះ ខ្ញុំក៏និយាយនឹង រាជបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំង-ឡាយ យកជញ្ជីងថ្លឹងបុរសនេះទាំងរស់ ហើយយកខ្សែបន្ទោះធ្ងចងរឹតរួត មិន ឲ្យមានដង្ហើមចេញចូលឲ្យស្ទាប់រួចយកជញ្ជីងមកថ្លឹងម្តងទៀត រាជបុរសទាំង នោះ ទទួលពាក្យរបស់ខ្ញុំថា ករុណាវិសេស ហើយក៏យកជញ្ជីងមកថ្លឹងបុរស នោះទាំងរស់ រួចយកខ្សែបន្ទោះធ្ងចងរឹតរួត មិនឲ្យមានដង្ហើមចេញចូលឲ្យ ស្ទាប់ ហើយយកជញ្ជីងមកថ្លឹងម្តងទៀត ។ កាលបុរសនោះនៅរស់ ជា បុគ្គលស្រាលជាងផង ទន់ជាងផង គួរដល់ការងារផង លុះបុរសនោះស្លាប់ ហើយ ក៏បែជារឆ្ងន់ជាងវិញផង រឹងជាងវិញផង មិនគួរដល់ការងារអ្វីផង ។

បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិក:មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[๑๕๑] *ថ្វាយព្រះពរព្រាហ្មញ: បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ បុរសអ្នកចេះដឹងពួកខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្រព្រាហ្មញ: ដូចជាបុរសយកជញ្ជីងថ្លឹងដុំដែក ដែលក្តៅឆេះរន្ទាលច្រាលឆ្អៅ មានអណ្តាតសន្ធោសន្ធៅ ក្តៅអស់មួយថ្ងៃ លុះសម័យខាងក្រោយមក គេក៏បានយកជញ្ជីងមកថ្លឹងដុំដែកដែលរលត់ក្តៅត្រជាក់អស់ហើយនោះ (ម្តងទៀត) ចុះដុំដែកនោះ ដែលទៅជាស្រាលជាង ឬទន់ជាង ឬគួរដល់ការងារជាង តើក្នុងកាលណា ក្នុងកាលដែលកំពុងឆេះរន្ទាលច្រាលឆ្អៅ មានអណ្តាតសន្ធោសន្ធៅឬ ឬក្នុងកាលដែលរលត់ក្តៅត្រជាក់អស់ហើយ ។ បពិត្រព្រះកស្សបដ៏ចម្រើន ក្នុងកាលណា ដែលដុំដែកនោះប្រកបដោយក្តៅ ទាំងប្រកបដោយខ្យល់ កំពុងឆេះរន្ទាលច្រាលឆ្អៅ មានអណ្តាតសន្ធោសន្ធៅក្នុងកាលនោះឯង ដុំដែកនោះស្រាលជាងផង ទន់ជាងផង គួរដល់ការងារជាងផង លុះតែកាលណាដុំដែកនោះ មិនប្រកបដោយក្តៅ មិនប្រកបដោយខ្យល់ រលត់ក្តៅត្រជាក់អស់ហើយ ក្នុងកាលនោះ ដុំដែកនោះ ទៅជាធ្ងន់ជាងផង រឹងជាងផង មិនគួរដល់ការងារជាងផង ។ ថ្វាយព្រះពរព្រាហ្មញ: កាយនេះឯងក៏យ៉ាងនោះដែរ កាលណាបើបានប្រកបដោយអាយុផង ប្រកបដោយភ្លើងធាតុផង ប្រកប*

ដោយវិញ្ញាណផង ទើបកាយនេះ ទៅជាស្រាលជាងផង ទន់ជាងផង គួរ ដល់ការងារជាងផង តែបើកាលណាកាយនេះ មិនប្រកបដោយអាយុផង មិនប្រកបដោយភ្លើងធាតុផង មិនប្រកបដោយវិញ្ញាណផងទេ កាយនេះឯង ក៏ ទៅជាធ្ងន់ជាងផង រឹងជាងផង មិនគួរដល់ការងារផង ។ ឱរាជញ្ញៈ បើតាម បរិយាយនេះ សូមមហាបពិត្រ យល់យ៉ាងនេះវិញថា លោកជនៃមាន ពួក សត្វជាឱបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ។

[១៥២] *ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះ ក៏គួរជ្រះហើយ តែ ខ្ញុំនៅតែមានសេចក្តីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកជនៃមិនមាន ពួក សត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរាជញ្ញៈ ចុះបរិយាយ នៅមានទៀតដែរឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន ។បេ។ ថ្វាយព្រះពរាជញ្ញៈ ចុះបរិយាយនោះតើដូចម្តេច ។ បពិត្រព្រះកស្សប ដ៏ចម្រើន ពួករាជបុរសក្នុងដែននេះ ចាប់បានចោរដែលប្រព្រឹត្តអាក្រក់មក ឲ្យខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន បុរសនេះជាចោរ ប្រព្រឹត្តអាក្រក់នឹងព្រះ អង្គ ព្រះអង្គសព្វព្រះហឫទ័យ នឹងដាក់អាជ្ញាណាដល់ចោរនេះ សូមព្រះអង្គ ដាក់អាជ្ញានោះចុះ ខ្ញុំក៏និយាយយ៉ាងនេះ នឹងរាជបុរសទាំងនោះថា នែអ្នកដ៏ ចម្រើនទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរសម្ងាប់បុរសនេះចុះ តែកុំ ឲ្យរូចស្បែកក្រៅ ស្បែកក្នុង សាច់ សរសៃ ឆ្អឹង និងខួរក្នុងឆ្អឹង ក្រែងលោ*

យើងនឹងបានយើញជីវ: (ព្រលឹង) របស់បុរសនោះចេញមក រាជបុរស
ទាំងនោះទទួលពាក្យរបស់ខ្ញុំថា ការុណាវិសេស ហើយក៏សម្ងាប់បុរសនោះ
មិនមានស្នាមជាំជាំ ត្រង់ស្បែកក្រៅស្បែកក្នុង សាច់ សរសៃ ឆ្អឹង និងខួរ
ក្នុងឆ្អឹងឡើយ ។ ក្នុងកាលដែលគេកំពុងប្រុងប្រៀបនឹងសម្ងាប់ចោរនោះ ខ្ញុំ
បាននិយាយនឹងរាជបុរសទាំងនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ
ចូរអ្នកទាំងឡាយ ឲ្យបុរសនេះដេកផ្ងារឡើង ក្រែងយើងនឹងបានយើញជីវ:
របស់វាចេញមក រាជបុរសទាំងនោះ ក៏ឲ្យបុរសនោះដេកផ្ងារឡើង ។ យើង
ក៏មិនយើញជីវ:របស់ចោរនោះចេញមកសោះ ខ្ញុំនិយាយនឹងរាជបុរសទាំង
នោះ យ៉ាងនេះទៀតថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ឲ្យ
បុរសនេះដេកផ្ការាប់ ដេកផ្អៀងទៅម្ខាងហើយ ឲ្យដេកផ្អៀងទៅម្ខាងទៀត ហើយ
លើកបញ្ឈរឡើង លើកសំយុងក្បាលចុះ យកដៃគោះមើល យកជុំដីគោះ
មើល យកជំបងគោះមើល យកគ្រឿងសស្ត្រាគោះមើល ទាញមក ច្រាន
ត្រឡប់ទៅវិញ ទាញប្រែត្រឡប់ទៅ ត្រឡប់មក ក្រែងយើងនឹងបានយើញ
ជីវ:របស់បុរសនេះចេញទៅ ឯរាជបុរសទាំងនោះ ក៏ទាញបុរសនោះមក
ច្រានត្រឡប់ទៅវិញ ទាញប្រែត្រឡប់ទៅ ត្រឡប់មក ។ យើងក៏មិនបាន
យើញជីវ:របស់បុរសនោះចេញមកសោះ ។ ភ្នែកនោះឯង របស់បុរសនោះ
ក៏នៅជាភ្នែកដដែល រូបទាំងឡាយនោះក៏នៅជារូបដដែល ប៉ុន្តែបុរសនោះឯង
មើលមិនយើញនូវរូបាយតន:នោះ (ដោយភ្នែកនោះ) សោះ ។ ត្រចៀក
នោះឯង ក៏នៅជាត្រចៀកដដែល សំឡេងទាំងឡាយនោះ ក៏នៅជាសំឡេង

ជដែល ទាស់តែបុរសនោះស្តាប់សទ្ទាយតនៈនោះមិនឮ (ដោយត្រចៀក) សោះ ។ ច្រមុះនោះឯង ក៏នៅជាច្រមុះជដែល ក្នុងទាំងឆ្បាយនោះ ក៏នៅជាក្នុងជដែល តែថា បុរសនោះមិនធុំនូវគន្ធាយតនៈនោះ (ដោយច្រមុះនោះ) សោះ ។ អណ្តាតនោះឯង ក៏នៅជាអណ្តាតជដែល រសទាំងឆ្បាយនោះ ក៏នៅជារសជដែល តែថាបុរសនោះមិនដឹងច្បាស់នូវរសាយតនៈនោះ (ដោយអណ្តាតនោះ) សោះ កាយនោះឯង ក៏នៅជាកាយជដែល ផោដ្ឋព្វៈទាំង-ឆ្បាយនោះ ក៏នៅជាផោដ្ឋព្វៈជដែល ទាស់តែបុរសនោះ មិនដឹងច្បាស់នូវផោដ្ឋព្វាយតនៈនោះ (ដោយកាយនោះ) សោះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានសេចក្តីចូលចិត្តយ៉ាងនេះថា លោកជទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឆ្បាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[១៥៣] ថ្វាយព្រះពរព្រាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ វិញ្ញូបុរសទាំងឆ្បាយពួកខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្រព្រាជញ្ញៈ កាលពីព្រេងនាយមកមានបុរសផ្តុំសង្ឃម្នាក់ កាន់សង្ឃដើរទៅកាន់ជនបទដែលនៅចុងដែន ។ បុរសនោះចូលទៅក្នុងស្រុកមួយ លុះចូលទៅដល់ហើយ ឃើញគណ្តាលស្រុក ផ្តុំសង្ឃ ៣ ជង ហើយជាក់សង្ឃលើផែនដី រួចអង្គុយក្នុងទីដ៏សមគួរ ។ បពិត្រព្រាជញ្ញៈ លំដាប់នោះ ពួកមនុស្សនៅក្នុងបច្ចន្តជនបទនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នែគ្នាយើងអើយ ចុះសំឡេងនោះ តើជាសំឡេងអ្វី បានជាគួរឲ្យ

យើងត្រេកអរអ្វីដល់ម្ដេ៉ះ គួរឲ្យចង់ស្តាប់អ្វីម្ដេ៉ះ គួរឲ្យភាន់ភាំងអ្វីម្ដេ៉ះ គួរឲ្យ
ជាប់ចិត្តអ្វីម្ដេ៉ះ គួរឲ្យរសាយទុក្ខអ្វីម្ដេ៉ះ ។ មនុស្សទាំងនោះប្រជុំគ្នាហើយ សួរ
ទៅអ្នកផ្ទុំសង្ខនោះយ៉ាងនេះថា នែអ្នកដ៏ចម្រើន ចុះសំឡេងនោះជាសំឡេងអ្វី
បានជាគួរឲ្យយើងត្រេកអរអ្វីដល់ម្ដេ៉ះ គួរឲ្យចង់ស្តាប់អ្វីម្ដេ៉ះ គួរឲ្យភាន់ភាំង
អ្វីម្ដេ៉ះ គួរឲ្យជាប់ចិត្តអ្វីម្ដេ៉ះ គួរឲ្យរសាយទុក្ខអ្វីម្ដេ៉ះ ។ បុរសអ្នកផ្ទុំសង្ខ
និយាយថា ម្នាលអ្នកដ៏ចម្រើន សំឡេងដែលគួរឲ្យអ្នកផង ត្រេកអរយ៉ាង
នេះ គួរឲ្យចង់ស្តាប់យ៉ាងនេះ គួរឲ្យភាន់ភាំងយ៉ាងនេះ គួរឲ្យជាប់ចិត្តយ៉ាង
នេះ គួរឲ្យសោយទុក្ខយ៉ាងនេះ សំឡេងនោះ គឺជាសំឡេងសង្ខនេះឯង ។
មនុស្សទាំងនោះ ក៏ផ្តេកសង្ខនោះឲ្យផ្ទារឡើង ហើយនិយាយថា នែសង្ខដ៏
ចម្រើន ចូរឯងបន្ទឺ (សំឡេង) ទៅមើល នែសង្ខដ៏ចម្រើន ចូរឯងបន្ទឺ
(សំឡេង) ទៅមើល ។ សង្ខនោះក៏មិនបន្ទឺ (សំឡេង) សោះ ។
មនុស្សទាំងនោះក៏ផ្ទាប់សង្ខនោះ ហើយផ្តេកទៅម្ខាង ផ្តេកទៅម្ខាងទៀត ហើយ
លើកបញ្ឈរឡើង សំយុងចុះយកដៃគោះ យកជុំជីគោះ យកជំបងគោះ យក
គ្រឿងសស្ត្រាគោះ ប្រមៀលមក ប្រមៀលទៅ ប្រមៀលចុះ ប្រមៀលឡើង
ហើយនិយាយថា នែសង្ខដ៏ចម្រើន ចូរឯងបន្ទឺ (សំឡេង) ទៅមើល នែ
សង្ខដ៏ចម្រើន ចូរឯងបន្ទឺ (សំឡេង) ទៅមើល ។ សង្ខនោះក៏នៅតែមិន
បន្ទឺ (សំឡេង) សោះ ។ បពិត្ររាជញ្ញៈ លំដាប់នោះ អ្នកផ្ទុំសង្ខនោះ
មានសេចក្តីត្រិរិះដូច្នេះថា ពួកមនុស្សអ្នកនៅក្នុងជនបទទាំងអស់នេះ ហៅ
ពេញជាមនុស្សល្ងង់ មិនសមបើនឹងស្វែងរកសំឡេងសង្ខ ដោយខុសទំនង

សោះ ។ កាលពួកមនុស្សទាំងនោះកំពុងមើល បុរសផ្ដុំសង្ឃនោះ ក៏ចាប់សង្ឃ ផ្ដុំ ៣ ដង ហើយកាន់សង្ឃដើរចៀសចេញទៅ ។ បពិត្រភាជញ្ញៈ លំដាប់ នោះ មនុស្សនៅក្នុងបច្ចន្តជនបទទាំងអស់នោះ មានសេចក្តីត្រិះរិះដូច្នេះថា នែ គ្នាយើងអើយ ធម្មតាសង្ឃនេះ លុះតែកាលណា បានផ្សំនឹងបុរសផង ផ្សំនឹង សេចក្តីព្យាយាមផង ផ្សំនឹងខ្សល់ផង ទើបសង្ឃនេះបន្លឺ (សំឡេង) ក្នុង កាលណោះបាន កាលណាបើសង្ឃនេះ មិនបានផ្សំនឹងបុរស មិនបានផ្សំនឹង សេចក្តីព្យាយាម មិនបានផ្សំនឹងខ្សល់ទេ សង្ឃនេះក៏បន្លឺសំឡេងមិនបាន ។ បពិត្រភាជញ្ញៈ កាយនេះក៏ដូច្នោះដែរ កាលណាប្រកបដោយអាយុផង ប្រកប ដោយភ្លើងធាតុផង ប្រកបដោយវិញ្ញាណផង ក្នុងកាលនោះ ទើបកាយនោះ ឈានទៅក៏បាន ថយក្រោយក៏បាន ឈរក៏បាន អង្គុយក៏បាន សម្រេច ឥរិយាបថដេកក៏បាន ឃើញរូបដោយភ្នែកក៏បាន ស្តាប់សំឡេងដោយត្រចៀក ក៏បាន ធុំក្លិនដោយច្រមុះក៏បាន លិទ្ធភក្សរសដោយអណ្តាតក៏បាន ពាល់ត្រូវ ផោដ្ឋព្វៈដោយកាយក៏បាន ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តក៏បាន តែកាល ណាកាយនេះ មិនប្រកបដោយអាយុផង មិនប្រកបដោយភ្លើងធាតុផង មិន ប្រកបដោយវិញ្ញាណផងទេ ក្នុងកាលនោះ កាយនេះឈានទៅមុខក៏មិនបាន ថយក្រោយក៏មិនបាន ឈរក៏មិនបាន អង្គុយក៏មិនបាន សម្រេចឥរិយាបថ ដេកក៏មិនបាន ឃើញរូបដោយចក្ខុក៏មិនបាន ស្តាប់សំឡេងដោយត្រចៀកក៏ មិនបាន ធុំក្លិនដោយច្រមុះក៏មិនបាន លិទ្ធភក្សរសដោយអណ្តាតក៏មិនបាន ប៉ះពាល់ត្រូវផោដ្ឋព្វៈដោយកាយក៏មិនបាន ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត

ក៏មិនបាន ។ ឱរាជញ្ញៈ បើតាមបរិយាយនេះ សូមមហាបពិត្រទ្រង់យល់មក យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឱបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ។

បឋមភាណវារ ចប់

[๑๕๔] *ព្រះកស្សបដ៏ចម្រើន និយាយយ៉ាងនេះក៏គួរដែរហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះទៀតថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពរាជញ្ញៈ ចុះបរិយាយនៅមានទៀតដែរឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន ។បេ។ ថ្វាយព្រះពរាជញ្ញៈបរិយាយនោះតើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួករាជបុរសក្នុងដែននេះ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ មកឲ្យដល់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនេះជាចោរប្រព្រឹត្តអាក្រក់នឹងព្រះអង្គ។ សព្វព្រះហឫទ័យនឹងដាក់អាជ្ញាណាដល់ចោរនេះ សូមព្រះអង្គដាក់អាជ្ញានោះចុះ ខ្ញុំនិយាយនឹងរាជបុរសទាំងនោះយ៉ាងនេះថា នែអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយឆូតស្បែកក្រៅរបស់បុរសនេះមើល ក្រែងលោយើងឃើញជីវៈរបស់បុរសនេះ ពួករាជបុរសទាំងនោះ ក៏ឆូតស្បែកក្រៅរបស់បុរសនោះ ។ យើងក៏មិនបានឃើញជីវៈ របស់បុរសនោះសោះ ។ ខ្ញុំនិយាយនឹងរាជបុរសទាំងនោះ យ៉ាងនេះទៀងថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយពន្លះស្បែកក្នុង អារសាច់ កាត់សរសៃ កាត់ឆ្អឹង ឆ្កៀលខួរក្នុងឆ្អឹងរបស់*

បុរសនេះមើល ក្រែងលោយើងបានឃើញជីវៈរបស់វា រាជបុរសទាំងនោះ ក៏ឆ្កៀលខួរក្នុងឆ្អឹងរបស់បុរសនោះ ។ យើងក៏នៅតែមិនឃើញជីវៈរបស់បុរសនោះសោះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំខ្ញុំឲ្យនៅមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់មិនមានដោយហេតុនេះ ។

[๑๕๕] *ថ្វាយព្រះពរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើឧបមាថ្វាយមហាបពិត្រ វិញ្ញូបុរសពួកខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតនេះ ដោយពាក្យឧបមាបាន ។ បពិត្រពរាជញ្ញៈ កាលពីព្រេងនាយមក មានជដិលម្នាក់ ជាអ្នកបម្រើភ្លើងនៅក្នុងកុដិស្មឹក ក្នុងព្រៃរំលោង ។ បពិត្រពរាជញ្ញៈ ក្នុងកាលនោះឯង មានពួកឈ្មួញរទេះមួយពួកនៅក្នុងជនបទ បាននាំគ្នាចេញអំពីជនបទនោះ ។ គ្រានោះ ពួកឈ្មួញរទេះនោះនៅឈប់សំចតជិតអាស្រមរបស់ជដិលអ្នកបម្រើភ្លើងនោះ អស់មួយយប់ ទើបនាំគ្នាចៀសចេញទៅ ។ បពិត្រពរាជញ្ញៈ គ្រានោះឯង ជដិលអ្នកបម្រើភ្លើងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា គួរតែអាត្មាអញចូលទៅត្រង់កន្លែងជាទីសំណាក់របស់ពួកឈ្មួញរទេះនោះ ក្រែងជួនជាបានគ្រឿងឧបករណ៍អ្វីមួយក្នុងទីនុ៎ះ ។ ទើបជដិលអ្នកបម្រើភ្លើងនោះ ក្រោកឡើងពីព្រលឹម ចូលទៅត្រង់កន្លែងជាទីសំណាក់ របស់ពួកឈ្មួញរទេះនោះ លុះចូលទៅដល់ហើយ ក៏បានឃើញក្មេងតូច ក្បាលត្រងោល ដេកផ្ងារ ដែលគេចោលក្នុងទីសំណាក់របស់ពួកឈ្មួញរទេះនោះ ។ ជដិលនោះ លុះឃើញហើយ ក៏មានសេចក្តីត្រិះរិះយ៉ាង*

នេះថា កាលបើអាត្មាអញមើលបំណាំបណ្តាយឲ្យមនុស្សស្លាប់ ដោយហេតុណា ហេតុនុ៉ះ មិនសមគួរដល់អញឡើយ បើដូច្នោះ គួរតែអាត្មាអញយកទារកនេះទៅឯអាស្រមថែទាំចិញ្ចឹមឲ្យចម្រើនឡើង ។ ទើបជដិលអ្នកបម្រើភ្លើងនោះ នាំយកទារកនោះទៅអាស្រម ថែទាំចិញ្ចឹមឲ្យចម្រើនឡើង ។ ក្នុងកាលដែលជាទារកនោះមានអាយុ ១០ ឆ្នាំ ឬ ១២ ឆ្នាំ ទើបជដិលអ្នកបម្រើភ្លើងនោះ មានករណីយកិច្ចមួយកើតឡើងក្នុងជនបទ ។ ទើបជដិលអ្នកបម្រើភ្លើងនោះបានផ្តាំនឹងទារកនោះយ៉ាងនេះថា នែបា អញប្រាថ្នានឹងទៅកាន់ជនបទ នែបា ត្រូវឯងបម្រើភ្លើង ប្រុងកុំឲ្យភ្លើងរបស់ឯងរលត់ឡើយ បើជួនជាភ្លើងរបស់ឯងរលត់ កាំបិតនេះ ឧសនេះ ឈើពំនួតភ្លើងនេះមាន ត្រូវឯងយកទៅបង្កាត់ភ្លើង ហើយបម្រើភ្លើង (ពុំខាន) ។ លំដាប់នោះ ជដិលអ្នកបម្រើភ្លើងនោះ ផ្តែផ្តាំទារកយ៉ាងនេះហើយ ក៏ទៅកាន់ជនបទ ។ ទារកនោះកំពុងតែខ្ចល់ខ្ចាយដោយល្បែង ភ្លើងក៏រលត់អស់ ។ ទើបទារកនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញយ៉ាងនេះថា នែបា ចូរឯងបម្រើភ្លើងកុំឲ្យភ្លើងរបស់ឯងរលត់ឡើយ បើជួនជាភ្លើងរបស់ឯងរលត់ហើយ កាំបិតនេះ ឧសនេះ ឈើពំនួតភ្លើងនេះមាន ត្រូវឯងយកទៅបង្កាត់ភ្លើង ហើយបម្រើភ្លើង (កុំខាន) បើដូច្នោះ គួរតែអាត្មាអញបង្កាត់ភ្លើង ហើយបម្រើភ្លើងចុះ ។ កាលនោះទារកនោះយកកាំបិតចាំងឈើពំនួតមើល ដោយគិតថា ធ្វើម្តេចហ្នាំ អាត្មាអញនឹងបានភ្លើងនេះ ។ ទារកនោះ ក៏មិនបានភ្លើងសោះ ហើយក៏ពុះឈើពំនួតជា ២ ចំណែក ៣ ចំណែក ៤ ចំណែក ៥ ចំណែក ១០ ចំណែក

๒๐ ចំណែក ធ្វើឲ្យជាចម្រៀកតូចៗ លុះធ្វើឲ្យជាចម្រៀកល្អិតៗ ហើយ ក៏យកទៅបុកក្នុងត្បាល់ លុះបុកក្នុងត្បាល់រួចហើយ រោយទៅតាមខ្យល់ខ្លាំង ដោយបំណងថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើងនេះ ។ ទារកនោះក៏នៅតែមិនបានភ្លើងសោះ ។ លំដាប់នោះ ជដិលអ្នកបម្រើភ្លើងនោះ សម្រេចកិច្ចដែលត្រូវធ្វើក្នុងជនបទនោះហើយ បានចូលទៅអាស្រមរបស់ខ្លួន លុះចូលទៅដល់ហើយ បាននិយាយនឹងទារកនោះយ៉ាងនេះថា ម្នៃបា ហេតុដូចម្តេច ក៏ឯងឲ្យភ្លើងរលត់ ។ ទារកនោះនិយាយថា បពិត្របិតា ខ្ញុំកំពុងតែខ្វល់ខ្វាយដោយការរលេងក្នុងទីនេះ ភ្លើងក៏រលត់ ខ្ញុំមានសេចក្តីត្រិះរិះយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញយ៉ាងនេះថា នែបា ឯងត្រូវបម្រើភ្លើង នែបា ឯងកុំឲ្យភ្លើងរលត់ទៅយ បើជួនជាភ្លើងរបស់ឯងរលត់ កាំបិតនេះ ឧសនេះ ឈើពំនួតភ្លើងនេះ ត្រូវឯងយកទៅបង្កាត់ភ្លើង ហើយបម្រើភ្លើង (កុំខាន) បើដូច្នោះ អាត្មាអញគួរតែបង្កាត់ភ្លើង ហើយបម្រើភ្លើងចុះ បពិត្របិតា លំដាប់នោះឯងខ្ញុំក៏យកកាំបិតច្រាសឈើពំនួតដោយបំណងថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើងអេះ ។ ខ្ញុំក៏មិនបានភ្លើងសោះទៅយ ខ្ញុំក៏ពុះឈើពំនួតភ្លើងជា ๒ ចំណែក ๓ ចំណែក ๔ ចំណែក ๕ ចំណែក ๑๐ ចំណែក ๒๐ ចំណែក ធ្វើឲ្យជាចម្រៀកតូចៗ លុះធ្វើឲ្យជាចម្រៀកតូចៗ រួចហើយ ក៏យកទៅបុកក្នុងក្បាល់ លុះបុកក្នុងក្បាល់ហើយ ក៏រោយតាមខ្យល់ខ្លាំង ដោយបំណងថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើង ខ្ញុំក៏មិនបានភ្លើងសោះ ។ គ្រានោះឯង ជដិលជាអ្នកបម្រើភ្លើងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ទារកនេះហៅ

ពេញជាមនុស្សខ្លៅ មិនវាងវៃមែន មិនសមបើនឹងស្វែករកភ្លើងដោយខុសទំនងសោះ ។ កាលដែលទារកនោះ កំពុងសម្ងឹងមើល ជដិលនោះក៏ចាប់យកឈើពំនួតភ្លើង ហើយពួតឲ្យកើតភ្លើង រួចនិយាយនឹងទារកនោះយ៉ាងនេះថា នែបា ភ្លើងគេត្រូវពួតឲ្យធេះយ៉ាងនេះ មិនមែនដូចជាបាឯងជាមនុស្សធោតមិនវាងវៃ ស្វែករកភ្លើងដោយខុសទំនងដូច្នោះទេ ។ បពិត្ររាជញ្ញៈ ឯមហាបពិត្រក៏យ៉ាងនោះដែរ គឺជាមនុស្សខ្លៅមិនវាងវៃ ស្វែករកបរលោកដោយខុសទំនង បពិត្ររាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នោះចេញ បពិត្ររាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៉ះចេញ ទិដ្ឋិដ៏អាក្រក់ (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ កុំបីមានដល់មហាបពិត្រឡើយ ។

[១៥៦] ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះ ក៏សមម្យ៉ាងដែរ ហើយ ប៉ុន្តែ ខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញបានទេ ព្រោះថា ព្រះបាទបសេនទិកោសលក្តី ពួកព្រះរាជាខាងក្រៅក្តី ដឹងច្បាស់នូវខ្ញុំថា ព្រះបាទបាយាសិរាជញ្ញៈ ធ្លាប់មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមានដោយហេតុនេះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បើខ្ញុំនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញហើយ មុខជាអ្នកផងនឹងស្តីឲ្យខ្ញុំថា ព្រះបាទបាយាសិរាជញ្ញៈ ហៅពេញជាមនុស្សខ្លៅ មិនវាងវៃ ប្រកាន់តែសេចក្តីខុស ដូច្នេះ ខ្ញុំមុខជានឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំ

នឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការលុបគុណខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រឡងវាសនាខ្លះ ។

[๑๕๗] ថ្វាយព្រះពរវាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតដោយពាក្យឧបមាបាន ។ បពិត្រវាជញ្ញៈ កាលពីព្រេងនាយមក មានឈ្មួញរនេះច្រើន នាំរនេះប្រមាណ ๑๐๐๐ បរចេញពីជនបទខាងកើត ទៅកាន់ជនបទខាងលិច ។ ពួកឈ្មួញរនេះនោះទៅក្នុងទីណាៗ ស្មៅ ឧស ទឹក និងស្វឹកឈើខៀវខ្ចី ក្នុងទីនោះក៏ធាប់អស់ទៅ ។ ក្នុងពួកឈ្មួញរនេះនោះឯង មាននាយឈ្មួញរនេះ ๒ នាក់ ម្នាក់មានរនេះ ๕๐๐ ម្នាក់ទៀត មានរនេះ ๕๐๐ ។ លំដាប់នោះឯង នាយឈ្មួញរនេះទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ពួកឈ្មួញរនេះនេះឯង មានរនេះ ๑๐๐๐ យើងទាំងឡាយទៅនៅក្នុងទីណាៗ ស្មៅ ឧស ទឹក និងស្វឹកឈើខៀវខ្ចី ក្នុងទីនោះៗ ក៏ធាប់អស់ទៅណាស់ បើដូច្នោះ មានតែយើងរាល់គ្នា ចែកពួកឈ្មួញរនេះនេះ ជា ๒ ចំណែក គឺមួយចំណែក ๕๐๐ រនេះ មួយចំណែកទៀត ๕๐๐ រនេះ ។ នាយឈ្មួញទាំងនោះក៏បានចែកឈ្មួញរនេះនោះជា ๒ ចំណែក គឺមួយចំណែក ๕๐๐ រនេះ មួយចំណែកទៀត ๕๐๐ រនេះ ។ នាយឈ្មួញរនេះម្នាក់ បានផ្តុកស្មៅ ឧស ទឹកជាច្រើន ហើយនាំគ្នាបរទៅ ។ កាលដែលពួកឈ្មួញរនេះនោះបរចេញទៅអស់ពីរបីថ្ងៃ ក៏បានឃើញបុរសមានសម្បុរខ្មៅ មានភ្នែកក្រហមចងបាច់កួនសរ ប្រដាប់ដោយផ្ការកុមុទ មានសំពត់ទទឹក មានសក់

ទទឹក បរវេជដ៏ល្អ មានកង់ប្រឡាក់ដោយភក់ មកជួបគ្នានៅពាក់កណ្តាលផ្លូវ លុះឃើញហើយក៏សួរដូច្នេះថា នែអ្នកដ៏ចម្រើន អ្នកមកពីទីណា ។ បុរសសម្បុរខ្មៅនោះឆ្លើយថា ខ្ញុំមកពីជនបទឯណោះ ។ ពួកឈ្មួញរនេះក៏សួរទៀតថា អ្នកនឹងទៅក្នុងទីណា ។ បុរសនោះប្រាប់ថា ខ្ញុំនឹងទៅជនបទឯណោះ ។ ពួកឈ្មួញរនេះសួរថា នែអ្នកដ៏ចម្រើន ផ្លូវលំបាកខាងមុខៗ មានមហាមេឃបង្អុរភ្លៀងជោកជាំខ្លះដែរឬ ។ បុរសនោះឆ្លើយប្រាប់ថា អើអ្នកដ៏ចម្រើន ផ្លូវលំបាកខាងមុខៗ មានមហាមេឃបង្អុរភ្លៀងជោកជាំ ផ្លូវទាំងឡាយមានទឹកពេញពាស មានទាំងស្មៅ ខស ទឹកជាច្រើន នែអ្នកដ៏ចចម្រើន ចូរអ្នកទាំងឡាយចោលស្មៅ ខស ទឹកចាស់ទាំងឡាយចេញទៅ ចូរនេះទាំងឡាយដែលមានបន្ទុកស្រាលៗ ទៅធាប់ៗចុះ កុំឲ្យពួកគោលំបាកឡើយ ។ លំដាប់នោះឯង នាយឈ្មួញរនេះនោះ ប្រាប់ពួកឈ្មួញរនេះថា នែអ្នកដ៏ចម្រើន បុរសនេះបាននិយាយយ៉ាងនេះថា ផ្លូវលំបាកខាងមុខៗ មានមហាមេឃបង្អុរភ្លៀងជោកជាំ ផ្លូវទាំងឡាយមានទឹកពេញពាស មានទាំងស្មៅ ខស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយចោល ស្មៅ ខស ទឹកចាស់ចេញទៅ ចូរបរនេះទាំងឡាយ មានបន្ទុកស្រាលៗ ទៅធាប់ៗចុះ កុំឲ្យពួកគោលំបាកឡើយ នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយ ចោលស្មៅ ខស ទឹកចាស់ទាំងឡាយចេញទៅ ចូរនាំគ្នាបរនេះទាំងឡាយ មានបន្ទុកស្រាលៗ ទៅចុះ ។ ពួកឈ្មួញរនេះទាំងនោះ ទទួលពាក្យនាយឈ្មួញរនេះនោះថា អើ អ្នកដ៏ចម្រើន ហើយក៏ចោលស្មៅ ខស ទឹកចាស់ចេញ ហើយនាំគ្នីគ្នាបរនេះ ដែលមាន

បន្ទុកស្រាលៗ ទៅ ។ ពួកឈ្មួញ រនេះទាំងនោះ ក៏មិនបានឃើញស្មៅ ឧស ឬទឹកក្នុងដំណាក់ពួកឈ្មួញ រនេះជាដំបូងផង ក្នុងដំណាក់ពួកឈ្មួញរនេះជាគម្រប់ ២ ផង ។ ក្នុងដំណាក់ពួកឈ្មួញរនេះទី ៣ ផង ។ ក្នុងដំណាក់ពួកឈ្មួញរនេះទី ៤ ផង ។ ក្នុងដំណាក់ពួកឈ្មួញរនេះទី ៥ ផង ។ ក្នុងដំណាក់ពួកឈ្មួញរនេះទី ៦ ផង ។ មិនបានឃើញស្មៅ ឧស ឬទឹក ក្នុងដំណាក់ពួកឈ្មួញរនេះទី ៧ ផង ហើយក៏ជល់នូវសេចក្តីវិនាសទាំងអស់គ្នា ។ ពួកមនុស្ស ឬពួកសត្វចិញ្ចឹម ក៏មានច្រើនក្នុងឈ្មួញរនេះនោះ ។ បុរសមានសម្បុរខ្មៅនោះ គឺជាយក្សជាអមនុស្ស ក៏ស៊ីពួកមនុស្ស និងសត្វចិញ្ចឹមទាំងអស់នោះ ។ នៅសល់តែឆ្អឹងទេប៉ុណ្ណោះឯង ។ កាលណានាយឈ្មួញរនេះទី ២ បានដឹងថា ឥឡូវនេះ ពួកឈ្មួញរនេះនោះ ចេញទៅយូរថ្ងៃហើយ ក៏ផ្ទុកស្មៅ ឧស ទឹកជាច្រើន នាំគ្នាបររនេះចេញទៅទៀត ។ លុះពួកឈ្មួញរនេះនោះ បរទៅអស់ពីរបីថ្ងៃ ក៏បានឃើញបុរសមានសម្បុរខ្មៅ មានក្អែកក្រហម ចងជាច់កូនសរ ប្រដាប់ដោយផ្កាកុមុទៈ មានសំពត់ទទឹក មានសក់ទទឹក កំពុងបររនេះដ៏ល្អ មានកងំប្រឡាក់ដោយភក់ មកជួបគ្នានៅពាក់កណ្តាលផ្លូវ លុះឃើញហើយ ក៏សួរយ៉ាងនេះថា នែអ្នកដ៏ចម្រើន អ្នកមកពីទីណា ។ បុរសសម្បុរខ្មៅនោះឆ្លើយថា ខ្ញុំមកពីជនបទឯណោះ ពួកឈ្មួញរនេះសួរថា អ្នកនឹងទៅក្នុងទីណា ។ បុរសនោះប្រាប់ថា ខ្ញុំនឹងទៅជនបទឯណោះ ។ ពួកឈ្មួញរនេះសួរថា នែអ្នកដ៏ចម្រើន ផ្លូវលំបាកខាងមុខៗ មានមហាមេឃបង្អុរភ្លៀងជោកជាំខ្លះដែរឬ ។ បុរសនោះឆ្លើយប្រាប់ថា អើអ្នកដ៏

ចម្រើន ក្នុងផ្ទូវលំបាកខាងមុខៗ មានមហាមេយបង្អុរភ្លៀងជោកជាំ ផ្ទូវទាំង-ឡាយមានទឹកពេញពាស មានទាំងស្មៅ ឧស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយចោលស្មៅ ឧស ទឹកចាស់ចេញទៅ ចូរបរតែរទេះទាំង-ឡាយដែលមានបន្ទុកស្រាលៗ ទៅធាប់ៗ ចុះ កុំឲ្យពួកគោលំបាកឡើយ ។ លំដាប់នោះឯង នាយឈ្ងួញរទេះនោះ ក៏បានប្រាប់ពួកឈ្ងួញរទេះថា នែអ្នកដ៏ចម្រើន បុរសនេះបាននិយាយយ៉ាងនេះថា ក្នុងផ្ទូវលំបាកខាងមុខៗ មានមហាមេយបង្អុរភ្លៀងជោកជាំ ផ្ទូវទាំងឡាយមានទឹកពេញពាស មានទាំងស្មៅ ឧស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយចោលស្មៅ ឧស ទឹកចាស់ចេញទៅ ចូរបរតែរទេះទាំងឡាយ មានបន្ទុកស្រាលៗ ទៅឲ្យធាប់ៗ ចុះ កុំឲ្យពួកគោលំបាកឡើយ ដូច្នេះ ម្នាលអ្នកដ៏ចម្រើន បុរសនេះមិនមែនជាមិត្ត មិនមែនជាញាតិសាលោហិតរបស់យើងទេ យើងនឹងទៅដោយជឿពាក្យបុរសនេះដូចម្តេចបាន អ្នកទាំងឡាយមិនត្រូវចោលស្មៅ ឧស ទឹកចាស់ឡើយ ។ ចូរអ្នកទាំងឡាយនាំគ្នាបររទេះទៅ យកទាំងរបស់ដែលបានផ្ទុកមកហើយ យើងកុំចោលរបស់ចាស់យើងឡើយ ។ ពួកឈ្ងួញរទេះទាំងនោះ ទទួលពាក្យនាយឈ្ងួញរទេះនោះថា អើ អ្នកដ៏ចម្រើន ហើយក៏នាំគ្នាបររទេះទៅ យកទាំងរបស់ដែលបានផ្ទុកមកហើយនោះ ។ ពួកឈ្ងួញរទេះទាំងនោះ ក៏មិនបានឃើញស្មៅ ឧស ទឹក ក្នុងដំណាក់ពួកឈ្ងួញរទេះជាដំបូងផង ។ ក្នុងដំណាក់ពួកឈ្ងួញរទេះទី ២ ផង ។ ក្នុងដំណាក់ពួកឈ្ងួញរទេះទី ៣ ផង ។ ក្នុងដំណាក់ពួកឈ្ងួញរទេះទី ៤ ផង ។ ក្នុងដំណាក់ពួកឈ្ងួញរទេះទី ៥ ផង ។

ក្នុងដំណាក់ពួកឈ្មួញរនេះទី ๖ ផង មិនបានឃើញស្មៅ ឧស ឬទឹកក្នុងដំណាក់ពួកឈ្មួញរនេះទី ๗ ផង បានឃើញតែពួកឈ្មួញរនេះនោះដែលដល់នូវសេចក្តីវិនាសប៉ុណ្ណោះ ។ ពួកមនុស្ស ឬសត្វចិញ្ចឹមក៏មានច្រើន ក្នុងពួកឈ្មួញរនេះនោះ ។ ពួកឈ្មួញរនេះទាំងនោះ បានឃើញតែឆ្អឹងមនុស្ស និងសត្វចិញ្ចឹមទាំងនោះ ។ ឯបុរសមានសម្បុរខ្មៅនោះ គឺជាយក្ស ជាអមនុស្ស បានស៊ីមនុស្ស និងសត្វចិញ្ចឹមនោះ (អស់ទៅ) ។ លំដាប់នោះឯង នាយឈ្មួញរនេះនោះ បានប្រាប់ពួកឈ្មួញរនេះថា នែអ្នកដ៏ចម្រើន ពួកឈ្មួញរនេះនោះឯង ដែលដល់នូវសេចក្តីវិនាស ព្រោះតែនាយឈ្មួញរនេះជាបរិនាយកជាមនុស្សល្ងង់នោះ ។ ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ទ្រព្យរបស់ទាំងឡាយណា ក្នុងពួកររនេះរបស់យើង ជារបស់មានថ្លៃតិច ចូរអ្នកទាំងឡាយ ចោលទ្រព្យរបស់ទាំងនោះចេញ ហើយយកតែរបស់ទាំងឡាយដែលមានថ្លៃច្រើនក្នុងពួកររនេះនេះចុះ ។ ពួកឈ្មួញរនេះទាំងនោះ ទទួលពាក្យរបស់នាយឈ្មួញរនេះថា អើ អ្នកដ៏ចម្រើន ហើយក៏ចោលទ្រព្យរបស់ទាំងឡាយ ដែលមានថ្លៃតិច ក្នុងពួកររនេះខ្លួន ហើយយកតែទ្រព្យរបស់ដែលមានថ្លៃច្រើន ក្នុងពួកររនេះនោះ រួចឆ្ងងផុតអំពីផ្លូវលំបាកនោះ បានដោយសួស្តី ព្រោះតែនាយឈ្មួញរនេះ ជាបរិនាយកនោះឯង ជាបណ្ឌិតឈ្លាសវៃ ។ បពិត្រភាជញ្ញៈមហាបពិត្រក៏យ៉ាងនោះឯង ជាបុគ្គលខ្ជៅមិនវាងវៃ ស្វែករកបរលោកដោយខុសទំនង គង់នឹងដល់នូវសេចក្តីវិនាស ដូចបុរសជានាយឈ្មួញរនេះនោះ មួយទៀត ពួកជនណាសម្គាល់នូវពាក្យរបស់មហាបពិត្រថា ជាពាក្យគួរស្តាប់

គួរជឿ ជនទាំងនោះមុខជានឹងដល់នូវសេចក្តីវិនាស ដូចពួកឈ្មួញរនេះនោះ បពិត្រព្រាជញ្ញៈ សូមមហាបពិត្រលះបង់នូវទិដ្ឋិអាក្រក់នុ៎ះចេញ បពិត្រព្រាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ទិដ្ឋិអាក្រក់ (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង កុំបីមានដល់មហាបពិត្រឡើយ ។

[១៥៨] ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះក៏សមម្យ៉ាងដែរហើយ ប៉ុន្តែ ខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញបានទេ ព្រោះថា ស្តេចបសេនទិកោសលក្តី ពួកស្តេចខាងក្រៅក្តី ជីងច្បាស់នូវខ្ញុំថា ព្រះបាទបាយាសិរាជញ្ញៈ ធ្លាប់មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់មិនមាន ដោយហេតុនេះ បពិត្រព្រះកស្សបដ៏ចម្រើន បើខ្ញុំនឹងលះបង់នូវទិដ្ឋិអាក្រក់នេះចេញ មុខជានឹងមានអ្នកផង ស្តីឲ្យខ្ញុំថា ព្រះបាទបាយាសិរាជញ្ញៈ ហៅពេញជាមនុស្សខ្លៅ មិនវាងវៃ ប្រកាន់តែសេចក្តីខុសដូច្នេះ ខ្ញុំមុខជានឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំនឹងប្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការលុបគុណខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រឡងវាសនាខ្លះ ។

[១៥៩] ថ្វាយព្រះពរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្រព្រាជញ្ញៈ កាលពីព្រេងនាយមក មានបុរសម្នាក់

ជាអ្នកចិញ្ចឹមជ្រូក បានចេញពីស្រុករបស់ខ្លួន ទៅកាន់ស្រុកដទៃ ក៏បានឃើញលាមកក្រៀមច្រើន ដែលគេចោលក្នុងទីនោះ ។ លុះបុរសនោះឃើញហើយ មានសេចក្តីត្រិះរិះដូច្នេះថា គេចោលលាមកក្រៀមនេះច្រើនណាស់ លាមកក្រៀមនេះ ត្រូវជាចំណីជ្រូកទាំងឡាយរបស់អាត្មាអញ គួរតែអាត្មាអញយកលាមកក្រៀមពីទីនេះទៅ ។ បុរសនោះក៏លាសំពត់បង់ក ហើយកើបលាមកក្រៀមជាច្រើនវេចជាបង្វែច លើកទូលលើក្បាលហើយដើរទៅ ។ កាលបុរសនោះដើរទៅដល់ពាក់កណ្តាលផ្លូវ មហាមេឃក៏បង្អុរភ្លៀងខុសកាល ។ បុរសនោះប្រឡាក់លាមកជរាបជល់ចុងក្រចក ក៏នៅតែទូលទ្រនូលលាមកដែលកំពុងហូរហៀរធ្លាក់សស្រាក់ដើរទៅ ។ មនុស្សទាំងឡាយឃើញបុរសនោះហើយ បាននិយាយយ៉ាងនេះថា នែវ៉ីយ ឯងជាមនុស្សឆ្កួតទេឬអ្វី ឯងជាមនុស្សលេលាឬអ្វី មិនសមបើឯងប្រឡាក់ដោយលាមកជល់ចុងក្រចក ហើយនៅតែទូលទ្រនូលលាមក ដែលកំពុងហូរហៀរ ធ្លាក់សស្រាក់សោះទៀយ ។ បុរសនោះឆ្លើយថា នែវ៉ីយ បណ្តាយើងទាំងឡាយនុ៎ះ អ្នករាល់គ្នាទេតើជាមនុស្សឆ្កួត អ្នករាល់គ្នាទេតើជាមនុស្សលេលា បានជាអញថាដូច្នោះព្រោះថា លាមកនេះជាជុយជ្រូករបស់អញ ។ បពិត្រភញ្ញៈ ឯមហាបពិត្រទុកដូចជាបុរសអ្នកទូលទ្រនូលលាមកយ៉ាងនោះដែរ បពិត្រភញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ បពិត្រភញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ទិដ្ឋិដ៏លាមក (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង កុំបីមានដល់មហាបពិត្រឡើយ ។

[๑๖๐] *ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះក៏សមដែរហើយ តែខ្ញុំនៅតែមិនអាចលះបង់ទិដ្ឋិអាក្រក់នេះចេញបានទេ (ព្រោះ) ស្តេចបសេនទិកោសលក្តី ពួកស្តេចខាងក្រៅក្តី តែងជ្រាបនូវខ្ញុំថា ស្តេចជយាសិរាជញ្ញៈធ្លាប់មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកជទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ បពិត្រព្រះកស្សបដ៏ចម្រើន បើខ្ញុំនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញ មុខជានឹងមានអ្នកផង ស្តីឲ្យខ្ញុំថា ស្តេចជយាសិរាជញ្ញៈនេះ ហៅពេញជាមនុស្សខ្លៅ មិនវាងវៃ ប្រកាន់តែសេចក្តីខុស ដូច្នេះ ខ្ញុំមុខជាត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីលុបគុណាខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រឡងវាសនាខ្លះ ។*

[๑๖๑] *ថ្វាយព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្ររាជញ្ញៈ កាលពីព្រេងនាយមក មានអ្នកលេងបាស្កា ๒ នាក់ បានលេងល្បែងបាស្កា ។ អ្នកលេងបាស្កាម្នាក់ តែងលេបកូនបាស្កាដែលចាញ់ ដែលបានមកជល់ខ្លួនៗ ។ អ្នកលេងបាស្កាជាគម្រប់ ๒ បានឃើញនូវអ្នកលេងបាស្កានោះ កំពុងលេបកូនបាស្កាដែលចាញ់ ដែលបានមកជល់ខ្លួនៗ លុះឃើញហើយក៏និយាយនឹងអ្នកលេងបាស្កានោះយ៉ាងនេះថា នែសម្លាញ់ អ្នកឯងចេះតែឈ្នះយើងជាដរាប នែសម្លាញ់*

ចូរអ្នកឯងឲ្យជាស្តាមកយើងចុះ យើងនឹងធ្វើការបូជាសិន ។ អ្នកលេងជាស្តា នោះនិយាយថា អើសម្លាញ់ ហើយក៏បានប្រគល់ជាស្តាទាំងឡាយ ដល់អ្នក លេងជាស្តា (ដែលសុំ) នោះ ។ គ្រានោះ អ្នកលេងជាស្តា (ដែលចាញ់) នោះយកថ្នាំពិសប្រឡាក់កូនជាស្តាទាំងឡាយ ហើយនិយាយនឹងអ្នកលេង ជាស្តា (វៀច) នោះយ៉ាងនេះថា នែសម្លាញ់ អ្នកចូរមក យើងនឹងលេង ជាស្តា (ទៀត) ។ អ្នកលេងជាស្តា (វៀច) នោះ ទទួលពាក្យអ្នក លេងជាស្តានោះថា អើសម្លាញ់ ។ អ្នកលេងជាស្តាទាំងនោះ បានលេង ជាស្តាលើកទី ២ ទៀត ។ អ្នកលេងជាស្តា (វៀច) នោះ នៅតែលេប កូនជាស្តាដែលចាញ់ ដែលបានមកដល់ខ្លួនៗ ក្នុងលើកទី ២ ទៀត ។ អ្នក លេងជាស្តាជាគម្រប់ ២ បានឃើញអ្នកលេងជាស្តា (វៀច) នោះ កំពុង លេបកូនជាស្តាដែលចាញ់ ដែលបានមកដល់ខ្លួនៗ ក្នុងលើកទី ២ ទៀត លុះឃើញហើយ ក៏និយាយនឹងអ្នកលេងជាស្តានោះយ៉ាងនេះថា

[๑๖๒] *បុរសអ្នកលេបនូវកូនជាស្តា ដែលគេលាបដោយថ្នាំពិស ដ៏ក្លៀវក្លាបំផុត ក៏នៅតែមិនដឹងខ្លួន ធម្មតាអ្នកលេងវៀចអាក្រក់ ជាអ្នក កម្សត់ តែងលេប (កូនជាស្តា) សេចក្តីក្តៅប្រហាយនឹងមានដល់អ្នកឯង ។*

[๑๖๓] *ថ្វាយព្រះពរវាជញ្ញៈ មហាបពិត្រទុកដូចជាអ្នកលេងជាស្តា យ៉ាងនោះដែរ បពិត្រវាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ បពិត្រវាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ទិដ្ឋិអាក្រក់ (ប្រព្រឹត្ត ទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង កុំបី*

មានដល់មហាបពិត្រឡើយ ។

[១៦៤] ព្រះកស្សបដ៏ចម្រើន និយាយយ៉ាងនេះ ក៏សមដែរហើយ តែខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញទេ (ព្រោះ) ស្តេចបសេនទិ-កោសលក្តី ពួកស្តេចខាងក្រៅក្តី សឹងតែជ្រាបនូវខ្ញុំថា ស្តេចបាយាសិ-រាជញ្ញៈ ធ្លាប់មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិមកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វ ធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ បពិត្រព្រះកស្សបដ៏ចម្រើន បើ ខ្ញុំនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញ មុខជានឹងមានអ្នកផង ស្តីឲ្យខ្ញុំថា ស្តេច បាយាសិរាជញ្ញៈ ហៅពេញជាមនុស្សខ្លៅ មិនវាងវៃ ប្រកាន់តែសេចក្តីខុស ដូច្នេះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំនឹងត្រឡប់ ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីលុបគុណខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះ វិញ ដោយការប្រឡងវាសនាខ្លះ ។

[១៦៥] ថ្វាយព្រះពររាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តី ឧបមា ថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះក្នុងលោកនេះ តែងយល់សេចក្តី នៃភាសិតដោយឧបមាបាន ។ បពិត្ររាជញ្ញៈ កាលពីព្រេងនាយមក មាន បុរសមួយនាក់ នៅក្នុងជនបទ ។ គ្រានោះឯង បុរសជាសម្លាញ់ បាន បបួលបុរសជាសម្លាញ់ថា នែសម្លាញ់ មកយើងនឹងទៅកាន់ជនបទនោះ ក្រែងជួនជាយើងបានទ្រព្យបន្តិចបន្តួច ក្នុងជនបទនោះ ។ បុរសជាសម្លាញ់ បានទទួលពាក្យបុរសជាសម្លាញ់ថា អើសម្លាញ់ ។ បុរសទាំងពីរនាក់នោះ

បានចូលតម្រង់ទៅកាន់ស្រុកមួយ ដែលគេបោះបង់ចោល នៅក្នុងជនបទនោះ ក៏បានឃើញសម្បកឆ្មៃជាច្រើន ដែលគេចោលក្នុងទីនោះ ។ លុះបុរសជាសម្ងាញ់ឃើញហើយ ក៏ប្រាប់បុរសជាសម្ងាញ់ថា នែសម្ងាញ់ សម្បកឆ្មៃជាច្រើននេះគេចោលហើយ នែសម្ងាញ់ បើដូច្នោះ ចូរឯងចងសម្បកឆ្មៃមួយបាច់ ឯអញក៏ចងសម្បកឆ្មៃមួយបាច់ដែរ យើងទាំងពីរនាក់ ក៏នាំយកបាច់សម្បកឆ្មៃទៅ ។ បុរសជាសម្ងាញ់ទទួលពាក្យបុរសជាសម្ងាញ់ថា អើសម្ងាញ់ ហើយក៏ចងសម្បកឆ្មៃជាបាច់ ។ បុរសទាំងពីរនាក់នោះបាននាំយកបាច់សម្បកឆ្មៃ ដើរចូលទៅកាន់ស្រុកមួយ ដែលគេចេញចោល ក៏បានឃើញសរសៃឆ្មៃជាច្រើន ដែលគេចោលក្នុងទីនោះ ។ បុរសជាសម្ងាញ់ឃើញហើយ ប្រាប់បុរសជាសម្ងាញ់ថា នែសម្ងាញ់ យើងត្រូវការសម្បកឆ្មៃ ដើម្បីប្រយោជន៍ដល់សរសៃឆ្មៃណា ឥឡូវនេះ សរសៃឆ្មៃនេះ គេចោលគរគោកស្រាប់ហើយ នែសម្ងាញ់ បើដូច្នោះ អ្នកឯងចូរចោលបាច់សម្បកឆ្មៃទៅ ឯខ្ញុំក៏នឹងចោលបាច់សម្បកឆ្មៃដែរ យើងទាំងពីរនាក់នឹងនាំយកបាច់សរសៃឆ្មៃនេះទៅវិញ ។ សម្ងាញ់ម្នាក់និយាយថា នែសម្ងាញ់ បាច់សម្បកឆ្មៃនេះឯងខ្ញុំបាននាំយកមកពីទីឆ្ងាយផង បានទាំងចងត្រឹមត្រូវផង របស់នោះគួរដល់ខ្ញុំហើយ អ្នកចូរដើរចុះ ។ លំដាប់នោះ បុរសជាសម្ងាញ់នោះ ចោលបាច់សម្បកឆ្មៃ ហើយកាន់យកបាច់សរសៃឆ្មៃវិញ ។ សម្ងាញ់ទាំងពីរនាក់នោះបានចូលទៅដល់ស្រុកមួយ ដែលគេចេញចោល ក៏បានឃើញសំពត់ដែលគេត្បាញពីសរសៃឆ្មៃជាច្រើន ដែលគេចោលក្នុងទីនោះ ។ លុះបុរសជាសម្ងាញ់

ឃើញហើយ ប្រាប់បុរសជាសម្ងាញ់ថា នែសម្ងាញ់ ឃើងត្រូវការសម្បកផ្ទៃក្តី សរសៃផ្ទៃក្តី ដើម្បីប្រយោជន៍ដល់សំពត់ផ្ទៃណា (ឥឡូវនេះ) សំពត់ដែលគេត្បាញអំពីសរសៃផ្ទៃនេះ គេចោលគរគោកស្រាប់ហើយ នែសម្ងាញ់ បើដូច្នោះ អ្នកចូរចោលបាច់សម្បកផ្ទៃទៅ ឯខ្ញុំនឹងចោលបាច់សរសៃផ្ទៃដែរ ឃើងទាំងពីរនាក់ នឹងនាំយកថាប់សំពត់ថ្មីនេះទៅវិញ ។ សម្ងាញ់ម្នាក់និយាយថា នែសម្ងាញ់ បាច់សម្បកផ្ទៃនេះឯង ខ្ញុំបាននាំមកពីទីឆ្ងាយផង បានទាំងចងត្រឹមត្រូវផង របស់នោះគួរដល់ខ្ញុំហើយ អ្នកចូរដឹងចុះ ។ ឯបុរសជាសម្ងាញ់នោះ ក៏ចោលបាច់សរសៃផ្ទៃចេញ ហើយប្រមូលយកថាប់សំពត់ ដែលគេត្បាញពីសរសៃផ្ទៃវិញ ។ អ្នកទាំងពីរនោះ បានចូលទៅដល់ស្រុកមួយទៀត ដែលគេចេញចោល ហើយបានឃើញសម្បកឈើជាច្រើន ដែលគេចោលក្នុងទីនោះ ។ ឃើញសរសៃសម្បកឈើជាច្រើន ដែលគេចោលហើយ ។ ឃើញសំពត់សម្បកឈើជាច្រើន ដែលគេចោលហើយ ។ ឃើញកប្បាសជាច្រើន ដែលគេចោលហើយ ។ ឃើញសរសៃកប្បាសជាច្រើន ដែលគេចោលហើយ ។ ឃើញសំពត់ធ្វើពីកប្បាសជាច្រើន ដែលគេចោលហើយ ។ ឃើញដែកជាច្រើន ដែលគេចោលហើយ ។ ឃើញទង់ដែងជាច្រើន ដែលគេចោលហើយ ។ ឃើញសំណប៉ាហាំងជាច្រើន ដែលគេចោលហើយ ។ ឃើញសំណភក់ជាច្រើន ដែលគេចោលហើយ ។ ឃើញប្រាក់ជាច្រើន ដែលគេចោលហើយ ។ ឃើញមាសជាច្រើន ដែលគេចោលហើយ ។ លុះបុរសជាសម្ងាញ់ម្នាក់ឃើញហើយ ក៏ប្រាប់បុរសជាសម្ងាញ់ថា នែសម្ងាញ់

យើងត្រូវការសម្បកឆ្មៃក្តី សរសៃឆ្មៃក្តី សំពត់ដែលគេត្បាញពីសរសៃឆ្មៃក្តី សម្បកឈើក្តី សរសៃសម្បកឈើក្តី សំពត់សម្បកឈើក្តី កប្បាសក្តី សរសៃកប្បាសក្តី សំពត់ដែលគេធ្វើពីសរសៃកប្បាសក្តី ដែកក្តី ទង់ដែងក្តី សំណប៉ាហាំងក្តី សំណកក់ក្តី ប្រាក់ក្តី ដើម្បីប្រយោជន៍ដល់មាសណា (ឥឡូវ) មាសនេះ គេចោលគរគោកស្រាប់ហើយ នែសម្ងាញ់ បើដូច្នោះ អ្នកចូរចោលបាច់សម្បកឆ្មៃទៅ ឯខ្ញុំនឹងចោលបង្វែចប្រាក់ដែរ យើងទាំងពីរនាក់នឹងយកបង្វែចមាសទៅវិញ ។ សម្ងាញ់ម្នាក់និយាយថា នែសម្ងាញ់ បាច់សម្បកឆ្មៃនេះឯង ខ្ញុំបាននាំយកមកពីទីឆ្ងាយផង បានទាំងចងត្រឹមត្រូវផង របស់នេះគួរដល់ខ្ញុំហើយ អ្នកឯងចូរដើងចុះ ។ លំដាប់នោះ បុរសជាសម្ងាញ់នោះ ចោលបង្វែចប្រាក់ចេញ ហើយយកបង្វែចមាសទៅ ។ បុរសទាំងពីរនាក់នោះ បានវិលចូលទៅដល់ស្រុករបស់ខ្លួនវិញ ។ បណ្តាបុរសទាំងពីរនាក់នោះ បុរសជាសម្ងាញ់ណា ដែលនាំយកបាច់សម្បកឆ្មៃទៅ មាតាបិតារបស់បុរសជាសម្ងាញ់នោះ មិនត្រេកអរសោះ ទាំងបុត្រភរិយាក៏មិនត្រេកអរ ទាំងពួកមិត្តអាមាត្យក៏មិនត្រេកអរ បុរសនោះ ត្រឡប់ជាមិនបានសេចក្តីសុខ សោមនស្ស ព្រោះតែសម្បកឆ្មៃនោះជាហេតុ ។ ចំណែកឯបុរសជាសម្ងាញ់ណា បាននាំយកបង្វែចមាសទៅ មាតាបិតារបស់បុរសជាសម្ងាញ់នោះ ក៏ត្រេកអរ ទាំងបុត្រភរិយាក៏ត្រេអរ ទាំងពួកមិត្តអាមាត្យក៏ត្រេកអរ បុរសនោះ ក៏បានសេចក្តីសុខ សោមនស្ស ព្រោះមាសនោះជាហេតុ ។ បពិត្រភជញ្ញៈ មហាបពិត្រក៏ប្រហែលដូចជាបុរសអ្នកស្គាយសម្បកឆ្មៃយ៉ាងនោះឯង

បពិត្ររាជញ្ញ: សូមមហាបពិត្រ លះបង់ទិដ្ឋិអាក្រក់ន៉ុះចេញ បពិត្ររាជញ្ញ: សូមមហាបពិត្រ លះបង់ទិដ្ឋិអាក្រក់ន៉ុះចេញ ទិដ្ឋិដ៏អាក្រក់ (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង កុំបីមានដល់ព្រះអង្គទ្បើយ ។

[១៦៦] ព្រះបាទបាយាសិរាជញ្ញ: មានបន្ទូលថា ខ្ញុំមានចិត្តត្រេកអរជ្រះថ្លាហើយ ដោយសារសេចក្តីឧបមា របស់ព្រះកស្សបដ៏ចម្រើន តាំងពីដំបូងមកម្ល៉ះ ប៉ុន្តែ ខ្ញុំចង់ស្តាប់បញ្ហាបដិភាណដ៏វិចិត្រនេះទៀត ទើបបានជាខ្ញុំធ្វើជាប្រកាន់ធ្វេង ឲ្យទាស់ខុសគ្នានឹងព្រះកស្សបដ៏ចម្រើនយ៉ាងនេះ បពិត្រព្រះកស្សបដ៏ចម្រើន ភាសិតរបស់លោកម្ចាស់ពីរោះណាស់ បពិត្រព្រះកស្សបដ៏ចម្រើន ភាសិតរបស់លោកម្ចាស់ពីរោះណាស់ បពិត្រព្រះកស្សបដ៏ចម្រើន ធម៌ដែលព្រះកស្សបបានសម្តែងដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជាគេផ្ទាររបស់ដែលផ្ទាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ឬក៏ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុនឹងមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះកស្សបដ៏ចម្រើន ខ្ញុំនេះសូមដល់នូវព្រះគោតមដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឆផង ជាទីពឹង ទីរពឹក ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះកស្សបដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះកវុណា ថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត បពិត្រព្រះកស្សបដ៏ចម្រើន មិនតែប៉ុណ្ណោះទេ ខ្ញុំត្រូវការនឹងបូជាមហាយញ្ញ សូមព្រះកស្សបដ៏

ចម្រើន ប្រៀនប្រដៅខ្ញុំផង ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាយូរអង្វែងដល់ខ្ញុំ ។ ថ្វាយព្រះពរព្រាជញ្ញៈ ពួកមនុស្សសម្លាប់គោទាំងឡាយក្តី សម្លាប់ពពែ និងចៀមទាំងឡាយក្តី សម្លាប់មាន់ និងជ្រូកទាំងឡាយក្តី ពួកសត្វមានជីវិតផ្សេងៗ ដល់នូវសេចក្តីវិនាសក្តី ទាំងបដិគ្គាហក (អ្នកទទួល) ក៏ជាអ្នកយល់ឃើញខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានសេចក្តីព្យាយាមខុស មានសតិខុស មានសមាធិខុស ក្នុងយញ្ញវិធី មានសភាពយ៉ាងណា ។ បពិត្រព្រាជញ្ញៈ យញ្ញវិធី មានសភាពយ៉ាងនោះឯង មិនមានផលច្រើនទេ មិនមានអានិសង្សច្រើនទេ មិនមានសេចក្តីរុងរឿងធំដុំទេ មិនមានគុណផ្សាយទៅច្រើនទេ ។ បពិត្រព្រាជញ្ញៈ ប្រៀបដូចអ្នកភ្ជួរ នាំយកពូជ និងនង្គ័លចូលទៅព្រៃ អ្នកនោះយកពូជទាំងឡាយដែលបែកធ្លាយ ស្អុយ ត្រូវខ្យល់ និងកម្តៅថ្ងៃបៀតបៀន ជាពូជមិនបានដាក់គ្រាប់ មិនបានហាលឲ្យស្ងួត ទៅព្រោះក្នុងស្រែមិនល្អនោះ មានទីមិនស្មើ មិនបានគាស់រម្ងើនូវជង្គត់ និងបន្ទាចេញ ទាំងក្បៀងសោត ក៏មិនបង្អុរនូវធារទឹកដោយល្អ តាមកាលដ៏គួរ ចុះពូជទាំងឡាយនោះ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ដុះដាលល្អឡើងបានដែរឬទេ អ្នកភ្ជួរសោត ត្រូវបានផលបរិបូណ៌ដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន ការនេះនឹងប្រព្រឹត្តទៅយ៉ាងនោះមិនបានទេ ។ ថ្វាយព្រះពរព្រាជញ្ញៈ ពួកមនុស្សសម្លាប់គោទាំង-ឡាយក្តី សម្លាប់ពពែ និងចៀមក្តី សម្លាប់មាន់និងជ្រូកក្តី ពួកសត្វមានជីវិតផ្សេងៗ ដល់នូវសេចក្តីវិនាសក្តី ទាំងបដិគ្គាហក ក៏សុទ្ធតែជាអ្នកយល់ខុស

មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានសេចក្តីព្យាយាមខុស មានសតិខុស មានសមាធិខុស ក្នុងយញ្ញ-វិធី មានសភាពយ៉ាងណា ។ បពិត្ររាជញ្ញ: យញ្ញវិធី មានសភាពយ៉ាងនោះឯង មិនមានផលច្រើនទេ មិនមានអានិសង្សច្រើនទេ មិនមានសេចក្តីរុងរឿងធំដុំទេ ជាយញ្ញវិធីមិនមានគុណផ្សាយទៅច្រើនទេ ។ បពិត្ររាជញ្ញ: (ប្រសិនបើ) ពួកជនមិនសម្ងាប់គោទាំងឡាយ មិនសម្ងាប់ពពែ និងចៀមទាំងឡាយ មិនសម្ងាប់មាន់ និងជ្រូកទាំងឡាយ ពួកសត្វមានជីវិតផ្សេងៗ មិនដល់នូវសេចក្តីវិនាសទាំងពួក បដិគ្គាហកសោត ក៏មានសេចក្តីយល់ត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានសេចក្តីព្យាយាមត្រូវ មានសតិត្រូវ មានសមាធិត្រូវ ក្នុងយញ្ញវិធី មានសភាពយ៉ាងណា ។ បពិត្ររាជញ្ញ: យញ្ញវិធី មានសភាពយ៉ាងនោះឯង ទើបមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងធំដុំ ជាយញ្ញ-វិធី មានគុណផ្សាយទៅច្រើន ។ បពិត្ររាជញ្ញ: ប្រៀបដូចជាអ្នកភ្ជួរ នាំយកពូជ និងនង្គ័លចូលទៅព្រៃ អ្នកនោះ យកពូជទាំងឡាយដែលមិនបែកធ្លាយ មិនស្អុយ មិនត្រូវខ្យល់ និងកម្តៅថ្ងៃបៀតបៀន ជាពូជដាក់គ្រាប់ គេហាលស្ងួត ទៅព្រោះក្នុងស្រែដ៏ល្អនោះ មានទីរាបស្មើ គេបានកាប់គាស់យកដង្គត់ និងបន្ទាចេញដោយល្អ ទាំងភ្លៀង ក៏បង្អុរនូវធារទឹកដោយល្អតាមកាលគួរ ចុះពូជទាំងនោះ នឹងដល់នូវសេចក្តីចម្រើនឡើងលូតលាស់ ដុះដាលបានឬទេ ទាំងអ្នកភ្ជួរសោត ត្រូវបានផលបរិបូណ៌ដែលឬទេ ។ បពិត្រ

ព្រះកស្សបដ៏ចម្រើន ការនេះប្រព្រឹត្តទៅយ៉ាងនោះបាន ។ ថ្វាយព្រះពរ ជញ្ញៈ សេចក្តីនេះមានឧបមេយ្យដូចពួកជនមិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែ និងចៀមទាំងឡាយ មិនសម្លាប់មាន់ និងជ្រូកទាំងឡាយ ពួកសត្វមានជីវិតផ្សេងៗ មិនដល់នូវសេចក្តីវិនាស ទាំងពួកបដិគ្គាហក ក៏មានសេចក្តីយល់ឃើញត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានសេចក្តីព្យាយាមត្រូវ មានសតិត្រូវ មានសមាធិត្រូវ ក្នុងយញ្ញវិធី មានសភាពយ៉ាងណា ។ បពិត្រព្រាជញ្ញៈ យញ្ញវិធីមានសភាពយ៉ាងនោះឯង ទើបមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងធំដុំ ជាយញ្ញវិធី មានគុណផ្សាយទៅច្រើន ។

[๑๖๗] គ្រានោះឯង ស្តេចបាយាសិរាជញ្ញៈ បានផ្តើមតម្កល់ទានចំពោះសមណព្រាហ្មណ៍ មនុស្សកម្សត់ អ្នកដើរផ្លូវ អ្នកពណិនាគុណ និងយាចកទាំងឡាយ ។ ក្នុងទាននោះឯង ស្តេចបាយាសិរាជញ្ញៈ តែងឲ្យកោជនមានសភាពយ៉ាងនេះ គឺបាយចុងអង្ករ មានជ្រក់ជាគម្រប់ ๒ និងសំពត់សាច់គគ្រាត មានជាយដ៏ក្រាស់ ។ ឯក្នុងការឲ្យនោះ មានមាណពម្នាក់ឈ្មោះឧត្តរៈ ជាអ្នកចាត់ចែងទាន ឧត្តរមាណនោះ ឲ្យទានហើយឧទ្ទិសយ៉ាងនេះថា ដោយការឲ្យទាននេះ សូមឲ្យខ្ញុំបានជួបនឹងស្តេចបាយាសិរាជញ្ញៈតែក្នុងលោកនេះចុះ សូមកុំឲ្យជួបទៅក្នុងលោកខាងមុខទៀតឡើយ ។ ស្តេចបាយាសិរាជញ្ញៈបានឮដំណឹងថា ឧត្តរមាណពឲ្យទានហើយ ក៏ឧទ្ទិសយ៉ាងនេះថា ដោយការឲ្យទាននេះ សូមឲ្យខ្ញុំបានជួបនឹងស្តេចបាយាសិរាជញ្ញៈតែ

ក្នុងលោកនេះ សូមកុំឲ្យជួបក្នុងលោកខាងមុខឡើយ ។ ទើបព្រះបាទជាយា-សិកាជញ្ញៈ ត្រាស់ឲ្យហៅឧត្តរមាណពមកហើយ មានព្រះឱង្ការយ៉ាងនេះថា នែបាឧត្តរៈ ឮថា អ្នកឯងឲ្យទានទាំងពួងហើយ តែងឧទ្ទិសយ៉ាងនេះថា ដោយការឲ្យទាននេះ សូមឲ្យខ្ញុំបានជួបនឹងស្តេចជាយាសិកាជញ្ញៈ តែក្នុងលោកនេះ សូមកុំឲ្យជួបក្នុងលោកខាងមុខឡើយ ដូច្នេះមែនឬ ។ ឧត្តរមាណពក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណាវិសេស ។ ព្រះបាទជាយាសិ-កាជញ្ញៈ មានព្រះឱង្ការសួរថា នែបាឧត្តរៈ ហេតុអ្វី ក៏អ្នកឲ្យទានហើយ ឧទ្ទិសយ៉ាងនេះថា ដោយការឲ្យទាននេះ ។បេ។ សូមកុំឲ្យជួបទៅក្នុងលោកខាងមុខឡើយ ដូច្នេះ នែបាឧត្តរៈ យើងមានសេចក្តីត្រូវការដោយបុណ្យ មានសេចក្តីសង្ឃឹមយកផលរបស់ទានប៉ុណ្ណោះ ដោយពិត ។ ឧត្តរមាណពក្រាបទូលថា ខ្ញុំព្រះអង្គតែងឲ្យកោជនមានសភាពយ៉ាងនេះ ក្នុងទានរបស់ព្រះអង្គនោះឯង គឺបាយចុងអង្ករ មានជ្រក់ជាគម្រប់ពីរ សូម្បីតែព្រះអង្គ ក៏មិនសព្វព្រះទ័យប៉ះពាល់ដោយព្រះបាទផង តើនឹងសោយដូចម្តេចកើត មួយទៀត សំពត់មានសាច់គគ្រាត មានជាយដ៏ក្រាស់ សូម្បីតែព្រះអង្គក៏មិនសព្វព្រះទ័យប៉ះពាល់ដោយព្រះបាទផង តើនឹងទ្រង់ដូចម្តេចកើត ចំណែកខាងព្រះអង្គជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ខ្ញុំព្រះអង្គ តែខ្ញុំព្រះអង្គនឹងយករបស់ជាទីស្រឡាញ់ ជាទីពេញចិត្ត ទៅលាយចម្រុះដោយវត្ថុមិនជាទីគាប់ចិត្តដូចម្តេចបាន ។ ព្រះបាទជាយាសិកាជញ្ញៈ មានព្រះឱង្ការថា ម្នាលបាឧត្តរៈ បើដូច្នោះ យើងធ្លាប់បរិភោគកោជនយ៉ាងណា ចូរអ្នកឯងតាក់តែង

កោជនយ៉ាងនោះចុះ មួយទៀត យើងធ្លាប់ស្មៀកដណ្តប់សំពត់យ៉ាងណា ចូរ អ្នកឯងតាក់តែងសំពត់យ៉ាងនោះចុះ ។ ឧត្តរមាណពទទួលព្រះឱង្ការនៃព្រះ បាទបាយាសិរាជញ្ញៈថា ព្រះករុណាវិសេស ហើយក៏តាក់តែងកោជន ដូច ជាកោជនដែលស្តេចបាយាសិរាជញ្ញៈតែងសោយ មួយទៀត តាក់តែងសំពត់ ដូចជាព្រះពស្ត្រដែលស្តេចបាយាសិរាជញ្ញៈតែងទ្រង់ ។ គ្រានោះឯង ព្រះ បាទបាយាសិរាជញ្ញៈ ឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយព្រះ ហស្តព្រះអង្គឯង ឲ្យទានដោយមិនផ្ចិតផ្ចង់ ឲ្យទានដោយបោះឲ្យ លុះបែក ធ្លាយរាងកាយ បន្ទាប់អំពីមរណភាព ក៏ចូលទៅកើតជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិកៈ ក្នុងសេរីសកវិមាន ជាវិមានស្វាត់សូន្យតែឯង ។ ចំណែកខាងឧត្តរមាណព ជាអ្នកចាត់ចែង ក្នុងទានរបស់ស្តេចបាយាសិ- រាជញ្ញៈនុ៎ះ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយ ផ្ចិតផ្ចង់ ឲ្យទានដោយមិនបានបោះឲ្យ លុះធ្លាយរាងកាយ បន្ទាប់អំពីមរណ- ភាពទៅ ក៏បានទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតា ជាន់តាវត្តិង្ស ។

[១៦៨] ជួនសម័យនោះឯង ព្រះគវម្បតិដ៏មានអាយុ និមន្តទៅកាន់ សេរីសកវិមាន ដែលជាវិមានស្វាត់ ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃតែរឿយៗ ។ គ្រានោះឯង បាយាសិទេវបុត្រ ក៏បានចូលទៅរកព្រះគវម្បតិដ៏មានអាយុ លុះ ចូលទៅដល់ហើយ បានថ្វាយបង្គំព្រះគវម្បតិដ៏មានអាយុ ហើយឋិតនៅក្នុងទី ដ៏សមគួរ ។ លុះបាយាសិទេវបុត្រ ឋិតនៅក្នុងទីដ៏សមគួរហើយ ព្រះគវម្បតិ

ដ៏មានអាយុ បានសួរដូច្នេះថា ម្នាលអ្នកដ៏មានអាយុ អ្នកជាអ្វី ។ បាយា-
សិទេវបុត្រតបថា បពិត្រលោកដ៏ចម្រើន ខ្ញុំជាស្តេចបាយាសិរាជញ្ញៈ ។ ព្រះ
គវម្បតិសួរថា ម្នាលអ្នកមានអាយុ ក្រែងអ្នកធ្លាប់យល់ឃើញយ៉ាងនេះថា
លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំង-
ឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ដូច្នេះឬ ។
បពិត្រលោកដ៏ចម្រើន ខ្ញុំមានសេចក្តីយល់ឃើញយ៉ាងនេះថា លោកដទៃមិន
មាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែល
សត្វធ្វើល្អធ្វើអាក្រក់មិនមាន ដោយហេតុនេះពិតមែន តែជួនគ្រោះល្អ បាន
លោកម្ចាស់ព្រះនាមកុមារកស្សប បានដោះខ្ញុំឲ្យរួចចាកទិដ្ឋិអាក្រក់ន៉ុះហើយ ។
នែអ្នកមានអាយុ ចុះចំណែកខត្តរមាណព ជាអ្នកចាត់ចែងក្នុងទានរបស់អ្នក
នោះ តើទៅកើតក្នុងទីណា ។ បពិត្រលោកដ៏ចម្រើន ខត្តរមាណព ដែល
ជាអ្នកខ្ងល់ខ្ងាយក្នុងទានរបស់ខ្ញុំ បានឲ្យទានដោយគោរព ឲ្យទានដោយដៃ
ខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់ ឲ្យទានដោយមិនបានបោះឲ្យ លុះបែកធ្លាយ
រាងកាយ បន្ទាប់អំពីមរណភាពទៅ ក៏បានទៅកើតក្នុងឋានសុគតិសួគិទេវ-
លោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស បពិត្រលោកដ៏ចម្រើន ចំណែក
ខាងខ្ញុំឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទាន
ដោយមិនផ្ចិតផ្ចង់ ឲ្យទានដោយបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពី
មរណភាពមក ក៏បានមកកើតក្នុងសេរីសកវិមាន ជាវិមានស្ងាត់ ជាមួយនឹង
ពួកទេវតាក្នុងជាន់ចាតុម្មហារាជិកៈ បពិត្រព្រះគវម្បតិដ៏ចម្រើន បើដូច្នោះ

(ដល់) លោកម្ចាស់ និមន្តទៅឯមនុស្សលោកវិញ សូមប្រាប់អស់ទាំងពួកមនុស្សយ៉ាងនេះថា អ្នកទាំងឡាយចូរឲ្យទានដោយគោរព ចូរឲ្យទានដោយដៃខ្លួនឯង ចូរឲ្យទានដោយផ្ងៃតផ្ងង់ ចូរឲ្យទានដោយមិនបោះឲ្យ (ដ្បិត) ស្តេចបាយាសិរាជញ្ញៈ ឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទានដោយមិនផ្ងៃតផ្ងង់ ឲ្យទានដោយបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណភាពទៅ ក៏ទៅកើតក្នុងសេរីសកវិមានស្មាត់ជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈទៅហើយ ចំណែកឯខត្តរមាណព ជាអ្នកចាត់ចែងក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈនោះ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ងៃតផ្ងង់ ឲ្យទានដោយមិនបានបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណភាពទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយពួកទេវតាជាន់តាវត្តឹង្សទៅហើយ ។ គ្រានោះឯង ព្រះគវម្បតិមានអាយុ ត្រឡប់មកមនុស្សលោកវិញ ហើយបានប្រាប់ (អស់ទាំងពួកមនុស្ស) យ៉ាងនេះថា អ្នកទាំងឡាយចូរឲ្យទានដោយគោរព ចូរឲ្យទានដោយដៃខ្លួនឯង ចូរឲ្យទានដោយផ្ងៃតផ្ងង់ ចូរឲ្យទានដោយមិនបោះឲ្យ (ដ្បិត) ស្តេចបាយាសិរាជញ្ញៈ បានឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទានដោយមិនផ្ងៃតផ្ងង់ ឲ្យដោយបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណភាពទៅ ក៏ទៅកើតក្នុងសេរីសកវិមានស្មាត់ជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិកៈទៅហើយ ចំណែកខាងខត្តរ-មាណព ជាអ្នកចាត់ចែងក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈនោះ បានឲ្យទាន

ដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្តិតផ្តង់ ឲ្យទានដោយមិនបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណកាលទៅ ក៏ទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តឹង្សទៅហើយ ។

បាយាសិរាជញ្ញសូត្រទី ១០ ចប់

ឧទ្ទាននៃមហាវគ្គនោះគឺ

មហាបទានសូត្រ ១ មហានិទានសូត្រ ១ មហាបរិនិព្វានសូត្រ ១ មហាសុទស្សនសូត្រ ១ ជនវសភសូត្រ ១ មហាគោវិន្ទសូត្រ ១ មហាសមយសូត្រ ១ សក្កបញ្ហសូត្រ ១ មហាសតិបដ្ឋានសូត្រ ១ បាយាសិរាជញ្ញសូត្រ ១ (ទាំង ១០ សូត្រនេះ) លោកឲ្យឈ្មោះថា មហាវគ្គ ។

អដ្ឋកថា

ចាយាសិរាជញ្ញសូត្រ

[១៣៩] ចាយាសិរាជញ្ញសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ ក្នុងចាយាសិរាជញ្ញសូត្រនោះ មានពណ៌នាតាមលំដាប់បទដូច្នេះ

ប្រវត្តិព្រះកុមារកស្សប

បទថា **អាយស្មា** នេះ ជាពាក្យដែលគួរស្រឡាញ់ ។ បទថា **កុមារ-កស្សបោ** ជាឈ្មោះរបស់លោក ។ ព្រោះលោកបួសតាំងពីនៅកុមារ ព្រះមានព្រះភាគ កាលត្រាស់នឹងភិក្ខុទាំងឡាយថា ពួកអ្នកចូរហៅកស្សបមក ចូរឲ្យផ្ទៃឈើនេះខ្ទះ របស់ទំពានេះខ្ទះ ដល់កស្សប ដូច្នេះ ភិក្ខុទាំងឡាយសង្ស័យថា កស្សបអង្គណា (ព្រោះភិក្ខុដែលឈ្មោះកស្សបមានច្រើនអង្គ) ទើបនាំគ្នាជាក់ឈ្មោះលោកថា កុមារកស្សប ។ តាំងពីនោះមក សូម្បីពេលលោកចាស់ជរា ក៏នៅតែហៅថា កុមារកស្សបន៉ុះឯង ។ ម្យ៉ាងទៀត ព្រោះលោកជាកូនចិញ្ចឹមរបស់ព្រះបាទបសេនទិកោសល ទើបមនុស្សទាំងឡាយ ហៅលោកថា កុមារកស្សប ។ នឹងពោលរឿងរបស់លោកឲ្យជាក់ច្បាស់ តាំងអំពីបុព្វប្បយោគដូចតទៅនេះថា

បានញ្ចថា ព្រះថេរ: (កុមារកស្សប) ជាបុត្រសេដ្ឋី កាលព្រះមានព្រះភាគព្រះនាមថា បទុមុត្តរ: ។ ថ្ងៃមួយ លោកឃើញព្រះមានព្រះភាគ ទ្រង់តែងតាំងព្រះសាវ័ករបស់ព្រះអង្គមួយរូប ដែលជាអ្នកពោលធម៌បានវិចិត្រទុកក្នុងតំណែង (ឯតទគ្គ) ទើបថ្វាយទានចំពោះព្រះមានព្រះភាគ ៧ ថ្ងៃ ធ្វើ

សេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ សូម្បីខ្ញុំព្រះអង្គក៏ជាព្រះសាវ័កអ្នកពោលធម៌យ៉ាងវិចិត្រ ដូចព្រះថេរៈអង្គនេះ របស់ព្រះពុទ្ធមួយព្រះអង្គ នាអនាគតកាល បានធ្វើបុណ្យទាំងឡាយ បួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាកស្សប មិនអាចធ្វើគុណវិសេសឲ្យកើតបាន ។ បានឮថា គ្រានោះ កាលព្រះមានព្រះភាគ ស្តេចរលត់ខន្ធបរិនិព្វានហើយ ព្រះសាសនាកំពុងសាបសូន្យ ភិក្ខុ ៥ រូប ធ្វើជណ្តើរឡើងទៅកាន់ភ្នំ ធ្វើសមណធម៌ ។ ភិក្ខុដែលជាសង្ឃត្ថេរ (ប្រធាន) សម្រេចអរហត្តក្នុងថ្ងៃទី ៣ ។ ភិក្ខុដែលជាអនុត្ថេរ បានជាព្រះអនាគាមី ក្នុងថ្ងៃទី ៤ ។ ៣ រូបទៀត មិនអាចធ្វើគុណវិសេសឲ្យកើតបាន ក៏ទៅកើតក្នុងទេវលោក ។ បណ្តាភិក្ខុ ៣ រូប ដែលសោយសម្បត្តិក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរនោះ មួយរូបទៅកើតក្នុងរាជត្រកូល ក្នុងក្រុងតក្កសិលា ជាព្រះរាជាព្រះនាមថា បុក្កុសាតិ បួសឧទ្ទិសព្រះមានព្រះភាគប្រាថ្នាមកកាន់ក្រុងរាជគ្រឹះ បានស្តាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគត្រង់រោងស្ងួនធ្នាំង ក៏សម្រេចអនាគាមិផល ។ មួយរូបទៅកើតក្នុងផ្ទះរបស់ត្រកូល ត្រង់កំពង់ទូកឈ្មោះសុបដ្ឋនៈ ជិតសមុទ្រមួយកន្លែង ធ្វើដំណើរតាមសំពៅៗ ក៏លិច ត្រូវយកឈើធ្វើសំពត់ស្បៀក បានលាភសក្ការៈ (ដែលមនុស្សល្ងង់គិតថា ជាព្រះអរហន្តគួរបូជា) ខ្លួនឯងក៏កើតការគិតថា ជាព្រះអរហន្ត ទេវតាដែលមានចំណងសេចក្តីល្អ បានជាស់តឿនថា អ្នកមិនមែនជាព្រះអរហន្តទេ ចូរទៅគាល់ព្រះមានជោគ ទូលសួរបញ្ហា ក៏ធ្វើតាមទេវតាជាស់តឿន បានសម្រេចអរហត្តផល ។ មួយរូបទៅកើតក្នុងគភ៌របស់ត្រកូលស្ត្រីម្នាក់

ក្នុងក្រុងរាជគ្រឹះ ។ កុលធីតានោះ អង្វរមាតាក៏មិនបានបួស ដរាបមានស្វាមី មិនដឹងខ្លួនថា តាំងគភ៌ យកចិត្តស្វាមីៗ ក៏អនុញ្ញាត ទើបបួសជាកិក្ខុនីនៅក្នុងសម្នាក់កិក្ខុនី ។ កិក្ខុនីទាំងឡាយ ឃើញនាងមានគភ៌ ទើបសួរកិក្ខុទេវទត្ត ។ កិក្ខុទេវទត្ត ក៏ប្រាប់ថា នាងមិនមែនជាសមណៈ ។ ហើយ (សង្ឃ៍យ) ក៏ទៅទូលសួរព្រះទសពល ។ ព្រះសាស្តា ត្រាស់បង្គាប់ឲ្យព្រះឧបាលិត្ថេរទទួលរឿងទៅវិនិច្ឆ័យ ។ ព្រះថេរៈអញ្ជើញត្រកូលអ្នកក្រុងសាវត្ថី និងនាងវិសាខាឧបាសិកាឲ្យជួយពិនិត្យមើល (បានដឹងសេចក្តីពិតហើយ) ទើបវិនិច្ឆ័យថា នាងមានគភ៌មកអំពីមុនបព្វជ្ជា ទើបមិនវិនាស ។ ព្រះសាស្តាប្រទានសាធុការ គាំទ្រដល់ព្រះថេរៈថា ឧបាលិវិនិច្ឆ័យអធិករណ៍ប្រពៃហើយ ។ កិក្ខុនីនោះប្រសូតបុត្រដូចដុំមាស ។ ព្រះបាទបសេនទិកោសល ប្រោសឲ្យទទួលទារកនោះមកចិញ្ចឹម ព្រះរាជទាននាមថា កស្សប ។ បន្ទាប់មកទ្រង់ចិញ្ចឹមកស្សបធំល្មមហើយ ទើបទ្រង់នាំទៅផ្ញើក្នុងសម្នាក់ព្រះសាស្តាឲ្យបព្វជ្ជា ។ ទើបមនុស្សទាំងឡាយស្គាល់លោកថា កុមារកស្សប ព្រោះជាបុត្រចិញ្ចឹមរបស់ព្រះរាជា ដោយប្រការដូច្នេះ ។ ថ្ងៃមួយ លោកធ្វើសមណធម៌នៅត្រង់ព្រៃអន្ធវន ទេវតាដែលមានចំណងស្និទ្ធ ឲ្យលោករៀនបញ្ហា ហើយប្រាប់ឲ្យលោកទៅទូលសួរបញ្ហាទាំងនេះ ចំពោះព្រះមានព្រះភាគ ។ ព្រះថេរៈទូលសួរបញ្ហាហើយ ក៏សម្រេចអរហត្ត ពេលចប់ការវិសជ្ជនាបញ្ហា ។ សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ស្តាបនាលោកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃកិក្ខុ អ្នកពោលធម៌បានវិចិត្រ ។

បទថា **សេតព្យា** ជាឈ្មោះរបស់នគរនោះ ។ បទថា **ឧត្តរេន សេតព្យំ** គឺទិសខាងជើងនៃសេតព្យនគរ ។ បទថា **រាជញ្ញោ** គឺស្តេចដែលមិនទាន់បានទទួលមុទ្ធាភិសេក ។ បទថា **ឧិដ្ឋិគតំ** គឺទិដ្ឋិន៉ុះឯង ។ កាលមានពាក្យដែលពោលថា **ត្ថថគតំ មុត្តគតំ** ដូច្នេះ វត្ថុដទៃក្រៅអំពីលាមកជាដើម រមែងមិនមានយ៉ាងណា ទិដ្ឋិន៉ុះឯង គឺទិដ្ឋិគតៈ ដូច្នោះ ។ បទថា **ឥតិបិ នត្ថិ** ដូច្នេះ សេចក្តីថា ស្តេចបាយាសិពោលថា សូម្បីនឹងអាងហេតុទាំងនោះយ៉ាងនេះ លោកដទៃ ។បេ។ ក៏មិនមាន ។

[១៤០] បទថា **បុរា ។បេ។ សញ្ញាបេតិ** សេចក្តីថា មិនទាន់យល់បានជរាបណា ។ បទថា **ឥមេ ភោ កស្សប ចន្ទិមសុរិយា** សេចក្តីថា បានញ្ចថា ស្តេចបាយាសិនោះ ត្រូវព្រះថេរៈសួរហើយ គិតថា សមណៈនេះនាំយកព្រះចន្ទ ព្រះអាទិត្យមកឧបមាមុន នឹងជាអ្នកដែលបុគ្គលដទៃគ្របសង្កត់មិនបានដោយបញ្ញា ដូចគ្នានឹងព្រះចន្ទព្រះអាទិត្យ បើអញឆ្លើយថា ព្រះចន្ទព្រះអាទិត្យមាននៅក្នុងលោកនេះ សមណៈនេះ ក៏នឹងធ្វើអញឲ្យទាល់ប្រាជ្ញាដោយបញ្ហាកម្មជាដើមថា ព្រះចន្ទព្រះអាទិត្យទាំងនោះ អាស្រ័យអ្វី ទទឹងប្រវែងប៉ុនណា កម្ពស់ប៉ុនណា អញក៏មិនអាចនឹងចងលោកបាន នឹងឆ្លើយចំពោះលោកថា មាននៅក្នុងលោកដទៃប៉ុណ្ណោះ ព្រោះដូច្នោះ ទើបស្តេចបាយាសិឆ្លើយយ៉ាងនោះ ។ ព្រះមានព្រះភាគត្រាស់សុធាភោជនីយជាតក ក្នុងកាលមិនយូរ មុនបាយាសិរាជញ្ញសូត្រនោះ ។ ក្នុងសុធាភោជនីយជាតកនោះ ព្រះចន្ទ ជាចន្ទទេវបុត្រ ព្រះអាទិត្យ ជាសុរិយទេវបុត្រ ។ ជាតក ឬព្រះសូត្រ

ដែលព្រះមានព្រះភាគត្រាស់ទុក ប្រាកដទូទៅពេញជម្ពូទ្វីប ។ ដោយហេតុនោះ ស្តេចបាយាសិនោះគិតថា អញមិនអាចពោលថា ទេវបុត្រទាំងឡាយដែលនៅប្រចាំក្នុងព្រះចន្ទ ព្រះអាទិត្យនោះមិនមាន ទើបពោលឆ្លើយថា ជាទេវតា មិនមែនមនុស្សទេ ។

[១៤១] បទថា **អត្ថិ បន រាជញ្ញ បរិយាយោ** សេចក្តីថា ព្រះថេរៈសួរថា ហេតុនៅមានឬ ។ បទថា **អាពាធិកា** គឺដែលប្រកបដោយជំងឺ ពោលគឺបុគ្គលដែលមានវិសភាគវេទនា ។ បទថា **ទុក្ខិតា** គឺដល់នូវសេចក្តីទុក្ខ ។ បទថា **ពាឡ្ហគិលានា** គឺជាជំងឺមានប្រមាណក្រៃលែង ។ បទថា **សទ្ធាយិកា** សេចក្តីថា ខ្ញុំជឿពួកអ្នក អ្នកជាបុគ្គលគួរជឿ មានវាចាដែលខ្ញុំជឿតាមបាន ។ បទថា **បច្ចយិកា** សេចក្តីថា ខ្ញុំទុកចិត្តពួកអ្នក ដែលជាបុគ្គលគួរទុកចិត្ត គួរជឿរបស់ខ្ញុំ ។

[១៤២] បទថា **ឧទ្ទិសិត្វា** សេចក្តីថា ធ្វើខ្ជួន និងទ្រព្យដែលរក្សាទុកដល់មនុស្សទាំងនោះឲ្យទទួល ។ បទថា **វិប្ឋលបន្ធស្ស** គឺរៀបរាប់ថា កូនប្រុសរបស់អញ កូនស្រីរបស់អញ ទ្រព្យរបស់អញ ។ បទថា **និរយចាលេសុ** គឺអ្នកជាក់ទោសសត្វក្នុងនរក ។ បុគ្គលពួកណាពោលថា កម្មន៉ុះឯងជាក់ទោស នាយនិរយបាលមិនមាន បុគ្គលទាំងឡាយនោះ ក៏ជំទាស់ទេវទូតសូត្រដែលទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់បុរសនោះ ដូច្នេះជាដើម ។ នាយនិរយបាលមាននៅក្នុងនរក ដូចមនុស្សអ្នកជាក់ទោសប្រចាំរាជត្រកូលក្នុងមនុស្សលោក ដូច្នោះ ។

[๑๔๔] *បទថា* **វេឡុទ្វារសិកាហិ** *ប្រែថា ដោយបន្ទះឫស្សី ។ បទថា* **សុនិម្មដ្ឋិតំ** *សេចក្តីថា លាមកជារបស់កោសចេញដោយល្អ ដោយប្រការណា ក៏កោសចេញទៅដោយប្រការនោះ អធិប្បាយថា ចូរកោសចេញ នាំចេញទៅដោយប្រការនោះ ។ បទថា* **អសុចិ** *គឺមិនគួរពេញចិត្ត ។ បទថា* **អសុចិសំខាតា** *គឺជាចំណែកមិនស្អាត ឬដែលសន្មតថា ជារបស់មិនស្អាត ។ បទថា* **ទុគ្គន្ធា** *គឺក្លិនស្អុយដូចសាកសព ។ បទថា* **ជេគុច្ឆា** *គឺគួរជារបស់គួរខ្ពើម ។ បទថា* **បដិក្កូលា** *គឺនាំសេចក្តីទាស់ចិត្តមក ដោយការឃើញប៉ុណ្ណោះ ។ បទថា* **ឧព្ភាឆតិ** *សេចក្តីថា ក្លិនរបស់ពួកមនុស្ស ទោះបីស្តេចចក្រពត្តិជាដើម ដែលងូតទឹកមួយថ្ងៃ ២ ដង ផ្ងាស់សំពត់មួយថ្ងៃ ៣ ដង តាក់តែងប្រដាប់កាយហើយ ក៏នៅស្អុយ ដូចសាកសពដែលព្យុះនឹងក ទេវតាដែលនៅឆ្ងាយជល់ ๑๐๐ យោជន៍ ។*

[๑๔๕] *បទថា* **តាវតីសានំ** *សេចក្តីថា លោកពោលទៀត ដោយអំណាចបុគ្គលអ្នកសមាទានសីល ๕ មានវៀរបាណាតិបាតជាដើម ប្រព្រឹត្តហើយ ។ និងអធិប្បាយពាក្យ* **តាវត្តឹសានំ** *ថា ទេវតាដែលកើតក្នុងទីឆ្ងាយកុំមក ព្រោះហេតុអ្វី ទើបទេវតាទាំងនោះ មិនមក ។*

[๑๔๖] *បទថា* **ជច្ចន្ធូបមោ មញ្ញេ បដិភាសិ** *គឺប្រាកដដូចជាបុគ្គលភ្នែកខ្វាក់អំពីកំណើត ។ បទថា* **អរញ្ញេវនបត្ថានិ** *អធិប្បាយថា ដែលឈ្មោះថា* **អរញ្ញ** *ព្រោះប្រកបដោយអង្គគុណរបស់អ្នកនៅព្រៃ ដែលឈ្មោះថា* **វន** *ព្រោះជាជួរព្រៃធំ ។ បទថា* **បត្ថានិ** *គឺឆ្ងាយ ។*

[๑๔๗] *បទថា* **កលฺยาณาธมฺโม** *គឺមានធម៌ល្អ ព្រោះសីលនោះឯង ។ បទថា* **ทุกฺขปฺปฏิกฺกูเล** *គឺអ្នកមិនប្រាថ្នាទុក្ខ ។ បទថា* **เสยฺยา ภวิสฺสติ** *អធិប្បាយថា នឹងមានសុគតិ ក្នុងលោកជាទៃ ។*

[๑๔๘] *បទថា* **อุปวิชฺญา** *គឺវេលាប្រសូតជិតចូលមកហើយ គកិចាស់ហើយ អធិប្បាយថា នឹងប្រសូតក្នុងកាលមិនយូរឡើយ ។ បទថា* **อุปโภคฺคา ภวิสฺสติ** *គឺនឹងជាស្រីបម្រើ (ប្រពន្ធ) ។ បទថា* **อนยพฺยสนំ** *បានដល់ ទុក្ខធំ ។ សុខ ឈ្មោះថា* **อย** *មិនមែនអយៈ ឈ្មោះថា* **อนย** *គឺទុក្ខ ទុក្ខនោះរមែងដេញ គឺបណ្តេញសុខចេញទៅដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបឈ្មោះថា* **พฺยสน** *ព្យសនៈ គឺទុក្ខ ឈ្មោះថា* **อนพฺยสน** *អធិប្បាយថា ទុក្ខធំ ដោយប្រការដូច្នេះ ។ បទថា* **อโยนิโส** *គឺដោយមិនមែនឧបាយ ។ បទថា* **อปกฺกำ น ปริจาเจสิ** *អធិប្បាយថា មិនបានចូលទៅកាត់អាយុដែលមិនទាន់ប្រែប្រួល មិនទាន់អស់ ឲ្យដាច់ទៅក្នុងចន្លោះឡើយ ។ បទថា* **ปริจากำ อาคเมสิ** *គឺរង់ចាំវេលាដែលឆ្អិននៃអាយុ ។ សូម្បីព្រះធម្មសេនាបតី ក៏បានពោលថា*

ชาคิเนฺตน มรณำ ชาคิเนฺตน ชีวิตำ

นิกฺขิปิสฺสำ สมำ กายำ สมฺปชาโน ปติสฺสโต ฯ

ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំជាបុគ្គលដឹងខ្លួន មានស្មារតីខ្ជាប់ខ្លួន ទម្លាយចោលនូវរាងកាយនេះ ដូច្នោះ[1] ។

๑- *ក្នុងទីខ្លះលោកលើកយកគាថាព្រះសង្គិច្ចមកពោល ព្រោះគាថានេះ ๒ បាទខាងដើមដូចគ្នា ។*

[๑๔๙] *បទថា* **ឧព្ពិទ្ធិត្វា** *គឺធ្លុះជីស្អិតដែលបូកទុក ។ បទថា* **រាម-ណេយ្យកំ** *គឺគួររីករាយ ។ បទថា* **ចេឌ្ឌារិកា** *គឺក្មេងស្រីដែលច្រើនដោយការលេង ។ បទថា* **កោមារិកា** *គឺក្មេងស្រីតូច ។ បទថា* **តុយ្ហំ ជីវំ** *សេចក្តីថា ស្រីទាំងនោះឯង ឃើញជីវៈដែលចេញទៅ ដែលចូលមក ខណៈដែលទ្រង់យល់សប្តិ ឃើញខ្លះទេ ។ ព្រះថេរៈកាន់យកថា ជីវៈជាអាការត្រាច់ទៅនៃចិត្ត ទើបពោលក្នុងទីនេះ ។ លោកមានសេចក្តីយល់ក្នុងអាការត្រាច់ទៅនៃចិត្តនោះថា ជីវៈ ។*

[๑๕๐] *បទថា* **ជិយាយ** *សេចក្តីថា ចងជីវៈដោយខ្សែធ្នូ ។ បទថា* **បត្តិន្នតរោ** *គឺរីង ។ ស្តេចបាយាសិសម្តែងអ្វី ដោយពាក្យនេះ ។ ព្រះបាទបាយាសិសម្តែងសេចក្តីនេះថា លោកទាំងឡាយពោលថា វេលានៅវស់ សត្វមានខន្ធ ๕ តែវេលាស្លាប់ នៅសល់ត្រឹមតែរូបក្ខន្ធប៉ុណ្ណោះ ខន្ធ ๓ ក៏ប្រព្រឹត្តទៅមិនបាន វិញ្ញាណក្ខន្ធក៏ទៅ រូបក្ខន្ធដែលនៅសល់គួរនឹងស្រាល តែត្រឡប់ជាធ្ងន់ ព្រោះដូច្នោះ អ្វីៗ ដែលទៅទីណាមិនមាន ដូច្នេះ ។*

[๑๕๑] *បទថា* **ឆិន្នំ** *គឺមានតេជោធាតុ ដែលស្ងប់ហើយ ។*

[๑๕๒] *បទថា* **អនុបហច្ច** *គឺមិនឲ្យខូចខាត ។ បទថា* **អទ្ធមតោ-ហោតិ** *គឺឲ្យស្លាប់សន្សឹមៗ ។ បទថា* **ឱធុណាថ** *ប្រែថា ទាញមកខាងអាយ ។ បទថា* **សន្ធុណាថ** *ប្រែថា រុញទៅខាងនាយ ។ បទថា* **ឯន្ធុណាថ** *ប្រែថា ទាញទៅទាញមក ។ បទថា* **តញ្ហាយតនំ ឧប្បដិសំវេទេតិ** *សេចក្តីថា រូបាយតនៈ*

នោះ មិនដឹងច្បាស់ដោយចក្ខុនោះ ។ គ្រប់បទក៏នយនេះ ។

[๑๕๓] *បទថា* **សង្ខុធមោ** *គឺអ្នកផ្ដុំសង្ខ ។ បទថា* **ឧបច្ឆាសិត្វា** *ប្រែថា ផ្ដុំ ។*

[๑๕๕] *បទថា* **អគ្គិកោ** *ប្រែថា អ្នកបម្រើភ្លើង ។ បទថា* **អាថា-ឧយ្យុំ** *គឺគប្បីឲ្យសម្រេច ឬគប្បីដល់អាយុ ។ បទថា* **ភោសេយ្យុំ** *គឺគប្បីចិញ្ចឹមដោយភោជនជាដើម ។ បទថា* **វឌ្ឍេយ្យុំ** *គឺគប្បីដល់សេចក្ដីធំធាត់ ។ បទថា* **អរណិសហិតំ** *គឺគូនៃឈើពួតភ្លើង ។*

[๑๕๖] *បទថា* **តិរោរាជានោ** *សេចក្ដីថា ព្រះរាជាទាំងឡាយក្នុងខាងក្រៅដែន គឺក្នុងជនបទដទៃក៏ដឹង ។ បទថា* **អព្យន្តោ** *គឺដែលមិនមានបញ្ញាដែលមិនឈ្លាស ។ បទថា* **កោបេនបិ** *សេចក្ដីថា បុគ្គលពួកណា ពោលនឹងខ្ញុំយ៉ាងនេះ ខ្ញុំក៏នឹងបបួល នឹងនាំ នឹងនាំបុគ្គលនោះ ដែលមានទិដ្ឋិយ៉ាងនោះ ត្រាច់ទៅដោយសេចក្ដីក្រោធ ដែលកើតក្នុងបុគ្គលទាំងនោះ ។ បទថា* **មក្ខេន** *គឺការលុបគុណ ដែលមានលក្ខណៈលុបគុណ ដូចលោកពោលហើយ ។ បទថា* **បឆ្ចាសេន** *គឺការវាយឫកស្មើ ដែលមានលក្ខណៈប្រកាន់ជាគូប្រណាំងប្រជែង ។*

[๑๕๗] *បទថា* **ហរីតកបណ្ណំ** *គឺសម័យប្រកេទណាមួយ អធិប្បាយថា ដោយហោចទៅ សូម្បីស្លឹកស្មៅខ្ចីក៏មិនមាន ។ បទថា* **អាសន្នទូកលាបំ** *គឺអ្នកមានបន្ទោះធ្ងចងហើយ ដែលចងស៊កហើយ ។ បទថា* **អាសិត្តោឧកានិ**

វដុមានិ គឺផ្ទូវ និងជ្រោះ មានទឹកបរិបូណ៌ ។ បទថា **យោគ្គានិ** គឺយានទឹម ដោយគោ ។ បទថា **ពហុនិកូន្តរោ** សេចក្តីថា ចេញទៅច្រើន ចេញទៅយូរ ហើយ ។ បទថា **យថាភតេន ភណ្ឌេន** សេចក្តីថា ភណ្ឌៈ គឺស្មៅ ឈើ និងទឹកណា ដែលពួកអ្នកផ្ទុកមក ចូរញ្ចុំងក្រុមរទេះឲ្យប្រព្រឹត្តទៅ ដោយ ភណ្ឌៈដែលលោកផ្ទុកមក នាំមក ដឹកមកនោះចុះ ។ បទថា **អប្ឈសារានិ** គឺទ្រព្យមានតម្លៃតិច ។ បទថា **បណិយានិ** ប្រែថា ទ្រព្យទាំងឡាយ ។

[១៥៩] បទថា **មម ច សូការភត្តំ** សេចក្តីថា នេះជាអាហារនៃជ្រូក ទាំងឡាយរបស់អញ ។ បទថា **ឧត្ឈរន្តំ** គឺហៀរឡើង ។ បទថា **បត្ឈរន្តំ** គឺហូរចុះ ។ បទថា **តុម្ហេ ទ្វេត្ត ភណេ** ប្រែថា នែវ៉ឺយ ពួកអ្នករាល់គ្នាទេតើ ជាមនុស្សឆ្ពួត ខូចចរិតក្នុងរឿងនេះ ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **តថា ហិ បន មេ សូការភត្តំ** ប្រែថា តែសូម្បីយ៉ាងនោះ លាមកនេះ ក៏ជាអាហារនៃជ្រូកទាំងឡាយរបស់ខ្ញុំ ។

[១៦១] បទថា **អាគតាគតំ កលឹ** ប្រែថា លេបកូនបាសកា ដែល ចាញ់ ដែលបានមកដល់ខ្ជួន ។ បទថា **បជោហិស្ឈាមិ** សេចក្តីថា ខ្ញុំនឹងធ្វើ ការសែន នឹងធ្វើការបួងសួង ។ បទថា **អកូហិ ធិញិស្ឈាមិ** ប្រែថា នឹងលេង ដោយកូនបាសកាទាំងឡាយ គឺលេងដោយកូនបាសកាទាំងឡាយ ។

[១៦២] បទថា **លិត្តំ បរមេន តេជសា** ប្រែថា ដែលលាបដោយ ថ្នាំពិស មានកម្ចាំងខ្ចាំងក្ចា ។

[๑๖๕] ប្រទេសនៃស្រុកជាទីរស់នៅ លោកហៅថា **គាមបដ្ឋ** បាលីថា **គាមបទ** ក៏មាន ឯសេចក្តីយ៉ាងនេះដូចគ្នា ។ បទថា **សាធការំ** គឺបាច់សម្បកឆៃ្ន ។ បទថា **សុសន្ថទ្ធោ** ប្រែថា ចងទុកល្អហើយ ។ បទថា **ភុំ បជានាហិ** ប្រែថា អ្នកចូរដឹង អធិប្បាយថា អ្នកចូរទទួល បើអ្នកត្រូវការនឹងកាន់យក ក៏កាន់យកបាន ។ បទថា **ខោមំ** ប្រែថា សម្បកឈើ ។ បទថា **អយសំ** ប្រែថា ដែក ។ បទថា **លោហំ** ប្រែថា ទង់ដែង ។ បទថា **សជ្ឈុំ** ប្រែថា ច្រាក់ ។ បទថា **សុវណ្ណំ** ប្រែថា មាសកៈធ្វើអំពីមាស ។ បទថា **អភិនន្នឹសុ** ប្រែថា ត្រេកអរហើយ ។

[๑๖๖] បទថា **អត្តមនោ** ប្រែថា មានចិត្តជារបស់ខ្លួន គឺមានចិត្តត្រេកអរហើយ ។ បទថា **អភិរទ្ធោ** ប្រែថា ជ្រះថ្លាត្រៃលែងហើយ ។ បទថា **បញ្ហាប្បដិភាណានិ** ប្រែថា ការប្រាកដបញ្ហាស់នៃបញ្ហា ។ បទថា **បច្ចនីកំ កាតព្វំ** សេចក្តីថា ធ្វើហាក់ដូចជាសត្រូវ គឺពោលជំទាស់ ។ បទថា **អវមញ្ញិស្សុំ** សេចក្តីថា ប្រកាន់ឆ្វេង ។

បទថា **សង្ឃាតំ អាបជ្ជន្តិ** ប្រែថា សម្ងាប់ វិនាស មរណៈ ។ បទថា **ន មហាបួលោ** សេចក្តីថា មិនមានផលច្រើនដោយវិបាក ។ បទថា **ន មហានិសំសោ** សេចក្តីថា មិនមានអានិសង្សច្រើន ដោយអានិសង្ស គឺគុណ ។ បទថា **ន មហាជុតិកោ** សេចក្តីថា មិនមានសេចក្តីរុងរឿងដោយមហាជោតិកាព ។ បទថា **ន មហាវិប្ផារោ** សេចក្តីថា មិនមានការ

ផ្សាយទូលំទូលាយ ដោយការផ្សាយទៅនៃវិបាក ។ បទថា **ពីជនង្គលំ** ប្រែថា ពូជ និងនង្គ័ល ។ បទថា **ឧុក្ខេត្តេ** ប្រែថា ក្នុងស្រែអាក្រក់ ស្រែគ្មានសារ: ។ បទថា **ឧុព្ភុម្មេ** ប្រែថា ផ្ទៃដីមិនរាបស្មើ ។ បទថា **បតិដ្ឋាបេយ្យ** ប្រែថា គប្បីទ្រទ្រង់ ។ បទថា **ទណ្ឌានិ** គឺបាក់ និងបែក ។ បទថា **ឃូតីនិ** គឺគ្មានសារ: (ស្អុយ) ។ បទថា **វាតាតបហតានិ** គឺត្រូវខ្យល់ និងកម្តៅថ្ងៃបៀតបៀន ។ បទថា **អសារធានិ** គឺខៀវស្រស់ ដរាបវៀរការដាក់គ្រាប់ស្រូវបាន ។ បទថា **អសុទសយិតានិ** គឺពូជឯណា ដែលគេធ្វើឲ្យស្ងួតហើយ រក្សានៅក្នុងជង្រុក ពូជទាំងនោះ ឈ្មោះថា **សុទសយិ** តែពូជទាំងនោះ មិនដូច្នោះទ្បើយ ។ បទថា **ន អនុប្បវេច្ឆេយ្យ** គឺភ្ជៀងមិនបង្អុរចុះមក សេចក្តីថា មិនធ្លាក់ដោយល្អ ត្រឹមត្រូវតាមរដូវកាល អធិប្បាយថា មិនធ្លាក់រាល់កន្លះខែ រាល់ ១០ ថ្ងៃ រាល់ ៥ ថ្ងៃ ។ បទថា **អបិ នុ តានិ** សេចក្តីថា កាលស្រែមានពូជ និងភ្ជៀង ជាទោសយ៉ាងនេះហើយ ពូជទាំងនោះ នឹងគប្បីធំធាត់ខ្ពស់ទ្បើង លូតលាស់ចាក់ឬស និងរីកសាយធំទូលាយដោយល្អ ដោយពន្លក ឬស និងស្លឹក ជាដើមបានឬ ។ បទថា **ឯវ្ហេ ទោ ទាជញ្ញ យញ្ញោ** សេចក្តីថា មហាបពិត្រ ទានបែបនេះ រមែងមិនមានផលច្រើន ព្រោះមិនបរិសុទ្ធដោយបច្ចយ ព្រោះការប្រទូស្តអ្នកដទៃធ្វើឲ្យកើតទ្បើងខ្លះ ដោយទាយកខ្លះ ដោយបដិគ្គាហកខ្លះ ។ បទថា **ឯវ្ហេ ទោ ទាជញ្ញ អញ្ញោ** សេចក្តីថា បពិត្ររាជញ្ញ: ទានបែបនេះ រមែងមានផលច្រើន ដោយបច្ចយដែលកើតទ្បើង ព្រោះការមិន

ប្រទូស្តអ្នកជនៃខ្ញុះ ដោយទាយកអ្នកមានសីល ព្រោះមិនប្រទូស្តអ្នកជនៃខ្ញុះ ដោយបដិគ្គាហក អ្នកជល់ព្រមដោយគុណ មានសម្មាទិដ្ឋិជាដើមខ្ញុះ ។ បើទានបានបដិគ្គាហកអ្នកចេញចាកនិរោធ ក្រៃលែងដោយគុណ (គុណាតិរេក-សម្បទា) និងចេតនារបស់ទាយកធំទូលាយសោត ក៏នឹងឲ្យវិបាកទាន់ភ្នែកនោះឯង ។ ព្រះបាទបាយាសិស្តាប់ធម្មកថារបស់ព្រះថេរៈ ទ្រង់និមន្តព្រះថេរៈប្រគេនមហាទាន ៧ ថ្ងៃ តមកល់ទានជាប្រចាំជល់មនុស្សទាំងពួង ចាប់តាំងពីពេលនោះមក ។ លោកសំដៅជល់ទាននោះ ទើបពោលថា គ្រានោះឯង ស្តេចបាយាសិរាជញ្ញៈជាដើម ។

[๑๖๗] *បណ្តាបទទាំងនោះ បទថា* **ការណារាជិកំ** *គឺបាយដែលចម្អិនអំពីអង្ករបាក់ មានកន្ទក់ ។ បទថា* **ពិលង្គទុតិយំ** *ប្រែថា មានទឹកជ្រក់ជាគម្រប់ពីរ ។ បទថា* **ចោរកានិ ច វត្តានិ** *ប្រែថា សំពត់ដែលមានសរសៃគ្រោតគ្រាត ។ បទថា* **គុឡ្យាលកានិ** *គឺសំពត់ដែលប្រឡាក់ដោយទឹកអំពៅ អធិប្បាយថា សំពត់ផ្ទាំងធំដែលជាក់ជាគំនរៗ ។ បទថា* **ឃាមឆុទ្ធិសតិ** *គឺប្រាប់យ៉ាងនេះ ។ បទថា* **ចាធាបិ** *ប្រែថា សូម្បីដោយជើង ។ បទថា* **អសក្កច្ចំ** *គឺវៀរសទ្ធា ឲ្យទានដោយមិនមានសទ្ធា ។ បទថា* **អសហត្ថា** *ប្រែ ថា មិនមែនដោយដៃរបស់ខ្លួនឯង ។ បទថា* **អចិត្តិកតំ** *គឺវៀរការធ្វើដោយសេចក្តីកោតក្រែងឲ្យទាន មិនបានចូលទៅតាំងការធ្វើសេចក្តីគោរព មិនបានឲ្យទានធ្វើឲ្យប្រណីត ។ បទថា* **អបវិដ្ឋំ** *គឺបោះឲ្យធ្លាក់រាត់រាយ ។ បទថា*

សុញ្ញំ សេរីសកំ សេចក្តីថា ចូលទៅកាន់វិមានប្រាក់ដែលស្វាត់មួយ ឈ្មោះ សេរីសក: ។ បានញ្ចថា មានដើមច្រេសធំ នៅជិតទ្វារវិមាននោះ ព្រោះ ហេតុនោះ ទើបវិមាននោះ ហៅថា **សេរីសក** ។

រឿងព្រះគវម្បតិ

បានញ្ចមកថា ព្រះថេរ: ជាប្រធានក្មេងចិញ្ចឹមគោ ក្នុងមនុស្សលោកក្នុងជាតិមុន បោសច្រាសសម្អាតគល់ច្រេសធំ ចាក់រោយដីខ្សាច់ និមន្តព្រះថេរ: អ្នកសមាទានបិណ្ឌបាតិកធុតង្គមួយរូប ឲ្យអង្ក្ឌុយត្រង់គល់ឈើ ប្រគេនអាហារដែលខ្ជូនបានមក ចុតិចាកមនុស្សលោកនោះ ទៅកើតក្នុងវិមានប្រាក់នោះ ដោយអានុភាពនៃបុណ្យនោះ ។ ដើមច្រេសតាំងនៅជិតទ្វារវិមាន ។ ៥០ ឆ្នាំ ទើបដើមច្រេសនោះមានផ្លែ ។ តពីនោះ ទេវបុត្រក៏ដល់សេចក្តីសង្វេគថា ឲកន្ធងទៅ ៥០ ឆ្នាំហើយ ។ សម័យតមក ទេវបុត្រនោះទៅកើតក្នុងពួកមនុស្សក្នុងសម័យរបស់ព្រះមានព្រះភាគនៃយើង ស្តាប់ធម្មកថារបស់ព្រះសាស្តា ក៏សម្រេចព្រះអរហត្ត ។ តែដោយអំណាចការធ្វាប់នៅ ព្រះថេរ: ក៏ទៅកាន់វិមាននោះឯងរឿយៗ ដើម្បីសម្រាកពេលថ្ងៃ ។ បានញ្ចថា វិមាននោះ មានសេចក្តីសុខតាមរដូវកាលរបស់ព្រះថេរ:នោះ លោកសំដៅយកហេតុយ៉ាងនោះ ទើបពោលថា គ្រានោះឯង ព្រះគវម្បតិ ដ៏មានអាយុ ដូច្នេះជាដើម ។

បទថា **សោ សក្ពចុំ ធានំ ធត្វា** សេចក្តីថា ខត្តរមាណពនោះ ឲ្យទានសូម្បីជារបស់អ្នកដទៃ ក៏ដោយគោរព ។ បទថា **ឯវមារោចេហិ** សេចក្តីថា

សូមលោកម្ចាស់ប្រាប់មនុស្ស ដោយន័យជាដើមថា អ្នកទាំងឡាយចូរឲ្យទាន ដោយគោរព ដូច្នេះ ។ កាលមហាជនស្តាប់ការរៀបរាប់របស់ព្រះថេរៈនោះ ហើយ ក៏ឲ្យទានដោយគោរព ទៅកើតក្នុងទេវលោក ។ ចំណែកស្រីបម្រើ (បរិចារិកា) របស់ស្តេចចាយាសិ ឲ្យទានដោយគោរព ក៏ទៅកើតក្នុងសម្នាក់ របស់ស្តេចចាយាសិន៉ុះឯង ដោយអំណាចសេចក្តីប្រាថ្នា ចានញ្ចថា សេរីស-កវិមាននោះ ជាវិមានសម្រាប់ទេវតា ដែលចារិកមកពីគ្រប់ទិស មាននៅក្នុង ព្រៃឈ្មោះវដ្តនី ។ ក្នុងថ្ងៃមួយ ចាយាសិទេវបុត្រ បង្ហាញខ្ជួនដល់ពួកឈ្ជួញ ទាំងឡាយ ហើយពោលកម្មដែលខ្ជួនធ្វើនោះឯង ។ អដ្ឋកថាចាយាសិ-រាជញ្ញសូត្រ ក្នុងទីឃនិកាយឈ្មោះសុមង្គលវិលាសិនី ចប់ ។

ចាយាសិរាជញ្ញសូត្រ ចប់

សូត្រធី ១០ ចប់

សុត្តន្តបិដក ទីឃនិកាយ

បញ្ចមភាគ ចាដិកវគ្គ

សូមនមស្ការ

ចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

ចាដិកសូត្រទី ១

[๑] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យ ๑ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអនុប្បិយនិគមរបស់ពួកមល្លជន ក្នុងមល្លជនបទ ។ គ្រានោះឯង វេលាព្រឹកព្រហាម ព្រះមានព្រះភាគទ្រង់ស្បង់ជាត្រ និងចីវរ ទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាតក្នុងអនុប្បិយនិគម ។ ពេលនោះឯង ព្រះមានព្រះភាគមានព្រះតម្រិះយ៉ាងនេះថា ការចូលទៅបិណ្ឌបាតក្នុងអនុប្បិយនិគម ក៏នៅព្រឹកពេកណាស់ បើដូច្នោះ គួរតែតថាគតចូលទៅរកបរិព្វាជក ជាភគ្គវ-គោត្រ ក្នុងអារាមនៃបរិព្វាជក ជាភគ្គវគោត្រសិន ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលទៅរកបរិព្វាជកជាភគ្គវគោត្រ ក្នុងអារាមនៃបរិព្វាជក ជាភគ្គវគោត្រ ។ ពេលនោះឯង ភគ្គវគោត្របរិព្វាជក បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្តេចមក បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគស្តេចមកល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគធ្វើនូវបរិយាយនេះ ដើម្បី*

និមន្តមកក្នុងទីនេះ អស់កាលយូរហើយ[๑] បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានបុណ្យស្តេចគង់ នេះឯងជាអាសនៈដែលខ្ញុំព្រះអង្គក្រាលបម្រុងទុក ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈ ដែលបរិព្វាជកបានក្រាលទុក ។ ចំណែកខាងភគ្គវគោត្តបរិព្វាជក បានកាន់យកអាសនៈដ៏ទាបមួយ អង្គុយក្នុងទីសមគួរ ។ លុះភគ្គវគោត្តបរិព្វាជក អង្គុយក្នុងទីសមគួរ ហើយបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីថ្ងៃមុន យូរថ្ងៃណាស់មកហើយ លិច្ឆវិបុត្រឈ្មោះសុនក្ខត្តៈ បានចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏និយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រអ្នកជាភគ្គវ-គោត្រ ឥឡូវនេះ ខ្ញុំបោះបង់ព្រះមានព្រះភាគហើយ បពិត្រអ្នកជាភគ្គវគោត្រ ឥឡូវនេះ ខ្ញុំមិនបាននៅពីនឹងផ្នែកនឹងព្រះមានព្រះភាគទេ បពិត្រព្រះអង្គដ៏ចម្រើន សុនក្ខត្តលិច្ឆវិបុត្រ បានក្រាបទូលព្រះអង្គយ៉ាងនុ៎ះមែនឬទេ ។ ព្រះមានព្រះភាគត្រាស់តបថា ម្នាលភគ្គវគោត្រ សុនក្ខត្តលិច្ឆវិបុត្រ បាននិយាយពាក្យនុ៎ះយ៉ាងនោះមែន ម្នាលភគ្គវគោត្រ កាលពីថ្ងៃមុនយូរថ្ងៃណាស់មកហើយ សុនក្ខត្តលិច្ឆវិបុត្រ បានចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីដ៏សមគួរ ។ ម្នាលភគ្គវគោត្រ លុះសុនក្ខត្តលិច្ឆវិបុត្រអង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គសូមលាព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គនឹងលែងនៅពីនឹងផ្នែកនឹង

๑- បានសេចក្តីថា ព្រះអង្គទានមន្តមកក្នុងទីនេះ យូរណាស់ហើយ ។

នឹងព្រះមានព្រះភាគហើយ ។ ម្នាលភគ្គវគោត្រ កាលសុនក្ខត្តលិច្ឆវិបុត្រ និយាយយ៉ាងនេះហើយ តថាគតក៏បាននិយាយទៅនឹងសុនក្ខត្តលិច្ឆវិបុត្រយ៉ាងនេះវិញថា ម្នាលសុនក្ខត្តៈ ចុះតថាគតមានបាននិយាយនឹងអ្នកយ៉ាងនេះថា នែសុនក្ខត្តៈ អ្នកចូរមកនៅពីងផ្អែកនឹងតថាគតចុះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គនឹងបានមានព្រះបន្ទូលយ៉ាងនុ៎ះនឹងខ្ញុំព្រះអង្គក៏ទេដែរ ។ តថាគតបានសួរតទៅទៀតថា ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពីងផ្អែកនឹងព្រះមានព្រះភាគ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបានក្រាបទូលយ៉ាងនុ៎ះចំពោះព្រះអង្គក៏ទេ ។ តថាគតបាននិយាយទៀតថា នែសុនក្ខត្តៈ តថាគតក៏ឥតបាននិយាយនឹងអ្នកថា ម្នាលសុនក្ខត្តៈ អ្នកចូរមកនៅពីងផ្អែកនឹងតថាគតចុះ ដូច្នេះទេ ចំណែកអ្នកក៏មិនបាននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពីងផ្អែកនឹងព្រះមានព្រះភាគ ដូច្នេះដែរ ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះមានហើយ អ្នកឯងជាអ្នកជាទុក្ខពោលលាអ្នកណា ម្នាលមោឃបុរស ចូរអ្នកមើលចុះ អំពើនេះ ជាកំហុសរបស់អ្នកហើយ ។

[๒] សុនក្ខត្តលិច្ឆវិបុត្រ បាននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគ មិនដែលបានធ្វើឥទ្ធិប្បាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ឲ្យដល់ខ្ញុំព្រះអង្គសោះ ។ តថាគតក៏បាននិយាយថា ម្នាលសុនក្ខត្តៈ ចុះតថាគតបាននិយាយនឹងអ្នកយ៉ាងនេះថា ម្នាលសុនក្ខត្តៈ ចូរអ្នកមកនៅពីងផ្អែកនឹងតថាគតចុះ តថាគតនឹងធ្វើឥទ្ធិបាដិ-

ហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស ឲ្យដល់អ្នកដូច្នេះដែរ ឬ ។ សុនក្ខត្តលិច្ឆវិបុត្រ ក៏ឆ្លើយតបមកថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គនឹងបានមានព្រះបន្ទូលយ៉ាងនុ៎ះ នឹងខ្ញុំព្រះអង្គក៏ទេ ។ តថាគតក៏សួរទៅទៀតថា ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពីងផ្អែកនឹងព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សឲ្យដល់ខ្ញុំដូច្នេះដែរឬ ។ សុនក្ខត្តលិច្ឆវិបុត្រក៏ឆ្លើយតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបាននិយាយយ៉ាងនោះនឹងព្រះអង្គក៏ទេ ។ តថាគតក៏និយាយទៅទៀតថា ម្នាលសុនក្ខត្តៈ តថាគតក៏ឥតបាននិយាយនឹងអ្នកថា ម្នាលសុនក្ខត្តៈ អ្នកចូរមកនៅពីងផ្អែកនឹងតថាគតចុះ តថាគតនឹងធ្វើឥទ្ធិប្បាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សឲ្យដល់អ្នក ដូច្នេះទេ ចំណែកខាងអ្នកក៏មិននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពីងផ្អែកនឹងព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងធ្វើឥទ្ធិប្បាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សឲ្យដល់ខ្ញុំព្រះអង្គ ដូច្នេះដែរ ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះមានហើយ អ្នកឯងជាអ្នកជាទុក្ខ ពោលលាអ្នកណា ។ ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើតថាគតធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី កាលបើតថាគត មិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី ធម៌ដែលតថាគតបានសម្តែងហើយ ដើម្បីជាប្រយោជន៍ ឲ្យអស់ទៅនៃទុក្ខ

ណា ធម៌នោះតែងដឹកនាំបុគ្គលអ្នកធ្វើតាម ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃ ។ សុនក្ខត្តលិច្ឆវិបុត្រឆ្លើយតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើព្រះអង្គធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី កាលបើព្រះអង្គមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ដើម្បីប្រយោជន៍ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះតែងដឹកនាំបុគ្គលអ្នកធ្វើតាម ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃ ។ តថាគតនិយាយថា ម្នាលសុនក្ខត្តៈ កាលបើតថាគតធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី កាលបើតថាគតមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី ធម៌ដែលតថាគតបានសម្តែងហើយ ដើម្បីឲ្យអស់ទៅនៃទុក្ខណា ធម៌នោះតែងដឹកនាំបុគ្គលអ្នកធ្វើតាម ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃ ។ ម្នាលសុនក្ខត្តៈ កាលបើធម៌ដែលតថាគតបានសម្តែងហើយនោះ ប្រព្រឹត្តទៅដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃយ៉ាងនេះហើយ នឹងចាំបាច់ធ្វើឥទ្ធិបាដិហារិយ៍ដែលជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សធ្វើអ្វី ម្នាលមោឃបុរស អ្នកចូរមើលចុះអំពើនេះជាកំហុសរបស់អ្នក ។

[๓] សុនក្ខត្តលិច្ឆវិបុត្រ និយាយទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគ មិនបានបញ្ញត្តនូវច្បាប់ទម្លាប់ដល់ខ្ញុំព្រះអង្គសោះ ។ តថាគតក៏និយាយទៅវិញថា ម្នាលសុនក្ខត្តៈ ចុះតថាគតបានពោលនឹងអ្នកយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកចូរមកនៅពឹងផ្អែកនឹងតថាគតចុះ តថាគត

នឹងបញ្ញត្តនូវច្បាប់ទម្លាប់ដល់អ្នក ដូច្នេះដែរឬ ។ សុនក្ខត្តលិច្ឆវិបុត្រឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គនឹងបានមានព្រះបន្ទូលយ៉ាងនោះនឹងខ្ញុំព្រះអង្គក៏ទេ ។ តថាគតនិយាយទៀតថា ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែកនឹងព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងបញ្ញត្តនូវច្បាប់ទម្លាប់ដល់ខ្ញុំព្រះអង្គដូច្នេះដែរឬទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបានពោលយ៉ាងនោះ នឹងព្រះអង្គក៏ទេ ។ តថាគតនិយាយថា នែសុនក្ខត្ត: តថាគតឥតបាននិយាយនឹងអ្នកថា ម្នាលសុនក្ខត្ត: អ្នកចូរមកនៅពឹងផ្អែកនឹងតថាគតចុះ តថាគតនឹងបញ្ញត្តនូវច្បាប់ទម្លាប់ដល់អ្នក ដូច្នេះទេ ចំណែកខាងអ្នកក៏មិននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែកនឹងព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងបញ្ញត្តនូវច្បាប់ទម្លាប់ដល់ខ្ញុំព្រះអង្គដូច្នេះដែរ ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះមានហើយ អ្នកឯងជាអ្នក ជាទុក្ខ ពោលលាអ្នកណា ។ ម្នាលសុនក្ខត្ត: អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើតថាគតបញ្ញត្តនូវច្បាប់ទម្លាប់ក្តី មិនបានបញ្ញត្តនូវច្បាប់ទម្លាប់ក្តី ធម៌ដែលតថាគតបានសម្តែងហើយ ដើម្បីប្រយោជន៍ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះតែងដឹកនាំបុគ្គលអ្នកប្រព្រឹត្តតាម ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃបានឬទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើព្រះអង្គបញ្ញត្តនូវច្បាប់ទម្លាប់ក្តី មិនបានបញ្ញត្តនូវច្បាប់ទម្លាប់ក្តី ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ដើម្បីប្រយោជន៍ឲ្យអស់នៃទុក្ខណា ធម៌នោះ

តែងដឹកនាំបុគ្គលអ្នកប្រព្រឹត្តតាមធម៌ឲ្យអស់ទៅនៃទុក្ខនោះ ដោយប្រពៃបានមែន ។ តថាគតនិយាយថា ម្នាលសុនក្ខត្តៈ កាលបើតថាគតបញ្ញត្តនូវច្បាប់ទម្លាប់ក្តី មិនបានបញ្ញត្តនូវច្បាប់ទម្លាប់ក្តី ធម៌ដែលតថាគតបានសម្តែងហើយដើម្បីប្រយោជន៍ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះ គង់នឹងដឹកនាំបុគ្គលអ្នកប្រព្រឹត្តតាមធម៌ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃទេតើ ។ ម្នាលសុនក្ខត្តៈ កាលបើធម៌ដែលតថាគតសម្តែងហើយនោះ ប្រព្រឹត្តទៅដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃយ៉ាងនេះហើយ នឹងចាំបាច់បញ្ញត្តច្បាប់ទម្លាប់ធ្វើអ្វី ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះ ជាកំហុសរបស់អ្នកឯង ។ ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណ នៃតថាគតក្នុងវជ្ជិគ្រាមដោយអនេកបរិយាយថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្តីចេះដឹង នឹងក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ស្តេចទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កពថ្មីទៀតដូច្នេះៗ ម្នាលសុនក្ខត្តៈ អ្នកឯងបានពោលសរសើរគុណរបស់តថាគតក្នុងវជ្ជិគ្រាម ដោយអនេកបរិយាយ ដូច្នេះឯង ។ ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណនៃព្រះធម៌ក្នុងវជ្ជិគ្រាម ដោយអនេកបរិយាយថា

ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ព្រះនវលោកុត្តរធម៌ជាធម៌ដែលព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីជឿចច្បាស់ដោយខ្លួនឯង ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណនៃព្រះធម៌ក្នុងវជ្ជិគ្រាម ដោយអនេកបរិយាយដូច្នេះឯង ។ ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណនៃព្រះសង្ឃ ក្នុងវជ្ជិគ្រាមដោយអនេកបរិយាយថា ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដោយត្រង់ ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដោយសមគួរ ពួកសាវ័កទាំងនេះ បើរាប់ជាគូបាន ៤ គូ បើរាប់រៀងគ្នាជាបុរសបុគ្គលបាន ៨ ពួកសាវ័ករបស់ព្រះមានព្រះភាគនេះ លោកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកអំពីចម្ងាយហើយបូជា លោកគួរទទួលនូវអាគន្តុកទាន លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា លោកគួរដល់អញ្ជលីកម្ម លោកជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណព្រះសង្ឃ ក្នុងវជ្ជិគ្រាមដោយអនេកបរិយាយ ដូច្នេះឯង ។ ម្នាលសុនក្ខត្តៈ តថាគតនឹងប្រាប់ដល់អ្នកឯង ម្នាលសុនក្ខត្តៈ តថាគតនឹងពន្យល់ឲ្យអ្នកដឹង ម្នាលសុនក្ខត្តៈ មុខជានឹងមានអ្នកផងស្តីឲ្យអ្នកថា

សុនក្ខត្តលិច្ឆវិបុត្រ មិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្ពាក់នៃព្រះសមណគោតមបានឡើយ លុះដល់គាត់មិនអាច (នឹងប្រព្រឹត្តព្រហ្មចរិយធម៌) ក៏ពោលលាសិក្ខា ហើយនឹងត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ម្នាលសុនក្ខត្តៈ ខ្លួនអ្នកមុខជានឹងមានអ្នកផងស្តីឲ្យយ៉ាងដូច្នេះមិនខាន ។ ម្នាលភគ្គវៈ សុនក្ខត្តលិច្ឆវិបុត្រ លុះដល់តថាគតស្តីថាឲ្យយ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

[๔] ម្នាលភគ្គវៈ សម័យមួយ តថាគតទៅក្នុងឧត្តរកានិគមរបស់ពួកជនចូលុ ក្នុងចូលុជនបទឯណោះ ។ ម្នាលភគ្គវៈ ក្នុងបុព្វណ្ហសម័យ តថាគតស្បែកស្បង់ ប្រដាប់បាត្រ និងចីវរ មានសុនក្ខត្តលិច្ឆបុត្រ ជាបច្ឆាសមណៈ ដើរចូលទៅបិណ្ឌបាតក្នុងឧត្តរកានិគម ។ ក៏សម័យនោះឯង មានអចេលក៍ម្នាក់ ជាកោរក្ខត្តិយៈ សមាទានកុក្កុរវត្ត គឺប្រព្រឹត្តដូចសុនខ ដើរវារជើង ๔ យកមាត់ត្រចាក់ស៊ី យកមាត់ស៊ីនូវភក្សាហារដែលគេចាក់ចោលលើផែនដី ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ បានឃើញអចេលកោរក្ខត្តិយៈ សមាទានកុក្កុរវត្ត ដើរវារជើង ๔ កំពុងយកមាត់ត្រចាក់ស៊ី យកមាត់ស៊ីនូវភក្សាហារដែលគេចាក់ចោលលើផែនដី ។ លុះសុនក្ខត្តលិច្ឆវិបុត្រនោះបានឃើញហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អើហ្ន៎ សមណៈជាព្រះអរហន្តល្អពេកណាស់ ដើរវារជើង ๔ យកមាត់ត្រចាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ ម្នាលភគ្គវៈ លំដាប់

នោះឯង តថាគតបានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត នៃសុនក្ខត្តលិច្ឆវិបុត្រ ដោយចិត្ត (របស់តថាគត) ហើយបាននិយាយនឹងសុនក្ខត្តលិច្ឆវិបុត្រ យ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើប្តេជ្ញាខ្លួនថាជាសក្យបុត្តិយ៍សោះឡើយ ។ សុនក្ខត្តលិច្ឆវិបុត្រនិយាយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុដូចម្តេចបានជាព្រះមានព្រះភាគ ទ្រង់បន្ទោសខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើនឹងប្តេជ្ញាខ្លួន ថាជាសក្យបុត្តិយ៍សោះឡើយ ។ តថាគតក៏និយាយត្រឡប់ទៅវិញថា ម្នាលសុនក្ខត្ត: ចុះអ្នកបានឃើញអចេលកោរក្ខត្តិយ:នេះសមាទានកុក្កុរវត្ត ដើរវារជើង ៤ យកមាត់ត្រចាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ លុះអ្នកឃើញហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អើហ្ន៎ សមណ:ជាព្រះអរហន្តល្អពេកណាស់ ដើរវារជើង ៤ យកមាត់ត្រចាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ដូច្នេះមែនឬទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ហេតុអ្វីក៏ព្រះមានព្រះភាគកំណាញ់ព្រះអរហត្តម្ល៉ះ ។ តថាគតនិយាយតបថា ម្នាលមោយ-បុរស តថាគតមិនមែនកំណាញ់ព្រះអរហត្តទេ តែថាទិដ្ឋិអាក្រក់យ៉ាងនេះកើតឡើងដល់អ្នកហើយ ចូរអ្នកលះបង់ទិដ្ឋិអាក្រក់នោះចេញ ទិដ្ឋិអាក្រក់ដែលប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ជាទុក្ខអស់កាលជ័យូរ កុំបីមានដល់អ្នកឡើយ ម្នាលសុនក្ខត្ត: អ្នកសម្គាល់នូវអចេលកោរក្ខត្តិយ:ណា ថាជាព្រះអរហន្ត ជាសមណ:ល្អដូច្នេះ ឯអចេលក៏នោះ នឹងធ្វើមរណកាលដោយ

អលសកព្យាធិក្នុងថ្ងៃទី ៧ ពុំខាន លុះដល់គាត់ធ្វើមរណកាលទៅហើយ នឹងទៅកើតក្នុងពួកអសុរឈ្មោះកាលកញ្ចិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ចំណែកខាងជនទាំងឡាយ នឹងនាំយកអចេលក៏ដែលធ្វើមរណកាលហើយនោះ ទៅចោលក្នុងព្រៃស្មសាន ដែលមានដើមស្បូវរណ្តាស ។ ម្នាលសុនក្ខត្តៈ បើអ្នកចង់ដឹង គប្បីចូលទៅរកអចេលកោរក្ខត្តិយៈ ហើយសួរថា នែអាវុសោកោរក្ខត្តិយៈ អ្នកដឹងគតិរបស់ខ្លួនដែរឬទេ ម្នាលសុនក្ខត្តៈ ហេតុនេះមានជាប្រាកដ គឺអចេលកោរក្ខត្តិយៈមុខជានឹងប្រាប់អ្នកថា នែអាវុសោសុនក្ខត្តៈ ខ្ញុំដឹងគតិរបស់ខ្ញុំថា ខ្ញុំឯងលុះធ្វើមរណកាលទៅ នឹងទៅកើតក្នុងពួកអសុរឈ្មោះកាលកញ្ចិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ។ ម្នាលកគ្គវៈ សម័យនោះឯង សុនក្ខត្តលិច្ឆវិបុត្រ បានចូលទៅរកអចេលកោ-រក្ខត្តិយៈ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងអចេលកោរក្ខត្តិយៈយ៉ាងនេះថា ម្នាលអាវុសោកោរក្ខត្តិយៈ ព្រះសមណគោតម ទ្រង់បានព្យាករឲ្យអ្នកថា អចេលកោរក្ខត្តិយៈនឹងធ្វើមរណកាល ដោយអលសកព្យាធិក្នុងថ្ងៃទី ៧ លុះដល់ធ្វើមរណកាលទៅហើយ នឹងទៅកើតក្នុងពួកអសុរឈ្មោះកាល-កញ្ចិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ជនទាំងឡាយនឹងនាំយកអចេលក៏ដែលធ្វើមរណកាលហើយនោះ ទៅចោលឯព្រៃស្មសាន ដែលមានដើមស្បូវរណ្តាស ម្នាលអាវុសោកោរក្ខត្តិយៈ ព្រោះហេតុនោះ គួរអ្នកបរិភោគកត្តាហារឲ្យល្មមៗ គួរផឹកទឹកឲ្យល្មមៗ ពាក្យរបស់ព្រះសមណ-គោតម ត្រឡប់ទៅជាពាក្យខុសវិញយ៉ាងណា (អ្នកគប្បីធ្វើយ៉ាងនោះ) ។

ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រ មិនជឿពាក្យតថាគត ហើយ ក៏រាប់តាំងអំពី ๑ ថ្ងៃ ๒ ថ្ងៃ រហូតដល់ ๗ យប់ ๗ ថ្ងៃ ។ ម្នាលភគ្គវៈ លំដាប់នោះឯង អចេលកោរក្ខត្តិយៈ ក៏បានធ្វើមរណកាល ដោយអលសក-ព្យាធិ ក្នុងថ្ងៃទី ๗ (នោះមែន) លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងពួកអសុរឈ្មោះកាលកញ្ចិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ពួកមហាជនក៏នាំគ្នាយកអចេលក៍ ដែលធ្វើមរណកាលហើយនោះ ទៅចោលក្នុងព្រៃស្មសាន ដែលមានជើមស្បូវណ្ណាស ។ ម្នាលភគ្គវៈ សុនក្ខត្តលិច្ឆវិបុត្រ បានឮដំណឹងថា អចេលកោរក្ខត្តិយៈបានធ្វើមរណកាលដោយអលសកព្យាធិ ពួកមនុស្សបាននាំយកទៅចោលឯព្រៃស្មសាន ដែលមានជើមស្បូវណ្ណាស ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវិបុត្រ ក៏ដើរចូលទៅរកអចេល-កោរក្ខត្តិយៈ ក្នុងព្រៃស្មសានដែលមានជើមស្បូវណ្ណាស លុះចូលទៅដល់ហើយ ក៏យកដៃទះសាកសពអចេលកោរក្ខត្តិយៈ ๓ ដង សួរថា ម្នាលអាវុសោកោរក្ខត្តិយៈ អ្នកជឿគតិរបស់ខ្ញុំនឬទេ ។ ម្នាលភគ្គវៈ សម័យនោះឯង សាកសពអចេលកោរក្ខត្តិយៈ យកដៃបោសខ្នងក្រោកឡើង ប្រាប់ថា ម្នាលអាវុសោសុនក្ខត្តៈ ខ្ញុំជឿគតិរបស់ខ្ញុំថា ខ្ញុំបានមកកើតក្នុងពួកអសុរឈ្មោះកាលកញ្ចិកៈហើយ ជាអសុរកាយថោកទាបជាងគេទាំងអស់ ដូច្នេះរួចហើយ ក៏ដួលដេកផ្ងារស្រេទាង ក្នុងទីនោះទៅវិញ ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រ ក៏ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្ត-

លិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ តថាគតក៏សួរយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថា ដូចម្តេច តថាគតបានប្រារព្ធព្យាករនូវអចេលកោរក្ខត្តិយៈប្រាប់អ្នក យ៉ាងណាមិញ វិបាកនោះក៏ពិតដូច្នោះមែន មិនបានទៅជាខុសវិញទេឬ ។ សុនក្ខត្តលិច្ឆវិបុត្រ ក៏ទូលតបមកវិញថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ប្រារព្ធព្យាករ នូវអចេលកោរក្ខត្តិយៈប្រាប់ខ្ញុំព្រះអង្គយ៉ាងណា វិបាកនោះ ក៏ពិតដូច្នោះមែន មិនមែនផ្សេងទេ ។ តថាគតសួរថា ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បើហេតុយ៉ាងនេះមានហើយ តើតថាគតឈ្មោះថា បានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ប្រសើរក្រៃលែងជាងធម៌របស់មនុស្សហើយ ឬមិនមែនបានធ្វើទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ឈ្មោះថា ព្រះអង្គបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សពិតមែនហើយ មិនមែនថាព្រះអង្គមិនធ្វើទេ ។ តថាគតនិយាយតបថា ម្នាលមោឃបុរស កាលបើដូច្នោះមែន (ចុះដូចម្តេច) ក៏អ្នកនិយាយនឹងតថាគត ដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគពិតជាមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សដល់ខ្ញុំព្រះអង្គទេ ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះ ជាកំហុសរបស់អ្នក ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ កាលតថាគតស្តីឲ្យយ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចជាសត្វដែលទៅកើតក្នុង

អបាយ ឬទៅកើតក្នុងនរក ។

[๕] *ម្នាលភគ្គវៈ សម័យមួយ តថាគតបរិនិព្វានក្នុងកូដាគារសាលា ក្នុងមហាវន ជិតក្រុងវេសាលី ។ សម័យនោះឯង មានអចេលកម្នាក់ឈ្មោះ កទ្ទារមជ្ឈកៈ នៅអាស្រ័យក្នុងក្រុងវេសាលី ជាអ្នកបានលាភ និងយសដ៏ ប្រសើរ ក្នុងវជ្ជីគ្រាម ។ ចំណែកវត្តទាំង ៧ អចេលកនោះក៏បានសមាទាន សព្វគ្រប់ថា អាត្មាអញគួរជាអ្នកអាក្រាត មិនត្រូវស្បៀកដណ្តប់សំពត់ដរាប ដល់អស់ជីវិត ១ អាត្មាអញគួរប្រព្រឹត្តធម៌ដ៏ប្រសើរ មិនត្រូវសេពមេថុនធម្ម ដរាបដល់អស់ជីវិត ១ អាត្មាអញគួរចិញ្ចឹមជីវិតដោយសុរា និងសាច់តែ ម្យ៉ាង មិនត្រូវបរិភោគបាយ និងនំដរាបដល់អស់ជីវិត ១ អាត្មាអញមិនត្រូវ បោះបង់ចោលនូវឧទេនចេតិយ ខាងកើតក្រុងវេសាលី ១ អាត្មាអញមិនត្រូវ បោះបង់ចោលនូវគោតមកចេតិយ ខាងត្បូងក្រុងវេសាលី ១ អាត្មាអញមិន ត្រូវបោះបង់ចោលនូវសត្តម្ពចេតិយ ខាងលិចក្រុងវេសាលី ១ អាត្មាអញមិន ត្រូវបោះបង់ចោលនូវពហុបុត្តកចេតិយ ខាងជើងក្រុងវេសាលី ១ ព្រោះហេតុ ដែលប្រព្រឹត្តសមាទាននូវចំណែកវត្តទាំង ៧ នេះហើយ ទើបអចេលកនោះ បាននូវលាភ និងយសដ៏ប្រសើរ ក្នុងវជ្ជីគ្រាម ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រ បានចូលទៅរកអចេលកទ្ទារមជ្ឈកៈ លុះចូលទៅដល់ ហើយ ក៏សួរប្រស្នានឹងអចេលកទ្ទារមជ្ឈកៈ ។ លុះសុនក្ខត្តលិច្ឆវិបុត្រនោះ សួរប្រស្នាយ៉ាងនោះហើយ អចេលកទ្ទារមជ្ឈកៈ ក៏ឆ្លើយដោះស្រាយប្រស្នា នោះមិនរួច កាលបើឆ្លើយមិនរួចហើយ ក៏ធ្វើនូវសេចក្តីក្រេវក្រោធផង ប្រទូស្ត

ផង សេចក្តីមិនត្រេកអរផងឲ្យប្រាកដឡើង ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវិបុត្រមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញបានដេញដោលទូវអរហន្តសមណៈ មានសភាពដ៏ល្អ ធ្វើដូចម្តេចហ្ន៎ អំពើដែលប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង កុំបីមានដល់អាត្មាអញទៅយ ។ ម្នាលភគ្គវៈ លំដាប់នោះ សុនក្ខត្តលិច្ឆវិបុត្រ បានចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ តថាគតក៏បានពោលពាក្យនេះថា ម្នាលមោឃបុរស អ្នកមិនសមបើមកប្តេជ្ញាខ្លួន ថាជាសក្យបុត្តិយ៍សោះទៅយ ។ សុនក្ខត្តលិច្ឆវិបុត្របាននិយាយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគទ្រង់បន្ទោសខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើមកប្តេជ្ញាខ្លួន ថាជាសក្យបុត្តិយ៍ ។ តថាគតក៏ត្រឡប់និយាយទៅវិញទៀតថា ម្នាលសុនក្ខត្តៈ ក្រែងអ្នកបានចូលទៅរកអចេលកឡារមជ្ឈកៈ ហើយសួរប្រស្នា ឯអចេលកឡារមជ្ឈកៈ លុះដល់សួរប្រស្នាហើយ ក៏រកឆ្លើយដោះប្រស្នាមិនរួច កាលបើឆ្លើយដោះប្រស្នាមិនរួចហើយ ក៏បានធ្វើនូវសេចក្តីក្រៀវក្រោធផង ប្រទូស្តផង សេចក្តីមិនត្រេកអរផងឲ្យប្រាកដឡើង អ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញបានដេញដោលនូវព្រះអរហន្ត-សមណៈ ដែលមានសភាពដ៏ល្អ ធ្វើដូចម្តេចហ្ន៎ អំពើដែលប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង កុំបីមានដល់

អាត្មាអញទ្បើយ ដូច្នេះមែនឬ ។ ឯសុនក្ខត្តលិច្ឆវិបុត្រ ក៏ត្រឡប់ទូលតបថា ព្រះកុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះមានព្រះភាគទ្រង់កំណាញ់ ព្រះអរហត្តឬអ្វី ។ តថាគតនិយាយថា ម្នាលមោឃបុរស តថាគតមិនមែនកំណាញ់ព្រះអរហត្តទេ តែទិដ្ឋិអាក្រក់យ៉ាងនេះ កើតទ្បើងដល់អ្នកទេតើ អ្នកចូរលះបង់នូវទិដ្ឋិអាក្រក់នោះចេញ ទិដ្ឋិអាក្រក់ដែលប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ជាទុក្ខអស់កាលដ៏យូរ កុំបីមានដល់អ្នកទ្បើយ ។ តថាគតនិយាយទៀតថា ម្នាលសុនក្ខត្ត: អ្នកឯងសម្គាល់នូវអចេលកទ្បារមជ្បក:ណាថា ជាអរហន្តសមណ: មានសភាពដ៏ប្រសើរដូច្នេះ មិនយូរប៉ុន្មាន អចេលក៍នោះ មុខជានឹងត្រឡប់ទៅជាអ្នកស្បៀកសំពត់ មានប្រពន្ធកូន បរិភោគកាមគុណនិងនំ លះបង់ចោលនូវចេតិយទាំងអស់ ដែលមាននៅជិតក្រុងវេសាលី និងសាបសូន្យចាកយស ហើយធ្វើមរណកាលទៅ ។ ម្នាលភគ្គវ: លំដាប់នោះ ឯង អចេលកទ្បារមជ្បក: មិនយូរប៉ុន្មាន ត្រឡប់ទៅជាអ្នកស្បៀកសំពត់ មានប្រពន្ធកូន បរិភោគកាមគុណ និងនំ លះបង់នូវចេតិយទាំងអស់ដែលមាននៅជិតក្រុងវេសាលី ជាអ្នកសាបសូន្យចាកយស ហើយធ្វើមរណកាលទៅដូច្នោះមែន ម្នាលភគ្គវ: សុនក្ខត្តលិច្ឆវិបុត្រ បានឮដំណឹងថា អចេលក-ទ្បារមជ្បក: ត្រឡប់ទៅជាអ្នកស្បៀកសំពត់ មានប្រពន្ធកូន បរិភោគកាមគុណនិងនំ លះបង់ចោលនូវចេតិយទាំងអស់ ដែលមាននៅជិតក្រុងវេសាលី សាបសូន្យចាកយសហើយ ធ្វើមរណកាលទៅដែរ ។ ម្នាលភគ្គវ: គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំ

តថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ តថាគតក៏បានសួរយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច តថាគតបានប្រោរព្ធព្យាករ នូវអចេលក-ទ្វារមជ្ឈកៈ ប្រាប់អ្នកយ៉ាងណា វិបាកនោះក៏ពិតដូច្នោះមែន មិនមែនទៅជាផ្សេងវិញទេឬ ។ ឯសុនក្ខត្តលិច្ឆវិបុត្របានឆ្លើយតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ប្រោរព្ធព្យាករនូវអចេលកទ្វារមជ្ឈកៈ ប្រាប់ខ្ញុំព្រះអង្គ យ៉ាងណា វិបាកនោះក៏ពិតដូច្នោះមែន មិនមែនទៅជាផ្សេងវិញទេ ។ តថាគត ក៏និយាយថា ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ តើឈ្មោះថាតថាគតបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សហើយ ឬថាមិនបានធ្វើទេ ។ សុនក្ខត្ត-លិច្ឆវិបុត្រក៏ទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមាន ហើយ ឈ្មោះថា ព្រះអង្គបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សពិតមែនហើយ មិនមែនថាព្រះអង្គមិនធ្វើទេ ។ តថាគត ពោលថា ម្នាលមោឃបុរស កាលបើហេតុយ៉ាងនោះទេ ចុះដូចម្តេចក៏អ្នក និយាយនឹងតថាគត ដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ដល់ខ្ញុំ ព្រះអង្គសោះ ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះជាកំហុសរបស់ អ្នកហើយ ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ កាលបើតថាគតស្តីថាឲ្យ

យ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចជាសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

[๖] *ម្នាលភគ្គវៈ សម័យមួយ តថាគតបិតនៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលីឯណោះ ។ សម័យនោះឯង អចេលបាដិកបុត្រ នៅអាស្រ័យក្នុងក្រុងវេសាលី ជាអ្នកបានលាភ និងយសដ៏ប្រសើរ ក្នុងវជ្ជីគ្រាម ។ អចេលបាដិកបុត្រនោះ ពោលពាក្យក្នុងកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីយ៉ាងនេះថា ព្រះសមណគោតមជាញាណវាទ (អ្នកពោលដោយប្រាជ្ញា) ឯយើងក៏ជាញាណវាទដែរ អ្នកដែលជាញាណវាទ និងអ្នកដែលជាញាណវាទដូចគ្នា គួរនឹងសម្តែងឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាធម៌របស់មនុស្សតគ្នា តែព្រះសមណគោតមគួរមកកាន់ទីពាក់កណ្តាលផ្លូវ ឯយើងក៏គួរតែទៅដល់ទីពាក់កណ្តាលផ្លូវដែរ ហើយយើងទាំងពីរនាក់នោះនឹងធ្វើនូវឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាធម៌របស់មនុស្សក្នុងទីដែលជួបគ្នានោះ បើព្រះសមណគោតម នឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាធម៌របស់មនុស្សបាន ๑ យើងអាចនឹងធ្វើបានពីរ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាធម៌របស់មនុស្សបានពីរ យើងអាចនឹងធ្វើបាន ๔ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាធម៌របស់មនុស្សបាន ๔ យើងអាចនឹងធ្វើបាន ๘ ។ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាធម៌របស់មនុស្សបានប៉ុន្មាន យើងអាចនឹងធ្វើឲ្យបានជា

ទ្វេគុណៗ ជាងនោះៗ ទៅទៀតបាន ដោយប្រការដូច្នេះឯង ។ ម្នាលភគ្គវៈ ព្រោះហេតុនោះឯង ចានជាសុនក្ខត្តលិច្ឆវិបុត្រ ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ ក៏បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អចេលចាដិកបុត្រនៅអាស្រ័យក្នុងក្រុងវេសាលី ជាអ្នកបានលាភ និងយសដ៏ប្រសើរ ក្នុងវជ្ជីគ្រាម អចេលចាដិក-បុត្រនោះក៏ពោលពាក្យក្នុងកណ្តាលបរិស័ទ នាក្រុងវេសាលីយ៉ាងនេះថា ព្រះសមណគោតមជាញាណវាទ ឯយើងក៏ជាញាណវាទដែរ អ្នកដែលជាញាណវាទ និងអ្នកដែលជាញាណវាទដូចគ្នា គួរនឹងសម្តែងឥទ្ធិបាដិហារិយ៍ជាធម៌ប្រសើរក្រៃលែងជាងធម៌របស់មនុស្សគ្នា តែព្រះសមណគោតម គួរមកកាន់ទីពាក់កណ្តាលផ្លូវ ឯយើងក៏គួរទៅកាន់ទីពាក់កណ្តាលផ្លូវដែរ ហើយយើងទាំងពីរនាក់នោះនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្នុងទីដែលជួបគ្នានោះ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារ្យជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សបាន ១ យើងអាចនឹងធ្វើបាន ២ ។ សេចក្តីបង្រួញ ។ យើងអាចនឹងធ្វើឲ្យជាទ្វេគុណៗ ជាងនោះៗ ទៅទៀតបាន ។ ម្នាលភគ្គវៈ កាលបើសុនក្ខត្តលិច្ឆវិបុត្រពោលពាក្យយ៉ាងនេះហើយ តថាគតក៏និយាយនឹងសុនក្ខត្តលិច្ឆវិបុត្រយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អចេលចាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ ក៏មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតឡើយ បើប្រសិនជា

អចេលបាដិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះមុខ នៃព្រះសមណគោតម ដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះ ។ សុនក្ខត្តលិច្ឆវិបុត្រក៏និយាយទៀតថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគរក្សានូវវាចានុ៎ះ សូមព្រះសុគតរក្សានូវវាចានុ៎ះ ។ តថាគតនិយាយថា ម្នាលសុនក្ខត្តៈ ព្រោះហេតុអ្វីបានជាអ្នកនិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគរក្សានូវវាចានុ៎ះ សូមព្រះសុគតរក្សាវាចានុ៎ះ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បានពោលនូវវាចានុ៎ះ ដោយជាច់ខាតដូច្នេះថា អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ បើប្រសិនជាអចេលបាដិកបុត្រនោះតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះមុខ នៃព្រះសមណគោតម ដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើអចេលបាដិកបុត្រនឹងមកកាន់ទីចំពោះព្រះកក្ខ្លៃនៃព្រះមានព្រះភាគ ដោយរូបផ្លែកបាន ពាក្យរបស់ព្រះមានព្រះភាគនោះ នឹងត្រឡប់ទៅជាពាក្យមុសាវិញ ។ តថាគតក៏និយាយទៀតថា ម្នាលសុនក្ខត្តៈ វាចាណាមានដំណើរបែកជា ២ ផ្លូវ តថាគតគប្បីពោលវាចានោះដែរឬទេ ។ សុនក្ខត្តលិច្ឆវិបុត្រក៏ទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះ

មានព្រះភាគទ្រង់បានកំណត់ជ្រាបចិត្ត របស់អចេលចាជិកបុត្រ ដោយព្រះហឫទ័យរបស់ព្រះអង្គថា អចេលចាជិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ បើប្រសិនជាអចេលចាជិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះ ហើយគប្បីទៅកាន់ទីចំពោះមុខនៃព្រះសមណគោតម ដូច្នេះ ក្បាលរបស់អចេលចាជិកបុត្រនោះ មុខជានឹងធ្លាក់ចុះ ដូច្នេះឬ ឬក៏ទេវតាទាំងឡាយមកក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អចេលចាជិកបុត្រ បើមិនលះបង់វាចានោះ មិនគួរនឹង ។បេ។ ក្បាលរបស់អចេលចាជិកបុត្រនោះ មុខជានឹងធ្លាក់ចុះ ។ តថាគតពោលថា ម្នាលសុនក្ខត្តៈ តថាគតបានកំណត់ដឹងចិត្ត របស់អចេលចាជិកបុត្រ ដោយចិត្តរបស់តថាគតថា អចេលចាជិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនគួរនឹង ។បេ។ ក្បាលរបស់អចេលចាជិកបុត្រនោះ មុខជានឹងធ្លាក់ចុះដូច្នេះផង ទាំងពួកទេវតាក៏ប្រាប់ដំណើរនុ៎ះ ដល់តថាគតថា បពិត្រព្រះអង្គដ៏ចម្រើន អចេលចាជិកបុត្រ បើមិនលះបង់វាចានោះ មិនគួរនឹង ។បេ។ ក្បាលរបស់អចេលចាជិកបុត្រនោះមុខជានឹងធ្លាក់ចុះ ដូច្នេះផង ។ មិនតែប៉ុណ្ណោះ បុរសឈ្មោះអជិត ជាសេនាបតីរបស់ពួកស្តេចលិច្ឆវី ទើបនឹងធ្វើមរណកាលថ្មីៗ ទៅកើតក្នុងពួកទេវតាជាន់តាវត្តិង្ស ឯអជិតសេនាបតីនោះ ក៏ចូលមករកតថាគត ហើយប្រាប់យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អចេលចាជិកបុត្រ

ឥតមានសេចក្តីអៀនខ្មាស បពិត្រព្រះអង្គដ៏ចម្រើន អចេលបាដិកបុត្រតែង
ពោលពាក្យកុហក បពិត្រព្រះអង្គដ៏ចម្រើន អចេលបាដិកបុត្រ បានទាយឲ្យ
ខ្ញុំព្រះអង្គថា អជិតសេនាបតីរបស់ពួកស្តេចលិច្ឆវី ក្នុងវជ្ជីគ្រាម ទៅកើតក្នុង
មហានរក ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមែនទៅកើតក្នុងមហា
នរកឡើយ បានទៅកើតក្នុងពួកទេវតាជាន់តាវត្តិង្សទេតើ បពិត្រព្រះអង្គដ៏
ចម្រើន អចេលបាដិកបុត្រ ឥតមានសេចក្តីអៀនខ្មាសទេ បពិត្រព្រះអង្គដ៏
ចម្រើន អចេលបាដិកបុត្រតែងពោលពាក្យកុហក បពិត្រព្រះអង្គដ៏ចម្រើន
អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនគួរនឹង ។បេ។ ក្បាលរបស់
អចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះមិនខាន ។ ម្នាលសុនក្ខត្តៈ តថាគត
បានកំណត់ដឹងចិត្តរបស់អចេលបាដិកបុត្រ ដោយចិត្តថា អចេលបាដិកបុត្រ
បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិន
គួរនឹងមកកាន់ទីចំពោះមុខតថាគតឡើយ បើប្រសិនជាអចេលបាដិកបុត្រតាំង
ចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះ
បង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណគោតម
ដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះដូច្នេះផង ទាំង
ពួកទេវតាក៏ប្រាប់ដំណើរនុ៎ះ ដល់តថាគតថា បពិត្រព្រះអង្គដ៏ចម្រើន អចេល-
បាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះ
ចេញទេ មិនគួរនឹងមកកាន់ទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគបានឡើយ បើ
ប្រសិនជាអចេលបាដិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់

វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះព្រះកត្រៃព្រះសមណគោតម ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះ ដូច្នេះផង ។ ម្នាលសុនក្ខត្តៈ ចំណែកខាងតថាគតត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងវេសាលី លុះដល់វេលាបច្ឆាភត្ត តថាគតត្រឡប់ពីបិណ្ឌបាតមក ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ម្នាលសុនក្ខត្តៈ ឥឡូវនេះ អ្នកចង់ប្រាប់នូវរឿងណា អ្នកចូរប្រាប់នូវរឿងនោះមកចុះ ។

[๗] ម្នាលភគ្គវៈ គ្រានោះឯង តថាគតស្ទៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលាព្រឹកព្រហាម ចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី លុះចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលីហើយ ត្រឡប់ពីបិណ្ឌបាតមកវិញក្នុងវេលាក្រោយភត្ត ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវិបុត្រជាអ្នកចូលទៅកាន់ក្រុងវេសាលី ដោយប្រញាប់ប្រញាល់ ហើយក៏ចូលទៅរកពួកលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ លុះចូលទៅដល់ហើយ ក៏និយាយនឹងពួកលិច្ឆវី ដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ យ៉ាងនេះថា ម្នាលអាវុសោទាំង-ទ្វាយ ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅបិណ្ឌបាត ក្នុងក្រុងវេសាលី ព្រះអង្គត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ បពិត្រអ្នកមានអាយុទាំងទ្វាយ អ្នកទាំងទ្វាយចូរអញ្ជើញទៅ បពិត្រអ្នកមានអាយុ

ទាំងឡាយ អ្នកទាំងឡាយចូរអញ្ជើញទៅ ជ្បិតឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស នៃសមណៈទាំងឡាយ មានសភាពដ៏ល្អ មុខជានឹងមានមិនខាន ។ ម្នាលភគ្គវៈ គ្រានោះឯង ពួកលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏ប្រឹក្សាគ្នាដូច្នេះថា ម្នាលគ្នាយើង បានឮថា ឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សរបស់សមណៈទាំងឡាយមានសភាពដ៏ល្អ មុខជានឹងមានមិនខាន ម្នាលគ្នាយើង បើដូច្នោះមានតែយើងទាំងឡាយនាំគ្នាទៅមើល ។ ឯសុនក្ខត្តលិច្ឆវិបុត្រ ក៏ដើរចូលទៅរកពួកព្រាហ្មណមហាសាល និងគហបតី អ្នកសន្សំទ្រព្យ សមណព្រាហ្មណ៍ដែលមានលទ្ធិផ្សេងៗ មានកេរ្តិ៍ឈ្មោះប្រាកដជាងគេ លុះចូលទៅដល់ហើយ បាននិយាយទៅនឹងសមណព្រាហ្មណ៍ ដែលមានលទ្ធិផ្សេងៗ មានកេរ្តិ៍ឈ្មោះប្រាកដជាងគេដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគនុ៎ះ ទ្រង់ពុទ្ធដំណើរទៅបិណ្ឌបាតក្នុងក្រុងវេសាលី ព្រះអង្គត្រឡប់ពីបិណ្ឌបាតមកវិញក្នុងវេលាក្រោយភត្ត ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីទៅសម្រាកក្នុងវេលាថ្ងៃ នៃអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរអញ្ជើញទៅ នៃអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរអញ្ជើញទៅ ជ្បិតឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស នៃសមណៈទាំងឡាយ មានសភាពដ៏ល្អ មុខជានឹងមានមិនខាន ។ ម្នាលភគ្គវៈ លំដាប់នោះឯង ពួកសមណព្រាហ្មណ៍ដែលមានលទ្ធិផ្សេងៗ មានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏ប្រឹក្សាគ្នាដូច្នេះថា ម្នាលគ្នាយើង បានឮថា ឥទ្ធិបាដិហារិយ៍ ជាធម៌

ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស នៃសមណៈទាំងឡាយ មានសភាព
ដ៏ល្អ មុខជានឹងមានមិនខាន ម្នាលគ្នាយើង បើដូច្នោះ មានតែពួកយើងនាំគ្នា
ទៅមើល ។ ម្នាលភគ្គវៈ លំដាប់នោះឯង ពួកលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះ
ប្រាកដជាងគេ និងពួកព្រាហ្មណមហាសាល និងគហបតីអ្នកសន្សំទ្រព្យ និង
ពួកសមណព្រាហ្មណ៍មានលទ្ធិផ្សេងៗ សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ
បាននាំគ្នាចូលទៅកាន់អារាមរបស់អចេលចាដិកបុត្រ ។ ម្នាលភគ្គវៈ បរិស័ទ
នោះមានប្រមាណច្រើនរយច្រើនពាន់នាក់ ។ ម្នាលភគ្គវៈ អចេលចាដិកបុត្រ
បានឮដំណឹងថា ពួកស្តេចលិច្ឆវី សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បានមក
ហើយ ពួកព្រាហ្មណមហាសាល និងគហបតីអ្នកសន្សំទ្រព្យ និងសមណ-
ព្រាហ្មណ៍មានលទ្ធិផ្សេងៗ សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏បានមកដែរ
ព្រះសមណគោតម ក៏គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អាត្មា
អញ ។ អចេលចាដិកបុត្រនោះ លុះឮដំណឹងហើយ ក៏កើតភ័យរន្ធត់ ព្រឺព្រួច
អស់ទាំងរោម ។ ម្នាលភគ្គវៈ លំដាប់នោះឯង លុះអចេលចាដិកបុត្រ កើត
មានភ័យតក់ស្លុតព្រឺព្រួចរោមហើយ ក៏ចូលទៅឯតិណ្ឌុកខានុបរិព្វាជការាម ។
ម្នាលភគ្គវៈ បរិស័ទនោះ បានឮដំណឹងថា អចេលចាដិកបុត្រកើតមានភ័យ
តក់ស្លុតព្រឺព្រួចរោមហើយ ក៏ចូលទៅឯតិណ្ឌុកខានុបរិព្វាជការាម ។ ម្នាល
ភគ្គវៈ វេលានោះឯង បរិស័ទនោះហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន
អ្នកចូរមកនេះ អ្នកចូរទៅរកអចេលចាដិកបុត្រ ក្នុងតិណ្ឌុកខានុបរិព្វាជការាម
លុះចូលទៅដល់ហើយ ចូរនិយាយនឹងអចេលចាដិកបុត្រយ៉ាងនេះថា នែអាវុសោ

ចាជិកបុត្រ ចូរអ្នកត្រឡប់ទៅវិញ ព្រោះពួកស្តេចលិច្ឆវី សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេបាននាំគ្នាមកហើយ ពួកព្រាហ្មណមហាសាល ពួកគហបតីអ្នកសន្សំទ្រព្យ និងពួកសមណព្រាហ្មណ៍មានលទ្ធិផ្សេងៗ សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏បាននាំគ្នាមកដែរ ទាំងព្រះសមណគោតមសោត ក៏នៅគង់សម្រាកព្រះអង្គនៅវេលាថ្ងៃក្តៅងអាពាធរបស់អ្នកមានអាយុ នែអាវុសោចាជិកបុត្រ ចំណែកអ្នកបានពោលវាចានេះក្នុងកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីថា សមណគោតមជាញាណវាទ យើងក៏ជាញាណវាទដែរ ចំណែកបុគ្គលជាញាណវាទគួរសម្តែងឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស មួយអន្ទើដោយបុគ្គលជាញាណវាទដូចគ្នា ព្រះសមណ-គោតម គួរមកកាន់ទីពាក់កណ្តាលផ្លូវ ឯយើងក៏គួរទៅកាន់ទីពាក់កណ្តាលផ្លូវដែរ យើងទាំងពីរនាក់នោះ នឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ក្នុងទីដែលជួបគ្នានោះ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបាន ១ យើងនឹងអាចធ្វើបាន ២ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបាន ២ យើងអាចនឹងធ្វើបាន ៤ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបាន ៤ យើងអាចនឹងធ្វើបាន ៨ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបានប៉ុន្មានៗ យើងអាចនឹងធ្វើឲ្យបានជាទ្វេគុណៗ ជាងនោះៗ ទៅទៀតដូច្នេះឯង ម្នាលអាវុសោ

ចាជិកបុត្រ អ្នកចូរត្រឡប់ទៅកាន់ទីពាក់កណ្តាលផ្លូវចុះ ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកនៅវេលាថ្ងៃក្នុង អាវាមរបស់អ្នកមានអាយុ ។ ម្នាលភគ្គវៈ បុរសនោះទទួលពាក្យបវិស័ទនោះ ថា អើ អ្នកដ៏ចម្រើន ហើយក៏ចូលទៅរកអចេលចាជិកបុត្រ ក្នុងតិណ្ឌុក-ខានុបរិព្វាជការាម លុះចូលទៅដល់ហើយ បាននិយាយនឹងអចេលចាជិកបុត្រ យ៉ាងនេះថា ម្នាលអាវុសោចាជិកបុត្រ អ្នកចូរត្រឡប់ទៅវិញ ព្រោះពួកស្តេច លិច្ឆវិសុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេបាននាំគ្នាមកហើយ ពួកព្រាហ្មណ-មហាសាលសុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏បាននាំគ្នាមកដែរ ។បេ។ ម្នាលអាវុសោចាជិកបុត្រ អ្នកចូរទៅកាន់ទីពាក់កណ្តាលផ្លូវ ព្រះសមណ-គោតមទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកព្រះអង្គនៅ វេលាថ្ងៃ ក្នុងអាវាមរបស់អ្នកមានអាយុ ។ ម្នាលភគ្គវៈ កាលបើបុរសនោះ និយាយយ៉ាងនេះហើយ អចេលចាជិកបុត្រឆ្លើយថា ម្នាលអ្នកមានអាយុ ខ្ញុំ នឹងទៅ ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ហើយក៏អង្គុយជ្រប់នៅត្រង់ទីនោះឯង មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ ទើបបុរសនោះនិយាយ នឹងអចេលចាជិកបុត្រយ៉ាងនេះថា ម្នាលអាវុសោចាជិកបុត្រ គួរអ្នកជាប់ នៅនឹងតាំងរបស់អ្នកឬ ឬតាំងជាប់ស្ថិតនៅនឹងគួរបស់អ្នក បានជាអ្នកគ្រាន់ តែនិយាយថា ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយសំកុកត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពី អាសនៈបាន ។ ម្នាលភគ្គវៈ អចេលចាជិកបុត្រ បើទុកជាបុរសនោះនិយាយ

យ៉ាងនេះ ក៏នៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលណាបុរសនោះដឹងថា អចេលកាជកបុត្រនេះ បរាជ័យហើយនៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ កាលនោះ បុរសនោះក៏ត្រឡប់មកកាន់បរិស័ទនោះវិញ ហើយប្រាប់យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អចេលកាជកបុត្រនេះបរាជ័យហើយ ក៏នៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលបើបុរសនោះនិយាយយ៉ាងនេះហើយ តថាគតបាននិយាយនឹងបរិស័ទនោះដូច្នេះថា ម្នាលអ្នកមានអាយុ អចេលកាជកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតឡើយ ប្រសិនបើអចេលកាជកបុត្រនោះតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញឡើយ ហើយទៅកាន់ទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតមឲ្យបានដូច្នេះ ក្បាលរបស់អចេលកាជកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ។

បឋមភាណវារ ចប់

[๘] *ម្នាលភគ្គវៈ លំដាប់នោះឯង លិច្ឆវីមហាមាត្យម្នាក់ក្រោកអំពី*

អាសនៈ ហើយនិយាយនឹងបរិស័ទនោះយ៉ាងនេះថា នែអ្នកដ៏ចម្រើន បើដូច្នោះ អ្នកទាំងឡាយ ចូររង់ចាំមួយរំពេចសិន ទម្រាំខ្ញុំទៅ ក្រែងជួនជាខ្ញុំអាចនាំអចេលចាដិកបុត្រមកកាន់បរិស័ទនេះបាន ។ ម្នាលភគ្គវៈ ទើបលិច្ឆវីមហាមាត្យនោះ ចូលទៅរកអចេលចាដិកបុត្រ ក្នុងតិណ្ឌុកខានុបរិព្វាជការាម លុះចូលទៅដល់ហើយ បាននិយាយនឹងអចេលចាដិកបុត្រយ៉ាងនេះថា ម្នាលអាវុសោចាដិកបុត្រ ចូរអ្នកត្រឡប់ទៅវិញ ការដែលអ្នកត្រឡប់ទៅវិញប្រសើរជាង ព្រោះពួកជនដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បាននាំគ្នាទៅអស់ហើយ ។ សេចក្តីបង្រួញ ។ ទាំងព្រះសមណគោតមសោត ក៏គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ ម្នាលអាវុសោចាដិកបុត្រ ឯអ្នកក៏បាននិយាយសម្តីនេះក្នុងកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីថា ព្រះសមណគោតមជាញាណវាទ ឯយើងក៏ជាញាណវាទដែរ ។បេ។ យើងអាចនឹងធ្វើឲ្យជាទេគុណៗ ជាងនោះៗ ទៀតបានដូច្នេះ ម្នាលអាវុសោចាដិកបុត្រ ចូរអ្នកទៅកាន់ទីពាក់កណ្តាលផ្លូវចុះ ព្រះសមណគោតមទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ ម្នាលអាវុសោចាដិកបុត្រ មួយវិញទៀត ព្រះសមណគោតមបានត្រាស់ព្រះវាចានេះ ក្នុងកណ្តាលបរិស័ទថា អចេលចាដិកបុត្រ បើមិនលះបង់វាចានោះ ។បេ។ ក្បាលរបស់អចេលចាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខានឡើយ នែអាវុសោចាដិកបុត្រ អ្នកចូរត្រឡប់ទៅវិញចុះ យើងនឹងឲ្យជ័យជម្នះដល់អ្នក នឹងឲ្យព្រះសមណគោតមចាញ់វិញ ព្រោះការ

ដែលអ្នកហ៊ានត្រឡប់ទៅវិញប៉ុណ្ណោះ ។ ម្នាលភគ្គវៈ កាលបើលិច្ឆវីមហា-
មាត្យនោះនិយាយយ៉ាងនេះហើយ អចេលបាដិកបុត្រក៏និយាយថា ម្នាល
អាវុសោខ្ញុំនឹងទៅ ម្នាលអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅអង្គុយជ្រប់
ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ
ទើបលិច្ឆវីមហាមាត្យនោះ និយាយនឹងអចេលបាដិកបុត្រយ៉ាងនេះថា នែ
អាវុសោបាដិកបុត្រ គួរអ្នកជាប់ស្អិតនៅនឹងតាំងរបស់អ្នកឬ ឬតាំងជាប់ស្អិត
នៅនឹងគួរបស់អ្នក បានជាអ្នកនិយាយថា ម្នាលអាវុសោខ្ញុំនឹងទៅ ម្នាល
អាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល
មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ អចេលបាដិកបុត្រ
បើទុកជាលិច្ឆវីមហាមាត្យនិយាយយ៉ាងនេះក្តី ក៏នៅតែនិយាយថា ម្នាល
អាវុសោខ្ញុំនឹងទៅ ម្នាលអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់
ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ
កាលណាលិច្ឆវីមហាមាត្យបានដឹងច្បាស់ថា អចេលបាដិកបុត្រនេះបរាជ័យ
ហើយ ក៏នៅតែនិយាយថា ម្នាលអាវុសោខ្ញុំនឹងទៅ ម្នាលអាវុសោខ្ញុំនឹងទៅ
ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពី
អាសនៈបានឡើយ ដូច្នេះហើយ ទើបត្រឡប់មកកាន់បរិស័ទនោះវិញ ប្រាប់
យ៉ាងនេះថា អចេលបាដិកបុត្រនេះបរាជ័យហើយ ក៏នៅតែនិយាយថា នែ
អាវុសោខ្ញុំនឹងទៅ នែអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់
កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ

កាលបើលិច្ឆវិមហាមាត្យនិយាយយ៉ាងនេះហើយ តថាគតក៏និយាយនឹងបរិស័ទ នោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ អចេលចាជិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនគួរ ។បេ។ ប្រសិនបើអចេលចាជិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតម ដូច្នេះ ក្បាលអចេល-ចាជិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ទោះបីពួកលិច្ឆវិមានអាយុគិតគ្នាថា បើទុកជាយើងទាំងឡាយ ចងអចេលចាជិកបុត្រដោយខ្សែព្រ័ត្រណា ហើយបង្អួសមកដោយគោច្រើនទឹម ដូច្នេះ ខ្សែព្រ័ត្រនោះនឹងដាច់ ឬខ្ជួនរបស់អចេលចាជិកបុត្រឯងនឹងដាច់ ឯអចេលចាជិកបុត្រ បើមិនលះបង់វាចានោះ មិនគួរ ។បេ។ ប្រសិនបើអចេលចាជិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតមដូច្នេះ ក្បាលអចេលចាជិកបុត្រនោះមុខជានឹងធ្លាក់ចុះមិនខាន ។

[៩] ម្នាលភគ្គវៈ លំដាប់នោះឯង ជាលិយបព្វជិត ជាសិស្សរបស់ទារុបត្តិកបព្វជិត ក្រោកអំពីអាសនៈ ហើយនិយាយនឹងបរិស័ទនោះយ៉ាងនេះថា នែអ្នកដ៏ចម្រើន បើដូច្នោះ អ្នកទាំងឡាយ ចូរអង់ចាំមួយរំពេចសិនទម្រាំខ្ញុំទៅ ក្រែងជួនជាខ្ញុំអាចនាំអចេលចាជិកបុត្រមកបាន ។ ម្នាលភគ្គវៈ គ្រានោះឯង ជាលិយបព្វជិត ជាសិស្សរបស់ទារុបត្តិកបព្វជិត បានចូលទៅរកអចេលចាជិកបុត្រ ក្នុងតិណ្ឌុកខានុបរិព្វាជការាម លុះចូលទៅដល់ហើយ បាននិយាយនឹងអចេលចាជិកបុត្រយ៉ាងនេះថា នែអាវុសោចាជិកបុត្រ អ្នកចូរ

ត្រឡប់ទៅវិញចុះ ការដែលអ្នកត្រឡប់ទៅវិញប្រសើរជាង ព្រោះថា ពួក
ស្តេចលិច្ឆវីសុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បានទាំគ្នាមកហើយ ។បេ។
ទាំងព្រះសមណគោតម ក៏គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអាភមរបស់
អ្នកមានអាយុ នែអាវុសោជាជិកបុត្រ ឯអ្នកសោតក៏បាននិយាយសម្តីនេះ
ក្នុងកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីថា ព្រះសមណគោតម ជាញាណវាទ
។បេ។ យើងអាចនឹងធ្វើឲ្យជាទ្វេគុណៗ ជាងនេះទៅទៀត នែអាវុសោ
ជាជិកបុត្រ អ្នកចូរទៅកាន់ទីពាក់កណ្តាលផ្លូវចុះ ព្រះសមណគោតម ទ្រង់
ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ
ក្នុងអាភមរបស់អ្នកមានអាយុ ម្នាលអាវុសោជាជិកបុត្រ មួយវិញទៀត ព្រះ
សមណគោតមបានត្រាស់ព្រះវាចានេះ ចំពោះរូបអ្នក ក្នុងកណ្តាលបរិស័ទថា
នែអាវុសោទាំងឡាយ អចេលជាជិកបុត្រ បើមិនលះបង់វាចានោះ មិនគួរ
។បេ។ ប្រសិនជាអចេលជាជិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិន
លះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណ-
គោតមដូច្នេះ ក្បាលអចេលជាជិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ប្រសិន
បើពួកលិច្ឆវីមានអាយុគិតគ្នាយ៉ាងនេះថា បើទុកជាយើងទាំងឡាយចង់អចេ-
លជាជិកបុត្រ ដោយខ្សែព្រំត្រណា ហើយបង្អួសមកដោយគោច្រើននឹមដូច្នេះ
ខ្សែព្រំត្រទាំងនោះនឹងជាប់ ឬខ្ជួនអចេលជាជិកបុត្រឯងនឹងជាប់ ឯអចេលជា-
ជិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះ
ចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ ប្រសិនបើអចេល-

ចាជិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាគ្នាអញមិនលះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណាគោតមដូច្នេះ ក្បាលអចេលចាជិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន នែអាវុសោចាជិកបុត្រ អ្នកចូរត្រឡប់ទៅវិញចុះ យើងនឹងឲ្យជ័យជម្នះដល់អ្នក នឹងឲ្យព្រះសមណាគោតមចាញ់ ព្រោះការដែលអ្នកត្រឡប់ទៅវិញប៉ុណ្ណោះ ។ នែភគ្គវៈ កាលបើជាលិយៈនិយាយយ៉ាងនេះហើយ អចេលចាជិកបុត្រនៅតែនិយាយថា នែអាវុសោខ្ញុំនឹងទៅ នែអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ នែភគ្គវៈ គ្រានោះ ជាលិយៈជាសិស្សនៃទារុបត្តិកៈ បាននិយាយនឹងអចេលចាជិកបុត្រយ៉ាងនេះថា នែអាវុសោចាជិកបុត្រ គួរអ្នកជាប់ស្ថិតនៅនឹងតាំងរបស់អ្នកឬ ឬតាំងជាប់ស្ថិតនៅនឹងគួរបស់អ្នក បានជាអ្នកនិយាយថា នែអាវុសោខ្ញុំនឹងទៅ នែអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់ទីនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ នែភគ្គវៈ អចេលចាជិកបុត្រ សូម្បីជាលិយៈស្តីថាឲ្យយ៉ាងនេះ ក៏នៅតែនិយាយថា នែអាវុសោខ្ញុំនឹងទៅ នែអាវុសោខ្ញុំនឹងទៅ ហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ នែភគ្គវៈ កាលណាជាលិយៈជាសិស្សទារុបត្តិកៈបានដឹងច្បាស់ថា អចេលចាជិកបុត្រនេះបរាជ័យហើយ ក៏នៅតែនិយាយថា នែអាវុសោខ្ញុំនឹងទៅ នែអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ដូច្នេះ

ហើយ ទើបនិយាយនឹងអចេលជាដិកបុត្រនោះយ៉ាងនេះថា នែអាវុសោជាដិក-បុត្រ កាលពីព្រេងនាយមក មានសីហមិគរាជមួយ មានសេចក្តីត្រិះរិះយ៉ាងនេះថា គួរតែអាត្មាអញនៅអាស្រ័យនឹងដងព្រៃមួយ ក៏សម្រេចការដេក លុះសម្រេចការដេកក្នុងដងព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ត្រូវចេញពីទីដេក លុះចេញអំពីទីដេកហើយ ត្រូវមីតពត់កាយ លុះមីតពត់កាយហើយ ត្រូវក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញ លុះក្រមើលទៅទិសទាំង ៤ ដោយជុំហើយ ត្រូវបន្ទឺសីហនាទ ៣ ដង លុះបន្ទឺសីហនាទ ៣ ហើយ ត្រូវចេញទៅរកចំណី អាត្មាអញនោះ ត្រូវសម្លាប់ហូងម្រឹគដ៏ធំៗ ហើយបរិភោគសាច់ដែលឆ្ងាញ់ៗ ហើយត្រឡប់ចូលទៅកាន់ទីដេកនោះដដែលវិញ ។ គ្រានោះឯង សីហមិគរាជនោះ អាស្រ័យនឹងដងព្រៃមួយ សម្រេចការដេក លុះសម្រេចការដេកក្នុងដងព្រៃនោះហើយ ក្នុងវេលាសាយណ្ហ-សម័យ ក៏ចេញពីទីដេក លុះចេញពីទីដេកហើយ មីតពត់ខ្លួន លុះមិតពត់ខ្លួនហើយ ក្រឡេកមើលទិសទាំង៤ ដោយជុំវិញ លុះក្រឡេកមើលទិសទាំង ៤ ដោយជុំហើយ បន្ទឺសីហនាទ ៣ ដង លុះបន្ទឺសីហនាទ ៣ ដងហើយ ទើបចេញទៅរកចំណី សីហមិគរាជនោះ សម្លាប់ហូងម្រឹគដ៏ធំៗ ហើយបរិភោគសាច់ដែលឆ្ងាញ់ៗ រួចត្រឡប់ចូលទៅកាន់ទីដេកនោះដដែលវិញ ។ នែអាវុសោជាដិកបុត្រ មានចចកចាស់មួយ ស៊ីសាច់រំពាបស់សីហមិគ រាជនោះឯង ហើយចម្រើន (សាច់ឈាម) ធាត់ធំមានកម្លាំងខ្លាំង ។ ម្នាលអាវុសោ លំដាប់នោះឯងចចកចាស់នោះ មានគំនិតយ៉ាងនេះថា អញដួចម្តេច សីហ-

มิคราชដូចម្តេច គួរតែអញឯង អាស្រ័យនឹងជង្ឃព្រៃមួយ សម្រេចការដេក លុះសម្រេចការដេកក្នុងជង្ឃព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ត្រូវចេញពីទីដេក លុះចេញអំពីទីដេកហើយ ត្រូវមីតពត់ខ្លួន លុះដល់មីតពត់ខ្លួនរួចហើយ ត្រូវក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញ លុះក្រឡេកមើលទៅទិសទាំង ៤ ដោយជុំហើយ ត្រូវបន្ទឺសីហនាទ ៣ ដង លុះបន្ទឺសីហនាទ ៣ ដងហើយ ត្រូវចេញទៅរកចំណី អាត្មាអញសម្លាប់ហ្វូងម្រឹគដ៏ធំៗ ហើយបរិភោគសាច់ដែលឆ្ងាញ់ៗ ហើយត្រឡប់ចូលទៅកាន់ទីដេកនោះដដែលវិញ ។ ម្នាលអាវុសោ ទើបចចកចាស់នោះ អាស្រ័យនឹងជង្ឃព្រៃមួយ សម្រេចការដេក លុះសម្រេចការដេកក្នុងជង្ឃព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ក៏ចេញអំពីទីដេក លុះចេញអំពីទីដេកហើយ ក៏មីតពត់ខ្លួន លុះមីតពត់ខ្លួនហើយ ក៏ក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញ លុះក្រឡេកមើលទៅទិសទាំង ៤ ដោយជុំហើយ ក៏គិតថា អញនឹងបន្ទឺសីហនាទ ៣ ដង ដូច្នេះហើយ ស្រែកជាសម្រែកចចក ស្រែកសម្រែកដ៏ពន្ឋឹកថា ចចក អាក្រក់ដូចម្តេចទៅ ចំណែកសីហនាទដូចម្តេចទៅ ។ នែអាវុសោជាដិកបុត្រ អ្នកក៏ដូចគ្នានឹងចចកចាស់នោះដែរ រស់នៅក្នុងសុគតាបទាន (ព្រៃសិក្ខាជាសាសនារបស់ព្រះសុគត) បរិភោគកោជនជាសំណល់ សល់អំពីព្រះសុគត ហើយតតាំងនឹងព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធថា ជាដិកបុត្រអាក្រក់ដូចម្តេច ការតតាំង (ជាដិហារិយ៍) របស់ព្រះតថាគតអរហន្ត-សម្មាសម្ពុទ្ធដូចម្តេច ។ ម្នាលភគ្គវៈ កាលណាជាលិយៈ ជាសិស្សទារុបត្តិកៈ

មិនអាចឲ្យអចេលបាដិកបុត្រ ឃ្លាតអំពីអាសនៈនោះ ដោយពាក្យប្រៀបផ្ទឹមនេះហើយ ។ ទើបនិយាយនឹងអចេលបាដិកបុត្រនោះយ៉ាងនេះថា

ចចកសម្គាល់ខ្លួន ថាជាសីហរាជ បានសម្គាល់ខ្លួនទៀតថា អាត្មាអញជាមិគរាជ ចចកនោះបន្ទឺនូវសម្រែកចចកនោះថា សម្រែកចចកអាក្រក់ដូចម្តេចទៅ ចំណែកខាងសីហនាទ ដូចម្តេចទៅ ។

[๑๐] *ម្នាលអាវុសោបាដិកបុត្រ អ្នកក៏ដូច្នោះដែរ រស់នៅក្នុងសុគតាបទាន (ត្រៃសិក្ខាជាសាសនារបស់ព្រះសុគត) បរិភោគកោជនជាសំណល់អំពីព្រះសុគតហើយ តតាំងនឹងព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធថា បាដិកបុត្រលាមកដូចម្តេចទៅ ការតតាំងរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ដូចម្តេចទៅ ។ ម្នាលភគ្គវៈ កាលណាជាលិយៈជាសិស្សទោរុបត្តិកៈមិនអាចឲ្យអចេលបាដិកបុត្រ ឃ្លាតអំពីអាសនៈនោះ ដោយពាក្យឧបមានេះហើយ ។ ទើបនិយាយនឹងអចេលបាដិកបុត្រនោះយ៉ាងនេះ ក្នុងកាលនោះថា*

ចចកដើរទៅកាន់ទីស្ងាត់ បានឃើញស្រមោលខ្លួន ដែលធ្លុះចូលទៅក្នុងទឹកសំណល់ (ក្នុងត្រពាំង) មិនបានឃើញខ្លួនច្បាស់ដរាបណា ក៏សម្គាល់នូវស្រមោលនោះថាជាខ្លាធំដរាបនោះ ចចកនោះបន្ទឺនូវសម្រែករបស់ចចកនោះឯងថា សម្រែកចចកអាក្រក់ដូចម្តេចទៅ ចំណែកខាងសីហនាទ ដូចម្តេចទៅ ។

[๑๑] នែអាវុសោចាជិកបុត្រ អ្នកក៏ដូច្នោះដែរ រស់នៅក្នុងសុគតា-
បទាន (ត្រៃសិក្ខាជាសាសនារបស់ព្រះសុគត) បរិភោគភោជនជាសំណាល់
អំពីព្រះសុគត ក៏តតាំងនឹងព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធថា ចាជិកបុត្រ
អាក្រក់ដូចម្តេចទៅ ការតតាំងរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធដូច
ម្តេចទៅ ។ ម្នាលភគ្គវៈ កាលណាជាលិយៈជាសិស្សទារុបត្តិកៈ មិនអាចឲ្យ
អចេលចាជិកបុត្រឃ្លាតអំពីអាសនៈនោះបាន ដោយពាក្យឧបមានេះហើយ ។
ទើបនិយាយនឹងអចេលចាជិកបុត្រនោះយ៉ាងនេះថា

> *ចចកស៊ីកង្កែបទាំងឡាយក្នុងរណ្តៅផង ស៊ីកណ្តុរទាំងឡាយ*
> *ក្នុងទីលានផង ស៊ីសាកសពទាំងឡាយ ដែលគេចោលក្នុង*
> *ព្រៃស្មសានផង បានចម្រើនធំឡើងក្នុងព្រៃធំ ជាព្រៃស្វាត់*
> *ក៏សម្គាល់ខ្លួនថា អាត្មាអញជាមិគរាជ ចចកនោះ ក៏បន្ទឺនូវ*
> *សម្រែកចចកយ៉ាងនោះដដែលថា សម្រែកចចក អាក្រក់*
> *ដូចម្តេចទៅ ចំណែកខាងសីហនាទតើដូចម្តេចទៅ ។*

[๑๒] នែអាវុសោចាជិកបុត្រ អ្នកក៏ដូច្នោះដែរ រស់នៅក្នុងសុគតា-
បទាន (ត្រៃសិក្ខាជាសាសនារបស់ព្រះសុគត) បរិភោគភោជនជា
សំណាល់អំពីព្រះសុគត ក៏តតាំងនឹងព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធថា
ចាជិកបុត្រអាក្រក់ដូចម្តេចទៅ ការតតាំងរបស់ព្រះតថាគតជាអរហន្តសម្មា-
សម្ពុទ្ធដូចម្តេចទៅ ។ ម្នាលភគ្គវៈ កាលណាជាលិយៈជាសិស្សទារុបត្តិកៈ
មិនអាចឲ្យអចេលចាជិកបុត្រឃ្លាតចាកអាសនៈនោះបាន ដោយពាក្យឧបមា

នេះហើយ ។ ទើបត្រឡប់មកវិញ ហើយប្រាប់យ៉ាងនេះថា អស់លោកដ៏ចម្រើន អចេលបាដិកបុត្របរាជ័យហើយ គ្រាន់តែនិយាយថា នែអាវុសោខ្ញុំនឹងទៅ នែអាវុសោខ្ញុំនឹងទៅ ដូច្នេះហើយ ក៏អង្គុយជ្រប់នៅត្រង់កន្លែងនោះដដែល មិនអាចក្រោកអំពីអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលបើជាលិយៈនិយាយយ៉ាងនេះហើយ តថាគតបាននិយាយនឹងបរិស័ទនោះយ៉ាងនេះថា នែអាវុសោទាំងឡាយ អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ បើប្រសិនជាអចេលបាដិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតម ដូច្នេះ ក្បាលអចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះមិនខាន ទោះបីពួកលិច្ឆវីដ៏មានអាយុគិតគ្នាយ៉ាងនេះថា យើងត្រូវចងនូវអចេលបាដិកបុត្រដោយខ្សែព្រ័ត្រណា ហើយបង្អួសមកដោយគោច្រើនទឹមដូច្នេះ ខ្សែព្រ័ត្រទាំងនោះនឹងដាច់ ឬខ្លួនបាដិកបុត្រឯងនឹងដាច់ ឯអចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនគួរ ។បេ។ នឹងមកកាន់ចំពោះមុខតថាគតបានឡើយ ទោះបីអចេលបាដិកបុត្រនោះតាំងចិត្តយ៉ាងនេះថា អញមិនលះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រព្រះសមណគោតមដូច្នេះ ក្បាលអចេលបាដិកបុត្រនោះ នឹងធ្លាក់ចុះមិនខាន ។ ម្នាលភគ្គវៈ លំដាប់នោះ តថាគតបានញុំាងបរិស័ទនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ

ដោយធម្មីកថា លុះញ៉ាំងបរិស័ទនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាច ហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ធ្វើឲ្យរួចចាកចំណងធំ ហើយ ស្រង់សត្វទាំង ៨ ហ្មឺន ៤ ពាន់ ចាកអន្ទង់ធំ (ឱឃៈទាំង ៤) រួចហើយ ចូលតេជោធាតុ ហោះទៅកាន់វេហាស៍កម្ពស់ប្រមាណ ៧ ដើមត្នោត ទាំង បាននិម្មិតភ្លើងដទៃកម្ពស់ប្រមាណ ៧ ដើមត្នោត ឲ្យភ្ញីរន្ទាល បាញ់ញ៉ែផ្សែង មកប្រាកដ ក្នុងកូដាគារសាលានាមហាវ័ន ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រ បានចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយ បង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ កាលសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ តថាគតបានសួរយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នក សម្គាល់សេចក្តីនោះថាដូចម្តេច តថាគតបានប្រារព្ធព្យាករនូវអចេលចាជិកបុត្រ ប្រាប់អ្នកយ៉ាងណា ផលវិបាកនោះ ក៏ពិតដូច្នោះមែន មិនបានទៅជាដទៃវិញ ទេឬ ។ សុនក្ខត្តលិច្ឆវិបុត្រឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះ ភាគ ទ្រង់ប្រារព្ធព្យាករនូវអចេលចាជិកបុត្រ ប្រាប់ខ្ញុំព្រះអង្គយ៉ាងណា ផល វិបាកនោះក៏ពិតដូច្នោះមែន មិនមែនទៅជាដទៃវិញទេ ។តថាគតសួរថា ម្នាល សុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមាន ហើយ តើតថាគតឈ្មោះថាបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស ឬមិនបានធ្វើទេ ។ សុនក្ខត្តលិច្ឆវិបុត្រឆ្លើយតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ឈ្មោះថា ព្រះអង្គ បានធ្វើនូវឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សពិត

មែនហើយ មិនមែនជាព្រះអង្គមិនបានធ្វើទេ ។ តថាគតតបថា ម្នាលមោឃ-បុរស កាលបើមានហេតុយ៉ាងនេះហើយ អ្នកនៅតែនិយាយនឹងតថាគតដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ដល់ខ្ញុំព្រះអង្គទេ ។ តថាគតពោលថា ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះ ជាសេចក្តីខុសរបស់អ្នក ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ កាលដែលតថាគតស្តីឲ្យយ៉ាងនេះហើយ ក៏គេចចេញចាកធម្មវិន័យនេះ ដូចជាសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

[១៣] ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទម្លាប់ផង ដឹងច្បាស់នូវគុណវិសេស ដ៏លើសលុបជាងនោះទៅទៀតផង កាលដែលតថាគតដឹងច្បាស់នូវធម៌នោះហើយ ក៏មិនបានប្រកាន់ខុស (ដោយអំណាចតណ្ហា ទិដ្ឋិ និងមានះ) ទេ ។ លុះតថាគតមិនបានប្រកាន់ខុស (នូវធម៌នោះហើយ) ទើបដឹងច្បាស់នូវសេចក្តីរលត់ (កិលេស) ចំពោះខ្លួនឯង កាលបើតថាគតដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តីវិនាសឡើយ ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទដែលព្រះឥសូរតាក់តែងហើយ ដែលព្រះព្រហ្មតាក់តែងហើយ តថាគតបានចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះហើយ សួរយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ឮថា អ្នកទាំងឡាយ បញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ

ដែលព្រះឥសូរតាក់តែងហើយ ដែលព្រះព្រហ្មតាក់តែងហើយ ពិតមែនឬ ។ ចំណែកខាងសមណព្រាហ្មណ៍ទាំងនោះ លុះដល់តថាគតសួរយ៉ាងនេះហើយ ក៏ច្រាប់ថា ព្រះកុណាដូច្នេះ ទើបតថាគត សួរសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ ដែលព្រះឥសូរតាក់តែងហើយ ដែលព្រះព្រហ្មតាក់តែងហើយ តើមានប្រការដូចម្តេចខ្លះ ។ សមណព្រាហ្មណ៍ទាំងឡាយនោះ លុះតថាគតសួរហើយ ក៏រកឆ្លើយដោះមិនរួច កាលបើឆ្លើយដោះមិនរួចហើយ ទើបត្រឡប់សួរមកតថាគតវិញ លុះសមណព្រាហ្មណ៍ទាំងឡាយនោះ សួរតថាគតហើយ តថាគតក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានសម័យដែលលោកនេះវិនាសទៅម្តងៗ ដោយកន្លងកាលយូរទៅពុំខាន កាលដែលលោកវិនាសទៅ ពួកសត្វច្រើនទៅកើតក្នុងអាភស្សរព្រហ្ម ពួកសត្វដែលទៅកើតក្នុងអាភស្សរព្រហ្មនោះ ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីភ្លឺដោយខ្លួនឯង គ្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅអស់កាលយូរអង្វែង ។ ម្នាលអាវុសោទាំងឡាយ មានសម័យដែលត្រូវលោកនេះកើតឡើងវិញម្តងៗ ដោយកន្លងកាលយូរទៅពុំខាន កាលដែលលោកនេះកើតឡើង វិមាននៃព្រហ្ម ដែលសូន្យស្ងាត់គ្មានសត្វ ក៏កើតឡើងជ្រាកជ គ្រានោះឯង មានសត្វម្នាក់ ច្យុតចាកពួកអាភស្សរព្រហ្ម ព្រោះអស់អាយុ ឬអស់បុណ្យ ហើយទៅកើតក្នុងវិមាននៃព្រហ្ម ដែលសូន្យស្ងាត់ (នោះ) លុះសត្វនោះ បានទៅកើតក្នុងវិមាននោះ ក៏ជាសត្វកើតដោយឈាន

ចិត្ត មានបីតិជាអាហារ មានវស្មីភ្លឺដោយខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅអស់កាលយូរអង្វែង សត្វម្នាក់នោះ ដែលទៅកើត ក្នុងវិមាននោះតែម្នាក់ឯង នៅអស់កាលជាយូរអង្វែងទៅ ក៏មានសេចក្តីប្រាថ្នា សេចក្តីអន្ទះអន្ទែងដោយឥណ្ហា កើតឡើងដូច្នេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យបានពួក សត្វដទៃ មកកាន់អត្តភាពជាព្រហ្មនេះផង ។ លំដាប់នោះឯង ពួកសត្វដទៃ ច្យុតចាកពួកអាភស្សរព្រហ្ម ព្រោះអស់អាយុ ឬបុណ្យ ហើយមកកើតក្នុង ព្រហ្មវិមាន ដែលសូន្យជាមួយនឹងសត្វនោះដែរ ឯសត្វទាំងនោះ លុះកើតក្នុង ព្រហ្មវិមាននោះហើយ ក៏ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានវស្មីភ្លឺដោយខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅ អស់កាលជាយូរអង្វែង ។ ម្នាលអាវុសោទាំងឡាយ បណ្តាសត្វទាំងនោះ សត្វណាបានទៅកើតជាដំបូង សត្វនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មា អញជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់នូវសត្វឯទៀតៗ បាន សត្វឯទៀតៗ មិនអាចគ្របសង្កត់លើអាត្មាអញបានឡើយ អាត្មាអញជាអ្នកឃើញហេតុ សព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ជាធំ (ក្នុងលោក) ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកចាត់ចែង លោក ជាអ្នកសួរដំនាញ ជាបិតារបស់ពួកភូត និងកព្យៈ សត្វទាំងនេះសុទ្ធ តែអាត្មាអញតាក់តែងហើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា អាត្មាអញ មានគំនិតក្នុងកាលពីដើមមកដូច្នេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យបានពួក សត្វឯទៀតមកកាន់អត្តភាពជាព្រហ្មនេះផង ពួកសត្វទាំងនេះ មកកាន់អត្តភាព

ជាព្រហ្ម ត្រូវតាមសេចក្តីប្រាថ្នារបស់អាត្មាអញដូច្នោះឯង ។ ពួកសត្វទាំង-
ឡាយណា ដែលមកកើតជាខាងក្រោយ សត្វទាំងនោះ ក៏មានសេចក្តីយល់
ឃើញយ៉ាងនេះថា ព្រហ្មដ៏ចម្រើននេះជាមហាព្រហ្ម គ្របសង្កត់នូវសត្វ
ឯទៀតៗ បាន សត្វឯទៀតៗ មិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញ
ហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះនៅក្នុងអំណាច ជាឥស្សរៈក្នុង
លោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជា
អ្នកចាត់ចែងលោក ជាអ្នកស្ទាត់ជំនាញ ជាបិតានៃពួកភូត និងកព្យៈ យើង
ទាំងឡាយ គឺព្រហ្មដ៏ចម្រើននេះឯង បានតាក់តែងហើយ ។ ដំណើរនោះ
ព្រោះហេតុដូចម្តេច ។ ព្រោះថា យើងបានឃើញព្រហ្មនេះ មកកើតក្នុងទីនេះ
មុន ចំណែកយើងមកកើតខាងក្រោយទេ ។ ម្នាលអាវុសោ បណ្តាសត្វទាំង
នោះ សត្វណាបានទៅកើតមុនគេ សត្វនោះឯង មានអាយុវែងជាងគេផង
មានសម្បុរល្អជាងគេផង មានសក្តិធំជាងគេផង ។ ចំណែកខាងពួកសត្វណា
ដែលទៅកើតខាងក្រោយគេ ពួកសត្វនោះ មានអាយុក៏តិចជាងគេផង មាន
សម្បុរអន់ជាងគេផង មានសក្តិតូចជាងគេផង ។ ម្នាលអាវុសោទាំងឡាយ
ហេតុនុ៎ះ តែងមានជាប្រាកដ ត្រង់ថា សត្វណាមួយ ច្យុតចាកពួកព្រហ្មនោះ
មកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សនេះហើយ
ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ
ក៏អាស្រ័យនូវព្យាយាម ជាគ្រឿងដុតកម្តៅកិលេស អាស្រ័យនូវព្យាយាមជា
គ្រឿងតម្កល់មាំ អាស្រ័យនូវព្យាយាមជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវ

សេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកជាក់ល្អ ក៏បានចេតោ-
សមាធិតាមបែបនៃចិត្តរបស់ព្រះយោគី ដែលតាំងនៅខ្ជាប់ខ្ជួនដោយសមាធិ
ហើយរឭកនូវខន្ធដែលសត្វអាស្រ័យនៅហើយក្នុងកាលមុននោះ កំណត់ត្រឹម
តែអត្តភាពជាព្រហ្មនោះប៉ុណ្ណោះ មិនអាចរឭកឃើញនូវខន្ធហួសអំពីនោះ
បានឡើយ ។ សត្វនោះឯងនិយាយយ៉ាងនេះថា ព្រហ្មដ៏ចម្រើនណា ជាមហា
ព្រហ្ម គ្របសង្កត់នូវសត្វឯទៀតៗ សត្វឯទៀតៗ មិនអាចគ្របសង្កត់លើបាន
ជាអ្នកឃើញនូវហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន
ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វ
លោក ជាអ្នកចាត់ចែងលោក ជាអ្នកស្ងាត់ជំនាញ ជាបិតារបស់ពួកភូត និង
ភព្យៈ ។ ព្រហ្មដ៏ចម្រើនណា ជាអ្នកតាក់តែងនូវយើងទាំងឡាយ ព្រហ្មនោះ
ឯង ជាអ្នកទៀងទាត់ បឋមថេរ មានអាយុវែង មានសេចក្តីមិនប្រែប្រួលជា
ធម្មតា តែងឋិតនៅដូចជាសស្សតិវត្តយ៉ាងនោះឯង ។ ចំណែកយើងទាំង-
ឡាយណា ដែលព្រហ្មដ៏ចម្រើននោះ បានតាក់តែងហើយ យើងទាំងឡាយ
នោះ ជាអ្នកមិនទៀងទាត់ឋិតថេរទេ មានអាយុខ្លី មានកិរិយាច្យុតជាធម្មតា
ទើបបានមកកាន់អត្តភាពជាមនុស្សនេះ ។ តថាគតសួរសមណព្រាហ្មណ៍ទាំង
នោះថា ម្នាលអ្នកមានអាយុដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយបញ្ញត្តនូវ
ច្បាប់ទម្លាប់ ជាអាចរិយវាទ ដែលព្រះឥសូរតាក់តែងហើយ ព្រះព្រហ្មតាក់
តែងហើយ មានប្រការយ៉ាងនេះឬ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ បាន
ឆ្លើយតបយ៉ាងនេះថា នែអាវុសោគោតម ព្រះគោតមមានអាយុពោលយ៉ាង

ណា យើងទាំងឡាយ ក៏បានឮមកយ៉ាងនោះដែរ ។ ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទម្លាប់ផង ។ សេចក្តីបង្រួញ ។ កាលដែលតថាគតបានដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តីវិនាសឡើយ ។

[๑๔] ម្នាលភគ្គវៈ មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវច្បាប់ទម្លាប់ ជាអាចរិយវាទ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូល (អ្នកវិនាសខ្លួនព្រោះល្បែង) តថាគតក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ បានឮថា ពួកអ្នកបញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូល ពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ច្រាប់ថា ព្រះករុណាព្រះអង្គដូច្នេះ ទើបតថាគតសួរសមណព្រាហ្មណ៍ទាំងនោះទៀតយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទម្លាប់ ជាអាចរិយវាទ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូល តើមានប្រការដូចម្តេចខ្លះ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរហើយ ក៏ឆ្លើយមិនរួច កាលបើឆ្លើយមិនរួច ក៏ត្រឡប់សួរមកតថាគតវិញ លុះសមណព្រាហ្មណ៍ទាំងនោះសួរតថាគតហើយ តថាគតក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានពួកទេវតាឈ្មោះខិឌ្ឌាបទោសិកា ទេវតាទាំងនោះជាអ្នកខ្វល់ខ្វាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយ និងល្បែងជាធម្មតា ហួសវេលា កាលទេវតាទាំងនោះ កំពុងតែខ្វល់ខ្វាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយ និងល្បែងជាធម្មតា ហួសវេលាហើយ សតិក៏ភ្លេចវង្វេង

ទៅ (ខានបរិភោគអាហារ) កាលបើសតិក្លេចវង្វេងហើយ ទេវតាទាំងនោះ ក៏ច្យុតចាកកាយនោះមក ។ ម្នាលអាវុសោទាំងឡាយ ហេតុនោះតែងមានប្រាកដត្រង់ថា សត្វណាមួយច្យុតចាកកាយនោះ បានមកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ ក៏អាស្រ័យនូវព្យាយាមជាគ្រឿងដុតកម្ដៅ (កិលេស) អាស្រ័យនូវព្យាយាមជាគ្រឿងតម្កល់មាំ អាស្រ័យនូវព្យាយាមជាគ្រឿងប្រកប អាស្រ័យនូវសេចក្ដីមិនធ្វេសប្រហែស អាស្រ័យនូវការធ្វើទុកក្នុងចិត្តដោយល្អ ក៏បាននូវចេតោ-សមាធិ តាមបែបនៃចិត្តរបស់ព្រះយោគី ដែលតាំងនៅខ្ជាប់ខ្ជួនដោយសមាធិ ហើយរឭកឃើញនូវខន្ធ ដែលសត្វអាស្រ័យនៅហើយក្នុងកាលមុននោះ កំណត់ត្រឹមតែអត្តភាពជាព្រហ្មនោះប៉ុណ្ណោះ មិនអាចរឭកឃើញនូវខន្ធហួសអំពីនោះទៅបានឡើយ ។ សត្វនោះឯង និយាយយ៉ាងនេះថា ទេវតាទាំង-ឡាយដ៏ចម្រើនណា មិនមែនឈ្មោះវិឌ្ឍបទោសិកា ទេវតាទាំងនោះជាអ្នកមិនខ្វល់ខ្វាយក្នុងសេចក្ដីត្រេកអរ ក្នុងការសើចសប្បាយ និងល្បែង ជាធម្មតាហួសវេលាឡើយ កាលដែលទេវតាទាំងនោះ មិនខ្វល់ខ្វាយក្នុងសេចក្ដីត្រេកអរ ក្នុងការសើចសប្បាយ និងល្បែងជាធម្មតា ហួសវេលាទេ សតិក៏មិនក្លេចវង្វេង កាលបើសតិមិនក្លេចវង្វេងហើយ ទេវតាទាំងនោះក៏មិនច្យុតចាកកាយនោះឡើយ ជាទេវតាទៀងទាត់ឋិតថេរ មានអាយុវែង មានសេចក្ដីមិនប្រែប្រួលជាធម្មតា តែងឋិតនៅដូចជាសស្សតិវត្ត ។ ចំណែកយើងទាំងឡាយណា

ជាវិឌ្ឌាបទោសិកា យើងទាំងនោះ ជាអ្នកខ្ងល់ខ្ងាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយ និងល្បែងជាធម្មតាហួសវេលា កាលដែលយើងទាំងនោះ កំពុងខ្ងល់ខ្ងាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយ និងល្បែងជាធម្មតាហួសវេលាហើយ សតិក៏ភ្លេចវង្វេងទៅ កាលបើសតិភ្លេចវង្វេងហើយ ពួកយើងទាំងនោះ ក៏ច្យុតចាកកាយនោះ ជាទេវតាមិនទៀងទាត់ មិនឋិតថេរ មានអាយុតិច មានកិរិយាច្យុតជាធម្មតា បានជាមកកាន់អត្តភាពជាមនុស្សនេះ ។ តថាគតសួរសមណព្រាហ្មណ៍ទាំងនោះថា នែអ្នកមានអាយុទាំង-ឡាយ ចុះអ្នកទាំងឡាយ បញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ មានទេវតាឈ្មោះវិឌ្ឌាបទោសិកាជាមូល មានប្រការយ៉ាងនេះឬ ។ សមណព្រាហ្មណ៍ទាំងនោះ បានឆ្លើយតបយ៉ាងនេះថា ម្នាលអាវុសោគោតម ព្រះគោតមមានអាយុពោលយ៉ាងណា យើងទាំងឡាយក៏បានព្ថមកយ៉ាងនោះដែរ ។ ម្នាលភគ្គវ: តថាគតដឹងច្បាស់នូវច្បាប់ទម្លាប់ផង ។បេ។ កាលដែលតថាគតដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ មិនដល់នូវសេចក្តីវិនាសឡើយ ។

[១៥] ម្នាលភគ្គវ: មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ មានទេវតាឈ្មោះមនោបទោសិកាជាមូល (អ្នកវិនាសខ្ជូនព្រោះចិត្ត) តថាគតបានចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ ព្ថថាអ្នកទាំងឡាយ បញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ មានទេវតាឈ្មោះមនោបទោសិកាជាមូល ពិតមែនឬ ។ ឯសមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ព្រះ

ករុណាព្រះអង្គដូច្នេះ ទើបតថាគតសួរសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះ ទៀតថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទម្លាប់ ជាអាចរិយវាទ មានទេវតាឈ្មោះ មនោបទោសិកាជាមូល តើមានប្រការដូច ម្តេចខ្លះ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរហើយ ក៏ឆ្លើយដោះ មិនរួច កាលបើឆ្លើយដោះមិនរួចហើយ ក៏ត្រឡប់សួរមកតថាគតវិញ លុះ សមណព្រាហ្មណ៍ទាំងនោះសួរមកតថាគតៗ ក៏ព្យាករថា ម្នាលអាវុសោទាំង-ឡាយ មានពួកទេវតាឈ្មោះមនោបទោសិកា ពួកទេវតាទាំងនោះសម្លក់រិះគន់ គ្នានិងគ្នាហួសវេលា កាលពួកទេវតាទាំងនោះ សម្លក់រិះគន់គ្នានឹងគ្នាហួស វេលាហើយ ក៏ធ្វើចិត្តឲ្យប្រទូស្តដល់គ្នា និងគ្នាទៀត ទេវតាទាំងឡាយនោះ លុះមានចិត្តប្រទូស្តដល់គ្នា និងគ្នាហើយ ក៏លំបាកកាយ លំបាកចិត្ត ទេវតា ទាំងនោះ ក៏ច្យុតចាកកាយនោះមក ម្នាលអាវុសោ ហេតុនោះតែងមានប្រាកដ ត្រង់ថា សត្វណាមួយ ច្យុតចាកកាយនោះ ហើយមកកាន់អត្តភាពជាមនុស្ស នេះលុះបានមកកាន់អត្តភាពជាមនុស្សហើយ ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ ក៏អាស្រ័យនូវព្យាយាមជាគ្រឿង ដុតកម្តៅ (កិលេស) ។បេ។ ក៏បាននូវចេតោសមាធិ តាមប៉ែបនៃចិត្តរបស់ យោគី ដែលតាំងនៅខ្ជាប់ខ្ជួនដោយសមាធិ ក៏រឭកឃើញនូវខន្ធដែលសត្វ អាស្រ័យនៅហើយក្នុងកាលមុននោះ កំណត់ត្រឹមតែអត្តភាពជាព្រហ្មនោះ ប៉ុណ្ណោះ មិនអាចរឭកឃើញនូវខន្ធ ហួសអំពីនោះទៅទៀតបានឡើយ ។ សត្វនោះបាននិយាយយ៉ាងនេះថា ពួកទេវតាដ៏ចម្រើនណា ដែលមិនមែន

ឈ្មោះថា មនោបទោសិកាទេ ទេវតាទាំងនោះមិនសម្លក់រិះគន់គ្នានិងគ្នាហួសវេលាហើយ ក៏មិនបានធ្វើចិត្តឲ្យប្រទូស្តជល់គ្នានិងគ្នា ទេវតាទាំងនោះ លុះមានចិត្តមិនបានប្រទូស្តជល់គ្នានិងគ្នាហើយ ក៏មិនលំបាកកាយ មិនលំបាកចិត្ត ទេវតាទាំងនោះ ក៏មិនច្យុតចាកកាយនោះឡើយ ជាទេវតាទៀងទាត់ ឋិតថេរ មានអាយុវែង មានសេចក្តីមិនប្រែប្រួលជាធម្មតា តែងតាំងនៅដូចជាសស្សតិវត្តុ ។ ចំណែកយើងទាំងឡាយណា ឈ្មោះថា មនោបទោសិកាទេវតាយើងទាំងនោះ បានសម្លក់រិះគន់គ្នានិងគ្នាហួសវេលា កាលដែលយើងទាំងនោះ សម្លក់រិះគន់គ្នានិងគ្នាហួសវេលាហើយ ក៏បានធ្វើចិត្តឲ្យប្រទូស្តជល់គ្នានិងគ្នាទៀត លុះដល់យើងទាំងនោះ មានចិត្តប្រទូស្តជល់គ្នានិងគ្នាហើយ ក៏លំបាកកាយ លំបាកចិត្ត យើងទាំងឡាយក៏ច្យុតចាកកាយនោះ ដោយអាការយ៉ាងនេះឯង ជាទេវតាមិនទៀងទាត់ មិនឋិតថេរ មានអាយុតិច មានការច្យុតជាធម្មតា បានជាមកកាន់អត្តភាពជាមនុស្សនេះ ។ តថាគតសួរពួកសមណព្រាហ្មណ៍ទាំងនោះថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទម្លាប់ជាអាចរិយវាទ មានទេវតាឈ្មោះមនោបទោសិកាជាមូលមានប្រការយ៉ាងនេះឬ ។ សមណព្រាហ្មណ៍ទាំងនោះបានឆ្លើយតបយ៉ាងនេះថា ម្នាលអាវុសោគោតម ព្រះគោតមមានអាយុពោលយ៉ាងណា យើងទាំងឡាយក៏បានឮមកយ៉ាងនោះដែរ ។ ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទម្លាប់ផង ។បេ។ កាលដែលតថាគតដឹងច្បាស់ នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តីវិនាសឡើយ ។

[๑๖] *ម្នាលភគ្គវៈ មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តច្បាប់ទម្ងាប់ជាអាចរិយវាទ ដែលកើតឡើងដោយមិនអាស្រ័យហេតុ តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ ឮថាអ្នកទាំងឡាយ បញ្ញត្តច្បាប់ទម្ងាប់ជាអាចរិយវាទ ដែលកើតឡើងដោយមិនអាស្រ័យហេតុ ពិតមែនឬ ។ ឯសមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ ដូច្នេះហើយ ទើបតថាគតសួរយ៉ាងនេះ ទៅសមណព្រាហ្មណ៍ទាំងនោះទៀតថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទម្ងាប់ជាអាចរិយវាទ ដែលកើតឡើងដោយមិនអាស្រ័យហេតុ តើមានប្រការដូចម្តេចខ្លះ ។ ឯសមណ-ព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរហើយ ក៏ឆ្លើយដោះមិនរួច កាលបើឆ្លើយដោះមិនរួចហើយ ក៏ត្រឡប់សួរមកតថាគតវិញ លុះសមណព្រាហ្មណ៍ទាំងនោះសួរ តថាគតក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានទេវតាឈ្មោះអសញ្ញីសត្វ គឺសត្វមិនមានសញ្ញា ទេវតាទាំងនោះ លុះមានសញ្ញាកើតឡើងហើយ ក៏ច្យុតចាកកាយនោះ ។ ម្នាលអាវុសោទាំងឡាយ ហេតុនោះតែងមានប្រាកដត្រង់ថា សត្វណាមួយ ច្យុតចាកកាយនោះហើយ មកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ អាស្រ័យនូវព្យាយាមជាគ្រឿងដុតកម្ដៅ (កិលេស) អាស្រ័យនូវព្យាយាមជាគ្រឿងតម្កល់មាំ ។បេ។ ក៏បាននូវចេតោសមាធិ តាមបែបនៃចិត្តរបស់យោគី ដែល*

តាំងនៅខ្ជាប់ខ្ជួនដោយសមាធិ ហើយក៏រឭកឃើញត្រឹមកំណត់កាល ដែលមានសញ្ញាកើតឡើងហើយនោះ មិនអាចរឭកឃើញ ឲ្យហួសអំពីនោះបានឡើយ ។ សត្វនោះក៏និយាយយ៉ាងនេះថា ខ្ជួន និងលោកកើតឡើង ដោយមិនអាស្រ័យហេតុ ការពោលដូច្នេះ តើព្រោះហេតុអ្វី ព្រោះថាអាត្មាអញក្នុងកាលមុននោះក៏មិនបានកើតជាសត្វអ្វីទេ កើតតែក្នុងកាលឥឡូវនេះឯង តទៅមុខទៀតក៏មិនបានកើតដែរ ត្រឡប់ទៅជាស្ងប់រម្ងាប់ ។ តថាគតសួរសមណ-ព្រាហ្មណ៍ទាំងនោះថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយ បញ្ញត្តច្បាប់ទម្ងាប់ជាអាចរិយវាទ ដែលកើតឡើងដោយមិនអាស្រ័យហេតុ មានប្រការយ៉ាងនេះឬ ។ សមណព្រាហ្មណ៍ទាំងនោះ បានឆ្លើយតបយ៉ាងនេះថា នែអាវុសោគោតម ព្រះគោតមមានអាយុពោលយ៉ាងណា យើងទាំងឡាយក៏បានឮមកយ៉ាងនោះដែរ ។ ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទម្ងាប់ផង ដឹងច្បាស់នូវគុណវិសេស លើសលុបជាងនោះផង កាលដែលតថាគតដឹងច្បាស់នូវធម៌នោះហើយ ក៏មិនបានប្រកាន់ខុសឡើយ ។ កាលតថាគតមិនបានប្រកាន់ខុសហើយ ទើបដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសចំពោះខ្ជួនឯង កាលដែលតថាគតដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តីវិនាសឡើយ ។

[๑๗] ម្នាលភគ្គវៈ សមណព្រាហ្មណ៍ពួកមួយ ពោលបង្កាច់តថាគតដែលមានវាទៈយ៉ាងនេះ ជាអ្នកប្រាប់យ៉ាងនេះ ដោយពាក្យមិនមាន ជាពាក្យទទេ ជាពាក្យកុហកមិនពិតថា ព្រះសមណគោតម និងពួកភិក្ខុ មានសេចក្តី

សម្គាល់ខុស ព្រោះព្រះសមណគោតម និយាយយ៉ាងនេះថា សម័យណា យោគីបានដល់នូវសុភវិមោក្ខ (វណ្ណកសិណ) សម័យនោះ យោគីរមែងដឹងច្បាស់នូវរបស់ទាំងពួងដែលល្អក្តី មិនល្អក្តី ថាជារបស់មិនល្អតែមួយយ៉ាង ។ ម្នាលភគ្គវៈ តថាគតឥតបានពោលយ៉ាងនេះថា សម័យណាយោគីបានដល់នូវសុភវិមោក្ខ សម័យនោះ យោគីរមែងដឹងច្បាស់នូវរបស់ទាំងពួងដែលល្អក្តី មិនល្អក្តី ថាជារបស់មិនល្អ តែមួយយ៉ាងដូច្នេះទេ្បីយ ។ ម្នាលភគ្គវៈ តថាគតតែងនិយាយយ៉ាងនេះថា សម័យណា យោគីបានដល់នូវសុភ-វិមោក្ខ សម័យនោះ យោគីរមែងដឹងច្បាស់ថា ជារបស់ល្អតែមួយយ៉ាង ដូច្នេះទេតើ ។ ភគ្គវគោត្របរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សមណព្រាហ្មណ៍ទាំងឡាយណា ជុតកម្តៅព្រះមានព្រះភាគ និងពួកភិក្ខុថា ជាអ្នកមានសេចក្តីសម្គាល់ខុស សមណព្រាហ្មណ៍ទាំងឡាយនោះ ជាបុគ្គលមានសេចក្តីសម្គាល់ខុសវិញទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គលជ្រះថ្លាចំពោះព្រះមានព្រះភាគ ដោយប្រការដូច្នេះ ដ្បិតព្រះមានព្រះភាគអាចសម្តែងធម៌ប្រោសខ្ញុំព្រះអង្គ ដោយអាការដែលធ្វើខ្ញុំព្រះអង្គឲ្យបានដល់នូវសុភវិមោក្ខបាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភគ្គវៈ ការដែលអ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចរិយវាទក្នុងទីដទៃ កម្រនឹងបានដល់នូវសុភវិមោក្ខនុ៎ះក្រៃពេក ម្នាលភគ្គវៈ ណ្ហើយចុះ សេចក្តីជ្រះថ្លាណារបស់អ្នកចំពោះតថាគត ចូរអ្នកពេញចិត្តរក្សាតែសេចក្តីជ្រះថ្លានោះឲ្យល្អ

ចុះ ฯ ភគ្គវគោត្របរិព្វាជកក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចរិយាទក្នុងទីដទៃ កម្រនឹងបានដល់នូវសុភវិមោក្ខនុ៎ះពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីជ្រះថ្លាណារបស់ខ្ញុំព្រះអង្គចំពោះព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រុងរក្សាតែសេចក្តីជ្រះថ្លានោះឯងឲ្យប្រពៃ ฯ ព្រះមានព្រះភាគ បានត្រាស់សម្តែងសេចក្តីនោះចប់ហើយ ฯ ភគ្គវគោត្របរិព្វាជក ក៏មានចិត្តរីករាយត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ฯ

ជាតិកសូត្រទី ๑ ចប់

អដ្ឋកថា

ចាតិកសូត្រ

[១] បាដិកសូត្រមានពាក្យផ្ដើមថា **ឯវំមេ្ម សុតំ ។ បេ។ មល្លេសុ វិហរតិ ។** ក្នុងបាដិកសូត្រនោះ នឹងបានអធិប្បាយសេចក្ដីតាមលំដាប់បទដូច្នេះ បទថា **មល្លេសុ វិហរតិ** មានពាក្យអធិប្បាយថា សូម្បីជនបទមួយកន្លែង ដែលជាទីស្នាក់អាស្រ័យរបស់បណ្ដាមល្លរាជកុមារ អ្នកមាននិវាសដ្ឋាននៅក្នុងជនបទ ក៏ហៅថា **មល្ល** ព្រោះបន្ថែមសព្ទចូលមក (ព្រះមានព្រះភាគប្រថាប់នៅ) ក្នុងជនបទមួយកន្លែងនោះ ក្នុងបណ្ដាមល្លជនបទទាំងឡាយ ។ បទថា **អនុប្បិយំ នាម មល្លានំ និគមោ** មានពាក្យអធិប្បាយដូច្នេះថា មាននិគមជនបទរបស់អ្នកមល្លៈមួយកន្លែង ឈ្មោះថា **អនុប្បិយ** ព្រះមានព្រះភាគប្រថាប់នៅក្នុងជង់ព្រៃមួយកន្លែង ដល់ព្រមដោយម្លប់ និងទឹក អាស្រ័យអនុប្បិយនិគមជនបទនោះ ជាគោចរគ្រាម ។ បាលីកន្លែងខ្លះជា **អនោបិយ** ក៏មាន ។ បទថា **បាវិសិ** គឺទ្រង់បានចូលទៅហើយ ។ មួយទៀត នឹងពោលថា ព្រះមានព្រះភាគទ្រង់យាងចូលទៅស្រេចហើយ មិនត្រូវពោលថា ទ្រង់ត្រូវយាងចូលទៅម្ដងទៀត ព្រោះថា សូម្បីទ្រង់យាងចេញមកហើយ ក៏ទ្រង់នៅមានព្រះបំណងនឹងយាងចូលទៅទៀត ។ មានឧបមាដូច្នេះ ។ ដូចបុរសម្នាក់ចេញពីស្រុកបំណងនឹងទៅកាន់ស្រុកមួយទៀត ដើរផ្លូវមិនទាន់ដល់ស្រុកនោះ កាលមានពាក្យសួរថា បុរសម្នាក់នេះនៅទីណា ក៏ត្រូវឆ្លើយថា គេទៅស្រុកនោះហើយ សេចក្ដីនេះមានឧបមាយ៉ាងណា ក៏មានឧបមេយ្យដូច្នោះដែរ ។

បទថា **ឯតទេហោសិ** គឺព្រះរាជតម្រិះនេះបានកើតឡើងហើយ កាលព្រះមានព្រះភាគប្រថាប់ឈរជិតស្រុក និងទតមើលព្រះអាទិត្យ ។ បទថា **អតិប្បតោ ខោ** ប្រែថា ដូចជានៅព្រឹកពេក មនុស្សក្នុងត្រកូលទាំងឡាយ ដាំបបរមិនទាន់ឆ្អិន ។ មានពាក្យសួរថា ព្រះមានព្រះភាគទ្រង់មិនជ្រាបវេលាឬ ទើបទ្រង់ចេញទៅ មានពាក្យឆ្លើយថា ព្រះអង្គទ្រង់មិនជ្រាបវេលាចេញទៅ ក៏មិនមែនដែរ ។ ព្រោះក្នុងវេលាព្រឹក ព្រះមានព្រះភាគទ្រង់ផ្សាយសំណាញ់ញាណ ពិចារណាមើលសត្វលោក ទតឃើញឆន្នបរិព្វាជក ភគ្គវគោត្រ ចូលទៅប្រាកដក្នុងសំណាញ់ព្រះញាណ ទ្រង់ជ្រាបច្បាស់ថា ក្នុងថ្ងៃនេះ តថាគតនឹងនាំហេតុដែលតថាគតបានបំពេញមកក្នុងកាលមុន សម្តែងធម៌ដល់បរិព្វាជកនោះ ធម្មកថានឹងមានផល ព្រោះបរិព្វាជកនោះ បានន្ទូវសេចក្តីជ្រះថ្លាក្នុងតថាគត ទ្រង់មានព្រះបំណងនឹងយាងចូលទៅកាន់អារាមរបស់បរិព្វាជក ទើបយាងចេញទៅអំពីព្រលឹម ព្រោះដូច្នោះ ទើបទ្រង់កើតមានព្រះតម្រិះយ៉ាងនេះ ព្រោះមានព្រះរាជបំណងនឹងយាងចូលទៅ ក្នុងអារាមរបស់ឆន្នបរិព្វាជកនោះ ។

បទថា **ឯតទេវោច** មានពាក្យអធិប្បាយដូច្នេះថា ឆន្នបរិព្វាជកឃើញ ព្រះមានព្រះភាគហើយ មិនបានសម្តែងអាការរឹងត្អឹង ព្រោះមានមានះ បានស្វាគមន៍ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់មកជាដើម ។ បទថា **ឥមំ បរិយាយំ** បានដល់ វារៈនេះ អធិប្បាយថា វារៈដែលទ្រង់យាងមកនេះក្នុងថ្ងៃនេះ ។ កាលមុន ព្រះមានព្រះភាគទ្រង់ធ្លាប់បានយាងទៅក្នុងអារាមរបស់ឆន្នបរិព្វាជកនោះខ្លះឬ ។ ទ្រង់មិនធ្លាប់ទៅឡើយ ។

តែបរិព្វាជកបានក្រាបទូលយ៉ាងនោះ ព្រោះអនុលោមតាមវោហារបស់សត្វលោកទាំងឡាយ ។ ព្រោះសត្វលោកទាំងឡាយបានឃើញអ្នកដែលខ្ជិនពេញចិត្ត ទោះធ្លាប់មកយូរហើយក្តី មិនធ្លាប់មកសោះក្តី រមែងពោលពាក្យជាដើមថា លោកដ៏ចម្រើន លោកមកពីណា អស់កាលយូរណាស់ហើយដែលលោកដ៏ចម្រើនបានមកទីនេះទៀត លោកដឹងផ្លូវមកទីនេះបានដូចម្តេច លោកវង្វេងផ្លូវមកឬជាដើម ព្រោះដូច្នោះ គប្បីជ្រាបថា ឆន្នបរិព្វាជកនេះបានពោលយ៉ាងនេះ ព្រោះអនុលោមតាមលោកវោហារ ។ ប្រយោគថា **ឥទមាសនំ** *សេចក្តីថា បរិព្វាជកបានពោលយ៉ាងនោះ ព្រមទាំងចង្អុលប្រាប់អាសនៈដែលខ្ជិនអង្គុយ ។*

បទថា **សុនក្ខត្តោ លិច្ឆវិបុត្តោ** *បានដល់ ព្រះរាជឱរសរបស់ក្សត្រលិច្ឆវី ព្រះនាមថា សុនក្ខត្ត ។ បានឮថា ព្រះរាជឱរសអង្គនោះ កាលនៅជាគ្រហស្ថជាសម្ងាញ់របស់ឆន្នបរិព្វាជកនោះ បានយាងមកកាន់សម្នាក់របស់បរិព្វាជកនោះម្តងម្កាល ។*

បទថា **បច្ចក្ខាតោ** *បានដល់ ពោលលា គឺលះបង់ដោយពោលពាក្យយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គសូមលាព្រះមានព្រះភាគហើយ ។*

បទថា **ភគវន្តំ ឧទ្ទិស្ស** *បានដល់ ពោលអាងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែកនឹងព្រះមានព្រះភាគ ។*

បទថា **កោសម្ពោ កំ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា អ្នក*

សូមគប្បីពោលលាជល់អ្នកត្រូវសូម ឬថា អ្នកត្រូវសូមគប្បីពោលលាជល់អ្នកសូម តែអ្នកមិនមែនជាអ្នកសូមផង មិនមែនអ្នកត្រូវសូមផង ម្នាលមោឃបុរស កាលបើដូច្នេះ អ្នកជាអ្នកណា ពោលលាជល់អ្នកណា ។

បទថា **បស្ស មោឃបុរិស** *ប្រែថា ម្នាលមោឃបុរស អ្នកចូរមើល ។ បទថា* **យាវញ្ហេ តេ ឥធំ អបរទ្ធំ** *ប្រែថា រឿងនេះជាកំហុសរបស់អ្នកច្រើនត្រឹមណា ។ ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតលើកទោសដែលមានហើយយ៉ាងនេះថា អ្នកមានកំហុសត្រឹមណា ក៏មានទោសត្រឹមនោះ ។*

[๒] *បទថា* **ឧត្តរិមនុស្សធម្មា** *គឺធម៌ដ៏ប្រសើរក្រៃលែងបំផុតជាងធម៌របស់មនុស្ស បានដល់ សីល ๕ និងសីល ๑๐ ។ បទថា* **ឥទ្ធិប្បាដិហារិយំ** *បានដល់ បាដិហារ្យដែលជាឫទ្ធិ ។ បទថា* **កតេ វា** *ប្រែថា បានធ្វើហើយក្តី ។ បទថា* **យស្សត្ថាយ** *បានដល់ ដើម្បីប្រយោជន៍នៃការអស់ទុក្ខណា ។ ដោយបទថា* **សោ ឯយ្យាតិ តក្ការស្ស** *ព្រះមានព្រះភាគត្រាស់សួរថា ធម៌នោះ រមែងទៅ គឺប្រព្រឹត្តទៅដើម្បីការអស់ទុក្ខក្នុងវដ្តៈទាំងពួង បានដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអមតនិព្វាន ដល់អ្នកធ្វើតាមធម៌នោះ គឺអ្នកធ្វើតាមធម៌ ដែលតថាគតបានសម្តែង បានដល់ បុគ្គលដែលបដិបត្តិត្រូវ ។ ឬដោយបទថា* **តត្រ សុនក្ខត្ត** *ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងការឥតប្រយោជន៍នៃបាដិហារ្យថា ម្នាលសុនក្ខត្ត កាលបើធម៌ដែលតថាគតបានសម្តែងហើយនោះ ប្រព្រឹត្តទៅដើម្បីការអស់ទៅនៃទុក្ខដោយប្រពៃដល់អ្នកបដិបត្តិធម៌នោះ ឥទ្ធិប្បាដិហារ្យ ដែលក្រៃលែងជាងធម៌របស់មនុស្ស*

ដែលតថាគតធ្វើហើយ នឹងធ្វើអ្វីបាន គឺមានប្រយោជន៍អ្វី ដោយការធ្វើចាដិហារ្យនោះ ព្រោះសូម្បីតថាគតធ្វើចាដិហារ្យនោះក្តី មិនធ្វើក្តី ការសាបសូន្យនៃពាក្យទូន្មានរបស់តថាគតរមែងមិនមាន សេចក្តីពិត តថាគតបំពេញបារមីមកដើម្បីប្រាថ្នាឲ្យទេវតា និងមនុស្សទាំងឡាយ សម្រេចអមតនិព្វាន មិនមែនប្រាថ្នាដើម្បីធ្វើចាដិហារ្យទេ ហើយទ្រង់លើកទោសទី ២ ថា ម្នាលមោឃបុរស អ្នកចូរឃើញ ។

[๓-๔] បទថា **អគ្គញ្ញំ** គឺបញ្ញត្តិនៃលោក ដែលគប្បីដឹងយ៉ាងនេះថា វត្ថុនេះជាកំពូលក្នុងលោក បានដល់ ការប្រព្រឹត្តដ៏ប្រសើរ ព្រះរាជកុមារត្រាស់ថា ព្រះមានព្រះភាគមិនបញ្ញត្តិវត្ថុដែលលោកសម្មតិថា ប្រសើរនោះ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ គប្បីជ្រាបតាមទំនងវារៈដែលនៅបន្ទាប់នោះឯង ។ បទថា **អនេកបរិយាយេន ខោ** នេះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធឡើង ព្រោះហេតុអ្វី ។ បានឮថា សុនក្ខត្តរាជកុមារទ្រង់បានរអ៊ូរទាំដោយពាក្យដូច្នេះថា អញនឹងលុបលាងគុណរបស់ព្រះមានព្រះភាគ បញ្ឆេះទោសឡើង កាលបានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគ តាំងនៅមិនបាន មិនហ៊ានបន្ទឺវាចា ។ គ្រានោះ ព្រះមានព្រះភាគបានត្រាស់ពាក្យថា **អនេកបរិយាយេន** ជាដើម ដើម្បីទ្រង់សម្តែងទោសក្នុងភាពជាអ្នកលុបគុណថា ម្នាលសុនក្ខត្ត អ្នកតាំងនៅក្នុងភាពជាអ្នកលុបគុណយ៉ាងនេះ នឹងបានទទួលពាក្យតិះដៀលខ្លួនឯងតែម្យ៉ាង ។ បទថា **អនេកបរិយាយេន** ក្នុងព្រះសូត្រនោះ ប្រែថា ដោយបរិយាយមិនមែនតែមួយ ។ បទថា **វជ្ជិគាមេ** បានដល់ វេសាលីនគរ

ដែលជាស្រុករបស់វជ្ជីគណៈ ។ បទថា **ឆោ វិសហិ** *បានដល់ មិនអាច ។ បទថា* **សោ អវិសហាឆ្ពោ** *បានដល់ សុនក្ខត្តរាជកុមារអង្គនោះ ។ ក្នុងកាលមុន ព្រះរាជកុមារអង្គណា កាលគ្រាស់សរសើរព្រះរតនត្រ័យ មាត់មិនគ្រប់គ្រាន់ក្នុងការសរសើរ ឥឡូវនេះ ព្រះរាជកុមារអង្គនោះ ទ្រង់បានប្រើមាត់នោះដូចគ្នា មកតិះដៀលព្រះរតនត្រ័យ ។*

បទថា **អវិសហាឆ្ពោ** *បានដល់ មិនអាចប្រព្រឹត្តព្រហ្មចរិយៈ បានពោលតិះដៀល ព្រោះភាពដែលព្រះអង្គជាបុគ្គលល្ងង់ ហើយវិលមកដើម្បីជាបុគ្គលថោកទាប ចំណែកពួកបុគ្គលអ្នកសរសើរព្រះរតនត្រ័យយ៉ាងនេះថា ព្រះពុទ្ធគ្រាស់ដឹងពិត ព្រះធម៌ដែលព្រះមានព្រះភាគគ្រាស់ពិត ព្រះសង្ឃបដិបត្តិពិត រមែងសម្តែងទោសរបស់អ្នកដោយចំពោះ ។ បទថា* **ឥតិ ខោ តេ** *សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលសុនក្ខត្ត ពួកមនុស្សនឹងពោលតិះដៀលយ៉ាងនេះឯង ។ ព្រោះដូច្នោះ កាលទោសកើតឡើងយ៉ាងនេះ អ្នកមិនអាចនឹងពោលបានថា ព្រះសាស្តាដែលមានព្រះញាណមិនទើសទាក់ក្នុងអតីត និងអនាគត សូម្បីទ្រង់ជ្រាបថា ទោសនឹងកើតដល់យើងយ៉ាងនេះ ក៏មិនគ្រាស់ជាស់តឿនយើងអំពីកាលមុន ។*

បទថា **អបក្កមេវ** *បានដល់ បានចៀសចេញទៅហើយ ។ ឬបានចៀសចេញទៅ អធិប្បាយថា ឃ្លាតចេញទៅ ។ បទថា* **យថា តំ អាចាយិកោ** *អធិប្បាយថា សត្វដែលគួរទៅកើតក្នុងអបាយ សត្វដែលគួរទៅកើតក្នុងនរក គប្បីគេចទៅ គឺបាត់អំពីលោកនេះទៅកើតក្នុងនរក យ៉ាងណា អ្នកក៏បានគេច*

ទៅ គឺបាត់ទៅ ជួញ្ជោះ ។

បទថា **ឯកមិធាហំ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងអ្វី ។ ព្រះអង្គទ្រង់ផ្តើមសូត្រនេះ ដោយពីរបទថា **ចាជិហារិយំ ឆ ករោតិ** និងបទថា **អគញ្ជំ ឆ បញ្ញបេតិ** ។ ក្នុងពីរបទនោះ បទថា **អគញ្ជំ ឆ បញ្ញាបេតិ** នេះ ទ្រង់សម្តែងក្នុងខាងចុងសូត្រ ។ ចំណែកបទថា **ចាជិហារិយំ ឆ ករោតិ** នេះ ទ្រង់បានផ្តើមទេសនានេះ ដោយអំណាចដែលទ្រង់សម្តែងបន្ត ។

បទថា **ឯកមិធាហំ** ក្នុងបាលីនោះ កាត់បទជា **ឯកស្មឹ អហំ** ។ បទថា **សមយំ** បានដល់ ក្នុងសម័យ ។ អធិប្បាយថា ក្នុងកាលមួយ តថាគត ។ បទថា **ថូលស្មុ** អធិប្បាយថា មានជនបទមួយកន្លែង ឈ្មោះថា ថូលុ តថាគតនៅក្នុងជនបទនោះ ។ បទថា **ឧត្តរកា ឆាម** អធិប្បាយថា មានទិគមថូលុជនបទ មានឈ្មោះជាឥត្តលិង្គថា **ឧត្តរកា** ទ្រង់អាស្រ័យទិគមនោះ ជាគោចរគ្រាម ។ បទថា **អចេលោ** បានដល់ អ្នកអាក្រាតកាយ ។ បទថា **កោរក្ខត្តិយោ** បានដល់ ស្តេចដែលមានជើងខ្លែ ។ បទថា **កុក្កុរវត្តិកោ** បានដល់ សមាទានសុនខវត្ត ហិតក្ងិន ស៊ីអាហារ ដេកក្នុងបរិវេណចង្រ្កានជូចឆ្កែ ធ្វើកិរិយារបស់ឆ្កែ សូម្បីដទៃទៀត ។ បទថា **ចតុកោណ្ឌិកោ** គឺវារជើង ៤ បានដល់ ជង្គង់ ២ និងដៃ ២ ច្រត់លើផែនដី គ្រាច់ទៅ ។ បទថា **ឆមានិកណ្ណំ** បានដល់ ដែលរាត់រាយ ដែលគេជាក់ ឬចាក់លើផែនដី ។ បទថា **កក្ខសំ** បានដល់ អាហារ គឺរបស់ទំពា របស់បរិភោគណាមួយ ។ បទថា **មុខេនេវ** គឺមិនបានប្រើដៃចាប់អាហារ ប្រើមាត់តែម្យ៉ាងត្រចាក់អាហារ

ដែលគប្បីទំពា ឬអាហារដែលគប្បីបរិភោគ ក៏ប្រើមាត់តែម្យ៉ាងបរិភោគ ។ បទ ថា **សាធុរូបោ** *បានដល់ មានរូបស្អាត ។ បទថា* **អរហំ សមណោ** *បានដល់ សមណៈដែលជាព្រះអរហន្តមួយអង្គ ។*

សព្ទថា **វត** *ក្នុងបាលីនោះ ត្រឹមតែជានិបាតចុះក្នុងអត្ថនៃសេចក្តីប្រាថ្នា ។ បានឮថា ព្រះរាជកុមារនោះ (សុនក្ខត្តលិច្ឆវិកិក្ខុ) មានសេចក្តីប្រាថ្នាយ៉ាងនេះថា អ្នកបួសដទៃ ដែលនឹងចាត់ថាជាសមណៈ ដូចសមណៈរូបនេះមិនមាន ព្រោះសមណៈរូបនេះមិនស្មៀកសំពត់ ព្រោះជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសម្គាល់ថា វត្តនេះជាហេតុឲ្យកើតសេចក្តីឃឺតឃួរ ទើបមិនប្រើ សូម្បីកាជនៈសម្រាប់ដាក់អាហារ បរិភោគអាហារដែលនៅលើផែនដីប៉ុណ្ណោះ អ្នកបួសរូបនេះចាត់ថាជាសមណៈ ចំណែកពួកយើងនឹងជាសមណៈបានដូចម្តេច ។ សាវ័កអ្នកដើរតាមក្រោយព្រះពុទ្ធជាសព្វញ្ញូយ៉ាងនេះ ក៏មានការនឹកគិតអាក្រក់ ដូច្នេះ ។*

បទថា **ឯតទវោចំ** *អធិប្បាយថា បានឮថា ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា សុនក្ខត្ត អ្នកមានអធ្យាស្រ័យថោកទាបនេះ ជាអ្នកបួសនេះ គិតដូចម្តេចហ្ន៎ កាលទ្រង់ត្រិះរិះយ៉ាងនេះ ទ្រង់ជ្រាបអធ្យាស្រ័យរបស់សុនក្ខត្តៈនោះ ទ្រង់ពិចារណាឃើញថា មោឃបុរសនេះ ដើរតាមក្រោយព្រះសព្វញ្ញូដូចតថាគត បែរជាសម្គាល់អ្នកបួសដែលអាក្រាតកាយ ថាជាព្រះអរហន្ត ឥឡូវនេះ ជនពាលនេះ គួរត្រូវតិះដៀលទោសក្នុងទីនេះឯង ដោយទ្រង់មិនទាន់ត្រឡប់ឡើយ បានត្រាស់បទថា* **ភុំបិ ឆាម** *ជាដើមនេះ ។* **បិ** *សព្ទ ក្នុងបទថា*

តុំបិ ឆាម នោះ ចុះក្នុងអត្ថថា តិះដៀល ។ ព្រោះព្រះមានព្រះភាគ កាលទ្រង់តិះដៀលសុនក្ខត្ត បានត្រាសបទថា **តុំបិ ឆាម** ។ ក្នុងពាក្យនេះ មានពាក្យអធិប្បាយដូច្នេះថា សូម្បីខ្លួនអ្នក មានអធ្យាស្រ័យថោកទាបថ្នាក់នេះ នៅតែប្តេជ្ញាយ៉ាងនេះថា យើងជាសមណៈ ជាសក្យបុត្រទៀតឬ ។ ដោយបទថា **កឹ បន មេ ភន្តេ** សុនក្ខត្តបានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ឃើញវត្ថុដែលគួរតិះដៀលអ្វី ក្នុងខ្លួនរបស់ខ្ញុំព្រះអង្គ ទើបបានត្រាស់យ៉ាងនេះ ។ គ្រានោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់សុនក្ខត្តនោះ បានត្រាស់បទថា **ឆន្ទុ តេ** ជាដើម ។ ដោយបទថា **មច្ចុរាយតិ** នេះ សុនក្ខត្តបានក្រាបទូលសួរថា ព្រះមានព្រះភាគ ទ្រង់ហួងហែងព្រះអរហត្ត ព្រោះទ្រង់ត្រិះរិះយ៉ាងនេះថា អ្នកជនៃចូរកុំបានជាព្រះអរហន្តឬ ។ បទថា **ន ខោ អហំ** អធិប្បាយថា ម្នាលមោឃបុរស តថាគតប្រាថ្នាឲ្យមនុស្សលោកព្រមទាំងទេវលោកបានព្រះអរហន្តទាំងអស់ តថាគតធ្វើកម្មដែលធ្វើបានលំបាកច្រើនណាស់ បំពេញបារមីមក ក៏ដើម្បីប្រយោជន៍យ៉ាងនេះប៉ុណ្ណោះ តថាគតមិនបានហួងហែងអរហត្តទេ ។ បទថា **ចាបកំ ទិដ្ឋិគតំ** អធិប្បាយថា សុនក្ខត្តកើតទិដ្ឋិក្នុងបុគ្គលដែលមិនមែនព្រះអរហន្ត ថាជាព្រះអរហន្ត និងក្នុងបុគ្គលដែលជាព្រះអរហន្តថាមិនមែនព្រះអរហន្ត ។ ព្រះមានព្រះភាគត្រាស់ថា **ចាបកំ ទិដ្ឋិគតំ** សំដៅដល់ទិដ្ឋិដូចពោលមកនោះ ។ បទថា **យំ ខោ បន** បានដល់ អ្នកសម្គាល់អ្នកបួសដែលអាក្រាតកាយរូបនោះយ៉ាងនេះ ។

បទថា **សត្តមំ ទិវសំ** ប្រែថា ក្នុងថ្ងៃទី ៧ ។ បទថា **អលសកេន** បាន

ដល់ ដោយព្យាធិឈ្មោះ អលសកៈ ។ បទថា **កាលំ ករិស្សតិ** ប្រែថា ស្ងាប់ ព្រោះមានពោះប៉ោង ។ បទថា **កាលកញ្ជិកា** ជាឈ្មោះរបស់អសុរ ទាំងនោះ ។ បានព្ថថា អសុរទាំងនោះមានអត្តភាពកម្ពស់ ៣ គាវុត មានសាច់ និងលោហិតតិច ដូចស្ងឹកឈើចាស់ មានភ្នែកលៀនចេញមកជាប់នៅលើ ក្បាលដូចក្តាម មានមាត់ប៉ុនរន្ធម្ជុលជាប់នៅលើក្បាលដូចគ្នា ឧនខ្ជូនចុះ យក មាត់ស៊ីអាហារ ។

បទថា **វីរណតម្ពកេ** អធិប្បាយថា ក្នុងព្រៃជាទីចោលសាកសពនោះ មានសសរគ្របដណ្តប់ដោយស្ស្យូវរណ្តាស ព្រោះដូច្នោះ ទើបហៅព្រៃជាទី ចោលសាកសពនោះថា **វីរណតម្ពក ។** បទថា **តេនុបសង្ពមិ** អធិប្បាយថា កាលព្រះមានព្រះភាគត្រាស់ដូច្នោះ ទ្រង់ចូលទៅបិណ្ឌបាតក្នុងស្រុកនោះ ហើយ យាងទៅវិហារ សុនក្ខត្តចេញពីវិហារចូលទៅរកអ្នកបួសស្រាតនោះ ។ បទថា **យេន ត្វំ** សេចក្តីថា អ្នកត្រូវព្រះមានព្រះភាគទ្រង់ព្យាករ ព្រោះហេតុណា ។ អធិប្បាយថា ព្រោះហេតុដែលលោក ត្រូវព្រះមានព្រះភាគទ្រង់ព្យាករ ។ បទ ថា **មត្តំ មត្តំ** បានដល់ ល្មមគួរដល់ប្រមាណៗ ។ បាលីកន្ងែងខ្ងះថា **មន្ត្តា មន្ត្តា** ក៏មាន អធិប្បាយថា ប្រើបញ្ញាពិចារណា ។ បទថា **យថា សមណស្ស** សេចក្តីថា សុនក្ខត្តបានពោលថា លោកគប្បីធ្វើឲ្យពាក្យពោលរបស់ព្រះ សមណគោតមខុសទៅ ។ កាលសុនក្ខត្តពោលយ៉ាងនេះហើយ អ្នកបួស អាក្រាតដេកក្នុងបរិវេណចង្ក្រានដូចឆ្កែ បានអើតក្បាល បើកភ្នែកមើល ពោល ថា ព្រះសមណគោតម ជាអ្នកចងពៀរ ជាសត្រូវនឹងពួកយើង បាននិយាយ

អ្វី ចាប់តាំងពីព្រះសមណគោតមកើតឡើងមក ពួកយើងមានសភាពដូចជាហ្វូងអំពិលអំពេកក្នុងព្រះអាទិត្យរះ ព្រះសមណគោតម គប្បីពោលវាចាយ៉ាងនេះនឹងពួកយើង ឬពោលយ៉ាងដទៃ តែជាធម្មតាថា ពាក្យរបស់អ្នកដែលជាសត្រូវនឹងគ្នា រមែងមិនពិត លោកចូរចេញទៅចុះ យើងនឹងដឹងក្នុងរឿងនេះឯង ហើយដេកបន្តទៀត ។

បទថា **ឯកឧីហិកាយ** បានដល់ ពោលរាប់ថា មួយពីរ ។ បទថា **យថាតំ** អធិប្បាយថា រាប់ដូចអ្នកខ្វះដែលមិនជឿគប្បីរាប់ និងក្នុង ១ ថ្ងៃ បានចូលទៅរក ៣ ដង ប្រាប់ថា ១ ថ្ងៃកន្ងទៅហើយ ២ ថ្ងៃកន្ងទៅហើយ ។ បទថា **សត្តមំ ឧវសំ** អធិប្បាយថា បានញ្ចថា អ្នកបួសស្រាតនោះ បានស្តាប់ពាក្យរបស់សុនក្ខត្តហើយ មិនបរិភោគអាហារឡើយ រហូតដល់អស់ ៧ ថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ឧបដ្ឋាកម្នាក់របស់អចេលក៍គិតថា ថ្ងៃនេះ ជាថ្ងៃទី ៧ ដែលសមណៈប្រចាំត្រកូលរបស់ពួកយើងមិនមក ប្រហែលជាមានជំងឺ ហើយឲ្យអាំងសាច់ជ្រូក នាំអាហារទៅគរលើផែនដីក្នុងទីចំពោះមុខ ។ អ្នកបួសអាក្រាតក្រឡេកមើលហើយ គិតថា ពាក្យរបស់ព្រះសមណគោតមពិតក្តី កុហកក្តី តែកាលអញបរិភោគឆ្អែតហើយ សូម្បីអញស្ងាប់ក៏សម្គាល់ថា ស្ងាប់ដោយល្អហើយក៏ក្រោកឡើង វារជើង ៤ បរិភោគអាហារដរាបពេញពោះ ។ ក្នុងវេលាកណ្តាលយប់ អចេលក៍មិនអាចនឹងឲ្យអាហាររលួយបាន ទើបអស់ជីវិតដោយរោគឈ្មោះ **អលសក ។** ទោះបីអាចេលមិនទាន់គិតថា មិនបរិភោគតែត្រូវបរិភោគក្នុងថ្ងៃនោះហើយ អស់ជីវិតដោយរោគឈ្មោះអលសក: ។

ព្រោះព្រះតថាគតទាំងឡាយ រមែងមិនមានវាចាបែកជាពីរ ។

បទថា **វីរណត្ថម្ភកេ** *អធិប្បាយថា បានឮថា ពួកតិរ្ថិយជ្រាបដំណឹងថា កោរក្ខត្តិយៈអស់ជីវិតហើយ រាប់ថ្ងៃហើយពោលថា ពាក្យព្យាករបស់ព្រះសមណគោតមក៏ជាពាក្យពិតហើយ ឥឡូវនេះ ពួកយើងនឹងនាំសាកសពគេទៅចោលក្នុងទីដទៃ នឹងគ្របសង្កត់ព្រះសមណគោតម ដោយមុសាវាទ បាននាំគ្នាទៅនាំយកវល្ជិមកចងសាកសព ហើយអូសទៅ ព្រមនឹងពោលថា ចោលសាកសពត្រង់នេះៗ ។ ទីកន្លែងដែលទាញសាកសពទៅនោះ ជាទីទួលទាំងអស់ ។ ទើបពួកគេអូសសាកសពទៅកាន់ព្រៃ ជាទីចោលសាកសពឈ្មោះវីរណត្ថម្ភកៈ ដឹងថា ជាព្រៃស្មសាន ក៏បានអូសសពទៅ តាំងចិត្តថា នឹងនាំទៅចោលក្នុងទីដទៃ ។ រំពេចនោះ វល្ជិទាញសាកសពក៏ជាប់ ។ ពួកគេមិនអាចនឹងឲ្យសាកសពកម្រើកបាន ទើបនាំគ្នាចៀសចេញពីទីនោះទៅ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ពួកមនុស្សបាននាំយកទៅចោលឯព្រៃស្មសាន ដែលមានជើមស្បូវរណ្តាស ។*

បទថា **តេឆុបសង្ឆមិ** *មានពាក្យអធិប្បាយដូច្នេះថា ព្រោះហេតុអ្វី ទើបសុនក្ខត្តលិច្ឆវិបុត្រចូលទៅរក បានឮថា សុនក្ខត្តលិច្ឆវិបុត្រនោះគិតថា ពាក្យពោលរបស់ព្រះសមណគោតមរមែងពិតប្រាកដ ធម្មតាថា អ្នកស្ទាប់នឹងក្រោកឡើងនិយាយនឹងអ្នកដទៃ រមែងមិនមាន ណ្ហើយចុះ អញនឹងទៅសួរ បើព្រះសមណគោតមត្រាស់ប្រាប់ក្តី បើមិនប្រាប់ក្តី អញនឹងគ្របសង្កត់ព្រះសមណគោតមដោយមុសាវាទ ។ សុនក្ខត្តចូលទៅគាល់ព្រោះហេតុនេះ ។ បទ*

ថា **អាកោដ្ដេសិ** ប្រែថា គោះ (ដោយបាតដៃ) ។ មានពាក្យសួរថា សាកសពរបស់អ្នកដែលស្លាប់ហើយ រមែងមិនអាចនឹងក្រោកឡើងមកនិយាយបាន អ្នកបួសអាក្រាតរូបនោះ បានពោលពាក្យថា ម្នាលអ្នកមានអាយុ យើងជីងបានជួបម្តេច ។ មានពាក្យឆ្លើយថា សាកសពនោះនិយាយបានដោយពុទ្ធានុភាព ។ បានឮថា ព្រះមានព្រះភាគបាននាំកោរក្ខត្តិយៈអំពីកំណើតអសុរឲ្យចូលសណ្ឋិតក្នុងសាកសព ហើយឲ្យនិយាយ ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់បានឲ្យសាកសពនោះនិយាយ ។ ព្រោះពុទ្ធវិសយ ជាអចិន្តេយ្យ ។ បទថា **តថេវ តំ វិចាកំ** បានដល់ ផលរបស់វាចានោះ កើតហើយយ៉ាងនោះឯង សព្ទថា **វិចាកំ** នោះ ចាត់ជាលិង្គវិបល្លាស ។ អត្ថដ៏ត្រឹមត្រូវ ក៏គឺ **តថេវ សោ វិចាកោ** ។ ចំណែកអាចារ្យពួកខ្លះពោលថា **វិបក្កំ** ក៏មាន ។ អត្ថ គឺ កើតហើយ ។ គ្រានេះ គួរនឹងបានប្រមូលចាជិហារ្យមក ឯហេតុការណ៍ទាំងអស់នេះ ជាចាជិហារ្យ ៥ យ៉ាង គឺព្រះតម្រាស់ថា អ្នកបួសអាក្រាតនោះ នឹងស្លាប់ក្នុងថ្ងៃទី ៧ ក៏ស្លាប់តាមព្រះតម្រាស់នោះ នេះជាចាជិហារ្យទី ១ ព្រះតម្រាស់ថា នឹងស្លាប់ដោយរោគអលសកៈ ក៏ស្លាប់ដោយរោគអលសកៈពិត នេះជាចាជិហារ្យទី ២ ព្រះតម្រាស់ថា អ្នកបួសអាក្រាតនោះ នឹងទៅកើតក្នុងកពអសុរឈ្មោះកាលកញ្ចិកា ក៏កើតក្នុងកពអសុរពិត នេះជាចាជិហារ្យទី ៣ ព្រះតម្រាស់ថា ពួកតិរ្ថិយនឹងចោលសាកសព ក្នុងព្រៃស្មសានឈ្មោះវីរណត្ថម្ភកៈ ក៏ត្រូវចោលក្នុងព្រៃស្មសាននោះពិត នេះជាចាជិហារ្យទី ៤ ព្រះតម្រាស់ថា នឹងមកអំពីទីដែលខ្លួនកើតហើយ ពោលនឹងសុនក្ខត្តលិច្ឆវិបុត្រ

ក៏ពោលពិត នេះជាបាដិហារ្យទី ៥ ។

[๕] *បទថា* **កច្ឆារមជ្ជកោ** *គឺអ្នកបួសស្រោត ដែលមានធ្មេញ និង ពុកមាត់ដុះចេញមក ឬបទថា* **កច្ឆារមជ្ជកោ** *នេះ ជាឈ្មោះរបស់អ្នកបួស ស្រោតនោះប៉ុណ្ណោះ ។ បទថា* **លាភគ្គប្បត្តោ** *គឺដល់ភាពជាកំពូលដោយ លាភ អធិប្បាយថា ដែលបាននូវលាភដ៏ប្រសើរ ។ បទថា* **យសគ្គប្បត្តោ** *គឺ បាននូវយសដ៏កំពូល សេចក្តីថា មានបរិវារដ៏ច្រើន ។ បទថា* **វត្តបទានិ** *គឺ វត្តបដិបត្តិទាំងអស់ ឬវត្តបដិបត្តិចំណែកខ្លះ ។ បទថា* **សមត្តានិ** *បានដល់ កាន់យក ។ បទថា* **សមាទិន្នានិ** *ជាវេវចនៈរបស់បទថា* **សមត្តានិ** *នុ៎ះឯង ។ បទថា* **បុរត្ថិមេន វេឡាលិ** *បានដល់ ក្នុងទិសខាងកើតជិតក្រុងវេសាលី ។ បទថា* **ចេតិយំ** *គឺជាចេតិយដ្ឋានរបស់យក្ខ ។ គ្រប់ៗ បទ ក៏មានន័យដូច្នេះ ។*

បទថា **យេន អចេលោ** *មានអធិប្បាយថា សុនក្ខត្តលិច្ឆវិបុត្រ ធ្វើវត្ត ព្រះមានព្រះភាគហើយ បានទៅកាន់ទិសដែលអចេលបរិព្វាជក ឈ្មោះថា កច្ឆារមជ្ជកៈនៅ ។ បទថា* **បញ្ហំ បុច្ឆិ** *គឺសួរបញ្ហាដែលប្រកបដោយត្រៃ លក្ខណ៍យ៉ាងជ្រាលជ្រៅ ។ បទថា* **ន សម្បាយាសិ** *អធិប្បាយថា កច្ឆារ- មជ្ជកបរិព្វាជក មិនបានប្រព្រឹត្តទៅដោយញាណគតិ ដែលត្រូវផ្លូវ គាត់ឆ្លើយ ខុសភ្លាំងភ្លាត់ ក្នុងបញ្ហានីមួយៗ នោះ ដូចបុគ្គលខ្វាក់ភ្នែក ដើរអិលដួលក្នុង ទីមិនរាបស្មើ គាត់មើលមិនឃើញខាងដើម ខាងចុងរបស់បញ្ហា ។ ម្យ៉ាងទៀត បទថា* **ន សម្បាយាសិ** *នេះ សេចក្តីថា មិនឲ្យដល់ព្រមដោយបញ្ហា គឺមិន អាចឲ្យបញ្ហាកើតឡើងឆ្លើយបាន កច្ឆារមជ្ជកបរិព្វាជក កាលមិនអាចឆ្លើយ*

បាន ក៏ឈរធ្វើក្អែកវិលទៅមក និយាយថា លោកនៅក្នុងសម្នាក់របស់អ្នក ដែលមិនបានទទួលការសិក្សា បួសក្នុងទីមិនមែនឱកាស ដើរសួរបញ្ហាទូទៅ ចូរចៀសទៅ កុំមកឈរក្នុងទីនេះ ។

បទថា **កោបញ្ច ទោសញ្ច អប្បច្ចយញ្ច ចាគ្វាកាសិ** មានអធិប្បាយដូច្នេះថា កឡ្យាវមជ្ជកបរិព្វាជក បានសម្តែងសេចក្តីក្រោធ គឺអាការកម្រើកទោសៈ មានអាការប្រទូស្ត និងការមិនត្រេកអរ គឺទោមនស្ស ដែលជាអាការនៃការមិនត្រេកអរ ។ បទថា **អាសាឌិយិម្ហសេ** បានដល់ បានរុករាន គឺបៀតបៀន ។ បទថា **មា វត នោ អហោសិ** ប្រែថា ឱហ្ន៎ ប្រការនោះមិនគប្បីមានដល់អញ ។ បាលីថា **មំ វត នោ អហោសិ** ដូច្នេះក៏មាន ។ បណ្តាបទទាំងនោះ បទថា **មំ** ជាទុតិយាវិភត្តិ ប្រើក្នុងអត្តនេជ្ជាវិភត្តិ ។ សេចក្តីថា ប្រការនោះ មានដល់អញហើយហ្ន៎ ឯសុនក្ខត្ត កាលគិតយ៉ាងនោះហើយ ទើបអង្គុយច្រហោង សូមខមាទោសកឡ្យាវមជ្ជកបរិព្វាជកនោះថា បពិត្រលោកដ៏ចម្រើន សូមលោកមេត្តាអត់ទោសដល់ខ្ញុំផងចុះ សូម្បីបរិព្វាជកនោះក៏ពោលថា តាំងអំពីឥឡូវនេះជាដើមទៅ អ្នកនឹងមិនត្រូវសួរបញ្ហាដទៃណាឡើយ ។ សុនក្ខត្តលិច្ឆវិបុត្រពោលថា ខ្ញុំសូមធានាថា នឹងមិនសួរបញ្ហាទៀតបរិព្វាជកនោះពោលថា បើដូច្នោះ លោកចូរទៅ ខ្ញុំអត់ទោសឲ្យដល់លោក ហើយឲ្យសុនក្ខត្តលិច្ឆវិបុត្រទៅ ។

បទថា **បរិហរិតោ** ប្រែថា ស្ទៀកដណ្តប់ សេចក្តីថា ត្រឡប់ស្ទៀកដណ្តប់សំពត់វិញ ។ បទថា **សាឧចារិកោ** សេចក្តីថា ភរិយាលោកហៅថា

អនុចារិកា ។ បុគ្គលដែលមានករិយា លោកហៅ **សានុចារិក** អធិប្បាយថា អចេលក៍ឈ្មោះ កឡារមជ្ជក: លះការប្រព្រឹត្តព្រហ្មចរិយ:នោះៗហើយ មានករិយា ។ បទថា **ឧទនកុម្ភាសំ** បានដល់ បរិភោគបាយខ្ទះ បរិភោគនំខ្ទះ ក្រៃលែងជាង គឺផឹកសុរា និងបរិភោគសាច់សត្ត ។ បទថា **យសា និហីនោ** សេចក្តីថា អាចេលក៍នោះបានន្ទូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរណា ក៏វិនាសចាកលាភ និងយសនោះ ឥទ្ធិបាដិហារ្យដែលជាឧត្តរិមនុស្សធម៌ ឈ្មោះថា ជាគុណដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ព្រោះហេតុនោះ ក្នុងប្រការនេះ គប្បីជ្រាបបាដិហារ្យ ៧ យ៉ាង គឺការឈានព្រះបាទទៅបាន ៧ ជំហាន ។

[៦] បទថា **ចាដិកបុត្តោ** គឺជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះបាដិក: ។ បទថា **ញាណវាទេន** គឺជាមួយញាណវាទ ។ បទថា **ឧបឌ្ឍបថំ** សេចក្តីថា បើក្នុងរវាងពួកយើងគប្បីមាន (ផ្លូវឆ្ងាយ) មួយយោជន៍ ព្រះសមណគោតម គប្បីយាងមកពាក់កណ្តាល យើងក៏គប្បីទៅក្នុងពាក់កណ្តាល ។ ក្នុងផ្លូវ មានកន្ទះយោជន៍ជាដើម ក៏នយនេះ ។ បុគ្គលដែលដើរទៅបាន ១ ជំហាន និងឈ្នះអ្នកមិនបានដើរទៅ អ្នកដែលមិនបានដើរទៅជាអ្នកចាញ់ ។ បទថា **តេ តត្ត** សេចក្តីថា ក្នុងទីជួបគ្នានោះ យើងទាំងពីរនឹងធ្វើឥទ្ធិបាដិហារ្យ ដែលជាឧត្តរិមនុស្សធម៌ ។ បទថា **តទ្ទិគុណំ តទ្ទិគុណាហំ** សេចក្តីថា យើងនឹងធ្វើឲ្យច្រើនជាងនោះជាទ្វេគុណៗ ។ អចេលក៍ឈ្មោះបាដិកបុត្រ សូម្បីជ្រាបសេចក្តីដែលខ្លួនមិនអាចធ្វើបាដិហារ្យ ប្រដែងនឹងព្រះមានព្រះភាគ តែក៏ជ្រាប

ថា អ្នកដែលផ្តើមធ្វើចាជិហារ្យប្រកួតនឹងអគ្គបុរស សូម្បីមិនអាចយកឈ្នះបាន ក៏បានទទួលពាក្យសរសើរ ហើយទើបពោលយ៉ាងនេះ ។ អ្នកនគរស្តាប់ពាក្យនោះហើយ ក៏នាំគ្នាគិតថា ធម្មតាបុគ្គលដែលមិនអាច រមែងមិនប្រកាសយ៉ាងនេះ អចេលកចាជិកបុត្រនេះ នឹងជាព្រះអរហន្តពិត ទើបបាននាំគ្នាធ្វើសក្ការៈ ជាច្រើនដល់គាត់ ។

បទថា **យេនាហន្តេនុបសង្កមិ** សេចក្តីថា បានឮថា សុនក្ខត្តបានឮមកថា អចេលចាជិកបុត្ររមែងពោលយ៉ាងនេះ ។ ពេលនោះ អចេលក៏ឈ្មោះថា ចាជិកបុត្រ បានកើតគំនិតយ៉ាងនេះ ព្រោះមានអធ្យាស្រ័យអាក្រក់ ព្រោះមានការគិតឃើញថោកទាប ។ សុនក្ខត្តធ្វើវត្តព្រះមានព្រះភាគហើយ កាលព្រះមានព្រះភាគទ្រង់ចូលព្រះគន្ធកុដិ ទើបទៅកាន់សម្នាក់អចេលក៏ឈ្មោះចាជិក-បុត្រ ហើយសួរថា បានឮថា លោកពោលពាក្យដូច្នេះឬ ។ អចេលក៏ឆ្លើយថា អើអាវុសោ ខ្ញុំពោល ។ សុនក្ខត្តពោលថា កាលបើដូច្នោះ លោកកុំគិត កុំខ្វាចឡើយ លោកជាអ្នកដែលជិតជិត ចូរនិយាយយ៉ាងនេះរឿយៗ ទៅ ខ្ញុំជាឧបដ្ឋាករបស់ព្រះសមណគោតម រមែងជ្រាបវិស័យរបស់ព្រះអង្គ ព្រះសមណ-គោតមនឹងមិនអាចធ្វើចាជិហារ្យជាមួយលោកបាន ខ្ញុំនឹងប្រាប់ដល់ព្រះសមណ-គោតម ឲ្យកើតសេចក្តីខ្វាច នឹងនាំព្រះអង្គទៅទីដទៃ លោកកុំខ្វាចឡើយ បានលួងលោមអចេលចាជិកបុត្រ ដរាបធូរស្រាលចិត្ត ទើបទៅកាន់សម្នាក់ព្រះមានព្រះភាគ ដោយហេតុនោះ ទើបលោកត្រាស់ថា **យេនាហំ តេនុបសង្កមិ** ។

ក្នុងបទថា **តំ ฯเปฯ** ជាដើមនោះ សេចក្តីថា អចេលចាជិកបុត្រ កាល

ពោលថា ខ្ញុំមិនមែនជាព្រះពុទ្ធទ្បើយ បានដើរនិយាយថា ខ្ញុំជាព្រះពុទ្ធ បានពោលពាក្យមិនពិតទ្បើយ ខ្ញុំមិនមែនជាព្រះពុទ្ធទ្បើយ ឈ្មោះថា លះបង់វាចានោះ អចេលបាដិកបុត្រអង្គុយគិតក្នុងទីកំបាំងភ្នែកថា ខ្ញុំមិនមែនជាព្រះពុទ្ធទ្បើយ រហូតដរាបអស់កាលនោះ បានដើរនិយាយថា ខ្ញុំជាព្រះពុទ្ធ ចាប់ផ្តើមតាំងពីពេលនេះជាដើមទៅ ខ្ញុំមិនមែនជាព្រះពុទ្ធ ឈ្មោះថា លះបង់ការគិតនោះ បាដិកបុត្រ កាលលះបង់ការគិតថា ខ្ញុំមិនមែនជាព្រះពុទ្ធ តែបានប្រកាន់ទិដ្ឋិអាក្រក់ថា ខ្ញុំជាព្រះពុទ្ធ ឯងត្រាច់ទៅអស់កាលប៉ុណ្ណេះ ខ្ញុំលះទិដ្ឋិនេះ ចាប់ពីពេលនេះជាដើមទៅ ឈ្មោះថា លះបង់ទិដ្ឋិនោះ តែបាដិកបុត្រមិនធ្វើយ៉ាងនេះ ទើបលោកពោលថា មិនលះបង់វាចានោះ មិនលះបង់សេចក្តីគិតនោះ មិនលះបង់ទិដ្ឋិនោះ ។ បទថា **វិបតេយ្យ** គឺក្បាលរបស់អចេលក៍នោះ គប្បីដាច់អំពីក ដូចផ្ទែត្នោតទុំជ្រុះចាកទង ឬគប្បីបែកជា ៧ ចម្រៀក ។

បទថា **រក្ខតេតំ** បានដល់ សូមទ្រង់រក្សាព្រះវាចានោះ ។ បទថា **ឯកំសេន** បានដល់ ដោយនិប្បរិយាយ ។ បទថា **ឧជារិតា** ប្រែថា ពោលហើយ ។ បទថា **អចេលោ ច ភន្តេ ចាដិកបុត្តោ** សេចក្តីថា បើអចេល-បាដិកបុត្រពោលហើយ ដោយវាចាដល់ព្រះមានព្រះភាគដោយចំណែកមួយ ដោយប្រការដូច្នេះ ។

បទថា **វិរូបរូបេន** បានដល់ កាឡាខ្ជូន អធិប្បាយថា អចេលក៍ឈ្មោះ បាដិកបុត្រ មកដោយរូប ដែលខុសពីសភាពដើម គឺលះបង់រូបរបស់មនុស្ស មកចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយការកំបាំងខ្ជូន ឬដោយរូបផ្សេងៗ

ដូចរាជសីហ៍ និងខ្ជាជាដើម ។ បទថា **តទស្ស ភគវតោ មុសា** សេចក្តីថា
កាលបើដូច្នោះ ព្រះតម្រាស់របស់ព្រះមានព្រះភាគនោះ គប្បីជាពាក្យកុហក
គឺ (អចេលកឧាដិកបុត្រ) សង្កត់ដោយមុសាវាទ ។ ឧានញ្ចថា ព្រះមាន
ព្រះភាគមិនគប្បីត្រូវគ្របសង្កត់ដោយមុសាវាទដទៃ រៀរតែមុសាវាទប្រការ
នោះ ។ បទថា **ទ្វយតាមិនី** សេចក្តីថា មានព្រះវាចាមិនបែកជាពីរ គឺមាន
ដោយសង្ខេប តែមិនមានន័យដែលជាប្រយោជន៍ ។ បទថា **ទ្វយតាមិនី** នោះ
ជាឈ្មោះវាចាដែលសូន្យទទេចាកប្រយោជន៍ និងមិនមានផល ។

បទថា **អជិតោបិ នាម លិច្ឆវីនំ សេនាបតិ** សេចក្តីថា ឧានញ្ចថា
អជិតៈនោះ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ទ្រង់សោយទិវង្គតហើយ ។
គ្រានោះ ពួកមនុស្សឧានធ្វើឈាបនកិច្ចសពរបស់ទ្រង់ ហើយសួរឧាដិកបុត្រ
ថា សេនាបតីកើតទីណា ឧាដិកបុត្រឆ្លើយថា កើតក្នុងមហានរក ។ ឯ
ឧាដិកបុត្រលុះពោលយ៉ាងនេះហើយ និយាយទៀតថា សេនាបតីរបស់ពួក
លោកមកកាន់សម្នាក់របស់យើង ហើយស្រែកយំថា យើងមិនធ្វើតាមពាក្យ
របស់លោក ជឿក្នុងវាទៈរបស់សមណគោតម ក៏ឧានទៅកើតក្នុងនរកហើយ ។

[៧] ក្នុងបទថា **តេនុបសង្ហមឹ ធិវា វិហារាយ** នេះ សួរថា ព្រោះ
ហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់ថា ដើម្បីធ្វើឧាដិហារ្យ ឆ្លើយថា ព្រោះ
មិនមានហេតុ សូម្បីការប្រឈមមុខដាក់គ្នា រវាងឧាដិកបុត្រនឹងព្រះមានព្រះ
ភាគមិនមាន ការធ្វើឧាដិហារ្យនឹងមានអំពីណា ព្រោះដូច្នោះ ទើបព្រះមានព្រះ
ភាគមិនត្រាស់យ៉ាងនោះ ត្រាស់ថា **ធិវា វិហារាយ** ។

បទថា **គហាបតិនេចនិកា** *បានដល់ គហបតីមហាសាល ។ ពិតហើយ គហបតីទាំងនោះបានសន្សំទ្រព្យ និងស្រូវអង្ករជាច្រើន ព្រោះដូច្នោះ ទើប គហបតីទាំងនោះ លោកហៅថា* **នេចយិកា** *។ បទថា* **អនេកសហាស្សា** *បានដល់ គណនាមិនបានសូម្បីដោយចំនួនពាន់ ។ បានឮថា បុគ្គលដទៃ រឿរ សុនក្ខត្ត រមែងមិនអាចឲ្យបរិស័ទធំប្រជុំគ្នាបានយ៉ាងនេះ ព្រោះហេតុនោះឯង ព្រះមានព្រះភាគបាននាំសុនក្ខត្តត្រាច់ទៅ រហូតអស់កាលប្រមាណប៉ុណ្ណោះ ។ សេចក្តីតក់ស្លុតនៃចិត្ត ឈ្មោះថា* **ភ័យ** *សេចក្តីញាប់ញ័រនៃសរីរៈគ្រប់ចំណែក ឈ្មោះថា* **ឆម្ភិតត្តំ** *ការដែលរោមទាំងឡាយបះឡើង ឈ្មោះថា* **លោមហំសោ** *។ បានឮថា អចេលក៍ឈ្មោះបាដិកបុត្រ គិតថា អញបានពោលពាក្យធំក្រៃលែង ធ្វើខុសជាមួយអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ភាពជាព្រះអរហន្ត ឬហេតុនៃការធ្វើបាដិហារ្យមិនមានខាងក្នុងអញឡើយ ចំណែកព្រះសមណគោតមនឹងធ្វើបាដិហារ្យ កាលបើដូច្នោះ មហាជនឃើញបាដិហារ្យរបស់ព្រះសមណគោតមនោះហើយ នឹងបៀតបៀនដោយគ្រឿងប្រហារ មានកំណាត់ដំបង ដុំដី និងអាជ្ញាជាដើម ដោយពោលថា ឥឡូវនេះ លោកមិនអាចធ្វើបាដិហារ្យបាន ព្រោះហេតុអ្វី ទើបមិនដឹងប្រមាណខ្លួនឯង មកតាំងខ្លួនជាគូប្រយុទ្ធនឹងអគ្គបុគ្គលក្នុងលោក នឹងសម្តែងកិរិយាបៀតបៀន ។ ព្រោះដូច្នោះ សេចក្តីខ្លាច សេចក្តីតក់ស្លុត ឬការព្រឺព្រួចរោម ទើបបានកើតឡើងដល់អចេលក៍នោះ ព្រោះស្តាប់ដំណឹងការប្រជុំគ្នារបស់មហាជន និងការយោងមករបស់ព្រះសាស្តា អចេលកបាដិកបុត្រនោះ ប្រាថ្នានឹងផុតចាកទុក្ខនោះ ទើប

បានទៅអាភមរបស់បរិព្វាជក ឈ្មោះតិណ្ឌុកខាណុ ។ ដើម្បីសម្តែងអត្តនោះ ទើបព្រះធម្មសង្គាហកាចារ្យ ពោលថា **អថ ខោ ភគ្គវ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឧបសង្កមិ** *សេចក្តីថា អចេលក៍ឈ្មោះចាជិកបុត្រ មិនបានចូលទៅរកតែម្យ៉ាង កាលចូលទៅហើយ ក៏ចូលទៅកាន់អាភមរបស់បរិព្វាជកឆ្ងាយបានកន្ទុះយោជន៍ មិនទាន់បានការសប្បាយចិត្ត ទើបចូលទៅផ្លូវផ្នែកខាងចុងបំផុតរបស់អាភម ជ្រើសរើសបានស្ថានទីជាព្រៃមួយកន្លែងខាងចុងអាភម អង្គុយលើផ្ទាំងថ្ម ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា បើអចេលកចាជិកបុត្រនេះជាជនពាលជឿពាក្យរបស់បុគ្គលខ្លះ គប្បីមកក្នុងស្ថានទីនេះសោត បុគ្គលពាលចូរកុំវិនាសឡើយ ទើបទ្រង់អធិដ្ឋានថា ចូរផ្ទាំងថ្មដែលអង្គុយ ជាប់នឹងសរីរៈរបស់អាចេលក៍នោះ ដំណាលគ្នានឹងចិត្តដែលអធិដ្ឋាននោះ ទីអង្គុយបានជាប់នឹងសរីរៈរបស់អាចេលក៍នោះ ។ អចេលកចាជិកបុត្រនោះ ដូចជាត្រូវចងដោយគ្រឿងចង គឺច្រវាក់ធំ និងដូចត្រូវកាត់ជើង ដូច្នោះ ។ បទថា* **អស្សោសិ** *សេចក្តីថា ពួកបរិស័ទនាំគ្នាស្វែងរកអចេលក៍ឈ្មោះចាជិកបុត្រខាងនេះ និងខាងនោះ កាលត្រូវបុរសណាម្នាក់ដើរតាមស្នាមជើងរបស់អចេលក៍ឈ្មោះចាជិកបុត្រ ដឹងទីអង្គុយមកហើយសួរថា ពួកលោកស្វែងរកអ្នកណា ជនទាំងនោះឆ្លើយថា ខ្ញុំស្វែងរកអចេលក៍ឈ្មោះចាជិកបុត្រ បានស្តាប់វាចាដែលបុរសនោះឆ្លើយថា អចេលក៍ឈ្មោះចាជិកបុត្រនោះ អង្គុយនៅក្នុងអាភម បរិព្វាជកឈ្មោះតិណ្ឌុកខាណុ ។ បទថា* **សំសប្បតិ** *បានដល់ ជ្រប់សរិសោ គឺនៅក្នុងអាភមនោះឯង ។ គួទលោកហៅ*

ថា **ចាវឌ្ឍ** ។ បទថា **បរាភូតរូចោ** បានដល់ ជាអ្នកបរាជ័យហើយ គឺ វិនាសហើយ ។

[៨] បទថា **គោយុគេហិ** សេចក្តីថា ទឹមហើយដោយគូនៃគោចំនួនមួយរយ ឬចំនួនមួយពាន់ ។ បទថា **អាវិញ្ជេយ្យាម** ប្រែថា គប្បីទាញមក ។ បទថា **ធិដ្ឋេរំ** បានដល់ គប្បីដាច់ចេញឬ អចេលក៍ឈ្មោះបាដិកបុត្រ គប្បីដាច់ចេញក្នុងទីចង ។

[៩] បទថា **ធារុបត្ថិកន្តេវាសី** បានដល់ ជាសិស្សនៃជាងក្រឡឹងឈើ[1] ។ បានព្ថថា សិស្សនៃជាងក្រឡឹងនោះមានការគិតថា ចូរលើកបាដិហារ្យទុកចុះ ព្រះសមណគោតមពោលថា អចេលក៍ឈ្មោះបាដិកបុត្រនឹងមិនក្រោកឡើងចាកអាសនៈ ណ្ហើយចុះ អញនឹងទៅឲ្យបាដិកបុត្រនោះក្រោកឡើងចាកអាសនៈដោយឧបាយណាមួយ ដោយហេតុត្រឹមតែប៉ុណ្ណោះ ព្រះសមណគោតមក៏នឹងចាញ់ ព្រោះដូច្នោះ ទើបសិស្សនៃជាងក្រឡឹងពោលយ៉ាងនេះ ។ បទថា **សីហស្ស** សេចក្តីថា សីហមិគរាជ មាន ៤ ប្រភេទ គឺសីហតិណរាជ សីហកាឡរាជ សីហបណ្ឌុរាជ និងសីហកេសររាជ ។ បណ្តាសីហរាជទាំងនោះ សីហកេសររាជ បានដល់ ជាសត្វដ៏ប្រសើរ ។ ក្នុងទីនេះ លោកបំណងយកសីហកេសររាជ ។ បទថា **មិគរញ្ញោ** បានដល់ ជាស្តេចនៃសត្វជើង ៤ គ្រប់ប្រភេទ ។ បទថា **អាសយំ** បានដល់ លំនៅ ។ បទថា **សីហនាទំ** គឺបន្ទឺបែបមិនខ្លាច ។ បទថា **គោចរាយ បក្ពមេយ្យំ**

---

[1] លេខយោងបិដកខ្មែរថា ជាកូនសិស្សរបស់អ្នកបួសដែលមានបាត្រឈើ ។

សេចក្តីថា គប្បីត្រាច់ទៅដើម្បីរកអាហារ ។ បទថា **វនំ វនំ** បានដល់ ហ្វូងម្រឹគដែលធាត់ៗ ប្រសើរៗ ។ បទថា **មុទុមំសានិ** បានដល់ សាច់ដែលខ្ចី ។ បាលីថា **មធុមំសានិ** ក៏មាន អធិប្បាយថា សាច់ដែលមានរសឆ្ងាញ់ ។ បទថា **អជ្ឈុបេយ្យុំ** បានដល់ គប្បីចូលទៅ ។ បទថា **សីឃាឆាឧំ ឆឧិតូ** សេចក្តីថា បន្ទឺហើយដោយសេចក្តីករុណា ដែលអាស្រ័យភាពជាអ្នកខ្វាំងក្លារបស់ខ្លួនថា សត្វពួកណាមានកម្លាំងតិច សត្វពួកនោះចូរគេចទៅ ។ បទថា **វិឃាសសំវឌ្ឍោ** សេចក្តីថា ចម្រើនដោយសាច់ដែលជាសំណល់ គឺសុីសាច់ដែលជារំពាពីសត្វដទៃសុីហើយ ចម្រើនធំធាត់ឡើង ។ បទថា **ឆិន្នោ** សេចក្តីថា ធំធាត់ គឺមានរាងកាយធាត់ ។ បទថា **ពលវា** គឺបរិបូណ៌ដោយកម្លាំង ។ បទថា **ឯតទហោសិ** បានដល់ មានហើយ ព្រោះហេតុអ្វី ។ ព្រោះទោសនៃអស្មិមានៈ ។ ក្នុងសេចក្តីនោះ មានអនុបុព្វីកថាដូច្នេះ

បានឮថា ថ្ងៃមួយ សីហរាជនោះ ត្រឡប់ពីទីស្វែងរកអាហារ បានឃើញចចកនោះកំពុងរត់គេច ព្រោះសេចក្តីខ្លាច កើតសេចក្តីករុណា ទើបនិយាយថា សម្លាញ់កុំខ្លាចឡើយ ឈប់សិន អ្នកឈ្មោះអ្វី ។ ចចកឆ្លើយថា ខ្ញុំឈ្មោះជម្ពុកៈ ។ ទើបសីហរាជនិយាយថា ជម្ពុកៈ អ្នកមានវ័យស្មើគ្នា តាំងអំពីនេះទៅ អ្នកអាចឧបដ្ឋាកយើងបានឬ ។ ចចកឆ្លើយថា ខ្ញុំនឹងឧបដ្ឋាកលោក ។ តាំងពីនោះមកចចកនោះក៏ឧបដ្ឋាក (សីហរាជ) ។ សីហរាជ កាលត្រឡប់ពីទីស្វែងរកអាហារ ក៏នាំសាច់មួយដុំធំមកឲ្យ ។ ចចកនោះទំពាសុីដុំសាច់ធំនោះហើយ ក៏នៅលើផែនថ្មក្នុងទីមិនឆ្ងាយ ។ លុះវេលាកន្លងទៅ

២-៣ ថ្ងៃប៉ុណ្ណោះ ចចកនោះក៏ធំធាត់ មានជង្ឃកំ ។ គ្រានោះ សីហរាជនោះ បានពោលនឹងចចកនោះថា នែជម្ពុកៈ អ្នកអាចនិយាយក្នុងវេលាដែលយើងពត់កាយ អ្នកអាចឈរក្នុងទីមិនឆ្ងាយ ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកក្រោធបានឬទេ ។ ចចកឆ្លើយថា អាចលោកម្ចាស់ ។ ក្នុងវេលាដែលសីហរាជពត់កាយ ចចកបានធ្វើតាមដែលបង្គាប់ ព្រោះការធ្វើតាមនោះ ។ ទើបសីហរាជមានអស្មិមានៈយ៉ាងក្រៃលែង ។ ថ្ងៃមួយ កាលចចកចាស់ផឹកទឹកក្នុងស្រះ បានឃើញស្រមោលរបស់ខ្លួន ឃើញរាងខ្លួនធំធាត់ និងដើមកធំ មិនធ្វើទុកក្នុងចិត្តថា អញជាចចកដែលចម្រើនហើយ តែសម្គាល់ថា សូម្បីអញក៏ជាសីហរាជ ទើបបាននិយាយពាក្យនេះនឹងខ្លួនថា នែជម្ពុកៈ ការដែលអត្តភាពនេះរបស់អ្នកឯង បរិភោគសាច់ដែលជាសំណល់អ្នកដទៃ គួរហើយឬ ឯងមិនមែនកូនប្រុសឬ សីហរាជក៏មានជើង ៤ ចង្កូម ២ ត្រចៀក ២ និងមានកន្ទុយ ១ ឯអវយវៈទាំងអស់របស់ឯងក៏មានដូចសីហរាជ ឯងមិនមែនមានកម្លាំងត្រឹមតែកេសរផ្កាតែម្យ៉ាងប៉ុណ្ណោះទេ ។ កាលចចកចាស់គិតយ៉ាងនេះ អស្មិមានៈក៏កម្រើកឡើង ។ គ្រានោះ ចចកចាស់នោះ បានកើតការសម្គាល់ថា **កោ ចាហំ** *ជាដើម ព្រោះទោសនៃអស្មិមានៈនោះ ។*

បណ្តាបទទាំងនោះ បទថា **កោ ចាហំ** *សេចក្តីថា អញ គឺនរណា សីហមិគរាជ គឺនរណា សីហមិគរាជមិនមែនញាតិ មិនមែនជាចៅហ្វាយរបស់អញ អធិប្បាយថា អញនឹងធ្វើការឱនលំទោនដល់សត្វធំធ្វើអ្វី ។ បទថា* **សិគាលកំយេវ** *បានដល់ ស្រែកដូចចចកនុ៎ះឯង ។ បទថា* **កេវណ្ណកំយេវ**

បានដល់ សំឡេងមិនគួរស្រឡាញ់ និងមិនគួរពេញចិត្ត ។ បទថា **កេ ច ឆេវ សិគាលេ** សេចក្តីថា ចចកថោកទាបដូចម្តេច ។ បទថា **កេ បន សីហានាទេ** បានដល់ ការបន្លឺបែបសីហៈដូចម្តេច អធិប្បាយថា ការបន្លឺរបស់ចចក និងរបស់សីហរាជ មានអ្វីជាប់ទាក់ទងគ្នា ។

បទថា **សុគតាបទានេសុ** បានដល់ តាមសិក្ខា ៣ យ៉ាង ដែលជាលក្ខណៈរបស់ព្រះសុគត គឺជាសាសនារបស់ព្រះសុគត ។ ឯព្រះសុគតនោះ ញុំាងជីវិតតាមបែបសិក្ខា ៣ យ៉ាងនោះយ៉ាងណា ។ ពិតហើយ ពុទ្ធសាសនិកជនកាលថ្វាយបច្ច័យ ๔ ចំពោះព្រះសុគតនោះ រមែងថ្វាយដោយគិតថា អញនឹងថ្វាយ (បច្ច័យ ๔) ចំពោះព្រះសម្មាសម្ពុទ្ធ ដែលបរិបូណ៌ដោយគុណមានសីលជាដើម (ចំណែក) អចេលកចាជិកបុត្រនោះ មិនមែនជាព្រះពុទ្ធ កាលបរិភោគបច្ច័យដែលជនកំណត់ថ្វាយព្រះពុទ្ធ ឈ្មោះថា មានជីវិតប្រព្រឹត្តទៅក្នុងសាសនារបស់ព្រះសុគត ។ បទថា **សុគតាតិរិត្តានិ** អធិប្បាយថា បានឮថា ប្រជាជនកាលនឹងថ្វាយភោជនដល់ព្រះពុទ្ធ ពួកទាំងនោះបានថ្វាយដល់ព្រះពុទ្ធ និងសាវ័ករបស់ព្រះពុទ្ធ ពួកទាំងនោះខាងក្រោយ ទើបឲ្យអាហារដែលនៅសល់ក្នុងវេលាល្ងាច ដល់អចេលក៍ឈ្មោះចាជិកបុត្រនេះ ឈ្មោះថាបរិភោគអាហារដែលជាសំណល់ព្រះសុគត ដោយប្រការដូច្នេះ ។ បទថា **តថាគតេ** សេចក្តីថា លោកសម្គាល់ថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាបុគ្គលដែលគប្បីបៀតបៀន គឺគប្បីរុករាន ។ ម្យ៉ាងទៀត បទថា **តថាគតេ** ជាដើម ជាទុតិយាវិភត្តិ ពហុវចនៈ ។ សូម្បីបទថា **អាសាទេតព្វំ** នេះ ក៏ជា

ពហុវចនៈដូចគ្នា លោកពោលថា ដូចជាឯកវចនៈ ។ បទថា **អាសាឌនា** បានដល់ ការបៀតបៀនថា អញនឹងធ្វើបាដិហារ្យជាមួយព្រះពុទ្ធ ។

បទថា **សមេក្ខិយាន** ប្រែថា ពិចារណាហើយ គឺសម្គាល់ហើយ ។ បទថា **អមញ្ញិ** ប្រែថា បានប្រកាន់ខ្ជួន ។ បទថា **កោត្តុ** សំដៅយកចចក ។

[១០] បទថា **អត្តានំ វិយាសេ សមេក្ខិយ** បានដល់ បានឃើញ អត្តភាពធាត់ធំក្នុងទឹកដែលថ្ជា ក្នុងស្រះទឹក ។ បទថា **យាវត្តានំ ន បស្សតិ** សេចក្តីថា រមែងមិនឃើញខ្ជួនតាមសេចក្តីពិតយ៉ាងនេះថា អញជាចចកចាស់ ធំធាត់ឡើងព្រោះសាច់ជាសំណល់របស់សីហមិគរាជ ។ បទថា **ញត្សោតិ មញ្ញតិ** បានដល់ រមែងសម្គាល់ថា អញជាសីហមិគរាជ ឬប្រកាន់ខ្ជួនថា អញមានកម្ជាំងស្មើនឹងសីហៈ ជាខ្ជាធំពិត ។

[១១] បទថា **ភុត្វាន ភេក** បានដល់ ស៊ីកង្កែបតាមអណ្តូង ។ បទថា **ទលមូសិកាយោ** សេចក្តីថា ស៊ីកណ្តុរក្នុងលានស្រូវ ។ បាទគាថាថា **កជសីសុ ទិត្តានិ ច ក្ខណាចានិ** សេចក្តីថា ស៊ីសាកសពដែលគេចោលក្នុងព្រៃស្មសាន ។ បទថា **មហាវនេ** គឺក្នុងព្រៃធំ ។ បទថា **សុញ្ញវនេ** គឺក្នុងព្រៃស្ងាត់ ។ បទថា **វិវឌ្ឍា** គឺធំធាត់ហើយ ។ បទថា **តថេវ សោ សិគាលកំ អនធិ** សេចក្តីថា ចចកនោះ សូម្បីធំធាត់បានយ៉ាងនេះ ក៏នៅសម្គាល់ថា អញជាស្តេចម្រឹគ ក៏ស្រែកដូចឆ្កែចាស់ ដូចជាចចកដែលមិនមានកម្ជាំងក្នុងកាលមុនដូច្នោះ ។ សិស្សរបស់ជាងក្រឡឹង ឈ្មោះជាលិយៈ បានរុករានបាដិកបុត្រនោះហើយថា លោកបរិភោគអាហារដែលជាសំណល់ ហើយជាប់នៅក្នុង

លាភសក្ការៈ ដូចឆ្កែចចកដែលស៊ីសត្វ មានកង្កែបជាដើម ហើយធំធាត់ឡើង ដូច្នោះ ដោយគាថានេះ ។

[๑๒] បទថា **ឆាគេហិ**[๑] គឺដោយពួកជ័រ ។ បទថា **មហាពន្ធនា** គឺឲ្យផុតពីគ្រឿងចង គឺកិលេសធំ ។ បទថា **មហាវិទុគ្គា** សេចក្តីថា ឱឃៈ ๔ យ៉ាង ឈ្មោះថា អន្ទង់ធំ ស្រង់ឡើងពីអន្ទង់ធំនោះហើយ ឲ្យតាំងនៅលើគោក គឺព្រះនិព្វាន ។

[๑๓] ព្រះអដ្ឋកថាចារ្យ លុះសម្តែងបទអនុសន្ធិថា ព្រះមានព្រះភាគ ទ្រង់មិនធ្វើឥទ្ធិបាដិហារ្យ ដោយកថាមគ្គប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលនឹងសម្តែងអនុសន្ធិនៃបទនេះថា **ឯ អគ្គញ្ញំ បញ្ញបេតិ** ទើបផ្តើមទេសនាថា **អគ្គញ្ញញ្ហាមាំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អគ្គញ្ញញ្ហាមាំ** សេចក្តីថា ម្នាលភគ្គវៈ តថាគតរមែងដឹងច្បាស់នូវវត្ថុដែលសត្វលោកសន្មតថា ខ្ពង់ខ្ពស់ និងចរិយាវត្ត ដែលកើតឡើងរបស់សត្វលោក ។ បទថា **តញ្ច បជានាមិ** សេចក្តីថា តថាគតមិនមែនមិនជ្រាបច្បាស់វត្ថុ ដែលលោកសន្មតថា ខ្ពង់ខ្ពស់តែម្យ៉ាងប៉ុណ្ណេះទេ រមែងដឹងច្បាស់វត្ថុដែលលោកសន្មតថា ខ្ពង់ខ្ពស់នោះផង ហើយដឹងច្បាស់ជាងនោះ គឺជ្រាបច្បាស់តាំងអំពីសីល សមាធិ រហូតដល់ព្រះសព្វញ្ញុតញ្ញាណ ។ បទថា **តញ្ច បជានន្តំ ឯ បរាមសាមិ** សេចក្តីថា តែតថាគតកាលជ្រាបច្បាស់នូវវត្ថុនោះ ក៏មិនប្រកាន់មាំដោយអំណាចនៃតណ្ហា

๑- បទនេះ ក្នុងបិដកខ្មែរមិនមាន ។

ទិដ្ឋិ និងមានៈថា អញ្ញវមែងជីងច្បាស់ ដល់វត្តុឈ្មោះនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ព្រះតថាគតមិនមានការប្រកាន់មាំ ។ បទថា **បច្ចត្តញ្ញេវ និព្ពុតិ ទិតិតា** *បានដល់ ទ្រង់ជ្រាបការរលត់កិលេសក្នុងព្រះអង្គ ដោយព្រះអង្គឯង ។ បទថា* **យថភិជានំ តថាគតោ** *គឺព្រះតថាគតទ្រង់ជីង គឺទ្រង់ជ្រាបការរលត់កិលេស ។ បទថា* **នោ អនយំ អាបជ្ជតិ** *អធិប្បាយថា ព្រះតថាគតរមែងមិនដល់អនយៈ គឺទុក្ខ បានដល់ សេចក្តីវិនាស ដូចតិរ្ថិយដែលមិនជ្រាបព្រះនិព្វាន ដូច្នោះ ។*

ឥឡូវនេះ ព្រះមានព្រះភាគ កាលសម្តែងដល់វត្តុដែលពួកតិរ្ថិយបញ្ញត្តថា ខ្ពង់ខ្ពស់ ទើបត្រាស់ថា **សន្តិ ភិក្ខវេ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ឥស្សរកុត្តំ ព្រហ្មកុត្តំ** *បានដល់ ព្រះឥសូរធ្វើឲ្យ ព្រះព្រហ្មធ្វើឲ្យ អធិប្បាយថា ព្រះឥសូរនិម្មិតឲ្យ ព្រះព្រហ្មនិម្មិតឲ្យ ។ ពិតហើយ គប្បីជ្រាបថា ព្រះព្រហ្មប៉ុណ្ណោះ ឈ្មោះថា ជាធំដោយភាពជាអធិបតី ក្នុងបទថា* **ឥស្សរកុត្តំ ព្រហ្មកុត្តំ** *នេះ ។ បទថា* **អាចរិយកំ** *គឺការៈជាអាចារ្យ បានដល់ លទ្ធិរបស់អាចារ្យ ។ ក្នុងបទថា* **អាចរិយកំ** *នោះ អាចរិយវាទ ឈ្មោះថា វត្តុដែលសត្វលោកសន្មតគ្នាថា ខ្ពង់ខ្ពស់ ។ អាចរិយវាទនោះ ដែលព្រះមានព្រះភាគទ្រង់អធិប្បាយថា វត្តុដែលសត្វលោកសន្មតថា ខ្ពង់ខ្ពស់ តថាគតសម្តែងក្នុងពាក្យថា អាចរិយវាទនេះ ទើបត្រាស់ថា* **អគ្គញ្ញំ** *ដូច្នេះ ។ បទថា* **កថំវិហិតកំ** *គឺនរណាបញ្ញត្ត បញ្ញត្តដូចម្តេច ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលអធិប្បាយពិស្តារហើយ ក្នុងព្រហ្មជាលសូត្រ ។*

[๑๔] បទថា **ទិដ្ឋាបទោសិកំ** បានដល់ មានមូលមកពីទេវតាពួកទិដ្ឋាបទោសិក: ។

[๑๗] បទថា **អសតា** គឺមិនមាន អធិប្បាយថា ព្រោះអត្ថថា មិនមាន ។ បទថា **តុច្ឆា** បានដល់ ដោយពាក្យទទេ គឺវៀរចាកខ្លឹមខាងក្នុង ។ បទថា **មុសា** គឺដោយពាក្យកុហក ។ បទថា **អភូតេន** គឺវៀរចាកពាក្យដែលពិត ។ បទថា **អញ្ញាចិកក្ខន្តិ** គឺពោលមួលបង្កាច់តថាគត ។ បទថា **វិបរីតោ** គឺមានសញ្ញាវិបរិតបានដល់ មានចិត្តវិបរិត ។ បទថា **ភិក្ខវោ ច** សេចក្តីថា មិនមែនព្រះសមណគោតមតែម្យ៉ាងដែលវិបរិត ពួកភិក្ខុដែលធ្វើតាមពាក្យទូន្មានព្រះសមណគោតមនោះ ក៏វិបរិតផងដែរ ។ គ្រានោះ ដើម្បីនឹងសម្តែងពាក្យពោលដែលពួកតិរ្ថិយពោលថា ព្រះសមណគោតមជាអ្នកវិបរិត ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **សមណោ គោតមោ** ជាដើម ។ បទថា **សុភវិមោក្ខំ** បានដល់ វណ្ណកសិណ ។ បទថា **អសុភន្តេវ** បានដល់ ដឹងច្បាស់យ៉ាងនេះថា វត្ថុដែលស្អាតនិងវត្ថុដែលមិនស្អាតទាំងអស់ ចាត់ជាអសុភ ។ បទថា **សុភន្តេន តស្មឹ សមយេ** សេចក្តីថា រមែងដឹងច្បាស់ក្នុងសម័យនោះថា វត្ថុនេះស្អាត រមែងមិនដឹងវត្ថុដែលមិនស្អាត ។

បទថា **ភិក្ខវោ ច** សេចក្តីថា ពួកភិក្ខុ និងសមណ:អន្តេវាសិករបស់ពួកជនដែលនិយាយយ៉ាងនេះ (នុ៎ះឯង) វិបរិត ។ បទថា **បហោតិ** បានដល់ មានសមត្ថភាព គឺអាច ។ បទថា **ទុក្ករំ ខោ** បានដល់ បរិព្វាជកនេះជ្រះថ្លាយ៉ាងនេះហើយ ទើបនិយាយថា **អហំ ភន្តេ** ជាដើម ។ ពិតហើយ

បរិព្វាជកពោលពាក្យនោះ ដោយការអួតអាង គឺដោយការបញ្ឆោតបន្ទំ ។ បានឮថា បរិព្វាជកនោះមានការគិតថា ព្រះសមណគោតមសម្តែងធម្មកថាប្រមាណប៉ុណ្ណេះដល់អញ ទោះបីអញស្តាប់ធម្មកថានោះហើយ ក៏មិនអាចបួសបាន អញគួរធ្វើខ្លួនហាក់ដូចបដិបត្តិតាមពាក្យទូន្មាន ព្រះសមណគោតមនោះ ។ ព្រោះហេតុនោះ ទើបបរិព្វាជកនោះ ពោលយ៉ាងនេះ ដោយការអួតអាង គឺដោយការបោកបញ្ឆោត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ដូចជានឹងកាត់ជាច់សេចក្តីជាប់ជំពាក់ដល់បរិព្វាជកនោះ ទើបត្រាស់ថា **ឧក្កំ ខោ ឯតំ ភគ្គវា តយា អញ្ញេនិដ្ឋិកេន** *ជាដើម ។ ពាក្យនោះ មានអត្ថតាមដែលបានពោលក្នុងបោដ្ឋបាទសូត្រ ។ បទថា* **សាធុកមនុរក្ខ** *បានដល់ ចូររក្សាឲ្យល្អ ។ ព្រះមានព្រះភាគ ទ្រង់ដឹកនាំបរិព្វាជកឲ្យរក្សាសេចក្តីជ្រះថ្លា (ត្រឹមតែដែលមាននៅឲ្យល្អ) ដោយប្រការដូច្នេះ ។ បរិព្វាជកឈ្មោះភគ្គវគោត្រនោះ ទោះបីស្តាប់ព្រះសូត្រយ៉ាងច្រើនដល់ម៉្លេះ ក៏មិនអាចធ្វើកិលេសឲ្យអស់ទៅបាន ។ ការទេសនា (ព្រះសូត្រនេះ) បានជាបច្ច័យ ដើម្បីវាសនាក្នុងភពតទៅរបស់បរិព្វាជកនោះ ។ ពាក្យដ៏សេសគ្រប់ៗ បទ មានអត្ថងាយយល់ហើយនោះឯង ។ អដ្ឋកថាជាជិកសូត្រ នៃទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនីចប់ ៗ*

ចាជិកសូត្រ ចប់

សូត្រទី ๑

សុត្តន្តបិដក

ឧទុម្ពរិកសូត្រទី ២

[១៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង បរិព្វាជក ឈ្មោះនិគ្រោធ នៅអាស្រ័យក្នុងបរិព្វាជការាម ជារបស់នាងទេវីឈ្មោះ ឧទុម្ពរិកា ជាមួយនឹងបរិព្វាជកបរិស័ទជាច្រើន ប្រមាណ ៣០០០ នាក់ ។ គ្រានោះឯង គហបតីឈ្មោះសន្ធាន បានចេញអំពីក្រុងរាជគ្រឹះ ដើម្បីគាល់ ព្រះមានព្រះភាគ ក្នុងវេលាថ្ងៃជ្រេពីត្រង់ ។ គ្រានោះ សន្ធានគហបតី មានសេចក្តីត្រិះរិះដូច្នេះថា កាលនេះជាកាលមិនគួរនឹងទៅគាល់ព្រះមានព្រះភាគ នៅឡើយ (ព្រោះថា) ព្រះមានព្រះភាគ ទ្រង់កំពុងសម្ងំនៅ ទាំងមិនជា សម័យដើម្បីជួបភិក្ខុទាំងឡាយ ដែលជាអ្នកចម្រើនចិត្ត ព្រោះពួកភិក្ខុជាអ្នក ចម្រើនចិត្ត ក៏កំពុងនៅសម្ងំដែរ ។ បើដូច្នោះ គួរតែអាត្មាអញ ចូលទៅរក និគ្រោធបរិព្វាជក ឯបរិព្វាជការាមរបស់ព្រះនាងឧទុម្ពរិកាទេវី (សិនចុះ) ។ ទើបសន្ធានគហបតីចូលទៅរកនិគ្រោធបរិព្វាជក ឯបរិព្វាជការាមរបស់នាង ឧទុម្ពរិកាទេវី ។

[១៩] សម័យនោះឯង និគ្រោធបរិព្វាជក កំពុងអង្គុយជាមួយនឹង បរិព្វាជកបរិស័ទជាច្រើន ដែលកំពុងគឹកកងរំពង មានសំឡេងហ៊ោ សំឡេង ខ្ជាំង និយាយតិរិច្ឆានកថាមានប្រការផ្សេងៗ គឺនិយាយអំពីស្តេច និយាយអំពី ចោរ និយាយអំពីមហាមាត្យ និយាយអំពីសេនា និយាយអំពីភ័យ និយាយ

អំពីចម្បាំង និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីកម្រងផ្កា និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីជនបទ និយាយអំពីក្រុង និយាយអំពីស្ត្រី និយាយអំពីបុរស និយាយអំពីការផឹកសុរា និយាយអំពីច្រកល្អក និយាយអំពីកំពង់ទឹក និយាយអំពីបុព្វ-ប្រេត និយាយអំពីរឿងផ្សេងៗ ដែលឥតប្រយោជន៍ និយាយរឿងលោក (និយាយរឿងក្អែកសកុកក្រហមជាដើម) និយាយអំពីសមុទ្រ និយាយអំពីសេចក្តីចម្រើន និងសេចក្តីសាបសូន្យដែលជាហេតុឥតប្រយោជន៍ថា ដូច្នេះខ្លះ ដូច្នោះខ្លះ ។ និគ្រោធបរិព្វាជក បានឃើញសន្ធានគហបតីកំពុងតែដើរមកពីចម្ងាយ ក៏ហាមបរិស័ទរបស់ខ្លួនថា ពួកអ្នកដ៏ចម្រើនចូរមានសំឡេងតិចៗ ពួកអ្នកដ៏ចម្រើនកុំនិយាយគ្នាឡើយ នេះជាសាវ័ករបស់ព្រះសមណគោតម ឈ្មោះសន្ធានគហបតីកំពុងដើរមក មួយទៀត ពួកគ្រហស្ថជាសាវ័ក របស់ព្រះសមណគោតម ជាមនុស្សមានសម្បៀកបំពាក់ស នៅអាស្រ័យក្នុងក្រុងរាជគ្រឹះ សន្ធានគហបតីនេះក៏ជាសាវ័ក ១ ក្នុងពួកសាវ័កទាំងនោះដែរ ពួកលោកមានអាយុ សុទ្ធតែត្រូវការមនុស្សមានសំឡេងតិច សរសើរតែមនុស្សមានសំឡេងតិចៗ ធ្វើម្តេចឲ្យគេដឹងនូវបរិស័ទដែលមានសំឡេងតិច ហើយសម្គាល់នូវទីដែលគេត្រូវចូលមកវិញ ។ កាលបើនិគ្រោធបរិព្វាជកនិយាយយ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នានៅស្ងៀម ។

[๒๐] *លំដាប់នោះ សន្ធានគហបតីបានចូលទៅរកនិគ្រោធបរិព្វាជក*

លុះចូលទៅដល់ហើយ ក៏បានវាក់ទាក់ជាមួយនឹងនិគ្រោធបរិព្វាជក បញ្ចប់ពាក្យដែលគួរពីរកាយ និងពាក្យដែលគួរឮកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសន្ធានគហបតីអង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះទៅនឹងនិគ្រោធបរិព្វាជកថា លោកដ៏ចម្រើនទាំងឡាយ ពួកបរិព្វាជកជាអន្យតិ្ថរិយនេះ ជួបជុំសមាគមគ្នាហើយ តែងមានសំឡេងហ៊ោ សំឡេងខ្ទាំង ប្រកបតិរច្ឆានកថាច្រើនយ៉ាង គឺនិយាយអំពីស្តេច និយាយអំពីចោរ ។បេ។ និយាយពីសេចក្តីចម្រើន និងសេចក្តីសាបសូន្យដែលជាហេតុឥតប្រយោជន៍ថា ដូច្នេះខ្លះ ដូច្នោះខ្លះ ឯព្រះមានព្រះភាគព្រះអង្គនោះដោយឡែក គឺទ្រង់សេពសេនាសនៈដ៏ស្ងាត់ តាំងនៅក្នុងព្រៃស្រោង ជាសេនាសនៈ មានសំឡេងសន្ធឹកគឹកកងតិច ប្រាសចាកពាក្យសម្តីរបស់អ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន ។ កាលបើសន្ធានគហបតីនិយាយយ៉ាងនេះហើយ និគ្រោធបរិព្វាជកក៏និយាយពាក្យនេះទៅនឹងសន្ធានគហបតីថា នែគហបតី ដូចជាយើងរិះគន់ អ្នកឯងត្រូវដឹងថា ព្រះសមណគោតមចរចាជាមួយនឹងអ្នកណា បានប្រទះសាកច្ចាជាមួយនឹងអ្នកណា ល្បងនូវភាពវាងវៃដោយប្រាជ្ញាជាមួយនឹងអ្នកណា (ដូចម្តេចបាន) ព្រោះប្រាជ្ញារបស់ព្រះសមណគោតម ជាត់វិនាស ក្នុងផ្ទះស្ងាត់អស់ទៅហើយ ព្រះសមណគោតមជាបុគ្គលមិនហ៊ានចុះកាន់បរិសទ មិនអាចធ្វើការចរចានឹងអ្នកដទៃបានទេ បានជាលោកតែងអាស្រ័យនៅតែក្នុងសេនាសនៈដ៏ស្ងាត់ប៉ុណ្ណោះ ដូចមេគោខ្វាក់ភ្នែកម្ខាងតែងគ្រាច់ទៅតែក្នុងទីជុំវិញ គប់រកតែទីស្ងាត់ប៉ុណ្ណោះ

ដូចម្តេចមិញ ប្រជ្ញារបស់ព្រះសមណគោតម ក៏វិនាសបាត់ទៅក្នុងផ្ទះស្ងាត់ ហើយ ព្រះសមណគោតមមិនហ៊ានចូលមកកាន់បរិស័ទ មិនគួរនឹងនិយាយ សំណេះសំណាលបានទេ លោកតែងអាស្រ័យនៅតែក្នុងសេនាសនៈដ៏ស្ងាត់ ជួច្នោះឯង នែអ្នកគហបតី ល្បងមើលចុះ បើព្រះសមណគោតមគប្បីមករក បរិស័ទនេះ ពួកយើងគួរសោកសួរលោកមួយប្រស្នាល្បងមើលដែរ ពួកយើង ត្រូវចាប់បង្វិលព្រះសមណគោតមនោះ ឲ្យដូចជាគេចាប់បង្វិលធ្នាំងទេ (មិនខាន) ។

[๒๑] *ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវពាក្យឆ្លើយឆ្លងនេះ របស់ សន្ធានគហបតី និងនិគ្រោធបរិព្វាជក ដោយសោតធាតុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវសោតធាតុរបស់មនុស្សសាមញ្ញ ។ លំដាប់នោះ ព្រះមានព្រះភាគ ស្តេចចុះអំពីភ្នំគិជ្ឈកូដ ហើយចូលទៅឯមោរនិវាបស្ថាន (កន្លែងសម្រាប់ឲ្យ ចំណីដល់សត្វក្ងោក) ក្បែរឆ្នេរស្រះឈ្មោះសុមាគធា លុះចូលទៅជិតហើយ ក៏ទ្រង់ចង្រ្កមក្នុងទីវាលទៀបមោរនិវាបស្ថាន ក្បែរឆ្នេរស្រះឈ្មោះសុមាគធា ។ លុះនិគ្រោធបរិព្វាជក បានឃើញព្រះមានព្រះភាគ ទ្រង់ចង្រ្កមក្នុងទីវាលជិត មោរនិវាបស្ថាន ទៀបឆ្នេរស្រះសុមាគធាហើយ ក៏បញ្ឈប់បរិស័ទរបស់ខ្លួនថា សូមអ្នកដ៏ចម្រើនទាំងឡាយមានសំឡេងតិចៗ សូមអ្នកទាំងឡាយកុំជជែកគ្នា ឡើយ នេះព្រះសមណគោតម កំពុងចង្រ្កមក្នុងទីវាល ជិតមោរនិវាបស្ថាន ក្បែរឆ្នេរស្រះសុមាគធា ជ្បិតលោកមានអាយុនោះ ត្រូវការតែបុគ្គលមាន សំឡេងតិចៗ សរសើរតែមនុស្សមានសំឡេងតិចៗ ធ្វើដូចម្តេចឲ្យលោក*

ជ្រាបថា បរិស័ទមានសំឡេងតិច ហើយគប្បីសម្គាល់នូវកិច្ចដែលលោកគួរ ចូលមករក (យើង) បើព្រះសមណគោតម គប្បីមករកបរិស័ទនេះ (មែន) ពួកយើងត្រូវសួរប្រស្នានេះនឹងលោកថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ទូន្មានពួកសាវ័កដោយធម៌ណា ពួកសាវ័កដែលព្រះមានព្រះភាគ ទ្រង់ទូន្មានដោយធម៌ណាហើយ ដល់នូវសេចក្តីត្រេកអរ បានបំពេញអរិយមគ្គជាព្រហ្មចរិយធម៌ដើម ជាធម៌ឲ្យកើតនិស្សរ័យដ៏ឧត្តម ធម៌របស់ព្រះមានព្រះភាគនោះ តើឈ្មោះដូចម្តេច ។ កាលបើនិគ្រោធបរិព្វាជកនិយាយយ៉ាងនេះហើយ បរិព្វាជកទាំងនោះ ក៏នាំគ្នានៅស្ងៀម ។

[๒๒] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលទៅត្រង់កន្លែងដែលនិគ្រោធបរិព្វាជកនៅ ។ ទើបនិគ្រោធបរិព្វាជក ក្រាបទូលសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្តេចចូលមក បពិត្រព្រះអង្គដ៏ចម្រើនព្រះអង្គស្តេចមកប្រពៃហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គបានធ្វើបរិយាយនេះ ដើម្បីមកក្នុងទីនេះយូរយារណាស់ហើយ សូមព្រះអង្គស្តេចគង់ចុះ បពិត្រព្រះអង្គដ៏ចម្រើន នេះអាសនៈដែល ខ្ញុំព្រះអង្គបានក្រាលទុកស្រេចហើយ ។ ព្រះមានព្រះភាគ ស្តេចគង់លើអាសនៈ ដែលគេក្រាលទុកស្រេចហើយ ។ ចំណែកឯនិគ្រោធបរិព្វាជក ក៏កាន់យកអាសនៈទាបមួយ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះមានព្រះភាគ បានត្រាស់សួរសេចក្តីនេះនឹងនិគ្រោធបរិព្វាជក ដែលអង្គុយក្នុងទីសមគួរយ៉ាងនេះថា ម្នាលនិគ្រោធអំបាញ់មិញនេះ អ្នកអង្គុយប្រជុំគ្នានិយាយរឿងអ្វី សម្តី

*ដូចម្តេចដែលពួកអ្នកឈប់បង្អង់ទាំងពាក់កណ្តាល ។ កាលបើព្រះមានព្រះភាគ
ត្រាស់សួរយ៉ាងនេះហើយ និគ្រោធបរិព្វាជកក្រាបទូលសេចក្តីនេះនឹងព្រះមាន
ព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គក្នុងទីនេះបានឃើញព្រះមាន
ព្រះភាគ ទ្រង់កំពុងចង្រ្កមក្នុងទីវាល ទៀបមោរនិវាបស្ថាន កែ្បរឆ្នេរស្រះ
ឈ្មោះសុមាគធា លុះឃើញហើយបាននាំគ្នានិយាយយ៉ាងនេះថា បើព្រះ
សមណគោតមគប្បីមករកបរិស័ទនេះ (មែន) ពួកយើងត្រូវសួរប្រស្នានេះ
ចំពោះព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ទូន្មានពួក
សាវ័កដោយធម៌ណា ពួកសាវ័កដែលព្រះមានព្រះភាគ ទ្រង់ទូន្មានដោយធម៌
ណាហើយ ដល់នូវសេចក្តីត្រេកអរ បានបំពេញអរិយមគ្គជាព្រហ្មចរិយធម៌
ដើម ដែលឲ្យកើតនិស្សរ័យដ៏ឧត្តមធម៌របស់ព្រះមានព្រះភាគនោះ តើឈ្មោះ
ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន សម្តីនេះឯងដែលពួកខ្ញុំព្រះអង្គឈប់បង្អង់
ទាំងពាក់កណ្តាល ក៏ទទួលព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះមានព្រះ
ភាគត្រាស់ថា ម្នាលនិគ្រោធ តថាគតទូន្មានពួកសាវ័កដោយធម៌ណា ពួក
សាវ័កដែលតថាគតទូន្មានហើយដោយធម៌ណា ដល់នូវសេចក្តីគាប់ចិត្ត បាន
បំពេញអរិយមគ្គជាព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្សរ័យដ៏ឧត្តម អ្នកឯង
ដែលមានទិដ្ឋិដោយទៃ្បក មានសេចក្តីពេញចិត្តដោយទៃ្បក មានសេចក្តីគាប់
ចិត្តដោយទៃ្បក មិនងាយនឹងដឹងធម៌នោះទេ ឮរំលងតែអ្នកមានព្យាយាមជា
គ្រឿងប្រកបខ្លាំង ឮរំលងតែអ្នកបានរៀនក្នុងសម្នាក់អាចារ្យ (នោះទើបដឹង
បាន) ម្នាលនិគ្រោធ អញើ្ញញអ្នកសួរប្រស្នាក្នុងការខ្ចីមបាប ជាអាចរិយវាទ*

របស់ខ្លួននឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងជុតកិលេស ដូចម្តេចឈ្មោះថាបរិបូណ៌ ដូចម្តេចឈ្មោះថាមិនបរិបូណ៌ ។ កាលបើព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នាបន្ទឹមានសំឡេងហ៊ោ សំឡេងខ្ទាំងថា នែអ្នកដ៏ចម្រើន គួរអស្ចារ្យណាស់តើ នែអ្នកដ៏ចម្រើន ហេតុមិនដែលមានហ្ន៎ ព្រះសមណ-គោតម ព្រះអង្គមានឫទ្ធិច្រើន មានអានុភាពខ្លាំង ព្រោះទ្រង់បញ្ឈប់វាទៈរបស់ព្រះអង្គ ទ្រង់បណ្តាយឲ្យអ្នកដទៃនិយាយវិញ ។

[๒๓] លំដាប់នោះឯង និគ្រោធបរិព្វាជក ធ្វើពួកបរិព្វាជកទាំងនោះឲ្យមានសំឡេងតិចហើយ បានទូលស្នើសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គជាតបោជិគុច្ឆវាទ (អ្នកពោលប្រកាន់ការខ្ពើមបាបដោយព្យាយាមជាគ្រឿងជុតកិលេស) ជាអ្នកមិនរួញរានឹងតបោ-ជិគុច្ឆវត្ត បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាបដោយព្យាយាម ជាគ្រឿងជុតកិលេសដូចម្តេច ទើបឈ្មោះបរិបូណ៌ ដូចម្តេចឈ្មោះថាមិនបរិបូណ៌ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ មនុស្សបំពេញព្យាយាម ជាគ្រឿងជុតកិលេសក្នុងលោកនេះ ជាអ្នកអាក្រាតកាយ មានមារយាទល្អលះបង់ហើយ ប្រកាន់ហត្ថាវលេខនបដិបត្តិ ជាអ្នកប្រកាន់វត្តដែលគេនិមន្តថា លោកដ៏ចម្រើនសូមចូលមកទទួលភត្ត ហើយមិនចូលមកប្រកាន់វត្តដែលគេនិមន្តថា លោកដ៏ចម្រើន ចូរឈប់ចាំសិន ហើយមិនឈប់ចាំ មិនត្រេកអរនឹងកិក្ខាដែលគេនាំមកមុនបំផុត មិនត្រេកអរនឹងកិក្ខាដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត

មិនទទួលភិក្ខាដែលគេជូនឲ្យអំពីឆ្នាំង មិនទទួលភិក្ខាដែលគេជូនឲ្យពីគញ្ជើ មិនទទួលភិក្ខាដែលគេកន្ទងធរណីទ្វារនាំមក មិនទទួលភិក្ខាដែលគេកន្ទងគ្បាល់នាំមក មិនទទួលភិក្ខាដែលគេកន្ទងអង្រែនាំមក មិនទទួលភិក្ខាដែលគេកន្ទងកំណាត់ឈើនាំមក មិនទទួលភិក្ខារបស់មនុស្សកំពុងបរិភោគពីរនាក់ មិនទទួលភិក្ខារបស់ស្ត្រីមានគភ៌ មិនទទួលភិក្ខារបស់ស្ត្រីកំពុងបំបៅកូន មិនទទួលភិក្ខារបស់ស្ត្រីដែលកំពុងសូបអង្អែលបុរស មិនទទួលភិក្ខារបស់បុគ្គលដែលមានគេជីកនាំឲ្យធ្វើ មិនទទួលភិក្ខាក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលភិក្ខាក្នុងទីដែលរុយកំពុងរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ ។ អចេលក:នោះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះ ១ ឬញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ១ ពំនូតខ្ញុះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះពីរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្ញុះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះ ៧ ឬញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅចំពោះតែក្នុងដុំបាយ ៧ ពំនូតខ្ញុះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយការជន៍ ១ ខ្ញុះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយការជន៍ ២ ខ្ញុះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយការជន៍ ៧ ខ្ញុះ បរិភោគអាហារំលង ១ ថ្ងៃខ្ញុះ បរិភោគអាហារំលង ២ ថ្ងៃខ្ញុះ បរិភោគអាហារំលង ៧ ថ្ងៃខ្ញុះ អចេលក:នោះ ប្រកបនូវព្យាយាមក្នុងកត្តា ភោជនដោយការផ្គាស់ប្តូរគ្នាកន្ទះខែយ៉ាងនេះដូច្នេះ ។ អចេលក:នោះ បរិភោគតែអន្ទក់ស្រស់ខ្ញុះ បរិភោគតែស្រងែខ្ញុះ បរិភោគតែស្លួយខ្ញុះ បរិភោគតែចំនៀរស្បែកដែលគេចោលខ្ញុះ បរិភោគតែជ័រ ឬសាវយខ្ញុះ បរិភោគតែកុណ្ឌកខ្ញុះ បរិភោគ

តែបាយក្តាំងដែលគេចោលខ្លះ បរិភោគតែម្សៅខ្លះ បរិភោគតែស្មៅខ្លះ បរិភោគតែអាចម៍គោខ្លះ បរិភោគតែមើម និងផ្លែក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះខ្លះ ។ គេប្រើសំពត់សម្បកឆ្មៃខ្លះ ប្រើសំពត់ដែលគេត្បាញលាយគ្នាខ្លះ ប្រើសំពត់រុំសាកសពខ្លះ ប្រើសំពត់បង្សុកូលខ្លះ ស្លៀកពាក់សម្បកឈើខ្លះ ស្លៀកពាក់ស្បែកខ្លាខ្លះ ស្លៀកពាក់ស្បែកខ្លាទាំងក្រចកខ្លះ ស្លៀកពាក់ស្បូវក្រែងខ្លះ ស្លៀកពាក់សំពត់សម្បកក្រចៅខ្លះ ប្រើសំពត់គេត្បាញដោយសម្បកផ្លែឈើខ្លះ ប្រើសំពត់កម្ពលដែលគេត្បាញដោយសក់មនុស្សខ្លះ ប្រើសំពត់កម្ពលដែលគេត្បាញដោយសក់កន្ទុយសេះខ្លះ ស្លៀកពាក់សំពត់ស្ងាបមៀមខ្លះ ជាអ្នកដកសក់ និងពុកមាត់ ប្រកបព្យាយាមក្នុងការដកសក់ និងពុកមាត់ខ្លះ ជាអ្នកឈរងើយ ហាមឃាត់អាសនៈខ្លះ ជាអ្នកអង្គុយច្រហោង ប្រកបព្យាយាមក្នុងការអង្គុយច្រហោងខ្លះ ជាអ្នកកាន់វត្តឈរ ដើរជាដើមលើបន្ថា សម្រេចការដេកលើបន្ថាខ្លះ សម្រេចការដេកលើបន្ទះក្តារខ្លះ សម្រេចការដេកលើផែនដីទួលខ្លះ ជាអ្នកដេកផ្អៀងតែម្ខាងខ្លះ ជាអ្នកប្រឡាក់ខ្ចនដោយធូលី ឈរក្នុងទីវាល អង្គុយតែលើអាសនៈមួយដែលខ្ចនបានមកយ៉ាងណាខ្លះ បរិភោគតែលាមក ប្រកបព្យាយាមក្នុងការបរិភោគលាមកខ្លះ ជាអ្នកហាមឃាត់ទឹកត្រជាក់ ប្រកបព្យាយាមក្នុងការហាមឃាត់ទឹកត្រជាក់ខ្លះ ប្រកបព្យាយាមក្នុងការចុះត្រាំទឹកក្នុងមួយថ្ងៃ ๓ ដងខ្លះ ។ ម្នាលនិគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមាន ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថាបរិបូណ៌ហើយ ឬមិនទាន់

បរិបូណ៌ទេ ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមាន ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងជុតកិលេស ឈ្មោះថា បរិបូណ៌ហើយដោយពិត មិនមែនមិនបរិបូណ៌ទេ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមជាបដោយព្យាយាម ជាគ្រឿងជុតកិលេស ទុកជាបរិបូណ៌ហើយយ៉ាងនេះ ក៏តថាគតឲ្យឈ្មោះថា នៅតែមានឧបក្កិលេសច្រើនយ៉ាង ។

[๒๔] និគ្រោធបរិព្វាជកទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមជាបដោយព្យាយាមជាគ្រឿងជុតកិលេស ជានបរិបូណ៌ប៉ុណ្ណេះដែរ ហេតុអ្វីក៏ព្រះមានព្រះភាគ នៅឲ្យឈ្មោះថាមានឧបក្កិលេសច្រើនយ៉ាង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ព្រោះមនុស្សមានតបវត្ត (វត្តសម្រាប់ព្យាយាមជុតកិលេស) ក្នុងលោកនេះ សមាទានតបវត្ត គេពេញចិត្តទាំងមានសេចក្តីត្រិះរិះអស់ហើយត្រឹមតបវត្តនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលមនុស្សមានតបវត្តសមាទានទូវតបវត្ត គេពេញចិត្តទាំងមានសេចក្តីត្រិះរិះអស់ហើយត្រឹមតបវត្តនោះ ម្នាលនិគ្រោធ នេះឯងជាឧបក្កិលេសរបស់មនុស្សអ្នកមានតបវត្ត ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត អ្នកនោះលើកតែខ្លួនឯង បង្អាប់អ្នកដទៃព្រោះតបវត្តនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទានទូវតបវត្ត គេលើកតែខ្លួនតែង បង្អាប់អ្នកដទៃព្រោះតបវត្តនោះ ម្នាលនិគ្រោធ នេះក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត មនុស្ស

អ្នកមានតបវត្ត សមាទានន្ទូវតបវត្ត គេស្រវឹងជ្រប់ដល់ន្ទូវសេចក្តីស្រវឹង ព្រោះតបវត្តនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលមនុស្សអ្នកមានតបវត្ត សមា-ទានន្ទូវតបវត្ត គេស្រវឹងជ្រប់ដល់ន្ទូវសេចក្តីស្រវឹងព្រោះតបវត្តនោះ ម្នាលនិគ្រោធ នេះក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានន្ទូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការ: និងសេចក្តីសរសើរ គេពេញចិត្តទាំងមានសេចក្តីត្រិះរិះអស់ហើយ ត្រឹមលាភសក្ការ: និងសេចក្តីសរសើរនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទានន្ទូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការ: និងសេចក្តីសរសើរ គេពេញចិត្តទាំងមានសេចក្តីត្រិះរិះអស់ហើយ ត្រឹមលាភសក្ការ: និងសេចក្តីសរសើរនោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានន្ទូវតបវត្ត គេយកតប-វត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការ: និងសេចក្តីសរសើរ គេលើកខ្ជូនឯងបង្អាប់អ្នកដទៃ ព្រោះតែលាភសក្ការ: និងសេចក្តីសរសើរនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទានន្ទូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការ: និងសេចក្តីសសើរ គេក៏លើកខ្ជូនឯង តែងបង្អាប់អ្នកដទៃ ព្រោះតែលាភសក្ការ:នោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិ-លេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានន្ទូវតបវត្ត គេយកតបវត្តនោះជាគ្រឿងឲ្យកើតលាភ

សក្ការៈ និងសេចក្តីសរសើរនោះ គេក៏ស្រាវឹងក្លេចខ្លួនដល់នូវសេចក្តីវង្វេង ព្រោះតែលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការៈ និងសេចក្តីសរសើរ គេក៏ស្រាវឹងក្លេចខ្លួន ដល់នូវសេចក្តីវង្វេង ព្រោះតែលាភសក្ការៈ និងសេចក្តីសរសើរនោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់មនុស្សអ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត ចែកភោជនជាពីរចំណែក ថា ភោជននេះគាប់ចិត្តខ្ញុំ ភោជននេះមិនគាប់ចិត្តខ្ញុំទេ ។ តាបសដែលប្រកបដោយសេចក្តីចង់នោះ មិនគាប់ចិត្តភោជនណា រមែងលះចោលភោជននោះ ចំណែកភោជនណាគាប់ចិត្តគេៗ ក៏ត្រេកត្រអាលក្លេចស្មារតី ជាប់ស្និតនឹងភោជននោះ ជាបុគ្គលឥតឃើញទោស ឥតមានប្រាជ្ញាជាគ្រឿងរលាស់ចិត្តចេញ ចេះតែបរិភោគ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត ដោយហេតុប្រាថ្នាលាភសក្ការៈ និងសេចក្តីសរសើរថា ពួកព្រះរាជា រាជមហាមាត្រ ក្សត្រ ព្រាហ្មណ៍ គហបតី តិរ្ថិយ នឹងធ្វើសក្ការៈចំពោះយើង ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ពោលបង្អាប់សមណព្រាហ្មណ៍ណាមួយថា បែបនេះ ឬសមណព្រាហ្មណ៍ជាអ្នកមានការចិញ្ចឹមជីវិតច្រើនយ៉ាង តែងសុីពូជឈើសព្វសារពើ គឺពូជកើត

អំពីឫស ពូជកើតអំពីមើម ពូជកើតអំពីដើម ពូជកើតអំពីថ្នាំង ពូជកើតអំពីចុង ពូជកើតអំពីពូជផងគ្នាជាគម្រប់ ៥ នរណាៗ ក៏ដឹងថា ញញួរ គឺធ្មេញរបស់សមណៈនេះ ដូចជាកាំនេះ អ្នកនេះជាសមណៈត្រឹមតែការប្តេជ្ញាថាសមណៈប៉ុណ្ណោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបៈវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ឃើញសមណព្រាហ្មណ៍ណាមួយ ដែលមានគេកំពុងធ្វើសក្ការៈ គោរព រាប់អាន បូជាក្នុងត្រកូលទាំងឡាយ ។ អ្នកនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា មនុស្សទាំងឡាយ គេធ្វើសក្ការៈ គោរព រាប់អាន បូជាសមណៈ ដែលមានការចិញ្ចឹមជីវិតច្រើនមុខនេះ ក្នុងត្រកូលទាំងឡាយ ប្រយោជន៍អ្វី ពួកគេម្តេចក៏មិនធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ដែលមានតបវត្ត ជាអ្នកមានការចិញ្ចឹមជីវិតសៅហ្មង ក្នុងត្រកូលទាំងឡាយវិញ ។ អ្នកនោះរមែងកើតសេចក្តីឫស្យាកំណាញ់ក្នុងត្រកូលទាំងឡាយ ដោយប្រការយ៉ាងនេះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់មនុស្សអ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត រមែងអង្គុយក្នុងទីចំកែ្នកមនុស្សមើលឃើញ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ដើរបង្ហាញខ្លួន ដើរទៅក្នុងត្រកូលទាំងឡាយ ដោយគិតថា ការនេះជាតបវត្តរបស់អាត្មា ការនេះជាតបវត្តរបស់អាត្មា ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត

អ្នកមានតបវត្ត អាស្រ័យល្បិចបិទបាំងនីមួយ គឺបើមានគេសួរអ្នកនោះថា លោកគាប់ចិត្តការនេះឬ បើទុកជាការនោះខ្លួនមិនគាប់ចិត្តទេ ក៏និយាយថាគាប់ចិត្ត បើការនោះខ្លួនគាប់ចិត្ត ក៏និយាយថាមិនគាប់ចិត្តវិញ ។ អ្នកនោះឈ្មោះថា និយាយកុហកទាំងដឹងខ្លួន ដោយសម្តីបែបនេះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត កាលបើព្រះតថាគត ឬសាវ័ករបស់ព្រះតថាគតកំពុងសម្តែងធម៌ រមែងមិនអនុមោទនា នូវបរិយាយដែលខ្លួនគួរអនុមោទនា ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ជាអ្នកមានសេចក្តីក្រោធចងសេចក្តីក្រោធទុក ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត មានសេចក្តីក្រោធចងសេចក្តីក្រោធទុកណា ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ជាអ្នករមិលគុណ វាយឫកស្មើ ឈ្នានីស កំណាញ់ អួតអាង មានកលមាយាវឹងត្អឹង មើលងាយគេ មានសេចក្តីប្រាថ្នាលាមក ទាំងលុះអំណាចនៃសេចក្តីប្រាថ្នាដ៏លាមក ជាមនុស្សមិច្ឆាទិដ្ឋិ ប្រកបដោយអន្តគ្គាហិកទិដ្ឋិ អ្នកប្រកាន់យកតែសេចក្តីឃើញរបស់ខ្លួន ប្រកាន់មាំ ជាបុគ្គលដែលគេមិនអាចឲ្យលះបង់បានដោយងាយ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្តជាអ្នកប្រកាន់យកតែសេចក្តីឃើញរបស់ខ្លួន ប្រកាន់មាំ ជាបុគ្គលដែលគេឲ្យលះបង់បានដោយក្រ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាល

និគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច តើការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសទាំងនេះ ជាឧបក្កិលេស ឬមិនមែនជាឧបក្កិលេសទេ ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសទាំងនេះ ជាឧបក្កិលេសពិតៗ មិនមែនជាអនុបក្កិលេសទេ បពិត្រព្រះអង្គដ៏ចម្រើន អ្នកមានតបវត្ត ពួកខ្លះក្នុងលោកនេះ ជាអ្នកប្រកបដោយឧបក្កិលេសទាំងអស់នេះទៅហើយ ចាំបាច់ពោលទៅថ្ងៃ ដោយឧបក្កិលេសឯទៀតៗ ។

[๒๕] ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ សមាទានទូវតបវត្ត គេមិនមែនពេញចិត្ត ទាំងមានសេចក្តីត្រិះរិះមិនមែនអស់ហើយត្រឹមតបវត្តនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទានទូវតបវត្តណា គេមិនមែនពេញចិត្ត ទាំងមានសេចក្តីត្រិះរិះ មិនមែនអស់ហើយត្រឹមតបវត្តនោះទេ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះយ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត គេមិនលើកខ្លួនឯង មិនកំហែងអ្នកដទៃ ព្រោះតបវត្តនោះ ។បេ។ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះយ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត គេមិនស្រវឹង មិនឈ្លក់គំនិត មិនជល់នូវសេចក្តីស្រវឹង ព្រោះតែតបវត្តនោះទេ ។បេ។ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខ នៅមានទៀត អ្នកមានតបវត្ត សមាទានទូវតបវត្ត គេញុំាងលាភសក្ការៈ និងសេចក្តីសរសើរ

ឲ្យកើតទ្បើង ព្រោះតបវត្តនោះ តែគេមិនពេញចិត្ត មិនមានសេចក្តីត្រិះរិះ អស់ហើយត្រឹមលាភសក្ការៈ និងសេចក្តីសរសើរនោះទេ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ។បេ។ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត គេញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតទ្បើង គេមិនលើកខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែលាភសក្ការៈ និងសេចក្តីសរសើរនោះទេ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ។បេ។ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត គេញុំាងលាភសក្ការៈ និងសេចក្តីសរសើរ ឲ្យកើតទ្បើង ដោយតបវត្តនោះ តែគេមិនស្រេវឹង មិនឈ្លក់គំនិត មិនជល់នូវសេចក្តីស្រេវឹង ព្រោះតែលាភសក្ការៈ និងសេចក្តីសរសើរនោះទេ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ។បេ។ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត មិនចែកកោជនជាពីរចំណែកថា កោជននេះគាប់ចិត្តខ្ញុំ កោជននេះមិនគាប់ចិត្តខ្ញុំទេ ។ គេជាមនុស្សគ្មានប្រាជ្ញាកោជនណា មិនគាប់ចិត្តគេៗ ក៏លះបង់កោជននោះដែរ តែថា កោជនណាគាប់ចិត្តគេៗ មិនត្រេកត្រអាល មិនភ្លេចស្មារតី មិនជាប់ស្និត ជាអ្នកឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចិត្តចេញ បរិភោគនូវកោជននោះ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាង

មុខនៅមានទៀត អ្នកមានតបវត្ត គេមិនសមាទានតបវត្តហេតុតែសេចក្តីប្រាថ្នាលាភសក្ការៈ និងសេចក្តីសរសើរថា ពួកព្រះរាជា រាជមហាមាត្យ ក្សត្រិយ៍ ព្រាហ្មណ៍ គហបតី តិរ្ថិយ នឹងធ្វើសក្ការៈចំពោះអាត្មាអញ អ្នកនោះឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត មិនបានពោលបង្អាប់សមណៈ ឬព្រាហ្មណ៍ណាមួយថា បែបនេះ ឬសមណព្រាហ្មណ៍ ជាអ្នកមានការចិញ្ចឹមជីវិតច្រើនយ៉ាង តែងស៊ីពូជសព្វសារពើ គឺពូជកើតអំពីឫស ពូជកើតអំពីដើម ពូជកើតអំពីថ្នាំង ពូជកើតអំពីចុង ពូជកើតអំពីពូជ ជាគម្រប់ ៥ នរណាៗ ក៏ដឹងថា ញញួរ គឺធ្មេញរបស់សមណៈនេះ ដូចជាកាំនួះ គេជាសមណៈត្រឹមតែការប្តេជ្ញាថា សមណៈប៉ុណ្ណោះទេ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះយ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ឃើញគេធ្វើសក្ការៈ គោរព រាប់អាន បូជាសមណៈ ឬព្រាហ្មណ៍ណាមួយក្នុងត្រកូលទាំងឡាយ ។ គេមិនបានត្រិះរិះយ៉ាងនេះថា គួរដែរឬ ពួកមនុស្សតែងធ្វើសក្ការៈ គោរព រាប់អាន បូជា សមណៈដែលមានអាជីវៈច្រើនក្នុងត្រកូលទាំងឡាយនេះ ចំណែកខាងអាត្មាអញ ជាអ្នកមានតបវត្ត មានអាជីវៈសៅហ្មង (ម្តេចក៏) ពួកគេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាក្នុងត្រកូលទាំងឡាយវិញ ។ គេមិនឲ្យកើតសេចក្តីឫស្យា និងសេចក្តីកំណាញ់ក្នុងត្រកូលទាំងឡាយដូច្នេះទៀយ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត មិន

ជាអ្នកអង្គុយក្នុងទីចំកែ្នកមនុស្ស គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាង នេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត មិន ដើរបង្ហាញខ្លួន ក្នុងត្រកូលទាំងឡាយថា ការនេះជាតបវត្តរបស់អាត្មាដែរ ការ នេះ ជាតបវត្តរបស់អាត្មាដែរ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះ បាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត មិនអា-ស្រ័យការបិទបាំងនីមួយ បើមានគេសួរអ្នកនោះថា ការនេះគាប់ចិត្តលោកឬ បើការនោះមិនគាប់ចិត្តខ្លួន ក៏និយាយថា មិនគាប់ចិត្ត របស់នេះគួរដល់អ្នកឬ ប្រាប់នូវរបស់ដែលមិនគួរថា មិនគួរ បើការនោះ ខ្លួនគាប់ចិត្ត ក៏និយាយថា គាប់ចិត្ត ។ អ្នកនោះមិនបាននិយាយកុហកទាំងដឹងខ្លួន គេឈ្មោះថា បរិសុទ្ធ ក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត កាលតថាគត ឬសាវ័ករបស់តថាគត កំពុងសម្តែងធម៌ រមែង អនុមោទនានូវបរិយាយដែលគួរអនុមោទនា គេឈ្មោះថា បរិសុទ្ធក្នុងហេតុ នោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមាន តបវត្ត ជាអ្នកមិនក្រោធ មិនចងសេចក្តីក្រោធទុក ។ ម្នាលនិគ្រោធ ត្រង់ ដែលអ្នកមានតបវត្ត ជាអ្នកមិនក្រោធ មិនចងសេចក្តីក្រោធទុក គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមាន ទៀត អ្នកមានតបវត្ត ជាអ្នកមិនរមិលគុណ មិនវាយប្រកស្មើ មិនឈ្នានីស មិនកំណាញ់ មិនអួតអាង មិនមានកលមាយា មិនរឹងត្អឹង មិនមើលងាយគេ មិនមានសេចក្តីប្រាថ្នាដ៏លាមក មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាដ៏លាមក

មិនមែនជាមិច្ឆាទិដ្ឋិ មិនប្រកបដោយអន្តគ្គាហិកទិដ្ឋិ មិនប្រកាន់យកតាមតែសេចក្តីឃើញរបស់ខ្លួន មិនប្រកាន់មាំ ជាមនុស្សដែលគេឲ្យលះបង់បានដោយងាយ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ជាអ្នកមិនប្រកាន់យកតាមតែសេចក្តីឃើញរបស់ខ្លួន មិនប្រកាន់មាំ ជាមនុស្សដែលគេឲ្យលះបង់បានដោយងាយ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ព្រះមានបុណ្យត្រាស់សួរថា ម្នាលនិគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើហេតុមានមកដូច្នេះ ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ។ និគ្រោធបរិព្វាជក ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុមានមកដូច្នេះ ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្ចីមធម៌ហើយផង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសត្រឹមតែប៉ុណ្ណោះ មិនទាន់ដល់កំពូលធម៌ មិនទាន់ដល់ខ្ចីមធម៌នៅឡើយទេ គ្រាន់តែដល់ត្រឹមធម៌ដូចជាក្រមប៉ុណ្ណោះទេតើ ។

[๒๖] និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចុះការខ្ពើមជាបដោយសេចក្តីព្យាយាមជាគ្រឿងដុតកិលេសត្រឹមណា ទើបឈ្មោះថា ដល់កំពូលធម៌ផង ដល់ខ្ចីមធម៌ផង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានបុណ្យសម្តែងឲ្យដល់កំពូល ឲ្យដល់ខ្ចីមសារ របស់ការខ្ពើមជាបដោយសេចក្តី

ព្យាយាម ជាគ្រឿងជុតកិលេសតែម្តងដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះ
ភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ ជាអ្នកសង្រួម
ដោយការសង្រួម ៤ យ៉ាង ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួម
ដោយការសង្រួម ៤ យ៉ាង តើដូចម្តេច ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត
ក្នុងលោកនេះ មិនសម្លាប់សត្វ មិនប្រើអ្នកដទៃឲ្យសម្លាប់សត្វ មិនគាប់ចិត្តនឹង
អ្នកសម្លាប់សត្វ មិនកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ មិនប្រើអ្នកដទៃ
ឲ្យកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ មិនគាប់ចិត្តនឹងអ្នកកាន់យកទ្រព្យ
ដែលម្ចាស់គេមិនបានឲ្យ រមែងមិននិយាយកុហក មិនប្រើអ្នកដទៃឲ្យនិយាយ
កុហក មិនគាប់ចិត្តនឹងអ្នកនិយាយកុហក មិនសេពកាវិតធម៌ (កាមគុណ
៥) មិនប្រើអ្នកដទៃឲ្យសេពនូវកាវិតធម៌ មិនគាប់ចិត្តនឹងអ្នកដែលសេពនូវ
កាវិតធម៌ ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម
៤ យ៉ាង ដោយហេតុយ៉ាងនេះ ។ ម្នាលនិគ្រោធ កាលណាអ្នកមានតបវត្ត
ជាអ្នកសង្រួមដោយការសង្រួមទាំង ៤ យ៉ាង ក៏រមែងមានពាក្យគេសរសើរ
អ្នកនោះ ព្រោះខ្លួនជាអ្នកមានតបវត្ត ។ គេទំប្រឹងបំពេញ (សីល) មិន
ត្រឡប់មកជើម្បីភេទថោកទាប (ភេទគ្រហស្ថ) ។ គេរមែងអាស្រ័យ
សេនាសនៈស្ងាត់ ព្រៃ គល់ឈើ ភ្នំ ញកភ្នំ ជ្រោះភ្នំ ទីស្មសាន ជង្ហែព្រៃ
ទីវាល និងទីដែលប្រក់ចាំងដោយស្មៅ ។ បុគ្គលនោះ លុះកាលខាងក្រោយ
ភត្ត ក៏ត្រឡប់មកពីបិណ្ឌបាត ហើយអង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់
ប្រុងស្មារតីឲ្យមានមុខឆ្ពោះ (ទៅរកកម្មដ្ឋាន) ។ គេលះអភិជ្ឈាក្នុងលោក

មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះព្យាបាទជាគ្រឿងប្រទូស្ត
មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះសត្វទាំងពួងដោយប្រយោជន៍ ជម្រះ
ចិត្តឲ្យស្អាតចាកព្យាបាទជាគ្រឿងប្រទូស្ត លះថីនមិទ្ធៈ មានចិត្តប្រាសចាក
ថីនមិទ្ធៈ មានសេចក្តីសម្គាល់ក្នុងពន្លឺ មានសតិ មានសម្បជញ្ញៈ ជម្រះចិត្ត
ចាកថីនមិទ្ធៈ លះឧទ្ធច្ចកុក្កុច្ចៈ មានចិត្តមិនរវើរវាយ មានចិត្តខាងក្នុងស្ងប់
រម្ងាប់ ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះវិចិកិច្ឆា មានចិត្តឆ្លងផុតចាកវិចិកិច្ឆា
មិនមានសេចក្តីងឿងឆ្ងល់ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ក្នុងកុសលធម៌ទាំង-
ឡាយ ។ គេលះនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេស ជាគ្រឿងធ្វើបញ្ញា
ឲ្យថយកម្លាំង ក៏សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្តក្របកដោយ
មេត្តាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូច្នោះ ទិសទី ៣ ក៏ដូច្នោះ ទិសទី ៤
ក៏ដូច្នោះ សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្តប្រកបដោយមេត្តា
ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វ
លោកទាំងមូល ដោយយកខ្លួនទៅប្រៀបនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង
គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយប្រការដូច្នេះ ។ ចិត្ត
ប្រកបដោយករុណា ។ ចិត្តប្រកបដោយមុទិតា ។ សម្រេចសម្រាន្តឥរិយាបថ
ដោយការផ្សាយចិត្តប្រកបដោយឧបេក្ខា ទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូច្នោះ
ទិសទី ៣ ក៏ដូច្នោះ ទិសទី ៤ ក៏ដូច្នោះ សម្រេចសម្រាន្តឥរិយាបថដោយការ
ផ្សាយចិត្ត ប្រកបដោយឧបេក្ខាដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ
មិនមានព្យាបាទទៅកាន់សត្វលោកទាំងមូល ដោយយកខ្លួនទៅប្រៀបនឹងសត្វ

ទាំងអស់ ក្នុងទិសទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ។ ម្នាលនិគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើហេតុមានមកដូច្នេះ ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើដូច្នេះ ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្ចីមធម៌ផង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមជាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសត្រឹមតែប៉ុណ្ណោះ មិនទាន់ឈ្មោះថា ដល់កំពូលធម៌ ឬដល់ខ្ចីមធម៌នៅឡើយទេ គ្រាន់តែដល់ត្រឹមសម្បកធម៌ប៉ុណ្ណោះទេ ។

[๒๗] និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចុះការខ្ពើមជាបដោយព្យាយាម ជាគ្រឿងដុតកិលេសត្រឹមណា ទើបឈ្មោះថា ដល់កំពូលធម៌ផង ដល់ខ្ចីមធម៌ផង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងឲ្យដល់កំពូល ឲ្យដល់ខ្ចីមសាររបស់ការខ្ពើមជាប ដោយសេចក្តីព្យាយាមជាគ្រឿងដុតកិលេសតែម្តង ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ ជាអ្នកសង្រួមដោយការសង្រួម ๔ យ៉ាង ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួម ដោយការសង្រួម ๔ យ៉ាង តើដូចម្តេច ។បេ។ ម្នាលនិគ្រោធ កាលណា អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ๔ យ៉ាង រមែងមានពាក្យគេសរសើរ

អ្នកនោះ ព្រោះខ្លួនជាអ្នកមានតបវត្ត ។ គេខំប្រឹងបំពេញសីល មិនត្រឡប់មកដើម្បីកេទថោកទាប ។ គេអាស្រ័យសេពសេនាសនៈស្ងាត់ ។បេ។ គេបានលះបង់នូវនីវរណធម៌ទាំង ៥ នេះ ដែលជាគ្រឿងធ្វើចិត្តឲ្យសៅហ្មង ជាគ្រឿងធ្វើប្រជ្ញាឲ្យថយកម្លាំង សម្រេចសម្រាន្តឥរិយាបថដោយការផ្សាយចិត្តប្រកបដោយមេត្តា ទៅកាន់ទិសទី ១ ។បេ។ គេរឭកឃើញខន្ធបញ្ចក: ដែលបានអាស្រ័យនៅអំពីមុន ជាច្រើនជាតិ គឺមួយជាតិខ្លះ ពីរជាតិខ្លះ បីជាតិខ្លះ បួនជាតិខ្លះ ប្រាំជាតិខ្លះ ។បេ។ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ មួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ ១ សែនជាតិខ្លះ ច្រើនសំវដ្តកប្ប (កប្បវិនាស) ខ្លះ ច្រើនវិវដ្តកប្ប (កប្បចម្រើន) ខ្លះ ច្រើនសំវដ្តវិវដ្តកប្ប (កប្បវិនាស និងកប្បចម្រើន) ខ្លះ ថា ក្នុងកាលឯណោះ អាត្មាអញបានមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុយ៉ាងនេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងកំពឯណោះ ក្នុងកំពនោះឯង អាត្មាអញបានមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុយ៉ាងនេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងកំពនេះ រមែងរឭកឃើញនូវខន្ធបញ្ចក:ដែលអាស្រ័យនៅអំពីមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ ម្នាលនិគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើដូច្នេះ ការខ្ពើមបាប

ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថាបរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើយ៉ាងនេះ ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថាបរិសុទ្ធដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្ចីមធម៌ផង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ត្រឹមតែប៉ុណ្ណោះ មិនទាន់ឈ្មោះថា ដល់កំពូលធម៌ ឬដល់ខ្ចីមធម៌នៅឡើយទេ បានដល់ត្រឹមតែស្រាយរបស់ធម៌ប៉ុណ្ណោះទេ ។

[๒๘] *និគ្រោធបរិព្វាជកក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសត្រឹមណាទើបឈ្មោះថាដល់កំពូលធម៌ផង ដល់ខ្ចីមធម៌ផង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងឲ្យដល់កំពូល ឲ្យដល់ខ្ចីមសារបស់ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសតែម្តង ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ ជាអ្នកសង្រួមដោយការសង្រួម ๔ យ៉ាង ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ๔ យ៉ាងតើដូចម្តេច ។បេ។ ម្នាលនិគ្រោធ កាលណា អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ๔ យ៉ាង ក៏រមែងមានពាក្យគេសរសើរអ្នកនោះព្រោះខ្លួនជាអ្នកមានតបវត្ត ។ គេទំប្រឹងបំពេញសីលមិនត្រឡប់មកដើម្បីកេរថោកទាប ។ គេអាស្រ័យសេពសេនាសនៈស្ងាត់ ។បេ។*

គេលះបង់នូវនីវរណៈទាំង ៥ នេះដែលជាឧបក្កិលេស ជាគ្រឿងធ្វើប្រជ្ញាឲ្យ
ថយកម្លាំង មានចិត្តប្រកបដោយមេត្តា ។បេ។ សម្រេចសម្រាន្តឥរិយាបថ
ដោយការផ្សាយចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ មិនមានប្រមាណ មិន
មានពៀរ មិនមានព្យាបាទ ។ គេរមែងឮឮកឃើញនូវខន្ធបញ្ចកៈ ដែលអា-
ស្រ័យនៅអំពីមុន ជាច្រើនជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រមែង
ឮឮកឃើញនូវខន្ធបញ្ចកៈ ដែលអាស្រ័យនៅអំពីមុនច្រើនជាតិ ព្រមទាំង
អាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ គេមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ
កន្លងចក្ខុមនុស្សសោមញ្ញ បានឃើញនូវសត្វទាំងឡាយ ដែលកំពុងច្យុត និង
ចាប់បដិសន្ធិដ៏ទាបថោក និងឧត្តម មានទ្រង់ទ្រាយល្អ និងអាក្រក់ ទៅកាន់
សុគតិ និងទុគ្គតិ រមែងដឹងច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម
ថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយ
វចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយបុគ្គល
ជាមិច្ឆាទិដ្ឋិ សមាទាននូវមិច្ឆាទិដ្ឋិកម្ម សត្វទាំងនោះ លុះបែកធ្លាយរាងកាយ
បន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ចំណែកខាងសត្វ
ទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយម
នោសុចរិត មិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវកម្មជា
សម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏
ទៅកើតឯសុគតិលោក គឺសួគ៌ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុមនុស្ស
សាមញ្ញ រមែងឃើញនូវសត្វទាំងឡាយ កំពុងច្យុត និងចាប់បដិសន្ធិដ៏ទាប

ថោក និងឧត្តម មានទ្រង់ទ្រាយល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដ៏ឆាប់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលនិគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើដូច្នេះ ការខ្ពើមបាបដោយ សេចក្តីព្យាយាម ជាគ្រឿងជុតកិលេស ឈ្មោះថាបរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ។ និគ្រោធបរិព្វាជកក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើដូច្នេះ ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងជុតកិលេស ឈ្មោះថាបរិសុទ្ធដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្ញីមធម៌ផង ។ ម្នាលនិគ្រោធ ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងជុតកិលេសទាំងប៉ុណ្ណោះ ទើបឈ្មោះថាដល់កំពូលធម៌ផង ដល់ខ្ញីមធម៌ផង ។ ម្នាលនិគ្រោធ អ្នកបាននិយាយនឹងតថាគតថា ព្រះមានព្រះភាគទ្រង់ទូន្មានពួកសាវ័កដោយធម៌ណា ពួកសាវ័កដែលព្រះអង្គទ្រង់ទូន្មានដោយធម៌ណាហើយ ដល់នូវសេចក្តីគាប់ចិត្ត បានបំពេញអរិយមគ្គ ជាព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្សរ័យដ៏ឧត្តម ធម៌របស់ព្រះមានព្រះភាគនោះ តើឈ្មោះដូចម្តេច ។ ម្នាលនិគ្រោធ តថាគតទូន្មានពួកសាវ័ក ដោយពាក្យប្រៀនប្រដៅណា ពួកសាវ័កដែលតថាគតបានទូន្មាន ដោយពាក្យប្រៀនប្រដៅណា ដល់នូវសេចក្តីត្រេកអរ បានបំពេញអរិយមគ្គ ជាព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្សរ័យដ៏ឧត្តម ហេតុ (របស់ពាក្យប្រៀនប្រដៅនោះ) ឧត្តមជាង វិសេសជាង ដូច្នេះឯង ។ កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ បរិព្វាជកទាំងនោះ ក៏បន្ទឺសំឡេងហ៊ោ សំឡេងខ្ទាំងថា ពួកយើងដែលជាអ្នក

រួមអាចារ្យជង្គា មិនដែលឃើញក្នុងដំណើរនេះទេ្បីយ ពួកយើងដែលជាអ្នករួមអាចារ្យជង្គា មិនដែលឃើញក្នុងដំណើរនេះទេ្បីយ ពួកយើងមិនធ្លាប់ដឹងឲ្យលើជាងពីនេះទៅទៀតទេ្បីយ ។

[๒๙] កាលណាសន្ធានគហបតីបានដឹងថា ឥទ្បូវនេះពួកបរិព្វាជកជាអន្យតិ្ថរិយទាំងនេះ កំពុងប្រុងស្តាប់កាសិតរបស់ព្រះមានព្រះភាគ ត្រាប់ត្រងស្រោតប្រសាទ តម្កល់ចិត្តមិនឲ្យរាយមាយ ដោយពិតជូច្នោះហើយ ទើបបាននិយាយពាក្យនេះ នឹងនិគ្រោធបរិព្វាជកថា បពិត្រនិគ្រោធ លោកបាននិយាយនឹងខ្ញុំរួចហើយថា នែគហបតី ដូចជាយើងរិះគន់ អ្នកត្រូវដឹងថា ព្រះសមណ-គោតមចរចាជាមួយនឹងអ្នកណាបាន ប្រទុះសាកច្ចាជាមួយនឹងអ្នកណាបាន ល្បងនូវភាពវាងវៃដោយប្រាជ្ញាជាមួយនឹងអ្នកណា (ដូចម្តេចបាន) ព្រោះប្រាជ្ញារបស់ព្រះសមណាគោតម វិនាសបាត់បង់ទៅក្នុងផ្ទះស្ងាត់ទៅហើយ ព្រះសមណាគោតមមិនហ៊ានចូលកាន់បរិស័ទទេ មិនអាចធ្វើការចរចានឹងអ្នកដទៃបានទេ បានជាលោកតែងអាស្រ័យសេនាសន:ដ៏ស្ងាត់ប៉ុណ្ណោះ ដូចមេគោខ្វាក់ភ្នែកម្ខាង តែងត្រាច់ទៅតែខាងៗ ជុំវិញ តែងគប់រកតែទីស្ងាត់ប៉ុណ្ណោះ ដូចម្តេចមិញ ប្រាជ្ញារបស់ព្រះសមណាគោតមវិនាសបាត់បង់ទៅក្នុងផ្ទះស្ងាត់ទៅហើយ ព្រះសមណាគោតមមិនហ៊ានចូលកាន់បរិស័ទ មិនអាចធ្វើការចរចានឹងអ្នកដទៃបានទេ បានជាលោកតែងអាស្រ័យនៅតែក្នុងសេនាសន:ស្ងាត់ ដូច្នោះឯង នែគហបតី ល្បងមើលចុះ (ប្រសិនបើ) ព្រះសមណាគោតម គប្បីមកកាន់បរិស័ទនេះ (មែន) ពួកយើងគួរសាកសួរលោកមួយប្រស្នាល្បង

មើលដែរ ពួកយើងត្រូវចាប់បង្វិលព្រះសមណគោតមនោះ ឲ្យដូចគេចាប់បង្វិលឆ្នាំងទេ (មិនខាន) បពិត្រលោកដ៏ចម្រើន ស្រាប់តែព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះស្តេចដល់មកក្នុងទីនេះ អើ ឥឡូវនេះ ដល់ហើយ ចូរលោកធ្វើព្រះអង្គឲ្យជាអ្នកមិនហ៊ានចូលមកកាន់បរិស័ទចុះ ចូរលោកធ្វើព្រះអង្គឲ្យដូចមេគោខ្វាក់ភ្នែកម្ខាង ដែលគ្រាច់ទៅតែខាងៗជុំវិញចុះ ចូរលោកសាកសួរព្រះអង្គដោយប្រស្នាចុះ ចូរបង្វិលព្រះសមណគោតមនោះឲ្យដូចជាគេចាប់បង្វិលឆ្នាំងទេចុះ ។ កាលសន្ធានគហបតីនិយាយយ៉ាងនេះហើយ និគ្រោធបរិព្វាជកអង្គុយនៅតែស្ងៀម អៀនខ្មាស ឱនក ជាក់មុខជ្រប់ស្រពោនទាល់ច្រកជ្រោះ ។

[๓๐] *លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា និគ្រោធបរិព្វាជកអង្គុយនៅស្ងៀម អៀនខ្មាស ឱនក ជាក់មុខជ្រប់ ស្រពោនទាល់ច្រកជ្រោះហើយ ក៏បានត្រាស់សួរនិគ្រោធបរិព្វាជកយ៉ាងនេះថា ម្នាលនិគ្រោធសម្តីនេះអ្នកបាននិយាយមែនឬ ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាននិយាយសម្តីនេះពិតមែន តាមដែលខ្ញុំព្រះអង្គជាមនុស្សល្ងង់ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អ្នកបានឮពួកបរិព្វាជកព្រឹទ្ធាចារ្យមានអាយុច្រើន ជាអាចារ្យ ប្រធានលើអាចារ្យនិយាយថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងកាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធទាំងឡាយមានព្រះភាគនោះ ទ្រង់ជួបជុំសមាគម ហើយបន្ទឹសំឡេងហ៊ោ សំឡេងខ្ទាំង*

ប្រកបនូវតិរច្ឆានកថាជាច្រើនយ៉ាង គឺនិយាយពីស្តេច និយាយពីចោរ ។បេ។ និយាយពីសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ដែលឥតប្រយោជន៍ថា ដូច្នេះខ្លះ ដូច្នោះខ្លះ ដូចជាអ្នកដែលរួមអាចារ្យផងគ្នា ក្នុងកាលឥឡូវនេះយ៉ាងនេះដែរឬ ឬថា ព្រះមានព្រះភាគទាំងនោះ តែងអាស្រ័យសេពសេនាសនៈដ៏ស្ងាត់ ជាទីតាំងនៅក្នុងព្រៃស្រោង ជាសេនាសនៈមានសំឡេងសន្ធឹកគឹងកងតិច ប្រាសចាកសម្តីអ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន ដូចជាតថាគតក្នុងកាលឥឡូវនេះ យ៉ាងនេះ ។ និគ្រោធបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពួកបរិព្វាជកព្រឹទ្ធាចារ្យមានអាយុច្រើន ជាអាចារ្យ ប្រធានលើអាចារ្យនិយាយគ្នាយ៉ាងនេះថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងកាលកន្លងទៅហើយ ព្រះមានព្រះភាគទាំងនោះ ជួបជុំសមាគមយ៉ាងនេះហើយ បន្ទីសំឡេងហ៊ោ សំឡេងខ្ទាំង ប្រកបនូវតិរច្ឆានកថាជាច្រើនយ៉ាង គឺនិយាយពីស្តេច និយាយពីចោរ ។បេ។ និយាយពីសេចក្តីចម្រើន និងសេចក្តីសាបសូន្យដែលឥតប្រយោជន៍ថា ដូច្នេះខ្លះ ដូច្នោះខ្លះ ដូចជាខ្ញុំព្រះអង្គជាអ្នករួមអាចារ្យផងគ្នាក្នុងកាលឥឡូវនេះយ៉ាងនេះក៏ទេ ព្រះមានព្រះភាគទាំងឡាយនោះ តែងអាស្រ័យសេពសេនាសនៈដ៏ស្ងាត់ ជាទីតាំងនៅក្នុងព្រៃស្រោង ជាសេនាសនៈ មានសំឡេងសន្ធឹកគឹងកងតិច ប្រាសចាកសម្តីរបស់អ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន ដូចព្រះមានព្រះភាគក្នុងកាលឥឡូវនេះយ៉ាងនេះដែរ ។ ព្រះអង្គត្រាស់ថា ម្នាលនិគ្រោធ វិញ្ញូជន

ចាស់ទុំដែលជាអ្នកមានសតិនោះ មិនមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹង (ដោយព្រះអង្គឯង) ហើយទ្រង់សម្តែងធម៌ដើម្បីញុំាងបុគ្គលដទៃឲ្យត្រាស់ដឹង ព្រះមានព្រះភាគអង្គនោះ ទ្រង់ទូន្មានព្រះអង្គបានហើយ ទើបសម្តែងធម៌ដើម្បីទូន្មានអ្នកដទៃ ព្រះមានព្រះភាគអង្គនោះ ទ្រង់សូបហើយ ទើបសម្តែងធម៌ ដើម្បីសេចក្តីសូបដល់អ្នកដទៃ ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្លងផុតហើយ ទើបសម្តែងធម៌ដើម្បីការឆ្លងដល់អ្នកដទៃ ព្រះមានព្រះភាគអង្គនោះ ទ្រង់រម្ងាប់កិលេសបានហើយ ទើបសម្តែងធម៌ដើម្បីសេចក្តីរម្ងាប់កិលេសដល់អ្នកដទៃ ។

[៣១] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ និគ្រោធបរិព្វាជកបានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទោសកំហុសបានគ្របសង្កត់នូវខ្ញុំព្រះអង្គ ព្រោះជាមនុស្សល្ងង់យ៉ាងណា ជាមនុស្សវង្វេងយ៉ាងណា ជាមនុស្សមិនឈ្លាសយ៉ាងណា ខ្ញុំព្រះអង្គបានពោលពាក្យឆ្គាំឆ្គងយ៉ាងនេះនឹងព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អត់នូវទោសតាមទោសដល់ខ្ញុំព្រះអង្គនោះ ដើម្បីសេចក្តីសង្រួមតទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនិគ្រោធ អើ ក៏ទោសកំហុសគ្របសង្កត់នូវអ្នក ព្រោះជាមនុស្សល្ងង់យ៉ាងណា ជាមនុស្សវង្វេងយ៉ាងណា ជាមនុស្សមិនឈ្លាសយ៉ាងណា អ្នកបានពោលពាក្យឆ្គាំឆ្គងណានឹងតថាគតយ៉ាងនេះហើយ ម្នាលនិគ្រោធ បើអ្នកឃើញទោសតាមទោសណាហើយ ត្រឡប់ធ្វើឲ្យសមគួរតាមធម៌វិញ តថាគតនឹងអត់ទោសនោះដល់

អ្នក ម្នាលនិគ្រោធ នេះឯងជាសេចក្តីចម្រើនក្នុងវិន័យរបស់ព្រះអរិយបុគ្គល ព្រោះមនុស្សណា ឃើញទោសតាមទោសហើយ ត្រឡប់ធ្វើឲ្យសមគួរតាមធម៌វិញ អ្នកនោះ រមែងដល់នូវសេចក្តីសង្រួមតទៅបាន ។ ម្នាលនិគ្រោធ មួយទៀត តថាគតបានពោលយ៉ាងនេះថា បុរសអ្នកជឿ ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ក៏ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសម្តែងធម៌ បុគ្គលនោះ កាលបើប្រតិបត្តិតាមធម៌ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) អស់ ៧ ឆ្នាំ ។ ម្នាលនិគ្រោធ ៧ ឆ្នាំ ចូរលើកទុកចុះ ។ បុរសជាអ្នកប្រាជ្ញ ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសម្តែងធម៌ បុគ្គលនោះ កាលបើប្រតិបត្តិតាមធម៌ ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) អស់ ៦ ឆ្នាំ ។ ៥ ឆ្នាំ ។ ៤ ឆ្នាំ ។ ៣ ឆ្នាំ ។ ២ ឆ្នាំ ។ ១ ឆ្នាំ ។ ម្នាលនិគ្រោធ ១ ឆ្នាំ ចូរលើកទុកចុះ ។ បុរសជាអ្នកប្រាជ្ញ ជាអ្នកមិនអួតអាង មិន

មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសម្តែងធម៌ បុគ្គលនោះ កាលបើប្រតិបត្តិតាមធម៌ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) អស់ ៧ ខែ ។ ម្នាលនិគ្រោធ ៧ ខែ ចូរលើកទុកចុះ ។ ៦ ខែ ។ ៥ ខែ ។ ៤ ខែ ។ ៣ ខែ ។ ២ ខែ ។ ១ ខែ ។ កន្លះខែ ។ ម្នាលនិគ្រោធកន្លះខែ ចូរលើកទុកចុះ ។ បុរសជាអ្នកប្រាជ្ញ ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសម្តែងធម៌ បុគ្គលនោះ កាលបើប្រតិបត្តិតាមធម៌ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) អស់ ៧ ថ្ងៃ ។ ម្នាលនិគ្រោធ សមតែអ្នកមានគំនិតយ៉ាងនេះថា ព្រះសមណ-គោតមបាននិយាយយ៉ាងនេះ ព្រោះចង់បានកូនសិស្ស ។ ម្នាលនិគ្រោធ តែថាអ្នកមិនត្រូវឃើញហេតុនុ៎ះយ៉ាងនេះឡើយ អ្នកណាជាអាចារ្យរបស់ពួកអ្នក អ្នកនោះ ចូរនៅជាអាចារ្យរបស់ពួកអ្នកដដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិតយ៉ាងនេះថា ព្រះសមណាគោតមប្រាថ្នាដើម្បីញុំាង

ពួកយើងឲ្យកក្រើកចាកឧទ្ទេស ទើបបានត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវយើញហេតុនុ៎ះ យ៉ាងនេះទ្បើយ ឧទ្ទេសណាជារបស់អ្នក ឧទ្ទេសនោះក៏នៅជាឧទ្ទេសរបស់អ្នកជដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិតយ៉ាងនេះថា ព្រះសមណគោតមប្រាថ្នា ដើម្បីញុំាងពួកយើងឲ្យកក្រើកចាកអាជីវៈ ទើបបានត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ អ្នកមិនត្រូវយើញហេតុនុ៎ះយ៉ាងនេះទ្បើយ អាជីវៈណាជារបស់អ្នក អាជីវៈនោះក៏នៅជាអាជីវៈរបស់អ្នកជដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិតយ៉ាងនេះថា ពួកធម៌ណាជាអកុសល រាប់ចូលក្នុងអកុសលរបស់ជនដែលរួមអាចារ្យផងគ្នា ព្រះសមណគោតម ប្រាថ្នានឹងញុំាងពួកអ្នក ឲ្យតាំងនៅក្នុងធម៌ទាំងនោះ ទើបបានត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវយើញហេតុនុ៎ះយ៉ាងនេះទ្បើយ ពួកធម៌ជាអកុសល រាប់ចូលក្នុងអកុសលនោះរបស់ជនរួមអាចារ្យផងគ្នា ចូរនៅជាអកុសលធម៌ដដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិតយ៉ាងនេះថា ពួកធម៌ណាជាកុសល រាប់ចូលក្នុងកុសលរបស់ជនជាអ្នករួមអាចារ្យផងគ្នា ព្រះសមណ-គោតមប្រាថ្នាដើម្បីញុំាងពួកអ្នក ឲ្យឃ្លាតចាកកុសលធម៌ទាំងនោះ ទើបបានត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវយើញហេតុនុ៎ះយ៉ាងនេះទ្បើយ ពួកធម៌ជាកុសល រាប់ចូលក្នុងកុសលនោះរបស់ពួកជនរួមអាចារ្យផងគ្នា ចូរនៅជាកុសលធម៌ដដែលចុះ ។ ម្នាលនិគ្រោធ តថាគតបានពោលយ៉ាងនេះព្រោះចង់បានអន្តេវាសិកក៏ទេ មានប្រាថ្នាដើម្បីញុំាងពួកអ្នកឲ្យកក្រើក

*ចាកឧទ្ទេស ទើបបានពោលយ៉ាងនេះក៏ទេ មានប្រាថ្នាដើម្បីញុំាងពួកអ្នក ឲ្យ
កន្ត្រើកចាកអាជីវៈ ទើបបានពោលយ៉ាងនេះក៏ទេ ពួកធម៌ណា ជាអកុសល
រាប់ថា ជាអកុសលរបស់ពួកជនដែលរួមអាចារ្យផងគ្នា តថាគតប្រាថ្នាដើម្បី
ញុំាងពួកអ្នកឲ្យតាំងនៅក្នុងធម៌ទាំងនោះ ទើបបានពោលយ៉ាងនេះក៏ទេ ពួកធម៌
ជាកុសល រាប់ថាជាកុសលរបស់ពួកជនដែលរួមអាចារ្យផងគ្នា តថាគតប្រាថ្នា
ដើម្បីញុំាងពួកអ្នកឲ្យឃ្លាតចាកធម៌ទាំងនោះ ទើបបានពោលយ៉ាងនេះក៏ទេ ។
ម្នាលនិគ្រោធ មួយទៀត ពួកធម៌ជាអកុសលដែលបុគ្គលលះមិនទាន់បាន
ប្រព្រឹត្តទៅដើម្បីសេចក្តីសៅហ្មង ប្រព្រឹត្តទៅដើម្បីសេចក្តីកើតទៀត ប្រកប
ដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល ជាបច្ច័យដល់សេចក្តីកើតចាស់
ស្លាប់ទៅខាងមុខ តថាគតសម្តែងធម៌ ដើម្បីលះបង់នូវធម៌ជាអកុសលទាំង-
ឡាយនោះ ។ កាលបើពួកអ្នកប្រតិបត្តិសមគួរហើយ ធម៌ទាំងឡាយ ប្រកប
ដោយសេចក្តីសៅហ្មង មុខជានឹងសាបសូន្យទៅ ធម៌ទាំងឡាយជាទីតាំងនៃ
សេចក្តីបរិសុទ្ធនឹងចម្រើនឡើង ពួកអ្នករាល់គ្នាមុខជានឹងធ្វើឲ្យជាក់ច្បាស់នូវ
ការបំពេញប្រាជ្ញា ដើម្បីមគ្គ និងសេចក្តីផូរផង់នៃប្រាជ្ញា ដើម្បីដល់ដោយ
ប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង
៤) ។ កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ
ក៏អង្គុយនៅស្ងៀម អៀនខ្មាស ឱនក ជាក់មុខជ្រប់ ស្រពោន ទាល់ប្រាជ្ញា
ព្រោះមារចូលជ្រែកចិត្ត ។*

[๓๒] *គ្រានោះឯង ព្រះមានព្រះភាគ មានសេចក្តីត្រិះរិះដូច្នេះថា*

មោឃបុរសទាំងអស់នេះ ត្រូវមានចិត្តបាបចូលជ្រែកហើយ ព្រោះថា សូម្បីតែម្នាក់មុខជាគ្មានគំនិតយ៉ាងនេះថា ណ្ហើយចុះ ពួកយើងទាំងអស់គ្នា ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះសមណគោតម ដើម្បីសេចក្តីដឹងទូទៅត្រឹម ๗ ថ្ងៃប៉ុណ្ណោះ នឹងយូរប៉ុន្មាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បន្ទឺន្ទវសីហនាទក្នុងអារាមនៃបរិព្វាជក ជារបស់នៃនាងខុទ្ទកនិកាទេវី ហើយទ្រង់ហោះទៅឯទៅកាន់វេហាសដ្ឋាន ត្រឡប់ទៅគង់លើភ្នំគិជ្ឈកូដវិញ ។ ឯសន្ធានគហបតី ក៏ចូលទៅកាន់ក្រុងរាជគ្រឹះ ក្នុងពេលនោះដែរ ។

ខុទ្ទកនិកសូត្រទី ๒ ចប់

អដ្ឋកថា

ឧទុម្ពរិកសូត្រ

[១៨] ឧទុម្ពរិកសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ ក្នុងឧទុម្ពរិកសូត្រនោះ មានពណ៌នាតាមលំដាប់បទដូច្នេះ បទថា **បរិព្វាជកោ** សំដៅយកធន្នបរិព្វាជក បទថា **ឧទុម្ពរិកាយ បរិព្វាជការាមេ** បានដល់ក្នុងអារាមបរិព្វាជក ក្នុងសម្នាក់របស់នាងឧទុម្ពរិកាទេវី ។ បទថា **សន្ធានោ** ជាឈ្មោះរបស់គហបតីនោះ ។ គហបតីនោះ មានអានុភាពច្រើន ជាកំពូលបុរសក្នុងចំនួនឧបាសក ៥០០ នាក់ ចោមរោមត្រាច់ទៅ ជាព្រះអនាគាមី (ដែរ) ។ ព្រះមានព្រះភាគបានសរសើរឧបាសកនេះ ត្រង់កណ្តាលមហាបរិស័ទថា ម្នាលភិក្ខុទាំងឡាយ សន្ធានគហបតីប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមានសេចក្តីជ្រះថ្លាមុតមាំក្នុងព្រះតថាគត តម្កល់ខ្ជួននៅក្នុងព្រះសទ្ធម្ម អង្ត ៦ ប្រការ តើដូចម្តេច ។ គឺដោយការជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ ១ មិនញាប់ញ័រក្នុងព្រះធម៌ ១ មិនញាប់ញ័រក្នុងព្រះសង្ឃ ១ បរិបូណ៌ក្នុងអរិយសីល ១ បរិបូណ៌ដោយអរិយញ្ញាណ ១ បរិបូណ៌ដោយអរិយវិមុត្តិ ១ ម្នាលភិក្ខុទាំងឡាយ សន្ធានគហបតីប្រកបដោយអង្ត ៦ ប្រការ យ៉ាងនេះឯង ទើបឈ្មោះថា មានសេចក្តីជ្រះថ្លាស៊ប់សួនក្នុងតថាគត តាំងនៅក្នុងព្រះសទ្ធម្ម ។ សន្ធានគហបតីនោះ អធិដ្ឋានអង្គឧបោសថអំពីព្រលឹម ហើយក្នុងវេលាព្រឹកក៏ថ្វាយទានចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ កាលពួកភិក្ខុទៅវិហារ ហើយ កើតសេចក្តីរំខានព្រោះសំឡេងបៀតបៀនរបស់ក្មេងតូច និងក្មេងធំក្នុង

ស្រុក ទើបចេញទៅដោយគិតថា នឹងស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ។ ដោយ ហេតុនោះ ទើបលោកពោលថា គហបតីឈ្មោះសន្ធានបានចេញអំពីក្រុង រាជគ្រឹះ ដើម្បីគាល់ព្រះមានព្រះភាគ ក្នុងវេលាថ្ងៃជ្រេពីត្រង់ ។

បណ្តាបទទាំងនោះ បទថា **ឧិវាឧិវសេ្សវ** បានដល់ វេលាហួសត្រង់ ឈ្មោះថា វេលារសៀល អធិប្បាយថា សន្ធានគហបតីនោះ បានចេញទៅ ក្នុងវេលារសៀល គឺត្រាច់ទៅវេលាត្រជាក់ ។

បទថា **បដិសល្ងីនោ** បានដល់ ប្រមូលចិត្តចាកអារម្មណ៍ មានរូបជាដើម នោះៗ ពួនសម្ងំ គឺជាអ្នកមានចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃការ សោយ ការត្រេកអរក្នុងឈាន ។ បទថា **មនោភាវនីយានំ** គឺអ្នកញ្ចាំង ចិត្តឲ្យចម្រើន បានដល់ ចិត្តរបស់អ្នករព្រកដល់ ធ្វើទុកក្នុងចិត្ត រមែងជាចិត្ត ដែលប្រាសចាកនីវរណៈ គឺចិត្តខ្ពស់ឡើង ចម្រើនឡើង ។

[១៩] បទទាំងឡាយ បទថា **ឧន្នាឧិនិយា** ជាដើម គប្បីជ្រាបតាម នយដោយពិស្តារក្នុងបោដ្ឋបាទសូត្រនុ៉ះឯង ។ បទថា **យាវតា** គឺមានចំនួនប៉ុន ណា ។ បទថា **អយន្តេសំ អញ្ញតរោ** សេចក្តីថា បណ្តាសាវកទាំងនោះ សន្ធានគហបតីនេះ រាប់បញ្ចូលក្នុងសាវកទាំងនោះ ឬជាសាវកម្នាក់ ។ បានព្ម ថា ពួកសាវករបស់ព្រះមានព្រះភាគ ចំពោះគ្រហស្ថដែលជាព្រះអនាគាមី មានចំនួន ៥០០ នាក់ អាស្រ័យនៅក្នុងក្រុងរាជគ្រឹះ ។ និគ្រោធបរិព្វាជក ពោលថា **អយំ តេសំ អញ្ញតរោ** ដូច្នេះជាដើម សំដៅដល់ពួកឧបាសក នីមួយៗ មានបរិវារ ៥០០ នាក់ ។ និគ្រោធបរិព្វាជកប្រាថ្នាការចូលមករបស់

គហបតីនោះ ទើបពោលថា **អប្បេវនាម** ដូច្នេះ ។ ហេតុនៃសេចក្តីប្រាថ្នា
ឧានពោលហើយក្នុងឧោដ្ឋឧាទសូត្រន៉ុះឯង ។

[២០] បទថា **ឯតទវោច** ឧានដល់ សន្ធានគហបតីកំពុងដើរមក
ឧានពោលពាក្យនេះថា **អញ្ញថា ខោ ឥមេ** ជាដើម ព្រោះខ្ញុនឧានស្តាប់ពាក្យ
របស់បរិព្វាជកទាំងនោះ ក្នុងចន្លោះផ្លូវន៉ុះឯង ។ ក្នុងបទទាំងនោះ បទថា **អញ្ញ-
តិត្ថិយា** សេចក្តីថា ដែលឈ្មោះថា **អន្យត្ថិរិយ** ព្រោះជាតិរិយដទៃ ដោយការ
ឃើញខ្លះ មារយាទខ្លះ កិរិយាខ្លះ អាចារខ្លះ ការនៅខ្លះ ឥរិយាបថខ្លះ ។ បទ
ថា **សន្ត្ថម្ម សមាគម្ម** ឧានដល់ ក្នុងស្ថានទី (ពួកបរិព្វាជក) ទៅមករួមគ្នា
អង្គុយជាក្រុម ។ បទថា **អរញ្ញេ វនបត្ថានិ** ឧានដល់ ដងព្រៃក្នុងព្រៃ គឺ
សេនាសនៈដែលឆ្ងាយផុតអំពីព្រំដែនស្រុក ។ បទថា **បន្ថានិ** គឺលំនៅឆ្ងាយចាក
ដែនរបស់មនុស្ស ។ បទថា **អប្បសទ្ទានិ** គឺមានសំឡេងតិច សូម្បីតែ
សំឡេង អ្នកធ្វើដំណើរ ដែលដើរឆ្លងទៅក្បែរលំនៅ ។ បទថា **អប្ប-
និគ្ឃោសានិ** គឺមានសំឡេងតិចៗ ដោយមានសំឡេងមិនគឹកកង ។ បទថា
វីជនវាតានិ គឺប្រាសចាកវាទៈរបស់អ្នកដែលសញ្ចរទៅខាងក្នុង ។ បទថា
មនុស្ឃរាហសេយ្យាកានិ ឧានដល់ សមគួរ គឺសមគួរដល់ការធ្វើកម្មកំឧាំង
របស់មនុស្ស ។ បទថា **បដិសល្ឋានសារុប្បានិ** ឧានដល់ សមគួរដល់ការនៅ
ម្នាក់ឯង ព្រោះដូច្នោះ ទើបសន្ធានគហបតីគិតថា ឱព្រះសាស្តារបស់យើង
សេពសេនាសនៈបែបនេះ ទើបផ្គងអញ្ជលីលើសិរសា ហើយអង្គុយបន្ទឺឧទាន

នេះ ។ បទថា **ឯវំ វុត្តេ** *សេចក្តីថា កាលសន្ទានគហបតីបន្ទឺឧទានយ៉ាងនេះ ទើបនិគ្រោធបរិព្វាជកគិតថា គហបតីនេះសូម្បីអង្គុយក្នុងសម្នាក់អញ ក៏នៅសរសើរព្រះសាស្តារបស់ខ្លួនតែមួយអង្គ ដោយមិនសម្គាល់អញថា មាននៅអញនឹងឲ្យការកម្រើក ដែលកើតឡើងក្នុងគហបតីនោះ ធ្លាក់ទៅខាងលើព្រះសមណគោតម ទើបពោលពាក្យនេះជាមួយសន្ទានគហបតី ។ បទថា* **យគ្ឃេ** *ជានិបាត ប្រើក្នុងអត្ថថា ជំទាស់ ។ បទថា* **ជានេយ្យាសិ** *ប្រែថា គួរដឹង គួរយើញ ។ បទថា* **កេន សមណោ គោតមោ សល្លបតិ** *សេចក្តីថា ព្រះសមណគោតម រមែងចរចា និយាយ ពោលជាមួយអ្នកណា ដោយហេតុដូចម្តេច ។ មានអធិប្បាយដូចម្តេច មានអធិប្បាយថា ប្រសិនបើ ហេតុនៃការចរចាណាមួយ គប្បីមាន ឬប្រសិនបើ អ្នកណាម្នាក់ ត្រូវការចរចា គប្បីទៅសម្នាក់ព្រះសមណគោតម គប្បីចរចា តែមិនមានហេតុ អ្នកណាម្នាក់ ក៏មិនទៅរកព្រះអង្គ ។ ព្រះសមណគោតមនោះ ចរចាជាមួយនឹងអ្នកណាហ្ន៎ កាលមិនបានចរចា ក៏នឹងបន្ទឺព្រះសីហនាទដូចម្តេចបាន ។ បទថា* **សាកច្ឆំ** *គឺ សន្ទនារួមគ្នា ។ បទថា* **បញ្ញាវេយ្យត្តិយំ** *បានដល់ ភាពជាអ្នកឈ្លាសក្នុងញាណ ដោយឧត្តរនយ និងបច្ចុត្តរនយ ។*

បទថា **សុញ្ញាគារគតា** *គឺវិនាសទៅហើយក្នុងសុញ្ញាគារ ។ និគ្រោធ-បរិព្វាជកពោលថា ព្រោះព្រះសមណគោតម បានសម្រេចព្រះបញ្ញា ត្រឹមតែបន្តិចបន្តួចត្រង់គល់ពោធិ៍ កាលព្រះសមណគោតមតែមួយព្រះអង្គ អង្គុយក្នុងសុញ្ញាគារ ព្រះបញ្ញានោះក៏វិនាសទៅ តែព្រះសមណគោតមនោះ គប្បីអង្គុយ*

ច្រឡូកច្រឡំដោយពួកគណៈដូចយើង ព្រះបញ្ញារបស់ព្រះអង្គ ក៏នឹងមិនគប្បីវិនាសទៅ ។ បទថា **អបរិសាវចរោ** បានដល់ មិនអាចចូលកាន់ទីប្រជុំបាន ព្រោះមិនក្លៀវក្លា ។ បទថា **ឆាលំ សល្លាបាយ** គឺមិនអាចចរចាប្រាស្រ័យបាន ។ បទថា **អន្តបន្តានេវ** សេចក្តីថា ព្រះសមណគោតមខ្លាចចំពោះបញ្ហាថា អ្នកណាម្នាក់ គប្បីសួរបញ្ហានឹងតថាគត ដូច្នេះ ទើបសេពទីដ៏ស្ងាត់ត្រង់កន្លែងមួយ គឺសេនាសនៈដែលស្ងាត់ ។ បទថា **គោកាណា** បានដល់ មេគោមានក្អែកខ្វាក់ម្ខាង បានឮថា មេគោខ្វាក់នោះ ដើរវិលវាល់ក្នុងទីស្ងាត់ខាងក្នុងប៉ុណ្ណោះ បានឮថា មេគោខ្វាក់នោះ ប្រាថ្នានឹងទៅកាន់ដងព្រៃ ក៏មិនអាចទៅបាន ព្រោះជាគោក្អែកខ្វាក់ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមេគោខ្វាក់នោះ រមែងខ្លាចចំពោះស្មៅកឈើ មែកឈើ ឬបន្ទាប់ៈពាល់ត្រូវ ។ រមែងមិនអាចនឹងទៅនៅចំពោះមុខហ្វូងគោបាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមេគោខ្វាក់នោះ រមែងខ្លាចស្នែងគោ ត្រចៀកគោ ឬកន្ទុយគោប៉ៈពាល់ ។

សព្ទថា **ឥង្ឃ** ជានិបាត ប្រើក្នុងអត្ថថា សាកសួរ ។ បទថា **សំសាទេយ្យាម** បានដល់ ខ្ញុំគប្បីល្បងមើល គឺឲ្យដល់សេចក្តីមិនជាច់ស្រេចប៉ុណ្ណោះដោយការសួរបញ្ហាប្រការមួយ ។ បទថា **តុច្ឆកុម្ភីវ ឆំ** បានដល់ (គប្បីបង្វិល) ព្រះសមណគោតមនោះ ដូចបុគ្គលបង្វិលឆ្នាំងទទេ ដូច្នោះ ។ បទថា **ឱរោធេយ្យាម** គឺគប្បីចាប់បង្វិល ។ ពិតហើយ ឆ្នាំងដែលពេញហើយ ប្រមៀលទៅខាងនោះខាងនេះ បុគ្គលចាប់បង្វិលមិនបាន ចំណែកឆ្នាំងទទេ បុគ្គលអាចត្រឡប់ចាប់បង្វិល តាមសេចក្តីពេញចិត្តបាន យ៉ាងណា និគ្រោធបរិព្វាជកនេះ

រមែងពោលថា អញនឹងបង្វិលព្រះសមណគោតម ដូចគ្នានឹងបង្វិលឆ្នាំងដែលទទេដោយជុំវិញ ដោយការបៀតបៀនដោយវាទៈ ព្រោះព្រះអង្គមានបញ្ញាត្រូវកម្ចាត់ចេញហើយ ។ បរិព្វាជក កាលមិនឃើញវង់ព្រះនលាដពណ៌មាសរបស់ព្រះសាស្តា ទើបសម្តែងកម្លាំងរបស់ខ្លួន ក្នុងទីកំបាំងព្រះភក្ត្រព្រះទសពល គំរាមទទេៗ ព្រាវៗ មានប្រការផ្សេងៗ ដូចជាកូនមនុស្សចណ្ឌាល បំបែកបំបាក់ខត្តិយកុមារ ដែលមិនបានលាយឡំដោយជាតិ និងដូចចចក បំបែកបំបាក់កេសរសីហរាជពិតៗ ដោយកម្លាំង ដូច្នោះ ។ ឧបាសកក៏គិតថា បរិព្វាជកនេះសម្បុត គំរាមហួសពេក ព្យាយាមដោយមិនមានប្រយោជន៍ ដូចលូកជើងទៅដើម្បីប៉ះអវិចី ដូចលាដៃទៅដើម្បីចាប់ភវគ្គព្រហ្មដូច្នោះ បើព្រះសាស្តារបស់យើងគប្បីមកកាន់ទីនេះ ព្រះអង្គគប្បីទម្លាក់ទង់ គឺមានះ ដែលបរិព្វាជកនេះ លើកឡើងដរាបដល់ភវគ្គព្រហ្ម ដោយហានៈតែមួយ ។ សូម្បីព្រះមានព្រះភាគ ទ្រង់ក៏បានស្តាប់ការសន្ទនាប្រាស្រ័យនោះ ។ ដោយហេតុនោះ ទើបលោកពោលថា **អស្សោសិ ខោ ។បេ។ ឥមំ កថាសល្លាបំ** *ដូច្នេះ ។*

[๒๑] *បទថា* **សុមាគធាយ** *សេចក្តីថា បុរសណាម្នាក់អង្គុយត្រង់មាត់ស្រះបោក្ខរណី ឈ្មោះសុមាគធា បានឃើញពួកអសុរ កំពុងចូលទៅកាន់កពអសុរ តាមទង់ផ្កាឈូក ។ អាហារ លោកហៅថា* **ឆិរាយ** *ក្នុងបទថា* **មោរឆិរាយេ** *នេះ អធិប្បាយថា បានដល់ ទីដែលបុគ្គលឲ្យចំណី ព្រមទាំងឲ្យអភ័យដល់សត្វក្អែក ។ បទថា* **អព្ភោកាសេ** *គឺក្នុងស្ថានទីទួល ។ បទថា* **អស្សាសប្បត្តា** *បានដល់ ប្រសព្វសេចក្តីត្រេកអរ គឺបានទួរសោមនស្ស ។*

បទថា **អជ្ឈាសយំ** គឺជានិស្សយនៃមគ្គជាន់ខ្ពស់ ។ បទថា **អាធិព្រហ្មចរិយំ** ឧានដល់ អរិយមគ្គ ពោល គឺព្រហ្មចរិយខាងដើម ។ និគ្រោធបរិព្វាជកឧាន ពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកសាវកដែលព្រះមានព្រះភាគទ្រង់ ទូន្មានហើយ បំពេញអរិយមគ្គដែលជាអាទិព្រហ្មចរិយ: ដោយអធ្យាស្រ័យ ហើយ ដល់នូវការរួចស្រឡះ រមែងដឹងចំពោះដោយការសម្រេចអរហត្ត ដោយធម៌ឈ្មោះអ្វី ។

[២២] បទថា **វិប្ឋកតា** ឧានដល់ ដែលឈប់បង្អង់នៅមិនទាន់ចប់ ព្រោះការមករបស់តថាគតជាបច្ចុ័យ ។ ព្រះមានព្រះភាគ ទ្រង់បវារណាដោយ សព្វញ្ញូថា អ្នកចូរពោលមកចុះ តថាគតនឹងសម្តែងធម៌នោះ ឲ្យដល់ទីបំផុត ។ បទថា **ឧុជ្ជានំ ខោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ បរិព្វាជក ហើយទ្រង់ត្រិះរិះថា បរិព្វាជកនេះ រមែងសួរដល់ធម៌ដែលតថាគត សម្តែងដល់ព្រះសាវក ដែលជាសាវកបដិបទា បើតថាគតពោលធម៌នោះ តាំងពីដើមដល់បរិព្វាជកនេះ បរិព្វាជកនេះ មិនដឹងនូវធម៌ដែលតថាគតពោល ហើយ បរិព្វាជកនេះ ជាអ្នកមានវាទ:ខ្ពើមឧាប ដោយសេចក្តីព្យាយាម ណ្ហើយចុះ តថាគតនឹងឲ្យគេសួរបញ្ហាក្នុងវិស័យនៃវាទ:នោះប៉ុណ្ណោះ ហើយ នឹងសម្តែងសេចក្តីមិនមានប្រយោជន៍ នៃលទ្ធិរបស់សមណព្រាហ្មណ៍ជាច្រើន ហើយនឹងព្យាករបញ្ហានេះក្នុងកាលជាក្រោយ ទើបត្រាស់ថា **ឧុជ្ជានំ ខោ ឯតំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សកេ អាចរិយកេ** គឺក្នុងលទ្ធិអាចារ្យរបស់

ខ្លួន ។ បទថា **អធិដ្ឋេតុញ្ចេ** *គឺក្នុងការខ្ពើមបាប ដោយសេចក្តីព្យាយាម ។ បទថា* **កថំ សន្តា** *គឺដូចម្តេច ។ បទថា* **តថោដ្ឋិតុច្ឆា** *បានដល់ ការខ្ពើមបាប គឺការនឿយណាយចំពោះបាបដោយសេចក្តីព្យាយាម ។ បទថា* **បរិបុណ្ណា** *គឺបរិសុទ្ធហើយ ។ បទថា* **កថំ អបរិបុណ្ណា** *បានដល់ អ្នកចូរសួរយ៉ាងនេះថា មិនបរិសុទ្ធដូចម្តេច ។ បទថា* **យត្រ ហិ នាម** *គឺ* **យោ នាម ។**

[๒๓] *បទថា* **អប្បសទ្ទេ កត្វា** *បានដល់ មិនឲ្យមានសំឡេងខ្លាំង គឺឲ្យមានសំឡេងតិច ។ បានឮថា បរិព្វាជកនោះគិតថា ព្រះសមណគោតម រមែងមិនប្រាប់ត្រឹមតែបញ្ហាមួយ សូម្បីការសន្ទនាប្រាស្រ័យរបស់ព្រះសមណ-គោតមនោះ មិនច្រើនពេក ឯជនទាំងនេះរមែងបណ្តាយតាម និងសរសើរព្រះសមណគោតមតាំងពីដើម ណ្តើយចុះ អញនឹងធ្វើជនទាំងនេះ ឲ្យស្ងាត់សំឡេង ហើយពោលឯង ។ បរិព្វាជកបានធ្វើតាមនោះហើយ ។ ដោយហេតុនោះ ទើបលោកពោលថា* **អប្បសទ្ទេ កត្វា** *ជាដើម ។*

ក្នុងបទជាដើមថា **តថោដ្ឋិតុច្ឆាទា** *សេចក្តីថា តថាគតពោលការខ្ពើមបាបដោយតបៈ រមែងកាន់យកការខ្ពើមបាបដោយតបៈនោះថាជាសារៈដោយចិត្តខ្លះ រមែងតម្កល់មាំ ការខ្ពើមបាបដោយតបៈនោះ ប្រកបសេចក្តីព្យាយាមក្នុងការទ្ទួន្ទានខ្លួនឯង ដែលមានប្រការផ្សេងៗ ហើយនៅដោយកាយខ្លះ ។ បទថា* **តបស្សី** *គឺអាស្រ័យតបៈ ។ បទថា* **អចេលកោ** *ជាដើម គប្បីជ្រាបដោយនយពិស្តារ ក្នុងសីហនាទសូត្រ ។*

[๒๔] *បទថា* **តបំ សមាទិយតិ** *បានដល់ ប្រកាន់តបៈ មានភាពជា*

អចេលក៍ជាដើម គឺប្រកាន់យ៉ាងមុតមាំ ។ បទថា **អត្តមនោ ហោតិ** សេចក្តីថា បរិព្វាជកត្រេកអរថា មានអ្នកដទៃណាក្នុងតបៈនេះដូចអញ ។ បទថា **បរិ-បុណ្ណសង្ពប្បោ** ឧានដល់ មានសេចក្តីត្រិះរិះដល់ទីបំផុតយ៉ាងនេះថា ត្រឹមនេះក៏ល្មម ។ ពាក្យនេះមកដោយអំណាចនៃពួកតិរ្ថិយ គប្បីសម្តែងដោយអំណាចការទាក់ទងក្នុងផ្ទូវសាសនា ។ ពិតហើយ បុគ្គលខ្ជះសមាទានធុតង្គ បុគ្គលនោះ រមែងត្រេកអរដោយធុតង្គនោះថា បុគ្គលដទៃណាហ្នឹងទ្រទ្រង់ធុតង្គដូចអញ ឈ្មោះថា មានសេចក្តីត្រិះរិះបរិបូណ៌ហើយ ។ បទថា **តបស្សិនោ ឧបក្ពិលេសោ ហោតិ** ឧានដល់ នេះគឺឧបក្ពិលេសរបស់អ្នកមានតបៈទាំងពីរប្រការនោះ ។ តថាគតរមែងពោលថា តបៈជាឧបក្ពិលេសដល់បុគ្គលនោះ ដោយហេតុប្រមាណប៉ុណ្ណេះ ។ បទថា **អត្តានុក្ពំសេតិ** ឧានដល់ លើកខ្ជូន គឺតម្តើងខ្ជូនថា អ្នកណានឹងមានដូចអញ ។ បទថា **បរំ វម្ភេតិ** ឧានដល់ សម្ទុត គឺមើលងាយអ្នកដទៃថា បុគ្គលនេះមិនដូចអញ ។ បទថា **មជ្ជតិ** គឺស្រវឹង ដោយការស្រវឹង គឺមានះ ។ បទថា **មុច្ចតិ** ឧានដល់ គ្មានសតិ គឺជាប់ ឧានដល់ ជំពាក់ ។ បទថា **មធមាបជ្ជតិ** ឧានដល់ ដល់សេចក្តីស្រវឹងថា វត្ថុនេះប៉ុណ្ណោះជាសារៈ ។ បរិព្វាជកនេះ សូម្បីបួសក្នុងសាសនាហើយ ជាអ្នកមានធុតង្គបរិសុទ្ធ មិនមែនមានកម្មដ្ឋានបរិសុទ្ធទេ ។ រមែងប្រកាន់ធុតង្គប៉ុណ្ណោះថាជាសារៈ ដូចប្រកាន់ព្រះអរហត្ត ។ ក្នុងបទថា **លាភសក្ការ-សិលោកំ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា

ដែលឈ្មោះថា **លាភ** ព្រោះអត្ថថា ឧានបច្ច័យ ៤ ។ បច្ច័យទាំងនោះ

ឯង ដែលតាក់តែងធ្វើយ៉ាងល្អបានមក ឈ្មោះថា សក្ការៈ ។ ការពោលសរសើរ ឈ្មោះថា **សិលោក** *។ បទថា* **ឯព្វត្តេតិ** *សេចក្តីថា លាភជាច្រើនរមែងកើតឡើង ព្រោះអាស្រ័យការៈជាអាចេលក៍ជាដើម ឬការសមាទានធុតង្គរបស់បុគ្គលនោះ ព្រោះដូច្នោះ ទើបបរិព្វាជកពោលថា* **ឯព្វត្តេតិ** *ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយអំណាចនៃអ្នកមានតបៈទាំងពីរប្រភេទ ដោយនយដែលពោលកាលមុនទុំៈឯង ។*

បទថា **ភោគាសំ អាបជ្ជតិ** *បានដល់ ដល់ ២ ចំណែក គឺធ្វើឲ្យជា ២ ចំណែក ។ បទថា* **ខមតិ** *គឺពេញចិត្ត ។ បទថា* **ន ខមតិ** *គឺមិនពេញចិត្ត ។ បទថា* **សាបេក្ខោ បជហាតិ** *បានដល់ អ្នកមានសេចក្តីប្រាថ្នា រមែងលះ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ពេលព្រឹក បុគ្គលនោះបរិភោគនំ ។ ពេលនោះ ទាយកបាននាំសាច់ទៅ ឲ្យបុគ្គលនោះទៀត ។ បុគ្គលនោះមានការគិតយ៉ាងនេះថា ឥឡូវនេះ កាលណា អញនឹងបានយ៉ាងនេះទៀត ។ បើជីងយ៉ាងនេះ អញមិនគួរបរិភោគនំពេលព្រឹក អញអាចធ្វើអ្វីបាន ទើបបំណងលះបង់ដូចការលះបង់ជីវិត ដោយការពោលថា ទៅចុះ លោកដ៏ចម្រើន លោកទុំៈឯងចូរបរិភោគ ។ បទថា* **គធិតោ** *គឺកើតត្រេកត្រអាលហើយ ។ បទថា* **មុច្ឆិតោ** *បានដល់ វង្វេងហើយ ព្រោះសេចក្តីប្រាថ្នាមានកម្លាំង គឺជាអ្នកមិនមានស្មារតី ។ បទថា* **អជ្ឈាបន្នោ** *គឺជាប់ជំពាក់ក្នុងអាមិស ។ មិនធ្វើត្រឹមតែការអញ្ជើញដោយធម៌ថា អាវុសោ លោកនឹងបរិភោគធ្វើឲ្យជាពំនូតធំៗ ។ បទថា* **អនាទីនវទស្សាវី** *គឺមិនឃើញត្រឹមតែទោស ។ ការស្គាល់*

ប្រមាណ ឈ្មោះថា **និស្ឋរណ** ក្នុងបទថា **អនិស្ឋរណប្ឋញ្ញោ** នេះ ។ បុគ្គលនោះមិនធ្វើសូម្បីត្រឹមតែការពិចារណា និងការបរិភោគ ។ បទថា **លាភ-សក្ការសិលោកនិក្ការន្តិហេតុ** គឺព្រោះហេតុនៃសេចក្តីប្រាថ្នាក្នុងលាភជាដើម ។ បទថា **សំភក្ខេត្តិ** ប្រែថា ទំពាស៊ី ។ បទថា **អសនីវិចក្ការំ** គឺមានសណ្ឋានមុតដូចកាំរន្ទះ ។ មានអធិប្បាយថា ចុងធ្មេញរបស់បុគ្គលនេះ មុតដូចកាំរន្ទះ មិនមែនមិនបរិភោគពូជអ្វី ក្នុងបណ្តាពូជដែលកើតពីប្រសជាដើម កាលដូច្នោះ ជនទាំងឡាយ រមែងស្គាល់បុគ្គលនោះថា ជាសមណៈ ដោយការពោលបង្ការច់ថាជាសមណៈ ។ បុគ្គលនោះរមែងរុកកូន គឺមើលងាយដោយអាការយ៉ាងនេះ ។ ប្រការនេះ មកដោយអំណាចពួកតិត្ថិយ ។ តែដោយអំណាចភិក្ខុក្នុងសេចក្តីនេះ មានអធិប្បាយប្រកបដូចតទៅនេះថា ភិក្ខុនេះ ខ្ជួនឯងបានទ្រទ្រង់ធុតង្គ ភិក្ខុនេះ រមែងរុកកូនអ្នកដទៃយ៉ាងនេះថា ជនទាំងនេះ នឹងឈ្មោះថាជាសមណៈបានដូចម្តេច តែពោលថា ពួកយើងជាសមណៈ ដូច្នេះ សូម្បីគុណត្រឹមតែធុតង្គ ក៏មិនមាន អ្នកទាំងនេះ កាលស្វែងរកអាហារ មានឧទ្ទេសកភត្តជាដើម ឈ្មោះថា ប្រាថ្នាច្រើនដោយបច្ចុយ ត្រាច់ទៅ ។ បទថា **លូឧជីវី** បានដល់ អ្នកមានការចិញ្ចឹមជីវិតសៅហ្មង ដោយភាពជាអចេលក៏ជាដើម ឬដោយអំណាចធុតង្គ ។ បទថា **ឥស្ឋាមច្ចរិយំ** បានដល់ សេចក្តីច្រណែន មានការច្រណែនដល់សម្បត្តិ មានសក្ការៈជាដើមរបស់អ្នកដទៃជាលក្ខណៈ និងសេចក្តីកំណាញ់ មានការមិនព្រមធ្វើសក្ការៈជាដើមជាលក្ខណៈ ។ បទថា **អាចាជ-កនិសាធី ហោតិ** បានដល់ អង្គុយនៅក្នុងផ្ទូវដើរ គឺក្នុងទីដែលឃើញមនុស្ស

ទាំងឡាយ ។ បុគ្គលដែលមានតបៈ ឈរក្នុងទីជនដែលទាំងឡាយនឹងឃើញ បាន រមែងទូន្មានវត្តិលវត្ត (បដិបទាដូចសត្វប្រចៀវ) បំពេញតបៈ ៥ យ៉ាង ឈរដោយជើងតែម្ខាង សំពះព្រះអាទិត្យ ។ សូម្បីភិក្ខុដែលបួសក្នុងសាសនាហើយ បានសមាទានធុតង្គ ដេកលក់រហូតដល់អស់មួយយប់ហើយ បំពេញតបៈក្នុងផ្លូវដែលមនុស្សមើលឃើញ វេលាល្ងាចធ្វើចីវរកុដិលើទីដេកធំ កាលព្រះអាទិត្យរះឡើងក៏រក្សា ពេលដឹងថា ពួកមនុស្សមករក ក៏គោរះគាំង ដាក់ចីវរលើសីសៈ ដើរចង្រ្កម (បន្ទាប់មក) ចាប់អំបោស បោសលានវិហារ ។ បទថា **អត្តានំ** *បានដល់ នូវគុណរបស់ខ្លួន ។* **អ** *អក្សរៈ ក្នុងបទថា* **អឧស្សុយ្យមានោ** *ត្រឹមតែជានិបាត ។ សេចក្តីថា សម្តែង ។ បទថា* **ឥទម្បិ មេ តបស្មឹ** *បានដល់ កម្មនេះនៅក្នុងតបៈរបស់អញ ។ ម្យ៉ាងទៀត បទថា* **តបស្មឹ** *នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្តបឋមាវិភត្តិ អធិប្បាយថា កម្មនេះជាតបៈរបស់អញ ។ ពិតហើយ អ្នកមានតបៈនោះ បានឮថា អ្នកបួសអចេលក៍ដែលលះបង់អាចារ មាននៅទីឯណោះជាដើម ក៏និយាយថានេះជាតបៈរបស់ខ្ញុំ អចេលក៍នោះជាអន្តេវាសិករបស់ខ្ញុំជាដើម បានឮថា ភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូល នៅក្នុងទីឯណោះជាដើម ក៏ពោលថានេះជាតបៈរបស់ខ្ញុំ ភិក្ខុនោះជាអន្តេវាសិករបស់ខ្ញុំជាដើម ។ បទថា* **កិញ្ចិទេវ** *បានដល់ ទោសឬទិដ្ឋិណាមួយ ។ បទថា* **បដិច្ចន្នំ សេវតិ** *បានដល់ រមែងសេពដោយប្រការដែលជនពួកដទៃមិនដឹង ។ បទថា* **អក្ខមមានំ អាហ ឥមតិ** *បានដល់ រមែងពោលដល់វត្ថុ ដែលខ្លួនមិនពេញចិត្តថា ខ្ញុំពេញចិត្ត ។ បុគ្គលមានតបៈ*

រមែងបញ្ញត្តិទោស ដែលខ្ជិនធ្វើច្រើនហើយថា មានចំនួនតិច តែសម្តែងទោសដែលអ្នកជនៃធ្វើហើយ ត្រឹមតែអាបត្តិទុក្កដថា ដូចជាត្រូវអាបត្តិចាជិក ។ បទថា **អនុញ្ញេយ្យំ** បានដល់ គប្បីជ្រាប គឺគប្បីអនុមោទនា ។ បទថា **កោធនោ ហោតិ ឧបនាហិ** បានដល់ ដែលប្រកបដោយកោធៈ មានការអាក់អន់ចិត្តជាលក្ខណៈ និងដោយឧបនាហៈ មានការមិនលះបង់ពៀរវេរជាលក្ខណៈ ។ បទថា **មក្ខី ហោតិ បឡាសី** បានដល់ ប្រកបដោយមក្ខៈ មានការលុបគុណអ្នកដទៃជាលក្ខណៈ និងដោយបឡាសៈ មានការវាយឫកស្មើជាលក្ខណៈ ។ បទថា **ឥស្សុកី ហោតិ មច្ឆរី** បានដល់ ប្រកបដោយសេចក្តីច្រណែនក្នុងសក្ការៈរបស់អ្នកដទៃជាដើមជាលក្ខណៈ និងដោយសេចក្តីកំណាញ់ ៥ យ៉ាង មានកំណាញ់ក្នុងអាវាស ត្រកូល លាភ វណ្ណៈ និងធម៌ជាលក្ខណៈ ។ បទថា **សឋោ ហោតិ មាយាវី** បានដល់ ប្រកបដោយសាឋេយ្យៈ មានការអួតអាងជាលក្ខណៈ និងមាយា មានការបិទបាំងកម្មដែលធ្វើហើយជាលក្ខណៈ ។ បទថា **ថទ្ធោ ហោតិ អតិមានី** បានដល់ ប្រកបដោយថម្ភៈ មានការរឹងត្អឹងដែលគ្មានមេត្តា និងកំណាជាលក្ខណៈ និងអតិមានៈ មានការមើលងាយអ្នកដទៃជាលក្ខណៈ ។ បទថា **ចាបិច្ឆោ ហោតិ** បានដល់ ប្រកបដោយការប្រាថ្នាលាភមក មានការលើកតម្កើង និងប្រាថ្នាអសប្បុរសជាលក្ខណៈ ។ បទថា **ចាបិការំ** គឺលុះក្នុងអំណាចសេចក្តីប្រាថ្នាដ៏លាមកទាំងនោះឯង ។ បទថា **មិច្ឆាទិដ្ឋិកោ** គឺប្រកបដោយទិដ្ឋិដែលមិនត្រឹមត្រូវ ដែលប្រព្រឹត្តទៅតាមន័យថា ទានដែលបុគ្គលឲ្យហើយ មិនមាន

ផលជាដើម ។ បទ ថា **អន្ធគ្គាហិកាយ** បានដល់ ទិដ្ឋិនោះឯង លោកហៅថា **អន្ធគ្គាហិកា** ព្រោះបុគ្គលនោះប្រកាន់ការជាច់សូន្យ អធិប្បាយថា អ្នកប្រកបដោយអន្ធគ្គាហិកទិដ្ឋិនោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សន្ទិដ្ឋិបរាមាសី** ជាដើមដូចតទៅនេះថា

ការយើញដោយខ្លួនឯង ឈ្មោះថា **សន្ទិដ្ឋិ** បុគ្គលណាស្ទាបអង្អែលប្រកាន់សន្ទិដ្ឋិនោះឯងត្រាច់ទៅ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **សន្ទិដ្ឋិ-បរាមាសី** ។ ការតាំងទុកដោយល្អ តាំងមាំល្អ ហៅថា **អាធាន** ។ បុគ្គលណាប្រកាន់យ៉ាងមុតមាំ បុគ្គលនោះ ឈ្មោះថា **អាធានគ្គាហី** ។ បុគ្គលណាមិនអាចលះបង់ការប្រកាន់មាំនោះ ដូចអរិដ្ឋសាមណេរ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **ទុប្បដិនិស្សគ្គី** សព្ទថា **យទិមេ** កាត់ជា **យទិ ឥមេ** ។

[២៥] បទថា **ឥធ និគ្រោធ តបស្សី** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងព្រះបាលីចំណែកដែលសៅហ្មង គឺទ្រង់សម្តែងលទ្ធិ ដែលពួកអន្យតិរ្ថិយកាន់យកតបៈ ដែលពួកតិរ្ថិយទាំងនោះ រក្សាថាជាវត្ថុសៅហ្មងទាំងអស់ហើយ ឥឡូវនេះ ដើម្បីសម្តែងបាលីចំណែកបរិសុទ្ធ កាលផ្តើមទេសនាទើបត្រាស់ថា **ឥធ និគ្រោធ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ន អត្ថមនោ** ជាដើម គប្បីជ្រាបដោយអំណាចបទដែលផ្ទុយគ្នាអំពីដែលពោលហើយ ។ ក្នុងវារៈបទគ្រប់ៗ បទ គប្បីប្រកបសេចក្តី ដោយអំណាចអ្នកមានតបៈសៅហ្មង និងអ្នកទ្រទ្រង់ធុតង្គ ។ បទថា **ឯវំ សោ តស្មឹ ឋានេ បរិ-សុទ្ធោ ហោតិ** សេចក្តីថា អ្នកមានតបៈនោះ ជាអ្នកបរិសុទ្ធ គឺគ្មានឧបក្កិលេស

ព្រោះមិនមានការពេញចិត្ត ដោយតបៈនោះ ព្រោះហេតុ ពោល គឺសេចក្តី ត្រិះរិះបរិបូណ៌ក៏មិនមែន ។ អ្នកមានតបៈនេះ កាលព្យាយាមក្រៃលែងឡើងទៅ ក៏ជាអ្នកមានកម្មដ្ឋានបរិសុទ្ធ រមែងសម្រេចអរហត្តបាន ។ គប្បីជ្រាបសេចក្តីក្នុងវារៈគ្រប់ៗ បទ ដោយន័យនេះ ។ បទថា **អជ្ជា ទោ ភន្តេ** សេចក្តីថា បរិព្វាជករមែងជឹងតាមថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នេះ វាទៈដែលខ្ពើមបាបដោយសេចក្តីព្យាយាម រមែងបរិសុទ្ធដោយចំណែកតែមួយ ។ ម្យ៉ាងទៀត បរិព្វាជកនោះ កាលមិនជឹងនូវកំពូល និងខ្ចឹមសារដទៃអំពីនេះ ទើបពោលថា **អគ្គប្បត្តា សារប្បត្តា ច** ដូច្នេះ ។ ពេលនោះ ព្រះមានព្រះភាគ កាលទ្រង់បដិសេធវាទៈនោះ ជាខ្ចឹមសារដល់បរិព្វាជកនោះ ទើបត្រាស់ថា **ន ទោ និគ្រោធ** ជាដើម ។ បទថា **បប្បដិកប្បត្តា ហោតិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់រមែងសម្តែងថា ការខ្ពើមបាបដោយតបៈបែបនេះ ដូចជាក្រមរខាងក្រៅ ផុតពីខ្ចឹម ស្រាយ សម្បកនៃដើមឈើមានខ្ចឹម ។

[២៦] បទថា **អគ្គំយេវ ចាបេតុ** សេចក្តីថា រមែងទូលសូមចំពោះព្រះទសពលថា សូមព្រះមានព្រះភាគមេត្តាសម្តែងឲ្យដល់កំពូល គឺមេត្តាសម្តែងឲ្យដល់ខ្ចឹម ដោយអំណាចនៃទេសនា ។ បទថា **ចាតុយាម-សំវរសំវុតោ** គឺបិទហើយ ដោយការសង្រួម ៤ យ៉ាង ។ បទថា **ន ចាណំ អតិចាតេតិ** គឺមិនបៀតបៀនសត្ត ។ បទថា **ន ភាវិតមាសឹសតិ** សេចក្តីថា កាមគុណ ៥ យ៉ាង ឈ្មោះថា ជាវត្ថុដែលនាំគ្នាបដិបត្តិមក ព្រោះកំណត់ចាំមិនប្រាថ្នា គឺមិនសេពកាមគុណទាំងនោះ ។ បទថា **អជុញ្ញស្ស ហោតិ** សេចក្តី

ថា បទដែលពោលក្នុងឥឡូវនេះ ជាដើមថា **សោ អភិហរតិ** ទើបជាលក្ខណៈរបស់បុគ្គលនោះ ។ បទថា **តបស្ឃិតាយ** គឺព្រោះភាពជាអ្នកមានតបៈ ។ បណ្តាបទទាំងនោះ បទថា **សោ អភិហរតិ** សេចក្តីថា បុគ្គលនោះ រមែងរក្សាសីលនោះឲ្យក្រែលែង គឺបំពេញឲ្យខ្ពស់ក្រែលែងឡើងទៅ បានដល់ មិនលះសេចក្តីព្យាយាមថា សីលអញបរិបូណ៌ហើយ តបៈអញផ្តើមឡើងហើយ គ្រប់គ្រាន់ដោយហេតុប្រមាណប៉ុណ្ណេះ ។ បទថា **ឆោ ហិឆា-យាវត្ថតិ** សេចក្តីថា មិនវិលមកដើម្បីភាពជាបុគ្គលថោកទាប គឺដើម្បីភាពជាគ្រហស្ថ បានដល់ ធ្វើសេចក្តីព្យាយាម ដើម្បីសម្រេចគុណវិសេសក្រែលែងជាងសីល ។ បុគ្គលនោះ កាលធ្វើបានយ៉ាងនេះ រមែងសេពសេនាសនៈដែលស្ងាត់ ។ បទថា **អរញ្ញំ** ជាដើម មានពិស្តារហើយក្នុងសាមញ្ញផលសូត្រ ។ បទថា **មេត្តាសហគតេន** ជាដើម លោកបានពណ៌នាហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **តចប្បត្តា** គឺ ដល់សម្បកខាងក្នុង ហួសក្រមរ ។

[២៧] បទថា **ផេគ្គុប្បត្តា** គឺដល់ស្រាយខាងក្នុងសម្បក អធិប្បាយថា ដូចជាស្រាយ ។

[២៨] ព្រះមានព្រះភាគ ទ្រង់ត្រាស់បទថា **ឯត្តាវតា និគ្រោធ តថោឯគុច្ឆា អគ្គប្បត្តា ច ហោតិ សារប្បត្តា ច** នេះ ដោយអំណាចពួកតិរ្ថិយ ។ ពិតហើយ លាភ និងសក្ការៈរបស់ពួកតិរ្ថិយ ដូចគ្នានឹងមែកឈើ និងស្ជឹកឈើ ។ ត្រឹមតែសីល ៥ ដូចក្រមរឈើ ។ ត្រឹមតែសមាបត្តិ ៨ ដូចសម្បកឈើ ។ បុព្វនិវាសញ្ញាណ និងអភិញ្ញាក្នុងទីបំផុតដូចស្រាយ ។ ពួក

តិរិយទាំងនោះ រមែងកាន់យកទិព្វចក្ខុថា ជាអរហត្ត ។ ព្រោះហេតុនោះ សេចក្តីប្រកាន់នោះរបស់ពួកតិរិយទាំងនោះថា ដូចខ្ញីមឈើ ។ ចំណែកលាភ និងសក្ការៈក្នុងព្រះសាសនា ដូចជាមែកឈើ និងស្លឹកឈើ ។ ការដល់ព្រមដោយសីល ដូចជាក្រមរ ឈាន និងសមាបត្តិ ដូចជាសម្បក ។ លោកិយ-អភិញ្ញា ដូចជាស្រាយ ។ មគ្គ និងផលជាខ្ញីម ។ ព្រះមានព្រះភាគ ទ្រង់ប្រៀបធៀបសាសនារបស់ព្រះអង្គ ដោយដើមឈើ មានផលរហូតដល់មែក ដែលបង្អោនចុះ និងផ្សាយចេញ ដោយប្រការដូច្នេះ ។ ព្រោះព្រះអង្គឈ្វាស ក្នុងការសម្តែងទេសនា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ផ្តើមសម្តែងថា **ឥតិ ខោ និគ្រោធ** ជាដើម ដើម្បីសម្តែងសេចក្តីប្លែកគ្នានៃទេសនារបស់ព្រះអង្គថា សាសនារបស់តថាគតក្រៃលែងជាង ប្រណីតជាង ការដល់ព្រមដោយខ្ញីមរបស់អ្នកនោះ អ្នកនឹងដឹងសាសនានោះក្នុងកាលណា ។ បទថា **តេ បរិព្វា-ជកា** បានដល់ បរិព្វាជកចំនួន ៣០០០ នាក់នោះ ជាបរិវារបស់និគ្រោធ-បរិព្វាជកនោះ ។ បទថា **ឯត្ត មយំ ន បស្សាម** បានដល់ ក្នុងបាលីមានបែបផែនអចេលក៍ជាដើមនេះ ។ លោកពោលថា បែបផែនអចេលក៍ ក៏មិនមានដល់ពួកយើង បែបផែនដែលបរិសុទ្ធនឹងមានអំពីណា បែបផែនដែលបរិសុទ្ធរបស់ពួកយើង ក៏មិនមានក្នុងទីនោះ ការសង្រួម ៤ យ៉ាងជាដើម នឹងមានអំពីណា ។ ការសង្រួម ៤ យ៉ាង ក៏មិនមាន ការនៅព្រៃជាដើម នឹងមានមកអំពីណា ។ ការនៅព្រៃមិនមាន ការលះនីវរណៈជាដើម នឹងមានអំពីណា ។ ការលះនីវរណៈមិនមាន ព្រហ្មវិហារជាដើម នឹងមានអំពីណា ។ ព្រហ្មវិហារមិន

មាន បុព្វនិវាសញ្ញាណជាដើម នឹងមានអំពីណា ។ បុព្វនិវាសញ្ញាណមិន មាន ទិព្វចក្ខុរបស់ពួកយើង នឹងមានអំពីណា ។ ពួកយើង ព្រមទាំងអាចារ្យ វិនាសក្នុងទីនេះ ។ បទថា **ឥតោ ភិយ្យោ ឧត្តរិតរំ** សេចក្តីថា បរិព្វាជក ទាំងនោះរមែងពោលថា ពួកយើងមិនទាន់ដឹងច្បាស់ការសម្រេចគុណវិសេស ដទៃ ដែលក្រៃលែងជាងការសម្រេចទិព្វចក្ខុញ្ញាណនេះ សូម្បីដោយអំណាច ការស្តាប់ ។

[២៩] បទថា **អថ ឆិគ្រោធំ បរិព្វាជកំ** សេចក្តីថា សន្ធានគហបតី នោះ មានការគិតយ៉ាងនេះថា បរិព្វាជកទាំងនេះតាំងចិត្តស្តាប់ភាសិតរបស់ ព្រះមានព្រះភាគក្នុងឥឡូវនេះ និគ្រោធបរិព្វាជកនេះ បានពោលពាក្យក្អេង ក្អាងយ៉ាងគ្រោតគ្រាត អំពីក្រោយខ្នងព្រះមានព្រះភាគ ឥឡូវនេះ បរិព្វាជក នេះបានកើតការចង់ស្តាប់ ឥឡូវនេះ ជាកាលដែលនឹងទម្លាក់ទង់ គឺមានះ របស់បរិព្វាជកនេះចុះហើយ លើកព្រះសាសនារបស់ព្រះមានព្រះភាគឡើង លំដាប់នោះ សន្ធានគហបតី ក៏ពោលពាក្យនោះចំពោះនិគ្រោធបរិព្វាជក ហើយ សន្ធានគហបតីនោះក៏មានការគិតដទៃទៀតថា បរិព្វាជកនេះ កាលអញមិន និយាយ ក៏មិនសូមខមាទោសព្រះសាស្តា ការមិនសូមខមាទោសនោះ នឹង ប្រព្រឹត្តទៅដើម្បីមិនមែនប្រយោជន៍ ដើម្បីទុក្ខដល់បរិព្វាជកនេះក្នុងអនាគត តែកាលអញនិយាយហើយ បរិព្វាជកនេះនឹងសូមខមាទោស ការសូមខមា-ទោសនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តី សុខដល់បរិព្វាជកនេះ អស់កាលយូរដូច្នេះ ពេលនោះ ទើបសន្ធានគហបតី

ពោលពាក្យនោះនឹងនិគ្រោធបរិព្វាជក ។ សព្ទថា **បន** ក្នុងបទថា **អបរិ-សាវចរំ បន នំ ករោថ** នេះជានិបាត ។ សេចក្តីថា ពួកលោកចូរធ្វើព្រះអង្គកុំឲ្យហ៊ាន ត្រាច់ទៅក្នុងទីប្រជុំ ។ បាលីថា **អបរិសាវចរេតំ** ដូច្នេះក៏មាន ។ ម្យ៉ាងទៀត អធិប្បាយថា ពួកលោកចូរធ្វើព្រះសមណគោតមនោះ ឲ្យមិនហ៊ានត្រាច់ទៅក្នុងទីប្រជុំ ឬចូរធ្វើឲ្យដូចជាមេគោខ្វាក់ភ្នែកជាដើមណាមួយ ។ ក្នុងបទថា **គោកាណំ** នេះ មានអធិប្បាយថា ពួកលោកចូរធ្វើព្រះសមណ-គោតមឲ្យដូចជាគោខ្វាក់ភ្នែក ត្រាច់វិលទៅ ដូច្នោះ ។ បទថា **តុណ្ហីភូតោ** គឺចូលដល់ភាពជាអ្នកស្ងៀម ។ បទថា **មង្កុភូតោ** គឺអស់អំណាច ។ បទថា **បត្តក្ខន្ធោ** គឺឱនក ។ បទថា **អធោមុខោ** គឺសំយុងមុខ ។

[๓๐] បទថា **ពុទ្ធោ សោ ភគវា សព្ពោធាយ** សេចក្តីថា ព្រះមានព្រះភាគ ត្រាស់ដឹងដោយព្រះអង្គឯង ហើយទ្រង់សម្តែងធម៌ដើម្បីឲ្យសត្វទាំងឡាយដឹងអរិយសច្ច ៤ ផង ។ បទថា **ទន្តោ** គឺទូន្មានចក្ខុខ្លះ ។បេ។ ទូន្មានចិត្តខ្លះ ។ បទថា **ទមថាយ** បានដល់ ដើម្បីទូន្មានសត្វពួកដទៃ មិនមែនដើម្បីវាទៈ ។ បទថា **សន្តោ** បានដល់ ទ្រង់ស្ងប់ហើយ ព្រោះមានរាគៈស្ងប់រម្ងាប់ គឺទ្រង់ស្ងប់ ព្រោះមានទោសៈ និងមោហៈស្ងប់ ព្រោះមានអកុសលធម៌ទាំងពួង និងអភិសង្ខារទាំងពួងស្ងប់ ។ បទថា **សមថាយ** គឺទ្រង់សម្តែងធម៌ដើម្បីឲ្យមហាជនមានរាគៈស្ងប់ជាដើម ។ បទថា **តិណ្ណោ** គឺឆ្លងផុតឱឃៈ ៤ យ៉ាងបាន ។ បទថា **តរណាយ** គឺដើម្បីឲ្យមហាជនឆ្លងផុតឱឃៈ ។ បទថា **បរិនិព្ពុតោ** បានដល់ ជាអ្នករម្ងាប់ហើយ ដោយកិលេសនិព្វាន ។ បទថា **បរិ-**

និញានាយ បានដល់ ទ្រង់សម្តែងធម៌ដើម្បីឲ្យមហាជនរលត់កិលេសគ្រប់យ៉ាង ។

[៣១-៣២] បទថា **អចូយោ** ជាដើម បានពោលហើយ ក្នុងសាមញ្ញផលសូត្រ ។ បទថា **ឧជុជាតិកោ** បានដល់ រឿរចាកការរឿចវេរផ្ទូវកាយជាដើម មានសេចក្តីទៀងត្រង់ជាសភាវ: ។ បទថា **អហមនុសាសាមិ** សេចក្តីថា តថាគតនឹងប្រៀនប្រដៅបុគ្គលដូចអ្នក នឹងសម្តែងធម៌ដល់បុគ្គលដូចអ្នកនោះ ។ បទថា **សត្តាហំ** គឺអស់ ៧ ថ្ងៃ ។ ព្រះមានព្រះភាគ ទ្រង់ប្រាថ្នាដល់បុគ្គលដែលមានបញ្ញាទន់ខ្សោយ ទើបត្រាស់ពាក្យទាំងអស់នេះ ។ បុគ្គលដែលមិនអួតអាង មិនមានមាយា ជាបុគ្គលត្រង់ នឹងអាចសម្រេចអរហត្តបាន ដោយត្រឹមតែមួយរំពេចប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងថា បុគ្គលអួតអាង បុគ្គលរឿចវេរ តថាគតមិនអាចទូន្មានបាន ដោយពាក្យជាដើមថា **អសឃោ** ដូច្នេះ ទើបដូចជាទ្រង់ចាប់បរិព្វាជកត្រង់ជើង គ្រវែងទៅត្រង់ជើងភ្នំសិនេរុ ។ សួរថា ព្រោះហេតុអ្វីឆ្ងើយថា ព្រោះបរិព្វាជកអ្នកនេះ អួតអាងហួសប្រមាណ មានសន្តានចិត្តរឿចវេរ ។ កាលព្រះសាស្តាត្រាស់ហើយយ៉ាងនេះ បរិព្វាជកក៏មិនបង្អោនចិត្តទៅក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឆ មិនផ្ទៀងសោត:ទៅដើម្បីភាពជាអ្នកបង្អោនចិត្ត តាំងនៅក្នុងសេចក្តីបោកបញ្ឆោត សូមខមាទោសព្រះសាស្តាព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យរបស់គេ ទើបត្រាស់ថា តថាគតក៏មិនអាចទូន្មាន មនុស្សអួតអាងបាន ។

បទថា **អន្តេវាសិកាម្យតា** បានដល់ ចង់បានអន្តេវាសិក គឺប្រាថ្នាពួក

យើងជាអន្តេវាសិក ។ បទថា **ឯវមាហ** បានដល់ ព្រះមានព្រះភាគត្រាស់ពាក្យ ថា បុរសអ្នកដឹង មិនអួតអាងចូរមកជាដើម ។ បទថា **យោ ឯវំ វោ អាចរិយោ** សេចក្តីថា អ្នកណាតាមប្រក្រតីជាអាចារ្យរបស់អ្នក ។ បទថា **ឧទ្ទេសា ឆោ ចាវេតុកាមោ** សេចក្តីថា ព្រះសមណគោតមប្រាថ្នា នឹងឲ្យយើងកាន់យក ពាក្យទូន្មានរបស់ព្រះអង្គ ហើយឲ្យពួកយើងយ្លាតចាកឧទ្ទេសរបស់ពួកយើង ។ បទថា **សោយេវ វោ ឧទ្ទេសោ ហោតុ** សេចក្តីថា តាមប្រក្រតី ឧទ្ទេសណា ជាឧទ្ទេសរបស់អ្នក ឧទ្ទេសនោះ ក៏ជាឧទ្ទេសរបស់អ្នកន៉ុះឯង តថាគតមិនមាន ត្រូវការដោយឧទ្ទេសរបស់អ្នក ។ បទថា **អាជីវា** គឺចាកការរស់នៅ ។ បទ ថា **អកុសលសង្ខាតា** គឺដល់ចំណែកថា អកុសល ។ បទថា **អកុសលា ធម្មា** បានដល់ ធម៌ គឺការកើតនៃអកុសលចិត្ត ១២ ដួង ម្យ៉ាងទៀត ដោយ វិសេស ក៏បានដល់តណ្ហាន៉ុះឯង ។ ពិតហើយ តណ្ហានោះ ព្រះមានព្រះភាគ ត្រាស់ហៅថា **ចោឆោព្ភវិកា** ព្រោះធ្វើឲ្យកើតទៀត ។ បទថា **សឧរថា** គឺ ប្រកបដោយ សេចក្តីក្រវល់ក្រវាយដោយកិលេស ។ បទថា **ជាតិជរា-មរណិយា** គឺជាបច្ចុ័យនៃជាតិ ជរា និងមរណៈ ។ បទថា **សង្ពិលេសិកា ធម្មា** គឺកាន់យកការកើតនៃអកុសលចិត្ត ១២ ដួង ។ បទថា **វោទានិយា** បានដល់ ធម៌ គឺសមថៈ និងវិបស្សនា ។ ព្រោះធម៌ គឺសមថៈ និងវិបស្សនា ទាំងនោះ រមែងធ្វើឲ្យសត្វបរិសុទ្ធបាន ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ព្រះ មានព្រះភាគត្រាស់ថា **វោទានិយា** ។ បទថា **បញ្ញាចារិបូរឹ** គឺបរិបូណ៌ដោយ មគ្គប្បញ្ញា ។ បទថា **វេបុល្លត្តញ្ច** បានដល់ ការបរិបូណ៌ ដោយផលប្បញ្ញា ។

ម្យ៉ាងទៀត ទាំង ២ បទនេះ ជាវេវចន:នៃគ្នានិងគ្នា ។ លោកអធិប្បាយ ថា ព្រោះហេតុនោះ ពួកលោកនឹងធ្វើឲ្យច្បាស់មគ្គប្បញ្ញា និងផលប្បញ្ញា ដោយបញ្ញាដ៏ក្រៃលែងរបស់ខ្លួន ក្នុងបច្ចុប្បន្នុ:ឯង ចូលដល់ហើយ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ប្រោរព្ធបរិព្វាជកទាំងឡាយ កាលទ្រង់នឹងសម្តែងកម្ចាំង នៃព្រះឱវាទានុសាសនីរបស់ព្រះអង្គ ទើបញ្ចាំងព្រះធម៌ទេសនាឲ្យចប់ដោយ កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ បទថា **យថាតំ មារេន** *បានដល់ ពួកបរិព្វាជកទាំងនោះ ជាអ្នកអង្គុយស្ងៀម ។បេ។ មិនមានបដិភាណ ដូចត្រូវ មារបណ្តាលចិត្ត ដូច្នោះ ។*

បានឮថា មារគិតថា ព្រះសាស្តាសម្តែងកម្ចាំងព្រះពុទ្ធគំរាមកំហែងហួស ប្រមាណ សម្តែងធម៌ដល់បរិព្វាជកទាំងនេះ គួរនឹងមានការគ្រាស់ជីងធម៌ខ្លះ ក្នុងពេលខ្លះ ណ្ហើយចុះ អញនឹងបណ្តាលចិត្ត ដូច្នេះ ។ ទើបមារបណ្តាលចិត្ត របស់បរិព្វាជកទាំងនោះ ។ ពិតហើយ ចិត្តដែលនៅលះវិបល្លាសមិនទាន់បាន ទើបត្រូវមារធ្វើតាមសេចក្តីប្រាថ្នា ។

សូម្បីបរិព្វាជកទាំងនោះ ត្រូវមារបណ្តាលចិត្តហើយ ក៏អង្គុយស្ងៀម មិនមានបដិភាណ ដូចមានអវយវ:គ្រប់ចំណែកវិងគាំង ដូច្នោះ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ពិចារណាថា បរិព្វាជកទាំងនោះអង្គុយស្ងៀមស្ងាត់ មានហេតុ អ្វីហ្ន៎ ដូច្នេះ ទើបបានជ្រាបថា ពួកបរិព្វាជកត្រូវមារបណ្តាលចិត្ត ។ បើហេតុ នៃការសម្រេចមគ្គ និងផលរបស់បរិព្វាជកទាំងនោះមាន ព្រះមានព្រះភាគ ក៏គប្បីហាមមារ ហើយសម្តែងធម៌ តែព្រះមានព្រះភាគនោះ ទ្រង់ជ្រាបថា

ហេតុនៃមគ្គផលមិនមានដល់បរិព្វាជកទាំងនោះ បរិព្វាជកទាំងអស់នេះ ជាមោយបុរស ព្រោះដូច្នោះ ទើបលោកពោលពាក្យជាដើមថា គ្រានោះឯងព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះថា បរិព្វាជកទាំងអស់នេះ ជាមោយ-បុរស ។

ក្នុងបណ្តាបទទាំងនោះ បទថា **ជុជ្ជា មារេន ចាបិមតា** បានដល់ត្រូវមារមានចិត្តបាបបណ្តាលចិត្តហើយ ។ បទថា **យត្រ ហិ នាម** ប្រែថា ក្នុងបរិព្វាជកពួកណា ។ បទថា **អញ្ញាណត្តំបិ** គឺដើម្បីការដឹង ។ បទថា **កឹ ការិស្សតិ សត្ថាហោ** បានដល់ ៧ ថ្ងៃ ដែលព្រះសមណគោតមកំណត់ហើយ នឹងធ្វើអ្វីដល់ពួកយើងបាន ។ ពួកបរិព្វាជកបានពោលថា ព្រះសមណ-គោតមត្រាស់ថា និគ្រោធបរិព្វាជកនឹងធ្វើឲ្យច្បាស់ដោយបញ្ញាដ៏ក្រៃលែងរបស់ខ្លួន រហូតដល់អស់មួយសប្តាហ៍ៗ នោះ នឹងធ្វើសេចក្តីមិនសុខស្រួលអ្វីដល់ពួកយើង ណ្ហើយចុះ ពួកយើងនឹងប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីសេចក្តីដឹងថា ក្នុងខាងក្នុងមួយសប្តាហ៍ ពួកយើងនឹងអាចធ្វើឲ្យច្បាស់ធម៌នោះបានឬទេ ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ មានអធិប្បាយថា បរិព្វាជកទាំងនោះ មិនបានកើតគំនិតដើម្បីនឹងដឹងត្រឹមតែម្តងថា ក្នុងមួយថ្ងៃ ពួកយើងនឹងដឹងធម៌របស់ព្រះអង្គបាន មួយសប្តាហ៍នឹងធ្វើអ្វីដល់បរិព្វាជក អ្នកខ្ជិលច្រអូសទាំងនោះបានបរិព្វាជកទាំងនោះ នឹងបំពេញរហូតដល់អស់សប្តាហ៍បានដូចម្តេច ។

បទថា **សីហនាទំ** គឺបន្ទឺហើយ បន្ទឺបែបមិនខ្លាចអ្នកណា ជាការទម្លាយ

ภาค:អ្នកជំទៃ និងជាការប្រកាសភាគ:របស់ខ្លួន ។ បទថា **បច្ចุฏฺฐาสิ** *គឺតាំងនៅហើយ ។ បទថា* **ตาวเทว** *ប្រែថា ក្នុងខណៈនុ៎ះឯង ។ បទថា* **ราชคหำ ปาวิสิ** *បានដល់ ទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះនុ៎ះឯង ។ ឯបរិព្វាជកទាំងនោះ មិនបានកើតគុណវិសេស ព្រោះស្តាប់ព្រះសូត្រនេះក៏ពិតមែន តែនឹងបានជាបច្ច័យ ដើម្បីជាវាសនាដល់បរិព្វាជកទាំងនោះតទៅ ។ ពាក្យដ៏សេស គ្រប់ៗបទ ជាក់ច្បាស់ហើយ នោះឯង ។ អដ្ឋកថាឧទុម្ពរិកសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ។*

ឧទុម្ពរិកសូត្រ ចប់

សូត្រធី ២ ចប់

ក្បាលទី ១១

សុត្តន្តបិដក ចាលីប្រែ –១៧

សន្ទីកចង្អុលប្រាប់មាតិកា

មាតិកា	*លេខទំព័រ*
មហាសុទស្សនសូត្រទី ៦	២
អដ្ឋកថា មហាសុទស្សនសូត្រ *(កុសាវតីរាជធានីកថា)*	៤៤
អធិប្បាយចក្ករតនៈជាដើម	៤៦
ឈានសម្បត្តិកថា	៧០
ជនវសភសូត្រទី ៥	៨០
អដ្ឋកថា ជនវសភសូត្រ	១១៣
អត្តរបស់ បរិក្ខារ សពូ	១២៧
មហាគោវិន្ទសូត្រទី ៦	១៣០
អដ្ឋកថា មហាគោវិន្ទសូត្រ	១៧៩
កិត្តិសពូរបស់មហាគោវិន្ទព្រាហ្មណ៍	២០៧
មហាសមយសូត្រទី ៧	២២៤
អដ្ឋកថា មហាសមយសូត្រ	២៤០
ជម្ងោះសក្យ និងកោលិយវង្ស	២៤០
សក្កប្បញ្ហាសូត្រទី ៨	២៨៥
អដ្ឋកថា សក្កប្បញ្ហាសូត្រ	៣២៥
រឿងមយមាណព	៣៤៩
អធិប្បាយបញ្ហាព្យាករណ៍	៣៦៣
រឿងព្រះសិវត្ថេរ	៣៨១
រឿងព្រះថេរៈ ៣ អង្គ	៤០១

មហាសតិប្បដ្ឋានសូត្រទី ៩ .... ៤០៩

អដ្ឋកថាមហាសតិប្បដ្ឋានសូត្រ ៤៥៣

រឿងកូនសត្វសេក ៤៥៤

ឧទ្ទេសវារកថា ៤៥៦

រឿងទុក្ខរបស់ព្រះតិស្សត្ថេរ ៤៦៤

រឿងទុក្ខរបស់ភិក្ខុ ៣០ រូប ៤៦៥

រឿងទុក្ខរបស់ព្រះបីតិមល្លត្ថេរ ៤៦៦

រឿង ទោមនស្សរបស់សក្កទេវរាជ និង សុព្រហ្មទេវបុត្រ ៤៦៨

កាយានុបស្សនាសតិប្បដ្ឋាន..... .... ៤៨៤

អានាបានបព្វៈ ៤៨៤

ចែកអាណាបានស្សតិដោយអរិយសច្ចៈ ៥០២

ឥរិយាបថបព្វៈ ៥០២

ចែកឥរិយាបទដោយដោយអរិយសច្ចៈ ៥០៧

សម្បជញ្ញបព្វៈ ៥០៧

ចែកសម្បជញ្ញៈដោយដោយអរិយសច្ចៈ ៥០៨

បដិកូលមនសិការបព្វៈ ៥០៨

ធាតុមនសិការបព្វៈ ៥១០

នវសីវថិកាបព្វៈ ៥១២

ចែកនវសីវថិកាបព្វៈជាសច្ចៈ ៥១៦

វេទនានុបស្សនាសតិប្បដ្ឋាន..... .... ៥១៧

រឿងព្រះថេរៈសោយទុក្ខវេទនា ៥១៨

ចិត្តានុបស្សនាសតិប្បដ្ឋាន ៥២២

ធម្មានុបស្សនាសតិប្បដ្ឋាន ៥២៤

ទីវរណបព្វៈ ๕๒๕

កាមច្ឆន្ទៈលះដោយធម៌ ๖ យ៉ាង ๕๒๖

ព្យាបាទលះដោយធម៌ ๖ យ៉ាង ๕๒๙

ថីនមិទ្ធៈលះដោយធម៌ ๖ យ៉ាង ๕๓๑

ឧទ្ធច្ចកុក្កុច្ចៈលះដោយធម៌ ๖ យ៉ាង..... .... ๕๓๓

វិចិកិច្ឆាលះដោយធម៌ ๖ យ៉ាង ๕๓๕

ខន្ធបព្វៈ ๕๓๗

អាយតនបព្វៈ ๕๓๘

ពោជ្ឈង្គៈបព្វៈ ๕๔๒

សតិសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๔ យ៉ាង ๕๔๓

ធម្មវិចយសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๗ យ៉ាង ๕๔๔

វិរិយសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๑๑ យ៉ាង ๕๔๘

រឿងព្រះមហាមិត្តត្ថេរ ๕๕๑

បីតិសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๑๑ យ៉ាង ๕๕๕

បស្សទ្ធិសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๗ យ៉ាង ๕๕๗

សមាធិសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๑๑ យ៉ាង ๕๕๘

ឧបេក្ខាសម្ពោជ្ឈង្គៈកើតឡើងដោយធម៌ ๕ យ៉ាង ๕๖๑

សច្ចៈបព្វៈ ๕๖๔

អធិប្បាយអានិសង្ស ๕๘๓

ចាយាសិរាជញ្ញសូត្រទី ๑๐ .... ๕๘๕

អដ្ឋកថា ចាយាសិរាជញ្ញសូត្រ ๖๔๔

ប្រវត្តិព្រះកុមារកស្សបៈ ๖๔๔

រឿងព្រះគវម្បតិ ๖๕๗

សុត្តន្តបិដក ចាលីប្រែ –១៨

ចាដិកសូត្រទី១ .... ៦៥៩

អដ្ឋកថា ចាដិកសូត្រ ៧១២

ឧទុម្ពរិកសូត្រទី២ .... ៧៤២

អដ្ឋកថា ឧទុម្ពរិកសូត្រ ៧៧៧